# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ១

បាលីប្រែ ១

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# វិនយបិដក

## និង

## សមន្តប្បាសាទិកា អដ្ឋកថា

### សេចក្ដីប្រែជាភាសាខ្មែរ

## មហាវិភង្គ បឋមភាគ

## វេរញ្ជកណ្ឌ និង បារាជិកកណ្ឌ

## ១

## បាលីប្រែ ១

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# គន្ថារម្ភកថា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ជាអ្នកឆ្ងាយចាក*
*កិលេស ត្រាស់ដឹងដោយព្រះអង្គឯង*

*យើងខ្ញុំ សូមអភិវាទព្រះតថាគតដ៏ប្រសើរ ទ្រង់មានព្រះមហាករុណា និងបញ្ញាមិនមានទីបំផុត មួយអន្លើដោយព្រះធម៌ ព្រមទាំងព្រះអរិយសង្ឃទាំងឡាយដោយសិរសា គឺ ត្បូង ។*

*ព្រះដ៏មានព្រះភាគ ទ្រង់អង់អាច មិនមានបុគ្គលប្រៀប ទ្រង់ជាទេវតាក្រៃលែងជាងទេវតាទាំងឡាយ ដែលពួកទេវតាចោមរោម បូជាហើយ ទ្រង់ត្រាស់ដឹងក្នុងរាត្រីណា បរិនិព្វានក្នុងរាត្រីណា ទ្រង់បំពេញនូវពុទ្ធកិច្ច ប្រកាសនូវព្រះសទ្ធម្មដ៏ប្រសើរ ចំឡងសត្វលោកឲ្យឆ្លងចាកភពបីទៅកាន់អមតៈមហានិព្វាន ដោយវីរិយៈដ៏ធំធេងណា...។*

*យើងខ្ញុំ ជាអ្នកប្រាថ្នានូវប្រយោជន៍ និងសេចក្តីចម្រើន បានព្រមព្រៀងគ្នាចងក្រងនូវ **ព្រះពុទ្ធដីកា** និង**ព្រះអដ្ឋកថា** ជាគម្ពីររួមគ្នា ដើម្បីងាយស្រួលដល់ការសិក្សា សម្រាប់កុលបុត្តក្នុងព្រះសាសនា ។*

*ដោយអានុភាពនៃព្រះរតនត្រ័យ ដែលយើងខ្ញុំបាននមស្ការហើយយ៉ាងនេះ សូមរួចផុតចាកអន្តរាយក្នុងទីទាំងពួង ។*

*ក្រុមអ្នករៀបរៀង*

# ក្បាលទី ១

## សូមនមស្ការថ្វាយបង្គំ ចំពោះព្រះដ៏មានព្រះភាគ
## ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ

## វេរញ្ជកណ្ឌវណ្ណនា

[ ១ ] សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្ដៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍ បានឮច្បាស់ ( នូវដំណឹងនោះហើយ ទើបប្រកាសសេចក្ដីថា ) ម្នាលគ្នាយើង បានឮថា ព្រះសមណគោតម ជាសក្យបុត្រចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវមកគង់នៅក្បែរដើមស្ដៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ កិត្តិសព្ទដ៏ពីរោះ របស់ព្រះគោតមដ៏ចម្រើននោះ ឮខ្ចរខ្ចាយ សុសសាយយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យ-ធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ គឺសេចក្ដីចេះដឹងនិងក្រឹត្យ ដែលបុគ្គលគប្បីប្រព្រឹត្ត ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ ទៅកាន់ព្រះនិព្វាន ថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ថា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ថា

បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ថា ពុទ្ធោ ព្រោះព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ថា ភគវា ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ចំពោះព្រះអង្គនូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចំពោះព្រះអង្គ ទ្រង់ញុំាងនូវពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យត្រាស់ដឹង ហើយទ្រង់ប្រកាស ទ្រង់សម្តែងធម៌ពីរោះបទដើម បទកណ្តាល និងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក ។

[ ២ ] គ្រានោះ វេរញ្ជព្រាហ្មណ៍ក៏ចូលសំដៅទៅត្រង់ទីដែលព្រះដ៏មានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលទៅរកព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ កាលដែលវេរញ្ជព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ក៏ផ្តើមពាក្យនេះក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំបានឮពាក្យថា ព្រះសមណគោតម មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំង-ឡាយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំ

មកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះឲ្យអង្គុយលើអាសនៈ ( ព្រះអង្គក៏មិនធ្វើ ) បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំបានឮមកនោះ ជាប្រាកដថា ព្រះគោតមដ៏ចម្រើន មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ថា សូម្បីត្រឹមតែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះឲ្យអង្គុយលើអាសនៈ ( ព្រះអង្គក៏មិនធ្វើ ) បពិត្រព្រះគោតមដ៏ចម្រើន កិច្ចមានមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ក្នុងលោក ( នេះ ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាមួយ ល្មមឲ្យតថាគតសំពះ ឬ ក្រោកទទួល ឬ អញ្ជើញហៅរកឲ្យអង្គុយលើអាសនៈនោះឡើយ ម្នាលព្រាហ្មណ៍ ព្រោះថា បើតថាគតសំពះអ្នកណា ឬក្រោកទទួលអ្នកណា ឬអញ្ជើញហៅរកអ្នកណាឲ្យអង្គុយលើអាសនៈ ក្បាលរបស់អ្នកនោះនឹងដាច់ធ្លាក់ចេញចាក ក ។ វេរញ្ជព្រាហ្មណ៍ ក៏ពោលពាក្យប្រទ្បោះបោះ ទៅរកព្រះសាស្តាថា ព្រះគោតមដ៏ចម្រើន ជាមនុស្សសោះកក្រោះ ឥតរសជាតិទេតើ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតមជាមនុស្សសោះកក្រោះ ឥតរសជាតិ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះរសជាតិ គឺ

រូប សំឡេង ក្លិន ឱជារស សម្ផស្ស ទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីងដូចជាដើមត្នោត ដែលគេក្របែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតមជាមនុស្សសោះកក្រោះ ឥតរសជាតិនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន គ្មានគ្រឿងបរិភោគទេតើ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សគ្មានគ្រឿងបរិភោគ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ពីព្រោះគ្រឿងបរិភោគ គឺរូប សំឡេង ក្លិន រស សម្ផស្សទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេក្របែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជាធម៌មិនមានកំណើតតទៅខាងមុខទៀតទេ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សគ្មានគ្រឿងបរិភោគនោះ គឺជាសំដីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកពោលពាក្យឃាត់កិច្ចការ ថាមិនត្រូវធ្វើទេតើ ។ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន

មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រកាន់និយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតឡើយ តថាគតតែងនិយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើនូវធម៌ទាំងឡាយជាអកុសលដ៏អាក្រក់ច្រើនប្រការនោះឡើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យឃាត់កិច្ចការថា មិនត្រូវធ្វើនោះ គឺជាសំដីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិលទេតើ ។ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យកាត់ផ្តាច់ផ្តិល ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រកាន់និយាយថា ឲ្យសត្វកាត់ផ្តាច់ផ្តិលនូវរាគៈ ទោសៈ មោហៈ តថាគតតែងនិយាយថា ឲ្យសត្វកាត់ផ្តាច់នូវធម៌ទាំងឡាយជាអកុសលដ៏អាក្រក់ ច្រើនយ៉ាងនោះចេញ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកពោលពាក្យផ្តាច់ផ្តិលនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកខ្ជិលរអើមណាស់ទេតើ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម ដែលគេថានោះត្រូវហើយ ម្នាល

ព្រាហ្មណ៍ ព្រោះតថាគតខ្ពើមសេចក្តីប្រព្រឹត្តអាក្រក់ ដោយកាយ វាចា ចិត្ត តថាគតខ្ពើមសេចក្តីប្រកបចិត្តផ្តេកផ្តិតទៅរកអកុសលធម៌ទាំងឡាយ ដ៏អាក្រក់ច្រើនប្រការ ( នោះណាស់ ) ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើមនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកបំផ្លាញទេតើ ។ ព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតមជាអ្នកបំផ្លាញ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះតថាគតសម្តែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលបំផ្លាញបង់នូវរាគៈ ទោសៈ មោហៈ តថាគតសម្តែងធម៌ចំពោះផ្លូវប្រតិបត្តិដែលរំលាងបង់នូវអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតមជាអ្នកបំផ្លាញនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកដុតកម្តៅទេតើ ។ ព្រះសព្វញ្ញូជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតមជាអ្នកដុតកម្តៅ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ តថាគតប្រកាន់និយាយថា ការប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ជាអកុសលធម៌ដ៏អាក្រក់ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ ( នោះ ) បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្តាច់

ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីងដូចដើមត្នោត ដែលគេក្របែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកដុតកម្តៅ ម្នាលព្រាហ្មណ៍ អកុសលធម៌ទាំងឡាយដ៏អាក្រក់ជាទីតាំងនៃសេចក្តីក្តៅក្រហាយ ( នោះ ) តថាគតឯងបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើត ឲ្យអស់រលីង ដូចជាដើមត្នោតដែលគេក្របែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកដុតកម្តៅនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាមនុស្សឥតកំណើតទេតើ ។ ព្រះដ៏មានជោគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែនហើយ មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សឥតកំណើត ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ព្រោះកិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅមុខទៀត បើអ្នកណា បានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោតដែលគេក្របែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នក

នោះថា អ្នកឥតកំណើត ម្នាលព្រាហ្មណ៍ កិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅមុខទៀត ( នោះ ) តថាគតឯងបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេក្របែលគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សឥតកំណើតនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុដែលអ្នកឯងនិយាយសំដៅនោះទេ ។

[ ៣ ] ម្នាលព្រាហ្មណ៍ ប្រៀបដូចជាពងមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ពងមាន់ទាំងនោះ គឺមេមាន់ក្រាបដោយប្រពៃហើយ ធ្វើឲ្យកក់ក្តៅដោយប្រពៃហើយ ឲ្យចាប់ក្លិនវាជាមេដោយប្រពៃហើយ ( លុះដល់វេលាញាស់ ) ក៏បណ្តាកូនមាន់ទាំងនោះ កូនមាន់ណា ទម្លាយសំបកពង ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលមុនគេបំផុត បើដូច្នេះ តើអ្នកផងគួរហៅកូនមាន់នោះថា កូនច្បង ឬកូនពៅហ្ន៎ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ( កូនមាន់នោះ ) គេគួរហៅថា កូនច្បង ព្រោះវាជាបងគេបំផុត ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ កាលបើពពួកសត្វ ដូចជាពងមាន់ កើតហើយ មានអវិជ្ជា គឺសេចក្តីល្ងង់ ដូចជាសំបកពងកំពុងរួបរឹតក្នុងលោក មានតែតថាគតម្នាក់ឯង ដែលទម្លាយសំបកពង គឺសេចក្តីល្ងង់ ហើយត្រាស់ដឹងខ្លួនឯង ដោយប្រពៃ នូវ

សម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតឯទៀត ប្រសើរជាងឡើយ ម្នាលព្រាហ្មណ៍ តថាគតឯងជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក ម្នាលព្រាហ្មណ៍ ព្យាយាមតថាគតបានតាំងផ្តើមហើយ មិនបន្ធូរបន្ថយទេ ទាំងស្មារតី តថាគតក៏ប្រុងមិនឲ្យមានភ្លាត់ កាយសោតក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ ចិត្តក៏នឹងល្អជាចិត្តមានអារម្មណ៍តែមួយ ម្នាលព្រាហ្មណ៍ តថាគតឯងលុះដល់ប្រាកដ ជាស្ងាត់ចាកកាមទាំងឡាយ ប្រាកដជាស្ងាត់ចាកធម៌ទាំងឡាយជាអកុសលហើយ ក៏ចូលដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិ និងសុខ ដែលកើតពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍នៅហើយ ។ លុះតថាគតចូលទៅជិតរម្ងាប់វិតក្កៈ វិចារៈ រួចហើយ ក៏បានចូលដល់ទុតិយជ្ឈាន ជាទីផូរផង់ប្រព្រឹត្តទៅខាងក្នុង មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈ វិចារៈ មានតែបីតិ និងសុខ កើតពីសមាធិនៅហើយ ។ លុះលះបង់បីតិចេញហើយ តថាគតជាបុគ្គលព្រងើយ មានសតិមានសេចក្តីដឹងច្បាស់នៅហើយ តថាគតសោយសុខដោយកាយផង អរិយបុគ្គលទាំងឡាយ តែងសម្តែងនូវបុគ្គលដែលបានតតិយជ្ឈានណាថា ជាបុគ្គលមានចិត្តព្រងើយ ជាអ្នកមានស្មារតីមានប្រក្រតីនៅជាសុខ តថាគតក៏បានដល់នូវតតិយជ្ឈាននោះហើយនៅ ។ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរំលត់នូវសោមនស្សនិងទោមនស្ស អំពីមុនផង តថាគតបានចូលដល់ចតុត្ថជ្ឈានឥតទុក្ខឥតសុខ មានសតិដ៏ស្អាត ព្រោះឧបេក្ខាហើយនៅ ។ កាលដែលចិត្តខាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ សម

គួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ តថាគតឯង ក៏បាន បង្អោនចិត្តចូលទៅ ក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ( ញាណជាគ្រឿងរលឹក ជាតិមុនបាន ) ។ តថាគតឯង ក៏រលឹកជាតិដែលបានអាស្រ័យនៅមកអំពីមុន ជាអនេកជាតិ ។ រលឹកជាតិបានដូចម្តេច ។ រលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រលឹកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា តថាគតបានកើតក្នុងភព ឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មាន អាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគត ច្យុតចាកអត្តភាពនោះ ហើយបានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុង ភពនោះ តថាគតក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាង នេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុ ប៉ុណ្ណេះ តថាគតឯងច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ តថាគតរលឹកតាមនូវជាតិ ដែលអាស្រ័យនៅពីមុន បានច្រើនជាតិ ព្រមទាំង អាការៈព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍ បឋមវិជ្ជានេះហើយ ដែល តថាគតបានត្រាស់ដឹងក្នុងយាមជាដំបូងនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លាត់បាត់ទៅ សេចក្តីចេះដឹងប្រាកដក៏កើតឡើង ងងឹតខ្ជាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់ តថាគតដែលកំពុងអន្ទុយប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញ កិលេស មានចិត្តមូលស្ទុងឥតមានទឹកនាដល់កាយ និងជីវិតឡើយ ដូចជា

បណ្ឌិតទាំងឡាយ ដែលបាននូវបឋមវិជ្ជានុ៎ះដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាបឋមវិជ្ជាដែលតថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ញាស់ចេញចាកសំបកពង ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេសប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ តថាគតទើបបង្អោនចិត្តចូលទៅក្នុងញាណ ដែលនាំឲ្យបានត្រាស់ដឹងនូវចុតិ និងបដិសន្ធិនៃសត្វទាំងឡាយ គឺចុតូបបាតញ្ញាណ ។ តថាគតពិចារណាឃើញនូវសត្វទាំងឡាយ ដែលច្យុត និងចាប់បដិសន្ធិ ទាបថោក និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់សុគតិ និងទុគ្គតិដោយចក្ខុ ដូចជាទិព្វដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ឃើញច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ថា អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្ម ជាមិច្ឆាទិដ្ឋិ និយាយតិះដៀលអរិយបុគ្គលទាំងឡាយ សត្វទាំងនោះ លុះដល់រំលាងខន្ធបន្ទាប់អំពីមរណៈ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក មួយសោត អើហ្ន៎ សត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវកម្ម ជាសម្មាទិដ្ឋិ មិនតិះដៀលអរិយបុគ្គលទាំងឡាយ សត្វទាំងអម្បាលនោះ លុះដល់រំលាងខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងលោក គឺសុគតិ និងឋានសួគ៌ ។ តថាគតពិចារណា មើលនូវសត្វទាំងឡាយ ដែលច្យុត និងចាប់បដិសន្ធិ ថោកទាប និងឧត្តម មានសណ្ឋានល្អ និងអាក្រក់ ទៅកាន់សុគតិ

និងទុគ្គតិ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ឃើញច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ២ នេះឯងហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាកណ្ដាលនៃរាត្រី លុះដល់សេចក្ដីល្ងង់ខ្វាត់បាត់ទៅ សេចក្ដីចេះដឹងប្រាកដ ក៏កើតឡើង ងងឹតខ្វាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ទុងឥតមាននឹកនាដល់កាយ និងជីវិតឡើយ ដូចជាបណ្ឌិតទាំងឡាយ ដែលបាននូវវិជ្ជាទី ២ នុ៎ះដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាវិជ្ជាទី ២ ដែលតថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ដែលញាស់ចេញចាកសម្បកពង ។ កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្ដីសៅហ្មង ជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ យ៉ាងនេះហើយ តថាគតទើបបង្អោនចិត្តចំពោះទៅក្នុងញាណ ជាហេតុឲ្យបានអស់ទៅនៃអាសវៈទាំងឡាយ គឺអាសវក្ខយញ្ញាណ តថាគតក៏ដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសេចក្ដីរំលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្ដីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណោះ ជាអាសវៈ ដឹងប្រាកដតាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្ដីរំលត់នៃអាសវៈ កាលដែលតថាគតដឹងយ៉ាងនេះ តថាគតឃើញយ៉ាងនេះ ចិត្តតថាគតក៏ផុតចាកគ្រឿងត្រាំ គឺកាមផង គឺភពផង គឺអវិជ្ជា

ផង កាលបើចិត្តតថាគតបានរួចផុតស្រឡះហើយ ប្រាជ្ញាក៏កើតប្រាកដដល់តថាគតថា ចិត្តរួចផុតស្រឡះចាកអាសវៈហើយ ទាំងតថាគតក៏ដឹងច្បាស់ថា កំណើតរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អញក៏បានធ្វើស្រេចហើយ កិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលព្រាហ្មណ៍វិជ្ជាទី ៣ នេះហើយ ដែលតថាគតបានត្រាស់ដឹងក្នុងយាមជាបំផុតនៃរាត្រី លុះដល់សេចក្តីល្ងង់ខ្លៅខ្ចាត់បាត់ទៅ សេចក្តីចេះដឹងប្រាកដក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគតដែលកំពុងអង្គុយប្រុងស្មារតី មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តមូលស្ងួនឥតមានទឹកនាដល់កាយ និងជីវិតឡើយ ដូចជាបណ្ឌិតទាំងឡាយដែលបាននូវវិជ្ជាទី ៣ នុ៎ះដូច្នោះដែរ ។ ម្នាលព្រាហ្មណ៍ ការត្រាស់ដឹងរបស់តថាគត ជាគម្រប់ ៣ នេះ ដូចគ្នានឹងការញាស់ចេញរបស់កូនមាន់អំពីសម្បកពង ។

[ ៤ ] កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេរញ្ជព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគវិញថា ព្រះគោតមដ៏ចម្រើន ព្រះអង្គជាចម្បងជាងមនុស្ស ប្រសើរបំផុតជាងមនុស្ស បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់

ដែលគេលាក់បិទបាំង ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានភ្នែករមែងមើលឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ចាប់ផ្តើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើនជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណគមន៍ស្មើដោយជីវិត មិនតែប៉ុណ្ណោះទេ សូមព្រះគោតមដ៏ចម្រើន ទទួលនិមន្តន៍គង់ចាំវស្សាជិតស្រុកវេរញ្ជា មួយអន្លើដោយភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគក៏ព្រមទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ វេរញ្ជព្រាហ្មណ៍ដឹងច្បាស់ថាព្រះអង្គទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ហើយធ្វើប្រទក្សិណដើរចេញទៅ ។

[ ៥ ] សម័យនោះឯង ស្រុកវេរញ្ជាកើតអំណត់អត់បាយ មនុស្សទាំងឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ ក៏ស្លាប់ មានឆ្អឹង ស ( ដេរដាសលើផែនដី ) មនុស្សដែលមានទ្រព្យសម្បត្តិល្មមទិញជូរស្រូវអង្ករគេបាន ក៏មិនងាយនឹងទិញជូរ បើលុះតែមានស្លាកកាន់ជាសម្គាល់ទើបទិញជូរបាន ជនទាំងអស់ក្នុងស្រុកនោះព្យាយាម ស្វែងរកអាហារបានដោយកម្រក្រៃពេក ។ សម័យនោះ មានពួកឈ្មួញសេះនៅក្នុងឧត្តរាបថប្រទេស នាំសេះចំនួន ៥០០ ចូលមកនៅសម្រាកក្នុងស្រុកវេរញ្ជា ក្នុងរដូវខែវស្សា ។ ពួកឈ្មួញដែលនៅក្នុងរោងសេះទាំងនោះ ក៏បានបញ្ញត្តគ្នាឲ្យប្រគេនបាយក្រៀមចំនួន ១ នាឡិៗ ម្នាក់ ដល់ភិក្ខុទាំងឡាយ ។ លុះដល់ពេល

បុព្វណ្ហសម័យ ភិក្ខុទាំងឡាយស្លៀកស្បង់ ទ្រង់ចីវរ និងបាត្រ នាំគ្នាចូលទៅបិណ្ឌបាតក្នុងស្រុកវេរញ្ជា ក៏មិនប្រទះបានអាហារបិណ្ឌបាតសោះឡើយ ទើបទៅបិណ្ឌបាតខាងពួកឈ្មួញ ឯរោងសេះវិញ ក៏បានបាយក្រៀម ១ នាឡិៗម្នាក់ ហើយវិលមកអារាមយកបាយក្រៀមនោះបុកក្នុងត្បាល់ រួចនាំគ្នាឆាន់ ។ ចំណែកខាងព្រះអានន្ទដ៏មានអាយុ យកបាយក្រៀម ១ នាឡិ កិនក្នុងត្បាល់ថ្ម ហើយយកទៅថ្វាយព្រះដ៏មានព្រះភាគ ។ ព្រះអង្គក៏ទ្រង់ទទួលសោយបាយក្រៀមនោះ ។ វេលានោះ ព្រះសម្ពុទ្ធទ្រង់បានឮសូរត្បាល់ និងអង្រែនោះដែរ ។ ព្រះតថាគតទាំងឡាយ បានជ្រាបនូវហេតុហើយសួរក៏មាន បានជ្រាបហើយមិនសួរក៏មានជ្រាបច្បាស់នូវកាលគួរហើយសួរក៏មានជ្រាបច្បាស់នូវកាលគួរហើយមិនសួរក៏មាន ឯព្រះតថាគតទាំងឡាយ ព្រះអង្គតែងសួរនូវការណ៍ណាដែលប្រកបដោយប្រយោជន៍ កម្មដែលមិនប្រកបដោយប្រយោជន៍ ព្រះអង្គមិនសួរឡើយ ព្រោះព្រះតថាគតទាំងឡាយ ទ្រង់បានផ្តាច់បង់នូវកម្មមិនប្រកបដោយប្រយោជន៍ទាំងឡាយ ដោយអរិយមគ្គជ្រះស្រឡះហើយ ។ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគទាំងឡាយ ទ្រង់តែងសួរនូវភិក្ខុទាំងឡាយ ដោយហេតុពីរប្រការ គឺទ្រង់សួរដើម្បីនឹងសម្តែងនូវធម៌ ១ ដើម្បីនឹងបញ្ញត្តនូវសិក្ខាបទដល់សាវកទាំងឡាយ១ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ហៅព្រះអានន្ទដ៏មានអាយុមកហើយទ្រង់សួរថា ម្នាលអានន្ទសូរសំឡេងនោះជាសូរត្បាល់អង្រែ ឬ អ្វី ។ ទើបព្រះអានន្ទដ៏មានអាយុ ក្រាបទូលរឿងនុ៎ះឲ្យព្រះដ៏មានព្រះភាគ ជ្រាបគ្រប់ប្រការ ។ ព្រះអង្គត្រាស់សរសើរថា ត្រូវហើយ អានន្ទ ប្រពៃហើយអានន្ទ

អ្នកឯងរាល់គ្នាជាសប្បុរសឈ្មោះពិសេសហើយ បណ្ដាជនខាងក្រោយគេនឹងនឹកចង់ឲ្យ[១] នូវចង្ហាន់ដែលគេចម្អិនដោយអង្ករស្រូវខ្សាយ ព្រមទាំងម្ហូបលាយដោយសាច់ដ៏ឆ្ងាញ់ពិសា ( ដល់អ្នករាល់គ្នា ) ។

[ ៦ ] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់បានក្រាបថ្វាយបង្គំព្រះអង្គដោយគោរព រួចហើយក៏គង់ក្នុងទីដ៏សមគួរ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលស្នើសេចក្ដីនេះចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ឥឡូវនេះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ មនុស្សទាំង-ឡាយនឹងចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលក្រលំបាកស្លាប់ក៏ស្លាប់មានឆ្អឹង ស ( ដេរដាសលើផែនដី ) មនុស្សដែលមានទ្រព្យសម្បត្តិល្មមទិញដូរស្រូវអង្ករគេបាន ក៏មិនងាយនឹងទិញដូរ បើលុះតែមានស្លាកកាន់ជាសម្គាល់នោះ ទើបទិញដូរបាន ជនទាំងអស់ ក្នុងស្រុកនោះ នឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក សូមទ្រង់ព្រះមេត្តាប្រោស ផ្ទៃខាងក្រោមនៃផែនដីនេះ មានឱជារសផ្អែមដូចទឹកឃ្មុំ ដែលស្អាតបរិសុទ្ធឥតលាយប្រឡំដោយមេឃ្មុំ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គចង់ប្រែត្រឡប់ផែនដីនេះឲ្យផ្ងារឡើង ដើម្បីនឹងឲ្យភិក្ខុទាំងឡាយឆាន់នូវឱជារស ដែលកើតឡើងអំពីស្រទាប់នៃផែនដីនោះ ។ ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ចុះអ្នកនឹង

---

១- សេចក្ដីក្នុងអដ្ឋកថាថា ភិក្ខុជំនាន់ក្រោយ នឹងមើលងាយនូវស្រូវសាលី និងបាយដែលលាយដោយសាច់ ... ។

យកមនុស្សសត្វទាំងឡាយដែលនៅអាស្រ័យលើផែនដីនេះ ឲ្យទៅនៅឯណា ។ ព្រះមហាមោគ្គល្លានទូលតបថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងនិម្មិតបាតដៃម្ខាង ឲ្យបានដូចជាផែនដីធំ នឹងឲ្យសត្វទាំងឡាយដែលនៅអាស្រ័យលើផែនដី មកនៅលើបាតដៃម្ខាងនោះ ហើយខ្ញុំព្រះអង្គនឹងប្រែទូវផែនដីដោយដៃម្ខាង ។ ព្រះអង្គទ្រង់ឃាត់ថា មោគ្គល្លាន អ្នកកុំពេញចិត្តនឹងត្រឡប់ផែនដីនោះឡើយ សត្វទាំងឡាយនឹងបាននូវសេចក្ដីជ្រួលជ្រើមរចល់ ។ ព្រះមហាមោគ្គ-ល្លានក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះពុទ្ធដីកាដែលទ្រង់ត្រាស់មកនោះប្រពៃហើយ ( បើដូច្នោះ )សូមឲ្យភិក្ខុសង្ឃទាំងអស់ទៅបិណ្ឌបាតឯឧត្តរ-កុរុទ្វីបវិញ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលមោគ្គល្លាន ចុះភិក្ខុទាំងឡាយឯណាដែលមិនមានឫទ្ធិ អ្នកនឹងធ្វើនូវភិក្ខុទាំងនោះដូចម្ដេចទៅ ។ ព្រះមហាមោគ្គល្លានក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុទាំងអស់នឹងទៅបានយ៉ាងណា ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា កុំ មោគ្គល្លាន អ្នកកុំពេញចិត្តឲ្យភិក្ខុទាំងអស់ទៅបិណ្ឌបាតឯឧត្តរកុរុទ្វីបនោះឡើយ ។

[ ៧ ] គ្រានោះ ព្រះសារីបុត្រដ៏មានអាយុ លោកចូលទៅនៅក្នុងរហោ-ឋានជាទីចេញចាកពួក ហើយសម្ងំនៅក្នុងកម្មដ្ឋាន មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រហ្មចរិយធម៌ របស់ព្រះពុទ្ធដ៏មានជោគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្ម-ចរិយធម៌មិនឋិតនៅយូរ ព្រហ្មចរិយធម៌ របស់ព្រះពុទ្ធដ៏មានជោគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌ឋិតនៅយូរ ។ គ្រានោះ ព្រះសារីបុត្តត្ថេរដ៏

មានអាយុ ចេញចាកទីពួនសម្ងំ ក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់បានក្រាបថ្វាយបង្គំព្រះអង្គដោយគោរព ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសួរចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គចូលទៅនៅក្នុងរហោឋានជាទីចេញចាកពួក ហើយសម្ងំនៅក្នុងកម្មដ្ឋាន មានសេចក្តីត្រិះរិះថា ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានជោគទាំង-ឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ព្រហ្មចរិយធម៌របស់ព្រះពុទ្ធដ៏មានជោគទាំងឡាយអង្គណាខ្លះហ្ន៎ ជាព្រហ្មចរិយធម៌ឋិតនៅយូរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ។ ម្នាលសារីបុត្ត ឯព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមកកុសន្ធ ១ ព្រះដ៏មានព្រះភាគព្រះនាមកោនាគមន ១ ព្រះដ៏មានព្រះភាគ ព្រះនាមកស្សប ១ ជាព្រហ្ម-ចរិយធម៌ឋិតនៅបានយូរ ។ ព្រះសារីបុត្តត្ថេរ ក្រាបទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ បានជាមិនឋិតនៅយូរនោះ តើព្រោះហេតុ និងបច្ច័យដូចម្តេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ១ ព្រះដ៏មានព្រះភាគព្រះនាមសិខី ១ ព្រះដ៏មានព្រះភាគព្រះនាមវេស្សភូ ១ ព្រះអង្គមិនសូវ

ប្រឹងប្រែងសម្តែងធម៌ដល់សាវកទាំងឡាយដោយពិស្តារប៉ុន្មានទេ ព្រហ្មចរិយធម៌មានអង្គ ៩ ប្រការ របស់ព្រះពុទ្ធទាំងឡាយនោះ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ជាធម៌មានចំនួនតិចៗ ណាស់ សិក្ខាបទក៏ព្រះពុទ្ធទាំងនោះ មិនបានបញ្ញត្តដល់សាវកទាំងឡាយទេ អាណាបាតិមោក្ខ ក៏ព្រះពុទ្ធទាំងនោះមិនបានសម្តែងឡើយ ដល់អំណើះតតពីព្រះពុទ្ធដ៏មានជោគទាំងឡាយនោះទៅ អំណើះតតពីសាវកទាំងឡាយជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធនោះទៅ សាវកទាំងឡាយជាខាងក្រោយតមក ដែលមាននាមផ្សេងៗ គ្នា មានគោត្រផ្សេងៗ គ្នា មានជាតិផ្សេងៗ គ្នា ចេញពីត្រកូលផ្សេងៗ គ្នា ហើយបួសនោះ ក៏ញុំាងព្រហ្មចរិយធម៌នោះឲ្យសាបសូន្យបាត់អស់ភ្លាមទៅ ម្នាលសារីបុត្ត ឧបមាដូចជាផ្កាឈើផ្សេងៗ ដែលគេមិនបានដោតក្រងចងដោយចេស ហើយគេដាក់លើបន្ទះក្តារ ខ្យល់ក៏រមែងបក់បោកកម្ចាត់កម្ចាយផ្កាទាំងនោះឲ្យវិនាសអស់ទៅ ខ្យល់ដែលធ្វើនូវផ្កាទាំងនោះឲ្យវិនាសព្រោះហេតុអ្វី ពីព្រោះផ្កាទាំងនោះ គេមិនបានដោតក្រងចងដោយចេស ក៏សេចក្តីនេះយ៉ាងណាមិញ ម្នាលសារីបុត្ត លុះអំណើះតតពីព្រះសម្ពុទ្ធដ៏មានព្រះភាគ ( ទាំង ៣ ព្រះអង្គ ) នោះ និងពួកសាវកដែលជាអ្នកត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះទៅហើយ ពួកសាវកជាន់ក្រោយៗ តមក មាននាម គោត្រ ជាតិផ្សេងៗ គ្នា ដែលចេញចាកត្រកូលផ្សេងៗ គ្នា មកបួសនោះ ក៏ញុំាងព្រហ្មចរិយធម៌នោះឲ្យវិនាសទៅឆាប់ភ្លាម ដូចជាផ្កាឥតកម្រងយ៉ាងនោះឯង ម្យ៉ាងទៀត ព្រះពុទ្ធដ៏មានជោគទាំងនោះ លោកមិនសូវប្រឹងប្រែងស្ទង់ចិត្ត

( របស់សាវក ) ដោយព្រះហឫទ័យ ( របស់ព្រះអង្គ ) ហើយទូន្មាននូវសាវក ទាំងឡាយប៉ុន្មានឡើយ ម្នាលសារីបុត្ត ពីដើមមកមានរឿងតំណាលថា ព្រះអរហំសម្មាសម្ពុទ្ធដ៏មានជោគទ្រង់ព្រះនាមវេស្សភូ ព្រះអង្គកំណត់នូវចិត្ត ( របស់សាវក ) ដោយព្រះហឫទ័យ ( របស់ព្រះអង្គ ) ហើយទ្រង់ទូន្មានប្រៀនប្រដៅភិក្ខុសង្ឃចំនួន ១ ពាន់រូប នៅនាដងព្រៃមួយ ជាដងព្រៃគួរស្ញែម ដោយពុទ្ធភាសិតថា អ្នកទាំងឡាយចូររិះគិតយ៉ាងនេះ កុំរិះគិតយ៉ាងនេះឡើយ ចូរយកចិត្តទុកដាក់យ៉ាងនេះ កុំយកចិត្តទុកដាក់យ៉ាងនេះឡើយ ចូរលះបង់អំពើយ៉ាងនេះចេញ ហើយចូរផ្តេកផ្តួលចិត្តឲ្យប្រជិតប្រជីទៅរកអំពើនេះវិញ ម្នាលសារីបុត្ត នៅវេលាដែលព្រះអរហំសម្មាសម្ពុទ្ធដ៏មានជោគទ្រង់ព្រះនាមវេស្សភូ ទ្រង់បានទូន្មានប្រៀនប្រដៅយ៉ាងនេះៗ ហើយ ចិត្តរបស់ភិក្ខុទាំង ១ ពាន់រូបនោះក៏បានរួចស្រឡះចាកអាសវក្កិលេស មិនមានសេចក្តីប្រកាន់មាំឡើយ ម្នាលសារីបុត្ត ដងព្រៃដែលមាននៅទីនោះ មុខគួរឲ្យស្ញែមពេកណាស់ បើបុគ្គលណាមួយមិនទាន់ប្រាសចាករាគៈនៅឡើយទេ លុះបានចូលទៅកាន់ដងព្រៃនោះហើយ បុគ្គលនោះនឹងព្រឺរោមដោយច្រើន ម្នាលសារីបុត្ត ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគ ព្រះនាមវិបស្សី ១ ព្រះនាមសិខី ១ ព្រះនាមវេស្សភូ ១ ជាព្រហ្មចរិយធម៌មិនឋិតនៅយូរ ព្រោះហេតុ និងបច្ច័យប៉ុណ្ណោះឯង ។ ព្រះសារីបុត្តក្រាបទូលសួរតទៅទៀតថា សូមទ្រង់ព្រះមេត្តាប្រោស ព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគព្រះនាមកកុសន្ធ ១ ព្រះនាមកោនាគមន ១ ព្រះនាមកស្សប ១ ( ទាំង ៣ ព្រះអង្គនេះ ) បានជាឋិតនៅយូរ តើព្រោះហេតុ និងបច្ច័យអ្វី ។ ព្រះសព្វញ្ញុ-

ពុទ្ធត្រាស់តបថា ម្នាលសារីបុត្ត ឯព្រះដ៏មានព្រះភាគព្រះនាមកកុសន្ធ ១ ព្រះនាមកោនាគមន ១ ព្រះនាមកស្សប ១ ( ទាំង ៣ ព្រះអង្គនោះ ) ទ្រង់មានសេចក្តីឧស្សាហ៍ខ្វល់ខ្វាយសម្តែងធម៌ ដល់ពួកសាវកដោយពិស្តារ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ របស់ព្រះពុទ្ធទាំង ៣ ព្រះអង្គនោះក៏សឹងមានច្រើន ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទ ទ្រង់សម្តែងអាណាបាតិមោក្ខដល់ពួកសាវក លុះព្រះសម្ពុទ្ធដ៏មានជោគទាំងអម្បាលនោះ ទ្រង់ចូលនិព្វានទៅ ទាំងសាវកដែលត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះ ក៏និព្វានអស់ទៅទៀត សាវកទាំងឡាយជាន់ក្រោយៗ តមក ដែលមាននាមផ្សេងៗ គ្នា មានគោត្រផ្សេងៗ គ្នា មានជាតិផ្សេងៗ គ្នា បានចេញអំពីត្រកូលផ្សេងៗ គ្នា ហើយបួសនោះ ក៏បានញ៉ាំងព្រហ្មចរិយធម៌ ឲ្យឋិតថេរអស់កាលជាអង្វែងតមក ម្នាលសារីបុត្ត មានគួរនាដូចជាផ្កាឈើផ្សេងៗ ដែលគេក្រងដោយចេស ហើយដាក់លើបន្ទះក្តារ ខ្យល់ក៏មិន ( អាច ) បក់បោកផ្កាទាំងនោះឲ្យរាត់រាយ ខ្ចាត់ខ្ចាយវិនាសទៅបានឡើយ សេចក្តីនោះព្រោះហេតុអ្វី ព្រោះថា ផ្កាទាំងនោះគេក្រងចងខ្ជាប់ដោយអំបោះ នេះមានឧបមាយ៉ាងណាមិញ ម្នាលសារីបុត្រ សេចក្តីឧបមេយ្យក៏ដូចគ្នាដែរ លុះព្រះពុទ្ធដ៏មានជោគទាំងអម្បាលនោះចូលនិព្វានហើយ សាវកទាំងឡាយដែលត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះក៏និព្វានទៅហើយដែរ សាវកទាំងឡាយជាខាងក្រោយដែលមានឈ្មោះផ្សេង ៗ គ្នា មានគោត្រផ្សេងៗ គ្នា មានជាតិផ្សេងៗ គ្នា ចេញចាកត្រកូលផ្សេងៗ ហើយបួស ក៏ញ៉ាំងព្រហ្មចរិយធម៌ ( សាសនា ) ឲ្យឋិតនៅជាអង្វែង

មក ម្នាលសារីបុត្រ នេះឯងជាហេតុជាបច្ច័យ ញ៉ាំងព្រហ្មចរិយធម៌របស់ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមកកុសន្ធក្តី ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមកោនាគមនក្តី ព្រះដ៏មានព្រះភាគទ្រង់ព្រះនាមកស្សបក្តី ឲ្យឋិតនៅបានយូរ ។

[ ៨ ] លំដាប់នោះ ព្រះសារីបុត្រដ៏មានអាយុក្រោកចាកអាសនៈហើយធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោសកាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះ ជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ៗ គួរបញ្ញត្តសិក្ខាបទ គួរសំម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយជាហេតុ នឹងឲ្យព្រហ្មចរិយធម៌ឋិតថេរអស់កាលជាអង្វែងទៅ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលសារីបុត្រ អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងសឹងដឹងកាលគួរក្នុងកិច្ច ដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈមិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្តាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សំម្តែងអាណាបាតិ-មោក្ខដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ធម៌ទាំងឡាយខ្លះជាទីតាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សំម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពាររារាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុអ្នកបួសចាស់វស្សា

ច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើន មានកិក្ខុបួសចាស់វស្សាច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះ ក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណា-បាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររារាំងនូវធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្ដីចម្រើនមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃ ក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើន មានគ្នាច្រើនក្នុងកាលណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណា-បាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពាររារាំងនូវធម៌ជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្ដីចម្រើនដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈក៏នៅមិនទាន់មានប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃដល់នូវសេចក្ដីចម្រើនដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទសម្ដែងអាណាបាតិមោក្ខ ដល់សាវកទាំងឡាយ

ដើម្បីការពាររកាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ(ឥឡូវ) ភិក្ខុសង្ឃនៅមិនទាន់មានពុត (ហ៊ានលបលួចធ្វើអាក្រក់) នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង សុទ្ធសឹងតែផូរផង់ផ្ទង់ចិត្តស្ថិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្ដាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់លែងធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលតៗ ទៅទៀតជាប្រាកដ ។

[ ៩ ] ( លុះដល់ចេញវស្សាហើយ ) ព្រះដ៏មានជោគទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមក ហើយមានព្រះបន្ទូលថា អានន្ទ ទំនៀមព្រះតថាគតទាំងឡាយ បើអ្នកណាគេនិមន្តឲ្យនៅចាំវស្សាហើយ តែនៅមិនទាន់បានលាអ្នកនោះទេ ក៏មិនដែលចៀសចេញ ( ពីទីនោះ ) ទៅកាន់ជនបទចារិកឡើយ ចរិតនេះជាទំនៀមរបស់ព្រះតថាគតទាំងឡាយ មកអានន្ទ យើងនឹងទៅលាវេរញ្ជព្រាហ្មណ៍ ។ ព្រះអានន្ទដ៏មានអាយុក៏ទទួលព្រះពុទ្ធដីកាថា សូមទ្រង់ព្រះមេត្តាប្រោស មែនយ៉ាងនេះហើយ ។ លំដាប់នោះ ព្រះកគវាព្រះអង្គទ្រង់ស្បង់ចីពរ ព្រមទាំងបាត្រស្រេចហើយ ទ្រង់យកព្រះអានន្ទដ៏មានអាយុជាបច្ឆាសមណៈ ( ឲ្យនិមន្តតាមក្រោយព្រះអង្គទៅ ) ទ្រង់យាងសំដៅទៅរកលំនៅរបស់វេរញ្ជព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេរៀបចំថ្វាយ ។ គ្រានោះ វេរញ្ជព្រាហ្មណ៍ ក៏ចូលមកគាល់ព្រះអង្គ លុះមកដល់ទីគំនាល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអង្គដោយគោរព ហើយអង្គុយក្នុងទីដ៏

សមគួរ ។ កាលបើវេរញ្ជព្រាហ្មណ៍អង្គុយស្រួលបួលហើយ ក៏ព្រះដ៏មានព្រះភាគមានព្រះបន្ទូលថា ព្រាហ្មណ៍ អ្នកឯងបាននិមន្តយើងឲ្យនៅចាំវស្សា ( ឥឡូវ ) ចេញវស្សាហើយ យើងត្រូវលាអ្នកនឹងចេញទៅកាន់ជនបទចារិក ។ វេរញ្ជព្រាហ្មណ៍ក៏ក្រាបទូលតបថា បពិត្រព្រះគោតមដ៏ចម្រើន មែនហើយ ខ្ញុំព្រះអង្គបាននិមន្តសូមឲ្យព្រះអង្គគង់ចាំវស្សា តែថា ទេយ្យធម៌ ដែលខ្ញុំព្រះអង្គបម្រុងនឹងថ្វាយនោះ ខ្ញុំព្រះអង្គមិនទាន់បានថ្វាយនៅឡើយ ឯទេយ្យធម៌នោះមិនមែនថាគ្មានទេ ខ្ញុំព្រះអង្គមានបំណងថា នឹងមិនថ្វាយនោះក៏ទេ ( ចេះតែខានមិនទាន់បានថ្វាយ ) ព្រោះជាតិជាគ្រហស្ថអ្នកគ្រប់គ្រងផ្ទះសម្បែង រមែងមានកិច្ចរវល់ច្រើន មានការងារក៏ច្រើន ចំណែកខាងព្រះអង្គសោត ទ្រង់នឹងបានទេយ្យធម៌នោះមកពីណា សូមព្រះគោតមដ៏ចម្រើន ព្រមទាំងព្រះភិក្ខុសង្ឃទទួលចង្ហាន់របស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកសិន ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះដ៏មានព្រះភាគក៏ត្រាស់សម្តែងធម៌ពន្យល់ណែនាំឲ្យវេរញ្ជព្រាហ្មណ៍យល់ប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោក ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយខ្មីឃ្មាតសង្វាតធ្វើការកុសល រួចទ្រង់ក្រោកចាកអាសនៈ ហើយយាងត្រឡប់មកវិញ ។ ដល់វេលាព្រឹកឡើង វេរញ្ជ-ព្រាហ្មណ៍បង្គាប់ជនទាំងឡាយឲ្យចាត់ចែងធ្វើខាទនីយភោជនីយាហារ ( បង្អែម និងចម្អាប ) ដ៏ឆ្ងាញ់ពិសាក្នុងលំនៅរបស់ខ្លួនស្រេចហើយ ទើបចាត់បម្រើឲ្យទៅក្រាបទូលព្រះដ៏មានព្រះភាគតាមកំណត់ពេលថា បពិត្រព្រះគោតមដ៏ចម្រើន កាលនេះជាកាលគួរហើយ ចង្ហាន់ក៏បានរៀបចំស្រេចហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ស្បង់ចីវរព្រមទាំងបាត្រ ហើយយាងចូលទៅ

កាន់លំនៅនៃវេរញ្ជព្រាហ្មណ៍ ជាមួយនឹងព្រះភិក្ខុសង្ឃក្នុងវេលាព្រឹកនោះ លុះដល់ហើយ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ ។ វេលានោះ វេរញ្ជព្រាហ្មណ៍បានអង្គាសថ្វាយខាទនីយភោជនីយាហារ ( បង្អែម និងចម្អាប ) ដ៏ឆ្ងាញ់ពិសាដោយដៃខ្លួនឯងចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ត្រាតែដល់ លោកប្រកែកលែងទទួលទៀត លុះព្រះដ៏មានជោគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏ថ្វាយចីវរ ១ ត្រៃ ហើយប្រគេនសំពត់ ព្រះភិក្ខុសង្ឃ ១ គូៗ រាល់អង្គ ។ លំដាប់នោះ ព្រះភគវាទ្រង់ត្រាស់សម្តែងធម៌ណែនាំពន្យល់ ឲ្យវេរញ្ជព្រាហ្មណ៍យល់ប្រយោជន៍ក្នុងបច្ចុប្បន្ន និងបរលោក ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយខ្មីឃ្មាតសង្វាតធ្វើការកុសល រួចព្រះអង្គក្រោកចាកអាសនៈ ហើយទ្រង់យាងត្រឡប់មកវិញ ។ លុះព្រះអង្គគង់នៅជិតស្រុកវេរញ្ជា តាមគួរដល់អធ្យាស្រ័យហើយ ទ្រង់ក៏យាងចេញទៅកាន់នគរសោរេយ្យ រួចទៅនគរសង្កស្ស ហើយហួសទៅនគរកណ្ណកុជ្ជៈ ( តពីនោះទៅ ) ទ្រង់យាងសំដៅទៅស្រុកបយាគបតិដ្ឋាន លុះទៅដល់ហើយទ្រង់ឆ្លងគង្គានទី ក្នុងស្រុកបយាគបតិដ្ឋាន ហើយយាងទៅដល់នគរពារាណសី ។ គ្រានោះ ព្រះអង្គគង់កម្សាន្តក្នុងក្រុងពារាណសី ហើយទ្រង់ចៀសទៅកាន់ចារិកនៃក្រុងវេសាលី កាលទ្រង់យាងទៅកាន់ចារិកតាមលំដាប់ ក៏បានទៅដល់ក្រុងវេសាលី ។ បានឮថា ព្រះដ៏មានជោគព្រះអង្គទៅគង់សម្រាន្តឥរិយាបថ ក្នុងកូដាគារសាលានៅនា មហាវន ( ព្រៃធំ ) ជិតក្រុងវេសាលីនោះ ។

ចារៈសម្តែងអំពីនិទានវេរញ្ជព្រាហ្មណ៍ ចប់

# អដ្ឋកថា
# ព្រះវិន័យ ឈ្មោះ សមន្តបាសាទិកា
# មហាវិភង្គវណ្ណនា

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

## អារម្ភកថា

ខ្ញុំព្រះករុណា សូមនមស្ការដល់ព្រះពុទ្ធជាទីពឹង ទ្រង់ប្រកបដោយព្រះមហាករុណា ព្រះអង្គទ្រង់ធ្វើនូវកម្មដែលធ្វើបានដោយកម្រ អស់កាលរាប់ប្រមាណមិនបាន សូម្បីដោយច្រើនកោដិកប្ប ទ្រង់ដល់នូវសេចក្ដីលំបាក ដើម្បីប្រយោជន៍ដល់សត្វលោក ។ ខ្ញុំព្រះករុណា សូមនមស្ការដល់ព្រះធម៌ដ៏ប្រសើរ ដែលកម្ចាត់បង់នូវសំណាញ់ គឺកិលេស មានអវិជ្ជាជាដើម ដែលព្រះពុទ្ធទ្រង់សេពជានិច្ច ដែលសត្វលោក កាលមិនពិចារណាដឹង តែងអន្ទោលទៅកាន់ភពតូច ភពធំ ។ ខ្ញុំព្រះករុណាសូមនមស្ការដោយសិរសា គឺត្បូង នូវព្រះអរិយសង្ឃ ដ៏ប្រកបដោយគុណ មានសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈជាគោល ជាស្រែបុណ្យរបស់ពួកជន ដែលមានសេចក្ដីត្រូវការដោយកុសល ។ ខ្ញុំព្រះករុណា សូមនមស្ការនូវព្រះរតនត្រ័យ ដែលគួរនមស្ការដោយចំណែកមួយ ដោយប្រការដូចពោលមកនេះ បានហើយនូវអានិសង្សដ៏ទូលាយ ដែលហួរបញ្ចូនមកមិនដាច់ឯណា ដោយអានុភាពនៃកុសលផលបុណ្យនោះ ខ្ញុំព្រះករុណាសូមជាអ្នកប្រាសចាកអន្តរាយ ។

ខ្ញុំព្រះករុណា នឹងអាស្រ័យអានុភាពរបស់បុព្វាចារ្យ ពណ៌នាព្រះវិន័យឲ្យមិនលាយគ្នា ដែលកាលទ្រទ្រង់ហើយ សាសនារបស់ព្រះពុទ្ធ ដែលទ្រង់មិនបានតាំងមាំ ( ក្នុងចំណែកបំផុត គឺទិដ្ឋិទាំង ២ ) តែទ្រង់តាំងនៅដោយប្រពៃ ( ក្នុងមជ្ឈិមប្បដិបទា ) ដែលប្រតិស្ឋាននៅបាន ។ ពិតហើយ ព្រះវិន័យនេះ សូម្បីបុព្វាចារ្យអ្នកអង់អាចដែលកម្ចាត់មន្ទិល និងអាសវៈចេញអស់ហើយដោយទឹក គឺញាណ មានវិជ្ជា និងបដិសម្ភិទាបរិសុទ្ធ ឈ្លាសក្នុងការពណ៌នាព្រះសទ្ធម្ម មិនងាយរកអ្នកប្រៀបផ្ទឹម ក្នុងភាពជាអ្នកជុសខាត់បានប្រៀបដូចទង់ជ័យរបស់មហាវិហារ បានពណ៌នាទុកដោយន័យដ៏វិចិត្រ ស្របតាមព្រះសម្ពុទ្ធដ៏ប្រសើរ ។ ព្រោះដូច្នោះ ការពិពណ៌នានេះ មិនបានផ្តល់ប្រយោជន៍ណាមួយដល់ភិក្ខុក្នុងកោះដទៃ ព្រោះលោករៀបរៀងទុកដោយភាសាអ្នកកោះសីហឡ ដូច្នេះ ខ្ញុំជាអ្នកមានសតិល្អដោយប្រពៃ កាលបើពាក្យអារាធនារបស់ព្រះថេរៈឈ្មោះថា ពុទ្ធសិរី ទើបចាប់ផ្តើមដោយល្អ នូវការពណ៌នានេះ ដែលគួរដល់ន័យក្នុងព្រះបាលី នាកាលឥឡូវនេះ ។ ឯកាលនឹងចាប់ផ្តើមដោយល្អនូវការពណ៌នានេះ នឹងយកមហាអដ្ឋកថាជាគោលរបស់វណ្ណនានោះ មិនលះបង់នូវសេចក្តីដែលគួរ សូម្បីអំពីសេចក្តីវិនិច្ឆ័យ ដែលលោកពោលទុកក្នុងអដ្ឋកថា មហាបច្ចរី និងអដ្ឋកថា ដែលប្រាកដដោយល្អដោយឈ្មោះថា កុរុន្ទីជាដើម ធ្វើថេរវាទទុកក្នុងខាងក្នុងហើយ នឹងចាប់ផ្តើមដោយល្អ ដោយប្រពៃ នូវសំវណ្ណនា សូមភិក្ខុទាំងឡាយជាថេរៈ ជាអ្នកបួសថ្មី និងកណ្តាល ជាអ្នកមានចិត្តជ្រះថ្លា គោរពរាប់អានព្រះធម៌របស់ព្រះ

តថាគត បុគ្គលមានដួងប្រទីប គឺ ព្រះធម៌ ចូរតាំងចិត្តស្តាប់ការពណ៌នានេះរបស់ខ្ញុំដោយគោរពចុះ ។

ព្រះអដ្ឋកថាចារ្យ អ្នកស្រុកសីហឡ មិនបានលះបង់មតិ ( អធិប្បាយ ) របស់ពុទ្ធបុត្តទាំងឡាយ ជាអ្នកដឹងធម្មវិន័យ ដូចព្រះពុទ្ធត្រាស់ត្រាស់ទុក បានរចនាអដ្ឋកថាក្នុងកាលមុន ។ ព្រោះហេតុនោះឯង ពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាទាំងអស់ វៀរលែងតែពាក្យដែលចារឹកដោយសេចក្ដីភ្លាំងភ្លាត់ចេញ រមែងជាប្រមាណនៃបណ្ឌិតទាំងឡាយ ដែលមានសេចក្ដីគោរពក្នុងសិក្ខាក្នុងព្រះសាសនានេះ ។ ឯវណ្ណនានេះ នឹងសម្ដែងសេចក្ដីនៃពាក្យទាំងឡាយដែលមកក្នុងព្រះសុត្តន្តឲ្យសមគួរដល់ព្រះសូត្រ លះចោលនូវភាសាដទៃចេញពីអដ្ឋកថានោះឯង និងកាត់បន្ថយសេចក្ដីពិស្ដារ ( ពាក្យរចនាដែលពិស្ដារ ) ឲ្យមករួមផ្ដុំចូល ក៏នឹងមិនឲ្យនៅសល់ ទុកនូវសេចក្ដីវិនិច្ឆ័យទាំងពួង មិនរំលងលំដាប់ព្រះបាលី ដែលជាបែបផែនឯណានីមួយនោះឡើយ ព្រោះដូច្នោះបណ្ឌិតគួរតាមសិក្សាវណ្ណនានេះដោយអើពើចុះ ។

ព្រោះខ្ញុំបានពោលទុកក្នុងគាថាទាំងនេះថា នឹងពណ៌នាព្រះវិន័យ ដូច្នេះ អ្នកសិក្សាគួរកំណត់ព្រះវិន័យជាមុនថា វិន័យនោះ គឺអ្វី ។ ព្រោះដូច្នោះ ទើបខ្ញុំពោលពាក្យនេះថា **តំ វណ្ណយិស្សំ វិនយំ** ដែលឈ្មោះថាវិន័យ ក្នុងទីនេះ ប្រាថ្នាយកវិនយបិដកទាំងអស់ ។ ដើម្បីនឹងពិពណ៌នាព្រះវិន័យនោះ ខ្ញុំនឹងពោលមាតិកាដូចតទៅនេះថា

ព្រះវិនយបិដកនេះ បុគ្គលណាពោលទុក ពោលក្នុងកាលណា ពោល

ទុកព្រោះហេតុដូចម្ដេច បុគ្គលណាជាអ្នកទ្រទ្រង់ទុក បុគ្គលណានាំបន្តមក និង តាំងនៅហើយក្នុងបុគ្គលណា ខ្ញុំពោលវិធីនេះហើយ ខាងក្រោយនឹងសម្ដែងអត្ថ នៃបាលីថា **តេន** ជាដើម ដោយប្រការផ្សេងៗ ធ្វើការពណ៌នាអត្ថនៃព្រះវិន័យ នោះ ។

បណ្ដាមាតិកាទាំងនោះ ពាក្យថា **បុគ្គលណាពោលទុក ពោលក្នុងកាល ណា ពោលទុកព្រោះហេតុដូចម្ដេច** នេះ លោកអាចារ្យពោលសំដៅយកពាក្យ ជាដើមយ៉ាងនេះមុនថា សម័យនោះ ព្រះដ៏មានព្រះភាគគង់នៅ ( ក្រោមដើម ស្ដៅ ជាលំនៅរបស់នឡេរុយក្ស ) ជិតស្រុកវេរញ្ជា ។ ព្រោះពាក្យនេះ មិន មែនជាពាក្យដែលពោលឲ្យប្រចក្សជាមួយព្រះអង្គឯង នៃព្រះដ៏មានព្រះភាគ ។ ព្រោះដូច្នោះ ទើបបណ្ឌិតគួរពោលតាំងបញ្ហានោះដូច្នេះថា ពាក្យនេះ បុគ្គល ណាពោលទុក ពោលទុកក្នុងកាលណា និងព្រោះហេតុដូចម្ដេច ទើបពោល ទុក ។ ( ឆ្លើយថា ) ពាក្យនេះ ព្រះឧបាលិត្ថេរពោលទុក ឯពាក្យនោះ ព្រះ ឧបាលិត្ថេរពោលទុកក្នុងគ្រាធ្វើបឋមមហាសង្គីតិ ។ ដែលឈ្មោះថា បឋម-មហាសង្គីតិនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានពោលហើយក្នុងបញ្ច-សតិកសង្គីតិក្ខន្ធកៈ ពិតមែនហើយ តែដើម្បីភាពជាអ្នកឈ្លាសក្នុងនិទាន បណ្ឌិតគួរជ្រាបតាមន័យនេះ សូម្បីក្នុងអដ្ឋកថានេះ ។

# ពាហិរនិទាន

## ប្រារព្ធហេតុធ្វើបឋមសង្គាយនា

សេចក្តីពិស្តារថា កាលព្រះមានព្រះភាគ ដែលជាទីពឹងនៃសត្វលោក ទ្រង់ធ្វើពុទ្ធកិច្ច តាំងពីទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅជាដើម ដរាបដល់ប្រោសសុភទ្ទបរិព្វាជកហើយ ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងពេលទៀបភ្លឺ ក្នុងថ្ងៃវិសាខបុណ្ណមី ត្រង់ចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងសាលវ័នដែលជាទីប្រពាតរបស់ស្តេចមល្លៈទាំងឡាយ ជិតក្រុងកុសិនារា ព្រះមហាកស្សបដែលជាសង្ឃត្ថេរនៃភិក្ខុប្រមាណ ៧ សែនអង្គ ដែលប្រជុំគ្នាត្រង់ទីបរិនិព្វាននៃព្រះមានព្រះភាគ ឮពាក្យដែលសុភទ្ទវុឌ្ឍបព្វជិតពោល កាលព្រះមានព្រះភាគទ្រង់បរិនិព្វានហើយ បាន ៧ ថ្ងៃថា អាវុសោទាំងឡាយ ណ្ហើយអ្នកទាំងឡាយ កុំសោកសៅ កុំខ្សឹកខ្សួលឡើយ ពួកយើងនឹងបានរួចស្រឡះហើយ ព្រោះថា ពួកយើង មហាសមណៈនោះតែងបៀតបៀនថា អំពើនេះគួរដល់អ្នក អំពើនេះមិនគួរដល់អ្នក ឥឡូវនេះ ពួកយើងនឹងប្រាថ្នាធ្វើនូវអំពើណា នឹងធ្វើនូវអំពើនោះ មិនប្រាថ្នាធ្វើនូវអំពើណា នឹងមិនធ្វើអំពើនោះបាន ដូច្នេះ លោកពិចារណាឃើញថា ការប្រជុំសង្ឃចំនួនច្រើនដូច្នេះ អំណឹះតទៅ នឹងរកបានដោយក្រ ទើបត្រិះរិះថា ការដែលពួកបាបភិក្ខុ នឹងគប្បីជាអ្នកសម្គាល់ថាបាវចនៈ មានព្រះសាស្តាកន្លងទៅហើយ ដូច្នេះ បានបក្ខពួកហើយ គប្បីញ៉ាំងព្រះសទ្ធម្មឲ្យអន្តរធានបាន មិនយូរឡើយ ក៏ដំណើរនេះ ជាឋានៈ ( ហេតុ ) ដែលនឹងមានជាប្រាកដ ។ សេចក្តីពិត ព្រះវិន័យតាំងនៅដរាបណា បាវចនៈនៅមានព្រះសាស្តា មិនកន្លងទៅដរាបនោះ សេចក្តីនេះសមដោយព្រះតម្រាស់

ដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលអានន្ទ ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសម្តែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណើះតអំពីតថាគតទៅ ធម៌ និងវិន័យនោះ ជាគ្រូរបស់អ្នកទាំងឡាយ ដូច្នេះ បើដូច្នោះ យើងគប្បីសង្គាយនាព្រះធម៌ និងព្រះវិន័យ ដែលជាវិធីសម្រាប់ព្រះសាសនានេះ គប្បីតាំងនៅមាំអស់កាលយូរ ។ ម្យ៉ាងទៀត ដោយហេតុដែលយើង ជាអ្នកដែលព្រះមានព្រះភាគត្រាស់ថា កស្សប អ្នកនឹងទ្រទ្រង់សំពត់បង្សុកូលដែលធ្វើដោយធ្មៃរបស់តថាគត ដែលតថាគតប្រើប្រាស់ ស្បៀកដណ្តប់ហើយឬ ដូច្នេះហើយទ្រង់អនុគ្រោះដោយអសាធារណបរិភោគក្នុងចីវរ និងដោយការទ្រង់លើកតម្កើងទុក ប្រៀបធៀបព្រះអង្គក្នុងឧត្តរិមនុស្សធម្ម មានអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ជាប្រភេទ ដោយន័យជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ តថាគតប្រាថ្នាដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះដរាបនោះ ។ ម្នាលភិក្ខុទាំង-ឡាយ ចំណែកកស្សបប្រាថ្នាដរាបណា ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងាត់នោះដរាបនោះដែរ ដូច្នេះ ភាពជាអ្នកមិនមានបំណុលដទៃណាមួយ នឹងមានដល់អាត្មាអញនោះបាន ព្រះមានព្រះភាគទ្រង់ជ្រាបអាត្មាអញថា កស្សបនេះ នឹងជាអ្នកបន្តវង្សព្រះសទ្ធម្មរបស់តថាគត ដូច្នេះហើយ ទើបទ្រង់អនុគ្រោះដោយអសាធារណានុគ្រោះនេះ ដូច

ព្រះរាជាទ្រង់ជ្រាបព្រះឱរសដែលនឹងបន្តវង្សរបស់ព្រះអង្គ ហើយទ្រង់អនុគ្រោះដោយទ្រង់ប្រគល់គ្រឿងក្រោះ និងឥស្សរិយយសរបស់ព្រះអង្គ ដូច្នោះ មិនមែនឬ ដូច្នេះ ទើបញ៉ាំងសេចក្ដីឧស្សាហ៍ឲ្យកើតដល់ភិក្ខុទាំងឡាយ ដើម្បីប្រារព្ធសង្គាយនាព្រះធម៌ ព្រះវិន័យ ដូចដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា លំដាប់នោះ ព្រះមហាកស្សបដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា អាវុសោទាំងឡាយ សម័យមួយ ខ្ញុំគិតថា នឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងបាវានេះ រូបហើយ នឹងទៅកាន់ក្រុងកុសិនារា ហើយក៏ដើរទៅតាមផ្លូវឆ្ងាយជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន ៥០០ រូប ដូច្នេះជាដើម ។

សុភទ្ទកណ្ឌទាំងពួង អ្នកសិក្សាគប្បីជ្រាបដោយពិស្ដារ ។

# ព្រះមហាកស្សបដឹកនាំធ្វើសង្គាយនា

ខាងមុខអំពីនោះ ព្រះមហាកស្សបបានពោលថា ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនានូវធម៌និងវិន័យ តំណទៅមុខ អកុសលធម៌មុខជានឹងរុងរឿងឡើង កុសលធម៌មុខជានឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យ មុខជានឹងរុងរឿងឡើង វិន័យមុខជានឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលជាអធម្មវាទី នឹងមានកម្លាំងឡើង ពួកបុគ្គលជាធម្មវាទី នឹងថយកម្លាំងចុះ ពួកបុគ្គលជាអវិនយវាទី នឹងមានកម្លាំងឡើង ពួកបុគ្គលជាវិនយវាទី នឹងថយកម្លាំងចុះ ដូច្នេះ ។ ភិក្ខុទាំងឡាយពោលថា បពិត្រព្រះថេរៈដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈជ្រើសរើសនូវភិក្ខុទាំងឡាយចុះ ។

## ព្រះមហាកស្សបជ្រើសរើសភិក្ខុ ៤៩៩ រូប

ព្រះថេរៈ វៀរភិក្ខុដែលជាបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រពសុក្ខវិបស្សកៈ ដែលទ្រទ្រង់ព្រះបរិយត្តិ គឺនវង្គសត្ថុសាសនៈទាំងអស់ចេញច្រើនរយ និងច្រើនពាន់ ជ្រើសរើសយកតែភិក្ខុជាខីណាស្រពចំនួន ៤៩៩ អង្គ ដែលទ្រទ្រង់ទុកនូវសព្វបរិយត្តិ គឺព្រះត្រៃបិដក បានសម្រេចបដិសម្ភិទា មានអានុភាពច្រើន បែកធ្លាយក្នុងវិជ្ជា ៣ ជាដើមដែលព្រះមានព្រះភាគ ទ្រង់លើកឡើងកាន់ឯតទគ្គៈដោយច្រើនប៉ុណ្ណោះ អ្នកដែលព្រះធម្មសង្គាហកាចារ្យជ្រើសយក ទើបពោលពាក្យនេះថា ព្រះមហាកស្សបដ៏មានអាយុជ្រើសរើសនូវព្រះអរហន្តបានចំនួន ៤៩៩ រូប ដូច្នេះជាដើម ។

## ការធ្វើសង្គាយនាវៀរព្រះអានន្ទមិនបាន

សួរថា ព្រះកស្សបត្រូវធ្វើឲ្យខ្វះមួយអង្គ ដើម្បីបុគ្គលណា ឆ្លើយថា ដើម្បីឲ្យឱកាសដល់ព្រះអានន្ទត្ថេរ ។ ពិតហើយ ការធ្វើសង្គាយនាធម៌ មិនអាចធ្វើទាំងរួម ទាំងបែកចាកព្រះអានន្ទបាននោះទេ ព្រោះព្រះអានន្ទនោះ ជាព្រះសេក្ខៈ មានកិច្ចចាំបាច់ត្រូវធ្វើនៅឡើយ ដូច្នោះហើយ ទើបមិនអាចធ្វើរួមទីងលោក តែព្រោះនវង្គសត្ថុសាសនៈ មានសុត្តៈ គេយ្យៈជាដើម ដែលព្រះទសពលសម្តែងហើយ ឈ្មោះថា លោកមិនបានទទួលចំពោះព្រះភក្ត្របស់ព្រះមានព្រះភាគនោះមិនមាន ព្រោះដូច្នោះ ទើបមិនអាចវៀរលោកបាន ។សួរថា កាលបើមិនអាចធ្វើយ៉ាងនោះបាន សូម្បីព្រះថេរៈនៅជាព្រះសេក្ខៈនៅឡើយ ព្រះថេរៈក៏គួរជ្រើសរើស ព្រោះជាអ្នកមានឧបការៈច្រើនដល់ការធ្វើសង្គាយនាព្រះធម៌ កាល

មានសេចក្តីចាំបាច់ត្រូវជ្រើសរើសយ៉ាងនោះ ហេតុអ្វី ទើបព្រះថេរៈមិនជ្រើសរើសលោក ។ ឆ្លើយថា ព្រោះចៀសវាងពាក្យតិះដៀលរបស់អ្នកដទៃ ។ សេចក្តីពិត ព្រះថេរៈជាអ្នកស្និទ្ធស្នាលក្នុងព្រះអានន្ទយ៉ាងក្រៃលែងបំផុត ។ ពិតហើយ សូម្បីសក់ស្កូវហើយ ព្រះមហាកស្សបក៏នៅតែហៅព្រះអានន្ទនោះដោយប្រើកុមារវាទថា អានន្ទនេះ នៅក្មេង មិនដឹងប្រមាណឡើយ ដូច្នេះ ។ម្យ៉ាងទៀត ព្រះអានន្ទនេះ ប្រសូតក្នុងសក្យត្រកូល ជាព្រះភាតារបស់ព្រះតថាគត ជាឱរសរបស់ព្រះបិតុលា ពិតមែន ភិក្ខុទាំងឡាយនឹងសម្គាល់ក្នុងព្រះមហាកស្សបត្ថេរនោះ ដូចជាដល់នូវឆន្ទាគតិ នឹងគប្បីពោលតិះដៀលថា ព្រះថេរៈវៀរភិក្ខុទាំងឡាយដែលបានសម្រេចបដិសម្ភិទា ជាអសេក្ខៈចេញជាច្រើនបែរជាជ្រើសរើសយកព្រះអានន្ទ ដែលសម្រេចបដិសម្ភិទាជាសេក្ខៈវិញ ។ ព្រះថេរៈ កាលនឹងវៀរពាក្យតិះដៀលរបស់អ្នកដទៃនោះចេញហើយ ទើបគិតថាការធ្វើសង្គាយនាមិនអាចធ្វើបានឡើយបើវៀរព្រះអានន្ទចេញ អញនឹងទទួលយកព្រះអានន្ទចូលផង តាមអនុមតិរបស់ភិក្ខុទាំងឡាយប៉ុណ្ណោះ ទើបមិនបានជ្រើសរើសព្រះអានន្ទនោះចូលផង ។

## ភិក្ខុទាំងឡាយសូមជ្រើសរើសព្រះអានន្ទ

គ្រានោះ ទើបភិក្ខុទាំងឡាយនាំគ្នាអង្វរព្រះថេរៈ ដើម្បីឲ្យជ្រើសរើសព្រះអានន្ទដោយខ្លួនឯងតែម្តង ដូចដែលបុរាណាចារ្យពោលទុកថា ពួកភិក្ខុបានពោលពាក្យនេះចំពោះព្រះមហាកស្សបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអានន្ទដ៏មានអាយុនេះ នៅជាសេក្ខៈ តែលោកមិនអាចនឹងលុះដោយឆន្ទាគតិ

ទោសាគតិ មោហាគតិ ភយាគតិទេ ធម៌ក្ដី វិន័យក្ដី ព្រះអានន្ទនេះ បានសិក្សារៀនសូត្រក្នុងសម្នាក់ព្រះមានព្រះភាគជាច្រើន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈធ្វើការជ្រើសរើសយកព្រះអានន្ទដ៏មានអាយុផង ។ ទើបព្រះមហាកស្សបដ៏មានអាយុ ជ្រើសរើសយកព្រះអានន្ទដ៏មានអាយុបញ្ចូលផងរួមជាមួយភិក្ខុទាំងឡាយនោះ ដែលព្រះមហាកស្សបជ្រើសរើសតាមអនុមតិរបស់ភិក្ខុទាំងឡាយ ទើបជាព្រះថេរៈ ៥០០ អង្គ ដោយប្រការដូច្នេះ ។

## ក្រុងរាជគ្រឹះជាកន្លែងធ្វើបឋមសង្គាយនា

គ្រានោះឯង ភិក្ខុថេរៈទាំងឡាយ មានបរិវិតក្កៈយ៉ាងនេះថា យើងទាំង-ឡាយគប្បីសង្គាយនាព្រះធម៌ និងព្រះវិន័យក្នុងទីណាហ្ន៎ ។ គ្រានោះឯង ភិក្ខុទាំងឡាយដែលជាថេរៈ មានសេចក្ដីរិះគិតឃើញដូច្នេះថា នគររាជគ្រឹះ ជាស្រុកមានទីគោចរក៏ច្រើន មានសេនាសនៈក៏ច្រើន បើដូច្នោះ គួរតែយើងរាល់គ្នាទៅនៅចាំវស្សាក្នុងនគររាជគ្រឹះ ទើបអាចសង្គាយនានូវធម៌ និងវិន័យបាន ចំណែកភិក្ខុទាំងឡាយឯទៀត កុំគប្បីចូលទៅនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈទាំងនោះប្រឹក្សាព្រមព្រៀងគ្នាដូច្នោះ ឆ្លើយថា ព្រោះនឹងមានវិសភាគបុគ្គលខ្លះចូលទៅកាន់កណ្ដាលជំនុំសង្ឃ ហើយគប្បីជំទាស់ថាវរកម្មរបស់លោកបាន ។ គ្រានោះ ទើបព្រះមហាកស្សបសូត្រប្រកាសដោយញត្តិទុតិយកម្មវាចា ។ ញត្តិទុតិយកម្មនោះ អ្នកសិក្សាគប្បីជ្រាបតាមន័យដែលលោកទុកក្នុងសង្គីតិក្ខន្ធកៈនោះឯង ។

## ព្រះមហាថេរៈចែកគ្នាទៅកាន់ក្រុងរាជគ្រឹះ

គ្រានោះ ព្រះមហាកស្សបត្ថេរជ្រាបថា ចាប់តាំងពីថ្ងៃដែលព្រះតថាគត បរិនិព្វានមក កាលថ្ងៃសាធុកីឡា និងថ្ងៃបូជាព្រះធាតុកន្លងទៅបាន ៧ ថ្ងៃម្តងៗ ជាការកន្លងទៅហើយកន្លះខែ ឥឡូវនេះគិម្ហន្តរដូវនៅសល់កន្លះខែ ជា តិថីដែលនឹងចូលវស្សា ក៏ជិតចូលមកហើយ ទើបពោលថា អ្នកមានអាយុទាំងឡាយ ពួកយើងទៅកាន់ក្រុងរាជគ្រឹះចុះ ហើយបាននាំយកភិក្ខុសង្ឃពាក់កណ្តាលដើរ ទៅផ្លូវមួយ ។ ព្រះអនុរុទ្ធត្ថេរ ក៏នាំយកភិក្ខុសង្ឃពាក់កណ្តាលដើរទៅផ្លូវមួយ ទៀត ។ ព្រះអានន្ទត្ថេរកាន់យកបាត្រ និងចីវររបស់ព្រះមានព្រះភាគដែលមាន ភិក្ខុសង្ឃហែហម មានបំណងនឹងធ្វើដំណើរឆ្លងកាត់ក្រុងសាវត្ថី ទៅកាន់ក្រុង រាជគ្រឹះ ក៏ចៀសចារិកទៅតាមផ្លូវក្រុងសាវត្ថី ។

## ព្រះអានន្ទទៅដល់ទីណាសំឡេងយំក៏មានក្នុងទីនោះ

ក្នុងទីដែលព្រះអានន្ទទៅហើយ មានការស្រែកយំរៀបរាប់យ៉ាងច្រើនថា ព្រះអានន្ទដ៏ចម្រើន លោកម្ចាស់យាត់ព្រះសាស្តាទុកឯណាទើបមក ហើយ កាលព្រះថេរៈទៅដល់ក្រុងសាវត្ថីដោយលំដាប់ មានការស្រែកទ្រហោយំរៀប រាប់យ៉ាងច្រើន ដូចក្នុងថ្ងៃដែលព្រះមានព្រះភាគស្តេចបរិនិព្វាននោះឯង ។

## ព្រះអានន្ទសម្អាតសេនាសនៈដែលធ្លាប់គង់

បានឮថា ក្នុងក្រុងសាវត្ថីនោះ ព្រះអានន្ទបានលួងលោមពន្យល់មហាជន នោះឲ្យធូរស្រាលចិត្តដោយធម្មីកថា ដែលបដិសំយុត្តដោយត្រៃលក្ខណ៍ មាន ការមិនទៀងជាដើម ហើយចូលទៅកាន់វត្តជេតពន បើកទ្វារព្រះគន្ធកុដិដែល

ព្រះទសពលធ្លាប់គង់ ហើយយកគ្រែ និងតាំងចេញមក គោះ វាយ បោស សម្អាតព្រះគន្ធកុដិ ប្រមូលសំរាមផ្កាឈើដែលស្ងួតៗ ទៅចោល ហើយនាំ យកគ្រែ និងតាំងត្រឡប់ចូលទៅរៀបចំទុកក្នុងទីដូចដើមវិញ បានធ្វើវត្តគ្រប់ យ៉ាង ដែលគួរធ្វើដូចក្នុងកាលដែលព្រះមានព្រះភាគមានព្រះជន្ម ដូច្នោះ ។

# ព្រះអានន្ទឆាន់ថ្នាំបញ្ចុះ

ក្នុងកាលនោះ ព្រះថេរៈ ព្រោះជាអ្នកច្រើនទៅដោយការឈរ និងការ អង្គុយ តាំងអំពីកាលព្រះមានព្រះភាគបរិនិព្វានមក ដើម្បីជម្រះកាយដែលមាន ធាតុក្រាស់ឲ្យស្រួលបួល ក្នុងថ្ងៃទី ២ ទើបអង្គុយផឹកថ្នាំបញ្ចុះដែលលាយដោយ ទឹកដោះ នៅក្នុងវិហារនោះឯង ដែលលោកសំដៅដល់ ទើបបានពោលពាក្យ នេះចំពោះមាណពដែលសុភមាណពបញ្ជូនទៅថា ម្នាលមាណព កាលនេះមិន គួរ ( ទៅទេ ) ដ្បិតថ្ងៃនេះ យើងបានផឹកថ្នាំខ្លះទៅហើយ បើដូច្នោះ ចាំយើង ពិចារណានូវកាល និងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែក ដូច្នេះ ។ ក្នុង ថ្ងៃស្អែកឡើង ព្រះថេរៈ មានព្រះចេតកត្ថេរជាបច្ឆាសមណៈ បានទៅ ( កាន់ លំនៅរបស់សុភមាណព ) ត្រូវសុភមាណពសួរ ទើបសម្ដែងព្រះសូត្រទី ១០ ឈ្មោះសុភសូត្រ ក្នុងទីឃនិកាយ ។ ក្នុងកាលនោះ ព្រះថេរៈបង្គាប់ឲ្យជាងធ្វើ ការជួសជុលទីកន្លែងដែលទ្រុឌទ្រោមក្នុងវត្តជេតពន ហើយកាលថ្ងៃវស្សូ- បនាយិកាជិតចូលមកដល់ បានទៅកាន់ក្រុងរាជគ្រឹះ ។ សូម្បីព្រះមហាកស្សប និងព្រះអនុរុទ្ធត្ថេរ ក៏បាននាំភិក្ខុសង្ឃទាំងអស់ទៅកាន់ក្រុងរាជគ្រឹះដូចគ្នា ។

## ព្រះថេរៈគិតជួសជុលវិហារ ១៨ កន្លែង

សម័យនោះឯង ក្នុងក្រុងរាជគ្រឹះ មានមហាវិហារ ១៨ វិហារធំៗ ទាំងអស់នោះ ក៏ស្រេកេកស្រេកាកទៅដោយរបស់ដែលត្រូវបោល និងធ្លាក់ពាសពេញ ពិតហើយ ពួកភិក្ខុទាំងអស់បាននាំគ្នាកាន់យកបាត្រ និងចីវររៀងៗ ខ្លួនលះបង់ចោលវិហារ និងបរិវេណទៅក្នុងទីកន្លែងដែលព្រះមានព្រះភាគបរិនិព្វានៗ ព្រះថេរៈទាំងឡាយនៅក្នុងវិហារទាំងនោះ ដើម្បីនឹងបូជាព្រះតម្រាស់របស់ព្រះមានព្រះភាគ និងដើម្បីដោះវាទៈរបស់ពួកតិត្ថិយ ទើបគិតគ្នាថា មួយខែដំបូងនេះ ពួកយើងនឹងធ្វើការជួសជុលវិហារដែលទ្រុឌទ្រោម ។ ឯពួកតិត្ថិយទាំងឡាយគប្បីពោលថា ពួកសាវករបស់ព្រះសមណគោតម កាលព្រះសាស្តាទ្រង់នៅមានព្រះជន្មប៉ុណ្ណោះ ទើបបដិបត្តិវិហារ កាលព្រះសាស្តាបរិនិព្វានហើយ ក៏នាំគ្នាលះបង់ចោលអស់ ។ លោកពោលអធិប្បាយទុកថា ដើម្បីនឹងដោះនូវវាទៈរបស់ពួកតិត្ថិយទាំងនោះ ទើបព្រះថេរៈទាំងឡាយបានគិតគ្នាយ៉ាងនោះ ។ សេចក្តីនេះ សមដូចព្រះធម្មសង្គាហកាចារ្យពោលទុកថា គ្រានោះ ភិក្ខុទាំងឡាយជាថេរៈ មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ បដិសង្ខរណកម្ម គឺការជួសជុលសេនាសនៈ ដែលបែកបាក់ធ្លុះធ្លាយ ព្រះមានព្រះភាគ ទ្រង់សរសើរហើយ ម្នាលអាវុសោ បើដូច្នោះ គួរតែយើងរាល់គ្នាជួលជុលសេនាសនៈដែលបែកបាក់ធ្លុះធ្លាយ អស់ខែមួយដំបូងសិន ដល់មកខែកណ្តាលយើងនឹងប្រជុំគ្នាធ្វើសង្គាយនានូវធម៌ និងវិន័យ ដូច្នេះ ។

## ព្រះមហាថេរៈទៅសូមហត្ថកម្មពីព្រះចៅអជាតសត្រូ

ក្នុងថ្ងៃទី ២ ព្រះថេរៈទាំងនោះបានទៅឈរត្រង់ទ្វារព្រះរាជវាំង ។ ព្រះ

បាទអជាតសត្តុស្តេចយាងមកថ្វាយបង្គំ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយ នាំគ្នាមកដោយហេតុដូចម្តេច ដូច្នេះ ហើយទើបទ្រង់ត្រាស់សាកសួរដល់កិច្ចដែលខ្លួនព្រះអង្គគួរធ្វើ ។ ព្រះថេរៈទាំង-ឡាយ បានទូលប្រាប់ហត្ថកម្ម ដើម្បីប្រយោជន៍ដល់ការជួសជុលមហាវិហារទាំង ១៨ កន្លែង ។

## ព្រះរាជាទ្រង់ឧបត្ថម្ភកិច្ចការសង្ឃគ្រប់យ៉ាង

ព្រះរាជាទ្រង់ទទួលថា សាធុ លោកម្ចាស់ ហើយបានព្រះរាជទានពួកមនុស្សអ្នកធ្វើហត្ថកម្ម ។ ព្រះថេរៈទាំងឡាយ ប្រាប់ឲ្យជួសជុលវិហារទាំងអស់ សម្រេចក្នុងមួយខែដំបូងប៉ុណ្ណោះ ហើយប្រាប់ឲ្យព្រះរាជាទ្រង់ជ្រាបថា សូមថ្វាយព្រះពរមហាបពិត្រ ការជួសជុលវិហារសម្រេចអស់ហើយ ឥឡូវនេះ អាត្មាភាពទាំងឡាយ នឹងធ្វើសង្គាយនាព្រះធម៌ និងព្រះវិន័យ ។

ព្រះរាជាត្រាស់ថា សាធុ លោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយកុំសន្ទិះសង្ស័យ ធ្វើចុះ អាណាចក្រ សូមទុកជាភារៈរបស់ខ្ញុំ ធម្មចក្រ សូមជាភារៈរបស់លោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់មេត្តាប្រើខ្ញុំចុះ លោកម្ចាស់នឹងឲ្យខ្ញុំធ្វើអ្វី ។

ព្រះថេរៈពោលថា សូមថ្វាយព្រះមហាបពិត្រ សូមព្រះអង្គមេត្តាឲ្យធ្វើទីកន្លែង អង្គុយប្រជុំសម្រាប់ភិក្ខុទាំងឡាយដែលធ្វើសង្គាយនា ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ តើឲ្យខ្ញុំធ្វើក្នុងទីណា ។

ព្រះថេរៈពោលថា សូមថ្វាយព្រះពរ គួរធ្វើត្រង់ល្អាងសត្តបណ្ណគុហា

*នាគ្គំវេការៈ ៗ*

# ព្រះរាជាបង្គាប់ឱ្យរចនាល្អាងដូចវិមានព្រហ្ម

*ព្រះបាទអជាតសត្រូ ទ្រង់ត្រាស់ថា បានលោកម្ចាស់ ដូច្នេះ ហើយបង្គាប់ឲ្យសាងមណ្ឌប មានគ្រឿងប្រដាប់ដែលជាសារៈ ដែលគួរទស្សនា ដូចទឹកន្ទៃងដែលវិស្សកម្មទេវបុត្រនិម្មិតទុក មានជញ្ជាំង សសរ និងជណ្តើរ ដែលជាងរៀបចំទុកដោយល្អ វិចិត្រដោយមាលាកម្ម និងលតាកម្ម មានប្រភេទផ្សេងៗ ហាក់ដូចជាគ្របសង្កត់នូវសម្បត្តិ នៃរាជមណ្ឌបរបស់ព្រះមហាក្សត្របាត់អស់ គួរនាបីដូចសិរីនៃទេវវិមាន ដូចជាស្ថានជាទីអាស្រ័យនៅនៃសិរី ដូចកំពង់ជាទីប្រជុំដ៏កំពូលរបស់ពួកវិហគៈ គឺភ្នែកនៃទេវតា និងមនុស្ស និងដូចរមណីយដ្ឋានក្នុងលោក ដែលគេប្រមូលចាត់ចែងសព្វគ្រប់ ការរចនាមណ្ឌបនោះដូចជាវិមានព្រហ្ម មានពិតានស្រស់ល្អរងរឿង ដូចកម្រងផ្កាកុសុមដែលរេរាំសំយុងចុះ មានប្រភេទផ្សេងៗ វិចិត្រដោយផ្កាឈើ និងគ្រឿងបូជាផ្សេងៗ មានការងារដែលគួរធ្វើត្រង់ផ្ទៃដីខាងក្រោម សម្រេចរៀបរយល្អហើយ ដូចជាមានផ្ទៃដីក្រាលពេញដោយកែវមណី ដ៏វិចិត្រដោយរតនៈដូច្នោះ ខាងក្នុងមហាមណ្ឌបនោះ ទ្រង់ត្រាស់ឲ្យក្រាលកម្រាលដែលជាកប្បិយ ៥០០ ដែលគណនាតម្លៃមិនបាន សម្រាប់ភិក្ខុ ៥០០ អង្គ ហើយឲ្យក្រាលថេរាសនៈដែលមានបង្អែក នាទិសទក្សិណ បែរមុខទៅទិសឧត្តរ ត្រង់កណ្តាលមណ្ឌបឲ្យតាំងធម្មាសនៈ ដែលគួរជាទីគង់ប្រថាប់របស់ព្រះមានព្រះភាគ បែរមុខទៅទិសបូព៌ា និងទ្រង់តម្កល់ផ្ចិតវាលវីជនីដ៏វិចិត្រដោយភ្លុក ទុកលើធម្មាសនៈនោះ ហើយប្រាប់ឲ្យប្រកាសដល់*

ភិក្ខុសង្ឃថា លោកម្ចាស់ដ៏ចម្រើន កិច្ចរបស់ខ្ញុំសម្រេចហើយ ដូច្នេះ ។

## ពួកភិក្ខុដាស់តឿនព្រះអានន្ទមិនឱ្យប្រមាទ

ពួកភិក្ខុបានពោលនឹងព្រះអានន្ទថា អាវុសោ ការប្រជុំនឹងមានក្នុងថ្ងៃស្អែក តែលោកនៅជាសេក្ខបុគ្គលនៅឡើយ ព្រោះហេតុនោះ លោកមិនគួរទៅកាន់ទីប្រជុំ លោកចូរជាអ្នកមិនប្រមាទចុះ ដូច្នេះ ។

គ្រានោះឯង ព្រះអានន្ទត្រិះរិះថា ការប្រជុំនឹងមានក្នុងថ្ងៃស្អែក ឯការដែលអញនៅជាសេក្ខៈនេះ នឹងគប្បីទៅកាន់ទីប្រជុំនោះ មិនសមគួរដល់អញឡើយ ហើយបានសម្រាកនៅដោយកាយគតាសតិ រហូតដល់យប់ជ្រៅនោះឯង ក្នុងពេលជិតភ្លឺ ក៏ចុះអំពីទីចង្ក្រម ហើយចូលទៅកាន់វិហារ ( កុដិ ) គិតថា នឹងសិង ក៏បានទម្រេតកាយចុះ ។ ជើងទាំងពីរផុតពីផែនដី តែសីសៈមិនទាន់ដល់ខ្នើយ ក្នុងចន្លោះឥរិយាបថនោះ ចិត្តក៏ផុតពីអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ។ ពិតហើយ ព្រះអានន្ទនេះ សម្រាកនៅហើយខាងក្រៅ ដោយការចង្ក្រម កាលមិនអាចនឹងញ៉ាំងគុណវិសេសឲ្យកើតឡើងបាន ទើបគិតថា ព្រះដ៏មានព្រះភាគបានត្រាស់ពាក្យនេះដល់អញ មិនមែនឬ ថាម្នាលអានន្ទ អ្នកជាបុគ្គលបានធ្វើបុណ្យទុកហើយ ចូរប្រកបព្យាយាមរឿយៗ ចុះ នឹងបានជាបុគ្គលមិនមានអាសវៈដោយឆាប់ ជាធម្មតា ទោសនៃព្រះតម្រាស់របស់ព្រះពុទ្ធទាំង-ឡាយមិនមាន អាត្មាអញប្រារព្ធសេចក្ដីព្យាយាមច្រើនពេកណាស់ ព្រោះហេតុនោះ ទើបចិត្តរបស់អាត្មាអញ ប្រព្រឹត្តទៅដើម្បីសេចក្ដីរាយមាយ ណ្ហើយចុះ

អញនឹងប្រកបសេចក្តីព្យាយាមឲ្យស្មើ ដូច្នេះ ទើបចុះពីទីចង្រ្កម ឈរលាងជើង ក្នុងទីសម្រាប់លាងជើង ហើយចូលទៅកាន់វិហារ គង់លើគ្រែ ត្រិះរិះថា នឹងសម្រាកមួយភ្លែត ក៏បានទម្រេតកាយនៅលើគ្រែ ។ ជើងទាំងពីរផុតអំពីផែនដី ក្បាលមិនទាន់ដល់ខ្នើយ ក្នុងចន្លោះឥរិយាបថនេះ ចិត្តក៏ផុតពីអាសវៈទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន ។ ភាពជាព្រះអរហន្តរបស់ព្រះថេរៈ វៀរចាកឥរិយាបថ ៤ ។ ព្រោះដូច្នោះ បើមានអ្នកសួរថា ក្នុងព្រះសាសនានេះ ភិក្ខុអង្គណា មិនដេក មិនអង្គុយ មិនឈរ មិនចង្រ្កម បានសម្រេចព្រះអរហត្ត គប្បីឆ្លើយថា ព្រះអានន្ទត្ថេរក៏គួរ ។

## ព្រះអានន្ទធ្វើដំណើរចូលទៅកាន់ទីប្រជុំនៃសង្ឃ

គ្រានោះ ក្នុងថ្ងៃទី ២ ភិក្ខុថេរៈទាំងឡាយ ធ្វើភត្តកិច្ចស្រេច ទុកដាក់បាត្រ និងចីវរហើយ ទៅប្រជុំគ្នាក្នុងធម្មសភា ។ ចំណែកព្រះអានន្ទត្ថេរ មានបំណងនឹងឲ្យអ្នកដទៃដឹងអំពីការសម្រេចភាពជាព្រះអរហន្តរបស់ខ្លួន មិនបានទៅព្រមនឹងភិក្ខុទាំងឡាយឡើយ ភិក្ខុទាំងឡាយ កាលគង់លើអាសនៈរៀងៗខ្លួន តាមលំដាប់វស្សា បានអង្គុយវៀរអាសនៈទុកសម្រាប់ព្រះអានន្ទត្ថេរ ។ កាលភិក្ខុពួកខ្លះក្នុងធម្មសភានោះសួរថា នុ៎ះអាសនៈរបស់ភិក្ខុណា ភិក្ខុទាំងឡាយឆ្លើយថា របស់អានន្ទ ភិក្ខុទាំងឡាយសួរថា ចុះអានន្ទទៅណាហ្ន៎ ក្នុងសម័យនោះ ព្រះថេរៈគិតថា ឥឡូវនេះ ជាកាលដែលអញនឹងទៅ កាលបើនឹងសម្តែងអានុភាពរបស់ខ្លួនក្នុងលំដាប់នោះ ទើបមុជចុះក្នុងផែនដី ហើយបង្ហាញខ្លួនលើអាសនៈរបស់ខ្លួននោះឯង ។ អាចារ្យពួកខ្លះពោលថា មកតាម

អាកាស ហើយអង្គុយក៏មាន ។

## ព្រះថេរៈចាប់ផ្ដើមប្រឹក្សា និងសន្មតខ្លួន

កាលព្រះអានន្ទនោះ អង្គុយហើយយ៉ាងនោះ ទើបព្រះមហាកស្សបត្ថេរ ប្រឹក្សាជាមួយភិក្ខុទាំងឡាយថា អ្នកដ៏មានអាយុទាំងឡាយ ពួកយើងនឹងសង្គាយនាអ្វីមុន ព្រះធម៌ ឬព្រះវិន័យ ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា បពិត្រលោកម្ចាស់កស្សប ធម្មតាព្រះវិន័យ ជាអាយុរបស់ព្រះពុទ្ធសាសនា កាលព្រះវិន័យតាំងនៅ ព្រះពុទ្ធសាសនារាប់ថា តាំងនៅ ព្រោះដូច្នោះ ពួកយើងនឹងសង្គាយនាព្រះវិន័យមុន ។

ព្រះមហាកស្សបពោលថា នឹងឲ្យធុរៈទៅអ្នកណា ។ ភិក្ខុទាំងឡាយពោលថា ឲ្យឧបាលីដ៏មានអាយុ ។

សួរថា ព្រះអានន្ទ មិនអាចឬ ។ ឆ្លើយថា មិនមែនមិនអាចទេ ។ ម្យ៉ាងទៀត កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនោះឯង ទ្រង់អាស្រ័យវិនយបរិយត្តិ ទើបតាំងព្រះឧបាលីទុកក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងឧបាលី ដូច្នេះ ព្រោះហេតុនោះ ទើបភិក្ខុទាំងឡាយប្រឹក្សាគ្នាថា ពួកយើងនឹងសួរឧបាលិត្ថេរ សង្គាយនាព្រះវិន័យ ដូច្នេះ ។

## ព្រះថេរៈសន្មតខ្លួនជាអ្នកបុច្ឆាវិសជ្ជនាព្រះវិន័យ

លំដាប់នោះ ព្រះថេរៈក៏បានសន្មតខ្លួនឯង ដើម្បីសួរនូវព្រះវិន័យ ។ ឯ

ព្រះឧបាលិត្ថេរក៏បានសន្មតខ្លួន ដើម្បីប្រយោជន៍ដល់ការវិសជ្ជនា ។

ក្នុងការសន្មតនោះ មានព្រះបាលីដូចតទៅ

គ្រានោះឯង ព្រះមហាកស្សបផ្ទៀងសង្ឃឲ្យជ្រាបថា អ្នកដ៏មានអាយុទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃគឺតិកម្មនេះ មានកាលសមគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យនឹងឧបាលី ។ ចំណែកព្រះឧបាលីក៏ប្រកាសឲ្យសង្ឃជ្រាបថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃគឺតិកម្មនេះ មានកាលសមគួរដល់សង្ឃហើយ លោកម្ចាស់កស្សបត្រូវសួរព្រះវិន័យចំពោះខ្ញុំ ខ្ញុំក៏ត្រូវដោះស្រាយក្នុងកាលឥឡូវនេះ ។

## បុច្ឆា និងវិសជ្ជនាព្រះវិន័យ

ព្រះឧបាលី កាលសន្មតខ្លួនយ៉ាងនោះហើយ ក៏ក្រោកឡើងអំពីអាសនៈ ដណ្តប់ចីវរឆៀងស្មាម្ខាង ថ្វាយបង្គំព្រះថេរៈទាំងឡាយហើយ គង់លើធម្មាសនៈ ចាប់ផ្ចិតវាលវីជនី ដ៏វិចិត្រដោយភ្លុក ។ គ្រានោះ ព្រះមហាកស្សបគង់លើថេរាសនៈ ហើយសួរព្រះវិន័យនឹងព្រះឧបាលីដ៏មានអាយុថា នែឧបាលីដ៏មានអាយុ បឋមបារាជិកសិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តក្នុងទីណា ព្រះឧបាលីឆ្លើយថា ក្នុងនគរវេសាលី លោកម្ចាស់ ។ ព្រះមហាកស្សបសួរថា ទ្រង់ប្រារព្ធនឹងបុគ្គលណា ព្រះឧបាលីឆ្លើយថា ទ្រង់ប្រារព្ធនឹងសុទិន្នកិក្ខុ ជាកូននៃកលន្ទកសេដ្ឋី ព្រះមហាកស្សបសួរថា ព្រោះវត្ថុអ្វី ព្រះឧបាលីឆ្លើយថា ព្រោះសេពមេថុនធម្ម ។

លំដាប់នោះឯង ព្រះមហាកស្សបដ៏មានអាយុសួរវត្ថុផង សួរនិទានផង

សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃបឋមបារាជិកសិក្ខាបទ ចំពោះព្រះឧបាលីដ៏មានអាយុ ។ ឧបមានេះថា ព្រះមហាកស្សបសួរវត្ថុផង ។បេ។ សួរអនាបត្តិផង នៃបឋមបារាជិកសិក្ខាបទយ៉ាងណា ព្រះមហាកស្សបក៏សួរវត្ថុផង ។បេ។ សួរអនាបត្តិផង នៃទុតិយ-បារាជិក ក៏យ៉ាងនោះ សួរវត្ថុផង ។បេ។ សួរអនាបត្តិផង នៃតតិយបារាជិកសិក្ខាបទ ក៏យ៉ាងនោះ សួរវត្ថុផង ។បេ។ សួរអនាបត្តិផង នៃចតុត្ថបារាជិកសិក្ខាបទក៏យ៉ាងនោះដែរ ព្រះឧបាលីដ៏មានអាយុ កាលបើព្រះមហាកស្សបសួរសព្វគ្រប់ហើយ ក៏បានដោះស្រាយសព្វគ្រប់ ។

## សង្គ្រោះព្រះវិន័យរបស់ភិក្ខុទុកជាពួកៗ

លំដាប់នោះ ព្រះថេរៈទាំងឡាយ បានលើកបារាជិក ៤ ឡើងកាន់សង្គហៈថា នេះឈ្មោះបារាជិកកណ្ឌ ហើយបានរៀបចំសង្ឃាទិសេស ១៣ ទុកថា តេរសកណ្ឌ រៀបចំសិក្ខាបទ ២ ទុកថា អនិយត រៀបចំសិក្ខាបទ ៣០ ទុកថា និស្សគ្គិយបាចិត្តិយ រៀបចំសិក្ខាបទ ៩២ ទុកថា បាចិត្តិយ រៀបចំសិក្ខាបទ ៤ ទុកថា បាដិទេសនីយ រៀបចំសិក្ខាបទ ៧៥ ទុកថា សេក្ខិយ រៀបចំធម៌ ៧ ប្រការទុកថា អធិករណសមថៈ ដូច្នេះ ។

## សង្គ្រោះវិន័យរបស់ភិក្ខុនីទុកជាពួកៗ

លុះព្រះថេរៈទាំងឡាយ លើកមហាវិភង្គឡើងកាន់សង្គហៈយ៉ាងនេះហើយ ទើបរៀបចំសិក្ខាបទ ៨ ក្នុងភិក្ខុនីវិភង្គទុកថា នេះឈ្មោះបារាជិកកណ្ឌ រៀបចំសិក្ខាបទ ១៧ ទុកថា សត្តរសកណ្ឌ រៀបចំសិក្ខាបទ ៣០ ទុកថា និស្សគ្គិយ-

បាចិត្តិយ រៀបចំសិក្ខាបទ ១៦៦ ទុកជា បាចិត្តិយ រៀបចំសិក្ខាបទ ៨ ទុកជា បាដិទេសនីយ រៀបចំសិក្ខាបទ ៧៥ ទុកជា សេក្ខិយ រៀបចំធម៌ ៧ ប្រការ ទុកជា អធិករណសមថៈ ដូច្នេះ ។

ព្រះថេរៈទាំងឡាយ កាលលើកភិក្ខុនីវិភង្គឡើងកាន់សង្គហៈយ៉ាងនេះហើយ ទើបលើកឡើងនូវខន្ធកៈ និងបរិវារ ( កាន់សង្គាយនា ) ដោយឧបាយនោះឯង ។ ព្រះវិនយបិដក ព្រមទាំងឧភតោវិភង្គក្ខន្ធកៈ និងបរិវារនេះ ព្រះថេរៈទាំងឡាយលើកឡើងកាន់សង្គហៈហើយ ដោយប្រការដូច្នេះ ។

ព្រះមហាកស្សបត្ថេរ បានសួរវិនយបិដកទាំងអស់ ។ ព្រះឧបាលិត្ថេរក៏បានវិសជ្ជនាហើយ ។ ក្នុងទីបំផុតនៃការបុច្ឆា និងវិសជ្ជនា ព្រះអរហន្តចំនួន ៥០០ អង្គ បានធ្វើការស្វាធ្យាយជាគណៈ ដោយន័យដែលលើកឡើងកាន់សង្គហៈនោះឯង ។ ក្នុងអវសាននៃការធ្វើសង្គាយនាព្រះវិន័យ ព្រះឧបាលិត្ថេរដាក់ផ្លិតវាលវីជនីដែលវិចិត្រដោយភ្លុក ហើយចុះអំពីធម្មាសនៈ ថ្វាយបង្គំព្រះថេរៈទាំងឡាយ ហើយគង់លើអាសនៈរបស់ខ្លួន ។

## ចាប់ផ្ដើមសង្គាយនាព្រះសូត្រ

ព្រះមហាកស្សប កាលសង្គាយនាព្រះវិន័យហើយ មានបំណងនឹងសង្គាយនាព្រះធម៌ ទើបសួរភិក្ខុទាំងឡាយថា កាលពួកយើងនឹងសង្គាយនាព្រះធម៌ គួរនឹងធ្វើឲ្យជាធុរៈរបស់ភិក្ខុអង្គណា ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា បពិត្រលោកម្ចាស់ ឲ្យអានន្ទត្ថេរដ៏មានអាយុ ។

# ពាក្យសន្មតបុច្ឆាវិសជ្ជនាព្រះសូត្រ

ឮដ៏កាលនោះ ព្រះមហាកស្សបដ៏មានអាយុ បានផ្ទៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្ម មានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវធម៌ចំពោះអានន្ទដ៏មានអាយុ ។ ព្រះអានន្ទដ៏មានអាយុ បានប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ បើសង្ឃតិកម្មមានកាលគួរដល់សង្ឃហើយ លោកម្ចាស់មហាកស្សបនឹងសួរធម៌ចំពោះខ្ញុំ ខ្ញុំគប្បីឆ្លើយក្នុងកាលឥឡូវនេះ ។

# បុច្ឆា និងវិសជ្ជនាព្រះសូត្រ

លំដាប់នោះឯង ព្រះអានន្ទក្រោកឡើងអំពីអាសនៈ ដណ្តប់ចីវរឆៀងស្មាម្ខាង ថ្វាយបង្គំព្រះថេរៈទាំងឡាយ ហើយគង់លើធម្មាសនៈ ចាប់ផ្ចិតវាលវីជនីដែលវិចិត្រដោយភ្លុក ។ ព្រះមហាកស្សបត្ថេរបានសួរព្រះធម៌ចំពោះព្រះអានន្ទត្ថេរដូច្នេះថា នែអានន្ទដ៏មានអាយុ ព្រហ្មជាលសូត្រ ព្រះដ៏មានព្រះភាគទ្រង់សម្តែងក្នុងទីណា ។

ព្រះអានន្ទឆ្លើយថា បពិត្រព្រះថេរៈដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងក្នុងព្រះដំណាក់នៃព្រះរាជា នៅនាអម្ពលដ្ឋិកាវ័ន ជាចន្លោះនៃក្រុងរាជគ្រឹះផង ជាចន្លោះនៃនាលន្ទាគ្រាមផង ។ ព្រះមហាកស្សបសួរថា ទ្រង់ប្រារព្ធនឹងបុគ្គលណា ព្រះអានន្ទឆ្លើយថា ទ្រង់ប្រារព្ធនឹងសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព ។

គ្រានោះ ព្រះមហាកស្សបដ៏មានអាយុសួរនិទានផង សួរបុគ្គលផង នៃ

ព្រហ្មជាលសូត្រចំពោះអានន្ទដ៏មានអាយុ ។

ហើយព្រះមហាកស្សបសួរតទៅទៀតថា អាវុសោអានន្ទ សាមញ្ញផលសូត្រ ព្រះដ៏មានព្រះភាគទ្រង់សម្តែងក្នុងទីណា ព្រះអានន្ទឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ទ្រង់សម្តែងក្នុងជីវកម្ពវ័ន ក្បែរក្រុងរាជគ្រឹះ ។ ព្រះមហាកស្សបសួរថា ទ្រង់សម្តែងជាមួយនឹងបុគ្គលណា ព្រះអានន្ទឆ្លើយថា ទ្រង់សម្តែងជាមួយនឹងព្រះបាទអជាតសត្តុវេទេហីបុត្រ ។

គ្រានោះ ព្រះមហាកស្សបដ៏មានអាយុ សួរនិទានផង សួរបុគ្គលផងនៃសាមញ្ញផលសូត្រចំពោះព្រះអានន្ទដ៏មានអាយុ ។ ហើយសួរនូវនិកាយទាំង ៥ ដោយឧបាយនេះឯង ដូច្នេះ ។

## និកាយ ៥

ដែលឈ្មោះថា និកាយ មាន ៥ គឺទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។ បណ្តានិកាយទាំងនោះ ព្រះពុទ្ធវចនៈដ៏សេស វៀរលែងតែនិកាយ ៤ចេញ ឈ្មោះថា ខុទ្ទកនិកាយ ។ ក្នុងខុទ្ទកនិកាយនោះ ព្រះវិន័យ ព្រះឧបាលិត្ថេរបានវិសជ្ជនាហើយ ។ ខុទ្ទកនិកាយដ៏សេស និងនិកាយ ៤ ទៀត ព្រះអានន្ទត្ថេរជាអ្នកវិសជ្ជនា ។

## ចំនួនព្រះពុទ្ធវចនៈផ្សេងៗ

ព្រះពុទ្ធវចនៈទាំងអស់នេះ គប្បីជ្រាបថា មានតែ ១ ដោយអំណាចរស មាន ២ ដោយអំណាចធម៌ និងវិន័យ មាន ៣ ដោយអំណាច បឋម មជ្ឈិម បច្ឆិម ម្យ៉ាងទៀត មាន ៣ ដោយអំណាចបិដក មាន ៥ ដោយអំណាចនិកាយ

មាន ៩ ដោយអំណាចអង្គ មាន ៨៤០០០ ដោយអំណាចព្រះធម្មក្ខន្ធ ។

## ពុទ្ធវចនៈមាន ១

ព្រះពុទ្ធវចនៈ ឈ្មោះថា មានតែ ១ ដោយអំណាចរសដូចម្ដេច គឺដោយសភាវៈពិត ព្រះដ៏មានព្រះភាគ បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ដរាបដល់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងរវាងនេះ ទ្រង់ទូន្មានទេវតា មនុស្ស នាគ និងយក្ខ ឬទ្រង់ពិចារណា រហូតដល់អស់វេលា ៤៥ ឆ្នាំ បានត្រាស់ព្រះពុទ្ធវចនៈណាទុក ព្រះពុទ្ធវចនៈទាំងអស់នោះ មានរសតែ ១ គឺវិមុត្តិរសប៉ុណ្ណោះ ។ ព្រះពុទ្ធវចនៈឈ្មោះថា មានតែ ១ ដោយអំណាចរស ដោយប្រការដូច្នេះ ។

## ពុទ្ធវចនៈមាន ២

ព្រះពុទ្ធវចនៈ មាន ២ ដោយអំណាចធម៌ និងវិន័យ ដូចម្ដេច គឺព្រះពុទ្ធវចនៈទាំងអស់នេះឯង រមែងដល់នូវការរាប់ថា ព្រះធម៌ និងព្រះវិន័យ ។ បណ្ដាធម៌ និងវិន័យនោះ វិនយបិដក ឈ្មោះថា វិន័យ ព្រះពុទ្ធវចនៈដ៏សេសឈ្មោះថា ធម៌ ។ ព្រោះហេតុនោះ ទើបព្រះមហាកស្សបបានពោលទុកហើយថា អ្នកដ៏មានអាយុ បើដូច្នោះ ពួកយើងគប្បីសង្គាយនាធម៌ និងវិន័យ ហើយខ្ញុំសួរព្រះវិន័យនឹងឧបាលីដ៏មានអាយុ សួរព្រះធម៌នឹងអានន្ទដ៏មានអាយុ ដូច្នេះ ព្រះពុទ្ធវចនៈ ឈ្មោះថា មាន ២ ដោយអំណាចធម៌ និងវិន័យ ដោយប្រការដូច្នេះ ។

## ពុទ្ធវចនៈមាន ៣

*ព្រះពុទ្ធវចនៈមាន ៣ ដោយអំណាចបឋម មជ្ឈិម និងបច្ឆិម ដូចម្ដេច គឺការពិត ព្រះពុទ្ធវចនៈទាំងអស់នោះឯង ចែកជា ៣ ប្រភេទ គឺបឋមពុទ្ធវចនៈ មជ្ឈិមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ។*

*បណ្ដាពុទ្ធវចនៈ ៣ យ៉ាងនោះ ព្រះពុទ្ធវចនៈថា*

**អនេកជាតិសំសារំ　　សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ　　ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ　　បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា　　គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ　　តណ្ហានំ ខយមជ្ឈគា ។**

*នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ កំពូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ដូច្នេះ នេះឈ្មោះថា បឋមពុទ្ធវចនៈ ។*

*អាចារ្យពួកខ្លះពោលដល់ឧទានគាថា ក្នុងខន្ធកៈថា ធម៌ទាំងឡាយរមែងប្រាកដ ... ក្នុងកាលណា ដូច្នេះជាដើម ឈ្មោះថា បឋមពុទ្ធវចនៈ ។*

*ឯគាថានោះ កើតដល់ព្រះដ៏មានព្រះភាគ ដែលទ្រង់សម្រេចជាព្រះសព្វញ្ញូ ទ្រង់ពិចារណាបច្ចយាការក្នុងព្រះញាណដែលសម្រេចដោយសោម-*

នស្ស ក្នុងថ្ងៃបាដិបទ បណ្ឌិតគប្បីជ្រាបថា ជាឧទានគាថា ។ម្យ៉ាងទៀត ព្រះសម្ពុទ្ធបានត្រាស់ព្រះតម្រាស់ណា ក្នុងកាលបរិនិព្វានថា **ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ** ម្នាលភិក្ខុទាំង-ឡាយ ណើ្ហយចុះ តថាគតប្រាប់អ្នកទាំងឡាយឲ្យបានដឹង សង្ខារទាំងឡាយមានសេចក្ដីសាបសូន្យជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឲ្យសម្រេចដោយការមិនប្រមាទចុះ នេះឈ្មោះថា បច្ឆិមពុទ្ធវចនៈ ។

ពុទ្ធវចនៈ ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងចន្លោះនៃកាលទាំង ២ នោះ ឈ្មោះថា មជ្ឈិមពុទ្ធវចនៈទាំងអស់ ។ ពុទ្ធវចនៈមាន ៣ យ៉ាង ដោយអំណាចបឋម មជ្ឈិម និងបច្ឆិម ដោយប្រការដូច្នេះ ។

## បិដក ៣

ពុទ្ធវចនៈទាំងពួង ចែកជា ៣ ដោយអំណាចនៃបិដក ដូចម្ដេច ។

ព្រះពុទ្ធវចនៈទាំងពួង មាន ៣ ប្រការប៉ុណ្ណោះ គឺវិនយបិដក សុត្តន្ត-បិដក និងអភិធម្មបិដក ។ ក្នុងបិដក ៣ នោះ ពុទ្ធវចនៈ គឺការសង្គ្រោះពុទ្ធវចនៈទាំងអស់ដែលចងក្រងក្នុងបឋមសង្គាយនា និងចងក្រងក្នុងកាលឯក្រោយ ជាបាតិមោក្ខ ២ ចំណែក គឺវិភង្គ ២ ខន្ធកៈ ២២ បរិវារ ១៦ ឈ្មោះវិនយបិដក ។ ពុទ្ធវចនៈ គឺទីឃនិកាយ ដែលសង្គ្រោះព្រះសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម មជ្ឈិមនិកាយ ដែលសង្គ្រោះសូត្រ ១៥២ មានមូល-បរិយាយសូត្រជាដើម សំយុត្តនិកាយ ដែលសង្គ្រោះសូត្រ ៧៧៦២ មាន

ឱឃតរណសូត្រជាដើម អង្គុត្តរនិកាយ ដែលសង្គ្រោះសូត្រ ៩៥៥៧ មាន ចិត្តបរិយាទានសូត្រជាដើម ខុទ្ទកនិកាយ ១៥ ប្រភេទ ដោយអំណាចនៃខុទ្ទក-បាឋៈ ធម្មបទ ឧទាន ឥតិវុត្តកៈ សុត្តនិបាត វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា ជាតក និទ្ទេស បដិសម្ភិទា អបទាន ពុទ្ធវង្ស ចរិយាបិដក ឈ្មោះ សុត្តន្តបិដក ។ ពុទ្ធវចនៈ គឺធម្មសង្គណី វិភង្គ ធាតុកថា បុគ្គលបញ្ញត្តិ កថាវត្ថុ យមកៈ បដ្ឋាន ឈ្មោះអភិធម្មបិដក ។

# អធិប្បាយពាក្យថា វិន័យ

បណ្តាព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្មនោះ ព្រះវិន័យដែលបណ្ឌិត អ្នកដឹងអត្ថនៃព្រះវិន័យទាំងឡាយពោលថា វិន័យ ព្រោះមានន័យផ្សេងៗ ព្រោះមានន័យដ៏ពិសេស និងព្រោះទូន្មាននូវកាយ និងវាចា ។

ពិតហើយ ក្នុងព្រះវិន័យនេះ មានន័យផ្សេងៗ គឺមានបាតិមោក្ខុទ្ទេស ៥ ប្រការ អាបត្តិ ៧ កង មានបារាជិកជាដើម មាតិកា និងន័យ មានវិភង្គជា ដើម ជាប្រភេទ និងន័យ គឺអនុប្បញ្ញត្តិ ជាពិសេស គឺមានន័យដែលធ្វើឲ្យមាំ ទាំ និងធ្វើឲ្យធូរ ជាប្រយោជន៍ ។ ម្យ៉ាងទៀត ព្រះវិន័យនេះ រមែងទូន្មានកាយ និងវាចា ព្រោះហាមឃាត់នូវអជ្ឈាចារផ្លូវកាយ និងផ្លូវវាចា ។ ព្រោះដូច្នោះ ទើបព្រះវិន័យនេះ លោកពោលថា វិន័យ ព្រោះមានន័យផ្សេងៗ ព្រោះមាន ន័យពិសេស និងព្រោះទូន្មានកាយ និងវាចា ។ ព្រោះហេតុនោះ ដើម្បីភាពជា អ្នកឈ្លាសក្នុងអធិប្បាយពាក្យនៃវិន័យនេះ ទើបខ្ញុំពោលគាថាប្រព័ន្ធនេះទុកថា

**វិវិធវិសេសនយត្តា វិនយនតោ ចេវ កាយវាចានំ**

**វិនយត្ថវិទូហិ អយំ វិនយោ វិនយោតិ អក្ខាតោ។**

*ព្រះវិន័យនេះ ដែលបណ្ឌិតដឹងអត្ថនៃព្រះវិន័យទាំងឡាយ ពោលថា វិន័យ ព្រោះមានន័យផ្សេងៗ ព្រោះមានន័យពិសេស និងព្រោះទូន្មានកាយ និងវាចា ដូច្នេះ ។*

## អធិប្បាយពាក្យថា សូត្រ

*ចំណែកព្រះសូត្រក្រៅពីនេះ លោកពោលថា សូត្រ ព្រោះប្រាប់ដល់ប្រយោជន៍ ព្រោះមានអត្ថដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយ ព្រោះនាំមកនូវប្រយោជន៍ ព្រោះបង្ហូរមកនូវប្រយោជន៍ ព្រោះការពារដោយល្អ និងព្រោះមានចំណែកស្មើដោយសរសៃអំបោះ ។*

*ពិតហើយ ព្រះសូត្រនោះ រមែងបង្ហាញនូវប្រយោជន៍ផ្សេងៗ ដោយប្រយោជន៍ មានប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃជាដើម ។ មួយវិញទៀត ប្រយោជន៍ទាំងឡាយដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយ ក្នុងព្រះសូត្រនេះ ព្រោះត្រាស់ដោយអនុលោមដល់អជ្ឈាស្រ័យរបស់វេនេយ្យសត្វម្យ៉ាងទៀតព្រះសូត្រនេះរមែងនាំមកនូវប្រយោជន៍ លោកអធិប្បាយថា រមែងនាំមកនូវផលដូចស្រូវ ដូច្នោះ ។*

*ម្យ៉ាងទៀត ព្រះសូត្រនេះ រមែងហូរមកនូវប្រយោជន៍ទាំងនោះ លោកអធិប្បាយថា រមែងហូរដូចមេគោបង្ហូរទឹកដោះ ដូច្នោះ។ ម្យ៉ាងទៀត ព្រះសូត្រនេះ រមែងការពារ លោកអធិប្បាយថា រមែងរក្សាដោយល្អនូវប្រយោជន៍ទាំង*

នោះ ។ ម្យ៉ាងទៀត ព្រះសូត្រនេះ មានចំណែកស្មើដោយសរសៃអំបោះ ។

ឧបមាដូចជាសរសៃខ្សែបន្ទាត់ រមែងជាប្រមាណរបស់ជាងឈើ យ៉ាងណា សូម្បីព្រះសូត្រនេះ ក៏រមែងជាប្រមាណនៃវិញ្ញូជន យ៉ាងនោះ ។ ម្យ៉ាងទៀត ដូចផ្កាឈើដែលគេក្រងទុកដោយសរសៃអំបោះ ដែលខ្យល់ធ្វើឲ្យរាត់រាយ ខ្ចាត់ខ្ចាយមិនបាន យ៉ាងណា ប្រយោជន៍ទាំងឡាយ ដែលទ្រង់ប្រមូលទុកដោយព្រះសូត្រនេះ រមែងមិនរាត់រាយ មិនខ្ចាត់ខ្ចាយ យ៉ាងនោះ ។ ដោយហេតុនោះ ដើម្បីភាពជាអ្នកឈ្លាសក្នុងអធិប្បាយពាក្យនៃព្រះសូត្រនេះ ទើបខ្ញុំពោលគាថាប្រព័ន្ធនេះទុកថា

**អត្ថានំ សូចនតោ សុវុត្តតោ សវនតោថ សូទនតោ**

**សុត្តាណា សុត្តសភាគតោ ច សុត្តន្តិ អក្ខាតំ ។**

ព្រះសូត្រលោកពោលថា សុត្តៈ ព្រោះប្រាប់នូវប្រយោជន៍ ព្រោះមានអត្ថដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ល្អហើយ ព្រោះនាំមកនូវប្រយោជន៍ ព្រោះហូរមកនូវប្រយោជន៍ ព្រោះការពារដោយល្អ និងព្រោះមានចំណែកស្មើដោយអំបោះ ដូច្នេះ ។

# អធិប្បាយពាក្យថា អភិធម្ម

ចំណែកព្រះអភិធម្ម ដែលក្រៅអំពីនេះ ព្រោះធម៌ទាំងឡាយដែលមានសេចក្ដីចម្រើន ដែលមានការកំណត់ដឹង ដែលបុគ្គលគោរពបូជា ដែលបណ្ឌិតកំណត់ហើយ និងដែលក្រៃលែង ដែលព្រះដ៏មានព្រះភាគត្រាស់ទុកហើយក្នុងព្រះអភិធម្មនេះ ដូច្នោះ ទើបលោកពោលថា អភិធម្ម ។

**អភិ** សព្ទនេះ រមែងប្រាកដក្នុងអត្ថថា ចម្រើន ប្រាកដក្នុងអត្ថថា មានការកំណត់ដឹង ប្រាកដក្នុងអត្ថថា ដែលបុគ្គលបូជាហើយ ប្រាកដក្នុងអត្ថថា ដែលបណ្ឌិតសម្រេចហើយ និងប្រាកដក្នុងអត្ថថា ក្រៃលែង ។ ពិតហើយ **អភិ** សព្ទនេះ មកក្នុងអត្ថថា ចម្រើន ដូចពាក្យជាដើមថា **ពាឡ្ហា មេ អាវុសោ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ** ទុក្ខវេទនារបស់ខ្ញុំព្រះអង្គធ្ងន់ណាស់ តែងចម្រើនឡើង ដូច្នេះ ។ មកក្នុងអត្ថថា មានការកំណត់ដឹង ដូចពាក្យជាដើមថា **យា តា រត្តិយោ អភិញ្ញាតា អភិលក្ខិតា** រាត្រីទាំង-ឡាយណាដែលគេដឹងច្បាស់ ដែលគេកំណត់ដឹង ដូច្នេះ ។ មកក្នុងអត្ថថា ដែលបុគ្គលគោរពបូជា ដូចពាក្យថា **រាជាភិរាជា មនុជិន្ទោ** បពិត្រព្រះគោតម ព្រះអង្គជាស្តេចដែលពួកស្តេចគោរពបូជា ជាធំជាងពួកមនុស្សជាដើម ។ មកក្នុងអត្ថថា ដែលបណ្ឌិតកំណត់ហើយ ដូចពាក្យជាដើមថា **បដិពលោ វិនេតុំ អភិធម្មេ អភិវិនយេ** ភិក្ខុអាចដើម្បីទូន្មានអន្តេវាសិក ឬសទ្ធិវិហារិកក្នុងអភិធម្ម ក្នុងអភិវិន័យ លោកអធិប្បាយថា ជាអ្នកអាចណែនាំក្នុងធម៌ និងវិន័យដែលវៀរចាកសេចក្តីប្របូកប្របល់លាយឡំគ្នានឹងគ្នា ។ មកក្នុងអត្ថថា ក្រៃលែង ដូចក្នុងពាក្យជាដើមថា **អភិក្កន្តេន វណ្ណេន** មានសម្បុរល្អក្រៃលែង ដូច្នេះ ។

ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ទាំងឡាយ ក្នុងព្រះអភិធម្មនេះ មានការចម្រើនខ្លះ ដោយន័យជាដើមថា **រូបូបបត្តិយា មគ្គំ** បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព **មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ** ភិក្ខុមានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសមួយ ។ ឈ្មោះថា

មានការកំណត់ដឹងខ្លះ ព្រោះជាធម៌គួរកំណត់បានដោយកម្មទ្វារ និងបដិបទាដែលសម្បយុត្តដោយអារម្មណ៍ជាដើម ដោយន័យជាដើមថា **រូបារម្មណំ វា សទ្ទារម្មណំ វា** ចិត្ត ... មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី ។ ដែលបុគ្គលបូជាហើយ អធិប្បាយថា គួរបូជា ដោយន័យជាដើមថា **សេក្ខា ធម្មា អសេក្ខា ធម្មា** ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខ-បុគ្គល **លោកុត្តរា ធម្មា** ពួកធម៌ជាលោកុត្តរ ។ ឈ្មោះថា ជាធម៌ដែលបណ្ឌិតកំណត់សម្រេចខ្លះ ព្រោះជាធម៌ដែលលោកកំណត់តាមសភាវៈ ដោយន័យជាដើមថា **តស្មិំ សមយេ ផស្សោ ហោតិ វេទនា ហោតិ** ផស្សៈកើតមានក្នុងសម័យនោះ វេទនាកើតមាន ។ សូម្បីធម៌ទាំងឡាយដ៏ក្រៃលែង ទ្រង់ត្រាស់ទុកដោយន័យជាដើមថា **មហគ្គតា ធម្មា អប្បមាណា ធម្មា** ពួកធម៌ដល់នូវភាពជាធំ ពួកធម៌ប្រមាណមិនបាន **អនុត្តរា ធម្មា** ពួកធម៌មិនមានឧត្តរៈ។ ព្រោះហេតុនោះ ដើម្បីភាពជាអ្នកឈ្លាសក្នុងអធិប្បាយនៃពាក្យអភិធម្មនេះ ទើបខ្ញុំពោលគាថាប្រព័ន្ធនេះទុកថា

**យំ ឯត្ថ វុឌ្ឍិមន្តោ សលក្ខណា បូជិតា បរិច្ឆិន្នា**
**វុត្តាធិកា ច ធម្មា អភិធម្មោ តេន អក្ខាតោ ។**

ព្រះអភិធម្ម បណ្ឌិតពោលថា ព្រោះអភិធម្មនេះ ព្រះដ៏មានព្រះភាគត្រាស់ដល់ធម៌ដែលចម្រើន ១ ធម៌ដែលគួរកំណត់ដឹង ១ ធម៌ដែលគួរបូជា ១ ធម៌ដែលកាត់សម្រេចទុក ១ និងធម៌ដ៏ក្រៃលែង ១ ។

ចំណែក **បិដក** សព្ទណា ជាសព្ទដែលមិនពិសេសក្នុងព្រះវិន័យ ព្រះ

សូត្រ និងព្រះអភិធម្មនេះ **បិដក** សព្ទនោះ ដែលបណ្ឌិតទាំងឡាយដឹងអត្ថនៃបិដក ពោលថា

**បិដកំ បិដកត្ថវិទូ បរិយត្តិព្ភាជនត្ថតោ អាហុ**

**តេន សមោធានេត្វា តយោបិ វិនយាទយោ ញេយ្យា ។**

បិដក ដោយអត្ថថា បរិយត្តិ និងភាជនៈ សព្ទទាំង ៣ មានវិន័យជាដើម បណ្ឌិតគប្បីឲ្យប្រជុំចុះ ដោយ **បិដក** សព្ទនោះហើយ ទើបជ្រាប ។

## បិដកប្រៀបដូចកញ្ជើ ឬ ល្អី

ពិតហើយ សូម្បីបរិយត្តិ លោកក៏ហៅថា បិដក ដូចពាក្យទាំងឡាយជាដើមថា **មា បិដកសម្បទានេន** កុំប្រកាន់ជឿដោយការអាងក្បួនតម្រា ។ សូម្បីភាជនៈឯណានីមួយ ក៏លោកហៅថា បិដក ដូចពាក្យជាដើមថា **អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ** កាលនោះបុរសម្នាក់កាន់ចប និងកញ្ជើដើរមក ។ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយដែលដឹងអត្ថនៃបិដក ពោលថា បិដក ដោយអត្ថថា បរិយត្តិ និងភាជនៈ ។

ឥឡូវនេះ គប្បីជ្រាបអត្ថនៃបាទគាថាថា **តេន សមោធានេត្វា តយោបិ វិនយាទយោ ញេយ្យា** ដោយន័យយ៉ាងនេះ សូម្បីសព្ទទាំង ៣ មានវិន័យជាដើមនោះ ដែលបណ្ឌិតគប្បីសង្គ្រួបចូលជាសមាសជាមួយនឹងបិដកសព្ទ ដែលមានអត្ថ ២ យ៉ាងនោះហើយ គប្បីជ្រាបយ៉ាងនេះថា វិន័យនោះផង ឈ្មោះថា បិដកផង ព្រោះជាបរិយត្តិ និងព្រោះជាភាជនៈនៃអត្ថនោះៗ ហេតុនោះ ទើបឈ្មោះថា វិនយបិដក សុត្តៈផង ឈ្មោះថា បិដកផង ដោយន័យតាមដែល

ពោលហើយនោះឯង ហេតុនោះ ទើបឈ្មោះថា សុត្តន្តបិដក អភិធម្មនោះផង ឈ្មោះថា បិដកផង ដោយន័យតាមដែលពោលហើយនោះឯង ហេតុនោះ ទើបឈ្មោះថា អភិធម្មបិដក ។ កាលជ្រាបយ៉ាងនេះហើយ ដើម្បីភាពជាអ្នកឈ្លាសដោយប្រការផ្សេងៗ ក្នុងបិដកទាំងនោះទៀត ដូចគាថានេះថា

បណ្ឌិតគប្បីសម្តែងសេចក្តីផ្សេងគ្នានៃទេសនា សាសនា កថា សិក្ខា បហាន គម្ភីរភាពក្នុងបិដកទាំងនោះ តាមសមគួរ ភិក្ខុរមែងដល់នូវភាពផ្សេងគ្នានៃបរិយត្តិក្តី សម្បត្តិ និងវិបត្តិក្តីឯណា ក្នុងបិដកណា មានវិន័យបិដកជាដើម ដោយប្រការណា បណ្ឌិតគប្បីប្រកាសភាពផ្សេងគ្នានៃបរិយត្តិជាដើមទាំងអស់នោះ ដោយប្រការនោះ ។

វាចាជាគ្រឿងសម្តែង និងវាចាជាគ្រឿងប្រកាសក្នុងបិដកទាំង ៣ នោះ ដូចតទៅនេះថា

ពិតហើយ បិដកទាំង ៣ នេះ លោកហៅថា អាណាទេសនា វោហារទេសនា បរមត្ថទេសនា និងយថាបរាធសាសនៈ យថានុលោមសាសនៈ យថាធម្មសាសនៈ សំវរាសំវរកថា ទិដ្ឋិវិនិវេដ្ឋនកថា និងនាមរូបបរិច្ឆេទកថា តាមលំដាប់ ។ ពិតហើយ បណ្តាបិដកទាំង ៣ នោះ វិនយបិដក លោកឲ្យឈ្មោះថា អាណាទេសនា ព្រោះព្រះដ៏មានព្រះភាគ ជាបុគ្គលគួរដល់អាណា ទ្រង់សម្តែងទុកជាបិដក ច្រើនដោយអាណា សុត្តន្តបិដក លោកឲ្យឈ្មោះថា វោហារទេសនា ព្រោះព្រះដ៏មានព្រះភាគ ជាបុគ្គលឈ្លាសក្នុងវោហារ ទ្រង់សម្តែងទុកជាបិដក ច្រើនដោយវោហារ អភិធម្មបិដក លោកឲ្យ

ឈ្មោះថា បរមត្ថទេសនា ព្រោះព្រះដ៏មានព្រះភាគ ទ្រង់ឈ្លាសក្នុងបរមត្ថ ទ្រង់សម្តែងទុកជាបិដក ច្រើនដោយបរមត្ថ ។ ម្យ៉ាងទៀត បឋមបិដក លោកឲ្យឈ្មោះថា យថាបរាធសាសនៈ ព្រោះសត្វទាំងឡាយដែលជាបុគ្គលធ្វើខុសច្រើននោះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រៀនប្រដៅតាមកំហុសក្នុងបិដកនេះ ។ បិដកទី ២ លោកឲ្យឈ្មោះថា យថានុលោមសាសនៈ ព្រោះសត្វទាំងឡាយដែលមានអជ្ឈាស្រ័យ អនុស័យ ចរិយា និងអធិមុត្តិ មិនមែនដូចគ្នា ព្រះដ៏មានព្រះភាគទ្រង់ទូន្មានតាមសមគួរក្នុងបិដកនេះ បិដកទី ៣ លោកឲ្យឈ្មោះថា យថាធម្មសាសនៈ ព្រោះសត្វទាំងឡាយ ជាបុគ្គលមានការសម្គាល់ក្នុងវត្ថុដែលត្រឹមតែជាគំនរធម៌ ថាអញ ថារបស់អញ ព្រះដ៏មានព្រះភាគទ្រង់ទូន្មានតាមធម៌ក្នុងបិដកនេះ ។ ម្យ៉ាងទៀត បិដកដំបូង លោកឲ្យឈ្មោះថា សំវរាសំវរកថា ព្រោះការសង្រួមតូចធំ ដែលជាបដិបក្ខចំពោះការល្មើស ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកក្នុងបិដកនេះ បិដកទី ២ លោកឲ្យឈ្មោះថា ទិដ្ឋិវិនិវេដ្ឋនកថា ព្រោះការកម្ចាត់ទិដ្ឋិ ដែលជាបដិបក្ខចំពោះទិដ្ឋិ ៦២ ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងបិដកនេះ បិដកទី ៣ លោកឲ្យឈ្មោះថា នាមរូបបរិច្ឆេទកថា ព្រោះការកំណត់នាមរូបដែលជាបដិបក្ខចំពោះកិលេស មានរាគៈជាដើម ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងបិដកនេះ ។ ក្នុងបិដកទាំង ៣ នេះ បណ្ឌិតគប្បីជ្រាបសិក្ខា ៣ បហាន ៣ គម្ភីរភាព ៤ ប្រការ ។ ពិតហើយ អធិសីលសិក្ខា លោកពោលទុកដោយពិសេសក្នុងព្រះវិនយបិដក អធិចិត្តសិក្ខា លោកពោលទុកពិសេសក្នុងព្រះសុត្តន្តបិដក អធិប្បញ្ញាសិក្ខា លោកពោលទុកដោយ

ពិសេស ក្នុងព្រះអភិធម្មបិដក ។ ម្យ៉ាងទៀត ការលះបង់វីតិក្កមកិលេស លោកពោលទុកក្នុងវិនយបិដក ព្រោះសីលជាបដិបក្ខចំពោះការល្មើសនៃកិលេសទាំងឡាយ ការលះបរិយុដ្ឋានក្កិលេស លោកពោលទុកក្នុងព្រះសុត្តន្ត-បិដក ព្រោះសមាធិជាបដិបក្ខចំពោះបរិយុដ្ឋានក្កិលេស ការលះអនុសយក្កិលេស លោកពោលទុកក្នុងអភិធម្មបិដក ព្រោះបញ្ញាជាបដិបក្ខចំពោះអនុសយក្កិលេស ម្យ៉ាងទៀត ការលះកិលេសទាំងឡាយដោយអង្គនោះៗ លោកពោលទុកក្នុងបិដកទី ១ ការលះដោយការសង្កត់ទុក និងជាសមុច្ឆេទ លោកពោលទុកក្នុងបិដកពីរក្រៅអំពីនេះ ។ ម្យ៉ាងទៀត ការលះសង្កិលេស គឺទុច្ចរិត លោកពោលទុកក្នុងបិដកទី ១ ការលះកិលេស គឺតណ្ហា និងទិដ្ឋិ លោកពោលទុកក្នុងបិដកពីរក្រៅអំពីនេះ ។ បណ្ឌិតគប្បីជ្រាបពុទ្ធវចនៈមួយបែបៗ ជាគុណជាតជ្រាលជ្រៅដោយធម៌ ដោយអត្ថ ដោយទេសនា និងដោយបដិវេធទាំង ៤ យ៉ាង ក្នុងបិដកទាំងនេះ ដូច្នេះ ។

## អធិប្បាយ គម្ភីរភាព ៤ យ៉ាង

បណ្ដាគម្ភីរភាពទាំង ៤ នោះ ព្រះបាលីឈ្មោះថា ធម៌ ។ សេចក្ដីនៃព្រះបាលីនោះឯង ឈ្មោះថា អត្ថ ។ ការសម្ដែងព្រះបាលីដែលកំណត់ទុកដោយចិត្តនោះ ឈ្មោះថា ទេសនា ។ ការចាក់ធ្លុះនូវព្រះបាលី និងអត្ថនៃព្រះបាលីតាមសេចក្ដីពិត ឈ្មោះថា បដិវេធ ។ ក៏ព្រោះក្នុងបិដកទាំង ៣ នេះ ធម៌ អត្ថ ទេសនា និងបដិវេធទាំងនេះ ដែលបុគ្គលមានបញ្ញាថោកថយទាំងឡាយចាក់ធ្លុះបានលំបាក និងមានទីតាំងអាស្រ័យដែលពួកបុគ្គលនោះ មិនគប្បីបាន

ដូចមហាសមុទ្រដែលសត្វទាំងឡាយ មានទន្សាយជាដើមប្រមាណបានលំបាក ព្រោះដូច្នោះ ទើបរាប់ថាជាគុណជាតជ្រាលជ្រៅ ។ ឯបណ្ឌិតគប្បីជ្រាបគម្ពីរ-ភាពទាំង ៤ ក្នុងបិដកទាំង ៣ នេះ ក្នុងបិដកនីមួយៗដោយប្រការដូច្នេះ ។

## អធិប្បាយគម្ភីរភាពន័យម្យ៉ាងទៀត

ម្យ៉ាងទៀត ហេតុ ឈ្មោះថា ធម៌ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា **ហេតុម្ហិ ញាណំ ធម្មប្បដិសម្ភិទា** ការដឹងក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា ។ ផលនៃហេតុ ឈ្មោះថា អត្ថ សមដូចព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា **ហេតុផលេ ញាណំ អត្ថប្បដិសម្ភិទា** ការដឹងក្នុងផលនៃហេតុ ឈ្មោះថា អត្ថប្បដិសម្ភិទា ។ បញ្ញត្តិ អធិប្បាយថា ការសន្ទនាធម៌តាមធម៌ ឈ្មោះថា ទេសនា ។ ការត្រាស់ដឹង ឈ្មោះថា បដិវេធ ។ បដិវេធនោះ ទាំងលោកិយ និងលោកុត្តរ គឺការដឹង សង្គ្រោះចូលក្នុងធម៌តាមសមគួរដល់អត្ថ ក្នុងអត្ថតាមសមគួរដល់ធម៌ ក្នុងបញ្ញត្តិតាមសមគួរដល់គន្លងនៃបញ្ញត្តិ ដោយវិស័យ និងដោយការមិនវង្វេង ។

ឥឡូវនេះ គួរជ្រាបគម្ភីរភាពទាំង ៤ ប្រការ ក្នុងបិដកទាំង ៣ នេះ ក្នុងបិដកនីមួយៗ ព្រោះហេតុដែលធម្មជាតិ ឬអត្ថជាតិណាមួយក្តី អត្ថដែលព្រះដ៏មានព្រះភាគគប្បីឲ្យជ្រាប រមែងជាអត្ថមានមុខចំពោះញាណរបស់អ្នកសិក្សាទាំងឡាយ ដោយប្រការណាមួយ ទេសនាដែលធ្នុះបញ្ចាំងអត្ថនោះ ឲ្យភ្លឺច្បាស់ដោយប្រការនោះៗ ក្តី បដិវេធ គឺការចាក់ធ្លុះ មិនវិបរិតក្នុងធម៌ អត្ថ និងទេសនាក្តី ក្នុងបិដកទាំងនេះ ធម៌ អត្ថ ទេសនា និងបដិវេធទាំងនេះ ដែល

បុគ្គលអ្នកមានបញ្ញាថោកថយទាំងឡាយ មិនមែនបុគ្គលមានកុសលសម្ភារបានសន្សំទុក គប្បីពិចារណាដឹងបានលំបាក និងមានទីអាស្រ័យមិនបាន ដូចមហាសមុទ្រដែលសត្វទាំងឡាយ មានទន្សាយជាដើមស្ទង់បានលំបាក ដូច្នោះ ដូចព្រះគាថានេះថា

**ទេសនាសាសនកថា ភេទំ តេសុ យថារហំ**
**សិក្ខាបហានគម្ភីរ ភាវញ្ច បរិទីបយេ ។**

បណ្ឌិតគប្បីសម្ដែងសេចក្ដីផ្សេងគ្នានៃទេសនា សាសនា កថា សិក្ខាបហាន គម្ពីរភាព ក្នុងបិដកទាំងនោះតាមសមគួរ ដូច្នេះ ដែលខ្ញុំពង្រីកសេចក្ដីហើយដោយពាក្យត្រឹមប៉ុណ្ណេះ ។ និងដូចព្រះគាថានេះថា

**បរិយត្តិភេទំ សម្បត្តឹ វិបត្តិញ្ចាបិ យំ យហឹ**
**ទាបុណាតិ យថា ភិក្ខុ តម្បិ សព្វំ វិភាវយេ ។**

ភិក្ខុរមែងដល់នូវសេចក្ដីផ្សេងគ្នានៃបរិយត្តិក្ដី សម្បត្តិ និងវិបត្តិក្ដីឯណា ក្នុងបិដកណា មានវិនយបិដកជាដើម ដោយប្រការណា បណ្ឌិតគប្បីប្រកាសការផ្សេងគ្នានៃបរិយត្តិជាដើមទាំងឡាយនោះ ដោយប្រការនោះ ដូច្នេះ ។

បណ្ឌិតគប្បីឃើញការផ្សេងគ្នានៃបរិយត្តិ ៣ យ៉ាង ក្នុងបិដក ៣ ដូច្នេះ ។

## បរិយត្តិ ៣ យ៉ាង

ពិតហើយ បរិយត្តិ ៣ គឺអលគទ្ទូបមបរិយត្តិ ១ និស្សរណត្ថបរិយត្តិ ១ ភណ្ឌាគារិយបរិយត្តិ ១ ក្នុងបរិយត្តិ ៣ នោះ បរិយត្តិណាដែលបុគ្គលសិក្សាមិនល្អ គឺសិក្សាព្រោះហេតុ មានការប្រកួតប្រជែងជាដើម បរិយត្តិនេះ

ឈ្មោះថា បរិយត្តិប្រៀបដូចអាសិរពិស ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ដូចបុរសអ្នកត្រូវការដោយពស់វែក ស្វែងរកពស់វែក ក៏ត្រាច់ទៅស្វែងរកពស់វែក បុរសនោះបានឃើញពស់វែក ១ យ៉ាងធំ ហើយក៏ចាប់ពស់វែកនោះត្រង់ខ្លួន ឬកន្ទុយ ពស់វែកនោះ ក៏ងាកមកចឹកបុរសនោះត្រង់ដៃ ឬដើមដៃ ឬអវយវៈតូចធំណាមួយ បុរសនោះក៏ដល់នូវសេចក្ដីស្លាប់ ឬដល់នូវសេចក្ដីទុក្ខជិតតែនឹងស្លាប់ ព្រោះមានពស់វែកនោះជាហេតុ ដំណើរនោះតើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ពស់វែក បុរសនោះចាប់មិនស្រួល ម្នាលភិក្ខុទាំងឡាយ មានមោឃបុរសពួកខ្លះ ក្នុងសាសនានេះ រៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ លុះមោឃបុរសទាំងនោះរៀនធម៌នោះហើយ មិនបានពិចារណានូវសេចក្ដីនៃធម៌ទាំងនោះដោយប្រាជ្ញា ធម៌ទាំងឡាយនោះ ដែលមោឃបុរសទាំងនោះ មិនបានពិចារណានូវសេចក្ដីដោយប្រាជ្ញាហើយ ក៏មិនប្រាកដច្បាស់ក្នុងចិត្ត មោឃបុរសទាំងនោះ រៀនធម៌ដោយមានបំណងតែខាងលើកទោសគេផង ដោយមានបំណងតែខាងដោះស្រាយនូវវាទៈ ដូច្នេះ ដូច្នោះផង កុលបុត្រទាំងឡាយរៀនធម៌ដើម្បីប្រយោជន៍ណា ពួកមោឃបុរសនោះ ក៏មិនបាននូវប្រយោជន៍នោះរបស់ធម៌នោះឡើយ ធម៌ទាំងឡាយនោះ ដែលមោឃបុរសទាំងនោះរៀនមិនល្អហើយ ក៏ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលយូរអង្វែង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ធម៌ទាំងឡាយដែលមោឃបុរសរៀន មិនល្អហើយយ៉ាងនេះឯង ។

មួយទៀត បរិយត្តិដែលបុគ្គលរៀនល្អហើយ គឺប្រាថ្នានូវភាពបរិបូណ៌នៃគុណ មានសីលក្ខន្ធជាដើមនោះឯង រៀនហើយ មិនរៀនព្រោះហេតុ មានការប្រកែកប្រណាំងជាដើម បរិយត្តិនេះ ឈ្មោះថា បរិយត្តិមានប្រយោជន៍ ដែលនឹងចេញចាកវដ្តៈ ដូចព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកុលបុត្រពួកខ្លះ រៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ កុលបុត្រទាំងនោះ លុះរៀនធម៌នោះហើយ ក៏ពិចារណានូវសេចក្តីនៃធម៌ទាំងឡាយនោះដោយប្រាជ្ញា ធម៌ទាំងនោះ លុះកុលបុត្រទាំងនោះពិចារណានូវសេចក្តីដោយប្រាជ្ញាហើយ ក៏ប្រាកដច្បាស់ក្នុងចិត្ត កុលបុត្រទាំងនោះ មិនមែនរៀនធម៌ដោយមានបំណងតែខាងលើកទោសគេផង មិនមែនរៀនធម៌ដោយមានបំណងតែខាងដោះស្រាយវាទៈ ដូច្នេះ ដូច្នោះផង កុលបុត្រឯទៀត រៀនធម៌ដើម្បីប្រយោជន៍ណា កុលបុត្រទាំងនោះ ក៏បាននូវប្រយោជន៍នោះរបស់ធម៌នោះ ធម៌ទាំងនោះដែលកុលបុត្រពួកនោះរៀនល្អហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរអង្វែង ដំណើរនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែធម៌ទាំងឡាយដែលកុលបុត្រទាំងនោះបានរៀនដោយល្អ ដូច្នេះ ។

ចំណែកព្រះខីណាស្រព ដែលមានខន្ធកំណត់ដឹងហើយ មានកិលេសដែលលះបង់ហើយ មានមគ្គដែលអប់រំល្អហើយ មានធម៌ដែលមិនកម្រើកចាក់ធ្លុះហើយ មាននិរោធដែលធ្វើឲ្យជាក់ច្បាស់ហើយ រមែងរៀននូវបរិយត្តិណា ដើម្បីតាំងនៅនៃបវេណី ដើម្បីតាមរក្សានូវវង្សបរិយត្តិ នេះឈ្មោះថា ភណ្ឌាគា-

វិយបរិយត្តិ ។

## ភិក្ខុដែលបដិបត្តិល្អ
## ក្នុងបិដក ៣ បានផលល្អផ្សេងគ្នា

ម្យ៉ាងទៀត ភិក្ខុដែលបដិបត្តិក្នុងព្រះវិន័យអាស្រ័យសីលសម្បត្តិ រមែងបានសម្រេចវិជ្ជា ៣ ព្រោះទ្រង់ត្រាស់ចែកប្រភេទវិជ្ជា ៣ ទាំងនោះៗ ឯង ទុកក្នុងព្រះវិន័យនោះ ។ បុគ្គលអ្នកបដិបត្តិល្អក្នុងព្រះសូត្រ អាស្រ័យសមាធិសម្បត្តិ រមែងបានសម្រេចអភិញ្ញា ៦ ព្រោះអាស្រ័យការចែកប្រភេទអភិញ្ញាទាំង ៦ នោះ ទុកក្នុងព្រះសូត្រនោះ ។ បុគ្គលបដិបត្តិល្អក្នុងព្រះអភិធម្មអាស្រ័យបញ្ញាសម្បត្តិ រមែងសម្រេចបដិសម្ភិទា ៤ ព្រោះទ្រង់ត្រាស់ចែកប្រភេទបដិសម្ភិទា ៤ នោះទុកក្នុងព្រះអភិធម្មនោះឯង ។ បុគ្គលបដិបត្តិល្អក្នុងបិដកទាំងនេះ រមែងសម្រេចសម្បត្តិផ្សេងគ្នា គឺវិជ្ជា ៣ អភិញ្ញា ៦ និងបដិសម្ភិទា ៤ នេះតាមលំដាប់ ដោយប្រការដូច្នេះ ។

## បុគ្គលអ្នកបដិបត្តិមិនល្អក្នុងបិដក ៣
## បានផលអាក្រក់ផ្សេងគ្នា

ភិក្ខុបដិបត្តិមិនល្អក្នុងព្រះវិន័យ រមែងមានការសម្គាល់ថា មិនមានទោសក្នុងផស្សៈទាំងឡាយ មានការប៉ះពាល់នូវរូបជាឧបាទិន្នកជាដើម ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហាមហើយ ដោយភាពជាអាការស្មើគ្នានឹងការប៉ះពាល់វត្ថុ មានកម្រាល និងសំពត់ដណ្តប់ជាដើម ដែលមានសម្ផស្សជាសុខ ដែល

ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ ។ សេចក្ដីនេះ សមដូចពាក្យដែលអរិដ្ឋភិក្ខុពោលថា ធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសម្ដែងថា តែងធ្វើនូវសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសម្ដែងហើយ ដោយប្រការដូច្នោះ ដូច្នេះ ។ ភិក្ខុនោះ រមែងដល់នូវភាពជាបុគ្គលទ្រុស្តសីល ព្រោះការបដិបត្តិមិនល្អនោះ ។

ភិក្ខុដែលបដិបត្តិមិនល្អក្នុងព្រះសូត្រ មិនដឹងនូវអធិប្បាយក្នុងព្រះបាលីជាដើមថា ម្នាលភិក្ខុទាំងឡាយ បុគ្គល ៤ ពួកនេះ រមែងមាន ដូច្នេះ រមែងប្រកាន់ខុស ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ឈ្មោះថា ពោលចង្អាច់តថាគតផង ឈ្មោះថា គាស់រំលើងនូវខ្លួនឯងផង ឈ្មោះថា ទទួលនូវបាបដ៏ច្រើនផង ព្រោះអំពើដែលខ្លួនប្រកាន់អាក្រក់ ដូច្នេះ ភិក្ខុនោះ រមែងដល់នូវភាពជាអ្នកមានទិដ្ឋិខុស ព្រោះការប្រកាន់នោះ ។

ភិក្ខុដែលបដិបត្តិមិនល្អក្នុងព្រះអភិធម្ម ពិចារណាធម៌ជ្រៅហួសពេក រមែងគិតនូវរឿងដែលមិនគួរគិត រមែងដល់នូវការរាយមាយនៃចិត្ត ព្រោះគិតនូវរឿងដែលមិនគួរគិតនោះ ។ សេចក្ដីនេះ សមដូចព្រះពុទ្ធវចនៈដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អចិន្តេយ្យ ហេតុដែលមិនគួរគិតមាន ៤ ប្រការដែលបុគ្គលមិនគួរគិតទេ តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួត និងសេចក្ដីលំបាក ដូច្នេះ ។ ភិក្ខុបដិបត្តិមិនល្អក្នុងបិដក ៣ នេះ រមែងដល់នូវវិបត្តិផ្សេង ៗ ដោយភាពជាបុគ្គលទ្រុស្តសីល ជាបុគ្គលមានមិច្ឆាទិដ្ឋិ

និងសេចក្ដីវិវែកចិត្តតាមលំដាប់ ដោយប្រការដូច្នេះ ដូចព្រះគាថានេះថា

**បរិយត្តិភេទំ សម្បត្តឹ វិបត្តឹ ចាបិ យំ យហឹ**

**ចាបុណាតិ យថា ភិក្ខុ តម្បិ សព្វំ វិភាវយេ ។**

ភិក្ខុរមែងដល់នូវសេចក្ដីផ្សេងគ្នានៃបរិយត្តិក្ដី សម្បត្តិ និងវិបត្តិក្ដី យ៉ាងណា ក្នុងបិដកណា មានវិនយបិដកជាដើម ដោយប្រការណា បណ្ឌិតគប្បីប្រកាសសេចក្ដីផ្សេងគ្នា នៃបរិយត្តិជាដើមទាំងអស់នោះ ដោយប្រការនោះដូច្នេះ ។

ការដែលខ្ញុំពង្រីកសេចក្ដីហើយ ដោយពាក្យត្រឹមប៉ុណ្ណេះ ។ បណ្ឌិតកាលជ្រាបបិដកដោយប្រការផ្សេងៗ យ៉ាងនោះហើយ ក៏គួរជ្រាបព្រះពុទ្ធវចនៈនោះថា មាន ៣ យ៉ាង ដោយអំណាចនៃបិដកទាំងឡាយនោះ ។

## ព្រះពុទ្ធវចនៈមាន ៥ និកាយ

ព្រះពុទ្ធវចនៈមាន ៥ ដោយអំណាចនៃនិកាយដូចម្ដេច ពិតហើយ ពុទ្ធវចនៈទាំងអស់នោះឯង រមែងមាន ៥ ប្រភេទ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ ។

## ទីឃនិកាយ ៣៤ សូត្រ

បណ្ដានិកាយទាំង ៥ នោះ ទីឃនិកាយដូចម្ដេច ព្រះសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម សង្គ្រោះជា ៣ វគ្គ ឈ្មោះថា ទីឃនិកាយ ។

និកាយណាមានព្រះសូត្រចំនួន ៣៤ សង្គ្រោះជា ៣ វគ្គ និកាយដំបូងនេះ អនុលោមតាមអត្ថ ឈ្មោះថា ទីឃនិកាយ ។

ព្រោះអ្វី ទើបនិកាយនេះ លោកហៅថា ទីឃនិកាយ ព្រោះជាទីប្រជុំ និង ជាទីរួមនៃព្រះសូត្រដែលមានខ្នាតវែងទាំងឡាយ ។ ពិតហើយ ទីប្រជុំ និងទីរួម លោកហៅថា និកាយ ឯក្នុង **និកាយ** សព្ទ ជាសព្ទប្រាប់ការប្រជុំ និងការ រួបរួមនេះ មានឧទាហរណ៍ដែលជាសាធកៈ ទាំងផ្លូវសាសនា ទាំងផ្លូវលោក យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆាននេះដ៏វិចិត្រយ៉ាងណា ចិត្ត ណាដែលវិចិត្រយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញសូម្បី នូវពួកធម៌មួយដទៃអំពីចិត្តនោះឡើយ គឺ **ចោណភិកនិកាយោ** ពួកកណ្ដៀរ **ចិក្ខល្លិកនិកាយោ** ពួកសត្វល្អិតៗ ជាដើម ។ បណ្ឌិតគប្បីជ្រាបវចនត្ថៈក្នុង សេចក្ដីដែលនិកាយទាំង ៤ ដ៏សេស ឈ្មោះថា **និកាយ** ដោយប្រការដូច្នេះ ។

## មជ្ឈិមនិកាយមាន ១៥២ សូត្រ

មជ្ឈិមនិកាយដូចម្ដេច ព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រ ជាដើម សង្គ្រោះជា ១៥ វគ្គ មានខ្នាតកណ្ដាល ឈ្មោះមជ្ឈិមនិកាយ ។

និកាយដែលមានសូត្រ ១៥២ ចែកជា ១៥ វគ្គ ឈ្មោះថា មជ្ឈិមនិកាយ ។

## សំយុត្តនិកាយមាន ៧៧៦២ សូត្រ

សំយុត្តនិកាយដូចម្ដេច ព្រះសូត្រ ៧៧៦២ សូត្រ មានឱឃតរណសូត្រ ជាដើម តាំងនៅដោយអំណាចនៃសំយុត្ត មានទេវតាសំយុត្តជាដើម ឈ្មោះ សំយុត្តនិកាយ ។

និកាយដែលមានសូត្រ ៧៧៦២ ដែលរួបរួមក្នុងពួកសំយុត្តនេះ ឈ្មោះ ថា សំយុត្តនិកាយ ។

# អង្គុត្តរនិកាយមាន ៩៥៥៧ សូត្រ

អង្គុត្តរនិកាយដូចម្តេច ព្រះសូត្រ ៩៥៥៧ សូត្រ មានចិត្តបរិយាទាន-សូត្រជាដើម ដែលតាំងនៅដោយអំណាចនៃអង្គមួយៗ និងច្រើនជាងមួយ ឈ្មោះអង្គុត្តរនិកាយ ។

ក្នុងអង្គុត្តរនិកាយ រាប់ចំនួនព្រះសូត្របានដូច្នេះ គឺ ៩៥៥៧ សូត្រ ។

# ខុទ្ទកនិកាយមាន ១៥ ប្រភេទ

ខុទ្ទកនិកាយដូចម្តេច វៀរនិកាយ ៤ ចេញ ព្រះពុទ្ធវចនៈដែលសល់ គឺ វិនយបិដក ព្រះអភិធម្មបិដកទាំងអស់ និងព្រះបាលី ១៥ ប្រភេទ ដែលសម្តែងទុកហើយខាងដើម មានខុទ្ទកបាឋៈជាដើម ឈ្មោះខុទ្ទកនិកាយ ដោយប្រការដូច្នេះ ។

វៀរនិកាយទាំង ៤ មានទីឃនិកាយជាដើមនោះចេញ ព្រះពុទ្ធវចនៈដទៃក្រៅអំពីនោះ បណ្ឌិតហៅថា ខុទ្ទកនិកាយដូច្នេះឯង ។

ព្រះពុទ្ធវចនៈមាន ៥ យ៉ាង ដោយអំណាចនៃនិកាយដូចពណ៌នាមក ដូច្នេះ ។

# ពុទ្ធវចនៈមានអង្គ ៩

ព្រះពុទ្ធវចនៈមាន ៩ យ៉ាង ដោយអំណាចនៃអង្គដូចម្តេច ពិតហើយ ព្រះពុទ្ធវចនៈនេះ ទាំងអស់មាន ៩ ប្រភេទ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្ម វេទល្ល ។

# អធិប្បាយ ព្រះពុទ្ធវចនៈមានអង្គ ៩

បណ្តាព្រះពុទ្ធវចនៈ ដែលមានអង្គ ៩ នោះ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ បរិវារ និងព្រះសូត្រ មានមង្គលសូត្រ រតនសូត្រ នាលកសូត្រ និង តុវដកសូត្រជាដើម ក្នុងសុត្តនិបាត និងព្រះតថាគតវចនៈ ដែលមានឈ្មោះថា សូត្រដទៃ គប្បីជ្រាបថា សុត្តៈ ។

ព្រះសូត្រ ដែលមានគាថាទាំងអស់ គប្បីជ្រាបថាជា គេយ្យៈ ។ សគាថកវគ្គទាំងអស់ក្នុងសំយុត្តនិកាយ គប្បីជ្រាបថាជាគេយ្យៈដោយពិសេស

ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថាលាយឡំ និង ព្រះពុទ្ធវចនៈដទៃដែលមិនបានសង្គ្រោះចូលដោយអង្គ ៨ គប្បីជ្រាបថា ជា វេយ្យាករណៈ ។

ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះថា សូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថា ជាគាថា ព្រះសូត្រ ៨២ ដែលបដិសំយុត្ត ដោយគាថា ដែលសម្រេចដោយសោមនស្សញ្ញាណ គប្បីជ្រាបថា ជាឧទាន ។

ព្រះសូត្រ ១១០ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា **វុត្តំ ហេតំ ភគវតា** សេចក្តីនេះ សមដូចព្រះតម្រាស់ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុក ហើយ គប្បីជ្រាបថា ឥតិវុត្តកៈ ។

ជាតក ៥៥០ មានអបណ្ណកជាតកជាដើម គប្បីជ្រាបថា ជាតក ។

ព្រះសូត្រ ដែលបដិសំយុត្តដោយអច្ឆរិយអព្ភូតធម៌ទាំងអស់ ដែលប្រព្រឹត្ត ទៅដោយន័យជាដើមថា

**ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតា ធម្មា អានន្ទេ** ម្នាលភិក្ខុ

ទាំងឡាយ អច្ឆរិយអព្ភូតធម៌ ៤ យ៉ាងនេះ រមែងមានក្នុងអានន្ទ គប្បីជ្រាបថាជា អព្ភូតធម្ម ។

ព្រះសូត្រដែលមនុស្សជាដើមសួរហើយ បាននូវការចេះដឹង និងការត្រេកអរទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កប្បញ្ហសូត្រ សង្ខារភាជនីយសូត្រ និងមហាបុណ្ណមសូត្រ គប្បីជ្រាបថាជា វេទល្ល ។

ព្រះពុទ្ធវចនៈ មានអង្គ ៩ ដោយអំណាចនៃអង្គដូចពណ៌នាមក ដូច្នេះ។

## ពុទ្ធវចនៈមាន ៨៤០០០ ព្រះធម្មក្ខន្ធ

ព្រះពុទ្ធវចនៈមាន ៨៤០០០ ដោយអំណាចនៃធម្មក្ខន្ធដូចម្តេច ពិតហើយ ព្រះពុទ្ធវចនៈទាំងអស់នោះឯង មាន ៨៤០០០ ដោយអំណាចនៃព្រះធម្មក្ខន្ធ ដែលព្រះអានន្ទត្ថេរសម្តែងទុកហើយយ៉ាងនេះថា

សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងហទយៈរបស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មានចំនួន ៨៤០០០ ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨២០០០ ធម្មក្ខន្ធ អំពីពួកភិក្ខុ ២០០០ ធម្មក្ខន្ធ ដូច្នេះ ។

## វិធីគណនារាប់ព្រះធម្មក្ខន្ធនីមួយៗ

បណ្តាធម្មក្ខន្ធ ៨៤០០០ នោះ ព្រះសូត្រដែលមានអនុសន្ធិ ១ ចាត់ជា ១ ធម្មក្ខន្ធ ។ ក្នុងព្រះសូត្រដែលមានអនុសន្ធិច្រើន រាប់ព្រះធម្មក្ខន្ធដោយអំណាចនៃអនុសន្ធិ ។ ក្នុងគាថាព័ន្ធទាំងឡាយ ពាក្យសួរបញ្ហា ( ១ ) ចាត់ជា

១ ធម្មក្ខន្ធ ពាក្យវិសជ្ជនា ( ១ ) ចាត់ជា ១ ធម្មក្ខន្ធ ។

ក្នុងព្រះអភិធម្ម ការចែកតិកៈ ទុកៈ អំពីតិកៈ ទុកៈនីមួយៗ និងការចែកវារចិត្ត ១ វារៈ ចាត់ជា ១ ព្រះធម្មក្ខន្ធ ។

ក្នុងព្រះវិន័យ មានវត្ថុ មានមាតិកា មានបទភាជនីយ មានអន្តរាបត្តិ មានអាបត្តិ មានអនាបត្តិ មានកំណត់តិកៈ បណ្តាវត្ថុ មាតិកាជាដើមទាំងនោះ ចំណែកនីមួយៗ គប្បីជ្រាបថា ជា ១ ធម្មក្ខន្ធ ។

ព្រះពុទ្ធវចនៈ មាន ៨៤០០០ ដោយអំណាចនៃព្រះធម្មក្ខន្ធ ដូចពណ៌នាមក ដូច្នេះ ។

## បឋមសង្គាយនារៀបចំពុទ្ធវចនៈទុកជាពួកៗ

ព្រះពុទ្ធវចនៈ ដោយន័យដូចពោលមកហើយនេះ ដោយការមិនផ្សេងគ្នា មានតែ ១ ដោយអំណាចរស ដោយការផ្សេងគ្នា គឺដោយការចែកជា ២ យ៉ាង ដោយអំណាចធម៌ និងវិន័យជាដើម ដែលព្រះមហាថេរៈជាវសីគណៈ មានព្រះមហាកស្សបជាប្រធាន កាលនឹងសង្គាយនា ទើបកំណត់ប្រភេទនេះមុន ហើយចងក្រងទុកថា នេះធម៌ នេះវិន័យ នេះបឋមពុទ្ធវចនៈ នេះមជ្ឈិម-ពុទ្ធវចនៈ នេះបច្ឆិមពុទ្ធវចនៈ នេះវិនយបិដក នេះសុត្តន្តបិដក នេះអភិធម្មបិដក នេះទីឃនិកាយ នេះមជ្ឈិមនិកាយ នេះសំយុត្តនិកាយ នេះអង្គុត្តរនិកាយ នេះខុទ្ទកនិកាយ នេះអង្គ ៩ មានសុត្តៈជាដើម នេះព្រះធម្មក្ខន្ធ ៨៤០០០ ។

លោកចងក្រងប្រភេទតាមដែលពោលទុកហើយនេះតែម៉្យាងប៉ុណ្ណោះ ក៏មិនមែន នៅមានកំណត់ប្រភេទដែលគួរសង្គ្រោះទុកដទៃៗ មានច្រើនប្រភេទ

មានឧទានសង្គហៈ វគ្គសង្គហៈ បេយ្យាលសង្គហៈ និបាតសង្គហៈ ដូចជា ឯកនិបាត និងទុកនិបាតជាដើម សំយុត្តសង្គហៈ និងបណ្ណាសកសង្គហៈជាដើម ដែលប្រាកដនៅក្នុងព្រះត្រៃបិដក បានចងក្រង ៧ ខែទើបស្រេច ដោយប្រការដូច្នេះ ។

## ព្រះពុទ្ធសាសនាតាំងនៅបាន ៥០០០ ឆ្នាំ

ក្នុងវេលាចប់ការចងក្រងពុទ្ធវចនៈនោះ មហាប្រឹថពីនេះ ហាក់ដូចជាកើតសេចក្ដីត្រេកអរ ឲ្យសាធុការថា ព្រះមហាកស្សបត្ថេរ ធ្វើសាសនារបស់ព្រះទសពលនេះឲ្យអាចប្រព្រឹត្តទៅបានអស់កាលប្រមាណ ៥០០០ ព្រះវស្សាដូច្នេះ ក៏ញាប់ញ័ររញ្ជួយខ្ទរខ្ទារជាអនេកប្បការ រហូតដល់ទឹកទ្រផែនដីជាទីបំផុត និងភាពអស្ចារ្យទាំងឡាយជាច្រើន បានប្រាកដមានហើយ ដោយប្រការដូច្នេះ ។

សង្គីតិណាក្នុងលោក លោកហៅថា បញ្ចសតាសង្គីតិ ព្រោះព្រះធម្មសង្គាហកត្ថេរ ៥០០ អង្គធ្វើ និងហៅថា ថេរិកាសង្គីតិ ព្រោះព្រះថេរៈទាំងឡាយនោះធ្វើហើយ សង្គីតិនេះ ឈ្មោះបឋមមហាសង្គីតិ ដោយប្រការដូច្នេះ ។

កាលមហាសង្គីតិនេះកំពុងប្រព្រឹត្តទៅ ព្រះមហាកស្សបកាលនឹងសួរដល់ព្រះវិន័យ( ជាមួយឧបាលិត្ថេរ ) ទើបសួរដល់និទានដែលលោកពោលទុកក្នុងពាក្យនេះថា សួរដល់វត្ថុខ្លះ សួរដល់និទានខ្លះ សួរដល់បុគ្គលខ្លះ ដូច្នេះជាដើម ដែលជាទីបំផុតនៃពាក្យជាដើមយ៉ាងនេះថា នែអាវុសោឧបាលី បឋមបារាជិក ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយក្នុងទីណាជាដើម ពាក្យនិទាននោះ ព្រះឧបាលិត្ថេរមានបំណងនឹងឲ្យពិស្ដារតាំងអំពីដើមហើយពោលដល់បុគ្គលជាដើម

ដែលបញ្ញត្តវិនយបិដក និងហេតុដែលបញ្ញត្តនោះឯង ទើបពោលទុកហើយ ។

## អធិប្បាយ ការផ្ដើមនៃនិទានវិន័យ

ពាក្យនិទាន ( ផ្ដើមដោយពាក្យ ) ថា **តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ វិហរតិ** ជាដើម បណ្ឌិតគួរពោលទុកទាំងអស់ ព្រោះពាក្យផ្ដើមនេះ ព្រះឧបាលិត្ថេរពោលទុកយ៉ាងនេះ ។ ឯពាក្យផ្ដើមនោះ បណ្ឌិតគួរជ្រាបថា ព្រះឧបាលិត្ថេរពោលទុកហើយក្នុងកាលធ្វើមហាបឋមសង្គាយនា ។ ឯអត្ថនៃបទនេះថា ពាក្យនេះបុគ្គលណាពោល និងពោលក្នុងកាលណាជាដើម ដែលខ្ញុំប្រកាសហើយដោយលំដាប់នៃពាក្យត្រឹមប៉ុណ្ណេះ ។ ឥឡូវនេះ ខ្ញុំនឹងវិសជ្ជនាក្នុងបទថា ពោលទុកព្រោះហេតុដូចម្ដេចនេះតទៅ

ព្រោះព្រះឧបាលីនេះ ត្រូវព្រះមហាកស្សបត្ថេរ សួរដល់និទានហើយដូច្នោះ ទើបលោកពោលនិទាននោះឲ្យពិស្ដារហើយ តាំងអំពីខាងដើម ដោយប្រការដូច្នេះ ។ ពាក្យផ្ដើមនេះ បណ្ឌិតគួរជ្រាបថា ព្រះឧបាលិត្ថេរកាលពោលក្នុងពេលធ្វើមហាបឋមសង្គាយនា បានពោលហើយព្រោះហេតុនេះ ដោយប្រការដូច្នេះ ឯអត្ថនៃបទមាតិកាទាំងនេះថា **វុត្តំ យេន យទា យស្មា** ដូច្នេះ គឺខ្ញុំប្រកាសហើយដោយលំដាប់នៃពាក្យត្រឹមប៉ុណ្ណេះ ។

ឥឡូវនេះ ដើម្បីប្រកាសអត្ថនៃបទមាតិកាទាំងនេះថា **ធារិតំ យេន ចាភតំ យត្ថ បតិដ្ឋិតញ្ចេតមេតំ វត្វា វិធឹ** ទើបបណ្ឌិតពោលពាក្យនេះទុក ។

# ព្រះមហាថេរៈ មានព្រះឧបាលីជាដើម នាំព្រះវិនយបិដកបន្តមក

សួរថា ព្រះវិនយបិដកនេះ មាននិទានប្រដាប់ដោយពាក្យជាដើមយ៉ាងនេះថា **តេន សមយេន ពុទ្ធោ ភគវា វេរញ្ជាយំ វិហរតិ** ដូច្នេះ បុគ្គលណាទ្រទ្រង់ទុក បុគ្គលណានាំបន្តមក និងតាំងហើយក្នុងបុគ្គលណា ខ្ញុំនឹងឆ្លើយដូចតទៅ

ព្រះវិនយបិដកនេះ ព្រះឧបាលិត្ថេរទ្រទ្រង់ទុកចំពោះព្រះភក្ត្ររបស់ព្រះដ៏មានព្រះភាគជាខាងដើមមុនគេ ។ កាលព្រះតថាគតមិនទាន់បរិនិព្វានទោះឯងភិក្ខុច្រើនពាន់អង្គ ដែលបានអភិញ្ញា ៦ ផ្សេងៗ ជាដើម ទ្រទ្រង់ទុកអំពីព្រះឧបាលិត្ថេរនោះ កាលព្រះតថាគតបរិនិព្វានហើយ ព្រះធម្មសង្គាហកត្ថេរទាំង-ឡាយ មានព្រះមហាកស្សបជាប្រធាន ក៏ទ្រទ្រង់ចាំទុកតមក ។

បទមាតិកាថា **កេនាភតំ** នេះ ខ្ញុំនឹងពោលតទៅ

ជាបឋមក្នុងជម្ពូទ្វីប ព្រះវិន័យនោះ នាំបន្តមកដោយលំដាប់នៃអាចារ្យចាប់ផ្តើមអំពីព្រះឧបាលិត្ថេរ រហូតដល់សង្គាយនាលើកទី ៣ ។ ក្នុងជម្ពូទ្វីបនោះ មានលំដាប់អាចារ្យដូចតទៅនេះ

ព្រះថេរៈ ៥ អង្គ គឺព្រះឧបាលី ១ ព្រះទាសកៈ ១ ព្រះសោណកៈ ១ ព្រះសិគ្គវៈ ១ ព្រះមោគ្គលីបុត្តតិស្សត្ថេរ ១ ជាអ្នកមានជ័យជម្នះដ៏វិសេសបាននាំព្រះវិន័យមកដោយលំដាប់ មិនឲ្យដាច់ខ្សែក្នុងសិរីជម្ពូទ្វីប រហូតដល់សង្គាយនាលើកទី ៣ ។

## ព្រះឧបាលិត្ថេររៀនព្រះវិន័យបិដកអំពីពុទ្ធសម្នាក់

សេចក្ដីពិស្ដារថា ព្រះឧបាលីរៀនយកវង្សប្រែបផែនបវេណីព្រះវិន័យ ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ហើយឲ្យតាំងនៅក្នុងហទយៈរបស់ភិក្ខុដ៏ច្រើន ។ ពិតហើយ បណ្ដាបុគ្គលអ្នករៀនយកវិនយវង្សក្នុងសម្នាក់របស់លោកនោះហើយ ដល់នូវភាពជាបុគ្គលឈ្លាស អង់អាចក្នុងព្រះវិន័យ បុគ្គលដែលជាបុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី រាប់មិនអស់ដែលជាព្រះខីណាស្រព មានចំនួន ១០០០ អង្គ ។

## ព្រះទាសកត្ថេររៀនព្រះវិន័យបិដក

ចំណែកទាសកត្ថេរភិក្ខុ បានជាសទ្ធិវិហារិករបស់ព្រះឧបាលិត្ថេរនោះឯងលោកបានរៀនយក ( ព្រះវិន័យ ) តអំពីព្រះឧបាលិត្ថេរ ហើយក៏បង្រៀនព្រះវិន័យ ( ដល់ភិក្ខុជាច្រើន ) យ៉ាងនោះ ។ បុថុជ្ជនជាដើម រៀនយកក្នុងសម្នាក់របស់ព្រះថេរៈនោះ ហើយដល់នូវភាពជាបុគ្គលឈ្លាស អង់អាចក្នុងព្រះវិន័យរាប់មិនអស់ ដែលជាព្រះខីណាស្រព មានចំនួនដល់ទៅ ១០០០ អង្គ ។

## ព្រះសោណកត្ថេររៀនព្រះវិន័យបិដក

ចំណែកព្រះសោណកត្ថេរ ជាសទ្ធិវិហារិករបស់ព្រះទាសកត្ថេរ ។ លោកក៏រៀនយក ( ព្រះវិន័យ ) បន្តអំពីព្រះទាសកត្ថេរ ដែលជាឧបជ្ឈាយ៍របស់ខ្លួន ហើយក៏បង្រៀនព្រះវិន័យ ( ដល់ភិក្ខុដ៏ច្រើន ) យ៉ាងនោះ ។ បុថុជ្ជនជាដើម ដែលរៀនយក ( ព្រះវិន័យ ) ក្នុងសម្នាក់របស់ព្រះថេរៈនោះ ហើយដល់នូវភាពជាអ្នកឈ្លាសក្នុងព្រះវិន័យរាប់មិនអស់ ដែលជាព្រះខីណាស្រព មាន

ចំនួនដល់ទៅ ១០០០ អង្គដូចគ្នា ។

## ព្រះសិគ្គវត្ថេររៀនព្រះវិនយបិដក

ចំណែកព្រះសិគ្គវត្ថេរ ជាសទ្ធិវិហារិករបស់ព្រះសោណកត្ថេរ រៀនយកព្រះវិន័យក្នុងសម្នាក់របស់ព្រះថេរៈ ហើយបានជាអ្នកទទួលធុរៈរបស់ព្រះអរហន្ត ១០០០ ។ម្យ៉ាងទៀត បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីក្តី ព្រះខីណាស្រពក្តី ដែលរៀនយក ( ព្រះវិន័យ ) ក្នុងសម្នាក់ព្រះថេរៈអង្គនោះ ហើយដល់នូវភាពជាបុគ្គលឈ្លាស អង់អាចក្នុងព្រះវិន័យ ក៏កំណត់មិនបានថា ប៉ុណ្ណោះរយ ឬប៉ុណ្ណោះពាន់ ។ បានឮថា វេលានោះ ក្នុងជម្ពូទ្វីបមានការប្រជុំភិក្ខុសន្និកសន្ទាប់ ។ អានុភាពរបស់ព្រះមោគ្គលីបុត្តតិស្សត្ថេរ នឹងមានប្រាកដច្បាស់ក្នុងតតិយសង្គាយនា ( ខាងមុខ ) ។ ព្រះវិនយបិដកនេះ គប្បីជ្រាបជាបឋម ក្នុងជម្ពូទ្វីបបន្តគ្នាមកដោយលំដាប់នៃអាចារ្យនេះ រហូតដល់សង្គាយនាលើកទី ៣ ដោយប្រការដូច្នេះ ។

# ឧតិយសង្គាយនា

ដើម្បីដឹងទុតិយសង្គាយនាឲ្យជាក់ច្បាស់ គួរជ្រាបលំដាប់ដូចតទៅនេះ ពិតហើយ ក្នុងកាលណា ព្រះថេរៈទាំង ៥០០ មានព្រះមហាកស្សបជាដើម ជាអ្នកមានអាសវៈអស់ហើយ មានបញ្ញាដ៏រុងរឿងទាំងនោះ កាលសង្គាយនាព្រះសទ្ធម្ម និងញុំាងព្រះសទ្ធម្មឲ្យរុងរឿងក្នុងទីទាំងពួងហើយ តាំងនៅរហូតដល់ទីបំផុតនៃជីវិត មិនមានអាល័យ មានពូជអស់ហើយ តែងរលត់ទៅ ដូចប្រទីបដែលរលត់ទៅ ដូច្នោះ ។

## ភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ

ក្នុងកាលនោះ កាលទិវា និងរាត្រីកន្លងទៅដោយលំដាប់ ក្នុងកាលព្រះដ៏មានព្រះភាគបរិនិព្វានហើយ បាន ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីបុត្រ អ្នកវេសាលីសម្ដែងវត្ថុ ១០ ប្រការទាំងនេះ ក្នុងក្រុងវេសាលី គឺ **កប្បតិ សិង្គិលោណា-កប្បោ** ការកំណត់ដោយអំបិលក្នុងក្លាក់គួរ ( ដល់សមណៈ ) **កប្បតិ ទ្វង្គុលកប្បោ** ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេទៅប្រមាណ ២ ធ្នាប់គួរ **កប្បតិ គាមន្តរកប្បោ** ការកំណត់ដោយចន្លោះស្រុកគួរ **កប្បតិ អាវាសកប្បោ** ការកំណត់ដោយអាវាសគួរ **កប្បតិ អនុមតិកប្បោ** ការកំណត់ដោយអនុមតិគួរ **កប្បតិ អាចិណ្ណកប្បោ** ការកំណត់ដោយអាចិន្នកប្ប ( ប្រពៃណី ) គួរ **កប្បតិ អមថិតកប្បោ** ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរគួរ **កប្ប ជលោគី ចាតុំ** ការផឹកនូវសុរាយ៉ាងទន់ ដែលមិនទាន់

ដល់នូវភាពជាទឹកស្រវឹង ក៏គួរ **កប្បតិ អទសកំ និសីទនំ** និសីទនៈដែលមិនមានជាយក៏គួរ **កប្បតិ ជាតរូបរជតំ** មាស និងប្រាក់គួរ ។

ព្រះរាជាទ្រង់ព្រះនាមថា **កាឡាសោក** ជាឱរសរបស់ព្រះបាទសុសូនាគ ទ្រង់បានជាបក្ខពួករបស់ពួកភិក្ខុទាំងនោះហើយ ។

## ព្រះយសត្ថេរដឹងភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០

សម័យនោះឯង ព្រះយសកាកណ្ឌកបុត្រត្រាច់ចារិកទៅក្នុងវជ្ជីជនបទបានឮថា ពួកវជ្ជីបុត្រអ្នកក្រុងវេសាលីសម្ដែងវត្ថុ ១០ ប្រការ ក្នុងក្រុងវេសាលីដូច្នេះ ទើបត្រិះរិះថា ប្រការដែលអញបានឮវិបត្តិនៃព្រះសាសនារបស់ព្រះទសពលហើយ នឹងគប្បីជាបុគ្គលមានសេចក្ដីខ្វល់ខ្វាយតិច មិនគួរដល់អញឡើយ ណ្ហើយចុះ អាត្មាអញ នឹងញាំញីពួកអធម្មវាទីចេញ ហើយនិងលើកតម្កើងធម៌ ដូច្នេះ ទើបបានទៅតាមផ្លូវ ១ ក្នុងក្រុងវេសាលី ។

បានឮមកថា ព្រះយសកាកណ្ឌកបុត្រ សម្រាកនៅត្រង់កូដាគារសាលាក្នុងព្រៃមហាវ័ន ជិតក្រុងវេសាលីនោះ ។ សម័យនោះឯង ពួកភិក្ខុវជ្ជីបុត្រអ្នកស្រុកវេសាលី ដាក់ទឹកឲ្យពេញថាសសំរឹទ្ធហើយ តាំងទុកត្រង់កណ្ដាលជំនុំសង្ឃ ក្នុងថ្ងៃឧបោសថនោះ ហើយបង្អកប្រកាសឧបាសកឧបាសិកា អ្នកក្រុងវេសាលីដែលមកហើយយ៉ាងនេះថា អ្នកដ៏មានអាយុ លោកទាំងឡាយចូរថ្វាយរូបិយដល់សង្ឃ ១ កហាបណៈក៏បាន កន្លះកហាបណៈក៏បាន ១ បាទក៏បាន ១ មាសកៈក៏បាន កិច្ចរបស់សង្ឃដែលត្រូវធ្វើដោយបរិក្ខារនឹងមាន ដូច្នេះ ។

ពាក្យទាំងពួងគួរពោលរហូតដល់ពាក្យថា សង្គីតិវិន័យនេះ មានភិក្ខុ ៧

វយអង្គ មិនខ្វះ មិនលើស ព្រោះដូច្នោះ សង្គីតិវិន័យនេះ ទើបលោកហៅថា សត្តសតិកា ។

ភិក្ខុមួយលានពីរសែនអង្គ ដែលព្រះយសស្រ្កាកណ្ឌកបុត្រដឹកនាំ បាន ប្រជុំគ្នាក្នុងសន្និបាតនេះ ។ វត្ថុទាំង ១០ ប្រការនោះ ព្រះរេវតៈជាអ្នកសួរ ព្រះ សព្វកាមិត្ថេរជាអ្នកវិសជ្ជនាព្រះវិន័យ វិនិច្ឆ័យសម្រេចក្នុងកណ្ដាលជំនុំភិក្ខុទាំង នោះ អធិករណ៍ ឈ្មោះថា រម្ងាប់ស្រេចហើយ ។

## ជ្រើសរើសព្រះថេរៈចាណ ៧០០ អង្គ ធ្វើទុតិយសង្គាយនា

ក្រោយមក ព្រះថេរៈទាំងឡាយប្រឹក្សាគ្នាថា ពួកយើងនឹងសង្គាយនាព្រះ ធម៌ និងព្រះវិន័យទៀត ដូច្នេះ ទើបបានជ្រើសរើសភិក្ខុ ៧០០ អង្គ ដែលជា អ្នកទ្រទ្រង់ព្រះត្រៃបិដក ជាអ្នកបាននូវបដិសម្ភិទា ហើយអង្គុយប្រជុំគ្នាត្រង់ វាលិការាម ជិតក្រុងវេសាលី ជម្រះមន្ទិលនៃព្រះសាសនាទាំងពួង បាន សង្គាយនាព្រះធម៌ និងព្រះវិន័យទាំងអស់ ដោយអំណាចបិដក និកាយ អង្គ និងធម្មក្ខន្ធដដែលទៀត ដូចដែលព្រះមហាកស្សបត្ថេរសង្គាយនាហើយនោះឯង សង្គីតិណាក្នុងលោក លោកហៅថា សត្តសង្គីតិ ព្រោះព្រះថេរៈ ៧០០ អង្គ ធ្វើ និងហៅថា ទុតិយសង្គីតិ ព្រោះប្រៀបធៀបនឹងសង្គីតិដែលធ្វើមុន សង្គីតិ នេះធ្វើ ៨ ខែទើបស្រេច ដោយប្រការដូច្នេះ ។ ឯសង្គីតិនេះ ព្រះថេរៈពួក ណាចងក្រងទុកហើយ បណ្ដាព្រះថេរៈទាំងនោះ ព្រះថេរៈដែលប្រាកដ គឺព្រះ សព្វកាមី ១ ព្រះសាឡ្ហៈ ១ ព្រះរេវតៈ ១ ព្រះខុជ្ជសោភិតៈ ១ ព្រះយស ១ ព្រះសោណសម្ភូតៈ ១ ទាំងនេះជាសទ្ធិវិហារិករបស់ព្រះអានន្ទត្ថេរ ធ្លាប់

ឃើញព្រះតថាគត ព្រះសុមនៈ ១ ព្រះវាសភគាមី ១ ពីរអង្គនេះ បណ្ឌិតគប្បីជ្រាបថា ជាសទ្ធិវិហារិករបស់ព្រះអនុរុទ្ធ ធ្លាប់ឃើញព្រះតថាគត ឯព្រះថេរៈទាំងឡាយដែលធ្វើសង្គាយនាលើកទី ២ គ្រប់ៗ អង្គ ជាបុគ្គលដាក់ចុះនូវភារៈហើយ មានកិច្ចសម្រេចហើយ មិនមានអាសវៈ ដូច្នេះឯង ។

ចប់ ទុតិយសង្គីតិប៉ុណ្ណោះ

## រឿងរ៉ាវមុនតតិយសង្គាយនា

ព្រះថេរៈទាំងឡាយនោះ កាលសង្គាយនាទុតិយសង្គីតិយ៉ាងនេះហើយ ទើបរំពឹងមើលថា ក្នុងអនាគត ចម្រូងចម្រាសបែបនេះ នឹងកើតដល់ព្រះ-សាសនាឬទេហ្ន៎ ហើយបានដឹងហេតុថា ក្នុងឆ្នាំទី ១៨ បន្ទាប់អំពី ១០០ ឆ្នាំនេះទៅ ព្រះរាជាទ្រង់ព្រះនាមថា ធម្មាសោកទ្រង់នឹងកើតក្នុងនគរបាដលិបុត្រ គ្រប់គ្រងរាជ្យសម្បត្តិក្នុងជម្ពូទីបទាំងមូល ព្រះរាជាអង្គនេះ ទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយនឹងញុំាងលាភ និងសក្ការៈដ៏ច្រើនឲ្យប្រព្រឹត្តទៅ ក្នុងកាលនោះ ពួកតិត្ថិយជាអ្នកប្រាថ្នាលាភ និងសក្ការៈ នឹងបួសក្នុងព្រះសាសនា ហើយសម្តែងទិដ្ឋិរបស់ខ្លួន ចម្រូងចម្រាសដ៏ធំនឹងកើតឡើងក្នុងសាសនា ដោយអាការយ៉ាងនេះ ។

## តិស្សមហាព្រហ្មចុតិអំពីព្រហ្មលោក

សម័យនោះ ព្រះថេរៈទាំងនោះ មានបរិវិតក្កៈដូច្នេះថា កាលចង្រៃនោះកើតឡើងហើយ ពួកយើងនៅទាន់ដែរឬទេហ្ន៎ លំដាប់នោះ ព្រះថេរៈទាំងអស់នោះឯងជ្រាបថា ខ្លួនជាអ្នកមិនទាន់ ( ហេតុការណ៍ ) ក្នុងពេលនោះ ទើបគិតថា នរណាហ្ន៎ នឹងជាអ្នកមានសមត្ថភាពឲ្យអធិករណ៍នោះស្ងប់រម្ងាប់បាន ហើយបានប្រមើលមើលមនុស្សលោក និងទេវលោកជាន់កាមា-វចរទាំងអស់ ក៏មិនបានឃើញបុគ្គលណា បានឃើញតែមហាព្រហ្មឈ្មោះតិស្សៈក្នុងព្រហ្មលោក ដែលមានអាយុជិតអស់ហើយ បានអប់រំបន្ទុំមគ្គដើម្បីកើតក្នុងព្រហ្មលោកជាន់លើជាបន្ត ។ ព្រះថេរៈទាំងឡាយនោះ កាលឃើញដូច្នេះហើយ ទើបមានសេចក្តីត្រិះរិះដូច្នេះថា ប្រសិនបើពួកយើង គប្បី

ធ្វើសេចក្ដីឧស្សាហ៍ ដើម្បីឲ្យព្រហ្មនោះ កើតក្នុងមនុស្សលោកសោត ព្រហ្ម នោះនឹងបដិសន្ធិក្នុងផ្ទះ របស់មោគ្គលីព្រាហ្មណ៍ពិតប្រាកដ ហើយបន្ទាប់អំពី នោះ ក៏នឹងត្រូវលួងលោមដោយមន្ត ហើយចេញបួស កាលតិស្សកុមារនោះ បួសហើយ សិក្សាព្រះពុទ្ធវចនៈទាំងអស់ ជាអ្នកបានសម្រេចបដិសម្ភិទា នឹង ញាំញីពួកតិរ្ថិយ វិនិច្ឆ័យអធិករណ៍នោះ ស្រោចស្រង់ព្រះសាសនាមិនខាន ។

## ព្រះថេរៈទាំងឡាយនិមន្តទៅអារាធនាតិស្សមហាព្រហ្ម

ព្រះថេរៈទាំងនោះ ទៅកាន់ព្រហ្មលោក ហើយបានពោលពាក្យនេះជា មួយតិស្សមហាព្រហ្មថា នែសម្លាញ់អ្នកនិទុក្ខ ក្នុងឆ្នាំទី ១៨ បន្ទាប់អំពី ១ រយឆ្នាំនេះទៅ ចម្រូងចម្រាស់យ៉ាងធំនឹងកើតឡើងក្នុងព្រះពុទ្ធសាសនា ហើយ ពួកខ្ញុំបានរំពឹងមើលមនុស្សលោក និងទេវលោកជាន់កាមាវចរទាំងអស់ ក៏ មិនបានឃើញបុគ្គលណា ជាអ្នកមានសមត្ថភាពដើម្បីនឹងលើកស្ទួយព្រះ-សាសនាបាន លុះរំពឹងមើលក្នុងព្រហ្មលោក ទើបបានឃើញលោកដ៏ចម្រើន ដូច្នេះ ពួកខ្ញុំសុំឱកាស នែលោកសប្បុរស សូមលោកឲ្យប្ដេជ្ញា ( ដល់ពួក ខ្ញុំ ) ដើម្បីកើតក្នុងមនុស្សលោក ហើយស្រោចស្រង់ព្រះសាសនារបស់ព្រះ ទសពលចុះ ។

កាលព្រះថេរៈទាំងឡាយ អារាធនាយ៉ាងនោះហើយ ទើបមហាព្រហ្ម ត្រិះរិះថា បានឮថា អាត្មាអញ ជាអ្នកអាចដើម្បីជម្រះភាពចម្រូងចម្រាស់ ដែលនឹងកើតក្នុងសាសនា ហើយលើកស្ទួយព្រះសាសនា ដូច្នេះហើយ ជា អ្នកត្រេកអរដ៏ក្រៃលែង បានឲ្យពាក្យប្ដេជ្ញាថា សាធុ ។ ព្រះថេរៈទាំងឡាយ

ពិចារណាកិច្ចដែលគួរធ្វើនោះក្នុងព្រហ្មលោកស្រេចហើយ ក៏នាំគ្នាត្រឡប់វិញ ។

## ព្រះថេរៈនាំគ្នាដាក់ទណ្ឌកម្មដល់ព្រះថេរៈពីរអង្គ

សម័យនោះឯង ព្រះថេរៈពីរអង្គ គឺ **សិគ្គវត្ថេរ** និង **ចណ្ឌវជ្ជិត្ថេរ** ដែលនៅជានវៈនៅឡើយ ។ ព្រះថេរៈទាំងនោះ ជាភិក្ខុកំលោះ ទ្រទ្រង់ព្រះត្រៃបិដក ដល់នូវត្រៃយបដិសម្ភិទា អស់អាសវៈហើយ ជាសទ្ធិវិហារិករបស់ព្រះសោណកៈ ។ ព្រះថេរៈទាំងពីរអង្គនោះ មិនបានមកចូលរួមរម្ងាប់អធិករណ៍នោះ ។ ទើបព្រះថេរៈទាំងឡាយ ពោលថា នៃអាវុសោ ពួកលោកមិនបានជាអ្នករួមគិតរបស់ពួកយើង ក្នុងអធិករណ៍នេះឡើយ ព្រោះហេតុនោះ ទណ្ឌកម្មនេះចូរមានដល់ពួកលោក គឺមហាព្រហ្មឈ្មោះតិស្សៈ នឹងបដិសន្ធិក្នុងផ្ទះរបស់មោគ្គលីព្រាហ្មណ៍ បណ្ដាលោកទាំងពីរ មួយអង្គត្រូវដឹកនាំតិស្សមហាព្រហ្មនោះមកបួស មួយអង្គទៀត ចូរបង្រៀនព្រះពុទ្ធវចនៈ ដូច្នេះ។

ព្រះថេរៈគ្រប់អង្គនោះ មានព្រះសព្វកាមីជាដើម ជាអ្នកមានឫទ្ធិច្រើន រុងរឿងហើយក្នុងលោក តាំងនៅរហូតអស់អាយុ ហើយក៏បរិនិព្វាន ដូចគំនរភ្លើងធំ ដែលភ្លឺរន្ទាលប្រាលឆ្អៅ រលត់ទៅហើយ ដូច្នោះ ព្រះថេរៈដែលមានឈ្មោះទាំងនោះ ជាអ្នកអស់អាសវៈហើយ ដល់នូវភាពជំនាញ បែកធ្លាយក្នុងបដិសម្ភិទា កាលធ្វើទុតិយសង្គាយនាជម្រះព្រះសាសនាឲ្យបរិសុទ្ធ ធ្វើហេតុដើម្បីសេចក្ដីចម្រើននៃព្រះសទ្ធម្ម ក្នុងអនាគតហើយ ក៏ចូលដល់នូវអំណាចនៃអនិច្ចតាធម៌ ធីរជនជ្រាបភាពដែលសង្ខារជារបស់មិនទៀង ជា

របស់លាមក ឈានកន្ទុនបានដោយកម្រយ៉ាងនេះហើយ គ៏គួរប្រឹងប្រែងព្យាយាម ដើម្បីធ្វើឲ្យសម្រេចនូវអមតបទ ដែលជាបទទៀង ស្ថិតស្ថេរដូច្នេះឯង ។

ពណ៌នាទុតិយសង្គីតិ ចប់ហើយដោយប្រការទាំងពួង
ដោយលំដាប់នៃពាក្យមានប្រមាណប៉ុណ្ណេះ

# តតិយសង្គាយនា
## តិស្សមហាព្រហ្មកើតក្នុងមនុស្សលោក

តិស្សមហាព្រហ្មនោះឯង ឃ្លាតចាកព្រហ្មលោកហើយ បានបដិសន្ធិក្នុងផ្ទះរបស់មោគ្គលីព្រាហ្មណ៍ ចំណែកព្រះសិគ្គវត្ថេរ ចាប់តាំងអំពីតិស្សមហាព្រហ្មនោះបដិសន្ធិ ក៏ចូលទៅបិណ្ឌបាតក្នុងផ្ទះរបស់ព្រាហ្មណ៍រហូត ៧ ឆ្នាំ ។ ក្នុងរយៈពេលនេះ សូម្បីមួយថ្ងៃ លោកក៏មិនដែលបានបបរត្រឹមតែមួយគ្រឡោក ឬបាយត្រឹមតែមួយវែកឡើយ ។ ដោយកន្លងទៅ ៧ ឆ្នាំ ក្នុងថ្ងៃមួយ លោកបានត្រឹមតែពាក្យថា និមន្តទៅប្រោសសត្វខាងមុខចុះលោកម្ចាស់ ។

ក្នុងថ្ងៃនោះឯង ព្រាហ្មណ៍បានធ្វើកិច្ចដែលគួរធ្វើខ្លះ ខាងក្រៅផ្ទះហើយដើរត្រឡប់មក ក៏ជួបព្រះថេរៈត្រង់ចំណែកនៃផ្លូវ ទើបសួរថា បព្វជិតដ៏ចម្រើន លោកបានមកកាន់ផ្ទះរបស់ខ្ញុំហើយឬ ព្រះថេរៈឆ្លើយថា ចម្រើនពរអាត្មាបានទៅហើយព្រាហ្មណ៍ៗ សួរថា លោកបានអ្វីខ្លះដែរឬ ព្រះថេរៈឆ្លើយថា ចម្រើនពរ បានព្រាហ្មណ៍ ព្រាហ្មណ៍នោះទៅដល់ផ្ទះហើយសួរថានរណាបានឲ្យអ្វីដល់បព្វជិតនោះខ្លះឬ ពួកជនក្នុងផ្ទះឆ្លើយថា មិនបានឲ្យអ្វីឡើយ ។

ក្នុងថ្ងៃទី ២ ព្រាហ្មណ៍នោះអង្គុយត្រង់ទ្វារផ្ទះនោះឯង ដោយគិតថាថ្ងៃនេះ អញនឹងសង្កត់សង្កិនបព្វជិតនេះ ដោយការពោលកុហក ។ ក្នុងថ្ងៃទី ២ ព្រះថេរៈក៏ទៅដល់ទ្វារផ្ទះរបស់ព្រាហ្មណ៍ ។ ព្រាហ្មណ៍កាលឃើញព្រះ

ថេរៈ ក៏និយាយយ៉ាងនេះថា ម្សិលមិញ លោកមិនបានអ្វីពីផ្ទះរបស់ខ្ញុំឡើយ ក៏ប្រាប់ថាបាន ការពោលកុហក សមគួរដល់លោកឬ ។

ព្រះថេរៈពោលថា ចម្រើនពរ ព្រាហ្មណ៍ ក្នុងផ្ទះរបស់អ្នក អាត្មាមិនបានសូម្បីត្រឹមតែពាក្យនិយាយថា និមន្តទៅប្រោសសត្វខាងមុខចុះ ដូច្នេះ អស់កាល ៧ ឆ្នាំ ម្សិលមិញ បានត្រឹមតែពាក្យនិយាយថា និមន្តទៅប្រោសសត្វខាងមុខចុះ កាលបើដូច្នោះ ទើបអាត្មានិយាយយ៉ាងនេះ សំដៅយកបដិសណ្ឋារកិច្ចនោះឯង ។

ចំណែកព្រាហ្មណ៍គិតថា សមណៈនេះបានត្រឹមតែការបដិសណ្ឋារៈ ក៏គង់សរសើរថា បាន ( ប្រសិនបើ )បានរបស់ដែលគួរទំពា គួរបរិភោគឯណាមួយដទៃហើយ ហេតុអ្វី នឹងមិនសរសើរហ្ន៎ ។ ព្រាហ្មណ៍ជ្រះថ្លាយ៉ាងនេះហើយ ទើបប្រាប់ឲ្យប្រគេនកិក្ខាមួយវែក និងសម្លដែលគួរដល់កិក្ខានោះអំពីកត្តដែលគេរៀបចំទុកដើម្បីខ្លួន ហើយពិតថា លោកម្ចាស់នឹងបានកិក្ខាយ៉ាងនេះរាល់ៗ ថ្ងៃ ដូច្នេះ ចាប់តាំងអំពីថ្ងៃរះឡើង ព្រាហ្មណ៍នោះបានឃើញ ការស្ងប់រៀបរយរបស់ព្រះថេរៈ ដែលចូលទៅ ក៏រឹងរឹតតែជ្រះថ្លាឡើង ហើយសូមពរព្រះថេរៈដើម្បីឲ្យធ្វើកត្តកិច្ចក្នុងផ្ទះរបស់ខ្លួន អស់កាលជានិច្ច ។ ព្រះថេរៈទទួលនិមន្តន៍ហើយ ក៏បានធ្វើកត្តកិច្ចរាល់ៗ ថ្ងៃ កាលនឹងត្រឡប់ ក៏បានសម្តែងព្រះពុទ្ធវចនៈបន្តិចបន្តួច ទើបត្រឡប់ទៅ ។

## ព្រះសិគ្គវត្ថេរផ្តើមច្រាស្រ័យជាមួយតិស្សមាណព

មាណពនោះឯង មានអាយុបាន ១៦ ឆ្នាំប៉ុណ្ណោះ ក៏បានដល់នូវត្រើយ

នៃត្រៃវេទ ។ បុគ្គលដទៃណាមួយ នឹងអង្គុយ ឬដេកលើអាសនៈរបស់សត្វអ្នកបរិសុទ្ធ ដែលចុះមកអំពីព្រហ្មលោកមិនបាន ។ វេលាណាតិស្សមាណពនោះទៅផ្ទះរបស់អាចារ្យ ពេលនោះ ពួកអ្នកបម្រើក៏យកសំពត់សគ្របលើគ្រែ និងតាំងរបស់តិស្សមាណពនោះសំយុងទុក ។ ព្រះថេរៈត្រិះរិះថា ឥឡូវនេះ ជាកាលដែលនឹងឲ្យមាណពបួសបានហើយ អញក៏មកទីនេះយូរហើយ ទាំងការនិយាយស្តីអ្វីៗ ជាមួយមាណពក៏មិនបានកើតឡើង ណ្ហើយចុះ ឥឡូវនេះ ការនិយាយ ( ជាមួយមាណពនោះ ) នឹងកើតឡើងបាន ព្រោះអាស្រ័យបល្ល័ង្ក ( របស់តិស្សៈ ) ដោយឧបាយយ៉ាងនេះ ទើបលោកទៅផ្ទះ ( របស់មាណពនោះ ) ហើយអធិដ្ឋានឲ្យអាសនៈណាមួយដទៃ ក្នុងផ្ទះនោះមិនប្រាកដវៀរលែងតែបល្ល័ង្ករបស់មាណព ។ មនុស្សក្នុងផ្ទះរបស់ព្រាហ្មណ៍ឃើញព្រះថេរៈហើយ កាលមិនឃើញអាសនៈណាមួយដទៃ ក៏បានក្រាលបល្ល័ង្ករបស់មាណពប្រគេនព្រះថេរៈ ព្រះថេរៈក៏អង្គុយលើបល្ល័ង្ក ចំណែកមាណពក៏ត្រឡប់មកអំពីផ្ទះរបស់អាចារ្យក្នុងខណៈនោះឯង ឃើញព្រះថេរៈអង្គុយលើបល្ល័ង្ករបស់ខ្លួន ក៏ខឹងក្រោធ ទើបពោលថា អ្នកណាឲ្យក្រាលបល្ល័ង្ករបស់ខ្ញុំដល់សមណៈ ព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយ កាលមាណពមានការប្រទូស្តស្ងប់រម្ងាប់ហើយ ទើបបាននិយាយយ៉ាងនេះថា នែមាណព អ្នកចេះមន្តអ្វីខ្លះឬ មាណពឆ្លើយថា បពិត្របព្វជិតដ៏ចម្រើន ក្នុងពេលនេះ បើខ្ញុំមិនចេះមន្តអ្នកដទៃណាហ្ន៎ ទើបនឹងចេះបាន ដូច្នេះហើយ ក៏សួរព្រះថេរៈថា ចុះលោកម្ចាស់វិញ ចេះមន្តឬ ព្រះថេរៈពោលថា ចូរសួរចុះមាណព អ្នកសួរហើយ

អាចនឹងដឹងបាន ។

សម័យនោះឯង មាណពបានសួរព្រះថេរៈក្នុងប្រស្នាដែលមានកំណួច ( ដែលអាថ៌កំបាំង ) ដែលមាននៅក្នុងត្រៃវេទ ព្រមទាំងនិឃណ្ឌុសាស្ត្រ កេដុភសាស្ត្រ ព្រមទាំងអក្ខរប្បភេទ មានឥតិហាសជាគម្រប់ ៥ ដែលមាណពខ្លួនឯង ព្រមទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញន័យដោយខ្លួនឯង ។

ព្រះថេរៈ ជាធម្មតាក៏ជាអ្នកដល់នូវត្រើយនៃវេទ ហើយឥឡូវនេះ ក៏បានសម្រេចបដិសម្ភិទា ព្រោះហេតុនោះ ក្នុងការដោះស្រាយបញ្ហាទាំងនោះ ទើបមិនជាភារៈធ្ងន់សម្រាប់លោក ដូច្នោះ ទើបលោកដោះស្រាយប្រស្នាទាំងនោះ ក្នុងខណៈនោះឯង ហើយបាននិយាយជាមួយមាណពថា នែមាណព អ្នកសួរអាត្មាមកល្មមហើយ ពេលនេះ អាត្មាក៏នឹងសួរបញ្ហាមួយជាមួយអ្នក តើអ្នកព្យាករដល់អាត្មាបានទេ មាណពឆ្លើយថា បពិត្របព្វជិតដ៏ចម្រើន សូមសួរចុះ ខ្ញុំនឹងដោះស្រាយ ។

ទើបព្រះថេរៈ សួរបញ្ហានេះ ក្នុងចិត្តយមកៈថា ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើតឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់ ដូច្នេះ ។

មាណពមិនអាចនឹងកំណត់ ( បញ្ហា ) ទាំងខាងលើ ឬខាងក្រោមបាន ទើបសួរថា បពិត្របព្វជិតដ៏ចម្រើន នេះឈ្មោះមន្តអ្វី ព្រះថេរៈឆ្លើយថា នេះឈ្មោះពុទ្ធមន្ត ។ មាណពសួរថា លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់អាច

ឲ្យពុទ្ធមន្តនេះដល់ខ្ញុំបានទេ ព្រះថេរៈឆ្លើយថា អាចឲ្យដល់បុគ្គលដែលកាន់យកភេទបព្វជ្ជាដូចអាត្មាប៉ុណ្ណោះ ។

បន្ទាប់អំពីនោះ មាណពចូលទៅរកមាតាបិតា ហើយពោលថា បព្វជិតអង្គនេះ រមែងចេះពុទ្ធមន្ត ហើយក៏មិនបានឲ្យដល់បុគ្គលដែលមិនបានបួសក្នុងសម្នាក់របស់លោក ខ្ញុំនឹងបួសក្នុងសម្នាក់របស់លោក ហើយរៀនមន្តនោះ ។

សម័យនោះ មាតាបិតារបស់មាណពសម្គាល់ថា កូនរបស់អញបួសហើយ ចូររៀនមន្តចុះ កាលរៀនហើយ ក៏នឹងត្រឡប់មកផ្ទះ ដូច្នេះទើបអនុញ្ញាតថា នែកូនចូររៀនចុះ ។

ព្រះថេរៈប្រាប់កម្មដ្ឋាន គឺអាការ ៣២ មុនហើយ ឲ្យកុមារបព្វជ្ជា ។ តិស្សសាមណេរនោះ ធ្វើបរិកម្មក្នុងកម្មដ្ឋាននោះ អស់កាលមិនយូរប៉ុន្មាន ក៏តាំងនៅក្នុងសោតាបត្តិផល ។

## ព្រះថេរៈបញ្ជូនតិស្សសាមណេរទៅ

លំដាប់នោះ ព្រះថេរៈគិតថា សាមណេរតាំងនៅក្នុងសោតាបត្តិផលហើយ ឥឡូវនេះ លោកមិនគួរនឹងឃ្លាតអំពីព្រះសាសនាឡើយ បើអញបង្រៀនកម្មដ្ឋានដល់លោក ឲ្យក្រៃលែងឡើងទៅ លោកក៏នឹងគប្បីសម្រេចជាព្រះអរហន្ត នឹងគប្បីជាបុគ្គលមានសេចក្តីខ្វល់ខ្វាយតិច ដើម្បីនឹងរៀនព្រះពុទ្ធវចនៈ ឥឡូវនេះ ក៏ជាវេលាដែលត្រូវបញ្ជូនលោកទៅកាន់សម្នាក់របស់ព្រះចណ្ឌវជ្ជិត្ថេរ ។

លំដាប់នោះ ព្រះថេរៈក៏និយាយនឹងសាមណេរនោះថា នែសាមណេរ អ្នកចូរទៅកាន់សម្នាក់របស់ព្រះថេរៈ រៀនយកព្រះពុទ្ធវចនៈចុះ ចូរសួរដល់ការមិនមានរោគតាមពាក្យរបស់ខ្ញុំ និងចូរប្រាប់យ៉ាងនេះថា ឧបជ្ឈាយ៍ ( របស់ខ្ញុំ ) បញ្ជូនខ្ញុំមកកាន់សម្នាក់របស់លោកម្ចាស់ បើលោកសួរថា ឧបជ្ឈាយ៍របស់អ្នកឈ្មោះអ្វី គប្បីប្រាប់ថា ឈ្មោះសិគ្គវៈ កាលលោកសួរថា ខ្ញុំឈ្មោះអ្វី គប្បីប្រាប់យ៉ាងនេះថា ឧបជ្ឈាយ៍របស់ខ្ញុំស្គាល់ឈ្មោះរបស់លោកម្ចាស់ ។

តិស្សសាមណេរទទួលថា សាធុ ហើយក្រាបថ្វាយបង្គំ ធ្វើប្រទក្សិណព្រះថេរៈហើយ ធ្វើដំណើរទៅកាន់សម្នាក់របស់ព្រះចណ្ឌវជ្ជិត្ថេរដោយលំដាប់ថ្វាយបង្គំហើយ ឈរនៅនាចំណែកម្ខាង ។

ព្រះថេរៈសួរថា សាមណេរ អ្នកមកពីណា សាមណេរឆ្លើយថា ព្រះឧបជ្ឈាយ៍បញ្ជូនខ្ញុំមកកាន់សម្នាក់របស់លោកម្ចាស់ ព្រះថេរៈសួរថា ឧបជ្ឈាយ៍របស់អ្នកឈ្មោះអ្វី សាមណេរឆ្លើយថា ឈ្មោះសិគ្គវត្ថេរ ព្រះថេរៈសួរថា ចុះខ្ញុំឈ្មោះអ្វី សាមណេរឆ្លើយថា ឧបជ្ឈាយ៍របស់ខ្ញុំទើបស្គាល់ឈ្មោះរបស់លោកម្ចាស់ ព្រះថេរៈប្រាប់ថា ចូររៀបចំទុកដាក់បាត្រ និងចីវរក្នុងឥឡូវនេះចុះ សាមណេរទទួលថា សាធុ ។

## តិស្សសាមណេរបដិបត្តិកិច្ចវត្ត

សាមណេរទុកដាក់បាត្រ និងចីវរហើយ ក្នុងថ្ងៃស្អែកឡើង ក៏បោសសម្អាតបរិវេណ ហើយចូលទៅរៀបចំទឹកឆាន់ និងឈើស្ទន់ទុក ។

ព្រះថេរៈ បោសសម្អាតទីកន្លែងដែលសាមណេរបោសហើយដដែល

ទៀត ចាក់ទឹកនោះចោល ហើយដងទឹកដទៃមកទុក ហើយនាំយកឈើស្ទន់នោះចេញទៅ ហើយកាន់យកឈើជម្រះធ្មេញដទៃ ។ ព្រះថេរៈធ្វើយ៉ាងនេះដល់ទៅ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទើបសួរ ( សាមណេរ ) ដដែលទៀត ។ សាមណេរក៏ប្រាប់ដូចដើម ដែលបានពោលមកហើយក្នុងកាលមុននោះឯង ។

ព្រះថេរៈដឹងយ៉ាងច្បាស់ថា ព្រាហ្មណ៍ម្នាក់នេះ ជាអ្នកប្រដៅងាយហ្ន៎ ទើបសួរថា អ្នកមកដើម្បីបំណងដូចម្តេច សាមណេរប្រាប់ថា ដើម្បីបំណងរៀនពុទ្ធវចនៈ ព្រះថេរៈប្រាប់ថា អ្នកចូររៀនក្នុងកាលឥឡូវនេះចុះ ទើបផ្តើមឲ្យរៀនព្រះពុទ្ធវចនៈ តាំងអំពីព្រលឹមនោះទៅ ។

តិស្សៈ ទាំងកាពដែលខ្លួនជាសាមណេរនោះឯង រៀនយកពុទ្ធវចនៈទាំងអស់ ព្រមទាំងអដ្ឋកថា វៀរព្រះវិនយបិដក ។ ក្នុងពេលឧបសម្បទាហើយ មិនបានវស្សាឡើយ បានជា តិបិដកធរៈ( ទ្រទ្រង់ព្រះត្រៃបិដក ) ។ អាចារ្យ និងឧបជ្ឈាយ៍ ប្រគល់ពុទ្ធវចនៈទាំងអស់ទុកក្នុងដៃរបស់មោគ្គលីបុត្តតិស្សភិក្ខុហើយ តាំងនៅដរាបដល់អស់អាយុ ក៏បរិនិព្វាន ។

ឯព្រះមោគ្គលីបុត្តតិស្សត្ថេរចម្រើនកម្មដ្ឋានហើយ សម្រេចជាព្រះអរហន្ត ក្នុងសម័យក្រោយមក បង្រៀនព្រះធម៌ និងព្រះវិន័យដល់ភិក្ខុដ៏ច្រើន ។

# រឿងអសោកមហារាជ

សម័យនោះឯង ព្រះបាទពិម្ពិសារ មានព្រះរាជឱរស ១០១ អង្គ ព្រះបាទអសោកបញ្ជាឲ្យសម្រេចទោស គឺសម្លាប់ព្រះរាជឱរសទាំងនោះអស់គ្មានសល់ ទុកតែតិស្សកុមារដែលរួមផ្ទៃមាតាជាមួយព្រះអង្គ ។ លោកកាលបញ្ជា

ឲ្យសម្រេចទោស ទ្រង់មិនទាន់បានអភិសេកឡើយ ទ្រង់គ្រងរាជ្យដល់ទៅ ៤ ឆ្នាំ លុះកន្លងទៅ បាន ៤ ឆ្នាំ ក្នុងឆ្នាំទី ១៨ បន្ទាប់អំពី ២០០ ឆ្នាំ គិតពីឆ្នាំបរិនិព្វានរបស់ព្រះតថាគតមក ទើបទ្រង់ដល់នូវការអភិសេក ជាស្តេចឯករាជ្យក្នុងជម្ពូទ្វីបទាំងមូល ។

ដោយអានុភាពនៃការអភិសេករបស់ទ្រង់ រាជឫទ្ធិទាំងឡាយនេះ បានមកហើយ ។ ព្រះរាជអំណាចផ្សាយទៅខាងក្រោមមហាប្រឹថពីប្រមាណមួយយោជន៍ ក្នុងអាកាសខាងលើក៏ដូចគ្នា ។

ព្រះរាជាទ្រង់មានសទ្ធាកើតហើយក្នុងព្រះសាសនា ទ្រង់បាន ( បែងចែក ) ទឹក ៨ ក្អមអំពីទឹក ១៦ ក្អម ដែលពួកទេវតានាំមកអំពីអនោតត្តស្រះ មួយថ្ងៃ ៨ អម្រែក ប្រគេនដល់ភិក្ខុសង្ឃ ប្រគេនដល់ភិក្ខុទាំងឡាយដែលទ្រទ្រង់ព្រះត្រៃបិដកប្រមាណ ៦០ អង្គ ( មួយថ្ងៃ ) ២ ក្អម ព្រះរាជទានដល់ព្រះនាងអសន្ធិមិត្តា ជាព្រះអគ្គមហេសី ( មួយថ្ងៃ ) ២ ក្អម ព្រះរាជទានដល់ស្ត្រីបាំទាំងឡាយ ១៦០០០ នាក់ ( មួយថ្ងៃ ) ២ ក្អម ទ្រង់ប្រើប្រាស់ដោយខ្លួនឯង ( មួយថ្ងៃ ) ២ ក្អម ។ កិច្ច គឺការជម្រះព្រះទន្តនិងការជម្រះធ្មេញរាល់ៗ ថ្ងៃរបស់ព្រះរាជា ព្រះមហេសី និងរបស់ពួកស្ត្រីអ្នករបាំ ១៦០០០ នាក់ និងរបស់ភិក្ខុប្រមាណ ៦ ម៉ឺនអង្គ រមែងសម្រេចបានដោយឈើជម្រះធ្មេញ ឈ្មោះនាគលតាដែលទន់ល្អ ប្រកបដោយឱជារសដែលមាននៅក្នុងព្រៃហិមពាន្ត ដែលទេវតាទាំងឡាយនាំមកថ្វាយរាល់ៗ ថ្ងៃនោះឯង ។

ម្យ៉ាងទៀត ទេវតាទាំងឡាយនាំផ្លែកន្ទួតព្រៃ ដែលជាឱសថ សម៉ដែលជាឱសថ និងផ្លែស្វាយទុំ ដែលមានពណ៌ដូចមាស សម្បូរដោយក្លិន និងរសមកថ្វាយដល់ព្រះរាជាអង្គនោះ រាល់ៗថ្ងៃ ដូចគ្នា និងបាននាំព្រះភូសាស្លៀកព្រះភូសាដណ្តប់ដែលមានពណ៌ ៥ សំពត់ជូតព្រះហស្ត ដែលមានពណ៌លឿង ហើយនាំទិព្វបានៈ គឺទឹកទិព្វអំពីស្រះឆទ្ទន្តមកថ្វាយរាល់ថ្ងៃយ៉ាងនោះ ។

ចំណែកស្តេចនាគទាំងឡាយ ក៏នាំគ្រឿងព្រះសុគន្ធសម្រាប់កក់ព្រះសីសៈ ព្រះសុគន្ធសម្រាប់លាបព្រះវរកាយ សំពត់មានពណ៌ដូចផ្កាម្លិះដែលមិនបានត្បាញដោយអំបោះ ដើម្បីជាព្រះភូសាដណ្តប់ និងថ្នាំបន្តក់ភ្នែកដែលមានតម្លៃច្រើន ពីនាគពិភពមកថ្វាយដល់ព្រះរាជាអង្គនោះរាល់ៗ ថ្ងៃដូចគ្នា ។

សត្វសេកទាំងឡាយ ក៏នាំស្រូវសាលី ៩ ពាន់រទេះ ដែលដុះឯងក្នុងស្រះឆទ្ទន្តនោះឯង មកថ្វាយរាល់ៗ ថ្ងៃ ។ កណ្តុរទាំងឡាយ ក៏បន្ទិចស្រូវទាំងនោះឲ្យអស់សម្បក និងកន្ទក់ ។ អង្ករដែលបាក់សូម្បីតែមួយគ្រាប់ក៏មិនមាន ។ អង្ករនេះឯង ដល់នូវភាពជាព្រះក្រយាស្ងោយនៃព្រះរាជា ក្នុងទីគ្រប់កន្លែង ។ ឃ្មុំទាំងឡាយ ក៏នាំទឹកឃ្មុំ ពួកខ្លាឃ្មុំ ក៏ពុះឧសក្នុងរោងចុងភៅ ពួកករវិក ក៏ហើរមកស្រែកបញ្ចេញសូរសៀងយ៉ាងពីរោះ ធ្វើពលិកម្មថ្វាយដល់ព្រះរាជា ។

## ព្រះបាទអសោកច្រាប់កាឡនាគឲ្យនិម្មិតជាព្រះពុទ្ធ

ព្រះរាជាទ្រង់ប្រកបដោយឫទ្ធិទាំងនេះ ថ្ងៃមួយ ទ្រង់ប្រើសង្វាលិកពន្ធដែលធ្វើដោយមាស ឲ្យទៅចងស្តេចនាគ ឈ្មោះថា កាឡៈ មានអាយុអស់

មួយកប្ប ដែលធ្លាប់បានឃើញរូបរបស់ព្រះពុទ្ធទាំងឡាយ ៤ ព្រះអង្គ ឲ្យមកធ្លាយរនេ្ទលលើបល្ល័ង្កដែលមានតម្លៃច្រើន ខាងក្រោមស្វេតច្ឆត្រ ទ្រង់ធ្វើការបូជាដោយផ្កាឈើដែលកើតក្នុងទឹក និងកើតលើគោក ច្រើនវណ្ណៈ និងដោយសុវណ្ណបុប្ផា ទ្រង់ហែហមដោយអ្នករបាំ ១៦០០០ នាក់ ដែលប្រដាប់ហើយដោយអលង្ការទាំងពួងដោយជុំវិញ ត្រាស់ថា សូមលោកធ្វើព្រះរូបរបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រទ្រង់នូវចក្រ គឺព្រះសទ្ធម្មដ៏ប្រសើរឲ្យវិលទៅ ទ្រទ្រង់នូវព្រះញាណ មិនមានទីបំផុត ឲ្យដល់នូវគន្លងនៃ ភ្នែករបស់ពួកខ្ញុំចុះ ដូច្នេះ ទ្រង់ទតរូបព្រះពុទ្ធដែលស្តេចនាគឈ្មោះកាឡៈនោះនិម្មិតហើយ ប្រៀបបីដូចផ្ទៃទឹកដែលលម្អហើយ ដោយផ្កាឈូកក្រហម ផ្កាឧប្បល និងបុណ្ឌរិកដែលរីកស្គុសស្គាយ ហាក់បីដូចលម្អមេឃ ដែលព្រោងព្រាយដោយភាពចិញ្ចែងចិញ្ចាចធ្លៀលធ្លាត់នៃសំណាញ់រស្មីរបស់ហ្វូងតារា ព្រោះភាពដែលព្រះពុទ្ធរូបនោះ ទ្រង់មានព្រះសិរីដោយមហាបុរិសលក្ខណៈ ៣២ ប្រការ លម្អហើយដោយអនុព្យញ្ជនៈ ៨០ ប្រការ ដែលកើតដោយអំណាចនៃបុណ្យដ៏ពណ្ណរាយពេញព្រះសរីរៈទាំងមូល រុងរឿងដោយព្រះកេតុមាលាដ៏ធើតធាយដែលប្រាសចាកមន្ទិលផ្សេងៗបីដូចកំពូលភ្នំមាស ធ្លៀលធ្លាត់ដោយពន្លឺឥន្ទធនូ និងផ្លេកបន្ទោរ ដែលលម្អដោយពន្លឺប្រាក់ ហាក់បីដូចស្រូបយកនូវកែវភ្នែកនៃគណៈមហាព្រហ្ម ទេវតា មនុស្ស នាគ និងពួកយក្ខទាំងឡាយ ព្រោះព្រះពុទ្ធរូបនោះ មានសភាពធ្លៀលធ្លាត់ដោយបណ្តាញនៃរស្មី ដែលផ្សាយចេញមួយព្យាមដោយជុំវិញ មានរស្មីវិចិត្រដោយពណ៌ខៀវ លឿង ក្រហមជាដើម

ទ្រង់បានធ្វើការបូជា ដែលបានឈ្មោះថាបូជាដោយភ្នែក រហូត ៧ ថ្ងៃ ។

## ព្រះរាជាមិនជ្រះថ្លាក្នុងអ្នកបួសក្រៅសាសនា

បានឮថា ព្រះរាជា កាលទ្រង់អភិសេកហើយ ទ្រង់បានរាប់អានលទ្ធិពាហិរបាសណ្ឌៈ[១] អស់កាល ៣ ឆ្នាំនោះឯង ។ ក្នុងឆ្នាំទី ៤ ទើបទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ បានឮថា ព្រះបាទពិន្ទុសារជាបិតារបស់ព្រះរាជាអង្គនេះ ទ្រង់បានរាប់អានពួកព្រាហ្មណ៍ ទ្រង់បានរៀបចំនិច្ចភត្តទុកដល់ពួកព្រាហ្មណ៍ ពួកបណ្ឌរង្គៈ គឺអ្នកស្លៀកពាក់ស និងបរិព្វាជកជាដើមដែលកាន់លទ្ធិបាសណ្ឌៈ ដែលជារបស់ប្រចាំជាតិព្រាហ្មណ៍ មានប្រមាណ ៦ សែននាក់ ។ សូម្បីព្រះបាទអសោក ក៏ទ្រង់ថ្វាយទានដែលព្រះជនក ឲ្យប្រព្រឹត្តទៅខាងក្នុងបុរីរបស់ព្រះអង្គយ៉ាងនោះដែរ ។ ថ្ងៃមួយ បានប្រថាប់ឈរត្រង់មាត់បង្អួច ទតឃើញពួកព្រាហ្មណ៍ទាំងនោះកំពុងបរិភោគ ( អាហារ ) ដោយមារយាទអាក្រក់ អំពីសេចក្តីស្ងប់រៀបរយ មិនមានការសង្រួមឥន្ទ្រិយផង មិនបានទទួលការអប់រំឥរិយាបថផង ទើបទ្រង់ត្រិះរិះថា ការដែលអញពិចារណាមុនហើយ ឲ្យទាន ដូច្នេះ ក្នុងស្រែបុណ្យដែលសម ទើបគួរ កាលទ្រង់ត្រិះរិះយ៉ាងនេះហើយ ទើបត្រាស់ហៅពួកអមាត្យថា នែអ្នកទាំងឡាយ ពួកអ្នកចូរនាំសមណៈ និងព្រាហ្មណ៍រៀងៗ ខ្លួន ដែលអ្នកសន្មតថា ល្អ មកខាងក្នុងព្រះរាជវាំង យើងនឹងថ្វាយទាន ។ ពួកអមាត្យទទួលព្រះរាជឱង្ការថា សាធុ

---

[១] បាសណ្ឌៈ គឺលទ្ធិដែលកាន់ខុស ឬមេលទ្ធិដែលកាន់ខុស ប្រែតាមរូបសព្ទថា លទ្ធិអន្ទាក់ គឺអន្ទាក់ទាក់ចិត្តសត្វ មាន ២ គឺតណ្ហាបាសៈ អន្ទាក់ គឺតណ្ហា ១ ទិដ្ឋិបាសៈ អន្ទាក់ គឺទិដ្ឋិ ១ ។

ព្រះអង្គ ហើយក៏បាននាំអ្នកបួសក្រៅសាសនា មានបណ្ឌុរង្គៈ បរិព្វាជក អាជីវក និងនិគ្រន្ថជាដើមនោះៗ មកហើយ ទូលថា បពិត្រព្រះអង្គ លោកទាំងនេះជាព្រះអរហន្តរបស់ទូលបង្គំទាំងឡាយ ពេលនោះ ព្រះរាជាទ្រង់ប្រើឲ្យក្រាលអាសនៈទាំងខ្ពស់ និងទាបទុកខាងក្នុងព្រះរាជវាំង ហើយប្រាប់ថា អញ្ជើញសមណៈមកចុះ ទើបទ្រង់អញ្ជើញពួកអ្នកបួសដែលមកហើយថា អញ្ជើញអង្គុយលើអាសនៈដែលសមគួររៀងៗ ខ្លួនចុះ ដូច្នេះ ។ បណ្ដាអ្នកបួសទាំងនោះ ពួកខ្លះអង្គុយលើតាំងដែលមានបន្ទះកដ៏ប្រសើរ ពួកខ្លះក៏អង្គុយលើតាំងបន្ទះក្ដារ ។ ព្រះរាជាទតឃើញកិរិយាដែលអង្គុយនោះហើយក៏ទ្រង់ជ្រាបបានថា អ្នកបួសទាំងនោះមិនមានធម៌ដែលជាសារៈខាងក្នុងឡើយ បានប្រគេនរបស់ដែលគួរទំពា គួរបរិភោគ ដែលគួរដល់អ្នកបួសទាំងនោះហើយ ទ្រង់ក៏បញ្ជូនត្រឡប់ទៅ ។

កាលវេលាកន្លងទៅយ៉ាងនោះ ថ្ងៃមួយ ព្រះបាទអសោកប្រថាប់ឈរត្រង់សីហបញ្ជរ បានទតឃើញនិគ្រោធសាមណេរ ដែលជាអ្នកទូន្មានខ្លួនល្អ ហើយមានឥន្ទ្រិយស្ងប់ សម្បូរដោយឥរិយាបថកំពុងដើរឆ្លងទៅ កាត់លានព្រះរាជវាំង ។

## ប្រវត្តិនិគ្រោធសាមណេរ

សួរថា ឈ្មោះថា និគ្រោធនេះ គឺនរណា ឆ្លើយថា និគ្រោធនេះ ជាឱរសរបស់សុមនរាជកុមារ ដែលជាព្រះជេដ្ឋារសរបស់ព្រះបាទពិន្ទុសារ ។ ក្នុងរឿងនោះ មានអនុបុព្វីកថាដូចតទៅនេះថា

បានឮមកថា ក្នុងកាលដែលព្រះបាទពិម្ពិសារ ( ដែលជាព្រះជនក ) ទ្រង់ទុព្វលភាពនោះឯង ( ទ្រង់ប្រឈួនធ្ងន់ ) អសោករាជកុមារ បានលះបង់រាជ្យសម្បត្តិក្នុងក្រុងឧជ្ជេនីដែលខ្លួនបានហើយ ទ្រង់ត្រឡប់មកជណ្តើមយកព្រះនគរទាំងអស់ទុកក្នុងកណ្តាប់ដៃរបស់ខ្លួន ហើយបានចាប់សុមនរាជកុមារទុក ក្នុងថ្ងៃនោះឯង ព្រះទេវីឈ្មោះសុមនារបស់សុមនរាជកុមារ ទ្រង់ព្រះគភ៌ចាស់ខែហើយ ។ ព្រះនាងសុមនាទេវីនោះ ក្លែងភេទរត់គេច ធ្វើដំណើរទៅកាន់ស្រុកមនុស្សចណ្ឌាលមួយកន្លែង ក្នុងទីមិនឆ្ងាយ ព្រះនាងបានស្តាប់សំឡេងរបស់ទេវតាដែលស្ថិតនៅត្រង់ដើមជ្រៃមួយកន្លែង ក្នុងទីមិនឆ្ងាយអំពីផ្ទះមេភូមិអ្នកចណ្ឌាល ដែលពោលជម្រាបថា បពិត្រព្រះនាងសុមនា សូមព្រះនាងយាងចូលមកផ្លូវនេះចុះ ព្រះនាងក៏បានយាងចូលទៅជិតទេវតានោះ ។ ទេវតាបាននិម្មិតសាលាមួយខ្នងដោយអានុភាពរបស់ខ្លួន ហើយបានថ្វាយថា សូមព្រះនាងប្រថាប់នៅត្រង់សាលានេះចុះ ។ ព្រះទេវីនោះបានយាងចូលទៅកាន់សាលានោះហើយ ។ ក្នុងថ្ងៃដែលព្រះនាងយាងចូលទៅដល់នោះឯង ក៏ប្រសូតព្រះឱរស ។ ព្រោះហេតុដែលព្រះឱរសនោះ ដែលទេវតាអាស្រ័យនៅត្រង់ដើមជ្រៃរក្សា ទើបព្រះនាងទេវីនោះ ទ្រង់ថ្វាយព្រះនាមថា និគ្រោធ ។ មេភូមិអ្នកស្រុកចណ្ឌាលបានសម្គាល់ព្រះទេវីនោះ ដូចធីតានៃចៅហ្វាយរបស់ខ្លួន តាំងអំពីថ្ងៃដែលខ្លួនបានជួប ទើបបានបដិបត្តិជាប្រចាំ ។ ព្រះរាជធីតាបានប្រថាប់នៅនាទីនោះអស់ ៧ ឆ្នាំ ។ ចំណែកនិគ្រោធកុមារ ក៏មានជន្មាយុបាន ៧ ឆ្នាំហើយ ។

ក្នុងកាលនោះ ព្រះថេរៈមួយអង្គ ឈ្មោះមហាវរុណត្ថេរ ជាព្រះអរហន្ត បានឃើញការដល់ព្រមនៃហេតុរបស់ទារក បានពិចារណាថា ឥឡូវនេះ កុមារមានអាយុបាន ៧ ឆ្នាំ ជាកាលសមគួរ ដែលនឹងឲ្យកុមារបួសបាន ទើបទូលព្រះរាជធីតាឲ្យជ្រាប ហើយឲ្យនិគ្រោធកុមារនោះបួស ។ ក្នុងពេលកោរសក់ស្រេចនោះឯង និគ្រោធកុមារបានសម្រេចជាព្រះអរហន្ត ។ ថ្ងៃមួយ និគ្រោធសាមណេរនោះ ជម្រះរាងកាយអំពីព្រលឹម ធ្វើអាចរិយវត្ត និង ឧបជ្ឈាយវត្តស្រេចហើយ កាន់យកបាត្រ និងចីវរ គិតថា អញនឹងទៅកាន់ផ្ទះរបស់ឧបាសិកាជាមាតា ហើយក៏ចេញទៅ ។ ឯនិវាសដ្ឋាននៃឧបាសិកាជាមាតារបស់និគ្រោធសាមណេរនោះ ត្រូវដើរចូលទៅកាន់ព្រះនគរតាមទ្វារទិសខាងត្បូង ធ្លងកាត់កណ្ដាលព្រះនគរ ទៅចេញតាមផ្លូវទ្វារទិសខាងកើត ។ សម័យនោះឯង ព្រះបាទអសោកធម្មរាជ ទ្រង់ចង្ក្រមត្រង់មាត់បង្អួច បែរព្រះភក្ត្រទៅទិសខាងកើត ។ ខណៈនោះឯង និគ្រោធសាមណេរ ជាអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ មានភ្នែកសម្លឹងប្រមាណមួយជួរនឹម ដើរទៅដល់លានព្រះរាជវាំង ។ ព្រោះហេតុនោះ ទើបខ្ញុំពោលទុកថា ថ្ងៃមួយ ព្រះបាទអសោកប្រថាប់ឈរត្រង់សីហបញ្ជរ បានទតឃើញនិគ្រោធសាមណេរដែលជាអ្នកទូន្មានខ្លួន មានឥន្ទ្រិយស្ងប់ សម្បូរដោយឥរិយាបថ កំពុងដើរកាត់ទៅតាមលានព្រះរាជវាំង ដូច្នេះ ។

កាលទតឃើញហើយ ព្រះរាជាទ្រង់បានរំពឹងដូច្នេះថា ជនទាំងអស់នេះ មានចិត្តរាយមាយ មានចំណែកប្រៀបដូចម្រឹគដែលរត់ស្ទុះទៅ ចំណែកកុមារ

នេះ មិនមានចិត្តរវើរវាយ ការមើលទៅមុខ ការក្រឡេកមើលឆ្វេងស្តាំ ការបត់កន្ទុញ ការលាតសណ្តូករបស់កុមារនេះល្អពន់ពេក ខាងក្នុងរបស់ទារកនេះ គួរនឹងមានលោកុត្តរធម៌ពិតប្រាកដ ដូច្នេះ ព្រមគ្នានឹងការទតឃើញរបស់ព្រះរាជានោះឯង ព្រះហឫទ័យក៏ជ្រះថ្លាក្នុងសាមណេរ ការស្រឡាញ់ក៏បានតាំងឡើង ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះឮថា ក្នុងកាលមុន ក្នុងវេលាធ្វើបុណ្យ និគ្រោធសាមណេរនេះ បានជាអ្នកជំនួញ ជាបងប្រុសរបស់ព្រះរាជា សមដូចពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា

**បុព្វេវ សន្និវាសេន បច្ចុប្បន្នហិតេន វា**
**ឯវំ តំ ជាយតេ បេមំ ឧប្បលំវ យថោទកេ ។**

សេចក្តីស្រឡាញ់នោះ រមែងកើតព្រោះហេតុ ២ យ៉ាង គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុង ១ ក្នុងបច្ចុប្បន្ននេះ ដូចជាឧប្បលដែលដុះក្នុងទឹក ដោយហេតុ ២ យ៉ាង គឺទឹក ១ ភក់ ១ ដូច្នោះ ។

លំដាប់នោះ ព្រះរាជាទ្រង់កើតសេចក្តីស្រឡាញ់ មានការរាប់អានខ្លាំងក្នុងសាមណេរនោះ ទើបទ្រង់បញ្ជាពួកអមាត្យថា ពួកលោកចូរនិមន្តសាមណេរនោះមក ។ ទ្រង់រំពឹងថា អមាត្យទាំងនោះមុខជានឹងយឺតយូរ ទើបទ្រង់បញ្ជូនទៅ ២-៣ នាក់ទៀតថា ចូរឲ្យសាមណេរនោះប្រញាប់មកចុះ ។ សាមណេរបានដើរទៅតាមប្រក្រតីរបស់ខ្លួននោះឯង ។ ព្រះរាជាត្រាស់ថា លោកម្ចាស់ជ្រាបអាសនៈដែលគួរហើយ និមន្តអង្គុយចុះ សាមណេរនោះក្រឡេកមើលឆ្វេងស្តាំ ហើយគិតថា ឥឡូវនេះ មិនមានភិក្ខុដទៃ ទើបដើរ

ចូលទៅក្បែរបល្ល័ង្កដែលលើកស្វេតច្ឆត្រទុក ហើយសម្ដែងអាការដល់ព្រះរាជា ដើម្បីឲ្យទ្រង់ទទួលបាត្រ ។ ព្រះរាជាទ្រង់ទតឃើញសាមណេរនោះកំពុងដើរចូលទៅជិតបល្ល័ង្កនោះឯង ទើបទ្រង់ព្រះតម្រិះថា ថ្ងៃនេះឯងសាមណេរអង្គនេះនឹងជាម្ចាស់របស់រាជមណ្ឌបនេះ ក្នុងឥឡូវនេះ សាមណេរឲ្យបាត្រត្រង់ដៃព្រះរាជា ហើយឡើងអង្គុយលើបល្ល័ង្ក ព្រះរាជាទ្រង់បង្អោនប្រគេនអាហារគ្រប់ប្រភេទ គឺបបរ ខាទនីយៈ និងភោជនីយៈ ដែលគេរៀបចំទុក ដើម្បីប្រយោជន៍ដល់ព្រះអង្គ ( ដល់សាមណេរនោះ ) ។ សាមណេរទទួលអាហារល្មមញុំាងអត្តភាពរបស់ខ្លួនឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ។

ក្នុងទីបំផុតកត្តកិច្ច ព្រះរាជាត្រាស់សួរថា បពិត្រសាមណេរ លោកចេះព្រះឱវាទដែលព្រះសាស្ដាទ្រង់ប្រទានដល់ពួកលោកដែរឬ ។

សាមណេរថ្វាយព្រះពរថា បពិត្រមហារាជ អាត្មាភាពរមែងចេះដោយឯកទេស ( ប៉ុណ្ណោះ ) ។

ព្រះរាជាទ្រង់អារាធនាថា បពិត្រសាមណេរ សូមលោកម្ចាស់សម្ដែងឱវាទដែលលោកម្ចាស់ដឹងនោះដល់ញោមខ្លះផង ។

សាមណេរទទួលថា បានមហាបពិត្រ ដូច្នេះហើយ បានពោលអប្បមាទវគ្គក្នុងធម្មបទតាមសមគួរដល់ព្រះរាជា ដើម្បីប្រយោជន៍ដល់ការអនុមោទនាឲ្យព្រះរាជាបានស្ដាប់ថា **អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ** ការមិនប្រមាទ ជាផ្លូវមិនស្លាប់ សេចក្ដីប្រមាទជាផ្លូវនៃសេចក្ដីស្លាប់ ដូច្នេះជាដើម ហើយទ្រង់អារាធនាថា បពិត្រសាមណេរ សូមញុំាង

ធម្មទេសនាដែលខ្ញុំបានដឹងហើយ ឲ្យចប់ជាមុន ដូច្នេះ ។

ក្នុងអវសាននៃការអនុមោទនា ព្រះរាជាទ្រង់ពិតថា បពិត្រសាមណេរ ញោមនឹងប្រគេនធុវភត្តដល់លោកម្ចាស់ ៨ សម្រាប់ ។ សាមណេរថ្វាយព្រះពរថា បពិត្រមហារាជ អាត្មានឹងប្រគេនធុវភត្តទាំងនេះដល់ព្រះឧបជ្ឈាយ៍ ( របស់អាត្មា ) ។ ព្រះរាជាត្រាស់សួរថា បពិត្រសាមណេរ ដែលឈ្មោះថាឧបជ្ឈាយ៍នេះ បានដល់ បុគ្គលដូចម្តេច សាមណេរឆ្លើយថា បពិត្រមហារាជ បុគ្គលដែលសម្លឹងទោសតូចធំ ហើយដាស់តឿន និងឲ្យរឭក ឈ្មោះថាឧបជ្ឈាយ៍ ។ ព្រះរាជាពិតថា បពិត្រសាមណេរ ញោមនឹងប្រគេនភត្ត ៨ សម្រាប់ដទៃទៀតដល់លោកម្ចាស់ ។ សាមណេរប្រាប់ថា បពិត្រមហារាជ អាត្មានឹងប្រគេនភត្តទាំងនោះដល់អាចារ្យ ( របស់អាត្មា ) ។ ព្រះរាជាត្រាស់សួរថា បពិត្រសាមណេរ បុគ្គលដែលឈ្មោះថាអាចារ្យនេះ បានដល់ បុគ្គលដូចម្តេច ។ សាមណេរឆ្លើយថា បពិត្រមហារាជ បុគ្គលដែលឲ្យអន្តេវាសិកនិងសទ្ធិវិហារិកតាំងនៅក្នុងធម៌ ដែលគួរសិក្សាក្នុងសាសនានេះ ឈ្មោះថាអាចារ្យ ។ ព្រះរាជាត្រាស់ថា សាធុ សាមណេរ ញោមនឹងប្រគេនភត្ត ៨ សម្រាប់ទៀតដល់លោកម្ចាស់ ។ សាមណេរពិតថា បពិត្រមហារាជ អាត្មានឹងប្រគេនភត្តទាំងនោះដល់ភិក្ខុសង្ឃ ព្រះរាជាត្រាស់សួរថា បពិត្រសាមណេរ បុគ្គលដែលឈ្មោះថា ភិក្ខុសង្ឃនេះ បានដល់បុគ្គលដូចម្តេច ។ សាមណេរពិតថា បពិត្រមហារាជ បព្វជ្ជា និងឧបសម្បទារបស់អាចារ្យ និងឧបជ្ឈាយ៍របស់អាត្មាក្តី បព្វជ្ជារបស់អាត្មាក្តី អាស្រ័យពួកភិក្ខុណា ពួកភិក្ខុនោះ ឈ្មោះ

ថា ភិក្ខុសង្ឃ ។ ព្រះរាជាទ្រង់ពេញព្រះរាជហឫទ័យក្រៃលែង ហើយទ្រង់ប្រាប់ថា បពិត្រសាមណេរ ញោមនឹងប្រគេនភត្ត ៨ សម្រាប់ដទៃទៀតដល់លោកម្ចាស់ ។ សាមណេរទទួលថា សាធុ ។ ក្នុងថ្ងៃស្អែកឡើង បាននាំយកភិក្ខុ ៣២ អង្គ ចូលទៅខាងក្នុងព្រះរាជវាំង ឆាន់ភត្តាហារ ។

ព្រះរាជា ទ្រង់បវារណាថា ភិក្ខុ ៣២ អង្គដទៃ ព្រមទាំងពួកលោកម្ចាស់ សូមទទួលភត្តក្នុងថ្ងៃស្អែកចុះ ដូច្នេះហើយ ទ្រង់ឲ្យបន្ថែមភិក្ខុច្រើនឡើងៗ រាល់ថ្ងៃ ដោយឧបាយយ៉ាងនោះឯង ទ្រង់បានកាត់បន្ថយភត្តពួកអ្នកបួសក្រៅពុទ្ធ-សាសនា មានព្រាហ្មណ៍ និងបរិព្វាជកជាដើម ទាំង ៦ សែននាក់ចេញ ហើយទ្រង់បានរៀបចំនិច្ចភត្តទុកសម្រាប់ភិក្ខុ ៦ សែនអង្គ ក្នុងព្រះរាជនិវេសន៍ ព្រោះការជ្រះថ្លាដែលប្រព្រឹត្តទៅក្នុងនិគ្រោធត្ថេរនោះឯង ។ ចំណែកព្រះនិគ្រោធត្ថេរក៏ឲ្យព្រះរាជា ព្រមទាំងបរិស័ទតាំងនៅក្នុងត្រៃសរណគមន៍ និងបញ្ចសីល ធ្វើឲ្យជាបុគ្គលមានសទ្ធាមិនកម្រើក ដោយការជ្រះថ្លាតាមបែបបុថុជ្ជន ហើយឲ្យតាំងមាំនៅក្នុងព្រះពុទ្ធសាសនា ។

## ព្រះរាជាទ្រង់សាងវត្ត និងចេតិយ

ព្រះរាជា ទ្រង់បញ្ជាឲ្យមេជាងសាងមហាវិហារ ឈ្មោះអសោការាម ហើយក៏ទ្រង់រៀបចំភត្តទុកដើម្បីប្រគេនភិក្ខុ ៦ សែនអង្គទៀត ហើយទ្រង់បញ្ជាឲ្យសាងព្រះវិហារ ៨៤០០០ ខ្នង ដែលប្រដាប់ដោយចេតិយ ៨៤០០០ ទុកក្នុងព្រះនគរ ៨៤០០០ កន្លែង ពេញជម្ពូទ្វីបទាំងមូលប្រកបដោយធម៌នោះឯង មិនមែនមិនប្រកបដោយធម៌ឡើយ ។

បានឮថា ក្នុងសម័យថ្ងៃមួយ ព្រះរាជាទ្រង់ថ្វាយមហាទានត្រង់អសោការាម ប្រថាប់គង់នាកណ្តាលពួកភិក្ខុសង្ឃ ដែលរាប់បានប្រមាណ ៦ សែនអង្គ ទ្រង់បវារណាសង្ឃដោយបច្ច័យ ៤ ហើយត្រាស់សួរបញ្ហានេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឈ្មោះថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ មានប្រមាណប៉ុនណា ព្រះសង្ឃថ្វាយព្រះពរថា បពិត្រមហារាជ ឈ្មោះថា ធម៌ ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយនោះ ពោលដោយអង្គ មានអង្គ ៩ ពោលដោយខន្ធ មាន ៨៤០០០ ព្រះធម្មក្ខន្ធ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងព្រះធម៌ ហើយទ្រង់បញ្ជាថា ខ្ញុំនឹងបូជាព្រះធម្មក្ខន្ធមួយធម្មក្ខន្ធ ដោយវិហារមួយៗ ដូច្នេះ ក្នុងមួយថ្ងៃប៉ុណ្ណោះ ទ្រង់បានលះបង់ព្រះរាជទ្រព្យដល់ទៅ ៩៦ កោដិ ហើយទ្រង់បានបង្គាប់ពួកអមាត្យថា ទៅចុះបា ពួកលោកកាលឲ្យសាងវិហារក្នុងនគរមួយ ចូរឲ្យសាងព្រះវិហារ ៨៤០០០ ទុកក្នុងព្រះនគរ ៨៤០០០ នគរចុះ ដូច្នេះ ចំណែកព្រះអង្គទ្រង់បានផ្តើមការងារដើម្បី ប្រយោជន៍ដល់អសោកមហាវិហារ ក្នុងអសោការាម ។ ព្រះសង្ឃបានឲ្យព្រះថេរៈឈ្មោះឥន្ទគុត្តត្ថេរ ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន មិនមានអាសវៈ ជានវកម្មាធិដ្ឋាយី គឺភិក្ខុអ្នកដឹកនាំកសាង ។ ព្រះថេរៈបានញុំាងការងារដែលមិនទាន់សម្រេចនោះៗ ឲ្យសម្រេចដោយអានុភាពរបស់ខ្លួន ព្រះថេរៈបានឲ្យការសាងព្រះវិហារសម្រេចត្រឹម ៣ ឆ្នាំ ដោយអានុភាពយ៉ាងនោះ ។

ព្រះរាជសារគ្រប់ៗ នគរ បានមកដល់ក្នុងថ្ងៃជាមួយគ្នានោះឯង ។ ពួកអមាត្យបានក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះករុណា ព្រះវិហារ ៨៤០០០

សាងស្រេចហើយ ព្រះរាជាទ្រង់បញ្ជាឲ្យវាយស្គរប្រកាសទូទាំងនគរថា កន្លង
ទៅ ៧ ថ្ងៃអំពីថ្ងៃនេះ នឹងមានការឆ្លងព្រះវិហារ សូមឲ្យប្រជាជនទាំងអស់
សមាទានឧបោសថសីល រៀបចំខ្លួនក្នុងការឆ្លងព្រះវិហារ ទាំងខាងក្នុងព្រះនគរ
និងខាងក្រៅព្រះនគរកន្លងទៅ ៧ ថ្ងៃ មុនការឆ្លងព្រះវិហារនោះ ព្រះរាជា
ហែហមដោយពួកសេនាមានអង្គ ៤ រាប់បានច្រើនសែននាក់ ដែលស្លៀកពាក់
ដោយគ្រឿងអលង្ការគ្រប់យ៉ាង ទ្រង់ត្រាច់ទតព្រះនគរដែលមហាជនមានសេចក្តី
ឧស្សាហ៍ ក្នុងបំណងនឹងតាក់តែងព្រះនគរ បានរៀបចំប្រដាប់តាក់តែងហើយ ឲ្យ
មានការស្រស់ស្អាតក្រៃលែងជាងសិរីនៃព្រះរាជធានី ឈ្មោះអមរវតី ក្នុងទេវ-
លោក ទ្រង់ព្រះរាជដំណើរទៅកាន់ព្រះវិហារ បានប្រថាប់ឈរត្រង់កណ្តាលភិក្ខុ
សង្ឃ ។ ក៏ភិក្ខុដែលប្រជុំគ្នាក្នុងខណៈនោះ មានប្រមាណ ៨០ កោដិ ឯពួកភិក្ខុនី
មានប្រមាណ ៩ លាន ៦ សែន ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុដែលជាព្រះ
ខីណាស្រពរាប់បានប្រមាណមួយសែនអង្គ ។ ភិក្ខុខីណាស្រពទាំងនោះ មាន
វិតក្កៈដូច្នេះថា បើព្រះរាជាគប្បីទតអធិការ ( ទានដ៏ក្រៃលែង ) មិនមានចំណែក
សេសសល់របស់ព្រះអង្គ ក៏នឹងគប្បីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាក្រៃលែងឡើង
បន្ទាប់អំពីនោះ ទើបធ្វើបាដិហារ្យឈ្មោះលោកវិវរណៈ ( គឺការបើកលោក ) ។

## ព្រះរាជាឃើញជម្ពូទ្វីបទាំងមូល

ព្រះរាជាប្រថាប់ឈរត្រង់អសោការាមនោះឯង ទ្រង់សម្លឹងមើលគ្រប់
ទិសទាំង ៤ បានឃើញជម្ពូទ្វីបដែលមានមហាសមុទ្រជាទីបំផុតដោយជុំវិញ និង
ព្រះវិហារ ៨៤០០០ ដែលរុងរឿងដោយការបូជា ក្នុងការឆ្លងព្រះវិហារ យ៉ាង

ឧឡារ ។ ព្រះរាជាកាលទតមើលសម្បត្តិនោះ ទ្រង់ក៏ប្រកបដោយបីតិបាមោជ្ជ ដ៏អស្ចារ្យ ទ្រង់ព្រះតម្រិះថា មានឬ ដែលបីតិបាមោជ្ជបែបនេះ ធ្លាប់កើតឡើង ដល់បុគ្គលដទៃណាមួយ ទើបត្រាស់សួរភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ ក្នុង សាសនារបស់ព្រះទសពលលោកនាថរបស់យើង មានបុគ្គលណា បានបរិច្ចាគ ដ៏សន្ធឹកសន្ធាប់ បរិច្ចាគរបស់បុគ្គលណាក្រៃលែងជាងនេះ ។ ភិក្ខុសង្ឃបាន ប្រគល់ការវិសជ្ជនាបញ្ហា ដែលព្រះរាជាត្រាស់សួរឲ្យជាកិច្ចដល់ ព្រះមោគ្គលី-បុត្តតិស្សត្ថេរ ។ ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ ឈ្មោះថា ការប្រគេន បច្ច័យក្នុងព្រះសាសនារបស់ព្រះទសពលដូចព្រះអង្គ ក្នុងកាលព្រះតថាគតគង់ ព្រះជន្មនៅ មិនមានបុគ្គលណាឡើយ មានតែព្រះអង្គប៉ុណ្ណោះ ទ្រង់បរិច្ចាគ ជាក្រៃលែង ។

## ព្រះរាជាមិនទាន់ជាទាយាទនៃសាសនា

ព្រះរាជា ទ្រង់ស្តាប់ពាក្យរបស់ព្រះថេរៈហើយ មានព្រះវរកាយ ដែល បីតិបាមោជ្ជដ៏ឧឡារពាល់ត្រូវហើយ មិនមានវាងចន្លោះ ទើបទ្រង់ព្រះតម្រិះថា បានឮថា បុគ្គលដែលប្រគេនបច្ច័យដូចអញមិនមាន បានឮថា អញមានមហា បរិច្ចាគ បានឮថា អញកំពុងលើកស្ទួយព្រះសាសនាដោយទេយ្យធម៌ បើដូច្នេះ អញបានឈ្មោះថា ជាទាយាទនៃព្រះសាសនាឬទេ ។ លំដាប់នោះ ទើបទ្រង់ ត្រាស់សួរភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ ញោមជាទាយាទនៃពុទ្ធសាសនា ឬ ក៏នៅទេ ។ លំដាប់នោះ ព្រះមោគ្គលីបុត្តតិស្សត្ថេរ ស្តាប់ព្រះរាជតម្រាស់នេះ ហើយ កាលសម្លឹងឃើញឧបនិស្ស័យសម្បត្តិនៃព្រះមហិន្ទ ដែលជាព្រះឱរស

( របស់ទ្រង់ ) ទើបត្រិះរិះថា បើរាជកុមារនេះបួសសោត ព្រះសាសនាក៏នឹងចម្រើនក្រៃលែង ទើបថ្វាយព្រះពររឿងនេះដល់ព្រះរាជាថា បពិត្រមហារាជ បុគ្គលដែលនឹងជាទាយាទនៃព្រះសាសនា មិនមែនដោយហេតុត្រឹមប៉ុណ្ណោះទេម្យ៉ាងទៀត បុគ្គលបូជាបច្ច័យដូច្នេះ រមែងដល់នូវការរាប់ថា បច្ចយទាយក ឬជាអ្នកឧបដ្ឋាក( ប៉ុណ្ណោះ ) បពិត្រមហារាជ ពិតហើយ បុគ្គលណាគប្បីបូជាបច្ច័យមានគំនរតាំងអំពីផែនដី រហូតដល់ព្រហ្មលោក បុគ្គលនោះ នៅមិនទាន់រាប់ថា ជាទាយាទក្នុងព្រះសាសនាបានឡើយ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ ទាយាទនៃព្រះសាសនា នឹងមានដូចម្ដេច ។ ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ បុគ្គលណាមួយ ជាអ្នកមានក៏ដោយ ជាអ្នកក្រក៏ដោយ ឲ្យបុត្រដែលជាឱរសរបស់ខ្លួនបួស ( ក្នុងព្រះសាសនា ) បពិត្រមហារាជ បុគ្គលនេះ លោកហៅថា ជាទាយាទនៃសាសនា ។

កាលព្រះមោគ្គលីបុត្តតិស្សត្ថេរ ថ្វាយព្រះពរយ៉ាងនោះហើយ ព្រះបាទអសោកធម្មរាជ ទ្រង់ព្រះតម្រិះថា បានឮថា អញធ្វើការបរិច្ចាគបែបនេះហើយក៏នៅមិនទាន់ដល់ភាពជាទាយាទនៃព្រះសាសនាបាន ទ្រង់ប្រាថ្នាភាពជាទាយាទក្នុងព្រះសាសនា ទើបទ្រង់ទតឆ្វេងស្តាំ បានឃើញព្រះមហិន្ទកុមារ ( ដែលជាព្រះរាជឱរសរបស់ព្រះអង្គ ) ដែលប្រថាប់ឈរក្នុងទីមិនឆ្ងាយ កាលទតឃើញហើយ ព្រះរាជាទ្រង់ក៏រំពឹងដូច្នេះថា អញមានបំណងនឹងស្ថាបនាកុមារអង្គនេះទុកក្នុងតំណែងជាឧបរាជ ចាប់តាំងអំពីពេលតិស្សកុមារបួសហើយក៏ពិត

សូម្បីយ៉ាងនោះ បព្វជ្ជានេះឯង ជាគុណជាតឧត្តមជាងតំណែងឧបរាជនោះទៅទៀត ។ លំដាប់នោះ ទើបព្រះរាជាទ្រង់ប្រាប់ព្រះកុមារថា នែកូន កូនអាចបួសបានឬទេ រាជកុមារតាមប្រក្រតី ចាប់តាំងពីពេលតិស្សកុមារទ្រង់បួសហើយ ក៏មានបំណងចង់បួសនោះឯង លុះបានឮព្រះរាជតម្រាស់ក៏កើតបាមោជ្ជយ៉ាងក្រៃលែង ហើយក្រាបទូលថា បពិត្រសម្មតិទេព ទូលបង្គំនឹងបួសក្រាបទូលសូមទ្រង់ព្រះបរមរាជានុញ្ញាត ឲ្យទូលបង្គំបួសចុះ នឹងបានជាទាយាទក្នុងព្រះសាសនា ។

សម័យនោះឯង សូម្បីព្រះនាងសង្ឃមិត្តាព្រះរាជធីតា ( របស់ទ្រង់ ) ក៏ឈរក្នុងទីនោះឯង ។ ព្រះរាជកុមារឈ្មោះថា អគ្គិព្រហ្ម ជាព្រះស្វាមីរបស់ព្រះនាងសង្ឃមិត្តានោះឯង ក៏បានបួសជាមួយតិស្សកុមារដែលជាឧបរាជហើយ ព្រះរាជាទតឃើញព្រះនាងសង្ឃមិត្តានោះហើយ ទើបប្រាប់ថា បុត្រី កូនអាចបួសបានឬទេ ព្រះនាងទូលថា សាធុ ព្រះបិតា ខ្ញុំម្ចាស់អាច ។ ព្រះរាជាទ្រង់ពេញព្រះទ័យនឹងព្រះរាជឱរស និងព្រះរាជធីតាហើយ មានព្រះរាជហឫទ័យរីករាយ ទើបមានតម្រាស់ជាមួយភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ ឲ្យកុមារទាំងនេះបួស ហើយធ្វើញោមឲ្យជាទាយាទក្នុងសាសនាចុះ ។ ព្រះសង្ឃទទួលព្រះរាជតម្រាស់ហើយ ក៏ឲ្យព្រះកុមារបព្វជ្ជាដោយមានព្រះមោគ្គលីបុត្តតិស្សត្ថេរជាឧបជ្ឈាយ៍ និងមានព្រះមហាទេវត្ថេរជាបព្វជ្ជាចារ្យ មានព្រះមជ្ឈន្តិកត្ថេរជាឧបសម្បទាចារ្យ ។ បានឮថា កាលនោះព្រះកុមារមានព្រះជន្មបាន ២០ ឆ្នាំបរិបូណ៌ ។

## ព្រះមហិន្ទត្ថេរបានសម្រេចអរហត្ត

លោកបានសម្រេចជាព្រះអរហន្ត មួយអន្លើដោយបដិសម្ភិទាក្នុងមណ្ឌល ឧបសម្បទានោះឯង ។ អាចារ្យរបស់ព្រះនាងសង្ឃមិត្តារាជធីតា ឈ្មោះថា អាយុបាលិត្ថេរី ចំណែកឧបជ្ឈាយ៍ឈ្មោះថា ធម្មបាលិត្ថេរី ។ បានឮថា កាល នោះព្រះនាងសង្ឃមិត្តា មានព្រះជន្ម ១៨ ឆ្នាំ ។ ភិក្ខុសង្ឃញ៉ាំងព្រះនាង សង្ឃមិត្តានោះ ដែលល្មមបព្វជ្ជាហើយ ឲ្យតាំងនៅក្នុងសិក្ខា ក្នុងរោងមាន សីមានោះឯង ។

វេលាដែលព្រះឱរស និងព្រះធីតាទាំងពីរបួសហើយ ព្រះរាជាទ្រង់ អភិសេកគ្រងរាជ្យបាន ៦ ឆ្នាំ ក្រោយពេលដែលទ្រង់បួសហើយ ព្រះមហិន្ទ ក៏សិក្សារៀនសូត្រព្រះធម៌ និងព្រះវិន័យ ក្នុងសម្នាក់ព្រះឧបជ្ឈាយ៍របស់ខ្លួន នោះឯង បានរៀនយកថេរវាទទាំងអស់ មួយអន្លើដោយអដ្ឋកថា ដែលលោក សង្គ្រោះដោយព្រះត្រៃបិដក ដែលឡើងកាន់សង្គីតិទាំងពីរលើក ចប់ក្នុងរយៈ ពេល ៣ ឆ្នាំ ហើយបានជាបាមោក្ខ ( ប្រធាន ) របស់ភិក្ខុទាំងឡាយប្រមាណ ១០០០ អង្គ ដែលជាអន្តេវាសិកនៃឧបជ្ឈាយ៍របស់ខ្លួន ។ សម័យនោះ ព្រះ បាទអសោកធម្មរាជ ទ្រង់អភិសេកបាន ៩ ឆ្នាំ ។

## ព្រះរាជាតាំងមូលនិធិថ្វាយសង្ឃ

ក្នុងរជ្ជកាលដែលព្រះរាជា ទ្រង់អភិសេកបាន ៨ ឆ្នាំនោះឯង ព្រះ កោន្តបុត្តតិស្សត្ថេរត្រាច់ទៅដើម្បីព្យាបាលរោគ ដោយភិក្ខាចារវត្ត ក៏មិនបាន ទឹកដោះសូម្បីមួយទូកដៃ ក៏អស់អាយុសង្ខារ ព្រោះកម្លាំងនៃព្យាធិ បានឲ្យ

ឱវាទភិក្ខុសង្ឃដោយការមិនប្រមាទ ហើយអន្លុយពត់ក្អែនក្នុងអាកាស ចូល
តេជោធាតុបរិនិព្វានហើយ ។

ព្រះរាជា ទ្រង់ជ្រាបការប្រព្រឹត្តទៅនោះហើយ ទ្រង់បានធ្វើសក្ការៈដល់
ព្រះថេរៈ ហើយទ្រង់ប្រាប់ថា បើយើងនៅគ្រងរាជ្យ ពួកភិក្ខុចូរកុំលំបាកដោយ
បច្ច័យយ៉ាងនេះ ហើយទ្រង់បញ្ជាឲ្យសាងស្រះបោក្ខរណីទុកត្រង់ទ្វារទាំង ៤ នៃ
ព្រះនគរ ឲ្យដាក់ពេញដោយភេសជ្ជៈទុកប្រគេន ។ បានឮថា សម័យនោះ
គ្រឿងបណ្ណាការ ៥ សែន កើតឡើងដល់ព្រះរាជារាល់ៗ ថ្ងៃ គឺត្រង់ទ្វារទាំង
៤ នៃព្រះនគរបាដលីបុត្រ ៤ សែន ត្រង់សភា ១ សែន កាលនោះព្រះរាជា
ទ្រង់លះបង់ប្រគេនព្រះនិគ្រោធត្ថេរមួយថ្ងៃ ១ សែន ១សែន ដើម្បីបូជា
ដោយវត្ថុមានគ្រឿងក្រអូប និងផ្កាជាដើម ត្រង់ពុទ្ធចេតិយ ១ សែនដើម្បី
បូជាព្រះធម៌ គឺទ្រង់ប្រគេន១សែននោះ ដើម្បីប្រយោជន៍ដល់បច្ច័យ ៤ ដល់
ភិក្ខុទាំងឡាយដែលទ្រទ្រង់ធម៌ ជាពហូសូត ១ សែន ប្រគេនភិក្ខុសង្ឃ ១
សែនទៀតដើម្បីប្រយោជន៍ដល់ភេសជ្ជៈ ត្រង់ទ្វារទាំង ៤ ទិស ។ លាភ និង
សក្ការៈដ៏ឧឡារិកកើតហើយក្នុងសាសនាដោយអាការយ៉ាងនេះ ។

## ពួកតិរ្ថិយបន្លំបួសក្នុងព្រះពុទ្ធសាសនា

តិរ្ថិយទាំងឡាយ សាបសូន្យលាភ និងសក្ការៈហើយ ដោយហោចមិន
បានសូម្បីត្រឹមតែរបស់បរិភោគ និងគ្រឿងស្លៀកដណ្តប់ កាលប្រាថ្នាលាភ និង
សក្ការៈ ទើបបន្លំបួសក្នុងព្រះពុទ្ធសាសនា ហើយសម្តែងទិដ្ឋិ ( លទ្ធិ ) រៀងៗ
ខ្លួនថា នេះធម៌ នេះវិន័យ ។ ពួកតិរ្ថិយទាំងនោះ សូម្បីកាលមិនបានបួស ក៏

កោរសក់ខ្លួនឯង ហើយស្លៀកសំពត់កាសាយៈ ត្រាច់ទៅក្នុងវិហារទាំងឡាយ ចូលទៅ ( រួម ) ឧបោសថខ្លះ បវារណាខ្លះ សង្ឃកម្មខ្លះ គណកម្មខ្លះ ។ ភិក្ខុទាំងឡាយ មិនព្រមធ្វើឧបោសថរួមជាមួយពួកភិក្ខុតិរ្ថិយទាំងនោះ ។ សម័យនោះ ព្រះមោគ្គលីបុត្តតិស្សត្ថេរត្រិះរិះថា ឥឡូវនេះ អធិករណ៍កើតឡើងហើយ មិនយូរឡើយអធិករណ៍នោះនឹងអាក្រក់ឡើង ឯអញក៏នៅក្នុងចំណោមនៃភិក្ខុតិរ្ថិយតាំងនោះដែរ ធ្វើម្ដេចនឹងរម្ងាប់អធិករណ៍នោះបាន ដូច្នេះ ទើបប្រគល់ការងារគណៈដល់ព្រះមហិន្ទត្ថេរ ក្នុងបំណងនឹងសម្រាកនៅផាសុវិហារដោយខ្លួនឯង ហើយបានទៅកាន់អហោគង្គបព៌ត ។

ពួកតិរ្ថិយទាំងនោះឯង ត្រូវភិក្ខុសង្ឃហាមប្រាមដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនា ក៏មិនព្រមតាំងនៅក្នុងគោលបដិបត្តិដែលអនុលោមតាមព្រះធម៌វិន័យ ថែមទាំងបានឲ្យពាក្យបម្រុងចម្រាសមន្ទិល និងចង្រៃ តាំងឡើងដល់ព្រះសាសនាជាអនេក ពួកខ្លះបម្រើភ្លើង ពួកខ្លះធ្វើខ្លួនឲ្យក្ដៅនៅក្នុងចង្អើរ ៥ យ៉ាង ពួកខ្លះប្រព្រឹត្តវិលទៅតាមព្រះអាទិត្យ ពួកខ្លះក៏ពោលបញ្ជាក់ថា ពួកយើងនឹងទម្លាយព្រះធម៌ ព្រះវិន័យរបស់ពួកលោក ដូច្នេះ ។

សម័យនោះ ភិក្ខុសង្ឃមិនបានធ្វើឧបោសថ ឬបវារណារួមជាមួយតិរ្ថិយទាំងនោះឡើយ ។ ក្នុងអសោការាម ឧបោសថដាច់ដល់ទៅ ៧ ឆ្នាំ ។ ពួកភិក្ខុបានក្រាបទូលរឿងនោះដល់ព្រះរាជាហើយ ។

ព្រះរាជាទ្រង់បង្គាប់អមាត្យជំម្នាក់ទៅថា អ្នកទៅកាន់ព្រះវិហាររម្ងាប់អធិករណ៍ហើយ និមន្តភិក្ខុសង្ឃឲ្យធ្វើឧបោសថចុះ ដូច្នេះ ។ អមាត្យមិនអាច

ស្តាប់ន័យព្រះរាជាបាន ទើបចូលទៅរកអមាត្យទាំងឡាយដទៃ ហើយពោលថា ព្រះរាជាបញ្ជូនខ្ញុំទៅថា អ្នកចូរទៅកាន់វិហារ រម្ងាប់អធិករណ៍ ធ្វើឧបោសថចុះ ដូច្នេះ អធិករណ៍នឹងរម្ងាប់បានដូចម្តេចហ្ន៎ ។ អមាត្យទាំងនោះនិយាយថា ពួកខ្ញុំយល់សេចក្តីបានដោយឧបាយយ៉ាងនេះថា ពួករាជបុរស កាលបង្ក្រាបបច្ចន្ត-ជនបទឲ្យរាបទាប ក៏ត្រូវសម្លាប់ពួកចោរ យ៉ាងណា ភិក្ខុណាមិនធ្វើឧបោសថ ព្រះរាជានឹងមានព្រះរាជបំណងឲ្យសម្លាប់ភិក្ខុទាំងនោះ យ៉ាងនោះដូចគ្នា ។

លំដាប់នោះ អមាត្យធំនោះ ទៅកាន់វិហារ ណាត់ឲ្យភិក្ខុសង្ឃប្រជុំគ្នា ហើយប្រកាសថា ព្រះរាជាបញ្ជូនខ្ញុំមកថា អ្នកចូរនិមន្តភិក្ខុសង្ឃឲ្យធ្វើឧបោសថចុះ បពិត្រលោកម្ចាស់ ឥឡូវនេះ សូមលោកម្ចាស់ធ្វើឧបោសថកម្មចុះ ។ ពួកភិក្ខុនិយាយថា អាត្មាទាំងឡាយមិនធ្វើឧបោសថជាមួយពួកតិរ្ថិយឡើយ អមាត្យផ្តើមយកដាវកាត់ក្បាល ( របស់ភិក្ខុទាំងនោះ ) ឲ្យដាច់ទៅ តាំងអំពីដើមអាសនៈរបស់ព្រះថេរៈរៀងទៅ ។ ចំណែកព្រះតិស្សត្ថេរបានឃើញអមាត្យនោះ បដិបត្តិខុសយ៉ាងនោះឯង ។

## ប្រវត្តិរបស់ព្រះតិស្សត្ថេរ

ព្រះតិស្សត្ថេរមិនមែនមនុស្សសាមញ្ញធម្មតាឡើយ គឺកាតា ( ប្អូនប្រុស ) រួមព្រះរាជមាតាជាមួយព្រះរាជា មានឈ្មោះថា តិស្សកុមារ ។ បានឮថា ព្រះរាជាអភិសេកហើយ បានតែងតាំងតិស្សកុមារនោះក្នុងតំណែងឧបរាជ ។ ថ្ងៃមួយ តិស្សកុមារនោះ យាងទៅលេងព្រៃ បានទតឃើញម្រឹគមួយហ្វូងធំ ដែលលេងដោយការលេងតាមទំនើងចិត្ត ( គឺតាមការប្រាថ្នារបស់ខ្លួន ) កាល

ទតឃើញហើយ តិស្សកុមារនោះត្រិះរិះដូច្នេះថា ម្រឹគទាំងនេះមានស្មៅជាអាហារ គង់លេងបានយ៉ាងនេះហ្ន៎ ។ ចំណែកសមណៈទាំងនេះ ឆាន់ភោជនដ៏ប្រណីតក្នុងរាជត្រកូល ហើយដេកនៅលើទីដេកដ៏ទន់ និងលេងល្បែងដែលគួរពេញចិត្ត មិនបានឬ ។ តិស្សកុមារនោះ លុះត្រឡប់មកអំពីព្រៃនោះហើយ បានក្រាបទូលការត្រិះរិះរបស់ខ្លួនដល់ព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា កុមារនេះសង្ស័យក្នុងទីដែលមិនមែនជាឋានៈ ( មិនមែនហេតុ ) ណ្ហើយចុះ អញនឹងឲ្យតិស្សៈដឹងដោយឧបាយយ៉ាងនេះ ។ ក្នុងថ្ងៃមួយ ទ្រង់ធ្វើហាក់ដូចជាពិរោធដោយហេតុការណ៍ឯណានីមួយ ហើយទ្រង់សម្គុតដោយមរណភ័យថា ឯងចូរមកទទួលរាជ្យសម្បត្តិអស់ ៧ ថ្ងៃចុះ ក្រោយអំពីនោះ យើងនឹងសម្លាប់ឯងចោល ដូច្នេះ ហើយឲ្យទទួលដឹងពាក្យបញ្ជានោះ ។ បានឮថា ព្រះរាជកុមារនោះទ្រង់ត្រិះរិះថា ក្នុងថ្ងៃទី ៧ ព្រះរាជានឹងសម្លាប់អញចោល ដូច្នេះ ទ្រង់មិនស្រង់ មិនសោយ ទាំងផ្ទុំក៏មិនលក់តាមសមគួរដល់ព្រះហឫទ័យ មានសរីរៈសៅហ្មងយ៉ាងខ្លាំង បន្ទាប់អំពីនោះ ព្រះរាជាត្រាស់សួរតិស្សកុមារនោះថា ឯងជាបុគ្គលមានរូបរាងយ៉ាងនេះ ព្រោះហេតុដូចម្តេច ព្រះរាជកុមារទូលថា បពិត្រព្រះអង្គ ព្រោះខ្លាចស្លាប់ ។ ព្រះរាជាទ្រង់ប្រាប់ថា អើ ឯងសម្លឹងឃើញសេចក្តីស្លាប់ ដែលយើងដាក់ទោសទុកហើយ អស់សេចក្តីសង្ស័យក្នុងគំនិតដែលគិតថា មិនលេងឬ ពួកភិក្ខុសម្លឹងឃើញសេចក្តីស្លាប់ ទាក់ទងដោយខ្យល់ដង្ហើមចេញចូល នឹងលេងសប្បាយដូចម្តេច ចាប់ពីពេលនោះមក ព្រះរាជកុមារទ្រង់ជ្រះថ្លាក្នុងព្រះសាសនា ។ លុះព្រឹកថ្ងៃមួយ ព្រះរាជកុមារនោះ

យានចេញទៅបរបាញ់សត្វ ត្រាច់សញ្ចរទៅក្នុងព្រៃ បានទតឃើញព្រះយោនកមហាធម្មរក្ខិតត្ថេរកំពុងឲ្យស្តេចដំរីមួយចាប់មែកសាលព្រឹក្សបក់ឲ្យ ។ ព្រះរាជកុមារនោះទតឃើញហើយ ក៏កើតបាមោជ្ជ ត្រិះរិះថា កាលណាហ្ន៎ អញគប្បីបួសដូចព្រះមហាថេរៈនេះ ថ្ងៃនោះ គប្បីមានឬហ្ន៎ ដូច្នេះ ព្រះថេរៈដឹងអធ្យាស្រ័យរបស់ព្រះរាជកុមារនោះហើយ កាលព្រះរាជកុមារនោះកំពុងឃើញនោះឯង បានហោះឡើងទៅក្នុងអាកាស ហើយបានឈរលើផ្ទៃទឹក ត្រង់ស្រះបោក្ខរណី ក្នុងវត្តអសោការាម ព្យួរចីវរ និងសំពត់ឧត្តរាសង្គទុកក្នុងអាកាស ហើយចាប់ផ្ដើមស្រង់ទឹក ។ ព្រះរាជកុមារទតឃើញអានុភាពរបស់មហាថេរៈនោះហើយ ក៏ទ្រង់ជ្រះថ្លាក្រៃលែង គិតថា អញនឹងបួសឲ្យបានក្នុងថ្ងៃនេះឯង ហើយយានត្រឡប់ បានសូមលាព្រះរាជាថា បពិត្រព្រះជេដ្ឋ ទូលបង្គំនឹងបួស ព្រះរាជាទ្រង់ពន្យារ ( ទ្រង់សំណូមពរ ) ជាច្រើនប្រការ កាលទ្រង់មិនអាចឲ្យព្រះរាជកុមារនោះបែរ ( ព្រះទ័យ ) បាន ទើបទ្រង់បញ្ជាឲ្យតុបតែងមាគ៌ាទៅកាន់វត្តអសោការាម ឲ្យព្រះរាជកុមារតាក់តែងព្រះកាយ ជាភេទមហោស្រពហែហមដោយពួកសេនា ដែលប្រដាប់តាក់តែងហើយ ទ្រង់នាំទៅកាន់វិហារ ភិក្ខុជាច្រើនបានឮថា ព្រះយុវរាជបួស ក៏នាំគ្នាត្រៀមបាត្រ និងចីវរទុក ព្រះរាជកុមារយានទៅផ្នះដែលជាទីបំពេញព្យាយាម ហើយទ្រង់បានព្រះផ្នួស ព្រមជាមួយបុរសមួយសែន ក្នុងសម្នាក់របស់ព្រះមហាធម្មរក្ខិតត្ថេរនោះឯង ។ កុលបុត្រទាំងឡាយ ដែលបួសតាមព្រះរាជកុមារកំណត់រាប់មិនបាន ។ ព្រះរាជកុមារទ្រង់ផ្នួសក្នុងវេលាដែលព្រះរាជា ទ្រង់អភិសេកបាន ៤ ឆ្នាំ ។ គ្រានោះ នៅ

មានព្រះរាជកុមារដទៃ ឈ្មោះអគ្គិព្រហ្មដែលជាព្រះស្វាមីរបស់ព្រះនាងសង្ឃមិត្តា ជាព្រះភាគិនេយ្យ ( ក្មួយ ) របស់ព្រះរាជា ។ ព្រះនាងសង្ឃមិត្តាប្រសូតព្រះឱរសរបស់អគ្គិព្រហ្មអង្គនោះ ត្រឹមតែមួយអង្គប៉ុណ្ណោះ ។ អគ្គិព្រហ្មបានឮថា ព្រះយុវរាជទ្រង់ព្រះផ្នួសហើយ ទើបចូលទៅគាល់ព្រះរាជា ហើយសូមព្រះបរមរាជានុញ្ញាតថា ទូលព្រះបង្គំក៏នឹងបួស ដូច្នេះ ។ ហើយអគ្គិព្រហ្មអង្គនោះបានទទួលព្រះរាជានុញ្ញាតថា ចូរបាបួសចុះ ក៏បានបួសក្នុងថ្ងៃនោះឯង ព្រះថេរៈដែលជាខត្តិយជន ដែលមានសម្បត្តិដ៏ឧឡារបួសតាមយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ព្រះតិស្សៈជាព្រះកនិដ្ឋភាតា ( ប្អូនប្រុស ) របស់ព្រះរាជាយ៉ាងនេះ ។

ព្រះតិស្សត្ថេរនោះ កាលឃើញអមាត្យធំនោះ ជាអ្នកបដិបត្តិខុសយ៉ាងនោះហើយ ទើបត្រិះរិះថា ព្រះរាជាទ្រង់មិនមែនបញ្ជូនមកដើម្បីឲ្យសម្លាប់ភិក្ខុទាំងឡាយឡើយ រឿងនេះ ជារឿងដែលអមាត្យយល់ខុសពិតប្រាកដតែម្តងដូច្នេះ ទើបទៅអង្គុយលើអាសនៈជិតអមាត្យនោះខ្លួនឯង ។ អមាត្យធំនោះស្គាល់ព្រះថេរៈនោះ ក៏មិនអាចផាសស្ត្រាចុះ ទើបត្រឡប់ទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ទូលបង្គំបានកាត់ក្បាលរបស់ពួកភិក្ខុ មានប្រមាណប៉ុណ្ណោះជាអ្នកមិនប្រាថ្នាធ្វើឧបោសថ ឲ្យដាច់ចុះទៅ ខណៈនោះ ក៏មកដល់លំដាប់នៃព្រះតិស្សត្ថេរ ទូលបង្គំនឹងធ្វើដូចម្តេច ។ ព្រះរាជា លុះទ្រង់បានស្តាប់ប៉ុណ្ណោះក៏ត្រាស់ថា នែ ខ្ញុំបានបញ្ជូនអ្នកឲ្យទៅសម្លាប់ភិក្ខុទាំងឡាយឬ ។ រំពេចនោះឯង ក៏កើតការក្តៅក្រហាយឡើងក្នុងព្រះវរកាយ ទើបយាងទៅកាន់ព្រះវិហារត្រាស់សួរភិក្ខុជាព្រះថេរៈថា បពិត្រលោកម្ចាស់ អមាត្យម្នាក់នេះ ញោមមិន

បានបញ្ជាឡើយ បានធ្វើកម្មយ៉ាងនេះ ហើយបាបនេះនឹងគប្បីមានដល់នរណាហ្ន៎ ។

ព្រះថេរៈពួកខ្លះ ថ្វាយព្រះពរថា មហាមាត្យនេះបានធ្វើតាមព្រះតម្រាស់របស់មហាបពិត្រហើយ ទើបបាបនោះមានដល់មហាបពិត្រដែរ ព្រះថេរៈពួកខ្លះថ្វាយព្រះពរថា បាបនោះ រមែងមានដល់មហាបពិត្រ និងអមាត្យទាំង ២ ផង ព្រះថេរៈពួកខ្លះថ្វាយព្រះពរយ៉ាងនេះថា សូមថ្វាយព្រះពរ មហាបពិត្រទ្រង់មានគំនិតឬថា មហាមាត្យនេះចូរទៅសម្លាប់ភិក្ខុទាំងឡាយ ព្រះរាជាទ្រង់ត្រាស់ថា បពិត្រលោកម្ចាស់ មិនមានឡើយ ញោមមានបំណងជាកុសល ទើបបញ្ជូនទៅដោយប្រាប់ថា សូមឲ្យភិក្ខុសង្ឃសាមគ្គីគ្នា ធ្វើឧបោសថចុះ ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរថា បើមហាបពិត្រមានព្រះរាជបំណងជាកុសលសោត បាបក៏មិនមានដល់មហាបពិត្រឡើយ បាបនោះ រមែងមានដល់អមាត្យប៉ុណ្ណោះ ។ ព្រះរាជាទ្រង់កើតសេចក្ដីសង្ស័យមិនដាច់ស្រេចក្នុងចិត្ត ទើបពោលថា បពិត្រលោកម្ចាស់ មានភិក្ខុអង្គណាទេ ជាអ្នកអាចដើម្បីនឹងកាត់សេចក្ដីសង្ស័យនេះរបស់ញោម ហើយលើកស្ទួយព្រះសាសនា ។ ភិក្ខុទាំងឡាយថ្វាយព្រះពរថា មានមហាបពិត្រ ភិក្ខុនោះឈ្មោះ មោគ្គលីបុត្តតិស្សត្ថេរលោកអាចកាត់សេចក្ដីសង្ស័យនេះរបស់មហាបពិត្រ ហើយលើកស្ទួយព្រះសាសនាបាន ។ ក្នុងថ្ងៃនោះឯង ព្រះរាជាទ្រង់បានបញ្ជូនព្រះធម្មកថិក ៤ អង្គមួយអង្គមានភិក្ខុ ១០០០ ជាបរិវារ និងអមាត្យ ៤ នាក់ ម្នាក់ៗ មានបុរស ១០០០ ជាបរិវារ ដោយព្រះតម្រាស់ថា សូមលោកទាំងឡាយទទួលយកព្រះថេរៈមកចុះ ។

# ព្រះមោគ្គលីបុត្តតិស្សត្ថេរមិននិមន្តមក

ព្រះធម្មកថិក និងអមាត្យទាំងនោះទៅហើយ បានប្រាប់ ( ព្រះថេរៈ ) ថា ព្រះរាជាត្រាស់ឲ្យរកលោកម្ចាស់ ដូច្នេះ ។ ព្រះថេរៈមិនព្រមមក ។ សូម្បីលើកទី ២ ព្រះរាជាក៏បានរៀបចំបញ្ជូនព្រះធម្មកថិក ៨ អង្គ និងអមាត្យ ៨ នាក់ ដែលមានបរិវារម្នាក់មួយពាន់ៗ ទៅ ដោយប្រាប់ថា លោកទាំងឡាយចូរពិត ( ព្រះថេរៈនោះ ) ថា បពិត្រលោកម្ចាស់ ព្រះរាជាត្រាស់ឲ្យរកហើយនិមន្តព្រះថេរៈមក ។ ព្រះធម្មកថិក និង អមាត្យទាំងនោះ បានប្រាប់ ( ព្រះថេរៈ ) ដូចព្រះរាជាទ្រង់ប្រាប់នោះឯង ។ សូម្បីលើកទី ២ ព្រះថេរៈក៏មិនមក ។ ព្រះរាជាត្រាស់សួរព្រះថេរៈទាំងឡាយថា បពិត្រលោកម្ចាស់ ញោមបានបញ្ជូនទូតដល់ទៅ ២ ដងហើយ ព្រោះហេតុអ្វី ទើបព្រះថេរៈមិនមក ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរថា មហាបពិត្រ ដែលលោកមិនមកនោះ ព្រោះទូតទាំងនោះប្រាប់លោកថា ព្រះរាជាត្រាស់ឲ្យរក តែបើទូតទាំងនោះប្រាប់លោកយ៉ាងនេះថា បពិត្រលោកម្ចាស់ ព្រះសាសនាវិនាសអន្តរាយ សូមលោកម្ចាស់មេត្តាជាសម្លាញ់របស់ពួកខ្ញុំ ដើម្បីលើកស្ទួយព្រះសាសនាចុះ ដូច្នេះ ព្រះថេរៈនឹងគប្បីមក ។ គ្រានោះ ព្រះរាជាទ្រង់ប្រាប់យ៉ាងនោះហើយ ទើបរៀបចំបញ្ជូនព្រះធម្មកថិក ១៦ អង្គ និងអមាត្យ ១៦ នាក់ ដែលមានបរិវារម្នាក់មួយពាន់ៗ ទៅ ទ្រង់បានសាកសួរភិក្ខុទាំងឡាយទៀតថា បពិត្រលោកម្ចាស់ ព្រះថេរៈចាស់ ឬនៅកំលោះ ភិក្ខុពិតថា ចាស់ មហាបពិត្រ ព្រះរាជាសួរថា ព្រះថេរៈនោះនឹងឡើងគ្រែស្នែង ឬវ លោកម្ចាស់ ភិក្ខុទាំងឡាយពិត

ថា លោកនឹងមិនឡើង ( ទាំងពីរយ៉ាង ) មហាបពិត្រ ព្រះរាជាសួរថា ព្រះថេរៈស្នាក់នៅក្នុងទីណា លោកម្ចាស់ ភិក្ខុពិតថា ត្រង់ស៊ឹងគង្គាភាគខាងជើង មហាបពិត្រ ។

ព្រះរាជាទ្រង់ប្រាប់ថា នែបា បើដូច្នោះ ពួកលោកចូរចងទូកចម្លង ហើយអារាធនាឲ្យព្រះថេរៈអង្គុយលើទូកចម្លង នោះៗឯង រួចរៀបចំការរក្សាត្រង់ប្រាំងទាំងពីរខាង នាំព្រះថេរៈមកចុះ ។ ពួកភិក្ខុ និងពួកអមាត្យទៅដល់សម្នាក់របស់ព្រះថេរៈហើយ បានពិតឲ្យជ្រាបតាមព្រះរាជសាសន៍ ។

ព្រះថេរៈបានស្តាប់ ( ព្រះរាជសាសន៍នោះ ) ហើយ គិតថា អញមកបួស ព្រោះហេតុដោយតាំងចិត្តថា នឹងស្រោចស្រង់ព្រះសាសនា តាំងអំពីដើមមកដូច្នោះ កាលនេះក៏មកដល់អញហើយ ទើបកាន់យកបន្ទះស្បែកក្រោកឡើង។

គ្រានោះ ព្រះរាជាទ្រង់ដាក់ព្រះរាជហឫទ័យហើយថា ស្អែកនេះ ព្រះថេរៈនឹងមកដល់នគរបាដលីបុត្រ ដូច្នេះ ក៏ទ្រង់សុបិនឃើញក្នុងចំណែកនៃរាត្រីមានព្រះសុបិនបែបនេះ គឺស្តេចដំរីសសុទ្ធ មកស្ទាបអង្អែលព្រះរាជាតាំងអំពីសីសៈ ហើយបានចាប់ព្រះរាជាត្រង់ព្រះហស្តខាងស្តាំ ។ លុះស្អែកឡើង ព្រះរាជាបានត្រាស់សួរពួកហោរា ដែលជាអ្នកទាយសុបិនថា ខ្ញុំយល់សប្តិឃើញបែបនេះ នឹងមានអ្វីកើតឡើងដល់ខ្ញុំ ហោរាអ្នកទាយសុបិនម្នាក់ទូលថ្វាយថា ព្រះករុណាជីវិតតម្កល់លើត្បូង ព្រះសមណៈដ៏ប្រសើរនឹងចាប់ព្រះអង្គត្រង់ព្រះហស្តខាងស្តាំ ។ គ្រានោះ ព្រះរាជាទ្រង់បានជ្រាបដំណឹងថា ព្រះថេរៈមកហើយ ក្នុងខណៈនោះឯង ទើបយាងទៅកាន់មាត់ប្រាំងទន្លេគង្គា ហើយយាងចុះ

ទឹកទៅរហូតដល់ព្រះថេរៈ ក្នុងទឹកមានប្រមាណត្រឹមព្រះជានុ( ជង្គង់ ) ហើយបានថ្វាយព្រះហស្តដល់ព្រះថេរៈ ដែលកំពុងចុះអំពីទូក ព្រះថេរៈបានចាប់ព្រះរាជាត្រង់ព្រះហស្តខាងស្តាំហើយ ។

ពួករាជបុរសកាន់ដាវ ឃើញកិរិយានោះហើយ ក៏ដកដាវអំពីស្រោមដោយគិតថា ពួកយើងនឹងកាត់ក្បាលរបស់ព្រះថេរៈឲ្យដាច់ទៅ ដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបានឮថា ក្នុងរាជត្រកូល មានទំនៀមថា បុគ្គលណាចាប់ព្រះរាជាត្រង់ដៃ រាជបុរសគប្បីយកដាវកាត់ក្បាលរបស់បុគ្គលនោះឲ្យដាច់ទៅ ។ ព្រះរាជាទតឃើញស្រមោល ( ដាវ ) ប៉ុណ្ណោះ ទ្រង់ក៏បញ្ជាថា កាលមុន យើងជួបការមិនសប្បាយចិត្ត ព្រោះហេតុដែលធ្វើខុសក្នុងភិក្ខុទាំងឡាយ ពួកអ្នកកុំធ្វើខុសក្នុងព្រះថេរៈឡើយ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈចាប់ព្រះរាជាទ្រង់ព្រះហស្ត ឆ្លើយថា ព្រោះព្រះថេរៈនោះ ព្រះរាជាឲ្យអារាធនាដើម្បីត្រាស់សួរបញ្ហា ដូច្នោះ ព្រះថេរៈដាក់ចិត្តថា ព្រះរាជាអង្គនេះជាកូនសិស្សរបស់អញ ទើបបានចាប់ ។

ព្រះរាជាទ្រង់នាំព្រះថេរៈទៅកាន់ព្រះរាជឧទ្យានរបស់ព្រះអង្គ ហើយទ្រង់បញ្ជាឲ្យរៀបចំការរក្សាដោយជុំវិញអំពីខាងក្រៅ រហូតដល់ ៣ ជាន់ ចំណែកខ្លួនព្រះអង្គទ្រង់ក៏លាងជើងព្រះថេរៈ ហើយលាបប្រេង ប្រថាប់គង់នៅក្នុងសម្នាក់របស់ព្រះថេរៈ ហើយទ្រង់ត្រិះរិះថា ព្រះថេរៈនឹងអាចឬទេហ្ន៎ ដើម្បីកាត់សេចក្តីសង្ស័យរបស់អញ នឹងរម្ងាប់អធិករណ៍ដែលកើតឡើង ហើយលើកស្ទួយព្រះសាសនា ដូច្នេះ ដើម្បីសាកល្បងមើល ទើបសួរថា បពិត្រលោកម្ចាស់

ញោមចង់ឃើញបាដិហារិយ៍ត្រឹមតែម្យ៉ាង ។ ព្រះថេរៈសួរថា សូមថ្វាយព្រះពរមហាបពិត្រ តើទ្រង់បំណងទតបាដិហារិយ៍ប្រភេទណា ។ ព្រះរាជាប្រាប់ថា បពិត្រលោកម្ចាស់ ញោមចង់មើលផែនដីកម្រើក ។ ព្រះថេរៈសួរថា សូមថ្វាយព្រះពរមហាបពិត្រ តើទ្រង់បំណងទតផែនដីកម្រើកទាំងអស់ ឬទតផែនដីកម្រើកត្រង់ចំណែកខ្លះ ។ ព្រះរាជាប្រាប់ថា បពិត្រលោកម្ចាស់ បណ្ដាបាដិហារិយ៍ពីរយ៉ាងនេះ មួយណាធ្វើលំបាកជាង ។ ព្រះថេរៈប្រាប់ថា សូមថ្វាយព្រះពរ បើថាសស្រទ្ធពេញដោយទឹក នឹងធ្វើឲ្យកម្រើកទាំងអស់ ឬឲ្យកម្រើកត្រឹមមួយចំហៀង របស់ណាធ្វើបានលំបាកជាង ។ ព្រះរាជាឆ្លើយថា បពិត្រលោកម្ចាស់ ឲ្យកម្រើកត្រឹមពាក់កណ្ដាលលំបាកជាង ។ ព្រះថេរៈប្រាប់ថា សូមថ្វាយព្រះពរ ដូចការថ្វាយព្រះពរមកហើយនោះឯង ការធ្វើផែនដីឲ្យកម្រើកចំណែកខ្លះ ធ្វើបានលំបាក ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ បើដូច្នោះ ញោមនឹងមើលផែនដីកម្រើកត្រង់ចំណែកខ្លះ ។ ព្រះថេរៈប្រាប់ថា សូមថ្វាយព្រះពរ បើដូច្នោះក្នុងទីមួយយោជន៍ជុំវិញ សូមរៀបចំរថ កង់ម្ខាងនៅក្នុងទិសបូព៌ សេះឲ្យជាន់ដែនដោយជើងទាំងពីរក្នុងទិសទក្សិណ បុរសចូរឈរជាន់ដែនដោយជើងម្ខាងត្រង់ទិសបច្ចិម ថាសទឹកមួយចូរដាក់មួយចំណែកត្រង់កណ្ដាលទិសឧត្តរ ។ ព្រះរាជាបញ្ជាឲ្យធ្វើយ៉ាងនោះហើយ ។

ព្រះថេរៈចូលចតុត្ថជ្ឈាន ដែលមានអភិញ្ញាជាបាទ ចេញហើយ បានអធិដ្ឋានឲ្យផែនដីកម្រើក មានប្រមាណមួយយោជន៍ ដោយអធិដ្ឋានថា សូមឲ្យព្រះរាជាទតឃើញដូច្នេះ ។ ទិសបូព៌ កង់រថដែលឈប់នៅខាងក្នុងដែននោះ

ឯងកម្រើកហើយ ក្រៅអំពីនេះមិនកម្រើក ។ ខាងទិសទក្សិណ និងទិសបច្ចិម ជើងរបស់សេះ និងបុរសដែលជាន់ខាងក្នុងដែនប៉ុណ្ណោះកម្រើកហើយ ខ្លួន (របស់សេះ និងបុរស) ក៏កម្រើកត្រឹមមួយចំហៀង ដោយប្រការយ៉ាងនេះ ។ ទិសឧត្តរ ទឹកដែលដាក់នៅខាងក្នុងដែននៃថាសទឹក កម្រើកពាក់កណ្តាលប៉ុណ្ណោះ ទីដ៏សេសមិនកម្រើកឡើយ ដូច្នេះ ។

ព្រះរាជាទតឃើញបាដិហារិយ៍នោះហើយ ក៏ដាក់ព្រះទ័យថា ឥឡូវនេះ ព្រះថេរៈនឹងអាចលើកស្ទួយព្រះសាសនាបាន ទើបត្រាស់សួរសេចក្តីសង្ស័យរបស់ព្រះអង្គថា បពិត្រលោកម្ចាស់ ញោមបានបញ្ជូនអមាត្យម្នាក់ទៅដោយប្រាប់ថា អ្នកចូរទៅកាន់វិហារ រម្ងាប់អធិករណ៍ និមន្តភិក្ខុឲ្យធ្វើឧបោសថចុះ ដូច្នេះ អមាត្យនោះទៅកាន់វិហារហើយ បានសម្លាប់ភិក្ខុឲ្យអស់ជីវិតចំនួនប៉ុណ្ណោះ អង្គ បាបនោះនឹងមានដល់អ្នកណា ។ ព្រះថេរៈទូលសួរថា បពិត្រមហារាជ ព្រះអង្គ មានគិតថា អមាត្យនេះ ចូរទៅកាន់វិហារ ហើយសម្លាប់ភិក្ខុទាំងឡាយចុះដែរឬទេ ។ ព្រះរាជាឆ្លើយថា បពិត្រលោកម្ចាស់ មិនមានទេ ។ ព្រះថេរៈឆ្លើយថា សូមថ្វាយព្រះពរ បើព្រះអង្គមិនមានការគិតបែបនេះសោត បាបមិនមានដល់ព្រះអង្គឡើយ ។

លំដាប់នោះ ព្រះថេរៈ (ថ្វាយវិសជ្ជនា) ឲ្យព្រះរាជាទ្រង់យល់អត្ថនោះ ដោយព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ចេតយិត្វា កម្មំ ករោតិ កាយេន វាចាយ មនសា** ចេតនាជាតួកម្ម បុគ្គលគិតហើយ ទើបធ្វើកម្មដោយកាយ វាចា ចិត្ត ដូច្នេះ

ដើម្បីសម្ដែងអត្ថនោះឯង ទើបព្រះថេរៈនាំតិត្តិរជាតក[១] មក ( ជាឧទាហរណ៍ ) ដូចតទៅនេះថា សូមថ្វាយព្រះពរមហាបពិត្រ ក្នុងអតីតកាល ទទាឈ្មោះទីបកៈ សាកសួរតាបសថា

សត្វទទាជាច្រើនមក ព្រោះគិតថា ញាតិយើងទំនៅ ( ត្រង់ទីនោះ ) ព្រានប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះអាស្រ័យខ្ញុំ ចិត្តរបស់ខ្ញុំ ក៏រង្កៀសក្នុងរឿងនោះ ។

តាបសឆ្លើយថា អ្នកមានការគិត ( យ៉ាងនេះ ) ឬថា សូមទទាទាំងឡាយនោះមក ព្រោះសំឡេង និងព្រោះឃើញរូបរបស់អញហើយ ចូរជាប់អន្ទាក់ ឬចូរត្រូវសម្លាប់ ។ សត្វទទាប្រាប់ថា បពិត្រលោកម្ចាស់ ការគិតនោះមិនមានទេ ។ លំដាប់នោះ ទើបតាបសឲ្យសត្វទទានោះយល់បានថា បើអ្នកមិនមានការគិតសោត បាបក៏មិនមាន ពិតហើយ កម្មរមែងពាល់ត្រូវបុគ្គលដែលមានចិត្តគិតប៉ុណ្ណោះ មិនប្រឡាក់បុគ្គលដែលមិនមានចិត្តគិតឡើយ ។

ម្នាលចៅបក្សី បើចិត្តរបស់អ្នកមិនបង្អោនទៅរកអំពើបាបទេ បាបក៏មិនប្រឡាក់នូវអ្នកដ៏ចម្រើន ដែលជាអ្នកមិនខ្វល់ខ្វាយឡើយ ។

ព្រះថេរៈ កាល ( វិសជ្ជនា ) ឲ្យព្រះរាជាទ្រង់យល់ក្នុងចិត្តយ៉ាងនោះហើយ សម្រាកនៅត្រង់ព្រះឧទ្យាន ក្នុងព្រះនគរនោះឯង អស់ ៧ ថ្ងៃ ហើយឲ្យព្រះរាជារៀនយកលទ្ធិសម័យ ( នៃព្រះសម្មាសម្ពុទ្ធ ) ។ ក្នុងថ្ងៃទី ៧ ព្រះរាជាទ្រង់ប្រាប់ភិក្ខុសង្ឃឲ្យប្រជុំគ្នា ត្រង់អសោការាម ឲ្យរាំងរាំងននទុក ហើយ

---

១- បិ. ៥៨ តិត្តិរជាតក ។

ប្រថាប់គន់ខាងក្នុងវាំងនន ទ្រង់ប្រាប់ឲ្យរៀបចំពួកភិក្ខុ ដែលមានលទ្ធិដូចគ្នា ឲ្យនៅរួមគ្នាជាពួក ហើយឲ្យនិមន្តភិក្ខុម្តងមួយពួក ត្រាស់សួរថា **កឹ វាទី សម្មាសម្ពុទ្ធោ** ព្រះសម្មាសម្ពុទ្ធមានវាទៈដូចម្តេច ។ លំដាប់នោះ ពួកភិក្ខុសស្សតវាទីប្រាប់ថា **សស្សតវាទី** មានវាទៈថា ទៀង ។ ពួកភិក្ខុឯកច្ចសស្សតិកាប្រាប់ថា **ឯកច្ចសស្សតិកវាទី** មានវាទៈថា ចំណែកខ្លះទៀង ។ ពួកភិក្ខុអន្តានន្តិកាប្រាប់ថា **អន្តានន្តិកវាទី** មានវាទៈថា លោកមានទីបំផុត និងមិនមានទីបំផុត ។ ពួកភិក្ខុអមរាវិក្ខេបិកាប្រាប់ថា **អមរាវិក្ខេបិកវាទី** មានវាទៈបោះពាក្យបោះសម្តីមិនឲ្យស្លាប់ខ្លួន ។ ពួកភិក្ខុអធិច្ចសមុប្បន្និកាប្រាប់ថា **អធិច្ចសមុប្បន្និកវាទី** មានវាទៈថា លោកកើតឡើងឯងៗ មិនមានហេតុ ។ ពួកភិក្ខុសញ្ញិវាទប្រាប់ថា **សញ្ញិវាទី** មានវាទៈថា ខ្លួនមានសញ្ញា ។ ពួកភិក្ខុអសញ្ញិវាទប្រាប់ថា **អសញ្ញិវាទី** មានវាទៈថា ខ្លួនមិនមានសញ្ញា ។ ពួកភិក្ខុនេវសញ្ញិនាសញ្ញិវាទប្រាប់ថា **នេវសញ្ញិនាសញ្ញិវាទី** មានវាទៈថា ខ្លួនមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។ ពួកភិក្ខុឧច្ឆេទវាទប្រាប់ថា **ឧច្ឆេទវាទី** មានវាទៈថា ដាច់សូន្យ ។ ពួកភិក្ខុទិដ្ឋធម្មនិព្វានវាទប្រាប់ថា **ទិដ្ឋធម្មនិព្វានវាទី** មានវាទៈថា ព្រះនិព្វានមាននៅក្នុងបច្ចុប្បន្ន[១] ។

ព្រះរាជាទ្រង់ជ្រាបថា បុគ្គលទាំងនេះ មិនមែនភិក្ខុ បុគ្គលទាំងនេះ ជាអន្យតិរ្ថិយ ព្រោះព្រះអង្គបានរៀនយកលទ្ធិពីមុននោះឯង ទើបព្រះរាជាប្រទានសំពត់សដល់លោកទាំងនោះ ហើយឲ្យសឹកចេញ ។ ពួកតិរ្ថិយទាំងនោះ មាន

១- ទី. ១៤ ព្រហ្មជាលសូត្រ ។

ចំនួនដល់ទៅ ៦ ម៉ឺននាក់ ។

លំដាប់នោះ ព្រះរាជាទ្រង់ប្រាប់ឲ្យអារាធនាភិក្ខុពួកដទៃមក ហើយត្រាស់សួរថា **កឹវាទី ភន្តេ សម្មាសម្ពុទ្ធោ** បពិត្រលោកម្ចាស់ ព្រះសម្មាសម្ពុទ្ធមានប្រក្រតីពោលដូចម្តេច ភិក្ខុទាំងឡាយទូលថា **វិភជ្ជវាទី** បពិត្រមហារាជ ព្រះសម្មាសម្ពុទ្ធ មានប្រក្រតីត្រាស់ចែក ។

កាលភិក្ខុទាំងឡាយទូលយ៉ាងនោះហើយ ទើបព្រះរាជាត្រាស់សួរព្រះថេរៈថា បពិត្រលោកម្ចាស់ ព្រះសម្មាសម្ពុទ្ធ ជាវិភជ្ជវាទី ( មែនឬ ) ព្រះថេរៈប្រាប់ថា បពិត្រមហារាជ ដូច្នោះឯង ។ លំដាប់នោះ ព្រះរាជាទ្រង់ប្រាប់ថា បពិត្រលោកម្ចាស់ ឥឡូវនេះ សាសនាបរិសុទ្ធហើយ សូមភិក្ខុសង្ឃធ្វើឧបោសថចុះ ដូច្នេះ ទ្រង់ព្រះរាជទានការរក្សាទុកហើយ ស្តេចយាងទៅកាន់ព្រះនគរ ។ សង្ឃព្រមព្រៀង បានប្រជុំគ្នាធ្វើឧបោសថហើយ ។ ក្នុងសន្និបាតនោះ មានភិក្ខុចំនួនដល់ទៅ ៦ លានអង្គ ។

ព្រះមោគ្គលីបុត្តតិស្សត្ថេរ កាលញាំញីពាក្យសម្តីដែលពោលតិះដៀលនៃជនដទៃ ទើបសម្តែងកថាវត្ថុប្បករណ៍ ក្នុងសមាគមនោះ ។ លំដាប់នោះ ព្រះថេរៈបានជ្រើសរើសបណ្តាភិក្ខុដែលមានចំនួន ៦ លានអង្គ យកចំពោះតែភិក្ខុមួយពាន់អង្គ ដែលទ្រទ្រង់បរិយត្តិ គឺព្រះត្រៃបិដក បែកធ្លាយក្នុងបដិសម្ភិទា ជំនាញក្នុងត្រៃវិជ្ជាជាដើម កាលនឹងសង្គាយនាព្រះធម៌ និងព្រះវិន័យ បានជម្រះមន្ទិលក្នុងព្រះសាសនាទាំងអស់ ទើបធ្វើតតិយសង្គីតិ ដូចព្រះមហាកស្សបត្ថេរ និងយសត្ថេរសង្គាយនាធម៌ និងវិន័យ ដូច្នោះ ។ ក្នុងទីបំផុតនៃសង្គីតិ ប្រឹថពី

ក៏បានញ៉ាំងជាអនេកប្រការ សង្គីតិធ្វើអស់ ៩ ខែ ទើបសម្រេច ដូច្នេះ ។

លោកហៅសង្គីតិនេះថា សហស្សិកសង្គីតិ ព្រោះមានភិក្ខុ ១០០០ អង្គ និងហៅថា តតិយសង្គីតិ ព្រោះប្រៀបធៀបនឹងសង្គីតិពីរលើក ដែលមានមកអំពីមុន ដោយប្រការដូច្នេះ ។

តតិយសង្គីតិ ចប់

# ការនាំវិនយបិដកបន្តគ្នាមក

*ដើម្បីវិសជ្ជនាបញ្ហាថា ព្រះវិនយបិដក អ្នកណានាំបន្តមក ទើបខ្ញុំពោលពាក្យណាទុកថា ព្រះវិនយបិដកនេះ នាំបន្តគ្នាមកតាមលំដាប់អាចារ្យ ចាប់ផ្ដើមអំពីព្រះឧបាលិត្ថេរជាដំបូង ក្នុងជម្ពូទ្វីប រហូតដល់តតិយសង្គីតិក្នុងជម្ពូទ្វីប កាលនោះ មានការនាំបន្តគ្នាមកតាមលំដាប់អាចារ្យ ដូច្នេះ ។*

*ព្រះថេរៈ ៥ អង្គ គឺឧបាលី ១ ទាសកៈ ១ សោណកៈ ១ សិគ្គវៈ ១ មោគ្គលីបុត្តតិស្សត្ថេរ ១ ជាបុគ្គលមានជ័យជម្នះដ៏ពិសេស បាននាំព្រះវិន័យមកក្នុងជម្ពូទ្វីបដ៏មានសិរីមិនដាច់ខ្សែ ដោយបន្តលំដាប់នៃអាចារ្យរហូតដល់សង្គាយនា ទី ៣ ។*

*សេចក្ដីនៃពាក្យនោះ ខ្ញុំប្រកាសហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។*

*ម្យ៉ាងទៀត បន្ទាប់អំពីតតិយសង្គាយនា ព្រះថេរៈទាំងឡាយ មានព្រះមហិន្ទជាដើម បាននាំព្រះវិនយបិដកមកកាន់កោះនេះ ( ប្រទេសស្រីលង្កា ) ព្រះថេរៈទាំងឡាយ មានព្រះអរិដ្ឋត្ថេរជាដើមរៀនអំពីព្រះមហិន្ទ ហើយបាននាំបន្តមកមួយរយៈ តាំងអំពីពេលដែលព្រះអរិដ្ឋត្ថេរជាដើមនោះនាំមក បណ្ឌិតគប្បីជ្រាបថា ព្រះវិនយបិដកនេះ បាននាំបន្តគ្នាមកតាមលំដាប់អាចារ្យដែលរាប់ថា ជាលំដាប់អន្តេវាសិករបស់ព្រះអរិដ្ឋត្ថេរជាដើមនោះឯង រហូតដល់សព្វថ្ងៃនេះ សមដូចបុរាណាចារ្យទាំងឡាយ ពោលទុកថា*

*ក្នុងកាលនោះ ព្រះថេរៈដ៏ប្រសើរ មានបញ្ញាច្រើនទាំងនេះ គឺមហិន្ទ ១ ឥដ្ដិយៈ ១ ឧត្តិយៈ ១ សម្ពលៈ ១ ព្រះថេរៈដែលជាបណ្ឌិតឈ្មោះភទ្ទៈ ១ មកក្នុងកោះសីហឡនេះ អំពីជម្ពូទ្វីប ពួកលោកបានបង្រៀនព្រះវិនយបិដកក្នុង*

កោះតម្ពបណ្ណិ បង្រៀននិកាយទាំង ៥ និងបករណ៍ទាំង ៧ ក្រោយមក ព្រះអរិដ្ឋៈដ៏មានបញ្ញា ១ ព្រះតិស្សទត្តៈដ៏ឈ្លាស ១ ព្រះកាឡសុមនៈដ៏អង់អាច ១ ព្រះថេរៈមានឈ្មោះថា ទីឃៈ ១ ព្រះទីឃសុមនៈជាបណ្ឌិត ១ បន្ទាប់មកទៀត ព្រះកាឡសុមនៈ ១ ព្រះនាគត្ថេរ ១ ព្រះពុទ្ធរក្ខិតៈ ១ ព្រះតិស្សត្ថេរដ៏មានបញ្ញា ១ ព្រះទេវត្ថេរដ៏ឈ្លាស ១ បន្ទាប់មកទៀត ព្រះសុមនៈដ៏មានបញ្ញា និងជំនាញក្នុងព្រះវិន័យ ១ ព្រះចុល្លនាគជាពហូសូត ដូចដំរីចុះប្រេងដ៏ខ្លាំងក្លា ១ ព្រះថេរៈឈ្មោះធម្មបាលិតៈដែលសាធុជនបូជាហើយ ក្នុងរោហណជនបទ ១ អន្តេវាសិករបស់ព្រះធម្មបាលិតៈនោះ ឈ្មោះខេមៈ មានបញ្ញាច្រើន ទ្រទ្រង់ចាំព្រះត្រៃបិដក រុងរឿងនៅកោះដោយបញ្ញា ដូចព្រះចន្ទជាស្តេចនៃពួកផ្កាយដូច្នោះ ១ ព្រះឧបតិស្សៈដ៏មានបញ្ញា ១ ព្រះបុស្សទេវៈជាមហាកវី ១ បន្ទាប់មកទៀត ព្រះសុមនៈដ៏មានបញ្ញា ១ ព្រះថេរៈឈ្មោះបុប្ផៈ (គឺព្រះមហាបទុម) ជាពហូសូត ១ ព្រះមហាសីវៈជាមហាកវី ឈ្លាសក្នុងព្រះត្រៃបិដក ១ បន្ទាប់មកទៀត ព្រះឧបាលីជាអ្នកមានបញ្ញាជំនាញក្នុងព្រះវិន័យ ១ ព្រះមហានាគអ្នកមានបញ្ញាច្រើនឈ្លាសក្នុងវង្សព្រះសទ្ធម្ម ១ បន្ទាប់មក មានព្រះអភយអ្នកមានបញ្ញាឈ្លាសក្នុងបិដកទាំងពួង ១ ព្រះតិស្សត្ថេរអ្នកមានបញ្ញា ជំនាញក្នុងព្រះវិន័យ ១ សិស្សរបស់ព្រះតិស្សត្ថេរនោះ ឈ្មោះបុប្ផៈ (គឺព្រះសុមនត្ថេរ) មានបញ្ញាច្រើនជាពហូសូត ជាអ្នកតាមរក្សាសាសនា ក្នុងជម្ពូទ្វីប ១ ព្រះចុល្លាភយដ៏មានបញ្ញា និងជំនាញក្នុងព្រះវិន័យ ១ ព្រះតិស្សត្ថេរអ្នកមានបញ្ញាឈ្លាសក្នុងវង្សព្រះសទ្ធម្ម ១ ព្រះចុល្លទេវៈអ្នកមានបញ្ញា និងជំនាញក្នុងព្រះ

វិន័យ ១ ព្រះសីវត្ថេរអ្នកមានបញ្ញាឈ្លាសក្នុងព្រះវិន័យទាំងមូល ១ ព្រះថេរៈដ៏ប្រសើរមានបញ្ញាច្រើនទាំងនេះ ចេះចាំព្រះវិន័យ ឈ្លាសក្នុងមាគ៌ា ( គឺឈ្លាសក្នុងផ្លូវសួគ៌ និងផ្លូវព្រះនិព្វាន ) បានប្រកាសព្រះវិនយបិដកទុកក្នុងកោះតម្ពបណ្ណិហើយ ។

## ការបញ្ជូនព្រះថេរៈទៅប្រកាសសាសនា

ក្នុងការនាំព្រះសាសនាបន្តមកតាមលំដាប់អាចារ្យនោះ មានអនុបុព្វីកថាដូចតទៅនេះថា បានឮថា ព្រះមោគ្គលីបុត្តតិស្សត្ថេរ កាលធ្វើតតិយសង្គីតិនេះហើយ បានគិតយ៉ាងនេះថា ក្នុងអនាគត ព្រះពុទ្ធសាសនានឹងគប្បីតាំងមាំដោយល្អ ក្នុងប្រទេសណាហ្ន៎ ។ លំដាប់នោះ កាលលោកពិចារណា ទើបជ្រាបដូច្នេះថា សាសនានឹងតាំងមាំនៅដោយល្អ ក្នុងបច្ចន្តិមជនបទទាំងឡាយ ។ ទើបលោកប្រគល់សាសនកិច្ចនោះឲ្យជាភារៈរបស់ភិក្ខុទាំងនោះ ហើយបញ្ជូនភិក្ខុនោះៗទៅក្នុងរដ្ឋនោះៗ គឺបញ្ជូនព្រះមជ្ឈន្តិកត្ថេរទៅកាន់ស្រុកកស្មិរគន្ធារៈ ហើយប្រាប់ថា អាវុសោ ទៅកាន់ដែននោះហើយ ចូរប្រតិស្ឋានព្រះសាសនាក្នុងដែននោះ ។ លោកបានប្រាប់ព្រះមហាទេវត្ថេរយ៉ាងនោះដូចគ្នា ហើយបញ្ជូនទៅកាន់មហិសកមណ្ឌល បញ្ជូនព្រះរក្ខិតត្ថេរទៅកាន់វនវាសីជនបទ បញ្ជូនព្រះយោនកធម្មរក្ខិតត្ថេរទៅកាន់អបរន្តកជនបទ បញ្ជូនព្រះមហាធម្មរក្ខិតត្ថេរទៅកាន់មហារដ្ឋជនបទ បញ្ជូនព្រះមហារក្ខិតត្ថេរទៅកាន់យោនកលោក បញ្ជូនព្រះមជ្ឈិមត្ថេរទៅកាន់ជនបទ ដែលជាចំណែកមួយនៃហិមវន្តប្រទេស បញ្ជូនព្រះសោណកត្ថេរ ១ ព្រះឧត្តរត្ថេរ ១ ទៅកាន់សុវណ្ណភូមិជនបទ បញ្ជូនព្រះ

មហិន្ទត្ថេរដែលជាសទ្ធិវិហារិករបស់ខ្លួន និងព្រះឥដ្ឋិយត្ថេរ ព្រះឧត្តិយត្ថេរ ព្រះសម្ពលត្ថេរ ព្រះភទ្ទសាលត្ថេរទៅកាន់កោះតម្ពបណ្ណិទ្វីប ដោយប្រាប់ថា ពួកលោកទៅកាន់កោះតម្ពបណ្ណិទ្វីប ហើយចូរប្រតិស្ឋានសាសនាក្នុងកោះនោះ ។ ព្រះថេរៈទាំងអស់ កាលនឹងទៅកាន់ទិសាភាគនោះៗ ក៏យល់ថា ក្នុងបច្ចន្តិម-ជនបទទាំងឡាយ ត្រូវមានគណៈបញ្ចវគ្គ ទើបសមគួរធ្វើឧបសម្បទាកម្មបាន ដូច្នេះទើបយកភិក្ខុ ៥ អង្គទៅជាមួយខ្លួន ។

## ព្រះមជ្ឈន្តិកត្ថេរនៅកស្មិរគន្ធាររដ្ឋ

សម័យនោះឯង ក្នុងដែនកស្មិរគន្ធារៈ ក្នុងរដូវសន្ទូងលាស់ ស្តេចនាគឈ្មោះអារវាឡ បានបណ្តាលភ្លៀងឈ្មោះភ្លៀងព្រិលឲ្យធ្លាក់ចុះមក ធ្វើឲ្យសន្ទូងអណ្តែតទៅកាន់មហាសមុទ្រ ព្រះមជ្ឈន្តិកត្ថេរហោះឡើងទៅកាន់វេហាស៍អំពីបាដលីបុត្តនគរ ហើយទៅចុះលើស្រះអារវាឡ ត្រង់ព្រៃហិមពាន្ត និមន្តចង្ក្រមខ្លះឈរខ្លះ អង្គុយខ្លះ សម្រេចការដេកខ្លះ លើផ្ទៃស្រះអារវាឡ ។ នាគមាណវិកាទាំងឡាយ ឃើញព្រះថេរៈនោះហើយ ទើបប្រាប់ស្តេចនាគអារវាឡថា បពិត្រមហារាជ មានសមណៈត្រងោលម្នាក់ ស្លៀកសំពត់ដែលកាត់ដាច់ដោយសស្ត្រា ដណ្តប់សំពត់ជ្រលក់ដោយទឹកម្ចត់ ប្រទូសរ៉ាយទឹករបស់ពួកយើង ។

ស្តេចនាគស្តាប់ពាក្យនោះហើយ ត្រូវសេចក្តីក្រោធគ្របសង្កត់ បានចេញទៅជួបព្រះថេរៈក្នុងមួយរំពេចនោះឯង កាលអត់ទ្រាំនឹងការមើលងាយមិនបាន ទើបនិម្មិតរូបដែលគួរខ្លាចដ៏ពន្លឹកលើអាកាស ( គឺ បណ្តាលឲ្យ ) ព្យុះដ៏ខ្លាំងក្លាបក់បោកទៅក្នុងទីនោះៗ រុក្ខជាតិទាំងឡាយ ក៏បាក់គល់រលំចុះ

កំពូលបព៌ិតទាំងឡាយក៏បាក់បែក ផ្គរទាំងឡាយក៏លាន់រំពង ផ្លេកបន្ទោរទាំង-ឡាយក៏វាសធ្លៀលធ្លាត់ ។ រន្ទះក៏បាញ់ចុះមក ឧទកវារីក៏រញ្ជួយ ផ្ទៃមេឃហាក់បែកដូច្នោះ ពួកកូននាគដែលមានរូបដ៏គួរខ្លាច ក៏ប្រជុំគ្នា ។ ចំណែកស្តេចនាគខ្លួនឯង ក៏បង្ហុយផ្សែងហុយទ្រលោមអណ្តែតទៅ បណ្តាលភ្លៀងគ្រឿងប្រហារគំរាមព្រះថេរៈដោយពាក្យគ្រោតគ្រាតថា សមណៈកំណោរនេះ ទ្រទ្រង់សំពត់ដែលកាត់ដាច់ដោយសស្ត្រា ជានរណា ។ បានបញ្ជាពួកពលនាគទៅថា ពួកឯងចូរមកចាប់សម្លាប់ បណ្តេញសមណៈនេះចេញទៅ ។

ព្រះថេរៈទប់ទល់កម្លាំងពលនាគ ដែលគួរខ្លាចបានទាំងអស់ ដោយកម្លាំងឫទ្ធិរបស់ខ្លួន ហើយនិយាយនឹងស្តេចនាគថា នែស្តេចនាគ បើលោក ព្រមទាំងទេវលោក គប្បីមានបុគ្គលមកញ៉ាំងអាត្មាឲ្យតក់ស្លុតបានសោត ក៏មិនគប្បីមានបុគ្គលអាចបណ្តាលភ័យ ដែលគួរខ្លាចឲ្យកើតដល់អាត្មាបានឡើយ នែស្តេចនាគ បើអ្នកអាចលើកផែនដីទាំងមូល ព្រមទាំងសមុទ្រ និងបព៌ត ហើយដាក់លើអាត្មាបានសោត អ្នកក៏មិនអាចបណ្តាលភ័យដែលគួរខ្លាចដល់អាត្មាបានឡើយ នែឧរគាធិបតី ការក្តៅក្រហាយចិត្តប៉ុណ្ណោះ នឹងមានដល់អ្នក ។

កាលព្រះថេរៈពោលយ៉ាងនេះហើយ ស្តេចនាគ ត្រូវព្រះថេរៈកម្ចាត់អានុភាពហើយ ជាបុគ្គលមានព្យាយាមឥតផល ដល់នូវភាពជាទុក្ខ ចង្អៀតចង្អល់ចិត្ត សុបសៅ ។ ព្រះថេរៈទូន្មានឲ្យស្តេចនាគនោះយល់ ឲ្យសមាទានឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាដ៏សមគួរដល់ខណៈនោះ ហើយឲ្យតាំងនៅក្នុងត្រៃសរណគមន៍ និងបញ្ចសីល មួយអន្លើដោយនាគបរិវារ ចំនួន

៨៤០០០ ។ យក្ខ គន្ធព្វ និងកុម្ភណ្ឌពួកដទៃដ៏ច្រើន ដែលនៅត្រង់ព្រៃហិមពាន្ត បានស្តាប់ព្រះធម្មកថារបស់ព្រះថេរៈហើយ ក៏បានតាំងនៅក្នុងសរណគមន៍ និង សីល សូម្បីបញ្ចកយក្ខ និងនាងហារិតីយក្ខិនី និងកូន ៥០០ ក៏បានតាំងនៅ ក្នុងសោតាបត្តិមគ្គ ។

លំដាប់នោះ ព្រះមជ្ឈន្តិកត្ថេរហៅពួកនាគ និងអារក្ខទឹកទាំងអស់មក ហើយ ទើបពោលយ៉ាងនេះថា ចាប់ពីពេលនេះទៅ ពួកអ្នកកុំឲ្យសេចក្តីក្រោធ កើត ដូចក្នុងកាលមុនឡើយ និងកុំបំផ្លាញសន្ទូងឲ្យវិនាស ព្រោះថា សត្វទាំង-ឡាយប្រាថ្នាសេចក្តីសុខ ចូរផ្សាយមេត្តាទៅក្នុងសត្វទាំងឡាយថា សូមពួក មនុស្សនៅជាសុខចុះ ។

នាគ និងយក្ខជាដើមទាំងឡាយនោះ ទទួលឱវាទរបស់ព្រះថេរៈថា សាធុ លោកម្ចាស់ បានបដិបត្តិតាមលោកប្រៀនប្រដៅហើយ ។ សម័យនោះឯងជា សម័យធ្វើការបូជាស្តេចនាគ ពេលនោះ ស្តេចនាគប្រាប់ឲ្យនាំរតនបល្ល័ង្ករបស់ ខ្លួន មករៀបចំប្រគេនព្រះថេរៈ ព្រះថេរៈក៏អង្គុយលើបល្ល័ង្ក ចំណែកស្តេចនាគ បានឈរបក់ផ្លិតថ្វាយព្រះថេរៈក្នុងទីជិតនោះឯង។ ខណៈនោះ មនុស្សទាំងឡាយ ដែលនៅក្នុងដែនកស្មិរគន្ធារៈ មកឃើញព្រះថេរៈហើយ ក៏និយាយគ្នាថា ព្រះ ថេរៈមានឫទ្ធិច្រើន សូម្បីស្តេចនាគរបស់ពួកយើង ក៏បានអង្គុយចុះថ្វាយបង្គំ ព្រះថេរៈនោះដែរ ។ ព្រះថេរៈក៏សម្តែងអាសិវិសូបមសូត្រដល់មនុស្សទាំង នោះ ។ ក្នុងពេលចប់ព្រះសូត្រ សត្វប្រមាណ ៨ ម៉ឺន បានសម្រេចធម្មាភិ-សម័យ ។ ត្រកូលមួយសែនចេញបួសហើយ ចាប់តាំងអំពីកាលនោះមក ដែន

កស្មិរគន្ធារៈក៏រុងរឿងទៅដោយសំពត់កាសាវពស្ត្រ ដេរដាសទៅដោយពួកឥសី ជរាបដល់សព្វថ្ងៃ ។

ក្នុងកាលនោះ ព្រះមជ្ឈន្តិកៈជាឥសី ទៅកាន់ដែនកស្មិរគន្ធារៈ ហើយញុំាងស្តេចនាគដ៏កាចឲ្យជ្រះថ្លាហើយ បានស្រោចស្រង់សត្វដ៏ច្រើន ឲ្យផុតអំពីគ្រឿងចងហើយ ដូច្នេះឯង ។

## ព្រះមហាទេវត្ថេរទៅផ្សាយសាសនា

ចំណែកព្រះមហាទេវត្ថេរ ទៅកាន់មហិស្សកមណ្ឌល ហើយក៏សម្តែងទេវទូតសូត្រ ក្នុងពេលចប់ព្រះសូត្រ សត្វប្រមាណ ៤ ម៉ឺន បានទូវធម្មចក្ខុ ហើយសត្វប្រមាណ ៤ ម៉ឺននោះឯង ចេញបួសហើយ ។

ព្រះមហាទេវត្ថេរ អ្នកមានឫទ្ធិច្រើន ទៅកាន់មហិស្សករដ្ឋ ហើយឲ្យឱវាទដាស់តឿនដោយទេវទូតទាំងឡាយ បានដោះសត្វដ៏ច្រើនឲ្យផុតអំពីចំណងហើយ ដូច្នេះឯង ។

## ព្រះរក្ខិតត្ថេរទៅប្រកាសសាសនា

ចំណែកព្រះរក្ខិតត្ថេរ ទៅកាន់ដែនវនវាសីជនបទ ហើយឈរនៅលើអាកាស ឲ្យអ្នកដែនវនវាសីជនបទជ្រះថ្លា ដោយសម្តែងអនមតគ្គបរិយាយ-កថា ។ ក្នុងពេលចប់កថារបស់ព្រះថេរៈនោះ សត្វប្រមាណ ៦ ម៉ឺននាក់ បានសម្រេចធម៌ហើយ ។ មហាជនប្រមាណ ៣ ម៉ឺន ៧ ពាន់បួសហើយ ។ វិហារ ៥០០ ក៏ប្រតិស្ឋានឡើងហើយ ។ ព្រះថេរៈនោះ បានប្រតិស្ឋានសាសនាឲ្យតាំងមាំក្នុងដែនវនវាសីជនបទនោះ ដោយប្រការដូច្នេះហើយ ។

ព្រះរក្ខិតត្ថេរ ជាអ្នកមានឫទ្ធិច្រើន ទៅកាន់វនវាសីជនបទហើយ បានឈរត្រង់កណ្តាលអាកាស ហើយសម្តែងអនមតគ្គិយកថា ( ដល់មហាជន ) ក្នុងវនវាសីជនបទនោះឯង ។

## ព្រះយោនកធម្មរក្ខិតត្ថេរទៅផ្សាយសាសនា

ចំណែកព្រះយោនកធម្មរក្ខិតត្ថេរ ទៅកាន់អបរន្តកជនបទហើយ ឲ្យអ្នកស្រុកអបរន្តកជនបទជ្រះថ្លា ដោយអគ្គិក្ខន្ធោបមសុត្តន្តកថាហើយ ក៏ឲ្យសត្វប្រមាណ ៣ ម៉ឺន ៧ ពាន់ ផឹកនូវអមតធម៌ ។ បុរសចេញបព្វជ្ជាអំពីខត្តិយត្រកូលមួយពាន់នាក់ និងស្ត្រីចេញបព្វជ្ជាចំនួន ៦ ពាន់ ។ ព្រះថេរៈនោះបានប្រតិស្ឋានសាសនាឲ្យតាំងមាំ នៅក្នុងអបរន្តកជនបទនោះហើយ ដោយប្រការដូច្នេះ ។

ព្រះយោនកធម្មរក្ខិតត្ថេរ ចូលកាន់អបរន្តកជនបទហើយ ក៏ឲ្យជនជាច្រើន ក្នុងអបរន្តកជនបទនោះជ្រះថ្លាហើយ ដោយអគ្គិក្ខន្ធោបមសូត្រដូច្នេះឯង ។

## ព្រះមហាធម្មរក្ខិតត្ថេរទៅផ្សាយសាសនា

ចំណែកព្រះមហាធម្មរក្ខិតត្ថេរ ទៅកាន់មហារដ្ឋជនបទហើយ ឲ្យអ្នកមហារដ្ឋជនបទជ្រះថ្លា ដោយមហានារទជាតកកថាហើយ ក៏ឲ្យសត្វប្រមាណ ៨៤០០០ តាំងនៅក្នុងមគ្គ និងផល ។ មហាជនចំនួន ១ ម៉ឺន ៣ ពាន់បួសហើយ ។ ព្រះថេរៈនោះបានប្រតិស្ឋានសាសនាឲ្យតាំងមាំនៅក្នុងមហារដ្ឋជនបទនោះហើយ ដោយប្រការដូច្នេះ ។

ព្រះមហាធម្មរក្ខិតត្ថេរជាឥសីនោះ ទៅកាន់មហារដ្ឋជនបទហើយ
ក៏សម្ដែងជាតកឲ្យមហាជនជ្រះថ្លាហើយ ដូច្នេះឯង ។

## ព្រះមហារក្ខិតត្ថេរនៅផ្សាយសាសនា

ចំណែកព្រះមហារក្ខិតត្ថេរ ទៅកាន់យោនករដ្ឋ ហើយឲ្យអ្នកស្រុកយោនកៈជ្រះថ្លា ដោយកាឡការាមសុត្តន្តកថាហើយ បានឲ្យគ្រឿងអលង្ការ គឺមគ្គ និងផលដល់សត្វប្រមាណ ១ សែន ៣ ម៉ឺន ៧ ពាន់ មហាជនប្រមាណមួយម៉ឺនបួសហើយក្នុងសម្នាក់ព្រះថេរៈនោះ ។ សូម្បីព្រះថេរៈក៏បានប្រតិស្ឋានសាសនាឲ្យតាំងមាំនៅក្នុងយោនករដ្ឋនោះហើយ ដោយប្រការដូច្នេះ ។

ក្នុងកាលនោះ ព្រះមហារក្ខិតត្ថេរជាឥសីនោះ ទៅកាន់យោនករដ្ឋ
ហើយ ឲ្យអ្នកយោនកៈទាំងនោះជ្រះថ្លា ដោយកាឡការាមសូត្រ
ដូច្នេះឯង ។

## ព្រះមជ្ឈិមត្ថេរនៅផ្សាយសាសនា

ចំណែកព្រះមជ្ឈិមត្ថេរ ១ ព្រះកស្សបគោត្តត្ថេរ ១ ព្រះអឡកទេវត្ថេរ ១ ព្រះទុន្ទុភិស្សរត្ថេរ ១ និងព្រះសហស្សទេវត្ថេរ ១ ទៅកាន់ជនបទជាចំណែកហិមវន្តប្បទេស ហើយឲ្យអ្នកស្រុកនោះជ្រះថ្លា ដោយធម្មចក្កប្បវត្តនសុត្តន្តកថាហើយសត្វប្រមាណ ៨០ កោដិ បានរតនៈ គឺមគ្គ និងផលហើយ ។ ព្រះថេរៈទាំង ៥ អង្គនោះ បានញ៉ាំងរដ្ឋទាំង ៥ ឲ្យជ្រះថ្លាហើយ ។ មហាជនដែលបួសក្នុងសម្នាក់របស់ព្រះថេរៈមួយអង្គៗ មានប្រមាណ ១ សែន ។ ព្រះថេរៈទាំង ៥ អង្គនេះបានប្រតិស្ឋានសាសនាឲ្យតាំងមាំនៅក្នុងហិមវន្តប្បទេសនោះហើយ

ដោយប្រការដូច្នេះ ។

ព្រះមជ្ឈិមត្ថេរទៅកាន់ហិមវន្តប្បទេស ហើយប្រកាសនូវ
ធម្មចក្កប្បវត្តនសូត្រឲ្យយក្ខ និងសេនាយក្ខជ្រះថ្លាហើយ
ដូច្នេះឯង ។

## ព្រះសោណកៈ និង ព្រះឧត្តរៈនៅផ្សាយសាសនា

ចំណែកព្រះសោណកត្ថេរ និងព្រះឧត្តរត្ថេរ បានទៅកាន់ដែនសុវណ្ណភូមិ សម័យនោះដែនសុវណ្ណភូមិនោះ មានអារក្ខទឹកស្រីម្នាក់ឡើងមកអំពីសមុទ្រ ទំពាស៊ីពួកទារកដែលកើតក្នុងរាជត្រកូល ។ ក្នុងថ្ងៃនោះឯង មានទារកម្នាក់កើតក្នុងរាជត្រកូល ។ មនុស្សទាំងឡាយឃើញព្រះថេរៈហើយ សម្គាល់ថា បុគ្គលនេះនឹងជាសម្លាញ់របស់ពួកអារក្ខទឹក ទើបនាំគ្នាកាន់អាវុធក្នុងបំណងនឹងប្រហារព្រះថេរៈ ។ ព្រះថេរៈពោលថា ពួកអ្នកកាន់អាវុធមកធ្វើអ្វី មនុស្សទាំងនោះនិយាយថា ពួកអារក្ខទឹករមែងទំពាស៊ីពួកក្មេងដែលកើតហើយ ក្នុងរាជត្រកូល ពួកលោកជាសម្លាញ់របស់អារក្ខទឹកទាំងនោះ ។ ព្រះថេរៈពោលថា ពួកអាត្មាមិនមែនជាសម្លាញ់របស់អារក្ខទឹកឡើយ ពួកអាត្មាឈ្មោះថា ជាសមណៈ ជាអ្នកវៀរចាកការធ្វើជីវិតសត្វឲ្យធ្លាក់កន្លង វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការនិយាយកុហក វៀរចាកការផឹកទឹកស្រវឹង ជាបុគ្គលបរិភោគតែម្តង មានសីល ប្រព្រឹត្តព្រហ្មចរិយៈ មានកល្យាណធម៌ ។

ក្នុងខណៈនោះឯង អារក្ខទឹកស្រីមួយ ព្រមទាំងបរិវារ ឡើងមកអំពី

សមុទ្រ ដោយគិតថា ទារកកើតក្នុងរាជត្រកូល ពួកយើងនឹងទំពាស៊ីក្មេងនោះ ។ ពួកមនុស្សឃើញស្រីអារក្ខនោះហើយក៏ខ្លាច រួចស្រែកដោយសំឡេងខ្លាំងថា អារក្ខទឹកនេះកំពុងមកហើយ ។ ព្រះថេរៈនិម្មិតអត្តភាពច្រើនជាងពួកអារក្ខទឹក ២ ដង ហ៊ុមព័ទ្ធទិសទាំងពីរ ដោយអត្តភាពទាំងនោះ រាំងស្រីអារក្ខទឹកនោះ ព្រមទាំងបរិវារទុកត្រង់កណ្តាល ។ អារក្ខទឹកស្រីនោះ ព្រមទាំងបរិស័ទគិតដូច្នេះថា ទីនេះនឹងជាដែនរបស់អារក្ខទឹកទាំងនេះពិតប្រាកដ ពួកយើងនឹងជាចំណីរបស់អារក្ខទឹកទាំងនេះ ។ ពួកអារក្ខទឹកទាំងអស់បានប្រញាប់ប្រញាល់រត់គេចទៅហើយ ។

ចំណែកព្រះថេរៈដេញអារក្ខទឹកទាំងនោះឲ្យចៀសចេញទៅហើយ រហូតដល់មើលលែងឃើញ ទើបតាំងការរក្សាទុកដោយជុំវិញកោះនោះ ។ម្យ៉ាងទៀត លោកឲ្យពួកមហាជនដែលប្រជុំព្រមគ្នាក្នុងសម័យនោះជ្រះថ្លា ដោយព្រហ្មជាលសុត្តន្តកថា និងឲ្យតាំងនៅក្នុងសរណគមន៍ និងសីលហើយ ។ ក្នុងសន្និបាតនេះ មហាជនប្រមាណ ៦ ម៉ឺនបានសម្រេចធម៌ហើយ ។ ពួកកុមារក្នុងត្រកូលប្រមាណ ៣៥០០ បានបួសហើយ ។ កុលធីតាប្រមាណ ១ ពាន់ ៥ រយនាក់ក៏បួសហើយដែរ ។ ព្រះថេរៈនោះ បានប្រតិស្ឋានសាសនាឲ្យតាំងមាំនៅក្នុងដែនសុវណ្ណភូមិនោះហើយ ដោយប្រការដូច្នេះ ។ ចាប់ពីពេលនោះមក អ្នកសុវណ្ណភូមិក៏បានដាក់ឈ្មោះឲ្យទារក ដែលកើតក្នុងរាជត្រកូលថា សោណុត្តរៈរហូតមក ។

ព្រះសោណៈ និងព្រះឧត្តរៈដ៏មានឫទ្ធិ ទៅកាន់ដែនសុវណ្ណភូមិ

ហើយ បណ្ដេញបិសាចទាំងឡាយឲ្យគេចទៅ បានសម្ដែង ព្រហ្មជាលសូត្រហើយ ដូច្នេះ ។

## ព្រះមហិន្ទត្ថេរទៅផ្សាយសាសនា

ចំណែកព្រះមហិន្ទត្ថេរ ដែលព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃអារាធនាសូមឲ្យលោកទៅប្រតិស្ឋានសាសនា នាកោះតម្ពបណ្ណិទ្វីប ដូច្នេះ ទើបត្រិះរិះថា ជាកាលដែលអញនឹងទៅកាន់តម្ពបណ្ណិទ្វីប ឬអត់ហ្ន៎ កាលលោកកំពុងពិចារណា ក៏ដឹងថា ជាកាលដែលមិនគួរទៅឡើយ ។

សួរថា ព្រះថេរៈនោះ បានជ្រាបដូច្នេះ ព្រោះឃើញហេតុការណ៍ដូចម្ដេច ឆ្លើយថា ព្រោះលោកឃើញថា ព្រះបាទមុដសីវៈទ្រង់ព្រះជរាភាពខ្លាំងពេក ។

## ព្រះថេរៈត្រាច់សួរសុខឧក្កញាតិដើម្បីពន្យារពេល

លំដាប់នោះ ព្រះថេរៈគិតថា ព្រះរាជាអង្គនេះ ទ្រង់ជរាទុព្វលភាពខ្លាំងណាស់ អញមិនអាចទទួលព្រះរាជានេះឲ្យលើកស្ទួយព្រះសាសនាបានឡើយ ឯឥឡូវនេះ ព្រះរាជឱរសរបស់ព្រះអង្គ ឈ្មោះថា ទេវានម្បិយតិស្សៈនឹងសោយរាជ្យ ( បន្ត ) អញនឹងអាចទទួលព្រះរាជានោះឲ្យលើកស្ទួយព្រះសាសនាបាន ណ្ហើយចុះ អញនឹងសួរសុខទុក្ខពួកញាតិសិនចុះ ទម្រាំពេលនោះមកដល់ ឥឡូវនេះអញគប្បីត្រឡប់មកកាន់ជនបទនេះទៀតឬទេហ្ន៎ ។ ព្រះថេរៈនោះ កាលគិតយ៉ាងនោះហើយ ទើបថ្វាយបង្គំព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃចេញអំពីអសោការាម ត្រាច់ចារិកទៅទក្ខិណាគីរីជនបទ ដែលវិលជុំវិញនគររាជគ្រឹះ ព្រមជាមួយព្រះថេរៈ ៤ អង្គ មានព្រះឥដ្ដិយៈជាដើមនោះ

សុមនសាមណេរដែលជាឱរសរបស់ព្រះនាងសង្ឃមិត្តា និងភណ្ឌុកឧបាសក សួរសុខទុក្ខពួកញាតិ រហូតដល់ទៅ ៦ ខែ ។ គ្រានោះ ព្រះថេរៈបានទៅដល់ក្រុងឈ្មោះវេទិសនគរ ដែលជាទីកន្លែងប្រថាប់របស់ព្រះមាតាដោយលំដាប់ ។

បានឮថា ព្រះបាទអសោកទ្រង់បានជនបទ ក្នុងពេលដែលទ្រង់នៅជាយុវរាជ កាលយាងទៅក្រុងឧជ្ជេនី ឆ្លងកាត់វេទិសនគរ ទ្រង់បានទទួលធីតារបស់វេទិសសេដ្ឋី មកធ្វើជាអគ្គមហេសី ។ ក្នុងថ្ងៃនោះឯង ព្រះនាងទ្រង់តាំងគភ៌ ហើយបានប្រសូតមហិន្ទកុមារ ក្នុងក្រុងឧជ្ជេនី ។ ក្នុងកាលដែលព្រះរាជ-កុមារមានព្រះជន្មបាន ១៤ វស្សា ព្រះរាជាទ្រង់បានទទួលការអភិសេកគ្រងរាជ្យ ។ សម័យនោះ ព្រះនាងដែលជាមាតារបស់មហិន្ទកុមារនោះ ក៏ប្រថាប់នៅត្រង់ដំណាក់របស់ព្រះញាតិ ព្រោះហេតុនោះ ទើបខ្ញុំពោលថា ព្រះថេរៈបានទៅដល់ក្រុងឈ្មោះវេទិសនគរ ដែលជាទីប្រថាប់របស់ព្រះមាតាដោយលំដាប់ ។

ឯព្រះទេវី ជាមាតារបស់ព្រះថេរៈទតឃើញព្រះថេរៈមកដល់ហើយ ទ្រង់ថ្វាយបង្គំបាទាទាំងពីរ ដោយសិរសា គឺត្បូង ហើយប្រគេនភត្ត ទ្រង់ប្រគេនវត្តឈ្មោះវេទិសគិរីមហាវិហារ ដែលខ្លួនសាងប្រគេនព្រះថេរៈ ។ ព្រះថេរៈអង្គុយគិតត្រង់វិហារនោះថា កិច្ចដែលអញគួរធ្វើក្នុងទីនេះសម្រេចហើយ ឥឡូវនេះ ជាពេលដែលគួរនឹងទៅកាន់កោះលង្កា ឬអត់ហ្ន៎ ។ លំដាប់នោះ លោកគិតថា សូមឲ្យព្រះរាជកុមារឈ្មោះថា ទេវានម្បិយតិស្សៈសោយនូវគ្រឿងអភិសេកដែលព្រះជនករបស់អញ ទ្រង់បញ្ជូនទៅថ្វាយជាមុនសិន សូមឲ្យបានស្តាប់គុណព្រះរតនត្រ័យ និងយាងចេញទៅអំពីព្រះនគរ ឡើងកាន់មិស្សកបព៌ត មាន

មហោស្រពជាគ្រឿងចំណាំ ពេលនោះ អញនឹងជួបព្រះអង្គក្នុងទីនោះ ។ ព្រះថេរៈ ក៏សម្រេចការស្នាក់នៅឯវេទិសគិរីមហាវិហារនោះឯង អស់ ១ ខែតទៅទៀត ។

ដោយកន្លងទៅមួយខែ គណៈសង្ឃ និងឧបាសកទាំងអស់ដែលប្រជុំគ្នា នៅក្នុងថ្ងៃឧបោសថ ក្នុងតិថីពេញបូណ៌មីខែជេស្ឋ បានពិភាក្សាគ្នាថា ជាកាល សមគួរដែលពួកយើងនឹងទៅកាន់កោះតម្ពបណ្ណិទ្វីប ឬអត់ហ្ន៎ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា ក្នុងកាលនោះ មានព្រះសង្ឃត្ថេរឈ្មោះ មហិន្ទដោយនាម ១ ព្រះឥដ្ដិយត្ថេរ ១ ព្រះឧត្តិយត្ថេរ ១ ព្រះភទ្ទសាលត្ថេរ ១ ព្រះសម្ពលត្ថេរ ១ សុមនសាមណេរ អ្នកបានអភិញ្ញាមានឫទ្ធិច្រើន ១ ភណ្ឌុក ឧបាសកអ្នកបានឃើញសច្ចៈជាគម្រប់ ៧ នៃព្រះថេរៈទាំងនោះ ១ ព្រះមហា នាគទាំងនោះឯង ស្នាក់នៅក្នុងទីស្ងប់ស្ងាត់ បានប្រឹក្សាគ្នាហើយ ដោយប្រការ ដូច្នេះ ។

គ្រានោះ សក្កទេវរាជ ជាស្ដេចនៃទេវតាយាងចូលទៅរកព្រះមហិន្ទត្ថេរ ហើយបានពោលថា បពិត្រលោកម្ចាស់ ព្រះបាទមុដសីវៈទ្រង់សោយទីវង្គត ហើយ ឥឡូវនេះ ព្រះបាទទេវានម្បិយតិស្សមហារាជ ទ្រង់សោយរាជ្យហើយ ឯសម្ដេចព្រះសម្មាសម្ពុទ្ធ ទ្រង់ក៏ព្យាករលោកម្ចាស់ទុកហើយថា ក្នុងអនាគត ភិក្ខុឈ្មោះមហិន្ទនឹងញុំាងអ្នកស្រុកកោះតម្ពបណ្ណិទ្វីបឲ្យជ្រះថ្លា បពិត្រលោកម្ចាស់ ព្រោះហេតុនោះឯង ជាកាលសមគួរដែលលោកម្ចាស់នឹងទៅកាន់កោះដ៏ប្រសើរ ហើយ សូម្បីខ្ញុំក៏នឹងរួមជាសម្លាញ់របស់លោកម្ចាស់ដែរ ។ សួរថា ព្រោះហេតុ អ្វី ទើបសក្កទេវរាជត្រាស់យ៉ាងនោះ ឆ្លើយថា ព្រោះបានឮថា ព្រះមានព្រះភាគ

ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ ត្រង់មណ្ឌលនៃពោធិព្រឹក្សនោះឯង បាន ទតឃើញសម្បត្តិនៃកោះនេះក្នុងអនាគត ទើបត្រាស់ប្រាប់សេចក្តីនោះដល់សក្ក-ទេវរាជនោះ ហើយទ្រង់ផ្តាំទុកផងថា ក្នុងពេលនោះ មហាបពិត្រ ក៏គួររួមជាសម្លាញ់របស់លោកម្ចាស់ដែរដូច្នេះ ដូច្នោះទើបសក្កទេវរាជត្រាស់យ៉ាងនោះ ។

ព្រះថេរៈទទួលពាក្យរបស់សក្កៈនោះហើយ បុគ្គល ៧ នាក់ ហោះឡើងទៅកាន់វេហាស៍អំពីវេទិសបព៌ត ហើយទៅចុះលើមិស្សកបព៌ត ដែលជនទាំងឡាយក្នុងសម័យនេះ ហៅថាចេតិយបព៌ត ត្រង់ទិសបូព៌ានៃអនុរាធបុរី ព្រោះហេតុនោះ ទើបបុរាណាចារ្យពោលទុកថា

ព្រះថេរៈទាំងឡាយ ស្នាក់នៅត្រង់វេទិសបព៌ត ជិតក្រុងរាជគ្រឹះ អស់ ៣០ រាត្រី បានត្រិះរិះថា ជាកាលសមគួរដែលនឹងទៅកាន់កោះដ៏ប្រសើរ ពួកយើងនឹងនាំគ្នាទៅកាន់កោះដ៏ឧត្តម ដូច្នេះហើយ បាន ហោះអំពីជម្ពូទ្វីប អណ្តែតទៅក្នុងអាកាស ដូចស្តេចហង្សហើរទៅលើអាកាស ដូច្នោះ ព្រះថេរៈទាំងឡាយហោះឡើងយ៉ាងនោះហើយ ក៏ចុះត្រង់កំពូលភ្នំ ឈរនៅលើកំពូលបព៌តដែលលម្អទៅដោយពពកតាំងនៅមុខ នៃបុរីដ៏ប្រសើរ ប្រៀបបីដូចស្តេចហង្សទំត្រង់កំពូលភ្នំដូច្នោះ ។

ឯព្រះមហិន្ទត្ថេរ ដែលមកជាមួយព្រះថេរៈទាំងឡាយ មានព្រះឥដ្ឋិយៈជាដើម ឈរនៅយ៉ាងនោះ បណ្ឌិតគប្បីជ្រាបថា បានឈរនៅហើយក្នុងកោះនេះ នាឆ្នាំ ២៣៦ រាប់អំពីឆ្នាំដែលសម្តេចព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វាន ។

# លំដាប់រាជវង្សក្នុងកោះលង្កា និង ជម្ពូទ្វីប

សេចក្តីពិស្តារថា សម្តេចព្រះសម្មាសម្ពុទ្ធ ទ្រង់បរិនិព្វានហើយ ក្នុងឆ្នាំទី ៨ នៃ ( រជ្ជកាល ) ព្រះបាទអជាតសត្តុរាជ ។ ក្នុងឆ្នាំនោះឯង ព្រះរាជឱរសរបស់ព្រះបាទសីហកុមារ ទ្រង់ជាស្តេចផែនដី ដើមវង្សនៃកោះតម្ពបណ្ណិទ្វីប ទ្រង់ព្រះនាមថា វិជយកុមារ ទ្រង់មកកាន់កោះនេះ ហើយបានធ្វើកោះនេះឲ្យជាទីលំនៅរបស់មនុស្ស ។ ព្រះបាទវិជយកុមារ ( សោយរាជ្យនៅក្នុងកោះនេះ ៣៨ ឆ្នាំ ) ហើយទិវង្គតត្រង់កោះនេះ ក្នុងឆ្នាំទី ១៤ នៃ ( រជ្ជកាល ) ព្រះបាទឧទេយ្យភទ្ទ ក្នុងជម្ពូទ្វីប ។ ព្រះរាជាទ្រង់ព្រះនាមថា ព្រះបាទបណ្ឌុវាសុទេព ឡើងគ្រងរាជ្យក្នុងកោះនេះ នៅឆ្នាំទី ១៥ នៃ ( រជ្ជកាល ) ព្រះបាទឧទយភទ្ទ ដែលសោយរាជ្យក្នុងជម្ពូទ្វីប ។ ព្រះបាទបណ្ឌុវាសុទេព ទ្រង់បានទិវង្គតនៅកោះនេះ ក្នុងឆ្នាំទី ២១ នៃ ( រជ្ជកាល ) ព្រះបាទនាគទស្សកៈ ( ដែលសោយរាជ្យនៅ ) ក្នុងជម្ពូទ្វីបនោះ ។ ព្រះរាជកុមារឈ្មោះថា អភ័យ ឡើងគ្រងរាជ្យក្នុងកោះនេះ ក្នុងឆ្នាំនោះឯង ។ ព្រះបាទអភ័យ ( សោយរាជ្យនៅ ) ក្នុងកោះនេះគ្រប់ ២០ ឆ្នាំបរិបូណ៌ក្នុងឆ្នាំទី ១៧ នៃ ( រជ្ជកាល ) ព្រះបាទសុសូនាគ ( ដែលសោយរាជ្យនៅ ) ក្នុងជម្ពូទ្វីបនោះ គ្រានោះ ទាមរិកឈ្មោះបកុណ្ឌកាភ័យ បានដណ្តើមរាជ្យសម្បត្តិក្នុងឆ្នាំទី ២០ នៃ ( រជ្ជកាល ) ព្រះបាទអភ័យ ( ដែលគ្រងរាជ្យនៅក្នុងគ្រានោះ ) ។ ព្រះបាទបកុណ្ឌកាភ័យ ( គ្រងរាជ្យនៅ ) ក្នុងកោះនេះ គ្រប់ ១៧ ឆ្នាំបរិបូណ៌ ក្នុងឆ្នាំទី ១៦ នៃ ( រជ្ជកាល ) ព្រះបាទកាឡាសោក ( ដែលសោយរាជ្យនៅ ) ក្នុងជម្ពូទ្វីបនោះ ។ ១៧ ឆ្នាំនោះ ថែមមួយឆ្នាំទៀត បន្ទាប់មក ត្រូវជា ១៨ ឆ្នាំ ព្រះបាទ

បកុណ្ឌកាភ័យបានសោយទិវង្គតក្នុងកោះនេះ ក្នុងឆ្នាំទី ១៤ នៃ ( រជ្ជកាល ) ព្រះបាទចន្ទ្រគុត្ត ( ដែលសោយរាជ្យនៅ ) ក្នុងជម្ពូទ្វីបនោះ ។ ( បន្ទាប់អំពីនោះ ) ព្រះបាទមុដសីវៈក៏ឡើងគ្រងរាជ្យ ( ក្នុងកោះនេះ ) ព្រះបាទមុដសីវៈបានសោយទិវង្គតក្នុងកោះនេះ ក្នុងឆ្នាំទី ១៧ នៃ( រជ្ជកាល ) ព្រះបាទអសោកធម្មរាជ ( ដែលសោយរាជ្យនៅ ) ក្នុងជម្ពូទ្វីបនោះ ។ បន្ទាប់អំពីនោះ ព្រះបាទទេវានម្បិយតិស្សក៏ឡើងគ្រងរាជ្យ ( ក្នុងកោះនេះ ) ។

ម្យ៉ាងទៀត កាលសម្ដេចព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វានហើយ ព្រះបាទអជាតសត្រូវសោយរាជ្យបាន ២៤ ឆ្នាំ ចំណែកព្រះបាទឧទេយ្យភទ្ទសោយរាជ្យបាន ១៦ ឆ្នាំ ។ បន្ទាប់អំពីនោះ ព្រះបាទអនុរុទ្ធ និងព្រះបាទមុណ្ឌៈសោយរាជ្យបាន ៨ ឆ្នាំ ។ ព្រះបាទនាគទស្សកៈសោយរាជ្យបាន ២៤ ឆ្នាំ ។ ព្រះបាទសុសូនាគសោយរាជ្យបាន ១៨ ឆ្នាំ ។ ព្រះបាទអសោកព្រះរាជឱរសរបស់ព្រះបាទសុសូនាគនោះឯង សោយរាជ្យបាន ២៨ ឆ្នាំ ។ ព្រះរាជាដែលជាបងប្អូននឹងគ្នា ១០ អង្គ ដែលជាព្រះរាជឱរសរបស់ព្រះបាទអសោកសោយរាជ្យបាន ២២ ឆ្នាំ ។ ក្រោយមក បន្ទាប់អំពីរជ្ជកាលនៃព្រះរាជាដែលជាបងប្អូនគ្នា ១០ អង្គនោះ មានព្រះរាជា ៩ អង្គ ទ្រង់មានព្រះនាមថា នន្ទៈ ( តខ្សែព្រះនាមគ្រប់ៗ ទាំង ៩ អង្គ ) សោយរាជ្យបាន ២២ ឆ្នាំប៉ុណ្ណោះ ។ ព្រះបាទចន្ទ្រគុត្តសោយរាជ្យបាន ២៤ ឆ្នាំ ។ ព្រះបាទពិន្ទុសារសោយរាជ្យបាន ២៨ ឆ្នាំ ។ ក្នុងទីបំផុត ( រជ្ជកាល ) នៃព្រះបាទពិន្ទុសារនោះ ព្រះបាទអសោកក៏ឡើងគ្រងរាជ្យ ។ ក្នុងកាលមុន ទ្រង់អភិសេកព្រះបាទអសោកនោះគ្រងរាជ្យបាន ៤ ឆ្នាំ ។ ក្នុងឆ្នាំ

ទី ១៨ រាប់តាំងអំពីពេលព្រះបាទអសោកទ្រង់អភិសេកហើយ ព្រះមហិន្ទត្ថេរក៏មកឈរនៅត្រង់កោះនេះ ។ ពាក្យថា ព្រះមហិន្ទត្ថេរមកឈរ នៅត្រង់កោះនេះក្នុងឆ្នាំទី២៣៦ វស្សា រាប់អំពីឆ្នាំដែលសម្តេចព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វាន ដូច្នេះ បណ្ឌិតគប្បីជ្រាបតាមខ្សែវង្ស ( របស់ព្រះរាជាក្នុងជម្ពូទ្វីប ) នោះ ដូចពណ៌នាមក ដូច្នេះ ។

## ព្រះថេរទៅកាន់មិស្សកបព៌តជួបព្រះថេរ

ក្នុងថ្ងៃនោះ ត្រង់កោះតម្ពបណ្ណិ មានបុណ្យនក្ខត្តឫក្សក្នុងជេដ្ឋមាស ( គឺខែ ៧ ) ។ ព្រះរាជាទ្រង់បញ្ជាឲ្យឃោសនានក្ខត្តឫក្ស ហើយទ្រង់បញ្ជាពួកអមាត្យថា ពួកអ្នកចូរលេងមហោស្រពចុះ ដូច្នេះ ។ មានរាជបុរសចំនួនដល់ទៅ ៤ ម៉ឺនជាបរិវារ ទ្រង់ចេញអំពីព្រះនគរ មានបំណងនឹងលេងកីឡា បរបាញ់សត្វ ទើបទ្រង់ទៅដោយផ្លូវត្រង់មិស្សកបព៌តនោះ ។ ពេលនោះ មានទេវតាមួយអង្គ អាស្រ័យនៅត្រង់បព៌តនោះ គិតថា អញនឹងបង្ហាញព្រះថេរៈទាំង-ឡាយដល់ព្រះរាជា ទើបកាឡាខ្លួនជារមាំង ធ្វើអាកប្បកិរិយាស៊ីស្មៅ និងស្លឹកឈើនៅត្រង់ទីមិនឆ្ងាយ ( អំពីព្រះថេរៈនោះ ) ។ ព្រះរាជាទ្រង់ទតឃើញរមាំងមួយនោះហើយ ទើបទ្រង់គិតថា ឥឡូវនេះ មិនគួរនឹងបាញ់ម្រឹគ ដែលកំពុងភ្លេចខ្លួន ទើបទ្រង់ផ្ទាត់ខ្សែធ្នូ ។ ម្រឹគផ្តើមនឹងរកផ្លូវគេច ក៏គេចទៅតាមផ្លូវដែលមានសញ្ញាដោយដើមស្វាយ ។ ព្រះរាជាទ្រង់រត់តាមទៅពីក្រោយហើយទ្រង់ឡើងកាន់ផ្លូវដែលកំណត់ដោយដើមស្វាយនោះឯង ។ ចំណែកម្រឹគក៏បាត់ខ្លួនទៅក្នុងទីមិនឆ្ងាយអំពីព្រះថេរៈទាំងឡាយ ។ ព្រះមហិន្ទត្ថេរឃើញព្រះ

រាជាកំពុងយាងមកក្នុងទីមិនឆ្ងាយ ទើបអធិដ្ឋានថា សូមឲ្យព្រះរាជាទតឃើញតែអាត្មាអញប៉ុណ្ណោះ កុំទតឃើញអ្នកដទៃឡើយ ទើបពោលថា តិស្ស: តិស្ស: សូមទ្រង់មកផ្លូវនេះ ។ ព្រះរាជាទ្រង់ឮហើយ ធ្លលក្នុងព្រះទ័យ ឈ្មោះថា ជនដែលកើតក្នុងកោះនេះ ដែលអាចហៅអញដោយប្រារព្ធឈ្មោះថា តិស្ស: មិនមាន ឯសមណ:ត្រងោលនេះ ទ្រទ្រង់សំពត់ដែលកាត់ដាច់ ( ដោយសស្ត្រា ) ដណ្តប់សំពត់កាសាវ: ហៅអញដោយចំឈ្មោះ សមណ:នេះ តើនរណាហ្ន៎ ជាមនុស្ស ឬអមនុស្ស ទើបព្រះថេរ:ឆ្លើយថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពទាំងឡាយឈ្មោះថា សមណ: ជាសាវ័ករបស់ព្រះធម្មរាជា មកត្រង់កោះនេះ អំពីជម្ពូទ្វីប ក៏ដើម្បីអនុគ្រោះមហាបពិត្រប៉ុណ្ណោះ ។

សម័យនោះឯង ព្រះបាទទេវានម្បិយតិស្សមហារាជ និងព្រះបាទអសោកធម្មរាជា ទ្រង់ជាព្រះអទិដ្ឋសម្លាញ់នឹងគ្នា (គឺសម្លាញ់ដែលមិនធ្លាប់ឃើញគ្នា )។ ដោយបុញ្ញានុភាពរបស់ព្រះបាទទេវានម្បិយតិស្សមហារាជ មានឫស្សី ៣ កំណាត់ មានប្រមាណប៉ុនចន្ទោលរថ កើតឡើងត្រង់គុម្ពឫស្សីមួយកន្លែង ត្រង់ជើងភ្នំឆាតក: ឈ្មោះលតាយដ្ឋិមួយដើម ឈ្មោះបុប្ផយដ្ឋិមួយដើម ឈ្មោះសកុណ-យដ្ឋិមួយដើម ។

បណ្តាឫស្សី ៣ កំណាត់នោះ ឫស្សីឈ្មោះថា លតាយដ្ឋិ មានពណ៌ដូចប្រាក់ មានវល្លិពណ៌មាសរុំត្រង់ដើមឫស្សីនោះ ។ ចំណែកឫស្សីឈ្មោះបុប្ផយដ្ឋិ ក៏មានផ្កាពណ៌ខៀវ លឿង ក្រហម ស និងខ្មៅ មានទង ស្លឹក និងកេសរ ដែលរចនាទុកយ៉ាងល្អ ។ ចំណែកឫស្សីឈ្មោះថា សកុណយដ្ឋិ ក៏មានពួក

សកុណជាច្រើន មានហង្ស មាន់ ត្រដក់ជាដើម និងមានសត្វចតុប្បាទច្រើនប្រភេទ ប្រាកដហាក់ដូចមានជីវិតរស់ ។ សមដូចសីហឡាចារ្យពោលទុកក្នុងគម្ពីរទីបវង្សថា

ឫស្សី ៣ កំណាត់ បានកើតហើយត្រង់ជើងភ្នំឈ្មោះឆាតកៈ
កំណាត់ដែលជាវល្លិ មានពណ៌ស និងល្អដូចពណ៌មាស ប្រាកដនៅ
ចំត្រង់ដើម ពណ៌ប្រាក់ ផ្កាពណ៌ខៀវជាដើម មាននៅយ៉ាងណា ផ្កា
ដូច្នោះ ក៏ប្រាកដនៅក្នុងកំណាត់ដែលមានឈ្មោះថាបុប្ផយដ្ឋិ សកុណ-
ជាតិច្រើនចម្រុះ ក៏នាំគ្នាទំនៅលើកំណាត់ដែលមានឈ្មោះសកុណយដ្ឋិ
ដោយរូបរបស់ខ្លួននោះឯង ។

រតនៈ ( គឺកែវ ) ច្រើនប្រភេទ មានកែវមុក្តា កែវមណី និងកែវពិទូរ្យកើតឡើងអំពីសមុទ្រ ដល់ព្រះបាទទេវានម្បិយតិស្សៈអង្គនោះ ចំណែកក្នុងកោះតម្ពបណ្ណិទីប មានកែវមុក្តាកើតឡើង ៨ ប្រភេទ គឺកែវមុក្តាមានសណ្ឋានដូចរូបសេះ ១ កែវមុក្តាមានសណ្ឋានដូចរូបដំរី ១ កែវមុក្តាមានសណ្ឋានដូចរូបរថ ១ កែវមុក្តាមានសណ្ឋានដូចផ្លែកន្ទួតព្រៃ ១ កែវមុក្តាមានសណ្ឋានដូចកងដៃ ១ កែវមុក្តាមានសណ្ឋានដូចវង់ចិញ្ចៀន ១ កែវមុក្តាមានសណ្ឋានដូចផ្លែថ្វាន់ ១ កែវមុក្តាប្រក្រតី ១ ។ ព្រះរាជាបានបញ្ជូនឫស្សីកែវមុក្តានោះៗ និងរតនៈជាច្រើនដទៃទៀត ដើម្បីជាគ្រឿងបណ្ណាការដល់ព្រះបាទអសោកធម្មរាជ ។

ព្រះបាទអសោកទ្រង់ជ្រះថ្លា ហើយទ្រង់បញ្ជូនគ្រឿងកកុធភណ្ឌ ៥ យ៉ាងទៅថ្វាយដល់ព្រះរាជា គឺស្វេតច្ឆត្រ ១ ផ្លិតចាមរី ( វាលវីជនី ) ១ ព្រះខ័ន ១

រតនៈប្រដាប់ព្រះមូលី ( គឺព្រះឧណ្ហីស ដែលជាប់នឹងព្រះមហាពិជ័យមកុដ ) ១ បាទុកា ១ និងគ្រឿងបណ្ណាការដទៃច្រើនប្រភេទ ដើម្បីប្រយោជន៍ដល់ការអភិសេក ។ គ្រឿងបណ្ណាការដទៃទៀតនោះ គឺអ្វី ។ គឺសង្ខ ១ គង្គោទកវារី ( ទឹកទន្លេគង្គា ឬទឹកដែលកើតពីអនោតត្តស្រះ ) ១ វឌ្ឍមានៈ គឺលម្អិតសម្រាប់ស្រង់ទឹក ១ វដំសកៈ ( ព្រះមាលាសម្រាប់ប្រដាប់ត្រចៀក ) ១ កិង្គារៈ គឺកុណ្ឌីមាស ១ នន្ទិយាវដ្ដៈ គឺភាជន៍មាស ( ធ្វើទុកដើម្បីការមង្គល មានសណ្ឋានដូចជើងក្អែក ) ១ សិវិកៈ គឺ វ ឬគ្រែស្នែង ១ កញ្ញា គឺខត្តិយកុមារី ១ អធោវិមទុស្សយុគ ( គូព្រះភូសាដែលមិនចាំបាច់ បោកគក់ ) ១ ហត្ថបុញ្ឆនៈ គឺសំពត់សម្រាប់ជូតព្រះហស្ត ១ ហរិចន្ទនៈ គឺខ្លឹមចន្ទន៍ក្រហម ១ អរុណវណ្ណមត្តិកៈ គឺដីពណ៌អរុណ ១ អញ្ជនៈ គឺថ្នាំបន្តក់ភ្នែក ១ ហរីតកៈ គឺសម៉ឱសថ ១ អាមលកៈ កន្ទួតព្រៃឱសថ ១ ដូច្នេះឯង ។

ពាក្យនេះ សមដូចពាក្យដែលសីហឡាចារ្យពោលក្នុងគម្ពីរទីបវង្សថា

ព្រះរាជាទ្រង់ព្រះនាមថា អសោក ទ្រង់បញ្ជូនបណ្ណាការដែលកើតឡើងព្រោះបុញ្ញកម្ម ( របស់ព្រះអង្គ ) ទៅ ( ថ្វាយដល់ព្រះបាទទេវានម្បិយតិស្សៈ ) គឺផ្ចិតវាលវីជនី ១ ព្រះឧណ្ហីស ១ ស្វេតច្ឆត្រ ១ ព្រះខ័ន ១ បាទុកា ១ វេឋនៈ គឺសំពត់ជូតក្បាល ១ សារបាមង្គៈ គឺសង្វារ ១ កិង្គារៈ គឺព្រះកុណ្ឌីមាស ១ នន្ទិវដ្ដកៈ គឺភាជន៍មាស ១ សិវិកៈ គឺ វ ឬគ្រែស្នែង ១ សង្ខ គឺសង្ខសម្រាប់ប្រូចទឹកក្នុងពេលអភិសេក ១ វដំសកៈ គឺព្រះមាលាសម្រាប់ប្រដាប់

ត្រចៀក ឬក្រវិល ១ អធោវិមវត្ថកោដិក គឺព្រះភូសាមួយគូ ដែលមិនចាំបាច់បោកគក់ ១ សោវណ្ណបាតី គឺថាសមាស ១ កដច្ឆុ គឺវែក ១ មហគ្ឃហត្ថបុញ្ឆនៈ គឺសំពត់សម្រាប់ជូតព្រះហស្តមានតម្លៃច្រើន ១ អនោតត្តោទកកាជៈ គឺអំរែកទឹកអនោតត្តស្រះ ១ ឧត្តមហរិចន្ទនៈ គឺខ្លឹមចន្ទន៍ក្រហមដ៏ប្រសើរ ១ អរុណវណ្ណមត្តិកៈ គឺដីពណ៌អរុណ ១ អញ្ជនៈ គឺថ្នាំបន្តក់ភ្នែកដែលនាគនាំមកថ្វាយ ១ ហរីតកៈ គឺសម៉ឱសថ ១ អាមលកៈ គឺកន្ទួតព្រៃឱសថ ១ មហគ្ឃអមតោសថ គឺព្រះឱសថកែរោគ ដែលមានតម្លៃច្រើន ១ ស្រូវសាលី មានក្លិនក្រអូប ៦ ពាន់រទេះ ដែលសេកនាំមកថ្វាយ ១ ។

ព្រះបាទអសោក ទ្រង់បញ្ជូនគ្រឿងបណ្ណាការមិនមែនគ្រាន់តែជា អាមិស ប៉ុណ្ណោះឡើយ បានព្ធថា ថែមទាំងបញ្ជូនបណ្ណាការនេះទៅថ្វាយទៀតផង បណ្ណាការទាំងនេះ គឺទូលបង្គំបានដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាសរណៈ គឺទីពឹងហើយ បានប្រកាសខ្លួនជាឧបាសកក្នុងព្រះសាសនានៃសក្យបុត្រ បពិត្រព្រះអង្គ ដ៏ឧត្តមជាងនរជន សូមព្រះអង្គទ្រង់ញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងឧត្តមវត្ថុទាំង ៣ នេះចុះ សូមទ្រង់ដល់នូវរតនៈទាំង ៣ នោះថា ជាសរណៈ គឺទីពឹងដោយព្រះសទ្ធាចុះ ។

ក្នុងថ្ងៃនោះ ព្រះរាជាអង្គនោះ ទ្រង់ទទួលមុទ្ធាភិសេកមួយខែ ដោយគ្រឿងឧបករណ៍អភិសេក ដែលព្រះបាទអសោកទ្រង់បញ្ជូនទៅថ្វាយ ។ ពិតហើយ ពួក

សេនាមាត្យបានធ្វើការអភិសេកថ្វាយដល់ទ្រង់ក្នុងតិថីពេញបូណ៌មី ខែពិសាខ ។

ព្រះរាជាអង្គនោះ កាលទ្រង់រឭកដល់សាសនប្បវត្តិនោះ ដែលព្រះអង្គបានឮមកមិនយូរ កាលទ្រង់បានឮពាក្យនោះរបស់ព្រះថេរៈថា សូមថ្វាយព្រះពរមហាបពិត្រ អាត្មាភាពទាំងឡាយ ឈ្មោះថា សមណៈ ជាសាវករបស់ព្រះធម្មរាជា ដូច្នេះជាដើម ហើយទ្រង់ព្រះតម្រិះថា លោកម្ចាស់ទាំងឡាយមកហើយហ្ន៎ ទើបទ្រង់ចោលអាវុធក្នុងវេលានោះឯង ហើយប្រថាប់គង់សន្ទនាសម្មោទនីយកថា ក្នុងចំណែកម្ខាង ។ ដូចបុរាណាចារ្យពោលទុកថា

ព្រះរាជាទ្រង់ដាក់អាវុធ ហើយស្តេចប្រថាប់គង់នាចំណែកម្ខាង
កាលប្រថាប់គង់ហើយ បានត្រាស់ព្រះតម្រាស់ប្រកបដោយប្រ-
យោជន៍ ដែលនាំមកនូវ សេចក្តីរីករាយ ។

កាលព្រះរាជាអង្គនោះ ទ្រង់សន្ទនាសម្មោទនីយកថានោះឯង ពួករាជបរិវារចំនួន ៤ ម៉ឺន ក៏នាំគ្នាមកចោមរោមព្រះអង្គ ។

គ្រានោះ ព្រះថេរៈក៏បង្ហាញជន ៦ នាក់ ក្រៅអំពីនេះ ។ ព្រះរាជាទតឃើញ ( ជនទាំង ៦ នោះ ) ហើយ ទើបទ្រង់សាកសួរថា បុគ្គលទាំងនេះមកក្នុងកាលណា ព្រះថេរៈឆ្លើយថា មកព្រមគ្នាជាមួយអាត្មានោះឯង ព្រះអង្គព្រះរាជាសួរថា ឥឡូវនេះ សមណៈដទៃដែលមានសភាពបែបនេះ មាននៅក្នុងជម្ពូទ្វីបខ្លះឬ ព្រះថេរៈឆ្លើយថា មានមហាបពិត្រ ឥឡូវនេះជម្ពូទ្វីបរុងរឿងទៅដោយសំពត់កាសាវពស្ត្រ ដេរដាសទៅដោយខ្យល់ ( សន្ធឹក ) ពួកឥសីក្នុងជម្ពូទ្វីបនោះ ។

មានព្រះអរហន្តជាពុទ្ធសាវកដ៏ច្រើន ជាអ្នកបាននូវវិជ្ជា ៣ និង បានសម្រេចឫទ្ធិ ជំនាញក្នុងចេតោបរិយញ្ញាណអស់អាសវៈហើយ។

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយ នាំគ្នាមកដោយផ្លូវណា ព្រះថេរៈឆ្លើយថា បពិត្រមហារាជ អាត្មាទាំងឡាយមិនបានមកតាមផ្លូវទឹក ឬ ផ្លូវគោកឡើយ ។ ព្រះរាជាទ្រង់ក៏ជ្រាបបានថា លោកម្ចាស់ទាំងនេះមកតាមផ្លូវអាកាស ។

ព្រះថេរៈដើម្បីនឹងសាកល្បងមើលថា ព្រះរាជាទ្រង់ឈ្លាសវៃដោយព្រះបញ្ញាឬទេ ទើបទូលសួរបញ្ហាប្រារព្ធដើមស្វាយដែលនៅជិតនោះថា បពិត្រមហារាជ ដើមឈើនេះឈ្មោះអ្វី ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ឈ្មោះដើមស្វាយ ព្រះថេរៈសួរថា សូមថ្វាយព្រះពរមហាបពិត្រ ក្រៅអំពីដើមស្វាយនេះហើយ ដើមស្វាយដទៃមានដែរឬទេ ព្រះរាជាត្រាស់ថា មាន លោកម្ចាស់ ដើមស្វាយដទៃមានច្រើន ព្រះថេរៈសួរថា មហាបពិត្រ វៀរដើមស្វាយនេះ និងដើមស្វាយដទៃចេញហើយ ដើមឈើប្រភេទដទៃមានដែរឬ ព្រះរាជាត្រាស់ថា មានលោកម្ចាស់ តែដើមឈើទាំងនោះមិនមែនជាដើមស្វាយ ។ ព្រះថេរៈសួរថា វៀរដើមស្វាយ និងមិនមែនដើមស្វាយដទៃចេញ តើដើមឈើប្រភេទដទៃមានឬ ព្រះរាជាត្រាស់ថា មាន លោកម្ចាស់ គឺដើមស្វាយនេះឯង ព្រះថេរៈពោលថា សាធុ មហាបពិត្រ ព្រះអង្គទ្រង់ជាបណ្ឌិត ឯព្រះញាតិរបស់ព្រះអង្គមានឬ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ជនដែលជាញាតិរបស់ខ្ញុំមានច្រើន ព្រះថេរៈសួរថា វៀរជនដែលជាព្រះញាតិរបស់ព្រះអង្គទាំងនេះចេញហើយ ជនពួក

ជនទៃដែលមិនមែនជាព្រះញាតិមានដែរឬ ព្រះរាជាត្រាស់ថា ជនដែលមិនមែនញាតិមានច្រើនជាងបុគ្គលដែលជាញាតិ ព្រះថេរៈសួរថា វៀរបុគ្គលដែលជាព្រះញាតិរបស់ព្រះអង្គ និងបុគ្គលដែលមិនមែនព្រះញាតិចេញ បុគ្គលដទៃណាមានឬ ព្រះរាជាត្រាស់ថា មាន គឺខ្ញុំនេះឯង ព្រះថេរៈពោលថា សាធុ មហាបពិត្រ ដែលឈ្មោះថា ខ្លួន មិនរាប់ថា ជាញាតិរបស់ខ្លួនផង មិនរាប់ថា មិនមែនជាញាតិរបស់ខ្លួនផង ។

លំដាប់នោះ ព្រះថេរៈគិតថា ព្រះរាជាជាបណ្ឌិត ទ្រង់នឹងអាចដឹងធម៌បាន ដូច្នេះហើយ ទើបសម្ដែងចូឡហត្ថិបទោបមសូត្រ ។ ក្នុងវេលាចប់កថា ព្រះរាជា ព្រមដោយរាជបរិវារប្រមាណ ៤ ម៉ឺនតាំងនៅក្នុងត្រៃសរណគមន៍ ។

ក្នុងខណៈនោះឯង អ្នកចាត់ចែងអាហារ ក៏នាំព្រះក្រយាហារមកថ្វាយដល់ព្រះរាជា ។ ចំណែកព្រះរាជាកំពុងស្ដាប់ព្រះសូត្រ ទ្រង់មានព្រះទ័យជ្រាបថា សមណៈសក្យបុត្រទាំងនេះ មិនគួរនឹងឆាន់ក្នុងពេលនេះ ហើយទ្រង់មានព្រះតម្រិះថា ការដែលអញមិនសួរ ហើយបរិភោគ មិនគួរ ដូច្នេះ ទើបត្រាស់សួរថា លោកម្ចាស់ ពួកលោកម្ចាស់នឹងឆាន់ឬ ព្រះថេរៈឆ្លើយថា មហាបពិត្រ ពួកអាត្មាភាពមិនគួរឆាន់ក្នុងវេលានេះ ព្រះរាជាសួរថា លោកម្ចាស់គួរឆាន់ក្នុងពេលណាវិញ ព្រះថេរៈឆ្លើយថា គួរឆាន់តាំងអំពីព្រះអាទិត្យរះ រហូតដល់ថ្ងៃត្រង់ ព្រះរាជាពោលថា ពួកយើងទៅកាន់ព្រះនគរជាមួយគ្នាចុះ ព្រះថេរៈពោលថា កុំឡើយ មហាបពិត្រ ពួកអាត្មានឹងស្នាក់នៅក្នុងទីនេះឯង ។ ព្រះរាជាពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ទាំងឡាយស្នាក់នៅ ( ក្នុងទីនេះ )

សោត ក្មេងម្នាក់នេះចូរទៅជាមួយខ្ញុំចុះ ព្រះថេរៈឆ្លើយថា សូមថ្វាយព្រះពរ មហាបពិត្រ កុមារនេះសម្រេចផលហើយ ដឹងច្បាស់ព្រះសាសនា ជាបព្វជ្ជា-បេក្ខៈ នឹងបំពេញបព្វជ្ជាក្នុងឥឡូវនេះ ។ ព្រះរាជាទ្រង់ផ្តាំថា បពិត្រលោកម្ចាស់ បើដូច្នោះ ស្អែកនេះ ខ្ញុំនឹងបញ្ជូនរថមក ( ទទួលលោកម្ចាស់ទាំងឡាយ ) សូមលោកម្ចាស់ទាំងឡាយ មកតាមរថនោះចុះ ដូច្នេះ ថ្វាយបង្គំហើយ ទ្រង់ក៏ចៀសចេញទៅ ។

## សុមនសាមណេរប្រកាសពេលស្តាប់ធម៌

ព្រះថេរៈ កាលព្រះរាជាទ្រង់ចៀសចេញទៅមិនយូរមិនប៉ុន្មាន ទើបហៅសុមនសាមណេរមកប្រាប់ថា សុមនៈ អ្នកចូរទៅប្រកាសពេលស្តាប់ធម៌ចុះ ។ សុមនសាមណេរសួរថា បពិត្រលោកម្ចាស់ ខ្ញុំនឹងប្រកាសឲ្យបានឮអស់ទីមានប្រមាណប៉ុនណា ព្រះថេរៈប្រាប់ថា ចូរប្រកាសឲ្យបានឮពេញតម្ពបណ្ណិទ្វីបចុះ ។

សាមណេរទទួលថេរបញ្ជាថា បពិត្រលោកម្ចាស់ ល្អណាស់ ហើយក៏ចូលចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ចេញ ( ចាកឈាន ) ហើយអធិដ្ឋានមានចិត្តតាំងមាំ ប្រកាសពេលស្តាប់ធម៌ឲ្យបានឮពេញកោះតម្ពបណ្ណិទ្វីប អស់វារៈ ៣ ដង ។

ព្រះរាជា ទ្រង់ស្តាប់សំឡេងនោះហើយ ទើបទ្រង់បញ្ជូនដំណឹងទៅកាន់សម្នាក់របស់ព្រះថេរៈទាំងឡាយថា មានឧបទ្រវៈអ្វីឬលោកម្ចាស់ ព្រះថេរៈទូលថា អាត្មាភាពទាំងឡាយ មិនមានឧបទ្រវៈអ្វីឡើយ អាត្មាភាពទាំងឡាយបានឲ្យសាមណេរប្រកាសពេលស្តាប់ធម៌ អាត្មាភាពទាំងឡាយ មានបំណង

នឹងសម្ដែងព្រះពុទ្ធវចនៈ ( ប៉ុណ្ណោះ ) ។

ឯពួកកុម្ភទេវតា បានស្ដាប់សំឡេងរបស់សាមណេរនោះហើយ ក៏បានប្រកាសសំឡេងឲ្យលាន់ឮហើយ សំឡេងបានលាន់ឮឡើងរហូតដល់ព្រហ្មលោកដោយឧបាយនោះ ព្រោះសំឡេងនោះ មានទេវតាមកធ្វើសន្និបាតដ៏ច្រើន ។ ព្រះថេរៈឃើញទេវតាមកប្រជុំគ្នាសន្ទឹកសន្ទាប់យ៉ាងនេះ ទើបសម្ដែងសមចិត្តសូត្រ ។ ក្នុងពេលចប់ធម្មកថា ពួកទេវតាមួយអសង្ខ្យេយ្យ បានសម្រេចធម៌ហើយ ។ នាគ និងគ្រុឌសន្ទឹកសន្ទាប់ ក៏បានតាំងនៅក្នុងសរណគមន៍ហើយ ។ កាលព្រះសារីបុត្តត្ថេរសម្ដែងព្រះសូត្រនេះ ការប្រជុំរបស់ទេវតាទាំងឡាយមានហើយយ៉ាងណា ទេវសន្និបាតនេះ ក៏បានកើតហើយក្នុងកាលព្រះមហិន្ទត្ថេរ ( សម្ដែងសូត្រនេះ ) ដូចគ្នា ។

គ្រានោះ រាត្រីនោះកន្លងទៅ ព្រះរាជាទ្រង់បញ្ជូនរថទៅដើម្បី ( ទទួល ) ព្រះថេរៈទាំងឡាយ ។ នាយសារថីបញ្ឈប់រថទុកត្រង់ចំណែកម្ខាង ហើយពិតព្រះថេរៈទាំងឡាយថា រថមកហើយ លោកម្ចាស់ មេត្តាឡើងរថចុះ ពួកយើងនឹងទៅ ។

ព្រះថេរៈទាំងឡាយពោលថា ពួកអាត្មាមិនឡើងរថទេ អ្នកចូរទៅចុះ ពួកអាត្មានឹងទៅតាមក្រោយ ដូច្នេះហើយ បានហោះឡើងកាន់វេហាស៍ ហើយទៅចុះក្នុងបឋមចេតិយដ្ឋាន ត្រង់ទិសបូព៌ានៃក្រុងអនុរាធបុរី ពិតហើយ ចេតិយនោះ អ្នកស្រុកហៅថា បឋមចេតិយ ព្រោះជាចេតិយដែលមហាជនសាងទុកក្នុងទីកន្លែងដែលព្រះថេរៈទាំងឡាយ ចុះគ្រាដំបូងនោះឯង ។

ចំណែកព្រះរាជា កាលបញ្ជូននាយសារថីទៅហើយ ទើបទ្រង់ប្រាប់ពួកអមាត្យឲ្យនាំគ្នាតាក់តែងមណ្ឌប ខាងក្នុងព្រះរាជនិវេសន៍ ។ ក្នុងវេលានោះឯង អមាត្យទាំងឡាយក៏ត្រេកអររីករាយ តុបតែងមណ្ឌបជាទីគួរជ្រះថ្លាក្រៃពន់ពេក ។ ព្រះរាជាទ្រង់ព្រះតម្រិះទៀតថា ម្សិលមិញនេះ ព្រះថេរៈ កាលសម្ដែងនូវសីលទាំងឡាយ បានពោលថា ទីដេកខ្ពស់ និងទីដេកដ៏ប្រសើរ រមែងមិនគួរ ( ដល់ពួកភិក្ខុ ) ដូច្នេះ លោកម្ចាស់ទាំងឡាយ នឹងអង្គុយលើអាសនៈទាំងឡាយឬទេហ្ន៎ កាលទ្រង់កំពុងត្រិះរិះយ៉ាងនេះឯង នាយសារថីនោះក៏មកដល់ទ្វារព្រះនគរល្មម ។ ខណៈនោះ នាយសារថីបានឃើញព្រះថេរៈ ទាំងឡាយក្រវាត់វត្ថពន្ធចង្កេះ ដណ្ដប់ចីវរមកដល់មុនស្រេច ។ កាលនាយសារថីឃើញហើយក៏ជាបុគ្គលមានចិត្តជ្រះថ្លាក្រៃលែង ត្រឡប់មកទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ព្រះថេរៈទាំងឡាយមកដល់ហើយ ។ ព្រះរាជាត្រាស់សួរថា ព្រះថេរៈទាំងឡាយជិះរថមកឬ នាយសារថីទូលថា មិនជិះទេ ព្រះអង្គ ម្យ៉ាងទៀត ព្រះថេរៈទាំងឡាយមកតាមក្រោយទូលព្រះបង្គំ តែមកដល់មុន បានឈរនៅត្រង់ទ្វារទិសបូព៌ា ព្រះរាជាទ្រង់ឮថា ព្រះថេរៈទាំងឡាយមិនឡើងរថ ទើបទ្រង់ព្រះតម្រិះថា ឥឡូវនេះ លោកម្ចាស់ទាំងឡាយ មិនត្រេកអរក្នុងអាសនៈខ្ពស់ ហើយត្រាស់បញ្ជាថា នែអ្នកទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរក្រាលអាសនៈដោយអាការផ្ទាល់ផែនដី ដើម្បីព្រះថេរៈទាំងឡាយ ដូច្នេះហើយ ទ្រង់បានចូលផ្លូវទៅ ។ ពួកអមាត្យក្រាលកន្ទេលដ៏ទន់លើផែនដីហើយ ក្រាលកម្រាលដ៏វិចិត្រ មានសំពត់កោជវៈ ( កម្រាលព្រំ ) ខាងលើ ។ ពួកហោរាអ្នកទាយ

និមិត្តឃើញ ( ហេតុការណ៍នោះ ) ហើយ នាំគ្នាព្យាករថា ផែនដីនេះត្រូវព្រះថេរៈទាំងនេះគ្រប់គ្រងហើយ ក្នុងឥឡូវនេះ លោកម្ចាស់ទាំងនេះ នឹងជាម្ចាស់នៃកោះតម្ពបណ្ណិទ្វីប ។ ឯព្រះរាជា ទ្រង់បានមកថ្វាយបង្គំព្រះថេរៈទាំងឡាយ ហើយទ្រង់ទទួលយកបាត្រអំពីដៃរបស់ព្រះមហិន្ទត្ថេរ ហើយនិមន្តព្រះថេរៈទាំង-ឡាយឲ្យចូលទៅក្នុងក្រុង ដោយការបូជា និងសក្ការៈដ៏ធំ ឲ្យចូលទៅកាន់ខាងក្នុងព្រះរាជនិវេសន៍ ។ ព្រះថេរៈឃើញការក្រាលអាសនៈហើយ អង្គុយបណ្ដើរគិតបណ្ដើរថា ព្រះពុទ្ធសាសនា នឹងផ្សាយទៅពេញលង្កាទ្វីប នឹងតាំងមាំមិនកម្រើកដូចផែនដី ។ ព្រះរាជាទ្រង់អង្គាសព្រះថេរៈទាំងឡាយ ឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយៈដ៏ប្រណីត ដោយព្រះហស្តព្រះអង្គស្រេចហើយ បានប្រាប់ឲ្យហៅស្ត្រី ៥០០ នាក់ មានព្រះនាងអនុឡាទេវីជាប្រធាន មកដោយព្រះតម្រាស់ថា ពួកនាងចូរធ្វើការអភិវាទ និងបូជាសក្ការៈព្រះថេរៈទាំងឡាយចុះ ដូច្នេះហើយ ទ្រង់បានប្រថាប់ក្នុងចំណែកម្ខាង ។

ក្នុងវេលាស្រេចភត្តកិច្ច ព្រះថេរៈកាលនឹងឲ្យនូវភ្លៀងរតនៈ គឺព្រះធម៌ធ្លាក់ចុះដល់ព្រះរាជា ព្រមទាំងបរិវារ ទើបបានសម្ដែងបេតវត្ថុ វិមានវត្ថុ និងសច្ចសំយុត្ត ។ ស្ត្រីទាំង ៥០០ នោះ ស្ដាប់ព្រះធម្មទេសនារបស់ព្រះថេរៈបានធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ សូម្បីពួកមនុស្សដែលបានជួបព្រះថេរៈនៅលើភ្នំមិស្សកបព៌តក្នុងថ្ងៃមុន ក៏នាំគ្នាពោលសរសើរគុណរបស់ព្រះថេរៈក្នុងទីនោះៗ ។ ពួកមហាជនស្ដាប់ ( អំពីសម្នាក់ ) របស់ជនទាំងនោះ បានប្រជុំគ្នាបន្លឺសំឡេងអឺងកង ត្រង់លានព្រះរាជវាំង ។ ព្រះរាជាត្រាស់សួរថា ទុំះ

សំឡេងអ្វីហ្នឹ ពួកអ្នកនគរក្រាបទូលថា ពួកមហាជននិយាយថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំមិនបានឃើញព្រះថេរៈ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បើមហាជនទាំងឡាយចូលមកក្នុងទីនេះសោត ឱកាសនឹងមិនមាន ទើបត្រាស់ថា នែបា ពួកអ្នកចូរទៅជម្រះរោងដំរី កៀរខ្សាច់ រោយផ្កា ៥ ពណ៌ ចងពិតានដោយសំពត់ ហើយក្រាលអាសនៈ ដើម្បីព្រះថេរៈទាំងឡាយលើទីរបស់ដំរីមង្គល ។ ពួករាជអមាត្យបានធ្វើយ៉ាងនោះហើយ ។ ព្រះថេរៈបានទៅគង់សម្ដែងទេវទូតសូត្រក្នុងទីនោះ ។ ក្នុងខណៈចប់ធម្មកថា ជនប្រមាណមួយពាន់ បានតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងវេលានោះ ជនទាំងឡាយគិតថា រោងដំរីចង្អៀតពេកណាស់ ហើយទើបរៀបចំអាសនៈ ត្រង់ឧទ្យាននន្ទវ័ន ជិតទ្វារទិសខាងត្បូង ។ ព្រះថេរៈ ( ទៅ ) គង់សម្ដែងអាសីវិសូបមសូត្រ ក្នុងឧទ្យាននន្ទវ័ននោះ ។ ព្រោះស្ដាប់អាសីវិសូបមសូត្រនោះ មនុស្សប្រមាណមួយពាន់បានសោតាបត្តិផល ។ ក្នុងថ្ងៃទី ២ បន្ទាប់អំពីព្រះថេរៈមកហើយ ធម្មាភិសម័យ ( ការត្រាស់ដឹងធម៌ ) មានដល់ជនប្រមាណ ២ ពាន់ ៥ រយនាក់ ។

កាលព្រះថេរៈនៅសំណេះសំណាលជាមួយនឹងស្រីក្នុងត្រកូលទាំងឡាយ កូនប្រសាក្នុងត្រកូល កុមារីក្នុងត្រកូល ដែលគេមកហើយជាបន្តបន្ទាប់ ក្នុងនន្ទវ័នឧទ្យាននោះឯង រហូតដល់ល្ងាច ។ ព្រះថេរៈសង្កេតវេលាហើយ ក្រោកឡើងបណ្ដើរ ពោលបណ្ដើរថា ដល់វេលាហើយ ពួកអាត្មានឹងទៅកាន់មិស្សកបព៌ត ។ ពួកអមាត្យសាកសួរថា លោកម្ចាស់ទាំងឡាយ នឹងទៅទីណា ព្រះថេរៈពោលថា នឹងទៅកាន់ទីសម្នាក់របស់ពួកអាត្មា ។ អមាត្យទាំងនោះក៏

*ក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ហើយក្រាបទូលតាមព្រះបរមរាជានុមតិថា បពិត្រលោកម្ចាស់ ពេលនេះ មិនមែនជាពេលដែលនឹងទៅក្នុងទីនោះ ឧទ្យាននន្ទវ័ននេះឯង សូមជាទីសម្រាករបស់លោកម្ចាស់ចុះ ។ ព្រះថេរៈពោលថា កុំឡើយ ពួកអាត្មានឹងទៅ ពួកអមាត្យប្រាប់តាមព្រះរាជតម្រាស់ទៀតថា បពិត្រលោកម្ចាស់ ព្រះរាជាត្រាស់ថា ឧទ្យានមេឃវ័ននេះ ជារបស់ព្រះបិតាខ្ញុំ នៅមិនជិតមិនឆ្ងាយអំពីព្រះនគរ សម្បូរដោយផ្លូវទៅមក សូមព្រះថេរៈទាំងឡាយមេត្តាសម្រេចឥរិយាបថក្នុងឧទ្យានមេឃវ័ននេះចុះ ។ ទើបព្រះថេរៈទាំងឡាយស្នាក់នៅត្រង់ឧទ្យានមេឃវ័ននោះ ។ ចំណែកព្រះរាជា លុះរាត្រីនោះកន្លងទៅ ទ្រង់បានយាងទៅកាន់សម្នាក់របស់ព្រះថេរៈ បានត្រាស់សួរដល់ការសិងជាសុខសប្បាយ ហើយត្រាស់សួរតទៅថា បពិត្រលោកម្ចាស់ អារាមនេះ សមគួរដល់ភិក្ខុសង្ឃដែរឬទេ ព្រះថេរៈឆ្លើយថា សមគួរមហាបពិត្រ ហើយទើបនាំព្រះសូត្រនេះមកថា* **អនុជានាមិ ភិក្ខវេ អារាមំ** *ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតអារាម ដូច្នេះជាដើម ។ ព្រះរាជាទ្រង់ពេញព្រះរាជហឫទ័យទ្រង់ចាប់ព្រះសុវណ្ណភិង្ការ ( កុណ្ឌីមាស ) ប្រូចទឹកឲ្យស្រក់ទៅត្រង់ដៃរបស់ព្រះថេរៈ បានប្រគេនមហាមេឃវ័នឧទ្យាន ដំណាលគ្នានឹងទឹកស្រក់ចុះនោះឯងផែនដីក៏ញាប់ញ័រហើយ ។ នេះជាការកម្រើកផែនដីគ្រាដំបូង ក្នុងមហាវិហារ ។ ព្រះរាជាទ្រង់មានព្រះទ័យភ័យខ្លាច ទើបត្រាស់សួរព្រះថេរៈថា បពិត្រលោកម្ចាស់ព្រោះហេតុអ្វី ទើបផែនដីកម្រើក ព្រះថេរៈទូលថា មហាបពិត្រ កុំព្រួយព្រះទ័យឡើយ សាសនារបស់ព្រះទសពលនឹងតាំងមាំក្នុងកោះនេះ ហើយទីនេះនឹង*

ជាទីតាំងមហាវិហារគ្រាដំបូង ផែនដីកម្រើកនោះ ជាបុព្វនិមិត្តនៃការប្រតិស្ឋានព្រះសាសនា និងជាទីកសាងវិហារនោះ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្រៃលែងហួសប្រមាណ ។

លុះស្អែកឡើង ព្រះថេរៈឆាន់ត្រង់ព្រះរាជមណ្ឌបតាមធម្មតា ហើយសម្តែងអនមតគ្គិយសូត្រ ក្នុងនន្ទវនឧទ្យាននោះ ។ ស្អែកឡើងសម្តែងអគ្គិក្ខន្ធោបមសូត្រ លោកសម្តែងដោយឧបាយនេះឯងរហូត ៧ ថ្ងៃ ។ ធម្មាភិសម័យមានដល់សត្វប្រមាណ ៨៥០០ នាក់ ។ តាំងអំពីនោះមក នន្ទវនឧទ្យានក៏បានឈ្មោះថា ជោតិវន ព្រោះអធិប្បាយថា ជាទីកន្លែងដែលសាសនារុងរឿងឡើង ។ ចំណែកក្នុងថ្ងៃទី ៧ ព្រះថេរៈសម្តែងអប្បមាទសូត្រប្រោសព្រះរាជាខាងក្នុងព្រះរាជវាំងហើយ ក៏បង្ហួសទៅកាន់ចេតិយគិរីបព៌តនោះឯង ។ គ្រានោះ ព្រះរាជាត្រាស់សួរពួកអមាត្យថា ព្រះថេរៈទូន្មានពួកយើងដោយឱវាទធ្ងន់ហើយ គប្បីចេញទៅឬហ្ន៎ ពួកអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះអង្គមិនបាននិមន្តព្រះថេរៈមកទេ គឺព្រះថេរៈនិមន្តមកដោយខ្លួនឯង ព្រោះដូច្នោះ សូម្បីការមិនលាព្រះអង្គ ហើយចេញទៅក៏បាន ។

លំដាប់នោះ ព្រះរាជាទ្រង់ឡើងរថ និងទ្រង់លើកព្រះទេវីទាំង ២ ឲ្យឡើងហើយ ស្តេចយាងទៅកាន់ចេតិយគិរីបព៌ត ដោយរាជានុភាពធំ ។ ព្រះរាជាកាលយាងទៅហើយ ឲ្យព្រះទេវីទាំង ២ សម្រាកនៅនាចំណែកម្ខាង ទ្រង់ក៏ចូលទៅកាន់សម្នាក់ព្រះថេរៈទាំងឡាយ មានព្រះវរកាយហត់នឿយពន់ពេក ។ ខណៈនោះ ព្រះថេរៈទូលព្រះរាជាថា បពិត្រមហារាជ ព្រោះហេតុអ្វី ទើបទ្រង់

យាងមក ទាំងមានសភាពលំបាកព្រះវរកាយយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំមកដើម្បីជ្រាបថា លោកម្ចាស់ទាំងឡាយ ឲ្យគេរកោរាទដល់ខ្ញុំហើយ ប្រាថ្នានឹងទៅវិញក្នុងកាលឥឡូវនេះឬ ព្រះថេរៈពោលថា បពិត្រមហារាជ អាត្មាភាពទាំងឡាយមិនទៅទេ តែពេលនេះ ជាវស្សូបនាយិកកាល គឺពេលដែលត្រូវចូលវស្សា បពិត្រមហារាជ ក្នុងវស្សូបនាយិកកាលនេះ សមណៈបានទីកន្លែងចាំវស្សា ទើបសមគួរ ។

ក្នុងថ្ងៃនោះឯង អមាត្យឈ្មោះអរិដ្ឋៈ មួយអន្លើដោយបងប្រុស និងប្អូនប្រុសចំនួន ៥៥ នាក់ ឈរនៅក្នុងទីជិតព្រះរាជា ក្រាបទូលថា បពិត្រមហារាជ ទូលបង្គំចង់បួសក្នុងសម្នាក់របស់ព្រះថេរៈ ។ ព្រះរាជាត្រាស់ថា សាធុ បា ចូរបួសចុះ ។ ព្រះរាជាកាលទ្រង់អនុញ្ញាតហើយ បានប្រគល់នាទីឲ្យព្រះថេរៈ ។ ព្រះថេរៈក៏ឲ្យបុគ្គលទាំងនោះបួសក្នុងថ្ងៃនោះឯង ។ បុគ្គលទាំងអស់ដែលបួសបានសម្រេចអរហត្តក្នុងខណៈកោរសក់រួចដូចគ្នា ។ ចំណែកព្រះរាជា ទ្រង់យកបន្ទាត់ទ្បលានព្រះចេតិយក្នុងខណៈនោះឯង ហើយទ្រង់ផ្តើមតាំងការងារទុកត្រង់គុហាទាំង ៦៨ ហើយទ្រង់ត្រឡប់ចូលព្រះនគរវិញ ។ ព្រះថេរៈទាំងនោះញុំាងរាជត្រកូលបងប្អូនទាំង ១០ ព្រះអង្គឲ្យជ្រះថ្លាហើយ នៅចាំវស្សាត្រង់ចេតិយគិរីបព៌ត ប្រៀនប្រដៅមហាជនក្នុងពេលនោះ ក៏មានព្រះអរហន្ត ៦២ អង្គ ចូលចាំវស្សាដំបូងក្នុងគិរីបព៌តចេតិយនោះ ។

គ្រានោះ ព្រះមហិន្ទនៅចាំវស្សា បវារណាហើយ បានទូលពាក្យនេះជាមួយព្រះរាជាក្នុងថ្ងៃឧបោសថពេញបូណ៌មីខែកត្តិកថា បពិត្រមហារាជ អាត្មា

ភាពទាំងឡាយ បានគាល់ព្រះសម្មាសម្ពុទ្ធមកយូរហើយ តែឥឡូវដូចជាគ្មានទីពឹង អាត្មាគិតទៅកាន់ជម្ពូទ្វីប ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំទំនុកបម្រុងលោកម្ចាស់ទាំងឡាយ ដោយបច្ច័យ ៤ ហើយមហាជនទាំងនេះអាស្រ័យលោកម្ចាស់ តាំងនៅក្នុងសរណៈទាំងឡាយ ហេតុដូចម្ដេច បានជាលោកម្ចាស់ទាំងឡាយនឿយណាយក្នុងពួកយើង ។ ព្រះថេរៈទូលថា បពិត្រមហារាជ អាត្មាភាពទាំងឡាយ បានគាល់ព្រះសម្មាសម្ពុទ្ធមកយូរហើយ ទីកន្លែងដែលធ្វើការអភិវាទ ការក្រោកទទួល អញ្ជលិកម្ម និងសាមីចិកម្មក្នុងទីនេះមិនមាន ព្រោះហេតុនោះ ទើបអាត្មាភាពទាំងឡាយនឿយណាយ ដូច្នេះ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ លោកម្ចាស់បានពោលមិនមែនឬថា ព្រះសម្មាសម្ពុទ្ធបរិនិព្វានហើយ ។ ព្រះថេរៈទូលថា បពិត្រមហារាជ ទ្រង់បរិនិព្វានហើយពិតមែន តែព្រះសរីរធាតុព្រះអង្គគង់នៅ នៅឡើយ ។ ព្រះរាជាត្រាស់ថា ខ្ញុំដឹង តាមពិតលោកម្ចាស់ មានបំណងនឹងសាងព្រះស្តូបហើយត្រាស់បន្តថា បពិត្រលោកម្ចាស់ ខ្ញុំនឹងសាងព្រះស្តូប សូមនិមន្តលោកម្ចាស់ជ្រើសរើសទីកន្លែងក្នុងកាលឥឡូវនេះចុះ ម្យ៉ាងទៀត ខ្ញុំនឹងបានព្រះធាតុអំពីទីណា ព្រះថេរៈទូលថា បពិត្រមហារាជ សូមទ្រង់ប្រឹក្សាជាមួយសុមនសាមណេរចុះ ។

ព្រះរាជាទ្រង់ទទួលថា សាធុ លោកម្ចាស់ ហើយចូលទៅរកសុមនសាមណេរត្រាស់សួរថា ទានប្រោស ឥឡូវនេះ ពួកយើងនឹងបានព្រះធាតុមកអំពីណា សុមនសាមណេរទូលថា បពិត្រមហារាជ សូមព្រះអង្គមានសេចក្តី

ខ្វល់ខ្វាយតិចចុះ សូមព្រះអង្គទ្រង់ឲ្យគេជម្រះផ្លូវប្រដាប់តាក់តែងដោយគ្រឿងលម្អ មានទង់ជ័យ ទង់ជ្វាលា និងផ្ទាំងតម្កល់ទឹកជាដើម ហើយសូមទ្រង់ និងជនជាបរិវារសមាទានអដ្ឋឧបោសថ ឲ្យពួកអ្នកកាន់ការខាងតូរ្យតន្ត្រីទាំងឡាយប្រជុំគ្នា ឲ្យប្រដាប់តាក់តែងដំរីមង្គល ដោយគ្រឿងអលង្ការគ្រប់យ៉ាង និងលើកស្វេតច្ឆត្រឡើងខាងលើខ្នងដំរីនោះ លុះពេលល្ងាច សូមព្រះអង្គយាងបែរព្រះកន្ត្រតម្រង់ទៅកាន់មហានាគវ័នឧទ្យាន ព្រះអង្គនឹងបានព្រះធាតុក្នុងទីនោះពិតប្រាកដ ។ ព្រះរាជាទ្រង់ទទួលថា សាធុ ។ ព្រះថេរៈទាំងឡាយក៏បានទៅកាន់គិរីបព៌ិតចេតិយនោះឯង ។

ក្នុងគិរីបព៌ិតចេតិយនោះ ព្រះមហិន្ទត្ថេរនិយាយនឹងសុមនសាមណេរថា នែសាមណេរ ចូរអ្នកទៅចុះ ហើយចូលគាល់ព្រះបាទអសោកធម្មរាជ ដែលជាព្រះអយ្យកោរបស់អ្នកក្នុងជម្ពូទ្វីប ទូលតាមពាក្យរបស់ខ្ញុំយ៉ាងនេះថា បពិត្រមហារាជ ព្រះបាទទេវានម្បិយតិស្សៈ ជាសម្លាញ់របស់ព្រះអង្គ ទ្រង់ជ្រះថ្លាក្នុងព្រះសាសនា ប្រាថ្នាចង់សាងព្រះស្តូប បានឮថា ព្រះអង្គមានព្រះធាតុនៅក្នុងដៃ ( នៅក្នុងការគ្រប់គ្រង ) សូមព្រះអង្គមេត្តាព្រះរាជទានព្រះធាតុនោះដល់អាត្មាចុះ ដូច្នេះហើយ ទទួលយកព្រះធាតុនោះ ហើយចូលទៅគាល់សក្កទេវរាជ ទូលយ៉ាងនេះថា បពិត្រមហារាជ បានឮថា ព្រះអង្គមានព្រះធាតុនៅក្នុងដៃ ២ ព្រះអង្គ គឺព្រះទន្តធាតុ ( ព្រះចង្កូមកែវ ) ខាងស្តាំ ១ ព្រះអក្ខកធាតុ ( ឆ្អឹងដងកាំបិត ) ខាងស្តាំ ១ ព្រោះដូច្នោះ សូមព្រះអង្គទុកព្រះទន្តធាតុខាងស្តាំ ធ្វើការបូជាចុះ ហើយព្រះរាជទានព្រះអក្ខកធាតុខាងស្តាំ

ដល់អាត្មាភាព និងទូលសក្កទេវរាជនោះយ៉ាងនេះថា បពិត្រមហារាជ ព្រោះហេតុអ្វី ព្រះអង្គបញ្ជូនអាត្មាភាពទាំងឡាយ ទៅកាន់កោះតម្ពបណ្ណិទ្វីបហើយ បោះបង់ លែងចោលយ៉ាងនេះ ។

សុមនសាមណេរទទួលពាក្យរបស់ព្រះថេរៈថា សាធុ លោកម្ចាស់ ដូច្នេះហើយ កាន់យកបាត្រ និងចីវរ ហោះឡើងទៅកាន់អាកាសក្នុងខណៈនោះឯង ចុះត្រង់ទ្វារនគរបាដលីបុត្រ ទៅកាន់រាជសម្នាក់ ទូលរឿងនោះឲ្យព្រះរាជាជ្រាប ។ ព្រះរាជាទ្រង់ត្រេកអរ ទទួលបាត្រអំពីដៃសាមណេរ អប់ដោយគ្រឿងក្រអូប ហើយបានយាងព្រះធាតុទុកក្នុងបាត្រ ដែលដូចជាកែវមុក្តាដ៏ប្រសើរ ប្រគេនសាមណេរ ។ សាមណេរទទួលយកព្រះធាតុនោះហើយ ចូលទៅគាល់សក្កទេវរាជ ។ សក្កទេវរាជឃើញសាមណេរហើយ ត្រាស់ថា បាសុមនៈដ៏ចម្រើន លោកម្ចាស់ត្រាច់មក ព្រោះហេតុអ្វី សាមណេរឆ្លើយថា បពិត្រមហារាជ ព្រះអង្គបញ្ជូនអាត្មាភាពទាំងឡាយទៅកាន់កោះតម្ពបណ្ណិទ្វីបហើយ ទ្រង់លែងចោលមិនអើពើ ព្រោះហេតុអ្វី សក្កទេវរាជពោលថា មិនបានលែងចោលឡើយ និយាយមកចុះ នឹងឲ្យខ្ញុំធ្វើអ្វី សាមណេរឆ្លើយថា បានឮថា ព្រះអង្គមានព្រះធាតុក្នុងដៃ ២ ព្រះអង្គ គឺព្រះចង្កូមកែវខាងស្តាំ ១ ព្រះធាតុដងកាំបិតខាងស្តាំ ១ ដូច្នោះ សូមមហាបពិត្រ ទ្រង់ទុកព្រះទន្តធាតុខាងស្តាំ គ្រាន់បូជាចុះ តែសូមទ្រង់ព្រះរាជទានព្រះអក្ខកធាតុខាងស្តាំដល់អាត្មាចុះ ។ សក្កទេវរាជស្តេចទេវតាត្រាស់ថា សាធុ លោកម្ចាស់ ហើយទ្រង់បើកព្រះស្តូបកែវមណីមានកម្ពស់ប្រមាណមួយយោជន៍ បាននាំព្រះអក្ខកធាតុខាងស្តាំចេញមកហើយ

ប្រគេនដល់សុមនសាមណេរ ។ សុមនសាមណេរនោះ ទទួលយកព្រះធាតុនោះហើយ ប្រតិស្ឋានទុកក្នុងចេតិយបព៌តនោះឯង ។

គ្រានោះឯង ព្រះមហានាគទាំងនោះ មានព្រះមហិន្ទជាប្រធាន ប្រតិស្ឋានព្រះធាតុ ដែលព្រះបាទធម្មាសោកទ្រង់ព្រះរាជទានមក ទុកត្រង់ចេតិយបព៌តនោះឯង ហើយអារាធនាព្រះអក្ខកធាតុខាងស្តាំ ទៅកាន់មហានាគវនឧទ្យានក្នុងពេលរសៀល ។ ចំណែកព្រះរាជា ទ្រង់ធ្វើការបូជាសក្ការៈ មានប្រការដូចសុមនសាមណេរពោលហើយ ប្រថាប់លើ-កដំរីដ៏ប្រសើរ ទ្រង់បាំងស្វេតច្ឆត្រដោយព្រះអង្គឯង លើក្បាលរបស់ដំរីមង្គល យាងទៅដល់មហា-នាគវនឧទ្យានល្ងម ។ គ្រានោះ ព្រះរាជាទ្រង់រំពឹងដូច្នេះថា បើនេះជាព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធសោត ស្វេតច្ឆត្រចូរបែរងាកចេញទៅ ដំរីមង្គលចូរលុតជង្គង់ចុះលើផែនដី សូមឲ្យកោដិដែលបញ្ចុះព្រះធាតុមកប្រតិស្ឋាននៅលើក្បាលរបស់អញ ។ ដំណាលគ្នានឹងចិត្តុប្បាទរបស់ព្រះរាជា ឆត្របានបែរងាកចេញទៅ ដំរីលុតជង្គង់ចុះលើផែនដី ព្រះកោដិបញ្ចុះព្រះធាតុក៏មកប្រតិស្ឋានលើព្រះសីសៈរបស់ព្រះរាជា ។ ព្រះរាជាទ្រង់ប្រកបដោយបីតិបាមោជ្ជយ៉ាងក្រៃលែងដូចមានទឹកអមតៈស្រោចស្រពលើព្រះអង្គ ហើយទើបត្រាស់សួរថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំនឹងបដិបត្តិក្នុងព្រះធាតុដូចម្តេច ។ ព្រះថេរៈប្រាប់ថា សូមព្រះអង្គទ្រង់ដាក់ព្រះធាតុទុកលើពោងដំរីនោះឯងសិន ។ ព្រះរាជាទ្រង់បានលើកព្រះកោដិបញ្ចុះព្រះធាតុដាក់លើពោងដំរី ។ ដំរីមានចិត្តត្រេកអរ បានបន្លឺសំឡេងដូចបក្សីក្រៀល ។ មហាមេឃមានអ័ព្ទខ្មៅឡើង ញុំាងនូវភ្លៀងបោក្ខរព័ស្សឲ្យធ្លាក់

ចុះមក ។ មហាប្រឹថពីបានញ័រដល់ទីបំផុតទឹក បញ្ជាក់ឲ្យដឹងថា ព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធប្រតិស្ឋានក្នុងបច្ចន្តជនបទដូច្នេះជាហេតុ ពួកទេវតា និងមនុស្ស បានត្រេកអររីករាយគ្រប់គ្នា ។

ព្រះមហាវីរៈ ( អ្នកមានព្យាយាមធំ ) យាងមកក្នុងកោះលង្កា
នេះអំពីទេវលោក បានប្រតិស្ឋានទូវលើពោងដីក្នុងតិថី ១៥ កើត
ជាគម្រប់ ៤ ខែ ( ពាក់កណ្តាលខែកត្តិក ) ។

ញុំាងឲ្យកើតបីតិដល់ពពួកទេវតា និងមនុស្សទាំងឡាយ ដោយសិរី គឺអានុភាពនៃឫទ្ធិ ដោយប្រការដូច្នេះឯង ។

គ្រានោះ ដំរីនោះ ដែលពួកតូរ្យតន្ត្រីជាច្រើនហែហមហើយ មានពួកអ្នកនគរធ្វើសក្ការបូជាយ៉ាងឱឡារិក ឆ្ពោះមុខទៅកាន់ទិសបច្ចិម មិនថយក្រោយរហូតដល់ទ្វារនគរទិសខាងកើត ហើយចូលកាន់នគរតាមទ្វារទិសខាងកើតនោះ មានពួកអ្នកនគរទូទាំងក្រុង ធ្វើការបូជាយ៉ាងឱឡារិក ចេញ ( អំពីក្រុង ) តាមទ្វារទិសទក្សិណ ធ្វើដំណើរទៅកាន់ទេវាល័យ ( ទេវស្ថាន ) របស់មហេជយក្ខ សេចក្តីថា ក្នុងទិសខាងលិចនៃថូបារាម ហើយត្រឡប់បែរមុខត្រង់ទៅកាន់ថូបារាមនោះឯងទៀត ។ សម័យនោះ ថូបារាមជាទីតាំងនៃបរិភោគចេតិយរបស់ព្រះសម្មាសម្ពុទ្ធអង្គមុនៗ ចំនួន ៣ អង្គ ។

## ប្រវត្តិកោះលង្កាជាប់ទាក់ទងនឹងព្រះពុទ្ធ

បានឮមកថា ក្នុងអតីតកាល ទ្វីបនេះមានឈ្មោះថា ឱជទ្វីប ។ ព្រះរាជាមានឈ្មោះថា អភ័យ ។ ទីក្រុងឈ្មោះថា អភយបុរៈ ។ ចេតិយបពិតមាន

ឈ្មោះទេវកូដបព៌ត ។ ចូបារាមមានឈ្មោះថា បដិយារាម ។ សម័យនោះឯង ព្រះដ៏មានព្រះភាគព្រះនាមថា កកុសន្ធៈ ទ្រង់កើតឡើងហើយក្នុងលោក ។ សាវករបស់ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះមហាទេវៈ បានឈរនៅលើទេវកូដបព៌តជាមួយភិក្ខុមួយពាន់អង្គ ដូចព្រះមហិន្ទត្ថេរ ឈរលើចេតិយបព៌តដូច្នោះ ។ សម័យនោះ ពួកសត្វលើកោះឱជទ្វីបដល់នូវវិបត្តិវិនាសហិនហោចព្រោះរោគឈ្មោះ បជ្ជរកៈ ( គ្រុនសន្និ ) ព្រះដ៏មានព្រះភាគព្រះនាមថា កកុសន្ធៈទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ បានទតឃើញហើយដូច្នេះនូវសត្វទាំងនោះ ដល់នូវវិបត្តិអន្តរាយ កាលទតឃើញហើយ មានភិក្ខុ ៤ ម៉ឺនហែហមទ្រង់ទៅ ( ត្រង់កោះនោះ ) ។ ដោយអានុភាពរបស់ព្រះដ៏មានព្រះភាគនោះ បជ្ជរករោគ បានស្ងប់រម្ងាប់ក្នុងខណៈនោះឯង ។ កាលរោគស្ងប់ហើយ ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ប្រោស ។ ធម្មាភិសម័យមានហើយដល់សត្វ ៨៤០០០ ។ ព្រះដ៏មានព្រះភាគបានប្រទានធម្មក្រកទុកហើយ ទ្រង់បានចៀសចេញទៅ ។ អ្នកស្រុកបានសាងចេតិយត្រង់បដិយារាម បញ្ចុះធម្មក្រកនោះទុកខាងក្នុង ។ ព្រះមហាទេវៈ បាននៅប្រៀនប្រដៅអ្នកកោះនោះ ។

ចំណែកក្នុងសម័យកាលរបស់ព្រះដ៏មានព្រះភាគកោនាគមនៈ ទ្វីបនេះមានឈ្មោះថា វរទ្វីប ។ ព្រះរាជាមានឈ្មោះថា សមិទ្ធិ ។ រាជធានីឈ្មោះថា វឌ្ឍមានៈ ។ ភ្នំឈ្មោះថា សុវណ្ណកូដ ។ ឯសម័យនោះ មានការរាំងភ្លៀងលំបាកដោយភិក្ខាហារ សន្ទូងក្នុងវរទ្វីបអន្តរាយអស់ ។ ពួកសត្វដល់នូវការវិនាសដោយរោគ គឺការអត់ឃ្លាន ។ ព្រះដ៏មានព្រះភាគកោនាគមនៈ ទ្រង់

ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ បានឃើញសត្វទាំងនោះដល់នូវសេចក្តីវិនាស កាលទតឃើញហើយ មានភិក្ខុ ៣ ម៉ឺនអង្គហែហមទ្រង់ទៅ ( កាន់កោះនោះ ) ។ ដោយពុទ្ធានុភាព ភ្លៀងបានធ្លាក់ត្រូវតាមរដូវកាល ។ ភិក្ខាហារក៏រកបានងាយ ។ ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ប្រោសដល់មនុស្សក្នុងទីនោះ សត្វមានប្រមាណ ៨៤០០០ បាននូវធម្មាភិសម័យហើយ ។ ព្រះដ៏មានព្រះភាគឃាត់ព្រះថេរៈឈ្មោះមហាសុមនៈ ដែលមានភិក្ខុមួយពាន់អង្គជាបរិវារ ទុកត្រង់កោះនោះ បានប្រទានវត្ថពន្ធចង្កេះទុកហើយ ទ្រង់ចៀសចេញទៅ ។ ជនទាំងឡាយបានសាងព្រះចេតិយបញ្ចុះវត្ថពន្ធចង្កេះនោះទុកខាងក្នុង ។

ម្យ៉ាងទៀត ក្នុងពុទ្ធកាលនៃព្រះដ៏មានព្រះភាគកស្សប កោះនេះមានឈ្មោះថា មណ្ឌទ្វីប មានព្រះរាជាទ្រង់ព្រះនាមថា ជយន្តៈ ។ នគរឈ្មោះថា វិសាល ។ ភ្នំមានឈ្មោះថា សុភកូដ ។ សម័យនោះឯង វិវាទដ៏ធំបានកើតឡើងក្នុងមណ្ឌទ្វីប ។ សត្វជាច្រើនកើតជម្លោះវិវាទទាស់ទែងគ្នា រមែងដល់នូវសេចក្តីវិនាស ។ ព្រះកស្សបដ៏មានព្រះភាគ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធ-ចក្ខុ បានឃើញសត្វទាំងនោះ ដល់នូវសេចក្តីវិនាស លុះទតឃើញហើយ មានភិក្ខុ ២ ម៉ឺនអង្គហែហមព្រះដ៏មានព្រះភាគ មករម្ងាប់វិវាទ ហើយសម្តែងធម៌ប្រោស សត្វប្រមាណ ៨៤០០០ បានសម្រេចធម្មាភិសម័យហើយ ។ ព្រះដ៏មានព្រះភាគឲ្យព្រះថេរៈឈ្មោះ សព្វនន្ទិ ដែលមានភិក្ខុមួយពាន់អង្គជាបរិវារឲ្យនៅនាកោះនោះ ហើយទ្រង់បានប្រទានឧទកសាដក ( សំពត់ស្រង់ទឹក ) ទុកហើយ ទ្រង់ចៀសចេញទៅ អ្នកកោះបានសាងព្រះចេតិយបញ្ចុះឧទកសាដក

*នោះទុកខាងក្នុង ។ បរិភោគចេតិយរបស់ព្រះដ៏មានព្រះភាគ ៣ អង្គមុនៗ បាន ប្រតិស្ឋានហើយក្នុងថូបារាម ដោយប្រការយ៉ាងនេះ ។ ចេតិយទាំងនោះ រមែង សាបសូន្យទៅ ព្រោះការអន្តរធានទៅនៃសាសនា សល់ត្រឹមតែទីកន្លែង ប៉ុណ្ណោះ ព្រោះហេតុនោះ ទើបខ្ញុំពោលពាក្យនេះថា សម័យនោះ ថូបារាម ជា ទីតាំងនៃបរិភោគចេតិយរបស់ព្រះសម្មាសម្ពុទ្ធ ៣ អង្គមុនៗ ។*

*កន្លែងនោះ កាលព្រះចេតិយសាបសូន្យទៅហើយ ត្រូវគ្របដណ្តប់ ដោយគុម្ពឈើផ្សេងៗ ដែលមានមែកតូចៗ ចាក់ស្រេះទៅដោយបន្លា ដោយ អានុភាពរបស់ទេវតាដែលតាំងចិត្តថា បុគ្គលណាមួយ កុំមកប្រទូសរ៉ាយទីនោះ ដោយរបស់ស្មោកគ្រោកមិនស្អាត មន្ទិល ឬកាកសំណល់ផ្សេងៗ ។*

## ដំរីមិនព្រមឲ្យលើកព្រះធាតុចុះអំពីពោង

*គ្រានោះ ពួករាជបុរសដើរអំពីខាងមុខដំរីនោះទៅមុន កាប់ឆ្ការគុម្ពឈើ ទាំងអស់ពង្រាបដីទីនោះឲ្យរាបដូចបាតដៃ ។ ស្តេចដំរីដើរបែរមុខទៅកាន់ទីនោះ បានឈរត្រង់កន្លែងដើមពោធិ៍ អំពីខាងលិចនៃទីនោះ ។ គ្រានោះ ពួករាជបុរស ប្រារព្ធនឹងលើកព្រះធាតុចុះអំពីពោងដំរីនោះ ។ ស្តេចដំរីមិនព្រមឲ្យលើកចុះ ។ ព្រះរាជាត្រាស់សួរព្រះថេរៈថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើបដំរីមិន ព្រមឲ្យលើកព្រះធាតុចុះ ។ ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ ព្រះធាតុ ដែលលើកឡើងហើយ នឹងលើកចុះមិនសមគួរ ។ ក្នុងកាលនោះ ទឹកក្នុងបឹង អភយវាបីរីងស្ងួតទៅ ។ ផែនដីដោយជុំវិញបែកក្រហែង ដីស្អិតលើកឡើង បានងាយ មហាជនប្រញាប់ប្រញាល់ជួយគ្នានាំដីអំពីបឹងអភយវាបីនោះ មកធ្វើ*

ជាបល្ល័ង្កប្រមាណប៉ុនពោងដីរ ។ ក្នុងខណៈនោះឯង ជនទាំងឡាយចាប់ផ្ដើមប៉ាន់ឥដ្ឋ ដើម្បីសាងព្រះស្តូប ។ ស្ដេចដីរឈរក្នុងរោងដីរជិតខឿនរបស់ដើមពោធិព្រឹក្សក្នុងពេលថ្ងៃ ពេលយប់រក្សាផ្ទៃដីដែលត្រូវសាងព្រះស្តូប ២-៣ ថ្ងៃរហូតដល់ឥដ្ឋសម្រេច ។ គ្រានោះ ព្រះរាជាបង្គាប់ឲ្យរៀបគ្រឿង ហើយត្រាស់សួរព្រះថេរៈថា បពិត្រលោកម្ចាស់ យើងគប្បីសាងព្រះស្តូប មានរូបរាងលក្ខណៈដូចម្ដេច ព្រះថេរៈថ្វាយព្រះពរថា ដូចគ្នានឹងពំនូកស្រូវ មហាបពិត្រ ព្រះរាជាទ្រង់ត្រាស់ថា សាធុ លោកម្ចាស់ ហើយបញ្ជាឲ្យសាងព្រះស្តូបប្រមាណត្រឹមជង្គង់ ហើយឲ្យធ្វើសក្ការៈធំ ដើម្បីលើកព្រះធាតុឡើង ។

ពួកអ្នកនគរទាំងអស់ និងអ្នកជនបទប្រជុំគ្នាហើយ ដើម្បីមើលការឆ្លងព្រះធាតុ ។ កាលពួកមហាជនប្រជុំគ្នាហើយ ព្រះធាតុរបស់ព្រះទសពលបានហោះឡើងទៅកាន់អាកាសប្រមាណ ៧ ដូរត្នោត អំពីពោងដីរ សម្ដែងយមកប្បាដិហារិយ៍ ។ ផ្កាទឹក និងផ្ការភ្លើង មានរស្មី ៦ ពណ៌ ក៏ផ្សាយចេញអំពីអង្គព្រះធាតុទាំងឡាយនោះៗ ។ ដូចគ្នានឹងបាដិហារិយ៍ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងនាគល់គណ្ឌម្ពព្រឹក្ស ( ដើមស្វាយ ) ជិតក្រុងសាវត្ថី ។ ឯបាដិហារិយ៍នោះមិនមែនដោយអានុភាពរបស់ព្រះថេរៈ មិនមែនដោយអានុភាពរបស់ទេវតាឡើយ ដែលពិតនោះ ដោយពុទ្ធានុភាពប៉ុណ្ណោះ ។

បានឮថា ព្រះដ៏មានព្រះភាគ កាលគង់ធរមាននៅនោះឯង ទ្រង់បានអធិដ្ឋានថា កាលតថាគតបរិនិព្វានហើយ យមកប្បាដិហារិយ៍ ចូរមានក្នុងថ្ងៃប្រតិស្ឋានអក្ខកធាតុខាងស្ដាំរបស់តថាគត លើទីតាំងបរិភោគចេតិយរបស់ព្រះពុទ្ធ

អង្គ ៣ អង្គមុនៗ ត្រង់ទិសទក្សិណនៃអនុរាធបុរីក្នុងកោះតម្ពបណ្ណិទ្វីប ដូច្នេះ ។

**ឯវំ អចិន្តិយា ពុទ្ធា ពុទ្ធធម្មា អចិន្តិយា**

**អចិន្តិយេ បសន្នានំ វិបាកោ ហោតិ អចិន្តិយោ ។**

ព្រះពុទ្ធជាអចិន្តេយ្យបុគ្គល ព្រះធម៌របស់ព្រះអង្គក៏ជាអចិន្តេយ្យ វិបាករបស់ជនដែលជ្រះថ្លាក្នុងព្រះពុទ្ធ និងព្រះគុណរបស់ព្រះពុទ្ធដែលជាអចិន្តេយ្យ ក៏ជាអចិន្តេយ្យដោយន័យដូចពោលមក ដូច្នេះ ។

បានឮថា ព្រះសម្មាសម្ពុទ្ធ កាលទ្រង់គង់ព្រះជន្មនៅ បានយាងមកកាន់កោះនេះអស់វារៈ ៣ ដង គឺជំបូងទ្រង់យាងមកមួយព្រះអង្គឯងប៉ុណ្ណោះ ដើម្បីទូន្មានយក្ខ កាលទូន្មានយក្ខហើយ ទ្រង់តាំងការរក្សាត្រង់កោះតម្ពបណ្ណិទ្វីប ទ្រង់ហោះប្រទក្សិណ ៣ ជុំ តាំងព្រះទ័យថា កាលតថាគតបរិនិព្វានហើយ សាសនារបស់តថាគត នឹងប្រតិស្ឋានត្រង់កោះនេះ ។

លើកទី ២ ទ្រង់យាងមកមួយព្រះអង្គឯងដូចគ្នា ដើម្បីទូន្មានស្តេចនាគដែលជាមារ និងក្មួយ កាលទ្រង់ទូន្មាននាគទាំងនោះហើយ ទើបទ្រង់យាងត្រឡប់ ។ លើកទី ៣ ទ្រង់យាងមកមានភិក្ខុ ៥០០ អង្គជាបរិវារ ប្រថាប់គង់ចូលនិរោធសមាបត្តិ ត្រង់ទីតាំងមហាចេតិយ ត្រង់ថូបារាមចេតិយ ដែលប្រតិស្ឋានមហាពោធិ៍ ត្រង់កន្លែងមុតិង្គណចេតិយ ត្រង់ទីឃវាបីចេតិយ និងត្រង់កល្យាណិយចេតិយ ។ ការយាងមកដោយព្រះសរីរធាតុលើកនេះ ជាលើកទី ៤ របស់ព្រះដ៏មានព្រះភាគអង្គនោះ ។

ដែលឈ្មោះថា ឱកាសតិចតួចលើទឹកដីកោះតម្ពបណ្ណិទ្វីប ដែលតំណក់

ទឹកផ្សាយចេញអំពីព្រះសរីរធាតុរបស់ព្រះដ៏មានព្រះភាគអង្គនោះ មិនពាល់ត្រូវមិនមាន ។ ព្រះសរីរធាតុរបស់ព្រះដ៏មានព្រះភាគអង្គនោះ ញុំាំងកាពក្តៅក្រហាយរបស់ដែនដីកោះតម្ពបណ្ណិទ្វីប ឲ្យស្ងប់ដោយតំណក់ភ្លៀង សម្តែងបាដិហារិយ៍ដល់មហាជន ហើយចុះមកប្រតិស្ឋានលើសីសៈរបស់ព្រះរាជាដោយប្រការយ៉ាងនេះ ។ ព្រះរាជាទ្រង់សម្គាល់ការបានអត្តភាពជាមនុស្សដែលមានផលទ្រង់ធ្វើសក្ការៈធំ ឲ្យបញ្ចុះព្រះធាតុហើយ ដំណាលគ្នានឹងការបញ្ចុះព្រះធាតុ ផែនដីបានញាប់ញ័រហើយ ។

ឯព្រះរាជកុមារឈ្មោះ អភ័យ ជាព្រះកនិដ្ឋភាតា ( ប្អូនប្រុស ) របស់ព្រះរាជា ញុំាំងព្រះហឫទ័យឲ្យជ្រះថ្លាក្នុងបាដិហារិយ៍នៃព្រះធាតុនោះហើយ ទ្រង់ព្រះផ្នួស ព្រមនឹងបុរសប្រមាណ ១០០០ ។ ពួកកុមារ ៥០០ នាក់ ចេញបួសអំពីស្រុកវេតាលិ អំពីស្រុកទ្វារមណ្ឌលជាដើម ពួកកុមារចេញបួសក្នុងស្រុកនីមួយៗ ៥០០ នាក់ដូចគ្នា ។ ពួកកុមារច្រើនរយចេញបួសខាងក្នុងក្រុងនិងខាងក្រៅក្រុង សរុបទាំងអស់ ជាភិក្ខុ ៣ ម៉ឺនអង្គ ។ កាលព្រះស្តូបសម្រេចហើយ ព្រះរាជា រាជអមាត្យ និងព្រះទេវីបានធ្វើការបូជាមួយផ្នែកៗសូម្បីដល់ពួកទេវតា នាគ និងយក្ខ ដ៏ឱឡារិក ។ម្យ៉ាងទៀត កាលការបូជាព្រះធាតុ ( និង ) ព្រះធាតុចេតិយសម្រេចហើយ ព្រះមហិន្ទត្ថេរទៅកាន់មេឃវនឧទ្យាន សម្រេចឥរិយាបថទីនោះឯង ។

សម័យនោះឯង ព្រះនាងអនុឡាទេវីមានព្រះបំណងចង់បួស ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ព្រះនាងហើយ បានត្រាស់ពាក្យ

នេះជាមួយព្រះថេរៈថា បពិត្រលោកម្ចាស់ ព្រះនាងអនុឡាទេវីមានបំណងចង់បួស សូមលោកម្ចាស់ឲ្យព្រះនាងបួសចុះ ។ ព្រះថេរៈថ្វាយព្រះពរថា បពិត្រមហារាជ ការឲ្យមាតុគ្រាមបួស មិនសមគួរដល់អាត្មាទាំងឡាយឡើយ តែក្នុងបាដលីបុត្រនគរ មានព្រះថេរីឈ្មោះសង្ឃមិត្តា ដែលជាប្អូនស្រីរបស់អាត្មា សូមព្រះអង្គទ្រង់ឲ្យនិមន្តព្រះថេរីនោះមក ឯពោធិព្រឹក្ស ( ត្រង់ទីត្រាស់ដឹង ) របស់ព្រះសម្មាសម្ពុទ្ធ ៣ អង្គមុនៗ បានប្រតិស្ឋានត្រង់កោះនេះ ពោធិព្រឹក្សដែលបញ្ចេញបណ្តាញរស្មីថ្មីៗ របស់ព្រះដ៏មានព្រះភាគនៃយើង ក៏គួរប្រតិស្ឋាននៅលើកោះនេះ ព្រោះដូច្នោះ ព្រះអង្គគប្បីបញ្ជូនព្រះរាជសាសន៍ទៅ ដោយវិធីដែលព្រះនាងសង្ឃមិត្តាថេរី គប្បីយាងព្រះពោធិព្រឹក្សមកផង ។

ព្រះរាជាទ្រង់ទទួលពាក្យរបស់ព្រះថេរៈថា សាធុ លោកម្ចាស់ ដូច្នេះហើយ ទ្រង់ប្រឹក្សាជាមួយពួកអមាត្យ ហើយត្រាស់នឹងអមាត្យដែលជាក្មួយរបស់ព្រះអង្គឈ្មោះអរិដ្ឋថា អ្នកអាចទៅកាន់នគរបាដលីបុត្រ និមន្តព្រះនាងសង្ឃមិត្តាថេរីមក មួយអន្លើដោយព្រះមហាពោធិ៍បានឬទេ អរិដ្ឋអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំអាច បើព្រះអង្គទ្រង់អនុញ្ញាតឲ្យទូលបង្គំបួស ។ ព្រះរាជាត្រាស់ថា ទៅចុះបា អ្នកនាំព្រះថេរីមកហើយ ចូរបួសចុះ ។ អមាត្យនោះកាន់យកព្រះរាជសាសន៍ និងថេរសាសន៍ហើយ ទៅកាន់កំពង់ឈ្មោះជម្ពុកោលបដ្តន: ដោយថ្ងៃមួយប៉ុណ្ណោះ ដោយកម្លាំងការអធិដ្ឋានរបស់ព្រះថេរៈ ចេញសំពៅឆ្លងសមុទ្រទៅកាន់រាជធានីបាដលីបុត្រនោះឯង ។ ឯព្រះនាងអនុឡាទេវី មួយអន្លើដោយស្ត្រី ៥០០ នាក់ និងស្រីក្នុងព្រះរាជវាំង ៥០០

នាក់ទៀត សមាទានសីល ១០ ស្លៀកសំពត់កាសាវពស្ត្រ ក្នុងព្រះពន្ធាជ័យ ក្នុងចំណែកម្ខាងនៃព្រះនគរ ហើយសម្រាកសម្រាន្តនៅ ។

ចំណែកអរិដ្ឋអមាត្យ ក៏ទៅដល់ក្នុងថ្ងៃនោះឯង បានថ្វាយព្រះរាជសាសន៍ ហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ព្រះមហិន្ទត្ថេរ ព្រះឱរស របស់ព្រះអង្គទូលយ៉ាងនេះថា បានឮថា ព្រះទេវីឈ្មោះអនុឡា ព្រះជាយា ( ប្រពន្ធ ) របស់ព្រះកនិដ្ឋកាតានៃព្រះបាទទេវានម្បិយតិស្សៈ ដែលជាសម្លាញ់ របស់ព្រះអង្គមានបំណងនឹងបួស ដើម្បីឲ្យព្រះនាងបានបួស សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស បញ្ជូនព្រះនាងសង្ឃមិត្តាថេរី និងមហាពោធិព្រឹក្សទៅជាមួយព្រះនាងផងចុះ ។ អរិដ្ឋអមាត្យ កាលទូលថ្វាយព្រះថេរសាសន៍ហើយ ចូលគាល់ព្រះនាងសង្ឃមិត្តាថេរី ពិតព្រះថេរីយ៉ាងនេះថា បពិត្រព្រះនាង ព្រះមហិន្ទជាបងរបស់ព្រះនាង បញ្ជូនខ្ញុំមកក្នុងសម្នាក់របស់ព្រះនាង ដោយប្រាប់ថា ព្រះនាងអនុឡាទេវី ជាព្រះជាយារបស់ព្រះកនិដ្ឋកាតានៃព្រះបាទទេវានម្បិយតិស្សៈ មួយអន្លើដោយស្ត្រី ៥០០ នាក់ និងស្ត្រីក្នុងរាជវាំង ៥០០ នាក់ មានបំណងចង់បួស សូមព្រះនាងឲ្យព្រះនាងអនុឡាទេវីនោះបានបួសផងចុះ ។ ក្នុងខណៈនោះឯង ព្រះថេរីរួសរាន់ទៅកាន់ព្រះរាជសម្នាក់ ហើយទូលយ៉ាងនេះថា បពិត្រមហារាជ ព្រះមហិន្ទត្ថេរជាបង ឲ្យដំណឹងមកយ៉ាងនេះថា បានឮថា ព្រះនាងអនុឡាទេវី ព្រះជាយារបស់ព្រះកនិដ្ឋកាតានៃព្រះរាជា មួយអន្លើដោយស្ត្រី ៥ រយនាក់ និងស្ត្រីក្នុងរាជវាំង ៥ រយនាក់ មានបំណងនឹងបួស ទន្ទឹងរង់ចាំការទៅរបស់អាត្មា បពិត្រមហារាជ អាត្មាប្រាថ្នានឹងទៅកាន់កោះតម្ពបណ្ណិទ្វីប ។ ព្រះ

រាជាត្រាស់ថា នែកូន មហិន្ទត្ថេរដែលជាកូនរបស់ញោម និងសុមនសាមណេរ ចៅរបស់ញោម ក៏ទៅកាន់កោះតម្ពបណ្ណិទ្វីប ធ្វើឲ្យញោមហាក់ដូចជាដាច់នូវដៃ ញោមកាលមិនឃើញកូន និង ចៅទាំងនោះ ក៏កើតសេចក្ដីសោយសោក កាល ឃើញមុខកូនស្រី ក៏បានសះស្បើយ កុំឡើយកូនស្រី កូនកុំទៅ ។ ព្រះ ថេរីទូលថា បពិត្រមហារាជ ពាក្យរបស់ព្រះជេដ្ឋានៃអាត្មាធ្ងន់ពេកណាស់ សូម្បី ព្រះនាងអនុឡាខត្តិយានី ដែលស្ត្រី ១០០០ នាក់ចោមរោមហើយ ក៏បែរមុខ មកកាន់បព្វជ្ជាទន្ទឹងមើលផ្លូវអាត្មាៗ នឹងទៅ ព្រះរាជាត្រាស់ថា ណ្ហើយកូន បើ ដូច្នោះ កូនចូរយាងមហាពោធិ៍ទៅផងចុះ ។

សួរថា ព្រះរាជាបានមហាពោធិ៍មកអំពីណា ឆ្លើយថា បានឮថា ព្រះរាជា មានបំណងនឹងបញ្ជូនមហាពោធិ៍ទៅកាន់កោះលង្កា កាលសុមនសាមណេរមិន ទាន់មកដល់ ដើម្បីទទួលយកព្រះធាតុតាំងអំពីមុនព្រះនាងសង្ឃមិត្តា គិតនឹង ទៅម៉្លេះ ព្រះរាជាទ្រង់ត្រិះរិះថា យើងនឹងបញ្ជូនមហាពោធិ៍ដែលមិនគួរនឹងកាត់ ដោយសស្ត្រាទៅ បានដូចម្ដេចហ្ន៎ កាលមិនឃើញឧបាយ ទើបត្រាស់សួរ អមាត្យឈ្មោះមហាទេវៈ ។ អមាត្យនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ភិក្ខុជាបណ្ឌិតមានច្រើន ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះហើយ ទ្រង់ឲ្យត្រៀម រៀបចំភត្តដើម្បីភិក្ខុសង្ឃ ក្នុងទីបំផុតនៃភត្តកិច្ច បានត្រាស់សួរព្រះសង្ឃថា បពិត្រលោកម្ចាស់ មហាពោធិ៍របស់ព្រះដ៏មានព្រះភាគ គួរទៅកាន់កោះលង្កាឬ ទេហ្ន៎ ។ ទើបសង្ឃប្រគល់ភារៈឲ្យដល់ព្រះមោគ្គលីបុត្តតិស្សត្ថេរ ។ ព្រះថេរៈ ថ្វាយព្រះពរថា មហាពោធិ៍ គួរទៅកាន់កោះលង្កាពិត បានទូលប្រាប់មហា-

អធិដ្ឋាន ៥ យ៉ាងរបស់ព្រះដ៏មានព្រះភាគ ។

មហាអធិដ្ឋាន ៥ ប្រការដូចម្តេច បានឮថា ព្រះដ៏មានព្រះភាគទ្រង់ផ្ទំលើទែនសយនាសម្រាប់បរិនិព្វាន ទ្រង់បានអធិដ្ឋានដើម្បីឲ្យមហាពោធិព្រឹក្សប្រតិស្ឋាននៅក្នុងលង្កាទ្វីប ព្រះបាទអសោកមហារាជទ្រង់យាងមកទទួលមហាពោធិ៍ ក្នុងពេលនោះ មែកមហាពោធិ៍ទិសខាងត្បូង ចូរដាច់ឯងនោះឯង ហើយប្រតិស្ឋាននៅក្នុងផើងមាស នេះជាអធិដ្ឋានទី ១ ។ ទ្រង់អធិដ្ឋានថា ក្នុងពេលប្រតិស្ឋាននៅក្នុងផើងមាសនោះ មហាពោធិ៍ ចូរអណ្តែតចូលទៅកាន់ស្រទាប់ទឹកសន្សើមនេះជាអធិដ្ឋានទី ២ ។ ទ្រង់អធិដ្ឋានថា ក្នុងថ្ងៃជាគម្រប់ ៧ មហាពោធិ៍ ចូរអណ្តែតចុះមកអំពីស្រទាប់ហិមវលាហកៈ តាំងនៅក្នុងផើងមាស បញ្ចេញឆព្វណ្ណរង្សីអំពីស្លឹក និងផ្លែទាំងឡាយ នេះជាអធិដ្ឋានទី ៣ ។ ព្រះដ៏មានព្រះភាគទ្រង់អធិដ្ឋានថា ព្រះអក្ខកធាតុខាងស្តាំ ចូរធ្វើយមកប្បាដិហារិយ៍ក្នុងថ្ងៃប្រតិស្ឋានត្រង់ថូបារាមចេតិយ នេះជាអធិដ្ឋានទី ៤ ។ ទ្រង់អធិដ្ឋានថា ព្រះធាតុប្រមាណមួយទោណក្នុងកោះលង្កានេះឯង ក្នុងពេលប្រតិស្ឋានក្នុងមហាចេតិយ ចូរបានជាព្រះពុទ្ធនិម្មិត ហើយហោះឡើងកាន់អាកាស ធ្វើយមកប្បាដិហារិយ៍ នេះជាអធិដ្ឋានទី ៥ ។

ព្រះរាជាទ្រង់ស្តាប់មហាអធិដ្ឋាន ៥ នេះហើយ មានព្រះហឫទ័យជ្រះថ្លាបង្គាប់ឲ្យជម្រះផ្លូវ តាំងអំពីបាដលីបុត្ររាជធានី រហូតដល់មហាពោធិព្រឹក្សហើយឲ្យនាំមាសជាច្រើនចេញមក ដើម្បីឲ្យសាងផើងមាស ។ ក្នុងខណៈនោះឯង វិស្សកម្មទេវបុត្រជ្រាបរាជហឫទ័យ បានកាឡាខ្លួនជាជាងមាស ឈរនៅ

ចំពោះព្រះភក្ត្រ ( របស់ព្រះរាជា ) ។ ព្រះរាជាទតឃើញវិស្សកម្មទេវបុត្រ ទើបត្រាស់ថា នែបា អ្នកយកមាសនេះទៅធ្វើផើង ។ វិស្សកម្មនិម្មិតទូលថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ប្រាប់ខ្នាតឲ្យទូលបង្គំជ្រាបផង ។ ព្រះរាជាត្រាស់ថា នែបា អ្នកនោះឯង ជ្រាបខ្លួនឯង និងចូរឲ្យត្រូវខ្នាតផង ។ វិស្សកម្មនិម្មិតទទួលថា សាធុ ព្រះសម្មតិទេព ទូលបង្គំនឹងធ្វើ ទើបកាន់យកមាសស្ទាបអង្អែលដោយអានុភាពរបស់ខ្លួន ធ្វើផើងមាស វាស់ដោយជុំវិញប្រមាណ ៩ ហត្ថ កម្ពស់ ៥ ហត្ថ ទទឹង ៣ ហត្ថ កម្រាស់ ៨ ធ្នាប់ កណ្តាប់មាត់មានទំហំប៉ុនគល់ប្រមោយដំរី ។

គ្រានោះ ព្រះរាជា ទ្រង់ចេញអំពីបាដលីបុត្រនគរ ដោយសេនាដ៏ធំបណ្តោយប្រមាណ ៧ យោជន៍ ទទឹងប្រមាណ ៣ យោជន៍ នាំព្រះអរិយសង្ឃ ទ្រង់បានយាងទៅកាន់ពោធិមណ្ឌល ។ សេនាទាំងឡាយឈរជុំវិញមហាពោធិព្រឹក្ស ដែលមានទង់ជ័យ និងទង់ផ្កាលា លើកឡើងហើយ វិចិត្រដោយរតនៈផ្សេងៗ ប្រដាប់ដោយគ្រឿងអលង្ការជាច្រើន ដេរដាសទៅដោយផ្កាមានប្រភេទផ្សេងៗ ប្រគំដោយគ្រឿងតូរ្យតន្ត្រីច្រើនចម្រុះ ។ ព្រះរាជានិមន្តមហាថេរៈ ដែលជាគណៈបាមោក្ខប្រមាណមួយពាន់អង្គ ហើយឲ្យព្រះរាជាដែលបានអភិសេកក្នុងជម្ពូទ្វីបចំនួន ១០០០ អង្គ ហែហមទ្រង់ និងមហាពោធិ៍បានប្រថាប់ឈរត្រង់ពោធិមណ្ឌល ទតមើលមហាពោធិព្រឹក្ស ។ ចំណែកដែលសល់ វៀរតែដើមរបស់មហាពោធិ៍ និងចំណែកនៃមែកធំ ក្នុងទិសទក្សិណប្រមាណ ៤ ហត្ថ មិនប្រាកដឲ្យឃើញ ព្រះរាជាទ្រង់ឃើញបាដិហារិយ៍នោះ កើត

បីតិបាមោជ្ជ ត្រាស់ដល់ភិក្ខុសង្ឃថា បពិត្រលោកម្ចាស់ ខ្ញុំឃើញបាដិហារិយ៍នេះហើយ ត្រេកអរ និងបូជាដើមមហាពោធិព្រឹក្សដោយរាជសម្បត្តិក្នុងទ្វីប ទើបបានថ្វាយការអភិសេក ។

គ្រានោះ ព្រះរាជាទ្រង់បូជាដោយផ្កា និងគ្រឿងក្រអូបជាដើម ធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំក្នុងទីទាំង ៨ ស្តេចក្រោកឡើងហើយ ប្រជាប់ឈរផ្គងអញ្ជលី មានព្រះបំណងនឹងយាងយកដើមមហាពោធិព្រឹក្ស ដោយសច្ចាធិដ្ឋាន ទ្រង់ប្រាប់ឲ្យរៀបចំផើងមាសអំពីលើតាំង ដែលសម្រេចដោយរតនៈគ្រប់យ៉ាង ដែលតម្កល់ឲ្យខ្ពស់ឡើង តាំងអំពីផែនដី រហូតដល់មែកខាងស្តាំរបស់មហាពោធិព្រឹក្ស ហើយទ្រង់ឡើងលើតាំងដែលវិចិត្រដោយរតនៈ កាន់យកព្រះសុវណ្ណតុលិកា ( ជក់មាស ) ធ្វើជាស្នាមគំនូសដោយមនោសិលា ហើយទ្រង់បានធ្វើសច្ចវចនកិរិយាថា បើដើមមហាពោធិព្រឹក្ស គួរប្រតិស្ឋានក្នុងកោះលង្កា ហើយខ្ញុំគប្បីជាអ្នកអស់សេចក្តីសង្ស័យក្នុងព្រះពុទ្ធសាសនាសោត សូមឲ្យមែកមហាពោធិព្រឹក្សប្រតិស្ឋាននៅក្នុងផើងមាសដោយខ្លួនឯងចុះ ។ ព្រមគ្នានឹងសច្ចវាចា មែកពោធិព្រឹក្សដាច់ត្រង់កន្លែងដែលទ្រង់យកមនោសិលាគូសចំណាំ ហើយតាំងនៅក្នុងផើងមាស ដែលពេញដោយភក់ផ្សំដោយគ្រឿងក្រអូប ។ ដើមពោធិ៍នោះ មានកម្ពស់ ១០ ហត្ថ មានមែកធំមាន ៥ មែក នីមួយៗ មានប្រមាណ ៤ ហត្ថ ប្រដាប់ដោយផ្លែ ៥ ដូចៗ គ្នា ។ ចំណែកមែកតូចៗ មានចំនួន ១០០០ ។ គ្រានោះ ព្រះរាជាទ្រង់កំណត់ស្នាមគំនូសក្នុងបទេស ( គឺក្នុងទី ) មានប្រមាណ ៣ អង្គុលីខាងលើស្នាមគំនូសអំពីមុន ។

ខណៈនោះឯង ឫសធំប្រមាណ ១០ ដុះជាពន្លក ដូចតំណក់ទឹកចេញអំពីស្នាមគំនូសនោះ ។ ព្រះរាជាទ្រង់កំណត់ស្នាមគំនូស ៩ កន្លែងដទៃៗ ទៀត ក្នុងមួយកន្លែង ៣ អង្គុលីបន្តៗ មកទៀត ។ ឫសចំនួន ៩០ ដុះជាពន្លក ដូចទឹកចេញអំពីស្នាមគំនូសទាំងនោះ មួយគំនូសដប់ៗ ឫស ។ ឫសធំ ១០ ដំបូងដុះចេញមកប្រមាណ ៤ ធ្នាប់ ឫស ៩០ ក្រៅអំពីនេះ ក៏ដុះចាក់ស្រេះគ្នា ដូចរោមគោត្រង់ក្រយៅ ។ ព្រះរាជាប្រថាប់ឈរត្រង់ទីបំផុតនៃតាំង ដែលវិចិត្រដោយរតនៈនោះឯង ឃើញបាដិហារិយ៍ប្រមាណប៉ុណ្ណោះ ទ្រង់បានផ្គងអញ្ជលីនមស្ការហើយ ។ ភិក្ខុច្រើនពាន់អង្គក៏បានស្រែកបន្លឺសាធុការ ។ រាជសេនាទាំងអស់ ក៏បានបន្លឺសំឡេងកងរំពង ទង់ជ្វាលាដែលលើកឡើងទាំងសែន បានរលាស់បោកបក់រវិច ។ ទេវតាទាំងឡាយ តាំងអំពីភុម្មដ្ឋកទេវតាបានឲ្យសាធុការ ប្រព្រឹត្តទៅដរាបដល់ពួកព្រហ្មកាយិកា ។

ព្រះរាជា កាលទតឃើញបាដិហារិយ៍នេះ មានកាយដែលបីតិពាល់ត្រូវមិនមានចន្លោះ ប្រថាប់ឈរផ្គងអញ្ជលី ដើមមហាពោធិព្រឹក្សក៏បានប្រតិស្ឋាននៅក្នុងផើងមាស ដោយចំនួនឫសរាប់រយ ។ ឫសធំ ១០ បានចាក់ចុះរហូតដល់បាតផើង ។ ឫសដែលនៅសល់ ៩០ ក៏ចម្រើនដុះដាលឡើងដោយលំដាប់ ចាក់ចុះត្រាំនៅក្នុងភក់ដែលផ្សំដោយគ្រឿងក្រអូប ។ កាលដើមមហា-ពោធិព្រឹក្សគ្រាន់តែប្រតិស្ឋាននៅក្នុងផើងមាសយ៉ាងនេះហើយ មហាប្រឹថពីក៏ញាប់ញ័រ ។ សំឡេងស្គររបស់ទេវតា បានលាន់ឮឡើងក្នុងអាកាស ។ កោលាហលដូចគ្នានេះ តាំងអំពីផ្ទៃផែនដី រហូតដល់ព្រហ្មលោក មានសំឡេង

គឺកកងដូចគ្នា ព្រោះការឱនទៅមកនៃស្តេចភ្នំ ព្រោះសំឡេងសាធុការនៃទេវតា និងព្រោះសំឡេងគ្រហឹមនៃពួកយក្ខ ព្រោះការពោលសរសើរនៃពួកអសុរ ព្រោះការធ្វើអញ្ជលីនៃពួកព្រហ្ម ព្រោះការគ្រហឹមនៃមេឃ ព្រោះសម្រែកនៃពួកសត្វចតុប្បាទ ព្រោះការកញ្ជ្រៀវនៃពួកបក្សី ( និង ) ព្រោះការប៉ិនប្រសប់នៃតន្ត្រីករទាំងពួង ។ ឆព្វណ្ណរង្សីផ្សាយចេញអំពីផ្លែក្នុងមែកទាំង ៥ ហើយក៏ផ្សាយឡើងទៅដល់ព្រហ្មលោក ហាក់ធ្វើចក្រវាលទាំងមូលឲ្យជាប់គ្នា ដូចបន្ទន់ផ្ទះកែវដូច្នោះ ។

ចាប់ផ្តើមតាំងអំពីខណៈនោះទៅ មែកពោធិព្រឹក្សក៏ចូលទៅកាន់ស្រទាប់ពពកដែលពេញទៅដោយសន្សើម ហើយតាំងនៅអស់ ៧ ថ្ងៃ ។ បុគ្គលណាក៏មិនឃើញមែកពោធិព្រឹក្សនោះ ។ ព្រះរាជាយាងចុះអំពីតាំងដែលវិចិត្រដោយរតនៈហើយ ទ្រង់បញ្ជាឲ្យធ្វើការបូជាមហាពោធិអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃជាគម្រប់ ៧ ទឹកសន្សើម និងរស្មីទាំងឡាយ ក៏វិលត្រឡប់អំពីទិសទាំងពួង ចូលទៅកាន់មណ្ឌលពោធិព្រឹក្សនោះឯង ។ កាលលម្អចក្រវាលប្រាសចាកពពកត្រជាក់ភ្លឺច្បាស់ហើយ មហាពោធិព្រឹក្ស មានដើម មែកធំ និងមែកតូចបរិបូណ៌ដែលប្រដាប់ទៅដោយផ្លែទាំង ៥ បានប្រាកដក្នុងផើងមាសនោះឯង ។

ព្រះរាជា ទតឃើញមែកពោធិព្រឹក្សហើយ មានបីតិបាមោជ្ជ ព្រោះបាដិហារិយ៍ទាំងនោះញុំាងឲ្យកើតហើយ ទើបទ្រង់ត្រិះរិះថា អញនឹងបូជាពោធិ-ព្រឹក្សធំទង់ដោយរាជ្យសម្បត្តិក្នុងសកលជម្ពូទ្វីប ដូច្នេះហើយ ទ្រង់បានប្រទានការអភិសេក ( ដល់មហាពោធិព្រឹក្សនោះ ) ហើយបានប្រថាប់ឈរត្រង់

មណ្ឌលពោធិព្រឹក្សនោះឯងអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃបវារណាដើមខែកត្តិកនោះ វេលាល្ងាច មហាពោធិព្រឹក្សក៏ប្រតិស្ឋាននៅក្នុងផើងមាសមុន ។ បន្ទាប់អំពីនោះមក ព្រះរាជាទ្រង់សម្រាកព្រះកាយ រហូតដល់សប្តាហ៍ដែលមហាពោធិ៍នៅក្នុងស្រទាប់ពពក និងសប្តាហ៍ដែលទ្រង់ព្រះរាជទានអភិសេក ទើបទ្រង់យាងចូលទៅកាន់បាដលីបុត្រនគរ ក្នុងថ្ងៃឧបោសថនៃកាឡបក្ខ ដោយថ្ងៃមួយប៉ុណ្ណោះ ក្នុងថ្ងៃបាដិបទនៃជុណ្ហបក្ខខែកត្តិក ទ្រង់តាំងមហាពោធិព្រឹក្សទុកត្រង់គល់មហាសាលព្រឹក្សធំ ត្រង់ទិសខាងកើត ។

ក្នុងថ្ងៃទី ១៧ រាប់ពីថ្ងៃព្រះពោធិព្រឹក្សប្រតិស្ឋាននៅក្នុងផើងមាស ពន្លកថ្មីៗ នៃព្រះពោធិព្រឹក្សក៏បានប្រាកដឡើង ។ ព្រះរាជាទតឃើញពន្លកទាំងនោះហើយ ទ្រង់ក៏ជ្រះថ្លា កាលនឹងបូជាព្រះពោធិព្រឹក្សដោយរាជ្យសម្បត្តិទៀត ទ្រង់បានថ្វាយការអភិសេកក្នុងសកលជម្ពូទ្វីប ។ សុមនសាមណេរទៅដើម្បីទទួលព្រះធាតុក្នុងថ្ងៃពេញបូណ៌មីខែកត្តិក បានឃើញការបូជាដល់មហាពោធិ៍ ជាកត្តិកមហោស្រព ។

ព្រះបាទអសោកមហារាជ ទ្រង់សំដៅដល់ព្រះពោធិព្រឹក្សដែលនាំមកអំពីមហាពោធិមណ្ឌលហើយដែលទុកត្រង់បាដលីបុត្រនគរ ដោយន័យដូចបានពោលមកនេះ ទើបត្រាស់ ( ជាមួយព្រះនាងសង្ឃមិត្តាថេរី ) ថា នៃកូន បើដូច្នោះ សូមកូនទទួលយកព្រះពោធិព្រឹក្សទៅផងចុះ ព្រះនាងសង្ឃមិត្តាថេរីនោះទទួលថា សាធុ ។

ព្រះរាជាព្រះរាជទានត្រកូលទេវតា ១៨ ត្រកូលអមាត្យ ៨ ត្រកូល

ព្រាហ្មណ៍ ៨ ត្រកូលកុដុម្ពិកៈ ៨ ត្រកូលអ្នកចិញ្ចឹមគោ ៨ ត្រកូលខ្វាជំបង ៨ និងត្រកូលអ្នកកាលិង្គៈ ៨ ទុកដើម្បីរក្សាមហាពោធិ៍ និងព្រះរាជទានក្អមមាស ៨ ក្អមប្រាក់ ៨ ទុកដើម្បីស្រោចទឹក ហើយទ្រង់ឲ្យលើកព្រះពោធិព្រឹក្សឡើងកាន់សំពៅ ព្រមដោយបរិវារត្រង់ទន្លេគង្គា ចំណែកព្រះអង្គឯង ទ្រង់យាងចេញអំពីព្រះនគរ ឆ្លងព្រៃឈ្មោះវិជ្ឈាដវី ហើយយាងទៅដល់កំពង់ឈ្មោះតាម្ពលិត្តិ អស់ ៧ ថ្ងៃ ដោយលំដាប់ ។ ក្នុងរវាងផ្លូវ ពួកទេវតា នាគ និងមនុស្សបាននាំគ្នា បូជាព្រះពោធិព្រឹក្សយ៉ាងមហោឡារិក ។ ចំណែកព្រះរាជា ទ្រង់បញ្ឈប់ពោធិព្រឹក្សទុកត្រង់ច្រាំងសមុទ្រ ៧ ថ្ងៃ ហើយទ្រង់ថ្វាយរាជ្យសម្បត្តិដ៏ធំក្នុងសកលទ្វីប ។ គ្រានេះ ជាការដែលទ្រង់ថ្វាយរាជ្យសម្បត្តិក្នុងជម្ពូទ្វីបលើកទី ៣ ដល់ព្រះពោធិព្រឹក្សនោះ ។

ព្រះបាទធម្មាសោក កាលទ្រង់បូជាដោយរាជ្យសម្បត្តិដ៏ធំយ៉ាងនោះហើយ ក្នុងថ្ងៃបាដិបទខាងដើមនៃខែមិគសិរ ទើបទ្រង់លើកព្រះពោធិព្រឹក្សឡើង ទ្រង់ចុះទឹកទៅប្រមាណត្រឹមក ទ្រង់ដាក់លើសំពៅ ហើយទ្រង់ប្រាប់ឲ្យព្រះនាងសង្ឃមិត្តាថេរី ព្រមទាំងបរិវារឡើងសំពៅ ទើបត្រាស់ពាក្យនេះនឹងអរិដ្ឋអមាត្យថា នែបា ខ្ញុំបូជាមហាពោធិព្រឹក្សដោយរាជ្យសម្បត្តិក្នុងសកលជម្ពូទ្វីប អស់វារៈ ៣ ដង ហើយចុះទឹកប្រមាណត្រឹម ក បញ្ជូន ( ព្រះពោធិព្រឹក្ស ) ទៅឲ្យសម្លាញ់របស់ខ្ញុំ សូម្បីសម្លាញ់របស់ខ្ញុំនោះ ក៏ចូរបូជាមហាពោធិព្រឹក្ស យ៉ាងនេះឯង ។

ព្រះរាជា កាលព្រះរាជទានរាជសាសន៍ដល់សម្លាញ់យ៉ាងនោះហើយ ទ្រង់កន្ទក់កន្ទេញ ផ្គងអញ្ជលី ប្រថាប់ឈរបង្ហូរព្រះជលនេត្រថា ដើមមហាពោធិ៍

របស់ព្រះទសពល ដែលបញ្ចេញពន្លឺរស្មី ដូចមានជីវិត ទៅហើយហ្ន៎ ដូច្នេះ នាវាដែលព្រះពោធិព្រឹក្សប្រតិស្ឋាននោះឯង កាលមហាជនកំពុងសម្លឹងមើល ក៏ចេញទៅកាន់មហាសមុទ្រ ។ រលកទាំងឡាយក្នុងមហាសមុទ្រ ស្ងប់ប្រមាណមួយយោជន៍ជុំវិញ ។ បទុមជាតិទាំងឡាយ ៥ ពណ៌ ក៏រីកស្គុសស្គាយ ទិព្វតូរ្យតន្ត្រីទាំងឡាយ ក៏លាន់រងំលើអាកាស ។ មានការបូជាដ៏ឱឡារិក ដែលពួកទេវតាអាស្រ័យនៅលើអាកាស លើទឹក លើគោក និងត្រង់ដើមឈើជាដើម បណ្ដាលឲ្យប្រព្រឹត្តទៅហើយ ។ ព្រះនាងសង្ឃមិត្តាថេរី ធ្វើឲ្យត្រកូលនាគទាំងឡាយក្នុងមហាសមុទ្រឲ្យភ័យខ្លាចហើយ ដោយ( កាឡាខ្លួន ) ជាគ្រុឌ ។ ឯនាគទាំងនោះភ័យខ្លាច មកឃើញសម្បត្តិនោះហើយ ទើបទូលសូមព្រះថេរី ហើយនាំព្រះពោធិព្រឹក្សទៅកាន់នាគពិភព បូជាដោយរាជសម្បត្តិនៃនាគអស់ ៧ ថ្ងៃ ( ទើបនាំត្រឡប់មក ) ឲ្យប្រតិស្ឋាននៅលើសំពៅវិញ ។ នាវាបានរសាត់ទៅដល់កំពង់ឈ្មោះជម្ពូកោលបដ្ដនៈ ក្នុងថ្ងៃនោះឯង ។ ចំណែកព្រះបាទធម្មាសោក ទ្រង់សោយទុក្ខ ព្រោះវិយោគចាកព្រះពោធិព្រឹក្ស ទ្រង់សោកសង្រេង សម្លឹងមើលរហូតដាច់កន្ទុយភ្នែក ហើយក៏យាងត្រឡប់ ។

ចំណែកព្រះបាទទេវានម្បិយតិស្សមហារាជ តាំងអំពីថ្ងៃបាដិបទនៃខែមិគសិរ ទ្រង់បញ្ជាឲ្យជម្រះតាក់តែងផ្លូវតាំងអំពីទ្វារទិសខាងជើង (នៃអនុរាធបុរី) រហូតដល់កំពង់ជម្ពូកោលបដ្ដនៈ តាមពាក្យរបស់សុមនសាមណេរ ក្នុងថ្ងៃដែលទ្រង់ចេញអំពីព្រះនគរ បានប្រថាប់ឈរត្រង់សាលា ដែលមាននៅត្រង់ឆ្នេរសមុទ្រ ជិតទ្វារទិសខាងជើងនោះឯង បានទតឃើញព្រះពោធិព្រឹក្ស ដែលកំពុងមកក្នុង

មហាសមុទ្រនោះឯង ដោយសម្បត្តិនោះ ព្រោះអានុភាពរបស់ព្រះថេរៈ ទ្រង់មានបីតិក្នុងព្រះហឫទ័យយាងចេញទៅ ត្រាស់ឲ្យយកផ្កាដែលមានពណ៌ ៥ រោយតាមផ្លូវទាំងអស់ ទ្រង់តាំងគ្រឿងបូជាដោយផ្កាដ៏មានតម្លៃទុកក្នុងរវាងផ្លូវជាចន្លោះៗ ហើយទ្រង់យាងទៅកាន់កំពង់ជម្ពុកោលបដ្ដនៈ ដោយថ្ងៃមួយប៉ុណ្ណោះ ដែលពួកតន្ត្រីករទាំងពួងហែហមហើយ ទ្រង់បូជា (ព្រះពោធិព្រឹក្ស) ដោយគ្រឿងសក្ការៈទាំងឡាយ មានផ្កា ធូប និងគ្រឿងក្រអូបជាដើម ទ្រង់យាងចុះទឹកទៅប្រមាណត្រឹម-ក ហើយទ្រង់ត្រាស់ថា ព្រះពោធិព្រឹក្សរបស់ព្រះទសពល ដែលបញ្ចេញព្រះរស្មី ដូចមានជីវិតមកហើយហ្ន៎ មានព្រះទ័យជ្រះថ្លាហើយ ទើបទ្រង់លើកព្រះពោធិព្រឹក្សឡើង ដាក់លើសិរសាដែលជាអវយវៈប្រសើរបំផុត ព្រមដោយពួកត្រកូលដែលសម្បូរដោយជាតិ ១៦ ត្រកូល ហែហមព្រះពោធិព្រឹក្ស ទ្រង់ឡើងអំពីមហាសមុទ្រ ហើយទ្រង់បញ្ឈប់ដើមពោធិ៍ត្រង់ឆ្នេរនៃមហាសមុទ្រ ទ្រង់បូជាដោយរាជសម្បត្តិក្នុងកោះតម្ពបណ្ណិទីបទាំងអស់ អស់ ៣ ថ្ងៃ ។ ព្រះរាជាទ្រង់ឲ្យត្រកូលដែលសម្បូរដោយជាតិ ១៦ ត្រកូល សម្រេចរាជការជំនួស ក្រោយមក ក្នុងថ្ងៃទី ៤ ព្រះរាជាទ្រង់ទទួលយកព្រះពោធិព្រឹក្សហើយ ទ្រង់ធ្វើការបូជាយ៉ាងឱឡារិក ទ្រង់យាងដល់ក្រុងអនុរាធបុរីដោយលំដាប់ ។

ព្រះរាជា កាលទ្រង់ធ្វើមហាសក្ការៈក្នុងអនុរាធបុរី ក្នុងថ្ងៃចាតុទ្ទសីនោះឯង ទ្រង់ត្រាស់ឲ្យបញ្ជូនព្រះពោធិព្រឹក្សចូលទៅតាមផ្លូវទិសខាងជើង ក្នុងពេលរសៀលជន្ទៃទៅត្រង់កណ្ដាលនគរ ចេញតាមទ្វារទិសទក្សិណ ហើយទ្រង់ឲ្យតម្កល់ព្រះពោធិព្រឹក្សទុកលើបល្ល័ង្កត្រង់ទ្វារនៃព្រះរាជឧទ្យាន ដែលធ្វើបរិកម្មផ្ទៃ

ដីទុកតាំងពីដំបូងនោះឯង តាមពាក្យរបស់សុមនសាមណេរ ដែលជាផ្ចិតកណ្ដាលនៃព្រះរាជឧទ្យានមហាមេឃវ័ន ជាកន្លែងដែលព្រះសម្មាសម្ពុទ្ធនៃយើងទាំងឡាយប្រថាប់គង់ចូលនិរោធសមាបត្តិ និងព្រះសម្មាសម្ពុទ្ធ ៣ អង្គមុនៗ ធ្លាប់ប្រថាប់គង់ចូលសមាបត្តិផងដែរ ទាំងជាកន្លែងដែលមានដើមប្រេសធំ ដែលជាឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគកកុសន្ធៈ ដើមល្វាដែលជាឈើត្រាស់ដឹងរបស់ព្រះដ៏-មានព្រះភាគកោនាគមនៈ និងដើមនិគ្រោធ (ដើមជ្រៃ) ដែលជាឈើត្រាស់ដឹងរបស់ព្រះកស្សបសម្មាសម្ពុទ្ធ ប្រតិស្ឋាននៅក្នុងទីប្រមាណ ៥០០ ជួរធ្នូ អំពីទ្វារទិសទក្សិណផងដែរ ។

សួរថា ព្រះរាជាទ្រង់ឲ្យរៀបចំមហាពោធិ៍នោះដូចម្ដេច ឆ្លើយថា ទ្រង់រៀបចំព្រះពោធិព្រឹក្សយ៉ាងនេះ គឺ បានឮថា ត្រកូលដែលសម្បូរដោយជាតិទាំង ១៦ ត្រកូល ដែលហែហមព្រះពោធិព្រឹក្សនោះ កាន់យកភេទជាព្រះរាជា ។ ព្រះរាជាក៏ទ្រង់កាន់យកភេទជានាយទ្វារបាល ។ ត្រកូលទាំង ១៦ យកព្រះពោធិព្រឹក្សដាក់ដាំហើយ ។

ក្នុងខណៈដែលផុតអំពីដៃរបស់ត្រកូលទាំង ១៦ នោះឯង មហាពោធិ-ព្រឹក្សក៏អណ្ដែតឡើងទៅកាន់អាកាសកម្ពស់ប្រមាណ ៨០ ហត្ថ ហើយបញ្ចេញរស្មីមានពណ៌ ៦ ប្រការ ។ រស្មីទាំងឡាយក៏ផ្សាយទៅគ្របដណ្ដប់កោះទាំងមូល និងដល់ព្រហ្មលោក ។ បុរសប្រមាណ ១០០០០ ឃើញបាដិហារិយ៍នោះហើយកើតសេចក្ដីជ្រះថ្លា ផ្ដើមចម្រើនអនុបុព្វវិបស្សនា បានសម្រេចជាព្រះអរហន្តហើយបួស ។ ព្រះពោធិព្រឹក្សបានប្រតិស្ឋាននៅលើអាកាសរហូតដល់ព្រះអាទិត្យ

អស្តង្គត ។ កាលព្រះអាទិត្យអស្តង្គតហើយ ទើបត្រឡប់មកប្រតិស្ឋានលើផែនដីវិញ ដោយរោហិណីនក្ខត្តប្ញក្ស ។ ដំណាលគ្នានឹងមហាពោធិព្រឹក្សប្រតិស្ឋានហើយនោះឯង មហាប្រឹថពីបានកម្រើករហូតដល់ទឹកទ្រផែនដី ។ ឯព្រះពោធិព្រឹក្សកាលប្រតិស្ឋានហើយ ក៏ឈប់ស្ងៀម មិនកម្រើកក្នុងស្រទាប់ពពក ( ពពកធ្លាក់ចុះមក ) អស់ ៧ ថ្ងៃ ជាហេតុធ្វើឲ្យមហាជនមើលមិនឃើញព្រះពោធិព្រឹក្សនោះ ។ ក្នុងថ្ងៃទី ៧ នភាកាសបានប្រាសចាកពពកហើយ រស្មីដែលមានពណ៌ ៦ ក៏ផ្សាយជះពន្លឺចេញ ។ ដើម មែក ស្លឹក និងផ្លែទាំង ៥ នៃព្រះពោធិ-ព្រឹក្សក៏ប្រាកដឲ្យឃើញ ។ ព្រះមហិន្ទត្ថេរ ព្រះនាងសង្ឃមិត្តាថេរី និងព្រះរាជាព្រមដោយរាជបរិវារ ទ្រង់បានទៅដល់មណ្ឌលព្រះពោធិព្រឹក្សនោះឯង ។ មហាជនអ្នកកោះទាំងអស់ ក៏ប្រជុំគ្នាហើយដោយច្រើន ។ កាលជនទាំងនោះកំពុងមើលនោះឯង ផ្លែមួយទុំហើយ បានជ្រុះចាកមែកទិសឧត្តរ ។ ព្រះថេរៈយកដៃទទួលទុក ផ្លែក៏បានតាំងនៅលើព្រះហស្តរបស់ព្រះថេរៈៗ បានថ្វាយផ្លែនោះដល់ព្រះរាជាដោយថ្វាយព្រះពរថា សូមព្រះអង្គទ្រង់ដាំចុះមហាបពិត្រ ។

ព្រះរាជាទ្រង់ទទួលហើយ ទ្រង់ក៏រោយដីដែលមានរសល្អចុះត្រង់ផើងមាសដាក់កក់ដែលផ្សំដោយគ្រឿងក្រអូបឲ្យពេញ ហើយបណ្ដុះក្នុងទីជិតព្រះពោធិព្រឹក្ស ។ កាលជនទាំងឡាយកំពុងមើលនោះឯង ដើមពោធិ៍តូចៗ ៨ ដើម មានប្រមាណ ៤ ហត្ថ បានដុះឡើងហើយ ។ ព្រះរាជាទតឃើញភាពអស្ចារ្យនោះ ទ្រង់ក៏បូជាព្រះពោធិព្រឹក្សតូចៗ ៨ ដើមដោយស្វេតច្ឆត្រ ហើយថ្វាយការអភិសេក ។ មហាជនដាំដើមពោធិ៍នោះមួយដើមទុកត្រង់កំពង់ ឈ្មោះជម្ពុកោលបដ្ដនៈ ក្នុង

ឱកាសដែលព្រះពោធិព្រឹក្សដាក់ចុះគ្រាដំបូង ក្នុងពេលដែលមកដល់ មួយដើមទៀតដាំទុកត្រង់មាត់ទ្វារស្រុកបស់គវក្កព្រាហ្មណ៍ មួយដើមទៀតត្រង់ថូបារាម មួយដើមទៀតត្រង់ឥស្សរនិម្មានវិហារ មួយដើមទៀតក្បែរបឋមចេតិយ មួយដើមទៀត ត្រង់ចេតិយបព៌ត មួយដើមទៀត ត្រង់ស្រុកកាជរ-គ្រាមក្នុងរោហណជនបទ និងមួយដើមទៀតត្រង់ស្រុកចន្ទនគ្រាម ក្នុងរោហណជនបទនោះឯង ។ មហាជនទាំងឡាយ បានដាំកូនព្រះពោធិព្រឹក្ស ៣២ ដើម ដែលកើតអំពីផ្លែទាំង ៤ ក្រៅអំពីនេះ ក្នុងអារាមដែលតាំងនៅក្នុងចម្ងាយមួយយោជន៍ ។

កាលព្រះពោធិព្រឹក្ស ដែលជាទង់ជ័យនៃព្រះសទ្ធម្មរបស់ព្រះទសពលប្រតិស្ឋានហើយ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់អ្នកកោះ ដោយជុំវិញ ដោយការបន្តលំដាប់នៃកូនចៅយ៉ាងនេះហើយ ព្រះនាងអនុឡាទេវី មួយអន្លើដោយមាតុគ្រាម ១០០០ គឺស្រីដែលជាបរិវារ ៥០០ នាក់ និងស្រីក្នុងវាំង ៥០០ នាក់ទៀត បួសក្នុងសម្នាក់របស់ព្រះនាងសង្ឃមិត្តាថេរី មិនយូរប៉ុន្មានព្រះនាង និងបរិវារ ក៏តាំងនៅក្នុងភាពជាព្រះអរហន្តី ។ ចំណែកព្រះរាជ-ភាគិនេយ្យ ឈ្មោះអរិដ្ឋ និងបុរសប្រមាណ ៥០០ បួសក្នុងសម្នាក់របស់ព្រះថេរៈ បានតាំងនៅក្នុងភាពជាព្រះអរហន្ត ក្នុងកាលមិនយូរដូចគ្នា ។

## សាសនាតាំងមាំព្រោះកុលបុត្រអ្នកកោះលង្កា

បន្ទាប់មក ថ្ងៃមួយ ព្រះរាជាថ្វាយបង្គំព្រះពោធិព្រឹក្ស ហើយយាងទៅកាន់ថូបារាមជាមួយព្រះថេរៈ ។ កាលព្រះរាជាយាងទៅដល់ទីដែលទីងសាង

លោហប្រាសាទ ពួករាជបុរសក៏នាំផ្កាទាំងឡាយមកថ្វាយ ។ ព្រះរាជាបាន ប្រគេនផ្កាទាំងឡាយដល់ព្រះថេរៈៗ ក៏យកផ្កាបូជាត្រង់ទីដែលនឹងសាងលោហ- ប្រាសាទ ។ កាលផ្កាទាំងឡាយគ្រាន់តែធ្លាក់ចុះត្រង់ផែនដី ផែនដីបានញ័រ ហើយ ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើបផែនដី កម្រើក ព្រះថេរៈទូលថា បពិត្រមហារាជ ក្នុងអនាគត ឧបោសថាគារនឹងមាន ដល់សង្ឃក្នុងឱកាសនេះ នេះជាបុព្វនិម្មិតនៃឧបោសថាគារនោះ ។

ព្រះរាជា ទ្រង់ក៏យាងទៅជាមួយព្រះថេរៈ ទ្រង់បានទៅដល់អម្ពង្គណស្ថាន ហើយ ឯអម្ពង្គណស្ថាននោះ រាជបុរសបាននាំផ្លែស្វាយទុំមួយ ដែលសម្បូរ ដោយពណ៌ និងក្លិន មានរសឆ្ងាញ់ក្រៃលែង ថ្វាយដល់ព្រះរាជាអង្គនោះ ។ ព្រះរាជាបានប្រគេនផ្លែស្វាយនោះដល់ព្រះថេរៈដើម្បីឆាន់ ។ ព្រះថេរៈក៏ឆាន់ក្នុង ទីនោះឯង ហើយទូលព្រះរាជាថា សូមព្រះអង្គទ្រង់ដាំគ្រាប់ស្វាយនេះទុកក្នុងទី នេះចុះ ។

ព្រះរាជា ទ្រង់ទទួលគ្រាប់ស្វាយនោះហើយ ទ្រង់ដាំទុកក្នុងទីនោះឯង ហើយ ទ្រង់ស្រោចទឹក ។ ព្រមគ្នានឹងការដាំគ្រាប់ស្វាយ ប្រឹថពីក៏កម្រើកហើយ ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ប្រឹថពីកម្រើកព្រោះហេតុអ្វី ព្រះថេរៈ ទូលថា បពិត្រមហារាជ ក្នុងអនាគត ទីប្រជុំសង្ឃឈ្មោះអម្ពង្គណៈនឹងមានក្នុង ទីនេះ នេះជាបុព្វនិមិត្តនៃសន្និបាតស្ថាននោះ ព្រះរាជាទ្រង់បាចសាចផ្កា ៨ ក្ដាប់ ចុះក្នុងទីនោះ ទ្រង់ថ្វាយបង្គំហើយ ក៏យាងទៅជាមួយព្រះថេរៈទៀត ទ្រង់បាន ទៅដល់កន្លែងសាងព្រះមហាចេតិយ ។ ក្នុងទីកន្លែងនោះ ពួករាជបុរសបាននាំផ្កា

ចម្ប៉ាទាំងឡាយមកថ្វាយដល់ព្រះរាជាអង្គនោះ ។ ព្រះរាជាបានប្រគេនផ្កាចម្ប៉ានោះដល់ព្រះថេរៈៗ ក៏យកផ្កាបូជាត្រង់កន្លែងសាងមហាចេតិយ ហើយថ្វាយបង្គំ ។ ក្នុងខណៈនោះឯង មហាប្រឹថពីក៏កម្រើក ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ប្រឹថពីកម្រើកព្រោះហេតុអ្វី ព្រះថេរៈទូលថា បពិត្រមហារាជ ក្នុងអនាគត មហាស្តូបដែលមិនមានទីណាដូចរបស់ព្រះដ៏មានព្រះភាគ នឹងមានក្នុងឱកាសនេះ នេះជាបុព្វនិមិត្តនៃមហាស្តូបនោះ ។ ព្រះរាជា ទ្រង់ទូលថា ខ្ញុំនេះឯងនឹងសាងលោកម្ចាស់ ព្រះថេរៈទូលថា កុំឡើយ មហាបពិត្រ ព្រះអង្គទ្រង់មានការងាររដទៃច្រើន តែព្រះរាជនត្តា ( ចៅ ) របស់ព្រះអង្គឈ្មោះ ទុដ្ឋគាមណីអភ័យ ទ្រង់នឹងកសាង ។ គ្រានោះ ព្រះរាជាទ្រង់ត្រាស់ថា បពិត្រលោកម្ចាស់ បើព្រះរាជនត្តារបស់ខ្ញុំនឹងសាងសោត ក៏នឹងសាងរបស់ដែលខ្ញុំសាងទុកហើយនោះឯង ដូច្នេះហើយ ទើបបញ្ជាឲ្យនាំយកសសរថ្ម មានប្រមាណ ១២ ហត្ថមក ហើយឲ្យចារឹកអក្សរថា ព្រះរាជនត្តាព្រះបាទទេវានម្បិយតិស្សៈ ព្រះនាមថា ទុដ្ឋគាមណីអភ័យ ចូរសាងព្រះស្តូបទុកក្នុងទីនេះចុះ ដូច្នេះ ទ្រង់បញ្ជាឲ្យប្រតិស្ឋានទុកហើយ ទើបត្រាស់សួរព្រះថេរៈថា បពិត្រលោកម្ចាស់ សាសនាតាំងមាំក្នុងកោះលង្កាហើយឬ ។ ព្រះថេរៈទូលថា សូមថ្វាយព្រះពរ មហាបពិត្រ សាសនាតាំងមាំហើយ តែឫសគល់នៃសាសនានោះមិនទាន់តាំងចុះស៊ប់ឡើយ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ អង្កាល់ណា ឫសគល់ ( នៃសាសនានោះ ) នឹងឈ្មោះថា តាំងមាំហើយ ។ ព្រះថេរៈទូលថា បពិត្រមហារាជ ក្នុងកាលណាកុលបុត្រដែលកើតក្នុងតម្ពបណ្ណិទ្វីប មានមាតាបិតាជាអ្នក

កោះតម្ពបណ្ណិទ្វីប នឹងចេញបួសក្នុងកោះតម្ពបណ្ណិទ្វីប ហើយរៀនព្រះវិន័យក្នុង កោះតម្ពបណ្ណិទ្វីបនោះឯង ចេញប្រៀនប្រដៅ (ព្រះវិន័យ) ក្នុងកោះតម្ពបណ្ណិ- ទ្វីបបាន ក្នុងកាលនោះ ឫសគល់នៃសាសនា ឈ្មោះថាតាំងមាំហើយ ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ភិក្ខុដូច្នេះមានឬ ព្រះថេរៈទូលថា មាន មហាបពិត្រ មហាអរិដ្ឋភិក្ខុ ជាអ្នកមានសមត្ថភាពក្នុងកម្មនោះ ព្រះរាជា ត្រាស់សួរថា បពិត្រលោកម្ចាស់ ខ្ញុំគួរធ្វើអ្វីខ្លះក្នុងកម្មនេះ ។ ព្រះថេរៈទូលថា គួរសាងមណ្ឌប មហាបពិត្រ ។

ព្រះរាជាទ្រង់ទទួលថា សាធុ លោកម្ចាស់ ហើយបញ្ជាឲ្យសាងមណ្ឌប ដោយរាជានុភាព ដូចគ្នានឹងមណ្ឌប ដែលព្រះបាទអជាតសត្តុមហារាជ ទ្រង់ សាងក្នុងកាលធ្វើមហាសង្គីតិ ទុកក្នុងទីកដីរបស់អមាត្យឈ្មោះមេឃវណ្ណាភយៈ ( របស់ព្រះបាទមេឃវណ្ណាភយៈ ) ហើយទ្រង់បញ្ជាឲ្យពួកតូរ្យតន្ត្រីទាំងឡាយ ហ្វឹកហាត់សិល្បៈរៀងៗ ខ្លួនទុក ហើយទ្រង់ប្រាប់ថា ខ្ញុំនឹងមើលឫសគល់នៃ ព្រះសាសនាដែលនឹងតាំងមាំល្អហើយ ដូច្នេះ ព្រះរាជាទ្រង់មានបុរស ១០០០ ហែហមហើយ បានយាងទៅដល់ថូបារាម ។

# ចតុត្ថសង្គាយនា

សម័យនោះឯង ភិក្ខុ ៦៨០០០ អង្គ ប្រជុំគ្នាត្រង់ថូបារាម ។ អាសនៈរបស់ព្រះមហិន្ទត្ថេរ រៀបចំបែរមុខទៅទិសទក្សិណ ។ ធម្មាសនៈរបស់ព្រះអរិដ្ឋត្ថេរ បែរមុខទៅទិសខាងជើង ។ គ្រានោះឯង ព្រះអរិដ្ឋត្ថេរ ដែលព្រះមហិន្ទត្ថេរអារាធនាហើយ ក៏អង្គុយលើធម្មាសនៈដោយលំដាប់ដល់ខ្លួន តាមសមគួរ ។ ព្រះថេរៈ ៦៨ អង្គ ដែលមានព្រះមហិន្ទត្ថេរជាប្រធាន ក៏អង្គុយជុំវិញធម្មាសនៈ ។ ព្រះកនិដ្ឋភាតារបស់ព្រះរាជា ឈ្មោះមត្តាភយត្ថេរ ដែលជាអ្នកទទួលយកការៈការងារ ( គឺតាំងចិត្តសិក្សារៀនសូត្រ ) រួមជាមួយភិក្ខុ ៥០០ អង្គ អង្គុយជុំវិញធម្មាសនៈរបស់ព្រះអរិដ្ឋត្ថេរនោះឯង ដោយតាំងចិត្តថានឹងរៀនយកនូវព្រះវិន័យ ។ ពួកភិក្ខុដ៏សេស និងបរិស័ទ មួយអន្លើដោយព្រះរាជាក៏បានអង្គុយលើអាសនៈដ៏សមគួររៀងៗ ខ្លួន ។

គ្រានោះ អរិដ្ឋត្ថេរបានសម្តែងនិទាននៃព្រះវិន័យថា សម័យនោះ ព្រះដ៏មានព្រះភាគ ប្រថាប់ត្រង់ដើមស្តៅ ដែលនឡេរុយក្ខស្ថិតនៅ ក្នុងក្រុងវេរញ្ជា ដូច្នេះជាដើម ។ កាលព្រះអរិដ្ឋត្ថេរសម្តែងនិទាននៃព្រះវិន័យហើយ អាកាសក៏គ្រហឹមខ្ទរខ្ទារ ។ ផ្លេកបន្ទោរពុំដូកាល ក៏ជាលប្រវាត់ឡើង ។ ពួកទេវតាបានថ្វាយសាធុការហើយ ។ មហាប្រឹថពីកម្រើករហូតដល់ទីបំផុតទឹកដែលទ្រផែនដី ។ កាលបាដិហារិយ៍ជាច្រើនប្រព្រឹត្តទៅយ៉ាងនោះ ព្រះអរិដ្ឋត្ថេរដែលមានព្រះថេរៈជាទីណាស្រេពជាមេគណៈ ក្នុងមួយគណៈ ៦៨ អង្គ ដែលមានព្រះមហិន្ទជាប្រធាន និងភិក្ខុ ៦០០០០ អង្គ ក្រៅអំពីនោះចោមរោមហើយ បានប្រកាសព្រះវិនយបិដក ដែលសម្តែងនូវគុណ មានព្រះករុណាគុណរបស់ព្រះសាស្តា

ជាដើម ដែលកម្ចាត់បង់នូវសេចក្ដីក្ដៅក្រហាយតាមកាយកម្ម វចីកម្ម របស់ពួកជន ដែលធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ ក្នុងកណ្ដាលនៃថូបារាមមហាវិហារ ក្នុងថ្ងៃបឋមបវារណាខែកត្តិក ។ ឯព្រះអរិដ្ឋត្ថេរ កាលប្រកាសហើយ ប្រៀនប្រដៅដល់ភិក្ខុជាច្រើន គឺឲ្យតាំងនៅក្នុងហទយៈរបស់ភិក្ខុជាច្រើន តាំងនៅដរាបដល់អស់អាយុ ហើយបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។

ព្រះថេរៈទាំង ៦៨ អង្គនោះ មានព្រះមហិន្ទត្ថេរជាប្រធាន ជាអ្នកកាន់យកនូវធុរៈក្នុងការងារ មកប្រជុំព្រមគ្នាហើយ ក្នុងសមាគមនោះ មេគណៈទីមួយៗ ជាសាវករបស់ព្រះធម្មរាជា មានអាសវៈអស់ហើយ ដល់នូវវសីភាវៈ មានវិជ្ជា ៣ ឈ្លាសក្នុងឥទ្ធិវិធ ដឹងច្បាស់នូវអត្ថដ៏ឧត្ដម បានប្រៀនប្រដៅព្រះរាជា ព្រះថេរៈអ្នកស្វែងរកនូវគុណដ៏ធំ សម្ដែងពន្លឺ ( គឺការភ្លឺស្វាងនៃញាណ ) ឲ្យឃើញច្បាស់ ញ៉ាំងផែនដី ( គឺកោះលង្កា ) ឲ្យរុងរឿងហើយ ក៏បរិនិព្វានដូចគំនរភ្លើងធំដែលឆេះសន្ធោសន្ធៅ ហើយរលត់ទៅដូច្នោះ ។

ចំណេរកាលតមក បន្ទាប់អំពីកាលបរិនិព្វាននៃមហាថេរៈទាំងនោះ លំដាប់បន្តគ្នាមកនៃអាចារ្យ ដែលមានប្រការដូចពោលហើយខាងដើមយ៉ាងនេះ គឺព្រះមហាថេរៈដទៃដែលជាអន្តេវាសិករបស់ព្រះថេរៈទាំងនោះ និងព្រះថេរៈទាំងឡាយមានព្រះតិស្សទត្តៈ ព្រះកាឡសុមនៈ និងព្រះទីឃសុមនៈជាដើម ដែលជាអន្តេ-វាសិកនៃអន្តេវាសិកទាំងឡាយ របស់ព្រះមហាអរិដ្ឋត្ថេរបាននាំព្រះវិនយបិដក

នេះមក រហូតដល់សព្វថ្ងៃនេះ ។

ព្រោះហេតុនោះ ទើបខ្ញុំពោលទុកថា បន្ទាប់អំពីតតិយសង្គាយនា ព្រះថេរៈទាំងឡាយ មានព្រះមហិន្ទជាដើម បាននាំព្រះវិនយបិដកមកកាន់កោះនេះ ព្រះថេរៈទាំងឡាយ មានព្រះអរិដ្ឋត្ថេរជាដើមរៀនអំពី (សម្នាក់) ព្រះមហិន្ទត្ថេរ ហើយបាននាំមកអស់វេលាមួយរយៈ តាំងអំពីពេលព្រះអរិដ្ឋត្ថេរជាដើមនោះ នាំមកព្រះវិនយបិដកនោះ គប្បីជ្រាបថា បាននាំបន្តមកដោយលំដាប់អាចារ្យ ដែលជាការបន្តលំដាប់អន្តេវាសិករបស់ព្រះអរិដ្ឋត្ថេរជាដើមនោះឯង រហូតដល់សព្វថ្ងៃនេះ ។

## ព្រះវិនយបិដកតាំងនៅហើយក្នុងបុគ្គលណា

បទមាតិកាថា ព្រះវិនយបិដកតាំងនៅហើយក្នុងបុគ្គលណា ខ្ញុំនឹងឆ្លើយដូចតទៅថា ព្រះវិនយបិដករបស់បុគ្គលពួកណា រមែងប្រព្រឹត្តទៅមិនមានខ្វះចន្លោះ ទាំងដោយបាលី និងដោយអដ្ឋកថា គឺមិនឃ្លៀងឃ្លាតសូម្បីបន្តិចបន្តួច ដូចប្រេងល្ង ដែលដាក់ក្នុងភាជន៍កែវមណី រមែងមិនជ្រាបចេញ ដូច្នោះ គប្បីជ្រាបថា ព្រះវិនយបិដកតាំងនៅហើយក្នុងបុគ្គលបែបនោះ ដែលជាអ្នកមានសតិ គតិ និងធិតិ មានប្រមាណក្រៃលែង ជាលជ្ជីបុគ្គល ច្រើនដោយសេចក្តីរង្កៀស ប្រាថ្នាក្នុងការសិក្សា ។

## អានិសង្សនៃការរៀនព្រះវិន័យ ៥ យ៉ាង

ព្រោះដូច្នោះ ដើម្បីឲ្យព្រះវិន័យតាំងមាំ កិក្ខុដែលកំណត់ដឹងនូវអានិសង្ស នៃវិនយបរិយត្តិ ប្រាថ្នាចំពោះការសិក្សា ក៏គួររៀនព្រះវិន័យចុះ ។ ក្នុងអធិការ

ពោលដោយការពណ៌នានិទាននោះ មានអានិសង្សនៃវិនយបរិយត្តិដូចតទៅនេះ

ពិតហើយ បុគ្គលអ្នកឈ្លាសក្នុងវិនយបរិយត្តិ តែងជាទីតាំងនៅក្នុងឋានៈជាមាតាបិតារបស់ពួកកុលបុត្រ ដែលជាអ្នកបានទូវសទ្ធាក្នុងព្រះសាសនា ព្រោះថា បព្វជ្ជាឧបសម្បទា គោលបដិបត្តិវត្តធំៗ កាពជាអ្នកឈ្លាសក្នុងអាចារៈ និងគោចររបស់កុលបុត្រទាំងនោះ ទាក់ទងដោយការឈ្លាសក្នុងវិនយបរិយត្តិនោះ ។

ប្រការ ១ ទៀត ព្រោះអាស្រ័យវិនយបរិយត្តិ គំនរសីលរបស់ខ្លួន គឺបុគ្គលនោះគ្រប់គ្រងរក្សាល្អហើយ រមែងជាទីពំនាក់អាស្រ័យរបស់ពួកកុលបុត្រ ដែលត្រូវសេចក្តីសង្ស័យគ្របសង្កត់ រមែងក្លាហានក្នុងការនិយាយក្នុងកណ្តាលជំនុំសង្ឃ រមែងញាំញីពួកសត្រូវបានដោយល្អ ដោយសហធម៌ រមែងជាអ្នកបដិបត្តិដើម្បីការតាំងមាំនៃព្រះសទ្ធម្ម ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំងឡាយ ៥ ( មាន ) ក្នុងបុគ្គលដែលទ្រទ្រង់ព្រះវិន័យ គឺគំនរសីលរបស់ខ្លួន រមែងជារបស់ដែលបុគ្គលនោះគ្រប់គ្រងរក្សាទុកល្អហើយ ១ រមែងជាទីពឹងពំនាក់អាស្រ័យរបស់កុលបុត្រទាំងឡាយ ដែលត្រូវសេចក្តីសង្ស័យគ្របសង្កត់ ១ រមែងជាអ្នកអង់អាចក្នុងការនិយាយកណ្តាលជំនុំសង្ឃ ១ រមែងញាំញីពួកសត្រូវបានដោយល្អដោយសហធម៌ ១ រមែងជាអ្នកបដិបត្តិដើម្បីការតាំងមាំនៃព្រះសទ្ធម្ម ១ ។

ម្យ៉ាងទៀត កុសលធម៌ទាំងឡាយណា ដែលមានសំវរៈជាមូល ដែលមានព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកហើយ បុគ្គលអ្នកទ្រទ្រង់វិន័យនោះឯង

ឈ្មោះថា ជាទាយាទនៃកុសលធម៌ទាំងនោះ ព្រោះធម៌ទាំងនោះ មានព្រះវិន័យជាមូល ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ថា

វិន័យ ដើម្បីប្រយោជន៍ដល់សេចក្ដីសង្រួម សេចក្ដីសង្រួមដើម្បីប្រយោជន៍ដល់ការមិនក្ដៅក្រហាយចិត្ត ការមិនក្ដៅក្រហាយចិត្ត ដើម្បីប្រយោជន៍ដល់បាមោជ្ជ គឺសេចក្ដីរីករាយទន់ បាមោជ្ជដើម្បីប្រយោជន៍ដល់បីតិ គឺសេចក្ដីរីករាយដ៏ក្លា បីតិដើម្បីប្រយោជន៍ដល់បស្សទ្ធិ គឺសេចក្ដីស្ងប់រម្ងាប់ បស្សទ្ធិដើម្បីប្រយោជន៍ដល់សុខ សុខដើម្បីប្រយោជន៍ដល់សមាធិ សមាធិដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ ( វិបស្សនាទន់ខ្ចី ) យថាភូតញ្ញាណទស្សនៈដើម្បីប្រយោជន៍ដល់និព្វិទា ( វិបស្សនាមានកម្លាំង ) និព្វិទាដើម្បីប្រយោជន៍ដល់វិរាគៈ គឺអរិយមគ្គ វិរាគៈដើម្បីប្រយោជន៍ដល់វិមុត្តិ គឺអរហត្តផល វិមុត្តិដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ វិមុត្តិញ្ញាណទស្សនៈដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន គឺរលត់មិនឲ្យមានបច្ច័យ ជាគ្រឿងប្រកាន់តទៅ ។ ការពោល ការប្រឹក្សា កិរិយាអង្គុយគិត កិរិយាផ្ទៀងត្រចៀកស្ដាប់ នីមួយៗ មានអនុបាទាបរិនិព្វាន គឺការផុតដ៏វិសេសនៃចិត្ត មិនប្រកាន់មាំនោះឯងជាផល ព្រោះដូច្នោះ គួរធ្វើសេចក្ដីព្យាយាមដោយអើពើ ក្នុងការរៀនសូត្រព្រះវិន័យដូច្នេះឯង ។

## គាថាសរុប

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណោះ ដែលខ្ញុំប្រកាសអត្ថនៃគាថានេះមានពាក្យថា

ព្រះវិនយបិដកនេះ បុគ្គលណាពោលទុក ពោលទុកក្នុងកាលណា ពោលទុកព្រោះហេតុអ្វី បុគ្គលណាទ្រទ្រង់ទុក បុគ្គលណានាំបន្តមក និងប្រតិស្ឋានហើយក្នុងបុគ្គលណា ខ្ញុំពោលវិធីដូច្នេះហើយ ខាងក្រោយ ( នឹងពណ៌នាអត្ថនៃព្រះវិន័យ ) ដូច្នេះ ។

ក្នុងមាតិកាដែលខ្ញុំរៀបចំទុកដើម្បីពណ៌នាព្រះវិន័យនោះមុន និងការពណ៌នាពាហិរនិទាននៃព្រះវិន័យ ក៏ខ្ញុំពណ៌នាហើយតាមដែលបានអធិប្បាយ មកដូច្នេះឯង ។

ពាហិរនិទានវណ្ណនា ចប់

# វេរញ្ជកណ្ឌវណ្ណនា

[ ១ ] ឥឡូវនេះ ខ្ញុំនឹងធ្វើការពណ៌នាសេចក្តីនៃបទទាំងឡាយ មាន បទថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ព្រោះបានពោលទុកហើយថា

នឹងធ្វើការពណ៌នាអត្ថនៃព្រះវិន័យ សម្តែងអត្ថនៃ
បាលីថា **តេន** ជាដើមដោយប្រការផ្សេងៗ ។
ខ្ញុំនឹងធ្វើការពណ៌នាអត្ថដូចម្តេចវិញ ។

## អធិប្បាយបទថា តេន ជាដើម

បទថា **តេន** ជាពាក្យសម្តែងចេញដោយមិនចំពោះ ។ បណ្ឌិតគប្បីជ្រាបបដិនិទ្ទេសនៃបទថា **តេន** នោះ ដោយពាក្យថា **យេន** នេះ ដែលជាពាក្យសរុប សូម្បីមិនពោលទុក តែសម្រេចបានដោយអត្ថក្នុងកាលខាងក្រោយ ។ ពិតហើយ ការរំពឹងរបស់ព្រះសារីបុត្រដែលជាហេតុនៃការអារាធនាព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តនូវព្រះវិន័យ សម្រេចបានក្នុងកាលខាងក្រោយ ព្រោះហេតុនោះ គប្បីជ្រាបសម្ពន្ធក្នុងពាក្យថា **តេន សមយេន** ជាដើមនេះយ៉ាងនេះថា ការរំពឹងនោះកើតឡើងដោយសម័យណា សម័យនោះ ព្រះដ៏មានព្រះភាគទ្រង់ប្រថាប់ត្រង់ស្រុកវេរញ្ជា ។

ពិតហើយ វិធីនេះជាវិធីដែលសមគួរក្នុងព្រះវិន័យទាំងអស់ គឺពាក្យថា **តេន** លោកពោលទុកក្នុងទីណាៗ ក្នុងទីនោះៗ បណ្ឌិតគប្បីធ្វើបដិនិទ្ទេសដោយពាក្យថា **យេន** នេះ ដែលសម្រេចដោយអត្ថក្នុងកាលមុន ឬខាងក្រោយ ។ ឧទាហរណ៍ល្មមជាផ្លូវនៃវិធី ដែលសមតាមពោលហើយនោះដូច្នេះ ។ សុទិន្នភិក្ខុសេពមេថុនធម្ម ព្រោះហេតុណា ម្នាលភិក្ខុទាំងឡាយ

*ព្រោះហេតុនោះឯង តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ មានពាក្យអធិប្បាយថា សុទិន្នភិក្ខុសេពមេថុនធម្ម ព្រោះហេតុណា ព្រោះហេតុនោះតថាគតនឹងបញ្ញត្ត ។ បដិនិទ្ទេសរមែងសមគួរដោយពាក្យថា* **យេន** *នេះដែលសម្រេចដោយអត្ថក្នុងកាលមុនយ៉ាងនេះមុន ។ បដិនិទ្ទេសរមែងសមគួរដោយពាក្យថា* **យេន** *នេះ ដែលសម្រេចដោយអត្ថក្នុងកាលក្រោយយ៉ាងនេះថា ធនិយភិក្ខុជាកូនស្មូនឆ្នាំងកាន់យករបស់ដែលម្ចាស់គេមិនបានឲ្យ គឺឈើទាំងឡាយរបស់ព្រះរាជា ដោយសម័យណា សម័យនោះព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងក្រុងរាជគ្រឹះ ។ អត្ថនៃពាក្យថា* **តេន** *គឺខ្ញុំពោលហើយដោយប្រការដូច្នេះ ។*

# អធិប្បាយបទថា សមយេន ជាដើម

*ចំណែក* **សមយ** *សព្ទ ដែលមានក្នុងបទថា* **សមយេន** *នេះ*
*រមែងប្រាកដក្នុងអត្ថ ៩ យ៉ាង គឺ* ***សមវាយៈ ១***
***ខណៈ ១ កាលៈ ១ សមុហៈ ១ ហេតុ ១ ទិដ្ឋិ ១***
***បដិលាភ ១ បហាន ១ បដិវេធ ១*** *ជាមុន ។*

*ពិតណាស់* **សមយ** *សព្ទ មានសមវាយៈ ( ព្រមគ្នា ) ជាអត្ថក្នុងពាក្យទាំងឡាយជាដើមយ៉ាងនេះថា* **អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយ** *បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យសិន ហើយសឹមទៅក្នុងថ្ងៃស្អែកព្រមគ្នា ។*

*មានខណៈជាអត្ថ ក្នុងពាក្យទាំងឡាយ មានពាក្យយ៉ាងនេះជាដើមថា*

**ឯកោវ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** *ម្នាលភិក្ខុទាំងឡាយ ខណៈ និងសម័យនៃការនៅប្រព្រឹត្តព្រហ្មចរិយៈ មានតែមួយ ។ មានកាលជាអត្ថ ដូចក្នុងពាក្យទាំងឡាយ យ៉ាងនេះជាដើមថា* **ឧណ្ហសមយោ បរិឡាហសមយោ** *កាលក្តៅ កាលស្អុះស្អាប់ ។ មានសមុហៈ ( ប្រជុំ ) ជាអត្ថ ដូចក្នុងពាក្យទាំងឡាយជាដើមថា* **មហាសមយោ បវនស្មឹ** *ថ្ងៃនេះជាថ្ងៃប្រជុំធំក្នុងដងព្រៃ ។ មានហេតុជាអត្ថ ដូចក្នុងពាក្យទាំងឡាយ យ៉ាងនេះជាដើមថា* **សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ ភគវា ខោ សាវត្ថិយំ វិហរតិ ភគវាបិ មំ ជានិស្សតិ ភទ្ទាលិ នាម ភិក្ខុ សត្ថុសាសនេ សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ** *ម្នាលភទ្ទាលិអ្នកមិនបានដឹងហេតុផលថា ព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងសាវត្ថី តែព្រះដ៏មានព្រះភាគគង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះភទ្ទាលិ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ ម្នាលភទ្ទាលិ នេះឯងជាហេតុដែលមិនបានដឹង ។ មានទិដ្ឋិជាអត្ថ ដូចក្នុងពាក្យទាំងឡាយ យ៉ាងនេះជាដើមថា* **តេន ខោ បន សមយេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិន្ទុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ** *សម័យនោះឯង បរិព្វាជកឈ្មោះឧគ្គហមានៈ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទម្ពាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវទិដ្ឋិ ។ មានបដិលាភៈជាអត្ថ ក្នុងពាក្យទាំងឡាយយ៉ាងនេះជាដើមថា*

**ទិដ្ឋេ ធម្មេ ច យោ អត្ថោ    យោ ចត្ថោ សម្បរាយិកោ**
**អត្ថាភិសមយា ធីរោ    បណ្ឌិតោតិ បវុច្ចតិ ។**

*ប្រយោជន៍ក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណាដែលមានក្នុងបរលោកក្តី ធីរជន ឈ្មោះថា បណ្ឌិត ព្រោះការបានចំពោះនូវប្រយោជន៍ទាំងពីរនោះ ។*

*មានបហានជាអត្ថ ដូចក្នុងពាក្យទាំងឡាយយ៉ាងនេះជាដើមថា* **សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្ស** *ធ្វើទីបំផុតទុក្ខបានហើយ ព្រោះត្រាស់ដឹងនូវការលះបង់សេចក្តីប្រកាន់តាមហេតុ ។ មានបដិវេធជាអត្ថ ដូចក្នុងពាក្យទាំងឡាយយ៉ាងនេះជាដើមថា* **ទុក្ខស្ស បីឡនដ្ឋោ សន្តាបដ្ឋោ សង្ខតដ្ឋោ វិបរិណាមដ្ឋោ** *ទុក្ខសច្ច មានអត្ថថា បៀតបៀន មានអត្ថថា ក្តៅក្រហាយ មានអត្ថថា មានបច្ច័យតាក់តែង មានអត្ថថា ប្រែប្រួល នេះជាអត្ថដែលគួរចាក់ធុះ ។ តែក្នុងទីនេះ* **សមយ** *សព្ទនោះ មានកាលៈជាអត្ថ ព្រោះ ហេតុនោះ គប្បីឃើញសេចក្តីក្នុងបទថា* **តេន សមយេន** *នេះ យ៉ាងនេះថា ការរំពឹង ជាហេតុអារាធនាព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តវិន័យកើតឡើងដល់ព្រះសារីបុត្រ ដោយកាលណា ដោយកាលនោះ ។*

*ក្នុងបទថា* **តេន សមយេន** *នេះ សូមចោទសួរថា បើដូច្នេះ ហេតុអ្វី ក្នុងវិន័យនេះ ទើបធ្វើនិទ្ទេសដោយតតិយាវិភត្តិថា* **តេន សមយេន** *មិនធ្វើដោយទុតិយាវិភត្តិថា* **ឯកំ សមយំ** *ដូចក្នុងសុត្តន្តៈ និងដោយសត្តមីវិភត្តិថា* **យស្មឹ សមយេ កាមាវចរំ** *ដូចក្នុងអភិធម្មហ្ន៎ ឆ្លើយថា ព្រោះការសមជាមួយ*

អត្ថដោយប្រការយ៉ាងនោះ ក្នុងសុត្តន្តៈ និងអភិធម្មនោះ និងព្រោះការសមជាមួយអត្ថដោយប្រការដទៃក្នុងវិន័យនេះ សួរថា សមជាមួយអត្ថដូចម្ដេច ឆ្លើយថា **សមយ** សព្ទ មានអច្ចន្តសំយោគជាអត្ថ សមក្នុងសុត្តន្តៈមុន ។ ពិតហើយ ព្រះដ៏មានព្រះភាគទ្រង់នៅដោយករុណាវិហារ រហូតទីបំផុតសម័យដែលទ្រង់សម្ដែងសុត្តន្តៈទាំងឡាយ មានព្រហ្មជាលសូត្រជាដើមនោះឯង ព្រោះហេតុនោះ ក្នុងសុត្តន្តៈនោះ ទើបលោកធ្វើឧបយោគនិទ្ទេស ដើម្បីផ្ទុះបញ្ចាំងអត្ថនោះ ។ ឯ **សមយ** សព្ទ មានអធិករណៈជាអត្ថ និងការកំណត់ភាវៈ ដោយភាវៈជាអត្ថ រមែងសមគួរក្នុងព្រះអភិធម្ម ។ ពិតហើយ **សមយ** សព្ទ មានកាលៈជាអត្ថ និងមានសមុហៈជាអត្ថ ជាអធិករណ៍នៃធម៌ទាំងឡាយមានផស្សៈជាដើម ដែលព្រះដ៏មានព្រះភាគត្រាស់ក្នុងអភិធម្មនោះ ភាវៈនៃធម៌ទាំងនោះ ដែលលោករមែងកំណត់ដោយការមាននៃសម័យ ពោល គឺខណៈសមវាយៈ និងហេតុ ព្រោះហេតុនោះ ក្នុងអភិធម្មនោះ ទើបលោកធ្វើនិទ្ទេសដោយសត្តមីវិភត្តិដើម្បីបំភ្លឺអត្ថនោះ ។ ចំណែកក្នុងវិន័យនេះ **សមយ** សព្ទ មានហេតុជាអត្ថ និងមានករណៈជាអត្ថ ទើបគួរ ។

ក្នុងសម័យបញ្ញត្តសិក្ខាបទណានោះ ជាសម័យដែលព្រះសារីបុត្រជាដើមដឹងបានលំបាក ដោយសម័យនោះ ដែលជាហេតុ និងករណៈ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទទាំងឡាយ ហើយទ្រង់ពិចារណាមើលហេតុនៃការបញ្ញត្តសិក្ខាបទ ទ្រង់បានប្រថាប់នៅក្នុងទីនោះៗ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា លោកធ្វើនិទ្ទេសដោយតតិយាវិភត្តិក្នុងវិន័យនេះ ដើម្បីបំភ្លឺអត្ថ

នោះ ។ ក៏ក្នុងទីនោះមានគាថាដូចតទៅនេះថា

ព្រោះពិចារណាអត្ថនោះៗ ព្រះថេរៈទាំងឡាយ ទើបពោល
សមយសព្ទក្នុងព្រះសូត្រ និងព្រះអភិធម្មឯណានីមួយ
ដោយតតិយាវិភត្តិ និងសត្តមីវិភត្តិ សមយសព្ទនោះ លោក
ពោលក្នុងព្រះវិន័យនេះ ដោយតតិយាវិភត្តិប៉ុណ្ណោះ ។

ចំណែកព្រះបុរាណាចារ្យពណ៌នាទុកថា សេចក្ដីផ្សេងគ្នានេះថា **តំ សមយំ** អស់សម័យនោះក្ដីថា **តស្មិំ សមយេ** ក្នុងសម័យនោះក្ដីថា **តេន សមយេន** ដោយសម័យនោះក្ដី ប្លែកគ្នាត្រឹមតែពាក្យក្នុងគ្រប់ៗ បទ មានសត្តមីវិភត្តិប៉ុណ្ណោះជាអត្ថ ព្រោះដូច្នោះ តាមលទ្ធិរបស់បុរាណាចារ្យនោះ កាលលោកពោលពាក្យថា **តេន សមយេន** ប្រែថា ដោយសម័យនោះ ក៏គប្បីឃើញសេចក្ដីថា **តស្មិំ សមយេ** ប្រែថា ក្នុងសម័យនោះ ។

ខ្ញុំពណ៌នាអត្ថនៃបទទាំងនេះថា **ពុទ្ធោ ភគវា** ដូច្នេះជាដើមខាងមុខ ។

## អធិប្បាយពាក្យថា វេរញ្ជាយំ វិហរតិ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **វេរញ្ជាយំ វិហរតិ** នេះ ដូចតទៅនេះ ពាក្យថា **វេរញ្ជាយំ** នេះ ជាឈ្មោះរបស់ស្រុកមួយ ក្នុងនគរនោះ ។ ពាក្យថា **វេរញ្ជាយំ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ។ ពាក្យថា **វិហរតិ** ជាការសម្ដែងដល់ភាពជាអ្នកដល់ព្រមដោយវិហារធម៌ឯណានីមួយ បណ្ដាវិហារធម៌គឺឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ ដោយមិនប្លែកគ្នា ។ តែក្នុងទីនេះសម្ដែងដល់ការប្រកបដោយឥរិយាបថឯណានីមួយ ក្នុងបណ្ដាឥរិយា-

បថ គឺការឈរ ការដើរ ការអង្គុយ និងការដេក ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់ឈរក្តី យាងក្តី ប្រថាប់គង់ក្តី ផ្ទំក្តី បណ្ឌិតគប្បីជ្រាបថា ទ្រង់ប្រថាប់នៅទាំងអស់ ។ ពិតហើយ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បំបាត់សេចក្តីលំបាកនៃឥរិយាបថមួយ ដោយឥរិយាបថមួយទៀត ទ្រង់នាំ គឺទ្រង់ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ មិនឲ្យទ្រុឌទ្រោម ព្រោះដូច្នោះ ទើបលោកហៅថា ទ្រង់ប្រថាប់នៅ ។

## អធិប្បាយពាក្យថា នឡេរុបុចិមន្ទមូលេ ជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **នឡេរុបុចិមន្ទមូលេ** នេះ ដូចតទៅនេះថា យក្ខឈ្មោះនឡេរុ ។ ដើមស្តៅឈ្មោះថា **បុចិមន្ទ** ។ បទថា **មូលំ** ប្រែថា ទីជិត ។ ពិតហើយ **មូល** សព្ទនេះ រមែងប្រាកដក្នុងឫសគល់ ក្នុងពាក្យទាំងឡាយ ដូចពាក្យថា **មូលានិ ឧទ្ធរេយ្យ អន្តមសោ ឧសីរនាឡិមត្តានិបិ** គប្បីជីកនូវឫសទាំងឡាយ ដោយហោច សូម្បីឫសស្បូវភ្លាំង ឫសបបុស ។ ក្នុងហេតុដែលមិនទូទៅ ដូចពាក្យជាដើមថា **លោភោ អកុសលមូលំ** លោភៈជាឫសគល់នៃអកុសល ។ ក្នុងទីជិត ដូចក្នុងពាក្យទាំងឡាយជាដើមថា **យាវ មជ្ឈន្តិកេ កាលេ ឆាយា ផរតិ និវាតេ បណ្ណានិ បតន្តិ ឯត្តាវតា រុក្ខមូលំ** ម្លប់ រមែងផ្សាយទៅក្នុងវេលាថ្ងៃត្រង់ ស្លឹកឈើទាំងឡាយ រមែងធ្លាក់ទៅក្នុងពេលស្ងប់ខ្យល់បានត្រឹមទីណា ទីមានប្រមាណប៉ុណ្ណោះ ឈ្មោះ រុក្ខមូល ។ តែក្នុងបទថា **មូលេ** នេះ លោកមានបំណងយកទីជិត ដូច្នោះ គប្បីឃើញអត្ថនេះយ៉ាងនេះថា ទីជិតដើមស្តៅដែលនឡេរុយក្ខអាស្រ័យហើយ ។ បានឮថា ដើម

ស្តៅនោះ គួររីករាយ គួរជ្រះថ្លា ធ្វើអាកប្បកិរិយាដូចជាម្ចាស់នៃដើមឈើជាច្រើន មាននៅក្នុងទីដែលដល់ព្រមដោយផ្លូវទៅមក មិនឆ្ងាយអំពីស្រុកនោះ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគយាងទៅស្រុកវេរញ្ជា កាលប្រថាប់នៅក្នុងទីកន្លែងដែលសមគួរ ទើបប្រថាប់នៅក្នុងទីជិត គឺចំណែកខាងក្រោមនៃដើមឈើនោះ ។ ព្រោះហេតុនោះ ទើបព្រះឧបាលីពោលថា ទ្រង់ប្រថាប់នៅត្រង់គល់ស្តៅដែលនឡេរុយក្សអាស្រ័យនៅ ជិតស្រុកវេរញ្ជា ។ បើមានពាក្យចោទសួរក្នុងសេចក្តីនេះថា បើព្រះដ៏មានព្រះភាគប្រថាប់នៅត្រង់ស្រុកវេរញ្ជាមុន ពាក្យថា ត្រង់គល់ស្តៅដែលនឡេរុយក្ខអាស្រ័យនៅ ព្រះឧបាលិត្ថេរមិនគួរពោល បើទ្រង់ប្រថាប់នៅត្រង់គល់ស្តៅ ដែលនឡេរុយក្ខអាស្រ័យនៅនោះ ពាក្យថា ស្រុកវេរញ្ជា លោកក៏មិនគួរពោល ព្រោះថា ព្រះដ៏មានព្រះភាគទ្រង់មិនអាចប្រថាប់នៅក្នុងតំបន់ពីរព្រមគ្នា ដោយសម័យតែមួយនោះបានឡើយ ។ តែពាក្យថា **វេរញ្ជាយំ វិហរតិ នឡេរុបុចិមន្ទមូលេ** នោះ បណ្ឌិតមិនគប្បីយល់ឃើញយ៉ាងនោះឡើយ ខ្ញុំបានពោលហើយមិនមែនឬថា បទថា **វេរញ្ជាយំ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថថា ជិត ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រថាប់នៅត្រង់គល់ស្តៅ ដែលនឡេរុយក្ខអាស្រ័យនៅក្នុងទីជិតនៃស្រុកវេរញ្ជា ទើបព្រះឧបាលិត្ថេរពោលថា ទ្រង់ប្រថាប់នៅត្រង់គល់ស្តៅដែលនឡេរុយក្ខអាស្រ័យនៅ ជិតស្រុកវេរញ្ជា សូម្បីក្នុងព្រះបាលីបទេសនេះ ដូចជាហ្វូងគោទាំងឡាយ កាលត្រាច់ទៅក្នុងទីជិតនៃទន្លេគង្គា និងយមុនាជាដើម ជនទាំងឡាយរមែងពោលថា ត្រាច់ទៅជិតស្ទឹងគង្គា ត្រាច់ទៅជិតស្ទឹងយមុនា

ដូច្នោះ ។

## អធិប្បាយពាក្យថា វេរញ្ជាយំ និង នឡេរុបុចិមន្ទមូលេ ជាដើម

ក្នុងពាក្យថា **វេរញ្ជាយំ វិហរតិ នឡេរុបុចិមន្ទមូលេ** នេះ បណ្ឌិតគប្បីជ្រាបអត្ថយោជនា ដោយន័យជាដើមយ៉ាងនេះថា ពិតហើយ ពាក្យថា **វេរញ្ជា** មានការសម្តែងគោចរគ្រាមរបស់ព្រះដ៏មានព្រះភាគនោះជាប្រយោជន៍ ។ ពាក្យថា **នឡេរុបុចិមន្ទមូល** មានការសម្តែងទីកន្លែងដែលសមគួរជាប្រយោជន៍ដល់បព្វជិត ។ ព្រះឧបាលិត្ថេរសម្តែងការដែលព្រះដ៏មានព្រះភាគទ្រង់ធ្វើការអនុគ្រោះពួកគ្រហស្ថ ក្នុងបណ្តាពាក្យប្រារព្ធទាំងពីរនោះ ដោយពាក្យប្រារព្ធថា **វេរញ្ជា** សម្តែងការដែលទ្រង់អនុគ្រោះបព្វជិត ដោយពាក្យប្រារព្ធថា **នឡេរុបុចិមន្ទមូល** ។

ម្យ៉ាងទៀត សម្តែងការវៀរអត្តកិលមថានុយោគ ព្រោះការទទួលបច្ច័យដោយពាក្យប្រារព្ធខាងដើម សម្តែងឧទាហរណ៍នៃឧបាយ ក្នុងការវៀរកាមសុខល្លិកានុយោគ ព្រោះលះវត្ថុកាមចោល ដោយពាក្យប្រារព្ធខាងចុង ម្យ៉ាងទៀតសម្តែងការដែលព្រះដ៏មានព្រះភាគ ទ្រង់ប្រកបក្រៃលែងដោយធម្មទេសនាដោយពាក្យប្រារព្ធខាងដើម សម្តែងដល់ការដែលព្រះដ៏មានព្រះភាគទ្រង់បង្អោនទៅដើម្បីវិវេក ដោយពាក្យប្រារព្ធខាងចុង ។ សម្តែងការដែលព្រះដ៏មានព្រះភាគទ្រង់ប្រកបដោយព្រះករុណា ដោយប្រារព្ធពាក្យខាងដើម ។ សម្តែងការដែលទ្រង់ប្រកបដោយព្រះបញ្ញា ដោយពាក្យប្រារព្ធខាងចុង ។ សម្តែងប្រការ

ដែលព្រះដ៏មានព្រះភាគ ទ្រង់បង្អោនព្រះទ័យទៅក្នុងការញុំាងហិតសុខឲ្យសម្រេច ដល់សត្វទាំងឡាយ ដោយពាក្យប្រារព្ធខាងដើម សំដែងប្រការដែលព្រះដ៏មាន ព្រះភាគ មិនចូលទៅជាប់ក្នុងការធ្វើហិតសុខដល់សត្វដទៃ ដោយពាក្យប្រារព្ធ ខាងចុង សំដែងប្រការដែលព្រះដ៏មានព្រះភាគ ទ្រង់សម្រាកសម្រាន្ត មានការ មិនលះបង់នូវសេចក្តីសុខ ដែលប្រកបដោយធម៌ជានិមិត្ត ដោយប្រារព្ធពាក្យ ខាងដើម សំដែងធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់នៅជាផាសុក មានការតាម ប្រកបក្នុងឧត្តរិមនុស្សធម្មជានិមិត្ត ដោយពាក្យប្រារព្ធខាងចុង ។ សំដែងប្រការ ដែលព្រះដ៏មានព្រះភាគ ជាបុគ្គលច្រើនដោយឧបការៈដល់មនុស្សទាំងឡាយ ដោយពាក្យប្រារព្ធខាងដើម សំដែងប្រការដែលព្រះអង្គជាអ្នកច្រើនដោយឧបការៈ ដល់ទេវតាទាំងឡាយ ដោយពាក្យប្រារព្ធខាងចុង សំដែងប្រការដែលព្រះដ៏មាន ព្រះភាគទ្រង់កើតឡើងក្នុងលោក ហើយចម្រើនព្រមក្នុងលោក ដោយពាក្យប្រារព្ធ ខាងដើម សំដែងការដែលព្រះដ៏មានព្រះភាគ មិនចូលទៅជាប់ក្នុងលោក ដោយ ពាក្យប្រារព្ធខាងចុង ។ ដោយពាក្យប្រារព្ធខាងដើម សំដែងការដែលព្រះអង្គ ទ្រង់ញុំាងប្រយោជន៍ដែលទ្រង់ កើតឡើងឲ្យសម្រេចរៀបរយ តាមព្រះបាលី ថា **ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុ-ស្សានំ ។ កតមោ ឯកបុគ្គលោ តថាគតោ អរហំ សម្មាសម្ពុទ្ធោ** ម្នាល ភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងដើម្បី ជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វ

លោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្ស ទាំងឡាយ បុគ្គលឯក តើគឺនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ដោយពាក្យប្រារព្ធខាងចុង សម្ដែងការនៅសមគួរដល់ទីកន្លែងដែលទ្រង់កើតឡើង ពិតហើយ ព្រះដ៏មានព្រះភាគ ទ្រង់កើតឡើងក្នុងព្រៃប៉ុណ្ណោះ ដោយការកើតឡើងទាំងដែលជាលោកិយ និងលោកុត្តរ គឺគ្រាដំបូង ត្រង់លុម្ពិនីវ័ន គ្រាទី ២ ត្រង់ពោធិមណ្ឌល ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរសម្ដែងទីលំនៅរបស់ព្រះអង្គក្នុងព្រៃទាំងនោះ ។

## អធិប្បាយពាក្យថា មហតា ភិក្ខុសង្ឃេន សទ្ធឹ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **មហតា ភិក្ខុសង្ឃេន សទ្ធឹ** នេះ តទៅ បទថា **មហតា** មានអត្ថថា ធំ ដោយភាពជាមហាគុណខ្លះ ធំដោយភាពជាបុគ្គលមានចំនួនច្រើនខ្លះ ។ ពិតហើយ ភិក្ខុសង្ឃនោះ បានជាធំដោយគុណទាំងឡាយខ្លះ ព្រោះថា ភិក្ខុដែលមានគុណយ៉ាងទាប ក្នុងភិក្ខុសង្ឃនោះ ក៏ត្រឹមសោតាបន្នបុគ្គល បានជាធំដោយចំនួនខ្លះ ព្រោះមានចំនួន ៥០០ ។ ពួកនៃភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុសង្ឃ ដោយភិក្ខុសង្ឃនោះ ។ អធិប្បាយថា ដោយពួកសមណៈដែលស្មើគ្នាដោយគុណ ពោល គឺជាអ្នកមានទិដ្ឋិ និងសីលស្មើគ្នា ។ បទថា **សទ្ធឹ** គឺដោយភាពជាពួកតែមួយ ។ ពាក្យថា **បញ្ចមត្តេហិ ភិក្ខុសតេហិ** មានវិគ្គហៈថា ចំនួន ៥ ជាប្រមាណរបស់ភិក្ខុទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **បញ្ចមត្តា** ។ ប្រមាណ លោកហៅថា **មត្តា** ។ ព្រោះដូច្នោះ បណ្ឌិតគប្បីឃើញអត្ថក្នុងបាលីប្រភេទនេះ យ៉ាងនេះថា ១០០

នៃភិក្ខុទាំងនេះ មានចំនួន ៥ គឺមានប្រមាណ ៥ ដូចកាលលោកពោលថា **ភោជនេ មត្តញ្ញូ** រមែងមានអត្ថថា មានចំនួន គឺស្គាល់ប្រមាណក្នុងភោជន ដូច្នោះ ។ ១០០ នៃភិក្ខុទាំងឡាយ ឈ្មោះថា **ភិក្ខុសតានិ** ។ ដោយ ១០០ នៃភិក្ខុដែលមានប្រមាណ ៥ ទាំងនោះ ។ តែក្នុងពាក្យដែលព្រះថេរៈពោលថា **មហតា ភិក្ខុសង្ឃេន សទ្ធិំ** នេះ លោកពោលសម្ដែងភាពដែលភិក្ខុសង្ឃច្រើននោះ ជាបុគ្គលធំដោយចំនួន ដោយពាក្យថា **បញ្ចមត្តេហិ ភិក្ខុសតេហិ** នេះ ។ ចំណែកការដែលភិក្ខុសង្ឃនោះ ជាអ្នកធំដោយគុណ នឹងមានពន្យល់ខាងមុខ ដោយពាក្យថា ម្នាលសារីបុត្រ ពីព្រោះ ( ឥឡូវនេះ ) ភិក្ខុសង្ឃនៅមិនទាន់មានពុត ( ហាំនលបលួចធ្វើអាក្រក់ ) នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មងសុទ្ធសឹងតែផូរផង់ ផ្ចង់ចិត្តស្ថិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្រ ក៏បណ្ដាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតាបន្នបុគ្គល ដូច្នេះ ។

## អធិប្បាយពាក្យថា អស្សោសិ ខោ ជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អស្សោសិ ខោ វេរញ្ជោ ព្រាហ្មណោ** ដូចតទៅនេះ បទថា **អស្សោសិ** សេចក្ដីថា ស្ដាប់ គឺបានស្ដាប់ បានដល់ បានជ្រាបតាមទំនងនៃសំឡេងរបស់ពាក្យនិយាយដែលដល់សោតទ្វារ ។ សព្ទថា **ខោ** ជានិបាត ចុះក្នុងអត្ថ ត្រឹមធ្វើបទឲ្យពេញ ឬចុះក្នុងអត្ថនៃអវធារណៈ ។ បណ្ដាអត្ថទាំង ២ នោះ ដោយអត្ថនៃអវធារណៈ គប្បីជ្រាបអត្ថដូច្នេះថា បាន

ស្តាប់ពិតៗ អន្តរាយនៃការស្តាប់ណាមួយ មិនមានដល់ព្រាហ្មណ៍នោះ ។ ដោយ អត្ថថា ធ្វើបទឲ្យពេញ គប្បីជ្រាបថា ត្រឹមតែជាការពីរោះរណ្តំនៃបទ និង ព្យញ្ជនៈប៉ុណ្ណោះ ។ ព្រាហ្មណ៍ដែលកើតក្នុងក្រុងវេរញ្ជា ឈ្មោះថា វេរញ្ជៈ ។ ព្រាហ្មណ៍មានក្នុងស្រុកវេរញ្ជា ឈ្មោះថា វេរញ្ជៈ ។ ម្យ៉ាងទៀត ស្រុកវេរញ្ជា ជាទីលំនៅរបស់ព្រាហ្មណ៍នោះ ព្រោះដូច្នោះ ទើបព្រាហ្មណ៍នោះ ឈ្មោះថា វេរញ្ជៈ ។ តែព្រាហ្មណ៍នេះ អ្នកស្រុកហៅថា ឧទយៈ ដោយអំណាចឈ្មោះ ដែលឪពុកម្តាយដាក់ឲ្យ ។ បុគ្គលណា រមែងស្វាធ្យាយវេទ អធិប្បាយថា ស្វាធ្យាយមន្តទាំងឡាយ ហេតុនោះ បុគ្គលនោះ ឈ្មោះថា ព្រាហ្មណ៍ ។ ពិត ហើយ ពាក្យថា ព្រាហ្មណ៍នេះឯង ជាពាក្យហៅពួកព្រាហ្មណ៍ដោយជាតិ ។ តែព្រះអរិយៈទាំងឡាយ លោកហៅថា ព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបន្សាត់ បង់ហើយ ។

## អធិប្បាយរឿងដែលព្រាហ្មណ៍បានស្តាប់

ឥឡូវនេះ ព្រះឧបាលិត្ថេរ កាលនឹងប្រកាសរឿងដែលវេរញ្ជព្រាហ្មណ៍ បានស្តាប់ ទើបពោលពាក្យថា **សមណោ ខលុ ភោ គោតមោ** ជាដើម ។ ក្នុងពាក្យនោះ បណ្ឌិតគប្បីជ្រាបថា ព្រះដ៏មានព្រះភាគ ឈ្មោះថា សមណៈ ព្រោះជាអ្នកមានបាបស្ងប់ហើយ ។ សេចក្តីនេះ សមដូចព្រះពុទ្ធវចនៈថា អ្នកដែលមានបាបបន្សាត់ហើយ ឈ្មោះថា ព្រាហ្មណ៍ អ្នកដែលតថាគតហៅ ថា សមណៈ ព្រោះ ( បាបទាំងឡាយដែល ) បុគ្គលនោះរម្ងាប់បានហើយ ។ ឯព្រះដ៏មានព្រះភាគ រាប់ថា ជាបុគ្គលមានបាប ដែលអរិយមគ្គដ៏កំពូលឲ្យ

ស្ងប់ហើយ ព្រោះដូច្នោះ ព្រះនាម គឺសមណៈនេះ ព្រះអង្គទ្រង់សម្រេចហើយ ដោយគុណតាមសេចក្ដីពិត ។

បទថា **ខលុ** ជានិបាត ចុះក្នុងអត្ថថា បានស្ដាប់មក ។

ពាក្យថា **ភោ** ត្រឹមតែជាពាក្យហៅ ដែលមកហើយដោយជាតិនៃពួកជន ដែលជាព្រាហ្មណជាតិ ។ សេចក្ដីនេះ សមដូចព្រះតម្រាស់ថា **ភោវាទី នាម សោ ហោតិ សចេ ហោតិ សកិញ្ចនោ** បុគ្គលនោះ គ្រាន់តែបានឈ្មោះថា **ភោ វាទី** ( អ្នកពោលថាចម្រើន ) ព្រោះបុគ្គលនោះឯង ជាអ្នកមានកិលេសជាគ្រឿងកង្វល់នៅឡើយ ។ ពាក្យថា **គោតមោ** នេះ វេវចនៈព្រាហ្មណ៍ ហៅព្រះដ៏មានព្រះភាគដោយអំណាចនៃគោត្រ ។ ព្រោះដូច្នោះ បណ្ឌិតគប្បីឃើញអត្ថ ក្នុងពាក្យថា **សមណោ ខលុ ភោ គោតមោ** នេះ យ៉ាងនេះថា បានឮថា ព្រះសមណគោតមគោត្រដ៏ចម្រើន ។ ចំណែកពាក្យថា **សក្យបុត្តោ** នេះ សម្ដែងដល់ត្រកូលខ្ពង់ខ្ពស់របស់ព្រះដ៏មានព្រះភាគ ។ ពាក្យថា **សក្យកុលា បព្វជិតោ** សម្ដែងភាពដែលព្រះដ៏មានព្រះភាគទ្រង់បួសដោយសទ្ធា ។ មានពាក្យអធិប្បាយថា ព្រះអង្គមិនបានត្រូវសេចក្ដីវិនាសណាមួយគ្របសង្កត់ ទ្រង់លះបង់ត្រកូលនោះដែលមិនមានសេចក្ដីវិនាសបាត់បង់សោះឡើយ ហើយទ្រង់បួសដោយសទ្ធា ។ ពាក្យដទៃក្រៅពីនោះ មានអត្ថដែលខ្ញុំពោលហើយនោះឯង ។

ទុតិយាវិភត្តិដែលមាននៅក្នុងបទថា **តំ ខោ បន** នេះ រមែងប្រព្រឹត្តទៅដោយអត្ថដែលពោលដល់ឥត្ថម្ភូត ។ សេចក្ដីថា ឯ ( កិត្តិសព្ទដ៏ល្អ ) របស់

ព្រះគោតមដ៏ចម្រើននោះឯង ( ផ្សាយទៅហើយយ៉ាងនេះថា ... ) ។

បទថា **កល្យាណោ** គឺប្រកបដោយគុណដ៏ល្អ អធិប្បាយថា ប្រសើរ កិត្តិនោះឯង ឬសំឡេងពោលសរសើរ ឈ្មោះថា កិត្តិសព្ទ ។

## ពុទ្ធគុណកថា

ក្នុងពាក្យទាំងឡាយជាដើមថា **ឥតិបិ សោ ភគវា** ជាដើម មានយោជនាជាបឋមដូចតទៅនេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្ត ព្រោះហេតុដូច្នេះ ជាសម្មាសម្ពុទ្ធ ព្រោះហេតុដូច្នេះ ជាបុគ្គលដល់ព្រមដោយវិជ្ជា និងចរណៈ ព្រោះហេតុដូច្នេះ ជាអ្នកមានដំណើរល្អហើយ ព្រោះហេតុដូច្នេះ ព្រោះដឹងច្បាស់នូវលោក ព្រោះហេតុដូច្នេះ ជាអ្នកទូន្មានបុរស ដែលគួរទូន្មានដ៏ប្រសើរ ព្រោះហេតុដូច្នេះ ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រោះហេតុដូច្នេះ ជាអ្នករីកហើយ ព្រោះហេតុដូច្នេះ ជាអ្នកចែកធម៌ ព្រោះហេតុដូច្នេះ មានអធិប្បាយដែលលោកពោលទុកថា ព្រោះហេតុនេះ និងហេតុនេះ ។

ឥឡូវនេះ នឹងធ្វើការពណ៌នាដោយន័យពិស្តារនៃបទទាំងនោះ ដើម្បីភាពជាបុគ្គលឈ្លាសក្នុងសុត្តន្តន័យ និងដើម្បីរីករាយនៃចិត្ត ដោយធម្មីកថាដែលប្រកបដោយពុទ្ធគុណ ក្នុងវារៈនៃការចាប់ផ្ដើមពណ៌នាព្រះវិន័យ នៃអ្នកទ្រទ្រង់វិន័យទាំងឡាយ ។ ព្រោះហេតុនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យដែលលោកពោលទុកថា ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្ត ព្រោះហេតុយ៉ាងនេះ ដូច្នេះជាដើម ។

# អធិប្បាយបទថា អរហំ

ព្រះដ៏មានព្រះភាគអង្គនោះ បណ្ឌិតគប្បីជ្រាបថា ជាព្រះអរហន្ត ព្រោះហេតុទាំងនេះមុន គឺព្រោះជាបុគ្គលឆ្ងាយ និងទ្រង់ទម្លាយសត្រូវទាំងឡាយ និងទ្រង់កាច់បំបាក់នូវចក្រទាំងឡាយ ព្រោះជាបុគ្គលគួរដល់បច្ច័យជាដើម ព្រោះមិនមានការធ្វើបាបក្នុងទីកំបាំង ។

ពិតហើយ ព្រះដ៏មានព្រះភាគអង្គនោះ ជាអ្នកឆ្ងាយ គឺទ្រង់តាំងនៅក្នុងព្រះគុណដែលឆ្ងាយសែនឆ្ងាយអំពីកិលេសសព្វយ៉ាង ព្រោះទ្រង់កម្ចាត់បង់នូវកិលេសទាំងឡាយ ព្រមទាំងវាសនាដោយមគ្គ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះជាអ្នកឆ្ងាយ ។ មួយវិញទៀត សត្រូវ គឺកិលេសទាំង-ឡាយ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់កាច់បំបាក់ហើយដោយមគ្គ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះទ្រង់កម្ចាត់នូវសត្រូវទាំងឡាយ ។ មួយវិញទៀត កាំទាំងអស់នៃសង្សារចក្រ មានដុំដែលសម្រេចដោយអវិជ្ជា និងភវតណ្ហា ពោល គឺអភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម មានខ្នង គឺជរាមរណៈ ដែលដោតទុកក្នុងភ្លៅ សម្រេចដោយអាសវសមុទយៈ ប្រកបចូលទុកក្នុងរថ ពោល គឺភព ៣ ដែលប្រព្រឹត្តទៅហើយ អស់កាលជាអង្វែងមិនមានទីបំផុតខាងដើម ដែលព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឈរជាន់ហើយលើដី គឺ សីល ដោយព្រះបាទទាំងគូ គឺវីរិយៈ ទ្រង់កាន់ពូថៅ គឺញាណដែលធ្វើនូវការអស់ទៅនៃកម្មដោយព្រះហស្ត គឺសទ្ធា ទ្រង់កាច់បំបាក់បង់បានហើយ ក្នុងពោធិមណ្ឌល ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះទ្រង់កាច់បំបាក់សង្សារចក្រហើយ ។

# សង្សារវដ្ត គឺបដិច្ចសមុប្បាទជាបច្ច័យដល់គ្នា

ម្យ៉ាងទៀត សង្សារវដ្ត មិនមានខាងដើម និងខាងចុង ព្រះដ៏មានព្រះភាគ ត្រាស់ហៅថា សង្សារចក្រ ។ ឯអវិជ្ជា ជាដុំរបស់សង្សារចក្រនោះ ព្រោះជាមូល ។ មានជរាមរណៈជាខ្នងកង់ ព្រោះជាទីបំផុត ធម៌ ១០ យ៉ាង ដ៏សេសជាកាំ ព្រោះមានអវិជ្ជាជាមូល និងព្រោះមានជរាមរណៈជាទីបំផុត ។ បណ្តាធម៌ មានអវិជ្ជាជាដើមនោះ ការមិនដឹងក្នុងអរិយសច្ច មានទុក្ខជាដើម ឈ្មោះថា អវិជ្ជា ។ ឯអវិជ្ជាក្នុងកាមភព រមែងជាបច្ច័យដល់សង្ខារទាំង-ឡាយ ក្នុងកាមភព អវិជ្ជាក្នុងរូបភព រមែងជាបច្ច័យដល់សង្ខារទាំងឡាយ ក្នុងរូបភព ។ អវិជ្ជាក្នុងអរូបភព ជាបច្ច័យដល់សង្ខារទាំងឡាយក្នុងអរូបភព ។ សង្ខារក្នុងកាមភព រមែងជាបច្ច័យដល់បដិសន្ធិវិញ្ញាណក្នុងកាមភព ។ ក្នុង រូបភព និងអរូបភព ក៏មានន័យដូច្នេះ ។ បដិសន្ធិវិញ្ញាណ ក្នុងកាមភព រមែងជាបច្ច័យដល់នាមរូបក្នុងកាមភព ។ ក្នុងរូបភពក៏យ៉ាងនោះ ។ រមែង ជាបច្ច័យដល់នាមតែម្យ៉ាងក្នុងអរូបភព ។ នាមរូបក្នុងកាមភព ជាបច្ច័យដល់ អាយតនៈ ៦ ក្នុងកាមភព ។ នាមរូបក្នុងរូបភព រមែងជាបច្ច័យដល់ អាយតនៈទាំង ៣ ក្នុងរូបភព ។ នាមក្នុងអរូបភព រមែងជាបច្ច័យដល់ អាយតនៈតែ ១ ( មនាយតនៈ ) ក្នុងអរូបភព ។ អាយតនៈ ៦ ក្នុងកាម ភព ជាបច្ច័យដល់ផស្សៈ ៦ ក្នុងកាមភព ។ អាយតនៈ ៣ ក្នុងរូបភពជាបច្ច័យ ដល់ផស្សៈ ៣ ក្នុងរូបភព ។ អាយតនៈ ១ ក្នុងអរូបភព រមែងជាបច្ច័យដល់ ផស្សៈ ១ ក្នុងអរូបភព ។ ផស្សៈ ៦ ក្នុងកាមភព រមែងជាបច្ច័យដល់ វេទនា ៦ ក្នុងកាមភព ។ ផស្សៈ ៣ ក្នុងរូបភព ជាបច្ច័យដល់វេទនា ៣

ក្នុងរូបភពនោះឯង ។ ផស្សៈ ១ ក្នុងអរូបភព រមែងជាបច្ច័យដល់វេទនា ១ ក្នុងអរូបភពនោះឯង ។ វេទនា ៦ ក្នុងកាមភព រមែងជាបច្ច័យដល់តណ្ហាកាយ ៦ ក្នុងកាមភព ។ វេទនា ៣ ក្នុងរូបភព ជាបច្ច័យដល់តណ្ហាកាយ ៣ ក្នុងរូបភពនោះឯង ។ វេទនា ១ ក្នុងអរូបភព រមែងជាបច្ច័យដល់តណ្ហាកាយ ១ ក្នុងអរូបភព ។ តណ្ហានោះៗ ក្នុងកាមភពជាដើមនោះៗ រមែងជាបច្ច័យដល់ឧបាទាននោះៗ ។ ឧបាទានជាដើម រមែងជាបច្ច័យដល់ភពជាដើម ។

សេចក្តីនេះដូចម្តេច សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ គិតថា នឹងបរិភោគកាម រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ព្រោះកាមុបាទានជាបច្ច័យ ព្រោះការពេញដោយជុំវិញនៃទុច្ចរិត បុគ្គលនោះរមែងកើតក្នុងអបាយ ។ កម្មជាហេតុកើតក្នុងអបាយនោះនៃបុគ្គលនោះ ជាកម្មភព ការកើតឡើងនៃខន្ធទាំងឡាយ ជាជាតិ ការចាស់នៃកាយ ជាជរា ការបែកធ្លាយ ជាមរណៈ ។

បុគ្គលខ្លះទៀត គិតថា នឹងសោយសម្បត្តិក្នុងស្ថានសួគ៌ ប្រព្រឹត្តសុចរិតយ៉ាងនោះដូចគ្នា ព្រោះការបរិបូណ៌នៃសុចរិត បុគ្គលនោះរមែងកើតក្នុងស្ថានសួគ៌ ។ ពាក្យថា កម្មជាហេតុកើតក្នុងស្ថានសួគ៌របស់បុគ្គលនោះ ជាកម្មភពជាដើម ក៏មានន័យដូចគ្នានោះ ។ ចំណែកបុគ្គលខ្លះទៀត គិតថា នឹងសោយសម្បត្តិក្នុងព្រហ្មលោក រមែងចម្រើនមេត្តា ចម្រើនករុណា មុទិតា ឧបេក្ខា ព្រោះកាមុបាទានជាបច្ច័យ បុគ្គលនោះ រមែងកើតក្នុងព្រហ្មលោក ព្រោះការបរិបូណ៌នៃភាវនា ។ ពាក្យថា កម្មជាហេតុកើតក្នុងព្រហ្មលោកនៃ

បុគ្គលនោះ ជាកម្មភពជាដើម ក៏មានន័យដូចគ្នានេះ ។ បុគ្គលខ្លះទៀត គិតថា នឹងសោយសម្បត្តិក្នុងអរូបភព ទើបចម្រើនសមាបត្តិទាំងឡាយ មានអាកាសានញ្ចាយតនៈជាដើមយ៉ាងនោះឯង ព្រោះការបរិបូណ៌នៃភាវនា បុគ្គលនោះ រមែងកើតក្នុងអរូបភពនោះ ។ កម្មជាហេតុកើតក្នុងអរូបភពនៃបុគ្គលនោះ ជាកម្មភព ខន្ធទាំងឡាយដែលកើតពីកម្ម ជាឧបបត្តិភព ការកើតនៃខន្ធទាំងឡាយ ជាជាតិ ការចាស់នៃកាយ ជាជរា ការបែកធ្លាយ ជាមរណៈ ដូច្នេះ ។ ក្នុងយោជនាទាំងឡាយ មានឧបាទានដ៏សេសជាមូល ក៏មានន័យដូច្នេះ ។

# ធម្មដ្ឋិតិញ្ញាណ

បញ្ញាក្នុងការកំណត់បច្ច័យ ដោយន័យដែលពោលទុកយ៉ាងនេះថា អវិជ្ជា ជាតួហេតុ សង្ខារទាំងឡាយ កើតមកអំពីហេតុ អវិជ្ជា និងសង្ខារទាំង ២ នេះ ក៏ជាហេតុសមុប្បន្នធម៌ ( ធម៌ដែលជាហេតុ និងកើតអំពីហេតុ ) ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ។ បញ្ញាក្នុងការកំណត់បច្ច័យ ដោយន័យដែលលោកពោលយ៉ាងនេះថា អវិជ្ជាទាំងជាអតីតទ្ធា ( អតីតកាល ) ទាំងជាអនាគតទ្ធា ( អនាគតកាល ) ជាតួហេតុ សង្ខារទាំងឡាយកើតមកអំពីហេតុ អវិជ្ជា និងសង្ខារទាំង ២ នេះ ក៏ជាហេតុសមុប្បន្នធម៌ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ដូច្នេះ ។ បទទាំងអស់ បុគ្គលអ្នកសិក្សាគប្បីធ្វើឲ្យពិស្តារដោយន័យដូច្នេះ ។

## សង្ខេប និង អទ្ធាក្នុងបដិច្ចសមុប្បាទ

បណ្តាអង្គនៃបដិច្ចសមុប្បាទនោះ អវិជ្ជា និងសង្ខារ ជាសង្ខេប ១ ។ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ជាសង្ខេប ១ ។ តណ្ហា ឧបាទាន និងភព ជាសង្ខេប ១ ។ ជាតិ និងជរាមរណៈ ជាសង្ខេប ១ ។ ក្នុងសង្ខេប ៤ នោះ សង្ខេបខាងដើម ជាអតីតទ្ធា ។ សង្ខេបកណ្តាល ជាបច្ចុប្បន្នទ្ធា ។ ជាតិ និងជរាមរណៈ ជាអនាគតទ្ធា ។

## វដ្តៈ និង សន្ធិ ៣ ក្នុងបដិច្ចសមុប្បាទ

ម្យ៉ាងទៀត ក្នុងសង្ខេបខាងដើមនោះ តណ្ហា ឧបាទាន និងភព លោកកាន់យកហើយ ដោយសព្ទ គឺអវិជ្ជា និងសង្ខារនោះឯង ព្រោះដូច្នោះ ធម៌ទាំង ៥ នេះ ចាត់ជាកម្មវដ្តៈក្នុងអតីត ។ ធម៌ ៥ យ៉ាង មានវិញ្ញាណជាដើម ចាត់ជាវិបាកវដ្តៈ ក្នុងបច្ចុប្បន្ន ។ អវិជ្ជា និងសង្ខារ លោកកាន់យកហើយ ដោយសព្ទ គឺតណ្ហា ឧបាទាន និងភពនោះឯង ព្រោះដូច្នោះ ធម៌ទាំង ៥ នេះ ចាត់ជាកម្មវដ្តៈ ក្នុងបច្ចុប្បន្ន ។ ធម៌ទាំង ៥ នេះ ចាត់ជាវិបាកវដ្តៈតទៅ ( ក្នុងអនាគត ) ព្រោះអង្គបដិច្ចសមុប្បាទ មានវិញ្ញាណជាដើម លោកសម្តែងលម្អិត ដោយអាងដល់ជាតិ ជរា មរណៈ ។ បដិច្ចសមុប្បាទ មានអវិជ្ជាជាដើមនោះ ពោលដោយអាការ មាន ២០ យ៉ាង ។

ម្យ៉ាងទៀត ក្នុងអង្គបដិច្ចសមុប្បាទ មានសង្ខារជាដើមនេះ ចន្លោះសង្ខារ និងវិញ្ញាណ ជាសន្ធិ ១ ។ ចន្លោះវេទនា និងតណ្ហា ជាសន្ធិ ១ ។ ចន្លោះពីភព និងជាតិ ជាសន្ធិ ១ ដូច្នេះឯង ។ ព្រះដ៏មានព្រះភាគ ទ្រង់ដឹង ទ្រង់ឃើញ ទ្រង់ជ្រាប ទ្រង់ចាក់ធ្លុះបដិច្ចសមុប្បាទនេះ ដែលមានសង្ខេប ៤

អទ្ធា ៣ អាការ ២០ សន្ធិ ៣ ដោយអាការគ្រប់យ៉ាង ដោយប្រការដូច្នេះ ការដឹងនោះ ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹង ( តាមសេចក្តីពិត ) ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងច្បាស់ ព្រោះហេតុនោះ ទើបលោកពោលថា បញ្ញាក្នុងការកំណត់បច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញាណ ។ ព្រះដ៏មានព្រះភាគទ្រង់ដឹងធម៌ទាំងនោះតាមសេចក្តីពិត ដោយធម្មដ្ឋិតិញាណនេះហើយ ទ្រង់នឿយណាយ ប្រាសចាកការពេញចិត្ត និងរួចផុតទៅក្នុងធម៌ មានអវិជ្ជាជាដើមនោះ ទើបបានកាច់បំបាក់ កម្ចាត់បង់នូវកាំទាំងឡាយនៃសង្សារចក្រ មានប្រការដូចពោលហើយនេះ ។ ព្រះអង្គទ្រង់ព្រះនាមថា **អរហំ** ព្រោះទ្រង់កាច់បំបាក់នូវចក្រ ដោយប្រការយ៉ាងនេះ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់គួរទទួលនូវចីវរាទិបច្ច័យ និងសក្ការៈវិសេសទាំងឡាយ ព្រោះព្រះអង្គជាអគ្គទក្ខិណេយ្យ ។ ព្រោះដូច្នោះ ទើបក្នុងកាលព្រះតថាគត ទ្រង់កើតឡើងហើយ ទេវតា និងមនុស្សអ្នកមានសក្តិធំទាំងឡាយ មិនបូជាក្នុងទីដទៃ ។ ពិតហើយ សហម្បតិព្រហ្មបូជាព្រះតថាគតដោយកម្រងកែវប៉ុនភ្នំសិនេរុ ។ ម្យ៉ាងទៀត ទេវតា និងមនុស្សដទៃៗ មានព្រះបាទពិម្ពិសារ និងព្រះបាទបសេនទិកោសលជាដើម ទ្រង់ក៏បូជាហើយតាមកម្លាំង ។ ម្យ៉ាងទៀត ព្រះបាទអសោកមហារាជ ទ្រង់លះបង់ព្រះរាជទ្រព្យដល់ទៅ ៩៦ កោដិ សាងព្រះវិហារ ៨៤០០០ វិហារក្នុងសកលជម្ពូទ្វីប ឧទ្ទិសចំពោះព្រះដ៏មានព្រះភាគ សូម្បីព្រះអង្គបរិនិព្វានហើយ ចាំបាច់ពោលទៅថ្វីដល់ការបូជាវិសេសដទៃៗ នោះ ។ ព្រោះដូច្នោះ

ទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះជាបុគ្គលគួរដល់បច្ច័យជាដើម ។ ម្យ៉ាងទៀត បុគ្គលពាលដែលប្រកាន់ខ្លួនថា ជាបណ្ឌិតឯណានីមួយក្នុងលោក រមែងធ្វើបាបក្នុងទីស្ងាត់ ព្រោះខ្លាចអំពីការតិះដៀល យ៉ាងណា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់រមែងមិនធ្វើដូច្នោះ សូម្បីក្នុងកាលខ្លះនោះឡើយ ព្រោះដូច្នោះទើបទ្រង់ព្រះនាមថា **អរហំ** ព្រោះមិនមានការធ្វើបាបក្នុងទីស្ងាត់ ។ ក្នុងព្រះនាមនេះ មានគាថាប្រព័ន្ធ មានសេចក្ដីដូច្នេះថា

**អារកត្តា ហតត្តា ច  កិលេសារីន សោ មុនិ**
**ហតសំសារចក្ការោ  បច្ចយាទីន ចារហោ**
**ន រហោ ករោតិ បាបានិ  អរហំ តេន វុច្ចតីតិ ។**

ព្រះមុនីអង្គនោះ ព្រោះហេតុតែទ្រង់ឃ្លាតឆ្ងាយ និងទ្រង់កម្ចាត់នូវសត្រូវ គឺកិលេសទាំងឡាយ ទ្រង់ជាអ្នកកាច់បំបាក់កាំនៃសង្សារចក្រ ជាអ្នកគួរដល់បច្ច័យជាដើម ទ្រង់រមែងមិនធ្វើបាបក្នុងទីកំបាំង ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា **អរហំ** ។

# អធិប្បាយបទថា សម្មាសម្ពុទ្ធោ

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគអង្គនោះ ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ ដោយព្រះអង្គឯង ។ ពិតហើយ ព្រះដ៏មានព្រះភាគនោះ ត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯងនូវធម៌ទាំងពួង គឺត្រាស់ដឹងនូវអភិញ្ញេយ្យធម៌ ដោយភាពជាធម៌ដែលគួរដឹងក្រៃលែង ត្រាស់

ដឹងនូវបរិញ្ញេយ្យធម៌ ដោយសភាពជាធម៌ដែលគួរកំណត់ដឹង ត្រាស់ដឹងនូវបហាតព្វធម៌ដោយសភាពធម៌ដែលគួរលះ ត្រាស់ដឹងនូវសច្ឆិកាតព្វធម៌ដោយសភាពជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងនូវភាវេតព្វធម៌ ដោយសភាពជាធម៌ដែលគួរធ្វើឲ្យចម្រើន ដោយហេតុនោះឯង ទើបទ្រង់ត្រាស់ថា

**អភិញ្ញេយ្យំ អភិញ្ញាតំ ភាវេតព្វញ្ច ភាវិតំ**
**បហាតព្វំ បហីនំ មេ តស្មា ពុទ្ធោស្មិ ព្រាហ្មណា ។**

ម្នាលព្រាហ្មណ៍ ទុក្ខសច្ចដែលគួរដឹងច្បាស់ តថាគតបានដឹងច្បាស់ហើយ មគ្គសច្ចដែលគួរចម្រើន តថាគតបានចម្រើនហើយ សមុទយសច្ចដែលគួរលះ តថាគតក៏បានលះហើយ ព្រោះហេតុនោះ ទើបតថាគតជាព្រះពុទ្ធ[១] ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគអង្គនោះ ត្រាស់ដឹងនូវធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ដោយការលើកឡើងត្រង់បទមួយថា ចក្ខុជាទុក្ខ-សច្ច តណ្ហាក្នុងភពមុនដែលញ៉ាំងចក្ខុនោះឲ្យកើត ដោយភាពជាមូលនៃចក្ខុនោះ ជាសមុទយសច្ច ការមិនប្រព្រឹត្តទៅនៃចក្ខុ និងហេតុកើតនៃចក្ខុទាំង ២ ជានិរោធសច្ច គោលបដិបត្តិជាហេតុឲ្យដឹងនិរោធ ជាមគ្គសច្ច ។ ក្នុងសោតៈ ឃានៈ ជិវ្ហា កាយ និងមនៈ ក៏មានន័យដូចគ្នា ។

បណ្ឌិតគប្បីប្រកបអាយតនៈ ៦ មានរូបជាដើម វិញ្ញាណកាយ ៦ មានចក្ខុវិញ្ញាណជាដើម ផស្សៈ ៦ មានចក្ខុសម្ផស្សជាដើម វេទនា ៦ មាន

១- ប៊ិ. ៥៧ គាថាព្រះសេលត្ថេរ ។

ចក្ខុសម្ផស្សជាវេទនាជាដើម សញ្ញា ៦ មានរូបសញ្ញាជាដើម ចេតនា ៦ មានរូបសញ្ចេតនាជាដើម តណ្ហាកាយ ៦ មានរូបតណ្ហាជាដើម វិតក្កៈ ៦ មានរូបវិតក្កៈជាដើម វិចារៈ ៦ មានរូបវិចារៈជាដើម ខន្ធ ៥ មានរូបក្ខន្ធជាដើម កសិណ ១០ អសុភ ១០ អនុស្សតិ ១០ សញ្ញា ១០ ដោយអំណាចឧទ្ធុមាតកសញ្ញាជាដើម អាការ ៣២ មានសក់ជាដើម អាយតនៈ ១២ ធាតុ ១៨ ភព ៩ មានកាមភពជាដើម ឈាន ៤ មានបឋមជ្ឈានជាដើម អប្បមញ្ញា៤ មានមេត្តាភាវនាជាដើម អរូបសមាបត្តិ ៤ មានអាកាសានញ្ចាយតនៈជាដើម និងអង្គនៃបដិច្ចសមុប្បាទ ដោយបដិលោម មានជរាមរណៈជាដើម ដោយអនុលោម មានអវិជ្ជាជាដើម ដោយន័យនេះឯង ។ ក្នុងជរាមរណៈជាដើមនេះ មានការប្រកបបទមួយដូចតទៅនេះថា

ព្រះដ៏មានព្រះភាគអង្គនោះ ត្រាស់ដឹង គឺត្រាស់ដឹងតាមសមគួរ បានដល់ ចាក់ធ្លុះនូវធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ដោយការលើកឡើងត្រង់បទមួយយ៉ាងនេះថា ជរាមរណៈ ជាទុក្ខសច្ច ជាតិ ជាសមុទយសច្ច ការរលាស់ចោលនូវជរាមរណៈ និងហេតុកើតនៃជរាមរណៈទាំង ២ នោះ ជានិរោធសច្ច បដិបទាជាហេតុឲ្យដឹងនិរោធ ជាមគ្គសច្ច ។ ព្រោះដូច្នោះ ទើបខ្ញុំពោលថា ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ។

## អធិប្បាយបទថា វិជ្ជាចរណសម្បន្នោ

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា ដល់ព្រមដោយវិជ្ជា

និងចរណៈ ក៏ព្រោះទ្រង់ដល់ព្រមដោយវិជ្ជា និងចរណៈ ។ ក្នុងវិជ្ជា និងចរណៈ នោះ វិជ្ជា ៣ ក្តី វិជ្ជា ៨ ក្តី ឈ្មោះថា វិជ្ជា ។ វិជ្ជា ៣ គប្បីជ្រាបតាមន័យ ដែលត្រាស់ទុកក្នុងភយភេរវសូត្រនោះឯង ។ វិជ្ជា ៨ មានសម្តែងក្នុងអម្ពដ្ឋសូត្រ ។ ក្នុងវិជ្ជា ៣ និងវិជ្ជា ៨ នោះ វិជ្ជា ៨ ទ្រង់ត្រាស់ប្រមូលអភិញ្ញា ៦ ជាមួយវិបស្សនាញាណ និងមនោមយិទ្ធិចូលគ្នាផងដែរ ។ ធម៌ ១៥ គឺសីលសំវរៈ ភាពជាបុគ្គលមានទ្វារសង្រួមហើយក្នុងឥន្ទ្រិយទាំងឡាយ ភាពជាបុគ្គលដឹងប្រមាណក្នុងភោជន ជាគរិយានុយោគ សទ្ធម្ម ៧ ឈាន ៤ គប្បីជ្រាបថា ជាចរណៈ ។ ពិតហើយ ធម៌ ១៥ នេះឯង ព្រះអង្គត្រាស់ហៅថា ចរណៈ ព្រោះហេតុជាគ្រឿងប្រព្រឹត្តទៅ គឺជាគ្រឿងទៅកាន់ទិស គឺអមតធម៌របស់ព្រះអរិយសាវក ។ ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា បពិត្រមហានាម ព្រះអរិយសាវកក្នុងសាសនានេះ ជាអ្នកមានសីលដូច្នេះជាដើម ។

បុគ្គលអ្នកសិក្សាគប្បីជ្រាបសេចក្តីពិស្តារ ។ ព្រះដ៏មានព្រះភាគ ទ្រង់ប្រកបដោយវិជ្ជាទាំងនេះ និងដោយចរណៈនេះ ព្រោះដូច្នោះ ទើបលោកហៅថា បុគ្គលដល់ព្រមដោយវិជ្ជា និងចរណៈ ក្នុងការដល់ព្រមដោយវិជ្ជា និងចរណៈនោះ ការដល់ព្រមដោយវិជ្ជា ញុំាងភាពដែលព្រះដ៏មានព្រះភាគឲ្យបានជាព្រះសព្វញ្ញូពេញបរិបូណ៌ ។ ការដល់ព្រមដោយចរណៈ ញុំាងព្រះមហាករុណាព្រះអង្គឲ្យពេញបរិបូណ៌ ។ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ស្គាល់វត្ថុដែលជាប្រយោជន៍ និងមិនមែនប្រយោជន៍ដល់សព្វសត្វ ដោយភាពជាសព្វញ្ញូ ហើយទ្រង់វៀររបស់ដែលមិនមែនប្រយោជន៍ ដោយភាពជា

អ្នកប្រកបដោយព្រះមហាករុណា ទ្រង់ដឹកនាំក្នុងរបស់ដែលជាប្រយោជន៍ ដូចអ្នកដែលដល់ព្រមដោយវិជ្ជា និងចរណៈដូច្នោះឯង ។ ព្រោះហេតុនោះ ទើបពួកសាវ័ករបស់ព្រះដ៏មានព្រះភាគអង្គនោះ ជាអ្នកបដិបត្តិល្អ មិនជាអ្នកបដិបត្តិអាក្រក់ទេ ។ ពួកសាវ័ករបស់ព្រះដ៏មានព្រះភាគអង្គនោះ មិនជាអ្នកបដិបត្តិអាក្រក់ ដូចពួកសាវ័ករបស់ពួកបុគ្គលដែលមានវិជ្ជា និងចរណវិបត្តិធ្វើខ្លួនឲ្យក្តៅក្រហាយជាដើមដូច្នោះឡើយ ។

# អធិប្បាយបទថា សុគតោ

សម្តេចព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **សុគតោ** គឺ **សោភណគមនត្តា** ព្រោះភាវៈដែលទ្រង់មានដំណើរល្អ **សុន្ទរំ ឋានំ** ព្រោះភាវៈដែលទ្រង់ទៅកាន់ស្ថានទីល្អ **គតត្តា** ព្រោះភាវៈដែលទ្រង់ទៅដោយប្រពៃ **សម្មាគតត្តា** ព្រោះភាវៈដែលត្រាស់ទុកដោយប្រពៃ ។ សូម្បី **គមនំ** នឹងពោលថា **គតំ** ក៏បាន ។ ការយាងនោះរបស់ព្រះដ៏មានព្រះភាគល្អស្អាត មិនមានទោស ។ ព្រះដំណើរនោះបានដល់អ្វី បានដល់ ផ្លូវដ៏ប្រសើរ ។ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ទៅកាន់ទិសក្សេម មិនជាប់ជំពាក់ដោយព្រះដំណើរនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះភាវៈដែលទ្រង់មានដំណើរទៅល្អ ។ម្យ៉ាងទៀត ទ្រង់យាងទៅកាន់ទីល្អ គឺអមតមហានិព្វាន ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះទ្រង់ទៅកាន់ស្ថានទីល្អ ។ម្យ៉ាងទៀត ព្រះអង្គទ្រង់ទៅដោយប្រពៃ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះទ្រង់មិនត្រឡប់មករកកិលេសទាំងឡាយ ដែលមគ្គនោះ

លះបានហើយ ។ សមដូចពាក្យដែលលោកពោលទុកថា ទ្រង់ព្រះនាមថា **សុគតោ** ព្រោះអត្ថថា មិនត្រឡប់មក មិនឡើងមក មិនវិលមករកកិលេស ទាំងឡាយ ដែលសោតាបត្តិមគ្គលះបានហើយ ។បេ។ ទ្រង់ព្រះនាមថា **សុគតោ** ព្រោះអត្ថថា មិនត្រឡប់ មិនឡើងមក មិនវិលមករកកិលេស ទាំងឡាយ ដែលអរហត្តមគ្គលះបានហើយ ។ ប្រការមួយទៀត ទ្រង់យាង ទៅដោយប្រពៃ គឺយាងទៅធ្វើប្រយោជន៍ និងសេចក្ដីសុខដល់លោកទាំង អស់តែម្យ៉ាង ដោយការបដិបត្តិប្រពៃដែលទ្រង់បំពេញមក ដោយអំណាច បារមី ៣០ កំណត់ចាប់ផ្ដើមតាំងអំពីបាទមូលរបស់ព្រះពុទ្ធទីបង្ករ រហូតដល់ មណ្ឌលពោធិព្រឹក្ស និងទ្រង់មិនយាងចូលទៅជិតចំណែកជាទីបំផុតទាំងនេះ គឺសស្សត ឧច្ឆេទ កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ ព្រោះហេតុ នោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះទ្រង់ទៅដោយប្រពៃ ។ ម្យ៉ាង ទៀត ព្រះដ៏មានព្រះភាគអង្គនោះត្រាស់ទុកដោយប្រពៃ គឺត្រាស់ព្រះវាចា ដែលគួរក្នុងឋានៈដែលគួរប៉ុណ្ណោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **សុគតោ** ព្រោះមានព្រះតម្រាស់ប្រពៃ ។

ក្នុងសេចក្ដីនោះ មានព្រះសូត្រជាសាធកៈដូចតទៅនេះថា ( ម្នាលព្រះ រាជកុមារយ៉ាងហ្នឹងឯង ) តថាគតដឹងនូវវាចាណា ដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់ជនទាំងឡាយដទៃផង តថាគតក៏មិនពោលវាចានោះ តថាគតដឹងនូវ វាចាណាដែលពិត ទៀង តែមិនប្រកបដោយប្រយោជន៍ និងវាចានោះ មិន

ជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃផង ព្រះតថាគតក៏មិនពោលនូវវាចានោះដែរ មួយវិញទៀត តថាគតដឹងនូវវាចាណាដែលពិត ទៀង ប្រកបដោយប្រយោជន៍ តែថា វាចានោះ មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគតស្គាល់កាលគួរនឹងពោលវាចានោះ ក្នុងព្យាករណ៍នោះដែរ តថាគតដឹងនូវវាចាណាដែលមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ វាចានោះ ទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំង-ឡាយដទៃ តថាគតក៏មិនពោលវាចានោះឡើយ ។ តថាគតដឹងនូវវាចាណាដែលពិត ទៀង តែមិនប្រកបដោយប្រយោជន៍ វាចានោះ ទោះបីជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃ តថាគតក៏មិនពោលវាចានោះដែរ ។ មួយវិញទៀត តថាគតដឹងនូវវាចាណាដែលពិត ទៀង ប្រកបដោយប្រយោជន៍ វាចានោះ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនទាំងឡាយដទៃផង តថាគតស្គាល់កាលគួរនឹងពោលនូវវាចានោះ ក្នុងព្យាករណ៍នោះ[១] ។

ព្រះដ៏មានព្រះភាគអង្គនោះ បណ្ឌិតគប្បីជ្រាបថា **សុគតោ** ព្រោះត្រាស់វាចាប្រពៃ ដោយប្រការដូច្នេះ ។

## អធិប្បាយបទថា លោកវិទូ

ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គទ្រង់ដឹងច្បាស់នូវលោក ដោយប្រការគ្រប់យ៉ាង ។ ពិតហើយ ព្រះដ៏មានព្រះភាគ

---

១- ម. ២៣ អភយរាជកុមារសូត្រ ។

អង្គនោះ ទ្រង់ដឹង គឺទ្រង់ដឹងទូទៅ ទ្រង់ចាក់ធ្លុះនូវលោក ដោយប្រការទាំង ពួង ដោយសភាវៈខ្លះ ដោយសមុទយៈខ្លះ ដោយនិរោធខ្លះ ដោយឧបាយជា ហេតុដល់នូវនិរោធខ្លះ ។ ដូចព្រះតម្រាស់ត្រាស់ថា ម្នាលអាវុសោ បុគ្គល មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិ ក្នុងសង្ខារលោកណា តថាគតមិនបានពោលថា បុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់នូវទីបំផុត នៃសង្ខារលោកនោះ ដោយកិរិយាដើរទៅ ( ដោយជើង ) បានឡើយ ។ ម្នាលអាវុសោ មួយទៀត បើតថាគតមិនបានដល់នូវទីបំផុត នៃសង្ខារលោក ហើយ ក៏មិនបានពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខឡើយ ម្នាលអាវុសោ មួយទៀត តថាគតតែងបញ្ញត្តនូវលោកផង លោកសមុទយៈផង លោកនិរោធ ផង លោកនិរោធគាមិនីបដិបទាផង ក្នុងអត្តភាពប្រមាណមួយព្យាមនេះឯង ដែលប្រកបដោយសញ្ញាផង ប្រកបដោយចិត្តផង ។

> ទីបំផុតនៃលោក បុគ្គលមិនគប្បីដល់ដោយការដើរទៅ ( ដោយជើង )
> ក្នុងកាលណាមួយឡើយ មួយទៀត ការមិនទាន់ដល់នូវទីបំផុតនៃលោក
> ឈ្មោះថា មិនបានរួចចាកទុក្ខឡើយ ព្រោះហេតុនោះឯង ព្រះមាន
> ព្រះភាគ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់មានបញ្ញាល្អ ទ្រង់ដល់នូវ
> ទីបំផុតនៃលោក ទ្រង់ប្រព្រឹត្តចប់ព្រហ្មចរិយៈហើយ ។ ទ្រង់មានបាប
> រម្ងាប់បង់ហើយ ទ្រង់ជ្រាបច្បាស់នូវទីបំផុតនៃលោកហើយ មិន
> ប្រាថ្នានូវលោកនេះ និងលោកខាងមុខឡើយ[1] ។

---

១- បិ. ៤២ រោហិតស្សវគ្គ ។

# អធិប្បាយបទថា លោក ៣

ម្យ៉ាងទៀត លោកមាន ៣ គឺសង្ខារលោក ១ សត្វលោក ១ ឱកាសលោក ១ ។

បណ្ដាលោកទាំង ៣ នោះ លោកក្នុងអាគតដ្ឋានថា លោក ១ គឺសត្វទាំងអស់តាំងនៅបាន ព្រោះអាហារ ដូច្នេះ គប្បីជ្រាបថា ជាសង្ខារលោក ។ លោកក្នុងអាគតដ្ឋានថា លោកទៀង ឬថា លោកមិនទៀង ដូច្នេះជាដើម គប្បីជ្រាបថា ជាសត្វលោក លោកក្នុងអាគតដ្ឋានថា

ព្រះចន្ទ និងព្រះអាទិត្យ ដើរបំភ្លឺទិសទាំងឡាយ ឲ្យភ្លឺបានត្រឹមណា លោក គឺចក្រវាលទាំង ១០០០ ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅបានត្រឹមតែ ១០០០ ចក្រវាលនោះ ដូច្នេះ គប្បីជ្រាបថា ជាឱកាសលោក[១] ។

ព្រះដ៏មានព្រះភាគ ទ្រង់បានដឹងច្បាស់នូវលោកទាំង ៣ នោះ ដោយប្រការទាំងពួង ។ ពិតហើយ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់បានដឹងច្បាស់នូវសង្ខារលោកនេះ ដោយប្រការទាំងពួង គឺលោក ១ បានដល់ពួកសត្វទាំងអស់ តាំងនៅបានដោយអាហារ លោក ២ បានដល់ នាម ១ រូប ១ លោក ៣ បានដល់ វេទនា ៣ លោក ៤ បានដល់ អាហារ ៤ លោក ៥ បានដល់ ឧបាទានក្ខន្ធ ៥ លោក ៦ បានដល់ អាយតនៈខាងក្នុង ៦ លោក ៧ បានដល់ វិញ្ញាណដ្ឋិតិ ៧ លោក ៨ បានដល់ លោកធម៌ ៨ លោក ៩ បានដល់ សត្តាវាស ៩ លោក ១០ បានដល់ អាយតនៈ

---

១- បិ. ២២ ព្រហ្មនិមន្តនិកសូត្រ ។

១០ លោក ១២ បានដល់ អាយតនៈ ១២ លោក ១៨ បានដល់ ធាតុ ១៨ ។

ម្យ៉ាងទៀត ព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ជ្រាបអាសយៈ ( គឺឆន្ទៈដែលដេកត្រាំ ) អនុស័យ ( គឺកិលេសដែលដេកត្រាំក្នុងសន្តាន ) ចរិត ( គឺការប្រព្រឹត្ត ) អធិមុត្តិ ( គឺអធ្យាស្រ័យ ) របស់សត្វទាំងពួង ( និង ) ទ្រង់ជ្រាបសត្វទាំងឡាយ ដែលមានធូលី គឺកិលេសក្នុងបញ្ញាចក្ខុតិច បុគ្គលមានធូលី គឺកិលេសក្នុងបញ្ញាចក្ខុច្រើន បុគ្គលមានឥន្ទ្រិយចាស់ក្លា បុគ្គលមានឥន្ទ្រិយទន់ បុគ្គលមានអាការល្អ បុគ្គលមានអាការអាក្រក់ បុគ្គលគប្បីឲ្យដឹងបានងាយ បុគ្គលគប្បីឲ្យដឹងបានលំបាក បុគ្គលគួរ ( នឹងត្រាស់ដឹង ) បុគ្គលមិនគួរ ( នឹងត្រាស់ដឹង ) ព្រោះដូច្នោះ សត្វលោកដែលព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ដឹងច្បាស់ហើយ ដោយប្រការទាំងពួង ។ ពិតហើយ ព្រះអង្គទ្រង់ដឹងច្បាស់នូវសត្វលោក យ៉ាងណា សូម្បីឱកាសលោក ក៏ទ្រង់ដឹងច្បាស់ហើយ ដូច្នោះ ។ ពិតហើយ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បានដឹងច្បាស់ គឺទ្រង់បានជ្រាប បានដល់ ទ្រង់ចាក់ធ្លុះហើយ នូវលោកធាតុដែលមិនមានទីបំផុត ដោយព្រះពុទ្ធញាណដែលមិនមានទីបំផុត រហូតអនន្តចក្រវាល យ៉ាងនេះ គឺចក្រវាលមួយ បើពោលដោយបណ្តោយ និងទទឹងមានប្រមាណ ១ លាន ២ សែន ៣ ពាន់ ៤ រយ ៥០ យោជន៍ លោកពោលប្រមាណដោយជុំវិញ ។

ចក្រវាលមានបរិមណ្ឌលទាំងមូល ៣ លាន ៦ សែន ១ ម៉ឺន ៣ រយ ៥០ យោជន៍ ផែនដីក្នុងចក្រវាលនោះ បណ្ឌិតពោលទុកដោយកម្រាស់ មាន

ប្រមាណ ២៤០០០០ យោជន៍ ។

ទឹកសម្រាប់ទ្រផែនដី មានប្រមាណ ៤៨០០០០ យោជន៍នោះឯង ដោយកម្រាស់ក៏មានប្រមាណប៉ុណ្ណោះ តាំងនៅលើខ្យល់ ។ ខ្យល់សម្រាប់ទ្រទឹកនោះ បក់ឡើងដល់ផ្ទៃមេឃ កម្ពស់ ៩៦០០០០ យោជន៍ ការតាំងនៅនៃលោក ដូច្នេះ ។

ក្នុងចក្រវាលនេះ ដែលតាំងនៅហើយយ៉ាងនេះ មានភ្នំសិនេរុខ្ពស់ជាងបណ្ដាភ្នំទាំងឡាយ ចាក់ចុះក្នុងមហាសមុទ្រ ជម្រៅ ៨៤០០០ យោជន៍ កម្ពស់ ( ឡើងលើ ) ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ។

បណ្ដាភ្នំធំទាំង ៧ គឺភ្នំយុគន្ធរ ១ ភ្នំឥសិន្ធរ ១ ភ្នំករវិក ១ ភ្នំសុទស្សនៈ ១ ភ្នំនេមិន្ធរ ១ ភ្នំវិនតកៈ ១ ភ្នំអស្សកណ្ណ ១ ជាភ្នំទិព្វវិចិត្រដោយរតនៈផ្សេងៗ ចាក់ចុះ ( ក្នុងបំសុបឋវី ) និងខ្ពស់ឡើងទៅតាមលំដាប់ដោយប្រមាណពាក់កណ្ដាលៗ នៃប្រមាណភ្នំសិនេរុ ដែលពោលហើយ ទាំងខាងក្រោម និងខាងលើនោះ ជាទីលំនៅរបស់ទេវមហារាជ ( ទាំង ៤ ) មានទេវតា និងយក្ខអាស្រ័យនៅរៀងៗ គ្នា ជុំវិញភ្នំសិនេរុ ដោយអំណាចនៃការព័ទ្ធជុំវិញ ។

ភ្នំហេមពាន្ត កម្ពស់ ៥០០ យោជន៍ បណ្ដោយ និងទទឹង ៣០០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤០០០ កំពូល ។

ជម្ពូទ្វីបលោកប្រកាសហើយ ដោយអានុភាពនៃដើមជម្ពូណា ដើមជម្ពូដែលឈ្មោះថា **នគៈ** នោះ វាស់ដោយទំហំដើម ប្រមាណ ១៥ យោជន៍

ប្រវែងដើម និងមែកប្រមាណ ៥០ យោជន៍ បរិមណ្ឌលជុំវិញប្រមាណ ១០០ យោជន៍ និងកម្ពស់ឡើងទៅ ( ខាងលើ ) ក៏មានប្រមាណប៉ុណ្ណោះឯង ។

ភ្នំកណ្ដាប់ចក្រវាលចាក់ចុះក្នុងបាតសមុទ្រ ៨២០០០ យោជន៍ កម្ពស់ឡើងទៅលើក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ភ្នំកណ្ដាប់ចក្រវាលនេះតាំងនៅព័ទ្ធជុំវិញលោកធាតុទាំងអស់នោះ ។

ក្នុងលោកធាតុនោះ ព្រះចន្ទ ( វាស់ដោយវិជ្ជមាត្រ ៤៩ យោជន៍ ) ព្រះអាទិត្យប្រមាណ ៥០ យោជន៍ ភពតាវត្តិំងស្រប្រមាណ ១០០០០ យោជន៍ ភពអាសុរ អវិចីមហានរក និងជម្ពូទ្វីបក៏មានប្រមាណប៉ុណ្ណោះ អមរគោ-យានទ្វីប មានប្រមាណ ៧ ពាន់យោជន៍ បុព្វវិទេហទ្វីបក៏មានប្រមាណប៉ុណ្ណោះ ឧត្តរកុរុទ្វីប ប្រមាណ ៨ ពាន់យោជន៍ ឯទ្វីបធំៗ ក្នុងលោកធាតុនេះ ទ្វីបនីមួយៗ មានទ្វីបតូចជាបរិវារ ៥ រយៗ ។ ចក្កវាឡ ១ គឺសម្ភារៈទាំងអស់នោះ ឈ្មោះថា លោកធាតុ ១ ក្នុងចន្លោះនៃចក្កវាឡទាំងនោះ ជាលោកន្តរិកនរក ។ ឱកាសលោកដែលព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ដឹងច្បាស់ហើយដោយប្រការទាំងពួង ដោយប្រការយ៉ាងនេះ ។ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះទ្រង់ដឹងច្បាស់នូវលោក ដោយប្រការទាំងពួង ដូចពណ៌នាមក ដូច្នេះ ។

## អធិប្បាយ បទថា អនុត្តរោ

បទថា **អនុត្តរោ** សេចក្ដីថា បុគ្គលប្រសើរក្រៃលែងជាង ឈ្មោះថា

រមែងមិនមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រោះមិនមានបុគ្គលណាដែលប្រសើរជាងព្រះអង្គដោយគុណរបស់ខ្លួន ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អនុត្តរោ** ( មិនមានបុគ្គលក្រៃលែងជាង ) ។ ពិតហើយ ព្រះដ៏មានព្រះភាគអង្គនោះ រមែងគ្របសង្កត់នូវលោកទាំងអស់ដោយព្រះគុណ គឺសីលផង ដោយគុណ គឺសមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈផង ។ ព្រះដ៏មានព្រះភាគអង្គនោះមិនមានបុគ្គលស្មើ រកបុគ្គលស្មើមិនបាន រកបុគ្គលប្រៀបមិនបាន មិនមានបុគ្គលប្រៀប រកបុគ្គលប្រៀបផ្ទឹមមិនបាន ដោយព្រះគុណ គឺសមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈផងដែរ ។ ដូចព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមើលមិនឃើញសមណៈ ឬព្រាហ្មណ៍ដទៃឡើយ ដែលទឹងសម្បូរដោយសីលក្រៃលែងជាងតថាគត ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។ គួរជ្រាបសេចក្តីពិស្តារ ( នៃព្រះសូត្រនោះ ) ។ ព្រះសូត្រទាំងឡាយ មានអគ្គប្បសាទសូត្រជាដើម មានគាថាជាដើមថា តថាគតមិនមានអាចារ្យទេ ដូច្នេះ ក៏គួរឲ្យពិស្តារតាមន័យដែលពោលមកហើយនោះ ។

# អធិប្បាយបទថា បុរិសទម្មសារថិ

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះអត្ថវិគ្គហៈថា ញ៉ាំងបុរសដែលល្មមទូន្មានបាន ឲ្យស្ទុះទៅ ។ អធិប្បាយថា រមែងទូន្មាន គឺដឹកនាំ ។ សត្វតិរច្ឆានឈ្មោលក្តី មនុស្សប្រុសក្តី អមនុស្ស

ប្រុសក្តី ដែលមិនទាន់បានទូន្មាន គួរដើម្បីនឹងទូន្មានបាន ឈ្មោះថា **បុរិសធម្មា** ក្នុងពាក្យថា **បុរិសធម្មសារថិ** នោះ ។ ពិតហើយ សូម្បីសត្វតិរច្ឆានឈ្មោល គឺអបលាលនាគរាជ ចូឡោទរនាគរាជ មហោទរនាគរាជ អគ្គិសិខនាគរាជ ធូមសិខនាគរាជ អាលវាឡនាគរាជ ( និង ) ដំរីធនបាល ដែលព្រះដ៏មានព្រះភាគអង្គនោះទ្រង់ទូន្មានហើយ គឺទ្រង់ធ្វើឲ្យអស់ពុស ហើយឲ្យតាំងនៅក្នុងសរណៈ និងសីលទាំងឡាយ ។ សូម្បីមនុស្សប្រុស មានសច្ចកនិគណ្ឋបុត្រ អម្ពដ្ឋមាណព បោក្ខរសាតិព្រាហ្មណ៍ សោណទណ្ឌព្រាហ្មណ៍ និងកូដទន្តព្រាហ្មណ៍ ក៏ព្រះដ៏មានព្រះភាគទ្រង់ទូន្មានហើយ ។ សូម្បីអមនុស្សប្រុស មានអាឡវកយក្ខ សូចិលោមយក្ខ ខរលោមយក្ខ និងសក្កទេវរាជជាដើម ដែលព្រះដ៏មានព្រះភាគទ្រង់ទូន្មានហើយ គឺទ្រង់ដឹកនាំហើយ ដោយឧបាយជាគ្រឿងដឹកនាំដ៏វិចិត្រ ។ ឯក្នុងសេចក្តីនេះ គួរញ៉ាំងព្រះសូត្រនេះឲ្យពិស្តារ ដូច្នេះ ម្នាលកេសី តថាគតរមែងណែនាំបុរសដែល គួរទូន្មានដោយល្អខ្លះ ដោយអាក្រក់ខ្លះ ដោយល្អ និងអាក្រក់ខ្លះ ។

ម្យ៉ាងទៀត ពីរបទថា **អនុត្តរោ បុរិសធម្មសារថិ** នេះ រួមជា ១ បទក៏បាន ពិតហើយ ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងបុរសដែលគួរទូន្មានបាន ឲ្យស្ទុះទៅ ដូចព្រះពុទ្ធទាំងឡាយប្រថាប់គង់នៅដោយបល្ល័ង្កមួយប៉ុណ្ណោះ ទ្រង់ស្ទុះទៅបាន មិនទើសទាក់ក្នុងទិសទាំង ៨ ដូច្នោះ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគ បណ្ឌិតហៅថា **អនុត្តរោ បុរិសធម្មសារថិ** ។ ក្នុងអត្ថនេះ គួរញ៉ាំងព្រះសូត្រនេះឲ្យពិស្តារដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ដំរីគួរទូន្មាន ដែល

ទម័កដីរបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី តែម្តងបាន ។

## អធិប្បាយបទថា សត្ថា

ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **សត្ថា** ( ជាព្រះសាស្តា ) ព្រោះអត្ថវិគ្គហៈថា ទ្រង់ប្រៀនប្រដៅ ( សត្ថសត្វ ) ទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍តាមសមគួរ ។ ម្យ៉ាងទៀត ក្នុងបទថា **សត្ថា** នេះ គប្បីជ្រាបនិទ្ទេសន័យជាដើមយ៉ាងនេះថា ពាក្យថា **សត្ថា** បានដល់ ព្រះដ៏មានព្រះភាគទ្រង់ជាសត្ថាវាហៈ គឺនាយនាំពួក ។ ពិតហើយ នាយនាំពួក រមែងនាំពួកឲ្យឆ្លងផ្លូវចោរកន្តារ ( កន្តារ គឺផ្លូវចោរ ) ឲ្យឆ្លងវាឡកន្តារ ( កន្តារ គឺសត្វសាហាវ ) ឲ្យឆ្លងទុព្ភិក្ខកន្តារ ( កន្តារ គឺផ្លូវដាច់បាយ ) ឲ្យឆ្លងនិរុទកកន្តារ( កន្តារ គឺផ្លូវអត់ទឹក ) គឺរមែងឲ្យឆ្លងផុត ឲ្យឆ្លងទៅ ឲ្យឆ្លងដល់ បានដល់ ឲ្យសម្រេចដល់ទឹកដីដែលក្សេម យ៉ាងណា ព្រះដ៏មានព្រះភាគ ក៏ដូច្នោះដូចគ្នា ទ្រង់ជាព្រះសាស្តា គឺទ្រង់ដូចជាមគ្គុទ្ទេសក៍ធ្វើពួកឲ្យឆ្លងផ្លូវកន្តារ បានដល់ ឲ្យឆ្លងជាតិកន្តារជាដើម ។

## អធិប្បាយបទថា ទេវមនុស្សានំ

បទថា **ទេវមនុស្សានំ** ប្រែថា របស់ទេវតាទាំងឡាយផង របស់មនុស្សទាំងឡាយផង ។ ពាក្យថា **ទេវមនុស្សានំ** នេះ ខ្ញុំពោលដោយអំណាចការកំណត់សត្វជាន់ខ្ពស់ និង ដោយអំណាចការកំណត់ភព្វបុគ្គល ( បុគ្គលដែលគួរត្រាស់ដឹងមគ្គផល ) ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ ឈ្មោះថា ទ្រង់ជាព្រះសាស្តារបស់ពួកសត្វតិរច្ឆាន ព្រោះទ្រង់ប្រទានអនុសាសនីឲ្យដូចគ្នា ។ ពិតហើយ សត្វតិរច្ឆានទាំងនោះ សម្រេចឧបនិស្សយសម្បត្តិ ក៏ព្រោះបានស្តាប់ធម៌របស់ព្រះដ៏មានព្រះភាគ រមែងជាបុគ្គលមានចំណែកនៃមគ្គ និងផល ក្នុងភពទី ២-៣ ព្រោះឧបនិស្សយសម្បត្តិនោះឯង ។ ក្នុងភាពជាព្រះសាស្តារបស់ពួកសត្វតិរច្ឆាននេះ មានមណ្ឌូកទេវបុត្រជាដើម ជាឧទាហរណ៍ ។

## រឿងមណ្ឌូកទេវបុត្រ

បានឮថា កាលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ដល់អ្នកនគរចម្ប៉ា ត្រង់មាត់ច្រាំងស្រះបោក្ខរណី ឈ្មោះគគ្គរា មានកង្កែបមួយ បានកាន់យកនិមិត្តក្នុងសំឡេងរបស់ព្រះដ៏មានព្រះភាគ ( ដែលទ្រង់កំពុងសម្តែងធម៌ ) ។ ( ខណៈនោះ ) មានអ្នកចិញ្ចឹមគោម្នាក់ កាលនឹងដាក់ឈើច្រត់ បានឈរសង្កត់ត្រង់ក្បាលកង្កែបនោះ ។ កង្កែបនោះក៏ស្លាប់ក្នុងរំពេចនោះឯង ហើយកើតក្នុងវិមានមាសប្រមាណ ១២ យោជន៍ ក្នុងតាវត្តិង្សពិភព ដូចដេកលក់ហើយភ្ញាក់ឡើងដូច្នោះ ។ ក្នុងពិភពតាវត្តិង្សនោះ មណ្ឌូកទេវបុត្រឃើញខ្លួនឯង ដែលពួកស្រីទេពអប្សរចោមរោមហើយ ពិចារណាថា ឱ ! ហេតុអ្វីទើបអញមកកើតក្នុងទីនេះ បានធ្វើកម្មដូចម្តេចហ្ន៎ ក៏មិនបានឃើញកម្មដទៃណា ក្រៅអំពីការកាន់យកនិមិត្តក្នុងសំឡេងរបស់ព្រះដ៏មានព្រះភាគ ( ប៉ុណ្ណោះ )។ ទើបមណ្ឌូកទេវបុត្រមកព្រមទាំងវិមានក្នុងរំពេចនោះឯង ហើយថ្វាយបង្គំព្រះយុគលបាទរបស់ព្រះដ៏មានព្រះភាគ ដោយសិរសា គឺត្បូង ។ ព្រះដ៏មានព្រះ

ភាគ ទ្រង់ជ្រាបស្រាប់ហើយនោះឯង ( តែ ) ត្រាស់សួរថា

អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ ដោយយស មានសម្បុរដ៏

ល្អ ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។

មណ្ឌូកទេវបុត្រក្រាបទូលថា

ក្នុងកាលមុន ខ្ញុំព្រះអង្គជាកង្កែប នៅក្នុងទឹក មានវារីជាទី

គោចរ កាលខ្ញុំព្រះអង្គកំពុងតែស្តាប់ធម៌របស់ព្រះអង្គ នាយ

គោបាលបានសម្លាប់ខ្ញុំ[១] ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ដល់មណ្ឌូកទេវបុត្រនោះហើយ ។ សត្វចំនួន ៨៤០០០ បានសម្រេចធម៌ ។ ចំណែកទេវបុត្រ ក៏តាំងនៅក្នុងសោតាបត្តិផល បានរីករាយហើយ ក៏ចៀសចេញទៅ ដូច្នេះ ។

## អធិប្បាយបទថា ពុទ្ធោ

ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **ពុទ្ធោ** ដោយអំណាចញាណដែលកើតក្នុងទីបំផុតនៃវិមោក្ខ ព្រោះបានឈ្មោះថា ញេយ្យធម៌ណាៗ ដែលមានទាំងអស់ ដែលព្រះអង្គត្រាស់ដឹងហើយ ។ម្យ៉ាងទៀត ព្រោះព្រះអង្គត្រាស់ដឹងអរិយសច្ច ៤ ដោយព្រះអង្គឯងខ្លះ ទ្រង់ញុំាងសត្វដទៃឲ្យត្រាស់ដឹងខ្លះ ដូច្នោះ ទើបទ្រង់ព្រះនាម **ពុទ្ធោ** ព្រោះហេតុជាដើមយ៉ាងនេះ ។ ដើម្បីឲ្យជ្រាបសេចក្តីនេះជាក់ច្បាស់ បណ្ឌិតគួរពង្រីកនិទ្ទេសន័យ ឬបដិសម្ភិទាន័យទាំងអស់ដែលប្រព្រឹត្តទៅហើយ ឲ្យពិស្តារយ៉ាងនេះថា ព្រះដ៏មានព្រះភាគ

---

១- បិ. ៥៥ មណ្ឌូកទេវបុត្តវិមាន ។

អង្គនោះ ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះត្រាស់ដឹងសច្ចៈទាំងឡាយ ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះទ្រង់ញ៉ាំងសត្វទាំងឡាយឲ្យត្រាស់ដឹង ដូច្នេះ ។

## អធិប្បាយបទថា ភគវា

ពាក្យថា **ភគវា** នេះ ជាពាក្យហៅព្រះអង្គ ដោយភាពជាបុគ្គលវិសេសដោយគុណ ជាបុគ្គលឧត្តមជាងសត្វ និងជាបុគ្គលគួរគោរពដោយឋានៈជាគ្រូ ។ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

ពាក្យថា ភគវា ជាពាក្យប្រសើរឧត្តម ពាក្យថា ភគវា
ជាពាក្យប្រសើរបំផុត ព្រោះព្រះអង្គគួរដល់ការគោរព
ដោយឋានៈជាគ្រូ ទើបបណ្ឌិតហៅថា ភគវា ។

## ឈ្មោះមាន ៤ យ៉ាង

ពិតហើយ ឈ្មោះមាន ៤ យ៉ាង គឺ អវត្ថិកនាម លិង្គិកនាម នេមិត្តកនាម អធិច្ចសមុប្បន្ននាម ។ មានពាក្យអធិប្បាយថា នាមដែលតាំងតាមសេចក្តីប្រាថ្នា តាមវោហាររបស់លោក ឈ្មោះថា អធិច្ចសមុប្បន្ននាម ។ ក្នុងនាម ៤ នោះ ពាក្យយ៉ាងនេះជាដើម គឺកូនគោ គោស្ទាវ គោប្រើ ជាអវត្ថិកនាម ( នាមដែលបញ្ញត្តអាស្រ័យការកំណត់ ) ។ ពាក្យយ៉ាងនេះជាដើម គឺមានឈើច្រត់ មានឆត្រ មានសិរ មានប្រមោយ ជាលិង្គិកនាម ( នាមដែលហៅតាមហេតុ ឬលក្ខណៈ ) ។ ពាក្យយ៉ាងនេះជាដើម គឺមានវិជ្ជា ៣ មានអភិញ្ញា ៦ ជានេមិត្តកនាម ( នាមដែលកើតឡើងដោយគុណនិមិត្ត ) ។ ពាក្យយ៉ាងនេះជាដើម គឺ សិរិវឌ្ឍកោ ធនវឌ្ឍកោ ដែលប្រព្រឹត្ត

ទៅមិនគិតដល់អត្ថរបស់ពាក្យ ជាអធិច្ចសមុប្បន្ននាម ( នាមដែលតាំងតាមពេញចិត្ត ) ។ តែព្រះនាមថា **ភគវា** នេះ ជានេមិត្តកនាម ព្រះនាងមហាមាយាក៏មិនបានថ្វាយ ព្រះបាទសុទ្ធោទនមហារាជក៏មិនបានថ្វាយ ព្រះញាតិ ៨ ម៉ឺន ក៏មិនបានថ្វាយ ទេវតាវិសេសទាំងឡាយ មានសក្កទេវរាជ និងសន្តុសិតជាដើម ក៏ទ្រង់មិនបានថ្វាយ ។ ពិតហើយ ពាក្យនេះ ព្រះសេនាបតីពោលហើយថា ព្រះនាមថា **ភគវា** នេះ កើតក្នុងទីបំផុតនៃការរួចផុតវិសេស ជាបញ្ញត្តិដែលប្រាកដដល់ព្រះដ៏មានព្រះភាគសម្ពុទ្ធទាំងឡាយ ព្រមគ្នានឹងការបានចំពោះនូវព្រះសព្វញ្ញុតញ្ញាណ ត្រង់គល់ព្រះពោធិព្រឹក្ស ។

ដើម្បីប្រកាសព្រះគុណ ដែលកើតអំពីគុណនេមិត្តកនាមនេះ ទើបព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថានេះថា

**ភគី ភជី ភាគី វិភត្តវា ឥតិ អកាសិ ភគ្គន្តិ គរូតិ ភាគ្យវា**
**ពហូហិ ញាយេហិ សុភាវិតត្តនោ ភវន្តគោ សោ ភគវាតិ វុច្ចតិ។**

ព្រះដ៏មានព្រះភាគអង្គណា ទ្រង់មានឥស្សរិយយស ទ្រង់សេព ( អរិយគុណ ) មានចំណែក ( នៃចតុប្បច្ច័យ ) ទ្រង់ចែក ( ធម្មរតនៈ ) ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគអង្គនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា **ភគវា** ព្រះដ៏មានព្រះភាគអង្គណា ទ្រង់បានកាច់បំបាក់កិលេស ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាម ព្រះដ៏មានព្រះភាគអង្គនោះថា **ភគវា** ព្រះដ៏មានព្រះភាគអង្គណា ទ្រង់ជាគ្រូ

ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាម ព្រះដ៏មានព្រះភាគអង្គនោះថា **ភគវា** ព្រះដ៏មានព្រះភាគអង្គណា ទ្រង់មានជោគ ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមព្រះដ៏មានព្រះភាគអង្គនោះថា **ភគវា** ព្រះដ៏មានព្រះភាគអង្គណា មានព្រះអង្គអប់រំល្អហើយ ដោយញ៉ាំងធម៌ដ៏ច្រើន ទ្រង់ដល់នូវទីបំផុតនៃភព ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាម ព្រះដ៏មានព្រះភាគអង្គនោះថា **ភគវា**។

ម្យ៉ាងទៀត ក្នុងគាថានេះ បណ្ឌិតគប្បីឃើញអត្ថនៃបទទាំងនោះ តាមន័យដែលពោលហើយក្នុងនិទ្ទេសនោះឯង ចំណែកន័យដទៃទៀត មានដូច្នេះ គឺ

**ភាគ្យវា ភគ្គវា យុត្តោ ភគេហិ ច វិភត្តវា**
**ភត្តវា វន្តគមនោ ភវេសុ ភគវា តតោតិ ។**

ព្រះដ៏មានព្រះភាគអង្គណា ទ្រង់មានជោគ (គឺមានចំណែកនៃបារមីធម៌) ទ្រង់កាច់បំបាក់កិលេសហើយ ទ្រង់ប្រកបដោយភគធម៌ ទ្រង់ចែក ទ្រង់សេព និងទ្រង់មានដំណើរទៅកាន់ភពទាំងឡាយខ្ជាក់ចោលហើយ ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាម ព្រះដ៏មានព្រះភាគអង្គនោះថា **ភគវា**។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះតទៅ បុគ្គលអ្នកសិក្សា គប្បីជ្រាបអត្ថរូបថា ព្រោះភាគ្យធម៌ ( គឺកុសល ) ដែលដល់នូវត្រើយនៃបារមី មានទាន និងសីលជាដើម ដែលញ៉ាំងសុខជាលោកិយផង លោកុត្តរផង ឲ្យកើតមាន

ដល់ព្រះដ៏មានព្រះភាគអង្គនោះ ដូច្នោះ ក្នុងកាលគួរថ្វាយព្រះនាមថា **ភាគ្យវា** តែលោកកាន់យកលក្ខណៈនៃនិរុត្តិ គឺចុះអក្ខរៈថ្មី ផ្លាស់អក្ខរៈជាដើម ឬកាន់យកលក្ខណៈ គឺសង្គ្រោះចូលក្នុង **ជុត** សព្ទ មាន **បិសោទរ** សព្ទជាដើម តាមន័យនៃសព្ទ ទើបថ្វាយព្រះនាមថា **ភគវា** ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បានបំបាក់បង់កិលេសជាគ្រឿងក្តៅក្រហាយ ក្រវល់ក្រវាយគ្រប់យ៉ាង រាប់សែន មានប្រភេទ គឺ លោភៈ ទោសៈ មោហៈ វិបរិតមនសិការ អហិរិកៈ អនោត្តប្បៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ តណ្ហា អវិជ្ជា អកុសលមូល ៣ ទុច្ចរិត ៣ សង្កិលេស ៣ មន្ទិល ៣ វិសមៈ ៣ សញ្ញា ៣ វិតក្កៈ ៣ បបញ្ចៈ ៣ វិបរិយេសៈ ៤ អាសវៈ ៤ គន្ថៈ ៤ ឱឃៈ ៤ យោគៈ ៤ អគតិ ៤ តណ្ហុប្បាទាន ៤ ចេតោខិលៈ ៥ វិនិពន្ធៈ ៥ នីវរណៈ ៥ អភិនន្ទនៈ ៥ វិវាទមូល ៦ តណ្ហាកាយ ៦ អនុស័យ ៧ មិច្ឆត្ត ៨ តណ្ហាមូលកៈ ៩ អកុសលកម្មបថ ១០ ទិដ្ឋិ ៦២ និងតណ្ហាវិចរិត ១០៨ ឬដោយសង្ខេប ទ្រង់បានបំបាក់បង់នូវមារ ៥ គឺកិលេសមារ ខន្ធមារ អភិសង្ខារមារ មច្ចុមារ និងទេវបុត្តមារ ដូច្នោះ ក្នុងកាលគួរនឹងថ្វាយព្រះនាមថា **ភគ្គវា** តែលោកថ្វាយព្រះនាមថា **ភគវា** ព្រោះទ្រង់បំបាក់បង់អន្តរាយទាំងនោះបានហើយ ។ ម្យ៉ាងទៀត ក្នុងទីនេះ លោកពោលទុកទៀតថា

**ភគ្គរាគោ ភគ្គទោសោ ភគ្គមោហោ អនាសវោ**

**ភគ្គស្ស ចាបកា ធម្មា ភគវា តេន វុច្ចតិ ។**
ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់កាច់បំបាក់រាគៈបានហើយ ទ្រង់កាច់បំបាក់ទោសៈបានហើយ ទ្រង់កាច់បំបាក់មោហៈបានហើយ មិនមានអាសវៈ បាបធម៌ទាំងឡាយ ទ្រង់កម្ចាត់បង់ហើយ ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា **ភគវា** ។

ការដល់ព្រមដោយរូបកាយ របស់ព្រះដ៏មានព្រះភាគអង្គនោះ ដែលទ្រទ្រង់នូវបុញ្ញលក្ខណៈរាប់រយ លោកសម្តែងហើយ ដោយភាពដែលទ្រង់មានព្រះកាយសមសួន ។ ការដល់ព្រមដោយធម្មកាយ លោកសម្តែងហើយ ដោយភាពដែលទ្រង់បំបាក់បង់ទោសៈបានហើយ ។ ទ្រង់ជាបុគ្គលដែលអ្នកត្រិះរិះខាងលោកិយទាំងឡាយរាប់អានច្រើន ព្រះអង្គជាបុគ្គលដែលគ្រហស្ថនិងបព្វជិតគប្បីចូលគាល់ ទ្រង់ជាបុគ្គលអាចក្នុងការបំបាត់ទុក្ខផ្លូវកាយ និងផ្លូវចិត្តរបស់គ្រហស្ថ និងបព្វជិតទាំងនោះ ដែលចូលគាល់ហើយ ទ្រង់មានឧបការៈដោយអាមិសទាន និងធម្មទាន និងទ្រង់អាចក្នុងការដឹកនាំដោយសេចក្តីសុខដែលជាលោកិយផង ជាលោកុត្តរផង ក៏លោកសម្តែងហើយដូចគ្នា ។

ម្យ៉ាងទៀត ព្រោះ **ភគ** សព្ទ រមែងប្រព្រឹត្តទៅក្នុងធម៌ ៦ គឺភាពជាធំ ធម៌ យស សេរី កាមៈ និងសេចក្តីព្យាយាមក្នុងលោក ។ ឯភាពជាធំក្នុងចិត្តរបស់ព្រះដ៏មានព្រះភាគអង្គនោះ ប្រសើរឧត្តម ឬភាពជាធំ ដែលលោកិយសន្មត មានការធ្វើកាយឲ្យតូចល្អិត និងធ្វើកាយឲ្យអណ្តែតទៅបាន

( មានការបំបាំងកាយ ) ជាដើម ក៏ទ្រង់មានយ៉ាងបរិបូណ៌ដោយអាការទាំងពួង ។ លោកុត្តរធម៌ក៏ដូចគ្នា គឺទ្រង់មានយ៉ាងបរិបូណ៌ដោយអាការទាំងពួង ។ ព្រះយសដែលគ្របដណ្តប់លោកទាំង ៣ ទ្រង់សម្រេចដោយព្រះគុណតាមសេចក្តីពិត បរិសុទ្ធក្រៃលែង ។ ព្រះសិរីនៃព្រះអង្គាវយវៈតូចធំ គ្រប់ចំណែកបរិបូណ៌ដោយអាការទាំងពួង អាចញុំាងសេចក្តីជ្រះថ្លានៃកែវភ្នែក និងចិត្តរបស់ជនអ្នកខ្វល់ខ្វាយក្នុងការមើលព្រះរូបកាយឲ្យកើត ។ កាមៈដែលជនទាំងឡាយសន្មតថា សេចក្តីសម្រេចនៃប្រយោជន៍ដែលប្រាថ្នា ( ក៏មាន ) ព្រោះការប្រាថ្នា ដែលព្រះអង្គទ្រង់តាំងទុកជាប្រយោជន៍ដ៏ធំដល់ព្រះអង្គ ឬជាប្រយោជន៍ដ៏ធំដល់អ្នកដទៃនោះៗ សម្រេចហើយយ៉ាងនោះឯង ឬថា សេចក្តីព្យាយាម ពោល គឺការព្យាយាមដោយប្រពៃ ដែលជាហេតុនៃការកើតឡើងរបស់ភាពជាគ្រូនៃលោកទាំងពួង ក៏ទ្រង់មានហើយ ព្រោះហេតុនោះ ព្រះអង្គទ្រង់ប្រកបហើយដោយភគធម៌ទាំងនេះ ក៏ថ្វាយព្រះនាមបានថា **ភគវា** ដោយសេចក្តីថា ភគធម៌ទាំងឡាយរបស់ព្រះអង្គមាន ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះទ្រង់ជាអ្នកចែក អធិប្បាយថា ទ្រង់ចែក គឺបើកផ្សាយសម្តែងនូវធម៌ទាំងពួង ដោយប្រភេទមានកុសលជាដើម ឬនូវធម៌ មានកុសលជាដើម ដោយប្រភេទ មានខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ និងបដិច្ចសមុប្បាទជាដើម ឬនូវអរិយសច្ច គឺទុក្ខ ដោយអត្ថថា បៀតបៀនត្រូវបច្ច័យតាក់តែង ដុតកោល និងជារបស់ប្រែប្រួល នូវសមុទយៈ ដោយអត្ថថា ប្រមូលមកនូវទុក្ខ ជាហេតុ ជាគ្រឿងចង និងជាគ្រឿងកង្វល់ នូវនិរោធ

ដោយអត្ថថា ជាគ្រឿងរលាស់ចេញ ជាសភាវៈស្ងប់ មិនមានបច្ច័យតាក់តែង និងជាអមតៈ នូវមគ្គ ដោយអត្ថថា ជាធម៌នាំចេញចាកទុក្ខ ជាហេតុ ជាគ្រឿងចង្អុលបង្ហាញ និងភាពជាធំ ដូច្នោះ ក្នុងកាលគួរ ថ្វាយព្រះនាមថា **វិភត្តវា** ក៏ថ្វាយព្រះនាមបានថា **ភគវា** ។

ម្យ៉ាងទៀត ព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់គប់រក គឺទ្រង់សេព ដោយអត្ថថា ទ្រង់បានធ្វើឲ្យច្រើននូវទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ នូវកាយវិវេក ចិត្តវិវេក និងឧបធិវិវេក នូវសុញ្ញតវិមោក្ខ អប្បណិហិត-វិមោក្ខ និងអនិមិត្តវិមោក្ខ និងនូវឧត្តរិមនុស្សធម្មដទៃៗ ទៀត ដែលជាលោកិយផង លោកុត្តរផង ដូច្នោះ ក្នុងកាលគួរថ្វាយព្រះនាមថា **ភត្តវា** ក៏ថ្វាយព្រះនាមបានថា **ភគវា** ។

ម្យ៉ាងទៀត ព្រោះការទៅ ពោល គឺតណ្ហាក្នុងភព ៣ ដែលព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ខ្ជាក់ចោលហើយ ដូច្នោះ ក្នុងកាលគួរថ្វាយព្រះនាមថា **ភវេសុ វន្តគមនោ** ( បុគ្គលមានការទៅក្នុងភពទាំងឡាយខ្ជាក់ចោលហើយ ) តែថ្វាយព្រះនាមថា **ភគវា** ព្រោះកាន់យក **ភ** អក្ខរៈ អំពី **ភវ** សព្ទ **គ** អក្ខរៈ អំពី **គមន** សព្ទ និង **វ** អក្ខរៈ អំពី **វន្ត** សព្ទ ធ្វើឲ្យជាទីឃៈ ប្រៀបដូចពាក្យក្នុងផ្លូវលោក កាលគួរនឹងពោលថា **មេហនស្ស ខស្ស មាលា** ( កម្រងផ្កានៃឱកាសដែលកំបាំង ) គេពោលថា **មេខលា** ដូច្នោះ ។

# អធិប្បាយបទថា សទេវក ជាដើម

ប្រើនបទថា **សោ ឥមំ លោកំ** សេចក្តីថា ព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ធ្វើលោកនេះឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ក្រៃលែងឯង ។ ដូច្នេះ នឹងបង្ហាញពាក្យដែលគួរពោលដូច្នេះថា បទថា **សទេវកំ** គឺព្រមដោយទេវតាទាំងឡាយ ឈ្មោះថា **សទេវក** ( ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ធ្វើលោកនេះ ) ព្រមដោយមារ ដែលឈ្មោះថា **សមារក** ព្រមដោយព្រហ្ម ដែលឈ្មោះថា **សព្រហ្មក** ព្រមដោយសមណៈ និងព្រាហ្មណ៍ ដែលឈ្មោះថា **សស្សមណព្រាហ្មណី** ( ឲ្យជាក់ច្បាស់ ) ដោយអាការយ៉ាងនេះ ។ ដែលឈ្មោះថា **បជា** ព្រោះភាពជាបុគ្គលកើតអំពីកម្មកិលេសរបស់ខ្លួន ។ ពួកសត្វនោះ ព្រមទាំងទេវតា និងមនុស្សទាំងឡាយ ឈ្មោះថា **សទេវមនុស្ស**។

បណ្តាពាក្យថា **សទេវក** ជាដើម គប្បីជ្រាបការកាន់យកទេវតាជាន់កាមាវចរ ៥ ជាន់ ដោយពាក្យថា **សទេវក** ( ព្រមទាំងទេវតា ) ។ គប្បីជ្រាបការកាន់យកទេវតាកាមាវចរជាន់ទី ៦ ដោយពាក្យថា **សមារក** ។ គប្បីជ្រាបការកាន់យកព្រហ្ម មានព្រហ្មកាយិកាជាដើម ដោយពាក្យថា **សព្រហ្មក** ។ គប្បីជ្រាបការកាន់យកសមណៈ និងព្រាហ្មណ៍ដែលជាសត្រូវចំពោះព្រះសាសនា និងការកាន់យកសមណៈ និងព្រាហ្មណ៍ ដែលមានបាបស្ងប់ហើយ និងអ្នកមានបាបបន្សាត់បង់ហើយ ដោយពាក្យថា **សស្សមណព្រាហ្មណី**។ គប្បីជ្រាបការកាន់យកសត្វលោក ដោយពាក្យថា **បជា**។ គប្បីជ្រាបការកាន់យកសម្មតិទេព និងមនុស្សដ៏សេស ដោយពាក្យថា **សទេវមនុស្ស** ។

បណ្ដាបទទាំង ៥ ដូចពណ៌នាមកនេះ ឱកាសលោក គប្បីជ្រាបថា លោកកាន់យកហើយ ដោយបទទាំង ៣ ( គឺសទេវកៈ ១ សមារកៈ ១ សព្រហ្មកៈ ១ ) សត្វលោក គប្បីជ្រាបថា លោកកាន់យកហើយដោយបទទាំង ២ ( គឺសស្សមណព្រាហ្មណី និងសទេវមនុស្ស ) ដោយអំណាចនៃពួកសត្វ ។

ន័យម្យ៉ាងទៀត អរូបាវចរលោក លោកកាន់យកហើយ ដោយ **សទេវក** សព្ទ ។ កាមាវចរទេវលោក ៦ ជាន់ លោកកាន់យកហើយ ដោយ **សមារក** សព្ទ ។ ព្រហ្មលោកដែលមានរូប លោកកាន់យកហើយ ដោយ **សព្រហ្មក** សព្ទ ។ មនុស្សលោក និងសម្មតិទេព ឬសត្វលោកទាំងអស់ដ៏សេស លោកកាន់យកហើយ ដោយសព្ទ មានសស្សមណព្រាហ្មណិជាដើម ដោយអំណាចនៃបរិស័ទ ៤ ។

ម្យ៉ាងទៀត ក្នុងពាក្យទាំងឡាយ មានពាក្យថា **សទេវក** ជាដើមនេះ ព្រះកិត្តិសព្ទរបស់ព្រះដ៏មានព្រះភាគអង្គនោះ ប្រកាសភាពនៃសត្វលោកទាំងពួង ដែលព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ហើយ ដោយកំណត់យ៉ាងឧក្រិដ្ឋ ដោយពាក្យថា **សទេវក** ល្បីខ្ចរខ្ចាយទៅហើយ ព្រោះហេតុនោះ ជនទាំង-ឡាយណា មានសេចក្ដីសង្ស័យថា មារឈ្មោះវសវត្តី មានអានុភាពច្រើនជាធំជាងទេវតាជាន់កាមាវចរ មារនោះ ព្រះមានព្រះភាគអង្គនោះទ្រង់ធ្វើឲ្យជាក់ច្បាស់បានដូចម្ដេច ព្រះកិត្តិសព្ទខ្ចរខ្ចាយទៅ ទម្លាយសេចក្ដីសង្ស័យរបស់ជនទាំងនោះ ដោយពាក្យថា **សមារកំ** នេះ ។

ម្យ៉ាងទៀត ជនទាំងឡាយណា គប្បីមានសេចក្តីសង្ស័យថា ព្រហ្ម ដែលមានអានុភាពច្រើន រមែងបញ្ចេញពន្លឺទៅក្នុងមួយពាន់ចក្រវាល ដោយ ម្រាមដៃមួយ ក្នុងពីរពាន់ចក្រវាលដោយម្រាមដៃពីរ ។បេ។ រមែងបញ្ចេញ ពន្លឺទៅមួយម៉ឺនចក្រវាលដោយម្រាម ១០ និងបានសោយសុខដែលកើតអំពី ឈានសមាបត្តិដ៏ក្រៃលែង សូម្បីព្រហ្មនោះ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ ធ្វើឲ្យជាក់ច្បាស់បានដូចម្តេច ព្រះកិត្តិសព្ទផ្សាយខ្ចរខ្ចាយទៅ ទម្លាយសេចក្តី សង្ស័យរបស់ជនទាំងនោះដោយពាក្យថា **សព្រហ្មកំ**។

ព្រះកិត្តិសព្ទ ( របស់ព្រះដ៏មានព្រះភាគ ) កាលប្រកាសឋានៈយ៉ាង ឧក្រិដ្ឋទាំងឡាយ ដែលទ្រង់ធ្វើឲ្យជាក់ច្បាស់ហើយយ៉ាងនោះ ក្នុងលំដាប់នោះ កាលនឹងប្រកាសការៈនៃសត្វលោកដ៏សេស ដែលព្រះអង្គទ្រង់ធ្វើឲ្យជាក់ ច្បាស់ហើយ ដោយអំណាចការកំណត់យ៉ាងឧក្រិដ្ឋ រហូតដល់សម្មតិទេព និងពួកមនុស្សដ៏សេស ផ្សាយខ្ចរខ្ចាយទៅ ដោយពាក្យថា **សទេវមនុស្សំ** ( ព្រមទាំងទេវតា និងមនុស្ស ) ។ ក្នុងបទទាំងឡាយ មានបទថា **សទេវកំ** ជាដើមនេះ មានលំដាប់អនុសន្ធិប៉ុណ្ណេះ ។

## អធិប្បាយបទថា សយំ ជាដើម

ម្យ៉ាងទៀត ក្នុងពាក្យថា **សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ** នេះ គប្បីជ្រាបវិនិច្ឆ័យថា បទថា **សយំ** ប្រែថា ដោយព្រះអង្គឯង **សយំ** សព្ទ នេះ ជាសព្ទមានអត្ថដែលបុគ្គលដទៃ នឹងគប្បីនាំទៅមិនមាន ។ បទថា **អភិញ្ញា** សេចក្តីថា ទ្រង់ដឹងដោយការដឹងដ៏ក្រៃលែង គឺដោយព្រះញាណដ៏

ក្រៃលែង ។ បទថា **សច្ឆិកត្វា** គឺទ្រង់ធ្វើឲ្យប្រចក្ស ។ ដោយបទថា **សច្ឆិ-កត្វា** នោះ គឺធ្វើការហាមកិច្ច មានការអនុមានជាដើមចេញ ។ បទថា **បវេទេតិ** សេចក្តីថា គឺទ្រង់ញ៉ាំងពួកសត្វឲ្យត្រាស់ដឹង គឺឲ្យដឹង បានដល់ទ្រង់ប្រកាសឲ្យដឹង ។

## លម្អបទទាំង ៣

ពាក្យថា **សោ ធម្មំ ទេសេតិ អាទិកល្យាណំ ។បេ។ បរិយោសានកល្យាណំ** អធិប្បាយថា ព្រះដ៏មានព្រះភាគអង្គនោះ សូម្បីត្រូវលះបង់សេចក្តីសុខដែលកើតអំពីវិវេកដ៏ក្រៃលែង ហើយទ្រង់សម្តែងធម៌ ក៏ព្រោះទ្រង់អាស្រ័យសេចក្តីករុណាក្នុងសត្វទាំងឡាយ ។ ឯព្រះអង្គ កាលទ្រង់សម្តែងធម៌នោះ ទោះតិច ឬច្រើនក៏ដោយ ទ្រង់សម្តែងគ្រប់ទាំង ៣ ប្រការ គឺលម្អបទដើមជាដើមប៉ុណ្ណោះ ។ ទ្រង់សម្តែងដូចម្តេច គឺទ្រង់សម្តែងយ៉ាងនេះ ដោយសេចក្តីពិស្តារថា សូម្បីព្រះគាថាមួយ ក៏មានលម្អបទដើម ដោយបាទដំបូង មានលម្អត្រង់កណ្តាល ដោយបាទទី ២ ទី ៣ មានលម្អបទចុងដោយបាទចុងក្រោយ ព្រោះព្រះធម៌មានលម្អដោយជុំវិញ ។ ព្រះសូត្រដែលមានអនុសន្ធិ ១ មានលម្អបទដើមដោយពាក្យនិទាន មានលម្អបទចុងដោយនិគមគាថា មានលម្អត្រង់កណ្តាលដោយពាក្យដ៏សេស ។ ព្រះសូត្រដែលមានអនុសន្ធិផ្សេងៗ មានលម្អបទដើមដោយអនុសន្ធិដំបូង មានលម្អបទចុង ដោយអនុសន្ធិខាងចុង មានលម្អបទកណ្តាលដោយអនុសន្ធិដ៏សេស សាសនធម៌ទាំងអស់ មានលម្អបទដើមដោយសីលជាអត្ថខាងដើម មានលម្អ

ត្រង់កណ្តាលដោយសមថៈ និងវិបស្សនា មគ្គ និងផល មានលម្អបទចុង ដោយព្រះនិព្វាន ។

ន័យម្យ៉ាងទៀត មានលម្អបទដើមដោយសីល និងសមាធិ មានលម្អបទកណ្តាលដោយវិបស្សនា និងមគ្គ មានលម្អក្នុងទីបំផុតដោយផល និងព្រះនិព្វាន ។

ម្យ៉ាងទៀត មានលម្អបទដើមដោយការត្រាស់ដឹងល្អរបស់ព្រះសម្ពុទ្ធ មានលម្អបទកណ្តាលដោយភាពជាធម៌ល្អនៃព្រះធម៌ មានលម្អបទចុងដោយការបដិបត្តិល្អរបស់សង្ឃ ។

ម្យ៉ាងទៀត មានលម្អបទដើម ដោយព្រះអភិសម្ពោធិញ្ញាណ ដែលបុគ្គលអ្នកស្តាប់សាសនធម៌នោះហើយ បដិបត្តិដូច្នោះ នឹងគប្បីសម្រេច មានលម្អបទកណ្តាលដោយបច្ចេកពោធិញ្ញាណ មានលម្អបទចុងដោយសាវកពោធិញ្ញាណ ។ ម្យ៉ាងទៀត សាសនធម៌នោះ កាលសាធុជនកំពុងស្តាប់ រមែងនាំមកនូវសេចក្តីល្អតែមួយចំណែក ដោយការស្តាប់ ព្រោះសង្កត់នីវរណធម៌បាន ព្រោះដូច្នោះ ទើបឈ្មោះថា មានលម្អបទដើម កាលសាធុជនកំពុងបដិបត្តិ ក៏រមែងនាំមកនូវសេចក្តីល្អតែមួយចំណែក ដោយការបដិបត្តិ ព្រោះនឹងនាំមកនូវសេចក្តីសុខ ដែលកើតអំពីសមថៈ និងវិបស្សនា ព្រោះដូច្នោះ ទើបឈ្មោះថា មានលម្អបទកណ្តាល កាលសាធុជនបដិបត្តិហើយដោយប្រការនោះ ក៏រមែងនាំមកនូវសេចក្តីល្អដូចគ្នា សូម្បីដោយផលនៃការបដិបត្តិ ព្រោះនឹងនាំនូវភាពជាបុគ្គលមិនញាប់ញ័រមកឲ្យ ក្នុងកាលបាន

សម្រេចផលនៃការបដិបត្តិហើយ ព្រោះដូច្នោះ ទើបឈ្មោះថា មានលម្អបទចុង ។ មួយទៀត មានលម្អបទដើម ដោយការបរិសុទ្ធនៃដែនកើត ព្រោះសាសនធម៌ មានទីពឹងជាដែនកើត មានលម្អបទកណ្ដាល ដោយការបរិសុទ្ធនៃអត្ថ មានលម្អបទចុង ដោយការបរិសុទ្ធនៃកិច្ច ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគអង្គនោះ កាលទ្រង់សម្ដែងធម៌ ទោះតិច ឬច្រើនក៏ដោយ គប្បីជ្រាបថា ទ្រង់សម្ដែងគ្រប់គ្រាន់ទាំង ៣ ប្រការ មានលម្អក្នុងបទដើមជាដើម ។

# អធិប្បាយបទថា សាត្ថំ សព្យញ្ជនំ

ក្នុងពាក្យជាដើមថា **សាត្ថំ សព្យញ្ជនំ** នេះ គប្បីជ្រាបវិនិច្ឆ័យយ៉ាងនេះថា ព្រះដ៏មានព្រះភាគអង្គនោះ កាលទ្រង់សម្ដែងធម៌នេះ ឈ្មោះថា ទ្រង់ប្រកាស គឺទ្រង់សម្ដែងសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈ ដោយន័យផ្សេងៗ ។ ឯសាសនព្រហ្មចរិយៈ និងមគ្គព្រហ្មចរិយៈនោះ ឈ្មោះថា ដល់ព្រមដោយអត្ថ ព្រោះដល់ព្រមដោយអត្ថ ឈ្មោះថា ដល់ព្រមដោយព្យញ្ជនៈ ព្រោះដល់ព្រមដោយព្យញ្ជនៈតាមសមគួរ ។ ឈ្មោះថា ដល់ព្រមដោយអត្ថ ព្រោះប្រកបព្រមដោយអត្ថ ក្នុងបទដែលសម្ដែង ប្រកាស បើកផ្សាយ ចែកធ្វើឲ្យរាក់ និងបញ្ញត្តិ ឈ្មោះថា ដល់ព្រមដោយព្យញ្ជនៈ ព្រោះដល់ព្រមដោយអក្ខរៈ បទ ព្យញ្ជនៈ អាការ និរុត្តិ និងនិទ្ទេស ឈ្មោះថា ដល់ព្រមដោយអត្ថ ព្រោះសាសនព្រហ្មចរិយៈជាដើម ជ្រៅដោយអត្ថ និងជ្រៅដោយបដិវេធ ឈ្មោះថា ដល់ព្រមដោយព្យញ្ជនៈ ព្រោះសាសនព្រហ្មចរិយៈនោះជ្រៅដោយធម៌ និងជ្រៅដោយទេសនា ឈ្មោះថា ដល់ព្រមដោយអត្ថ ព្រោះ

ជាវិស័យ គឺអារម្មណ៍នៃអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ឈ្មោះថា ដល់ព្រមដោយព្យញ្ជនៈ ព្រោះជាវិស័យនៃធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិ-សម្ភិទា ។

ព្រហ្មចរិយៈនោះ ឈ្មោះថា ដល់ព្រមដោយអត្ថ ព្រោះថា ជាទីជ្រះថ្លានៃជនជាអ្នកប្រាជ្ញ ព្រោះជារបស់ដែលបណ្ឌិតគប្បីដឹង ឈ្មោះថា ដល់ព្រមដោយព្យញ្ជនៈ ព្រោះជាទីជ្រះថ្លានៃលោកិយជន ព្រោះជារបស់គួរជឿ ឈ្មោះថា ដល់ព្រមដោយអត្ថ ព្រោះមានសេចក្តីអធិប្បាយជ្រៅ ឈ្មោះថា ដល់ព្រមដោយព្យញ្ជនៈ ព្រោះមានបទពាក់ ឈ្មោះថា បរិសុទ្ធដោយមិនមានសេសសល់ ព្រោះបរិបូណ៌គ្រប់គ្រាន់ គឺមិនមានរបស់ដែលត្រូវបន្ថែម ឈ្មោះថា បរិសុទ្ធ ព្រោះជារបស់មិនមានទោស ព្រោះមិនមានរបស់ដែល ត្រូវនាំចេញ ឈ្មោះថា ព្រហ្មចរិយៈ ព្រោះបុគ្គលជាធំ គឺបុគ្គលប្រសើរ គប្បីបដិបត្តិ ព្រោះព្រហ្មចរិយៈនោះ លោកកំណត់ដោយត្រៃសិក្ខា និងព្រោះជាចរិយារបស់លោកប៉ុណ្ណោះ ដូច្នោះ ទើបព្រះឧបាលិត្ថេរពោលថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ប្រកាសព្រហ្មចរិយៈ ប្រកបដោយអត្ថ ដល់ព្រមដោយព្យញ្ជនៈ បរិសុទ្ធ បរិបូណ៌ដោយឥតសេសសល់ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងធម៌ មានហេតុ និងរឿងដែលកើតឡើង ឈ្មោះថា ទ្រង់សម្តែង ( ធម៌នោះ ) មានលម្អបទដើម និងឈ្មោះថា ទ្រង់សម្តែងមានលម្អបទកណ្តាល ព្រោះអត្ថមិនវិបរិត និងព្រោះប្រកបដោយហេតុ និងឧទាហរណ៍ ដោយសមគួរដល់វេនេយ្យសត្វ

និងឈ្មោះថា ទ្រង់សម្តែងមានលម្អបទចុង ព្រោះធ្វើឲ្យអ្នកស្តាប់ទាំងឡាយបាននូវសទ្ធា និងការចូនក្នុងចិត្ត ទ្រង់សម្តែងយ៉ាងនោះ ឈ្មោះថា ទ្រង់ប្រកាសព្រហ្មចរិយៈ ។

ឯព្រហ្មចរិយៈ ឈ្មោះថា ដល់ព្រមដោយអត្ថ ព្រោះជ្រាបច្បាស់ក្នុងធម៌ដែលគួរសម្រេចបាន ដោយការបដិបត្តិ ឈ្មោះថា ដល់ព្រមដោយព្យញ្ជនៈ ព្រោះជំនាញក្នុងគម្ពីរដោយបរិយត្តិ ឈ្មោះថា បរិបូណ៌ទាំងអស់ ព្រោះប្រកបដោយធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម ឈ្មោះថា បរិសុទ្ធ ព្រោះមិនមានគ្រឿងសៅហ្មង ព្រោះប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងលះបង់នូវទុក្ខក្នុងវដ្តៈ និងព្រោះមិនមានសេចក្តីប្រាថ្នាលោកាមិស ហៅថា ព្រហ្មចរិយៈ ព្រោះជាចរិយារបស់លោកអ្នកធំ ដោយអត្ថថា ជាបុគ្គលប្រសើរ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធសាវក ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគអង្គនោះពោលបានថា ទ្រង់សម្តែងធម៌មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង ទ្រង់ប្រកាសព្រហ្មចរិយៈ បរិសុទ្ធ បរិបូណ៌ដោយឥតសេសសល់ ព្រមដោយអត្ថ ព្រមដោយព្យញ្ជនៈ ។

បទថា **សាធុ ខោ បន** សេចក្តីថា ម្យ៉ាងទៀត ( ការឃើញព្រះអរហន្តទាំងឡាយមានសភាពបែបនេះ ) ជាការប្រពៃដូច្នេះ ។ អធិប្បាយថា នាំប្រយោជន៍មកឲ្យ នាំសេចក្តីសុខមកឲ្យ ។

បទថា **តថារូបានំ អរហតំ** សេចក្តីថា ( ការឃើញ ) ព្រះអរហន្តទាំងឡាយ បុគ្គលដែលបានឈ្មោះថា ជាព្រះអរហន្តក្នុងលោក ព្រោះបាន

សម្រេចគុណតាមសេចក្ដីពិត បែបព្រះគោតម ( ជាការប្រពៃពិត ) ។

បទថា **ឧស្សន្នំ ហោតិ** សេចក្ដីថា វេរញ្ជព្រាហ្មណ៍ ធ្វើអធ្យាស្រ័យទុកយ៉ាងនេះថា សូម្បីត្រឹមតែការបើកភ្នែកទាំងពីរដ៏ថ្លា ដោយបសាទ ហើយសម្លឹងមើល រមែងជាការប្រពៃ ដូច្នេះ ( ទើបចូលទៅគាល់ជាខាងក្រោយ )។

# អធិប្បាយ វិសេសនសព្ទនាម គឺ យេន តេន

[ ២ ] បទថា **យេន** ក្នុងបទថា **អថខោ វេរញ្ជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ** នេះ ជាតតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ព្រោះដូច្នោះ ក្នុងពីរបទថា **យេន តេន** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ព្រះដ៏មានព្រះភាគប្រថាប់នៅក្នុងទីណា វេរញ្ជព្រាហ្មណ៍បានចូលទៅគាល់ក្នុងទីនោះ ។ ម្យ៉ាងទៀត ក្នុងពីរបទថា **យេន តេន** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ព្រះដ៏មានព្រះភាគដែលទេវតា និងមនុស្សទាំងឡាយ គប្បីចូលទៅគាល់ ដោយហេតុណា វេរញ្ជព្រាហ្មណ៍ក៏ចូលគាល់ដោយហេតុនោះ ។ ព្រះដ៏មានព្រះភាគអង្គនោះ ដែលទេវតា និងមនុស្សទាំងឡាយគប្បីចូលទៅគាល់ ព្រោះហេតុអ្វី គប្បីចូលទៅគាល់ ព្រោះមានបំណងក្នុងការសម្រេចគុណវិសេសមានប្រការផ្សេងៗ ដូចដើមឈើធំ មានផ្លែជានិច្ច ដែលពួកទិជជាតិទាំងឡាយគប្បីហើរចូលទៅរក ព្រោះមានបំណងក្នុងការស៊ីផ្លែដែលល្អដូច្នោះ ម្យ៉ាងទៀត បទថា **ឧបសង្កមិ** មានអធិប្បាយថា **គតោ** ប្រែថា ទៅហើយ ។ ពាក្យថា **ឧបសង្កមិត្វា** ជាពាក្យសម្ដែងបរិយោសានកាលកិរិយានៃការចូលទៅគាល់ ។ ម្យ៉ាងទៀត លោកពោលអធិប្បាយទុកថា វេរញ្ជព្រាហ្មណ៍ទៅហើយយ៉ាងនោះ

គឺទៅកាន់ទីជិតជាងនោះ បានដល់ ទីដែលរាប់ថា ជិតចំពោះព្រះដ៏មានព្រះភាគ ដូច្នេះ ។

ប្រែនបទថា **ភគវតា សទ្ធឹ សម្មោទិ** សេចក្តីថា ព្រះដ៏មានព្រះភាគ កាលត្រាស់សួរដល់សេចក្តីសុខទុក្ខជាដើម ទ្រង់មានការរាក់ទាក់ ទៅកាន់ព្រាហ្មណ៍នោះហើយ យ៉ាងណា សូម្បីព្រាហ្មណ៍នោះក៏យ៉ាងនោះ មានការរាក់ទាក់ប្រព្រឹត្តទៅជាមួយព្រះដ៏មានព្រះភាគ គឺបានដល់នូវភាពជាបុគ្គលរីករាយ បានដល់ភាពជាពួកតែមួយ ដូចទឹកត្រជាក់ និងទឹកក្តៅផ្សំជាមួយគ្នា ដូច្នោះ ។

## អធិប្បាយបទថា សម្មោទនីយំ និង សារាណីយំ

វេរញ្ជព្រាហ្មណ៍បានរាក់ទាក់ ( នឹងព្រះដ៏មានព្រះភាគ ) ដោយពាក្យជាដើមថា បពិត្រព្រះគោតម ព្រះអង្គល្មមអត់ធន់បានដែរឬ ល្មមញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅបានដែរឬ ហើយសាវកទាំងឡាយរបស់ព្រះគោតម មិនមានអាពាធទេឬ មិនមានទុក្ខឬ នៅរហ័សរហួនឬ នៅមានកម្លាំងឬ នៅមានផាសុកឬ ដូច្នេះ យ៉ាងណា ពាក្យសម្តីនោះ ឈ្មោះថា **សម្មោទនីយ** ( ពាក្យសម្តីដែលជាទីតាំងនៃការរីករាយ ) ព្រោះឲ្យកើតការត្រេកអរ ពោលគឺបីតិ និងបាមោជ្ជ និងព្រោះជាពាក្យសម្តីសមគួរដល់ការរីករាយ ឈ្មោះថា **សារាណីយ** គឺពាក្យសម្តីជាទីតាំងនៃការរឭកដល់គ្នា ព្រោះជាពាក្យសម្តីដែលសមគួរ និងព្រោះជាពាក្យសម្តីដែលគួររឭកដល់ ដើម្បីឲ្យរឭកដល់អស់កាលដ៏យូរដោយល្អ គឺដើម្បីឲ្យប្រព្រឹត្តទៅ មិនមានចន្លោះ ព្រោះជាពាក្យ

សម្តីទន់ផ្អែម ដោយអត្ថ និងព្យញ្ជនៈ ។

ម្យ៉ាងទៀត ឈ្មោះថា **សម្មោទនីយ** ព្រោះស្តាប់ក៏ជាសុខ ។ ឈ្មោះថា **សារាណីយ** ព្រោះតាមរឭកដល់ក៏ជាសុខ ម្យ៉ាងទៀត ឈ្មោះថា **សម្មោទនីយ** ព្រោះជាពាក្យបរិសុទ្ធដោយព្យញ្ជនៈ ឈ្មោះថា **សារាណីយ** ព្រោះ ជាពាក្យសម្តីបរិសុទ្ធដោយអត្ថ ដោយប្រការដូច្នេះឯង ។

## អធិប្បាយបទថា ឯកមន្តំ និសីទិ

វេរញ្ជព្រាហ្មណ៍ ញ៉ាំងពាក្យសម្តីដែលជាទីតាំងនៃការរីករាយ គឺពាក្យសម្តីដែលជាទីតាំងនៃការរឭកដល់គ្នានឹងគ្នា ឲ្យកន្លងទៅ គឺឲ្យចប់ហើយបានដល់ ឲ្យសម្រេចចុះដោយអនេកបរិយាយយ៉ាងនោះហើយ មានបំណងនឹងទូលសួរដល់ប្រយោជន៍ដែលជាហេតុឲ្យខ្ជួនមក ទើបអង្គុយហើយក្នុងទីដ៏សមគួរនាចំណែកម្ខាង ។

សព្ទថា **ឯកមន្តំ** នេះ ជាសព្ទសម្តែងភាវៈនបុំសលិង្គ ។ ( សព្ទថា **ឯកមន្តំ** នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ) ដូចក្នុងពាក្យទាំង-ឡាយជាដើមថា ព្រះចន្ទ និងព្រះអាទិត្យ រមែងគោចរជុំវិញ ទៅក្នុងទីដែលមិនស្មើ ដូច្នេះ ព្រោះហេតុនោះ ក្នុងពាក្យថា **ឯកមន្តំ និសីទិ** នេះ គប្បីឃើញអត្ថយ៉ាងនេះថា វេរញ្ជព្រាហ្មណ៍នោះអង្គុយហើយ និងឈ្មោះថា ជាអ្នកអង្គុយក្នុងទីដ៏សមគួរក្នុងចំណែកម្ខាង ដោយប្រការណា ក៏អង្គុយហើយដោយប្រការនោះ ។

ម្យ៉ាងទៀត ពាក្យថា **ឯកមន្តំ** នោះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃ

សត្តមីវិភត្តិ ។ បទថា **និសីទិ** ប្រែថា ចូលទៅជិតហើយ ។ ពិតហើយ បុរសទាំងឡាយអ្នកឈ្លាស ចូលទៅរកគរុដ្ឋានីយបុគ្គល ( បុគ្គលដែលតាំងនៅក្នុងឋានៈជាគ្រូ ) ឈ្មោះថា រមែងអង្គុយនៅក្នុងទីដ៏សមគួរនាចំណែកម្ខាង ព្រោះភាពជាបុគ្គលឈ្លាសក្នុងការអង្គុយ បណ្តាបុរសអ្នកឈ្លាសទាំងនោះ វេរញ្ជព្រាហ្មណ៍នេះ ជាបុគ្គលឈ្លាសមួយដែរ ព្រោះដូច្នោះ ទើបព្រាហ្មណ៍នោះ អង្គុយហើយក្នុងទីសមគួរនាចំណែកម្ខាង ។

# ការអង្គុយវៀរទោស ៦ យ៉ាង

សួរថា បុគ្គលអង្គុយដូចម្តេច ទើបឈ្មោះថាជាអ្នកអង្គុយហើយក្នុងទីសមគួរនាចំណែកម្ខាង ឆ្លើយថា ត្រូវអង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាង ទើបឈ្មោះថា ជាអ្នកអង្គុយហើយក្នុងទីដ៏សមគួរនាចំណែកម្ខាង ។ ទោសនៃការអង្គុយ ៦ យ៉ាងដូចម្តេច ទោសនៃការអង្គុយ ៦ យ៉ាង គឺអង្គុយឆ្ងាយពេក ១ អង្គុយជិតពេក ១ អង្គុយលើខ្យល់ ១ អង្គុយទីខ្ពស់ ១ អង្គុយចំពីមុខពេក ១ អង្គុយខាងក្រោយពេក ១ ។

ពិតហើយ បុគ្គលអង្គុយនៅត្រង់ទីឆ្ងាយគ្នាពេក បើមានបំណងនឹងនិយាយ ក៏ត្រូវនិយាយដោយសំឡេងខ្លាំង ។ អង្គុយក្នុងទីជិតពេក រមែងធ្វើការជ្រៀតជ្រៀតគ្នា ។ អង្គុយក្នុងទីលើខ្យល់ រមែងបៀតបៀន ( បុគ្គលដទៃ ) ដោយក្លិនខ្លួន ។ អង្គុយក្នុងទីខ្ពស់ រមែងប្រកាសការមិនគោរព ។ អង្គុយចំពីមុខពេក បើមានបំណងនឹងមើល ត្រូវសម្លឹងមើលភ្នែកគ្នា ។ អង្គុយខាងក្រោយពេក បើមានបំណងនឹងមើល នឹងត្រូវលំបាកងាកអើត ក

មើល ព្រោះដូច្នោះ ទើបវេរញ្ជព្រាហ្មណ៍នេះអង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាងនោះឯង ហេតុដូច្នោះ ទើបព្រះឧបាលិត្ថេរពោលទុកថា ព្រាហ្មណ៍នោះអង្គុយហើយ ក្នុងទីសមគួរនាចំណែកម្ខាង ។

## អធិប្បាយ បទផ្សេងៗ មាន ឯតំ ជាដើម

វេរញ្ជព្រាហ្មណ៍ អង្គុយហើយក្នុងទីសមគួរ ក្នុងចំណែកម្ខាង ដូច្នេះ ទើបបានក្រាបទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគ ។ ដោយបទថា **ឯតំ** ជាដើម អាចារ្យសម្តែងអត្ថដែលគួរនឹងពោលក្នុងឥឡូវនេះ ។ **ឧ** អក្ខរៈ ធ្វើការតភ្ជាប់បទ ។ បទថា **អវោច** ប្រែថា បានក្រាបទូលហើយ ។ ប្រជុំបទថា **សុតម្មេតំ** កាត់បទជា **សុតំ មេ តំ** ប្រែថា សេចក្តីនោះ ខ្ញុំព្រះអង្គបានស្តាប់មកហើយ ។ អាចារ្យសម្តែងក្នុងកាលដែលគួរពោលក្នុងឥឡូវនេះដោយពាក្យថា **ឯតំ មយា សុតំ** ជាដើម ។

វេរញ្ជព្រាហ្មណ៍ ហៅព្រះដ៏មានព្រះភាគដោយគោត្រថា **ភោ គោតម** ប្រែថា បពិត្រព្រះគោតមដ៏ចម្រើន ឥឡូវនេះ ព្រះឧបាលិត្ថេរកាលនឹងសម្តែងសេចក្តីដែលវេរញ្ជព្រាហ្មណ៍នោះបានស្តាប់ហើយ ទើបបានពោលពាក្យជាដើមយ៉ាងនេះថា **ន សមណោ គោតមោ ។** ក្នុងពាក្យថា **សមណោ គោតមោ** ជាដើមនោះ មានការពណ៌នាបទដែលមិនងាយយ៉ាងនេះថា បទថា **ព្រាហ្មណោ** បានដល់ ព្រាហ្មណ៍ដោយជាតិ ។

បទថា **ជិណ្ណេ** បានដល់ ជាបុគ្គលចាស់គ្រាំគ្រា គឺត្រូវជរាបញ្ចូនឲ្យទៅដល់ភាពជាបុគ្គល មានអវយវៈបាក់ជាកំណាត់ជាដើម ។

បទថា **វុឌ្ឍា** បានដល់ បុគ្គលចូលដល់ដែននៃសេចក្ដីចម្រើនរបស់អវយវៈតូចធំ ។

បទថា **មហល្លកា** គឺដែលមកតាមព្រមហើយ ដោយភាពជាមនុស្សចាស់ដោយជាតិ ។ អធិប្បាយថា ដែលកើតមកយូរយារហើយ ។

បទថា **អទ្ធគតា** បានដល់ បុគ្គលឆ្លងកាលមកយូរហើយ ។ អធិប្បាយថា អ្នកកន្លងមក ២-៣ ជួរជួកាលហើយ ។

បទថា **វយោអនុបត្តា** បានដល់ បុគ្គលឈានចូលបច្ឆិមវ័យហើយ ។ ចំណែកទី ៣ ដែលមានក្នុងទីបំផុតនៃ ១០០ ឆ្នាំ ឈ្មោះថា បច្ឆិមវ័យ ( គឺវ័យចុងក្រោយ ) ។

ម្យ៉ាងទៀត ក្នុងបទទាំងឡាយ មានបទថា **ជិណ្ណា** ជាដើមនេះ គប្បីជ្រាបយោជនាយ៉ាងនេះថា បទថា **ជិណ្ណា** បានដល់ អ្នកកើតមុន ។ មានអធិប្បាយថា អ្នកប្រព្រឹត្តទៅតាមត្រកូលអស់កាលយូរ ។

បទថា **វុឌ្ឍា** បានដល់ អ្នកប្រកបដោយការចម្រើននៃគុណ មានសីលនិងមារយាទជាដើម ។

បទថា **មហល្លកា** គឺអ្នកមកតាមព្រមហើយ ដោយភាពជាបុគ្គលមានសម្បត្តិច្រើន គឺបុគ្គលមានទ្រព្យច្រើន មានភោគៈច្រើន ។

បទថា **អទ្ធគតា** បានដល់ អ្នកដើរទៅរហូតដល់អស់ផ្លូវហើយ គឺអ្នកប្រព្រឹត្តមិនឈានកន្លងដែននៃគុណ មានវត្តចរិយាជាដើមរបស់ពួកព្រាហ្មណ៍។

បទថា **វយោអនុប្បត្តា** បានដល់ អ្នកឈានចូលដល់ភាពជាបុគ្គល

ចាស់ដោយជាតិ គឺវ័យចុងក្រោយ ។ ឥឡូវនេះ បណ្ឌិតគប្បីប្រកបបទទាំង-ឡាយយ៉ាងនេះថា **អភិវាទេតិ** ជាដើម ដោយ **ឆ** អក្ខរៈ ដែលលោកពោលទុកក្នុងពាក្យថា **ឆ សមណោ គោតមោ** នេះ ហើយជ្រាបអត្ថយ៉ាងនេះថា ព្រះសមណគោតមមិនសំពះ មិនក្រោកទទួល ទាំងមិនអញ្ជើញដោយអាសនៈយ៉ាងនេះថា លោកដ៏ចម្រើនទាំងឡាយ ចូរអង្គុយលើអាសនៈនេះ ។ ពិតហើយ **វា** សព្ទ ដែលមាននៅក្នុងបទជាដើមថា **អភិវាទេតិ** នេះ រមែងប្រព្រឹត្តទៅក្នុងអត្ថឈ្មោះថា **វិភាវន** ( គឺពាក្យប្រកាសតាមប្រក្រតី របស់សត្វលោក ) ដូច **វា** សព្ទ ក្នុងប្រយោគជាដើមថា **រូបំ និច្ចំ វា អនិច្ចំ វា** រូបទៀង ឬមិនទៀង ។

វេរញ្ជព្រាហ្មណ៍ កាលក្រាបទូលយ៉ាងនេះហើយ លំដាប់នោះ ឃើញព្រះដ៏មានព្រះភាគ ទ្រង់មិនធ្វើសាមីចិកម្ម មានការថ្វាយបង្គំជាដើមដល់ខ្លួន ទើបក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំស្តាប់មកហើយនេះ ពាក្យនោះជាពាក្យពិត អធិប្បាយថា ពាក្យនោះ ខ្ញុំបានស្តាប់មកហើយ ពាក្យនោះ រមែងពិតដូច្នោះ គឺពាក្យដែលខ្ញុំបានស្តាប់មក និងបានឃើញមកនោះ រមែងសមគ្នា គឺស្មើគ្នា បានដល់ មានបែបផែនដូចគ្នាដោយអត្ថ ។ វេរញ្ជព្រាហ្មណ៍ពោលត្រូតរឿងដែលខ្លួនបានស្តាប់មក ព្រមទាំងដែលខ្លួនបានឃើញមកយ៉ាងនេះថា ព្រះគោតមមិនសំពះ មិនក្រោកទទួលពួកព្រាហ្មណ៍ដែលចាស់ ដែលចម្រើន ដែលធំ ដែលកន្លងកាល កន្លងវ័យមកដោយលំដាប់ ឬមិនអញ្ជើញដោយអាសនៈឡើយ កាលនឹងតិះដៀល ទើបក្រាបទូល

ថា **តយិធំ ភោ គោតម ន សម្បន្នមេវ** ដូច្នេះ អធិប្បាយថា ការដែលព្រះអង្គទ្រង់មិនធ្វើសាមីចិកម្ម មានការសំពះជាដើមនោះ មិនសមគួរឡើយ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់មិនចូលទៅអាស្រ័យទោស គឺការពោលលើកខ្លួន សង្កត់សង្កិនព្រាហ្មណ៍ តែមានព្រះបំណងកម្ចាត់ការមិនដឹងនោះ ដោយព្រះហឫទ័យដែលត្រជាក់ ព្រោះករុណា ហើយសម្តែងការសមគួរដល់ព្រាហ្មណ៍នោះ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ក្នុងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនឃើញអ្នកណាមួយ ល្មមឲ្យតថាគតសំពះ ឬក្រោកទទួល គួរអញ្ជើញហៅឲ្យអង្គុយលើអាសនៈនោះឡើយ ម្នាលព្រាហ្មណ៍ ព្រោះថា បើតថាគតសំពះអ្នកណា ឬក្រោកទទួលអ្នកណា ឬអញ្ជើញហៅរកអ្នកណា ឲ្យអង្គុយលើអាសនៈ ក្បាលរបស់អ្នកនោះ នឹងដាច់ធ្លាក់ចេញចាក ក ។

ក្នុងពាក្យថា **នាហន្តំ** ជាដើមនោះ មានអត្ថសង្ខេបដូច្នេះថា ម្នាលព្រាហ្មណ៍ តថាគត រំពឹងមើលដោយចក្ខុ គឺសព្វញ្ញុតញ្ញាណ ដែលមិនមានអ្វីទើសទាក់បាន ក៏មិនសម្លឹងឃើញបុគ្គលដែលគួរសំពះ គួរក្រោកទទួល ឬគួរអញ្ជើញដោយអាសនៈ ក្នុងលោកផ្សេងៗ ដោយប្រភេទ មានទេវលោកជាដើមនោះឡើយ ម្យ៉ាងទៀត អ្វីដែលតថាគតបានសម្រេចជាសព្វញ្ញូក្នុងថ្ងៃនេះ មិនឃើញមានបុគ្គលដែលគួរធ្វើការលំអុតលំឱនបែបនោះ មិនជាអស្ចារ្យឡើយ ប្រការមួយទៀតនោះ ក្នុងកាលតថាគតកើតបានមួយភ្លែតប៉ុណ្ណោះ ក៏

បែរមុខទៅទិសខាងជើង ដើរបាន ៧ ជំហាន ហើយបានពិនិត្យមើលលោកធាតុទាំងអស់ សូម្បីក្នុងកាលនោះ តថាគតមិនបានឃើញបុគ្គលដែលតថាគតគួរសំពះ គួរក្រោកទទួល ឬគួរអញ្ជើញដោយអាសនៈក្នុងលោកដទៃ ដោយប្រភេទ មានទេវលោកនេះឡើយ គ្រានោះឯង សូម្បីមហាព្រហ្មដែលជាព្រះខីណាស្រព ដែលមានអាយុបាន ១៦០០០ កប្ប ក៏បានផ្គងអញ្ជលី កើតសោមនស្ស ទទួលតថាគត តថាគតដែលជាមហាបុរសក្នុងលោក ជាអគ្គ-បុគ្គល ចម្រើនក្រៃលែង និងប្រសើរឧត្តមនៃលោក ព្រមទាំងទេវលោក មិនមានបុគ្គលដែលខ្ពស់ជាង ម្យ៉ាងទៀត សូម្បីក្នុងកាលនោះ តថាគតកាលមិនសម្លឹងឃើញបុគ្គលដែលក្រៃលែងជាងខ្លួន ទើបបន្លឺអាសភិវាចាថា យើងជាកំពូលនៃលោក យើងជាបុគ្គលចម្រើនបំផុតក្នុងលោក យើងជាបុគ្គលប្រសើរបំផុតក្នុងលោក ដូច្នេះ បុគ្គលដែលគួរដល់សាមីចិកម្ម មានការសំពះជាដើមរបស់តថាគត សូម្បីកើតបានមួយភ្លែត ក៏គង់មិនមានដោយប្រការដូច្នេះឥឡូវនេះ តថាគតបានសម្រេចសព្វញ្ញុតញ្ញាណហើយ នឹងគប្បីក្រាបថ្វាយបង្គំ គប្បីក្រោកទទួល ឬគប្បីអញ្ជើញបុគ្គលណា ដោយអាសនៈនោះ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកកុំប្រាថ្នាការលំអុតលំឱនបែបនោះ អំពីតថាគតឡើយ ម្នាលព្រាហ្មណ៍ ព្រោះថា តថាគតគប្បីសំពះ គប្បីក្រោកទទួល ឬគប្បីអញ្ជើញបុគ្គលណាដោយអាសនៈ ក្បាលរបស់បុគ្គលនោះ គប្បីដាច់អំពី កធ្លាក់ទៅលើផែនដីដោយរំពេចនោះឯង ដូចផ្លែត្នោតដែលមានគ្រៀងស្អិតជាប់តិច ព្រោះទុំ តែងជ្រុះចាកទងក្នុងទីបំផុតនៃរាត្រី ដូច្នោះ ។

កាលព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រាហ្មណ៍ក៏កំណត់មិនបាន នូវការៈដែលព្រះតថាគតជាចម្បងក្នុងលោក ព្រោះបញ្ញាទន់ខ្សោយ អត់ទ្រាំនឹងព្រះតម្រាស់នោះមិនបាន ទើបពោលថា ព្រះគោតមដ៏ចម្រើន ជាមនុស្សស្រោះកក្រោះ ឥតរសជាតិទេតើ ។ បានឮថា ព្រាហ្មណ៍នោះមានបំណងដូច្នេះថា សាមីចិកម្ម គឺការសំពះ ការក្រោកទទួល និងការថ្វាយបង្គំឯណា ដែលអ្នកស្រុកហៅក្នុងលោកថា សាមគ្គីរស សាមីចិកម្ម មានការសំពះជាដើមនោះរបស់ព្រះគោតម រមែងមិនមាន ព្រោះដូច្នោះ ទើបព្រះគោតមជាបុគ្គលមិនមានរស គឺមានព្រះជាតិមិនមានរស មានសភាពមិនមានរស ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ដើម្បីព្រាហ្មណ៍នោះកើតចិត្តទោរទន់ ទើបទ្រង់ចៀសវាងអំពីភាពជាសត្រូវដោយត្រង់ ទ្រង់ទទួលព្រមសេចក្តីនៃពាក្យនោះ ដោយប្រការដទៃក្នុងព្រះអង្គ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ដូច្នេះជាដើម ។

ក្នុងពាក្យថា **បរិយាយោ** ជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ការណៈឈ្មោះថា បរិយាយ ។ ពិតហើយ **បរិយាយ** សព្ទនេះ រមែងប្រព្រឹត្តទៅក្នុងទេសនា វារៈ និងការណៈ ។

សេចក្តីពិត បរិយាយសព្ទនោះ រមែងប្រព្រឹត្តទៅក្នុងទេសនា ក្នុងពាក្យទាំងឡាយជាដើមថា **មធុបណ្ឌិកបរិយាយោត្វេវ នំ ធារេហិ** ចូរអ្នកចាំទុកនូវសេចក្តីនោះថា ធម្មបរិយាយនេះឈ្មោះថា មធុបិណ្ឌិកបរិយាយ ដូច្នេះចុះ ។

ប្រព្រឹត្តទៅក្នុងវារៈ ក្នុងពាក្យទាំងឡាយជាដើមថា **កស្ស នុ ខោ**

**អានន្ទ អដ្ឋ បរិយាយោ ភិក្ខុនិយោ ឱវទិតុំ** ម្នាលអានន្ទ ថ្ងៃនេះជាវេនភិក្ខុណាហ្ន៎ ដែលត្រូវឲ្យឱវាទពួកភិក្ខុនីតាមវេន ។

ប្រព្រឹត្តទៅក្នុងការណៈ ( ហេតុ ) ក្នុងពាក្យទាំងឡាយជាដើមថា **សាធុ ភន្តេ ភគវា អញ្ញំ បរិយាយំ អាចិក្ខតុ យថា យំ ភិក្ខុសង្ឃោ អញ្ញាយ សណ្ឋហេយ្យ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ ភិក្ខុសង្ឃនេះ គប្បីស្ថិតស្ថេរនៅបានដោយហេតុណា សូមព្រះដ៏មានព្រះភាគទ្រង់សម្តែងហេតុនោះដទៃទៀត ។

ក្នុងទីនេះ បរិយាយសព្ទនោះ រមែងប្រព្រឹត្តទៅក្នុងការណៈ ( ហេតុ ) ព្រោះដូច្នោះ ក្នុងបទថា **បរិយាយោ** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ម្នាលព្រាហ្មណ៍ បុគ្គលពោលរកតថាគតថា ព្រះគោតមដ៏ចម្រើន ជាមនុស្សសោះកក្រោះ ឥតរសជាតិ ដូច្នេះ គប្បីនិយាយត្រូវ គប្បីដល់នូវការរាប់ថាជាអ្នកនិយាយមិនខុស ព្រោះហេតុណា ហេតុនោះ មានពិតដូច្នេះ ។ សួរថា ឯបរិយាយ ( ហេតុ ) នោះ ដូចម្តេច ឆ្លើយថា ម្នាលព្រាហ្មណ៍ ពីព្រោះរសជាតិ គឺរូប សំឡេង ក្លិន ឱជារស សម្ផស្សទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ ។ សួរថា ព្រះដ៏មានព្រះភាគទ្រង់អធិប្បាយដូចម្តេច ឆ្លើយថា ទ្រង់អធិប្បាយ យ៉ាងនេះ គឺរសក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ពោល គឺសេចក្តីត្រេកអរក្នុងកាមសុខទាំងនោះឯណា រមែងកើតឡើងដល់បុថុជ្ជនទាំងឡាយ ដែលសត្វលោកសន្មតថា ជាបុគ្គលប្រសើរដោយអំណាចជាតិ ឬដោយអំណាចបដិសន្ធិ បុគ្គលដែលនៅត្រេកអរ រីករាយ ត្រេក-

ត្រអាល ក្នុងរូបារម្មណ៍ជាដើម រសទាំងនោះឯណា រមែងអូសទាញលោកនេះទុក ដូចចងត្រង់ក ដែលបណ្ឌិតតែងហៅថា សាមគ្គីរស ព្រោះកាលមានការព្រមព្រៀងគ្នានៃវត្ថុ និងអារម្មណ៍ជាដើមក៏កើតឡើងបាន រសទាំងអស់នោះ តថាគតលះបានហើយ ។

កាលព្រះដ៏មានព្រះភាគគួរនឹងត្រាស់ថា តថាគតលះបានហើយ ទ្រង់ក៏សម្តែងធម៌ មិនលើកខ្លួនឡើង ( មកគ្រប់សង្កត់អ្នកដទៃ ) ដោយមមង្ការន័យម្យ៉ាងទៀត សេចក្តីនុ៎ះជាវិលាសនៃទេសនារបស់ព្រះដ៏មានព្រះភាគ ។

បណ្តាបទទាំងនោះ បទថា **បហីនា** សេចក្តីថា រសក្នុងរូបជាដើម ប្រាសទៅអំពីចិត្តសន្តាន ( របស់ព្រះតថាគត ) ឬដែលព្រះតថាគត ទ្រង់លះបានហើយ ។ តែក្នុងអត្ថនេះ គប្បីឃើញឆដ្ឋីវិភត្តិ ចុះក្នុងអត្ថតតិយា-វិភត្តិ ។ រសក្នុងរូបជាដើម ឈ្មោះថា មានឫសគល់ ដែលព្រះដ៏មានព្រះភាគ ទ្រង់កាត់ផ្តាច់ហើយ ព្រោះអត្ថថា ឫសគល់នៃការជាប់ជំពាក់ក្នុងរូបជាដើមនោះ ដែលសម្រេចមកអំពីតណ្ហា និងអវិជ្ជា ដែលព្រះអង្គទ្រង់កាត់ផ្តាច់ហើយដោយសស្ត្រា គឺអរិយមគ្គ ។ ឈ្មោះថា ទ្រង់ធ្វើឲ្យដូចជាត្នោតកំបុតក ព្រោះអត្ថថា វត្ថុនៃរូបរសជាដើមនោះ ដែលព្រះអង្គទ្រង់ធ្វើឲ្យដូចជាត្នោតកំបុតក ដូច្នោះ ។ ដូចឧបមាថា កាលបុគ្គលដកដើមត្នោតឡើង ព្រមទាំងឫសហើយ ធ្វើប្រទេសនោះ ឲ្យគ្រាន់តែជាជង្គត់នៃដើមត្នោតនោះ ការកើតឡើងនៃដើមត្នោតនោះ រមែងប្រាកដមិនបានទៀត យ៉ាងណា កាលព្រះដ៏មានព្រះភាគទ្រង់ដករសក្នុងរូបជាដើមឡើង ព្រមទាំងឫស ដោយសស្ត្រា

គឺអរិយមគ្គហើយ ទ្រង់ធ្វើចិត្តសន្តានឲ្យត្រឹមតែជាទីតាំងនៃរសក្នុងរូបជាដើម នោះ ដោយភាពជាទីធ្លាប់កើតមកក្នុងកាលមុន រសក្នុងរូបជាដើមទាំងអស់ នោះ លោកហៅថា **តាលាវត្ថុកតា** ( ធ្វើឲ្យដូចជាត្នោតកំបុតក ) ដូច្នោះ ។

ម្យ៉ាងទៀត រស មានរូបជាដើមនោះ មានការមិនដុះឡើងជាធម្មតា ដែលព្រះដ៏មានព្រះភាគ ទ្រង់ធ្វើឲ្យដូចជាត្នោតកំបុតក ដូច្នោះ ព្រោះហេតុ នោះ ទើបឈ្មោះថា **តាលាវត្ថុកតា** ។ ម្យ៉ាងទៀត ព្រោះរូបជាដើម ទ្រង់ ធ្វើឲ្យដូចជាត្នោតកំបុតក ដោយន័យដែលពោលមកហើយយ៉ាងនោះ ឈ្មោះ ថា ត្រូវព្រះអង្គទ្រង់ធ្វើមិនឲ្យមានក្នុងកាលជាខាងក្រោយ គឺទ្រង់ធ្វើដោយ អាការ ដែលរូបជាដើមនោះ មិនមានក្នុងកាលជាខាងក្រោយបាន ដូច្នោះ ទើបទ្រង់ត្រាស់ថា **អនភាវំ កតា** ( ធ្វើមិនឲ្យមានក្នុងកាលជាខាងក្រោយ ) ។

## អធិប្បាយសព្ទថា អនភាវំ កតា និង អនភាវំ គតា

ក្នុងបទថា **អនភាវំ កតា** នេះ កាត់បទដូច្នេះ គឺ **អនុ អភាវំ កតា** ភ្ជាប់បទជា **អនភាវំ កតា** ប្រែថា ធ្វើមិនឲ្យមានក្នុងកាលជាក្រោយ ។ បាឋៈថា **អនភាវំ គតា** ដូច្នេះក៏មាន ។ សេចក្តីនៃបាឋៈនោះថា ដល់ហើយ នូវការមិនមានក្នុងកាលខាងក្រោយ ។ ក្នុងបទថា **អនភាវំ គតា** នោះ កាត់បទដូច្នេះ គឺ **អនុ អភាវំ គតា** ភ្ជាប់បទជា **អនភាវំ គតា** ប្រែថា ដល់ហើយនូវការមិនមានក្នុងកាលខាងក្រោយ ដូចការកាត់បទក្នុងប្រយោគ ថា **អនុអច្ឆរិយា** ភ្ជាប់បទជា **អនច្ឆរិយា** ប្រែថា ព្រះគាថាទាំងឡាយជាហេតុ អស្ចារ្យសមគួរនេះ ព្រះដ៏មានព្រះភាគ មិនដែលបានឮក្នុងកាលមុនឡើយ ក៏

កើតប្រាកដដល់ព្រះអង្គ ។

ពីរបទថា **អាយតឹ អនុប្បាទធម្មា** ប្រែថា មានការមិនកើតឡើងក្នុងអនាគតជាសភាវៈ ។ ពិតហើយ រូបរសជាដើមណា ដែលដល់នូវការមិនមានហើយ រូបរសជាដើមនោះ នឹងកើតឡើងបានដូចម្តេច ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ដល់នូវការមិនមានក្នុងកាលជាខាងក្រោយ មានការមិនកើតឡើងតទៅទៀតឡើយ ។

ប្រើនបទថា **អយំ ខោ ព្រាហ្មណ បរិយាយោ** សេចក្តីថា ម្នាលព្រាហ្មណ៍ អ្នកផងគេតែងពោលមករកតថាគតថា ព្រះសមណគោតមជាអ្នកមិនមានរស ដូច្នេះ ឈ្មោះថា គប្បីនិយាយត្រូវដោយហេតុណា ហេតុនេះមានពិតៗ ។

ប្រើនបទថា **នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ** សេចក្តីថា ឯហេតុដែលអ្នកឯងនិយាយសំដៅចំពោះតថាគត មិនមាន ។

សួរថា ព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគត្រាស់យ៉ាងនោះ កាលព្រះអង្គត្រាស់យ៉ាងនោះ គឺ ទ្រង់ទទួលសេចក្តីនូវសាមគ្គីរសដែលព្រាហ្មណ៍ពោលនោះមាននៅក្នុងព្រះអង្គ មិនមែនឬ ខ្ញុំនឹងពោលឆ្លើយតទៅថា សាមគ្គីរសដែលព្រាហ្មណ៍ពោល មិនមានឡើយ ពិតហើយ បុគ្គលណា ជាអ្នកធ្វើសាមគ្គីរសនោះ តែមិនធ្វើ បុគ្គលនោះ គប្បីជាបុគ្គលពោលថា ជាបុគ្គលមានរូបមិនមានរស ព្រោះមិនមានការធ្វើសាមគ្គីរសនោះ ។ ឯព្រះដ៏មានព្រះភាគ ទ្រង់មិនគួរដើម្បីធ្វើសាមគ្គីរសនោះ ព្រោះហេតុនោះ កាលព្រះដ៏មាន

ព្រះភាគទ្រង់ប្រកាសខ្លួនព្រះអង្គ ជាបុគ្គលមិនគួរក្នុងការធ្វើ សាមគ្គីរសនោះ ទើបត្រាស់ថា **នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ** អធិប្បាយថា អ្នកសំដៅដល់ហេតុណា ទើបពោលជាមួយតថាគតថា ជាបុគ្គលមិនមានរស ហេតុនោះ អ្នកមិនគួរពោលក្នុងតថាគតឡើយ ។

ព្រាហ្មណ៍មិនអាចនឹងលើកភាពដែលព្រះដ៏មានព្រះភាគ ជាបុគ្គលមិនមានរស ( ឡើងប្រកាស ) តាមដែលខ្លួនប្រាថ្នាយ៉ាងនោះ ទើបពោលពាក្យដទៃតទៅទៀតថា ព្រះគោតមដ៏ចម្រើន គ្មានគ្រឿងបរិភោគ ម្យ៉ាងទៀត បណ្ឌិតកាលជ្រាបលំដាប់យោជនា ដោយន័យដូចពោលហើយនោះឯង ក្នុងបរិយាយទាំងពួង ក្នុងព្រះបាលីនោះ ក៏គួរជ្រាបអត្ថតាមដែលព្រាហ្មណ៍ពោលសំដៅដោយន័យដូចពោលតទៅនេះថា ព្រាហ្មណ៍សម្គាល់សាមីចិកម្ម មានការសំពះពួកជនដែលចម្រើនដោយវ័យជាដើមនោះឯងថា ជាសាមគ្គីបរិភោគក្នុងលោក ទើបបានពោលនឹងព្រះដ៏មានព្រះភាគថា ជាមនុស្សគ្មានភោគៈ ព្រោះការមិនមានសាមីចិកម្ម មានការសំពះជាដើមនោះ ព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាមិនឃើញ មានការបរិភោគដោយអំណាចឆន្ទរាគៈ ( ដូច ) សត្វទាំងឡាយក្នុងរូបារម្មណ៍ជាដើម ក្នុងព្រះអង្គ ទើបទ្រង់ទទួលបរិយាយ ដទៃទៀត ។

ព្រាហ្មណ៍ពិចារណាឃើញការមិនធ្វើកម្ម គឺមារយាទសម្រាប់ត្រកូលមានការសំពះពួកជនដែលចម្រើនដោយវ័យជាដើម ដែលមហាជនក្នុងលោកធ្វើដល់គ្នានឹងគ្នាក្នុងលោក ទើបពោលជាមួយព្រះដ៏មានព្រះភាគទៀតថា ព្រះ

គោតមដ៏ចម្រើន ជាអ្នកពោលពាក្យឃាត់កិច្ចការ ថាមិនត្រូវធ្វើ ។ តែព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាឃើញថា ការមិនធ្វើនោះ ( មាន ) នៅក្នុងព្រះអង្គ ព្រោះព្រះអង្គត្រាស់ការមិនធ្វើកាយទុច្ចរិតជាដើម ទើបទ្រង់ទទួលដោយបរិយាយដទៃទៀត ។

ឯចេតនាក្នុងការធ្វើជីវិតសត្វឲ្យធ្លាក់ចុះ ក្នុងការកាន់យករបស់ដែលគេមិនបានឲ្យ និងក្នុងមិច្ឆាចារ គប្បីជ្រាបថា ជាកាយទុច្ចរិត ក្នុងបណ្តាបទទាំងនោះ ។ ចេតនាក្នុងការនិយាយកុហក ការនិយាយញុះញង់ ការនិយាយពាក្យគ្រោតគ្រាត និងនិយាយរោយរាយ គប្បីជ្រាបថា ជាវចីទុច្ចរិត ។ ការចង់បាន ការប្រទូស្ត ការយល់ខុស គប្បីជ្រាបថា ជាមនោទុច្ចរិត ។ អកុសលទាំងឡាយដ៏សេស វៀរធម៌ទាំងនេះចេញ គប្បីជ្រាបថា ជាអកុសលធម៌ដ៏លាមក មានចំណែកមិនមែនតិច ។

ព្រាហ្មណ៍មិនឃើញកម្ម មានការសំពះជាដើមនោះឯង ក្នុងព្រះដ៏មានព្រះភាគ យល់ថា អាស្រ័យព្រះដ៏មានព្រះភាគនេះ បែបផែន ប្រពៃណីរបស់លោកនេះ ក៏នឹងដាច់សូន្យ ទើបពោលនឹងព្រះដ៏មានព្រះភាគទៀតថា ព្រះគោតមដ៏ចម្រើន ជាអ្នកពោលពាក្យផ្តាច់ផ្តិលទេតើ ។ តែព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាឃើញការពោលការផ្តាច់ផ្តិលនោះ ( មាននៅ ) ក្នុងព្រះអង្គ ព្រោះព្រះអង្គជាអ្នកពោលការផ្តាច់ផ្តិលនៃរាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ក្នុងចិត្តុប្បាទ ដែលសហគតៈដោយលោភៈ ៨ និងទោសៈដែលកើតឡើងក្នុងអកុសលចិត្ត ២ ដោយអនាគាមិមគ្គ ម្យ៉ាងទៀត ទ្រង់

ត្រាស់ការផ្ដាច់ផ្ដិលនៃមោហៈ ដែលកើតអំពីអកុសលទាំងអស់ មិនមាន សេសសល់ដោយអរហត្តមគ្គ ត្រាស់ការផ្ដាច់ផ្ដិលនៃអកុសលធម៌ដ៏លាមក ដែលសេសសល់ ក្រៅអំពីលោភៈ ទោសៈ មោហៈ ទាំង ៣ នោះ ដោយ មគ្គ ៤ តាមសមគួរ ទើបទ្រង់ទទួលដោយបរិយាយដទៃទៀត ។

ព្រាហ្មណ៍យល់ថា ព្រះសមណគោតម ប្រហែលជាទ្រង់ខ្ពើមរអើមកម្ម គឺមារយាទសម្រាប់ត្រកូល មានការសំពះពួកជន ដែលចម្រើនដោយវ័យជា ដើមនេះ ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់មិនធ្វើកម្មនោះ ក៏ពោលជាមួយ ព្រះដ៏មានព្រះភាគទៀតថា ព្រះគោតមដ៏ចម្រើន ជាអ្នកខ្ពើមរអើមណាស់ ទេតើ ។ តែព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាឃើញការខ្ពើមនោះ ( មាន នៅ ) ក្នុងព្រះអង្គ ព្រោះទ្រង់ខ្ពើមរអើមតែកាយទុច្ចរិតជាដើម ។ ព្រះអង្គ ត្រាស់អធិប្បាយដូចម្ដេច ទ្រង់អធិប្បាយថា ព្រះអង្គខ្ពើមកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ មនោទុច្ចរិត ៣ និងការចូលដល់សេចក្ដីដល់ព្រម ភាពជា បុគ្គលមានការដល់ព្រម ដោយធម៌ទាំងឡាយដ៏សេស វៀរទុច្ចរិតទាំងនោះ ដែលឈ្មោះថា កម្មអាក្រក់ ព្រោះអត្ថថា អាក្រក់ថោកទាប ដែលឈ្មោះថា អកុសល ព្រោះអត្ថថា ជាអំពើមិនឈ្លាសទាំងអស់ ដូចបុរសមានជាតិជា អ្នកស្អិតស្អាងរាងកាយ ខ្ពើមលាមក ដូច្នោះ ទើបទ្រង់ទទួលដោយបរិយាយ ដទៃទៀត ។

បណ្ដាបទទាំងនោះ បទថា **កាយទុច្ចរិតេន** ជាដើម គប្បីជ្រាបថា ជា តតិយាវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។

ព្រាហ្មណ៍កាលសម្លឹងមិនឃើញកម្ម មានការសំពះជាដើម ក្នុងព្រះដ៏មានព្រះភាគ ទើបយល់ថា ព្រះគោតមនេះទ្រង់រមែងបំផ្លាញ គឺទ្រង់ធ្វើកម្មដែលគួរធ្វើដល់បុគ្គលប្រសើរក្នុងលោកនេះឲ្យវិនាស ម្យ៉ាងទៀត ព្រោះទ្រង់មិនធ្វើសាមីចិកម្មនោះ ដូច្នោះ ទើបព្រះគោតមនេះ គួរបំផ្លាញ គឺគួរពោលសង្កត់សង្កិន ទើបពោលនឹងព្រះដ៏មានព្រះភាគទៀតថា ព្រះគោតមដ៏ចម្រើនជាអ្នកបំផ្លាញទេតើ ។

ក្នុងបទថា **វេនយិកោ** នោះ មានអត្ថចំពោះបទយ៉ាងនេះថា ឧបាយដែលឈ្មោះថា **វិនយ** ព្រោះអត្ថថា រមែងកម្ចាត់ ។ អធិប្បាយថា រមែងធ្វើឲ្យវិនាស ។ វិន័យនោះឯង ឈ្មោះ **វេនយិក** ។ ម្យ៉ាងទៀត បុគ្គលរមែងគួរដល់ការកម្ចាត់ ហេតុនោះ ទើបឈ្មោះថា **វេនយិក** ( បុគ្គលគួរកម្ចាត់ ) មានអធិប្បាយថា រមែងគួរដល់ការញាំញីសង្កត់សង្កិន ។ តែព្រះដ៏មានព្រះភាគ ទ្រង់រមែងជាបុគ្គលឈ្មោះថា ជាអ្នកកម្ចាត់ ព្រោះព្រះអង្គទ្រង់សម្តែងធម៌ដើម្បីកម្ចាត់ គឺ ដើម្បីការស្ងប់កិលេសទាំងឡាយ មានរាគៈជាដើម ។ ក្នុងបទថា **វេនយិកោ** នេះ មានអត្ថចំពោះបទទាំងនេះឯង ។ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា **វេនយិក** ព្រោះអត្ថថា ទ្រង់រមែងសម្តែងធម៌ដើម្បីកម្ចាត់ ( កិលេសទាំងឡាយ មានរាគៈជាដើម ) ។ ពិតហើយ វិធីព្រឹទ្ធិនៃតទ្ធិតសព្ទ ជារបស់វិចិត្រ ។ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ពិចារណាឃើញភាពជាអ្នកកម្ចាត់ គឺបំផ្លាញ ( មាននៅ ) ក្នុងព្រះអង្គ ទើបទ្រង់ទទួលដោយបរិយាយដទៃទៀត ។

ព្រាហ្មណ៍យល់ថា ព្រះដ៏មានព្រះភាគនេះ រមែងដុតកម្តៅពួកជនដែលចម្រើនដោយវ័យ ព្រោះជនទាំងឡាយ កាលធ្វើសាមីចិកម្ម មានការសំពះជាដើម រមែងធ្វើជនអ្នកចម្រើនដោយវ័យ ឲ្យត្រេកអរ ឲ្យរីករាយ តែកាលមិនធ្វើ រមែងធ្វើឲ្យក្តៅក្រហាយ អាក់អន់ ឲ្យកើតទោមនស្សដល់ជនដែលចម្រើនដោយវ័យនោះ ហើយព្រះដ៏មានព្រះភាគ មិនធ្វើសាមីចិកម្មទាំងនោះ ។ ម្យ៉ាងទៀត យល់ថា ព្រះដ៏មានព្រះភាគអង្គនេះ ជាបុគ្គលកំព្រា ព្រោះវៀរចាកមារយាទរបស់មនុស្សល្អ ទើបពោលនឹងព្រះដ៏មានព្រះភាគទៀតថា ព្រះសមណគោតមដ៏ចម្រើន ជាអ្នកដុតកម្តៅទេតើ ។

ក្នុងអត្ថវិកប្បដំបូងនោះ មានអត្ថចំពោះបទយ៉ាងនេះថា ធម៌ដែលឈ្មោះថា **តប** ព្រោះអត្ថថា ដុតកម្តៅ មានអធិប្បាយថា រមែងរុកកួន គឺរមែងបៀតបៀន ។ ពាក្យថា **តប** នេះ ជាឈ្មោះនៃការធ្វើសាមីចិកម្ម ។ ព្រះដ៏មានព្រះភាគ ទ្រង់ឈ្មោះថា **តបស្សី** ព្រោះអត្ថថា ទ្រង់មានតបៈ ។ ក្នុងអត្ថវិកប្បទី ២ បណ្ឌិតមិនចាំបាច់ពិចារណាដល់ព្យញ្ជនៈ ហៅមនុស្សកំព្រាក្នុងលោកថា **តបស្សី** ។ តែព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាឃើញការដុតកម្តៅនោះ ( មាននៅ ) ក្នុងព្រះអង្គ ព្រោះទ្រង់ដល់នូវការរាប់ថា ជាអ្នកដុតកម្តៅ ព្រោះទ្រង់លះបង់អកុសលធម៌ទាំងឡាយ ដែលហៅថា ជាទីតាំងនៃការក្តៅក្រហាយ ព្រោះដុតកម្តៅសត្វលោក ទើបទ្រង់ទទួលដោយបរិយាយដទៃទៀត ។

ក្នុងបទថា **តបស្សី** នោះ មានអត្ថចំពោះបទយ៉ាងនេះថា អកុសលធម៌

ទាំងឡាយឈ្មោះថា **តប** ព្រោះអត្ថថា ដុតកម្តៅ ។ ពាក្យថា **តប** នោះ ជាឈ្មោះនៃអកុសលធម៌ទាំងឡាយ ។ សេចក្តីនេះ សមដូចព្រះតម្រាស់ ដែលទ្រង់ត្រាស់ទុកក្នុងគាថាថា

**ឥធ តប្បតិ បេច្ច តប្បតិ ចាបការី ឧភយត្ថ តប្បតិ**
**ចាបំ មេ កតន្តិ តប្បតិ ភិយ្យោ តប្បតិ ទុគ្គតឹ គតោ។**

បុគ្គលអ្នកធ្វើអំពើបាប តែងក្តៅក្រហាយក្នុងលោកទាំង ២ គឺក្តៅក្រហាយក្នុងលោកនេះ ១ ក្តៅក្រហាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងក្តៅក្រហាយ ដោយគិតឃើញថា បាបអញបាន ធ្វើហើយ លុះធ្វើមរណកាល ទៅកាន់ទុគ្គតិ ក៏រឹតតែក្តៅក្រហាយ ដ៏ក្រៃលែង ដូច្នេះ[១] ។

ព្រះដ៏មានព្រះភាគ ឈ្មោះថា **តបស្សី** ព្រោះអត្ថថា ទ្រង់គ្រវែង ទ្រង់ រលាស់ ទ្រង់លះបង់ គឺទ្រង់កម្ចាត់តបធម៌ទាំងនោះចោល ។

ព្រាហ្មណ៍យល់ថា កម្ម មានការសំពះជាដើមនោះ រមែងប្រព្រឹត្តទៅ ដើម្បីការចូលដល់ព្រមនៃគភ៌ក្នុងទេវលោក ដើម្បីបានចំពោះ គឺបដិសន្ធិក្នុង ទេវលោក និងឃើញកម្មនោះ មិនមានក្នុងព្រះដ៏មានព្រះភាគ ទើបពោលនឹង ព្រះដ៏មានព្រះភាគទៀតថា ព្រះគោតមដ៏ចម្រើន ជាមនុស្សឥតកំណើតទេតើ ។ ម្យ៉ាងទៀត ព្រាហ្មណ៍ កាលសម្តែងទោស ព្រោះការកាន់យកបដិសន្ធិក្នុង ផ្ទៃនៃមាតារបស់ព្រះដ៏មានព្រះភាគ ដោយអំណាចសេចក្តីក្រោធ ទើបពោល

---

១- ឋិ. ៥២ យមកវគ្គ ។

យ៉ាងនោះ ។

ក្នុងបទថា **អបគព្ភោ** នោះ មានអត្ថចំពោះបទយ៉ាងនេះថា ព្រះគោតម ឈ្មោះថា **អបគព្ភ** ព្រោះអត្ថថា ប្រាសចាកគព្ភ អធិប្បាយថា ព្រះសមណគោតមមិនសមគួរដល់នូវការកើតក្នុងទេវលោក ។ ម្យ៉ាងទៀត កំណើតរបស់ព្រះសមណគោតមនោះ អាក្រក់ ហេតុនោះ ទើបលោកឈ្មោះ **អបគព្ភ** អធិប្បាយថា ព្រះសមណគោតម ឈ្មោះថា ជាអ្នកមានចំណែកបានគព្ភដែលអាក្រក់តទៅ ព្រោះជាបុគ្គលឆ្ងាយចាកគព្ភក្នុងទេវលោក ព្រោះហេតុនោះ ទើបការនៅក្នុងផ្ទៃនៃមាតារបស់ព្រះសមណគោតមនោះ ជាការអាក្រក់ ។ ក៏ព្រោះការដេកក្នុងគព្ភតទៅរបស់ព្រះដ៏មានព្រះភាគប្រាសចាកទៅហើយ ដូច្នោះ កាលទ្រង់ពិចារណាឃើញការប្រាសចាកគព្ភនោះ ( មាននៅ ) ក្នុងព្រះអង្គ ទើបទ្រង់ទទួលដោយបរិយាយដទៃទៀត ។

បណ្តាបទទាំងនោះអត្ថនៃបទទាំងនោះថា **យស្ស ខោ ព្រាហ្មណ អាយតឹ គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា** ប្រែថា ម្នាលព្រាហ្មណ៍ ព្រោះកិរិយាដេកក្នុងគព្ភតទៅទៀត ដំណើរកើតក្នុងភពតទៅមុខទៀត បើអ្នកណាបានលះបង់ស្រឡះហើយ ព្រោះមានហេតុដែលមគ្គដ៏កំពូលកម្ចាត់បង់ហើយ ។

ក្នុងអធិការនេះ ជលាពុជកំណើត ព្រះដ៏មានព្រះភាគទ្រង់កាន់យកដោយ **គព្ភសេយ្យ** សព្ទ ។ កំណើត ៣ ទៀតក្រៅអំពីនេះ ទ្រង់កាន់យកដោយ **បុនព្ភវាភិនិព្វត្តិ** សព្ទ ។

ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងពីរបទថា **គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ**

នេះ យ៉ាងនេះថា ការដេកនៃសត្វដែលកើតក្នុងគភ៌ ឈ្មោះថា **គព្ភសេយ្យា** ការកើតឡើង គឺភពថ្មី ឈ្មោះថា **បុនព្ភវាភិនិព្វត្តិ** ដូចជាពាក្យថា **វិញ្ញាណដ្ឋិតិ** ទីតាំងដទៃអំពីវិញ្ញាណទៅ រមែងមិនមាន យ៉ាងណា ក្នុងទីនេះក៏ដូច្នោះ មិនគប្បីយល់ការដេកដទៃ ក្រៅអំពីសត្វដែលដេកក្នុងគភ៌ឡើយ ។ ដែលបានឈ្មោះថា ការកើតដែលជាភពថ្មីក៏មាន ដែលមិនមែនភពថ្មីក៏មាន តែក្នុងទីនេះ សំដៅយកការកើតក្នុងភពថ្មី ព្រោះដូច្នោះ ទើបខ្ញុំពោលថា ការកើតឡើង គឺភពថ្មី ឈ្មោះថា **បុនព្ភវាភិនិព្វត្តិ** ។

[ ៣ ] ព្រះដ៏មានព្រះភាគ ទ្រង់ជាធម្មិស្សរ ធម្មរាជា ធម្មសាមី ព្រះតថាគត ទ្រង់ទតមើលព្រាហ្មណ៍ ជាអ្នកកំពុងជេរ ដោយអក្កោសវត្ថុ ៨ មានភាពដែលព្រះអង្គ មានប្រក្រតីមិនជាប់ជំពាក់ក្នុងរូបជាដើម ចាប់តាំងពីពេលដែលមកដល់ ដោយប្រការដូច្នេះ ដោយពុទ្ធចក្ខុដ៏ទន់ត្រជាក់ ដោយព្រះករុណាតែម្យ៉ាង ទ្រង់កម្ចាត់ងងឹតក្នុងហឫទ័យរបស់ព្រាហ្មណ៍ ដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី និងដូចព្រះអាទិត្យ ក្នុងសរទកាល អណ្តែតលយលឿនក្នុងអាកាសដែលប្រាសចាកពពក ដូច្នោះ ព្រោះព្រះអង្គទ្រង់ចាក់ធ្លុះធម្មធាតុឯណាហើយ ដល់នូវលម្អនៃទេសនា ធម្មធាតុនោះ ទ្រង់ចាក់ធ្លុះល្អហើយ ទ្រង់សម្តែងអក្កោសវត្ថុទាំងនោះឯង ដោយប្រការដទៃ អំពីបរិយាយនោះៗហើយ កាលនឹងប្រកាសការផ្សាយទៅនៃព្រះករុណារបស់ព្រះអង្គ លក្ខណៈនៃតាទិគុណ ដែលព្រះអង្គបានហើយ ដោយភាពដែលព្រះអង្គ ទ្រង់មិនបានញាប់ញ័រ ព្រោះលោកធម៌ ៨ ភាពដែលព្រះអង្គមានចិត្តស្មើដោយផែនដី

និងភាពដែលព្រះអង្គមានការមិនកម្រើក ជាធម៌ដដែលទៀត ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍នេះ រមែងជ្រាបការដែលខ្លួនជាធំ ដោយហេតុ ជាបុគ្គលមានសក់ស្កូវលើក្បាល មានធ្មេញបាក់ មានស្បែកយារជាដើមតែម៉្យាង តែមិនដឹងសភាពដែលខ្លួនមានជាតិជាប់តាម ជរាប្រួបរឹត ព្យាធិគ្របសង្កត់ មរណៈកម្ចាត់ ដូចជន្លត់ក្នុងវដ្តៈដែលគប្បីស្លាប់ក្នុងថ្ងៃនេះ ហើយដល់នូវភាពជាទារកដេកផ្ងារ ក្នុងថ្ងៃស្អែកនេះទៀត ឯព្រាហ្មណ៍នេះមកកាន់សម្នាក់របស់តថាគតដោយភាពឧស្សាហ៍ធំ ដូច្នេះ ចូរឲ្យការមករបស់ព្រាហ្មណ៍នោះ ប្រព្រឹត្តទៅដោយប្រយោជន៍ចុះ ដូច្នេះហើយ កាលទ្រង់សម្តែងភាពដែលព្រះអង្គជាអ្នកកើតមុន ដែលនឹងរកបុគ្គលប្រៀបផ្ទឹមមិនបានក្នុងលោកនេះ ទើបញ៉ាំងព្រះធម្មទេសនាឲ្យចម្រើនដល់ព្រាហ្មណ៍ ដោយន័យថា **សេយ្យថាបិ ព្រាហ្មណ** ជាដើម បណ្តាសព្ទនោះ បទថា **សេយ្យថា** ជានិបាត ចុះក្នុងអត្ថគឺឧបមា ។ **បិ** សព្ទ ជានិបាត ចុះក្នុងអត្ថ គឺសម្ភាវនៈ ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងថា **យថា នាម ព្រាហ្មណ** ដោយនិបាតសព្ទទាំង ២ ឯក្នុងពាក្យថា ពងមាន់ ៨ ក្តី ១០ ក្តី ១២ ក្តីនេះ សូម្បីពងមាន់មានចំនួនតិចឬច្រើនជាងចំនួនដូចដែលពោលហើយ ក៏ពិតមែនហើយ តែក៏គួរជ្រាបថា ព្រះដ៏មានព្រះភាគត្រាស់ពាក្យយ៉ាងនេះ ព្រោះជាសេចក្តីពីរោះរណ្តំនៃពាក្យ ។ ពិតហើយ ពាក្យដូច្នោះ រាប់ថាជាពាក្យពីរោះរណ្តំក្នុងផ្លូវលោក ។

បទថា **តានិស្សុ** កាត់បទជា **តានិ អស្សុ** អធិប្បាយថា **ភវេយ្យុំ** ប្រែថា ពងមាន់ទាំងនោះគប្បីមាន ។ បទជាច្រើនថា **កុក្កុដិយា សម្មា**

**អធិសយិតានិ** *សេចក្តីថា ពងទាំងឡាយដែលមេមាន់ឲ្យកំណើតនោះ ត្រដាងស្លាបចេញមកដេកក្រាប នៅខាងលើនៃពងទាំងនោះ ឈ្មោះថា ក្រាបដោយប្រពៃហើយ ។*

*ពីរបទថា* **សម្មា បរិសេទិតានិ** *សេចក្តីថា កាលមេមាន់ឲ្យពងបានទទួលកម្តៅ តាមពេលវេលាដ៏សមគួរ ឈ្មោះថា ឲ្យកម្តៅដោយទូទៅដោយល្អ ។ មានពាក្យអធិប្បាយថា ធ្វើឲ្យមានកម្តៅ ។*

*ពីរបទថា* **សម្មា បរិភាវិតានិ** *សេចក្តីថា ពងទាំងឡាយដែលមេមាន់ក្រាបពាល់ត្រូវដោយទូទៅ តាមកាលវេលាដ៏សមគួរ ។ អធិប្បាយថា ឲ្យបានទទួលក្លិនខ្លួនអំពីមេមាន់ ។*

*ឥឡូវនេះ ព្រោះពងមាន់ទាំងនោះ ដែលមេមាន់នោះ បរិបាលហើយដោយវិធីទាំង ៣ យ៉ាងនេះ ទើបពងមិនស្អុយ កាលទឹករំអិលនៃពងទាំងនោះដល់នូវការអស់ទៅ សម្បកពងមាន់នឹងស្តើង ចុងក្រចកក្តី ចំពុះក្តី នឹងរឹង ។ កូនមាន់ទាំងឡាយ ( ដែលនៅខាងក្នុងពង ) រមែងដល់នូវភាពមានខ្លួនចាស់ ពន្លឺខាងក្រៅ រមែងប្រាកដដល់ខាងក្នុង ព្រោះសម្បកពងស្តើង វេលាពន្លឺកំពុងប្រាកដនោះ កូនមាន់ទាំងនោះស្រមើស្រមៃថា យូរពិតហ្ន៎ ពួកយើងដេកបត់ស្លាប និងជើងនៅក្នុងទីចង្អៀត ឯពន្លឺខាងក្រៅក៏កំពុងប្រាកដឥឡូវនេះ ការនៅយ៉ាងសប្បាយ នឹងមានដល់ពួកយើងក្នុងពន្លឺនេះ ដូច្នេះ ទើបមានបំណងនឹងចេញមក ទើបយកជើងចោះទម្លាយសម្បកពង អើត កចេញមក ។ បន្ទាប់អំពីនោះ សម្បកពងមាន់នោះក៏បែកចេញជាពីរចំណែក ។*

កូនមាន់ទាំងឡាយក៏ចេញមក រលាស់ស្លាបបណ្តើរ ស្រែកបណ្តើរ តាមសមគួរដល់ខណៈនោះ ។ បណ្តាកូនមាន់ទាំងនោះ ដែលចេញមកយ៉ាងនោះ កូនមាន់ណាចេញមកមុនគេ កូនមាន់នោះ ហៅថា កូនច្បង ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ មានបំណងនឹងញ៉ាំងភាពដែលព្រះអង្គជាធំជាងគេ ឲ្យសម្រេចដោយឧបមានោះ ទើបត្រាស់សួរព្រាហ្មណ៍ថា បណ្តាកូនមាន់ទាំងនោះ កូនមាន់ណាទម្លាយសម្បកពង ដោយចុងក្រចក ឬដោយចុងចំពុះ ហើយញាស់ចេញមកបានដោយស្រួលមុនគេបំផុត បើដូច្នោះ តើអ្នកផងគួរហៅកូនមាន់នោះថា កូនច្បង ឬកូនពៅ ។

បណ្តាបទទាំងនោះ បទថា **កុក្កុដច្ឆាបកានំ** ប្រែថា បណ្តាកូនមាន់ គឺបណ្តាកូនមាន់ទាំងឡាយ ។

បទជាច្រើនថា **កិន្តិ ស្វាស្ស វចនីយោ** សេចក្តីថា កូនមាន់នោះគួរហៅដូចម្តេច គឺគួរហៅថា បង ឬប្អូន ពាក្យដ៏សេសមានអត្ថងាយហើយ ។

លំដាប់នោះ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ( កូនមាន់នោះ ) អ្នកផងគួរហៅថា កូនច្បង អធិប្បាយថា បពិត្រព្រះគោតមដ៏ចម្រើន កូនមាន់នោះ គួរហៅថា កូនច្បង ។ បើមានពាក្យសួរថា ហេតុដូចម្តេច ទើបហៅថា បង ឆ្លើយថា ព្រោះកូនមាន់នោះ ចាស់ជាងគេ អធិប្បាយថា ព្រោះកូនមាន់នោះធំចម្រើនជាងបណ្តាកូនមាន់ ដែលញាស់មកក្នុងកាលខាងក្រោយទាំងនោះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រៀបធៀបសេចក្តីឧបមា

ដល់ព្រាហ្មណ៍នោះ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ កាលបើពួកសត្វ ដូចជាពងមាន់កើតហើយ មានអវិជ្ជា គឺសេចក្តីល្ងង់ ដូចជាសម្បកពងកំពុងរួបរឹតក្នុងលោក មានតែតថាគត ដែលទម្លាយសម្បកពង គឺសេចក្តីល្ងង់ ហើយត្រាស់ដឹងខ្លួនឯងដោយប្រពៃ នូវសម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតិឯទៀតប្រសើរជាងឡើយ ម្នាលព្រាហ្មណ៍ តថាគតនេះឯង ជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក ។

ការមិនដឹង លោកហៅថា **អវិជ្ជា** ក្នុងបទថា **អវិជ្ជាគតាយ** នេះសេចក្តីថា បណ្តាពួកសត្វដែលធ្លាក់នៅក្នុងអវិជ្ជានោះ ។ ពាក្យថា **បជាយ** នេះ ជាឈ្មោះរបស់សត្វ ។ ព្រោះដូច្នោះ ក្នុងពាក្យថា **អវិជ្ជាគតាយ បជាយ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា បណ្តាសត្វទាំងឡាយដែលធ្លាក់ចូលទៅខាងក្នុងនៃសម្បកពង គឺអវិជ្ជា ។

បទថា **អណ្ឌភូតាយ** សេចក្តីថា ដែលកើតហើយ អ្នកកើតហើយ គឺបុគ្គលកើតព្រមហើយក្នុងពង ដូចជាសត្វពួកខ្លះដែលកើតក្នុងពង គេហៅថា **អណ្ឌភូតា** យ៉ាងណា ពួកសត្វទាំងអស់នេះ ក៏យ៉ាងនោះ លោកហៅថា **អណ្ឌភូតា** ព្រោះការដែលខ្លួនកើតក្នុងសម្បកពង គឺអវិជ្ជា ។

បទថា **បរិយោនទ្ធាយ** សេចក្តីថា បុគ្គលដែលសម្បកពង គឺអវិជ្ជានោះរួបរឹត គឺចងធ្វាក់ ព័ទ្ធព័ន្ធដោយជុំវិញ ។

បទថា **អវិជ្ជណ្ឌកោសំ បទាលេត្វា** សេចក្តីថា តថាគតបានទម្លាយសម្បកពងដែលសម្រេចមកអំពីអវិជ្ជានោះហើយ ។

ពីរបទថា **ឯកោវ លោកេ** សេចក្ដីថា ក្នុងលោកសន្និវាសទាំងមូល មានតែតថាគតម្នាក់ប៉ុណ្ណោះ គឺមិនមានបុគ្គលជាគម្រប់ពីរ ។

បទថា **អនុត្តរំ** ក្នុងពាក្យថា **អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ** នេះ សេចក្ដីថា វៀរចាកអរិយមគ្គដ៏ប្រសើរចេញហើយ គឺប្រសើរជាងធម៌ទាំងពួង។

បទថា **សម្មាសម្ពោធឹ** ប្រែថា ត្រាស់ដឹងខ្លួនឯងដោយប្រពៃ គឺត្រាស់ដឹងដោយប្រពៃ និងដោយព្រះអង្គឯង ។ម្យ៉ាងទៀត ប្រែថា ត្រាស់ដឹងដោយប្រពៃ និងដោយព្រះអង្គឯង ។ ម្យ៉ាងទៀត ប្រែថា នូវការត្រាស់ដឹងដែលអ្នកប្រាជ្ញសរសើរផង ល្អផង ។

## បទថា ពោធិ មានអត្ថ ៤ យ៉ាង

ដើមឈើក្ដី មគ្គក្ដី សព្វញ្ញុតញ្ញាណក្ដី និព្វានក្ដី លោកហៅថា **ពោធិ**។

ពិតហើយ លោកហៅដើមឈើថា **ពោធិ** ក្នុងទីទាំងឡាយ ដែលមកហើយថា **ពោធិរុក្ខមូលេ បឋមាភិសម្ពុទ្ធោ** បានត្រាស់ដឹងដំបូង ត្រង់មណ្ឌលពោធិព្រឹក្ស និងពាក្យមួយទៀតថា **អន្តរា ច គយំ អន្តរា ច ពោធឹ** ក្នុងចន្លោះនៃដើមពោធិ៍ និងស្ទឹងគយា ។

មគ្គ លោកហៅថា **ពោធិ** ក្នុងបទដែលមកហើយថា **ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ** ញាណក្នុងមគ្គទាំង ៤ លោកហៅថា **ពោធិ** ។

សព្វញ្ញុតញ្ញាណ លោកហៅថា **ពោធិ** ក្នុងទីដែលមកហើយថា **បប្បោតិ ពោធឹ វរភូរិមេធសោ** ជាអ្នកមានប្រាជ្ញាដ៏ប្រសើរ ប្រៀបដូចផែនដី និងបានដល់ ( សម្រេច ) ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ មានចំណែកដ៏ប្រសើរ

ក្នុងផ្លូវប្រាជ្ញា ។

ព្រះនិព្វាន លោកហៅថា **ពោធិ** ក្នុងទីដែលមកហើយថា **បត្វាន ពោធឹ អមតំ អសង្ខតំ** ព្រះសិទ្ធត្ថពោធិសត្វ ទ្រង់សម្រេចពោធិ ដែលជាអមតៈ ជាអសង្ខតៈ ។

តែក្នុងបទថា **សម្មាសម្ពោធឹ** នេះ លោកសំដៅយកអរហត្តមគ្គញ្ញាណរបស់ព្រះដ៏មានព្រះភាគ។ អាចារ្យពួកខ្លះពោលថា ប្រាជ្ញាយកសព្វញ្ញុតញ្ញាណ។

សួរថា អរហត្តមគ្គរបស់ពួកបុគ្គលដទៃ ( ក្រៅអំពីព្រះពុទ្ធ ) រាប់ថាជាពោធិដ៏កំពូលដែរឬទេ ឆ្លើយថា មិនចាត់ជាពោធិដ៏កំពូលទេ សួរថា ព្រោះហេតុអ្វី ទើបមិនចាត់ជាពោធិដ៏កំពូល ឆ្លើយថា ព្រោះអរហត្តមគ្គរបស់ពួកបុគ្គលដទៃនោះ មិនផ្តល់នូវគុណគ្រប់យ៉ាង ។

ពិតហើយ អរហត្តមគ្គរបស់បណ្តាបុគ្គលទាំងនោះ បុគ្គលខ្លះ បានចំពោះអរហត្តផលប៉ុណ្ណោះ ។ បុគ្គលខ្លះ បានចំពោះវិជ្ជា ៣ បុគ្គលខ្លះបានចំពោះអភិញ្ញា ៦ បុគ្គលខ្លះបានចំពោះបដិសម្ភិទា ៤ បុគ្គលខ្លះបានចំពោះសាវកបារមីញាណ សូម្បីព្រះបច្ចេកពុទ្ធទាំងឡាយ ក៏បានចំពោះបច្ចេកពោធិញ្ញាណប៉ុណ្ណោះ ចំណែកអរហត្តមគ្គរបស់ព្រះពុទ្ធទាំងឡាយ រមែងឲ្យគុណសម្បត្តិគ្រប់យ៉ាង ដូចការអភិសេករបស់ព្រះរាជា ឲ្យនូវភាពជាធំក្នុងលោកទាំងមូល ដូច្នោះ ព្រោះដូច្នោះ ទើបអរហត្តមគ្គរបស់បុគ្គលដទៃខ្លះ មិនរាប់ថា ជាពោធិដ៏កំពូល ដោយប្រការដូច្នេះ ។

បទថា **អភិសម្ពុទ្ធោ** ដឹងក្រៃលែង សេចក្តីថា តថាគតបានដឹងក្រៃលែង

ហើយ គឺបានចាក់ធ្លុះហើយ អធិប្បាយថា តថាគតបានសម្រេច ហើយ គឺបានដល់រួចហើយ ។

ឥឡូវនេះ បណ្ឌិតគួរប្រៀបធៀបពាក្យឧបមា ដែលព្រះដ៏មានព្រះភាគត្រាស់ដោយន័យជាដើមថា **ឯវមេវ ខោ អហំ ព្រាហ្មណ** ហើយគប្បីជ្រាបសេចក្ដីដោយន័យដូចពោលតទៅនេះថា ដូចការដែលមេមាន់នោះ ធ្វើកិរិយាទាំង ៣ មានការក្រាបនៅលើពងទាំងឡាយជាដើមរបស់ខ្លួន យ៉ាងណា សេចក្ដីដែលព្រះដ៏មានព្រះភាគ ទ្រង់ញុំាងកាលជាពោធិសត្វ អង្គុយលើពោធិបល្ល័ង្កហើយទ្រង់បំពេញអនុបស្សនាទាំង ៣ គឺមិនទៀង ជាទុក្ខ ជាអនត្តា ក្នុងចិត្តសន្តានរបស់ព្រះអង្គ ក៏ដូច្នោះ ។

ការមិនសាបសូន្យទៅនៃវិបស្សនាញាណ ក៏ព្រោះព្រះដ៏មានព្រះភាគកាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឲ្យដល់ព្រមប្រៀបដូចពងទាំងឡាយមិនស្អុយ ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ឲ្យដល់ព្រមដូច្នោះ ។

ការអស់ទៅនៃសេចក្ដីស្រឡាញ់ គឺការជាប់ចិត្តទៅក្នុងត្រៃភព ក៏ព្រោះព្រះដ៏មានព្រះភាគ កាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឲ្យដល់ព្រម ប្រៀបដូចការអស់ទៅនៃទឹករំអិលរបស់ពងទាំងឡាយ ក៏ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ។

ភាពដែលសម្បកពង គឺអវិជ្ជា ជាធម្មជាតិស្តើង ក៏ព្រោះព្រះដ៏មានព្រះភាគ កាលនៅជាព្រះពោធិសត្វទ្រង់បំពេញអនុបស្សនាទាំង ៣ ឲ្យដល់

ព្រម ប្រៀបដូចសម្បកពងទៅជាស្ដើង ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ។

ភាពដែលវិបស្សនាញាណ ជាគុណជាតិរឹងមាំ ផូរផង់ និងអង់អាច ក៏ព្រោះព្រះដ៏មានព្រះភាគ កាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឲ្យដល់ព្រម ប្រៀបដូចក្រចក និងចំពុះរបស់កូនមាន់ ជារបស់គ្រោតគ្រាត និងរឹងមាំ ក៏ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ។

គួរជ្រាបខណៈដែលវិបស្សនាញាណចាស់ក្លា ខណៈចម្រើន ( និង ) ខណៈកាន់យកបន្ទប់ ក៏ព្រោះព្រះដ៏មានព្រះភាគ កាលនៅជាព្រះពោធិសត្វ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឲ្យដល់ព្រម ប្រៀបដូចខណៈដែលកូនមាន់ចម្រើនហើយ ក៏ព្រោះមេធ្វើកិរិយាទាំង ៣ ដូច្នោះ ។

ព្រោះហេតុនោះ គួរជ្រាបវេលាដែលព្រះដ៏មានព្រះភាគ ទ្រង់ឲ្យវិបស្សនាញាណកាន់យកបន្ទប់ ហើយទម្លាយសម្បកពង គឺអវិជ្ជា ដោយអរហត្តមគ្គ ដែលព្រះអង្គទ្រង់បានសម្រេចដោយលំដាប់ ហើយទ្រង់ទទះស្លាប គឺអភិញ្ញា ទើបទ្រង់ធ្វើឲ្យជាក់ច្បាស់នូវពុទ្ធគុណទាំងអស់ ដោយសួស្ដី ក៏ព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បំពេញអនុបស្សនាទាំង ៣ ឲ្យដល់ព្រម ប្រៀបដូចវេលាដែលកូនមាន់យកចុងក្រចក និងចំពុះចោះសម្បកពង ហើយទទះស្លាបចេញមកបានដោយសួស្ដី ក៏ព្រោះមេមាន់ធ្វើកិរិយាទាំង ៣ ដូច្នោះ ។

បទជាច្រើនថា **ស្វាហំ ព្រាហ្មណា ជេដ្ឋោ សេដ្ឋោ លោកស្ស** សេចក្ដីថា ម្នាលព្រាហ្មណ៍ បណ្ដាពួកសត្វដែលធ្លាក់នៅក្នុងអវិជ្ជា តថាគត

នោះបានទម្លាយសម្បកពង គឺអវិជ្ជានោះហើយ ដល់នូវការរាប់ថា ជាបុគ្គលចម្រើនបំផុត គឺចម្រើនឧត្ដម ព្រោះជាអ្នកកើតហើយដោយអរិយជាតិមុនគេបង្អស់ ប្រៀបដូចបណ្ដាកូនមាន់ទាំងនោះ កូនមាន់ដែលចោះទម្លុះសម្បកពងចេញមកបានមុនគេ រមែងជាកូនមាន់ច្បង ដូច្នោះ ចំណែកព្រះដ៏មានព្រះភាគឈ្មោះថា ដល់នូវការរាប់ថា ជាបុគ្គលប្រសើរបំផុត ព្រោះមិនមានបុគ្គលណា ប្រៀបផ្ទឹមបានដោយព្រះគុណទាំងពួង ។

ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រកាសភាពដែលព្រះអង្គ ជាបុគ្គលចម្រើនបំផុត និងប្រសើរបំផុត ជាអគ្គបុគ្គលដល់ព្រាហ្មណ៍យ៉ាងនោះហើយ ឥឡូវនេះ ដើម្បីសម្ដែងបដិបទាដែលជាហេតុឲ្យទ្រង់សម្រេចជាបុគ្គលចម្រើនបំផុតជាដើមនោះ ចាប់តាំងអំពីចំណែកខាងដើម ទើបត្រាស់ថា **អារទ្ធំ ខោ បន មេ ព្រាហ្មណ** ជាដើម ។

ម្យ៉ាងទៀត ព្រោះបានស្ដាប់សេចក្ដីដែលព្រះដ៏មានព្រះភាគជាបុគ្គលចម្រើនបំផុត និងប្រសើរបំផុត ជាអគ្គបុគ្គលនេះហើយ ទើបព្រាហ្មណ៍កើតគំនិតយ៉ាងនេះថា ព្រះដ៏មានព្រះភាគ ទ្រង់បានសម្រេចភាពជាបុគ្គលចម្រើនបំផុត និងប្រសើរបំផុតដោយបដិបទា ដូចម្ដេចហ្ន៎ ដូច្នេះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបការគិតរបស់ព្រាហ្មណ៍នោះហើយ កាលទ្រង់សម្ដែងថា តថាគតបានសម្រេចភាពជាបុគ្គលចម្រើនបំផុត និងប្រសើរបំផុត ជាអគ្គបុគ្គលនេះដោយបដិបទានេះ ទើបទ្រង់ត្រាស់យ៉ាងនេះ ។

បណ្ដាបទទាំងនោះ បទជាច្រើនថា **អារទ្ធំ ខោ បន មេ ព្រាហ្មណ**

**វីរិយំ អហោសិ** សេចក្តីថា ម្នាលព្រាហ្មណ៍ ការដែលតថាគតជាចម្បង និងប្រសើរបំផុត ជាអគ្គបុគ្គលនេះ តថាគតមិនបានសម្រេចដោយការខ្ជិលច្រអូស ដោយការវង្វេងភ្លេចសតិ ដោយការមានកាយសោប់សេល់ ( និង ) ដោយការមានចិត្តរាយមាយនោះឡើយ ។ ម្យ៉ាងទៀត ព្រោះតថាគតប្រារព្ធសេចក្តីព្យាយាមហើយ ដើម្បីសម្រេចភាពជាបុគ្គលចម្បងបំផុត និងប្រសើរបំផុតនោះ គឺតថាគតអង្គុយហើយ ត្រង់ពោធិមណ្ឌល បានប្រារព្ធសេចក្តីព្យាយាមប្រកបដោយអង្គ ៤ អធិប្បាយថា បានផ្គង គឺឲ្យប្រព្រឹត្តទៅមិនធូរថយ ។ ឯសេចក្តីព្យាយាមនោះ បានឈ្មោះថា ជាគុណជាតិមិនធូរថយ ព្រោះតថាគតបានប្រារព្ធហើយយ៉ាងពិតប្រាកដ ទាំងមិនមែនតែការព្យាយាមតែម្យ៉ាងប៉ុណ្ណោះឡើយ សូម្បីសតិរបស់តថាគតក៏បាន ចូលទៅតាំងចំពោះហើយ ដោយភាពជាគុណធម៌បែរមុខត្រង់ចំពោះអារម្មណ៍ និងឈ្មោះថា ជាការមិនវង្វេង ព្រោះប្រាកដនៅចំពោះមុខនោះឯង ។

ពីរបទថា **បស្សទ្ធោ កាយោ** សេចក្តីថា សូម្បីកាយរបស់តថាគតក៏ជារបស់ស្ងប់ហើយ ដោយអំណាចនៃកាយបស្សទ្ធិ និងចិត្តបស្សទ្ធិ ។ កាលនាមកាយស្ងប់ហើយ សូម្បីរូបកាយក៏ស្ងប់ដូចគ្នា ដូច្នោះ ក្នុងព្រះបាលីនោះ ព្រះដ៏មានព្រះភាគ មិនត្រាស់ឲ្យពិស្តារឡើយថា នាមកាយ រូបកាយ ត្រាស់ត្រឹមតែកាយស្ងប់ប៉ុណ្ណោះ ។

បទថា **អសារទ្ធោ** សេចក្តីថា កាយនោះ ឈ្មោះថា មិនមានការសោប់សេល់ ព្រោះជាកាយដែលស្ងប់ហើយនោះឯង អធិប្បាយថា ជាកាយ

ដែលប្រាសចាកសេចក្ដីក្រវល់ក្រវាយហើយ ។

បទជាច្រើនថា **សមាហិតំ ចិត្តំ ឯកគ្គំ** សេចក្ដីថា សូម្បីចិត្តរបស់តថាគត ក៏តាំងនៅហើយដោយប្រពៃ គឺតាំងមាំល្អហើយ ជាចិត្តមាំទាំហើយ ហើយចិត្តរបស់តថាគតនោះ ឈ្មោះថា មានអារម្មណ៍តែមួយ គឺមិនញាប់ញ័របានដល់ មិនមានការក្ដៅក្រហាយ ព្រោះជាចិត្តតម្កល់មាំល្អនោះឯង ។ វត្តបដិបត្តិជាចំណែកខាងដើមនៃឈាន គឺព្រះដ៏មានព្រះភាគត្រាស់ហើយ ដោយលំដាប់មានប្រមាណប៉ុណ្ណេះ ។

# បឋមជ្ឈានកថា

ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងគុណវិសេស តាំងអំពីបឋមជ្ឈាន រហូតដល់វិជ្ជា ៣ ជាទីបំផុត ដែលទ្រង់បានសម្រេចហើយដោយបដិបទានេះ ទើបត្រាស់ថា **សោ ខោ អហំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ អត្ថនៃបទជាដើមថា **វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ** ព្រះដ៏មានព្រះភាគត្រាស់ហើយក្នុងវិកប្ប៍នោះឯងដោយន័យជាដើមថា បណ្តាកាម និងអកុសលធម៌ទាំងនោះ កាមដូចម្តេច គឺ ការពេញចិត្ត ឈ្មោះថា កាម តម្រេក ឈ្មោះថា កាម តម្រេកដោយអំណាចការពេញចិត្ត ឈ្មោះថា កាម ការត្រិះរិះ ឈ្មោះថា កាម រាគៈ ឈ្មោះថា កាម រាគៈដោយអំណាចការត្រិះរិះ ឈ្មោះថា កាម ទាំងនេះតថាគតហៅថា កាម ។ បណ្តាកាម និងអកុសលធម៌ទាំងនោះអកុសលធម៌ដូចម្តេច កាមច្ឆន្ទៈ ព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា ពួកកិលេសទាំងនេះ ហៅថា អកុសលធម៌ ។ ភិក្ខុជាអ្នកស្ងាត់ចាកកាមទាំងនេះផង ចាកអកុសលធម៌ទាំងនេះផង ហេតុនោះ ទើបទ្រង់ត្រាស់ថា ស្ងាត់ចាកកាមទាំងឡាយ ចាកអកុសលធម៌ទាំងឡាយ ដោយប្រការដូច្នេះ សេចក្តីនេះពិតមែនហើយ តែសេចក្តី ( នៃបទទាំងនោះ ) វៀរន័យរបស់អដ្ឋកថាចេញនឹងប្រាកដដោយល្អមិនបាន ខ្ញុំនឹងប្រកាសអត្ថនោះតាមអដ្ឋកថានោះឯង យ៉ាងនេះថា សេចក្តីនេះដូចម្តេច សេចក្តីនេះដូច្នេះ គឺពីរបទថា **វិវិច្ចេវ កាមេហិ** ប្រែថា ស្ងាត់ចាកកាមទាំងឡាយ គឺចៀសចេញចាកកាមទាំងឡាយ ។

# អធិប្បាយ ឯវ អក្ខរៈ

ឯ **ឯវ** អក្ខរៈនេះ ក្នុងបទថា **វិវិច្ចេវ** នេះ គប្បីជ្រាបថា មានការកំណត់ជាអត្ថ ។ ព្រោះ **ឯវ** អក្ខរៈ មានការកំណត់ជាអត្ថនោះ ដូច្នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់សំម្តែងភាពដែលកាមទាំងឡាយ សូម្បីមិនមានក្នុងវេលាចូលបឋមជ្ឈានទោះ ក៏ជាសត្រូវដល់បឋមជ្ឈាននោះ ហើយការសម្រេចបឋមជ្ឈាននោះបាន ក៏ដោយការលះបង់កាមនោះឯង ។ សួរថា សេចក្តីនោះដូចម្តេច ឆ្លើយថា គឺស្ងាត់ហើយចាកកាមទាំងឡាយនោះឯង អធិប្បាយថាពិតហើយ កាលធ្វើសេចក្តីនិយមយ៉ាងនោះ ពាក្យនេះ រមែងប្រាកដច្បាស់ថាកាមទាំងឡាយ រមែងជាសត្រូវចំពោះឈានយ៉ាងពិតប្រាកដ កាលកាមពួកណា មានបឋមជ្ឈាននេះ រមែងប្រព្រឹត្តទៅមិនបាន ដូចកាលមានងងឹត ពន្លឺប្រទីបក៏មិនមានដូច្នោះ ឯការសម្រេចបឋមជ្ឈាននោះ នឹងមានបានដោយការលះបង់កាមទាំងនោះចេញបាន ប្រៀបដូចការទៅកាន់ត្រើយនាយបាន ក៏ដោយការលះត្រើយអាយនេះ ដូច្នោះ ។ ព្រោះដូច្នោះ ទើបលោកធ្វើការកំណត់ដូច្នេះ ។

ក្នុងពាក្យថា **វិវិច្ចេវ កាមេហិ** នោះ គប្បីមានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគត្រាស់ **ឯវ** អក្ខរៈនោះចំពោះបទដើមប៉ុណ្ណោះ មិនត្រាស់ក្នុងបទក្រោយផង ព្រះយោគាវចរសូម្បីមិនស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏គប្បីបានសម្រេចឈានឬ ឆ្លើយថា ឯ **ឯវ** អក្ខរៈ ដែលជា**អវធារណា** នោះ បណ្ឌិតមិនគួរឃើញយ៉ាងនោះ ព្រោះថា **ឯវ** អក្ខរៈនោះព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងបទដើម ក៏ព្រោះឈានជាគ្រឿងរលាស់ចោល

នូវកម្មនោះ ។ ពិតហើយ ឈាននេះ ឈ្មោះថា រលាស់ចោលនូវកាមទាំង-ឡាយនោះឯង ព្រោះឈានកន្លងកាមធាតុបាន និងព្រោះជាសត្រូវចំពោះកាមរាគៈ ដូចព្រះសារីបុត្រពោលថា **កាមានមេតំ និស្សរណំ យទិទំ នេក្ខម្មំ** ការរលាស់ចេញចាកកាមទាំងឡាយនេះ បានដល់ នេក្ខម្មៈ គឺ បឋមជ្ឈាន ដូច្នេះ ។

**ឯវ** អក្ខរៈនោះ បណ្ឌិតគួរពោលទុកក្នុងបទក្រោយ ដូច **ឯវ** អក្ខរៈ ដែលព្រះដ៏មានព្រះភាគ ទ្រង់នាំមកត្រាស់ទុកក្នុងពាក្យនេះថា **ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ** ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ( គឺសោតាបន្ន ) មានតែក្នុងសាសនានេះ សមណៈទី ២ ( គឺសកទាគាមី ) ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ( គឺអនាគាមី ) ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ( គឺអរហន្ត ) ក៏មានតែក្នុងសាសនានេះ ដូច្នេះ ។ ពិតហើយ បុគ្គលណាមួយ មិនស្ងាត់ហើយចាកអកុសលធម៌ទាំងឡាយ ពោល គឺនីវរណៈដទៃអំពីកាមច្ឆន្ទៈនេះ មិនអាចសម្រេចឈានបានឡើយ ព្រោះដូច្នោះ បណ្ឌិតគប្បីឃើញការនិយមនេះ ក្នុងបទទាំង ២ យ៉ាងនេះថា ព្រះយោគាវចរស្ងាត់ហើយចាកកាមទាំងឡាយ ស្ងាត់ហើយចាកអកុសលធម៌ទាំងឡាយ ដូច្នេះ ។

ម្យ៉ាងទៀត វិវេកទាំងអស់ មានតទង្គវិវេក និងកាយវិវេកជាដើម រមែងដល់នូវការសង្គ្រោះចូលក្នុងបទទាំង ២ ដោយពាក្យដែលជាសាធារណៈនេះថា **វិវិច្ច** ក៏ពិត ដូច្នោះ ក្នុងអធិការនេះ ក៏គួរឃើញវិវេកត្រឹមតែ ៣

ប៉ុណ្ណោះ គឺកាយវិវេក ចិត្តវិវេក វិក្ខម្ភនវិវេក ។

ឯវត្ថុកាមទាំងឡាយ ដែលព្រះសារីបុត្តត្រេរពោលទុកក្នុងនិទ្ទេស ដោយន័យជាដើមថា **កតមេ វត្ថុកាមា មនា បិយា រូបា** ពួកវត្ថុកាមដូចម្តេច រូបជាទីគាប់ចិត្ត និងពួកកិលេសកាម ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងវិភង្គ ក្នុងនិទ្ទេសនោះៗ ឯង ដោយន័យជាដើមថា **ឆន្ទោ កាមោ** សេចក្តីប្រាថ្នា ឈ្មោះថា កាម ទាំងអស់នោះ បណ្ឌិតគប្បីឃើញថា លោកសង្គ្រោះចូលដោយបទថា **កាមេហិ** ដូច្នេះ ។ កាលបើដូច្នោះ ពីរបទ គឺ **វិវិច្ចេវ កាមេហិ** សេចក្តីថា ស្ងាត់ហើយអំពីវត្ថុកាមទាំងឡាយ ដូច្នេះក៏បាន ។ កាយវិវេក លោកបានពោលហើយ ដោយការស្ងាត់ចាកវត្ថុកាមនោះ ។

បទជាច្រើនថា **វិវិច្ច អកុសលេហិ ធម្មេហិ** សេចក្តីថា ស្ងាត់ហើយចាកកិលេសកាមទាំងឡាយ ឬចាកអកុសលធម៌ទាំងពួង ដូច្នេះក៏បាន ។ ចិត្តវិវេក គឺលោកពោលហើយ ដោយការស្ងាត់ចាកកិលេសកាម ឬចាកអកុសលធម៌ទាំងពួងនោះ ។

បណ្តាកាយវិវេក និងចិត្តវិវេក ២ នេះ ការលះកាមសុខ គឺលោកប្រកាសហើយ ដោយកាយវិវេកបទដើម ព្រោះពោលដល់ការស្ងាត់ចាកវត្ថុកាមទាំងឡាយនោះឯង ការផ្គងនៃនេក្ខម្មសុខ គឺលោកប្រកាសហើយ ដោយចិត្តវិវេកបទចុង ព្រោះពោលដល់ការស្ងាត់ចាកកិលេសកាមទាំងឡាយ ។

ម្យ៉ាងទៀត បណ្តាបទទាំង ២ តាមដែលពោលហើយនោះ ការលះសង្កិលេសវត្ថុ គប្បីដឹងថា លោកប្រកាសហើយ ដោយបទទី ១ ការលះ

សង្កិលេស គប្បីដឹងថា លោកប្រកាសហើយ ដោយបទទី ២ ការលះហេតុនៃការចងបាន គប្បីដឹងថា លោកប្រកាសហើយ ដោយបទទី ១ ការលះហេតុនៃសេចក្តីល្ងង់ខ្លៅ គប្បីដឹងថា លោកប្រកាសហើយ ដោយបទទី ២ ការបរិសុទ្ធនៃការប្រកបសេចក្តីព្យាយាម គប្បីដឹងថា លោកប្រកាសហើយ ដោយបទី ១ ហើយការដុសខាត់អជ្ឈាស្រ័យ គប្បីដឹងថា លោកប្រកាសហើយ ដោយបទទី ២ ព្រោះពោលដល់ការស្ងាត់ចាកវត្ថុកាម និងកិលេសកាមនោះឯង ដូចពណ៌នាមក ដូច្នេះ ។

បណ្តាកាមតាមដែលពោលហើយ ក្នុងបទថា **កាមេហិ** នេះ ក្នុងចំណែកវត្ថុកាមមានន័យប៉ុណ្ណោះសិន ។ ឯក្នុងផ្នែកកិលេសកាម កាមច្ឆន្ទៈនោះឯង ដែលមានច្រើនប្រភេទ លោកដៅយកថា **កាម** ដោយន័យជាដើមយ៉ាងនេះថា ឆន្ទៈ ឈ្មោះថា កាម និងរាគៈ ឈ្មោះថា កាម ។ ឯកាមច្ឆន្ទៈនោះ ដល់នូវការរាប់បញ្ចូលក្នុងអកុសលក៏ដោយ ព្រះដ៏មានព្រះភាគក៏ត្រាស់ទុកក្នុងគម្ពីរវិភង្គមួយផ្នែក ព្រោះជាសត្រូវចំពោះឈាន ដោយន័យជាដើមថា **តត្ថ កតមោ កាមច្ឆន្ទោ** បណ្តាធម៌ទាំងនោះ ការពេញចិត្តក្នុងកាមដូចម្តេច គឺ កាម ដូច្នេះ ។

ម្យ៉ាងទៀត កាមច្ឆន្ទៈនោះ ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងបទទី ១ ព្រោះជាកិលេសកាម ។ ត្រាស់ទុកក្នុងបទទី ២ ព្រោះជាកាម ទាក់ទងក្នុងអកុសល ។ ម្យ៉ាងទៀត មិនបានត្រាស់ថា **កាមតោ** តែត្រាស់ថា **កាមេហិ** ព្រោះកាមច្ឆន្ទៈនោះ មានប្រភេទច្រើនសន្ធឹកសន្ធាប់ ។ កាលធម៌ទាំងឡាយ

ដទៃជាអកុសលនៅមាន ។ នីវរណៈទាំងឡាយប៉ុណ្ណោះ ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងគម្ពីរវិភង្គ ព្រោះទ្រង់សម្ដែងនីវរណៈ ជាសត្រូវដោយត្រង់ចំពោះអង្គឈានជាន់ខ្ពស់ឡើងទៅ ដោយន័យជាដើមថា **តត្ថ កតមេ អកុសលា ធម្មា ។ កាមច្ឆន្ទោ ។បេ។** បណ្ដាធម៌ទាំងនោះ ពួកធម៌ជាអកុសលដូចម្ដេច កាមច្ឆន្ទៈ ។បេ។ ដូច្នេះ ។ ពិតហើយ នីវរណៈទាំងឡាយរមែងជាសត្រូវដោយត្រង់ចំពោះអង្គឈាន ។ មានពាក្យអធិប្បាយថា អង្គឈានទាំងឡាយប៉ុណ្ណោះ ជាបដិបក្ខ គឺជាគ្រឿងកម្ចាត់នីវរណៈទាំងនោះ ។ ពិតហើយ ព្រះមហាកច្ចាយនត្ថេរ ក៏បានពោលទុកក្នុងបេដកបករណ៍ថា សមាធិជាបដិបក្ខចំពោះកាមច្ឆន្ទៈ បីតិជាបដិបក្ខចំពោះព្យាបាទ វិតក្កៈជាបដិបក្ខចំពោះថីនមិទ្ធៈ សុខជាបដិបក្ខចំពោះឧទ្ធច្ចកុក្កុច្ចៈ វិចារៈជាបដិបក្ខចំពោះវិចិកិច្ឆា ។

បណ្ដាបទទាំង ២ នេះ ការស្ងាត់ដោយអំណាចការសង្កត់កាមច្ឆន្ទៈទុក គឺព្រះដ៏មានព្រះភាគត្រាស់ហើយ ដោយបទនេះថា **វិវិច្ចេវ កាមេហិ ។** ការស្ងាត់ដោយអំណាចនៃការសង្កត់នីវរណៈទាំង ៥ ទុក គឺទ្រង់ត្រាស់ដោយបទនេះថា **វិវិច្ច អកុសលេហិ ធម្មេហិ** ដោយន័យដូចពោលមក ដូច្នេះ ។

ម្យ៉ាងទៀត ការស្ងាត់ដោយអំណាចការសង្កត់កាមច្ឆន្ទៈទុក គឺព្រះដ៏មានព្រះភាគ ត្រាស់ទុកដោយបទទី ១ ដោយសព្ទដែលលោកមិនបានកាន់យក ការស្ងាត់ដោយអំណាចការសង្កត់នីវរណៈដ៏សេសទុក គឺទ្រង់ត្រាស់ដោយបទទី ២ ។ ម្យ៉ាងទៀត បណ្ដាអកុសលមូលទាំង ៣ ការស្ងាត់ដោយ

អំណាចការសង្កត់សង្កិនលោភៈ ដែលមានសភាពផ្សេងនៃបញ្ចកាមគុណជាអារម្មណ៍ គឺទ្រង់ត្រាស់ទុកដោយបទទី ១ ការស្វាត់ដោយអំណាចការសង្កត់សង្កិនទោសៈ និងមោហៈ ដែលមានប្រភេទនៃអាឃាតវត្ថុជាដើមជាអារម្មណ៍ គឺទ្រង់ត្រាស់ទុកដោយបទទី ២ ។

ម្យ៉ាងទៀត បណ្ដាធម៌ទាំងឡាយ មានឱឃៈជាដើម ការស្វាត់ដោយអំណាចការសង្កត់សង្កិនសំយោជនៈ គឺកាមោឃៈ កាមយោគៈ កាមាសវៈ កាមុបាទាន អភិជ្ឈាកាយគន្ថៈ និងកាមរាគៈទុក គឺព្រះដ៏មានព្រះភាគត្រាស់ដោយបទទី ១ ។ ការស្វាត់ដោយអំណាចការសង្កត់សង្កិនសំយោជនៈ គឺ ឱឃៈ យោគៈ អាសវៈ ឧបាទាន និងគន្ថៈដ៏សេសទុក គឺទ្រង់ត្រាស់ដោយបទទី ២ ។ ម្យ៉ាងទៀត ការស្វាត់ដោយអំណាចការសង្កត់សង្កិនតណ្ហា និងកិលេសដែលសម្បយុត្តដោយតណ្ហានោះទុកជាដើម ព្រះអង្គត្រាស់ដោយបទទី ១ ការស្វាត់ដោយអំណាចការសង្កត់សង្កិនអវិជ្ជា និងកិលេសដែលសម្បយុត្តដោយអវិជ្ជានោះទុក គឺទ្រង់ត្រាស់ដោយបទទី ២ ។

ម្យ៉ាងទៀត ការស្វាត់ដោយអំណាចការសង្កត់សង្កិនចិត្តុប្បាទ ៨ ដួងដែលសម្បយុត្តដោយលោភៈទុក គប្បីជ្រាបថា គឺទ្រង់ត្រាស់ដោយបទទី ១ ការស្វាត់ដោយអំណាចការសង្កត់សង្កិនអកុសលចិត្តុប្បាទ ៤ ដួងដ៏សេសទុក គប្បីជ្រាបថា ទ្រង់ត្រាស់ដោយបទទី ២ ការប្រកាសអត្ថក្នុងពាក្យថា **វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ** នេះ មានត្រឹមប្រមាណប៉ុណ្ណោះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងអង្គសម្រាប់លះនៃបឋមជ្ឈាន

ដោយពាក្យមានប្រមាណត្រឹមប៉ុណ្ណោះហើយ គ្រានេះ កាលទ្រង់សម្តែងអង្គប្រកប ទើបត្រាស់ពាក្យជាដើមថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ ។

ក្នុងពាក្យថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈជាដើមនោះ មានវិនិច្ឆ័យថា ការលើកចិត្តឡើងកាន់អារម្មណ៍ ឈ្មោះថា វិតក្កៈ លោកអធិប្បាយថា ការត្រិះរិះ ។ វិតក្កៈនេះ មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ មានការទល់ទ្រ និងទល់ទ្រដោយជុំវិញជាកិច្ច ។ ពិតហើយ ព្រះយោគាវចរលោកហៅថា ធ្វើអារម្មណ៍ឲ្យជាធម្មជាតិដែលវិតក្កៈទល់ទ្រហើយ និងទល់ទ្រដោយជុំវិញហើយដោយវិតក្កៈនោះ ។ វិតក្កៈនោះ មានការនាំមកនូវចិត្តក្នុងអារម្មណ៍ជាបច្ចុប្បដ្ឋាន ។ ការពិចារណា ឈ្មោះថា វិចារៈ លោកអធិប្បាយថា អាការដែលចិត្តត្រាច់ទៅ ។ វិចារៈនេះ មានការពិចារណាអារម្មណ៍ជាលក្ខណៈ មានការប្រកបរឿយៗ នូវសហជាតធម៌ក្នុងអារម្មណ៍ជាកិច្ច មានការតាមចងចិត្តទុកក្នុងអារម្មណ៍ជាបច្ចុប្បដ្ឋាន ។

ការមិនប្រាសចាកគ្នា នៃវិតក្កៈវិចារៈទាំងនោះ ក្នុងចិត្តុប្បាទក្ខណៈខ្លះសូម្បីមានវិតក្កៈ ក៏គឺការផ្ទាក់ទៅចំពោះអារម្មណ៍គ្រាដំបូងរបស់ចិត្ត ដូចសំឡេងជួង ដោយសេចក្តីថា ជាសភាវៈដែលគ្រោតគ្រាត និងដោយសេចក្តីថា សភាវៈដែលចាប់ផ្តើម ។ វិចារៈ គឺការតាមចងចិត្តទុកក្នុងអារម្មណ៍ ដូចសំឡេងខ្ទរបស់ជួង ដោយអត្ថថា ជាសភាវៈដែលល្អិត ។ ក្នុងវិតក្កៈវិចារៈទាំងនេះ វិតក្កៈ មានការផ្សាយទៅ ( ឬញាប់ញ័រ ) ជាការញ័ររបស់

ចិត្ត ( ក្នុងខណៈដែលចិត្តគិតឡើងគ្រាដំបូង ) ដូចការទទះស្លាបរបស់សត្វបក្សី ដែលត្រូវការហើរឡើងទៅក្នុងអាកាស និងដូចការបោះពួយតម្រង់ផ្កាឈូកធំរបស់ឃ្មុំ ដែលមានចិត្តផ្តោតត្រង់ក្លិន វិចារៈ មានការប្រព្រឹត្តទៅស្ងប់ មិនមែនញាប់ញ័រដោយកម្លាំងរបស់ចិត្ត ដូចការត្រដាងស្លាបរបស់បក្សី ដែលហើរទៅហើយក្នុងអាកាស និងដូចការហើរសំកាំងក្នុងចំណែកខាងលើផ្កាឈូករបស់ឃ្មុំ ដែលហើរចុះបែរមុខកាន់ផ្កាឈូក ដូច្នោះ ។ ចំណែកសេចក្តីប្លែកគ្នានៃវិតក្កៈ និងវិចារៈនោះ នឹងប្រាកដក្នុងបឋមជ្ឈាន និងទុតិយជ្ឈាន ។

ឈាននេះ រមែងប្រព្រឹត្តទៅព្រមដោយវិតក្កៈនេះ និងដោយវិចារៈនេះ ដូចដើមឈើ រមែងប្រព្រឹត្តទៅដោយផ្កា និងផ្លែ ដូច្នោះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបឈាននេះ ព្រះដ៏មានព្រះភាគត្រាស់ថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ ។ តែក្នុងគម្ពីរវិភង្គទ្រង់ធ្វើទេសនាជាបុគ្គលាធិដ្ឋាន ដោយន័យជាដើមថា **ឥមិនា ច វិតក្កេន ឥមិនា ច វិចារេន ឧបេតោ ហោតិ សមុបេតោ** ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រមដោយវិតក្កៈនេះផង ដោយវិចារៈនេះផង សូម្បីសេចក្តីក្នុងគម្ពីរវិភង្គនោះ ក៏គប្បីឃើញយ៉ាងនេះឯង ។

ក្នុងបទថា **វិវេកជំ** នេះ មានវិនិច្ឆ័យថា ការស្ងាត់ ឈ្មោះថា វិវេក អធិប្បាយថា ការប្រាសចាកនីវរណៈ ។ ម្យ៉ាងទៀត ធម៌ដែលស្ងាត់ចាកនីវរណៈ ឈ្មោះថា វិវេក ព្រោះអត្ថថា ស្ងាត់ហើយ អធិប្បាយថា គំនរនៃធម៌ដែលសម្បយុត្តដោយឈាន ។ បីតិ និងសុខ កើតអំពីវិវេកនោះ ឬកើត

ក្នុងវិវេកនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **វិវេកជំ** ។

ក្នុងបទថា **បីតិ សុខំ** មានវិនិច្ឆ័យថា ធម្មជាតដែលឈ្មោះថា **បីតិ** ព្រោះអត្ថថា ធ្វើឲ្យឆ្អែត ។ បីតិនោះ មានការឆ្អែតជាលក្ខណៈ មានការធ្វើកាយ និងចិត្តឲ្យឆ្អែតជាកិច្ច ម្យ៉ាងទៀត មានការផ្សាយទៅជាកិច្ច មានការត្រេកអរនៃចិត្តជាសមុដ្ឋាន ។ ការសប្បាយ ឈ្មោះថា សេចក្តីសុខ ។ ម្យ៉ាងទៀត ធម្មជាតដែលឈ្មោះថា សុខ ព្រោះអត្ថថា រមែងទំពាស៊ី និងជីកចេញដោយល្អនូវអាពាធផ្លូវកាយ និងចិត្ត ។ សុខនោះ មានការសប្បាយជាលក្ខណៈ មានការធ្វើឲ្យចម្រើននូវសម្បយុត្តធម៌ ដោយសុខនោះជាកិច្ច មានការអនុគ្រោះជាអាការប្រាកដ ។

កាលការមិនប្រាសចាកគ្នានៃបីតិ និងសុខទាំងនោះ ក្នុងចិត្តុប្បាទក្ខណៈខ្លះ សូម្បីមាន បីតិ គឺការត្រេកអរ ដោយការបានឥដ្ឋារម្មណ៍ សុខ គឺការសោយរសនៃអារម្មណ៍ដែលខ្លួនបានហើយ ។ បីតិ មានក្នុងចិត្តុប្បាទណា សុខក៏មានក្នុងចិត្តុប្បាទនោះ ។ សុខមានក្នុងចិត្តុប្បាទណា ក្នុងចិត្តុប្បាទនោះដោយច្រើនមិនមានបីតិ ។ បីតិ លោកសង្គ្រោះចូលជាសង្ខារក្ខន្ធ សុខ លោកសង្គ្រោះចូលជាវេទនាខន្ធ បីតិ ប្រៀបដូចការឆ្អែតចិត្តរបស់បុគ្គលដែលហត់នឿយក្នុងផ្លូវកន្តារ ព្រោះបានឃើញ និងបានឮថា មានព្រៃឈើ និងមានទឹក សុខ ប្រៀបដូចការសប្បាយចិត្តរបស់បុគ្គលដែលហត់នឿយក្នុងផ្លូវកន្តារ ព្រោះបានចូលទៅកាន់ម្លប់នៃព្រៃឈើ និងបានបរិភោគទឹកដូច្នោះ ។ បណ្ឌិតគប្បីជ្រាបសន្និដ្ឋានថា ពាក្យដែលអាចារ្យទាំងឡាយពោលទុកថា បីតិ គឺការត្រេកអរ

ដោយការបានឥដ្ឋារម្មណ៍ជាដើមនោះ ក៏ព្រោះបីតិកំពុងប្រាកដក្នុងសម័យនោះៗ ។ បីតិផង សុខផង មានដល់ឈាននោះ ឬមានទៅក្នុងឈាននោះ ព្រោះហេតុនោះ ទើបឈាននេះ ព្រះដ៏មានព្រះភាគត្រាស់ថា **បីតិ សុខំ** ។

ម្យ៉ាងទៀត បីតិផង សុខផង ឈ្មោះថា បីតិ និងសុខ ដូចធម៌ និងវិន័យជាដើមដូច្នោះ ។ បីតិ និងសុខ កើតអំពីវិវេក មានដល់ឈាននោះ ឬមានទៅក្នុងឈាននោះ ព្រោះហេតុនោះ ទើបឈ្មោះថា បីតិ និងសុខ កើតអំពីវិវេក ដូចពណ៌នាមក ដូច្នេះ ។ ឈានកើតអំពីវិវេក យ៉ាងណា ក្នុងឈាននេះ បីតិ និងសុខ រមែងជារបស់កើតអំពីវិវេក យ៉ាងនោះ ដូច្នោះ ។ ម្យ៉ាងទៀត បីតិ និងសុខ មានដល់ឈាននោះ ព្រោះហេតុដូច្នេះនោះ នឹងពោលសង្គ្រោះដោយបទដូចគ្នាថា **វិវេកជ បីតិសុខំ** ដូច្នេះខ្លះ ក៏ប្រើបាន ។ តែក្នុងគម្ពីរវិភង្គ ព្រះដ៏មានព្រះភាគត្រាស់បីតិសុខនោះទុក ដោយន័យជាដើមថា សុខនេះ សហគតៈដោយបីតិនេះ ដូច្នេះ ។ ឯអត្ថក្នុងគម្ពីរវិភង្គនោះ គប្បីឃើញយ៉ាងនេះឯង ។

បទថា **បឋមំ** គឺទី ១ ព្រោះជាលំដាប់នៃការគណនា ។ ឈាននេះឈ្មោះថា ដំបូង ព្រោះអត្ថថា ព្រះយោគាវចរសម្រេចក្នុងគ្រាដំបូង ។ គុណធម៌ ឈ្មោះថា ឈាន ព្រោះអត្ថថា ដុតធម៌ដែលជាសត្រូវ ( មាននីវរណៈជាដើម ) ។ ព្រះយោគីទាំងឡាយ រមែងដុត ( ធម៌ដែលជាសត្រូវ មាននីវរណៈជាដើម ) ដោយឈាននេះ ព្រោះហេតុនោះ ទើបឈ្មោះថា ឈាន អធិប្បាយថា ព្រះយោគីទាំងឡាយ រមែងដុតធម៌ដែលជាសត្រូវ ឬរមែងគិត

ដល់គោចរ ( គឺអារម្មណ៍ដែលសម្រាប់គោង មានកសិណជាដើម ) ។ម្យ៉ាងទៀត ឈ្មោះថា ឈាន ព្រោះអត្ថថា សម្លឹង គឺចូលទៅសម្លឹងអារម្មណ៍នោះឯង ព្រោះហេតុនោះ ទើបឈាននោះ លោកហៅថា មានការចូលទៅសម្លឹងជាលក្ខណៈ ។

ឈាននោះមាន ២ យ៉ាង គឺ **អារម្មណូបនិជ្ឈាន** ( ចូលទៅសម្លឹងអារម្មណ៍ ) ១ **លក្ខណូបនិជ្ឈាន** ( ចូលទៅសម្លឹងលក្ខណៈ ) ១ ។ បណ្ដាឈានទាំង ២ នោះ សមាបត្តិ ៨ ព្រមទាំងឧបចារៈ លោកហៅថា អារម្មណូបនិជ្ឈាន ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះចូលទៅសម្លឹងអារម្មណ៍ គឺកសិណ ។ វិបស្សនា មគ្គ និងផល លោកហៅថា លក្ខណូបនិជ្ឈាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះចូលទៅសម្លឹងលក្ខណៈ ។

ពិតហើយ បណ្ដាវិបស្សនា មគ្គ និងផលទាំងនេះ វិបស្សនា រមែងចូលទៅសម្លឹងត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម ។ កិច្ច គឺការចូលទៅសម្លឹងដោយវិបស្សនា រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ មគ្គ លោកហៅថា លក្ខណូបនិជ្ឈាន ។ ចំណែកផល លោកហៅថា លក្ខណូបនិជ្ឈាន ព្រោះអត្ថថា ចូលទៅសម្លឹងលក្ខណៈដែលពិតនៃនិរោធ ។ តែក្នុងអត្ថនេះ លោកដៅយកអារម្មណូបនិជ្ឈានប៉ុណ្ណោះថា **ឈាន**។

ក្នុងអធិការពោលអំពីឈាននេះ អាចារ្យអ្នកចោទសួរថា ឈ្មោះថា ឈាន ដែលគួរទឹងគប្បីអាងដល់យ៉ាងនេះថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ

ប្រព្រឹត្តទៅព្រមដោយវិចារៈ ។បេ។ មានបីតិ និងសុខ ដូច្នេះនោះ ដូចម្តេច ខ្ញុំនឹងឆ្លើយថា ប្រៀបដូចបុរសដទៃ វៀរទ្រព្យ និងបរិជនចេញ រមែងជាបុគ្គលមិនសមគួរនឹងគប្បីអាងដល់ក្នុងប្រយោគជាដើមថា ជាអ្នកមានទ្រព្យ ជាអ្នកមានបរិជន យ៉ាងណា ឈាន វៀរធម៌ មានវិតក្កៈជាដើមចេញ គួរអាងដល់ រមែងមិនមានយ៉ាងនោះ ។ ដូចការសន្មតថា សេនាក្នុងអង្គសេនាទាំងឡាយ ដែលសត្វលោកពោលថា សេនា មានពលរថ ពលថ្មើរជើង ដូច្នេះនោះឯង បណ្ឌិតគួរជ្រាប យ៉ាងណា ក្នុងអធិការនេះ ក៏គួរជ្រាបថា ការសន្មតថា ឈាន ព្រោះមានអង្គ ៥ នោះឯង ដូច្នោះ ។ គួរជ្រាបក្នុងអង្គ ៥ ពួកណា ក្នុងអង្គទាំង ៥ នេះ គឺវិតក្កៈ ការត្រិះរិះ វិចារៈ ការញ៉ាំងចិត្តឲ្យត្រាច់ទៅក្នុងអារម្មណ៍ បីតិ ការឆ្អែតចិត្ត សុខ ការសុខចិត្ត ចិត្តេកគ្គតា ការដែលចិត្តមានអារម្មណ៍ ១ ។ ពិតហើយ អង្គ ៥ នេះឯង ព្រះដ៏មានព្រះភាគត្រាស់ថាជាអង្គនៃឈាននោះ ដោយន័យជាដើមថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ ។

បើអាចារ្យដែលចោទគប្បីសួរថា ឯកគ្គតា ( ភាពដែលចិត្តមានអារម្មណ៍ ១ ) ចាត់ជាអង្គ ( នៃឈាន ) មិនបាន ព្រោះព្រះដ៏មានព្រះភាគមិនបានត្រាស់ទុក ( ក្នុងបាលីនៃឈាន ) មិនមែនឬ ឆ្លើយថា ពាក្យដែលអ្នកពោលនោះ រមែងមិនត្រឹមត្រូវ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះចិត្តេកគ្គតានោះ ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងបាលីនៃឈាននោះឯង ។

ពិតហើយ ចិត្តេកគ្គតានោះ ព្រះដ៏មានព្រះភាគត្រាស់ទុកពិតប្រាកដក្នុង

គម្ពីរវិភង្គយ៉ាងនេះថា **ឈានន្តិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា** ប្រែថា ត្រង់ពាក្យថា ឈាន គឺវិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតានៃចិត្ត ព្រោះដូច្នោះ ពាក្យដែលលោកពោលថា ប្រព្រឹត្តទៅព្រមដោយវិតក្កៈ ប្រព្រឹត្តទៅព្រមដោយវិចារៈ ដូច្នេះ យ៉ាងណា សូម្បីកាលព្រះដ៏មានព្រះភាគ មិនបានត្រាស់ទុកអធិការនេះថា **សចិត្តេកគ្គតា** សូម្បីចិត្តេកគ្គតា ក៏គួរជ្រាបថាជាអង្គ ( នៃឈាន ) នោះឯង តាមព្រះបាលីក្នុងគម្ពីរវិភង្គនេះ ដូច្នោះ ។ ពិតហើយ ឧទ្ទេស ព្រះដ៏មានព្រះភាគទ្រង់ធ្វើទុកហើយ ដោយព្រះបំណងណា ឧទ្ទេសនោះឯង ក៏ឈ្មោះថា ទ្រង់ប្រកាសទុកហើយក្នុងគម្ពីរវិភង្គ ដោយព្រះបំណងនោះដូច្នេះ ។

បទថា **ឧបសម្បជ្ជ** ប្រែថា ចូលទៅជិតហើយ លោកអធិប្បាយថា សម្រេចហើយ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ឲ្យចូលដល់ព្រមហើយ គឺឲ្យសម្រេចហើយ ។ តែក្នុងគម្ពីរវិភង្គ ព្រះដ៏មានព្រះភាគត្រាស់ទុកថា **ឧបសម្បជ្ជាតិ យោ បឋមស្ស ឈានស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា** ត្រង់ពាក្យថា ចូល គឺការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញនូវបឋមជ្ឈាន ។ អត្ថនៃពាក្យនោះ គប្បីជ្រាបយ៉ាងនោះឯង ។

បទថា **វិហាសិ** សេចក្តីថា តថាគតជាបុគ្គលដល់ព្រមដោយឈានមានប្រការដូចពោលហើយយ៉ាងនេះ ទើបញ៉ាំងការបន្តជាប់គ្នា ការប្រព្រឹត្តទៅ ការរក្សាការប្រព្រឹត្តទៅ ការឲ្យប្រព្រឹត្តទៅ ការត្រាច់ទៅ ការស្នាក់នៅនៃ

អត្តភាពឲ្យសម្រេចដោយឥរិយាបថវិហារ ពោលគឺ ការអង្គុយនាពោធិ-មណ្ឌល ។ សេចក្តីនេះ សមដូចព្រះតម្រាស់ក្នុងគម្ពីរវិភង្គថា **វិហរតីតិ ឥរិយតិ វត្តតិ ចាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរតីតិ** ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ត្រាច់ទៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

សួរថា ព្រះដ៏មានព្រះភាគទ្រង់ធ្វើអ្វី ទើបចូលឈាននេះ ឆ្លើយថា ទ្រង់ចម្រើនកម្មដ្ឋាន សួរថា ទ្រង់ចម្រើនកម្មដ្ឋានអ្វី ឆ្លើយថា ទ្រង់ចម្រើនអានាបានស្សតិកម្មដ្ឋាន សួរថា បុគ្គលដទៃដែលមានសេចក្តីត្រូវការដោយអានាបានស្សតិកម្មដ្ឋាននោះ គួរធ្វើដូចម្តេច ឆ្លើយថា សូម្បីអ្នកដទៃ ក៏គួរចម្រើនកម្មដ្ឋាននោះ ឬបណ្តាកម្មដ្ឋានទាំងឡាយ មានបឋវីកសិណជាដើម ឯណានីមួយ ។

ន័យក្នុងការចម្រើនអានាបានស្សតិកម្មដ្ឋានជាដើមនោះ គប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ កាលខ្ញុំពោលន័យក្នុងការចម្រើនទុកក្នុងអធិការនេះ និទាននៃព្រះវិន័យ ក៏នឹងជាភារៈធ្ងន់ក្រៃលែង ព្រោះដូច្នោះ ទើបខ្ញុំធ្វើត្រឹមតែការប្រកាសអត្ថនៃព្រះបាលីប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

បឋមជ្ឈានកថា ចប់

# ទុតិយជ្ឈានកថា

ពីរបទថា **វិតក្កវិចារានំ វូបសមា** សេចក្ដីថា ព្រោះចូលទៅស្ងប់ព្រោះឈានកន្លងអង្គទាំង ២ នេះ គឺវិតក្កៈ និងវិចារៈ ។ អធិប្បាយថា ព្រោះវិតក្កៈវិចារៈមិនប្រាកដក្នុងខណៈនៃទុតិយជ្ឈាន ។

គប្បីជ្រាបសន្និដ្ឋានថា ក្នុងបណ្ដាបទទាំងពីរនោះ ធម៌ក្នុងបឋមជ្ឈានទាំងអស់ មិនមានក្នុងទុតិយជ្ឈាន ព្រោះថា ធម៌ទាំងឡាយ មានផស្សៈជាដើម មានក្នុងបឋមជ្ឈានម្យ៉ាង ក្នុងទុតិយជ្ឈាននេះម្យ៉ាង តែសូម្បីយ៉ាងនោះព្រះដ៏មានព្រះភាគក៏ត្រាស់យ៉ាងនេះថា ព្រោះចូលទៅស្ងប់វិតក្កៈវិចារៈ ដើម្បីសម្ដែងថា ការសម្រេចឈានដទៃក្រៅអំពីបឋមជ្ឈាន មានទុតិយជ្ឈានជាដើម នឹងមានបានព្រោះឈានកន្លងអង្គដែលគ្រោតគ្រាត ។

ក្នុងអធិការនេះ បណ្ឌិតសំដៅយក **និយកជ្ឈត្តំ** ឈ្មោះថា **អជ្ឈត្តំ** តែក្នុងគម្ពីរវិភង្គ ព្រះដ៏មានព្រះភាគត្រាស់ទុកត្រឹមប៉ុណ្ណោះថា **អជ្ឈត្តំ បច្ចត្តំ** ប៉ុណ្ណោះ ។ ព្រោះបណ្ឌិតមានបំណងយក **និយកជ្ឈត្តំ** ឈ្មោះថា **អជ្ឈត្តំ** ដូច្នោះក្នុងបទថា **អជ្ឈត្តំ** នេះ បណ្ឌិតគប្បីឃើញអត្ថដូច្នេះថា កើតហើយក្នុងខ្លួន គឺកើតហើយក្នុងសន្ដានរបស់ខ្លួន ។

សទ្ធា ( ការជឿ ) ព្រះដ៏មានព្រះភាគត្រាស់ហៅថា **សម្បសាទន** ក្នុងបទថា **សម្បសាទនំ** នេះ សូម្បីឈាន ក៏ត្រាស់ហៅថា **សម្បសាទន** ព្រោះប្រកបដោយសេចក្ដីជ្រះថ្លា ដូចសំពត់ពណ៌ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ដូច្នោះ ។ ម្យ៉ាងទៀត ព្រោះឈាននោះ រមែងញ៉ាំងចិត្តឲ្យជ្រះថ្លាដោយល្អ ព្រោះប្រកបដោយសទ្ធាដែលជាគ្រឿងញ៉ាំងចិត្តឲ្យផូរផង់ (និង)

ព្រោះស្ងប់រម្ងាប់ការកម្រើកនៃវិតក្កៈ និងវិចារៈបាន ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **សម្បសាទនំ ។** ក្នុងអត្ថវិកប្បនេះ គប្បីជ្រាបសម្ពន្ធចំពោះបទយ៉ាងនេះថា **សម្បសាទនំ ចេតសោ** ( ជាការផូរផង់នៃចិត្ត ) ។ តែក្នុងអត្ថវិកប្បខាងដើម គប្បីប្រកបបទថា **ចេតសោ** នោះ ចូលជាមួយ **ឯកោទិភាវំ** ។

ក្នុងបទថា **ឯកោទិភាវំ** នោះ មានអត្ថយោជនាតទៅថា សមាធិឈ្មោះថា **ឯកោទិ** ព្រោះអត្ថថា ជាធម៌ឯកផុសឡើង ។ អធិប្បាយថា ឈ្មោះថា ជាធម៌ដ៏លើស គឺធម៌ដ៏ប្រសើរបំផុត ផុសឡើង ព្រោះវិតក្កៈវិចារៈមិនផុសឡើង ។ ពិតហើយ សូម្បីបុគ្គលដែលប្រសើរបំផុត យើងក៏ហៅថាជាបុគ្គលឯកក្នុងលោក ។ មួយទៀត នឹងពោលថា សមាធិដែលវៀរចាកវិតក្កៈ និងវិចារៈ ឈ្មោះថា ជាធម៌ឯក គឺមិនមានសម្លាញ់ ដូច្នេះក៏គួរ បរិយាយមួយទៀត សមាធិ ឈ្មោះថា **ឧទិ** ព្រោះអត្ថថា រមែងញ៉ាំងសម្បយុត្តធម៌ឲ្យផុសឡើង អធិប្បាយថា ឲ្យតាំងឡើង ។ សមាធិនោះ ជាឯក ព្រោះអត្ថថាប្រសើរ និងផុសឡើង ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកោទិ ។** ពាក្យថា **ឯកោទិ** នោះ ជាឈ្មោះរបស់សមាធិ ។ ទុតិយជ្ឈាន រមែងញ៉ាំងសមាធិដែលឈ្មោះថា **ឯកោទិ** នេះ ដូចពោលនេះឲ្យកើត គឺឲ្យចម្រើន ។ ហេតុនោះ ទើបទុតិយជ្ឈាននេះ ឈ្មោះថា **ឯកោទិភាវំ ។** ព្រោះសមាធិ ឈ្មោះថា **ឯកោទិ** នេះ រមែងមានដល់ចិត្ត មិនមែនមានដល់សត្វ ដល់ជីវៈឡើយ ព្រោះដូច្នោះ ទើបទុតិយជ្ឈាននោះ ព្រះដ៏មានព្រះភាគត្រាស់ថា **ចេតសោ**

**ឯកោទិភាវំ** ( មានសភាពជាចិត្តខ្ពស់ឯក ) ។

មានពាក្យសួរថា ឯសទ្ធានេះ និងសមាធិ ដែលមានឈ្មោះថា **ឯកោទិ** នេះ មានក្នុងបឋមជ្ឈាន មិនមែនឬ បើដូច្នោះ ព្រោះហេតុអ្វី ទើបទុតិយជ្ឈាន នេះប៉ុណ្ណោះ ព្រះដ៏មានព្រះភាគត្រាស់ថា ជាគ្រឿងញុំាងចិត្តឲ្យផូរផង់ និងថា ជាឯកោទិភាវៈទៅវិញ ខ្ញុំនឹងឆ្លើយថា ព្រោះថា បឋមជ្ឈាននោះ ឈ្មោះថា មិនទាន់ផូរផង់ល្អ ព្រោះវិតក្កៈ និងវិចារៈនៅកម្រើកនៅឡើយ ដូចទឹកដែល ល្អក់ ព្រោះរលកតូចធំ ដូច្នោះ ព្រោះហេតុនោះ កាលសទ្ធាមាន ក៏គប្បី ជ្រាបថា បឋមជ្ឈាននោះ ព្រះដ៏មានព្រះភាគមិនបានត្រាស់ថា ជាគ្រឿងញុំាង ចិត្តឲ្យផូរផង់ ។ ម្យ៉ាងទៀត ព្រោះបឋមជ្ឈានមិនទាន់ផូរផង់ដោយល្អនោះឯង សូម្បីសមាធិក្នុងបឋមជ្ឈានេះ ក៏មិនមែនជាធម៌ប្រាកដដោយល្អឡើយ ព្រោះ ដូច្នោះ គប្បីជ្រាបថា បឋមជ្ឈាននោះ ព្រះដ៏មានព្រះភាគមិនបានត្រាស់ថា ជាឯកោទិភាវៈឡើយ ។ ចំណែកសទ្ធា បានឱកាស មានកម្លាំងហើយ ព្រោះ ក្នុងឈាននេះ មិនមានហេតុជាគ្រឿងកង្វល់ គឺវិតក្កៈវិចារៈ សូម្បីសមាធិក៏ ប្រាកដ ព្រោះត្រឡប់បានសម្លាញ់ គឺសទ្ធាមានកម្លាំង ព្រោះដូច្នោះ គប្បី ជ្រាបថា ទុតិយជ្ឈានប៉ុណ្ណោះ ទើបព្រះដ៏មានព្រះភាគត្រាស់ទុកយ៉ាងនេះ ។ តែក្នុងគម្ពីរវិភង្គ ព្រះដ៏មានព្រះភាគត្រាស់ទុកត្រឹមតែប៉ុណ្ណេះថា ដែលឈ្មោះ ថា **សម្បសាទនំ** នោះ បានដល់ សទ្ធា ការជឿ ការដាក់ចិត្តជឿ ការជ្រះថ្លា ក្រៃលែង ដែលឈ្មោះថា **ចេតសោ ឯកោទិភាវំ** នោះ បានដល់ ការតាំង នៅនៃចិត្ត ។បេ។ ការតាំងមាំប្រពៃ ដូច្នេះ ។ ឯអត្ថវណ្ណនានេះ រួមជាមួយ

បាឋៈក្នុងគម្ពីរវិភង្គនោះ ដែលព្រះដ៏មានព្រះភាគត្រាស់ទុកយ៉ាងនោះ រមែងមិនខុស គឺរមែងប្រហាក់ប្រហែល និងស្មើគ្នាដោយពិត យ៉ាងណា បណ្ឌិតគប្បីជ្រាបអត្ថវណ្ណនានេះ ដូច្នោះ ។

ក្នុងពាក្យថា **អវិតក្កំ អវិចារំ** នេះ មានវិនិច្ឆ័យថា ទុតិយជ្ឈានឈ្មោះថា មិនមានវិតក្កៈ ព្រោះអត្ថថា វិតក្កៈមិនមានក្នុងទុតិយជ្ឈាននេះ ឬដល់ទុតិយជ្ឈាននេះ ព្រោះលះវិតក្កៈបានដោយភាវនា ។ ទុតិយជ្ឈាន ឈ្មោះថា មិនមានវិចារៈក៏ដោយន័យនេះឯង សូម្បីក្នុងគម្ពីរវិភង្គ ព្រះដ៏មានព្រះភាគក៏ត្រាស់ទុកហើយថា វិតក្កៈនេះផង វិចារៈនេះផង ជាធម៌ស្ងប់រម្ងាប់រលត់ ខ្ចាត់ចេញ វិនាសសាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា មិនមានវិតក្កៈ មិនមានវិចារៈ ដោយប្រការដូច្នេះ ។

ក្នុងអធិការនេះ អាចារ្យអ្នកចោទសួរថា តើសេចក្ដីនេះ សម្រេចហើយដោយបទថា ព្រោះស្ងប់រម្ងាប់វិតក្កៈ និងវិចារៈ ដូច្នេះមិនមែនឬ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគត្រាស់ទុកទៀតថា មិនមានវិតក្កៈ មិនមានវិចារៈ ដូច្នេះដែរ ។ ខ្ញុំនឹងឆ្លើយថា អត្ថនេះ សម្រេចហើយយ៉ាងនោះពិតហើយ តែពាក្យថា ព្រោះស្ងប់រម្ងាប់វិតក្កៈ និងវិចារៈនេះ សម្ដែងអត្ថពោល គឺការមិនមានវិតក្កៈ វិចារៈនោះ ។ ខ្ញុំបានពោលហើយមិនមែនឬថា សូម្បីដូច្នោះ ព្រះដ៏មានព្រះភាគក៏ត្រាស់ទុកយ៉ាងនេះថា ព្រោះស្ងប់រម្ងាប់វិតក្កៈ និងវិចារៈ ដើម្បីទ្រង់សម្ដែងថា ការសម្រេចឈានជាដើមដទៃអំពីបឋមជ្ឈាន

រមែងមានបាន ព្រោះឈានកន្ទង់អង្គដែលគ្រោតគ្រាតបាន ម្យ៉ាងទៀត ទុតិយជ្ឈាននេះ ឈ្មោះថា **សម្បសាទន** ព្រោះស្ងប់វិតក្កៈ និងវិចារៈបាន មិនមែនព្រោះចូលទៅស្ងប់ការផ្សាយឡើងនៃទោស ពោល គឺកិលេសឡើយ ហើយទុតិយជ្ឈាននេះ ឈ្មោះថា **ឯកោទិភាវ** ព្រោះស្ងប់វិតក្កៈ និងវិចារៈ ហើយទុតិយជ្ឈាននេះ ឈ្មោះថា **ឯកោទិភាវ** ព្រោះលះនីវរណៈបាន មិនដូចឧបចារជ្ឈាន និងទុតិយជ្ឈាននេះ ឈ្មោះថា **ឯកោទិភាវ** ព្រោះមានអង្គប្រាកដមិនដូចបឋមជ្ឈាននោះឡើយ ។

ព្រោះហេតុនោះ ពាក្យថា ព្រោះស្ងប់វិតក្កៈ វិចារៈនេះ រមែងជាពាក្យសម្តែងដល់ហេតុនៃភាពដែលទុតិយជ្ឈាន ជាគ្រឿងញុំាងចិត្តឲ្យផូរផង់ផង ជាធម៌ឯក ញុំាងសមាធិឲ្យផុសឡើងផង ដូចពោលមកហើយនេះ ។ ម្យ៉ាងទៀត ទុតិយជ្ឈាននេះ ឈ្មោះថា មិនមានវិតក្កៈ មិនមានវិចារៈ ព្រោះស្ងប់វិតក្កៈផង វិចារៈផង ទុតិយជ្ឈាននេះ ឈ្មោះអវិតក្កាវិចារៈ ព្រោះមិនមានវិតក្កៈ និងវិចារៈ មិនមែនដូចតតិយជ្ឈាន និងចតុត្ថជ្ឈាន និងដូចវិញ្ញាណមានចក្ខុវិញ្ញាណជាដើមនោះឡើយ ព្រោះហេតុនោះ ពាក្យថា ព្រោះស្ងប់វិតក្កៈ វិចារៈនេះ រមែងជាពាក្យសម្តែងដល់ហេតុនៃទុតិយជ្ឈានមិនមានវិតក្កៈ និងមិនមានវិចារៈ ហើយមិនមែនជាពាក្យសម្តែងត្រឹមតែការមិនមាននៃវិតក្កៈ និងវិចារៈនោះឡើយ ដូចពោលមកដូច្នេះ ។ តែពាក្យថា មិនមានវិតក្កៈ មិនមានវិចារៈនេះ ជាពាក្យសម្តែងត្រឹមតែការមិនមានវិតក្កៈ និងវិចារៈប៉ុណ្ណោះ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ សូម្បីត្រាស់ពាក្យខាងដើម ហើយក៏គួរ

ត្រាស់ពាក្យខាងក្រោយទៀត ។

បទថា **សមាធិជំ** សេចក្ដីថា កើតអំពីបឋមជ្ឈានសមាធិ ឬអំពីសមាធិ ឬអំពីសមាធិដែលសម្បយុត្តគ្នា ។ ក្នុងព្រះបាលីនោះ ព្រះដ៏មានព្រះភាគត្រាស់ទុតិយជ្ឈាននេះប៉ុណ្ណោះថា កើតអំពីសមាធិ ដើម្បីសរសើរទុតិយជ្ឈាននេះ ព្រោះសូម្បីបឋមជ្ឈានទើងកើតអំពីសមាធិ ដែលសម្បយុត្តក៏ពិត តែសមាធិនេះប៉ុណ្ណោះ គួរហៅបានថា សមាធិ ព្រោះជាសមាធិដែលមិនញាប់ញ័រ និងផូរផង់ក្រៃលែង ព្រោះវៀរចាកការកម្រើកញាប់ញ័រនៃវិតក្កៈវិចារៈ ។

ពាក្យថា **បីតិសុខំ** នេះ មានន័យដូចពោលមកហើយនោះឯង ។

បទថា **ទុតិយំ** គឺជាចំណែកទី ២ ដោយលំដាប់នៃការគណនា ។ ឈាននេះឈ្មោះថា ទី ២ ព្រោះអត្ថថា ព្រះយោគាវចរសម្រេចជាលើកទី ២ ដូច្នេះក៏មាន ។

ក្នុងពាក្យថា **ឈានំ** នេះ គប្បីជ្រាបថា បឋមជ្ឈានមានអង្គ ៥ ព្រោះអង្គទាំងឡាយ មានវិតក្កៈជាដើម យ៉ាងណា ទុតិយជ្ឈាននេះក៏មានអង្គ ៤ ព្រោះអង្គទាំងឡាយ មានសម្បសាទជាដើម ដូច្នោះ ។ ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា **ឈានន្តិ សម្បសាទោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា** ត្រង់ពាក្យថា ឈាន គឺសេចក្ដីជ្រះថ្លាស៊ប់ បីតិ សុខ ឯកគ្គតានៃចិត្ត ។ យ៉ាងនោះជាន័យដោយអមប៉ុណ្ណោះ ។ តែន័យដោយត្រង់ទុតិយជ្ឈាននោះ វៀរអង្គ គឺសម្បសាទចេញហើយ មានអង្គ ៣ ប៉ុណ្ណោះ ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា **តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិត្តស្ស**

**ឯកគ្គតា** ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺបីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ទុតិយជ្ឈានកថា ចប់

# តតិយជ្ឈានកថា

*បីតិ ក្នុងពាក្យថា* **បីតិយា ច វិរាគា** *នេះ មានអត្ថដូចពោលហើយនោះឯង ។ ការនឿយណាយ ឬការឈានកន្លងបីតិនោះ ឈ្មោះថា វិរាគៈ ( ការខ្ពាក់ចោល ) ។ ច សព្ទ ត្រង់ចន្លោះបទទាំង ២ មានការប្រមូលមកជាអត្ថ ។ ច សព្ទ ប្រមូលមកនូវសេចក្ដីស្ងប់ ឬការចូលទៅស្ងប់វិតក្កៈវិចារៈ ។ គប្បីជ្រាបយោជនាយ៉ាងនេះថា ក្នុងការប្រមូលទាំង ២ យ៉ាងនោះក្នុងកាលណាប្រមូលសេចក្ដីស្ងប់មកតែម្យ៉ាង ក្នុងពេលនោះ ព្រោះបន្ទោបង់ចោលនូវបីតិ និងព្រោះស្ងប់បានបន្ថែមឡើងទៀតបន្តិចបន្តួច ។ ក្នុងយោជនានេះ* **វិរាគ** *សព្ទ មានការនឿយណាយជាអត្ថ ព្រោះដូច្នោះ គប្បីឃើញអត្ថដូច្នេះថា ព្រោះនឿយណាយផង ព្រោះរម្ងាប់បីតិផង ។*

*គប្បីជ្រាបយោជនាយ៉ាងនេះថា ក្នុងពេលណាប្រមូលសេចក្ដីស្ងប់រម្ងាប់វិតក្កៈវិចារៈមក ក្នុងវេលានោះ ព្រោះនឿយណាយក្នុងបីតិ និងព្រោះចូលទៅស្ងប់វិតក្កៈ វិចារៈ បន្ថែមឡើងទៀតបន្តិចបន្តួច ។ ក្នុងយោជនានេះ* **វិរាគ** *សព្ទ មានការឈានកន្លងជាអត្ថ ព្រោះដូច្នោះ គប្បីឃើញអត្ថដូច្នេះថា ព្រោះកន្លងបង់នូវបីតិផង ព្រោះស្ងប់វិតក្កៈវិចារៈផង ។ ម្យ៉ាងទៀត វិតក្កៈ វិចារៈនេះ ស្ងប់ហើយក្នុងទុតិយជ្ឈាននោះឯងក៏ពិត សូម្បីយ៉ាងនោះ ពាក្យថា ព្រោះចូលទៅស្ងប់វិតក្កៈ វិចារៈនេះ ព្រះដ៏មានព្រះភាគត្រាស់ទុកហើយ ដើម្បីទ្រង់សម្ដែងឧបាយជាគ្រឿងសម្រេចឈាននេះផង ដើម្បីពោលសរសើរឈាននេះផង ។*

*សួរថា ពិតហើយ កាលទ្រង់ត្រាស់ថា និងព្រោះការស្ងប់រម្ងាប់វិតក្កៈ*

វិចារៈ ពាក្យនេះ រមែងប្រាកដថា ការស្ងប់រម្ងាប់វិតក្កៈ វិចារៈ ក៏ជាឧបាយគ្រឿងសម្រេចឈាននេះ មិនមែនឬ ឆ្លើយថា ក្នុងអរិយមគ្គទី ៣ លោកពោលការលះបង់យ៉ាងនេះថា ព្រោះលះឱរម្ភាគិយសំយោជនៈទាំង ២ មានសក្កាយទិដ្ឋិជាដើម ដែលមិនទាន់លះបាន រមែងជាការពោលសរសើរ ( អរិយមគ្គទី ៣ ) ដើម្បីឲ្យកើតសេចក្ដីឧស្សាហ៍ដល់ជនទាំងឡាយ ដែលមានការខ្នះខ្នែង ដើម្បីសម្រេចអរិយមគ្គទី ៣ នោះ យ៉ាងណា ក្នុងតតិយជ្ឈាននេះ លោកពោលការស្ងប់រម្ងាប់វិតក្កៈ វិចារៈ ដែលមិនទាន់ស្ងប់រម្ងាប់ទុក ជាការពោលសរសើរ ( ឈាននេះ ) យ៉ាងនោះដូចគ្នា ។ ព្រោះហេតុនោះ ទើបលោកពោលអត្ថនេះទុកថា ព្រោះឈានកន្លងបីតិផង ព្រោះស្ងប់រម្ងាប់វិតក្កៈ វិចារៈផង ដូច្នេះ ។

ក្នុងពាក្យថា **ឧបេក្ខកោ ច វិហាសិ** នេះ មានវិនិច្ឆ័យថា ធម្មជាតិឈ្មោះថា ឧបេក្ខា ព្រោះអត្ថថា សម្លឹងដោយឧប្បត្តិ ។ អធិប្បាយថា រមែងឃើញស្មើ គឺរមែងឃើញមិនធ្លាក់ទៅក្នុងចំណែកណាមួយ ។ បុគ្គលដល់ព្រមដោយតតិយជ្ឈាន លោកហៅថា អ្នកមានឧបេក្ខា ។ ព្រោះជាបុគ្គលប្រកបដោយឧបេក្ខានោះ រុងរឿងបរិបូណ៌ដ៏មានកម្លាំង ។

## ឧបេក្ខា ១០ យ៉ាង

ឧបេក្ខាមាន ១០ យ៉ាងគឺ **ឆឡង្គុបេក្ខា** ឧបេក្ខាក្នុងអង្គ គឺអារម្មណ៍ប្រាំមួយ ១ **ព្រហ្មវិហារុបេក្ខា** ឧបេក្ខាក្នុងព្រហ្មវិហារ ១ **ពោជ្ឈង្គុបេក្ខា** ឧបេក្ខាក្នុងពោជ្ឈង្គ ១ **វីរិយុបេក្ខា** ឧបេក្ខាក្នុងវីរិយៈ ១ **សង្ខារុបេក្ខា**

ឧបេក្ខាក្នុងសង្ខារ ១ **វេទនុបេក្ខា** ឧបេក្ខាក្នុងវេទនា ១ **វិបស្សនុបេក្ខា** ឧបេក្ខាក្នុងវិបស្សនា ១ **តត្រមជ្ឈត្តុបេក្ខា** ឧបេក្ខាក្នុងការដាក់ខ្លួនជាកណ្តាលក្នុងធម៌នោះៗ ១ **ឈានុបេក្ខា** ឧបេក្ខាក្នុងឈាន ១ **ចារិសុទ្ធុបេក្ខា** ឧបេក្ខាក្នុងភាពបរិសុទ្ធ ១ ។

ក្នុងឧបេក្ខាទាំង ១០ ដូចពោលមកនេះ គប្បីជ្រាបតាមន័យដែលលោកពោលទុកហើយ ក្នុងវណ្ណនានៃភយភេរវសូត្រ ក្នុងអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ឬក្នុងអដ្ឋកថា ធម្មសង្គហ: ឈ្មោះអដ្ឋសាលិនី ដោយន័យដែលមកហើយក្នុងទីនោះៗ និងដោយអំណាចនៃសង្ខេប គឺភូមិ បុគ្គល ចិត្ត អារម្មណ៍ ខន្ធសង្គហ: ឯកក្ខណចិត្ត និងកុសលត្តិក: ។ ឧបេក្ខា កាលខ្ញុំពោលទុកក្នុងអធិការនេះ រមែងធ្វើនិទាននៃព្រះវិន័យឲ្យជាការ:ធ្ងន់ក្រៃលែង ព្រោះហេតុនោះ ទើបខ្ញុំមិនពោល ។

ចំណែកឧបេក្ខាដែលដោយកក្នុងអធិការនេះ ដោយលក្ខណ:ជាដើម គប្បីជ្រាបថា មានភាពជាកណ្តាលជាលក្ខណ: មានការមិនអើពើជាកិច្ច មានការមិនខ្វះខ្វែងជាបច្ចុប្បដ្ឋាន មានការមិនមានបីតិជាបទដ្ឋាន ។

ក្នុងអធិការពោលដោយតតិយជ្ឈាននេះ អាចារ្យអ្នកចោទសួរថា ឯឈានុបេក្ខានេះ ដោយអត្ថ គឺតត្រមជ្ឈត្តុបេក្ខានោះឯង ហើយឈានុបេក្ខានោះ ក៏មាននៅក្នុងបឋមជ្ឈាន និងទុតិយជ្ឈាន ព្រោះដូច្នោះ ឈានុបេក្ខានេះព្រះដ៏មានព្រះភាគ ក៏គួរត្រាស់ទុកក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ យ៉ាងនេះថា **ឧបេក្ខកោ ច វិហាសិ** ដូច្នេះ មិនមែនឬ ព្រោះហេតុអ្វី ទើបមិន

ត្រាស់ឈានុបេក្ខានោះទុកផង ធ្លើយថា ព្រោះមានកិច្ចមិនទាន់ប្រាកដច្បាស់ៗ ពិតហើយ កិច្ចនៃឈានុបេក្ខានោះ ក្នុងបឋមជ្ឈាន និងទុតិយជ្ឈាននោះ ឈ្មោះថា មិនទាន់ប្រាកដច្បាស់ ព្រោះត្រូវបដិបក្ខធម៌ មានវិតក្កៈជាដើមគ្រប សង្កត់ ។ ចំណែកក្នុងតតិយជ្ឈាននេះ ឈានុបេក្ខាកើតមានកិច្ចប្រាកដច្បាស់ ដូចជា ងើបក្បាលឡើងបានហើយ ព្រោះវិតក្កៈ វិចារៈ និងបីតិ គ្របសង្កត់ មិនបាន ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ឈានុបេក្ខានោះទុកដូច្នេះៗ

ការពណ៌នាអត្ថដោយប្រការទាំងពួងនៃបទថា **ឧបេក្ខកោ ច វិហាសិ** នេះចប់ហើយ ។

ឥឡូវនេះ មានវិនិច្ឆ័យក្នុងបាលីថា **សតោ ច សម្បជានោ** ។ ឈ្មោះថា **សតោ** ព្រោះអត្ថថា រឭកបាន ។ ឈ្មោះថា **សម្បជានោ** ព្រោះអត្ថថា ដឹងច្បាស់ដោយប្រពៃ សតិ និងសម្បជញ្ញៈ ត្រាស់ដោយបុគ្គល ។ ក្នុង សតិ និងសម្បជញ្ញៈនោះ សតិមានការរឭកបានជាលក្ខណៈ មានការមិន វង្វេងជាកិច្ច មានការឃុំគ្រងជាអាការប្រាកដ ។ សម្បជញ្ញៈ មានការមិន វង្វេងជាលក្ខណៈ មានការពិចារណាជាកិច្ច មានការធ្លុះបំភ្លឺជាអាការប្រាកដៗ សតិ និងសម្បជញ្ញៈនេះ គប្បីជ្រាបដោយពិស្ដារតាមន័យដែលខ្ញុំពោល ហើយ ក្នុងវណ្ណនានៃសតិប្បដ្ឋានសូត្រ ក្នុងអដ្ឋកថាមជ្ឈិមនិកាយនោះឯង ។

បណ្ដាធម៌ក្នុងតតិយជ្ឈាននោះ សតិ និងសម្បជញ្ញៈនេះ រមែងមានក្នុង ឈានមុនៗ ដោយពិត ព្រោះថា គុណជាតិត្រឹមឧបចារៈ រមែងមិនសម្រេច ដល់ព្រះយោគាវចរ ដែលមិនមានសតិ មិនមានសម្បជញ្ញៈ នឹងពោលថ្វី

ដល់អប្បនា ។ ព្រោះឈានទាំងនោះគ្រោតគ្រាត ទើបការប្រព្រឹត្តទៅរបស់ចិត្ត មានការងាយស្រួល ដូចការប្រព្រឹត្តទៅលើផែនដីរបស់បុរស ដូច្នោះ កិច្ចនៃសតិ និងសម្បជញ្ញៈក្នុងឈានទាំងនោះ ទើបមិនប្រាកដច្បាស់ ។ ព្រោះឈាននេះមានសភាពល្អិត ព្រោះលះអង្គដែលគ្រោតគ្រាតបាន ការប្រព្រឹត្តទៅរបស់ចិត្ត ដែលកិច្ចនៃសតិ និងសម្បជញ្ញៈគ្រប់គ្រងហើយនោះឯង ដូចការដើរជិតមុខកាំបិតកោររបស់បុរស ដូច្នោះ ព្រោះហេតុនេះ ទើបត្រាស់ទុកក្នុងតតិយជ្ឈាននេះ សេចក្តីដែលគួរពោលបន្ថែមនៅមានបន្តិចបន្តួចទៀត ។ អ្នកប្រាជ្ញគប្បីជ្រាបសន្និដ្ឋានថា ពាក្យថា **សតោ ច សម្បជានោ** ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងតតិយជ្ឈាននេះប៉ុណ្ណោះ ក៏ដើម្បីសម្តែងអត្ថវិសេសនេះថា កូនគោដែលនៅដើរតាមមេគោ ត្រូវព្រាត់អំពីមេគោ កាលមិនឃ្លាំថែរក្សាទុក រមែងចូលរកមេគោទៀតនោះឯង យ៉ាងណា សេចក្តីសុខក្នុងតតិយជ្ឈាននេះក៏ដូច្នោះ ត្រូវព្រាត់អំពីបីតិ ហើយសេចក្តីសុខ កាលមិនគ្រប់គ្រងដោយគ្រឿងគ្រប់គ្រង គឺសតិ និងសម្បជញ្ញៈ គប្បីចូលរកបីតិទៀតនោះឯង គប្បីជាសុខដែលសម្បយុត្តដោយបីតិនោះឯង ។ សូម្បីសត្វទាំងឡាយ រមែងមានតម្រេកពន់ពេកក្នុងសេចក្តីសុខ ហើយសេចក្តីសុខនេះ ក៏ជាសុខក្រៃពេក ព្រោះមិនមានសុខដទៃក្រៃលែងជាងនោះ តែការមិនត្រេកអរខ្វាំងក្នុងសេចក្តីសុខ រមែងមានក្នុងតតិយជ្ឈាននេះ ដោយអានុភាពនៃសតិ និងសម្បជញ្ញៈ មិនមែនមានដោយប្រការដទៃឡើយ ដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **សុខញ្ច កាយេន បដិសំវេទេសី**

នេះ ដូច្នេះថា ព្រះយោគីដែលដល់ព្រមដោយតតិយជ្ឈាន មិនមានការរំពឹង ក្នុងការសោយសេចក្ដីសុខក៏ពិត ទោះបីដូច្នោះ ព្រះយោគីនោះ សូម្បីចេញអំពីឈានហើយ ក៏គប្បីសោយសុខបាន ព្រោះរូបកាយរបស់លោក ជារូបដែលប្រណីតក្រៃលែង ព្រោះមានសេចក្ដីសុខដែលសម្បយុត្ត ដោយនាមកាយរបស់លោក ឬសេចក្ដីសុខដែលប្រកបនាមកាយនោះ ជាសមុដ្ឋាន ពាល់ត្រូវ ជ្រួតជ្រាបហើយ ។

ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងសេចក្ដីនោះ ទើបត្រាស់ថា **សុខញ្ច កាយេន បដិសំវេទេសី** ដូច្នេះ ។

ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងពាក្យថា **យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារី** ដូច្នេះថា ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម រមែងប្រាប់ គឺរមែងសម្ដែង រមែងបញ្ញត្ត រមែងតែងតាំង រមែងបើកផ្សាយ រមែងចែក រមែងធ្វើឲ្យរាក់ អធិប្បាយថា រមែងប្រកាស គឺរមែងសរសើរនូវបុគ្គលដែលមានការដល់ព្រមដោយតតិយជ្ឈាននោះ ព្រោះហេតុនៃឈានណា គឺព្រោះឈានណាជាហេតុ ។ រមែងសរសើរដូចម្ដេច រមែងសរសើរថា ជាអ្នកមានឧបេក្ខា មានសតិ នៅជាសុខ ដូច្នេះ ។ តថាគតចូលដល់តតិយជ្ឈាននោះហើយ យោជនាក្នុងពាក្យថា **យន្តំ អរិយា** ជាដើមនេះ គប្បីជ្រាបដូចពណ៌នាមកយ៉ាងនេះ ដោយប្រការដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះអរិយៈទាំងនោះ សរសើរបុគ្គលដែលមានការដល់ព្រមដោយតតិយជ្ឈាននោះទុកយ៉ាងនោះ ឆ្លើយថា ព្រោះជា

បុគ្គលដែលគួរសរសើរ ។

ពិតហើយ ព្រោះយោគីនេះ ជាបុគ្គលមានការព្រងើយក្នុងតតិយជ្ឈាន ដែលមានសុខដ៏ត្រជាក់ចិត្តពន់ពេក ដែលដល់នូវត្រើយនៃសេចក្ដីសុខហើយក៏ដោយ មិនត្រូវសេចក្ដីត្រេកអរក្នុងសុខអូសទាញទៅក្នុងតតិយជ្ឈាននោះបានឡើយ និងឈ្មោះថា ជាបុគ្គលមានសតិ ព្រោះជាបុគ្គលមានសតិតាំងមាំដោយអាការដែលបីតិកើតឡើងមិនបាន និងព្រោះលោកបានសោយសេចក្ដីសុខដែលមិនសៅហ្មង ដែលជាអរិយកន្តៈ និងដែលជាអរិយជនសេពហើយនោះឯង ដោយនាមកាយ ដូច្នោះ ទើបជាបុគ្គលគួរសរសើរ ។

គប្បីជ្រាបសន្និដ្ឋានថា ព្រោះជាបុគ្គលគួរសរសើរ ព្រះអរិយៈទាំង-ឡាយ កាលទឹងប្រកាសគុណ ដែលជាហេតុគួរសរសើរទាំងនោះ ទើបទ្រង់សរសើរបុគ្គល ដែលមានការដល់ព្រមដោយតតិយជ្ឈាននោះ យ៉ាងនេះថា ជាអ្នកមានឧបេក្ខា មានសតិ នៅជាសុខ ដូចពណ៌នាដូច្នេះ ។

បទថា **តតិយំ** គឺលំដាប់ទី ៣ នៃការគណនា ។ ឈានេនះឈ្មោះថាទី ៣ ព្រោះអត្ថថា ព្រះយោគាវចរសម្រេចលើកទី ៣ ដូច្នេះក៏មាន ។

ក្នុងពាក្យថា **ឈានំ** នេះ គប្បីជ្រាបវិនិច្ឆ័យថា ទុតិយជ្ឈានមានអង្គ ៤ ដោយអង្គទាំងឡាយ មានសម្បសាទជាដើម យ៉ាងណា តតិយជ្ឈាននេះក៏មានអង្គ ៥ ដោយអង្គទាំងឡាយ មានឧបេក្ខាជាដើមយ៉ាងនោះ ដូចព្រះដ៏ព្រះភាគត្រាស់ទុកថា **ឈានន្តិ ឧបេក្ខា សតិ សម្បជញ្ញំ សុខំ ចិត្តស្ស ឯកគ្គតា** ។ត្រង់ពាក្យថា ឈាន គឺឧបេក្ខា សតិ សម្បជញ្ញៈ សុខ

ឯកគ្គតានៃចិត្ត ដូច្នេះ ជានយ័អមប៉ុណ្ណោះ តែដោយនយ័ត្រង់ តតិយជ្ឈាន នោះ វៀរអង្គ គឺឧបេក្ខា សតិ និងសម្បជញ្ញៈចេញ រមែងប្រកបដោយអង្គ ២ ប៉ុណ្ណោះ ដូចព្រះដ៏ព្រះភាគត្រាស់ទុកថា ឈានមានអង្គ ២ គឺសុខ និង ឯកគ្គតានៃចិត្ត មាននៅក្នុងសម័យនោះដូចម្ដេច ពាក្យដ៏សេសមាននយ័ ដូច ពោលមកហើយនោះឯង ។

តតិយជ្ឈាន ចប់

# ចតុត្ថជ្ឈានកថា

បទថា **សុខស្ស ច បហានា ទុក្ខស្ស ច បហានា** ព្រោះលះបង់នូវសុខផង ព្រោះលះបង់នូវទុក្ខផង ដូច្នោះ គឺព្រោះលះសុខផ្លូវកាយ និងទុក្ខផ្លូវកាយ ។ បទថា **បុព្វេវ** សេចក្តីថា កាលលះសុខ និងទុក្ខនោះឯង មានហើយអំពីមុនពិត មិនមែនមានក្នុងខណៈចតុត្ថជ្ឈាននោះឡើយ ។ បទថា **សោមនស្សទោមនស្សានំ អត្ថង្គមា** នេះ សេចក្តីថា ព្រោះដល់នូវការតាំងនៅមិនបាននៃសោមនស្ស និងទោមនស្ស មានពាក្យអធិប្បាយថា ព្រោះលះបាននោះឯងនូវធម៌ ២ ប្រការទាំងនេះ គឺសុខផ្លូវចិត្ត និងទុក្ខផ្លូវចិត្តអំពីមុននោះឯង ។ សួរថា លះសុខ ទុក្ខ សោមនស្ស និងទោមនស្សទាំងនោះបានក្នុងកាលណា ឆ្លើយថា ក្នុងខណៈនៃឧបចារៈរបស់ឈានទាំង ៤ ។ ពិតហើយសោមនស្សដែលព្រះយោគាវចរ លះបានក្នុងខណៈឧបចារៈនៃឈានទី ៤ នោះឯង ។ ទុក្ខទោមនស្ស និងសុខ លះបានក្នុងខណៈនៃឧបចារៈរបស់ឈានទី១ ទី២ និង ទី៣ ។ ដោយប្រការដូចពោលមកនេះ គប្បីជ្រាបការលះបង់សុខ ទុក្ខ សោមនស្ស និងទោមនស្សទាំងនេះ ដែលព្រះដ៏ព្រះភាគមិនបានត្រាស់ទុកដោយលំដាប់នៃការលះនោះឯង តែក៏បានត្រាស់ទុកក្នុងទីនោះ ដោយលំដាប់ឧទ្ទេសនៃឥន្ទ្រិយទាំងឡាយ ក្នុងឥន្ទ្រិយវិភង្គនោះឯង ។

មានពាក្យសួរថា បើសុខទុក្ខជាដើមនេះ ព្រះយោគាវចរលះបានក្នុងខណៈឧបចារៈនៃឈាននោះៗ សោត កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបត្រាស់ការរលត់ ( សុខទុក្ខជាដើម ) ទុកក្នុងឈានទាំងឡាយនោះឯង យ៉ាងនេះថា ចុះទុក្ខិន្ទ្រិយកើតឡើងក្នុងទីដូចម្តេច ទើបរលត់ទៅ មិនមានសេស

សល់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ រមែងចូលកាន់បឋមជ្ឈាន ដែលប្រកប ដោយវិតក្កៈ និងវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ។ ទុក្ខិន្ទ្រិយ កើតឡើងក្នុងបឋមជ្ឈាននេះ តែងរលត់ទៅឥតមានសេសសល់ ចុះទោមនស្សិន្ទ្រិយ ... ចុះសុខិន្ទ្រិយ ... សោមនស្សិន្ទ្រិយ ... កើតឡើងក្នុងបឋមជ្ឈាន នេះ តែងរលត់ទៅឥតមានសេសសល់ក្នុងទីណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង ធម្មវិន័យនេះ ព្រោះលះសុខចេញបាន ។បេ។ ចូលដល់ចតុត្ថជ្ឈាន សោមនស្សិន្ទ្រិយកើតហើយ រលត់មិនមានសេសសល់ក្នុងឈាននេះ ដូច្នេះ ។

មានពាក្យឆ្លើយថា ព្រោះជាការរលត់ដ៏ប្រសើរ ។ ពិតហើយ ការ រលត់ទុក្ខជាដើមទាំងនោះ ក្នុងឈានទាំងឡាយ មានបឋមជ្ឈានជាដើម ជា សេចក្ដីរលត់ដ៏ប្រសើរ ។ តែការរលត់ក្នុងខណៈនៃឧបចារៈប៉ុណ្ណោះ មិនមែន ជាសេចក្ដីរលត់ដ៏ប្រសើរទេ ។ ពិតហើយ ទុក្ខិន្ទ្រិយ សូម្បីរលត់ហើយក្នុង ឧបចារៈនៃបឋមជ្ឈាន ដែលមានអាវជ្ជនៈផ្សេងៗ គ្នា តែគប្បីកើតឡើងបាន ទៀត ព្រោះសម្ផស្ស មានរបោម និងមូសជាដើម ឬព្រោះក្ដៅក្រហាយដែល កើតអំពីការអង្គុយមិនស្មើ តែមិនមែនកើតក្នុងអប្បនាឡើយ ។ ម្យ៉ាងទៀត ទុក្ខិន្ទ្រិយនោះ សូម្បីរលត់ហើយក្នុងឧបចារៈ គង់រលត់មិនស៊ប់ល្អ ព្រោះធម៌ ដែលជាសត្រូវមិនទាន់កម្ចាត់បាន ។ ចំណែកខាងក្នុងអប្បនា កាយទាំងមូល ឈោងចុះកាន់សេចក្ដីសុខ ព្រោះមានបីតិជ្រួបជ្រាប ហើយទុក្ខិន្ទ្រិយរបស់ ព្រះយោគាវចរ ដែលមានកាយឈោងចុះកាន់សេចក្ដីសុខ រាប់ថា រលត់ទៅ

ដោយល្អ ព្រោះធម៌ដែលជាសត្រូវ ត្រូវកម្ចាត់ចេញបាន ។

ឯទោមនស្សិន្ទ្រិយ ដែលព្រះយោគាវចរលះបានហើយ ក្នុងឧបចារៈនៃទុតិយជ្ឈាន ដែលមានអាវជ្ជនៈផ្សេងៗ គ្នានោះឯង តែគប្បីកើតឡើងបានទៀត ព្រោះទោមនស្សិន្ទ្រិយនោះ កាលមានសេចក្តីលំបាកកាយ និងការបង្អៀតចង្អល់ចិត្ត ដែលមានវិតក្កៈវិចារៈជាបច្ច័យ រមែងកើតឡើងបាន តែមិនកើតឡើយ កាលបើមិនមានវិតក្កៈវិចារៈ តែទោមស្សិន្ទ្រិយ នឹងកើតក្នុងចិត្តុប្បាទណា ព្រោះមានវិតក្កៈវិចារៈ ទើបកើតក្នុងចិត្តុប្បាទនោះ វិតក្កៈ វិចារៈ ក្នុងឧបចារៈនៃទុតិយជ្ឈាន លោកមិនទាន់លះបានឡើយ ព្រោះដូច្នោះ ទោមនស្សិន្ទ្រិយនោះ គប្បីកើតបានក្នុងឧបចារៈនៃទុតិយជ្ឈាននោះ ព្រោះមានបច្ច័យលះមិនទាន់បាន តែក្នុងទុតិយជ្ឈានកើតឡើងមិនបានឡើយ ព្រោះមានបច្ច័យលះបានហើយ ។

ម្យ៉ាងទៀត សុខិន្ទ្រិយ សូម្បីលះបានហើយក្នុងឧបចារៈនៃតតិយជ្ឈាន ក៏គប្បីកើតឡើងដល់ព្រះយោគាវចរអ្នកមានកាយ ដែលរូបប្រណីត មានបីតិជាសមុដ្ឋានពាល់ត្រូវហើយ តែក្នុងតតិយជ្ឈានកើតឡើងមិនបានឡើយ ។ ពិតហើយ បីតិដែលជាបច្ច័យនៃសុខក្នុងតតិយជ្ឈាន រលត់ទៅហើយ ដោយប្រការទាំងពួង ដូច្នេះ ។

ម្យ៉ាងទៀត សោមនស្សិន្ទ្រិយ សូម្បីលះបានហើយក្នុងឧបចារៈនៃចតុត្ថជ្ឈាន ក៏គប្បីកើតឡើងទៀតបាន ព្រោះនៅជិតបីតិនៅឡើយ និងព្រោះមិនទាន់ធ្លងទៅដោយល្អ ព្រោះនៅមានឧបេក្ខាដែលដល់អប្បនា តែក្នុង

ចតុត្ថជ្ឈាន នឹងកើតឡើងមិនបានឡើយ ។ ព្រោះហេតុដូចពោលមកនេះឯង ទើបព្រះដ៏ព្រះភាគទ្រង់ធ្វើ **អបរិសេស** សព្ទ ទុកក្នុងទីនោះថា ទុក្ខិន្ទ្រិយកើតឡើងហើយ រលត់ឥតសេសសល់ក្នុងឈាននេះ ដូច្នេះឯង ។

ក្នុងអធិការនៃចតុត្ថជ្ឈាននេះ អាចារ្យអ្នកចោទសួរថា បើដូច្នោះ វេទនាទាំងនោះ សូម្បីលះបានហើយក្នុងឧបចារៈនៃឈាននោះៗ ព្រោះហេតុអ្វី ទើបក្នុងចតុត្ថជ្ឈាននេះ ទ្រង់ប្រមូលមកទុកម្ដងទៀត ឆ្លើយថា ដើម្បីឲ្យកាន់យកស្រួល ( ដើម្បីយល់ងាយ ) ពិតហើយ អទុក្ខមសុខវេទនាដែលព្រះដ៏មានភាគត្រាស់ទុកក្នុងអង្គឈាននេះថា **អទុក្ខមសុខំ** នេះ ជារបស់ល្អិត ដឹងបានដោយលំបាក មិនអាចនឹងកាន់យកបានដោយងាយឡើយ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគទ្រង់ប្រមូលវេទនានោះមកទុកទាំងអស់ ដើម្បីឲ្យកាន់យកស្រួល ឧបមាដូចជាចាប់គោកាចដែលបុគ្គល មិនអាចចូលទៅជិតៗបានដោយប្រការណាមួយ ទើបនាយគោបាលកៀងគោទាំងអស់មកទុកក្នុងក្រោលតែមួយ ក្រោយមក ទើបបញ្ចេញម្ដងមួយៗ ឲ្យចាប់គោកាចនោះ ដែលដើរចេញមកតាមលំដាប់ ដោយប្រាប់ថា នេះគឺគោកាច ចូរពួកអ្នកចាប់វាដូច្នេះ ។ ពិតហើយ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងវេទនាទាំងនោះ ដែលទ្រង់ប្រមូលមកហើយយ៉ាងនោះ ទ្រង់រមែងអាចឲ្យកាន់យកវេទនានេះថា ធម្មជាតិដែលមិនមែនសុខ មិនមែនទុក្ខ មិនមែនសោមនស្ស មិនមែនទោមនស្សនេះ គឺអទុក្ខមសុខវេទនា ម្យ៉ាងទៀត វេទនាទាំងនោះ បណ្ឌិតគប្បីជ្រាបថា ព្រះអង្គត្រាស់ទុក ក៏ដើម្បីទ្រង់សម្ដែង បច្ច័យនៃអទុក្ខមសុខចេតោវិមុត្តិ ។

ពិតហើយ ធម៌ទាំងឡាយ មានការលះ សុខជាដើម ជាបច្ច័យនៃចេតោវិមុត្តិនោះ ។ ដូចព្រះនាងធម្មទិន្នាថេរីពោលទុកថា ម្នាលអាវុសោ អទុក្ខមសុខ-ចេតោវិមុត្តិសមាបត្តិ មានបច្ច័យ ៤ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្តីសុខ ១ ព្រោះលះបង់ នូវសេចក្តីទុក្ខ ១ ព្រោះរំលត់នូវសោមនស្ស និងទោមនស្សក្នុងកាលមុន ១ ចូលកាន់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំងបួន ១ ម្នាលអាវុសោ អទុក្ខមសុខចេតោវិមុត្តិសមាបត្តិមានបច្ច័យ ៤ នេះឯង ។

ម្យ៉ាងទៀត សំយោជនៈទាំងឡាយ មានសក្កាយទិដ្ឋិជាដើម ដែលលះបានហើយក្នុងមគ្គដទៃ មានសោតាបត្តិមគ្គជាដើម ទ្រង់ត្រាស់ថា លះបានហើយក្នុងមគ្គទី ៣ នោះ ដើម្បីត្រាស់សរសើរមគ្គទី ៣ យ៉ាងណា វេទនាមានសុខជាដើមនោះ គួរជ្រាបថា ទ្រង់ត្រាស់ទុកក្នុងចតុត្ថជ្ឈាននេះ ដើម្បីសរសើរឈាននោះ យ៉ាងនោះ ។

ម្យ៉ាងទៀត វេទនា មានសុខជាដើមនោះ គប្បីជ្រាបថា ទ្រង់ត្រាស់ទុកក្នុងចតុត្ថជ្ឈាននេះ ដើម្បីទ្រង់សម្តែងរាគៈ និងទោសៈ ជាធម្មជាត ដែលនៅសែនឆ្ងាយ ព្រោះសម្លាប់បច្ច័យចេញបាន ។ ពិតហើយ បណ្តាវេទនា មានសុខជាដើមនោះ សុខជាបច្ច័យនៃទោមនស្សៗ ជាបច្ច័យនៃរាគៈ ទុក្ខជាបច្ច័យនៃទោមនស្សៗ ជាបច្ច័យនៃទោសៈ ហើយរាគៈ ទោសៈ ព្រមទាំងបច្ច័យ ត្រូវចតុត្ថជ្ឈាននោះកម្ចាត់ហើយ ព្រោះសម្លាប់សេចក្តីសុខជាដើម

ចេញបាន ព្រោះហេតុនោះ ទើបរាគៈ និងទោសៈ មាននៅក្នុងទីឆ្ងាយក្រៃលែង ដូច្នេះឯង ។

បទថា **អទុក្ខមសុខំ** សេចក្តីថា ឈ្មោះថា អទុក្ខ ព្រោះមិនមានទុក្ខ ឈ្មោះថា អសុខ ព្រោះមិនមានសុខ ។ ក្នុងពាក្យថា **អទុក្ខមសុខំ** នេះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងវេទនាទី ៣ ដែលជាបដិបក្ខចំពោះទុក្ខ និងសុខ ដោយព្រះតម្រាស់នេះ ទ្រង់មិនមែនសម្តែងត្រឹមតែការមិនមាននៃទុក្ខ និងសុខនោះឡើយ ។ អទុក្ខ និងអសុខ ឈ្មោះថា វេទនាទី ៣ លោកហៅថា **ឧបេក្ខា** ក៏មាន ។ ឧបេក្ខានោះ បណ្ឌិតគប្បីជ្រាបថា មានការសោយអារម្មណ៍ដែលប្លែកអំពីអារម្មណ៍ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ជាលក្ខណៈ មានភាពជាកណ្តាលជាកិច្ច មានអារម្មណ៍មិនជាក់ច្បាស់ជាអាការប្រាកដ មានការរលត់សុខជាបទដ្ឋាន ។

បទថា **ឧបេក្ខាសតិបរិសុទ្ធឹ** សេចក្តីថា មានសតិជាធម្មជាតិបរិសុទ្ធដែលឧបេក្ខាឲ្យកើតហើយ ។ ពិតហើយ ក្នុងឈាននេះ សតិជាធម្មជាតិបរិសុទ្ធដោយល្អ និងការបរិសុទ្ធនៃសតិនោះ ដែលឧបេក្ខាធ្វើហើយ មិនមែនធម៌ដទៃធ្វើឡើយ ព្រោះហេតុនោះ ទើបឈាននោះ ព្រះដ៏មានព្រះភាគត្រាស់ហៅថា មានសតិបរិសុទ្ធ ដែលឧបេក្ខាឲ្យកើតហើយ ដូច្នេះ ។ ក្នុងគម្ពីរវិភង្គ ទ្រង់ត្រាស់ទុកថា សតិនេះ ជាធម្មជាតិបើក បរិសុទ្ធ ផូរផង់ ដោយឧបេក្ខានេះ ដោយហេតុនោះ ទើបពោលថា មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ។ ឯសេចក្តីបរិសុទ្ធនៃសតិក្នុងចតុត្ថជ្ឈាននេះ រមែងមានព្រោះឧបេក្ខាណា ឧបេក្ខា

នោះ ដោយអត្ថ គប្បីជ្រាបថា មានភាពជាកណ្ដាលក្នុងធម៌នោះៗ ម្យ៉ាងទៀត ក្នុងចតុត្ថជ្ឈាននេះ សតិប៉ុណ្ណោះ មិនមែនជាធម្មជាតិបរិសុទ្ធ ព្រោះឧបេក្ខាតែម្យ៉ាងនោះឡើយ ម្យ៉ាងទៀត សម្បយុត្តធម៌ទាំងអស់ ក៏បរិសុទ្ធ ព្រោះឧបេក្ខានោះ ( ដូចគ្នា ) ។ តែទេសនា ទ្រង់ត្រាស់ទុកដោយលើកសតិឡើងជាប្រធាន ។

បណ្ដាធម៌ក្នុងចតុត្ថជ្ឈាននោះ ឧបេក្ខានេះ មានក្នុងឈានទាំង ៣ សូម្បីក្នុងគ្រាក្រោយក៏ពិត តែចន្ទលេខា ពោល គឺតត្រមជ្ឈត្តុបេក្ខានេះ សូម្បីមានក្នុងការផ្សេងគ្នានៃឈាន មានបឋមជ្ឈានជាដើម រមែងឈ្មោះថា ជាធម្មជាតិមិនបរិសុទ្ធ ព្រោះត្រូវតេជះនៃធម៌ដែលជាសត្រូវ មានវិតក្កៈជាដើមគ្របសង្កត់ និងព្រោះមិនបានរាត្រី ពោល គឺឧបេក្ខាវេទនា ដែលជាសភាគៈគ្នា ប្រៀបដូចចន្ទលេខា ( ព្រះចន្ទ ) សូម្បីមានក្នុងវេលាថ្ងៃ ក៏ឈ្មោះថា ជារបស់មិនបរិសុទ្ធ មិនផូរផង់ ព្រោះត្រូវរស្មីព្រះអាទិត្យគ្របសង្កត់ពេលថ្ងៃ ឬព្រោះមិនបានពេលយប់ដែលជាសភាគៈគ្នា ដោយភាពជារបស់ដែលមានឧបការៈដល់ខ្លួន ដោយភាពជារបស់ស្រស់ស្អាត ដូច្នោះ ។ កាលតត្រមជ្ឈត្តុបេក្ខានោះមិនបរិសុទ្ធ ធម៌ទាំងឡាយ មានសតិជាដើម សូម្បីកើតឡើងរួមគ្នា ក៏ជាធម្មជាតិមិនបរិសុទ្ធដោយពិត ដូចរស្មីនៃព្រះចន្ទ មិនបរិសុទ្ធក្នុងពេលថ្ងៃ ដូច្នោះ ។ ព្រោះហេតុនោះ សូម្បីឈានមួយ ក្នុងបណ្ដាបឋមជ្ឈានជាដើមនោះ ព្រះដ៏មានព្រះភាគក៏មិនត្រាស់ថា មានសតិបរិសុទ្ធ ព្រោះឧបេក្ខា ចំណែកក្នុងចតុត្ថជ្ឈាននេះ ព្រះចន្ទ ពោល គឺតត្រមជ្ឈត្តុបេក្ខានេះ ជាធម្មជាតិ

បរិសុទ្ធយ៉ាងក្រៃលែង ព្រោះមិនត្រូវតែជះនៃធម៌ដែលជាសត្រូវ មានវិតក្កៈ ជាដើមគ្របសង្កត់ និងព្រោះបានពេលយប់ គឺឧបេក្ខាវេទនា ដែលជាសភាគៈ គ្នា ព្រោះតត្រមជ្ឈត្តុបេក្ខានោះ ជាធម្មជាតិបរិសុទ្ធ ធម៌ទាំងឡាយ មានសតិ ជាដើមដែលកើតរួមគ្នា ក៏ជាធម្មជាតិបរិសុទ្ធផូរផង់ ដូចរស្មីនៃព្រះចន្ទដែល បរិសុទ្ធ ដូច្នោះ ព្រោះហេតុនោះ ចតុត្ថជ្ឈាននេះប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាប ថា ព្រះដ៏មានព្រះភាគត្រាស់ថា មានសតិបរិសុទ្ធ ព្រោះឧបេក្ខា ។

បទថា **ចតុត្ថំ** គឺទី ៤ តាមលំដាប់នៃការគណនា ។ ឈាននេះ ឈ្មោះថា ទី ៤ ព្រោះអត្ថថា ព្រះយោគាវចរសម្រេចលើកទី ៤ ។

ក្នុងពាក្យថា **ឈានំ** នេះ មានវិនិច្ឆ័យដូច្នេះថា តតិយជ្ឈានមានអង្គ ៥ ដោយអង្គទាំងឡាយ មានឧបេក្ខាជាដើម យ៉ាងណា ចតុត្ថជ្ឈាននេះ ក៏ មានអង្គ ៣ ដោយអង្គទាំងឡាយ មានឧបេក្ខាជាដើមយ៉ាងនោះ ។ ដូចព្រះ ដ៏មានព្រះភាគត្រាស់ទុកថា ត្រង់ពាក្យថា ឈាន គឺឧបេក្ខា សតិ ឯកគ្គតា នៃចិត្ត ដូច្នេះ ។ នុ៎ះជាន័យដោយអមប៉ុណ្ណោះ តែដោយន័យត្រង់ ចតុត្ថជ្ឈាន នេះ វៀរអង្គ គឺសតិចេញ ព្រោះកាន់យកអង្គ គឺឧបេក្ខាវេទនានោះឯង ទើប ប្រកបដោយអង្គ ២ ។ ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា ឈានមានអង្គ ២ គឺឧបេក្ខា ចិត្តេកគ្គតា មានក្នុងសម័យនោះដូចម្តេច ពាក្យដ៏សេសមានន័យ ដូចដែលពោលមកហើយនោះឯង ។

ចតុត្ថជ្ឈាន ចប់

## បុព្វេនិវាសញ្ញាណកថា

ឈាន ៤ យ៉ាងដូចពណ៌នាមកនេះ របស់បុគ្គលពួកខ្លះ ដែលចិត្តមានអារម្មណ៍តែមួយជាប្រយោជន៍ របស់បុគ្គលពួកខ្លះជាបាទនៃវិបស្សនា របស់បុគ្គលពួកខ្លះជាបាទនៃអភិញ្ញា របស់បុគ្គលពួកខ្លះជាបាទនៃនិរោធ របស់ពួកបុគ្គលខ្លះ មានការឈានចុះកាន់ភពជាប្រយោជន៍ ។

បណ្ដាបុគ្គល ៥ ពួកនោះ ឈាន ៤ របស់ព្រះខីណាស្រពទាំងឡាយជាចិត្តមានអារម្មណ៍តែមួយជាប្រយោជន៍ ។ ពិតហើយ ព្រះខីណាស្រពទាំងនោះ តាំងចិត្តទុកយ៉ាងនេះថា អញចូលឈានហើយ មានឯកគ្គតាចិត្ត នឹងនៅជាសុខអស់ថ្ងៃ ដូច្នេះ ហើយបរិកម្មក្នុងកសិណ ឲ្យសមាបត្តិទាំង ៨ កើតឡើង ។

ឈានទាំងឡាយរបស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ដែលចេញអំពីសមាបត្តិហើយ តាំងចិត្តទុកថា អញមានចិត្តតាំងមាំហើយ នឹងឃើញច្បាស់ ហើយកើតឡើង រាប់ថា ជាបាទនៃវិបស្សនា ។

ចំណែកបុគ្គលទាំងឡាយណា ឲ្យសមាបត្តិទាំង ៨ កើតឡើងហើយ ទើបចូលឈានដែលមានអភិញ្ញាជាបាទ ហើយចេញអំពីសមាបត្តិ ប្រាថ្នាអភិញ្ញា មានន័យដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ជាមនុស្សម្នាក់ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ដូច្នេះ ទើបឲ្យកើតឡើង ឈានទាំងឡាយរបស់បុគ្គលទាំងនោះ រមែងជាបាទនៃអភិញ្ញា ។

ចំណែកបុគ្គលទាំងឡាយណា ឲ្យសមាបត្តិទាំង ៨ កើតឡើង ទើបចូលនិរោធសមាបត្តិ ហើយតាំងចិត្តទុកថា អញនឹងជាបុគ្គលមិនមានចិត្ត

សម្រេចនិរោធនិព្វាន នៅជាសុខក្នុងទិដ្ឋធម៌ អស់ ៧ ថ្ងៃ ហើយឲ្យកើតឡើង ឈានទាំងឡាយរបស់បុគ្គលទាំងនោះ រមែងជាបាទនៃនិរោធ ។

ចំណែកបុគ្គលទាំងឡាយណា ឲ្យសមាបត្តិទាំង ៨ កើតឡើង ហើយ តាំងចិត្តទុកថា អាត្មាអញជាបុគ្គលមានឈានមិនសាបសូន្យ នឹងកើតឡើង ក្នុងព្រហ្មលោក ហើយឲ្យឈានកើតឡើង ឈានទាំងឡាយរបស់បុគ្គលទាំង នោះ មានការឈានចុះកាន់ភពជាប្រយោជន៍ ។

ក្នុងចតុត្ថជ្ឈាននេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យកើតឡើងហើយ ត្រង់ មណ្ឌលពោធិព្រឹក្ស ចតុត្ថជ្ឈាននោះ របស់ព្រះដ៏មានព្រះភាគអង្គនោះ បាន ជាបាទនៃវិបស្សនាផង ជាបាទនៃអភិញ្ញាផង ជាបាទនៃនិរោធផង ធ្វើកិច្ចទាំង ២ ឲ្យសម្រេចផង បណ្ឌិតគប្បីជ្រាបថា ជាគុណជាតិញុំាងនូវគុណដែលជា លោកិយ និងលោកុត្តរ ឲ្យកើតឡើងបានគ្រប់យ៉ាង ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងឯកទេសនៃគុណទាំងឡាយ ដែល ចតុត្ថជ្ឈានជាហេតុផ្តល់ឲ្យទាំងនោះ ទើបត្រាស់ថា **ឯវំ សមាហិតេ ចិត្តេ** កាលដែលចិត្តខ្ជាប់ខ្ជួនដូច្នេះជាដើម ។

ក្នុងពាក្យថា **សោ ឯវំ** ជាដើមទាំងនោះ មានវិនិច្ឆ័យដូចតទៅនេះ បទថា **សោ** គឺ **សោ អហំ** ប្រែថា តថាគតនោះ ។ បទថា **ឯវំ** នោះ ជាបទ សម្តែងលំដាប់នៃចតុត្ថជ្ឈាន ។ អធិប្បាយថា តថាគតបានចំពោះចតុត្ថជ្ឈាន ដោយលំដាប់នេះ ។

បទថា **សមាហិតេ** សេចក្តីថា ( កាលចិត្តរបស់តថាគត ) តាំងមាំ

ហើយដោយសមាធិ ក្នុងចតុត្ថជ្ឈានទេះ ។

ចំណែកក្នុងពាក្យថា **បរិសុទ្ធេ** ជាដើម មានវិនិច្ឆ័យថា បទថា **បរិសុទ្ធេ** ព្រោះមានសតិ ជាធម្មជាតិបរិសុទ្ធដែលឧបេក្ខាឲ្យកើតហើយ ។ មានពាក្យអធិប្បាយទុកថា បទថា **បរិយោទាតេ** គឺផូរផង់ ព្រោះភាពជាធម្មជាតិបរិសុទ្ធនោះឯង ។

បទថា **អនង្គណេ** ព្រោះភាពដែលកិលេសដូចទីទួល មានរាគៈជាដើមដែលមគ្គកម្ចាត់ហើយ ព្រោះសម្លាប់នូវបច្ច័យ មានសុខជាដើមចេញបាន ។ បទថា **វិគតូបក្កិលេសេ** ព្រោះប្រាសចាកកិលេស ដូចទីទួលនោះឯង ។ ពិតហើយ ចិត្តរមែងសៅហ្មង ព្រោះកិលេសដែលដូចជាទីទួល ។

បទថា **មុទុភូតេ** ជាចិត្តទន់ ព្រោះអប់រំល្អហើយ អធិប្បាយថា ដល់នូវភាពជំនាញ ។ ពិតហើយ ចិត្តដែលប្រព្រឹត្តទៅក្នុងអំណាច លោកហៅថា **មុទុ** ( ទន់ ) ។ ម្យ៉ាងទៀត បទថា **កម្មនិយេ** ប្រែថា គួរដល់ការងារ ព្រោះភាពជាចិត្ត ទន់នោះឯង មានពាក្យអធិប្បាយថា សមគួរដល់ការងារ គឺគួរប្រកបក្នុងការងារ ។ ពិតហើយ ចិត្តដែលទន់រមែងជារបស់គួរដល់ការងារ ដូចមាស ដែលជម្រះមន្ទិលចេញល្អហើយ ដូច្នោះ ។ ចិត្តទាំង ២ គឺចិត្តទន់ និងចិត្តដែលគួរដល់ការងារនោះ នឹងមានបាន ក៏ព្រោះជាចិត្តដែលបានទទួលអប់រំល្អហើយនោះឯង ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាសភាវៈទន់ផង គួរដល់ការងារផង ដូចចិត្តនេះ

សោះឡើយ ។

បទថា **ឋិតេ** ព្រោះតាំងនៅក្នុងធម៌ទាំងឡាយ មានភាព បរិសុទ្ធជាដើមនោះ បទថា **អានេញ្ជប្បត្តេ** ព្រោះភាពជាចិត្តនឹងធឹងនោះឯង អធិប្បាយថា ជាចិត្តមិនញាប់ញ័រ គឺអស់នូវការញាប់ញ័រ ។ ម្យ៉ាងទៀត ឈ្មោះថា **ឋិតេ** ព្រោះភាពជាចិត្តនឹងធឹងហើយក្នុងអំណាចរបស់ខ្លួន ដោយភាពជាចិត្តទន់ និងគួរដល់ការងារ ។ ឈ្មោះថា **អានេញ្ជប្បត្តេ** ព្រោះភាពជាចិត្ត ដែលធម៌ទាំងឡាយ មានសទ្ធាជាដើម ផ្គងទុកហើយ ។

ពិតហើយ ចិត្តដែលសទ្ធាផ្គងទុកហើយ រមែងមិនញាប់ញ័រ ព្រោះអសទ្ធិយ ( ការមិនមានសទ្ធា ) ដែលវីរិយៈផ្គងទុកហើយ រមែងមិនញាប់ញ័រ ព្រោះកោសជ្ជៈ ( ការខ្ជិលប្រអូស ) ដែលសតិផ្គងទុកហើយ រមែងមិនញាប់ញ័រ ព្រោះសេចក្ដីប្រមាទ ដែលសមាធិផ្គងទុកហើយ រមែងមិនញាប់ញ័រ ព្រោះឧទ្ធច្ចៈ ដែលបញ្ញាផ្គងទុកហើយ រមែងកម្រើកព្រោះអវិជ្ជា ដែលដល់នូវសភាពភ្លឺ រមែងមិនញាប់ញ័រព្រោះងងឹត គឺកិលេស ចិត្តដែលធម៌ ៦ យ៉ាងនេះ ផ្គងទុកហើយ ជាចិត្តដល់នូវការមិនញាប់ញ័រ ។ ចិត្តដែលប្រកបដោយអង្គ ៨ ដូចពណ៌នាមកហើយនេះ រមែងជារបស់គួរដល់អភិនីហារ ដើម្បីការធ្វើឲ្យជាក់ដោយអភិញ្ញា នូវធម៌ទាំងឡាយ ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា ។

ន័យម្យ៉ាងទៀត កាលចិត្តនឹងធឹងហើយ ដោយសមាធិក្នុងចតុត្ថជ្ឈាន ឈ្មោះថា **បរិសុទ្ធេ** ព្រោះជាចិត្តឆ្ងាយចាកនីវរណៈ ឈ្មោះថា **បរិយោទាតេ**

ព្រោះឈានកន្ទងអង្គ មានវិតក្កៈជាដើម ឈ្មោះថា **អនង្គណោ** ព្រោះមិនមាន ការប្រព្រឹត្តថោកថយ ដោយការប្រាថ្នាដ៏លាមក ដែលជាសត្រូវចំពោះការ ត្រឡប់បានឈាន អធិប្បាយថា ឈ្មោះថា **អនង្គណោ** ព្រោះមិនមានការ ប្រព្រឹត្តថោកថយ ដោយសេចក្តីប្រាថ្នា គឺព្រោះមិនមានបច្ច័យនៃកាមរាគៈ មានប្រការផ្សេងៗ ដែលឈមចុះហើយ គឺប្រព្រឹត្តទៅហើយ ដោយអំណាច ការប្រាថ្នា ។ ឈ្មោះថា **វិគតូបក្កិលេសោ** ព្រោះការប្រាសទៅនៃការ សៅហ្មងរបស់ចិត្ត មានអភិជ្ឈាជាដើម ។ សូម្បីធម៌ទាំង ២ ( គឺការមិន មានកិលេសដូចទីទួល និងមានកិលេសប្រាសទៅ ) នោះ បណ្ឌិតគប្បីជ្រាប តាមគន្លងនៃអនង្គណសូត្រ និងវត្ថូបមសូត្រចុះ[១] ។

ឈ្មោះថា **មុទុភូតេ** ព្រោះដល់នូវភាពជំនាញ ។ ឈ្មោះថា **កម្មនិយេ** ព្រោះចូលដល់ភាពជាបាទនៃឫទ្ធិ ។ ឈ្មោះថា **ឋិតេ** ព្រោះដល់នូវភាព នឹងធឹង ព្រោះចូលដល់ភាពជាធម្មជាតិប្រណីត ដោយការពេញបរិបូណ៌នៃ ភាវនា អធិប្បាយថា ចិត្តរមែងដល់នូវការមិនញាប់ញ័រ យ៉ាងណា តាំងមាំ ហើយ យ៉ាងនោះ ។ ចិត្តដែលប្រកបដោយអង្គ ៨ ប្រការដូចពណ៌នាមក ហើយនេះ រមែងជារបស់គួរដល់អភិនីហារ ជាបាទ ជាបទដ្ឋាននៃការធ្វើឲ្យ ជាក់ច្បាស់ដោយអភិញ្ញា នូវធម៌ទាំងឡាយ ដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយ អភិញ្ញា ដោយប្រការដូច្នេះ ។

បទថា **បុព្វេនិវាសានុស្សតិញ្ញាណាយ** សេចក្តីថា កាលចិត្តនោះ

---

១- បិ. ២០ មជ្ឈិ. មូល. អនង្គណសូត្រ និងវត្ថូបមសូត្រ ។

ដែលជាបាទនៃអភិញ្ញាកើតយ៉ាងនោះ ( តថាគតបានបង្អោនចិត្តទៅ ) ដើម្បីប្រយោជន៍ដល់បុព្វេនិវាសានុស្សតិញ្ញាណនោះ ។

ក្នុងបណ្តាបទថា **បុព្វេនិវាសា** ជាដើមនេះ គប្បីជ្រាបវិគ្គហសព្ទយ៉ាងនេះថា ខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅហើយក្នុងកាលមុន គឺក្នុងអតីតជាតិ ឈ្មោះថា **បុព្វេនិវាស** ( ខន្ធដែលខ្លួនធ្លាប់នៅហើយក្នុងកាលមុន ) ។

ខន្ធដែលខ្លួនធ្លាប់នៅរួចហើយ គឺដែលខ្លួនតាមសោយហើយ បានដល់ដែលកើតឡើងក្នុងសន្តានរបស់ខ្លួន ហើយរលត់ទៅ ឬធម៌ដែលខ្លួនធ្លាប់នៅហើយ ឈ្មោះថា **និវុដ្ឋា** ( ខន្ធ ឬធម៌ដែលខ្លួនធ្លាប់អាស្រ័យហើយ ) ។

ធម៌ទាំងឡាយដែលខ្លួនធ្លាប់នៅ ដោយការនៅដោយភាពជាគោចរ គឺដែលខ្លួនដឹងច្បាស់ បានដល់ ដែលខ្លួនកំណត់ហើយ ដោយវិញ្ញាណរបស់ខ្លួន ឬដែលខ្លួនដឹងច្បាស់ហើយ ដោយវិញ្ញាណរបស់បុគ្គលដទៃ ក្នុងញាណទាំងឡាយ មានការតាមរឭកដល់សង្សារវដ្ត ដែលខ្លួនកាត់ផ្តាច់បានហើយ ឈ្មោះថា **និវុដ្ឋា**។

ព្រះយោគាវចរ តាមរឭកបាន ដល់ខន្ធដែលខ្លួនធ្លាប់នៅក្នុងកាលមុន ដោយសតិណា សតិនោះ ឈ្មោះថា **បុព្វេនិវាសានុស្សតិ** ក្នុងពាក្យថា **បុព្វេនិវាសានុស្សតិ** នេះ ។

ញាណដែលសម្បយុត្តដោយសតិនោះ ឈ្មោះថា **ញាណ** ។ ដើម្បីប្រយោជន៍ដល់បុព្វេនិវាសានុស្សតិញ្ញាណនេះ អធិប្បាយថា ( តថាគតបានបង្អោនចិត្តទៅ ) ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺដើម្បីសម្រេច បានដល់

ដើម្បីដល់ញាណនោះ ដោយប្រការដូច្នេះ ។

បទថា **អភិនិន្នាមេសឹ** ប្រែថា តថាគតបានបង្អោនទៅចំពោះហើយ ។ បទថា **សោ** គឺ **សោ អហំ** ប្រែថា តថាគតនោះ ។ បទថា **អនេកវិហិតំ** ប្រែថា មិនមែនជាតិមួយ ។ ន័យម្យ៉ាងទៀត អធិប្បាយថា ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ គឺពណ៌នាទុកហើយ ដោយអនេកប្រការ ។ បទថា **បុព្វេនិវាសំ** បានដល់ សន្តានដែលតថាគតធ្លាប់នៅប្រចាំក្នុងភពនោះៗ តាំងអំពីដើមនៃភពដែលកន្លងហើយ ជាលំដាប់ទៅ ។ ដោយបទថា **អនុស្សរាមិ** នេះ ព្រះដ៏មានព្រះភាគទ្រង់រមែងសម្ដែងថា តថាគតបានតាមរឭកទៅៗ ដល់លំដាប់នៃជាតិបានយ៉ាងនេះ គឺមួយជាតិខ្លះ ពីរជាតិខ្លះ បីជាតិខ្លះជាដើម ។ ម្យ៉ាងទៀត តថាគតរឭកតាមបានពិតៗ គឺកាលចិត្តគ្រាន់តែតថាគតបានបង្អោនទៅចំពោះហើយប៉ុណ្ណោះ តថាគតក៏រឭកបាន ។ ពិតហើយ ព្រះមហាបុរសទាំងឡាយ ដែលមានបារមីពេញលេញហើយ មិនមានការធ្វើបរិកម្ម ព្រោះហេតុនោះ មហាបុរសទាំងនោះ លុះបង្អោនចិត្តឲ្យបែរត្រង់ទៅប៉ុណ្ណោះ ក៏រមែងរឭក ( ជាតិ ) បាន ។ ចំណែកកុលបុត្រដែលជាអាទិកម្មិកទាំងឡាយ ត្រូវធ្វើបរិកម្ម ទើបរឭក ( ជាតិ ) បាន ព្រោះហេតុនោះ ទើបការបរិកម្មដោយអំណាចនៃកុលបុត្រទាំងនោះ គួរពោលទុកដែរ ។ តែកាលខ្ញុំនឹងពោលបរិកម្មនោះ នឹងធ្វើនិទាននៃព្រះវិន័យ ឲ្យជាការៈធ្ងន់ក្រៃលែង ព្រោះដូច្នោះ ខ្ញុំមិនពោលការបរិកម្មនោះទុក អ្នកសិក្សាដែលមានសេចក្ដីត្រូវការ កាន់យកបរិកម្មនោះ តាមន័យដែលខ្ញុំពោលទុកហើយ ក្នុងបករណ៍វិសេស

ឈ្មោះវិសុទ្ធិមគ្គនោះចុះ ។ ឯក្នុងនិទាននៃព្រះវិន័យនេះ ខ្ញុំនឹងពណ៌នាទុកចំពោះព្រះបាលីប៉ុណ្ណោះ ។

បទថា **សេយ្យថីទំ** ជានិបាត ចុះក្នុងអត្ថនៃការសម្តែងប្រការដែលព្រះអង្គ ទ្រង់បន្ថែមទុកហើយ ។ ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងប្រការដែលផ្សេងគ្នានៃបុព្វេនិវាស ដែលទ្រង់បន្ថែមទុកហើយនោះទើបត្រាស់ពាក្យជាដើមថា **ឯកម្បិ ជាតឹ** ជាដើម ។ ក្នុងពាក្យថា **ឯកម្បិ ជាតឹ** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **ឯកម្បិ ជាតឹ** សេចក្តីថាជាតិមួយខ្លះ បានដល់ ខន្ធសន្តានដែលទាក់ទងក្នុងភពមួយ ដែលមានបដិសន្ធិជាមូល មានចុតិជាខាងចុង ។ បទថា **ទ្វេបិ ជាតិយោ** ជាដើមក៏មានន័យដូច្នេះ ។

## អធិប្បាយ អំពីកប្ប

ម្យ៉ាងទៀត ក្នុងបទថា **អនេកេបិ សំវដ្តកប្បេ** ជាដើម គប្បីជ្រាបថាកប្បដែលកំពុងវិនាស ឈ្មោះថា សំវដ្តកប្ប កប្បដែលកំពុងចម្រើនឡើងឈ្មោះថា វិវដ្តកប្ប បណ្តាសំវដ្តកប្ប និងវិវដ្តកប្បទាំងនោះ សំវដ្តដ្ឋាយីកប្បឈ្មោះថា លោកកាន់យកហើយ ដោយសំវដ្តកប្ប ព្រោះសំវដ្តកប្ប ជាមូលដើមនៃសំវដ្តដ្ឋាយីកប្បនោះ ហើយវិវដ្តដ្ឋាយីកប្ប ក៏លោកកាន់យកហើយដោយវិវដ្តកប្ប ។ ពិតហើយ កាលកាន់យកដូច្នោះ កប្បទាំងឡាយ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យនៃកប្បនេះមាន ៤ ។ អសង្ខេយ្យ ៤ គឺអ្វីខ្លះ ។ គឺសំវដ្តកប្ប ១ វដ្តដ្ឋាយីកប្ប ១ វិវដ្តកប្ប ១

វិវដ្ដដ្ឋាយីកប្ប ១ ទាំងអស់នេះ ឈ្មោះថា លោកកាន់យកហើយ ។

បណ្ដាកប្បទាំងនោះ សំវដ្តកប្បមាន ៣ គឺតេជោសំវដ្តកប្ប ( កប្បដែលវិនាសដោយភ្លើង ) ១ អបោសំវដ្តកប្ប ( កប្បដែលវិនាសដោយទឹក ) ១ វាយោសំវដ្តកប្ប ( កប្បដែលវិនាសដោយខ្យល់ ) ១ ។

ដែននៃសំវដ្តកប្បមាន ៣ គឺជាន់អាភស្សរា ១ ជាន់សុភកិណ្ហា ១ ជាន់វេហប្ផលា ១ ។ ក្នុងកាលណាកប្បរមែងវិនាសដោយភ្លើង ក្នុងកាលនោះ លោកត្រូវភ្លើងឆេះខាងក្រោមអាភស្សរាចុះមក ។ ក្នុងកាលណាកប្បវិនាសដោយទឹក ក្នុងកាលនោះ លោកត្រូវទឹកបំផ្លាញឲ្យខ្ទេចខ្ទីខាងក្រោមសុភកិណ្ហាចុះមក ។ ក្នុងកាលណាកប្បវិនាសដោយខ្យល់ ក្នុងកាលនោះ លោកត្រូវខ្យល់បក់បំបើង ឲ្យខ្ចាត់ខ្ចាយពីខាងក្រោមវេហប្ផលាចុះមក ។ ដោយចំណែកច្រើនពុទ្ធខេត្ត ១ រមែងវិនាសទៅក្នុងកាលគ្រប់កាល ។

## ពុទ្ធខេត្ត ៣ យ៉ាង

ដែលបានឈ្មោះថា **ពុទ្ធខេត្ត** មាន ៣ គឺ **ជាតិខេត្ត ១ អាណាខេត្ត ១ វិសយខេត្ត ១ ។**

ក្នុងពុទ្ធខេត្ត ៣ យ៉ាងនោះ ទីដែលកម្រើកញាប់ញ័រហើយ ព្រោះហេតុទាំងឡាយ មានការចុះចាប់បដិសន្ធិជាដើមរបស់ព្រះតថាគត ឈ្មោះថា **ជាតិខេត្ត** ដែលមានចក្រវាលមួយម៉ឺនជាទីបំផុត ។

ស្ថានទីដែលអានុភាពនៃព្រះបរិត្ត មានរតនបរិត្ត មេត្តាបរិត្ត ខន្ធបរិត្ត ធជគ្គបរិត្ត អាដានាដិយបរិត្ត មោរបរិត្ត ដែលប្រព្រឹត្តទៅ ឈ្មោះថា

**អាណាខេត្ត** ដែលមានចក្រវាលមួយសែនកោដិជាទីបំផុត ។

ខេត្តដែលជាដែន ដែលព្រះអង្គទ្រង់ចង់ឮកដល់ ដែលព្រះអង្គទ្រង់បំណងចង់ដឹង ឬព្រះតថាគតគប្បីប្រាថ្នាជ្រាបលោកធាតុ មានប្រមាណត្រឹមណា ដូច្នេះជាដើម ឈ្មោះថា **វិសយខេត្ត** ដែលមានប្រមាណចក្រវាលមិនមានទីបំផុត ។

បណ្ដាពុទ្ធខេត្តទាំង ៣ នោះ អាណាខេត្ត ១ រមែងវិនាសទៅ ដូចពណ៌នាមក ដូច្នេះ ។ កាលអាណាខេត្តនោះវិនាស ជាតិខេត្តក៏រមែងវិនាសទៅដែរដូចគ្នា ។ ហើយជាតិខេត្ត កាលវិនាសទៅ ក៏រមែងវិនាសជាមួយគ្នានោះឯង ។ កាលតាំងនៅ ក៏រមែងតាំងនៅដូចគ្នា ។ ការវិនាសទៅ និងតាំងនៅនៃខេត្តនោះ ខ្ញុំពោលទុកហើយ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ។ អ្នកសិក្សាទាំងឡាយ ដែលមានសេចក្ដីត្រូវការពិស្ដារ គប្បីកាន់យកអំពីបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គនោះចុះ ។

បណ្ដាសំវដ្ដកប្ប និងវិវដ្ដកប្ប ដែលព្រះដ៏មានព្រះភាគត្រាស់ទុកហើយយ៉ាងនោះ ព្រះដ៏មានព្រះភាគប្រថាប់គង់នាពោធិមណ្ឌល ដើម្បីការត្រាស់ដឹងក្រៃលែងនូវព្រះសម្មាសម្ពោធិញ្ញាណ ទ្រង់រឭកអស់សំវដ្ដកប្ប ដោយក្រៃលែងខ្លះ អស់វិវដ្ដកប្បដោយក្រៃលែងខ្លះ អស់សំវដ្ដកប្ប និងវិវដ្ដកប្បដោយក្រៃលែងខ្លះ ។ ទ្រង់រឭកបានដោយន័យដូចម្ដេច គឺទ្រង់រឭកបានដោយន័យថា **អមុត្រាសឹ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អមុត្រាសឹ** សេចក្ដីថា ក្នុងសំវដ្ដកប្ប

ឈ្មោះនោះ តថាគតបានមានហើយ គឺក្នុងភពក្តី ក្នុងកំណើតក្តី ក្នុងគតិក្តី ក្នុងវិញ្ញាណដ្ឋិតិក្តី ក្នុងសត្តាវាសក្តី ក្នុងសត្តនិកាយក្តី ឈ្មោះនោះ តថាគតបានមានហើយ ។

បទថា **ឯវំនាមោ** សេចក្តីថា ( ក្នុងភពជាដើមឈ្មោះនោះ ) តថាគតមានឈ្មោះថា វេស្សន្តរ ឬមានឈ្មោះថា ជោតិបាល ។

បទថា **ឯវំគោត្តោ** សេចក្តីថា តថាគតជាភគវគោត្រ ឬគោតមគោត្រ

បទថា **ឯវំវណ្ណោ** សេចក្តីថា តថាគតមានសម្បុរ ស ឬសម្បុរសណ្តែកបាយ ។

បទថា **ឯវមាហារោ** សេចក្តីថា តថាគតមានអាហារ គឺបាយនៃស្រូវដែលចម្អិនដោយសាច់ ឬមានផ្លែឈើដែលជ្រុះឯង ជារបស់បរិភោគ ។

បទថា **ឯវំសុខទុក្ខប្បដិសំវេទី** សេចក្តីថា តថាគតបានសោយសុខនិងទុក្ខ ដោយប្រភេទ មានសាមិសសុខ និងនិរាសមិសសុខជាដើម ដែលប្រព្រឹត្តទៅតាមកាយ និងចិត្ត ដោយអនេកប្រការ ។

បទថា **ឯវមាយុបរិយន្តោ** សេចក្តីថា ( ក្នុងភពឈ្មោះនោះជាដើម ) តថាគតមានទីបំផុតនៃអាយុ កំណត់បាន ១០០ ឆ្នាំ ឬទីបំផុតនៃអាយុកំណត់បាន ៨៤០០០ កប្បយ៉ាងនោះ ។

បទជាច្រើនថា **សោ តតោ ចុតោ អមុត្រ ឧទបាទឹ** សេចក្តីថា តថាគតនោះ ចុតិអំពីភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ឬសត្តនិកាយនោះ ហើយបានកើតឡើងក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស

ឬក្នុងសត្តនិកាយឈ្មោះនោះទៀត ។

បទថា **តត្រាបាសឹ** សេចក្តីថា ខាងក្រោយតថាគតកើតហើយក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ឬក្នុងសត្តនិកាយនោះដដែលទៀត ។ ពាក្យថា **ឯវំ នាមោ** ជាដើម មានន័យដូចពោលហើយនោះឯង ។

ន័យម្យ៉ាងទៀត ព្រោះការរឭកនេះថា **អមុត្រាសឹ** គឺទ្រង់រឭកតាមដែលត្រូវការរបស់ទ្រង់ ដែលទ្រង់រឭកទៅតាមលំដាប់ ការរឭកថា **សោ តតោ ចុតោ** ជាការពិចារណារបស់ព្រះដ៏មានព្រះភាគ ដែលទ្រង់រឭកបញ្ច្រាសថយក្រោយ ព្រោះដូច្នោះ គប្បីជ្រាបអត្ថថា ព្រះដ៏មានព្រះភាគទ្រង់សំដៅយកតុសិតភព ទើបត្រាស់ពាក្យនេះថា **អមុត្រ ឧទបាទឹ** ក្នុងលំដាប់នៃការឧប្បត្តិកឡើងក្នុងភពនេះៗ ថា **ឥធូបបន្នោ**។

បទជាច្រើនថា **តត្រាបាសឹ ឯវន្នាមោ** សេចក្តីថា តថាគតបានជាទេវបុត្រ មានឈ្មោះថា **សេតុកេតុ** ក្នុងតុសិតពិភពនោះ ។

បទថា **ឯវំគោត្តោ** សេចក្តីថា តថាគតមានគោត្រដូចគ្នានឹងទេវតាទាំងនោះ ។

បទថា **ឯវំវណ្ណោ** សេចក្តីថា តថាគតមានពណ៌សម្បុរដូចមាស ។

បទថា **ឯវមាហារោ** សេចក្តីថា តថាគតមានអាហារ សស្អាតជាទិព្វ ។

បទថា **ឯវំសុខទុក្ខប្បដិសំវេទី** សេចក្តីថា តថាគតបានសោយសុខដែលជាទិព្វយ៉ាងនេះ ។ ចំណែកទុក្ខត្រឹមតែជាទុក្ខប្រចាំសង្ខារប៉ុណ្ណោះ ។

បទថា **ឯវមាយុបរិយន្តោ** សេចក្តីថា តថាគតមានទីបំផុតនៃអាយុ

៥៧ កោដិ និង ៦០ សែនឆ្នាំយ៉ាងនេះ ។

បទជាច្រើនថា **សោ តតោ ចុតោ** សេចក្តីថា តថាគតនោះ ចុតិចាកតុសិតពិភពនោះហើយ ។

ប្រជុំបទថា **ឥធូបបន្នោ** សេចក្តីថា តថាគតកើតហើយ ក្នុងផ្ទៃរបស់ព្រះនាងមហាមាយាទេវីក្នុងភពនេះ ។

បទថា **ឥតិ** ប្រែថា ដោយប្រការដូច្នេះ ។

ពីរបទថា **សាការំ សឧទ្ទេសំ** គឺព្រមដោយឧទ្ទេស ដោយអំណាចឈ្មោះ និងគោត្រ ព្រមទាំងអាការ ដោយអំណាចពណ៌សម្បុរជាដើម ។

ពិតហើយ សត្វបុគ្គលដែលសត្វលោក រមែងសម្តែងឡើង ដោយឈ្មោះ និងគោត្រថា តិស្សៈ គោតម ដូច្នេះ ។ សត្វរមែងប្រាកដដោយភាពផ្សេងៗ គ្នា ដោយពណ៌សម្បុរជាដើមថា ស សណ្តែកបាយ ដូច្នេះជាដើម ។ ព្រោះហេតុនោះ ឈ្មោះ និងគោត្រ ឈ្មោះថា ឧទ្ទេស ពណ៌សម្បុរជាដើមក្រៅអំពីនេះ ឈ្មោះថា អាការ ។

## តិរ្ថិយទាំងឡាយរឭកជាតិបាន ៤០ កប្ប

សួរថា ព្រះពុទ្ធទាំងឡាយ ទ្រង់រឭកបុព្វេនិវាសបានតែមួយពួកប៉ុណ្ណោះឬ ខ្ញុំនឹងឆ្លើយថា ព្រះពុទ្ធទាំងឡាយ ទ្រង់មិនមែនរឭកបានតែមួយពួកឡើយ សូម្បីព្រះបច្ចេកពុទ្ធ ព្រះសាវកពុទ្ធ និងតិរ្ថិយ ក៏រឭកបានដែរ តែរឭកបានដោយមិនវិសេសឡើយ ។ ពិតហើយ ពួកតិរ្ថិយរមែងរឭកបានត្រឹម ៤០ កប្បប៉ុណ្ណោះ ហួសអំពីនោះទៅ មិនអាចរឭកបានឡើយ ។ សួរថា ព្រោះ

ហេតុអ្វី ឆ្លើយថា ព្រោះបញ្ញាមានកម្លាំងខ្សោយ ។

ពិតហើយ បញ្ញារបស់ពួកតិរ្ថិយទាំងនោះ រាប់ថា មានកម្លាំងខ្សោយ ព្រោះវៀរចាកការកំណត់នាម និងរូប ។

## អសីតិមហាសាវ័ករឭកជាតិបានមួយសែនកប្ប

បណ្ដាសាវ័កទាំងឡាយ ព្រះមហាសាវ័ក ៨០ អង្គ រឭកបានមួយសែនកប្ប ។ អគ្គសាវ័កទាំងពីរអង្គរឭកបានមួយអសង្ខេយ្យ និងមួយសែនកប្ប ។ ព្រះបច្ចេកពុទ្ធទាំងឡាយរឭកបានពីរអសង្ខេយ្យ និងមួយសែនកប្ប ពិតហើយ អភិនីហាររបស់ព្រះមហាសាវ័ក អគ្គសាវ័ក និងព្រះបច្ចេកពុទ្ធទាំងនោះ មានប្រមាណប៉ុណ្ណោះ ចំណែកព្រះពុទ្ធទាំងឡាយ មិនមានកំណត់ ព្រះពុទ្ធទាំងឡាយ រមែងរឭកបានដរាបប៉ុនដែលទ្រង់ប្រាថ្នា ។ តែពួកតិរ្ថិយរមែងរឭកបានតាមលំដាប់ខន្ធប៉ុណ្ណោះ មិនអាចរឭករំលងលំដាប់ខន្ធបានឡើយ ដោយអំណាចចុតិ និងបដិសន្ធិ ព្រោះថា ការឈានចុះកាន់បទេស ( នៃញាណ ) ដែលខ្លួនប្រាថ្នា រមែងមិនមានដល់តិរ្ថិយទាំងនោះ ដែលដូចជាបុគ្គលខ្វាក់ ។ សាវ័កទាំងឡាយ រមែងរឭកបានដោយប្រការទាំងពីរ ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ដូច្នោះដែរ ។ ចំណែកព្រះពុទ្ធទាំងឡាយ ទ្រង់រឭកបានគ្រប់អន្លើ ដែលទ្រង់បំណងនោះៗ ទាំងអស់នោះឯង ទាំងខាងក្រោម ឬខាងលើ ក្នុងកោដិកប្បដ៏ច្រើន ដោយលំដាប់ខន្ធខ្លះ ដោយអំណាចចុតិ និងបដិសន្ធិខ្លះ ដោយអំណាចការឈានទៅ ដូចរាជសីហ៍ខ្លះ ។

ក្នុងពាក្យថា **អយំ ខោ មេ ព្រាហ្មណា** ជាដើម មានវិនិច្ឆ័យដូច្នេះថា

បទថា **មេ** គឺ **មយា** ប្រែថា ដែលតថាគត ។ ការដឹងច្បាស់ លោកហៅថា **វិជ្ជា** ព្រោះអត្ថថា ធ្វើឲ្យដឹងច្បាស់ ។

សួរថា រមែងធ្វើឲ្យដឹងច្បាស់នូវអ្វី ឆ្លើយថា រមែងធ្វើឲ្យដឹងច្បាស់នូវបុព្វេនិវាស ។

មោហៈ ដែលបិទបាំងវិជ្ជានោះ លោកហៅថា **អវិជ្ជា** ព្រោះអត្ថថា ជាហេតុធ្វើមិនឲ្យដឹងច្បាស់នូវបុព្វេនិវាសនោះឯង ។ មោហៈនោះឯង លោកហៅថា **តម** ( ការងងឹត ) ក្នុងបទថា **តមោ** ព្រោះអត្ថថា បិទបាំង ។ វិជ្ជានោះឯង លោកហៅថា **អាលោក** ក្នុងបទថា **អាលោកោ** ព្រោះអត្ថថា ធ្វើឲ្យភ្លឺ ។ បណ្ដាបទទាំងនេះ ក្នុងបទថា **វិជ្ជា អធិគតា** នេះ មានអធិប្បាយប៉ុណ្ណេះ ។ ពាក្យដ៏សេសជាពាក្យពោលសរសើរ ។

ចំណែកក្នុងបទទាំងពីរ គឺបទថា **វិជ្ជា អធិគតា វិជ្ជា វិហតា** នេះ មានយោជនាថា វិជ្ជានេះឯង តថាគតបានសម្រេចហើយ អវិជ្ជា ដែលតថាគតអ្នកបានវិជ្ជានោះកម្ចាត់បានហើយ អធិប្បាយថា ឲ្យវិនាសហើយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះវិជ្ជាកើតឡើងហើយ ។

ក្នុងបទទាំងពីរ ( គឺ **តមោ វិហតោ អាលោកោ ឧប្បន្នោ** ) សូម្បីក្រៅអំពីនេះ ក៏មានន័យនេះ ។

សព្ទថា **យថា** ក្នុងពាក្យថា **យថា តំ** នេះ ជានិបាត ចុះក្នុងការឧបមា សព្ទថា **តំ** ជានិបាត ។

( វិជ្ជាជាដើមកើតឡើងហើយ ) ដល់បុគ្គលដែលឈ្មោះថា មិន

*ប្រមាទ ព្រោះការមិននៅប្រាសចាកសតិ បុគ្គលឈ្មោះថា មានសេចក្តីព្យាយាមដុតកម្តៅកិលេស ព្រោះញ៉ាំងកិលេសឲ្យក្តៅដោយសេចក្តីព្យាយាម ជាបុគ្គលឈ្មោះថា មានខ្លួនបញ្ជូនទៅហើយ អធិប្បាយថា ដែលបញ្ជូនចិត្តទៅហើយ ព្រោះជាបុគ្គលមិនមានការជាប់ជំពាក់ក្នុងកាយ និងជីវិត ។*

*ព្រះដ៏មានព្រះភាគ ត្រាស់ពាក្យអធិប្បាយនេះទុកថា* **អវិជ្ជា** *តថាគតកម្ចាត់បានហើយ* **វិជ្ជា** *កើតឡើងហើយ ( ដល់តថាគត ) ងងឹត តថាគតកម្ចាត់បានហើយ ពន្លឺកើតឡើងហើយ ( ដល់តថាគត ) ផលដែលសមគួរដល់ការប្រកបសេចក្តីព្យាយាមរឿយៗ នោះ តថាគតបានហើយ ដូចជាអវិជ្ជាដែលព្រះយោគាវចរគប្បីកម្ចាត់ វិជ្ជាគប្បីកើតឡើង ងងឹតគប្បីត្រូវកម្ចាត់ ពន្លឺគប្បីកើតឡើងដល់ព្រះយោគាវចរដែលមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស ដែលមានខ្លួនបញ្ជូនទៅហើយដូច្នោះ ដូចគ្នា ។*

*បទជាច្រើនថា* **អយំ ខោ មេ ព្រាហ្មណ បឋមា អភិនិព្ភិទា**[១] **អហោសិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា** *ប្រែថា ម្នាលព្រាហ្មណ៍ នេះឯងជាបឋមវិជ្ជា ដែលតថាគតបានត្រាស់ដឹងហើយ ដូចជាកូនមាន់ញាស់ចេញចាកសម្បកពង បានដល់ ការកើតជាអរិយៈលើកទី ១ នេះឯង មានហើយដល់តថាគត ព្រោះទម្លាយសម្បកពង គឺអវិជ្ជា ដែលបិទបាំងនូវបុព្វេនិវុត្ថក្ខន្ធ គឺខន្ធដែលតថាគតអាស្រ័យក្នុងភពមុនដោយចំពុះ គឺបុព្វេនិវាសានុស្សតិញ្ញាណ ដូចការជ្រែកចេញ គឺការចេញទៅ បានដល់ ការកើតក្នុង*

---

*១- បិដកខ្មែរថា និព្វិទា ។*

កាលខាងក្រោយនៃកូនមាន់ទាំងឡាយ អំពីសម្បកពងនោះ នៃកូនមាន់ ព្រោះទម្លាយសម្បកពងដោយចំពុះ ឬដោយចុងក្រចក ដូច្នេះ ដោយប្រការដូច្នេះ ។

បុព្វេនិវាសកថា ចប់

# **ទិព្វចក្ខុកថា**

បទជាច្រើនថា **សោ ឯវំ ។បេ។ ចុតូបបាតញាណាយ** សេចក្តីថា ( តថាគតបានបង្អោនចិត្តទៅហើយ ) ដើម្បីញាណ ( ការដឹង ) ក្នុងចុតិ និងបដិសន្ធិ ( របស់សត្វទាំងឡាយ ) ។ អធិប្បាយថា ( តថាគតបាន បង្អោនចិត្តទៅហើយ ) ដើម្បីញាណដែលជាគ្រឿងដឹងចុតិ និងបដិសន្ធិ របស់សត្វទាំងឡាយ ។

ពីរបទថា **ចិត្តំ អភិនិន្នាមេសឹ** សេចក្តីថា តថាគតបានបង្អោនបរិកម្ម ចិត្តទៅ ។ ចំណែកក្នុងពាក្យថា **សោ ទិព្វេន ។បេ។ បស្សាមិ** នេះ មាន វិនិច្ឆ័យថា ព្រះមហាសត្វទាំងឡាយ ដែលមានបារមីបរិបូណ៌ហើយ រមែង មិនមានការធ្វើបរិកម្ម ពិតហើយ ព្រះមហាសត្វទាំងនោះ លុះបង្អោនចិត្តទៅ ប៉ុណ្ណោះ រមែងឃើញសត្វទាំងឡាយ ដែលកំពុងចុតិ កំពុងបដិសន្ធិ ថោក ទាប ប្រណីត មានពណ៌សម្បុរល្អ មានពណ៌សម្បុរអាក្រក់ មានសុគតិ ទុគ្គតិ ក្រលំបាក ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្ស ។ កុលបុត្រដែល ជាអាទិកម្មិកទាំងឡាយ ត្រូវធ្វើបរិកម្មទើបឃើញ ។ ព្រោះហេតុនោះ ការ បរិកម្មដោយអំណាចនៃកុលបុត្រទាំងនោះ ទើបគួរពោលទុក ។ តែកាលខ្ញុំ នឹងពោលការបរិកម្មនោះ នឹងធ្វើនិទាននៃព្រះវិន័យឲ្យជាភារៈធ្ងន់ពេក ព្រោះ ដូច្នោះ ខ្ញុំមិនពោលបរិកម្មនោះទុកទេ ។ ចំណែកអ្នកសិក្សាទាំងឡាយ ដែល មានសេចក្តីត្រូវការ គួរកាន់យកបរិកម្មនោះតាមន័យដែលខ្ញុំពោលទុកហើយ ក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គឯណោះចុះ ។ តែក្នុងនិទាននៃព្រះវិន័យ នេះ ខ្ញុំនឹងពណ៌នាទុកចំពោះព្រះបាលីប៉ុណ្ណោះ ។

# អធិប្បាយ ពាក្យថា ទិព្វចក្ខុ ជាដើម

បទថា **សោ** គឺ **សោ អហំ** ប្រែថា តថាគតនោះ ។ ក្នុងពាក្យថា **ទិព្វេន** ជាដើម មានវិនិច្ឆ័យយ៉ាងនេះថា ចក្ខុបសាទ ឈ្មោះថា **ទិព្វ** ព្រោះដូចជាចក្ខុទិព្វ ។ ពិតហើយ ចក្ខុបសាទរបស់ទេវតាទាំងឡាយ ដែលកើតព្រោះសុចរិតកម្ម ដែលទឹកប្រមាត់ស្លេស្ម និងឈាម ជាដើមមិនបានរុំព័ទ្ធដែលអាចទទួលអារម្មណ៍ក្នុងទីឆ្ងាយបាន ព្រោះជាធម្មជាតិដែលផុតចាកឧបក្កិលេស គ្រឿងសៅហ្មង ឈ្មោះថា ជាទិព្វ ។ ម្យ៉ាងទៀត ញាណចក្ខុនេះដែលកើតព្រោះកម្លាំងនៃវីរិយភាវនា ក៏ដូចជាចក្ខុបសាទនោះដូចគ្នា ព្រោះដូច្នោះ ញាណចក្ខុនោះ ទើបឈ្មោះថា ជាទិព្វ ព្រោះជាចក្ខុដែលទ្រង់បានហើយ ដោយអំណាចទិព្វវិហារ និងព្រោះសូម្បីខ្លួនក៏អាស្រ័យទិព្វវិហារ ។ ឈ្មោះថា ជាទិព្វ ព្រោះមានការរុងរឿងច្រើន ដោយការកំណត់ពន្លឺ ។ ឈ្មោះថា ជាទិព្វ ព្រោះមានគតិ ( ផ្លូវទៅ ) ច្រើន ដោយការឃើញរូប ដែលនៅខាងក្រៅជញ្ជាំងផ្ទះជាដើម ។ ពួក ៥ នៃអត្ថទាំងអស់នោះ បណ្ឌិតគប្បីជ្រាបតាមគន្លងនៃគម្ពីរសព្ទសាស្ត្រ ។

ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា ឃើញ ដូចជាចក្ខុ ព្រោះធ្វើកិច្ចនៃចក្ខុ ព្រោះហេតុនោះ ទើបឈ្មោះថា **ចក្ខុ** ។ ឈ្មោះថា **បរិសុទ្ធ** ព្រោះជាហេតុនៃទិដ្ឋិវិសុទ្ធិ ដោយការឃើញចុតិ និងបដិសន្ធិ ( នៃសត្វទាំងឡាយ ) ។ ពិតហើយ បុគ្គលណា ឃើញត្រឹមតែចុតិប៉ុណ្ណោះ មិនឃើញបដិសន្ធិ ( នៃសត្វទាំងឡាយ ) បុគ្គលនោះ រមែងកាន់យកឧច្ឆេទទិដ្ឋិ ( ឃើញថាដាច់សូន្យ ) ។ បុគ្គលណា ឃើញត្រឹមតែបដិសន្ធិប៉ុណ្ណោះ មិនឃើញចុតិ ( នៃសត្វទាំង-

ឡាយ ) បុគ្គលនោះ កាន់យកទិដ្ឋិ គឺការប្រកាន់ដឡើងនៃសត្វថ្មីៗ ។ ចំណែក បុគ្គលណា ឃើញទាំងពីរយ៉ាងនោះ បុគ្គលនោះ កន្លងបង់ទិដ្ឋិទាំងពីរយ៉ាងនោះបាន ព្រោះហេតុនោះ ទស្សនៈនោះ របស់បុគ្គលនោះ ឈ្មោះថា ជាហេតុនៃទិដ្ឋិវិសុទ្ធិ ។ ចំណែកព្រះដ៏មានព្រះភាគ បានទតឃើញទាំងពីរយ៉ាងនោះហើយ ព្រោះហេតុនោះ ទើបខ្ញុំពោលពាក្យនេះថា ឈ្មោះថា **បរិសុទ្ធ** ព្រោះភាពជាហេតុនៃទិដ្ឋិវិសុទ្ធិ ដោយឃើញចុតិ និងបដិសន្ធិ ( នៃសត្វទាំងឡាយ ) ដូច្នេះ ។

## ទិព្វចក្ខុរបស់ព្រះមានព្រះភាគប្រាសចាកឧបក្កិលេស

ម្យ៉ាងទៀត ឈ្មោះថា បរិសុទ្ធ ព្រោះវៀរចាកឧបក្កិលេស ( គ្រឿងសៅហ្មងចិត្ត ) ១១ យ៉ាង ។ ពិតហើយ ទិព្វចក្ខុរបស់ព្រះដ៏មានព្រះភាគ វៀរចាកឧបក្កិលេស ១១ យ៉ាងហើយ ។ ដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលអនុរុទ្ធទាំងឡាយ កាលបើតថាគតដឹងច្បាស់ថា វិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវវិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា អមនសិការៈ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវអមនសិការៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្ដីរន្ធត់កាយ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្ដីរន្ធត់កាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្ដីឆ្មើងឆ្មៃ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវ

សេចក្តីធ្មេ្មងធ្មៃ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា នានត្តសញ្ញា ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវនានត្តសញ្ញា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ការសម្លឹងមើលនូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវការសម្លឹងមើលនូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមិនបានប្រហែសធ្វេស ខំព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់នូវពន្លឺ តែមិនបានឃើញរូបទាំង-ឡាយទេ បានឃើញរូបទាំងឡាយ តែមិនបានស្គាល់ច្បាស់នូវពន្លឺទេ របួតអស់មួយយប់ក៏មាន ដូច្នេះជាដើម[១] ។ ញាណចក្ខុនោះ ( របស់ព្រះដ៏មានព្រះភាគ ) ឈ្មោះថា បរិសុទ្ធ ព្រោះវៀរចាកឧបក្កិលេស ( គ្រឿងសៅហ្មង

---

១- បិ. ២៧ ឧបក្កិលេសសូត្រ ។

របស់ចិត្ត ) ១១ យ៉ាង ដូចពណ៌នាមក ដូច្នេះ ។

ឈ្មោះថា **អតិក្កន្តមានុសកំ** ប្រែថា កន្លងបង់នូវចក្ខុរបស់មនុស្ស ព្រោះឃើញរូបកន្លងឧបចារៈនៃមនុស្សទៅ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ឈ្មោះថា **អតិក្កន្តមានុសក** ព្រោះកន្លងបង់មំសចក្ខុរបស់មនុស្សទៅ ។ ដោយទិព្វចក្ខុ ដែលបរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សនោះ ។

ពីរបទថា **សត្តេ បស្សាមិ** សេចក្ដីថា តថាគតរមែងមើល គឺរមែងឃើញ បានដល់ រំពឹងមើលសត្វទាំងឡាយ ( ដោយទិព្វចក្ខុ ) ដូចមនុស្សមើលដោយមំសចក្ខុ ដូច្នោះ ។

ក្នុងពាក្យថា **ចវមានេ ឧប្បជ្ជមានេ** ជាដើមនេះ មានវិនិច្ឆ័យដូច្នេះថា បុគ្គលណាមួយ មិនអាចឃើញសត្វទាំងឡាយបានដោយទិព្វចក្ខុ ក្នុងខណៈចុតិ ឬក្នុងខណៈបដិសន្ធិ តែសត្វពួកណាដែលជិតចំពោះចុតិថា នឹងចុតិឥឡូវនេះ សត្វទាំងនោះ លោកដៅថា កំពុងចុតិ ហើយសត្វពួកណា ដែលបដិសន្ធិហើយ ឬកើតហើយភ្លាមៗ សត្វទាំងនោះ លោកក៏រាប់ថា កំពុងបដិសន្ធិ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងថា តថាគតរមែងឃើញសត្វទាំងនោះ គឺឃើញបែបនោះ ដែលកំពុងចុតិ និងកំពុងបដិសន្ធិ ដូច្នេះ ។

បទថា **ហីនេ** សេចក្ដីថា បុគ្គលត្រូវគេតិះដៀល គឺមើលងាយ មើលថោក ដោយអំណាចជាតិ ត្រកូល និងភោគៈជាដើម ដែលឈ្មោះថា ថោកទាប ព្រោះជាបុគ្គលប្រកបដោយផលវិបាកនៃមោហៈ ។

បទថា **បណីតេ** សេចក្តីថា ផុយគ្នានឹងបុគ្គលអាក្រក់នោះ ព្រោះភាពជាបុគ្គលប្រកបដោយផលវិបាកនៃអមោហៈ ។

បទថា **សុវណ្ណេ** សេចក្តីថា បុគ្គលប្រកបដោយពណ៌សម្បុរដែលគួរប្រាថ្នា គួរស្រឡាញ់ និងគួរពេញចិត្ត ព្រោះជាបុគ្គលប្រកបដោយផលវិបាកនៃអទោសៈ ។

បទថា **ទុព្វណ្ណេ** សេចក្តីថា បុគ្គលប្រកបដោយពណ៌សម្បុរដែលមិនគួរប្រាថ្នា មិនគួរស្រឡាញ់ និងមិនគួរពេញចិត្ត ព្រោះជាបុគ្គលប្រកបដោយផលវិបាកនៃទោសៈ ។ អធិប្បាយថា បុគ្គលមានរូបផុយនឹងបុគ្គលដែលមានរូបស្អាត ដូច្នេះក៏មាន ។

បទថា **សុគតេ** បានដល់ បុគ្គលទៅសុគតិ ។ ម្យ៉ាងទៀត បានដល់ បុគ្គលដែលមាំទាំ គឺមានទ្រព្យច្រើន ដោយភាពជាបុគ្គលប្រកបដោយផលវិបាកនៃអលោភៈ ។

បទថា **ទុគ្គតេ** បានដល់ ទៅកាន់ទុគ្គតិ ម្យ៉ាងទៀត បានដល់ បុគ្គលក្រខ្សត់ មានបាយ និងទឹកតិច ព្រោះជាបុគ្គលប្រកបដោយផលវិបាកនៃលោភៈ ។

បទថា **យថាកម្មូបគេ** បានដល់ បុគ្គលចូលដល់តាមកម្ម ដែលខ្លួនចូលទៅសន្សំទុកហើយ ។

បណ្តាបទទាំងនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់កិច្ចនៃទិព្វចក្ខុ ដោយបទខាងដើមៗ ថា **ចវមានេ** ជាដើម ។ ម្យ៉ាងទៀត កិច្ចនៃយថាកម្មូប-

គញ្ញាណ ( ញាណជាគ្រឿងដឹងសត្វ ដែលចូលដល់តាមកម្ម ) ក៏ជាការត្រាស់ហើយដោយបទនេះ ។

## លំដាប់ការកើតឡើងនៃយថាកម្មូបគញ្ញាណ

ឯលំដាប់ការកើតឡើងនៃញាណនោះ មានដូច្នេះថា ( ភិក្ខុក្នុងសាសនានេះ ) ចម្រើនអាលោកកសិណ បែរមុខចំពោះនរកខាងក្រោមហើយ រមែងឃើញសត្វនរកទាំងឡាយ ដែលសោយទុក្ខយ៉ាងធំ ។ ការឃើញនោះរាប់ថា ជាកិច្ចនៃទិព្វចក្ខុដោយពិត ។ ព្រះយោគីនោះប្រាថ្នាយ៉ាងនេះថា សត្វទាំងនេះ ធ្វើកម្មដូចម្តេចហ្ន៎ ទើបបានសោយទុក្ខយ៉ាងនេះ លំដាប់នោះ ញាណដែលមានកម្មនោះជាអារម្មណ៍ ក៏កើតឡើងដល់ព្រះយោគីនោះថា ព្រោះធ្វើកម្មឈ្មោះនេះ ។ ម្យ៉ាងទៀត ព្រះយោគីនោះ ចម្រើនអាលោកកសិណ បែរមុខចំពោះទេវលោកខាងលើហើយ រមែងឃើញសត្វទាំងឡាយក្នុងសួននន្ទនវ័ន មិស្សកវ័ន និងបារុសកវ័នជាដើម ដែលសោយសម្បត្តិយ៉ាងធំ ការឃើញនោះរាប់ថាជាកិច្ចនៃទិព្វចក្ខុដោយពិត ។ ព្រះយោគីនោះមានបំណងយ៉ាងនេះថា សត្វទាំងនេះធ្វើកម្មដូចម្តេចហ្ន៎ ទើបបានសោយសម្បត្តិយ៉ាងនេះ លំដាប់នោះ ញាណដែលមានកម្មនោះជាអារម្មណ៍ ក៏កើតឡើងដល់លោកថា ព្រោះធ្វើកម្មឈ្មោះនេះ នេះឈ្មោះថា យថាកម្មូបគញ្ញាណ ( ញាណឃើញយថាកម្មរបស់សត្វ ) ។ ឈ្មោះថា ការបរិកម្មមួយផ្នែកនៃយថាកម្មូបគញ្ញាណនេះ ក៏មិនមាន ។ យថាកម្មូបគញ្ញាណនេះ មិនមានការបរិកម្មទុកមួយផ្នែក យ៉ាងណា សូម្បីអនាគតង្សញ្ញាណក៏មិនមានយ៉ាងនោះ ។ ពិតហើយ ញាណទាំង

នេះ ជាបាទនៃទិព្វចក្ខុនោះឯង រមែងសម្រេចព្រមជាមួយទិព្វចក្ខុនោះឯង ។

ក្នុងពាក្យថា **កាយទុច្ចរិតេន** ជាដើម មានវិនិច្ឆ័យដូច្នេះថា ការប្រព្រឹត្តអាក្រក់ ឬការប្រព្រឹត្តវិនាស ព្រោះមានកិលេសជាការវិនាស ព្រោះហេតុនោះ ទើបឈ្មោះថា ទុច្ចរិត ។ ការប្រព្រឹត្តអាក្រក់ផ្លូវកាយ ឬការប្រព្រឹត្តអាក្រក់ដែលកើតអំពីកាយ ព្រោះហេតុនោះ ទើបឈ្មោះថា កាយទុច្ចរិត សូម្បីវចីទុច្ចរិត និងមនោទុច្ចរិត ក៏គួរជ្រាបដូចអធិប្បាយមកនេះ ។

បទថា **សមន្នាគតា** ប្រែថា ជាអ្នកដល់ព្រម ។

## អរិយូបវាទ

ពីរបទថា **អរិយានំ ឧបវាទកា** សេចក្ដីថា សត្វទាំងឡាយ មានការយល់ខុស ជាអ្នកប្រាថ្នានូវសេចក្ដីវិនាស មិនមែនប្រយោជន៍ ពោលប្រទូស្ត អធិប្បាយថា ជេរប្រទេច តិះដៀលព្រះអរិយៈទាំងឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះពុទ្ធ ដោយហោចគ្រហស្ថដែលជាសោតាបន្ន ដោយអន្តិមវត្ថុ ឬដោយការកម្ចាត់បង់នូវគុណ ។

ក្នុងការប្រទូស្ត ២ យ៉ាងនោះ បុគ្គលដែលពោលថា សមណធម៌របស់លោកទាំងនោះមិនមាន លោកទាំងនោះ មិនមែនសមណៈ ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា ពោលប្រទូស្តដោយអន្តិមវត្ថុ ។ បុគ្គលពោលថា ឈានក្ដី វិមោក្ខក្ដី មគ្គក្ដី ផលក្ដី របស់លោកទាំងនោះមិនមាន ដូច្នេះ គប្បីជ្រាបថា ឈ្មោះថា ពោលប្រទូស្តដោយការកម្ចាត់បង់នូវគុណ ។ ឯបុគ្គលនោះ គប្បីពោលប្រទូស្តទាំងដែលដឹងខ្លួន ឬមិនដឹងក៏ដោយ រមែងឈ្មោះថា

ជាអ្នកពោលប្រទូស្តព្រះអរិយៈដោយពិត សូម្បីដោយប្រការទាំងពីរ ។ កម្ម ( គឺការពោលតិះដៀលព្រះអរិយៈ ) ជាកម្មធ្ងន់ ជាសគ្គាវរណៈ ( រាំងសួគ៌ ) និងមគ្គាវរណៈ ( រាំងនូវមគ្គ ) ។

## រឿងភិក្ខុកំលោះតិះដៀលព្រះអរិយៈ

ដើម្បីប្រកាសសេចក្តី ត្រង់ការជេរ ជាកម្មដែលធ្ងន់នោះ ទើបបុរាណាចារ្យទាំងឡាយនាំរឿងនេះមកជាគំរូដូចតទៅនេះ បានឮថា ព្រះថេរៈមួយអង្គ និងភិក្ខុកំលោះមួយអង្គ ត្រាច់ទៅបិណ្ឌបាតក្នុងស្រុកមួយកន្លែង លោកទាំងពីរនោះ បានយាគូក្តៅប្រមាណមួយត្រឡោក ក្នុងផ្ទះទី ១ នោះឯង ។ តែព្រះថេរៈកើតរោគខ្យល់សៀតក្នុងពោះឡើង ទើបគិតថា បបរនេះជារបស់សប្បាយដល់អាត្មាអញៗ នឹងផឹកបបរនោះមុនវាត្រជាក់ ទើបលោកអង្គុយហុតលើកំណាត់ឈើ ដែលពួកមនុស្សអូសមកទុក ដើម្បីធ្វើធរណីទ្វារ ។ ភិក្ខុកំលោះបានរង្កៀសចំពោះព្រះថេរៈនោះ ដោយគិតថា ព្រះព្រះថេរៈកញ្ចាស់អង្គនេះ ឃ្លានហួសហេតុ ធ្វើឲ្យអញបានទទួលនូវការខ្មាស-អៀន ។ ព្រះថេរៈត្រាច់ទៅក្នុងស្រុក ហើយត្រឡប់ទៅកាន់វិហារ បានពោលជាមួយភិក្ខុកំលោះថា អាវុសោ ទីពឹងក្នុងព្រះសាសនានេះរបស់លោកមានឬ ភិក្ខុកំលោះឆ្លើយថា មានលោកម្ចាស់ ព្រោះខ្ញុំជាសោតាបន្ន ។ ព្រះថេរៈដាស់តឿនថា អាវុសោ បើដូច្នោះ លោកមិនអាចធ្វើសេចក្តីព្យាយាមដើម្បីមគ្គខាងលើបានឡើយ ព្រោះព្រះខីណាស្រពលោកបានតិះដៀលហើយ ។ ភិក្ខុកំលោះអង្គនោះ បានសូមខមាទោសហើយ ព្រោះហេតុនោះ កម្មនោះ របស់

ភិក្ខុកំលោះអង្គនោះ ក៏បានត្រឡប់ជាប្រក្រតីដូចដើមហើយ ។

ព្រោះដូច្នោះ បុគ្គលដទៃណា ពោលតិះដៀលព្រះអរិយៈនោះហើយ បើភិក្ខុអ្នកធ្វើខុសចាស់ជាងសោត គប្បីសូមលោកឲ្យអត់ទោសឲ្យ ដោយប្រាប់លោកថា អាវុសោ ខ្ញុំបានពោលពាក្យនេះ និងពាក្យនេះ ជាមួយលោកហើយ សូមលោកអត់ទោសនោះឲ្យដល់ខ្ញុំផងចុះ បើលោកអ្នកធ្វើខុសខ្ចីវស្សាជាងសោត ថ្វាយបង្គំលោក ហើយអង្គុយប្រហោងផ្គងអញ្ជលី គប្បីសុំឲ្យលោកអត់ទោសឲ្យ ដោយប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំបានពោលនូវពាក្យនេះ និងពាក្យនេះ ជាមួយលោកម្ចាស់ហើយ សូមលោកម្ចាស់អត់ទោសនោះឲ្យដល់ខ្ញុំផងចុះ បើលោកមិនព្រមអត់ទោសឲ្យ ឬលោកចៀសចេញទៅកាន់ទិស ( ដទៃ ) គប្បីទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ដែលនៅក្នុងវិហារនោះ បើភិក្ខុអ្នកធ្វើខុសចាស់វស្សាជាងសោត គប្បីឈរសូមខមាទោស បើភិក្ខុអ្នកធ្វើខុសខ្ចីវស្សាជាងខ្លួនសោត គប្បីអង្គុយប្រហោងផ្គងអញ្ជលី ឲ្យលោកជួយអត់ទោសឲ្យ គប្បីប្រាប់លោកឲ្យអត់ទោសយ៉ាងនេះថា បពិត្រលោកម្ចាស់ ខ្ញុំបានពោលពាក្យនេះ និងពាក្យនេះ ដល់លោកដ៏មានអាយុឈ្មោះនោះហើយ សូមលោកមានអាយុអង្គនោះ អត់ទោសឲ្យដល់ខ្ញុំផងចុះ ។ បើព្រះអរិយៈអង្គនោះបរិនិព្វានហើយសោត គួរទៅកាន់ទីកន្លែងគ្រែ ឬតាំងដែលលោកបរិនិព្វាន សូម្បីទៅរហូតដល់ឈាបនដ្ឋានហើយ គប្បីឲ្យអត់ទោស កាលខ្លួនបានធ្វើហើយយ៉ាងនេះ កម្ម គឺការតិះដៀលនោះ ក៏មិនជាសគ្គាវរណៈ ឬ មគ្គាវរណៈ រមែងត្រឡប់ជាប្រក្រតីដូចដើមនោះឯង ។

បទថា **មិច្ឆាទិដ្ឋិកា** ប្រែថា មានការឃើញវិបរិត ។

បទថា **មិច្ឆាទិដ្ឋិកម្មសមាទានា** សេចក្តីថា បុគ្គលពួកណា ឲ្យជនដទៃសមាទាន បណ្តាកម្ម មានកាយកម្មជាដើម ដែលមានមិច្ឆាទិដ្ឋិជាមូល បុគ្គលទាំងនោះ ឈ្មោះថា មានកម្មច្រើនប្រភេទដែលខ្លួនសមាទានយកហើយ ដោយអំណាចមិច្ឆាទិដ្ឋិ ។ បណ្តាអរិយុបវាទ និងមិច្ឆាទិដ្ឋិទាំងនោះ លោកសង្គ្រោះអរិយុបវាទចូលក្នុងវចីទុច្ចរិតសព្ទនោះឯង និងមិច្ឆាទិដ្ឋិចូលក្នុងមនោ-ទុច្ចរិតសព្ទដូចគ្នា ហើយពោលដល់កម្មទាំងពីរនេះដដែលទៀត គប្បីជ្រាបថា មានការសម្តែងដល់កម្មទាំងពីរនោះ មានទោសច្រើនជាប្រយោជន៍ ។ ពិតហើយ អរិយុបវាទ មានទោសច្រើនដូចគ្នានឹងអនន្តរិយកម្ម ។ ដូចព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្រ ភិក្ខុបរិបូណ៌ដោយសីលហើយ បរិបូណ៌ដោយសមាធិហើយ បរិបូណ៌ដោយបញ្ញាហើយ រមែងសម្រេចនូវអរហត្តផលក្នុងបច្ចុប្បន្ននេះឯង យ៉ាងណាមិញ ម្នាលសារីបុត្រ តថាគតពោលនូវហេតុ ( នៃការមិនលះបង់នូវវាចាជាដើមរបស់បុគ្គលនោះ ) ថា មានឧបមេយ្យប្រហែលគ្នាយ៉ាងនោះដែរ ។ បុគ្គលនោះ បើមិនលះបង់នូវវាចានោះទេ មិនលះបង់នូវចិត្តនោះទេ មិនលះបង់នូវទិដ្ឋិនោះទេ នឹងធ្លាក់ទៅរងទុក្ខក្នុងនរកដូចគេនាំយកទៅទម្លាក់ យ៉ាងនោះឯង[១] ។ ឯកម្មដទៃ ឈ្មោះថា មានទោសច្រើនជាងមិច្ឆាទិដ្ឋិ រមែងមិនមាន ដូចព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌ ១ ដែលមាន

---

១- បិ. ២០ មហាសីហនាទសូត្រ ។

ទោសធំយ៉ាងនេះ ដូចមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ ទោសទាំងឡាយ មានតែមិច្ឆាទិដ្ឋិ ជាទោសក្រៃលែង ដូច្នេះ[១] ។

ពីរបទថា **កាយស្ស ភេទា** សេចក្ដីថា ព្រោះលះបង់ឧបាទិន្នកក្ខន្ធចេញ ( ខន្ធដែលមានកិលេសចូលទៅប្រកាន់ ) ។

បទថា **បរម្មរណា** សេចក្ដីថា តែការកាន់យកខន្ធដែលកើតឡើងក្នុងលំដាប់នៃការលះបង់នោះ ។ ម្យ៉ាងទៀត ពីរបទថា **កាយស្ស ភេទា** គឺព្រោះការដាច់សូន្យនៃជីវិតិន្ទ្រិយ ។ បទថា **បរម្មរណា** គឺបន្ដអំពីចុតិចិត្ត ។

## អធិប្បាយពាក្យថា នរក ឈ្មោះថា អបាយជាដើម

ពាក្យទាំងឡាយយ៉ាងនេះជាដើមថា **អបាយំ** ជាវេវចនៈនៃពាក្យថា **និរយ** ។ ពិតហើយ **និរយ** ឈ្មោះថា **អបាយ** ព្រោះទៅប្រាសចាកសេចក្ដីចម្រើន ដែលសន្មតថា ជាបុណ្យ ដែលជាហេតុនៃស្ថានសួគ៌ និងនិព្វាន ឬព្រោះមិនមានសេចក្ដីចម្រើនឡើងនៃសេចក្ដីសុខ ។

ដែលឈ្មោះថា **ទុគ្គតិ** ព្រោះអត្ថថា មានគតិនៃទុក្ខជាទីពឹង ។ ម្យ៉ាងទៀត ឈ្មោះថា **ទុគ្គតិ** ព្រោះអត្ថថា មានគតិកើតព្រោះកម្មអាក្រក់ ព្រោះមានទោសច្រើន ។

ដែលឈ្មោះថា **វិនិបាត** ព្រោះអត្ថថា ជាទីដែលពួកសត្វ ដែលចូលចិត្តធ្វើអាក្រក់ ធ្លាក់ទៅ គ្មានអំណាច ។ ម្យ៉ាងទៀត ឈ្មោះថា **វិនិបាត** ព្រោះអត្ថថា ជាទីដែលពួកសត្វកំពុងវិនាស មានអវយវៈតូចធំបែកខ្ចាត់ខ្ចាយ

---

១- បិ. ៤០ អបរាឯកធម្មាទិបាលីដទៃទៀត វគ្គទី ៣ ។

ធ្លាក់ទៅ ។

ដែលឈ្មោះថា **និរយ** ព្រោះអត្ថថា ជាទីកន្លែងមិនមានសេចក្ដីចម្រើន ដែលសន្មតថា សេចក្ដីត្រេកអរ ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគទ្រង់សម្ដែងកំណើតសត្វតិរច្ឆាន ដោយ **អបាយ** សព្ទ ។ ពិតហើយ កំណើតសត្វតិរច្ឆាន រាប់ថា ជាអបាយ ព្រោះប្រាសចាកសុគតិ តែមិនរាប់ជាទុគ្គតិ ព្រោះជាទីកើតនៃសត្វទាំងឡាយ មានស្ដេចនាគជាដើម ដែលមានសក្ដាច្រើន ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងបេតវិស័យ ដោយ **ទុគ្គតិ** សព្ទ ។ ពិតហើយ បេតវិស័យនោះ រាប់ថា ជាអបាយផង ជាទុគ្គតិផង ព្រោះប្រាសទៅអំពីសុគតិ និងព្រោះជាគតិនៃទុក្ខ តែមិនមែនជាវិនិបាត ព្រោះមិនមានការធ្លាក់ទៅ ដូចគ្នានឹងពួកអសុរ ។ ពិតហើយ សួម្បីវិមានទាំងឡាយ រមែងកើតឡើងដល់ពួកប្រេតដែលមានឫទ្ធិច្រើន ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងអសុរកាយ ដោយ **វិនិបាត** សព្ទ ។ សេចក្ដីពិត អសុរកាយនោះ លោកហៅថា ជាអបាយផង ជាទុគ្គតិផង ព្រោះអត្ថតាមដែលពោលមកហើយ ថាជាវិនិបាត ព្រោះជាបុគ្គលមានការធ្លាក់ទៅអំពីការកើតឡើងនៃសម្បត្តិទាំងពួង ។ ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងនិរយៈនោះឯង ដែលមានច្រើនប្រភេទ មានអវីចីជាដើម ដោយ **និរយ** សព្ទ ។

បទថា **ឧបបន្នា** ប្រែថា ចូលដល់ហើយ អធិប្បាយថា កើតឡើងហើយក្នុងនរកនោះ សុក្កបក្ខ ( ចំណែក ស ) គប្បីជ្រាបដោយបរិយាយដែលផ្ទុយគ្នាក្នុងពាក្យដែលពោលហើយ ។ ចំណែកការប្លែកគ្នាមានដូច្នេះថា

សុម្បីគតិនៃមនុស្ស លោកក៏សង្គ្រោះដោយ **សុគតិ** សព្ទ ក្នុងសុក្កបក្ខនេះ ។ ទេវគតិប៉ុណ្ណោះ លោកសង្គ្រោះចូលដោយ **សគ្គ** សព្ទ ។

ក្នុងបទថា គឺ **សុគតឹ សគ្គំ លោកំ** នោះ មានអត្ថចំពោះពាក្យដូច្នេះថា ឈ្មោះថា **សុគតិ** ព្រោះអត្ថថា ជាគតិល្អ ។ ឈ្មោះថា **សគ្គ** ព្រោះអត្ថថា ល្អលើសដោយអារម្មណ៍ទាំងឡាយ មានរូបជាដើម ។ **សុគតិ** និង **សគ្គ** ទាំងអស់នោះ ឈ្មោះថា **លោក** ព្រោះអត្ថថា វិនាស និងបែកធ្លាយទៅ ។

វិជ្ជា គឺទិព្វចក្ខុញ្ញាណ ឈ្មោះថា **វិជ្ជា** ។ អវិជ្ជាជាគ្រឿងបិទបាំងចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ឈ្មោះថា **អវិជ្ជា** ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ទិព្វចក្ខុកថា ចប់

## អាសវក្ខយញ្ញាណកថា

ពិតហើយ ក្នុងទិព្វចក្ខុញ្ញាណកថានេះ មានការប្លែកគ្នាដូច្នេះថា ក្នុងបុព្វេនិវាសកថា ខ្ញុំពោលទុកហើយថា ព្រោះទម្លាយសម្បកពង គឺអវិជ្ជាដែលបិទបាំងខន្ធ ដែលខ្លួនធ្លាប់អាស្រ័យនៅហើយ ក្នុងកាលមុន ដោយចំពុះ គឺបុព្វេនិវាសានុស្សតិញ្ញាណ ដូច្នេះ យ៉ាងណា ក្នុងទិព្វចក្ខុញ្ញាណកថានេះ ក៏គួរពោលថា ព្រោះទម្លាយសម្បកពង គឺអវិជ្ជាដែលបិទបាំងនូវចុតិ និងបដិសន្ធិ ( របស់សត្វទាំងឡាយ ) ដោយចំពុះ គឺចុតូបបាតញ្ញាណ ដូច្នេះក៏យ៉ាងនោះ ។

ក្នុងពាក្យថា **សោ ឯវំ សមាហិតេ ចិត្តេ** នេះ គួរជ្រាបចិត្តក្នុងចតុត្ថជ្ឈានដែលជាបាទនៃវិបស្សនា ( តទៅ ) ។

ពីរបទថា **អាសវានំ ខយញ្ញាណាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់អរហត្តមគ្គញ្ញាណ ។ ពិតហើយ អរហត្តមគ្គ លោកហៅថា ធម៌ជាទីអស់ទៅនៃអាសវៈទាំងឡាយ ព្រោះធ្វើអាសវៈឲ្យវិនាសទៅ ។ ឯញាណនេះក្នុងអរហត្តមគ្គនោះ លោកហៅថា ធម៌ជាទីអស់ទៅនៃអាសវៈទាំងឡាយ ព្រោះញាណនោះ ជាធម៌ដែលទាក់ទងហើយក្នុងមគ្គនោះ ដោយប្រការដូច្នេះ ។

ពីរបទថា **ចិត្តំ អភិនិន្នាមេសឹ** សេចក្តីថា តថាគតបានបង្អោនវិបស្សនាចិត្តទៅចំពោះហើយ ។ ក្នុងពាក្យយ៉ាងនេះជាដើមថា **សោ ឥទំ ទុក្ខំ** គប្បីជ្រាបអត្ថយ៉ាងនេះថា តថាគតបានដឹង គឺជ្រាប បានដល់ ចាក់ធ្លុះហើយ នូវទុក្ខសច្ចទាំងអស់តាមការពិត ដោយការចាក់ធ្លុះលក្ខណៈ តាមពិតថា ទុក្ខមានប្រមាណប៉ុណ្ណេះ មិនមានទុក្ខដទៃក្រៃលែងជាងនេះ ព្រោះតថាគតបាន

ដឹង គឺជ្រាប បានដល់ ចាក់ធ្លុះហើយ នូវតណ្ហាដែលញ៉ាំងទុក្ខនោះឲ្យកើតតាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈតាមពិតថា នេះទុក្ខសមុទយៈ ស្ថិតិទុក្ខ និងតណ្ហាទាំងនោះ ទៅដល់ទីណា រមែងរលត់ទៅ តថាគតក៏បានដឹង គឺ បានជ្រាប បានដល់ ចាក់ធ្លុះហើយនូវស្ថាននោះ គឺ ព្រះនិព្វាន ដែលប្រព្រឹត្តទៅមិនបាននៃទុក្ខ និងតណ្ហានោះ តាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈពិតថា នេះទុក្ខនិរោធ ហើយតថាគតក៏បានដឹង គឺបានជ្រាប បានដល់ ចាក់ធ្លុះហើយ នូវអរិយមគ្គ ដែលជាហេតុឲ្យសម្រេចទុក្ខនិរោធនោះ តាមសេចក្ដីពិត ដោយការចាក់ធ្លុះលក្ខណៈតាមសេចក្ដីពិតថា នេះទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងសច្ចៈទាំងឡាយ ដោយសរុបយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងដោយអំណាចកិលេស ដោយបរិយាយ ទើបត្រាស់ពាក្យជាដើមថា **ឥមេ អាសវា** ដូច្នេះ ។

បទជាច្រើនថា **តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ** សេចក្ដីថា កាលតថាគតនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ។ ព្រះដ៏មានព្រះភាគបានត្រាស់មគ្គដែលដល់នូវទីបំផុត ព្រមជាមួយវិបស្សនាទុក ( ក្នុងបទទាំងនេះ ) ។

បទថា **កាមាសវា** ប្រែថា ចាកកាមាសវៈ ទ្រង់សម្ដែងខណៈនៃផលទុកដោយពាក្យថា រួចផុតហើយនេះ ពិតហើយ ចិត្តរមែងរួចផុត ក្នុងខណៈនៃមគ្គ ក្នុងខណៈនៃផល រាប់ថា រួចផុតហើយ ទ្រង់សម្ដែងបច្ចវេក្ខណញ្ញាណទុកដោយពាក្យនេះថា កាលចិត្តរួចផុតហើយ ក៏មានញាណដឹងថា រួចផុត

ហើយ ដូច្នេះ ទ្រង់សម្តែងភូមិនៃបច្ចវេក្ខណញ្ញាណនោះទុក ដោយពាក្យជាដើមថា ជាតិអស់ហើយ ពិតហើយ ព្រះដ៏មានព្រះភាគ កាលទ្រង់ពិចារណាដោយព្រះញាណនោះ ទ្រង់ក៏បានដឹងហើយនូវទុក្ខសច្ចជាដើមថា ជាតិអស់ហើយ ។

សួរថា ជាតិណារបស់ព្រះដ៏មានព្រះភាគ ឈ្មោះថា អស់ហើយ ហើយព្រះដ៏មានព្រះភាគទ្រង់ដឹងជាតិនោះ បានដូចម្តេច ខ្ញុំនឹងពោលឆ្លើយថា ជាតិដែលជាអតីតរបស់ព្រះអង្គ ឈ្មោះថា មិនទាន់អស់ទៅមុន ( ដោយមគ្គភាវនា ) ព្រោះជាតិនោះអស់ទៅហើយក្នុងកាលមុន ជាតិដែលជាអនាគតរបស់ព្រះអង្គ ឈ្មោះថា មិនទាន់អស់ទៅ ព្រោះមិនមានសេចក្តីព្យាយាមក្នុងអនាគត ជាតិដែលជាបច្ចុប្បន្នរបស់ព្រះអង្គ ឈ្មោះថា មិនទាន់អស់ទៅ ព្រោះជាតិនៅមាន ។ ចំណែកជាតិណា ដែលផ្សេងដោយប្រភេទ គឺខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ដែលគប្បីកើតឡើងក្នុងឯកវោការភព ចតុវោការភព និងបញ្ចវោការភព ព្រោះមិនទាន់បានអប់រំមគ្គ ជាតិនោះរាប់ថា អស់ទៅហើយ ព្រោះដល់នូវការមិនកើតឡើងជាធម្មតា ព្រោះមានមគ្គបានអប់រំហើយ ព្រះដ៏មានព្រះភាគអង្គនោះ កាលទ្រង់ពិចារណាដល់កិលេសដែលព្រះអង្គ ទ្រង់លះដោយមគ្គភាវនាហើយ ទ្រង់ជ្រាបថា កាលមិនមានកិលេស កម្ម សូម្បីនៅមាន ក៏មិនមានបដិសន្ធិតទៅ ទើបឈ្មោះថា ទ្រង់បានដឹងជាតិនោះហើយ។

បទថា **វុសិតំ** សេចក្តីថា ( ព្រហ្មចរិយៈ ) ដែលតថាគតនៅហើយ គឺនៅចប់ហើយ អធិប្បាយថា ដែលតថាគតធ្វើ ប្រព្រឹត្ត ឲ្យស្រេចអស់ហើយ ។

បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ។ ពិតហើយ ព្រះសេក្ខ-បុគ្គល ៧ ពួក រួមទាំងកល្យាណបុថុជ្ជន ឈ្មោះថា រមែងនៅអប់រំព្រហ្ម-ចរិយៈ ។ ព្រះខីណាស្រព មានព្រហ្មចរិយៈនៅចប់ហើយ ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ពិចារណាដល់ព្រហ្មចរិយវាសរបស់ព្រះអង្គ ក៏ទ្រង់បានដឹងហើយថា ព្រហ្មចរិយៈ តថាគតនៅចប់ហើយ ។

ពីរបទថា **កតំ ករណីយំ** សេចក្តីថា កិច្ច ១៦ តថាគតឲ្យចប់ហើយ ដោយអំណាចនៃការកំណត់ដឹង ការលះ ការធ្វើឲ្យជាក់ច្បាស់ និងការអប់រំឲ្យច្រើន ដោយមគ្គ ៤ ក្នុងសច្ចៈទាំង ៤ ។ ពិតហើយ សេក្ខបុគ្គល ៧ ពួក មានកល្យាណបុថុជ្ជនជាដើម កំពុងធ្វើកិច្ចនោះ ។ ព្រះខីណាស្រពមានកិច្ចដែលគួរធ្វើសម្រេចហើយ ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ពិចារណាដល់កិច្ចដែលគួរធ្វើរបស់ព្រះអង្គ ទ្រង់ក៏បានជ្រាបថា កិច្ចដែលគួរធ្វើ តថាគតធ្វើសម្រេចហើយ ។

បទជាច្រើនថា **នាបរំ ឥត្ថត្តាយ** សេចក្តីថា ព្រះដ៏មានព្រះភាគ ទ្រង់បានដឹងហើយថា ឥឡូវនេះ កិច្ច គឺការអប់រំដោយមគ្គ ដើម្បីភាពយ៉ាងនេះទៀត គឺដើម្បីការចម្រើននៃសោឡសកិច្ច ឬដើម្បីការអស់ទៅនៃកិលេសយ៉ាងនេះរបស់តថាគត រមែងមិនមាន ។

ឥឡូវនេះ កាលទ្រង់សម្តែងការសម្រេចញាណ ដែលជាហេតុអស់ទៅនៃអាសវៈទាំងឡាយនោះ ដែលបច្ចវេក្ខណញ្ញាណផ្គងហើយយ៉ាងនោះដល់ព្រាហ្មណ៍ ទើបត្រាស់ថា **អយំ ខោ មេ ព្រាហ្មណ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ ការដឹងដែលសម្បយុត្តដោយអរហត្តមគ្គញ្ញាណ ឈ្មោះថា វិជ្ជា ការមិនដឹងដែលបិទបាំងសច្ចៈ ៤ ឈ្មោះថា អវិជ្ជា ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

ចំណែកការប្រែកគ្នា មានដូចតទៅនេះ ក្នុងពាក្យថា **អយំ ខោ មេ ព្រាហ្មណ តតិយា អភិនិព្ភិទា អហោសិ** នេះ អធិប្បាយថា ម្នាលព្រាហ្មណ៍ ការញាស់លើកទី ៣ គឺការចេញលើកទី ៣ បានដល់ ការកើតជាអរិយៈលើកទី ៣ នេះឯង មានហើយដល់តថាគត ព្រោះបានទម្លាយសម្បកពង គឺអវិជ្ជាដែលបិទបាំងសច្ចៈ ៤ ដោយចុងចំពុះ គឺអាសវក្ខយញ្ញាណ ដូចការញាស់ចេញ គឺការចេញទៅ បានដល់ ការកើតនៃពួកកូនមាន់អំពីសម្បកនោះ ក្នុងកាលខាងក្រោយ ព្រោះបានទម្លាយសម្បកពងដោយចុងចំពុះ ឬដោយចុងក្រចក ដូច្នោះ ។

សួរថា ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងព្រះបំណងអ្វីទុក ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ឆ្លើយថា ទ្រង់សម្តែងព្រះបំណងទុកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ ឯកូនមាន់នោះ បានទម្លាយសម្បកពងហើយ ចេញទៅអំពីសម្បកនោះ រមែងឈ្មោះថា កើតម្តងប៉ុណ្ណោះ ចំណែកតថាគតបានទម្លាយសម្បកពង គឺអវិជ្ជាដែលបិទបាំងខន្ធ ដែលតថាគតធ្លាប់អាស្រ័យនៅក្នុងកាលមុនហើយ ឈ្មោះថា កើតហើយលើកទី ១ ព្រោះវិជ្ជា គឺបុព្វេ-និវាសានុស្សតិញ្ញាណ បន្ទាប់អំពីនោះ បានទម្លាយសម្បកពង គឺអវិជ្ជាដែលបិទបាំងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ឈ្មោះថា កើតហើយលើកទី

២ ព្រោះអវិជ្ជា គឺទិព្វចក្ខុញ្ញាណ បន្ទាប់មកទៀត បានទម្លាយសម្បកពង គឺអវិជ្ជាដែលបិទបាំងសច្ចៈ ៤ ឈ្មោះថា កើតហើយលើកទី ៣ ព្រោះអវិជ្ជា គឺអាសវក្ខយញ្ញាណ តថាគតជាបុគ្គលឈ្មោះថា កើតហើយ ៣ ដង ព្រោះវិជ្ជាទាំង ៣ ដូចពណ៌នាមកដូច្នេះ ទើបជាតិរបស់តថាគតនោះ ជាអរិយៈ គឺរុងរឿងបរិសុទ្ធ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងយ៉ាងនេះ ទ្រង់ប្រកាសអតីតង្សញ្ញាណ ដោយបុព្វេនិវាសញ្ញាណ បច្ចុប្បន្នំសញ្ញាណ និងអនាគតង្សញ្ញាណ ដោយទិព្វចក្ខុ ព្រះគុណដែលជាលោកិយ និងលោកុត្តរទាំងអស់ ដោយអាសវក្ខយញ្ញាណ កាលទ្រង់ប្រកាសគុណ គឺព្រះសព្វញ្ញូទាំងអស់ ដោយវិជ្ជា ៣ ដូចពោលមកហើយ ទើបទ្រង់សម្ដែងភាពដែលព្រះអង្គជាបុគ្គលចម្រើន និងប្រសើរបំផុត ដោយអរិយជាតិដល់ព្រាហ្មណ៍ ដោយប្រការដូច្នេះ ។

អាសវក្ខយញ្ញាណកថា ចប់

# វេរញ្ជព្រាហ្មណ៍មានសតិដឹងខ្លួនមកវិញ

[ ៤ ] ក្នុងពាក្យថា **ឯវំ វុត្តេ វេរញ្ជោ ព្រាហ្មណោ** អធិប្បាយថា កាលព្រះដ៏មានព្រះភាគ ទ្រង់អនុគ្រោះដល់លោក និងទ្រង់អនុគ្រោះព្រាហ្មណ៍ បានត្រាស់ភាពដែលព្រះអង្គជាបុគ្គលចម្រើន និងប្រសើរបំផុត ដោយអរិយជាតិសូម្បីដែលគួរបិទបាំង ដោយធម្មទេសនា ដែលប្រកាសវិជ្ជា ៣ ដោយន័យដូចពោលមកយ៉ាងនេះ វេរញ្ជព្រាហ្មណ៍ មានកាយ និងចិត្តពេញបរិបូណ៌ ដោយការផ្សាយទៅនៃបីតិ ដឹងសភាពដែលព្រះដ៏មានព្រះភាគ ជាបុគ្គលចម្រើន និងប្រសើរបំផុត ដោយអរិយជាតិនោះ ទើបត្រិះរិះខ្លួនឯងថា អញបានពោលនឹងព្រះសព្វញ្ញូ ដែលប្រសើរលើសលោកទាំងអស់ ទ្រង់ប្រកបដោយព្រះគុណទាំងពួង មានសភាពដូច្នេះថា ទ្រង់មិនធ្វើកម្ម មានការថ្វាយបង្គំជាដើមដល់ជនដទៃ ឱ គួរតិះដៀលការមិនដឹងពិតហ្ន៎ ដូច្នេះ ទើបសន្និដ្ឋានគិតថា ឥឡូវនេះ ព្រះដ៏មានព្រះភាគអង្គនេះ ឈ្មោះថា ជាបុគ្គលចម្រើនបំផុតក្នុងលោក ព្រោះអត្ថថា ជាអ្នកកើតមុនដោយអរិយជាតិ ឈ្មោះថា ជាបុគ្គលប្រសើរបំផុត ព្រោះអត្ថថា មិនមានបុគ្គលស្មើដោយព្រះគុណទាំងពួង ហើយបានក្រាបទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា ព្រះគោតមជាបុគ្គលចម្រើនបំផុត ព្រះគោតមជាបុគ្គលប្រសើរបំផុត កាលក្រាបទូលយ៉ាងនោះហើយ កាលនឹងសរសើរព្រះធម្មទេសនា របស់ព្រះដ៏មានព្រះភាគនោះទៀត ទើបក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះតម្រាស់របស់ព្រះអង្គពីរោះពន់ពេកណាស់ ដូច្នេះជាដើម ។

## អត្ថនៃអភិក្កន្តសព្ទ មានអត្ថ ៤ និង ៩ យ៉ាង

ក្នុងពាក្យថា **អភិក្កន្តំ** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា **អភិក្កន្ត** សព្ទនេះ រមែងប្រាកដក្នុងអត្ថ គឺ **ខយៈ** ( ការអស់ទៅ ) ១ **សុន្ទរ** ( សេចក្តីល្អ ) ១ **អភិរូប** ( រូបល្អ ) ១ **អព្ភនុមោទន** ( ការសរសើរ ) ១ ។

ពិតហើយ **អភិក្កន្ត** សព្ទ ប្រាកដក្នុងការអស់ទៅ ដូចក្នុងប្រយោគទាំង-ឡាយជាដើមថា **អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ** បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីអស់ហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ ។

**អភិក្កន្ត** សព្ទ ប្រាកដក្នុងសេចក្តីល្អ ដូចក្នុងប្រយោគទាំងឡាយជាដើមថា **អយំ មេ បុគ្គលោ ខមតិ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច** បណ្តាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះល្អជាងផង ប្រសើរជាងផង រមែងគាប់ចិត្តដល់ខ្ញុំព្រះអង្គ ។

**អភិក្កន្ត** សព្ទ ប្រាកដក្នុងរូបល្អ ដូចក្នុងប្រយោគទាំងឡាយជាដើមថា

**កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ**
**អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា ។**

អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ ដោយយស មានសម្បុរដ៏ល្អ ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត[១] ។

**អភិក្កន្ត** សព្ទ ប្រាកដក្នុងសេចក្តីសរសើរ ដូចក្នុងប្រយោគទាំងឡាយជាដើមថា **អភិក្កន្តំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ( ភាសិតព្រះអង្គ )

---

១- បិ. ៥៥ មណ្ឌូកទេវបុត្តវិមាន ។

ពីរោះពេកណាស់ ។

ក្នុងអធិការនេះ **អភិក្កន្ត** សព្ទ ប្រាកដក្នុងការសរសើរនោះឯង គប្បីជ្រាបសន្និដ្ឋានថា ព្រោះ **អភិក្កន្ត** សព្ទ ប្រាកដក្នុងការសរសើរ ដូច្នោះទើបវេរញ្ជព្រាហ្មណ៍ពោលអធិប្បាយទុកថា សាធុ ព្រះគោតមដ៏ចម្រើន ។

ក្នុងអធិការនេះ **អភិក្កន្ត** សព្ទនេះ គប្បីជ្រាបថា លោកពោលទុកពីរដង ដោយអំណាចនៃការជ្រះថ្លា និងដោយអំណាចនៃការសរសើរ ដោយលក្ខណៈនេះថា បណ្ឌិតជាអ្នកដឹង គប្បីធ្វើការពោល ម្ដងហើយម្ដងទៀតទុក ( ក្នុងអត្ថ ៩ យ៉ាង ) គឺក្នុងភយៈ ក្នុងកោធៈ ក្នុងបសំសា ( ការសរសើរ ) ក្នុងតុរិតៈ ( ការប្រញាប់ប្រញាល់ ) ក្នុងកោតុហលៈ ( ការភ្ញាក់ផ្អើល ) ក្នុងអច្ឆរៈ ( ការអស្ចារ្យ ) ក្នុងហាសៈ ( ការសប្បាយ ) ក្នុងសោកៈ និងក្នុងបសាទៈ ( ការជ្រះថ្លា ) ។

ម្យ៉ាងទៀត បទថា **អភិក្កន្តំ** ប្រែថា គួរស្រឡាញ់ពន់ពេក គួរប្រាថ្នាពន់ពេក គួរពេញចិត្តពន់ពេក អធិប្បាយថា រុងរឿងពន់ពេក ។

បណ្ដា **អភិក្កន្ត** សព្ទ ២ យ៉ាងនោះ វេរញ្ជព្រាហ្មណ៍ រមែងសរសើរទេសនា ដោយ **អភិក្កន្ត** សព្ទ ១ រមែងសរសើរការជ្រះថ្លារបស់ខ្លួន ដោយ **អភិក្កន្ត** សព្ទ ១ ។ ពិតហើយ ក្នុងការសរសើរនេះ មានអធិប្បាយដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះធម្មទេសនារបស់ព្រះអង្គ គួរសរសើរពន់-ពេក ការជ្រះថ្លារបស់ខ្ញុំព្រះអង្គ អាស្រ័យធម្មទេសនារបស់ព្រះអង្គ ល្អពន់-ពេក ។ វេរញ្ជព្រាហ្មណ៍ សរសើរបាវចនារបស់ព្រះដ៏មានព្រះភាគនោះឯង

មានបំណងជា ២ យ៉ាង ។

## ចាវចនៈមានលម្អ ១៨ យ៉ាង

បណ្ឌិតគប្បីប្រកបបាវចនៈ ដោយហេតុទាំងឡាយ យ៉ាងនេះជាដើមថា ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន ឈ្មោះថា ល្អពន់ពេក ព្រោះញុំាងទោសៈឲ្យវិនាស ១ ឈ្មោះថា ល្អពន់ពេក ព្រោះឲ្យសម្រេចគុណ ១ ម្យ៉ាងទៀត ព្រោះឲ្យកើតសទ្ធា ១ ព្រោះឲ្យកើតបញ្ញា ១ ព្រោះប្រព្រឹត្តទៅព្រមដោយអត្ថ ១ ព្រោះប្រព្រឹត្តទៅព្រមដោយព្យញ្ជនៈ ១ ព្រោះមានបទរាក់ ១ ព្រោះមានអត្ថជ្រាលជ្រៅ ១ ព្រោះពីរោះត្រចៀក ១ ព្រោះចូលដល់ហទយៈ ១ ព្រោះមិនលើកខ្លួនឡើងអួតអាង ១ ព្រោះមិនសង្កត់សង្កិនអ្នកដទៃ ១ ព្រោះត្រជាក់ដោយព្រះករុណា ១ ព្រោះទ្រង់ត្រាស់ដោយបញ្ញា ១ ព្រោះជាទីរីករាយនៃគន្លង ១ ព្រោះអត់ធន់ចំពោះការញាំញីបានយ៉ាងវិសេស ១ ព្រោះកំពុងស្តាប់ក៏ជាសុខ ១ ព្រោះកំពុងពិចារណាក៏មានប្រយោជន៍ ១ ដូច្នេះ ។

បន្ទាប់អំពីនោះទៅ វេរញ្ជព្រាហ្មណ៍ រមែងសរសើរទេសនានោះឯង ដោយឧបមា ៤ ប្រការ ។

បណ្តាបទទាំងនោះ បទថា **និក្កុជ្ជិតំ** គឺកាជនៈដែលគេផ្កាប់មាត់ទុក ឬមានមាត់នៅខាងក្រោម ។ បទថា **ឧក្កុជ្ជេយ្យ** គឺគប្បីផ្ងារមាត់ឡើង ។ បទថា **បដិច្ឆន្នំ** គឺដែលគេបិទទុកដោយវត្ថុ មានស្មៅ និងស្លឹកឈើជាដើម ។ បទថា **វិវរេយ្យ** គឺគប្បីបើកឡើង ។ បទថា **មូឡ្ហស្ស** គឺបុគ្គលវង្វេងទិស ។

ពីរបទថា **មគ្គំ អាចិក្ខេយ្យ** សេចក្តីថា គប្បីចាប់ត្រង់ដៃ ហើយប្រាប់ថា នេះផ្លូវ ។ បទថា **អន្ធការេ** សេចក្តីថា ក្នុងកាពងងឹតមានអង្គ ៤ ( គឺ ) ព្រោះថ្ងៃ ១៤ រោចក្នុងកាឡបក្ខ ១ កណ្តាលយប់ ១ ព្រៃដែលក្រាស់ ១ ដុំពពក ១ ។ អត្ថនៃបទដែលមិនទាន់ក្លីច្បាស់ មានប៉ុណ្ណេះសិន ។

ចំណែកការប្រកបសេចក្តីអធិប្បាយមានដូច្នេះថា ( វេរញ្ជព្រាហ្មណ៍សរសើរព្រះដ៏មានព្រះភាគថា ) ព្រះគោតមដ៏ចម្រើន ទ្រង់ញ៉ាំងខ្ញុំដែលជាអ្នកបែរមុខចេញអំពីព្រះសទ្ធម្ម ធ្លាក់ទៅក្នុងអសទ្ធម្មហើយ ឲ្យចេញអំពីអសទ្ធម្ម ដូចបុគ្គលផ្ងារភាជនៈដែលផ្កាប់ ដូច្នោះ ទ្រង់បើកផ្ងារព្រះសាសនាដែលត្រូវព្រៃស្តុក គឺមិច្ឆាទិដ្ឋិបិទបាំង ចាប់ផ្តើមអំពីព្រះសាសនារបស់ព្រះកស្សបទសពលអន្តរធានទៅ ដូចបុគ្គលបើករបស់ដែលបិទទុកចេញ ដូច្នោះ ទ្រង់ប្រាប់ផ្លូវសួគ៌ និងនិព្វានឲ្យដល់ខ្ញុំ ដែលដើរទៅកាន់ផ្លូវអាក្រក់ និងផ្លូវខុស ដូចបុគ្គលប្រាប់ផ្លូវឲ្យដល់អ្នកវង្វេងផ្លូវ ដូច្នោះ ទ្រង់បញ្ចេញពន្លឺ គឺទេសនាដែលជាគ្រឿងកម្ចាត់ងងឹត គឺមោហៈដែលបិទបាំងរូប គឺព្រះរតនត្រ័យមានពុទ្ធរតនៈជាដើមនោះដល់ខ្ញុំ ដែលកំពុងលិចក្នុងងងឹត គឺមោហៈ ដែលមិនឃើញរូប គឺរតនត្រ័យ មានពុទ្ធរតនៈជាដើម ដូចបុគ្គលទ្រោលប្រទីបប្រេងក្នុងទីងងឹតបំភ្លឺឲ្យ ដូច្នោះ ទ្រង់បានប្រកាសព្រះធម៌ដល់ខ្ញុំដោយអនេកបរិយាយ ព្រោះទ្រង់ប្រកាសដោយបរិយាយទាំងឡាយនេះ ។

វេរញ្ជព្រាហ្មណ៍ កាលសរសើរព្រះធម្មទេសនាយ៉ាងនេះហើយ មានចិត្តជ្រះថ្លាក្នុងព្រះរតនត្រ័យ ព្រោះព្រះធម្មទេសនានេះ កាលនឹងធ្វើអាការ

ដែលបុគ្គលមានសទ្ធាគប្បីធ្វើ ទើបក្រាបទូលថា **ឯសាហំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯសាហំ** កាត់បទជា **ឯសោ អហំ** ប្រែថា ខ្ញុំព្រះអង្គនេះ ។

បទជាច្រើនថា **ភវន្តំ គោតមំ សរណំ គច្ឆាមិ** សេចក្តីថា ខ្ញុំព្រះអង្គសូមដល់ព្រះគោតមដ៏ចម្រើន ជាទីពឹង គឺខ្ញុំព្រះអង្គ សូមដល់ សូមគប់រក សូមសេព បានដល់ សូមចូលទៅអង្គុយជិតព្រះគោតមដ៏ចម្រើន ដោយបំណងថា ព្រះគោតមដ៏ចម្រើន ទ្រង់ជាទីពឹងដល់ខ្ញុំព្រះអង្គ គឺទ្រង់ជាទីទៅខាងមុខ ទ្រង់ជាអ្នកកំចាត់សេចក្តីទុក្ខ និងទ្រង់ធ្វើប្រយោជន៍ ( ដល់ខ្ញុំ ) ខ្ញុំព្រះអង្គរមែងជ្រាប គឺរមែងរឭកដូចក្រាបទូលមកហើយនោះឯង ។

ពិតហើយ **គតិ** ( ការដល់ ) ជាអត្ថនៃធាតុពួកណា សូម្បី **ពុទ្ធិ** ( ការដឹង ) ក៏ជាអត្ថនៃធាតុទាំងនោះ ព្រោះដូច្នោះ បទថា **គច្ឆាមិ** លោកពោលអត្ថនេះទុកដូច្នេះថា **ជានាមិ ពុជ្ឈាមិ** ( ប្រែថា រមែងជ្រាប គឺរមែងរឭក ) ។

ក្នុងពាក្យថា **ធម្មញ្ច ភិក្ខុសង្ឃញ្ច** នេះ មានវិនិច្ឆ័យថា សភាវៈដែលឈ្មោះថា ធម៌ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវបុគ្គលដែលបានសម្រេចមគ្គ បុគ្គលដែលធ្វើឲ្យជាក់ច្បាស់នូវនិរោធ និងបុគ្គលបដិបត្តិតាមពាក្យប្រៀនប្រដៅមិនឲ្យធ្លាក់ទៅក្នុងអបាយ ។ ធម៌នោះ ដោយអត្ថ បានដល់ អរិយមគ្គ និងនិព្វាន ។ សមដូចព្រះតម្រាស់ ដែលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកសង្ខតធម៌ ធម៌ដែលបច្ច័យតាក់តែងទាំងប៉ុន្មាន មគ្គប្រកបដោយ

អង្គ ៨ ដ៏ប្រសើរ ប្រាកដជាប្រសើរជាងពួកសង្ខតធម៌ទាំងនោះ ។ គួរពោល ឲ្យពិស្តារ ។ ធម៌នោះ បានដល់ អរិយមគ្គ និងនិព្វានតែម្យ៉ាងក៏មិនមែន សូម្បីបរិយត្តិធម៌ និងអរិយផល ក៏ឈ្មោះថា ធម៌ដែរ សមដូចព្រះដ៏មាន ព្រះភាគត្រាស់ទុកក្នុងឆត្តមាណវកវិមានថា

អ្នកចូរដល់នូវធម៌ ដែលប្រាសចាករាគៈ ( អរិយមគ្គ ) មិន
រំភើប មិនមានសោក ( អរិយផល ) ជាសភាវធម៌ដែលបច្ច័យ
ប្រជុំតាក់តែងមិនបាន ជាធម៌មិនគួរខ្ពើម ជាធម៌ដ៏ពីរោះ ដ៏ល្អិត
ដែលលោកចែកត្រឹមត្រូវហើយ ដើម្បីជាសរណៈចុះ[១] ដូច្នេះ ។

ពិតហើយ ក្នុងព្រះគាថានេះ ព្រះដ៏មានព្រះភាគ ត្រាស់មគ្គថា ជាធម៌ ប្រាសចាកតម្រេក ត្រាស់ផលថា ជាធម៌មិនរំភើប មិនមានការសោយសោក ត្រាស់ព្រះនិព្វានថា ជាធម៌ដែលបច្ច័យតាក់តែងមិនបាន ត្រាស់ធម្មក្ខន្ធទាំង អស់ដែលទ្រង់ចែកដោយបិដក ៣ ថា មិនបដិកូល ជាធម៌ពីរោះដ៏ល្អិត ជា ធម៌ដែលតថាគតចែកល្អហើយ ។

ឈ្មោះថា ព្រះសង្ឃ ព្រោះអត្ថថា រួមគ្នាដោយធម៌ដែលស្មើគ្នា គឺទិដ្ឋិ និងសីល ។ ព្រះសង្ឃនោះ ដោយអត្ថ បានដល់ ប្រជុំព្រះអរិយបុគ្គល ៨ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងវិមានវត្ថុថា

អ្នកប្រាជ្ញទាំងឡាយ បានពោលនូវទាន ដែលបុគ្គលឲ្យហើយ
ចំពោះគូបុរសដ៏ស្អាត ៤ គូណា ថាជាទានមានផលច្រើន គូនៃ

---

១- បិ. ៥៥ ឆត្តមាណវកវិមានទី ៣ ។

បុរសនោះ ចាត់ជាបុគ្គល ៨ ពួក ជាអ្នកឃើញនូវធម៌ អ្នកចូរដល់នូវព្រះសង្ឃនេះ ជាសរណៈចុះ[១] ដូច្នេះ ។

ពួកភិក្ខុទាំងឡាយ ឈ្មោះថា ភិក្ខុសង្ឃ ។ ព្រាហ្មណ៍ប្រកាសសរណ-គមន៍ ៣ មានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ដើម្បីភាពជាបុគ្គលឈ្លាសក្នុងត្រៃសរណគមន៍ទាំងនោះឯង គួរជ្រាបវិធីដូច្នេះថា សរណៈ សរណគមន៍ អ្នកដល់សរណៈ ប្រភេទនៃសរណគមន៍ ផលនៃសរណគមន៍ សង្កិលេស ( ការសៅហ្មង ) ភេទៈ ( ការបែកធ្លាយនៃសរណគមន៍ ) ។ ឯវិធីនោះ បើខ្ញុំពោលទុកក្នុងអធិការនេះ ក៏រមែងធ្វើនិទាននៃព្រះវិន័យ ឲ្យជាការៈធ្ងន់ពន់ពេក ព្រោះដូច្នោះ ទើបខ្ញុំមិនពោល ។ ចំណែកអ្នកសិក្សាទាំងឡាយ ដែលមានសេចក្ដីត្រូវការ គប្បីកាន់យកវិធីនេះអំពីវណ្ណនានៃភយភេរវសូត្រ ក្នុងអដ្ឋកថានៃមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី អំពីវណ្ណនាសរណៈ ក្នុងអដ្ឋកថាខុទ្ទកនិកាយ ឈ្មោះបរមត្ថជោតិកា ឬក្នុងអដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនីឯណោះ ។

ពាក្យថា **ឧបាសកំ មំ ភវំ គោតមោ ធារេតុ** អធិប្បាយថា សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសក ដូច្នេះចុះ ។ ក្នុងអធិការនេះ ដើម្បីភាពជាបុគ្គលឈ្លាសក្នុងវិធីប្រកាសខ្លួនជាឧបាសក គួរជ្រាបបកិណ្ណកដូច្នេះថា បុគ្គលណាលោកហៅថា ឧបាសក ហេតុអ្វី ទើបលោកហៅថា ឧបាសក ឧបាសកមានសីលដូចម្ដេច មានអាជីវៈដូចម្ដេច មានអ្វីជា

---

១- បិ. ៥៥ ឆត្តមាណវកវិមានទី ៣ ។

វិបត្តិ មានអ្វីជាសម្បត្តិ ខ្ញុំមិនបានចែកបកិណ្ណកនោះទុកក្នុងអធិការពោលដោយនិទាននេះ ព្រោះធ្វើឲ្យជាភារៈធ្ងន់ពន់ពេក តែអ្នកសិក្សាទាំងឡាយ ដែលមានសេចក្តីត្រូវការ គប្បីជ្រាបដោយន័យដែលខ្ញុំពោលទុកហើយ ក្នុងអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនីនោះហោង ។

## អគ្គសព្ទ មានអត្ថ ៤ យ៉ាង

**អគ្គ** សព្ទ ក្នុងបទថា **អជ្ជតគ្គេ** នេះ រមែងប្រាកដក្នុងអត្ថ គឺ **អាទិ** ( ខាងដើម ) **កោដិ** ( ខាងចុង ) **កោដ្ឋាស** ( ចំណែក ) និង **សេដ្ឋ** ( ប្រសើរ ) ។

ពិតហើយ **អគ្គ** សព្ទ រមែងប្រាកដក្នុងអត្ថ គឺខាងដើម ក្នុងប្រយោគទាំងឡាយជាដើមថា **អជ្ជតគ្គេ សម្ម ទោវារិក អាវរាមិ ទ្វារំ និគណ្ឋានំ និគណ្ឋីនំ** ម្នាលអ្នករក្សាទ្វារជាសម្លាញ់ ពីថ្ងៃនេះជាដើមរៀងទៅ ខ្ញុំបិទទ្វារចំពោះពួកនិគ្រន្ថ និងពួកនិគ្រន្ថស្រី ។

**អគ្គ** សព្ទ រមែងប្រាកដក្នុងអត្ថ គឺខាងចុង ក្នុងប្រយោគទាំងឡាយជាដើមថា **តេន អង្គុលគ្គេន តំ អង្គុលគ្គំ បរាមសតិ** ស្ទាបអង្អែលនូវចុងម្រាមនោះ ដោយចុងម្រាមនោះ ។ **ឧច្ឆគ្គំ** ចុងអំពៅ **វេឡគ្គំ** ចុងឫស្សី ។

រមែងប្រាកដក្នុងអត្ថ គឺចំណែក ក្នុងប្រយោគទាំងឡាយជាដើមថា **អម្ពិលគ្គំ វា មធុរគ្គំ វា តិត្តកគ្គំ វា** ចំណែករបស់ដែលមានរសជូរខ្លះ ចំណែករបស់ដែលមានរសផ្អែមខ្លះ ឬចំណែករបស់ដែលមានរសល្វីងខ្លះ ។ **អនុជានាមិ ភិក្ខវេ វិហារគ្គេន វា បរិវេណគ្គេន វា ភាជេតុំ** ម្នាលភិក្ខុ

ទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រគល់តាមចំណែកនៃវិហារ ឬចំណែកនៃបរិវេណ ។

រមែងប្រាកដក្នុងអគ្គ គឺប្រសើរ ក្នុងប្រយោគទាំងឡាយជាដើមថា **យាវតា ភិក្ខវេ សត្តា អបទា ទ្វិបទា វា ចតុប្បទា វា ពហុប្បទា វា រូបិនោ វា អរូបិនោ វា សញ្ញិនោ វា អសញ្ញិនោ វា នេវសញ្ញីនាសញ្ញិនោ វា តថាគតោ តេសំ អគ្គមក្ខាយតិ អរហំ សម្មាសម្ពុទ្ធោ។** ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ជាសត្វឥតជើងក្តី មានជើង ២ ក្តី មានជើង ៤ ក្តី មានជើងច្រើនក្តី មានរូបក្តី ឥតរូបក្តី មានសញ្ញាក្តី ឥតសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនក្តី ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ[១] ។

តែ **អគ្គ** សព្ទ ក្នុងអធិការនេះ គប្បីឃើញថា ចុះក្នុងអគ្គ គឺខាងដើម ព្រោះដូច្នោះ ក្នុងបទថា **អជ្ជតគ្គេ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ចាប់ផ្តើមអំពីថ្ងៃនេះជាដើមទៅ ។ លោកពោលអធិប្បាយទុកថា បទថា **អជ្ជតគ្គំ** គឺ **អជ្ជភាវំ** ប្រែថា ក្នុងថ្ងៃនេះ ម្យ៉ាងទៀត បាឋៈថា **អជ្ជទគ្គេ** ដូច្នេះក៏មាន ។ **ទ** អក្ខរៈ ធ្វើការតបទ ។ អធិប្បាយថា ចាប់ផ្តើមអំពីថ្ងៃនេះ ។

បទថា **បាណុបេតំ** សេចក្តីថា អ្នកចូលដល់( ព្រះរតនត្រ័យ ) ដោយបាណៈ ( គឺជីវិត ) ។ វេរញ្ជព្រាហ្មណ៍ក្រាបទូលថា ជីវិតរបស់ខ្ញុំព្រះអង្គប្រព្រឹត្តទៅត្រឹមណា បពិត្រព្រះគោតម សូមទ្រង់ចាំ គឺទ្រង់ជ្រាបខ្ញុំព្រះអង្គថា

---

១- បិ. ៣៧ អប្បមាទវគ្គ ។

( ជាឧបាសក ) អ្នកចូលដល់ អ្នកដល់សរណៈ ដែលមិនមានសាស្តាដទៃ ដោយត្រៃសរណគមន៍ត្រឹមប៉ុណ្ណោះ ខ្ញុំព្រះអង្គ សូម្បីបុគ្គលណាមួយ យកកាំបិតដ៏មុត កាត់ក្បាលរបស់ខ្ញុំព្រះអង្គសោត ក៏មិនគប្បីពោលដល់ព្រះពុទ្ធថា មិនមែនព្រះពុទ្ធ ព្រះធម៌ ថាមិនមែនព្រះធម៌ ឬព្រះសង្ឃ ថាមិនមែនព្រះសង្ឃ ដូច្នេះឡើយ ។

ចំណែកក្នុងអធិការនេះ គប្បីជ្រាបអធិប្បាយថា ព្រាហ្មណ៍កាលពោលដល់សរណគមន៍ដដែលទៀតថា អ្នកដល់សរណគមន៍ រហូតអស់មួយជីវិត ឈ្មោះថា ប្រកាសការប្រគល់កាយថ្វាយខ្លួន ( ដល់ព្រះរតនត្រ័យ ) ។

វេរញ្ជព្រាហ្មណ៍ កាលប្រគល់កាយថ្វាយខ្លួនយ៉ាងនោះហើយ មានបំណងនឹងធ្វើជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ព្រមទាំងបរិស័ទ ទើបទូលថា សូមព្រះគោតមដ៏ចម្រើន ព្រមដោយភិក្ខុសង្ឃ ទ្រង់ទទួលការនៅចាំវស្សាត្រង់ ស្រុកវេរញ្ជារបស់ខ្ញុំព្រះអង្គចុះ ។

ព្រាហ្មណ៍ក្រាបទូលបំណងទុកដូចម្តេច ក្រាបទូលទុកយ៉ាងនេះថា បពិត្រព្រះគោតម សូមទ្រង់ចាំនូវខ្ញុំព្រះអង្គថាជាឧបាសកនិងសូមទ្រង់ទទួលការនៅចាំវស្សាត្រង់ស្រុកវេរញ្ជារបស់ខ្ញុំព្រះអង្គចុះ គឺសូមឲ្យទ្រង់ទទួលការអាស្រ័យក្រុងវេរញ្ជា នៅចាំវស្សាអស់ត្រៃមាស ដើម្បីអនុគ្រោះខ្ញុំព្រះអង្គចុះ ។

បទជាច្រើនថា **អធិវាសេសិ ភគវា តុណ្ហីភាវេន** សេចក្តីថា គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍នោះហើយ ទ្រង់ក៏មិនញ៉ាំងព្រះកាយ ឬវាចាឲ្យកម្រើកឡើយ ទ្រង់ទុកនូវព្រះខន្តីក្នុងខាងក្នុង

នោះឯង ទ្រង់ទទួល ( ពាក្យអារាធនា ) ដោយតុណ្ហីភាព ។ លោកអធិប្បាយទុកថា ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយព្រះទ័យនោះឯងដើម្បីអនុគ្រោះព្រាហ្មណ៍ ។

បទជាច្រើនថា **អថខោ វេរញ្ជោ ព្រាហ្មណោ ភគវតោ អធិវាសនំ វិទិត្វា** សេចក្តីថា គ្រានោះឯង វេរញ្ជព្រាហ្មណ៍គិតថា បើព្រះគោតមមិនគប្បីទួល ( ពាក្យអារាធនា ) របស់អញ ទ្រង់គប្បីបដិសេធដោយកាយ ឬដោយវាចា តែព្រោះព្រះអង្គ ទ្រង់មិនបដិសេធ ទ្រង់ព្រះខន្តីទុកខាងក្នុង ដូច្នោះ ព្រះអង្គទ្រង់ក៏ទទួល ( ពាក្យអារាធនា ) របស់អញ ដោយព្រះទ័យនោះឯង ដូច្នេះ កាលជ្រាបការដែលទ្រង់ទទួលពាក្យអារាធនារបស់ព្រះដ៏មានព្រះភាគហើយ ព្រោះភាពដែលខ្លួនជាបុគ្គលឈ្លាសក្នុងការកំណត់ដឹងអាការដូចពណ៌នាហើយនោះ ទើបក្រោកចាកអាសនៈដែលខ្លួនអង្គុយ ថ្វាយបង្គំព្រះដ៏មានព្រះភាគក្នុងទិសទាំង ៤ ដោយសេចក្តីគោរព ហើយធ្វើប្រទក្សិណ ៣ ជុំ សូម្បីបានតិះដៀលតាំងអំពីពេលដែលខ្លួនមកថា ព្រះសមណគោតមទ្រង់មិនធ្វើសាមីចិកម្ម មានការថ្វាយបង្គំជាដើមដល់ពួកព្រាហ្មណ៍ ដែលចាស់ជាងដោយជាតិជាដើម ឥឡូវនេះ បានដឹងព្រះពុទ្ធគុណយ៉ាងជ្រាលជ្រៅហើយ ថ្វាយបង្គំដោយកាយវាចា និងចិត្ត ច្រើនលើក ច្រើនដង ក៏ជាបុគ្គលមិនឆ្អែតនោះឯង ទើបបានផ្គងអញ្ជលី ដែលរុងរឿងដោយការប្រជុំព្រមនៃម្រាមទាំង ១០ លើកឡើងដាក់លើក្បាល ដើរថយក្រោយបែរមុខទៅកាន់ផ្លូវ ( ដែលព្រះដ៏មានព្រះភាគគង់នៅ ) រហូតផុតទស្សនវិស័យ បានថ្វាយបង្គំក្នុងទីផុត

ទស្សនវិស័យហើយ ចៀសចេញទៅ ។

## ស្រុកវេរញ្ជាកើតទុព្ភិក្ខភ័យ

[ ៥ ] បទជាច្រើនថា **តេន ខោ បន សមយេន វេរញ្ជា ទុព្ភិក្ខា ហោតិ** ក្នុងសម័យដែលវេរញ្ជព្រាហ្មណ៍ ទូលអារាធនាឲ្យព្រះដ៏មានព្រះភាគទ្រង់អាស្រ័យស្រុកវេរញ្ជាចាំវស្សានោះ ស្រុកវេរញ្ជា ជាស្រុកមានទុរ្ភិក្ស ។

បទថា **ទុព្ភិក្ខា** ប្រែថា មានភិក្ខាហារកបានដោយលំបាក ។ ឯការមានភិក្ខាហារកបានលំបាកនោះ រមែងមានក្នុងទឹកដីដែលពួកមនុស្សមិនមានសទ្ធា មិនមានការជ្រះថ្លា ក្នុងវេលាដែលសន្ទូងសម្បូរល្អក៏ដោយ ក្នុងវេលាបុព្វណ្ណៈនិងអបរណ្ណៈមានតម្លៃថោកក៏ដោយ ។ តែក្នុងស្រុកវេរញ្ជា មិនមែនដូច្នោះឡើយ ដោយពិត មិនមែនមានព្រោះទោស គឺការអត់ឃ្លាន ព្រោះមានសន្ទូងវិនាសនោះឡើយ ព្រោះដូច្នោះ កាលព្រះឧបលិត្តេរសម្តែងសេចក្តីនោះ ទើបពោលថា **ទ្វីហិតិកា** ដូច្នេះជាដើម ។

ក្នុងពាក្យថា **ទ្វីហិតិកា** ជាដើមនេះ មានវិនិច្ឆ័យថា **ទ្វីហិតិកា** បានដល់ ការព្យាយាមដែលប្រព្រឹត្តទៅហើយ ២ យ៉ាង ។ ការកម្រើកឃ្លាតឈ្មោះថា **ឦហិត** ( សេចក្តីព្យាយាម ) សេចក្តីព្យាយាមដែលប្រព្រឹត្តទៅហើយ ២ យ៉ាង គឺចិត្តឥរិយា ( ការកម្រើកឃ្លាតនៃចិត្ត ) ១ **ចិត្តឦហា** ( សេចក្តីព្យាយាមនៃចិត្ត ) ១ ។

ក្នុងបទថា **ទ្វីហិតិកា** មានអធិប្បាយដូច្នេះថា ការកម្រើកឃ្លាតនៃចិត្តដែលប្រព្រឹត្តទៅហើយយ៉ាងនេះ គឺពួកយើងសូមវត្ថុណាមួយ នៅក្នុងទីនេះ

នឹងបាន ឬមិនបានហ្ន៎ ម្យ៉ាងទៀត ពួកយើងនឹងអាចដើម្បីរស់នៅ ឬមិនអាចហ្ន៎ ម្យ៉ាងទៀត បទថា **ទុហិតិកា** ប្រែថា ជាអ្នករស់នៅយ៉ាងលំបាក ។ ពិតហើយ បទទាំងឡាយជាដើម គឺ **ឦហិតំ** ( សេចក្ដីព្យាយាម ) **ឦហា** ( សេចក្ដីប្រឹងប្រែង ) **ឥរិយនំ** ( ការកម្រើកឃ្លាត ) **បវត្តនំ** ( ការប្រព្រឹត្តទៅ ) **ជីវិតំ** ( ការរស់នៅ ) មានអត្ថតែម្យ៉ាងដូចគ្នា ព្រោះដូច្នោះ ក្នុងបទថា **ទុហិតិកា** នេះ មានអត្ថចំពោះបទដូច្នេះ គឺសេចក្ដីព្យាយាមដោយភាពជាទុក្ខ រមែងប្រព្រឹត្តទៅក្នុងស្រុកវេរញ្ជានេះ ព្រោះហេតុនោះ ទើបស្រុកវេរញ្ជានេះ ឈ្មោះថា **ទុហិតិកា**។

បទថា **សេតដ្ឋិកា** សេចក្ដីថា ស្រុកវេរញ្ជា ឈ្មោះថា មានឆ្អឹងអ្នកស្លាប់សក្បុស ព្រោះអត្ថវិគ្គហៈថា ត្រង់ស្រុកវេរញ្ជានេះ មានឆ្អឹងសដេរដាស អធិប្បាយថា សាកសពរបស់មនុស្សដែលសូមទាន សូម្បីអស់មួយថ្ងៃ ក៏មិនបានវត្ថុណាមួយ ស្លាប់ហើយ មានឆ្អឹងពណ៌ដូចផ្សិតក្បាលពស់ ដេរដាសក្នុងទីនោះៗ ។

បាឋៈថា **សេតដ្ដិកា** ដូច្នេះក៏មាន ។ អត្ថនៃបាឋៈនោះថា រោគក្រា ស មាននៅក្នុងស្រុកវេរញ្ជានេះ ហេតុនោះ ទើបស្រុកវេរញ្ជានេះ ឈ្មោះថា មានរោគក្រា ស ។ ការឈឺចាប់ គឺការចាក់ដោត ព្រោះជំងឺតម្កាត់ ឈ្មោះថា **អដ្ដិ**។ ឯក្នុងស្រុកវេរញ្ជានោះ ក្នុងវេលាដែលស្រូវផើម កួរស្រូវសាលីក្ដី កួរស្រូវជំណើបក្ដី ស្រូវផែក្ដី មានពណ៌សៗ ត្រូវរោគក្រានោះឯងធ្វើឲ្យខូច ក៏ជាប់ទឹកដោះ មិនមានគ្រាប់ស្រូវដុះចេញមក ( គឺធ្លាក់ជាកួរចេញមក ) ព្រោះ

ដូច្នោះ ទើបស្រុកវេរញ្ជានេះ លោកហៅថា **សេតដ្ឋិកា** ( ស្រុកមានរោគសន្ទូងក្រាស )។

ក្នុងវេលាសាបព្រោះ សន្ទូងដែលប្រជាជនសូម្បីផ្សំពូជ ព្រោះទុកល្អហើយ រមែងសម្រេចជាស្លាកប៉ុណ្ណោះ ក្នុងស្រុកវេរញ្ជានោះ ព្រោះហេតុនោះ ទើបស្រុកវេរញ្ជានោះ ឈ្មោះថា មានសន្ទូងដែលព្រោះហើយ សម្រេចជាស្លាក ។ម្យ៉ាងទៀត ប្រជាជនទាំងឡាយ រមែងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅក្នុងស្រុកវេរញ្ជានោះដោយស្លាក ( គឺការចែកប័ណ្ណ ) ព្រោះដូច្នោះ ទើបស្រុកវេរញ្ជានោះ ឈ្មោះថា មានជីវិតប្រព្រឹត្តទៅដោយស្លាក ។

មានពាក្យអធិប្បាយទុកដូចម្តេច មានពាក្យអធិប្បាយទុកយ៉ាងនេះថា បានឮមកថា ក្នុងស្រុកវេរញ្ជានោះ កាលមហាជនទាំងឡាយ អ្នកទិញ ទៅកាន់សម្នាក់របស់ពួកឈ្មួញលក់ស្រូវ ពួកមនុស្សមានកម្លាំង ( ទ្រព្យ ) ទាញកន្ត្រាក់ពួកមនុស្សដែលមិនមានកម្លាំង ហើយទិញយកស្រូវទៅ ( អស់ ) ពួកមនុស្សដែលមិនមានកម្លាំង( ទ្រព្យ ) កាលមិនបានស្រូវ រមែងស្រែកដោយសំឡេងខ្លាំង ។ ពួកឈ្មួញលក់ស្រូវ ប្រឹក្សាគ្នាថា ពួកយើងនឹងធ្វើការសង្គ្រោះមហាជនទាំងអស់ ទើបប្រាប់ឲ្យអ្នកវាល់ស្រូវ អង្គុយក្នុងកន្លែងធ្វើការរៀងៗខ្លួន ចាំវាល់ស្រូវ ហើយឲ្យអ្នកជំនាញក្នុងការមើលកហាបណៈអង្គុយក្នុងចំណែកម្ខាង ។ ពួកមនុស្សដែលមានសេចក្តីត្រូវការស្រូវ ក៏ទៅកាន់សម្នាក់របស់អ្នកជំនាញខាងមើលកហាបណៈ ។ អ្នកជំនាញខាងមើលកហាបណៈនោះ កាន់យកតម្លៃដោយលំដាប់នៃជនដែលមកហើយ ទើប

សរសេរស្លាក ( គឺប័ណ្ណ ) ឲ្យទៅ ប្រាប់ថា គួរឲ្យដល់ជនឈ្មោះនេះ មានប្រមាណប៉ុណ្ណេះ ។ ពួកមនុស្សដែលមានសេចក្តីត្រូវការស្រូវទាំងនោះទទួលយកស្លាកនោះហើយ ទៅកាន់សម្នាក់របស់អ្នកវាល់ស្រូវ ហើយទទួលយកស្រូវដោយលំដាប់ដែលគេវាល់ឲ្យ ។ មហាជនទាំងឡាយ រមែងឲ្យជីវិតប្រព្រឹត្តទៅក្នុងស្រុកវេរញ្ជានោះដោយស្លាក ព្រោះហេតុនោះ ទើបស្រុកវេរញ្ជានោះ ឈ្មោះថា មានជីវិតប្រព្រឹត្តទៅបានដោយស្លាក ដូចពណ៌នាដូច្នេះ ។

បទជាច្រើនថា **ន សុករា ឧញ្ឆេន បគ្គហេន យាបេតុំ** សេចក្តីថា ភិក្ខុសង្ឃនឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយការកាន់បាត្រ ស្វែងរកក៏ធ្វើមិនបានងាយ ។ អធិប្បាយថា បុគ្គលណាមួយ កាន់បាត្រហើយ នឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយការស្វែងរក ដូចពួកព្រះអរិយៈធ្វើការស្វែងរក គឺត្រាច់បិណ្ឌបាតនោះ ក៏ធ្វើមិនបានងាយៗ ឡើយ ។ បានឮថា គ្រានោះ ក្នុងស្រុកវេរញ្ជានោះ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាត រហូត ៧-៨ ភូមិ ក៏មិនបានអាហារល្មមត្រឹមតែញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ សូម្បីក្នុងមួយថ្ងៃ ។

## ឈ្មួញសេះប្រគេនចាយមួយនាឡិដល់ភិក្ខុមួយអង្គ

ពាក្យថា **តេន ខោ បន សមយេន ឧត្តរាបថកា អស្សវាណិជា ។បេ។ អស្សោសិ ខោ ភគវា ឧទុក្ខលសទ្ទំ** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

បទថា **តេន** សេចក្តីថា ដោយសម័យដែលព្រះដ៏មានព្រះភាគ ទ្រង់អាស្រ័យស្រុកវេរញ្ជាចាំវស្សានោះ ពួកឈ្មួញសេះ ដែលនៅក្នុងឧត្តរាបថជនបទ ឬ

បុគ្គលដែលបានឈ្មោះយ៉ាងនោះ ព្រោះមកអំពីឧត្តរាបថជនបទ ទទួល ( ទិញ ) យកសេះ ៥០០ ក្បាល ដែលជាតំបន់កើតរបស់សេះទាំងឡាយ ក្នុងឧត្តរា-បថជនបទហើយ កាលប្រាថ្នាចំណូល ( ចំណេញ ) ២-៣ ដង ក៏បានទៅកាន់ប្រទេសដទៃ ហើយចូលស្នាក់រដូវភ្លៀងក្នុងស្រុកវេរញ្ជា ព្រមដោយហ្វូងសេះមានប្រមាណ ៥០០ ដែលជាមុខទំនិញខ្លួនត្រូវលក់ដូរទាំងនោះ ។

សួរថា ព្រោះហេតុអ្វី ទើបត្រូវស្នាក់នៅដូច្នោះ ឆ្លើយថា ព្រោះក្នុងស្រុកនោះ បុគ្គលណាមួយ មិនអាចដើរផ្លូវឆ្ងាយ រហូត ៤ ខែ ក្នុងរដូវភ្លៀងបានឡើយ ... ឯពួកឈ្មួញសេះទាំងនោះ កាលនឹងស្នាក់ក្នុងរដូវភ្លៀង ទើបបានបញ្ជាឲ្យមេជាងសាងផ្ទះសម្នាក់សម្រាប់ខ្លួន និងរោងសេះសម្រាប់ពួកសេះទុកក្នុងកន្លែងដែលទឹកមិនលិច ខាងក្រៅព្រះនគរ ហើយបោះរបងទុក ។ ទីកន្លែងស្នាក់របស់ពួកឈ្មួញទាំងនោះ ប្រាកដឈ្មោះថា **អស្សមណ្ឌលិកា** ( ក្រោលសេះ ) ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា ពួកឈ្មួញដែលនៅក្នុងរោងសេះទាំងនោះ ក៏បានបញ្ញត្តគ្នា ឲ្យប្រគេនបាយក្រៀមម្នាក់មួយនាឡិៗ ដល់ភិក្ខុទាំងឡាយ ដូច្នេះ ។

បទថា **បត្ថបត្ថបុលកំ** បានដល់ បាយក្រៀមមានប្រមាណមួយកម្សង់ៗ សម្រាប់ភិក្ខុមួយអង្គៗ ។ ឈ្មោះថា មួយបត្ថៈ មានប្រមាណស្មើមួយកម្សង់ គឺល្មមដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅសម្រាប់មនុស្សម្នាក់ ។ សមដូចព្រះដ៏មានព្រះភាគត្រាស់ទុកថា បាយមួយកម្សង់នេះ មិនគ្រប់គ្រាន់ដើម្បីញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅសម្រាប់មនុស្សពីរនាក់ទេ ។

អង្ករក្រហម ដែលបុគ្គលធ្វើឲ្យអស់សម្បកហើយ ចំហុយឲ្យឆ្អិន ទើបកាន់យក ហៅថា បាយក្រៀម ។ ពិតហើយ អង្ករក្រហមនោះ កាលនៅមានសម្បក សត្វល្អិតតូចៗ រមែងចោះបាន រមែងមិនគួររក្សាទុកបានយូរ ព្រោះដូច្នោះ ពួកឈ្មួញទាំងនោះ ធ្វើឲ្យជារបស់គួររក្សាទុកបានយូរ ហើយកាន់យកអង្ករក្រហម ទើបដើរផ្លូវឆ្ងាយ ដោយគិតថា ក្នុងទីឯណាស្មៅដែលជាអាហារពួកសេះស៊ី ជារបស់រកបានដោយលំបាក ទីកន្លែងនោះឯង បាយអង្ករក្រហមនោះ នឹងជាអាហាររបស់សេះ ។

សួរថា ព្រោះហេតុអ្វី ទើបពួកឈ្មួញទាំងនោះ បានរៀបចំបាយអង្ករក្រហមនោះ ទុកសម្រាប់ភិក្ខុទាំងឡាយ ខ្ញុំសូមឆ្លើយថា ពិតណាស់ ពួកមនុស្សអ្នកឧត្តរាបថជនបទទាំងនោះ ជាបុគ្គលមិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា ដូចពួកមនុស្សអ្នកទក្ខិណាជនបទ ក៏ទេ ។ តាមពិត ពួកមនុស្សឧត្តរាបថជនបទទាំងនោះ ជាអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា ជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឃមាមកៈ ពួកឈ្មួញទាំងនោះ ក្នុងពេលព្រឹក កាលចូលទៅកាន់ក្រុង ដោយករណីយកិច្ចឯណានីមួយនោះឯង បានជួបភិក្ខុ ៧-៨ អង្គដែលស្លៀកដណ្តប់រៀបរយ បរិបូណ៌ដោយឥរិយាបថ ត្រាច់ទៅបិណ្ឌបាតទូទាំងស្រុក ក៏មិនបានវត្ថុណាមួយ របូត ២-៣ ថ្ងៃ លុះឃើញហើយ ឈ្មួញទាំងនោះ គិតដូច្នេះថា លោកម្ចាស់ទាំងឡាយ អាស្រ័យស្រុកនេះចាំវស្សា ឆាទកភ័យក៏កំពុងប្រព្រឹត្តទៅ ហើយភិក្ខុទាំងនេះ ក៏មិនបានរបស់ណាមួយ រមែងលំបាកក្រៃលែង ទាំងពួកយើងជាអាគន្តុកៈ រមែងមិនអាចចាត់ចែង

*រៀបចំបបរ និងបាយ ប្រគេនភិក្ខុទាំងនោះរាល់ៗ ថ្ងៃបាន តែសេះទាំងឡាយ របស់ពួកយើង បានអាហារពីរពេល គឺក្នុងពេលព្រឹក និងពេលល្ងាច ធ្វើ ម្ដេចហ្ន៎ ពួកយើងគប្បីចែករំលែកបាយក្រហមមួយកម្សង់ៗ ដល់ភិក្ខុមួយអង្គៗ អំពីអាហារពេលព្រឹក របស់សេះនីមួយៗ បើដូច្នេះ ភិក្ខុទាំងឡាយ នឹងមិន លំបាកផង សេះក៏នឹងល្មមញុំាងជីវិតឲ្យប្រព្រឹត្តទៅបានផង ។*

*ទើបពួកឈ្មួញទាំងនោះ ទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ ប្រាប់ សេចក្ដីឲ្យជ្រាប ហើយធ្វើសំណូមពរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ ទាំងឡាយ ទទួលបាយក្រៀមមួយកម្សង់ៗ ហើយធ្វើឲ្យទៅជាអាហារឯណា នីមួយ ឆាន់ចុះ ដូច្នេះហើយ ទើបបានរៀបចំបាយអង្ករក្រហមមួយកម្សង់ៗ ទុក រាល់ៗថ្ងៃ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា ពួកឈ្មួញសេះ ទាំងនោះ បានរៀបចំបាយក្រៀមមួយកម្សង់ៗ សម្រាប់ភិក្ខុទាំងឡាយ ទុក ត្រង់ក្រោលសេះ ។*

*បទថា* **បញ្ញត្តំ** *ប្រែថា បានតាំងទុកហើយ ដោយសន្ធ្មេបបែបនិច្ចភត្ត ។*

*ឥឡូវនេះ គួរជ្រាបវិនិច្ឆ័យក្នុងពាក្យថា* **ភិក្ខូ បុព្វណ្ហសមយំ និវា-សេត្វា** *ជាដើមថា បទថា* **បុព្វណ្ហសមយំ** *ប្រែថា សម័យដែលជាចំណែក ខាងដើមនៃថ្ងៃ អធិប្បាយថា ក្នុងបុព្វណ្ហសម័យ ។ ម្យ៉ាងទៀត សម័យ គឺ ពេលព្រឹក ឈ្មោះថា បុព្វណ្ហសម័យ លោកពោលអធិប្បាយទុកថា ខណៈ មួយក្នុងវេលាព្រឹក ។ កាលអធិប្បាយយ៉ាងនេះ ទុតិយាវិភត្តិ រមែងបានក្នុង អត្ថនៃអច្ចន្តសំយោគ ។*

បទថា **ឆិវាសេត្វា** ប្រែថា ស្មៀកដណ្តប់ហើយ ។ បទថា **ឆិវាសេត្វា** នោះ គប្បីជ្រាបដោយអំណាចនៃការផ្លាស់ប្តូរការស្លៀកដណ្តប់ក្នុងវិហារ ។ ក្នុងកាលមុនវេលាត្រាច់បិណ្ឌបាតនោះ ភិក្ខុទាំងនោះ មិនមែនមិនស្លៀកដណ្តប់នោះឡើយ ។

បទថា **បត្តចីវរមាទាយ** សេចក្តីថា យកដៃទាំង ២ ឱបបាត្រ យកចីវរប្រដាប់កាយ អធិប្បាយថា ទ្រទ្រង់ទុក គឺកាន់យក ។ ពិតហើយ ពួកភិក្ខុកាលកាន់យក ( បាត្រ និងចីវរ ) ដោយប្រការណាមួយក៏ដោយ លោកក៏ហៅថា កាន់យកដូចគ្នា ។ ដូចក្នុងប្រយោគថា លុះកាន់យកបានប៉ុណ្ណោះក៏ចៀសចេញទៅ ដូច្នេះ ។

ពីរបទថា **បិណ្ឌំ អលភមានា** សេចក្តីថា ត្រាច់ទៅពេញស្រុកវេរញ្ជាកុំថាឡើយតែដុំបាយមិនបាន ដោយហោច សូម្បីពាក្យថា និមន្តប្រោសសត្វខាងមុខចុះក៏មិនបានដែរ ។

ប្រើនបទថា **បត្តបត្តបុលកំ អារាមំ ហរិត្វា** សេចក្តីថា កាន់យកបាយក្រៀមមួយកម្សង់ៗ ដែលខ្លួនបានក្នុងទីដែលទៅហើយ ហើយនាំទៅកាន់អារាម ។

ប្រើនបទថា **ឧទុក្ខលេ កោដេត្វា កោដេត្វា បរិភុញ្ជន្តិ** សេចក្តីថា បុគ្គលណាមួយ ដែលជាកប្បិយការកៈទទួលយកអង្ករក្រហមមួយកម្សង់នោះទៅដាំជាបបរ ឬដាំជាបាយ ប្រគេនដល់ព្រះថេរៈទាំងនោះ រមែងមិនមាន ។ ការចម្អិនខ្លួនឯង រមែងមិនជាសមណសារូប ទាំងមិនសមគួរ ។ ភិក្ខុទាំងនោះ

រួមជាពួកៗ មួយពួក ៨ អង្គខ្ះ មួយពួក ១០ អង្គខ្ះ ប្រឹក្សាគ្នាថា ភាពជាអ្នកប្រព្រឹត្តស្រោល និងដោះចាកការចម្អិនឲ្យឆ្អិនឯង នឹងមានដល់ពួកយើងដោយវិធីយ៉ាងនេះ ដូច្នេះ ទើបបុកឲ្យល្អិតក្នុងត្បាល់ ហើយយកទឹកចាក់លាយចំណែករៀងៗ ខ្លួន ឲ្យសើមហើយឆាន់ កាលលោកទាំងនោះឆាន់ហើយ ក៏ជាអ្នកមានការខ្វល់ខ្វាយតិច នៅបំពេញសមណធម៌ដោយប្រការ ដូច្នេះ ។

ចំណែកពួកឈ្មួញសេះទាំងនោះ ក៏ប្រគេនបាយអង្ករក្រហមមួយកម្សង់ និងទឹកដោះថ្លា ទឹកឃ្មុំ និងស្ករ ដែលគួរដល់បាយអង្ករក្រហមនោះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអានន្ទនាំយកបាយអង្ករក្រហមនោះ មកបុកត្រង់ថ្ម ។ បាយអង្ករក្រហមនោះ ដែលបុរសបណ្ឌិតអ្នកមានបុណ្យធ្វើហើយ រមែងជារបស់ពេញចិត្តនោះឯង ។ គ្រានោះ ព្រះអានន្ទ កាលបុកបាយអង្ករក្រហមនោះ ក៏ផ្សំដោយគ្រឿងផ្សំ មានទឹកដោះថ្លាជាដើម បង្អោនចូលប្រគេនដល់ព្រះដ៏មានព្រះភាគ ។

ខណៈនោះ ពួកទេវតាបានដាក់ទិព្វឱជាក្នុងបាយក្រៀមដែលផ្សំនេះ ។ ព្រះដ៏មានព្រះភាគ ក៏សោយព្រះក្រយាហារដែលបុកថ្វាយនោះ កាលសោយហើយ ទ្រង់ក៏ញ៉ាំងកាលឲ្យកន្លងទៅដោយផលសមាបត្តិ ចំណេរកាលតាំងអំពីនោះមក ទ្រង់ក៏មិនបាច់ត្រាច់បិណ្ឌបាត ។

## ២០ វស្សា ព្រះមានព្រះភាគមិនមានឧបដ្ឋាក

សួរថា គ្រានោះ ព្រះអានន្ទត្ថេរមិនទាន់បានជាឧបដ្ឋាករបស់ព្រះដ៏មានព្រះភាគទេឬ ឆ្លើយថា មិនទាន់បានទេ ហើយលោកក៏មិនបានទទួល

តំណែងជាឧបដ្ឋាកឡើយ ។ សេចក្តីពិត ក្នុងបឋមពោធិកាល ឈ្មោះថា ភិក្ខុដែលជាឧបដ្ឋាកប្រចាំរបស់ព្រះដ៏មានព្រះភាគ ក្នុងរយៈ ២០ វស្សា រមែង មិនមាន ។ គ្រាខ្លះ ព្រះនាគសមាលត្ថេរជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ពេល ខ្លះ ព្រះនាគិតត្ថេរ គ្រាខ្លះ ព្រះមេឃិយត្ថេរ ពេលខ្លះ ព្រះឧបវាណត្ថេរ គ្រា ខ្លះ ព្រះសាគតត្ថេរ ពេលខ្លះ ព្រះថេរៈដែលជាឱរសរបស់ព្រះបាទលិច្ឆវី ឈ្មោះ សុនក្ខត្តឧបដ្ឋាកព្រះដ៏មានព្រះភាគ ។ ព្រះថេរៈទាំងនោះឧបដ្ឋាកតាមការពេញ ចិត្តរបស់ខ្លួនហើយ ក៏ចៀសចេញទៅក្នុងវេលាដែលខ្លួនប្រាថ្នា ( នឹងចៀស ចេញទៅ ) ។ ព្រះអានន្ទត្ថេរ កាលលោកទាំងនោះនៅឧបដ្ឋាក ក៏ជាអ្នកមាន សេចក្តីខ្វល់ខ្វាយតិច កាលលោកចេញទៅហើយ ក៏ធ្វើវត្តបដិបត្តិដល់ព្រះដ៏ មានព្រះភាគ ទ្រង់ដាក់ព្រះទ័យថា ញាតិដែលជាធំរបស់តថាគតមិនទាន់បាន ទទួលតំណែងជាឧបដ្ឋាកមកអំពីមុនក៏ពិត ដូច្នោះ អានន្ទនេះឯង ជាអ្នក សមគួរក្នុងឋានៈទាំងឡាយបែបនេះ ដូច្នេះ ទើបទ្រង់នៅដោយតុណ្ហីភាព ។ ព្រោះហេតុនោះ ទើបព្រះឧបាលីពោលទុកថា អានន្ទបុកបាយអង្ករក្រហម មួយកម្សង់ត្រង់ថ្ម ហើយបង្អោនចូលទៅថ្វាយដល់ព្រះដ៏មានព្រះភាគៗ ក៏ សោយព្រះក្រយាហារដែលបុកថ្វាយនោះ ។

សួរថា ក្នុងវេលាទុរ្ភិក្ស មនុស្សទាំងឡាយកើតការឧស្សាហ៍ ធ្វើបុណ្យ ពន់ពេក សូម្បីខ្លួនក៏មិនបរិភោគ រមែងសម្គាល់របស់ដែលខ្លួនគួរប្រគេនដល់ ពួកភិក្ខុមិនមែនឬ ចុះហេតុអ្វីក្នុងគ្រានោះ ទើបពួកមនុស្សទាំងនោះ មិនបាន ប្រគេនភត្តត្រឹមមួយវែកហ្ន៎ ហើយវេរញ្ជព្រាហ្មណ៍នេះ ក៏បានទូលអារាធនា

ព្រះដ៏មានព្រះភាគ ទ្រង់ចាំវស្សាដោយឧស្សាហៈយ៉ាងធំ ព្រោះហេតុអ្វី ទើបព្រាហ្មណ៍នោះ មិនដឹងសូម្បីភាពដែលព្រះដ៏មានព្រះភាគស្នាក់នៅ ឆ្លើយថាព្រោះត្រូវមារបណ្តាលចិត្ត ។ ពិតហើយ មារបានបណ្តាលចិត្ត គឺធ្វើវេរញ្ជព្រាហ្មណ៍ដែលគ្រាន់តែចៀសចេញទៅ អំពីសម្នាក់ព្រះដ៏មានព្រះភាគប៉ុណ្ណោះ និងអ្នកនគរទាំងអស់ ឲ្យភ្លេចទាំងអស់ រហូតទីមានប្រមាណមួយយោជន៍ដោយជុំវិញ ( ស្រុកវេរញ្ជា ) ដែលជាទីកន្លែងពួកភិក្ខុអាចត្រាច់ទៅបិណ្ឌបាតក្នុងវេលាមុនឆាន់ ហើយត្រឡប់មក បានធ្វើឲ្យពួកមនុស្សទាំងអស់កំណត់មិនបាន ហើយក៏ចៀសទៅ ព្រោះដូច្នោះ ទើបបុគ្គលណាមួយ ក៏មិនបានចាប់ភ្ញាក់នឹកដល់កិច្ចដែលខ្លួនគួរធ្វើ ដោយហោចសូម្បីសាមីចិកម្មក៏គ្មាន ។

សួរថា ព្រះដ៏មានព្រះភាគ ទ្រង់ក៏មិនជ្រាបថា មារនឹងបណ្តាលចិត្តឬ ទើបទ្រង់ចាំវស្សាក្នុងស្រុកវេរញ្ជានោះ ឆ្លើយថា មិនមែនទ្រង់មិនជ្រាបឡើយ សួរថា បើទ្រង់ជ្រាបដូច្នោះ ហេតុអ្វី ទើបទ្រង់មិនចាំវស្សាក្នុងបណ្តានគរឯណាទីមួយ មាននគរចម្ប៉ា សាវត្ថី និងរាជគ្រឹះជាដើម ឆ្លើយថា ព្រោះនគរទាំងឡាយ មាននគរចម្ប៉ា សាវត្ថី និងរាជគ្រឹះជាដើម លើកទុកសិនចុះទោះបីព្រះមានព្រះភាគទ្រង់ទៅកាន់ឧត្តរកុរុទ្វីប ឬត្រៃត្រិង្សបុរី ហើយចាំវស្សាក្នុងឆ្នាំនោះសោត មារក៏គប្បីបណ្តាលចិត្តអ្នកឧត្តរកុរុទ្វីប ឬត្រៃត្រិង្សបុរីនោះបានដែរ ។ បានឮថា មារនោះបានជាបុគ្គលមានចិត្ត ត្រូវអាឃាតចូលរួបរឹតយ៉ាងក្រៃលែងពេញមួយឆ្នាំនោះ ចំណែកក្នុងស្រុកវេរញ្ជានេះ ព្រះដ៏មានព្រះភាគក៏បានទតឃើញហេតុនេះបានយ៉ាងល្អថា ពួកឈ្មួញសេះ នឹងធ្វើការ

សង្គ្រោះភិក្ខុទាំងឡាយ ព្រោះដូច្នោះ ទើបទ្រង់ចាំវស្សាក្នុងស្រុកវេរញ្ជានោះឯង ។

## មារមិនអាចធ្វើអន្តរាយដល់បច្ច័យ ៤ ឋាន

សួរថា មារមិនអាចបណ្ដាលចិត្តពួកឈ្មួញបានឬ ឆ្លើយថា មិនមែនមិនអាច តែព្រោះឈ្មួញទាំងនោះបានមកក្នុងកាលមហាជនត្រូវមារបណ្ដាលចិត្តរួចស្រេចបាច់ហើយ ។ សួរថា ព្រោះហេតុអ្វី ទើបមារមិនត្រឡប់មកបណ្ដាលចិត្តម្ដងទៀត ឆ្លើយថា ព្រោះមិនមែនជាវិស័យ ទើបមិនត្រឡប់មក ។

ពិតហើយ មារនោះ រមែងមិនអាចធ្វើអន្តរាយដល់កត្តដែលបុគ្គលនាំទៅចំពោះព្រះតថាគត ដល់និព្ទទាន ដល់វត្ថុទាន ដែលបុគ្គលកំណត់ថ្វាយទុកហើយ ។ សេចក្ដីពិត បុគ្គលណាក៏ដោយ មិនអាចនឹងធ្វើអន្តរាយដល់បច្ច័យ ៤ បានឡើយ ។ សួរថា ដល់បច្ច័យ ៤ ពួកណា ឆ្លើយថា បុគ្គលណាក៏ដោយ មិនអាចនឹងធ្វើអន្តរាយដល់បច្ច័យ ៤ ទាំងនេះ គឺបុគ្គលណាមិនអាចនឹងធ្វើអន្តរាយដល់និព្ទទាន ដោយសង្ខេបថា កត្តដែលបុគ្គលនាំទៅចំពោះតថាគត ឬដល់បច្ច័យ ៤ ដែលបុគ្គលបរិច្ចាគហើយដល់ព្រះតថាគតដោយសង្ខេបថា វត្ថុទានដែលបុគ្គលកំណត់ថ្វាយទុកហើយ ១ បុគ្គលណាមិនអាចនឹងធ្វើអន្តរាយដល់ព្រះជន្មរបស់ព្រះពុទ្ធទាំងឡាយបាន ១ បុគ្គលណាមិនអាចនឹងធ្វើអន្តរាយដល់អនុព្យញ្ជនៈ ៨០ ឬដល់រស្មីដែលផ្សាយចេញជុំវិញ មួយព្យាមបានឡើយ ។ ពិតហើយ រស្មីនៃព្រះចន្ទ ព្រះអាទិត្យ ទេវតា និងព្រហ្ម លុះទៅដល់ប្រទេសនៃព្រះអនុព្យញ្ជនៈ និងព្រះរស្មីដែលផ្សាយ

ចេញម្ខាងមួយព្យាមរបស់ព្រះតថាគតហើយ ក៏អស់អានុភាពទៅ ១ បុគ្គលណា មិនអាចធ្វើអន្តរាយដល់ព្រះសព្វញ្ញុតញ្ញាណរបស់ព្រះពុទ្ធទាំងឡាយបាន ១ ( រួមជា ៤ យ៉ាងដោយប្រការដូច្នេះ ) ។

ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ព្រះដ៏មានព្រះភាគ ព្រមទាំងព្រះសង្ឃសាវ័ក សោយ និងឆាន់កត្តុដែលមារធ្វើអន្តរាយមិនបានក្នុងគ្រានោះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សោយយ៉ាងនោះ ថ្ងៃមួយ ( ទ្រង់បានឮសំឡេងត្បាល់ ) ។

ត្រើនបទថា **អស្សោសិ ខោ ភគវា ឧទុក្ខលសទ្ទំ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់បានឮសំឡេងត្បាល់ដែលកើតព្រោះអង្រែប៉ះ ( ត្បាល់ ) របស់ពួកភិក្ខុ ដែលបុកបាយក្រៀមអង្ករក្រហមមួយកម្បង់ៗ ។ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពោលពាក្យជាដើម ដែលមានបន្ទាប់អំពីពាក្យនោះយ៉ាងនេះថា ព្រះតថាគតទាំងឡាយ សូម្បីទ្រង់ជ្រាបដូច្នេះ ដើម្បីសម្តែងការធ្វើយ ដែលព្រះដ៏មានព្រះភាគត្រាស់សួរខាងមុខថា ម្នាលអានន្ទ ទុំះសំឡេងត្បាល់ឬហ្ន៎ ក្នុងពាក្យទាំងនោះ មានការពណ៌នាដោយសង្ខេបដូច្នេះថា ធម្មតាព្រះតថាគតទាំងឡាយ កាលទ្រង់ជ្រាបហេតុនៃការសួរដូច្នោះ មានសោតទើបត្រាស់សួរ តែបើហេតុនៃការសួរដូច្នោះមិនមាន សូម្បីទ្រង់ជ្រាប ក៏ទ្រង់មិនសួរ ។ ព្រោះឈ្មោះថា វត្ថុដែលព្រះសម្ពុទ្ធទាំងឡាយទ្រង់មិនជ្រាបមិនមាន ព្រោះដូច្នោះ ទើបលោកមិនពោលពាក្យថា សូម្បីកាលមិនដឹង ។

ត្រើនបទថា **កាលំ វិទិត្វា បុច្ឆន្តិ** សេចក្តីថា បើពេលនៃការត្រាស់

សួរនោះៗ មានសោត ទ្រង់ជ្រាបកាលនោះយ៉ាងនោះហើយ ទើបត្រាស់សួរ បើពេលនៃការត្រាស់សួរនោះមិនមានសោត ទ្រង់ជ្រាបកាលយ៉ាងនោះហើយ ក៏មិនត្រាស់សួរ ។ មា្យ៉ងទៀត ព្រះតថាគតទាំងឡាយ សូម្បីកាលត្រាស់សួរយ៉ាងនោះ រមែងត្រាស់សួរតែពាក្យដែលប្រកបដោយប្រយោជន៍ គឺរមែងត្រាស់សួរចំពោះតែពាក្យដែលអាស្រ័យប្រយោជន៍ អាស្រ័យហេតុប៉ុណ្ណោះ មិនត្រាស់សួរដល់ពាក្យដែលមិនប្រកបដោយប្រយោជន៍ឡើយ ។ ព្រោះហេតុអ្វី ព្រោះព្រះតថាគតទាំងឡាយ ទ្រង់កម្ចាត់ពាក្យដែលមិនប្រកបដោយប្រយោជន៍ចេញបានដោយមគ្គ ឈ្មោះថា **សេតុ។** មគ្គ លោកហៅថា **សេតុ។** មានពាក្យអធិប្បាយទុកថា ការកម្ចាត់ គឺការកាត់ផ្តាច់ដោយល្អនូវពាក្យដូច្នោះដោយមគ្គនោះឯង ។

ឥឡូវនេះ ព្រះឧបាលិត្ថេរ កាលនឹងសម្តែងដល់ព្រះតម្រាស់ដែលអាស្រ័យប្រយោជន៍ គឺព្រះតថាគតទាំងឡាយត្រាស់សួរនោះ ក្នុងបទថា **អត្ថសញ្ហិតំ** នេះ ទើបពោលពាក្យជាដើមថា **ទ្វីហិ អាការេហិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាការេហិ** គឺដោយហេតុទាំងឡាយ ។

ពីរបទថា **ធម្មំ វា ទេសេស្សាម** សេចក្តីថា តថាគតនឹងសម្តែងព្រះសូត្រដែលប្រកបដោយអត្ថុប្បត្តិហេតុ ( គឺរឿងដែលកើតឡើងចំពោះមុខ ) ឬជាតកដែលប្រកបដោយហេតុនៃបុព្វចរិត ( គឺការប្រព្រឹត្តក្នុងជាតិមុន ) ។

ព្រើនបទថា **សាវកានំ វា សិក្ខាបទំ បញ្ញាបេស្សាម** សេចក្តីថា ឬតថាគតនឹងដាក់ទោសដែលកន្លងល្មើសឲ្យប្រាកដដោយការសួរនោះ ហើយ

នឹងបញ្ញត្តសិក្ខាបទ គឺតាំងបទបញ្ញត្តិចូន ឬស្រោលទុកដល់សាវកទាំងឡាយ ។

ក្នុងពាក្យថា **អជ្ជេវ ភគវា ។បេ។ ឯតមត្ថំ អារោចេសិ** នេះ មិនមានពាក្យអ្វីដែលគួរពោលទុកឡើយ ។ ព្រោះថា ព្រះអានន្ទ កាលទូលប្រាប់ការបានបាយក្រៀមអង្ករក្រហមមួយកម្បង់ៗ ភាពជាបុគ្គលអ្នកមានការប្រព្រឹត្តស្រោល និងរួចចាកការចម្អិន ឲ្យឆ្អិនឯង របស់ពួកភិក្ខុ ដែលខ្ញុំពោលហើយក្នុងខាងដើមនោះឯង ហៅថា បានទូលប្រាប់សេចក្តីនោះហើយ ។

ចំណែកព្រះដ៏មានព្រះភាគ កាលទ្រង់ធ្វើឲ្យព្រះអានន្ទរីករាយ ទើបបានត្រាស់ព្រះតម្រាស់នេះថា សាធុសាធុ អានន្ទ កាលទ្រង់ប្រទានសាធុការហើយ កាលទ្រង់នឹងសម្តែងធម៌ រមែងទទួលយកអាការមួយ ក្នុងបណ្តាអាការទាំង ២ ទើបត្រាស់ថា អានន្ទ អ្នកឯងរាល់គ្នាជាសប្បុរស ឈ្នះវិសេសហើយ បណ្តាជនខាងក្រោយ គេនឹងនឹកចង់ឲ្យនូវចង្ហាន់ដែលគេចម្អិនដោយអង្ករស្រូវខ្សាយ ព្រមទាំងម្ហូបលាយដោយសាច់ ដ៏ឆ្ងាញ់ពិសា ( ដល់អ្នករាល់គ្នា ) ។

ក្នុងពាក្យថា **តុម្ហេហិ** ជាដើមនោះ មានអធិប្បាយដូចតទៅនេះថា ( ព្រះដ៏មានព្រះភាគត្រាស់ថា ) ម្នាលអានន្ទ ក្នុងគ្រាទុព្ភិក្ខភ័យ គឺក្នុងគ្រាដែលមានដុំបាយរកបានលំបាកយ៉ាងនេះ ពួកអ្នកជាសប្បុរសឈ្នះវិសេសហើយ ដោយភាពជាអ្នកប្រព្រឹត្តស្រោលបែបនេះ និងដោយធម៌ដែលជាគ្រឿងដុសខាត់នេះ ។

សួរថា ពួកលោកឈ្នះអ្វី ឆ្លើយថា ឈ្នះទុព្ភិក្ខភ័យបាន ឈ្នះសេចក្តី

លោកបាន ឈ្មោះការប្រព្រឹត្តដោយអំណាចនៃសេចក្តីប្រាថ្នាបាន ។ សួរថា ឈ្មោះដូចម្តេច ឆ្លើយថា សូម្បីភិក្ខុមួយអង្គ រមែងមិនមានគំនិត ឬការបង្អៀតបង្អល់ថា ស្រុកវេរញ្ជានេះ មានភត្តរកបានលំបាក តែស្រុក និងនិគម ក្នុងចន្លោះដោយជុំវិញ ( នៃស្រុកវេរញ្ជានេះ ) មានស្រូវឱនចុះដោយធ្ងន់នឹងផ្លែ គឺមានភិក្ខាល្អ មានដុំបាយរកបានដោយងាយ ណ្ហើយចុះ ពួកយើងទៅស្រុក ឬនិគមឯណោះហើយ សឹមឆាន់ សូម្បីបើដូច្នោះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលយកពួកយើងនៅក្នុងស្រុកនេះ ដូច្នេះ ទុព្ភិក្ខភ័យដែលភិក្ខុទាំងនោះឈ្នះបានហើយ គឺគ្របសង្កត់បានហើយ បានដល់ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ ដោយអាការយ៉ាងនេះ ។

សួរថា ឈ្មោះសេចក្តីលោភបានដូចម្តេច ឆ្លើយថា សូម្បីភិក្ខុមួយអង្គ មិនបានធ្វើឲ្យរាត្រីដាច់ ដោយអំណាចនៃលោភៈថា ស្រុកវេរញ្ជានេះ មានភិក្ខារកបានលំបាក ចំណែកស្រុក និងនិគម ក្នុងចន្លោះដោយជុំវិញ មានស្រូវឱនចុះ ដោយការធ្ងន់ គឺផ្លែ បានដល់ មានភិក្ខាល្អ មានដុំបាយរកបានដោយងាយ ណ្ហើយចុះ ពួកយើងនឹងនាំគ្នាទៅឆាន់ឯស្រុក និងនិគមនោះ ឬមិនបានធ្វើឲ្យវស្សាដាច់ ដោយគិតថា ពួកយើងនឹងចូលចាំវស្សាក្នុងស្រុក និងនិគមនោះ ក្នុងវស្សាក្រោយ ដូច្នេះ សេចក្តីលោភដែលភិក្ខុទាំងនោះឈ្នះបានហើយ ដោយប្រការយ៉ាងនេះ ។

សួរថា ឈ្មោះការប្រព្រឹត្តដោយអំណាចនៃការប្រាថ្នាបានដូចម្តេច ឆ្លើយថា សូម្បីភិក្ខុមួយអង្គ មិនបានឲ្យសេចក្តីប្រាថ្នាបែបនេះកើតឡើងឡើយថា

ស្រុកវេរញ្ជានេះ មានភិក្ខាកេបានដោយលំបាក ហើយមនុស្សទាំងឡាយនេះ រមែងមិនសម្គាល់ពួកយើង សូម្បីជាអ្នកស្នាក់នៅអស់ ២-៣ ខែ ក្នុងគុណអ្វីឡើយ ពួកយើងធ្វើការជួញគុណធម៌ ( អួតឧត្តរិមនុស្សធម្ម ) គឺប្រកាសនូវគ្នានឹងគ្នាដល់មនុស្សទាំងឡាយ យ៉ាងនេះថា ភិក្ខុអង្គនោះបានបឋមជ្ឈាន ។បេ។ អង្គនោះបានអភិញ្ញា ៦ ដូច្នេះ ហើយចម្អែតផ្ទៃ ក្រោយមក សឹមអធិដ្ឋានសីល ដូច្នេះ ការប្រព្រឹត្តដោយអំណាចនៃសេចក្តីប្រាថ្នា ដែលភិក្ខុទាំងនោះឈ្នះបានហើយ គឺគ្របសង្កត់បានហើយ ប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ ដោយអាការយ៉ាងនេះ ។

ចំណែកក្នុងអនាគត សព្រហ្មចារីជាន់ក្រោយ អង្គុយក្នុងវិហារហើយ សូម្បីបាន ( ភត្តាហារ ) ដោយសេចក្តីលំបាកត្រឹមបន្តិចបន្តួច ក៏នឹងមើលងាយនូវដុំបាយស្រូវសាលី និងស្រូវខ្សាយ ដែលលាយដោយសាច់ គឺនឹងធ្វើឲ្យជារបស់មើលងាយ គួរតិះដៀល ដោយន័យជាដើមថា បាយស្អីហ្នឹង ជាបាយពងបង្គួយ ជ្រាយពេក មិនប្រៃ ប្រៃពេក មិនជូរ ជូរពេក ប្រយោជន៍អ្វីដោយបាយនេះ ដូច្នេះ ។

ម្យ៉ាងទៀត ( ព្រះដ៏មានព្រះភាគត្រាស់អធិប្បាយទុកថា ) ដែលឈ្មោះថា ជនបទមានភត្តរកបានដោយលំបាកជានិច្ច មិនមាន គឺគ្រាខ្លះ ក៏មានភត្តរកបានដោយលំបាក គ្រាខ្លះ ក៏មានភត្តរកបានងាយ ក្នុងកាលណា ជនបទនេះ នឹងមានភត្តរកបានងាយ ក្នុងកាលនោះ មនុស្សទាំងឡាយជ្រះថ្លាចំពោះបដិបទានេះរបស់ពួកអ្នកជាសប្បុរស ហើយនឹងសម្គាល់នូវបាយដែលចម្អិន

ដោយស្រូវសាលី និងស្រូវខ្សាយ ដែលលាយដោយសាច់ មានប្រការច្រើន យ៉ាង ដោយប្រភេទ មាននំបប និងរបស់ទំពាជាដើម ដែលខ្ញុំទគប្បីប្រគេន ដល់ភិក្ខុទាំងឡាយ បច្ឆិមជនតាជន ពោល គឺមិត្តសព្រហ្មចារីរបស់ពួកអ្នក អង្គុយក្នុងចន្លោះពួកអ្នកហើយ សោយនូវសក្ការៈ ដែលអាស្រ័យពួកអ្នកកើត ឡើងហើយនោះឯង នឹងមើលងាយ នឹងមើលថោក ដែលមានការសោយ សក្ការៈនោះជាបច្ច័យ ។

សួរថា នឹងមើលងាយ មើលថោកដូចម្តេច ឆ្លើយថា នឹងមើលងាយ យ៉ាងនេះថា ហេតុអ្វី ទើបពួកអ្នកចម្អិនបបរ មានប្រមាណប៉ុណ្ណោះទៅវិញ ភាជនៈសម្រាប់ដាក់របស់ពួកអ្នក មិនមានឬ ។

## មហាមោគ្គល្លានសីហនាទកថា

ក្នុងបទទាំងឡាយជាដើមថា **អថខោ អាយស្មា មហាមោគ្គល្លានោ** មានវិនិច្ឆ័យដូច្នេះ បទថា **អាយស្មា** នេះ ជាពាក្យពោលដោយសេចក្តីស្រឡាញ់ បទនេះជាឈ្មោះនៃសេចក្តីគោរព និងការកោតក្រែងដោយឋានៈជាគ្រូ ។ បទថា **មហាមោគ្គល្លានោ** សេចក្តីថា ព្រះថេរៈនោះ ឈ្មោះ **មហា** ដោយភាពជាបុគ្គលមានគុណធំ និងឈ្មោះថា **មហាមោគ្គល្លាន** ដោយគោត្រ ព្រោះហេតុនោះ ទើបព្រះថេរៈនោះ ឈ្មោះថា **មហាមោគ្គល្លាន**។

បទថា **ឯតទវោច** សេចក្តីថា ព្រះមហាមោគ្គល្លានបានទូលក្រាបទូលពាក្យនេះ ( នឹងព្រះដ៏មានព្រះភាគ ) គឺសម្តែងពាក្យជាដើម ដែលខ្លួនគួរក្រាបទូលក្នុងកាលឥឡូវនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ( ស្រុកវេរញ្ជា មានភិក្ខារកបានលំបាក ) ដូច្នេះ ។

សួរថា ព្រះមហាមោគ្គល្លានបានក្រាបទូល ( ពាក្យនេះ ) ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបានឮថា ព្រះថេរៈបួសហើយក្នុងថ្ងៃទី ៧ ទើបបានដល់ទីបំផុតនៃសាវកបារមីញាណ សូម្បីព្រះសាស្តាទ្រង់ក៏តាំងលោកទុកក្នុងតំណែងឯតទគ្គៈ ព្រោះលោកជាអ្នកមានឫទ្ធិច្រើន ។ ព្រះថេរៈនោះ អាស្រ័យភាពដែលខ្លួនមានឫទ្ធិច្រើននោះ ទើបត្រិះរិះថា ស្រុកវេរញ្ជានេះ មានអាហាររកបានលំបាកផង ភិក្ខុទាំងឡាយក៏រមែងលំបាកផង បើដូច្នោះ អញនឹងត្រឡប់ផែនដី ហើយឲ្យភិក្ខុទាំងឡាយឆាន់ក្រមរផែនដី ។ គ្រានោះ លោកមានការរំពឹងដូច្នេះថា អាត្មាអញ នៅក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ បើមិនទូលសូមព្រះដ៏មានព្រះភាគ ហើយគប្បីធ្វើយ៉ាងនោះសោត សេចក្តីនោះមិន

សមគួរដល់អញឡើយ ហាក់បីដូចជាការប្រណាំងប្រជែង ដែលអញធ្វើជាមួយព្រះដ៏មានព្រះភាគ ព្រោះដូច្នោះ ព្រះថេរៈមានបំណង នឹងទូលសូម ទើបក្រាបទូលពាក្យនោះជាមួយនឹងព្រះដ៏មានព្រះភាគ ។

ពីរបទថា **ហេដ្ឋិមតលំ សម្បន្នំ** សេចក្តីថា បានឮថា ព្រះថេរៈពោលសំដៅយកក្រមរដី ឱជាដី ស្រទាប់នៃផែនដី ដែលមាននៅខាងក្រោមនៃផែនដី ។ បណ្តាបទទាំងនោះ បទថា **សម្បន្នំ** ប្រែថា មានរសផ្អែម អធិប្បាយថា មានរសល្អ ។ ដូចក្នុងប្រយោគនេះថា ដើមឈើមានផ្លែសម្បូរ និងមានផ្លែកើតហើយ គប្បីមានក្នុងទឹកន្លែងនោះ ដូច្នេះ គប្បីជ្រាបអត្ថថា មានផ្លែឆ្ងាញ់ យ៉ាងណា ក្នុងអធិការនេះ ក៏ដូច្នោះ បណ្ឌិតគប្បីជ្រាបអត្ថនៃបទថា **សម្បន្នំ** នេះថា មានរសផ្អែម គឺរសល្អ ។

ចំណែកពាក្យថា **សេយ្យថាបិ ខុទ្ទកមធុ អនីលកំ** នេះ ព្រះថេរៈពោលហើយ ក៏ដើម្បីសម្តែងការឧបមា ព្រោះផ្ទៃខាងក្រោមនៃផែនដីនោះ ជាធម្មជាតិមានរសផ្អែម ។ ទឹកផ្អែមដែលមេឃ្មុំតូចៗ ធ្វើទុកហើយ ឈ្មោះថា ខុទ្ទកមធុ ( ទឹកឃ្មុំផ្អិត ) ។

បទថា **អនីលកំ** ប្រែថា មិនមានមេ គឺមិនមានកូន បានដល់ ទឹកឃ្មុំដែលបរិសុទ្ធ ។ បានឮថា ទឹកឃ្មុំនោះជារបស់លើស ប្រសើរ មានរសល្អ និងមានឱជាជាងទឹកដែលផ្អែមទាំងអស់ ព្រោះហេតុនោះ ទើបព្រះថេរៈពោលថា **សេយ្យថាបិ ខុទ្ទកមធុ អនីលកំ ឯវមស្សាទំ** ប្រែថា ( ជាទីពេញចិត្ត ដូចទឹកឃ្មុំផ្អិតដែលមិនមានមេ ដូច្នេះ ) ដូច្នេះជាដើម ។

ប្រជុំបទជាច្រើនថា **សាធាហំ ភន្តេ** កាត់បទជា **សាធុ អហំ ភន្តេ** ប្រែថា បពិត្រព្រះអង្គ សូមប្រទានព្រះវរោកាសដល់ខ្ញុំព្រះអង្គ ( ដើម្បីត្រឡប់ផែនដី ) ។

បទថា **សាធុ** នោះ ដែលមាននៅក្នុងបទថា **សាធាហំ** នេះ ជាពាក្យក្រាបទូលសូម ។ ពិតហើយ ព្រះថេរៈ កាលនឹងក្រាបទូលសូមអនុញ្ញាតការត្រឡប់ផែនដី ទើបបានក្រាបទូលជាមួយព្រះដ៏មានព្រះភាគយ៉ាងនោះ ។

បទថា **បរិវត្តេយ្យំ** សេចក្តីថា គប្បីផ្ងារឡើង គឺគប្បីធ្វើផ្ទៃខាងក្រោមឲ្យត្រឡប់ឡើងខាងលើ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈត្រូវធ្វើយ៉ាងនោះ ឆ្លើយថា ព្រោះកាលព្រះថេរៈធ្វើយ៉ាងនោះហើយ ភិក្ខុទាំងឡាយនឹងបានឆាន់ស្រទាប់ផែនដី គឺក្រមរផែនដីដោយស្រួល ។

គ្រានោះ ព្រះដ៏មានព្រះភាគ សូម្បីមានព្រះបំណងមិនអនុញ្ញាតក៏ដោយ តែដើម្បីឲ្យព្រះថេរៈបន្លឺសីហនាទ ទើបត្រាស់សួរថា មោគ្គល្លាន អ្នកនឹងធ្វើសត្វដែលអាស្រ័យផែនដីទុកដូចម្តេច ត្រាស់អធិប្បាយទុកថា សត្វទាំង-ឡាយក្នុងស្រុក និងនិគមជាដើម ពួកណាអាស្រ័យផែនដី កាលអ្នកត្រឡប់ផែនដី អ្នកនឹងធ្វើសត្វទាំងនោះ ដែលមិនអាចតាំងនៅក្នុងអាកាសបានដូចម្តេច គឺនឹងដាក់ក្នុងស្ថានទីឯណា ។

គ្រានោះ ព្រះថេរៈ កាលនឹងប្រកាសឥទ្ធានុភាពរបស់ខ្លួន ដែលសមគួរដល់ភាពនៃខ្លួន ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកក្នុងតំណែងឯតទគ្គៈ ទើបបានក្រាបទូលថា **ឯកាហំ ភន្តេ** ជាដើម ។

អត្ថនៃពាក្យថា **ឯកាហំ ភន្តេ** ជាដើមនោះ ដូច្នេះថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងនិម្មិតដៃម្ខាង ដូចផែនដីធំនេះ គឺនឹងធ្វើឲ្យដូចគ្នានឹងផែនដី កាលខ្ញុំព្រះអង្គធ្វើយ៉ាងនោះហើយ នឹងធ្វើពួកសត្វដែលអាស្រ័យផែនដីទុកលើដៃនោះ ដូចធ្វើឲ្យសត្វដែលតាំងនៅហើយ លើបាតដៃម្ខាងនោះ ដាក់លើបាតដៃម្ខាងទៀត ដូច្នោះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ជំទាស់ការទូលសូមរបស់ព្រះថេរៈនោះ ទើបត្រាស់ពាក្យជាដើមថា កុំឡើយមោគ្គល្លាន ។

បណ្តាបទទាំងនោះ បទថា **អលំ** ជាព្រះតម្រាស់ដែលត្រាស់បដិសេធ។

ច្រើនបទថា **វិបល្លាសម្បិ សត្តា បដិលភេយ្យុំ** សេចក្តីថា សត្វទាំងឡាយ គប្បីចូលដល់ការកាន់យកដោយឃៀងឃ្លាតទៅ ។

សួរថា គប្បីកាន់យកដោយឃៀងឃ្លាតដូចម្តេច ឆ្លើយថា កាន់យកយ៉ាងនេះ គឺនេះជាផែនដី ឬមិនមែនផែនដីហ្ន៎ ម្យ៉ាងទៀត គប្បីដល់នូវការកាន់យកដោយឃៀងឃ្លាត ដែលផ្ទុយគ្នាយ៉ាងនេះ គឺនេះជាស្រុករបស់ពួកយើង ឬជាស្រុករបស់អ្នកដទៃហ្ន៎ ។ ក្នុងនិគម ជនបទ ស្រែ និងចម្ការជាដើម ក៏មានន័យដូចពោលមកហើយនោះ ។

ម្យ៉ាងទៀត នុ៎ះមិនមែនវិបល្លាស ព្រោះថា ឥទ្ធិវិស័យរបស់លោកអ្នកមានឫទ្ធិជាអចិន្តេយ្យ ។ ចំណែកមនុស្សទាំងឡាយ គប្បីទទួលនូវការយល់ខុសយ៉ាងនេះថា ដែលឈ្មោះថា ទុព្ភិក្ខភ័យនេះ មិនមែនមានតែក្នុងកាលឥឡូវនេះប៉ុណ្ណោះឡើយ សូម្បីក្នុងអនាគតក៏នឹងមាន ក្នុងកាលនោះ

ភិក្ខុទាំងឡាយនឹងបានមិត្តសព្រហ្មចារី ដែលមានឫទ្ធិដូច្នោះអំពីទីណា លោកទាំងនោះ ជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះសុក្ខវិបស្សកៈ អ្នកដែលបានឈាន អ្នកដែលសម្រេចបដិសម្ភិទា សូម្បីព្រះខីណាស្រពក៏មាន នឹងចូលទៅបិណ្ឌបាតកាន់ត្រកូលដទៃ ព្រោះមិនមានកម្លាំងនៃឫទ្ធិ ការត្រិះរិះយ៉ាងនេះរបស់មនុស្សទាំងឡាយ នឹងមានឡើងក្នុងភិក្ខុទាំងនោះថា ក្នុងសម័យពុទ្ធកាល ភិក្ខុទាំងឡាយបានជាបុគ្គលបំពេញឲ្យបរិបូណ៌នូវសិក្ខាទាំង-ឡាយហើយ លោកទាំងនោះ បានឲ្យគុណទាំងឡាយកើតឡើងហើយ ក្នុងគ្រាទុព្ភិក្ខភ័យ ក៏បានត្រឡប់ផែនដី ហើយឆាន់ក្រមរដី តែឥឡូវនេះ លោកអ្នកបំពេញឲ្យបរិបូណ៌ក្នុងសិក្ខា រមែងមិនមាន បើនឹងគប្បីមានសោត ក៏គប្បីនឹងធ្វើយ៉ាងនោះឯង ដោយគិតថា មនុស្សទាំងឡាយ មិនគប្បីប្រគេនបិណ្ឌបាតដែលឆ្អិន ឬឆៅឯណានីមួយដល់ពួកយើង ដើម្បីទំពា ដូច្នេះ ព្រោះការត្រិះរិះដូចពោលមកនេះ មនុស្សទាំងនោះ គប្បីបានវិបល្លាស ( ការយល់ឃ្លៀងឃ្លាត ) នេះ ក្នុងព្រះអរិយបុគ្គលទាំងឡាយ ដែលមាននៅនោះឯងថា ព្រះអរិយបុគ្គលទាំងឡាយមិនមាន ឯមនុស្សទាំងឡាយដែលប្រមាទនូវព្រះអរិយបុគ្គលទាំងឡាយ ដោយអំណាចវិបល្លាស នឹងគប្បីជាអ្នកចូលដល់អបាយ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ការត្រឡប់ផែនដីអ្នកកុំពេញចិត្តឡើយ ដូច្នេះ ។

លំដាប់នោះ ព្រះថេរៈ កាលទូលសូមរឿងនេះមិនបាន នឹងទូលសូមរឿងដទៃ ទើបបានក្រាបទូលពាក្យជាដើមថា សាធុ ព្រះអង្គ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់ជំទាស់ពាក្យទូលសូមនោះរបស់ព្រះថេរៈ ទើបត្រាស់ពាក្យជាដើមថា កុំឡើយមោគ្គល្លាន ។

ពាក្យថា **សត្វទាំងឡាយ គប្បីបានទទួលនូវវិបល្លាស** ដូច្នេះ ព្រះដ៏មានព្រះភាគមិនបានត្រាស់ទុកក្នុងពាក្យថា កុំឡើយមោគ្គល្លាន ដូច្នោះជាដើម ក៏ពិត តែបណ្ឌិតក៏គួរកាន់យក ដោយន័យដូចពោលមកហើយខាងដើមនោះ។ ម្យ៉ាងទៀត សូម្បីអត្ថនៃពាក្យទាំងនោះ ក៏គួរជ្រាបដូចពោលមកហើយនោះ ។

សួរថា បើព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតសោត ព្រះថេរៈគប្បីធ្វើដូចម្តេច ឆ្លើយថា ព្រះថេរៈគប្បីអធិដ្ឋានមហាសមុទ្រ ឲ្យមានទំហំប៉ុនប្រឡាយដែលនឹងគប្បីឆ្លងដោយជំហានមួយ ហើយលើកផ្លូវអំពីដើមស្តៅ ដែលនឡេរុយក្ខអាស្រ័យនៅ បែរមុខទៅកាន់ឧត្តរកុរុទ្វីប ហើយសម្តែងឧត្តរកុរុទ្វីបក្នុងទីដែលសម្បូរដោយការទៅ និងការមក ឲ្យភិក្ខុទាំងឡាយចូលទៅបិណ្ឌបាត ហើយចេញទៅបានតាមសប្បាយ ដូចគេទៅកាន់គោចរគ្រាមដូច្នោះ ។

សីហនាទកថារបស់ព្រះមហាមោគ្គល្លាន ចប់

# ប្រស្នារបស់ព្រះសារីបុត្រ

[ ៧ ] ឥឡូវនេះ ព្រះឧបាលី កាលនឹងសម្ដែងការដែលព្រះសារីបុត្រកើតបរិវិតក្កៈ ដែលបដិសំយុត្តដោយសិក្ខាបទ ដើម្បីសម្ដែងនិទាន តាំងអំពីដើមនៃការទ្រង់បញ្ញត្តព្រះវិន័យ ទើបបានពោលពាក្យជាដើមថា **អថខោ អាយស្មតោ សារីបុត្តស្ស** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រហោគតស្ស** ប្រែថា ទៅហើយក្នុងទីស្ងាត់ ។ បទថា **បដិសល្លីនស្ស** ប្រែថា ពួនសម្ងំ គឺដល់នូវភាពជាបុគ្គលម្នាក់ឯង ។

បទថា **កតមេសានំ** សេចក្ដីថា បណ្ដាព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីសម្ពុទ្ធជាដើម ដែលកន្លងទៅហើយរបស់ព្រះពុទ្ធអង្គណា ។ ព្រហ្មចរិយៈឈ្មោះថា តាំងនៅយូរ ព្រោះអត្ថថា ព្រហ្មចរិយៈនោះ តាំងនៅរហូតអស់កាលយូរ ឬមានការតាំងនៅយូរ ។ ពាក្យដ៏សេសក្នុងបទថា **អថខោ អយស្មតោ** ជាដើមនេះ មានអត្ថងាយយល់ទាំងអស់ហើយយ៉ាងនោះ ។

សួរថា ព្រះថេរៈមិនអាចវិនិច្ឆ័យបរិវិតក្កៈរបស់ខ្លួននេះ ដោយខ្លួនឯងឬ ខ្ញុំនឹងឆ្លើយតទៅថា ព្រះថេរៈ ទាំងអាច ទាំងមិនអាច ពិតហើយ ព្រះសារីបុត្តត្ថេរនេះ រមែងអាចវិនិច្ឆ័យហេតុមានប្រមាណប៉ុណ្ណោះបាន គឺធម្មតាសាសនារបស់ព្រះពុទ្ធអង្គនោះៗ តាំងនៅមិនបានយូរ របស់ព្រះពុទ្ធអង្គនោះៗ តាំងនៅបានយូរ តែលោកមិនអាចវិនិច្ឆ័យហេតុនោះថា សាសនាតាំងនៅមិនបានយូរព្រោះហេតុនេះ តាំងនៅបានយូរព្រោះហេតុនេះ ដូច្នេះ ។

ចំណែកព្រះមហាបទុមត្ថេរពោលទុកថា ហេតុការណ៍នោះ ជារបស់

មិនធ្ងន់ដល់ព្រះអគ្គសាវក ដែលបានដល់នូវទីបំផុតនៃបញ្ញា ១៦ យ៉ាងឡើយ ចំណែកព្រះអគ្គសាវកដែលនៅក្នុងទីកន្លែងជាមួយព្រះសម្មាសម្ពុទ្ធ ធ្វើការវិនិច្ឆ័យខ្លួនឯង ក៏ដូចជាការលះបង់ជញ្ជីង ហើយថ្លឹងដោយដៃ ដូច្នោះ ព្រោះហេតុនោះ ទើបព្រះថេរៈចូលទៅទូលសួរព្រះដ៏មានព្រះភាគនោះឯង ។ បន្ទាប់អំពីនោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់វិសជ្ជនាពាក្យទូលសួររបស់ព្រះថេរៈនោះ ដោយព្រះតម្រាស់ថា **ភគវតោ ច សារីបុត្ត វិបស្សិស្ស** ជាដើម ដូច្នេះ ។ ពាក្យនេះមានអត្ថងាយហើយ ។

ព្រះថេរៈ កាលនឹងទូលសួរដល់ហេតុការណ៍តទៅទៀត ទើបបានក្រាបទូលពាក្យថា **កោ នុ ខោ ភន្តេ ហេតុ** ជាដើម ( ដែលប្រែថា អ្វីហ្ន៎ជាហេតុព្រះអង្គ ) ។ បណ្ដាបទទាំងនោះ បទថា **កោ នុ ខោ ភន្តេ** ជាពាក្យទូលសួរដល់ហេតុការណ៍ ។ អត្ថនៃបទនោះថា ហេតុដូចម្ដេចហ្ន៎ ព្រះអង្គ ។

ពាក្យទាំងពីរនេះ គឺ **ហេតុ បច្ចយោ** ជាឈ្មោះនៃការណ៍ ពិតហើយការណ៍ លោកហៅថា ហេតុ ព្រោះជាគ្រឿងហូរចេញ គឺប្រព្រឹត្តទៅនៃផលរបស់ហេតុនោះ ។ ព្រោះផលអាស្រ័យហេតុនោះហើយ ទើបមានដំណើរទៅ គឺទើបប្រព្រឹត្តទៅបាន ដូច្នោះ ទើបលោកហៅថា **បច្ច័យ** ។ បទទាំងពីរនេះក្នុងទីនោះៗ ជាបទតែមួយដោយអត្ថ ព្រះថេរៈក៏ពោលទុកដោយអំណាចនៃវោហារ និងដោយការពីរោះរណ្ដំនៃពាក្យ ដែលពោលមកហើយនោះ ។ ពាក្យដ៏សេសក្នុងពាក្យថា **កោ នុ ខោ** ជាដើមនេះ ក៏មានអត្ថរាក់ហើយ ។

ដើម្បីសម្ដែងហេតុ និងបច្ច័យនោះ ឥឡូវនេះ ទើបព្រះដ៏មានព្រះភាគ

ត្រាស់ពាក្យថា **សារីបុត្ត វិបស្សី** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **កិលាសុនោ អហេសុំ** សេចក្ដីថា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីសម្ពុទ្ធជាដើម ទ្រង់មិនយកព្រះទ័យទុកដាក់ ព្រោះការខ្ជិលច្រអូសក៏ទេ ។ ពិតហើយ ការខ្ជិលច្រអូសក្ដី ការមានព្រះវិរិយភាពធូរថយក្ដីនៃព្រះពុទ្ធទាំងឡាយ រមែងមិនមាន ។ ព្រោះថា ព្រះពុទ្ធទាំងឡាយកាលទ្រង់សម្ដែងធម៌ដល់ចក្រវាលមួយក្ដី ពីរចក្រវាលក្ដី ចក្រវាលទាំងអស់ក្ដី ទ្រង់រមែងសម្ដែងដោយឧស្សាហៈស្មើគ្នានោះឯង កាលទតឃើញបរិស័ទមានចំនួនតិចហើយ ទ្រង់បន្ថយវិរិយភាពចុះក៏ទេ សូម្បីទ្រង់ទតឃើញបរិស័ទមានចំនួនច្រើនហើយ ទ្រង់មានវិរិយភាពច្រើនឡើងក៏ទេ ។ ដូចសីហមិគរាជកន្ទុំង ៧ ថ្ងៃ ទើបចេញរកអាហារ កាលឃើញ សត្វតូច ឬធំក៏ដោយ រមែងស្ទុះទៅដោយកម្លាំងរហ័ស ដូចគ្នាជានិច្ច សេចក្ដីនោះ ព្រោះហេតុអ្វី ព្រោះការដាក់ចិត្តថា សន្ទុះរបស់អញកុំវិនាសទៅឡើយ ដូច្នេះ យ៉ាងណា ព្រះពុទ្ធទាំងឡាយក៏យ៉ាងនោះ ទ្រង់រមែងសម្ដែងធម៌ដល់បរិស័ទ ទោះមានចំនួនតិច ឬច្រើនក៏ដោយ ដោយឧស្សាហៈស្មើគ្នាទាំងអស់ សេចក្ដីនោះព្រោះហេតុអ្វី ព្រោះទ្រង់ដាក់ព្រះទ័យថា ពួកជនដែលធ្ងន់ក្នុងធម៌របស់តថាគតកុំបានវិនាសទៅ ដូច្នេះ ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់ធ្ងន់ក្នុងធម៌ ទ្រង់គោរពព្រះធម៌នោះឯង ដូចព្រះដ៏មានព្រះភាគនៃយើងទាំងឡាយ ទ្រង់បានសម្ដែងធម៌ដោយពិស្ដារ ដូច ( វលាហកទេវតា ) ញុំាំងមហាសមុទ្រឲ្យពេញ យ៉ាងណា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីជាដើមនោះ មិនមែន

សម្តែងធម៌ដូច្នោះឡើយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសត្វទាំងឡាយ មានធូលី គឺកិលេសក្នុងបញ្ញាចក្ខុតិច ស្រាលស្តើង ។

បានឮមកថា ក្នុងកាលនៃព្រះពុទ្ធទាំងនោះ សត្វទាំងឡាយមានអាយុយឺនយូរ ជាអ្នកមានធូលី គឺកិលេសក្នុងភ្នែកតិច ។ សត្វទាំងនោះ លុះបានស្តាប់មួយព្រះគាថា ដែលប្រកបដោយសច្ចៈ ៤ រមែងត្រាស់ដឹងធម៌បាន ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងនោះ ទ្រង់មិនសម្តែងធម៌ដោយពិស្តារ ។ ព្រោះហេតុនោះ នវង្គសត្ថុសាសនៈរបស់ព្រះពុទ្ធទាំងនោះ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តក ជាតក អព្ភូតធម្ម វេទល្លៈ ទើបមានតិច ។ ភាពដែលនវង្គសត្ថុសាសនៈ មានសុត្តៈជាដើម ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងពាក្យថា **អប្បកញ្ច** ជាដើមនោះផ្សេងៗ គ្នា ខ្ញុំបានពោលទុកហើយ ក្នុងបឋមសង្គីតិវណ្ណនានោះឯង ។

## ព្រះវិបស្សីជាដើមទ្រង់មិនបានបញ្ញត្តសិក្ខាបទ

ត្រើនបទថា **អប្បញ្ញត្តំ សាវកានំ សិក្ខាបទំ** សេចក្តីថា សិក្ខាបទ គឺការហាមប្រាម ដោយអាបត្តិ ៧ កង ដែលទ្រង់គួរបញ្ញត្ត ដោយសមគួរដល់ទោស ដែលព្រះពុទ្ធ មានព្រះវិបស្សីជាដើមទាំងនោះ ទ្រង់មិនបានបញ្ញត្តទុកដល់សាវកទាំងឡាយ ព្រោះជាបុគ្គលមិនមានទោស ។

ពីរបទថា **អនុទ្ទិដ្ឋំ បាតិមោក្ខំ** សេចក្តីថា បាតិមោក្ខ គឺបញ្ញត្តិ ទ្រង់ក៏មិនបានសម្តែងរាល់កន្លះខែ ។ ព្រះពុទ្ធទាំងនោះ ទ្រង់បានសម្តែងចំពោះឱវាទ-

ប្បាតិមោក្ខប៉ុណ្ណោះ ហើយសូម្បីឱវាទប្បាតិមោក្ខនោះ ក៏មិនបានសម្តែងរាល់កន្ទះខែដែរ ។ ពិតហើយ ព្រះដ៏មានព្រះភាគវិបស្សី ទ្រង់សម្តែងឱវាទ-ប្បាតិមោក្ខរាល់ ៦ ឆ្នាំម្តង ឯឱវាទប្បាតិមោក្ខនោះ ទ្រង់សម្តែងដោយព្រះអង្គឯងប៉ុណ្ណោះ ។ ចំណែកពួកសាវ័ករបស់ព្រះអង្គ មិនបានសម្តែងក្នុងលំនៅរៀងៗខ្លួន ភិក្ខុសង្ឃទាំងអស់ក្នុងសកលជម្ពូទ្វីប ធ្វើឧបោសថ ក្នុងទីកន្លែងមួយប៉ុណ្ណោះ គឺក្នុងឧទ្យានខេមមិគទាយវ័ន ជិតរាជធានី ឈ្មោះពន្ធុមតី ដែលជាទីទ្រង់ប្រថាប់នៃព្រះដ៏មានព្រះភាគវិបស្សី ។ ឯឧបោសថនោះ បានធ្វើជាសង្ឃុបោសថតែម្យ៉ាង មិនបានធ្វើជាគណៈឧបោសថ បុគ្គលឧបោសថ បារិសុទ្ធិ-ឧបោសថ អធិដ្ឋានឧបោសថឡើយ បានឮថា ក្នុងកាលនោះ ក្នុងជម្ពូទ្វីបមានវិហារ ៨៤០០០ កន្លែង ក្នុងវិហារមួយកន្លែង មានភិក្ខុនៅកុះករ មួយវិហារមួយម៉ឺនអង្គខ្លះ ពីរម៉ឺនអង្គខ្លះ បីម៉ឺនអង្គខ្លះ ច្រើនជាងនេះខ្លះ ។

ពួកទេវតាដែលប្រាប់ថ្ងៃឧបោសថ ត្រាច់ទៅប្រាប់ក្នុងទីនោះៗ ថា លោកនិទ្ទុក្ខទាំងឡាយ កន្លងទៅហើយមួយឆ្នាំ កន្លងទៅហើយពីរឆ្នាំ បីឆ្នាំ បួនឆ្នាំ ប្រាំឆ្នាំ នេះជាឆ្នាំទីប្រាំមួយ កាលតិថីពេញបូណ៌មីមកដល់ ពួកលោកគួរទៅដើម្បីគាល់ព្រះសម្ពុទ្ធ និងដើម្បីធ្វើឧបោសថ កាលប្រជុំរបស់ពួកលោកមកដល់ហើយ ក្នុងវេលានោះ ពួកភិក្ខុដែលមានអានុភាព ក៏ទៅដោយអានុភាពរបស់ខ្លួន ភិក្ខុក្រៅអំពីនេះ ទៅដោយអានុភាពរបស់ទេវតា ។

សួរថា ភិក្ខុក្រៅអំពីនេះ ទៅដោយអានុភាពរបស់ទេវតាបានដូចម្តេច ឆ្លើយថា បានឮថា ភិក្ខុទាំងនោះ នៅជិតសមុទ្រទិសខាងកើត ឬជិតសមុទ្រ

ទិសខាងលិច ខាងជើង និងខាងត្បូង បំពេញគមិយវត្ត ហើយកាន់យកបាត្រ និងចីវរ ញុំាងគំនិតឲ្យកើតឡើងថា អញនឹងទៅ ។ ព្រមដោយចិត្តប្បាទ ពួកភិក្ខុក៏ទៅដល់រោងឧបោសថតែម្តង ។ ពួកភិក្ខុថ្វាយ អភិវាទព្រះវិបស្សីសម្ពុទ្ធ ហើយ អង្គុយក្នុងទីមួយ ។

## ឱវាទបាដិមោក្ខគាថា

ព្រះដ៏មានព្រះភាគ ទ្រង់ក៏សម្តែងឱវាទបាដិមោក្ខនេះ ក្នុងបរិស័ទដែលគង់ប្រជុំគ្នាហើយថា

អធិវាសនខន្តិ ពោលគឺ សេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយ តែងត្រាស់ថា ព្រះនិព្វានជាធម៌ដ៏ឧត្តម បព្វជិតអ្នកសម្លាប់សត្វដទៃ បៀតបៀនសត្វដទៃ មិនឈ្មោះថា សមណៈឡើយ ។

ការមិនធ្វើអំពើបាបទាំងពួង ការបំពេញកុសល ការញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ ទាំង ៣ នេះ ជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

ការមិនពោលតិះដៀល ការមិនបៀតបៀន ការសង្រួមក្នុងបាតិមោក្ខ ការៈជាអ្នកដឹងប្រមាណក្នុងភត្ត ទីដេក ទីអង្គុយដ៏ស្ងាត់ ការបំពេញព្យាយាមក្នុងអធិចិត្ត ទាំង ៦ នេះ ជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ(១) ។

---

១- ឋិ. ១៦ មហាបទានសូត្រ ។

គប្បីជ្រាបបាតិមោក្ខុទ្ទេសរបស់ព្រះពុទ្ធទាំងឡាយ ក្រៅអំពីនេះ ដោយឧបាយនេះឯង ។ ពិតហើយ ព្រះពុទ្ធគ្រប់អង្គ មានឱវាទបា្បតិមោក្ខគាថាត្រឹម ៣ គាថានេះប៉ុណ្ណោះ ។ គាថាទាំងនោះ រមែងមកកាន់ឧទ្ទេស រហូតដល់ទីបំផុតនៃសាសនារបស់ព្រះសម្ពុទ្ធ ដែលមានព្រះជន្មាយុយឺនយូរទាំងឡាយ ។ តែសម្រាប់ព្រះសម្ពុទ្ធដែលមានព្រះជន្មាយុតិចទាំងឡាយ គាថាទាំងនោះមកកាន់ឧទ្ទេសចំពោះក្នុងបឋមពោធិកាលប៉ុណ្ណោះ ។ ព្រោះថា តាំងអំពីពេលទ្រង់បញ្ញត្តសិក្ខាបទមក ក៏សម្តែងចំពោះអាណាបាតិមោក្ខប៉ុណ្ណោះ។ ឯអាណាបាតិមោក្ខនោះ ពួកភិក្ខុប៉ុណ្ណោះសម្តែង ព្រះពុទ្ធទាំងឡាយ មិនសម្តែងឡើយ ។ ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគនៃយើង ទ្រង់សម្តែងឱវាទបា្បតិមោក្ខនេះអស់កាលវេលាត្រឹម ២០ ឆ្នាំ ក្នុងបឋមពោធិកាលប៉ុណ្ណោះ ។

បន្ទាប់មក ថ្ងៃមួយ ព្រះដ៏មានព្រះភាគប្រថាប់គង់នៅឯប្រាសាទរបស់មិគារមាតាក្នុងបុព្វារាម បានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ចាប់ផ្តើមអំពីថ្ងៃនេះតទៅមុខ ចូរអ្នកទាំងឡាយនាំគ្នាធ្វើឧបោសថ សម្តែងបាតិមោក្ខចុះ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងធ្វើឧបោសថ សម្តែងបាតិមោក្ខជាមួយនឹងបរិស័ទ មិនបរិសុទ្ធ ដោយហេតុណាហេតុនុ៎ះ មិនមែនជាទីតាំង មិនមែនជាឱកាស[១] ( ល្មមនឹងធ្វើបានទេ ) ។

តាំងអំពីនោះមក ពួកភិក្ខុក៏សម្តែងអាណាបាតិមោក្ខ ។ អាណាបាតិមោក្ខនេះ ជារបស់ដែលព្រះពុទ្ធ ៣ អង្គ មានព្រះវិបស្សីជាដើម ទ្រង់មិន

---

១- បិ. ១១ បាតិមោក្ខដ្ឋបនក្ខន្ធកៈ ។

លើកឡើងសម្ដែងដល់ភិក្ខុទាំងនោះទេ ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **អនុទ្ទិដ្ឋំ បាតិមោក្ខំ** ។

ពាក្យថា **តេសំ ពុទ្ធានំ** សេចក្ដីថា នៃព្រះពុទ្ធទាំង ៣ អង្គ មានព្រះវិបស្សីជាដើមនោះ ។ បទថា **អន្តរធានេន** គឺព្រោះខន្ធអន្តរធានទៅ អធិប្បាយថា ព្រោះបរិនិព្វាន ។ បទថា **ពុទ្ធានុពុទ្ធានំ** សេចក្ដីថា ព្រោះការអន្តរធានទៅនៃខន្ធរបស់សាវកទាំងឡាយ ដែលបានត្រាស់ដឹងតាមព្រះពុទ្ធទាំងនោះ គឺសាវកដែលទាន់ព្រះសាស្ដា ។ ពាក្យថា **យេ តេ បច្ឆិមា សាវកា** សេចក្ដីថា បច្ឆិមសាវកទាំងឡាយ ដែលបួសក្នុងសម្នាក់របស់ពួកសាវកដែលទាន់ព្រះសាស្ដា ។ បទថា **នានានាមា** សេចក្ដីថា មានឈ្មោះផ្សេងៗគ្នា ដោយអំណាចឈ្មោះថា ពុទ្ធរក្ខិតៈ ធម្មរក្ខិតៈ សង្ឃរក្ខិតៈជាដើម ។ បទថា **នានាគោត្តា** សេចក្ដីថា មានគោត្រផ្សេងៗ គ្នា ដោយអំណាចគោត្រ មានគោតម មោគ្គល្លាន ជាដើម ។ បទថា **នានាជច្ចា** គឺមានជាតិផ្សេងៗ គ្នា ដោយអំណាចជាតិ មានក្សត្រ ព្រាហ្មណ៍ជាដើម ។ ពីរបទថា **នានាកុលា បព្វជិតា** សេចក្ដីថា ចេញបួសអំពីត្រកូលផ្សេងៗ គ្នា ដោយអំណាចត្រកូលក្សត្រជាដើម ឬដោយអំណាចត្រកូល មានត្រកូលខ្ពស់ត្រកូលទាប ត្រកូលមានភោគៈស្ដុកស្ដម្ភ និងមិនស្ដុកស្ដម្ភជាដើម ។ បទថា **តេ តំ ព្រហ្មចរិយំ** សេចក្ដីថា ព្រោះបច្ឆិមសាវកទាំងនោះ ធ្វើទុកក្នុងចិត្តថា ពួកអញមានឈ្មោះដូចគ្នា មានគោត្រដូចគ្នា មានជាតិដូចគ្នា បួសអំពីត្រកូលដូចគ្នា សាសនាបែបផែនប្រពៃណីរបស់ពួកអញ ទើបជួយគ្នារក្សា

ព្រហ្មចរិយៈ ធ្វើឲ្យជាភារៈរបស់ខ្លួន បរិហារព្រះបរិយត្តិធម៌ទុកឲ្យយូរ តែបច្ឆិមសាវកទាំងនោះ មិនដូច្នោះឡើយ ព្រោះដូច្នោះ ទើបពួកអ្នកបៀតបៀនគ្នា កាន់យកទិដ្ឋិផ្សេងគ្នា ធ្វើការចូរថយ ដោយប្រកាន់ថា ព្រះថេរៈឯណោះទើបដឹង ព្រះថេរៈឯណោះទើបជ្រាប គប្បីញុំាងព្រហ្មចរិយៈនោះ ឲ្យអន្តរធានទៅដោយឆាប់រហ័សនោះឯង គឺមិនលើកឡើងកាន់សង្គាយនា រក្សាទុក ។ បទថា **សេយ្យថាបិ** ជាការសម្ដែងនូវអត្ថនោះដោយឧបមា ។ បទថា **វិកិរតិ** ប្រែថា រមែងបក់ខ្ចាត់ខ្ចាយ ។ បទថា **វិធមតិ** ប្រែថា រមែងបក់ខ្ចាយទៅកាន់ទីដទៃ ។ បទថា **វិទ្ធំសេតិ** គឺរមែងបក់ចេញទៅអំពីទីដែលតាំងនៅ ។ បទថា **យថាតំ សុត្តេន អសង្គហិតត្តា** សេចក្ដីថា ខ្យល់រមែងបក់កម្ចាយទៅ ដូចបក់ផ្កាឲ្យរាត់រាយ ព្រោះមិនបានក្រង ព្រោះមិនបានចងដោយអំបោះដូច្នោះ ។ អធិប្បាយថា ( ផ្កាទាំងឡាយ ) ដែលមិនបានដោតក្រងរក្សាដោយអំបោះ រមែងត្រូវខ្យល់បក់ខ្ចាត់ខ្ចាយទៅ យ៉ាងណា រមែងរាត់រាយទៅយ៉ាងនោះ ។ បទថា **ឯវមេវ ខោ** ជាការញុំាងការឧបមេយ្យឲ្យដល់ព្រម ។ បទថា **អន្តរធាបេសុំ** សេចក្ដីថា ( ពួកសាវកឯក្រោយ ) កាលមិនសង្គ្រោះ ( គឺសង្គាយនាជាពួក ) ដោយវគ្គសង្គហៈ និងបណ្ណាសកសង្គហៈជាដើម កាន់យកតែព្រហ្មចរិយៈ ពោល គឺបរិយត្តិធម៌ ដែលខ្លួនពេញចិត្តប៉ុណ្ណោះ ចំណែកដ៏សេស ក៏បណ្ដោយឲ្យវិនាសទៅ គឺនាំទៅកាន់ភាពមិនប្រាកដ ។

បទថា **កិលាសុនោ ច តេ**[១] **ភគវន្តោ អហេសុំ សាវកានំ ចេតសា**

១- បិដកថា តេ ពុទ្ធា ភគវន្តោ ។ យកតាមអដ្ឋកថាបាលី ។

**ចេតោ បរិច្ច ឱវទិតុំ** *សេចក្តីថា ម្នាលសារីបុត្រ ម្យ៉ាងទៀត ព្រះពុទ្ធទាំងនោះ ទ្រង់មិនមានចិត្តប្រឹងប្រែង ដើម្បីប៉ាន់ស្មាន គឺ កំណត់ចិត្តរបស់ពួកសាវ័ក ដោយចិត្តរបស់ព្រះអង្គ ហើយទ្រង់ប្រៀនប្រដៅ គឺទ្រង់ជ្រាបចិត្តនៃបុគ្គលដទៃហើយ ទ្រង់សម្តែងការទូន្មានប្រៀនប្រដៅ ដោយមិនជាការៈធ្ងន់ ដោយមិនយឺតយូរ ។ ព្រះដ៏មានព្រះភាគត្រាស់ពាក្យជាដើមថា* **ភូតបុព្វំ សារីបុត្ត** *ដូច្នេះ ដើម្បីប្រកាសភាពដែលព្រះពុទ្ធទាំងនោះ ទ្រង់មិនដាក់ព្រះទ័យ ។ បទថា* **ភឹសនកេ** *គឺគួរខ្លាច បានដល់ ឲ្យកើតការស្រយុតស្រយង់ ។ ពាក្យថា* **ឯវំ វិតក្កេថ** *សេចក្តីថា ពួកអ្នកចូរត្រិះរិះកុសលវិតក្កៈ ៣ មាននេក្ខម្មវិតក្កៈជាដើម ។ ពាក្យថា* **មា ឯវំ វិតក្កយិត្ថ** *សេចក្តីថា ពួកអ្នកកុំត្រិះរិះក្នុងអកុសលវិតក្កៈ ៣ មានកាមវិតក្កជាដើម ។ ពាក្យថា* **ឯវំ មនសិករោថ** *សេចក្តីថា ពួកអ្នកចូរធ្វើទុកក្នុងចិត្តថា មិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាត ។ ពាក្យថា* **មា ឯវំ មនសា កត្ថ** *សេចក្តីថា ពួកអ្នកកុំធ្វើទុកក្នុងចិត្តថា ទៀង ជាសុខ ជាអត្តា ស្អាតឡើយ ។ ពាក្យថា* **ឥទំ បជហថ** *គឺចូរលះអកុសល ។ ពាក្យថា* **ឥទំ ឧបសម្បជ្ជ វិហរថ** *សេចក្តីថា ពួកអ្នកចូរដល់ត្រឡប់បាន គឺឲ្យកុសលសម្រេចចុះ ។ បទថា* **អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចិំសុ** *គឺ រួចផុតហើយ ព្រោះមិនប្រកាន់មាំ ។ ពិតហើយ ចិត្តរបស់ព្រះសាវ័កទាំងនោះរួចផុតចាកអាសវៈពួកណា ចិត្តទាំងនោះរួចផុតហើយ ព្រោះមិនប្រកាន់មាំអាសវៈទាំងនោះ ។ ឯអាសវៈទាំងឡាយ រលត់ទៅដោយការរលត់ គឺការមិនកើតឡើង ឈ្មោះថា រួចផុតហើយ ព្រោះមិន*

ប្រកាន់មាំ ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសុ។**

ភិក្ខុទាំងអស់នោះ បានសម្រេចអរហត្តហើយ ជាអ្នកមានចិត្តរីករាយ ដូចផ្កាបទុមដែលត្រូវពន្លឺព្រះអាទិត្យ ដូច្នោះ ។

ក្នុងបទថា **តត្រ សុទំ សារីបុត្ត ភឹសនកស្ស វនសណ្ឌស្ស ភឹសនកតស្មឹ ហោតិ** នេះ បទថា **តត្រ** ជាពាក្យពោលសម្ព័ន្ធដល់ពាក្យដើម ។ បទថា **សុទំ** ជានិបាត ចុះក្នុងអត្ថត្រឹមតែធ្វើបទឲ្យពេញ ។ បទថា **សារីបុត្ត** ជាអាលបនៈ ឯក្នុងពាក្យថា **តត្រ សុទំ** ជាដើមនេះ មានអត្ថក្នុងយោជនាថា បទថា **តត្រ** សេចក្តីថា នៃដងព្រៃដែលគួរខ្លាច ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា **ភឹសនក** ក្នុងព្រះតម្រាស់ ដែលព្រះអង្គត្រាស់ទុកថា **អញ្ញតរស្មឹ ភឹសនកេ វនសណ្ឌេ** អធិប្បាយថា ភាវៈដែលគួរស្បើម ឈ្មោះថា ភាពគួរតក់ស្លុត មានក្នុងភាវៈគួរភ័យខ្លាច គឺក្នុងការធ្វើឲ្យស្រៀវខ្លាច ។ សួរថា គួរភ័យខ្លាចដូចម្តេច ឆ្លើយថា គួរភ័យខ្លាចយ៉ាងនេះ គឺបុគ្គលណាមួយដែលមិនទាន់ប្រាសចាករាគៈ ចូលទៅកាន់ដងព្រៃនោះដោយច្រើន លោមជាតិរមែងបះ ។ ម្យ៉ាងទៀត ពាក្យថា **តត្រ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។ សព្ទថា **សុ** ជានិបាត ដូចក្នុងប្រយោគទាំងឡាយថា **កឹសុ នាម តេ ភោន្តោ សមណព្រាហ្មណា** ជាដើម ប្រែថា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ឈ្មោះដូចម្តេច ។ បទថា **ឥទំ** បណ្ឌិតគប្បីឃើញថា ជាពាក្យសម្តែងអត្ថតាមដែលបំណង ដូចធ្វើឲ្យឃើញបាន

ច្បាស់ ។ បទថា **សុ ឥធំ** សន្ធិចូលគ្នាជា **សុធំ**។ គប្បីជ្រាបថា លុប **ឥ** អក្ខរៈ ដោយអំណាចនៃសន្ធិ ដូចក្នុងប្រយោគជាដើមថា **ចក្ខុន្ទ្រិយំ ឥត្ថិ-ន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ កឹស្សូធ វិត្តំ** ប្រែថា ឥន្ទ្រិយ គឺចក្ខុ ឥន្ទ្រិយ គឺស្រី ឥន្ទ្រិយ គឺការតាំងចិត្តថា នឹងដឹងព្រះអរហត្តដែលមិនទាន់ដឹង អ្វីហ្ន៎ ជាទ្រព្យដ៏ប្រសើរក្នុងលោកនេះ ។ ក្នុងពាក្យនេះ មានអត្ថយោជនាថា ម្នាល សារីបុត្រ ព្រោះដងព្រៃដែលគួរស្ញើមនោះ ជាទីគួរស្រៀវខ្លាច ទើបមាន ពាក្យពោល ដូច្នេះ ។ បទថា **ភឹសនកតស្មឹ** សេចក្តីថា ព្រោះដងព្រៃជាដែន ដីដែលគួរខ្លាច ។ គប្បីឃើញថា លុប **ត** អក្ខរៈ ១ អង្គ ចេញ ម្យ៉ាងទៀត បាលីថា **ភឹសនកត្តស្មឹ** ដូច្នេះក៏មាន ។ ម្យ៉ាងទៀត ក្នុងកាលគួរនឹងពោលជា ឥត្ថីលិង្គថា **ភឹសនកតាយ** លោកក៏ធ្វើឲ្យជាលិង្គវិបល្លាស ។ ឯក្នុងពាក្យថា **ភឹសនកតស្មឹ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃនិមិត្ត ។ ព្រោះដូច្នោះ គប្បី ឃើញសម្ពន្ធយ៉ាងនេះថា ពាក្យនេះឯងរមែងមាន ព្រោះដងព្រៃគួរខ្លាច ជា តំបន់ដែលមានការតក់ស្លុតជានិមិត្ត គឺមានពាក្យពោលនេះឯង ព្រោះមានការ តក់ស្លុតជាហេតុ ព្រោះមានការតក់ស្លុតជាបច្ច័យ ពាក្យថា បុគ្គលណានីមួយ ដែលមានរាគៈមិនទាន់ប្រាសទេ ចូលទៅកាន់ដងព្រៃនោះ ដោយច្រើន រមែង ព្រឺរោម សេចក្តីថា រោមជាច្រើនរមែងបះ គឺបះចុងឡើងដូចជាម្ជុល និងដូច ជាបន្លា រោមចំនួនតិចណាស់ដែលមិនបះ ម្យ៉ាងទៀត លោមជាតិរបស់សត្វជា ច្រើន រមែងត្រូវបះ តែសម្រាប់បុគ្គលក្លាហាន តិចតួចណាស់ រមែងមិនព្រឺ ។

ឥឡូវនេះ ពាក្យថា **អយំ ខោ សារីបុត្ត ហោតុ** ជាដើម ជាពាក្យ

ពោលត្រួតសេចក្ដី ។ ចំណែកពាក្យដែលខ្ញុំមិនបានពោលទុកក្នុងចន្លោះៗ នៃព្រះបាលីនេះ មានអត្ថរាក់ហើយ ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបតាមលំដាប់នៃព្រះបាលីនោះឯង ។ តែព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា **មិនតាំងនៅចានយូរ** បណ្ឌិតគប្បីជ្រាបថា ព្រះអង្គត្រាស់ដោយអំណាចនៃយុគរបស់មនុស្ស ។

## ព្រះជន្មាយុព្រះវិបស្សីជាដើម

ពិតហើយ ព្រះដ៏មានព្រះភាគវិបស្សី គណនាដោយឆ្នាំ មានព្រះជន្ម ៨ ម៉ឺនឆ្នាំ សូម្បីសាវកដែលទាន់សាសនារបស់ព្រះអង្គ ក៏មានអាយុប្រមាណប៉ុណ្ណោះដូចគ្នា ។ ព្រហ្មចរិយៈ ( សាសនា ) បន្តដោយសាវករបស់ព្រះដ៏មានព្រះភាគនោះ ដែលជាអង្គក្រោយគេទាំងអស់ តាំងនៅបានរហូត ១ សែន ៦ ម៉ឺនឆ្នាំ ដោយប្រការយ៉ាងនេះ ។ តែដោយអំណាចនៃយុគរបស់មនុស្ស ព្រហ្មចរិយៈបានតាំងនៅតមក ដោយការបន្តគ្នានៃយុគរហូតដល់យុគមនុស្ស ២ យុគប៉ុណ្ណោះ ( ២ តំណមនុស្ស ) ។ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **មិនតាំងនៅចានយូរ** ។ ឯព្រះដ៏មានព្រះភាគព្រះនាមសិខី មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ សូម្បីពួកសាវកដែលទាន់សាសនាព្រះអង្គ ក៏មានអាយុប្រមាណប៉ុណ្ណោះដូចគ្នា ។ ព្រះដ៏មានព្រះភាគ ព្រះនាមវេស្សភូ មានព្រះជន្ម ៦ ម៉ឺនឆ្នាំ សូម្បីពួកសាវកដែលទាន់សាសនារបស់ព្រះអង្គក៏មានអាយុប្រមាណប៉ុណ្ណោះដូចគ្នា ។ ព្រហ្មចរិយៈ ( សាសនា ) បន្តដោយសាវកអង្គចុងក្រោយគេបង្អស់ នៃព្រះដ៏មានព្រះភាគ ព្រះនាមថា

សិខី និងវេស្សភូនោះ តាំងនៅបន្តមកបានប្រមាណ ១ សែន ៤ ម៉ឺនឆ្នាំ និងប្រមាណ ១ សែន ២ ម៉ឺនឆ្នាំ ។ តែពោលដោយអំណាចនៃយុគមនុស្ស ព្រហ្មចរិយៈតាំងនៅរហូតមកបាន ដោយការបន្តនៃយុគ រហូតដល់យុគមនុស្ស ២ តំណដូចគ្នា ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **តាំងនៅមិនបានយូរ** ។

ព្រះសារីបុត្រ ស្តាប់ហេតុនៃការតាំងនៅមិនយូរនៃព្រហ្មចរិយៈ របស់ព្រះពុទ្ធ ៣ អង្គ យ៉ាងនេះហើយ មានបំណងនឹងស្តាប់ហេតុនៃការតាំងនៅបានយូរនៃព្រហ្មចរិយៈរបស់ព្រះពុទ្ធ ៣ អង្គក្រៅអំពីនេះ ទើបបានទូលសួរព្រះដ៏មានព្រះភាគទៀត ដោយន័យជាដើមថា អ្វីជាហេតុព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់បានព្យាករដល់លោក ពាក្យព្យាករណ៍ទាំងអស់នោះ គប្បីជ្រាបដោយអំណាចន័យដែលផ្ទុយគ្នា អំពីការដែលពោលហើយ ។ ហើយសូម្បីក្នុងការតាំងនៅយូរ ក្នុងពាក្យព្យាករណ៍នោះ បណ្ឌិតគប្បីជ្រាបការតាំងនៅយូរដោយហេតុទាំង ២ គឺដោយប្រមាណនៃព្រះជន្មរបស់ព្រះពុទ្ធទាំងនោះខ្លះ ដោយយុគនៃមនុស្សខ្លះ ។ សេចក្តីពិស្តារថា ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថាកកុសន្ធៈ មានព្រះជន្ម ៤ ម៉ឺនឆ្នាំ ព្រះដ៏មានព្រះភាគព្រះនាមកោនាគមនៈ មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ព្រះដ៏មានព្រះភាគព្រះនាមថាកស្សប មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ សូម្បីសាវ័កដែលទាន់សាសនាទាំងឡាយរបស់ព្រះពុទ្ធទាំងនោះ ក៏មានអាយុប៉ុណ្ណោះដូចគ្នា ។ យុគនៃសាវ័កដ៏ច្រើនរបស់ព្រះពុទ្ធទាំងនោះ ញុំាងព្រហ្មចរិយៈឲ្យប្រព្រឹត្តទៅដោយការបន្តគ្នាមក ។ ព្រហ្មចរិយៈ

តាំងនៅយូរដោយហេតុទាំង ២ គឺដោយប្រមាណនៃព្រះជន្ម នៃព្រះពុទ្ធនោះខ្លះ ដោយយុគនៃសាវកខ្លះ ដោយប្រការដូច្នេះ ។

## ហេតុដែលព្រះពុទ្ធ
## នៃយើងកើតក្នុងកាលនៃមនុស្សមានអាយុតិច

ឯព្រះដ៏មានព្រះភាគនៃយើង គួរតែទ្រង់ឧប្បត្តិកឡើង ក្នុងកាលនៃមនុស្សមានអាយុ ១ ម៉ឺនឆ្នាំ ដែលស្មើគ្នានឹងអាយុពាក់កណ្តាលនៃព្រះជន្មរបស់ព្រះដ៏មានព្រះភាគព្រះនាមថាកស្សប មិនដល់កាលនៃមនុស្សមានអាយុ ១ ម៉ឺនឆ្នាំនោះ ក៏គួរទ្រង់កើតឡើងក្នុងកាលនៃមនុស្សមានអាយុ ៥ ពាន់ឆ្នាំ ឬក្នុងកាលនៃមនុស្សមានអាយុ ១ ពាន់ឆ្នាំ ឬសូម្បីក្នុងកាលនៃមនុស្សមានអាយុ ៥០០ ឆ្នាំ តែព្រោះកាលព្រះអង្គទ្រង់ស្វែងរក គឺស្វែងរកធម៌ដែលធ្វើជាព្រះពុទ្ធ ទ្រង់ញ៉ាំងញាណឲ្យចាស់ក្លា ឲ្យតាំងគភ៌ ( ដើម្បីប្រសូតគុណវិសេស ) ញាណ បានដល់ ភាពចាស់ក្លា ក្នុងកាលនៃមនុស្សមានអាយុ ១០០ ឆ្នាំ ព្រោះដូច្នោះ ទើបព្រះអង្គទ្រង់ឧប្បត្តិកឡើង ក្នុងកាលនៃមនុស្សមានអាយុតិចពន់ពេក ព្រោះដូច្នេះ គួរពោលបានថា ព្រហ្មចរិយៈតាំងនៅបានយូរ ដោយអំណាចការបន្តគ្នានៃសាវករបស់ព្រះអង្គ តែការតាំងនៅមិនបានយូរ ដោយការរាប់ឆ្នាំ ដោយអំណាចបរិមាណនៃអាយុដូចគ្នា ។

## ព្រះសារីបុត្រទូលសូមឱ្យទ្រង់បញ្ញត្តសិក្ខាបទ

[ ៨ ] សួរថា ក្នុងពាក្យថា **អថខោ អាយស្មា សារីបុត្តោ** មានអ្វីជាអនុសន្ធិ ឆ្លើយថា គឺព្រះសារីបុត្រ កាលបានស្តាប់ហេតុនៃការតាំងនៅយូរនៃ

ព្រហ្មចរិយៈរបស់ព្រះពុទ្ធ ៣ អង្គយ៉ាងនេះហើយ ដល់នូវការសន្និដ្ឋានថា ការបញ្ញត្តសិក្ខាបទប៉ុណ្ណោះ ជាហេតុនៃការតាំងនៅបានយូរ កាលប្រាថ្នាការតាំងនៅបានយូរនៃព្រហ្មចរិយៈរបស់ព្រះដ៏មានព្រះភាគ ទើបអារាធនាសូមការបញ្ញត្តសិក្ខាបទពីព្រះដ៏មានព្រះភាគ ។ ព្រះឧបាលិត្ថេរពោលពាក្យថា **អថខោ អាយស្មា សារីបុត្តោ ឧដ្ឋាយាសនា ។បេ។ ចិរដ្ឋិតិកំ** នេះ ដើម្បីសម្តែងវិធីអារាធនាសូមការបញ្ញត្តសិក្ខាបទនោះ ។ បណ្តាបទទាំងនោះ បទថា **អទ្ធនិយំ** គឺគួរដល់កាលយូរ អធិប្បាយថា មានកាលយឺនយូរ ។ ពាក្យដ៏សេសមានអត្ថរាក់ហើយ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រកាសដល់ព្រះសារីបុត្រនោះថា វេលានេះ មិនជាកាលនៃការបញ្ញត្តសិក្ខាបទទុកជាមុនទេ ទើបត្រាស់ថា **អាគមេហិ ត្វំ សារីបុត្ត** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **អាគមេហិ ត្វំ** សេចក្តីថា អ្នកចូររង់ចាំសិន អធិប្បាយថា អ្នកចូរបង្អង់សិន ពាក្យនេះ ព្រះដ៏មានព្រះភាគត្រាស់ដដែលជាគម្រប់ ២ ដង ដោយអំណាចការអើពើ ។ ដោយពាក្យថា **អាគមេហិ** ជាដើមនេះ ព្រះដ៏មានព្រះភាគទ្រង់ឃាត់ការបញ្ញត្តសិក្ខាបទ ជាវិស័យរបស់ព្រះសាវក កាលទ្រង់ធ្វើឲ្យជាក់ច្បាស់ថា ការបញ្ញត្តសិក្ខាបទជាពុទ្ធវិស័យ ទើបត្រាស់ពាក្យថា **តថាគតោវ** ជាដើម ។ ក្នុងពាក្យថា **តថាគតោវ** នេះ ពាក្យថា **តត្ថ** ជាសត្តមីវិភត្តិសម្ព័ន្ធដល់ការអារាធនាសូមឲ្យទ្រង់បញ្ញត្តសិក្ខាបទ ។ ក្នុងពាក្យថា **តថា-គតោវ** នោះ មានយោជនាដូចតទៅនេះថា ក្នុងពាក្យដែលលោកពោលថា

ព្រះដ៏មានព្រះភាគគប្បីបញ្ញត្តសិក្ខាបទនោះ ព្រះតថាគតប៉ុណ្ណោះ នឹងដឹងកាលនៃការបញ្ញត្តសិក្ខាបទនោះ ។ ព្រះដ៏មានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ដើម្បីសម្តែងសម័យមិនមែនកាលមុន ទើបត្រាស់ពាក្យជាដើមថា **ន តាវ សារីបុត្ត** ដូច្នេះ ។ ក្នុងពាក្យថា **ន តាវ សារីបុត្ត** ជាដើមនេះ មានវិនិច្ឆ័យថា អាសវៈទាំងឡាយ រមែងតាំងនៅក្នុងធម៌ទាំងនេះ ព្រោះហេតុនោះ ទើបធម៌ទាំងនេះ ឈ្មោះថា ជាទីតាំងនៃអាសវៈ ម្យ៉ាងទៀត ធម៌ទាំងឡាយដែលអាសវៈគប្បីតាំងនៅ គឺមិនគប្បីកន្លងទៅ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា ជាទីតាំងនៃអាសវៈ ។ អធិប្បាយថា អាសវៈ គឺទុក្ខផងអាសវៈ គឺកិលេសផង ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងក្នុងសម្បរាយភពអាសវៈ មានការតិះដៀលរបស់អ្នកដទៃ វិប្បដិសារៈ ការសម្លាប់ និងការចងជាដើម និងអាសវៈដែលជាទុក្ខវិសេសក្នុងអបាយ រមែងតាំងនៅនោះឯងក្នុងវីតិក្កមធម៌ពួកណា ព្រោះវីតិក្កមធម៌ទាំងនោះជាហេតុនៃអាសវៈ មានអាសវៈដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ជាដើមនោះ ។

វាចាសម្រាប់ប្រកបក្នុងពាក្យថា **ន តាវ** ជាដើមនេះ ដូច្នេះថា វីតិក្កមធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះ មិនទាន់មានប្រាកដក្នុងសង្ឃដរាបណា ព្រះសាស្តា ទ្រង់មិនបញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយដរាបនោះ ។ បើគប្បីបញ្ញត្តសោត មិនគប្បីផុតចាកការតិះដៀលរបស់អ្នកដទៃ ចាកការជំទាស់របស់អ្នកដទៃ ចាកទោស គឺការនិន្ទា ។

សួរថា មិនគប្បីផុតដូចម្តេច ឆ្លើយថា ពិតហើយ សិក្ខាបទទាំងពួង

មាន **យោ បន ភិក្ខុ មេថុនំ ធម្មំ បដិសេវេយ្យ** ជាដើមនេះ គប្បីជាសិក្ខាបទដែលព្រះសាស្តាទ្រង់បញ្ញត្ត គួរបញ្ញត្ត ។ ចំណែកជនដទៃ មិនឃើញវីតិក្កមទោស តែដឹងបញ្ញត្តិនេះ គប្បីញុំាងការតិះដៀល ការជំទាស់ និងការនិន្ទាឲ្យប្រព្រឹត្តទៅយ៉ាងនេះថា ហេតុអ្វី ព្រះសមណគោតមនឹងចងធ្វាក់ដោយសិក្ខាបទទាំងឡាយ នឹងបញ្ញត្តបារាជិក ដោយហេតុត្រឹមប៉ុណ្ណោះថា ភិក្ខុសង្ឃរមែងតាមអញ ធ្វើតាមពាក្យរបស់អញ កុលបុត្រទាំងនេះ លះគំនរភោគៈធំលះផៅញាតិធំ និងលះសូម្បីរាជ្យសម្បត្តិ ដែលនៅក្នុងកណ្តាប់ដៃ ហើយបួសជាអ្នកសន្តោស ដោយភាពជាបុគ្គលមានអាហារ និងគ្រឿងស្លៀកដណ្តប់យ៉ាងក្រៃលែង មានការគោរពមុតស្រួចក្នុងសិក្ខា មិនជាប់ជំពាក់ក្នុងរាងកាយ និងជីវិតមិនមែនឬ ក្នុងកុលបុត្រទាំងនោះ អ្នកណាទៅ នឹងសេពមេថុន ដែលជាលោកាមិស ឬនឹងលួចរបស់អ្នកដទៃ ឬនឹងចូលទៅកាត់ផ្តាច់ជីវិតរបស់អ្នកដទៃ ដែលជារបស់ជាទីស្រឡាញ់យ៉ាងក្រៃលែង ឬនឹងសម្រេចការចិញ្ចឹមជីវិត ដោយអួតគុណដែលមិនមាននោះ កាលបារាជិកសូម្បីទ្រង់មិនបញ្ញត្តទុក សិក្ខាបទនោះ គឺព្រះអង្គទ្រង់ធ្វើឲ្យប្រាកដហើយដោយសង្ខេបក្នុងបព្វជ្ជានោះឯង មិនមែនឬ ជនទាំងឡាយមិនជ្រាបថាមពលនៃព្រះតថាគត សិក្ខាបទដែលទ្រង់បញ្ញត្តទុក នឹងគប្បីកម្រើក គឺមិនគង់នៅក្នុងសភាពដើម ។

គ្រូពេទ្យដែលមិនឈ្លាស ហៅបុរសខ្វះ ដែលបួសមិនទាន់កើតឡើងហើយប្រាប់ថា មកនេះ បាដ៏ចម្រើន បូសធំនឹងកើតឡើងក្នុងសរីរប្បទេស

ត្រង់នេះរបស់ឯង នឹងញុំាងការវិនាសឲ្យមកដល់ឯង ឯងចូរប្រញាប់ឲ្យពេទ្យ ដាក់ថ្នាំចុះ ដូច្នោះ បុរសនោះពោលថា សាធុ លោកអាចារ្យ សូមលោកព្យាបាលចុះ ទើបវះសរីរប្បទេសដែលមិនមានរោគរបស់បុរសនោះ បង្ហូរឈាមចេញហើយ ធ្វើសរីរប្បទេសត្រង់នោះឲ្យមានស្បែកល្អមកវិញ ដោយលាបថ្នាំ និងបិទថ្នាំ មួយអន្លើដោយការលាងជាដើម ទើបពោលនឹងបុរសនោះថា រោគធំរបស់ឯង យើងបានព្យាបាលហើយ ឯងចូរឲ្យថ្លៃឈ្នួលដល់យើង ។ បុរសនោះគប្បីតិះដៀល គប្បីជំទាស់ គប្បីនិន្ទាគ្រូពេទ្យយ៉ាងនេះថា ពេទ្យល្ងង់នេះនិយាយអ្វី បានឮថា រោគប្រភេទណារបស់អញ ដែលពេទ្យល្ងង់នេះបានព្យាបាលហើយ ពេទ្យល្ងង់នេះធ្វើទុក្ខឲ្យកើតដល់អញ និងធ្វើឲ្យអញអស់ឈាមទៅ មិនមែនឬ ដូច្នេះ នឹងមិនគប្បីដឹងគុណដល់ពេទ្យនោះ សេចក្តីនេះ យ៉ាងណា បើវីតិក្កមទោសមិនទាន់កើតឡើង ព្រះសាស្តាគប្បីបញ្ញត្តសិក្ខាបទដល់ព្រះសាវកសោត ព្រះអង្គមិនគប្បីផុតចាកអនិដ្ឋផលមានការត្មះតិះដៀលរបស់អ្នកដទៃជាដើមផង ជនទាំងឡាយ នឹងមិនគប្បីដឹងកម្លាំងបញ្ញា និងសមត្ថភាពរបស់ព្រះអង្គផង យ៉ាងនោះឯង សិក្ខាបទដែលទ្រង់បញ្ញត្តហើយ នឹងគប្បីកម្រើក គឺមិនតាំងនៅក្នុងទីដើម ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **ន តាវ សារីបុត្ត សត្ថា សាវកានំ ។បេ។ ធាតុភវត្តិ** ។ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងកាលដែលមិនគួរយ៉ាងនេះហើយ ទើបត្រាស់ពាក្យថា **យតោ ច ខោ សារីបុត្ត** ជាដើម ដើម្បីសម្តែងកាលទៀត ។ បណ្តាបទទាំងនេះ បទថា **យតោ** គឺកាលណា

អធិប្បាយថា ក្នុងកាលណា ។ ពាក្យដ៏សេសគប្បី ជ្រាបដោយទំនងដែលពោលហើយនោះឯង ។

ម្យ៉ាងទៀត ក្នុងពាក្យថា **យតោ** ជាដើមនេះ មានសេចក្ដីសង្ខេបថា វីតិក្កមទោស ដែលដល់នូវការរាប់ថា ធម៌ជាទីតាំងនៃអាសវៈ រមែងមានប្រាកដក្នុងសង្ឃ ក្នុងកាលណា ក្នុងកាលនោះ ព្រះសាស្ដា ទ្រង់រមែងបញ្ញត្តសិក្ខាបទដល់ពួកសាវក ទ្រង់រមែងសម្ដែងបាតិមោក្ខ ព្រោះហេតុអ្វី ព្រោះដើម្បីកម្ចាត់វីតិក្កមទោសទាំងនោះឯង ដែលដល់នូវការរាប់ថា ធម៌ជាទីតាំងនៃអាសវៈ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់បញ្ញត្តយ៉ាងនោះ រមែងជាបុគ្គលមិនគួរតិះដៀលជាដើម និងជាបុគ្គលមានអានុភាពប្រាកដក្នុងសព្វញ្ញុវិស័យរបស់ព្រះអង្គ រមែងដល់នូវសក្ការៈ ហើយសិក្ខាបទរបស់ព្រះអង្គនោះ រមែងមិនកម្រើក គឺតាំងនៅក្នុងកន្លែងដើម ប្រៀបដូចគ្រូពេទ្យអ្នកឈ្លាសក្នុងការព្យាបាលបូស ដែលកើតឡើងហើយ ដោយការវះកាត់ បិទថ្នាំ រុំដំបៅ និងលាងសម្អាតជាដើម ធ្វើឲ្យសុខស្រួល មានស្បែកល្អ ជាបុគ្គលមិនគួរតិះដៀលជាដើមឡើយ និងជាបុគ្គលមានអានុភាពប្រាកដ ព្រោះកម្មនៃអាចារ្យរបស់ខ្លួន រមែងបាននូវសក្ការៈ ដូច្នោះ ។

ព្រះដ៏មានព្រះភាគ កាលត្រាស់ការមិនកើតឡើង និងការកើតឡើងនៃធម៌ ដែលជាទីតាំងនៃអាសវៈ អកាល និងកាល នៃការបញ្ញត្តសិក្ខាបទយ៉ាងនេះ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីសម្ដែងកាលដែលមិនទាន់កើតឡើងនៃធម៌ទាំងនោះឯង ទើបត្រាស់ពាក្យថា **ឆ តាវ សារីបុត្ត**

**ឥនេកាប្ច** ជាដើម ។ ក្នុងពាក្យថា **តាវ** ជាដើមនោះ បទទាំងឡាយ មានអត្ថរាក់ហើយ គប្បីជ្រាបដោយអំណាចព្រះបាលីនោះឯង ។ ចំណែកការពណ៌នាបទដែលជ្រាលជ្រៅ មានដូចតទៅនេះថា

ភិក្ខុទាំងឡាយ ឈ្មោះថា **រត្តញ្ញូ** ព្រោះអត្ថថា ដឹងរាត្រីយូរ គឺដឹងរាត្រីច្រើន តាំងអំពីថ្ងៃដែលខ្លួនបួសមក អធិប្បាយថា បួសមកយូរ ។ ភាពជាពួកដោយពួកភិក្ខុអ្នកដឹងរាត្រីយូរ ឈ្មោះថា **រត្តញ្ញុមហត្ត** ។ អធិប្បាយថា ភាពជាក្រុមធំ ដោយពួកភិក្ខុដែលបួសមកយូរ ។

បណ្ឌិតគប្បីជ្រាបថា សិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តប្រារព្ធព្រះឧបសេនវង្គន្តបុត្ត ព្រោះសង្ឃដល់នូវភាពជាក្រុមធំ ដោយភិក្ខុអ្នកដឹងរាត្រីយូរ ក្នុងបណ្ដាភាពជាក្រុមធំទាំងនោះ ។ ពិតហើយ លោកដ៏មានអាយុនោះបានឃើញភិក្ខុទាំងឡាយ ដែលមានវស្សាក្រោម ១០ ឲ្យឧបសម្បទាខ្លួនមានវស្សា ១ ទើបឲ្យសទ្ធិវិហារិកឧបសម្បទាខ្លះ ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានវស្សាថយអំពី ១០ ចុះមក មិនត្រូវឲ្យឧបសម្បទាដល់កុលបុត្រឡើយ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។

កាលសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយយ៉ាងនោះ ភិក្ខុទាំងឡាយដែលល្ងង់ខ្លៅ មិនឈ្លាស គិតថា អញបានវស្សា ១០ អញមានវស្សាគ្រប់ ១០ ទើបឲ្យឧបសម្បទាទៀត ។ លំដាប់នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទដដែលម្ដងទៀតថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

ពាលមិនឈ្លាស មិនត្រូវឲ្យឧបសម្បទា ( ដល់កុលបុត្រ ) ឡើយ ភិក្ខុពាលណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឈ្លាសប្រតិពលមានវស្សា ១០ ឬមានវស្សាច្រើនជាង ១០ ឡើងទៅ គួរឲ្យឧបសម្បទា ( ដល់កុលបុត្រ ) បាន ។ ក្នុងកាលដែលសង្ឃដល់ភាពជាពួកធំ ដោយភិក្ខុដែលដឹងរាត្រីយូរ ទ្រង់បានបញ្ញត្ត ២ សិក្ខាបទ ។

បទថា **វេបុល្លមហត្តំ** សេចក្តីថា ភាពជាពួកធំ ដោយភាពជាពួកគណៈច្រើន ។ ពិតហើយ សង្ឃមិនទាន់ដល់នូវភាពជាក្រុមធំ ដោយអំណាចភិក្ខុទាំងឡាយជាព្រះថេរៈ ជានវៈ និងជាមជ្ឈិមត្រឹមណា សេនាសនៈ រមែងគ្រប់គ្រាន់ អាសវដ្ឋានិយធម៌ខ្លះសោត ក៏មិនទាន់កើតឡើងក្នុងសាសនាត្រឹមនោះ តែកាលសង្ឃដល់នូវភាពជាធំ ដោយភាពជាពួក ជាក្រុមហើយ អាសវដ្ឋានិយធម៌ទាំងនោះ រមែងកើតឡើង ។ ពេលនោះ ព្រះសាស្តាទ្រង់រមែងបញ្ញត្តសិក្ខាបទ ។ សិក្ខាបទដែលទ្រង់បញ្ញត្ត ព្រោះសង្ឃដល់នូវភាពជាធំ ដោយភាពជាពួកគណៈច្រើន ក្នុងបណ្តាភាពជាពួកធំទាំងនោះ បណ្ឌិតគប្បីជ្រាបតាមន័យនេះថា ម្យ៉ាងទៀត ភិក្ខុណាមួយ សម្រេចនូវទីដេករួមជាមួយនឹងអនុបសម្បន្ន លើសជាងពីរយប់ ឬបីយប់ឡើងទៅ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ ។ ម្យ៉ាងទៀត ភិក្ខុនីណាមួយ ឲ្យឧបសម្បទារាល់ឆ្នាំនាងភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។ ម្យ៉ាងទៀត ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់ស្រីពីររូប ក្នុង ១ ឆ្នាំ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

បទថា **លាភគ្គមហត្តំ** សេចក្តីថា ភាពជាធំ ជាអគ្គនៃលាភ អធិប្បាយថា ភាពជាធំណា ជាកំពូល គឺឧត្តមនៃលាភ សង្ឃជាអ្នកដល់នូវភាពជាធំនោះ ។ ម្យ៉ាងទៀត ដល់នូវភាពជាធំដ៏លើសដោយលាភក៏បាន អធិប្បាយថា ដល់នូវភាពជាក្រុមប្រសើរ និងភាពជាគណៈធំដោយលាភ ។ ពិតហើយ សង្ឃមិនទាន់ដល់នូវភាពជាធំដ៏លើស ដោយលាភត្រឹមណា អាសវដ្ឋានិយធម៌អាស្រ័យលាភ ក៏មិនទាន់កើតឡើងត្រឹមនោះ តែកាលដល់ហើយ រមែងកើតឡើង ។ ពេលនោះ ព្រះសាស្តាទ្រង់រមែងបញ្ញត្តសិក្ខាបទថា ម្យ៉ាងទៀត ភិក្ខុណាមួយ ឲ្យវត្ថុដែលបុគ្គលគួរទំពាស៊ី ឬវត្ថុដែលបុគ្គលគួរបរិភោគដល់អចេលក៏ក្តី បរិព្វាជកក្តី បរិព្វាជិកាក្តីដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ពិតហើយ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តព្រោះសង្ឃដល់នូវភាពជាពួកធំដ៏កំពូលដោយលាភ ។

បទថា **ពាហុសច្ចមហត្តំ**[១] សេចក្តីថា ពហុសច្ចៈ ជាគុណធំ ។ ពិតហើយ សង្ឃមិនទាន់ដល់នូវភាពដែលជាពហុសច្ចៈ ជាគុណធំដរាបណា អាសវដ្ឋានិយធម៌ ក៏មិនទាន់កើតឡើងដរាបនោះ ។ តែកាលដល់នូវភាពជាធំ ក្នុងពហុសច្ចៈហើយ រមែងកើតឡើង ព្រោះថា បុគ្គលទាំងឡាយ រៀនពុទ្ធវចនៈ ១ និកាយខ្លះ ២ និកាយខ្លះ ។បេ។ ៥ និកាយខ្លះ ហើយកាលពិចារណាដោយអយោនិសោមនសិការ ប្រៀបធៀបរស ដោយរសហើយ រមែងសម្តែងសត្ថុសាសនាក្រៅធម៌ ក្រៅវិន័យ ។ ពេលនោះ ព្រះសាស្តា

---

១- បិដកមិនមានបទនេះ ។ យកតាមអដ្ឋកថា ។

ទ្រង់រមែងបញ្ញត្តសិក្ខាបទដោយន័យជាដើមថា ភិក្ខុណាមួយពោលយ៉ាងនេះថា ធម៌ទាំងឡាយណា តែងធ្វើនូវសេចក្តីអន្តរាយ ដែលព្រះដ៏មានព្រះភាគសម្តែងហើយ ធម៌ទាំងឡាយនោះ មិនអាចធ្វើនូវសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ដោយប្រការយ៉ាងណា ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគ សម្តែងហើយដោយប្រការយ៉ាងនោះ ។បេ។ បើសមណុទ្ទេសពោលយ៉ាងនេះ ។បេ។ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងកាលមិនកើតឡើងនិងកាលកើតឡើងនៃធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈយ៉ាងនេះហើយ កាលទ្រង់សម្តែងការមិនមាននៃអាសវដ្ឋានិយធម៌ទាំងនោះ ដោយប្រការទាំងពួង ក្នុងសម័យនោះ ទើបត្រាស់ពាក្យថា **និរព្វុទោ ហិ សារីបុត្ត** ប្រែថា ម្នាលសារីបុត្រជាដើម ។

## អធិប្បាយពាក្យថា និរព្វុទោ ជាដើម

បណ្តាបទទាំងនោះ បទថា **និរព្វុទោ** គឺប្រាសចាកពុតត្បុត ។ ពួកចោរ លោកហៅថា ពុទៈ អធិប្បាយថា ប្រាសចាកចោរ ។ ឯក្នុងអត្ថនេះ ពួកភិក្ខុទ្រុស្តសីល លោកហៅថា ជាចោរ ។ ពិតហើយ ភិក្ខុទ្រុស្តសីលទាំងនោះ រមែងលួចបច្ច័យរបស់មនុស្សដទៃ ព្រោះមិនមែនជាសមណៈ តែមានការសម្គាល់ថា ជាសមណៈ ព្រោះហេតុនោះ ភិក្ខុសង្ឃមិនមានពុត មិនមានចោរ អធិប្បាយថា មិនមានបុគ្គលទ្រុស្តសីល ។ បទថា **និរាទីនវោ** បានដល់ មិនមានឧបទ្រវ គឺមិនមានឧបសគ្គ ។ អធិប្បាយថា វៀរចាកទោសរបស់បុគ្គលទ្រុស្តសីលនោះឯង បុគ្គលទ្រុស្តសីល លោកហៅថា **បុគ្គលខ្មៅ**

ក្នុងពាក្យថា **អបគតកាឡកោ** នេះ ។ ពិតហើយ បុគ្គលទ្រុស្តសីលទាំង នោះ សូម្បីមានពណ៌សម្បុរដូចមាស គប្បីជ្រាបថា ជាបុគ្គលខ្មៅនោះឯង ព្រោះប្រកបដោយធម៌ខ្មៅ ។ ព្រោះមិនមានបុគ្គលមានធម៌ខ្មៅទាំងនោះ ទើប ឈ្មោះថា **អបគតកាឡក** ។ បាឋៈថា **អបហាតកាឡក** ដូច្នេះក៏មាន ។ បទថា **សុទ្ធោ** គឺឈ្មោះថា បរិសុទ្ធ ព្រោះមានបុគ្គលខ្មៅប្រាសទៅហើយនោះ ឯង ។ បទថា **បរិយោទាតោ** គឺផូរផង់ ។ គុណ គឺសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ លោកហៅថា សារៈ ក្នុងពាក្យថា **សារេ-បតិដ្ឋិតោ** នេះ ព្រោះតាំងនៅហើយក្នុងសារៈនោះ ទើបឈ្មោះថា តាំងនៅ ក្នុងសារគុណ ។ ព្រះដ៏មានព្រះភាគ កាលត្រាស់ភាពដែលភិក្ខុសង្ឃតាំងនៅ ក្នុងសារគុណយ៉ាងនេះហើយ កាលទ្រង់សម្តែងពាក្យថា ភាពដែលភិក្ខុសង្ឃ នោះ តាំងនៅក្នុងសារគុណនោះ គប្បីជ្រាបយ៉ាងនេះ ទើបត្រាស់ពាក្យជាដើម ថា **ឥមេសំ ហិ សារីបុត្ត** ។

ក្នុងពាក្យនោះ មានពណ៌នាដោយសង្ខេបដូចតទៅនេះថា បណ្តាភិក្ខុ ដែលចូលវស្សានាស្រុកវេរញ្ជាទាំង ៥០០ អង្គនេះ ភិក្ខុដែលតូចទាបដោយ អំណាច គឺមានគុណទាបជាងភិក្ខុគ្រប់អង្គ ក៏ត្រឹមព្រះសោតាបន្ន ពាក្យថា **សោតាបន្នោ** គឺបុគ្គលធ្លាក់ដល់ក្រសែ ។ ឯពាក្យថា **សោតា** នេះ ជា ឈ្មោះរបស់មគ្គ ។ បទថា **សោតាបន្នោ** ជាឈ្មោះរបស់បុគ្គលដែល ប្រកបដោយមគ្គនោះ ។ ដូចព្រះតម្រាស់ថា ម្នាលសារីបុត្រ គេតែងពោល ថា សោតៈៗ ដូច្នេះ ម្នាលសារីបុត្រ ចុះសោតៈ តើដូចម្តេច ។ បពិត្រ

ព្រះអង្គដ៏ចម្រើន ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាសោតៈ ។ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺសេចក្តីឃើញត្រូវ ១ ការត្រិះរិះត្រូវ ១ ការនិយាយត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តនឹងត្រូវ ១ ។

ម្នាលសារីបុត្រ ប្រពៃពេកណាស់ ម្នាលសារីបុត្រ មែនហើយ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាសោតៈ ។ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ គឺសេចក្តីឃើញត្រូវ ១ ។បេ។ ការតម្កល់ចិត្តនឹងត្រូវ ១ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណាប្រកបដោយផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះ ហៅថា បុគ្គលដល់នូវសោតៈ លោកដ៏មានអាយុនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ដូច្នេះ ។

ឯក្នុងបទនេះ គប្បីជ្រាបថា មគ្គឲ្យឈ្មោះដល់ផល ព្រោះដូច្នោះ បុគ្គលដែលតាំងនៅក្នុងផល ឈ្មោះថា **សោតាបន្ន** ។ បទថា **អវិនិបាតធម្មោ** មានវិគ្គហៈថា ធម៌ដែលឈ្មោះថា **វិនិបាត** ព្រោះអត្ថថា ឲ្យធ្លាក់ទៅ ។ សោតាបន្ន ឈ្មោះថា **អវិនិបាតធម៌** ព្រោះអត្ថថា លោកមិនមានវិនិបាតធម៌ ។ អធិប្បាយថា លោកមិនមានការញុំាងខ្លួនឲ្យធ្លាក់ទៅក្នុងអបាយជាសភាវៈ ។ ព្រោះហេតុអ្វី ព្រោះការអស់ទៅនៃធម៌ ដែលជាហេតុនាំទៅកាន់អបាយ ។ ម្យ៉ាងទៀត ការធ្លាក់ទៅ ឈ្មោះថា **វិនិបាត** ។ ព្រះសោតាបន្ន ឈ្មោះថា **អវិនិបាតធម៌** ព្រោះអត្ថថា លោកមិនមានធម៌ដែលធ្លាក់ទៅ អធិប្បាយថា ការធ្លាក់ទៅក្នុងអបាយ ជាសភាវៈមិនមានដល់លោក ។

ឈ្មោះថា ជាបុគ្គលទៀង ព្រោះជាបុគ្គលទៀងទាត់ដោយមគ្គ ដែលកំណត់ដោយភាពជាធម្មតាត្រូវ ។ ឈ្មោះថា ជាបុគ្គលដែលត្រាស់ដឹងក្នុងខាងមុខ ព្រោះអត្ថថា ព្រះសោតាបន្ននោះ មានការត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ គឺជាគតិខាងមុខ អធិប្បាយថា ព្រះសោតាបន្ននោះ នឹងធ្វើខ្លួនឲ្យសម្រេចដល់មគ្គ ៣ ខាងលើពិតប្រាកដ ។ ព្រោះហេតុអ្វី ព្រោះលោកបានបឋមមគ្គហើយ ដូច្នេះ ។

## អាចិណ្ណៈ ២ យ៉ាង

[៩] គ្រានោះឯង ព្រះដ៏មានព្រះភាគ កាលទ្រង់ញ៉ាំងព្រះធម្មសេនាបតីឲ្យយល់ព្រមយ៉ាងនោះហើយ ទ្រង់ស្នាក់នៅរហូតអស់វស្សានោះ ក្នុងស្រុកវេរញ្ជា ទ្រង់ចេញវស្សាក្នុងថ្ងៃមហាបវារណាហើយ ទើបត្រាស់ហៅព្រះអានន្ទមក ។

បទថា **អាមន្តេសិ** សេចក្តីថា ទ្រង់បានហៅ គឺទ្រង់បានត្រាស់ហៅបានដល់ ទ្រង់ជាស់តឿនឲ្យដឹង ។ សួរថា ទ្រង់ជាស់តឿនឲ្យដឹងដូចម្តេច ឆ្លើយថា ទ្រង់ជាស់តឿនឲ្យដឹងរឿងជាដើមយ៉ាងនេះថា **អាចិណ្ណំ ខោ បនេតំ ។**

បទថា **អាចិណ្ណំ** គឺជាការប្រព្រឹត្តជាទំនៀម បានដល់ ជាធម្មតា ។

ឯការធ្លាប់ប្រព្រឹត្តមកនោះឯង មាន ២ យ៉ាងគឺ **ពុទ្ធាចិណ្ណ ១ សាវកាចិណ្ណ ១ ។**

**ពុទ្ធាចិណ្ណ** ដូចម្តេច សេចក្តីថា ព្រះតថាគតទាំងឡាយ កាលមិនទាន់បានលា គឺមិនទាន់បានលាបុគ្គលដែលនិមន្តឲ្យនៅចាំវស្សាហើយ ទ្រង់មិន

ចៀសទៅកាន់ទីចារិកក្នុងជនបទឡើយ ដូច្នេះ នេះជា **តុរិតចារិក** ប្រការ ១ ។ ចំណែកសាវកទាំងឡាយ ទោះលា ឬមិនលាក៏ដោយ រមែងចៀសចេញទៅតាមសប្បាយ ។

នៅមាន **តុរិតចារិក** ដទៃទៀត គឺព្រះពុទ្ធទាំងឡាយ ទ្រង់នៅចាំវស្សាបវារណាហើយ ទ្រង់រមែងទៅកាន់ទីចារិក ក្នុងជនបទនោះឯង ដើម្បីទ្រង់អនុគ្រោះមហាជន ។

## ព្រះដ៏មានព្រះភាគទ្រង់ចារិកទៅកាន់មណ្ឌល

ព្រះពុទ្ធទាំងឡាយ កាលទ្រង់ត្រាច់ចារិកទៅក្នុងជនបទ ទ្រង់រមែងត្រាច់ទៅក្នុងមណ្ឌលណានីមួយ បណ្ដាមណ្ឌលទាំង ៣ គឺ **មហាមណ្ឌល** ( មណ្ឌលធំ ) ១ **មជ្ឈិមមណ្ឌល** ( មណ្ឌលកណ្ដាល ) ១ **អន្តិម-មណ្ឌល** ( មណ្ឌលតូច ) ១ ។

បណ្ដាមណ្ឌលទាំង ៣ នោះ មហាមណ្ឌលប្រមាណ ៩០០ យោជន៍ មជ្ឈិមមណ្ឌលប្រមាណ ៦០០ យោជន៍ អន្តិមមណ្ឌលប្រមាណ ៣០០ យោជន៍ ។

ក្នុងកាលណា ព្រះពុទ្ធទាំងឡាយ មានបំណងនឹងយាងចារិកទៅក្នុងមហាមណ្ឌល ក្នុងកាលនោះ ទ្រង់បវារណាក្នុងថ្ងៃមហាបវារណាហើយ មានមហាភិក្ខុសង្ឃជាបរិវារ ទ្រង់ចេញទៅក្នុងថ្ងៃបាដិបទ កាលទ្រង់អនុគ្រោះមហាជន ក្នុងស្រុក និងនិគមជាដើម ដោយទ្រង់ទទួលអាមិស និងកាលទ្រង់បន្ថែមកុសល ដែលអាស្រ័យវិវដ្ដគាមិនីដល់មហាជននោះដោយធម្មទាន

ទ្រង់ញុំាងការយាងចារិកទៅក្នុងជនបទឲ្យសម្រេចអស់កាល ៩ ខែ ។

បើខាងក្នុងវស្សា សមថៈ និងវិបស្សនារបស់ភិក្ខុទាំងឡាយនៅទន់ខ្ចី នៅឡើយ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនបវារណាក្នុងថ្ងៃបវារណាឡើយ ទ្រង់ប្រទានបវារណាសង្គហៈ ទៅបវារណាក្នុងថ្ងៃពេញបូណ៌មី ខែកត្តិកស្រេចហើយ មានមហាភិក្ខុសង្ឃជាបរិវារ យាងចេញទៅក្នុងថ្ងៃខាងដើម ខែមិគសិរ ហើយញុំាងការយាងត្រាច់ចារិកទៅក្នុងមជ្ឈិមមណ្ឌល ឲ្យចប់សព្វគ្រប់ អស់កាល ៨ ខែ តាមន័យដូចពោលមកហើយនោះឯង ។

បើវេនេយ្យសត្វទាំងឡាយរបស់ព្រះពុទ្ធ ដែលទ្រង់យាងចេញវស្សាហើយទាំងនោះ នៅមានឥន្ទ្រិយមិនទាន់ចាស់ក្លា ព្រះពុទ្ធទាំងឡាយទ្រង់ក៏រង់ចាំឲ្យវេនេយ្យសត្វទាំងនោះ មានឥន្ទ្រិយចាស់ក្លា ទ្រង់ស្នាក់នៅទីកន្លែងនោះឯង អស់ខែមិគសិរ ហើយមានមហាភិក្ខុសង្ឃជាបរិវារ ទ្រង់ចេញទៅក្នុងថ្ងៃខាងដើមនៃខែបុស្ស ហើយទ្រង់ញុំាងការយាងចារិកទៅ ក្នុងអន្តិមមណ្ឌលឲ្យស្រេចចប់សព្វគ្រប់ក្នុង ៧ ខែ តាមន័យដូចពោលមកហើយនោះឯង ។

ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយ កាលយាងត្រាច់ទៅក្នុងបណ្តាមណ្ឌលទាំងនោះ កន្លែងណាមួយ ទ្រង់ដោះសត្វទាំងឡាយនោះៗ ឲ្យផុតចាកកិលេសទាំងឡាយ ទ្រង់ប្រកបសត្វទាំងឡាយនោះ ទុកដោយអរិយផល មានសោតាបត្តិផលជាដើម ទ្រង់ត្រាច់ទៅដោយអំណាចនៃវេនេយ្យសត្វ ប៉ុណ្ណោះ ដូចទ្រង់រក្សាផ្កាដែលមានពណ៌ ៥ ដូច្នោះ ។

នៅមានពុទ្ធាចិណ្ណៈដទៃទៀត គឺក្នុងវេលាអរុណរះរាល់ៗ ថ្ងៃ កាល

ទ្រង់ធ្វើព្រះនិព្វានដែលជាសុខស្ងប់ឲ្យជាអារម្មណ៍ ទ្រង់ចូលផលសមាបត្តិ ចេញអំពីផលសមាបត្តិហើយ ទ្រង់ចូលសមាបត្តិដែលប្រកបដោយព្រះមហាករុណា ក្រោយអំពីនោះ ទ្រង់ក៏ប្រមើលមើលវេនេយ្យសត្វ ដែលល្មមនឹងប្រោសឲ្យត្រាស់ដឹងបាន ក្នុងម៉ឺនចក្រវាល ។

នៅមានពុទ្ធាចិណ្ណៈដទៃទៀត គឺទ្រង់ធ្វើបដិសណ្ឋារៈនឹងពួកអាគន្តុកៈស្រេចហើយ ទ្រង់សម្តែងធម៌ ដោយអំណាចរឿងដែលកើតឡើង កាលទោសកើតឡើង ទ្រង់បញ្ញត្តសិក្ខាបទ នេះជាពុទ្ធាចិណ្ណៈ ដូចពណ៌នាមកដូច្នេះឯង ។

## សាវកាចិណ្ណៈ

សាវកាចិណ្ណៈដូចម្តេច គឺក្នុងកាលនៃព្រះដ៏មានព្រះភាគ មានការប្រជុំ ( សាវក ) ២ ដង គឺពេលមុនចូលវស្សា និងថ្ងៃចូលវស្សា ដើម្បីរៀនយកកម្មដ្ឋាន ១ ដើម្បីប្រាប់គុណដែលបានសម្រេចដល់ភិក្ខុដែលចេញវស្សាមកហើយ ១ ដើម្បីរៀនយកកម្មដ្ឋានដែលខ្ពស់ៗ ឡើងទៅ ១ នេះជាសាវកាចិណ្ណៈ ។ ចំណែកក្នុងអធិការនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងដល់ពុទ្ធាចិណ្ណៈ ទើបត្រាស់ពាក្យជាដើមថា **អាចិណ្ណំ ខោ បនេតំ អានន្ទ តថាគតានំ** ដូច្នេះ ។

បទថា **អាយាម** ប្រែថា មក យើងទៅរួមគ្នាចុះ ។

បទថា **អបលោកេស្សាម** គឺយើងនឹងលា ( វេរញ្ជព្រាហ្មណ៍ ) ដើម្បីត្រាច់ទៅកាន់ទីចារិក ។

សព្ទថា **ឯវំ** ជានិបាត ចុះក្នុងអត្ថថា ព្រមទទួល ។

ពាក្យថា **ភន្តេ** នោះ ជាឈ្មោះហៅដោយសេចក្តីគោរព និងនិយាយថ្វាយពាក្យទូលតបចំពោះព្រះសាស្តា ដូច្នេះ ក៏ប្រើបាន ។

ពីរបទថា **ភគវតោ បច្ចស្សោសិ** សេចក្តីថា ព្រះអានន្ទទទួលព្រះតម្រាស់ គឺតម្រង់មុខស្តាប់ បានទទួលព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ។ អធិប្បាយថា ទទួលដោយពាក្យថា **ឯវំ** នេះ ។

ក្នុងពាក្យថា **អថខោ ភគវា និវាសេត្វា** នេះ ព្រះឧបាលីមិនបានពោលទុកថា ជាពេលព្រឹក ឬពេលល្ងាចឡើយ ។ សូម្បីដូច្នោះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់បង្អង់នៅរហូតដល់ពេលថ្ងៃត្រង់ ឲ្យព្រះអានន្ទជាបច្ឆាសមណៈ ទ្រង់ញុំាងថ្នល់ក្នុងព្រះនគរឲ្យចាប់ផ្តើម តាំងពីទ្វារព្រះនគរទៅ ឲ្យរុងរឿងទៅដោយពុទ្ធរស្មី ដែលមានសំណុំដូចខ្សែមាស ទ្រង់ចូលទៅដោយផ្លូវ ត្រង់និវេសន៍របស់វេរញ្ជព្រាហ្មណ៍នោះតាំងនៅ ។ ឯបរិជន ឃើញព្រះដ៏មានព្រះភាគ ដែលកំពុងប្រថាប់ឈរត្រង់ទ្វារផ្ទះរបស់វេរញ្ជព្រាហ្មណ៍ប៉ុណ្ណោះ ក៏បានប្រាប់ដំណឹងដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍ក៏ត្រឡប់រឭកបានហើយ កើតសេចក្តីសង្វេគ ទើបប្រញាប់ក្រោកឡើង បញ្ជាឲ្យរៀបចំក្រាលអាសនៈ ដែលគួរដល់តម្លៃច្រើន ចេញទៅទទួលព្រះដ៏មានព្រះភាគ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សូមទ្រង់យាងចូលមកតាមផ្លូវនេះចុះ ។ ព្រះដ៏មានព្រះភាគបានយាងចូលទៅប្រថាប់គង់លើអាសនៈដែលគេរៀបចំទុក លំដាប់នោះឯង វេរញ្ជព្រាហ្មណ៍ មានបំណងនឹងចូល

ទៅអង្គុយជិតព្រះដ៏មានព្រះភាគ ទើបបានចូលទៅគាល់ដោយផ្លូវដែលព្រះដ៏មានព្រះភាគប្រថាប់គង់អំពីទីដែលខ្ទនឈរ ។ ពាក្យខាងមុខតទៅ មានអត្ថភ្លឺច្បាស់ហើយទាំងអស់ ។

ក្នុងពាក្យដែលព្រាហ្មណ៍ក្រាបទូលថា ម្យ៉ាងទៀត ទេយ្យធម៌ដែលគួរនឹងប្រគេន ខ្ញុំព្រះអង្គមិនបានប្រគេន មានពាក្យអធិប្បាយថា ខ្ញុំព្រះអង្គមិនទាន់បានប្រគេនទេយ្យធម៌ដែលគួរប្រគេនជាដើមយ៉ាងនេះ គឺរាល់ៗ ថ្ងៃអស់ ៣ ខែ ពេលព្រឹកគួរប្រគេនយាគូ និងរបស់គួរទំពា ពេលថ្ងៃត្រង់ គួរប្រគេនខាទនីយៈ ភោជនីយៈ ពេលល្ងាច គួរបូជាសក្ការៈ ដោយវត្ថុ មានទឹកបានៈដែលផ្សំប្រភេទផ្សេងៗ ជាច្រើន គ្រឿងក្រអូប និងផ្កាជាដើមដល់ព្រះអង្គដែលខ្ញុំព្រះអង្គនិមន្តឲ្យនៅចាំវស្សាហើយ ។ ឯក្នុងពាក្យថា **តញ្ច ខោ នោ អសន្តំ** នេះ គប្បីជ្រាបថា ជាលិង្គវិបល្លាស ។ ក្នុងពាក្យនេះ មានអត្ថដូច្នេះថា ឯទេយ្យធម៌នោះ មិនមានដល់ខ្ញុំព្រះអង្គក៏ទេ ។ ម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងពាក្យនេះយ៉ាងនេះថា ខ្ញុំព្រះអង្គគប្បីប្រគេនរបស់ណាមួយ ដល់ព្រះអង្គ ឯរបស់នោះ មិនមែនមិនមានឡើយ ។ ពាក្យថា **នោ បិ អទាតុកម្យតា** សេចក្ដីថា ការមិនចង់ប្រគេនរបស់ខ្ញុំព្រះអង្គ ដូចរបស់ពួកជនដែលមានសេចក្ដីកំណាញ់ ដែលមានគ្រឿងឧបភោគបរិភោគ ជាគ្រឿងរីករាយចិត្តជាច្រើន មិនចង់ប្រគេនដូច្នោះ ក៏មិនមាន ។ ខាងក្នុង ៣ ខែនេះ ព្រះអង្គនឹងគប្បីបានទេយ្យធម៌នោះអំពីណា ព្រោះឃរាវាសមានកិច្ចច្រើន មានករណីច្រើន ។ ក្នុងពាក្យថា **តំ កុតេត្ថ លព្ភា ពហុកិច្ចា ឃរាវាសា** នោះ

មានការប្រកបសេចក្តីយ៉ាងនេះថា ព្រាហ្មណ៍កាលនឹងតិះដៀលការនៅគ្រប់គ្រងផ្ទះ ទើបបានក្រាបទូលថា ព្រោះការនៅគ្រប់គ្រងផ្ទះមានកិច្ចច្រើន ដូច្នោះ ខាងក្នុងត្រីមាសនេះ កាលទេយ្យធម៌ និងសេចក្តីប្រាថ្នាដើម្បីប្រគេនមាន ព្រះអង្គគប្បីបានទេយ្យធម៌ដែលខ្ញុំព្រះអង្គ គប្បីប្រគេនដល់ព្រះអង្គអំពីទីណា គឺព្រះអង្គអាចបានទេយ្យធម៌នោះ អំពីទីណា ។ បានឮថា វេរញ្ជព្រាហ្មណ៍ នោះ រមែងមិនដឹងភាពដែលខ្លួនត្រូវមារបណ្តាលចិត្ត ទើបបានសម្គាល់ថា អញកើតជាអ្នកមានសតិភ្លេចភ្លាំង ព្រោះរវល់តែខ្វល់ខ្វាយ ដោយការគ្រប់គ្រងផ្ទះ ។ ព្រោះដូច្នោះ ទើបព្រាហ្មណ៍ក្រាបទូលយ៉ាងនោះ ។

ម្យ៉ាងទៀត ក្នុងពាក្យថា **តំ កុតេត្ថ លព្ភា** នេះ គប្បីជ្រាបការប្រកបសេចក្តីយ៉ាងនេះថា ខាងក្នុង ៣ ខែនេះ ខ្ញុំគប្បីថ្វាយទេយ្យធម៌ឯណាដល់ព្រះអង្គ ទេយ្យធម៌នោះ ខ្ញុំគប្បីបានអំពីណា ព្រោះថា ការនៅគ្រប់គ្រងផ្ទះមានកិច្ចច្រើន ។

គ្រានោះ ព្រាហ្មណ៍ត្រិះរិះថា ទេយ្យធម៌ណា ជារបស់ដែលអញគប្បីប្រគេនដោយ ៣ ខែ អញគួរប្រគេនទេយ្យធម៌ទាំងអស់នោះ ដោយថ្ងៃមួយប៉ុណ្ណោះ ហើយទើបក្រាបទូលពាក្យជាដើមថា សូមព្រះគោតមទ្រង់មេត្តាទទួលភត្តាហាររបស់ខ្ញុំព្រះអង្គចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ស្វាតនាយ** សេចក្តីថា ដើម្បីប្រយោជន៍ដល់បុណ្យកុសល និងបីតិបាមោជ្ជ ដែលនឹងមានក្នុងថ្ងៃស្អែកនេះ ក្នុងកាលខ្ញុំព្រះអង្គបានធ្វើសក្ការៈក្នុងព្រះអង្គ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ជាព្រះតថាគត ទ្រង់ពិចារណាថា បើតថាគតមិនទទួលពាក្យអារាធនាសោត ព្រាហ្មណ៍ និងអ្នកស្រុកវេរញ្ជា គប្បីនិន្ទាយ៉ាងនេះថា សមណៈអង្គនេះ មិនបានវត្ថុណាមួយអស់ ៣ ខែ ប្រហែលជាខឹងទេដឹង ព្រោះហេតុនោះ អញអង្វរក៏ទ្រង់មិនព្រមទទួល សូម្បីភត្តាហារមួយពេល ក្នុងព្រះសមណៈអង្គនេះ មិនមានអធិវាសនខន្តី សមណៈអង្គនេះមិនមែនជាសព្វញ្ញូឡើយ នឹងជួបរបស់ដែលមិនមែនជាបុណ្យដ៏ច្រើន ការជួបរបស់ដែលមិនមែនជាបុណ្យនោះ កុំមានដល់ជនទាំងនោះឡើយ ដូច្នេះហើយ ទើបទ្រង់ទទួលពាក្យអារាធនាដើម្បីអនុគ្រោះដល់ជនទាំងនោះ ដោយតុណ្ហីភាព ។

គ្រានោះឯង ព្រះដ៏មានព្រះភាគ កាលទ្រង់ទទួលអារាធនាហើយ ទ្រង់បានដាស់តឿនវេរញ្ជព្រាហ្មណ៍ឲ្យយល់ព្រមថា មិនគួរគិតដល់ការកន្លល់ដោយការនៅគ្រប់គ្រងផ្ទះឡើយ ហើយទ្រង់ចង្អុលឲ្យវេរញ្ជព្រាហ្មណ៍ឃើញប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍ខាងមុខ ឲ្យសមាទាន គឺឲ្យទទួលយកកុសលធម៌ និងឲ្យវេរញ្ជព្រាហ្មណ៍នោះឲ្យអាចហ៊ាន គឺធ្វើឲ្យមានឧស្សាហៈក្នុងកុសលធម៌ តាមដែលខ្លួនសមាទានហើយនោះ ហើយទ្រង់លួមលោមឲ្យរីករាយដោយភាពជាអ្នកមានឧស្សាហៈនោះ និងដោយគុណធម៌ដែលមានដទៃទៀត ដោយធម្មីកថាដ៏សមគួរដល់ខណៈនោះ ទ្រង់បានញុំាងភ្លៀង គឺព្រះធម្មរតនៈឲ្យធ្លាក់ចុះហើយ ទ្រង់ក៏ក្រោកចាកអាសនៈ និមន្តត្រឡប់ទៅ ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រឡប់ទៅហើយ វេរញ្ជព្រាហ្មណ៍បាន

ហៅបុត្រ និងភរិយាមកប្រាប់ថា នែអ្នកដ៏ចម្រើន ខ្ញុំបាននិមន្តព្រះដ៏មានព្រះភាគ ( ឲ្យនៅចាំវស្សា ) អស់ត្រៃមាសហើយ សូម្បីមួយថ្ងៃ ក៏មិនបានប្រគេនភត្តាហារត្រឹមតែមួយដុំឡើយ ណ្ហើយចុះ ឥឡូវនេះ ពួកអ្នកចូររៀបចំទាន ឲ្យដូចជាទេយ្យធម៌ ដែលគួរថ្វាយអស់ត្រៃមាស ជារបស់អាចប្រគេនក្នុងថ្ងៃស្អែកនេះបានដោយមួយថ្ងៃប៉ុណ្ណោះ ។

បន្ទាប់អំពីនោះ វេរញ្ជព្រាហ្មណ៍ប្រាប់ឲ្យរៀបចំទានដ៏ប្រណីត ពេញមួយថ្ងៃ ដែលខ្លួននិមន្តព្រះដ៏មានព្រះភាគ ដោយកន្លងទៅនៃរាត្រីនោះ ក៏បានប្រាប់ឲ្យរចនាត្រង់តាំងអាសនៈ ឲ្យក្រាលអាសនៈទាំងឡាយដែលមានតម្លៃច្រើន រៀបចំការបូជាយ៉ាងធំ ដែលវិចិត្រដោយគ្រឿងក្រអូប ធូបក្រអូប គ្រឿងអប់ និងផ្កាកុសុមរួចស្រេចហើយ ទើបប្រាប់ឲ្យមេការទៅក្រាបទូលផ្ទៀងកាលដល់ព្រះដ៏មានព្រះភាគ ។ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរបានពោលថា **អថខោ វេរញ្ជោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន ។បេ។ និដ្ឋិតំ ភត្តំ ។**

ព្រះដ៏មានព្រះភាគ មានភិក្ខុសង្ឃហែហមហើយ បានយាងទៅឯនិវេសន៍របស់ព្រាហ្មណ៍នោះ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរបានពោលថា **អថខោ ភគវា ។បេ។ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។**

បទថា **ពុទ្ធប្បមុខំ** ក្នុងពាក្យថា **អថខោ វេរញ្ជោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ** នេះ ប្រែថា មានព្រះពុទ្ធជាប្រធាន អធិប្បាយថា ទ្រង់គង់ជាព្រះសង្ឃត្ថេរ ។

បទថា **បណីតេន** ប្រែថា ដ៏ប្រណីត ។

បទថា **សហត្ថា** ប្រែថា ដោយដៃរបស់ខ្លួនឯង ។

បទថា **សន្តប្បេត្វា** សេចក្តីថា ឲ្យឆ្អែតដោយល្អ គឺឲ្យបរិបូណ៌ បាន ដល់ ស្កប់ស្កល់ដោយល្អ រហូតល្មមដល់សេចក្តីត្រូវការ ។

បទថា **សម្បវារេត្វា** សេចក្តីថា ឲ្យទ្រង់ឃាត់ដោយល្អ គឺឲ្យទ្រង់ ជំទាស់ដោយហត្ថសញ្ញា មុខសញ្ញា និងវចីភេទថា ល្មមហើយៗ ។

បទថា **ភុត្តាវី** ប្រែថា ដែលសោយស្រេចហើយ ។

បទថា **ឱនីតបត្តបាណឹ** ប្រែថា ទ្រង់នាំព្រះហស្តចេញអំពីបាត្រ អធិប្បាយថា ទ្រង់ដកព្រះហស្តចេញហើយ ( ទ្រង់លាងព្រះហស្តហើយ ) ។

ពីរបទថា **តិចីវរេន អច្ឆាទេសិ** សេចក្តីថា ( ព្រាហ្មណ៍ ) បានប្រគេន ត្រៃចីវរដល់ព្រះដ៏មានព្រះភាគ ។ ឯពាក្យថា **តិចីវរេន អច្ឆាទេសិ** នេះ ត្រឹមតែជាវោហារវចនៈ ក្នុងត្រៃចីវរនោះ សំពត់សាដកតែមួយផ្ទាំង មាន តម្លៃ ១០០០ ។ ព្រាហ្មណ៍បានប្រគេនត្រៃចីវរដែលល្អក្រៃលែង ដូចជា សំពត់ដែលកើតក្នុងដែនកាសី មានតម្លៃដល់ ៣០០០ ដល់ព្រះដ៏មានព្រះភាគ ដោយប្រការដូច្នេះ ។

ច្រើនបទថា **ឯកមេកញ្ច ភិក្ខុំ ឯកមេកេន ទុស្សយុគេន** សេចក្តីថា ព្រាហ្មណ៍បានឲ្យភិក្ខុមួយអង្គៗ គ្រងដោយសំពត់មួយគូៗ ។ បណ្តាសំពត់ ទាំងនោះ សំពត់នីមួយៗ មានតម្លៃ ៥០០ ។ ព្រាហ្មណ៍បានប្រគេនសំពត់ មានតម្លៃ ៥ សែន ដល់ភិក្ខុ ៥០០ អង្គ ដោយប្រការដូច្នេះ ។ ព្រាហ្មណ៍ ប្រគេនហើយ សូម្បីដល់ប៉ុណ្ណោះ ក៏នៅមិនទាន់ល្មមដល់ចិត្ត បានបែងចែក

សំពត់កម្ពលក្រហម និងសំពត់បត្តុណ្ណៈ និងសំពត់ដណ្តប់ដ៏សន្ទឹកសន្ទាប់ មានតម្លៃ ៧-៨ ពាន់ ប្រគេនដើម្បីប្រយោជន៍ដល់បរិក្ខារ មានសំពត់រឹតជង្គង់ សំពត់ទៀង វត្ថុពន្ធចង្កេះ និងសំពត់តម្រងទឹកជាដើមទៀត និងបានវាល់ប្រេងថ្នាំដែលចម្រាញ់រាប់រយពាន់ដងឲ្យពេញនាឡិ ប្រគេនប្រេង មានតម្លៃ ១០០០ ដើម្បីប្រយោជន៍ដល់ការលាប ដល់ភិក្ខុមួយអង្គៗ ។ នឹងមានប្រយោជន៍អ្វីដោយការពោលច្រើនក្នុងបច្ច័យ ៤ ។ បរិក្ខារណាមួយ ដែលជាគ្រឿងប្រើប្រាស់របស់សមណៈ ឈ្មោះថា ព្រាហ្មណ៍មិនបានប្រគេនហើយមិនមាន តែក្នុងបាលីពោលត្រឹមតែចីវរប៉ុណ្ណោះ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគ កាលទ្រង់ញុំាងភ្លៀង គឺអមតធម៌ឲ្យធ្លាក់ចុះ ធ្វើវេរញ្ញព្រាហ្មណ៍ដែលសាបសូន្យ ខានបរិភោគរសនៃអមតៈ គឺការស្តាប់ធម៌ ដោយត្រូវមារបណ្តាលចិត្ត ឲ្យភ្លេចភ្លាំងអស់ ៣ ខែ ដែលធ្វើការបូជាធំយ៉ាងនោះហើយ មួយអន្លើដោយបុត្រ និងភរិយា ដែលកំពុងថ្វាយបង្គំ ហើយអង្គុយឲ្យជាអ្នកមានតម្រិះត្រូវពេញបរិបូណ៌ ដោយថ្ងៃមួយប៉ុណ្ណោះ ទើបញុំាងព្រាហ្មណ៍ឲ្យឃើញ ឲ្យសមាទាន ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈនិមន្តទៅ ចំណែកព្រាហ្មណ៍ បុត្រ និងភរិយា ថ្វាយបង្គំព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឃហើយ ដើរតាមព្រះដ៏មានព្រះភាគទៅបណ្តើរ ពោលពាក្យជាដើមបណ្តើរយ៉ាងនេះថា បពិត្រព្រះអង្គ សូមព្រះអង្គធ្វើការអនុគ្រោះដល់ខ្ញុំព្រះអង្គទាំងឡាយទៀត ហើយបណ្តោយឲ្យទឹកភ្នែកហូរចុះមក ។

ប្រើនបទថា **អថខោ ភគវា វេរញ្ជាយំ យថាភិរន្តំ វិហរិត្វា** សេចក្តីថា ព្រះដ៏មានព្រះភាគ ទ្រង់នៅតាមព្រះអធ្យាស្រ័យ គឺតាមការពេញចិត្តហើយ ចេញអំពីស្រុកវេរញ្ជា ទ្រង់មានព្រះបំណងលះពុទ្ធវិថី យាងទៅក្នុងកាលដែលយាងចារិកក្នុងមហាមណ្ឌល ទ្រង់នាំភិក្ខុសង្ឃ ដែលលំបាកដោយទុព្ភិក្ខទោស យាងទៅដោយផ្លូវត្រង់ ទើបទ្រង់មិនគេចស្រុកទាំងឡាយមាននគរសោរេយ្យជាដើម ទ្រង់យាងទៅកាន់ស្រុកបយាគបតិដ្ឋាន ឆ្លងទន្លេគង្គា នាស្រុកនោះហើយ យាងទៅដោយទិសាភាគ ក្រុងពារាណសី ។ ព្រះដ៏មានព្រះភាគ បានយាងទៅដោយទិសាភាគនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **តទវសរិ** ។ ទ្រង់ប្រថាប់នៅតាមព្រះអធ្យាស្រ័យក្នុងក្រុងពារាណសីនោះហើយ បានយាងទៅកាន់ក្រុងវេសាលី ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា ទ្រង់មិនវាងនគរសោរេយ្យ នគរសង្កស្សៈ នគរកណ្ណកុជ្ជៈ យាងទៅតាមផ្លូវស្រុកបយាគបតិដ្ឋាន ហើយយាងឆ្លងទន្លេគង្គា ត្រង់ស្រុកបយាគបតិដ្ឋាន ទៅដោយទិសាភាគ ឆ្ពោះក្រុងពារាណសី ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់នាកាឡបក្ខ ក្នុងក្រុងពារាណសីតាមពេញព្រះទ័យ ហើយទ្រង់ចៀសចារិកទៅតាមផ្លូវក្រុងវេសាលី កាលយាងចារិកទៅដោយលំដាប់ ទ្រង់បានដល់ក្រុងវេសាលី ។ បានឮថា ព្រះដ៏មានព្រះភាគ ប្រថាប់នៅត្រង់កូដាគារសាលា ក្នុងព្រៃមហាវ័ន ជិតក្រុងវេសាលីនោះ ។

វេរញ្ជកណ្ឌវណ្ណនាក្នុងអដ្ឋកថាវិន័យ

ឈ្មោះ សមន្តប្បាសាទិកា ចប់

## វេរញ្ជកណ្ឌវណ្ណនាគាថា

ក្នុងអដ្ឋកថា ឈ្មោះសមន្តប្បាសាទិកា ក្នុងវិន័យនោះ នាំឲ្យកើតជ្រះថ្លាដោយជុំវិញ មានពាក្យអធិប្បាយដូចពោលតទៅនេះថា

កាលវិញ្ញូជនទាំងឡាយ ធ្លុះបញ្ចាំងដោយលំដាប់នៃអាចារ្យ ដោយការសម្តែងប្រភេទនិទាន និងវត្ថុ ដោយវៀរលទ្ធិដទៃ ដោយសេចក្តីបរិសុទ្ធនៃលទ្ធិរបស់ខ្លួន ដោយការជម្រះ ព្យញ្ជនៈឲ្យល្អរៀបរយ ដោយអត្ថចំពោះបទ ដោយលំដាប់នៃបាលី និងយោជនានៃបាលី ដោយការវិនិច្ឆ័យសិក្ខាបទ និងដោយការចង្អុលបង្ហាញសេចក្តីផ្សេងគ្នា របស់ន័យក្នុងវិភង្គ ពាក្យបន្តិចបន្តួចដែលមិននាំឲ្យកើតសេចក្តីជ្រះថ្លា រមែងមិនប្រាកដក្នុងសមន្តប្បាសាទិកានេះ ព្រោះហេតុនោះ វិនយវណ្ណនា ដែលព្រះលោកនាថ ទ្រង់អនុគ្រោះសត្វលោក ទ្រង់ឈ្លាសក្នុងការទូន្មានវេនេយ្យសត្វបានត្រាស់ទុក ទើបប្រព្រឹត្តទៅដោយឈ្មោះថា សមន្តប្បាសាទិកា ដូច្នេះ ។

វេរញ្ជកណ្ឌវណ្ណនា ចប់

# វិនយបិដក

## បារាជិកកណ្ឌ

## សិក្ខាបទទី ១

[ ១០ ] សម័យនោះឯង មានស្រុកមួយឈ្មោះកលន្ទនៅមិនឆ្ងាយប៉ុន្មានអំពីក្រុងវេសាលី ។ ក្នុងស្រុកនោះមានកូនសេដ្ឋីម្នាក់ឈ្មោះសុទិន្នកុមារជាបុត្ររបស់កលន្ទសេដ្ឋី ។ គ្រានោះ សុទិន្នកុមារកលន្ទបុត្រជាមួយនឹងសម្លាញ់ទាំងឡាយច្រើននាក់ នាំគ្នាទៅឯក្រុងវេសាលី ដោយមានកិច្ចការអ្វីមួយ ។ សម័យនោះឯង ព្រះដ៏មានព្រះភាគជាអម្ចាស់មានពពួកបរិស័ទច្រើនគាល់ត្រៀបត្រា ទ្រង់កំពុងគង់សម្តែងធម៌ ។ សុទិន្នកលន្ទបុត្រ ក៏ទៅប្រទះបានឃើញព្រះអង្គមានបរិសទ្យច្រើនគាល់ត្រៀបត្រា កំពុងគង់សម្តែងធម៌ ។ លុះឃើញហើយ សុទិន្នកុមារនោះក៏មានសេចក្តីត្រិះរិះថា អាត្មាអញគួរតែស្តាប់ធម៌សិន ។ គ្រានោះ សុទិន្នកលន្ទបុត្រក៏ចូលទៅកាន់ទីដែលបរិសទ្យអង្គុយនោះ លុះចូលទៅហើយបានអង្គុយនៅក្នុងទីមួយដ៏សមគួរ ។ កាលដែលសុទិន្នកុមារកលន្ទ-បុត្របានអង្គុយនៅក្នុងទីមួយដ៏សមគួរហើយ ក៏មានសេចក្តីត្រិះរិះថា ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដោយដំណើរយ៉ាងណាៗ អញក៏បានស្តាប់យល់តាមដំណើរទាំងនោះហើយ ប៉ុន្តែបើអញនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ បើលុះតែអញកោរសក់ និងពុកមាត់ពុកចង្ការួចស្លៀកដណ្តប់សំពត់ជ្រលក់អម្ចត់ ហើយចេញចាកផ្ទះទៅបួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ ដោយកិច្ចការក្នុងផ្ទះ ( នោះទើបប្រព្រឹត្តព្រហ្ម-

ចរិយធម៌កើត ) ។ គ្រានោះ ពួកពុទ្ធបរិសទ្យបានស្តាប់ធម្មីកថាដែលព្រះដ៏មានព្រះភាគ ទ្រង់ណែនាំពន្យល់ឲ្យជឿជាក់កុសលធម៌ ឲ្យរីករាយរាល់គ្នាហើយ ក៏ក្រោកចាកទីអង្គុយ ក្រាបថ្វាយបង្គំព្រះអង្គ រួចដើរប្រទក្សិណហើយ ក៏ចេញអស់ទៅ ។ ឯសុទិន្នកលន្ទបុត្រ កាលបើពួកពុទ្ធបរិសទ្យក្រោកទៅអស់ហើយភ្លាម ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្រាបថ្វាយបង្គំព្រះអង្គដោយគោរព រួចអង្គុយក្នុងទីមួយដ៏សមគួរ ។ លុះសុទិន្នកលន្ទបុត្រ អង្គុយនៅក្នុងទីមួយដ៏សមគួរហើយ ក៏ក្រាបទូលព្រះអង្គថា សូមទ្រង់ព្រះមេត្តាប្រោស ធម៌ដែលព្រះអង្គសម្តែងហើយដោយដំណើរយ៉ាងណាៗ ខ្ញុំព្រះអង្គបានយល់តាមដំណើរទាំងនោះដែរហើយ ប៉ុន្តែបើខ្ញុំព្រះអង្គនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ ( យ៉ាងនេះ ) ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ សូមទានខ្ញុំព្រះអង្គចង់កោរសក់និងពុកមាត់ ពុកចង្កា រួចស្លៀកដណ្តប់សំពត់ជ្រលក់អម្ចត់ហើយចេញចាកផ្ទះមកបួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ ដោយកិច្ចការក្នុងផ្ទះ ( នោះណាស់ ) សូមព្រះដ៏មានជោគទ្រង់បំបួសខ្ញុំព្រះអង្គផង ។ ព្រះសាស្តាទ្រង់ត្រាស់សួរថា ម្នាលសុទិន្ន ចុះអ្នកឯងមាតាបិតាបានយល់ព្រមឲ្យចេញចាកផ្ទះមកបួសប្រតិបត្តិក្នុងបព្វជ្ជា ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះហើយឬ ។ សុទិន្នក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមាតាបិតាមិនទាន់បានយល់ព្រមឲ្យចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនានៅឡើយទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលសុទិន្ន ព្រះតថាគតទាំងឡាយ មិនដែល

បំបួសកូនដែលមាតាបិតា មិនទាន់អនុញ្ញាតនោះទេ ។ សុទិន្នក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងទទួចលាមាតាបិតា ត្រាតែអនុញ្ញាតឲ្យខ្ញុំព្រះអង្គចេញចាកផ្ទះ មកបួសក្នុងព្រះពុទ្ធសាសនាឲ្យបាន ។

[ ១១ ] លំដាប់នោះ សុទិន្នកលន្ទបុត្រ បានសម្រេចកិច្ចការដែលខ្លួនត្រូវធ្វើក្នុងក្រុងវេសាលីនោះរួចស្រេចហើយ ក៏វិលត្រឡប់មកស្រុកកលន្ទវិញ បានចូលទៅរកមាតាបិតាហើយ ជម្រាបមាតាបិតាថា បពិត្រអ្នកម្តាយ អ្នកឪពុក ខ្ញុំបាទបានស្តាប់ធម៌ដែលព្រះដ៏មានជោគទ្រង់សម្តែងដោយដំណើរ យ៉ាងណាៗ ក៏យល់តាមដំណើរទាំងនោះហើយ ខ្ញុំបាទគិតថា បើខ្ញុំនៅជា គ្រហស្ថគ្រប់គ្រងផ្ទះនោះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ ខ្ញុំបាទចង់កោរសក់ និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សំពត់ជ្រលក់អម្ចត់ ហើយចេញចាកផ្ទះ ទៅបួសប្រតិបត្តិក្នុងផ្នួសដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ ( នោះណាស់ ) សូមអ្នកម្តាយ អ្នកឪពុកអនុញ្ញាតឲ្យខ្ញុំបាទចេញចាកផ្ទះ ទៅបួសក្នុងព្រះពុទ្ធសាសនាទាន ។ មាតាបិតារបស់សុទិន្នកលន្ទបុត្រ កាលបើបានឮកូនលាដូច្នេះហើយ ក៏និយាយឃាត់ថា ម្នាលសុទិន្នកូន បាឯងជាបុត្រឯករបស់យើង ជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់ឋិតនៅក្នុងសេចក្តីសុខ មានអ្នកទំនុកបម្រុងឲ្យបានសេចក្តីសុខ នែសុទិន្នកូន បាឯងមិនដែលស្គាល់ទុក្ខបន្តិចបន្តួចសោះឡើយ ទោះបីបាឯងស្លាប់ក្តី យើងក៏មិនចង់ព្រាត់ប្រាសចាកបាឯងទេ យើងនឹងអនុញ្ញាតបាកំពុងរស់នៅ ឲ្យចេញចាកផ្ទះទៅបួសក្នុងព្រះពុទ្ធសាសនាម្តេចបាន ។ ទើប

សុទិន្នកលន្ទបុត្រនិយាយពាក្យនេះនឹងមាតាបិតាជាគម្រប់ពីរដងថា បពិត្រមាតាបិតា ធម៌ដែលព្រះដ៏មានព្រះភាគសម្តែងហើយដោយដំណើរយ៉ាងណាៗ ខ្ញុំបានយល់តាមដំណើរទាំងនោះដែរហើយ ប៉ុន្តែបើខ្ញុំនៅជា គ្រហស្ថគ្រប់គ្រងផ្ទះ ( យ៉ាងនេះ ) ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ ខ្ញុំចង់កោរសក់ និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់ជ្រលក់អម្ចត់ ហើយចេញចាកផ្ទះមកបួសក្នុងព្រះពុទ្ធសាសនា សូមមាតាបិតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះ ទៅបួសក្នុងព្រះពុទ្ធសាសនាទាន ។ មាតាបិតារបស់សុទិន្នកលន្ទបុត្រ ទើបនិយាយនឹងសុទិន្នកលន្ទបុត្រជាគម្រប់ពីរដងដូច្នេះថា នែសុទិន្នកូន បាឯងជាបុត្រតែមួយជាទីស្រឡាញ់ពេញចិត្តរបស់យើង ( បាឯង ) ធ្លាប់បិតនៅក្នុងសេចក្តីសុខ មានអ្នកថែរក្សាឲ្យបានសេចក្តីសុខ នែបាសុទិន្ន បាមិនធ្លាប់ស្គាល់សេចក្តីទុក្ខបន្តិចបន្តួចសោះ ទោះបីស្លាប់បាឯងក្តី យើងមិនចង់ព្រាត់ប្រាសចាកបាទេ យើងនឹងអនុញ្ញាតបាកំពុងរស់នៅ ឲ្យចេញចាកផ្ទះទៅបួសក្នុងព្រះពុទ្ធសាសនាម្តេចបាន ។ សុទិន្នកលន្ទបុត្រ បាននិយាយពាក្យនេះនឹងមាតាបិតាជាគម្រប់បីដងថា បពិត្រមាតាបិតា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងដោយអាការយ៉ាងណាៗ ធម្មតាអ្នកនៅគ្រប់គ្រងផ្ទះនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង បីដូចជាស័ង្ខដែលបុគ្គលដុសខាត់ហើយ មិនងាយធ្វើទេ ខ្ញុំប្រាថ្នាដើម្បីកោរសក់និងពុកមាត់ហើយ ស្លៀកដណ្តប់សំពត់កាសាយៈ ហើយចេញចាកផ្ទះទៅបួស ជាបុគ្គលមិនត្រូវការដោយផ្ទះ ហេតុនេះ សូមមាតា

បិតាអនុញ្ញាតខ្ញុំឲ្យចេញចាកផ្ទះទៅបួស ជាបុគ្គលមិនត្រូវការដោយផ្ទះវិញចុះ ។ មាតាបិតារបស់សុទិន្នកលន្ទបុត្រ បាននិយាយពាក្យនេះនឹងសុទិន្នកលន្ទបុត្រ ជាគម្រប់បីដងថា នែសុទិន្នកូន បាឯងជាបុត្រតែមួយ ជាទីស្រឡាញ់ពេញចិត្ត របស់យើង ធ្លាប់ឋិតនៅតែក្នុងសេចក្តីសុខ មានអ្នកថែទាំឲ្យបានសេចក្តីសុខ នែបាសុទិន្ន បាមិនស្គាល់សេចក្តីទុក្ខបន្តិចសោះ ទោះបីស្លាប់ទៅក្តី យើងក៏មិន ប្រាថ្នាឲ្យព្រាត់ប្រាសចាកបា យើងនឹងអនុញ្ញាតបា ដែលកំពុងរស់នៅឲ្យចេញ ចាកផ្ទះ ហើយបួសក្នុងសាសនាដូចម្តេចបាន ។ គ្រានោះឯង សុទិន្នកលន្ទបុត្រ គិតថា មាតាបិតាមិនអនុញ្ញាតអញឲ្យចេញចាកផ្ទះ បួសក្នុងសាសនា ដូច្នេះ ហើយ ក៏ដួលដេកនៅលើផែនដី ប្រាសចាកគ្រឿងកម្រាលក្នុងទីនោះឯង ដោយ គិតថា អញនឹងស្លាប់ ឬនឹងបានបួសក្នុងទីនេះជាប្រាកដ ។ គ្រានោះ សុទិន្នក-លន្ទបុត្រមិនបានបរិភោគបាយអស់ ១ ពេល ២ ពេលក៏មាន ៣ ពេលក៏មាន ៤ ពេលក៏មាន ៥ ពេលក៏មាន ៦ ពេលក៏មាន ៧ ពេលក៏មាន ។

[ ១២ ] លំដាប់នោះ មាតាបិតារបស់សុទិន្នកលន្ទបុត្រនិយាយនឹង សុទិន្នកលន្ទបុត្រថា ម្នាលសុទិន្នកូន បាឯងជាកូនប្រុសតែមួយ ហើយជាទី ស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់សុខ ធ្លាប់សប្បាយដោយមានស្រីកីលៀង ថែរក្សា សុទិន្នកូន បាឯងមិនធ្លាប់ស្គាល់សេចក្តីទុក្ខតិចតួចសោះទេ ទោះបីបា ស្លាប់ទៅក្តី យើងក៏មិនចង់ឲ្យព្រាត់ប្រាសចាកបាឡើយ យើងនឹងអនុញ្ញាតអ្នក កំពុងរស់នៅ ឲ្យចេញចាកផ្ទះហើយបួសក្នុងព្រះពុទ្ធសាសនាដូចម្តេចបាន សុទិន្ន កូន អ្នកចូរក្រោកឡើងបរិភោគបាយ ផឹកទឹក និងឲ្យគេបម្រើទៅ កាលបើអ្នក

បរិភោគបាយ ផឹកទឹក និងឲ្យគេបម្រើហើយ ចូរបរិភោគកាម និងធ្វើបុណ្យចុះ យើងមិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ ។ កាលបើមាតាបិតាពោលយ៉ាងនេះហើយ សុទិន្នកលន្ទបុត្រ ក៏ស្ងៀមនៅ ។ ឯមាតា បិតាសុទិន្នកលន្ទបុត្រ និយាយលួងលោមសុទិន្នកលន្ទបុត្រពីរដង ។បេ។ បីដងថា នែសុទិន្នកូន អ្នកឯងជាកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តយើង ធ្លាប់ចម្រើនដោយសេចក្តីសុខ មានទាំងស្រីកីលៀងថែរក្សាសប្បាយ សុទិន្នកូន អ្នកឯងមិនដែលស្គាល់សេចក្តីទុក្ខតិចតួចសោះ ទោះបីអ្នកឯងស្លាប់ទៅក្តី យើងមិនចង់ឲ្យព្រាត់ប្រាសចាកអ្នកឯងឡើយ យើងនឹងអនុញ្ញាតដល់អ្នកកំពុងរស់នៅឲ្យចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាដូចម្តេចបាន សុទិន្នកូន អ្នកចូរក្រោកឡើងបរិភោគបាយផឹកទឹកនិងឲ្យគេបម្រើទៅ កាលបរិភោគបាយ ផឹកទឹក និងឲ្យគេបម្រើហើយ ចូរបរិភោគកាម និងធ្វើបុណ្យតាមប្រាថ្នាចុះ យើងមិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ ។ សុទិន្នកលន្ទបុត្រក៏នៅស្ងៀមទៅវិញជាគម្រប់បីដង ។

[ ១៣ ] លំដាប់នោះ ពួកសម្លាញ់សុទិន្នកលន្ទបុត្រ បាននាំគ្នាចូលទៅនិយាយអង្វរសុទិន្នកលន្ទបុត្រថា នែសុទិន្នសម្លាញ់ អ្នកឯងជាកូនប្រុសតែមួយ ហើយជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា ធ្លាប់បានសេចក្តីសុខ មានទាំងស្រីកីលៀងថែរក្សាសប្បាយ នែសុទិន្នសម្លាញ់ អ្នកឯងមិនធ្លាប់ស្គាល់សេចក្តីលំបាកតិចតួចសោះទេ ទោះបីអ្នកស្លាប់ទៅក្តី មាតាបិតារបស់អ្នក ក៏មិនចង់ឲ្យព្រាត់ប្រាសចាកអ្នកឡើយ មាតាបិតាទាំងឡាយរបស់អ្នកនឹងអនុញ្ញាតអ្នកដែល

កំពុងរស់នៅឲ្យចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាដូចម្តេចបាន នែសុទិន្នសម្លាញ់ ចូរអ្នកក្រោកឡើងបរិភោគបាយ ផឹកទឹក ឲ្យគេបម្រើទៅ កាលបើអ្នកបរិភោគបាយ ចំណី ផឹកទឹក ឲ្យគេបម្រើខ្លួនហើយ នឹងបរិភោគនូវកាមទាំងឡាយ ធ្វើបុណ្យ ( ឲ្យទាន ) រីករាយសប្បាយតាមសេចក្តីប្រាថ្នាចុះ មាតាបិតាទាំងឡាយរបស់អ្នក មិនព្រមអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ ។ កាលបើពួកសម្លាញ់របស់សុទិន្នពោលពាក្យយ៉ាងនេះហើយ សុទិន្នកលន្ទបុត្រ ក៏នៅស្ងៀម ។ ពួកសម្លាញ់របស់សុទិន្នកលន្ទបុត្របានពោលនូវពាក្យនេះនឹងសុទិន្នកលន្ទបុត្រពីរដង ។បេ។ បីដងថា នែសុទិន្នសម្លាញ់ អ្នកឯង ។បេ។ សុទិន្នកលន្ទបុត្រក៏នៅតែស្ងៀម អស់វារៈជាគម្រប់បីដង ។ គ្រានោះឯង មាតាបិតាទាំងឡាយរបស់សុទិន្នកលន្ទបុត្រនៅក្នុងទីណា សម្លាញ់ទាំងឡាយរបស់សុទិន្នកលន្ទបុត្រ ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ បានពោលនូវពាក្យនេះនឹងមាតាបិតាទាំងឡាយនៃសុទិន្នកលន្ទបុត្រថា បពិត្រលោកម្តាយលោកឪពុក សុទិន្ននេះ ដេកនៅលើផែនដី រកគ្រឿងកម្រាលអ្វីគ្មានសោះទេ ហើយគិតថា សេចក្តីស្លាប់ក្តី បព្វជ្ជាក្តី នឹងមានដល់អញក្នុងទីនេះឯង បើលោកទាំងឡាយមិនព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាទេ សុទិន្ននឹងដល់នូវសេចក្តីស្លាប់ ក្នុងទីនោះមិនខានឡើយ ប្រសិនបើលោកទាំងឡាយ ព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនា គង់តែនឹងបានឃើញមុខសុទិន្នដែលនៅជាអ្នកបួសតទៅ បើសុទិន្នមិនត្រេកអរក្នុងបព្វជ្ជា ហើយគតិរបស់សុទិន្ននោះ

ប្រព្រឹត្តទៅក្នុងទីដទៃ ដូចម្តេចបាន មុខជានឹងត្រឡប់មកក្នុងទីនេះវិញមិនខាន ដូច្នេះ សូមលោកទាំងឡាយអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនា ។ មាតាបិតាទាំងឡាយនៃសុទិន្នក៏ពោលថា ម្នាលអ្នកទាំងឡាយ យើងទាំងឡាយព្រមអនុញ្ញាតឲ្យសុទិន្នចេញចាកផ្ទះ ហើយបួសក្នុងព្រះពុទ្ធសាសនាចុះ ។

[ ១៤ ] គ្រានោះឯង សុទិន្នកលន្ទបុត្រនៅក្នុងទីណា សម្លាញ់ទាំងឡាយនៃសុទិន្នកលន្ទបុត្រ ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ បានពោលនូវពាក្យនេះនឹងសុទិន្នកលន្ទបុត្រថា នៃសុទិន្នសម្លាញ់ ចូរអ្នកក្រោកឡើង អ្នកឯងមាតាបិតាព្រមព្រៀងអនុញ្ញាតឲ្យចេញចាកផ្ទះ បួសក្នុងព្រះពុទ្ធ-សាសនាហើយ ។ គ្រានោះ សុទិន្នកលន្ទបុត្របានដឹងថា មាតាបិតាព្រមព្រៀងអនុញ្ញាតឲ្យចេញចាកផ្ទះ ដើម្បីបួសក្នុងព្រះពុទ្ធសាសនា ( ដូច្នោះ ) ហើយក៏មានចិត្តរីករាយ ដូចជាអណ្តែតឡើង ជូតសម្អាតខ្លួនដោយដៃទាំងឡាយហើយក្រោកឡើង ។ គ្រានោះ សុទិន្នកលន្ទបុត្រ សម្រាកកម្លាំងបានពីរបីថ្ងៃ ព្រះដ៏មានព្រះភាគគង់ក្នុងទីណា ក៏ចូលទៅកាន់ទីនោះ លុះចូលទៅហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសុទិន្នកលន្ទបុត្រអង្គុយនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាបុគ្គល គឺមាតាបិតាអនុញ្ញាតឲ្យចេញចាកផ្ទះ ហើយបួសក្នុងភេទ ជាបុគ្គលមិនមានប្រយោជន៍ដោយការនៅរក្នុងផ្ទះហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់បំបួសខ្ញុំ

ព្រះអង្គផងចុះ ។ សុទិន្នកលន្ទបុត្រ បានបព្វជ្ជា និងឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគហើយ ។ សុទិន្នភិក្ខុដ៏មានអាយុបានឧបសម្បទាហើយមិនយូរប៉ុន្មាន ក៏ប្រព្រឹត្តសមាទានធុតង្គគុណ មានសភាពយ៉ាងនេះ គឺជាអ្នកនៅក្នុងព្រៃ ប្រព្រឹត្តបិណ្ឌបាត ប្រើប្រាស់សំពត់បង្សុកូល និងត្រាច់ទៅ ( បិណ្ឌបាត ) តាមលំដាប់ផ្ទះ ហើយចូលទៅអាស្រ័យនៅក្នុងស្រុកវជ្ជីឯណាទីមួយ ។

[ ១៥ ] សម័យនោះឯង ស្រុកវជ្ជីមានអំណត់អត់បាយ មនុស្សទាំងឡាយនឹងចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ក៏ដល់នូវសេចក្តីស្លាប់មានឆ្អឹង ស ( ដេរដាសលើផែនដី ) មនុស្សដែលមានទ្រព្យសម្បត្តិល្មមទិញដូរស្រូវអង្ករគេបាន ក៏មិនងាយនឹងទិញដូរដែរ លុះតែមានស្លាកជាទីសម្គាល់ ទើបទិញដូរបាន ជនទាំងអស់ក្នុងស្រុកនោះ នឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក ។ លំដាប់នោះឯង សុទិន្នភិក្ខុដ៏មានអាយុមានសេចក្តីត្រិះរិះដូច្នេះថា ក្នុងកាលឥឡូវនេះ ស្រុកវជ្ជីមានអំណត់អត់បាយ មនុស្សទាំងឡាយនឹងចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្សណាដែលក្រលំបាកស្រាប់ក៏ដល់នូវសេចក្តីស្លាប់មានឆ្អឹង ស ( ដេរដាសលើផែនដី ) មនុស្សដែលមានទ្រព្យសម្បត្តិល្មមទិញដូរស្រូវអង្ករគេបាន ក៏មិនងាយនឹងទិញដូរដែរ លុះតែមានស្លាកជាទីសម្គាល់ ទើបទិញដូរបាន ជនទាំងអស់ក្នុងស្រុកនោះ នឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក ញាតិទាំងឡាយរបស់អញមានច្រើនក្នុងក្រុងវេសាលី ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ច្រើន មានទ្រព្យ និង

ស្រូវច្រើន បើដូច្នោះ មានតែអាត្មាអញ គប្បីចូលទៅអាស្រ័យនូវញាតិទាំងឡាយហើយនៅ ញាតិទាំងឡាយសោត អាស្រ័យនូវអាត្មាអញហើយ នឹងបានឲ្យទាន នឹងធ្វើបុណ្យ ភិក្ខុទាំងឡាយនឹងបានលាភផង អាត្មាអញនឹងមិនលំបាកដោយបិណ្ឌបាតផង ។ ទើបសុទិន្នភិក្ខុដ៏មានអាយុ រៀបចំសេនាសនៈហើយកាន់យកបាត្រ និងចីវរ ក្រុងវេសាលីនៅក្នុងទិសណា ក៏ចៀសចេញទៅក្នុងទិសនោះ កាលដែលត្រាច់ទៅកាន់ចារិកដោយលំដាប់ៗ ក្រុងវេសាលីនៅក្នុងទីណា ក៏ចូលទៅដល់ទីនោះ ។ មានដំណឹងថា សុទិន្នភិក្ខុដ៏មានអាយុនៅក្នុងកូដាគារសាលាព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះ ។ ពួកញាតិសុទិន្នភិក្ខុដ៏មានអាយុ បានឮថា សុទិន្នភិក្ខុជាកលន្ទបុត្រមកដល់ក្រុងវេសាលីហើយ ។ ពួកញាតិទាំងនោះក៏នាំនូវភោជនប្រមាណហុកសិបសម្រាប់ទៅប្រគេនសុទិន្នភិក្ខុដ៏មានអាយុ ។ លំដាប់នោះឯង សុទិន្នភិក្ខុដ៏មានអាយុ ចែកចាយភោជនប្រមាណហុកសិបថាសនោះដល់ភិក្ខុទាំងឡាយ ហើយស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរក្នុងវេលាព្រឹកហើយចូលទៅកាន់កលន្ទគ្រាមដើម្បីបិណ្ឌបាត កាលដើរទៅដើម្បីបិណ្ឌបាតតាមលំដាប់ផ្ទះក្នុងកលន្ទគ្រាម លំនៅនៃបិតារបស់ខ្លួននៅក្នុងទីណាក៏ចូលទៅក្នុងទីនោះ ។ ក្នុងសម័យនោះឯង ទាសីរបស់ញាតិនៃសុទិន្នភិក្ខុដ៏មានអាយុ មានប្រាថ្នាដើម្បីចោលនំកុម្មាសផ្អូម ។ គ្រានោះ សុទិន្នភិក្ខុដ៏មានអាយុ និយាយនឹងខ្ញុំស្រីរបស់ញាតិនោះថា ម្នាលនាងទាសី បើនំនោះជារបស់ចោលហើយ ចូរនាងចាក់ដាក់មកក្នុងបាត្រអាត្មានេះវិញ ។ លំដាប់នោះខ្ញុំស្រីនៃញាតិរបស់សុទិន្នដ៏មានអាយុ ក៏ចាក់នំកុម្មាសផ្អូមនោះទៅក្នុងបាត្ររបស់

សុទិន្ន ហើយបានស្គាល់ជាក់នូវដៃជើង និងសំឡេងរបស់សុទិន្ននោះច្បាស់ ។ វេលានោះ មាតារបស់សុទិន្នដ៏មានអាយុនៅក្នុងទីណា ខ្ញុំស្រីរបស់ញាតិនៃសុទិន្ន ដ៏មានអាយុក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងមាតា របស់សុទិន្នដ៏មានអាយុថា បពិត្រអ្នកម្ចាស់ សូមអ្នកជ្រាប សុទិន្នជាអយ្យបុត្រ និមន្តមកដល់ហើយ ។ មាតារបស់សុទិន្នឆ្លើយថា នែហង បើហងឯងនិយាយ ពាក្យពិតមែន អញនឹងឲ្យហងរួចជាអ្នកជា ។ សម័យនោះឯង សុទិន្នភិក្ខុដ៏ មានអាយុក៏ឆាន់នំកុម្មាសផ្អូមនោះប្របជញ្ជាំងសាលា ១ ។ ចំណែកខាងបិតា របស់សុទិន្នមកពីធ្វើការងារវិញ ក៏បានឃើញសុទិន្នកំពុងឆាន់នំកុម្មាសផ្អូមនោះ ប្របជញ្ជាំងសាលា លុះឃើញហើយ សុទិន្នភិក្ខុនៅក្នុងទីណា ( បិតានោះ ) ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងសុទិន្នដ៏មានអាយុថា នែសុទិន្នកូន យើងជាអ្នកមានទ្រព្យសម្បត្តិច្រើន ថ្វីក៏លោកមកឆាន់នំកុម្មាស ផ្អូមវិញ សុទិន្នកូនគួរតែលោកទៅឯផ្ទះរបស់ខ្លួនវិញ ។ សុទិន្នភិក្ខុឆ្លើយថា បពិត្រគហបតី អាត្មាបានទៅឯផ្ទះញោមហើយ នំកុម្មាសផ្អូមនេះ អាត្មាបានពី ផ្ទះនោះមក ។ លំដាប់នោះ បិតាសុទិន្នភិក្ខុក៏ចាប់កំភួនដៃសុទិន្នភិក្ខុហើយនិយាយ នឹងសុទិន្នថា សុទិន្នកូន លោកចូរមក យើងនឹងទៅផ្ទះ ។ លំដាប់នោះ លំនៅ បិតារបស់ខ្លួននៅក្នុងទីណា សុទិន្នដ៏មានអាយុ ក៏ចូលទៅក្នុងទីនោះ លុះចូល ទៅដល់ហើយ ក៏គង់លើអាសនៈដែលគេបានក្រាលប្រគេន ។ បិតាក៏និយាយ នឹងសុទិន្នក្នុងពេលនោះថា សុទិន្នកូន សូមលោកនិមន្តឆាន់ចង្ហាន់ ។ សុទិន្ន ឆ្លើយថា ណ្ហើយគហបតី ថ្ងៃនេះ អាត្មាភាពឆាន់រួចហើយ ។ បិតាឆ្លើយថា

សុទិន្នកូន សូមលោកនិមន្តទទួលចង្ហាន់ក្នុងថ្ងៃស្អែក ។ សុទិន្នភិក្ខុក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ សុទិន្នភិក្ខុក៏ក្រោកចាកអាសនៈ ហើយនិមន្តទៅក្នុងពេលនោះឯង ។

[ ១៦ ] លុះដល់វេលាព្រឹកឡើង មាតាសុទិន្នភិក្ខុ ប្រើមនុស្សឲ្យបង្អាប់ប្រឹថពីដោយអាចម៍គោស្រស់ រួចឲ្យគរគំនរទ្រព្យ ២គំនរ គឺ ប្រាក់ ១ គំនរ មាស ១ គំនរ ជាគំនរធំៗ បុរសឈរខាងអាយមើលទៅបុរសឈរខាងនាយមិនឃើញ បុរសឈរខាងនាយមើលមកបុរសឈរខាងអាយក៏មិនឃើញ ហើយឲ្យបិទបាំងគំនរទាំងពីរនោះដោយកន្ទេល ឲ្យក្រាលអាសនៈទុកត្រង់កណ្តាល រួចឲ្យបាំងវនាំងជុំវិញពីខាងក្រៅ ( គំនរនោះ ) ហើយហៅស្រីជាគូពីមុនរបស់សុទិន្នដ៏មានអាយុមកបង្គាប់ថា កូនស្រី បើដូច្នោះ គ្រឿងប្រដាប់ណាដែលឯងស្អិតស្អាងហើយ ជាទីស្រឡាញ់ពេញចិត្តរបស់សុទិន្នកូនអញ ត្រូវឯងស្អិតស្អាងគ្រឿងប្រដាប់នោះចុះ ។ ស្រីជាគូពីមុនរបស់សុទិន្នដ៏មានអាយុ ក៏ទទួលពាក្យមាតារបស់សុទិន្នដ៏មានអាយុថា ចាសអ្នកមាតា ។ គ្រានោះ សុទិន្នដ៏មានអាយុស្លៀកស្បង់រួចកាន់យកបាត្រ និងចីវរក្នុងវេលាព្រឹក លំនៅបិតារបស់ខ្លួននៅត្រង់ទីណា ចូលទៅត្រង់ទីនោះ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុកបម្រុង ។ លំដាប់នោះ បិតារបស់សុទិន្នដ៏មានអាយុ សុទិន្នដ៏មានអាយុនៅត្រង់ទីណា ក៏ចូលទៅត្រង់ទីនោះ លុះចូលទៅដល់ហើយ បង្គាប់អ្នកបម្រើឲ្យបើកគំនរទ្រព្យទាំងនោះ ហើយប្រាប់សុទិន្នដ៏មានអាយុថា សុទិន្នកូន នេះជាទ្រព្យសម្បាច់ដើមខាងស្រីរបស់មាតាលោក នៅមានទ្រព្យសម្បាច់ដើម

ខាងប្រុសរបស់បិតា និងមតិ៌ករបស់ជីតាផ្សេងទៀត សុទិន្នកូន បើលោកបាន សឹកចេញជាគ្រហស្ថមក នឹងបានប្រើប្រាស់សម្បត្តិផង ធ្វើបុណ្យទាំងឡាយផង សុទិន្នកូន ចូរលោកសឹកចេញជាគ្រហស្ថមក ហើយនឹងប្រើប្រាស់សម្បត្តិទាំង-ឡាយផង ធ្វើបុណ្យឲ្យទានផង ។ សុទិន្នតបថា ញោម អាត្មាមិនអាចនឹងសឹក បានទេ ព្រោះអាត្មាពេញចិត្តតែក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ ។ បិតាសុទិន្នដ៏ មានអាយុនិយាយនឹងសុទិន្នដ៏មានអាយុ ជាគម្រប់ពីរដងផង ។បេ។ ជាគម្រប់ បីដងផងថា សុទិន្នកូន នេះជាទ្រព្យសម្បាច់ដើមខាងស្រីរបស់មាតាលោក នៅ មានទ្រព្យសម្បាច់ដើមខាងប្រុសរបស់បិតា និងមតិ៌ករបស់ជីតាផ្សេងទៀត សុទិន្នកូន បើលោកបានសឹកចេញជាគ្រហស្ថមក នឹងបានគ្រប់គ្រងសម្បត្តិទាំង-ឡាយផង ធ្វើបុណ្យឲ្យទានផង ។ សុទិន្នកូន ចូរលោកសឹកចេញជាគ្រហស្ថ មក ហើយគ្រប់គ្រងសម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង ។ សុទិន្នភិក្ខុ តបថា គហបតី បើញោមអត់ទោសឲ្យអាត្មាភាពៗ នឹងសូមជម្រាបញោម បន្តិច ។ បិតាទទួលព្រមថា សុទិន្នកូន ចូរលោកនិយាយមកចុះ មិនជាអ្វីទេ ។ សុទិន្នភិក្ខុក៏ប្រាប់ថា គហបតី បើដូច្នោះ ញោមត្រូវបង្គាប់មនុស្សឲ្យធ្វើការុងធ្មៃ ធំៗ ហើយឲ្យប្រេកប្រាក់ និងមាសឲ្យពេញ រួចផ្ទុកដោយរទេះ យកទៅចាក់ ចោលក្នុងកណ្តាលខ្សែទឹកទន្លេគង្គា ហេតុអ្វីបានជាអាត្មាថាដូច្នោះ គហបតី ព្រោះ ថា ទ្រព្យទាំងពួងតែមានដល់អ្នកណាហើយ សេចក្តីខ្លាចក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តី ការថែរក្សាក្តី តែងមានដល់អ្នកនោះមិនខាន ព្រោះតែទ្រព្យ ទាំងនោះជាហេតុ ( បើអ្នកយកមាសប្រាក់ទៅចាក់ចោលក្នុងខ្សែទឹកហើយ )

សេចក្តីអន្តរាយ មានភ័យជាដើមនោះ នឹងមិនមានដល់អ្នកឡើយ ។ កាល សុទិន្នដ៏មានអាយុពោលយ៉ាងនេះហើយ បិតារបស់សុទិន្នដ៏មានអាយុ មានសេចក្តីទោមនស្សតូចចិត្តថា ហេតុដូចម្តេច បានជាលោកសុទិន្នជាកូនពោលយ៉ាងនេះ ។ គ្រានោះឯង បិតារបស់សុទិន្នដ៏មានអាយុ ទើបហៅស្រីបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុមកប្រាប់ថា នែនាងក្រមុំ បើដូច្នោះ នាងឯងជាទីស្រឡាញ់ពេញចិត្តរបស់សុទិន្នកូនអញ នាងធ្វើដូចម្តេចនឹងឲ្យសុទិន្នកូនអញធ្វើតាមពាក្យនាងឯងបាន ។ គ្រានោះឯង ស្រីបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុបានប្រវាំឱបជើងទាំងពីររបស់សុទិន្នដ៏មានអាយុ ហើយបាននិយាយពាក្យនេះនឹងសុទិន្នភិក្ខុថា បពិត្រអយ្យបុត្រ លោកប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុនៃស្រីអប្សរទាំងឡាយណា ស្រីអប្សរទាំងឡាយនោះ មានទ្រង់ទ្រាយប្រពៃដូចម្តេចទៅ ។ សុទិន្នភិក្ខុឆ្លើយថា នែប្អូនស្រី អាត្មាមិនបានប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីស្រីអប្សរទាំងនោះទេ ។ វេលានោះ ស្រីបុរាណទុតិយិការបស់សុទិន្នភិក្ខុ ក៏នឹកទោមនស្សតូចចិត្តថា តាំងពីថ្ងៃនេះទៅ លោកសុទិន្នអយ្យបុត្រ គ្រាន់តែហៅអញថា ប្អូនស្រីៗ ប៉ុណ្ណោះទេ ដូច្នេះហើយ ក៏ជ្រប់ដួលដេកក្នុងទីនោះឯង ។ គ្រានោះ សុទិន្នដ៏មានអាយុ ទើបនិយាយពាក្យនេះនឹងបិតាថា គហបតី បើញោមមានភោជនគួរនឹងឲ្យទានអាត្មាបានសូមញោមឲ្យទានមកចុះ កុំធ្វើឲ្យអាត្មាលំបាកពេកឡើយ ។ បិតាសុទិន្នឆ្លើយថា សុទិន្នកូន ភោជនាហារនោះមាន សូមលោកនិមន្តឆាន់ចុះ ។ វេលានោះ មាតាបិតារបស់សុទិន្នដ៏មានអាយុបានចាត់ចែងចង្ហាន់ដ៏ឆ្ងាញ់ពិសា ឲ្យសុទិន្នភិក្ខុដ៏មាន

អាយុ ឆាន់ដោយដៃខ្លួនឯង ។ សម័យនោះឯង មាតារបស់សុទិន្នដ៏មាន អាយុបាននិយាយនឹងសុទិន្នភិក្ខុនៅវេលាឆាន់រួច ហើយលែងលូកដៃទៅក្នុង បាត្រហើយថា នែសុទិន្នកូន ត្រកូលនេះស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈ ច្រើន មានមាសប្រាក់បរិបូណ៌ មានគ្រឿងឧបករណ៍បរិបូណ៌ មានស្រូវអង្ករ បរិបូណ៌ នែសុទិន្នកូន សូមលោកនិមន្តសឹកចេញជាគ្រហស្ថមក នឹងបានប្រើ ប្រាស់នូវទ្រព្យសម្បត្តិទាំងឡាយផង ធ្វើបុណ្យឲ្យទានផង សុទិន្នកូន សូម លោកនិមន្តសឹកចេញជាគ្រហស្ថមក ហើយនឹងចាយវាយនូវសម្បត្តិទាំងឡាយ ធ្វើបុណ្យឲ្យទានចុះ ។ សុទិន្នភិក្ខុឆ្លើយថា ញោម អាត្មាមិនអាច ( ធ្វើ យ៉ាងនោះទេ ) អាត្មាត្រេកអរចំពោះត្រង់ការប្រព្រឹត្តព្រហ្មចរិយធម៌តែម្យ៉ាង ។ មាតារបស់សុទិន្នភិក្ខុដ៏មានអាយុ បាននិយាយពាក្យនេះ នឹងសុទិន្នភិក្ខុដ៏មាន អាយុជាគម្រប់ពីរដងផង ។បេ។ ជាគម្រប់បីដងផងថា សុទិន្នកូន ត្រកូលនេះ ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់បរិបូណ៌ មាន គ្រឿងឧបករណ៍បរិបូណ៌ មានស្រូវអង្ករបរិបូណ៌ សុទិន្នកូន បើដូច្នេះ សូម លោកអាណិតគ្រាន់តែឲ្យពូជបន្តិចចុះ កុំឲ្យពួកស្តេចលិច្ឆវីមករឹបជាន់ យកទ្រព្យ សម្បត្តិជារបស់យើង ដែលជាត្រកូលឥតកូននោះឡើយ ។ សុទិន្នភិក្ខុឆ្លើយថា ញោម បើគ្រាន់តែធ្វើកិច្ចប៉ុណ្ណោះអាត្មាអាចធ្វើឲ្យបាន ។ មាតាសុទិន្នសួរថា សុទិន្នកូន ឥឡូវនេះ លោកគង់នៅឯណា ។ សុទិន្នភិក្ខុតបថា ញោមអាត្មានៅ ក្នុងព្រៃមហាវន ។ គ្រានោះឯង សុទិន្នដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ហើយចេញដើរទៅ ។

[ ១៧ ] គ្រានោះ មាតារបស់សុទិន្នដ៏មានអាយុ ហៅនាងបុរាណទុតិយិកា របស់សុទិន្នដ៏មានអាយុមកហើយនិយាយថា ម្នាលនាងកូនប្រសា បើកាល ណានាងមានរដូវហើយ ផ្កា គឺឈាមរបស់នាងកើតឡើងហើយ នាងត្រូវប្រាប់ ដល់ម៉ែ ក្នុងកាលនោះ ។ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ បាន ទទួលពាក្យមាតារបស់សុទិន្នដ៏មានអាយុថា ចាសម៉ែ ។ លំដាប់នោះ នាង បុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ មិនយូរប៉ុន្មាននាងក៏មានរដូវ ផ្កា គឺ ឈាមនៃនាងនោះក៏កើតឡើង ។ ទើបនាងបុរាណទុតិយិការបស់សុទិន្នដ៏មាន អាយុ បានប្រាប់មាតារបស់សុទិន្នដ៏មានអាយុយ៉ាងនេះថា ម៉ែ ខ្ញុំមានរដូវហើយ ផ្កា គឺឈាមរបស់ខ្ញុំកើតហើយ ។ មាតាតបថា ម្នាលនាងកូនប្រសា បើដូច្នោះ នាងឯងប្រដាប់តាក់តែងដោយគ្រឿងអលង្ការឯណា ដែលជាទីស្រឡាញ់ពេញ ចិត្តរបស់សុទិន្នកូន ( យើង ) នាងចូរប្រដាប់តាក់តែងដោយគ្រឿងសម្រាប់ ស្អិតស្អាងនោះចុះ ។ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ បានទទួល ពាក្យមាតារបស់សុទិន្នដ៏មានអាយុថា ចាសម៉ែ ។ លំដាប់នោះ មាតារបស់ សុទិន្នដ៏មានអាយុ ក៏នាំនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុចូលទៅកាន់ ព្រៃមហាវន់ដែលសុទិន្នភិក្ខុនៅនោះឯង លុះចូលទៅហើយ ក៏បានពោលនូវពាក្យ នេះនឹងសុទិន្នដ៏មានអាយុថា ម្នាលសុទិន្នកូន ត្រកូលនេះស្តុកស្តម្ភ មានទ្រព្យ ច្រើន មានរបស់សម្រាប់ប្រើប្រាស់ច្រើន មានមាសប្រាក់ច្រើន មានគ្រឿង ឧបករណ៍ជាទីគាប់ចិត្តច្រើន មានធនធានស្រូវអង្ករច្រើន ម្នាលសុទិន្នកូន អ្នក ត្រឡប់មកដើម្បីហីនភេទ ក៏គង់នឹងបានបរិភោគនូវភោគសម្បត្តិផង ធ្វើបុណ្យ

ទាំងឡាយផង ម្នាលសុទិន្នកូន អ្នកត្រូវត្រឡប់មកកាន់ភេទជាគ្រហស្ថវិញ ហើយបរិភោគនូវភោគសម្បត្តិផង ធ្វើបុណ្យទាំងឡាយផង ។ សុទិន្នតបថា ញោម អាត្មាសឹកមិនកើតទេ អាត្មាមិនព្រមសឹកទេ អាត្មាត្រេកអរតែប្រព្រឹត្តព្រហ្មចរិយធម៌ ។ មាតារបស់សុទិន្នដ៏មានអាយុ បាននិយាយនឹងសុទិន្នដ៏មានអាយុ អស់វារៈ ២-៣ ដងយ៉ាងនេះថា នែសុទិន្នកូន ត្រកូលនេះស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីគាប់ចិត្តច្រើន មានធនធានស្រូវអង្ករច្រើន នែសុទិន្នកូន បើដូច្នោះ អ្នកចូរឲ្យត្រឹមតែពូជចុះ កំឲ្យពួកស្តេចលិច្ឆវីមករឹបយកសម្បត្តិទ្រព្យយើងដែលជាត្រកូលឥតកូនទៅបាន ។ សុទិន្នឆ្លើយថា ញោម អាត្មាអាចធ្វើកិច្ចនេះជូនបាន ហើយក៏ចាប់ដៃនាងបុរាណទុតិយិកា កៀកចូលទៅកាន់ព្រៃមហាវន យល់ឃើញថា មិនមានទោសព្រោះសិក្ខាបទព្រះអង្គមិនទាន់បានបញ្ញត្ត ហើយញុំាងមេថុនធម្មឲ្យសម្រេចដោយនាងបុរាណទុតិយិកាអស់វារៈ ៣ ដង នាងក៏មានគភ៌ ដោយមេថុនសេវនៈនោះ ។

[ ១៨ ] ភុម្មទេវតាទាំងឡាយ ក៏ញុំាងសំឡេងឲ្យឮទូទាំងឡើងទៅថា ម្នាលគ្នាយើងទាំងឡាយ ពួកភិក្ខុមិនដែលវឹកវរ មិនដែលមានទោស ( ឥឡូវនេះ ) សុទិន្នកលន្ទបុត្រធ្វើសេចក្តីវឹកវរ និងទោសឲ្យកើតឡើងហើយ ។ ចាតុម្មហារាជិកាទេវតាទាំងឡាយ ឮសំឡេងភុម្មទេវតាទាំងនោះហើយ ក៏ញុំាងសំឡេងឲ្យឮឡើងទៅ ពួកទេវតាជាន់តាវត្តិង្ស យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី ( រហូតដល់ ) ពួកព្រហ្ម ( បានឮសំឡេងតៗ គ្នាមកហើយ )

ក៏ញុំាងសំឡេងឲ្យឮឡើងៗ ទៅថា ម្នាលគ្នាយើងទាំងឡាយ ពួកភិក្ខុមិនដែលវិកវរ មិនដែលមានទោស ( ឥឡូវនេះ ) សុទិន្នកលន្ទបុត្រ មកធ្វើសេចក្តីវិកវរ និងទោសឲ្យកើតឡើងហើយ ។ សូរសព្ទ ( យ៉ាងនេះ ) ក៏ឮកងរំពងឡើងទៅ ដរាបដល់ព្រហ្មលោកដោយ ១ ខណៈ ១ រំពេចនោះឯង ។ គ្រានោះ នាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុ អាស្រ័យគភ៌នោះកាន់តែចាស់ឡើងជាលំដាប់ ទើបសម្រាលនូវកូនប្រុសមួយ ។ លំដាប់នោះ ពួកសម្លាញ់សុទិន្នដ៏មានអាយុ បានតាំងឈ្មោះទារកនោះថា ពីជកៈ បានតាំងឈ្មោះនាងបុរាណទុតិយិការបស់សុទិន្នដ៏មានអាយុថា ពីជកមាតា បានតាំងឈ្មោះសុទិន្នដ៏មានអាយុថា ពីជកបិតា ។ លុះដល់សម័យខាងក្រោយមក អ្នកទាំងពីរនោះ បានចេញចាកផ្ទះហើយបួសក្នុងភេទជាបុគ្គលអ្នកមិនមានប្រយោជន៍ដល់ការងារក្នុងផ្ទះ ហើយបានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

[ ១៩ ] គ្រានោះ សេចក្តីសង្ស័យ និងសេចក្តីក្តៅក្រហាយស្តាយក្រោយក៏កើតមានដល់សុទិន្នដ៏មានអាយុថា អាត្មាអញពេញហោជាឥតលាភ លាភមិនមានដល់អាត្មាអញទេ ភាពជាមនុស្សពេញហោអាត្មាអញបានដោយអាក្រក់មិនមែនអាត្មាអញ បានដោយល្អទេ ដោយហេតុអាត្មាអញ បានបួសក្នុងធម្មវិន័យ ដែលព្រះសាស្តាទ្រង់សម្តែងដោយប្រពៃយ៉ាងនេះហើយ មិនអាចដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធ ដរាបដល់អស់ជីវិត ។ ព្រោះសេចក្តីសង្ស័យ និងសេចក្តីក្តៅក្រហាយស្តាយក្រោយនោះឯង សុទិន្នក៏ទៅជាស្គមប្រជក់មានសម្បុរអាក្រក់កើតទៅជាពោគលឿងស្លេកស្លាំង មានខ្នួនរវាម

ដោយសរសៃ មានចិត្តក្រៀមក្រំទ្រមឹងទ្រមើយ កើតទុក្ខតូចចិត្តនឹកស្តាយក្រោយសញ្ជប់សញ្ជឹង ។ លំដាប់នោះ ភិក្ខុទាំងឡាយជាសម្លាញ់របស់សុទិន្នដ៏មានអាយុបាននិយាយពាក្យនេះនឹងសុទិន្នដ៏មានអាយុថា អាវុសោសុទិន្ន កាលពីដើមលោកមានសម្បុរល្អ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខដ៏ថ្លា មានសម្បុរថ្លៃស្រស់បស់ផូរផង់ល្អ ឥឡូវនេះលោកទៅជាស្គមសៅហ្មង មានសម្បុរអាក្រក់ កើតរោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ មានចិត្តក្រៀមក្រំទ្រមឹងទ្រមើយ កើតទុក្ខតូចចិត្តក្តៅក្រហាយសញ្ជប់សញ្ជឹង ម្នាលអាវុសោសុទិន្ន លោកមិនសូវត្រេកអរហើយចេះតែខំប្រព្រឹត្តព្រហ្មចរិយធម៌ទៅទេឬអ្វី។ សុទិន្នឆ្លើយតបថា នែលោកដ៏មានអាយុទាំងឡាយ ខ្ញុំមិនមែនមិនត្រេកអរហើយចេះតែខំប្រព្រឹត្តព្រហ្មចរិយធម៌ទេ ខ្ញុំបានធ្វើបាបកម្ម គឺសេពមេថុនធម្មនឹងស្រ្តីបុរាណទុតិយិកា ម្នាលអាវុសោទាំងឡាយ សេចក្តីសង្ស័យ និងសេចក្តីស្តាយក្រោយ ក៏កើតមានដល់ខ្ញុំនោះឯងថា អាត្មាអញពេញហៅជាឥតលាភលាភមិនមានដល់អាត្មាអញទេ ភាពជាមនុស្សពេញហៅថាអាត្មាអញបានដោយអាក្រក់ មិនមែនអាត្មាអញបានដោយល្អទេ ដោយហេតុអាត្មាអញបានបួសក្នុងធម្មវិន័យ ដែលព្រះសាស្តាទ្រង់សម្តែងដោយប្រពៃយ៉ាងនេះ ហើយមិនអាចដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ បរិសុទ្ធ ដរាបដល់អស់ជីវិត ។ ភិក្ខុទាំងឡាយជាសម្លាញ់ក៏និយាយថា អាវុសោសុទិន្ន លោកបួសក្នុងធម្មវិន័យដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងល្អហើយយ៉ាងនេះ មិនអាចដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិសុទ្ធពេញលេញ ដរាបដល់អស់ជីវិតបាន ព្រោះមេថុន-

ធម្មសេវនកិច្ចណា ម្នាលអាវុសោ មេថុនធម្មសេវនកិច្ចនោះ ល្មមឲ្យលោកសង្ស័យ ល្មមឲ្យស្តាយក្រោយមែន ម្នាលអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយអនេកបរិយាយ ( សុទ្ធតែ ) ដើម្បីឲ្យប្រាសចាករាគៈ មិនមែនសំដែងដើម្បីឲ្យប្រកបដោយរាគៈទេ ធម៌ដែលព្រះអង្គសំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប មិនមែនសំដែងដើម្បីតម្រូវទៅរកកិលេសជាគ្រឿងប្រកបទេ ធម៌ដែលព្រះអង្គសំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ មិនមែនសំដែងដើម្បីឲ្យប្រកាន់មាំទេ ( ក្រែងដូច្នេះ ) មិនមែនឬនៃអាវុសោ ត្រង់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីឲ្យប្រាសចាករាគៈ លោកត្រឡប់ជាយល់ក្នុងធម៌នោះថា ប្រកបដោយរាគៈទៅវិញ ត្រង់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប លោកត្រឡប់ជាចូលចិត្តតម្រូវទៅរកកិលេសជាគ្រឿងប្រកបទៅវិញ ត្រង់ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ លោកទៅជាចូលចិត្តថា ឲ្យប្រកាន់មាំវិញ ម្នាលអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយដោយអនេកបរិយាយ ដើម្បីប្រាសចាករាគៈ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ដើម្បីញាំញីនូវសេចក្តីស្រវឹង ដើម្បីកម្ចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ដើម្បីដកចេញនូវសេចក្តីអាល័យក្នុងកាម ដើម្បីផ្តាច់បង់នូវវដ្តៈ ដើម្បីអស់ទៅនៃតណ្ហា ដើម្បីគ្មានរាគៈ ដើម្បីនិរោធ ដើម្បីព្រះនិព្វាន ( ក្រែងដូច្នេះ ) មិនមែនឬ ម្នាលអាវុសោ កិរិយាលះបង់នូវកាមទាំងឡាយ ព្រះដ៏មានព្រះភាគទ្រង់សំដែងហើយ ការកំណត់ដឹងនូវសេចក្តី

សម្គាល់ក្នុងកាម ព្រះអង្គក៏បានសម្តែងហើយ កិរិយាកម្ចាត់បង់នូវសេចក្តីស្រេកឃ្លានក្នុងកាម ព្រះអង្គក៏បានសម្តែងហើយ កិរិយាដកចេញនូវសេចក្តីត្រិះរិះក្នុងកាមទាំងឡាយ ក៏ព្រះអង្គបានសម្តែងហើយ កិរិយាចូលទៅរម្ងាប់នូវសេចក្តីក្តៅក្រហាយអន្ទះអន្ទែងក្នុងកាមទាំងឡាយ ក៏ព្រះអង្គបានសម្តែងហើយ ដោយអនេកបរិយាយ ( យ៉ាងនេះ ) មិនមែនឬ ម្នាលអាវុសោ កម្មដ៏លាមករបស់លោកនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លានោះទេ មិនមែនដឹកនាំជនដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ម្នាលអាវុសោ កម្មដ៏លាមករបស់លោកនេះ រមែងដឹកនាំសេចក្តីមិនជ្រះថ្លាឲ្យកើតមានដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លានៅឡើយ ដឹកនាំជនទាំង-ឡាយខ្លះ ដែលជ្រះថ្លាហើយឲ្យទាស់ចិត្តគំនិតទៅវិញទេតើ ។ លំដាប់នោះ ភិក្ខុទាំងនោះ ក៏តិះដៀលសុទិន្នដ៏មានអាយុដោយអនេកបរិយាយ ហើយនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

[ ២០ ] ព្រោះរឿងនេះ ព្រោះដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរសុទិន្នដ៏មានអាយុក្នុងកាលនោះថា នែ សុទិន្ន ឮថាអ្នកឯងសេពមេថុនធម្មនឹងនាងបុរាណទុតិយិកា ពិតមែនឬ ។ សុទិន្នក្រាបទូលថា សូមទាន ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃ-បុរស បាបកម្មដែលអ្នកឯងធ្វើនេះមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ នែមោឃបុរស គួរបើដែរអ្នកឯងបួសក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយដោយប្រពៃយ៉ាងនេះត្រឡាំង

ទៅជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញ ដរាបដល់អស់ជីវិតមិនកើត នែមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយអនេកបរិយាយ (សុទ្ធតែ) ដើម្បីប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ ធម៌ដែលតថាគត សំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប មិនមែនសំដែង ដើម្បីតម្រូវទៅរកកិលេសជាគ្រឿងប្រកបទេ ធម៌ដែលតថាគតសំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ មិនមែនសំដែងដើម្បីឲ្យប្រកាន់មាំទេ មិនមែនឬ ម្នាល មោឃបុរស ត្រង់ធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាករាគៈ អ្នក ឯងត្រឡប់ចូលចិត្តក្នុងធម៌នោះថា ឲ្យប្រកបដោយរាគៈវិញ ត្រង់ធម៌ដែល តថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកកិលេសជាគ្រឿងប្រកប អ្នកឯង ត្រឡប់ជាចូលចិត្តថា ឲ្យប្រកបដោយកិលេសជាគ្រឿងប្រកបវិញ ត្រង់ធម៌ដែល តថាគតសំដែងហើយ ដើម្បីមិនឲ្យប្រកាន់មាំ អ្នកឯងត្រឡប់ទៅជាចូលចិត្តថា ឲ្យប្រកាន់មាំវិញ នែមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយអនេក-បរិយាយ ដើម្បីឲ្យប្រាសចាករាគៈ ធម៌ដែលតថាគតសំដែងហើយ ដើម្បីញាំញី នូវសេចក្ដីស្រវឹង ដើម្បីកម្ចាត់បង់នូវសេចក្ដីស្រេកឃ្លានក្នុងកាម ដើម្បីដកចេញ នូវសេចក្ដីអាល័យក្នុងកាម ដើម្បីផ្ដាច់បង់នូវវដ្ដៈ ដើម្បីអស់ទៅនៃតណ្ហា ដើម្បី ប្រាសចាកតម្រេក ដើម្បីរំលត់ ដើម្បីព្រះនិព្វាន មិនមែនឬ នែមោឃបុរស កិរិយាលះបង់នូវកាមទាំងឡាយ តថាគតបានសំដែងហើយ ការកំណត់ដឹងនូវ សេចក្ដីសម្គាល់ក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាកម្ចាត់ បង់នូវសេចក្ដីស្រេកឃ្លានក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយា

ដកចេញនូវសេចក្តីត្រិះរិះក្នុងកាមទាំងឡាយ តថាគតបានសម្តែងហើយ កិរិយាចូលទៅរម្ងាប់នូវសេចក្តីក្តៅក្រហាយក្នុងកាមទាំងឡាយ តថាគតបានសម្តែងហើយ ដោយអនេកបរិយាយ មិនមែនឬ ម្នាលមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់អាសិរពិសជាសត្វមានពិសក្លៀវក្លា ប្រសើរជាងអ្នកឯងដាក់អង្គជាតទៅក្នុងអង្គជាតរបស់មាតុគ្រាម មិនប្រសើរឡើយ មោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់ពស់វែកប្រសើរជាង អង្គជាតដែលអ្នកឯងដាក់ទៅក្នុងអង្គជាតរបស់មាតុគ្រាមមិនប្រសើរឡើយ មោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងគំនររងើកភ្លើងដែលឆេះភ្លឺប្រាលរន្ទាលប្រសើរជាងអង្គជាតដែលអ្នកឯងដាក់ទៅក្នុងអង្គជាតរបស់មាតុគ្រាមមិនប្រសើរឡើយ ហេតុអ្វី បានជាតថាគតពោលដូច្នោះ មោឃបុរស ព្រោះថា មនុស្សដែលដាក់អង្គជាតទៅក្នុងគំនររងើកភ្លើងគ្រាន់តែដល់នូវសេចក្តីស្លាប់ ឬដល់នូវសេចក្តីទុក្ខប្រហែលនឹងស្លាប់ប៉ុណ្ណោះ ឯទីងបានទម្លាយរាងកាយស្លាប់ហើយទៅកើតក្នុងតិរច្ឆានកំណើត ប្រេត អសុរកាយ នរក ព្រោះបច្ច័យដែលដាក់អង្គជាតទៅក្នុងគំនររងើកភ្លើងនោះក៏ទេ នែមោឃបុរស ចំណែកខាងភិក្ខុដែលដាក់អង្គជាត ទៅក្នុងអង្គជាតមាតុគ្រាមនោះ តែទម្លាយរាងកាយហើយ ត្រូវទៅកើតក្នុងតិរច្ឆានកំណើត ប្រេត អសុរកាយ នរក ម្នាលមោឃបុរស កាលបើកម្មទាំងនេះ ( សុទ្ធតែជាកម្មប្រកបដោយទោសធំយ៉ាងនេះ ) អ្នកឯងនៅតែប្រព្រឹត្តធ្វើនូវអសទ្ធម្ម ជាធម៌របស់អ្នកស្រុក ជាធម៌របស់មនុស្សថោកថយ អាក្រក់ មានកិច្ចដោយទឹកជាទីបំផុត ជាធម៌លាក់លៀម ជាធម៌របស់ជនពីរៗ នាក់ តែងប្រជុំធ្វើតាមតែប្រទះនោះ មោឃបុរស

( ក្នុងសាសនានេះ ) មានតែអ្នកឯងទេ ជាអ្នកធ្វើអកុសល ខាងដើមនៃអកុសលធម៌ទាំងឡាយមានប្រមាណច្រើន ហៅថា ជាអ្នកផ្តើមធ្វើមុនគេ ម្នាលមោឃបុរស កម្មដ៏លាមករបស់អ្នកឯងនេះ មិនបណ្តាលឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឡើយ មិនមែនដឹកនាំជនដែលជ្រះថ្លា ហើយឲ្យរឹងរឹតតែជ្រះថ្លាថែមឡើងទៀតទេ ម្នាលមោឃបុរស កម្មដ៏លាមករបស់អ្នកឯងនេះ រមែងបណ្តាលឲ្យកើតសេចក្តីមិនជ្រះថ្លា ដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លានៅឡើយ ដឹកនាំជនទាំងឡាយខ្លះដែលជ្រះថ្លាហើយឲ្យត្រឡប់ទាស់ចិត្តគំនិតទៅវិញ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលសុទិន្នដ៏មានអាយុ ដោយអនេកបរិយាយ ហើយទ្រង់សំដែងនូវទោស នៃការចិញ្ចឹមក្រ ថែទាំក្រក្រ ប្រាថ្នាច្រើន មិនសន្តោស ប្រឡូកប្រឡំដោយពួកគណៈ និងសេចក្តីខ្ជិលច្រអូស ទើបទ្រង់សំដែងដោយអនេកបរិយាយនូវគុណនៃការដែលគេចិញ្ចឹមងាយ ការដែលគេថែទាំរក្សាងាយ ប្រាថ្នាតិច សន្តោស ចិត្តផូរផង់ ការកម្ចាត់បង់នូវកិលេស ការនាំឲ្យកើតសេចក្តីជ្រះថ្លា ការមិនសន្សំ និងការប្រារព្ធព្យាយាម ហើយទ្រង់សំដែងធម្មីកថាដ៏ល្មមសមគួរដល់សិក្ខាបទនោះ ដល់សំវរៈនោះចំពោះភិក្ខុទាំងឡាយ ហើយហៅភិក្ខុទាំងឡាយមក ( មានព្រះពុទ្ធដីកា ) ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទ ដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីនៅសប្បាយដល់សង្ឃ ១ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនអៀនខ្មាស ១ ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែល

មានសីលជាទីស្រឡាញ់ ១ ដើម្បីរារាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីញុំាងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាច្រើនឡើង ១ ដើម្បីឲ្យតម្កល់នៅមាំនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះដូច្នេះថា ភិក្ខុណាមួយ សេពមេថុនធម្ម ( ភិក្ខុនោះ ) ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយចំពោះភិក្ខុទាំងឡាយដោយប្រការយ៉ាងនេះ ។

### ភាណវារៈពោលអំពីរឿងសុទិន្នភិក្ខុ ចប់

[ ២១ ] សម័យនោះ មានភិក្ខុ ១ រូប ប្រលោមលួងមេស្វា ដោយអាមិសៈ ក្នុងព្រៃមហាវន ទៀបក្រុងវេសាលី ហើយសេពមេថុនធម្មនឹងមេស្វានោះ ។ លំដាប់នោះ ភិក្ខុនោះស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ហើយចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាតក្នុងវេលាព្រឹកព្រហាម ។ ក្នុងសម័យនោះ ភិក្ខុទាំងឡាយច្រើនរូបដើរទៅកាន់សេនាសនចារិក ក៏នាំគ្នាចូលទៅត្រង់កន្លែងដែលភិក្ខុនោះនៅ ។ មេស្វានោះ បានឃើញភិក្ខុអម្បាលនោះមកអំពីចម្ងាយ ក៏ចូលទៅត្រង់កន្លែងដែលភិក្ខុទាំងនោះនៅ លុះចូលទៅដល់ហើយ ( ក៏សំដែងអាការ ) ធ្វើចង្កេះឲ្យញាក់ញ័រផង ធ្វើកន្ទុយឲ្យកម្រើកផង ពើងចង្កេះផង បានធ្វើនូវនិមិត្តផង អំពីខាងមុខភិក្ខុទាំងឡាយនោះ ។ គ្រានោះ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះយល់ឃើញថា ភិក្ខុនោះសេពមេថុនធម្មនឹងមេស្វា

នេះ ដោយពិតឥតមានសង្ស័យ ទើបនាំគ្នាពួនចាំឃ្លាំមើលក្នុងទីកំបាំង ១ ។ លំដាប់នោះ ភិក្ខុនោះដើរទៅបិណ្ឌបាតក្នុងក្រុងវេសាលី បានបិណ្ឌបាតហើយ ត្រឡប់មកវិញ ។ គ្រានោះ មេស្វានោះក៏ចូលទៅត្រង់កន្លែងដែលភិក្ខុនោះនៅ ។ លំដាប់នោះ ភិក្ខុនោះឆាន់បិណ្ឌបាតនោះ ១ ចំណែក បានឲ្យដល់មេស្វា ១ ចំណែក ។ គ្រានោះ មេស្វាស៊ីអាហារបិណ្ឌបាតនោះហើយ ក៏ពើងចង្កេះចំពោះទៅភិក្ខុនោះ ។ លំដាប់នោះ ភិក្ខុនោះក៏សេពមេថុនធម្មនឹងមេស្វានោះ ។ ទើបភិក្ខុទាំងឡាយនោះ បានពោលពាក្យនេះនឹងភិក្ខុនោះថា អាវុសោ សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយមិនមែនឬ នែអាវុសោ ហេតុអ្វី ក៏បានជាអ្នកមកសេពមេថុនធម្មនឹងមេស្វានេះ ។ ភិក្ខុនោះឆ្លើយថា នែអាវុសោទាំងឡាយ សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តពិតមែនហើយ តែសិក្ខាបទនោះ ទ្រង់បញ្ញត្តចំពោះតែស្រីមនុស្ស មិនមែនបញ្ញត្តចំពោះសត្វតិរច្ឆានញីទេ ។ ភិក្ខុទាំងឡាយនោះពោលថា នែអាវុសោ សិក្ខាបទដែលព្រះអង្គបញ្ញត្តចំពោះស្រីមនុស្ស ក៏ដូចសត្វតិរច្ឆានញីដែរ មិនមែនឬ នែអាវុសោ ( អំពើអាក្រក់ដែលអ្នកធ្វើនោះ ) ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ នែអាវុសោ គួរបើដែរ អ្នកឯងបួសក្នុងធម្មវិន័យ ដែលព្រះមានព្រះភាគត្រាស់សម្តែងល្អហើយយ៉ាងនេះត្រឡាំង ទៅជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញ ដរាបអស់ជីវិតមិនកើត នែអាវុសោ ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដើម្បីឲ្យប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ ។បេ។ កិរិយារម្ងាប់នូវសេចក្តីក្តៅ

ក្រហាយ អន្ទះអន្ទែងក្នុងកាមទាំងឡាយ ព្រះអង្គទ្រង់សម្តែងហើយដោយអនេកបរិយាយ មិនមែនឬ ម្នាលអាវុសោ អំពើអាក្រក់ដែលអ្នកធ្វើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ មិនមែនដឹកនាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹងរឹតតែជ្រះថ្លាថែមទៀតទេ នែអាវុសោ អំពើអាក្រក់ដែលអ្នកធ្វើនេះ រមែងនាំឲ្យកើតសេចក្តីមិនជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ដឹកនាំជនទាំងឡាយខ្លះដែលជ្រះថ្លាហើយឲ្យបាត់ជ្រះថ្លាទៅវិញ ។ គ្រានោះ ភិក្ខុទាំងឡាយនោះ ក៏តិះដៀលភិក្ខុនោះដោយ បរិយាយច្រើនហើយនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

[ ២២ ] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរភិក្ខុនោះ ក្នុងវេលានោះថា ម្នាលភិក្ខុ ឮថា អ្នកឯងសេពមេថុនធម្មនឹងមេស្វាពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា សូមទាន ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស ( អំពើអាក្រក់ដែលអ្នកឯងធ្វើនេះ ) ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើទេ នែមោឃបុរស គួរបើដែរអ្នកឯងបួសក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ ដោយល្អយ៉ាងនេះ ឲ្យត្រឡាំង ទៅជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធពេញលេញដរាបដល់អស់ជីវិតមិនកើត នែមោឃបុរស ធម៌ដែលតថាគតសម្តែងហើយ ដើម្បីប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ ។បេ។ កិរិយារម្ងាប់នូវសេចក្តី

ក្តៅក្រហាយអន្ទះអន្ទែងក្នុងកាមទាំងឡាយ តថាគតសម្តែងហើយ ដោយអនេកបរិយាយ នែមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់អាសិរពិសមានពិសដ៏ក្លៀវក្លាប្រសើរជាង ដែលអ្នកឯងដាក់អង្គជាតទៅក្នុងអង្គជាតរបស់មេស្វាមិនប្រសើរសោះឡើយ ម្នាលមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់ពស់វែកប្រសើរជាង ដែលអ្នកឯងដាក់អង្គជាតទៅក្នុងអង្គជាតរបស់មេស្វានោះ ពុំប្រសើរសោះឡើយ ម្នាលមោឃបុរស សូវអ្នកឯងដាក់អង្គជាតទៅក្នុងគំនររងើកភ្លើងក្តៅ ដែលកំពុងឆេះសន្ធោសន្ធៅ មានអណ្តាតភ្លើងដ៏រុងរឿងវិញប្រសើរជាង ឯអង្គជាតដែលអ្នកឯងដាក់ទៅក្នុងអង្គជាតរបស់មេស្វានោះ ពុំប្រសើរឡើយ ពាក្យដែលតថាគតពោលនោះ ព្រោះហេតុអ្វី ម្នាលមោឃបុរស ព្រោះថា ទោះបីបុគ្គលដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខស្មើនឹងស្លាប់ ដោយហេតុដែលដាក់នូវអង្គជាតទៅក្នុងមាត់ពស់វែកជាដើមនោះក៏ដោយ បុគ្គលនោះលុះរំលាងខន្ធ នឹងបានចូលទៅកាន់តិរច្ឆានកំណើត ប្រេត អសុរកាយ នរក ព្រោះតែដាក់អង្គជាតទៅក្នុងមាត់ពស់វែកជាដើមនោះក៏ទេ ម្នាលមោឃបុរស ( ឯភិក្ខុនោះ ) លុះរំលាងខន្ធ ក៏រមែងតែទៅកាន់តិរច្ឆានកំណើត ប្រេត អសុរកាយ នរក ព្រោះហេតុដែលដាក់អង្គជាតទៅក្នុងអង្គជាតមេស្វានេះឯង ម្នាលមោឃបុរស កាលបើកម្មនោះមានទោសធ្ងន់ដល់ម៉្លោះហើយ អ្នកឯងមិនគួរបើហ៊ានសេពអសទ្ធម្មជាធម៌របស់អ្នកស្រុក ជាធម៌របស់មនុស្សថោកទាប គ្រោះដោយអំពើអាក្រក់ មានកិច្ចដោយទឹកជាទីបំផុត របស់ជនមានគូស្រករ ជាធម៌លាក់លៀម ដែលគេត្រូវរួបរួមគ្នាតែ

ពីរនាក់នោះសោះ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនោះមិនប្រព្រឹត្តទៅ ដើម្បីសេចក្តី ជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណា មួយសេពមេថុនធម្ម ដោយហោចទៅ សូម្បីនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវ អាបត្តិបារាជិក រកសំវាសគ្មាន ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះ ចំពោះភិក្ខុទាំងឡាយដោយហេតុយ៉ាងនេះឯង ។

## និទានមេស្វា ចប់

[ ២៣ ] ក្នុងសម័យនោះ ពួកភិក្ខុវជ្ជីបុត្រនៅក្នុងក្រុងវេសាលីជាច្រើន រូប នាំគ្នាឆាន់ឆ្អែតហើយសិងៗ ស្ងួតហើយស្រង់ទឹកៗ ហើយឆាន់ៗ ហើយ សិងៗ ស្ងប់ស្ងាល់ហើយស្រង់ទឹក ឥតបានធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ឡើយ មិនពោលលាសិក្ខា មិនធ្វើឲ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ( គឺមិនសឹកសិន ) ហើយសេពមេថុនធម្ម ។ លុះសម័យតមកខាងក្រោយ ភិក្ខុទាំងនោះ ប្រទះសេចក្តីព្រាត់ប្រាសចាកញាតិខ្លះ ប្រទះសេចក្តីវិនាសភោគ- សម្បត្តិខ្លះ ប្រទះរោគមកបៀតបៀនខ្លះ ( ក៏នាំគ្នា ) ចូលទៅរកព្រះអានន្ទដ៏ មានអាយុ ហើយពោលពាក្យយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងខ្ញុំ ទាំងឡាយមិនមែនជាអ្នកតិះដៀលព្រះពុទ្ធ តិះដៀលព្រះធម៌ តិះដៀលព្រះ សង្ឃទេ បពិត្រព្រះអានន្ទដ៏ចម្រើន យើងខ្ញុំទាំងឡាយជាអ្នកតិះដៀលតែខ្លួន ឯង មិនមែនតិះដៀលអ្នកដទៃទេ យើងខ្ញុំទាំងឡាយ បានមកបួសក្នុងធម្មវិន័យ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយប្រពៃយ៉ាងនេះ ក៏ទៅ

ជាប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិសុទ្ធ ឲ្យបរិបូណ៌អស់មួយជីវិតមិនកើត យើងខ្ញុំទាំងឡាយហៅពេញជាមនុស្សឥតសំណាងវាសនា យើងខ្ញុំពេញជាមនុស្សឥតបុណ្យ បពិត្រព្រះអានន្ទដ៏ចម្រើន ប្រសិនបើយើងខ្ញុំបានទូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់ព្រះដ៏មានព្រះភាគឥឡូវនេះទៀត នោះយើងខ្ញុំគង់នឹងបានឃើញនូវកុសលធម៌ទាំងឡាយ នឹងខំប្រឹងប្រកបព្យាយាមជាគ្រឿងញ៉ាំងធម៌ទាំងឡាយ ដែលជាចំណែកនៃពោធិញ្ញាណឲ្យចម្រើនអស់រាត្រីមុននិងរាត្រីក្រោយ ( គឺបឋមយាម និងបច្ឆិមយាម ) ក្នុងកាលឥឡូវនេះឯងបពិត្រព្រះអានន្ទដ៏ចម្រើន យើងខ្ញុំសូមអង្វរ សូមលោកម្ចាស់នាំសេចក្តីនេះទៅក្រាបទូលព្រះដ៏មានព្រះភាគឲ្យទានផង ។ ព្រះអានន្ទដ៏មានអាយុក៏ទទួលពាក្យរបស់ពួកភិក្ខុវជ្ជីបុត្រអ្នកក្រុងវេសាលីថា អើ អាវុសោ ហើយចូលទៅកាន់ទីដែលព្រះដ៏មានព្រះភាគគង់ លុះចូលទៅដល់ហើយក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទតថាគតគប្បីដកសិក្ខាបទឈ្មោះបារាជិក ដែលតថាគតបានបញ្ញត្តហើយដល់សាវកទាំងឡាយ ព្រោះហេតុនៃជនអ្នកនៅក្នុងដែនវជ្ជីទាំងឡាយក្តី ព្រោះហេតុនៃវជ្ជីបុត្តកភិក្ខុទាំងឡាយក្តី ដោយអំពើណា អំពើនុ៎ះ មិនមែនជាហេតុមិនមែនជាឱកាសឡើយ ។

[ ២៤ ] ព្រោះនិទាននេះ ព្រោះដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្តែងធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកហើយ មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយមិនពោលលាសិក្ខា មិនប្រកាស

ខ្លួនថាជាអ្នកមានកម្លាំងថយ ហើយសេពមេថុនធម្ម បើភិក្ខុនោះមក ( សូមឧបសម្បទានឹងសង្ឃទៀត ) សង្ឃមិនត្រូវឲ្យឧបសម្បទាឡើយ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុណាមួយពោលលាសិក្ខាហើយ ប្រកាសខ្លួនថាជាអ្នកមានកម្លាំងថយ ហើយសេពមេថុនធម្ម បើភិក្ខុនោះ ( សូមបួសទៀត ) សង្ឃគប្បីឲ្យឧបសម្បទាចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដល់ព្រមដោយសិក្ខា និងសាជីវៈ ( ដែលតថាគតបញ្ញត្តហើយ ) សម្រាប់ភិក្ខុទាំងឡាយ ហើយមិនពោលលាសិក្ខា មិនធ្វើឲ្យជាក់ច្បាស់នូវការៈជាអ្នកមានកម្លាំងថយ ហើយសេពមេថុនធម្ម ដោយហោចទៅ សូម្បីតែនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវអាបត្តិបារាជិក រកសំវាសគ្មាន។

[ ២៥ ] ត្រង់ពាក្យថា ណាមួយ អធិប្បាយថា ភិក្ខុជាថេរៈក្តី ភិក្ខុបួសថ្មីក្តី ភិក្ខុកណ្តាលក្តីឯណា គឺថា តាមតែភិក្ខុរូបណា ដែលប្រកបក្នុងកម្មយ៉ាងណា មានជាតិយ៉ាងណា មានឈ្មោះយ៉ាងណា មានគោត្រយ៉ាងណា មានប្រក្រតីយ៉ាងណា មានគ្រឿងនៅយ៉ាងណា មានគោចរយ៉ាងណាក៏ដោយ ភិក្ខុនេះ តថាគតហៅថា ( ភិក្ខុ ) ណាមួយ ។

[ ២៦ ] ត្រង់ពាក្យថា ភិក្ខុ មានវិគ្រោះថា សមណៈណាជាអ្នកសូមសមណៈនោះហៅថា ភិក្ខុ ។ សមណៈណាចូលទៅអាស្រ័យនូវភិក្ខាចរិយវត្តសមណៈនោះហៅថា ភិក្ខុ ។ ជនណាទ្រទ្រង់សំពត់ដែលគេកាត់ហើយ ជននោះហៅថា ភិក្ខុ ។ ជនដែលហៅថា ភិក្ខុ ព្រោះហេតុវោហារបញ្ញត្តិថាសមណៈ ។ ហៅថា ភិក្ខុ ព្រោះបានប្តេជ្ញាខ្លួន ។ ហៅថា ភិក្ខុ ព្រោះសម្រេច

ជា ឯហិភិក្ខុ ។ ហៅថា ភិក្ខុ ព្រោះបានឧបសម្បទាដោយសរណគមន៍ ៣ ។ ហៅថា ភិក្ខុ ព្រោះហេតុជាអ្នកចម្រើន ។ ហៅថា ភិក្ខុ ព្រោះមានសារធម៌ ។ ហៅថា ភិក្ខុ ព្រោះជាអ្នកសិក្សា ។ ហៅថា ភិក្ខុ ព្រោះមិនបាច់សិក្សា ។ ហៅថា ភិក្ខុ ព្រោះបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចាដ៏សមគួរដល់ហេតុ ដែលមិនមានសេចក្តីអន្តរាយ ដោយសង្ឃដែលព្រមព្រៀងហើយ ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុណាដែលបានឧបសម្បទា ដោយញត្តិចតុត្ថកម្មវាចា ដ៏សមគួរដល់ហេតុដែលមិនមានវិបត្តិកម្រើក ដោយសង្ឃដែលព្រមព្រៀងហើយ ភិក្ខុនេះ តថាគតសំដៅយកក្នុងអត្ថនេះ ។

[ ២៧ ] ត្រង់ពាក្យថា សិក្ខា សំដៅត្រង់សិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ បណ្តាសិក្ខាទាំង ៣ នោះ សិក្ខាណាដែលហៅថា អធិសីលសិក្ខា សិក្ខានេះតថាគតសំដៅយកក្នុងសេចក្តីនេះ។

[ ២៨ ] ត្រង់ពាក្យថា សាជីវៈ គឺសិក្ខាបទណា ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ សិក្ខាបទដែលព្រះដ៏មានព្រះភាគបានបញ្ញត្តហើយនុ៎ះ ហៅថា សាជីវៈ ភិក្ខុដែលសិក្សាក្នុងសិក្ខាបទ ហៅថា សាជីវៈ នោះ តថាគតហៅថា អ្នកដល់ព្រមដោយសាជីវៈ ដោយហេតុនោះឯង ។

[ ២៩ ] ត្រង់ពាក្យថា មិនពោលលាសិក្ខា មិនធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ( មានព្រះពុទ្ធភាសិតថា ) ម្នាលភិក្ខុទាំងឡាយ កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ប៉ុន្តែសិក្ខាហៅថា ភិក្ខុមិនទាន់ពោលលានៅឡើយក៏មាន ។ ម្នាលភិក្ខុទាំងឡាយ កិរិយាដែល

ភិក្ខុបានធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយហើយ សិក្ខា ហៅថា ភិក្ខុបានពោលលាហើយក៏មាន ។

[ ៣០ ] ម្នាលភិក្ខុទាំងឡាយ កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់ នូវភាវៈជាអ្នកមានកម្លាំងថយ ប៉ុន្តែសិក្ខា ហៅថា ភិក្ខុមិនទាន់បានពោលលានៅឡើយ នោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អផ្សុកមិនរីករាយ ចង់ដើម្បីឲ្យឃ្លាតផុតចាកភេទជាសមណៈ នឿយណាយ ធុញទ្រាន់ ខ្ពើមរអើមនឹងភាពខ្លួនជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ប្រាថ្នាភាពជាឧបាសក ប្រាថ្នាភាពជាអ្នករក្សាអារាម ប្រាថ្នាភាពជាសាមណេរ ប្រាថ្នាភាពជាតិរ្ថិយ ប្រាថ្នាភាពជាតិរ្ថិយសាវក ប្រាថ្នាភាពនៃខ្លួនមិនមែនជាសមណៈ ប្រាថ្នាភាពនៃខ្លួនមិនមែនជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ប៉ុន្តែសិក្ខាហៅថា ភិក្ខុមិនទាន់បានពោលលានៅឡើយ ។ មួយវិញទៀត ភិក្ខុអផ្សុកមិនរីករាយ ចង់ចេញចាកសមណៈភាព នឿយណាយ ធុញទ្រាន់ ខ្ពើមរអើមនឹងភាពខ្លួនជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ។បេ។ ប្រាថ្នានូវភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះធម៌ ។បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះសង្ឃ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់សិក្ខា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់វិន័យ ។

និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់បាតិមោក្ខ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ឧទ្ទេស ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ឧបជ្ឈាយ៍ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់អាចារ្យ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់សទ្ធិវិហារិក។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់អន្តេវាសិក។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ភិក្ខុដែលមានឧបជ្ឈាយ៍ស្មើគ្នា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ភិក្ខុដែលមានអាចារ្យស្មើគ្នា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ភិក្ខុអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរស្មើគ្នា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាគ្រហស្ថ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាឧបាសក ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាអ្នករក្សាវត្ត ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាសាមណេរ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាតិរ្ថិយ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំត្រូវទៅជាតិរ្ថិយសាវក ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំលែងធ្វើជាសមណៈ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើដូច្នោះ មានតែខ្ញុំលែងធ្វើជាសក្យបុត្រ ។ ម្នាលភិក្ខុទាំងឡាយយ៉ាងនេះឯងហៅថា កិរិយាដែលភិក្ខុគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នក

មានកម្លាំងថយ ប៉ុន្តែសិក្ខាមិនទាន់ហៅថា ភិក្ខុបានពោលលានៅឡើយ ។ មួយវិញទៀត ភិក្ខុអផ្សុកមិនរីករាយ ចង់ឃ្លាតចាកសមណភាព កាលជាទុក្ខធុញទ្រាន់ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ។បេ។ ប្រាថ្នាភាពមិនមែនជាសក្យបុត្រ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើមែន មានតែខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បើមែន មានតែខ្ញុំត្រូវលែងធ្វើជាសក្យបុត្រ ។បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កាលបើហេតុយ៉ាងនេះមានពិតមែន ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កាលបើយ៉ាងនេះ មានតែខ្ញុំត្រូវលែងធ្វើជាសក្យបុត្រ ។បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ណ្ហើយចុះ ខ្ញុំត្រូវតែលះបង់ព្រះពុទ្ធ ។បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ណ្ហើយចុះ ខ្ញុំត្រូវលែងធ្វើជាសក្យបុត្រ ។បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ហេតុរបស់ខ្ញុំលើកទុកសិនចុះ ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។បេ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ហេតុរបស់ខ្ញុំលើកទុកសិនចុះ ត្រូវតែខ្ញុំលែងធ្វើជាសក្យបុត្រ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ប៉ុន្តែសិក្ខាមិនទាន់ហៅថា ភិក្ខុបានពោលលានៅឡើយ ។ មួយវិញទៀត ភិក្ខុអផ្សុក មិនរីករាយប្រាថ្នាដើម្បីឲ្យឃ្លាតផុតចាកសមណភាព ជាទុក្ខ ធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ។បេ។ នឹងចង់ឲ្យខ្លួនទៅជាអសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកមាតា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបិតា ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបងប្អូនប្រុស ។ និយាយ

ឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកបងប្អូនស្រី ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកកូនប្រុស ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកកូនស្រី ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកប្រពន្ធ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកពួកញាតិ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកពួកមិត្ត ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកស្រុក ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកនិគម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកស្រែ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកចម្ការ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកប្រាក់ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកមាស ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកសិល្បសាស្ត្រ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំរឭកជាញឹកញយនូវការសើច ការស្រដី និងការលេងអំពីមុន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ប៉ុន្តែសិក្ខា មិនចាត់ថាភិក្ខុបានពោលលាឡើយ ។ មួយវិញទៀត ភិក្ខុអផ្សុក មិនរីករាយ ប្រាថ្នាឲ្យឃ្លាតផុតចាកសមណភាព ជាទុក្ខ ធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ពេញចិត្តនឹងភាពជាគ្រហស្ថ ។បេ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមានមាតាៗ នោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បិតារបស់ខ្ញុំមាន បិតានោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនប្រុសរបស់ខ្ញុំមាន បងប្អូនប្រុសនោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនស្រីរបស់ខ្ញុំមាន បងប្អូនស្រីនោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹង

អ្នកដទៃដឹងច្បាស់ថា កូនស្រីរបស់ខ្ញុំមាន កូនស្រីនោះខ្ញុំត្រូវតែចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រពន្ធរបស់ខ្ញុំមាន ប្រពន្ធនោះខ្ញុំត្រូវតែចិញ្ចឹម។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកញាតិរបស់ខ្ញុំមាន អ្នកទាំងនោះត្រូវតែខ្ញុំចិញ្ចឹម ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកមិត្តរបស់ខ្ញុំមាន ពួកមិត្តទាំងនោះខ្ញុំត្រូវតែចិញ្ចឹម ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ប៉ុន្តែសិក្ខាមិនទាន់ហៅថា ភិក្ខុបានពោលលាឡើយ ។ ន័យមួយទៀត ភិក្ខុអផ្សុក មិនរីករាយ ចង់ឃ្លាតចេញចាកសមណភាព ជាទុក្ខ ធុញទ្រាន់ ខ្ពើមរអើមភាពជាភិក្ខុ ប្រាថ្នាភាពជាគ្រហស្ថ ។បេ។ មិនប្រាថ្នាភាពជាសក្យបុត្រ ក៏និយាយឲ្យអ្នកដទៃដឹងច្បាស់ថា មាតារបស់ខ្ញុំមាន មាតានោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បិតារបស់ខ្ញុំមាន បិតានោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនប្រុសរបស់ខ្ញុំមាន បងប្អូនប្រុសនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា បងប្អូនស្រីរបស់ខ្ញុំមាន បងប្អូនស្រីនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនប្រុសរបស់ខ្ញុំមាន កូនប្រុសនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា កូនស្រីរបស់ខ្ញុំមាន កូនស្រីនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រពន្ធរបស់ខ្ញុំមាន ប្រពន្ធនោះនឹងចិញ្ចឹមខ្ញុំ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកញាតិរបស់ខ្ញុំមាន ញាតិទាំងនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ពួកមិត្តរបស់ខ្ញុំមាន មិត្តទាំងនោះនឹងចិញ្ចឹមខ្ញុំ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ស្រុករបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹម

ជីវិតដោយស្រុកនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា និគមរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយនិគមនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ស្រែរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយស្រែនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ចម្ការរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយចម្ការនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ប្រាក់របស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយប្រាក់នោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា មាសរបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយមាសនោះក៏បាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា សិល្បសាស្ត្ររបស់ខ្ញុំមាន ខ្ញុំនឹងចិញ្ចឹមជីវិតដោយសិល្បសាស្ត្រនោះក៏បាន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ប៉ុន្តែសិក្ខាមិនទាន់ហៅថា ភិក្ខុបានពោលលាឡើយ ។ ន័យមួយទៀត ភិក្ខុអផ្សុក មិនរីករាយ ចង់ចេញចាកភាពជាសមណៈ ជាទុក្ខ និងភាពជាភិក្ខុជិនឆ្អន់ ខ្ពើមរអើមភិក្ខុភាព ប្រាថ្នានូវភាពជាគ្រហស្ថ ។បេ។ ប្រាថ្នាភាពមិនមែនជាសក្យបុត្រ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ( អំពើនេះ ) កម្របុគ្គលនឹងធ្វើបាន ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ( អំពើនេះ ) បុគ្គលមិនមែនងាយនឹងធ្វើបានទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ( អំពើនេះ ) បុគ្គលប្រព្រឹត្តបានដោយកម្រ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ( អំពើនេះ ) បុគ្គលមិនមែនប្រព្រឹត្តបានដោយងាយទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនអាច ( នៅក្នុងភេទបព្វជិតបាន ) ទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំមិនហ៊ាន ( នៅក្នុងភេទបព្វជិត ) ទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំ

មិនត្រេកអរ ( នឹងភេទបព្វជិត ) ទេ ។ និយាយឲ្យអ្នកដទៃដឹងច្បាស់ថា ខ្ញុំ មិនពេញចិត្ត ( នឹងភេទបព្វជិត ) ទេ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅ ថា កិរិយាគ្រាន់តែធ្វើឲ្យច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ប៉ុន្តែសិក្ខាមិនទាន់ ហៅថា ភិក្ខុបានពោលលាឡើយ ។

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ កិរិយាដែលភិក្ខុធ្វើឲ្យច្បាស់នូវភាវៈនៃ ខ្លួនជាបុគ្គលមានកម្លាំងថយ ទាំងសិក្ខាក៏ហៅថា ភិក្ខុបានពោលលានោះ តើ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អផ្សុកមិនត្រេកអរ ចង់ឃ្លាតចាកភាពជាសមណៈ នឿយណាយ ជិនឆ្អន់ ខ្ពើមរអើមនឹងភាពជា ភិក្ខុ ប្រាថ្នានូវភាពជាគ្រហស្ថ ។បេ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ ក៏និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះពុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ទើបហៅថា កិរិយាធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមាន កម្លាំងថយ ទាំងសិក្ខាក៏ហៅថា ភិក្ខុបានពោលលា ។ ម្យ៉ាងទៀត ភិក្ខុអផ្សុក មិនត្រេកអរ ប្រាថ្នាចង់ឃ្លាតចាកភាពជាសមណៈ នឿយណាយ ជិនឆ្អន់ ខ្ពើម រអើមនឹងភាពជាភិក្ខុ ពេញចិត្តនឹងភាពជាគ្រហស្ថ ។បេ។ ពេញចិត្តនឹងភាព មិនមែនជាសក្យបុត្រ ក៏និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះធម៌ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ព្រះសង្ឃ ។ និយាយឲ្យគេដឹង ច្បាស់ថា ខ្ញុំសូមលះបង់សិក្ខា ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ វិន័យ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់បាតិមោក្ខ ។ និយាយឲ្យ គេដឹងច្បាស់ថា ខ្ញុំសូមលះបង់នូវឧទ្ទេស ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូម

លះបង់ឧបជ្ឈាយ៍ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់អាចារ្យ ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់សទ្ធិវិហារិក ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់អន្តេវាសិក ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់បព្វជិត ដែលមានឧបជ្ឈាយ៍ស្មើគ្នា ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់បព្វជិតដែលមានអាចារ្យស្មើគ្នា ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំសូមលះបង់ភិក្ខុ ដែលប្រព្រឹត្តព្រហ្មចរិយធម៌ជាមួយគ្នា ។បេ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាគ្រហស្ថចុះ ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាឧបាសកចុះ ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាញោមវត្តចុះ ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាសាមណេរចុះ ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាតិរ្ថិយចុះ ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាជាសាវកនៃតិរ្ថិយចុះ ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថាមិនមែនជាសមណៈទេចុះ ។ និយាយឲ្យគេដឹងច្បាស់ថា លោកចូរចាំទុកនូវខ្ញុំថា មិនមែនជាសក្យបុត្រទេ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះទើបហៅថា កិរិយាធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមានកម្លាំងថយ ទាំងសិក្ខាក៏ហៅថា ភិក្ខុបានពោលលាហើយ ។ ម្យ៉ាងទៀត ភិក្ខុអផ្សុក មិនត្រេកអរ ចង់ឃ្លាតចាកភាពជាសមណៈ នឿយណាយ ជិនធុញ ខ្ពើមរអើមនឹងភាពជាភិក្ខុ ពេញចិត្តនឹងភាពជាគ្រហស្ថ ។បេ។ ពេញចិត្តនឹងភាពមិនមែនជាសក្យបុត្រ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំមិនត្រូវការដោយព្រះពុទ្ធទេ ។បេ។ ពោលឲ្យគេដឹងច្បាស់

ថា ខ្ញុំមិនត្រូវការដោយបព្វជិតមានព្រហ្មចារ្យស្មើគ្នាទាំងឡាយទេ ។ ម្នាលភិក្ខុទាំងឡាយ ក៏យ៉ាងនេះ ។បេ។ ម្យ៉ាងទៀត ។បេ។ និយាយឲ្យគេដឹងច្បាស់ថា ប្រយោជន៍អ្វីដោយព្រះពុទ្ធដល់ខ្ញុំ ។បេ។ និយាយឲ្យគេដឹងច្បាស់ថា ប្រយោជន៍អ្វីដោយសព្រហ្មចារីភិក្ខុទាំងឡាយដល់ខ្ញុំ ។ ក៏យ៉ាងនេះ ។បេ។ ម្យ៉ាងទៀត ។បេ។ និយាយឲ្យគេដឹងច្បាស់ថា សេចក្តីត្រូវការដោយព្រះពុទ្ធ នៃខ្ញុំមិនមាន ។បេ។ និយាយឲ្យគេដឹងច្បាស់ថា សេចក្តីត្រូវការដោយ សព្រហ្មចារីភិក្ខុទាំងឡាយនៃខ្ញុំមិនមាន ។ ក៏យ៉ាងនេះ ។បេ។ ម្យ៉ាងទៀត ។បេ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំរួចស្រឡះចាកព្រះពុទ្ធហើយ ។បេ។ និយាយឲ្យគេដឹងច្បាស់ថា ខ្ញុំរួចស្រឡះចាកសព្រហ្មចារីភិក្ខុទាំងឡាយហើយ ។ ម្នាលភិក្ខុទាំងឡាយក៏យ៉ាងនេះហៅថា ការបានធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជា បុគ្គលមានកម្លាំងថយ ទាំងសិក្ខាក៏ហៅថា ភិក្ខុបានពោលលាហើយ ។ ម្យ៉ាងទៀត ពាក្យទាំងឡាយណា សូម្បីដទៃជាពាក្យផ្លាស់ប្តូរដោយពាក្យថា ព្រះពុទ្ធក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា ព្រះធម៌ក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា ព្រះសង្ឃក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សិក្ខាក្តី ជាពាក្យផ្លាស់ប្តូរ ដោយពាក្យថា វិន័យក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា បាតិមោក្ខក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា ឧទ្ទេសក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា ឧបជ្ឈាយ៍ក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា អាចារ្យក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សទ្ធិវិហារិកក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា អន្តេវាសិកក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សមានុបជ្ឈាយកៈក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សមានាចរិយកៈ

ក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សព្រហ្មចារីក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា គ្រហស្ថក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា ឧបាសកក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា អារាមិកៈក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា សាមណេរក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា តិត្ថិយក្តី ជាពាក្យផ្លាស់ប្តូរ ដោយពាក្យថា តិត្ថិយសាវកក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា មិនមែនជាសមណៈក្តី ជាពាក្យផ្លាស់ប្តូរដោយពាក្យថា មិនមែនជាសក្យបុត្រក្តី ភិក្ខុនិយាយឲ្យគេដឹងច្បាស់ដោយពាក្យអម្បាលនោះ ដែលជាអាការ ( ពោលលាសិក្ខា ) ដែលជាភេទ ដែលជានិមិត្ត ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា ការធ្វើឲ្យជាក់ច្បាស់នូវភាវៈនៃខ្លួនជាបុគ្គលមានកម្លាំងថយ ទាំងសិក្ខាក៏ហៅថា ភិក្ខុបានពោលលាហើយ ។

[ ៣២ ] ម្នាលភិក្ខុទាំងឡាយ សិក្ខាដែលភិក្ខុមិនបានពោលលានោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សិក្ខាដែលភិក្ខុក្នុងសាសនានេះ បានពោលលាហើយដោយអាការ និងភេទ និងនិមិត្តទាំងឡាយណាៗ ភិក្ខុជាមនុស្សឆ្កួតក៏បានពោលលាសិក្ខាដោយអាការ និងភេទ និងនិមិត្តទាំងឡាយនោះៗ ដែរ ។ សិក្ខាមិនហៅថាភិក្ខុឆ្កួតនោះបានពោលលាឡើយ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់បុគ្គលឆ្កួត ។ សិក្ខាមិនហៅថាភិក្ខុបានពោលលាទេ ។ ភិក្ខុមានចិត្តរវើរវាយហើយពោលលាសិក្ខា ។ សិក្ខាមិនហៅថាភិក្ខុបានពោលលាទេ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់បុគ្គលមានចិត្តរវើរវាយហើយ ។ សិក្ខាមិនហៅថា ភិក្ខុបានពោលលាទេ ។ ភិក្ខុដែលវេទនាកំពុងគ្របសង្កត់ ពោលលា

សិក្ខា ។ សិក្ខាមិនហៅថាភិក្ខុបានពោលលាទេ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់បុគ្គលដែលវេទនាកំពុងគ្របសង្កត់ ។ សិក្ខាមិនហៅថាភិក្ខុបានពោលលាទេ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ទេវតា ។ សិក្ខាមិនហៅថាភិក្ខុបានពោលលាទេ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់សត្វតិរច្ឆាន ។ សិក្ខាមិនហៅថាភិក្ខុបានពោលលាទេ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ជនជាមិលក្ខកជាតិ ដោយអរិយកភាសា ។ បើជនជាមិលក្ខកជាតិនោះ មិនដឹងសេចក្ដីច្បាស់ទេ សិក្ខាក៏មិនហៅថា ភិក្ខុបានពោលលាទេ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ជនជាអរិយកជាតិដោយមិលក្ខកភាសា ។ បើជនជាអរិយកជាតិនោះ មិនដឹងសេចក្ដីច្បាស់ទេ សិក្ខាមិនហៅថាភិក្ខុបានពោលលាទេ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ជនជាអរិយកជាតិដោយអរិយកភាសា ។ បើជនជាអរិយកជាតិនោះមិនដឹងសេចក្ដីច្បាស់ទេ សិក្ខាមិនហៅថាភិក្ខុបានពោលលាឡើយ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់ជនជាមិលក្ខកជាតិដោយមិលក្ខកភាសា ។ បើជនជាមិលក្ខកជាតិនោះ មិនដឹងសេចក្ដីច្បាស់ទេ សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ ។ ភិក្ខុពោលលាសិក្ខាជាល្បែងលេង ។ សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ ។ ភិក្ខុពោលលាសិក្ខាដោយភ្លាត់មាត់ ។ សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ ។ ភិក្ខុមិនមានប្រាថ្នាឲ្យអ្នកដទៃឮតែបែរជាឲ្យឮវិញ[១] សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ ។ ភិក្ខុមានប្រាថ្នាឲ្យអ្នក

[១] សំដៅភិក្ខុដែលកំពុងបង្ហាញក្ដី សាកសួរក្ដី រៀនក្ដី ទន្ទេញក្ដី ពណ៌នាក្ដី នូវបាលីសូត្រលាសិក្ខា គឺសូត្របាលីសឹក ។

ជទៃទព្វតែបែរជាមិនឲ្យព្វវិញ[១] ។ សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ ។ ភិក្ខុពោលលាសិក្ខាក្នុងសំណាក់មនុស្សដែលមិនដឹងសេចក្តីច្បាស់ ។ សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ ។ ភិក្ខុមិនពោលលាសិក្ខាឲ្យព្វដល់មនុស្សដែលដឹងសេចក្តីច្បាស់ ។ សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ ។ ម្យ៉ាងទៀត ភិក្ខុពោលលាសិក្ខាខ្សឹបៗ គ្រប់បទមិនឲ្យអ្នកដទៃព្វ ។ សិក្ខាហៅថាភិក្ខុមិនបានពោលលាឡើយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង សិក្ខាហៅថា ភិក្ខុមិនបានពោលលាឡើយ ។

[ ៣៣ ] ធម៌ដែលហៅថា មេថុននោះ គឺធម៌ដែលជារបស់អសប្បុរសធម៌របស់អ្នកស្រុក ធម៌របស់មនុស្សថោកទាប ឬអំពើអាក្រក់ មានកិច្ចដោយទឹកជាទីបំផុត ជាអំពើដែលជនពីរនាក់តែងរួបរួមគ្នាក្នុងទីកំបាំង នេះឯងហៅថា មេថុនធម្ម ។

[ ៣៤ ] បុគ្គលណា ឲ្យនិមិត្តខ្លួនចូលទៅដោយនិមិត្ត ( គេ ) ឲ្យអង្គកំណើត ( ខ្លួន ) ចូលទៅដោយអង្គកំណើត ( គេ ) ដោយហោចទៅសូម្បីអស់ទីត្រឹមតែ ១ គ្រាប់ល្ង បុគ្គលនោះហៅថា សេព ។

[ ៣៥ ] ត្រង់ពាក្យថា ដោយហោចទៅសូម្បីដោយសត្វតិរច្ឆានញី អធិប្បាយថា ភិក្ខុសេពចំពោះមេថុនធម្ម សូម្បីដោយសត្វតិរច្ឆានញី ក៏មិនមែនជាសមណៈ មិនមែនជាសក្យបុត្រឡើយ នឹងបាច់និយាយទៅថ្វីដល់ភិក្ខុដែលសេពមេថុនធម្ម ដោយស្រីមនុស្ស ព្រោះហេតុនោះ បានជាហៅថា

---

១- សំដៅភិក្ខុដែលមិនបញ្ចេញវចីភេទឲ្យអ្នកដទៃព្វ ។

( ភិក្ខុសេពមេថុនធម្ម ) យ៉ាងហោចទៅសូម្បីដោយសត្វតិរច្ឆានញី ( ក៏ត្រូវអាបត្តិបារាជិក ) ។

[ ៣៦ ] ត្រង់ពាក្យថា ភិក្ខុត្រូវអាបត្តិបារាជិក អធិប្បាយថា ធម្មតាបុរសដែលមានក្បាលដាច់ មិនអាចនឹងតភ្ជាប់ដោយសរីរៈនោះ ហើយរស់នៅវិញបាន យ៉ាងណាមិញ ភិក្ខុតែសេពមេថុនធម្មហើយ ក៏មិនមែនជាសមណៈមិនមែនជាសក្យបុត្រ យ៉ាងនោះឯង ព្រោះហេតុនោះ បានជាហៅថា ត្រូវអាបត្តិបារាជិក ។

[ ៣៧ ] ត្រង់ពាក្យថា រកសំវាសគ្មាន អធិប្បាយថា សង្ឃកម្មជាមួយគ្នាក្តី ឧទ្ទេសជាមួយគ្នាក្តី ការសិក្សាស្មើគ្នាក្តី នេះឯងហៅថាសំវាស សំវាសនោះមិនមានជាមួយភិក្ខុដែលត្រូវអាបត្តិបារាជិកនោះទេ ព្រោះហេតុនោះ បានជាហៅថា រកសំវាសគ្មាន ។

[ ៣៨ ] ស្រីមាន ៣ ពួក គឺស្រីមនុស្ស ១ ស្រីអមនុស្ស ១ សត្វតិរច្ឆានញី ១ ។ ឧភតោព្យញ្ជនក គឺជនដែលមានភេទពីរ មាន ៣ ពួក គឺមនុស្សមានភេទពីរ ១ អមនុស្សមានភេទពីរ ១ តិរច្ឆានមានភេទពីរ ១ ។ បណ្ឌក គឺជនខ្ទើយមាន ៣ ពួក គឺមនុស្សខ្ទើយ ១ អមនុស្សខ្ទើយ ១ តិរច្ឆានខ្ទើយ ១ ។ បុរសមាន ៣ ពួក គឺមនុស្សប្រុស ១ អមនុស្សប្រុស ១ តិរច្ឆានឈ្មោល ១ ។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំង ៣ គឺវច្ចមគ្គ ( ទ្វារធំ ) ១ បស្សាវមគ្គ ( ទ្វារតូច ) ១ មុខមគ្គ ( ទ្វារមាត់ ) ១ ( ទ្វារមគ្គណាមួយ ) របស់មនុស្សស្រី ត្រូវអាបត្តិបារាជិក ។ កាលបើ

ភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំង ៣ គឺវច្ចមគ្គ ១ បស្សាវមគ្គ ១ មុខមគ្គ ១ ( ទ្វារមគ្គណាមួយ ) របស់អមនុស្សស្រី ។បេ។ របស់តិរច្ឆានញី ត្រូវអាបត្តិបារាជិក ។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំង ៣ គឺវច្ចមគ្គ ១ បស្សាវមគ្គ ១ មុខមគ្គ ១ ( ទ្វារមគ្គណាមួយ ) របស់មនុស្សមានភេទពីរ ។បេ។ របស់អមនុស្សមានភេទពីរ ។បេ។ របស់តិរច្ឆានមានភេទពីរ ត្រូវអាបត្តិបារាជិក ។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំងពីរ គឺវច្ចមគ្គ ១ មុខមគ្គ ១ ( ទ្វារមគ្គណាមួយ ) របស់មនុស្សខ្ទើយ ត្រូវអាបត្តិបារាជិក ។ កាលបើភិក្ខុសេពមេថុនធម្មចំពោះទ្វារមគ្គទាំងពីរ គឺវច្ចមគ្គ ១ មុខមគ្គ ១ ( ទ្វារមគ្គណាមួយ ) របស់អមនុស្សខ្ទើយ ។បេ។ របស់តិរច្ឆានខ្ទើយ ។បេ។ របស់អមនុស្សប្រុស ។បេ។ របស់តិរច្ឆានឈ្មោល ត្រូវអាបត្តិបារាជិក ។

[ ៣៩ ] ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គមនុស្សស្រី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារបស្សាវមគ្គមនុស្សស្រី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារមុខមគ្គមនុស្សស្រី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង ហើយបញ្ចូលអង្គជាត របស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គក្តី ទ្វារបស្សាវមគ្គក្តី ទ្វារមុខមគ្គក្តី ( ទ្វារមគ្គណាមួយ ) របស់អមនុស្សស្រី ។បេ។ របស់តិរច្ឆានញី របស់មនុស្សមានភេទពីរ របស់អមនុស្សមានភេទពីរ របស់តិរច្ឆានមានភេទពីរ ត្រូវអាបត្តិបារាជិក ។ ភិក្ខុ

មានចិត្តចង់សេពតាំងឡើងប្រាកដ ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គក្តី ។បេ។ មុខមគ្គក្តី របស់មនុស្សស្រីឡើយ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានចិត្តចង់សេពតាំងឡើងប្រាកដ ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គក្តី ទ្វារមុខមគ្គក្តី ( ទ្វារមគ្គណាមួយ ) របស់អមនុស្សស្រីឡើយ ។បេ។ របស់តិរច្ឆានឡើយ របស់មនុស្សប្រុស របស់អមនុស្សប្រុស របស់តិរច្ឆានឈ្មោល ត្រូវអាបត្តិបារាជិក ។

[ ៤០ ] ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គ ( ស្រីនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គ ( ស្រីនោះ ) ។ បើភិក្ខុនោះមិនត្រេកអរនឹងអង្គជាត ដែលកំពុងចូលទៅទេ តែជាត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គ ( ស្រីនោះ ) ។ បើភិក្ខុនោះមិនត្រេកអរនឹង

អង្គជាតដែលកំពុងចូលទៅក្តី មិនត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី តែថាត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គ ( ស្រីនោះ ) ។ បើភិក្ខុនោះមិនត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី មិនត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី មិនត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី តែថាត្រេកអរនឹងអង្គជាតដែលបន្ថយចេញ ត្រូវអាបត្តិបារាជិក ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គ ( ស្រីនោះ ) ។ បើភិក្ខុមិនត្រេកអរនឹងអង្គជាតដែលកំពុងចូលក្តី មិនត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី មិនត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី មិនត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារបស្សាវមគ្គក្តី ។បេ។ ទ្វារមុខមគ្គក្តី ( របស់ស្រីនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ បើភិក្ខុ

នោះមិនត្រេកអរ ក៏ពុំត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) ដែលទៅក្រាក់ដីនខ្ទួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយមានទ្វារមគ្គ សត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយមានទ្វារមគ្គ សត្វពុំទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រីស្លាប់ ( ១ នាក់ ) ដែលមានទ្វារមគ្គ សត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ ( របស់មនុស្សស្រីស្លាប់នោះ ) ។ បើភិក្ខុនោះ ត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ទយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ បើភិក្ខុនោះមិនត្រេកអរទេ ក៏ពុំត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកអមនុស្សស្រី ។បេ។ តិរច្ឆានញី មនុស្សមានភេទពីរ អមនុស្សមានភេទពីរ តិរច្ឆានមានភេទពីរ មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ ( របស់ជនទាំងនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ទយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ បើមិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។

ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានមានភេទពីរ ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានមានភេទពីរដែលស្លាប់ហើយ មានទ្វារមគ្គសត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ ( របស់តិរច្ឆានមានភេទពីរដែលស្លាប់ហើយនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សខ្ទើយ ។បេ។ អមនុស្សខ្ទើយ តិរច្ឆានខ្ទើយ មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គក្តី ។បេ។ តាមទ្វារមុខមគ្គក្តី ( របស់ជនទាំងនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ បើមិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានខ្ទើយដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែល

កំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីហើយដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានទ្វីយដែលស្លាប់ហើយ មានទ្វារមគ្គសត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គក្តី ។បេ។ ទ្វារមុខមគ្គក្តី ( របស់តិរច្ឆានទ្វីយដែលស្លាប់ហើយនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សប្រុស ។បេ។ អមនុស្សប្រុស ។បេ។ តិរច្ឆានឈ្មោលមកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( ភិក្ខុនោះ ) ទៅតាមទ្វារវច្ចមគ្គក្តី ។បេ។ មុខមគ្គក្តី ( របស់ជនទាំងនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានឈ្មោលដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែល

ខូចស្អុយតិចក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានឈ្មោលដែលស្លាប់ហើយ មានទ្វារមគ្គសត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាតភិក្ខុនោះទៅតាមទ្វារវច្ចមគ្គក្តី ។បេ។ ទ្វារមុខមគ្គក្តី ( របស់តិរច្ឆាននោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។

[ ៤១ ] ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( របស់ភិក្ខុនោះ ) ដែលគ្មានស្រោមទ្រនាប់តាមទ្វារវច្ចមគ្គ ឬបស្សាវមគ្គ ឬមុខមគ្គ ( របស់ស្រី ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ស្រី ) ដែលគ្មានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ស្រី ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ស្រី ) គ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែល

កំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ( ១ នាក់ ) ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលខូចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកស្រីដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( របស់ភិក្ខុ ) ដែលគ្មានស្រោមទ្រនាប់ តាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ (របស់ស្រី ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ស្រី ) គ្មានស្រោមទ្រនាប់ក្តី អង្គជាត (របស់ភិក្ខុ) មានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ស្រី ) មានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ស្រី ) គ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកអមនុស្សស្រី ។បេ។ តិរច្ឆានញី មនុស្សមានភេទពីរ អមនុស្សមានភេទពីរ តិរច្ឆានមានភេទពីរ មកកាន់សំណាក់ភិក្ខុ ( ១ រូប )

ហើយបញ្ចូលអង្គជាត ( របស់ភិក្ខុ ) ដែលគ្មានស្រោមទ្រនាប់ទៅតាមទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ ( របស់ជនទាំងនោះ ) ដែលមានស្រោមក្តី អង្គជាតភិក្ខុមានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ជនទាំងនោះ ) គ្មានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ជនទាំងនោះ ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលគ្មានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ជនទាំងនោះ ) ដែលគ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានមានភេទពីរ ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានមានភេទពីរ ដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( របស់ភិក្ខុ ) ដែលគ្មានស្រោមទ្រនាប់ តាមទ្វារវច្ចមគ្គក្តី ។បេ។ តាមទ្វារមុខមគ្គក្តី ( របស់តិរច្ឆានមានភេទពីរ ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ តាមទ្វារមគ្គ ( របស់តិរច្ឆានមានភេទពីរ )

ដែលគ្មានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) មានស្រោមទ្រនាប់ តាមទ្វារមគ្គ ( របស់តិរច្ឆានមានភេទពីរ ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ តាមទ្វារមគ្គ ( របស់តិរច្ឆានមានភេទពីរ ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ តាមទ្វារមគ្គ ( របស់តិរច្ឆានមានភេទពីរ ) ដែលគ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រីឲ្យ អមនុស្សស្រីឲ្យ តិរច្ឆានញីឲ្យ មនុស្សប្រុស អមនុស្សប្រុស តិរច្ឆានឈ្មោល មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( របស់ភិក្ខុនោះ ) ដែលគ្មានស្រោមទ្រនាប់ តាមទ្វារវច្ចមគ្គក្តី ។បេ។ តាមទ្វារមុខមគ្គក្តី ( របស់ជនទាំងនោះ ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ជនទាំងនោះ ) ដែលគ្មានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ជនទាំងនោះ ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលគ្មានស្រោមទ្រនាប់ ( តាមទ្វារមគ្គរបស់ជនទាំងនោះ ) ដែលគ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាត

ដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាត ដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ ( បើភិក្ខុនោះ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានឈ្មោលដែលនៅក្រាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកតិរច្ឆានឈ្មោលដែលស្លាប់ហើយ សត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) មកកាន់សំណាក់ភិក្ខុ ( ១ រូប ) ហើយបញ្ចូលអង្គជាត ( របស់ភិក្ខុ ) ដែលឥតស្រោមទ្រនាប់ទៅតាមទ្វារវច្ចមគ្គក្តី ។បេ។ តាមទ្វារមុខមគ្គក្តី ( របស់តិរច្ឆានឈ្មោល ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ តាមទ្វារមគ្គតិរច្ឆានឈ្មោល ដែលគ្មានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ តាមទ្វារមគ្គ ( របស់តិរច្ឆានឈ្មោល ) ដែលមានស្រោមទ្រនាប់ក្តី អង្គជាត ( របស់ភិក្ខុ ) ដែលគ្មានស្រោមទ្រនាប់ តាមទ្វារមគ្គ ( របស់តិរច្ឆានឈ្មោល ) ដែលគ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះ ត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។

[ ៤២ ] ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់មនុស្សស្រី ( ម្នាក់ ) ហើយបញ្ចូលទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ ( របស់ស្រីនោះ ) ឲ្យចូលទៅដោយអង្គជាត ( របស់ភិក្ខុនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់មនុស្សស្រី ( ម្នាក់ ) ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់មនុស្សស្រីដែលស្លាប់ហើយ សត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) ហើយញុំាងទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ ( របស់ស្រីនោះ ) ឲ្យចូលទៅដោយអង្គជាត ( របស់ភិក្ខុនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់អមនុស្ស

ស្រី ។បេ។ តិរច្ឆានញី មនុស្សមានភេទពីរ អមនុស្សមានភេទពីរ តិរច្ឆានមានភេទពីរ មនុស្សខ្ទើយ អមនុស្សខ្ទើយ តិរច្ឆានខ្ទើយ មនុស្សប្រុស អមនុស្សប្រុស តិរច្ឆានឈ្មោល ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារមុខមគ្គ (របស់ជនទាំងនោះ ) ឲ្យចូលទៅដោយអង្គជាត ( របស់ភិក្ខុនោះ ) ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់តិរច្ឆានឈ្មោល ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់តិរច្ឆានឈ្មោល ដែលស្លាប់ហើយ សត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារមុខមគ្គ ( របស់តិរច្ឆានឈ្មោលនោះ ) ឲ្យចូលទៅដោយអង្គជាត ( របស់ភិក្ខុនោះ ) ។ បើភិក្ខុនោះត្រេកអរនឹង អង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។

[ ៤៣ ] ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់មនុស្សស្រី ( ម្នាក់ ) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ ( របស់ស្រីនោះ ) ដែលគ្មានស្រោមទ្រនាប់ ឲ្យចូលទៅដោយអង្គជាត ( របស់ភិក្ខុនោះ ) ដែលមានស្រោមទ្រនាប់ក្តី ទ្វារមគ្គរបស់ស្រីដែលមានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) ដែលគ្មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់ស្រី ) មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់ស្រី ) គ្មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះ ត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់មនុស្សស្រី ( ម្នាក់ ) ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់មនុស្សស្រី ដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារបស្សាវមគ្គ ឬទ្វារមុខមគ្គ ( របស់ស្រីនោះ ) ដែលគ្មានស្រោមទ្រនាប់ ឲ្យចូលទៅដោយអង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ក្តី ទ្វារមគ្គ

( របស់ស្រី ) មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់ស្រី ) មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់ស្រី ) គ្មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្តយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់មនុស្សស្រី ។បេ។ តិរច្ឆានញី មនុស្សមានភេទពីរ អមនុស្សមានភេទពីរ តិរច្ឆានមានភេទពីរ មនុស្សខ្ទើយ អមនុស្សខ្ទើយ តិរច្ឆានខ្ទើយ មនុស្សប្រុស អមនុស្សប្រុស តិរច្ឆានឈ្មោល ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារមុខមគ្គ ( របស់ជនទាំងនោះ ) ដែលគ្មានស្រោមទ្រនាប់ឲ្យចូលទៅដោយអង្គជាត ( របស់ភិក្ខុ ) ដែលមានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់ជនទាំងនោះ ) មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់ជនទាំងនោះ ) មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់ជនទាំងនោះ ) គ្មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹង

អង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិបារាជិក ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់តិរច្ឆានឈ្មោល ដែលនៅភ្ញាក់ដឹងខ្លួនក្តី ដែលកំពុងដេកលក់ក្តី ដែលស្រវឹងក្តី ដែលឆ្កួតក្តី ដែលភ្លេចស្មារតីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីក្តី ដែលស្លាប់ហើយសត្វមិនទាន់ស៊ីដោយច្រើនក្តី ។បេ។ ត្រូវអាបត្តិបារាជិក ។បេ។ ពួកភិក្ខុជាសត្រូវនាំយកភិក្ខុ ( ១ រូប ) មកកាន់សំណាក់តិរច្ឆានឈ្មោលដែលស្លាប់ហើយសត្វស៊ីហើយដោយច្រើន ( នៅសល់បន្តិចបន្តួច ) ហើយញ៉ាំងទ្វារវច្ចមគ្គ ឬទ្វារមុខមគ្គ ( របស់តិរច្ឆានឈ្មោល ) ដែលគ្មានស្រោមទ្រនាប់ឲ្យចូលទៅដោយអង្គជាត ( របស់ភិក្ខុ ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់តិរច្ឆានឈ្មោល ) មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់តិរច្ឆានឈ្មោល ) មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) មានស្រោមទ្រនាប់ក្តី ទ្វារមគ្គ ( របស់តិរច្ឆានឈ្មោល ) គ្មានស្រោមទ្រនាប់ អង្គជាត ( របស់ភិក្ខុ ) គ្មានស្រោមទ្រនាប់ក្តី ។ បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ ( ក្នុងទ្វារមគ្គនោះ ) ក្តី ត្រេកអរនឹងអង្គជាតដែលបន្ថយចេញក្តី ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ( បើភិក្ខុ ) មិនត្រេកអរទេ ក៏មិនត្រូវអាបត្តិឡើយ ។

[ ៤៤ ] ពួកភិក្ខុជាសត្រូវដែលបានសម្តែងហើយដោយពិស្តារយ៉ាងណា ពួកស្តេចជាសត្រូវក្តី ពួកចោរជាសត្រូវក្តី ពួកអ្នកលេងជាសត្រូវក្តី

ពួកសត្រូវអ្នកពុះទ្រូងអាវុធយកបេះដូងក្តី បណ្ឌិតគប្បីពោលឲ្យពិស្តារយ៉ាងនោះដែរចុះ ។

[ ៤៥ ] ភិក្ខុញុំាងមគ្គឲ្យចូលទៅដោយមគ្គ[១] ត្រូវអាបត្តិបារាជិក ។ ភិក្ខុញុំាងអមគ្គឲ្យចូលទៅដោយមគ្គ[២] ត្រូវអាបត្តិបារាជិក ។ ភិក្ខុញុំាងមគ្គឲ្យចូលទៅដោយអមគ្គ[៣] ត្រូវអាបត្តិបារាជិក ។ ភិក្ខុញុំាងអមគ្គឲ្យចូលទៅដោយអមគ្គ[៤] ត្រូវអាបត្តិថុល្លច្ច័យ ។

[ ៤៦ ] ភិក្ខុសេពមេថុនធម្មនឹងភិក្ខុផងគ្នាដែលកំពុងដេកលក់ បើភិក្ខុនោះភ្ញាក់ឡើងហើយត្រេកអរដែរ សង្ឃត្រូវឲ្យវិនាស ( គឺត្រូវផ្សឹកចេញ ) ទាំងពីររូប ។ បើភិក្ខុនោះភ្ញាក់ឡើងហើយមិនត្រេកអរទេ សង្ឃត្រូវឲ្យវិនាសតែភិក្ខុដែលប្រទូស្ត ( គឺភិក្ខុអ្នកសេពនោះ ) ។ ភិក្ខុសេពមេថុនធម្មនឹងសាមណេរដែលកំពុងដេកលក់ បើសាមណេរនោះភ្ញាក់ឡើង ហើយត្រេកអរដែរ សង្ឃត្រូវឲ្យវិនាសទាំងពីររូប ។ បើសាមណេរនោះភ្ញាក់ឡើងហើយមិនត្រេកអរទេ សង្ឃត្រូវឲ្យវិនាសតែភិក្ខុដែលប្រទូស្ត ។ សាមណេរសេពមេថុន-ធម្មនឹងភិក្ខុដែលកំពុងដេកលក់ បើភិក្ខុនោះភ្ញាក់ឡើងហើយត្រេកអរដែរ សង្ឃត្រូវឲ្យវិនាសទាំងពីររូប ។ បើភិក្ខុនោះភ្ញាក់ឡើងហើយមិនត្រេកអរទេ សង្ឃ

---

១- គឺភិក្ខុញុំាងអង្គជាតរបស់ខ្លួនឲ្យចូលទៅតាមទ្វារមគ្គទាំង ៣ ទ្វារមគ្គណាមួយ ។

២- គឺបញ្ចូលអង្គជាតទៅតាមទ្វារមគ្គ ហើយបន្ថយអង្គជាតចេញតាមមុខដំបៅដែលមានជុំវិញទ្វារមគ្គនោះ ។

៣- គឺបញ្ចូលអង្គជាតទៅតាមមុខដំបៅ ហើយបន្ថយចេញតាមទ្វារមគ្គវិញ ។

៤- គឺបញ្ចូលអង្គជាតទៅតាមមុខដំបៅមួយ ហើយបន្ថយចេញតាមមុខដំបៅផ្សេងវិញ ។

ត្រូវឲ្យវិនាសតែសាមណេរដែលប្រទូស្ត ។ សាមណេរសេពមេថុនធម្មនឹងសាមណេរផងគ្នា ដែលកំពុងដេកលក់ បើសាមណេរនោះភ្ញាក់ឡើងហើយត្រេកអរដែរ សង្ឃត្រូវឲ្យវិនាសទាំងពីររូប ។ បើសាមណេរនោះភ្ញាក់ឡើងហើយមិនត្រេកអរទេ សង្ឃត្រូវឲ្យវិនាសតែសាមណេរដែលប្រទូស្ត ។

[ ៤៧ ] អាបត្តិមិនមាន ( ដល់ភិក្ខុ ៥ ពួក ) គឺ ភិក្ខុមិនដឹង ១ ភិក្ខុឆ្កួត ១ ភិក្ខុមានចិត្តរវើរវាយ ១ ភិក្ខុដែលវេទនាគ្របសង្កត់ ១ អាទិកម្មិក ( គឺភិក្ខុដើមបញ្ញត្តិ ) ១ ។

## របៀបសម្តែងអំពីអង្គជាត និងទ្វារមគ្គមានស្រោមទ្រនាប់ ចប់

[ ៤៨ ] ( មាតិកានុក្រម គឺ បញ្ជីរឿងតាមលំដាប់ហូរហែ ដែលនឹងសម្តែងតទៅដូចខាងក្រោមនេះគឺ )

រឿងស្វាញី រឿងពួកវជ្ជីបុត្តកភិក្ខុ រឿងភិក្ខុក្លែងភេទជាគ្រហស្ថ រឿងភិក្ខុអាក្រាត រឿងពួកភិក្ខុប្រព្រឹត្តតាមលទ្ធិតិរ្ថិយ រឿងទារិកា រឿងឧប្បលវណ្ណាភិក្ខុនី រឿងជនផ្សេងគ្នាពីររូប គឺ ភិក្ខុក្លាយជាភេទស្រី និងភិក្ខុនីក្លាយភេទជាបុរស រឿងមាតា រឿងបិតា រឿងបងប្អូនស្រី រឿងប្រពន្ធ រឿងភិក្ខុខ្នងទន់ រឿងភិក្ខុមានអង្គជាតយារ រឿងស្នាមដំបៅពីរយ៉ាង រឿងរូបគំនូរ រឿងឈើចម្លាក់ជារូបធីតា រឿងភិក្ខុ ៥ រូបទាំងសុន្ទរភិក្ខុផង រឿងភិក្ខុ ៥ រូប នៅក្នុងព្រៃខ្មោច រឿងនាគញី រឿងយក្ខិនី រឿងស្រីប្រេត រឿងភិក្ខុខ្ទើយ រឿងភិក្ខុកើតរោគស្ពឹក រឿងភិក្ខុចាប់មាតុគ្រាមប្រុងនឹងសេព រឿងភិក្ខុសិងលក់ក្នុងទី

ស្វាត់ក្បែរក្រុងភទ្ទិយ រឿងភិក្ខុទាំងឡាយ ៤ រូបឯទៀតក្នុងក្រុងសាវត្ថី រឿងអ្នកចំបាប់ ៣ នាក់ក្នុងក្រុងវេសាលី រឿងការុកច្ឆកភិក្ខុយល់សុបិនមិត្ត រឿងនាងសុបញ្ញា រឿងនាងសទ្ធា រឿងភិក្ខុនី រឿងសិក្ខមានា រឿងសាមណេរី រឿងស្រីផ្កាមាស រឿងមនុស្សខ្ទើយ រឿងគ្រហស្ថ រឿងភិក្ខុសេពគ្នានឹងគ្នា រឿងភិក្ខុបួសឯចាស់ រឿងសត្វម្រឹគ ។

[ ៤៩ ] សម័យនោះឯង ភិក្ខុ ១ រូបបានសេពមេថុនធម្មនឹងស្វាញី ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យថា សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ អញប្រហែលជាត្រូវអាបត្តិបារាជិកហើយដឹង ។ ទើបភិក្ខុនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ៥០ ] សម័យនោះឯង ពួកវជ្ជីបុត្តកភិក្ខុច្រើនរូបនៅក្នុងក្រុងវេសាលី មិនបានលាសិក្ខា មិនបានធ្វើឲ្យជាក់ច្បាស់ថា ខ្លួនមានកម្លាំងថយ ហើយសេពមេថុនធម្ម ។ ភិក្ខុទាំងអម្បាលនោះ មានសេចក្តីសង្ស័យថា សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ យើងរាល់គ្នាប្រហែលជាត្រូវអាបត្តិបារាជិកហើយដឹង ។ ភិក្ខុទាំងនោះ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកឯងទាំងអស់គ្នាត្រូវអាបត្តិបារាជិកហើយ ។

[ ៥១ ] សម័យនោះឯង ភិក្ខុ ១ រូបក្លែងខ្លួនជាគ្រហស្ថ ហើយសេពមេថុនធម្មដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ ។

ភិក្ខុនោះក៏មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯង ត្រូវអាបត្តិបារាជិកហើយ ។

[ ៥២ ] សម័យនោះឯង ភិក្ខុ ១ រូប ធ្វើជាអ្នកអាក្រាត ហើយសេពមេថុនធម្ម ដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ៥៣ ] សម័យនោះឯង ភិក្ខុ ១ រូប ស្លៀកស្បូវក្រង ។បេ។ ស្លៀកសំពត់សម្បកឈើ ស្លៀកសំពត់ដែលត្បាញជារូបផ្លៃឈើ[១] ស្លៀកសំពត់ដែលត្បាញដោយសក់ ស្លៀកសំពត់ដែលត្បាញដោយរោមកន្ទុយសត្វ ស្លៀកសំពត់ដែលត្បាញដោយស្លាបមៀម ស្លៀកស្បែកខ្លាដែលនៅមានទាំងរោមទាំងក្រចក ហើយសេពមេថុនធម្ម ដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ៥៤ ] សម័យនោះឯង ភិក្ខុ ១ រូប ជាអ្នកប្រព្រឹត្តបិណ្ឌបាត បានឃើញនាងទារិកាម្នាក់ដេកនៅលើតាំង ក៏មានចិត្តត្រេកអរហើយយកមេជើង ( ខ្ទង់ ) ទៅរុកបញ្ចូលចំអង្គជាតនាងទារិកានោះ ។ នាងក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស ។

---

១- បិដកថៃថា សំពត់ក្រងដោយផ្លៃឈើ ។

[ ៥៥ ] សម័យនោះឯង មាណពម្នាក់មានសេចក្តីប្រតិព័ទ្ធចាប់ចិត្តនឹងឧប្បលវណ្ណាភិក្ខុនី ។ កាលដែលឧប្បលវណ្ណាភិក្ខុនីចូលទៅបិណ្ឌបាតក្នុងស្រុក មាណពនោះក៏ចូលទៅពួននៅក្នុងកុដិតូចចាំ ។ លុះដល់ឧប្បលវណ្ណាភិក្ខុនីត្រឡប់មកពីបិណ្ឌបាតវិញ ឆាន់រួចហើយ ក៏លាងជើង ហើយចូលទៅក្នុងកុដិអង្គុយនៅលើគ្រែ ។ ខណៈនោះ មាណពនោះ ក៏ស្ទុះមកសង្គ្រុបឧប្បលវណ្ណាភិក្ខុនី ហើយប្រទូស្ត ។ ឧប្បលវណ្ណាភិក្ខុនីក៏ប្រាប់សេចក្តីនុ៎ះដល់ពួកភិក្ខុនីផងគ្នា ។ ភិក្ខុនីទាំងឡាយក៏ប្រាប់សេចក្តីនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយ ក៏នាំសេចក្តីនុ៎ះទៅក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧប្បលវណ្ណាមិនត្រូវអាបត្តិទេ ព្រោះមិនមានសេចក្តីត្រេកត្រអាលឡើយ ។

[ ៥៦ ] សម័យនោះឯង ភិក្ខុ ១ រូប ក្លាយភេទខ្លួនប្រែទៅជាស្រី ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឧបជ្ឈាយ៍នោះដដែល និងឧបសម្បទានោះដដែល និងវស្សាទាំងនោះ[១] និងអនុញ្ញាតឲ្យនៅរួមជាមួយនឹងភិក្ខុនីទាំងឡាយ ( ម្យ៉ាងទៀត ) អាបត្តិណា ដែលជារបស់ភិក្ខុដែលទូទៅដល់ភិក្ខុនីទាំងឡាយ តថាគតអនុញ្ញាតនូវអាបត្តិទាំងនោះ ដើម្បីឲ្យភិក្ខុដែលក្លាយភេទជាស្រីនោះ នៅក្នុងសំណាក់ភិក្ខុនីទាំងឡាយបាន អាបត្តិណាជារបស់ភិក្ខុ

---

១- គឺទ្រង់អនុញ្ញាតមិនបាច់ឲ្យសូមឧបជ្ឈាយ៍ និងឧបសម្បទាជាថ្មីទៀត វស្សាក៏មិនបាច់ឲ្យរាប់ជាថ្មី ត្រូវរាប់តាំងពីឧបសម្បទាជាភិក្ខុនោះមកដដែល ។

ដែលមិនទូទៅដល់ភិក្ខុនីទាំងឡាយ ភិក្ខុនីនោះ មិនត្រូវអាបត្តិព្រោះអាបត្តិនោះ ឡើយ ។ សម័យនោះឯង ភិក្ខុនី ១ រូប ក្លាយភេទខ្លួនទៅជាប្រុស ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឧបជ្ឈាយ៍នោះដដែល និងឧបសម្បទានោះដដែល និងវស្សាទាំងនោះ និងអនុញ្ញាតឲ្យនៅរួមជាមួយនឹងភិក្ខុទាំងឡាយ អាបត្តិណាជារបស់ភិក្ខុនីដែលទូទៅដល់ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវអាបត្តិទាំងនោះ ដើម្បីឲ្យភិក្ខុនីដែលក្លាយភេទខ្លួនជាប្រុសនោះនៅក្នុងសំណាក់ភិក្ខុទាំងឡាយបាន អាបត្តិណាជារបស់ភិក្ខុនីដែលមិនទូទៅដល់ភិក្ខុទាំងឡាយទេ ( ភិក្ខុនីនេះ ) មិនមានអាបត្តិព្រោះអាបត្តិទាំងនោះឡើយ ។

[ ៥៧ ] សម័យនោះឯង ភិក្ខុ ១ រូបសេពមេថុនធម្មនឹងមាតា ( របស់ខ្លួន ) ដោយយល់ថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ ។បេ។ សេពមេថុនធម្មនឹងធីតា ( របស់ខ្លួន ) ។បេ។ សេពមេថុនធម្មនឹងប្អូនស្រី ( របស់ខ្លួន ) ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ទើបក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូប សេពមេថុនធម្មនឹងស្រីដែលមាតាបិតាផ្សំផ្គុំឲ្យអំពីមុន ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ៥៨ ] សម័យនោះឯង ភិក្ខុ ១ រូប មានខ្នងទន់ ។ ភិក្ខុនោះមានសេចក្តីអផ្សុកបៀតបៀន ហើយបានយកអង្គជាតខ្លួនមកបៀមនឹងមាត់ ។ ភិក្ខុនោះ

មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូប មានអង្គជាតយាវវែង ។ ភិក្ខុនោះមានសេចក្តីអផ្សុកបៀតបៀន ក៏ចាប់បំពត់អង្គជាតខ្លួនបញ្ចូលទៅក្នុងវច្ចមគ្គ ( គឺទ្វារធំ ) របស់ខ្លួន ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ៥៩ ] សម័យនោះឯង ភិក្ខុ ១ រូប ឃើញសរីរៈមនុស្សស្លាប់ ។ ឯសរីរៈនោះ មានដំបៅជុំវិញអង្គជាត ។ ភិក្ខុនោះបានបញ្ចូលអង្គជាត ( ខ្លួន ) ទៅក្នុងអង្គជាត ( សរីរៈនោះ ) ហើយបន្ទយអង្គជាតចេញមកវិញតាមដំបៅ ដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះក៏មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូបឃើញសរីរៈមនុស្សស្លាប់ ។ ឯសរីរៈនោះមានដំបៅជុំវិញអង្គជាត ។ ភិក្ខុនោះបានបញ្ចូលអង្គជាត ( ខ្លួន ) ទៅក្នុងដំបៅ ហើយបន្ទយចេញមកវិញតាមអង្គជាត ដោយគិតថា កាលបើអញធ្វើយ៉ាងនេះ អញនឹងមិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ៦០ ] សម័យនោះឯង ភិក្ខុ ១ រូបមានតម្រេក ហើយយកអង្គជាត ( ខ្លួន )ទៅញាល់នឹងនិមិត្តរបស់រូបគំនូរ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង ភិក្ខុ ១ រូបមានតម្រេក ហើយយកអង្គជាត

( ខ្ទួន ) ទៅញាល់នឹងនិមិត្តរបស់រូបតុក្កតាស្រីដែលធ្វើដោយឈើ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៦១ ] សម័យនោះឯង ភិក្ខុ ១ រូបឈ្មោះសុន្ទរៈ ចេញពីក្រុងរាជគ្រឹះទៅបួស ហើយដើរទៅតាមថ្នល់ ។ មានស្រីម្នាក់បានឃើញភិក្ខុនោះហើយក៏និយាយថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្អង់មួយរំពេចសិន ខ្ញុំព្រះករុណានឹងថ្វាយបង្គំ ។ ស្រីនោះ កាលដែលថ្វាយបង្គំ ក៏សើយស្បង់ឡើងហើយយកមាត់ទៅបៀមអង្គជាត ( របស់ភិក្ខុនោះ ) ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងត្រេកអរដែរឬទេ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិទេ ព្រោះមិនត្រេកអរ ។

[ ៦២ ] សម័យនោះឯង មានស្រីម្នាក់ បានឃើញភិក្ខុ ១ រូបហើយនិយាយថា បពិត្រលោកម្ចាស់ សូមនិមន្តលោកម្ចាស់មកសេពមេថុនឯនេះ ។ ភិក្ខុនោះនិយាយថា កុំនាង ការសេពមេថុនធម្មនេះមិនគួរទេ ។ ស្រីនោះអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តមក ( កុំប្រកែក ) ខ្ញុំព្រះករុណានឹងព្យាយាម លោកម្ចាស់មិនបាច់ព្យាយាមទេ ( នៅតែស្ងៀមបានហើយ ) សេពយ៉ាងនេះ លោកម្ចាស់មិនត្រូវអាបត្តិទេ ។ ភិក្ខុនោះ ក៏បានធ្វើតាមពាក្យស្រីនោះ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាល

ភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានស្រីម្នាក់មាននាមមិនប្រាកដ ឃើញភិក្ខុ ១ រូបហើយនិយាយថា បពិត្រលោកម្ចាស់ សូមនិមន្តលោកមកសេពមេថុនធម្ម ( នឹងខ្ញុំសិន ) ។ ភិក្ខុនោះឆ្លើយថា កុំនាងអំពើនេះមិនគួរទេ ។ ស្រីនោះក៏និយាយអង្វរថា បពិត្រលោកម្ចាស់ សូមនិមន្តមក សូមលោកម្ចាស់ព្យាយាមចុះ ខ្ញុំព្រះករុណាមិនព្យាយាមទេ ធ្វើយ៉ាងនេះលោកម្ចាស់មិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យស្រីនោះទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានស្រីម្នាក់ បានឃើញភិក្ខុ ១ រូប ក៏និយាយបបួលថា បពិត្រលោកម្ចាស់ សូមនិមន្តមកសេពមេថុនធម្ម ( នឹងខ្ញុំព្រះករុណាឯនេះ ) ។ ភិក្ខុនោះឆ្លើយថា កុំប្អូនស្រី អំពើនេះមិនគួរទេ ។ ស្រីនោះក៏ពន្យល់ថា បពិត្រលោកម្ចាស់ សូមលោកនិមន្តមកព្យាយាមក្នុងអង្គជាតខ្ញុំ រួចបញ្ចេញអសុចិទៅខាងក្រៅអង្គជាតវិញ ។បេ។ ព្យាយាមខាងក្រៅអង្គជាត ហើយបញ្ចេញអសុចិទៅខាងក្នុងអង្គជាតវិញ ធ្វើយ៉ាងនេះលោកម្ចាស់មិនត្រូវអាបត្តិឡើយ ។ ភិក្ខុនោះក៏ធ្វើតាមពាក្យស្រីនោះទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ៦៣ ] សម័យនោះឯង មានភិក្ខុ ១ រូប ចូលទៅកាន់ព្រៃខ្មោច ឃើញសរីរៈខ្មោចដែលសត្វមិនទាន់ស៊ី ហើយសេពមេថុនធម្មនឹងសរីរៈខ្មោចនោះ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯង

ត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូបចូលទៅកាន់ព្រៃខ្មោច ឃើញសរីរៈខ្មោចដែលសត្វមិនទាន់ស៊ីច្រើនអន្ទើប៉ុន្មាន ហើយសេពមេថុនធម្មនឹងសរីរៈខ្មោចនោះ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូបចូលទៅកាន់ព្រៃខ្មោច ឃើញសរីរៈខ្មោចដែលសត្វស៊ីច្រើនអន្ទើ ហើយសេពមេថុនធម្មនឹងសរីរៈខ្មោចនោះ ។ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ព្រៃខ្មោច ឃើញក្បាលខ្មោចដាច់ ក៏បញ្ចូកអង្គជាត ( ខ្លួន ) ឲ្យចូលទៅក្នុងមាត់ដែលបើកហាឲ្យប៉ះទង្គិច ( ក្នុងមាត់នោះ ) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូបចូលទៅកាន់ព្រៃខ្មោច ឃើញក្បាលខ្មោចដាច់ ហើយបញ្ចូកអង្គជាត ( ខ្លួន ) ទៅក្នុងមាត់ខ្មោចដែលបើកហា មិនឲ្យប៉ះទង្គិច ( ក្នុងមាត់នោះ ) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ ១ រូបមានចិត្តប្រតិព័ទ្ធស្រឡាញ់ស្រីម្នាក់ ។ ស្រីនោះធ្វើកាលកិរិយាទៅហើយ គេនាំខ្មោចយកទៅចោលក្នុងព្រៃស្មសាន[១] ។

---

( ១ ) **ស្មសាន** គឺព្រៃសម្រាប់ចោលខ្មោច ជាពាក្យសំស្រ្កឹត ឲ្យអានថា **ស្មៈសានៈ** ដែលអានក្លាយមកថា **សំសាន** ។ ពាក្យបាលីថា **សុសាន** ។

ឆ្អឹងទាំងឡាយ ( នៃខ្មោចស្រីនោះ ) ក៏ខ្ចាត់ខ្ចាយរាត់រាយ ។ គ្រានោះ ភិក្ខុនោះទៅកាន់ព្រៃខ្មោច ហើយប្រមូលឆ្អឹងទាំងឡាយមកតម្រៀប ហើយបញ្ចូលអង្គជាត ( ខ្លួន ) ទៅក្នុងនិមិត្ត ( នៃរាងឆ្អឹងនោះ ) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៦៤ ] សម័យនោះឯង មានភិក្ខុ ១ រូប ទៅសេពមេថុនធម្មនឹងនាគី ( នាគញី ) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះ មានភិក្ខុ ១ រូប សេពមេថុនធម្មនឹងយក្ខិនី ។បេ។ សេពមេថុនធម្មនឹងស្រីប្រេត ។បេ។ សេពមេថុនធម្មនឹងមនុស្សខ្ទើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ៦៥ ] សម័យនោះ មានភិក្ខុ ១ រូប មានឥន្ទ្រិយសាបសូន្យ ( គឺមានរោគស្ពឹក ) ។ ភិក្ខុនោះក៏សេពមេថុនធម្មដោយគិតថា អញមិនដឹងសេចក្តីសុខទុក្ខ អាបត្តិនឹងមិនមានដល់អញឡើយ ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុរសសោះសូន្យនោះ ទោះបីដឹង ( សេចក្តីសុខទុក្ខ ) ក្តី មិនដឹងក្តី ក៏ត្រូវអាបត្តិបារាជិកហើយ ។

[ ៦៦ ] សម័យនោះឯង មានភិក្ខុ ១ រូប គិតថាអញនឹងសេពមេថុនធម្មនឹងស្រី គ្រាន់តែយកដៃទៅចាប់ពាល់ក៏មានសេចក្តីក្តៅក្រហាយ ។ ភិក្ខុនោះ

មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៦៧ ] សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃជាតិយាវន ជិតនគរភទ្ទិយ ហើយសិងលក់ទៅ ។ ឯអវយវៈតូចធំរបស់ភិក្ខុនោះ មានខ្យល់បក់មកឧបត្ថម្ភ ( នាំឲ្យលោកនោះសិងលក់ស៊ប់ ) ។ មានស្រីម្នាក់ឃើញហើយក៏អង្គុយសង្កត់ពីលើអង្គជាត ធ្វើ ( សេវនកិច្ច ) ស្រេចហើយក៏ចៀសចេញទៅ ។ ភិក្ខុនោះ ( ភ្ញាក់ឡើង ) ឃើញសេចក្តីសៅហ្មង ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្មដោយអាការ ៥ យ៉ាង គឺដោយតម្រេក ១ ដោយអាចម៍ ១ ដោយទឹកមូត្រ ១ ដោយខ្យល់ ១ ដោយដង្កូវមាស់រោល ១ ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្មដោយអាការ ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរដល់កម្ម ព្រោះតម្រេករបស់ភិក្ខុនោះ មិនមែនជាហេតុ មិនមែនជាទីឱកាសឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអរហន្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ឥតមានត្រូវអាបត្តិអ្វីឡើយ ។

[ ៦៨ ] សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃអន្ធវន ទៀបនគរសាវត្ថីហើយសិងលក់ទៅ ។ មានស្រីគង្វាលគោម្នាក់ឃើញហើយទៅអង្គុយសង្កត់ពីលើអង្គជាតភិក្ខុនោះ ។ ភិក្ខុនោះកាលអង្គជាតកំពុងតែចូលទៅក៏ត្រេកអរ ចូលស៊ប់ទៅហើយក៏ត្រេកអរ ឋិតនៅខាងក្នុងក៏ត្រេកអរ បន្ថយចេញមកវិញក៏ត្រេកអរ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ

។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃអន្ធវន ទៀបនគរសាវត្ថី ហើយសិងលក់ទៅ ។ មានស្រីគង្វាលពពែម្នាក់បានឃើញភិក្ខុនោះ ។បេ។ មានស្រីអ្នករកឧសម្នាក់បានឃើញភិក្ខុនោះ ។បេ។ មានស្រីអ្នកនាំអាចម៍គោម្នាក់បានឃើញភិក្ខុនោះ ក៏ទៅអង្គុយសង្កត់ពីលើអង្គជាត ។ ភិក្ខុនោះ កាលដែលអង្គជាតកំពុងចូលទៅ ត្រេកអរ ចូលស៊ប់ទៅហើយត្រេកអរ ស្ថិតនៅខាងក្នុងត្រេកអរ បន្ថយចេញមកវិញត្រេកអរ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ៦៩ ] សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃមហាវន ទៀបនគរវេសាលី ហើយសិងលក់ទៅ ។ មានស្រីម្នាក់បានឃើញ ក៏ទៅអង្គុយសង្កត់ពីលើអង្គជាត លុះធ្វើកិច្ចសម្រេចហើយ ក៏មកឈរសើចជិតភិក្ខុនោះ ។ ភិក្ខុនោះ ភ្ញាក់ឡើងហើយនិយាយទៅនឹងស្រីនោះថា អំពើនេះជាអំពើរបស់នាងឬ ។ ស្រីនោះឆ្លើយថា ករុណាលោកម្ចាស់ អំពើនេះជាអំពើរបស់ខ្ញុំករុណា ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងដឹងដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ មិនដឹងទេ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងកាលបើមិនដឹង មិនមានអាបត្តិទេ ។ សម័យនោះ មានភិក្ខុ ១ រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃមហាវន ជិតនគរវេសាលី ហើយ

សិងលក់ផ្អែកនឹងដើមឈើ ១ ។ មានស្រីម្នាក់បានឃើញក៏ទៅអង្គុយសង្កត់ពីលើអង្គជាត ។ ភិក្ខុនោះ ក៏ក្រោកឡើងដោយរហ័ស ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងត្រេកអរដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងកាលបើមិនត្រេកអរ មិនត្រូវអាបត្តិទេ ។ សម័យនោះ មានភិក្ខុ ១ រូបទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងព្រៃមហាវន ជិតនគរវេសាលី ហើយសិងលក់ផ្អែកនឹងដើមឈើ ១ ។ មានស្រីម្នាក់ឃើញហើយក៏ទៅអង្គុយសង្កត់ពីលើអង្គជាត ។ ភិក្ខុនោះ ក៏ជាក់ច្រាន ( ឲ្យស្រីនោះ ) ខ្ទាតចេញទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកត្រេកអរឬទេ ។ ភិក្ខុនោះក្រាបទូលវិញថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកកាលបើមិនត្រេកអរ មិនមានអាបត្តិទេ ។

[ ៧០ ] សម័យនោះ មានភិក្ខុ ១ រូប ទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ក្នុងកូដាគារសាលា ឰដ៏ព្រៃមហាវន ជិតនគរវេសាលី បើកទ្វារហើយចូលទៅសិង ។ អវយវៈតូចធំរបស់ភិក្ខុនោះ មានខ្យល់បក់មកឧបត្ថម្ភ ( នាំឲ្យសិងលក់ស៊ប់ ) ។ សម័យនោះ មានស្រីទាំងឡាយច្រើនគ្នាមានប្រាថ្នានឹងទៅវត្តទើបកាន់នូវគ្រឿងក្រអូបខ្លះ ផ្កាកម្រងខ្លះ ដើរទៅកាន់អារាម ។ គ្រានោះ ស្រីទាំងអស់នោះបានឃើញភិក្ខុនោះហើយក៏អង្គុយសង្កត់ពីលើអង្គជាតធ្វើ ( សេវនកិច្ច ) ដរាបដល់ហើយស្រេច ទើបនិយាយថា ឱហ្ន៎ ភិក្ខុនេះ ជាបុរស

ឧសភៈ ដូច្នេះហើយ លើកឡើងនូវគ្រឿងក្រអូបនិងផ្កាកម្រងហើយក៏ដើរចៀសទៅ ។ ភិក្ខុនោះ ឃើញសេចក្តីសៅហ្មងក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់មានពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរជល់កម្មដោយអាការ ៥ យ៉ាង គឺដោយតម្រេក ១ ដោយអាចម៍ ១ ដោយទឹកមូត្រ ១ ដោយខ្យល់ ១ ដោយជន្លួវមាសរោល ១ ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរជល់កម្ម ដោយអាការ ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ អង្គជាតគួរជល់កម្ម ព្រោះតម្រេករបស់ភិក្ខុនោះ មិនមែនជាហេតុជាទីតាំង មិនមែនជាឱកាសឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអរហន្ត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនមានអាបត្តិឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុ កាលដែលសិងសម្ងំក្នុងវេលាថ្ងៃត្រូវបិទទ្វារ ហើយសឹមសិងសម្ងំចុះ ។

[ ៧១ ] សម័យនោះ មានភិក្ខុ ១ រូបជាកូនអ្នកស្រុកភារុកច្ឆកៈយល់សប្តិឃើញថា សេពមេថុនធម្មនឹងនាងបុរាណទុតិយិកា ហើយគិតថា ខ្ញុំនអញមិនមែនជាសមណៈទេ អញនឹងសឹកទៅវិញ ដូច្នេះហើយ ដើរទៅកាន់ជនបទឈ្មោះភារុកច្ឆៈ ក៏បានឃើញព្រះឧបាលីដ៏មានអាយុ ក្នុងទីពាក់កណ្តាលផ្លូវហើយនិយាយប្រាប់រឿងនុ៎ះ ។ ព្រះឧបាលិត្ថេរដ៏មានអាយុបានប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ឥតមានអាបត្តិអ្វីដោយចំណែកនៃការយល់សប្តិនោះទេ ។

[ ៧២ ] សម័យនោះ ក្នុងក្រុងរាជគ្រឹះ មានឧបាសិកាម្នាក់ឈ្មោះសុបញ្ញា ជាស្រីមានសេចក្តីជ្រះថ្លាខ្សាយ ។ នាងមានសេចក្តីយល់ឃើញយ៉ាងនេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ ។ លុះ

ដល់នាងបានឃើញភិក្ខុ ១ រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ ។ ភិក្ខុនោះប្រកែកថា កុំប្អូនស្រី ការសេពមេថុន-ធម្មនោះមិនគួរទេ ។ នាងសុបញ្ញាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះភ្លៅចុះ កាលបើលោកព្យាយាមដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះ ។ ទើបភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស ។ សម័យនោះ ក្នុងក្រុងរាជគ្រឹះ មានឧបាសិកាម្នាក់ឈ្មោះសុបញ្ញា ជាស្រីមានសេចក្តីជ្រះថ្លាខ្សោយ ។ នាងមានសេចក្តីយល់ឃើញយ៉ាងនេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះឈ្មោះថាឲ្យនូវទានដ៏ប្រសើរ ។ លុះដល់នាងបានឃើញភិក្ខុ ១ រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ ។ ភិក្ខុនោះប្រកែកថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ ។ នាងសុបញ្ញាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្ចិតចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្ទត់ពោះចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ក្លៀកចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់កចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់រន្ធត្រចៀកចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្នួងសក់ចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះម្រាមដៃចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកចុះ ខ្ញុំព្រះករុណានឹងព្យាយាមឲ្យចេញទឹកសុក្កៈដោយដៃខ្ញុំ កាលបើដូច្នេះ លោកនឹង

មិនមានអាបត្តិឡើយ ។ ភិក្ខុនោះ ក៏បានធ្វើតាមពាក្យនោះ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស ។

[ ៧៣ ] សម័យនោះ ក្នុងក្រុងសាវត្ថី មានឧបាសិកាម្នាក់ឈ្មោះសទ្ធា ជាអ្នកមានសេចក្ដីជ្រះថ្លាខ្លាយ ។ នាងមានសេចក្ដីយល់ឃើញដូច្នេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះ ឈ្មោះថា ឲ្យនូវទានដ៏ប្រសើរ ។ លុះដល់នាងបានឃើញភិក្ខុ ១ រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ ។ ភិក្ខុនោះប្រកែកថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ ។ នាងសទ្ធាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ចន្លោះភ្លៅចុះ កាលបើដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ ។ ភិក្ខុនោះក៏បានធ្វើតាមពាក្យនោះទៅ ។ ទើបភិក្ខុនោះកើតមានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស ។

[ ៧៤ ] សម័យនោះ ក្នុងក្រុងសាវត្ថី មានឧបាសិកាម្នាក់ឈ្មោះសទ្ធា ជាស្រីមានសេចក្ដីជ្រះថ្លាខ្លាយ ។ នាងមានសេចក្ដីយល់ឃើញដូច្នេះថា ស្រីណាឲ្យនូវមេថុនធម្ម ស្រីនោះ ឈ្មោះថា ឲ្យនូវទានដ៏ប្រសើរ ។ លុះនាងបានឃើញភិក្ខុ ១ រូប ក៏និយាយនិមន្តថា លោកម្ចាស់ សូមលោកនិមន្តមកសេពមេថុនធម្មចុះ ។ ភិក្ខុនោះ ប្រកែកថា កុំប្អូនស្រី ការសេពមេថុនធម្មនោះមិនគួរទេ ។ នាងសទ្ធាពោលថា លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្ចិតចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាម ត្រង់ផ្នត់ពោះ

ចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ក្លៀកចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាម ត្រង់កចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ន្ទ្រត្រចៀកចុះ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាមត្រង់ផ្នួងសក់ចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកព្យាយាម ត្រង់ចន្លោះម្រាមដៃចុះ ។បេ។ លោកម្ចាស់ សូមលោកនិមន្តមកចុះ ខ្ញុំព្រះករុណានឹងព្យាយាមឲ្យចេញទឹកសុក្កៈដោយដៃខ្ញុំ កាលបើដូច្នេះ លោកនឹងមិនមានអាបត្តិឡើយ ។ ភិក្ខុនោះ ក៏បានធ្វើតាមពាក្យនោះទៅ ។ ទើបភិក្ខុនោះកើតមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិសង្ឃាទិសេស ។

[ ៧៥ ] សម័យនោះ ពួកលិច្ឆវិកុមារក្នុងក្រុងវេសាលីនាំភិក្ខុ ១ រូបទៅហើយ ឲ្យធ្វើមេាះមិនគាប់ជាមួយនឹងភិក្ខុនី ។ បើអ្នកទាំងពីរមានសេចក្តីត្រេកអរដូចគ្នា សង្ឃគប្បីឲ្យអ្នកទាំងពីរសឹកចេញ ។ បើអ្នកទាំងពីរឥតមានសេចក្តីត្រេកអរទេ អ្នកទាំងពីរមិនមានអាបត្តិឡើយ ។ សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវិកុមារនាំភិក្ខុ ១ រូបទៅហើយឲ្យធ្វើមេាះមិនគាប់ជាមួយនឹងសិក្ខមានា ។បេ។ ឲ្យធ្វើមេាះមិនគាប់ជាមួយនឹងសាមណេរី ។ បើអ្នកទាំងពីរត្រេកអរដូចគ្នាហើយ សង្ឃត្រូវឲ្យអ្នកទាំងពីរសឹកចេញ ។ បើអ្នកទាំងពីរឥតមានសេចក្តីត្រេកអរទេ អ្នកទាំងពីរឥតមានអាបត្តិឡើយ ។

[ ៧៦ ] សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវិកុមារនាំភិក្ខុ ១ រូបទៅហើយឲ្យធ្វើមេាះមិនគាប់ជាមួយនឹងស្រីវេស្យា ។បេ។ ឲ្យធ្វើមេាះមិនគាប់

ជាមួយនឹងមនុស្សទេ្វីយ ។បេ។ ឲ្យធ្វើមោះមិនគាប់ជាមួយនឹងស្រីគ្រហស្ថ ។ បើភិក្ខុមានសេចក្តីត្រេកអរ សង្ឃត្រូវឲ្យភិក្ខុ ( នោះ ) សឹកចេញ ។ បើភិក្ខុឥតមានសេចក្តីត្រេកអរទេ ភិក្ខុ ( នោះ ) ក៏ឥតមានអាបត្តិអ្វីឡើយ ។ សម័យនោះ ក្នុងក្រុងវេសាលី ពួកលិច្ឆវិកុមារនាំភិក្ខុ ១ រូបទៅ ហើយឲ្យធ្វើមោះមិនគាប់ចំពោះគ្នានឹងគ្នា ។ បើអ្នកទាំងពីរមានសេចក្តីត្រេកអរដូចគ្នា សង្ឃត្រូវឲ្យអ្នកទាំងពីរសឹកចេញ ។ បើអ្នកទាំងពីរឥតមានសេចក្តីត្រេកអរទេ អ្នកទាំងពីរឥតមានអាបត្តិឡើយ ។

[ ៧៧ ] សម័យនោះឯង មានភិក្ខុ ១ រូប បួសខាងចាស់ និមន្តទៅសួរកិរិយាដែលជាគូស្រករ ( របស់ខ្លួន ) ពីដើម ។ ឯកិរិយាក៏និយាយថា បពិត្រលោកដ៏ចម្រើន លោកចូរនិមន្តសឹកចេញទៅ ថាហើយក៏ស្ទុះទៅចាប់ ។ ភិក្ខុនោះថយដោះខ្លួន ក៏ដួលផ្ងារទៅក្រោយ ។ កិរិយាចាស់ក៏ឡើងជិះអង្គុយសង្កត់ពីលើអង្គជាត ។ ទើបភិក្ខុនោះមានសេចក្តីសង្ស័យ ។ ហើយបានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងបានត្រេកអរដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានត្រេកអរទេ ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនបានត្រេកអរ មិនត្រូវអាបត្តិទេ ។

[ ៧៨ ] សម័យនោះឯង មានភិក្ខុមួយរូបនៅក្នុងព្រៃ ។ មានកូនម្រឹគ ១ ដើរមកកាន់ទីដែលភិក្ខុនោះកំពុងបន្ទោបង់បស្សាវៈ ហើយផឹកនូវបស្សាវៈរួចបៀមនូវអង្គជាតភិក្ខុដោយមាត់វា ។ ភិក្ខុនោះ ក៏មានសេចក្តីត្រេកអរ ។ ភិក្ខុ

នោះមានសេចក្តីសង្ស័យ ។ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

បឋមបារាជិក ចប់

# អដ្ឋកថា

# មេថុនធម្មសិក្ខាបទវណ្ណនា
# រឿង សុទិន្នភិក្ខុ

[ ១០ ] *បន្ទាប់អំពីវេរញ្ជកណ្ឌនេះទៅ ពាក្យថា* **តេន ខោ បន សមយេន វេសាលិយា អវិទូរេ** *ជាដើម មានអត្ថក្លីច្បាស់ដោយច្រើន ព្រោះដូច្នោះ ខ្ញុំនឹងវៀរការពណ៌នាតាមលំដាប់បទចោល និងពណ៌នាចំពោះតែបទ ដែលមានពាក្យសមគួរនឹងពោលប៉ុណ្ណោះ ។*

*ស្រុកដែលបានឈ្មោះថា* **កលន្ទគាម** *ក៏ដោយអំណាចនៃសត្វកន្ធែនទាំងឡាយ ដែលហៅថា* **កលន្ទក។**

*បទថា* **កលន្ទបុត្តោ** *សេចក្តីថា ( សុទិន្ន ) ជាកូនរបស់កលន្ទសេដ្ឋី ដែលមានទ្រព្យ ៤០ កោដិ ដែលបានឈ្មោះដោយអំណាចនៃស្រុក ដែលព្រះរាជាសន្មតឲ្យ ។ ក៏ព្រោះមនុស្សដទៃដែលមានឈ្មោះថា កលន្ទៈ មានក្នុងតំបន់នោះ ដូច្នោះ ទើបលោកពោលថា* **កលន្ទបុត្ត** *ហើយពោលដដែលទុកទៀតថា* **សេដ្ឋីបុត្ត។**

*បទថា* **សម្ពហុលេហិ** *ប្រែថា ច្រើនសន្ធឹកសន្ធាប់ ។*

*បទថា* **សហាយកេហិ** *សេចក្តីថា បុគ្គល ឈ្មោះថា សម្លាញ់ ព្រោះអត្ថថា ទៅរួមគ្នា គឺចូលដល់សុខ និងទុក្ខផងគ្នា ។ សម្លាញ់នោះឯង ឈ្មោះថា* **សហាយកា។** *( សុទិន្នកលន្ទបុត្របានទៅក្រុងវេសាលី ) មួយអន្លើ*

ដោយសម្មាញ់ទាំងនោះ ។

បទថា **សទ្ធឹ** ប្រែថា ជាពួកតែមួយ ។

ពីរបទថា **កេនចិទេវ ករណីយេន** សេចក្ដីថា ដោយកិច្ចឯណាមួយ មានប្រកបការលក់ដូរទំនិញ ការឲ្យខ្ចី និងការទារបំណុលជាដើម ។ អាចារ្យពួកខ្លះពោលថា ដោយកិច្ច គឺការលេងកីឡា ដែលជានក្ខត្តឫក្សក្នុងខែកត្ដិកដូច្នេះក៏មាន ។ ពិតហើយ ព្រះដ៏មានព្រះភាគយាងទៅដល់នគរវេសាលីក្នុងជុណ្ហបក្ខ ( ខាងខ្នើត ) នៃខែកត្ដិក ។ មួយវិញទៀត ក្នុងនគរវេសាលីនេះមានការលេងកីឡា ដែលជានក្ខត្តឫក្សប្រចាំខែកត្ដិក យ៉ាងឱឡារិក សុទិន្នកលន្ទបុត្រនោះ គប្បីជ្រាបថា ទៅ ( កាន់នគរវេសាលី ) ដើម្បីលេងកីឡានក្ខត្តឫក្សនោះ ។

បទថា **អទ្ទសា ខោ** សេចក្ដីថា សុទិន្នកលន្ទបុត្រនោះបានឃើញអ្វី បានឃើញយ៉ាងនេះ គឺបានឮថា សុទិន្ននោះ បានឃើញមហាជនបរិភោគអាហារព្រឹកស្រេចហើយ ស្លៀកដណ្ដប់សំពត់ស មានដៃកាន់ផ្កា គ្រឿងក្រអូប និងគ្រឿងលាប ចេញអំពីនគរទៅ ដើម្បីគាល់ព្រះសម្ពុទ្ធ និងដើម្បីស្ដាប់ធម៌ ទើបសួរថា ពួកអ្នកទៅទីណាហ្នុ៎ះ ។

មហាជនឆ្លើយថា ទៅដើម្បីគាល់ព្រះពុទ្ធ និងដើម្បីស្ដាប់ធម៌ ។ សុទិន្នពោលថា បើដូច្នោះ ខ្ញុំក៏ទៅ ហើយទៅ បានឃើញព្រះដ៏មានព្រះភាគ ដែលបរិស័ទទាំង ៤ ចោមរោមហើយ ទ្រង់សម្ដែងធម៌ដោយព្រះសូរសៀង ដ៏ពីរោះដូចសំឡេងព្រហ្ម ព្រោះហេតុនោះ ទើបព្រះឧបលិត្ថេរពោលទុកថា

សុទិន្នកលន្ទបុត្រ បានក្រឡេកឃើញព្រះដ៏មានព្រះភាគ ដែលបរិស័ទជាច្រើន ចោមរោមហើយ ប្រថាប់គង់សម្ដែងព្រះធម៌ ។

បទថា **ទិស្វានស្ស** កាត់បទជា **ទិស្វាន អស្ស** ប្រែថា ព្រោះបាន ឃើញ ( ការរំពឹងនេះមាន ) ដល់សុទិន្ន ។

បទថា **ឯតទហោសិ** សេចក្ដីថា ការរំពឹងនេះ មានដល់សុទិន្នដែល ជាភព្វកុលបុត្រ( កុលបុត្រដែលគួរត្រាស់ដឹង ) ដែលបុព្វេកតបុញ្ញតាជាស់-តឿន ។ សួរថា ការរំពឹងនេះ មានហើយដូចម្ដេច ឆ្លើយថា មានដូច្នេះថា កាលណាហ្ន៎ អញគប្បីបានស្ដាប់ធម៌ ។

បណ្ដាបទទាំងនោះ បទថា **យន្នូន** នោះ ជាបទសម្ដែងដល់សេចក្ដី រំពឹង ។ បានឮថា សុទិន្ននោះ បានកើតសេចក្ដីរំពឹងឡើងយ៉ាងនេះថា បរិស័ទ នេះ មានចិត្តស្ងប់តែមួយ ស្ដាប់ធម៌ណា ឱហ្ន៎ សូម្បីអញ ក៏គប្បីស្ដាប់ធម៌ នោះ ។

បើមានអាចារ្យចោទសួរថា ក្នុងពាក្យថា គ្រានោះឯង សុទិន្នកលន្ទបុត្រ ចូលទៅដោយផ្លូវបរិស័ទនោះ នេះព្រោះហេតុអ្វី ទើបព្រះឧបាលិត្ថេរមិនពោល ទុកថា ចូលទៅគាល់ដោយផ្លូវ ដែលព្រះដ៏មានព្រះភាគប្រថាប់នៅ តែបែរជា ពោលថា ចូលទៅដោយផ្លូវត្រង់បរិស័ទនោះ ឆ្លើយថា ពិតហើយ មហា បរិស័ទ មានពួកជនជាអ្នកមានសក្តិធំៗ នៅអង្គុយចោមរោមព្រះដ៏មានព្រះ ភាគហើយ សុទិន្នកលន្ទបុត្រនេះមកក្រោយគេ មិនអាចចូលទៅអង្គុយគាល់ ព្រះដ៏មានព្រះភាគក្នុងបរិស័ទនោះបាន តែក៏អាចចូលទៅអង្គុយក្នុងទីមួយ

កន្ទែងជិតបរិស័ទបាន ព្រោះដូច្នោះ សុទិន្នកលន្ទបុត្រនោះ ក៏ចូលទៅរកបរិស័ទនោះឯង ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលថា គ្រានោះ សុទិន្នកលន្ទបុត្រ ក៏ចូលទៅកាន់ទីដែលបរិស័ទអង្គុយនោះ ។

ប្រើនបទថា **ឯកមន្តំ និសិន្នស្ស ខោ សុទិន្នស្ស កលន្ទបុត្តស្ស ឯតទហោសិ** សេចក្តីថា ការរំពឹងនេះ មិនមានដល់សុទិន្នកលន្ទបុត្រ ដែលគ្រាន់តែអង្គុយហើយប៉ុណ្ណោះឡើយ ដោយពិតនោះ ការរំពឹងនោះ មានដល់សុទិន្នកលន្ទបុត្រនោះ ដែលអង្គុយហើយ ក្នុងទីសមគួរ នាចំណែកម្ខាងនោះឯង ព្រោះបានស្តាប់ធម្មកថាដែលប្រកបដោយត្រៃសិក្ខាបានបន្តិចរបស់ព្រះដ៏មានព្រះភាគ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា ការរំពឹងនេះមានដល់សុទិន្នកលន្ទបុត្រដែលអង្គុយហើយ ក្នុងទីសមគួរ នាចំណែកម្ខាងដូច្នេះ ។ សួរថា ការរំពឹងនេះមានហើយដូចម្តេច ឆ្លើយថា មានដូច្នេះថា ដោយអាការណាហ្ន៎ ( អញគប្បីដឹងទូទៅនូវធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ) ដូច្នេះជាដើម ។

ក្នុងពាក្យថា **យថា** ជាដើមនោះ មានការពោលដោយសង្ខេបយ៉ាងនេះថា អញនេះឯងនឹងដឹងទូទៅដល់ធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយអាការណាមួយ ការរំពឹងយ៉ាងនេះ រមែងមានដល់អញ ដែលពិចារណាដោយអាការនោះៗ ។ ព្រហ្មចរិយៈ គឺត្រៃសិក្ខា ឈ្មោះថា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ គប្បីប្រព្រឹត្តឲ្យបរិបូណ៌ដោយចំណែកមួយ ព្រោះត្រូវធ្វើមិនឲ្យដាច់ជាកំណាត់ៗ សូម្បីអស់មួយថ្ងៃ ហើយគប្បីឲ្យសម្រេចដល់

**ចរិមកចិត្ត** ( គឺចិត្តដែលចេញចាកកព ) និងឈ្មោះថា បុគ្គលដែល ( នៅគ្រប់គ្រងផ្ទះ ) គប្បីប្រព្រឹត្តឲ្យបរិសុទ្ធដោយចំណែកមួយ ព្រោះត្រូវធ្វើមិនឲ្យសៅហ្មងដោយមន្ទិល គឺកិលេស សូម្បីអស់មួយថ្ងៃ ហើយគប្បីឲ្យសម្រេចដល់ **ចរិមកចិត្ត** បានឡើយ ។

បទថា **សង្ខលិខិតំ** សេចក្ដីថា គប្បីបដិបត្តិឲ្យដូចជាស័ង្ខ ដែលគេដុសខាត់ហើយ គឺឲ្យមានចំណែកប្រៀបដូចស័ង្ខ ដែលជម្រះស្អាតហើយ ។

ប្រើនបទថា **ឥទំ ន សុករំ អគារំ អជ្ឈាវសតា**[១] សេចក្ដីថា ដែលបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ នឹងប្រព្រឹត្តព្រហ្មចរិយៈនេះឲ្យបរិបូណ៌ដោយចំណែកមួយ ឲ្យបរិសុទ្ធដោយចំណែកមួយ ដូចស័ង្ខដែលខាត់ហើយ ជារបស់ធ្វើមិនបានងាយ ធ្វើម្ដេចហ្ន៎អញគប្បីកោរសក់ និងពុកមាត់ ពុកចង្កាគ្រង គឺស្លៀកដណ្ដប់សំពត់កាសាវៈ ជារបស់ជ្រលក់ហើយ ដោយរសនៃទឹកម្ចត់ ដែលជារបស់សមគួរដល់បព្វជិតអ្នកប្រព្រឹត្តព្រហ្មចរិយៈ ហើយចេញចាកផ្ទះ បួសជាបព្វជិត ។

ក៏ព្រោះកសិកម្ម និងពាណិជ្ជកម្មជាដើម ដែលជាប្រយោជន៍ដល់ផ្ទះ លោកហៅថា **អគារិយ** ក្នុងបទថា **អនគារិយំ** នេះ ។ ហើយកសិកម្មពាណិជ្ជកម្មជាដើមនោះ រមែងមិនមានក្នុងបព្វជ្ជា ព្រោះហេតុនោះ បព្វជ្ជាបណ្ឌិតគប្បីដឹងថា **អនគារិយា** គឺបព្វជ្ជាដែលមិនមានផ្ទះនោះ ។

បទថា **បព្វជេយ្យំ** ប្រែថា គប្បីចូលដល់ ។

---

១- បិដកថា នយិទំ សុករំ ... ។ យកតាមអដ្ឋកថា ។

ច្រើនបទថា **អចិរវុដ្ឋិតាយ បរិសាយ យេន ភគវា តេនុបសង្កមិ** សេចក្ដីថា សុទិន្ន កាលបរិស័ទមិនទាន់ក្រោកទៅ ក៏មិនទាន់ទូលសូមបព្វជ្ជា នឹងព្រះដ៏មានព្រះភាគ ។ ព្រោះហេតុអ្វី ព្រោះក្នុងបរិស័ទនោះ ញាតិសាលោហិត មិត្ត និងអមាត្យរបស់សុទិន្ននោះមានច្រើន ពួកញាតិជាដើមទាំងនោះនឹងគប្បីពោលថា លោកជាបុត្រទោលតែមួយរបស់មាតាបិតា លោកមិនអាចបួសបានទេ ដូច្នេះហើយក៏ចាប់ត្រង់ដៃអូសចេញទៅ ក្នុងពេលនោះ សុទិន្នគិតថា អន្តរាយនឹងមានដល់បព្វជ្ជា ទើបក្រោកដើរទៅបានបន្តិចជាមួយបរិស័ទនោះឯង ហើយវិលត្រឡប់មកវិញ ដោយអាងលេសនៃសរីរកិច្ចឯណានីមួយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយទូលសូមបព្វជ្ជា ។ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា គ្រានោះឯង សុទិន្នកលន្ទបុត្រ កាលបរិស័ទក្រោកទៅហើយមិនយូរប៉ុន្មាន ក៏ចូលគាល់ព្រះដ៏មានព្រះភាគដែលកំពុងគង់នោះឯង កាលចូលគាល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ អង្គុយនៅក្នុងទីដ៏សមគួរនាចំណែកម្ខាង ។ សុទិន្នកលន្ទបុត្រ កាលអង្គុយក្នុងទីដ៏សមគួរនាចំណែកម្ខាងហើយ បានក្រាបទូលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្ដែងហើយ ដោយដំណើរយ៉ាងណាៗ ខ្ញុំព្រះអង្គបានយល់តាមដំណើរទាំងនោះដែរហើយ ប៉ុន្តែបើខ្ញុំព្រះអង្គនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ ( យ៉ាងនេះ ) ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌តែម្យ៉ាង ឲ្យបរិសុទ្ធតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់កោរសក់ និងពុក

មាត់ពុកចង្កា រូបស្លៀកដណ្ដប់សំពត់ជ្រលក់ទឹកម្ចត់ ហើយចេញចាកផ្ទះ មកបួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការ ក្នុងផ្ទះ ( នោះណាស់ ) សូមព្រះដ៏មានជោគ ទ្រង់បំបួសខ្ញុំព្រះអង្គផង ។

តែព្រោះចាប់តាំងអំពីរាហុលកុមារបព្វជ្ជាមក ព្រះដ៏មានព្រះភាគ ទ្រង់ក៏មិនបំបួសកុលបុត្រដែលមាតាបិតាមិនអនុញ្ញាត ព្រោះដូច្នោះ ទើបត្រាស់សួរសុទិន្ននោះថា ម្នាលសុទិន្ន អ្នកឯងមាតាបិតាបានយល់ព្រមឲ្យចេញចាកផ្ទះមកបួស ប្រតិបត្តិក្នុងបព្វជ្ជា ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះហើយឬ ។

## មាតាបិតាមិនអនុញ្ញាតឲ្យសុទិន្នបួស

[ ១១ ] ខាងមុខអំពីព្រះពុទ្ធតម្រាស់នេះទៅ បណ្ឌិតគប្បីជ្រាបអត្ថទៅតាមគន្លងព្រះបាលីនោះឯងយ៉ាងនេះក្នុងបទថា **តំ ករណីយំ តីរេត្វា** នេះ ។ ( សុទិន្នកលន្ទបុត្រនោះ ) ឲ្យករណីយកិច្ចនោះសម្រេចដោយការលះបង់ធុរៈនោះឯង ។ ពិតហើយ ទឹកចិត្តរបស់សុទិន្នកលន្ទបុត្រ ដែលមានឆន្ទៈខ្លាំងក្លាក្នុងបព្វជ្ជា មិនបានបង្អោនទៅក្នុងធុរកិច្ចទាំងឡាយ មានការប្រកបការលក់ដូរការឲ្យខ្ចីបុល និងការទារបំណុលជាដើម ឬក្នុងការលេងនក្ខត្តឫក្សឡើយ ។

ក្នុងបទថា **អម្ម តាត** នេះ មានវិនិច្ឆ័យដូច្នេះថា សុទិន្នកលន្ទបុត្រហៅមាតាថា **អម្ម** ម៉ែ ( និង ) ហៅបិតាថា **តាត** ពុក ។

ពីរបទថា **ត្វំ ខោសិ** កាត់បទជា **ត្វំ ខោ អសិ** ប្រែថា បាឯងជា ( បុត្រតែមួយ ) គឺអ្នកឯងប៉ុណ្ណោះជា ...

បទថា **ឯកបុត្តកោ** សេចក្តីថា ជាកូនតែមួយពិតៗ គឺបងប្រុស ឬប្អូនប្រុសរបស់អ្នកមិនមាន ។

ម្យ៉ាងទៀត ក្នុងបទថា **ឯកបុត្តកោ** នេះ កាលមាតាបិតាគួរនឹងពោលថា **ឯកបុត្តោ** តែពោលថា **ឯកបុត្តកោ** ដោយអំណាចសេចក្តីអាណិតអាសូរ ។

បទថា **បិយោ** ប្រែថា ដែលឲ្យកើតបីតិ ។

បទថា **មនាបោ** ប្រែថា ជាទីពេញចិត្ត ។

បទថា **សុខេធិតោ** ប្រែថា រុងរឿងដោយសេចក្តីសុខ អធិប្បាយថា អ្នកចម្រើនមកដោយសេចក្តីសុខ បទថា **សុខបរិហតោ** សេចក្តីថា អ្នកដែលពួកជនចិញ្ចឹមបីបាច់មកដោយសេចក្តីសុខ គឺតាំងពីពេលកើតមកហើយ ក៏មានកីលៀង នាងមេដោះទាំងឡាយ ផ្លាស់ប្តូរចង្កេះគ្នាបី-ព តែងលេងដោយវត្ថុជាគ្រឿងលេង កាលដែលនៅជាកុមារតូចៗ មានសេះ និងរថជាដើម ដែលកីលៀងជាដើមឲ្យបរិភោគភោជនីយាហារ ដែលមានរសឆ្ងាញ់ល្អ ឈ្មោះថា ជាអ្នកដែលពួកជនចិញ្ចឹមបីបាច់មកដោយសេចក្តីសុខ ។

ច្រើនបទថា **ន ត្វំ តាត សុទិន្ន កិញ្ចិ ទុក្ខស្ស ជានាសិ** សេចក្តីថា នែកូនសុទិន្ន អ្នកឯងរមែងមិនដឹងចំណែកតូចនៃទុក្ខណាមួយ សូម្បីត្រឹមតែតិចតួចឡើយ ។ ម្យ៉ាងទៀត អធិប្បាយថា អ្នកមិនបានសោយសេចក្តីទុក្ខណាមួយ ។ ពាក្យថា **ទុក្ខស្ស** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។ ឯការដឹងប្រព្រឹត្តទៅក្នុងអត្ថ គឺការសោយ ។

ម្យ៉ាងទៀត អធិប្បាយថា អ្នករមែងរឭកដល់សេចក្តីទុក្ខណាមួយមិនបាន ។ ពាក្យថា **ទុក្ខស្ស** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ ការដឹងប្រព្រឹត្តទៅក្នុងអត្ថ គឺការរឭក ។

សូម្បីក្នុងវិកប្បទាំងពីរ គប្បីឃើញការលុបវិភត្តិដែលស្មើគ្នា នៃបទខាងដើម ដោយបទខាងចុងចេញ ។ ពាក្យតាមដែលពោលមកហើយទាំងអស់នោះ អ្នកសិក្សាគួរជ្រាបតាមគន្លងគម្ពីរសព្ទសាស្ត្រ ។

ច្រើនបទថា **មរណេនបិ មយន្តេ អកាមកា វិនា ភវិស្សាម** សេចក្តីថា សូម្បីបើយើងទាំងពីរនៅមានជីវិតនៅឡើយ កូននឹងគប្បីស្លាប់សោត សូម្បីដោយការស្លាប់របស់កូននោះ យើងទាំងពីរ ក៏មិនត្រូវការ គឺមិនប្រាថ្នា ឈ្មោះថា នឹងមិនព្រមវៀរ ( ឲ្យកូនស្លាប់ ) តាមការពេញចិត្តរបស់ខ្លួន អធិប្បាយថា យើងទាំងពីរនឹងជួបនូវការព្រាត់ប្រាសអំពីកូនមិនបាន ។ ច្រើនបទថា **កឹ បន មយំ តំ** សេចក្តីថា បើដូច្នោះ ហេតុអ្វីនឹងជាហេតុឲ្យយើងទាំងពីរអនុញ្ញាតឲ្យកូនដែលនៅមានជីវិតនៅឡើយ ( ចេញបួសជាបព្វជិត ) ។

ម្យ៉ាងទៀត ក្នុងបទថា **កឹ បន មយំ តំ** នេះ គប្បីឃើញអត្ថយ៉ាងនេះថា ព្រោះហេតុអ្វី ទើបយើងទាំងពីរនឹងព្រមអនុញ្ញាតឲ្យកូនដែលនៅមានជីវិតនៅឡើយ ។

បទថា **តត្ថេវ** សេចក្តីថា ( សុទិន្នកលន្ទបុត្រនោះដេកចុះ ) ក្នុងកន្លែងដែលគេកំពុងឈរ កាលមាតាបិតាមិនអនុញ្ញាតឲ្យបួសនោះឯង ។

បទថា **អនន្តរហិតាយ** សេចក្តីថា លើផែនដីដែលគេមិនបានក្រាល ដោយកម្រាលណាមួយឡើយ ។

## មាតាបិតាលួងលោមសុទិន្ន

[ ១២ ] បទថា **បរិចារេហិ** សេចក្តីថា អ្នកចូរឲ្យពួកអ្នកចម្រៀង អ្នករបាំជាដើមបម្រើចំពោះខ្លួនហើយ ចូរឲ្យឥន្ទ្រិយ ( គឺវាងកាយគ្រប់ចំណែក ) ត្រាច់ទៅ គឺឲ្យសញ្ចរទៅតាមសប្បាយ រួមជាមួយសម្លាញ់ទាំងឡាយ ក្នុងពួកអ្នកច្រៀងរាំទាំងនោះ អធិប្បាយថា អ្នកចូរនាំអ្នកចម្រៀងជាដើម ចូលមកផ្លូវនេះ និងផ្លូវនេះចុះ ។

ម្យ៉ាងទៀត បទថា **បរិចារេហិ** សេចក្តីថា អ្នកចូរឲ្យពួកអ្នកចម្រៀង និងអ្នករបាំ ជាដើមបម្រើចំពោះខ្លួនហើយ ចូរលេង គឺចូរទៅសមាគម បានដល់ ចូររីករាយរួមជាមួយសម្លាញ់ទាំងឡាយចុះ អធិប្បាយថា ចូរលេងកីឡាចុះ ក៏មាន ។

ពីរបទថា **កាមេ បរិភុញ្ជន្តោ** សេចក្តីថា អ្នកចូរបរិភោគភោគទ្រព្យទាំងឡាយរួមជាមួយបុត្រ និងភរិយារបស់ខ្លួនចុះ ។

ពីរបទថា **បុញ្ញានិ ករោន្តោ** សេចក្តីថា អ្នកចូរប្រារព្ធព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ហើយបំពេញកុសលធម៌ទាំងឡាយ ដែលជាគ្រឿងជម្រះផ្លូវសុគតិឲ្យបរិសុទ្ធដោយល្អ មានការបំពេញទានជាដើមចុះ ។

ពីរបទថា **តុណ្ហី អហោសិ** សេចក្តីថា សុទិន្នកលន្ទបុត្រដើម្បីកាត់ការជាប់ជំពាក់ដោយការចរចា ទើបបានវៀរការប្រាស្រ័យសន្ទនាចោល ។

# សម្លាញ់ទៅឃាត់សុទិន្នមិនសម្រេច

[ ១៣-១៤ ] គ្រានោះ មាតាបិតារបស់សុទិន្នទិយាយ ( លួងលោម ) អស់វារៈ ៣ ដង កាលមិនបានសូម្បីត្រឹមតែចម្លើយ ទើបប្រាប់ឲ្យហៅពួកសម្លាញ់ ( របស់សុទិន្ន ) មកហើយប្រាប់ថា សុទិន្នជាសម្លាញ់របស់ពួកអ្នកនោះ មានបំណងនឹងបួស ពួកអ្នកចូរជួយឃាត់គេផង ។ សម្លាញ់ទាំងនោះចូលទៅរកសុទិន្នហើយ ក៏បាននិយាយ ( អង្វរ ) អស់វារៈ ៣ ដង តែសុទិន្នក៏បានស្ងៀមចំពោះ ( មុខ ) សម្លាញ់ទាំងនោះ ។ ព្រោះហេតុនោះ ព្រះឧបាលិត្ថេរបានពោលទុកថា **អថខោ សុទិន្នស្ស កលន្ទបុត្តស្ស សហាយកា ។បេ។ តុណ្ហី អហោសិ ។**

គ្រានោះ សម្លាញ់ទាំងឡាយរបស់សុទិន្ននោះ មានគំនិតដូច្នេះថា បើសុទិន្នមិនបានបួស នឹងស្លាប់ នឹងមិនមានគុណអ្វី តែមាតាបិតានឹងបានឃើញសុទិន្នបួសហើយម្ដងម្កាល ឯពួកយើងក៏បានឃើញ ម្យ៉ាងទៀត ឈ្មោះថាការបួសនោះ ជាភារៈធ្ងន់ អ្នកបួសត្រូវកាន់បាត្រ ដើរបិណ្ឌបាតរាល់ថ្ងៃ ព្រហ្មចរិយៈ មានការដេកម្ដង ឆាន់ម្ដង ជាកិច្ចដែលធ្វើបានលំបាកក្រៃលែង ឯសុទិន្ននេះ ជាអ្នកសុខុមាលជាតិ ជាអ្នកក្រុង គេកាលមិនអាចប្រព្រឹត្តព្រហ្មចរិយៈនោះបាន ក៏នឹងត្រឡប់មកផ្ទះនេះវិញនោះឯង ណ្ហើយចុះ ពួកយើងនឹងសូមឲ្យឪពុកម្ដាយរបស់គេអនុញ្ញាតឲ្យបួស ។ សម្លាញ់ទាំងនោះក៏បានធ្វើយ៉ាងនោះហើយ ។

ចំណែកមាតាបិតា ក៏បានអនុញ្ញាតឲ្យសុទិន្នបួស ។ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា **អថខោ សុទិន្នស្ស កលន្ទបុត្តស្ស សហា-**

**យក្កា យេន សុទិន្នស្ស កលន្ទបុត្តស្ស មាតាបិតរោ ។បេ។ អនុញ្ញាតោសិ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយ។**

បទថា **ហដ្ឋោ** សេចក្តីថា ជាអ្នកត្រេកអរហើយ ។

បទថា **ឧទគ្គោ** សេចក្តីថា ជាអ្នកមានកាយ និងចិត្តអណ្តែតឡើង ដោយអំណាចបីតិ ។

បទថា **កតិបាហំ** សេចក្តីថា អស់ថ្ងៃបន្តិចបន្តួច ។

ពីរបទថា **ពលំ គាហេត្វា** សេចក្តីថា សុទិន្នកលន្ទបុត្រនោះ កាលបរិភោគភោជនីយាហារដែលសប្បាយ និងបរិហាររាងកាយដោយកិច្ច មានកម្ដៅ និងងូតទឹកជាដើមឲ្យកើតកម្លាំងកាយហើយ ថ្វាយបង្គំមាតាបិតា លាផៅពង្សញាតិដែលមានមុខជោកដោយទឹកភ្នែក ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគរហូតដល់ទីប្រថាប់ ។បេ។ បានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ សូមព្រះអង្គមេត្តាឲ្យខ្ញុំព្រះអង្គបួសចុះ ។

ព្រះដ៏មានព្រះភាគ ត្រាស់ហៅភិក្ខុអង្គណាទីមួយ ដែលត្រាច់បិណ្ឌបាតជាវត្ត ដែលឈរគាល់នៅក្នុងទីជិតមកថា ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរឲ្យសុទិន្នបព្វជ្ជា និងឧបសម្បទាចុះ ភិក្ខុអង្គនោះ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា សាធុ ព្រះអង្គ ហើយឲ្យសុទិន្នកលន្ទបុត្រដែលព្រះជិនស្រីទ្រង់ប្រទានជាសទ្ធិវិហារិក បួស និងឧបសម្បទាហើយ ។ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា សុទិន្នកលន្ទបុត្របានទទួលបព្វជ្ជា និងឧបសម្បទាក្នុងសម្នាក់ព្រះដ៏មានព្រះភាគហើយ ។

ម្យ៉ាងទៀត វៀរក្នុងអធិការពោលដោយសុទិន្ន បានទទួលបព្វជ្ជាឧបសម្បទានេះចេញ បព្វជ្ជា និងឧបសម្បទា ព្រះអដ្ឋកថាចារ្យទាំងឡាយក៏បានពោលទុកហើយក្នុងអដ្ឋកថាទាំងពួង ។ ចំណែកខ្ញុំ នឹងពោល ( បព្វជ្ជា និងឧបសម្បទានោះ ) ក្នុងខន្ធកៈ ដោយអំណាចនៃព្រះបាលីតាមដែលពោលទុកហើយនោះឯង មិនមែនពោលតែបព្វជ្ជា និងឧបសម្បទាក្នុងខន្ធកៈតែម្យ៉ាងប៉ុណ្ណោះឡើយ ពាក្យដទៃណាដែលគួរពោលក្នុងខន្ធកៈក្តី ក្នុងគម្ពីរបរិវារក្តី ដែលព្រះអដ្ឋកថាចារ្យទាំងឡាយពោលទុកហើយក្នុងវិភង្គ ខ្ញុំនឹងពោលពាក្យទាំងអស់នោះ ទុកក្នុងទីនោះឯង ។ ពិតហើយ កាលខ្ញុំពណ៌នាតាមដែលអធិប្បាយមកយ៉ាងនេះ គឺខ្ញុំធ្វើហើយដោយលំដាប់នៃព្រះបាលីនោះឯង ព្រោះហេតុនោះ អ្នកសិក្សាទាំងឡាយដែលមានសេចក្តីត្រូវការដោយវិនិច្ឆ័យនោះៗ ពិនិត្យមើលវិន័យវណ្ណនានេះ ដោយលំដាប់ព្រះបាលីនោះឯង ក៏នឹងដឹងវិនិច្ឆ័យដែលនៅសល់បានល្អ ដូច្នេះឯង ។

បទថា **អចិរូបសម្បន្នោ** គឺសុទិន្នភិក្ខុនោះ ជាអ្នកឧបសម្បទាហើយមិនយូរ អធិប្បាយថា ដោយកាលមិនយូរប៉ុន្មាន បន្ទាប់អំពីឧបសម្បទាមកនោះឯង ។

បទថា **ឯវរូបេ** គឺមានចំណែកយ៉ាងនេះ បានដល់ មានជាតិយ៉ាងនេះ។

បទថា **ធុតគុណោ** បានដល់ ធុតង្គគុណ ។

ពីរបទថា **សមាទាយ វត្តតិ** សេចក្តីថា ( សុទិន្ននោះ ) សមាទានគឺទទួលយក ប្រព្រឹត្ត ត្រាច់ទៅ ។

ពីរបទថា **អារញ្ញិកោ ហោតិ** សេចក្តីថា បដិសេធសេនាសនៈក្នុងស្រុកចេញហើយ ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃជាវត្ត ដោយអំណាចសមាទានអារញ្ញិកធុតង្គ ។

បទថា **បិណ្ឌបាតិកោ** សេចក្តីថា បដិសេធភត្ត ១៤ យ៉ាង ដោយការបដិសេធអតិរេកលាភចោលហើយ ជាអ្នកប្រព្រឹត្តបិណ្ឌបាតជាវត្ត ដោយអំណាចសមាទានបិណ្ឌបាតិកធុតង្គ ។

បទថា **បំសុកូលិកោ** សេចក្តីថា បដិសេធគហបតីចីវរចោលហើយ ជាអ្នកប្រព្រឹត្តទ្រទ្រង់សំពត់បង្សុកូលជាវត្ត ដោយអំណាចសមាទានបង្សុកូលិកធុតង្គ ។

បទថា **សបទានចារិកោ** សេចក្តីថា បដិសេធការត្រាច់ល្មោភចេញហើយ ជាអ្នកប្រព្រឹត្តត្រាច់តាមលំដាប់ច្រកផ្លូវជាវត្ត គឺចូលទៅដើម្បីភិក្ខាតាមលំដាប់ផ្ទះ ដោយអំណាចសមាទានចារិកធុតង្គ ។

បទថា **វជ្ជិគាមំ** សេចក្តីថា ( សុទិន្ននោះចូលអាស្រ័យ ) ដែនវជ្ជីឬស្រុកក្នុងដែនវជ្ជី ។

## ញាតិរបស់សុទិន្នឯក្រុងវេសាលីមានសម្បត្តិច្រើន

[ ១៥ ] ក្នុងពាក្យជាដើមថា **អឌ្ឍា មហទ្ធនា** មានវិនិច្ឆ័យដូច្នេះថា ( ញាតិទាំងឡាយរបស់អញក្នុងក្រុងវេសាលី ) ឈ្មោះថា ជាអ្នកស្តុកស្តម្ភ ព្រោះមានគ្រឿងឧបភោគ និងឧបករណ៍នៃគ្រឿងបរិភោគច្រើន អធិប្បាយថា ពិតហើយ គ្រឿងឧបភោគ និងឧបករណ៍នៃគ្រឿងឧបភោគរបស់ញាតិទាំង

នោះមានច្រើន គឺមានសន្ទឹកសន្ធាប់ ទាំងជាវត្ថុមានសារៈ ។

ឈ្មោះថា **មហទ្ធនា** ព្រោះមានទ្រព្យកប់ទុកច្រើន ។

បទថា **មហាភោគោ** ឈ្មោះថា មានភោគៈច្រើន ព្រោះមានភោគៈ គឺវត្ថុដែលជាស្បៀង ( សម្រាប់ចាយវាយ ) ប្រចាំថ្ងៃច្រើន ។

ឈ្មោះថា **បហូតជាតរូបរជតា** ព្រោះក្រៅអំពីគ្រឿងឧបភោគដទៃ ក៏នៅមានមាស និងប្រាក់នោះឯងច្រើន ។

ឈ្មោះថា **បហូតវិត្តូបករណា** ព្រោះ ឧបករណ៍នៃទ្រព្យជាគ្រឿង រីករាយចិត្ត ដែលជាគ្រឿងប្រដាប់ ដែលធ្វើបីតិបាមោជ្ជឲ្យកើតមានច្រើន ។ គប្បីជ្រាបថា ជាអ្នកមានទ្រព្យ និងស្រូវច្រើន ព្រោះទ្រព្យនិងស្រូវដែល ផ្លាស់ប្តូរគ្នា ដោយអំណាចការទិញលក់ មានចំនួនច្រើន ។

ពីរបទថា **សេនាសនំ សំសាមេត្វា** សេចក្តីថា ទុកដាក់សេនាសនៈ ហើយ អធិប្បាយថា រៀបចំសេនាសនៈនោះទុកយ៉ាងមានរបៀប ដោយការ ដែលសេនាសនៈ នឹងមិនវិនាស ។

ពីរបទថា **សដ្ឋិមត្តេ ថាលិបាកេ** សេចក្តីថា ( ញាតិទាំងឡាយរបស់ សុទិន្នភិក្ខុនាំភត្តាហារទៅប្រគេនសុទិន្ន ) មានប្រមាណ ៦០ ថាស ដោយ កំណត់នៃការគណនា ។

បណ្តាភត្ត ៦០ ថាសនេះ ភត្តមួយថាសៗ ល្មមដល់ភិក្ខុ ១០ អង្គ ភត្តទាំងអស់នោះ ល្មមភិក្ខុ ៦០០ រូបធាន់បាន ។

ក្នុងពីរបទថា **ភត្តាភិហារំ អភិហរឹសុ** នេះ មានវិគ្គហៈដូច្នេះថា

អាហារដែលឈ្មោះថា **អភិហារ** ព្រោះអត្ថថា ដែលបុគ្គលនាំទៅចំពោះ ។ សួរថា នាំនូវអ្វីទៅ ឆ្លើយថា នាំកត្តទៅ ។ អភិហារ គឺកត្តនោះឯង ឈ្មោះ កត្តាភិហារ ។ នូវកត្តាភិហារនោះ ។

បទថា **អភិហរឹសុ** សេចក្តីថា ញាតិទាំងឡាយនាំកត្តាហារទៅចំពោះ មុខ អធិប្បាយថា កាន់យកហើយ បានទៅកាន់សម្នាក់របស់សុទិន្ននោះ ។

សួរថា កត្តនោះមានប្រមាណប៉ុនណា ឆ្លើយថា មាន ៦០ ថាស ។ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា ញាតិទាំងឡាយនាំកត្តាហារ មានប្រមាណ ៦០ ថាស ទៅប្រគេនសុទិន្នភិក្ខុ ។

ពីរបទថា **ភិក្ខូនំ វិស្សជ្ជេត្វា** សេចក្តីថា សុទិន្នភិក្ខុនោះ មានបំណង នឹងត្រាច់ចារិកទៅតាមលំដាប់ប្រកដោយខ្លួនឯង ព្រោះជាអ្នកសមាទានបិណ្ឌ- បាតជាវត្តយ៉ាងឧក្រិដ្ឋ ទើបបានលះបង់ គឺប្រគេន ( កត្តាហារមានប្រមាណ ៦០ ភាជនៈនោះ ) ដើម្បីជារបស់ធាន់ដល់ភិក្ខុទាំងឡាយ ។ ពិតហើយ លោកដ៏មានអាយុអង្គនោះដាក់ចិត្តថា ភិក្ខុទាំងឡាយនឹងបានលាភ ឯអញក៏ នឹងមិនលំបាកដោយបិណ្ឌបាត ហើយទើបមកដើម្បីប្រយោជន៍នោះឯង ព្រោះ ដូច្នោះ សុទិន្នភិក្ខុនោះ កាលធ្វើកិច្ចដែលសមគួរដល់ការមករបស់ខ្លួន ទើប បានលះបង់ដល់ភិក្ខុទាំងឡាយ ចំណែកខ្លួនឯងក៏ចូលទៅបិណ្ឌបាត ។ ទាសី របស់ពួកញាតិ ឈ្មោះញាតិទាសី ។

## អធិប្បាយ រឿងនំផ្អូម

បទថា **អាភិទោសិកំ** បានដល់ នំកុម្មាសដែលទុកយូរ គឺកន្លងទៅបាន

មួយយប់ហើយ ជារបស់ផ្អូម ។

ក្នុងបទថា **អាភិទោសិកំ** នោះ មានអត្ថចំពោះបទដូច្នេះថា នំកុម្មាស ដែលឈ្មោះថា អភិទោស ព្រោះអត្ថថា ត្រូវទោស គឺការផ្អូមគ្រប់សង្កត់ ។ អភិទោសនោះឯង ឈ្មោះថា **អាភិទោសិក** ។ ម្យ៉ាងទៀត សញ្ញា គឺ អភិទោសិកនេះ ជាសញ្ញា គឺឈ្មោះនៃនំកុម្មាសដែលកន្លងទៅបានមួយយប់ ហើយ ។ នូវនំកុម្មាស ឈ្មោះអភិទោសិកនោះ ។

បទថា **កុម្មាសំ** បានដល់ នំកុម្មាសដែលគេធ្វើដោយអង្ករដំណើប ។

ពីរបទថា **ឆឌ្ឌេតុកាមា ហោតិ** សេចក្ដីថា នំកុម្មាសនោះ ជារបស់ មិនគួរស៊ី ដោយហោចសូម្បីពួកទាសៈ និងកម្មករ សូម្បីហ្វូងគោ ព្រោះ ដូច្នោះ ទើបទាសីមានបំណងនឹងចាក់នំកុម្មាសនោះចោលខាងក្រៅ ដូចចាក់ សំរាមចោលដូច្នោះ ។

បទថា **សចេ តំ** កាត់បទជា **សចេ ឯតំ** ប្រែថា បើរបស់នោះ ។

សុទិន្នភិក្ខុហៅទាសីរបស់ញាតិថា ម្នាលប្អូនស្រី ដោយអំណាចអរិយ- វោហារ ។

បទថា **ឆឌ្ឌនីយធម្មំ** សេចក្ដីថា មានការត្រូវលះបង់ជាសភាវៈ ។ អធិប្បាយថា ម្នាលប្អូនស្រី បើរបស់នោះ មានការដែលត្រូវចាក់ចោលខាង ក្រៅជាធម្មតា គឺជារបស់ដែលគេលះបង់ការហួងហែងហើយសោត នាងចូរ ចាក់ក្នុងបាត្ររបស់អាត្មានេះចុះ ។

សួរថា ឯបព្វជិតរមែងបានដើម្បីពោលយ៉ាងនេះឬ មិនជាវិញ្ញត្តិ ( ការ

ហាមាត់សុំ ) ឬបយុត្តវាចា ( វាចាពោលកោសដោយបច្ច័យ ) ឬ ឆ្លើយថា មិនដូច្នោះឡើយ ។ សួរថា ព្រោះហេតុអ្វី ទើបមិនដូច្នោះ ឆ្លើយថា ព្រោះជារបស់ដែលគេលះបង់ការហួងហែងហើយ ។

ពិតហើយ នឹងនិយាយថា អ្នកចូរឲ្យ គឺចូរនាំរបស់ដែលមានការត្រូវបោលជាធម្មតា គឺជារបស់គេលះបង់ការហួងហែងហើយ ដែលពួកម្ចាស់របស់មិនមានការស្តាយអ្វីឡើយ មកចាក់ក្នុងបាត្រនេះចុះក៏គួរ ។ ពិតហើយ សូម្បីវដ្តបាលភិក្ខុអ្នកប្រព្រឹត្តអរិយវង្សដ៏ល្អលើស ក៏បាននិយាយថា ចូរអ្នកចាក់នំកុម្មាសដែលមានការត្រូវបោលជាធម្មតា ចូលក្នុងបាត្ររបស់អាត្មានេះចុះ ព្រោះដូច្នោះ របស់ណាដែលមានការចាក់បោលជាធម្មតាបែបនេះក្តី របស់ដទៃ មានឫសឈើ ផ្លែឈើ និងភេសជ្ជៈក្នុងព្រៃជាដើម ដែលមិនមានអ្នកដទៃហួងហែងក្តី ភិក្ខុគួរនាំរបស់ទាំងអស់នោះមកហើយ ឆាន់បានតាមសប្បាយ មិនគួររង្កៀសឡើយ ។

បទថា **ហត្ថានំ** សេចក្តីថា ទាសីរបស់ញាតិបានកាន់យកនិមិត្តដៃទាំងពីររបស់សុទិន្នភិក្ខុ ដែលបង្អោនបាត្រចូលទៅដើម្បីទទួលភិក្ខា តាំងអំពីកដៃឡើងទៅ ។

បទថា **បាទានំ** សេចក្តីថា ទាសីរបស់ញាតិបានកាន់យកនិមិត្តជើងទាំងពីរ ចាប់តាំងអំពីជាយស្បង់ចុះទៅ ។

បទថា **សរស្ស** សេចក្តីថា កាលសុទិន្នភិក្ខុបន្លឺវាចាថា ម្នាលប្អូនស្រី បើរបស់នោះ ដូច្នេះជាដើម ទាសីរបស់ញាតិក៏ចាំសំឡេង ( របស់លោក )

បាន ។

ពីរបទថា **និមិត្តំ អគ្គហេសិ** សេចក្តីថា ទាសីរបស់ញាតិបានកាន់យក គឺចាំបាន សេចក្តីថា កំណត់ការដែលខ្លួនធ្លាប់សង្កេតបានក្នុងពេលដែលលោកនៅជាគ្រហស្ថ ។

ពិតហើយ សុទិន្នភិក្ខុបួសក្នុងវស្សាទី ១២ របស់ព្រះដ៏មានព្រះភាគ ក្នុងវស្សាទី ២០ របស់ព្រះដ៏មានព្រះភាគ បានចូលទៅបិណ្ឌបាតកាន់ត្រកូលញាតិរបស់ខ្លួន មានវស្សាបាន ៨ តាំងអំពីបួសមក ព្រោះហេតុនោះ ទាសីរបស់ញាតិម្នាក់នោះ ឃើញលោកហើយ ទើបចាំមិនបាន តែកាន់យកទ្រង់ទ្រាយ ( និមិត្ត ) បានដោយប្រការដូច្នេះ ។

ច្រើនបទថា **សុទិន្នស្ស មាតរំ ឯតទវោច** សេចក្តីថា ទាសីរបស់ញាតិមិនអាចនឹងពោលពាក្យជាដើមថា លោកម្ចាស់ លោកឬហ៎ គឺព្រះសុទិន្នដែលជាម្ចាស់របស់ខ្ញុំ ដូច្នេះ ជាមួយកូនប្រុសរបស់ចៅហ្វាយ ( របស់ខ្លួន ) ដែលចូលបួសហើយ ព្រោះការគោរពក្រៃលែង ទើបប្រញាប់ប្រញាល់ត្រឡប់ចូលទៅក្នុងផ្ទះ ហើយជម្រាបដំណឹងនេះដល់មាតារបស់ព្រះសុទិន្ន ។

សព្ទថា **យគ្ឃេ**[១] ជានិបាត ចុះក្នុងអត្ថនៃពាក្យប្រាប់ ។

សព្ទថា **ជេ** ដែលមាននៅក្នុងបទថា **សចេ ជេ សច្ចំ** នេះ ជានិបាត ចុះក្នុងអត្ថនៃពាក្យហៅ ។ ពិតហើយ ជនទាំងឡាយក្នុងប្រទេសនោះ រមែងហៅស្ត្រីអ្នកបម្រើដោយភាសាយ៉ាងនោះ ។ ព្រោះហេតុនោះ ក្នុងពាក្យថា

---

១- បិដកថា យគ្ឃេយ្យ ។ យកតាមអដ្ឋកថា ។

**សចេ ជេ សច្ចំ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា នែទាសីដ៏ចម្រើន បើនាង និយាយពិតសោត ... ។

## បព្វជិតមិនអង្គុយចាំក្នុងទីមិនសមគួរដូចអ្នកសុំទាន

ពីរបទថា **អញ្ញតរំ កុណ្ឌមូលំ** សេចក្ដីថា បានឮថា ក្នុងប្រទេសនោះ ក្នុងផ្ទះរបស់ពួកជនដែលជាទានបតី មានរោងសម្រាប់ចាន់ទុក ហើយក្នុងរោងចាន់នេះ គេរៀបចំក្រាលអាសនៈទុក ទាំងបានរៀបចំទឹកចាន់ និងទឹកលាងដៃទុកព្រម ។ បព្វជិតទាំងឡាយ កាលត្រាច់ទៅបិណ្ឌបាតហើយ ( ត្រឡប់មក ) អង្គុយចាន់ត្រង់រោងនោះ ប្រាថ្នានឹងទទួលយកកត្តាហារដែលមាននៅ ក៏ទទួលយករបស់ដែលមាននៅ របស់ពួកជនដែលជាទានបតីទៅបាន ព្រោះដូច្នោះ ទីកន្លែងនោះ គួរជ្រាបថា បានដល់ សំយាបជញ្ជាំងផ្ទះឯណានីមួយ ក្បែររោងចាន់នោះ នៃត្រកូលណានីមួយ ។ ពិតហើយ បព្វជិតទាំងឡាយ រមែងមិនអង្គុយចាន់ក្នុងទីកន្លែងមិនសមគួរ ដូចពួកមនុស្សកំព្រា ដូច្នោះឯង ។

សព្ទថា **អត្ថិ** ដែលមាននៅក្នុងបទថា **អត្ថិ ណាម តាត** នេះ ជានិបាត ចុះក្នុងអត្ថថា មាន ឯសព្ទថា **ណាម** ( ដែលមាននៅក្នុងបទនោះ ) ក៏ជានិបាត ចុះក្នុងអត្ថនៃពាក្យសួរ និងក្នុងអត្ថនៃការមើលងាយ ។

ពិតហើយ លោកពោលពាក្យអធិប្បាយនេះទុកថា ( បិតាពោលនឹងសុទិន្នភិក្ខុដែលជាកូនប្រុសថា ) សុទិន្នកូន ទ្រព្យរបស់យើងក៏នៅមានដែរ មិនមែនឬ ពួកយើងដែលមានកូនឯងជាបុត្រប្រុស មកអង្គុយចាន់នំកុម្មាសដែលរក្សាទុកកន្ទងមួយយប់នៅក្នុងទីដូច្នេះ នឹងគប្បីត្រូវពួកជនគេតិះដៀលថា

ជាអ្នកមិនមានទ្រព្យ មិនមែនឬ ។

ម្យ៉ាងទៀត សុទិន្នកូន ពុក និងម៉ែ ក៏នៅមានជីវិតនៅឡើយ មិនមែនឬ ពុក ម៉ែ ដែលមានលោកជាកូនប្រុស មកអង្គុយឆាន់នំកុម្មាសផ្អូមក្នុងទីដូច្នេះ នឹងត្រូវពួកជនគេតិះដៀលថា ( មានបិតា ) ស្លាប់ហើយ មិនមែនឬ ។

ម្យ៉ាងទៀត សុទិន្នកូន កូនឯងសម្គាល់ថា សមណគុណដែលកូនឯងបាន ព្រោះអាស្រ័យសាសនាមាននៅខាងក្នុងសន្តានចិត្តរបស់កូនឯង ដែលចម្រើនជំជាត់មកដោយរសនៃអាហារដ៏ល្អ កូនឯងនៅតែមិនរអើម ឆាន់នំកុម្មាសផ្អូមដែលជារបស់គួរខ្ពើមរអើមនេះ ដូចផឹកទឹកអម្រឹត ដូច្នោះ ។

ឯគហបតីនោះ ព្រោះត្រូវសេចក្តីទុក្ខបៀតបៀន មិនអាចនឹងពោលពាក្យថ្វាថ្លែងសេចក្តីនោះឲ្យបរិបូណ៌បាន ទើបបានពោលពាក្យត្រឹមប៉ុណ្ណោះថា នៃសុទិន្នកូន យើងជាអ្នកមានទ្រព្យច្រើន ហេតុអ្វីក៏លោកមកឆាន់នំកុម្មាសដែលទុកកន្លងរាត្រីទៅវិញ ។

ចំណែកក្នុងពាក្យថា **អត្ថិ ឆាម តាត** ជាដើមនេះ អាចារ្យអក្ខរសាស្ត្រទាំងឡាយ រមែងពោលលក្ខណៈនេះទុកដូច្នេះថា កាលមាន **អត្ថិ** សព្ទនៅក្នុងទីជិត ( គឺនៅបទខាងមុខ ) ទើបបណ្ឌិតទាំងឡាយ បានរចនាពាក្យអនាគតកាលនេះទុកដូច្នេះថា **បរិភុញ្ជិស្សសិ** ដោយអំណាចអត្ថ ដែលមិនគួរជឿ និងមិនអាចកើតបាន ។

អត្ថនៃពាក្យអនាគតកាលនោះ មានដូច្នេះថា ពាក្យថា **អត្ថិ ឆាម ។បេ។ បរិភុញ្ជិស្សសិ** សេចក្តីថា ឪពុកមិនជឿ ទាំងមិនពេញចិត្តនូវការឆាន់

នេះ សូមរឿងឃើញទឹងក្អែក ដូច្នេះ ។

ពីរបទថា **តតាយំ អភិទោសិកោ** សេចក្តីថា នំកុម្មាសដែលទុកកន្លង រាត្រីនេះ ជានំដែលបានមកអំពីផ្ទះរបស់ញោមនោះ ។

បាឋៈថា **តតោយំ** ក៏មាន អាចារ្យពួកខ្លះសូធ្យថា **តទាយំ** ក៏មាន តែពាក្យនោះ មិនសមគួរ ។

ច្រើនបទថា **យេន សកបិតុ និវេសនំ** សេចក្តីថា និវេសន៍នៃបិតា របស់ខ្លួន គឺនៃបិតារបស់អាត្មាមាននៅក្នុងទីណា ព្រះថេរៈជាអ្នកប្រដៅឆាយ ទើបបានទៅ ( កាន់និវេសន៍នោះ ) ព្រោះសេចក្តីស្រឡាញ់ក្នុងបិតានោះឯង ។

បទថា **អធិវាសេសិ**[១] សេចក្តីថា ព្រះថេរៈសូមរឿងជាអ្នកសមាទាន បិណ្ឌបាតជាវត្តយ៉ាងឧក្រិដ្ឋក៏ដោយ តែក៏នៅជាក់ចិត្តថា បើអញមិនទទួល កត្តាហារមួយពេលសោត ពួកញាតិទាំងនោះក៏នឹងខូចចិត្តក្រៃលែង ទើប ទទួលពាក្យអារាធនាដើម្បីអនុគ្រោះពួកញាតិ ។

## បិតាលួងលោមសុទិន្នភិក្ខុដោយទ្រព្យ

បទថា **ឱបុញ្ជាបេត្វា** ប្រែថា ប្រាប់ឲ្យលាប ។

បទថា **តិរោករណីយំ** ជាសត្តមីវិភត្តិចុះក្នុងអត្ថតតិយាវិភត្តិ សេចក្តីថា បិទបាំង ( គំនរទ្រព្យនោះ ) ទុកដោយរាំងនន ម្យ៉ាងទៀត ជនទាំងឡាយ រមែងធ្វើរនាំងទុកខាងក្រៅរាំងននោះ ហេតុនោះ ទើបរនាំងនោះ ឈ្មោះថា **តិរោករណីយ។** សេចក្តីថា រាំងរនាំងនោះដោយជុំវិញ ។

---

១- បិដកថា សេហិ ។ យកតាមអដ្ឋកថា ។

*ក្នុងពីរបទថា* **ឯកំ ហិរញ្ញស្ស** *នេះ កហាបណៈ គួរជ្រាបថា ប្រាក់ ។ បុរសមិនខ្ពស់ពេក មិនទាបពេក ជាមនុស្សខ្នាតកណ្តាល គប្បីជ្រាបថា បុរស ។*

*បទថា* **តេន ហិ** *សេចក្តីថា ព្រោះកូនសុទិន្នទីឯមកក្នុងថ្ងៃនេះ ។*

*សព្ទថា* **ហិ** *ជានិបាត ចុះក្នុងអត្ថ គ្រាន់តែធ្វើបទឲ្យពេញ ន័យម្យ៉ាងទៀត សព្ទថា* **តេន** *នេះ គ្រាន់តែជានិបាត ចុះក្នុងអត្ថនៃពាក្យអញ្ជើញនោះឯង ។ ក្នុងបទថា* **បុព្វណ្ហសមយំ** *នេះ លោកមិនបានពោលពាក្យផ្តៀងកាលទុកក្នុងព្រះបាលីក៏ពិត សូម្បីដូច្នោះ ក៏គួរជ្រាបអធិប្បាយថា កាលគេផ្តៀងកាលហើយនោះឯង ព្រះថេរៈក៏បានទៅ ។*

*បិតារបស់សុទិន្នភិក្ខុ ចង្អុលប្រាប់គំនរទ្រព្យទាំងពីរគំនរថា សុទិន្នកូននេះទ្រព្យមាតារបស់លោកជាដើម ។*

*បទថា* **មាតុ** *បានដល់ នៃស្រីអ្នកឲ្យកើត ។*

*បទថា* **មត្តិកំ** *បានដល់ ទ្រព្យដែលមានមកអំពីចំណែកមាតា អធិប្បាយថា ទ្រព្យចំណែកប៉ុណ្ណេះ លោកយាយបានប្រគល់ឲ្យម្តាយរបស់កូន ដែលមកកាន់ផ្ទះនេះ ។*

*បិតាពោលតិះដៀល ( ទ្រព្យសម្បាច់ខាងស្រី ) ដោយពាក្យថា* **អត្ថិ-កាយ អត្ថីជនំ** *សេចក្តីថា ទ្រព្យ ឈ្មោះថា ត្រកូលខាងស្រីបានមក ដើម្បីប្រយោជន៍ដល់គ្រឿងលម្អិតសម្រាប់ងូតទឹកជាដើម ដែលជាគ្រឿងប្រើប្រាស់របស់ស្រីនោះឯង មានប្រមាណប៉ុនណា សូមលោកពិនិត្យបរិមាណទ្រព្យ*

ខាងស្រីនោះមុន ។

ម្យ៉ាងទៀត អធិប្បាយថា សុទិន្នកូន នេះទ្រព្យមាតារបស់លោក ឯទ្រព្យនោះ ជាមត៌កខាងមាតា ឪពុកមិនបានឲ្យទុក គឺជារបស់មាតារបស់កូនប៉ុណ្ណោះ ។

បទថា **អត្ថិកាយ ឥត្ថីធនំ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ទ្រព្យនេះប្រមូលមកបានដោយកសិកម្ម ពាណិជ្ជកម្មក៏ទេ ម្យ៉ាងទៀតទ្រព្យដែលជាចំណែកស្ត្រីគប្បីបានមក ឈ្មោះថា **ឥត្ថីធនំ** ( ទ្រព្យខាងស្រី ) សេចក្ដីថា ទ្រព្យខាងស្រីចំណែកណា ដែលជាចំណែកស្រីអ្នកទៅកាន់ត្រកូលស្វាមី អំពីត្រកូលញាតិគប្បីបានមក ដើម្បីប្រយោជន៍ដល់គ្រឿងលម្អិត សម្រាប់ងូតទឹកជាដើម ទ្រព្យចំណែកនោះ ក៏មានប្រមាណប៉ុណ្ណោះ ។

ប្រើនបទថា **អញ្ញំ បេត្តិកំ អញ្ញំ បិតាមហំ** សេចក្ដីថា ទ្រព្យចំណែកណាដែលជាកេរ្តិ៍របស់បិតា និងជីតាទាំងឡាយរបស់ឪពុក ទ្រព្យចំណែកនោះ ក៏ជាចំណែកដទៃផ្សេងទៀត ដែលគេកប់ទុក និងដែលប្រកបការជួញដូរក៏មានសន្ធឹកសន្ធាប់ ។

ម្យ៉ាងទៀត បទថា **បិតាមហំ** ដែលមាននៅក្នុងបទទាំងពីរថា **បេត្តិកំ បិតាមហំ** នេះ គួរជ្រាបថា ធ្វើការលុបបច្ច័យនៃតទ្ធិតចេញ ។ ម្យ៉ាងទៀតបាឋៈថា **បេតាមហំ** ដូច្នេះក៏មាន ។

ប្រើនបទថា **លព្ភា តាត សុទិន្ន ហីនាយាវត្តិត្វា** សេចក្ដីថា សុទិន្នកូន លោកគួរលះភេទបព្វជិតដ៏ខ្ពង់ខ្ពស់ ដែលជាទង់ជ័យនៃព្រះអរិយៈចោល

ហើយត្រឡប់មកដើម្បីភាពជាគ្រហស្ថ ដែលជាភេទថោកទាប គប្បីបាន ប្រើប្រាស់ គឺបានបរិភោគភោគសម្បត្តិ លោកខ្លាចចំពោះរាជអាជ្ញា ទើបបួសក៏ទេ ទាំងត្រូវម្ចាស់បំណុលតឹងទារក៏ទេដែរ ។

ឯពាក្យថា **តាត** ដែលមាននៅក្នុងបទថា **តាត ន ឧស្សហាមិ** នេះ សុទិន្នភិក្ខុពោល ( ជាមួយបិតា ) ព្រោះសេចក្ដីស្រឡាញ់អាស្រ័យផ្ទះ មិនមែនពោលព្រោះតេជះនៃសមណៈឡើយ ។

បទថា **ន ឧស្សហាមិ** ប្រែថា អាត្មាមិនអាច ។

បទថា **ន វិស្សហាមិ** ប្រែថា អាត្មាមិនព្រម គឺមិនអាច ។

ឯពាក្យថា **វទេយ្យាម ខោ តំ គហបតិ** នេះ សុទិន្នភិក្ខុពោល ( ជាមួយបិតា ) ព្រោះតេជះនៃសមណៈ ។

បទថា **ញាតិករុញ្ញយ្យាសិ** សេចក្ដីថា ការស្រឡាញ់ឯណារបស់ញោម ដែលតាំងនៅហើយក្នុងអាត្មា ញោមមិនគួរកាត់ផ្ដាច់ការស្រឡាញ់នោះចេញ ដោយអំណាចសេចក្ដីក្រោធ អធិប្បាយថា បើញោមមិនគប្បីក្រោធសោត ។

លំដាប់នោះ លោកសេដ្ឋីមានចិត្តរីករាយ ដោយនឹកក្នុងចិត្តថា កូនប្រុសហាក់ជាមានបំណងនឹងធ្វើការសង្គ្រោះទេដឹង ទើបបាននិយាយថា និយាយចុះសុទិន្នកូន ។

សព្ទថា **តេនហិ** ជានិបាត មានរូបសព្ទស្រដៀងវិភត្តិ ចុះក្នុងអត្ថនៃពាក្យអញ្ជើញ ។

បទថា **តតោ និទានំ** គប្បីជ្រាបការអាទេស **តំ** បឋមាវិភត្តិយ៉ាងនេះ

គឺ **តំនិទានំ តំហេតុកំ** ( មានទ្រព្យនោះជានិទាន មានទ្រព្យនោះជាហេតុ ) ជា **តោ**។ ឯក្នុងសមាសបទនោះ មិនមានការលុប **តោ** បច្ច័យ ។

ភ័យ មានរាជភ័យជាដើម ដែលលោកពោលទុកដោយន័យជាដើមថា ព្រះរាជាទាំងឡាយ នឹងមិនគប្បីរឹបជាន់យកភោគសម្បត្តិរបស់យើង ឬយ៉ាងណា ឈ្មោះថា ភ័យក្តី អធិប្បាយថា ចិត្តភ័យខ្លាច ។

កាយញាប់ញ័រ ( ក្តី ) កាយកក្រើក ( ក្តី ) បេះដូងលោតញាប់ ( ក្តី ) របស់បុគ្គលដែលត្រូវព្រះរាជា ឬចោរដាក់អាជ្ញា ដោយបញ្ជាថា ឯងចូរឲ្យទ្រព្យ ដូច្នេះ ឈ្មោះថា **ឆម្ភិតត្ត** ( ការស្រៀវខ្លាច ) ។

ការព្រឺរោម គឺមានចុងរោមបះឡើងលើ ក្នុងកាលមានភ័យកើតឡើង ឈ្មោះថា **លោមហំស** ( ព្រឺរោមព្រឺស្បែក ) ។

ការរក្សាយ៉ាងមាំទាំ ទាំងខាងក្នុង និងខាងក្រៅ ទាំងយប់ និងថ្ងៃ ឈ្មោះថា **អារក្ខា** ( ការថែរក្សា ) ។

ពីរបទថា **តេនហិ វតុ** សេចក្តីថា សេដ្ឋីគហបតី កាលបង្ហាញទ្រព្យហើយ ក៏មិនអាចនឹងលួងលោមកូនប្រុសដើម្បីឲ្យសឹកដោយខ្លួនឯង ទើបសម្គាល់ថា ឥឡូវនេះ គ្រឿងចងពួកបុរស ដូចជាមាតុគ្រាម រមែងមិនមាន ទើបបានហៅបុរាណទុតិយិកាភរិយារបស់សុទិន្នទោះមកប្រាប់ថា **តេនហិ វតុ** ជាដើម ។

បទថា **បុរាណទុតិយិកំ** បានដល់ ស្រីជាគម្រប់ ២ ដែលជាភរិយាអំពីដើម គឺស្រីជាភរិយាក្នុងកាលមុន គឺក្នុងគ្រាដែលជាគ្រហស្ថ ។ អធិប្បាយ

ថា បានដល់ កិរិយាដែលធ្លាប់ជាស្រីរួមក្នុងការសេពសុខដែលអាស្រ័យផ្ទះ ។

បទថា **តេនហិ** សេចក្ដីថា ព្រោះមិនមានគ្រឿងចងដទៃ ដូចជាមាតុ-គ្រាមនេះឡើយ ។

ពីរបទថា **ចាទេសុ គហេត្វា** សេចក្ដីថា កិរិយាចាស់បានចាប់ជើងទាំង ២ ( របស់សុទិន្ន ) ។ បទថា **ចាទេសុ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ មួយ៉ាងទៀត សេចក្ដីថា កិរិយាចាស់បានចាប់សុទិន្នភិក្ខុនោះត្រង់ជើងទាំងពីរ ។

សួរថា ព្រោះហេតុអ្វី ទើបកិរិយាចាស់ពោលនឹងសុទិន្នភិក្ខុយ៉ាងនេះថា បពិត្រអយ្យបុត្រ លោកប្រព្រឹត្តព្រហ្មចរិយធម៌ព្រោះហេតុនៃស្រីអប្សរទាំង-ឡាយណា ស្រីទេពអប្សរទាំងឡាយនោះ មានទ្រង់ទ្រាយប្រពៃដូចម្ដេចទៅ ឆ្លើយថា ព្រោះបានឮថា ក្នុងកាលនោះ មហាជនមិនស្គាល់គុណនៃបព្វជ្ជា កាលឃើញខត្តិយកុមារខ្លះ ព្រាហ្មណកុមារខ្លះ កូនសេដ្ឋីខ្លះជាច្រើន ដែលនាំគ្នាលះមហាសម្បត្តិ ហើយចេញបួស ទើបសន្ទនាគ្នាថា ព្រោះហេតុអ្វី ទើបខត្តិយកុមារជាដើមនោះចេញបួស គ្រានោះ ពួកជនដទៃក៏និយាយថា ខត្តិយ-កុមារជាដើមទាំងនោះចេញបួស ព្រោះហេតុនៃទេពអប្សរទាំងឡាយ ដែលជា **ទេពឆាជកា** ( ទេពធីតារបាំ ) ។ ពាក្យនោះ ត្រូវជនទាំងនោះបានឲ្យផ្សាយខ្ចរខ្ចាយទៅហើយ ( តាមរឿងព្រះនន្ទ ) ។ កិរិយាចាស់របស់សុទិន្ននោះ បានកាន់យកពាក្យនោះ ទើបបានពោលយ៉ាងនោះ ។

ព្រះថេរៈ កាលជំទាស់ពាក្យរបស់កិរិយាចាស់នោះ ទើបបានពោលថា

**ន ខោ អហំ ភគិនិ** ជាដើម សេចក្តីថា ម្នាលប្អូនស្រី អាត្មាមិនបានប្រព្រឹត្តព្រហ្មចរិយៈ ព្រោះហេតុនៃស្រីទេពអប្សរឡើយ ។

បទថា **សមុទាចរតិ** សេចក្តីថា រមែងហៅ គឺរមែងពោល ។

ប្រើនបទថា **តត្ថេវ មុច្ឆិតា បបតា** សេចក្តីថា កិរិយាចាស់ព្ទុសុទិន្នទោះហៅខ្លួនដោយពាក្យថា ប្អូនស្រី ទើបគិតក្នុងចិត្តថា ឥឡូវនេះ បងសុទិន្ននេះមិនត្រូវការអញ បានសម្គាល់អញដែលជាកិរិយាពិតៗ ដូចជាក្មេងស្រីដែលដេកក្នុងផ្ទៃមាតារួមគ្នា ក៏កើតសេចក្តីសោកជាកម្លាំង ហើយឱនជ្រប់សន្លប់នៅក្នុងទីត្រង់នោះឯង ។

ប្រើនបទថា **មា នោ វិហេឋយិត្ថ** សេចក្តីថា សុទិន្នពោលនឹងបិតាថា ញោមប្រុសកុំចង្អុលប្រាប់ និងបញ្ជូនមាតុគ្រាមមកបៀតបៀនអាត្មាឡើយ ពិតហើយ វាចានោះធ្វើឲ្យលំបាកដល់បព្វជិត ។

## មាតាសូមពូជអំពីសុទិន្ន

មាតារបស់សុទិន្ន បាននិមន្តសុទិន្នទុកក្នុងការអភិរម្យ ដោយសេចក្តីថា បើដូច្នោះ ... ដូច្នេះ ដែលមាននៅក្នុងបទនេះថា សុទិន្នកូន បើដូច្នេះ សូមលោកអាណិត គ្រាន់តែឲ្យពូជបន្តិចចុះ គឺមាតាបានពោលថា បើសុទិន្ននៅត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយៈសោត សូមលោកប្រព្រឹត្តអន្តរាយបរិនិព្វានលើអាកាសចុះ តែសូមលោកឲ្យកូនប្រុស ម្នាក់ទុកជាពូជសម្រាប់តវង្សត្រកូលរបស់យើងចុះ ។

ប្រើនបទថា **មា នោ អបុត្តកំ សាបតេយ្យំ លិច្ឆវយោ អតិហារា-**

**បេសុំ** សេចក្ដីថា មាតារបស់សុទិន្នភិក្ខុពោលថា ព្រោះពួកយើងនៅក្នុងរជ្ជ-សម័យនៃស្ដេចលិច្ឆវី ដែលជារាជគណៈ អំណឹះឥតអំពីបិតារបស់លោក ស្ដេចលិច្ឆវីទាំងនោះ នឹងឲ្យរឹបអូសយកមត៌កនេះ គឺទ្រព្យសម្បត្តិរបស់ពួកយើងដ៏ច្រើនយ៉ាងនេះ ដែលមិនមានបុត្រ គឺប្រាសចាកកូន ដែលជាអ្នករក្សាទ្រព្យរបស់ត្រកូល នាំទៅខាងក្នុងព្រះរាជវាំងរបស់ព្រះអង្គ ដូច្នោះ ស្ដេចលិច្ឆវីទាំងនោះ កុំបីរឹបអូស គឺកុំបញ្ជាឲ្យរឹបអូសយកទ្រព្យសម្បត្តិនោះទៅឡើយ ។

សួរថា ព្រោះហេតុអ្វី ទើបសុទិន្នបានពោលយ៉ាងនេះថា ញោមស្រី ព្រោះរឿងនេះឯង អាត្មាអាចធ្វើបាន ។

ឆ្លើយថា បានឮថា សុទិន្ននោះគិតថា អញប៉ុណ្ណោះនឹងជាម្ចាស់របស់ទ្រព្យមត៌ករបស់មាតាជាដើមទាំងនោះ អ្នកដទៃរមែងមិនមាន មាតាជាដើមនោះក៏នឹងតាមចងអញជានិច្ចដើម្បីត្រូវការឲ្យរក្សាទ្រព្យមត៌ក ព្រោះហេតុនោះ អញនឹងមិនបានជាអ្នកមានសេចក្ដីខ្វល់ខ្វាយតិច បំពេញសមណធម៌ឡើយ ឯលោកទាំងនេះ កាលបានឃើញកូនប្រុសហើយ នឹងវៀរ ( ការតាមចងអញ ) បន្ទាប់អំពីនោះ អញនឹងបានបំពេញសមណធម៌តាមសប្បាយ កាល ( លោក ) សម្លឹងឃើញន័យនេះ ទើបពោលយ៉ាងនោះ ។

## ស្ត្រីមានរដូវរួចក៏តាំងគភ៌

[ ១៧ ] ពាក្យថា **បុប្ផំ** នេះ ជាឈ្មោះនៃលោហិតដែលកើតក្នុងពេលមាតុគ្រាមមានរដូវ ។ ពិតហើយ ក្នុងវេលាដែលមាតុគ្រាមមានរដូវ ក្រពេញ

មានពណ៌ក្រហម តាំងឡើងក្នុងកន្ទែងដែលតាំងគភ៌ ( ក្នុងស្បូន ) ហើយចម្រើនឡើងរហូត ៧ ថ្ងៃ ក៏បែកធ្លាយទៅ លោហិតក៏ហូរចេញអំពីក្រពេញឈាមដែលបែកធ្លាយទៅហើយនោះ ។ ពាក្យថា **បុប្ផំ** នោះ ជាឈ្មោះនៃលោហិតនោះ ។

ម្យ៉ាងទៀត លោហិតនោះជារបស់មានកម្លាំង នៅហូរចេញមកច្រើនត្រឹមណា បដិសន្ធិ ( របស់សត្វដែលកើតក្នុងគភ៌ ) ដែលបិតាឲ្យហើយ ក៏តាំងនៅមិនបានដរាបនោះ គឺ រមែងហូរចេញព្រមគ្នានឹងទោស ( មន្ទិលនៃលោហិត ) នោះឯង ក៏កាលទោស ( មន្ទិលនៃលោហិត ) ហូរចេញហើយ បដិសន្ធិ ( របស់សត្វដែលកើតក្នុងគភ៌ ) ដែលបិតាឲ្យហើយ ក្នុងវត្ថុ ( សម្បុកពង ) ដែលបរិសុទ្ធ ក៏តាំងឡើងបានដោយឆាប់រហ័ស ។

ពីរបទថា **បុប្ផំសា ឧប្បជ្ជតិ** សេចក្ដីថា ក្រពេញឈាមកើតឡើងដល់ភរិយាចាស់របស់សុទិន្ននោះហើយ ។ គប្បីជ្រាបការលុបបទសំយោគ ព្រមនឹងការលុប **អ** អក្ខរៈចេញ ។

ច្រើនបទថា **បុរាណទុតិយិកាយ ពាហាយំ គហេត្វា** សេចក្ដីថា សុទិន្នចាប់ភរិយាចាស់នោះត្រង់ដើមដៃទាំងពីរនោះ ។

ពីរបទថា **អប្បញ្ញត្តេ សិក្ខាបទេ** សេចក្ដីថា ព្រោះបឋមបារាជិកសិក្ខាបទ ទ្រង់មិនទាន់បានបញ្ញត្តទុក ។

## ទ្រង់បញ្ញត្តបឋមបារាជិកក្នុងវស្សាទី ២០

បានឮថា ក្នុងបឋមពោធិកាលនៃព្រះដ៏មានព្រះភាគ ភិក្ខុទាំងឡាយបាន

ផ្គងចិត្តឲ្យព្រះដ៏មានព្រះភាគត្រេកអរហើយ រហូត ២០ ឆ្នាំ មិនបានធ្វើអជ្ឈាចារ ( ការប្រព្រឹត្តកន្លង ) បែបនេះ ( ឲ្យកើតឡើងឡើយ ) ។ ព្រះដ៏មានព្រះភាគ ទ្រង់សំដៅយកអជ្ឈាចារនោះឯង ទើបត្រាស់សូត្រនេះថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុបានញុំាងចិត្តតថាគតឲ្យត្រេកអរ ក្នុងសម័យមួយហើយ ។

គ្រានោះ ព្រះដ៏មានព្រះភាគ កាលទ្រង់មិនសម្លឹងឃើញអជ្ឈាចារ ទើបទ្រង់មិនបានបញ្ញត្តបារាជិក ឬសង្ឃាទិសេស តែទ្រង់បានបញ្ញត្តពួកអាបត្តិតូចតាចដ៏សេសទុកត្រឹម ៥ កងប៉ុណ្ណោះ ក្នុងរឿងនោះៗ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរបានពោលទុកថា ព្រោះសិក្ខាបទទ្រង់មិនទាន់បានបញ្ញត្ត ។

បទថា **អាណាឌីនវនសេ្សា** សេចក្តីថា សុទិន្នកាលមិនសម្លឹងឃើញបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទ ចង្អុលទោសទុកក្នុងកាលឥឡូវ ទើបជាបុគ្គលមានការសម្គាល់ ( ក្នុងការសេពមេថុនធម្មនោះ ) ថា មិនមានទោស ។ ពិតហើយ បើសុទិន្ននេះគប្បីដឹងថា របស់នេះមិនគួរធ្វើ ឬរបស់ដែលធ្វើនេះ រមែងប្រព្រឹត្តទៅដើម្បីមូលច្ឆេទ ( កាត់ផ្តាច់ឫសគល់ ) ដូច្នេះសោត កុលបុត្រដែលបួសដោយសទ្ធា សូម្បីដល់ការអស់ជីវិតទៅ ការមានកម្មនោះជាហេតុ ក៏នឹងមិនគប្បីធ្វើ តែលោកកាលមិនសម្លឹងឃើញទោសក្នុងការសេពមេថុនធម្មនេះ ទើបបានជាអ្នកមានការសម្គាល់ថា មិនមានទោស ។ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរបានពោលទុកថា ជាអ្នកមានសេចក្តីយល់ថា មិនមានទោស ។

បទថា **បុរាណទុតិយិកាយ** នេះ ជាសត្តមីវិភត្តិ ។

បទថា **អភិវិញ្ញាបេសិ** គឺឲ្យប្រព្រឹត្តទៅហើយ ។

ពិតហើយ សូម្បីការឲ្យប្រព្រឹត្តទៅ លោកហៅថា **វិញ្ញាបនា** ព្រោះញុំាងកាយវិញ្ញត្តិឲ្យកម្រើក ។ ឯសុទិន្ននេះ បណ្ឌិតគប្បីជ្រាបថា បានធ្វើការញុំាងកាយវិញ្ញត្តិឲ្យកម្រើកដល់ទៅ ៣ ដង ដើម្បីការដាក់ចិត្តចុះ និងឲ្យតាំងគភ៌ ។

ច្រើនបទថា **សា តេន គព្ភំ គណ្ហិ** សេចក្ដីថា សូម្បីកិរិយាចាស់របស់សុទិន្ននោះ ក៏តាំងគភ៌ព្រោះអជ្ឈាចារនោះឯង មិនបានតាំងគភ៌ដោយប្រការដទៃឡើយ ។

## ហេតុដែលឲ្យស្ត្រីតាំងគភ៌មាន ៧ យ៉ាង

សួរថា ការតាំងគភ៌រមែងមានដោយប្រការដទៃឬ ឆ្លើយថា រមែងមានបាន សួរថា រមែងមានបានដូចម្ដេច ឆ្លើយថា រមែងមានបាន ព្រោះការស្ទាបអង្អែលកាយ ១ ព្រោះការចាប់សំពត់ ( ស្បៀកដណ្ដប់ ) ១ ព្រោះការផឹកទឹកអសុចិ ១ ព្រោះការស្ទាបអង្អែលផ្ចិត ១ ព្រោះការសម្លឹងមើល ១ ព្រោះសំឡេង ១ ព្រោះក្លិន ១ ។

ពិតហើយ ស្ត្រីទាំងឡាយពួកខ្លះ ជាអ្នកមានតម្រេកដោយឆន្ទរាគៈក្នុងវេលាដែលខ្លួនមានរដូវ កាលត្រេកអរក្នុងការដែលបុរសចាប់ដៃ ចាប់ផ្នួងសក់ និងការស្ទាបអង្អែលអវយវៈតូចធំ រមែងតាំងគភ៌បាន ។ ការតាំងគភ៌រមែងមានបាន ព្រោះការស្ទាបអង្អែលកាយ ដោយប្រការយ៉ាងនេះ ។

ម្យ៉ាងទៀត ភិក្ខុនីជាកិរិយាចាស់របស់ព្រះឧទាយិត្ថេរ យកមាត់លិទ្ធ

ទឹកអសុចិនោះទុកមួយចំណែក មួយចំណែកទៀត ដាក់ចូលក្នុងអង្គជាត រួមជាមួយសំពត់នោះឯង ។ នាងក៏តាំងគភ៌បាន ព្រោះហេតុនោះ ។ ការតាំងគភ៌រមែងមានព្រោះការចាប់សំពត់ ( ស្លៀកដណ្តប់ ) ដោយអាការយ៉ាងនេះ ។

សូម្បីម្រឹគដែលជាម្តាយរបស់មិគសិង្គតាបស បានមកកាន់ទីកន្លែងបន្ទោបង់បស្សាវៈរបស់តាបស ក្នុងវេលាដែលខ្លួនមានរដូវ ហើយបានផឹកទឹកបស្សាវៈ ដែលមានទឹកសម្ភវលាយឡំ ។ មេម្រឹគនោះក៏តាំងគភ៌ ហើយកើតកូនជាមិគសិង្គតាបស ព្រោះហេតុដែលខ្លួនផឹកទឹកបស្សាវៈនោះ ។ ការតាំងគភ៌ រមែងមានព្រោះការផឹកទឹកអសុចិ ដោយអាការយ៉ាងនេះ ។

មួយទៀត សក្កទេវរាជទ្រង់ជ្រាបមាតាបិតារបស់សាមតាបសពោធិសត្វ ត្រូវខ្វាក់ភ្នែក មានបំណងនឹងប្រទានបុត្រ ( ដល់តាបសទាំងពីរនោះ ) ទើបទ្រង់ប្រាប់ទុកូលបណ្ឌិត ( ជាបិតា ) ថា មេថុនធម្មគួរដល់លោកទាំងពីរ ឬ ទុកូលបណ្ឌិតឆ្លើយថា អាត្មាភាពទាំងពីរបួសជាឥសីហើយ មិនត្រូវការដោយមេថុននោះឡើយ សក្កទេវរាជប្រាប់ថា បើដូច្នោះ ក្នុងវេលាដែលនាងបារិកាតាបសិនីនេះមានរដូវ លោកគប្បីយកម្រាមដៃស្ទាបអណ្តែលផ្ចិត ( របស់នាង ) ចុះ ។

ទុកូលបណ្ឌិតបានធ្វើយ៉ាងនោះហើយ ។ នាងបារិកាតាបសិនីនោះ ក៏តាំងគភ៌ ហើយប្រសូតទារកឈ្មោះសុវណ្ណសាមតាបស ព្រោះស្ទាបអណ្តែលផ្ចិតនោះ ។ ការតាំងគភ៌ រមែងមានព្រោះការស្ទាបផ្ចិត ដោយអាការយ៉ាងនេះ ។ ដោយន័យនេះឯង គួរជ្រាបរឿងមណ្ឌព្យមាណព និងរឿងព្រះបាទ

ចណ្ឌប្បជ្ជោតផងដែរ ។

សួរថា ការតាំងគភ៌ រមែងមានព្រោះការសម្លឹងមើល ( រូប ) ដូចម្តេច ឆ្លើយថា ស្ត្រីពួកខ្លះក្នុងលោកនេះ ក្នុងពេលដែលខ្លួនមានរដូវ កាលមិនបានបបោសអង្អែលជាមួយបុរស ទើបចូលទៅក្នុងផ្ទះសម្លឹងមើលបុរសដោយអំណាចតម្រេក ពេញចិត្ត ( ហើយក៏តាំងគភ៌ ) ដូចស្រីស្នំអ្នករាជវាំងដូច្នោះ ។ នាងរមែងតាំងគភ៌ ព្រោះការសម្លឹងមើលបុរសនោះ ។ ការតាំងគភ៌ រមែងមានព្រោះការសម្លឹងមើលរូប ដោយអាការយ៉ាងនេះ ។

មួយទៀត បណ្តាសត្វកុកទាំងឡាយ ឈ្មោះថា កុកឈ្មោលរមែងមិនមាន ។ កុកញីទាំងនោះ ក្នុងវេលាដែលខ្លួនមានរដូវ បានស្តាប់សំឡេងមេឃគំរាម ( ផ្គរលាន់ ) ហើយ រមែងតាំងគភ៌ សូម្បីមេមាន់ទាំងឡាយ ដោយច្រើនក៏ដូចគ្នា ក្នុងកាលខ្លះបានស្តាប់សំឡេងមាន់ឈ្មោល ( រងាវ ) ក៏រមែងតាំងគភ៌ ។ សូម្បីមេគោទាំងឡាយ កាលបានស្តាប់សំឡេងគោឧសភៈហើយក៏រមែងតាំងគភ៌យ៉ាងនោះ ។ ការតាំងគភ៌រមែងមាន ព្រោះសំឡេង ដោយអាការយ៉ាងនេះ ។

មួយទៀត មេគោទាំងឡាយនោះឯង ក្នុងកាលខ្លះ រមែងតាំងគភ៌បានព្រោះក្លិនរបស់គោឈ្មោល ។ ការតាំងគភ៌ រមែងមានព្រោះក្លិន ដោយអាការយ៉ាងនេះ ។

ចំណែកក្នុងរឿងនេះ កិរិយាចាស់របស់សុទិន្ននេះ រមែងតាំងគភ៌ព្រោះអជ្ឈាចារ ដូចព្រះដ៏មានព្រះភាគ ទ្រង់សំដៅយកដោយត្រាស់ទុកថា ម្នាល

ភិក្ខុទាំងឡាយ លុះតែកាលណា មាតាបិតាមកប្រជុំគ្នាផង មាតាជាស្រីមានរដូវផង សត្វដែលគួរកើតក៏មានប្រាកដក្នុងឱកាសនោះផង លុះប្រជុំហេតុទាំង ៣ ប្រការនេះឯង ទើបសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាបាន ។

## ទេវតាប្រកាសកម្មអាក្រក់របស់សុទិន្ន

[ ១៨ ] ប្រើនបទថា **កុម្មា ទេវា សទ្ទមនុស្សាវេសុំ** ឈ្មោះថា អាថ៌-កំបាំងរបស់អ្នកធ្វើកម្មអាក្រក់ រមែងមិនមានក្នុងលោក ពិតហើយ ខ្លួនរបស់ជនអ្នកធ្វើអាក្រក់នោះ រមែងដឹងកម្មអាក្រក់ ( ដែលខ្លួនធ្វើនោះ ) មុនបុគ្គលដទៃទាំងអស់ បន្ទាប់អំពីនោះ អារក្ខទេវតាទាំងឡាយ រមែងដឹងខាងក្រោយបន្ទាប់មក ទេវតាពួកដទៃដែលដឹងចិត្តរបស់បុគ្គលដទៃក៏រមែងដឹង ព្រោះហេតុនោះ កុម្មទេវតាទាំងឡាយដែលអាស្រ័យនៅក្នុងដងព្រៃទាំងអស់ ដែលជាអ្នកដឹងចិត្តរបស់បុគ្គលដទៃ ឃើញអជ្ឈាចាររបស់សុទិន្ននោះ ក៏បានបន្លឺសំឡេងឲ្យលាន់ឮឡើង គឺបានបន្លឺសំឡេងដោយអាការដែលទេវតាពួកដទៃនឹងបានឮ ។

សួរថា បានឮដូចម្ដេច ឆ្លើយថា បានឮដូច្នេះថា លោកដ៏ចម្រើន ឱភិក្ខុសង្ឃមិនដែលមានពុត មិនមានទោស ( តែ ) សុទិន្នកលន្ទបុត្រ ធ្វើនូវពុតនិងទោសឡើងហើយ ។ អត្ថនៃពាក្យថា មិនមានពុតជាដើមនោះ បណ្ឌិតគប្បីជ្រាបដោយន័យដូចខ្ញុំពោលទុកហើយ ក្នុងវេរញ្ជកណ្ឌនោះឯង ។

ម្យ៉ាងទៀត ក្នុងពាក្យថា **កុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហា-រាជិកា** នេះ គប្បីជ្រាបលំដាប់ដូច្នេះថា អាកាសដ្ឋទេវតាទាំងឡាយ បាន

ស្តាប់សំឡេងនៃភុម្មទេវតាហើយ ទេវតាជាន់ចាតុម្មហារាជទាំងឡាយបាន ស្តាប់សំឡេងពួកអាកាសដ្ឋទេវតាហើយ ដូច្នេះជាដើម ។

បទថា **ព្រហ្មកាយិកា** សេចក្តីថា ព្រហ្មទាំងអស់ វៀរពួកអសញ្ញីសត្វ និងពួកអរូបាវចរចេញ គប្បីជ្រាបថា បានស្តាប់ហើយ កាលបានស្តាប់ហើយ ក៏បានបន្លឺសំឡេងឲ្យលាន់ឮហើយ ។

ប្រើនបទថា **ឥតិហ តេន ខណេន** សេចក្តីថា មួយជួរខណៈនៃ អជ្ឈាចាររបស់សុទិន្នភិក្ខុនោះ ដោយអាការយ៉ាងនេះ ។

ពីរបទថា **តេន មុហុត្តេន** សេចក្តីថា មួយរំពេចនៃអជ្ឈាចារនោះឯង

ពីរបទថា **យាវ ព្រហ្មលោកា** សេចក្តីថា ( សំឡេងបានផ្សាយឡើង ទៅហើយ ) រហូតដល់អកនិដ្ឋកព្រហ្មលោក ។

បទថា **អព្ភុគ្គញ្ឆិ** ប្រែថា បានឮសុសសាយឡើងទៅហើយ គឺបានតាំង ឡើងហើយ សេចក្តីថា មានសំឡេងទ្រហឹងអឺងកងដូចគ្នាហើយ ។

ពីរបទថា **បុត្តំ វិជាយិ** សេចក្តីថា ភរិយាចាស់របស់សុទិន្នបានឲ្យ បច្ឆិមភវិកសត្វ ដែលដូចជាពុម្ពមាសកើតហើយ ។

ប្រើនបទថា **ពីជកោតិ នាមំ អកំសុ** សេចក្តីថា ពួកសម្លាញ់សុទិន្ន មិនព្រមឲ្យដាក់ឈ្មោះដទៃ គឺបាននាំគ្នាដាក់ឈ្មោះថា ពីជកៈ ( កុមារពូជ ) ដោយយល់ឃើញស្របគ្នាថា ទារកនោះ ចូរមានឈ្មោះថា កុមារពូជប៉ុណ្ណោះ ព្រោះហេតុនៃពាក្យដែលជីដូនបានពោលសូមថា អ្នកចូរឲ្យត្រឹមតែពូជចុះ ដូច្នេះ ប្រាកដច្បាស់ហើយ ។ ពួកសម្លាញ់ក៏បានតាំងឈ្មោះឲ្យដល់មាតាបិតានៃពីជក-

កុមារនោះ ដោយអំណាចឈ្មោះបុត្រដូចគ្នា ( ពីជកបិតា ពីជកមាតា ) ។

ពាក្យថា **តេ អបរេន សមយេន** នេះ លោកពោលសំដៅយក ពីជក-កុមារ និងម្តាយរបស់ពីជកៈនោះ ។

## មាតា និង ពីជកកុមារបួសហើយ បានសម្រេចអរហត្ត

បានឮថា ក្នុងពេលដែលពីជកៈ មានអាយុ ៧-៨ ឆ្នាំ មាតារបស់ពីជកៈបានបួសក្នុងសម្នាក់ភិក្ខុនី ឯពីជកកុមារនោះ ក៏បានបួសក្នុងសម្នាក់ភិក្ខុ បានអាស្រ័យសព្រហ្មចារី ដែលជាកល្យាណមិត្ត ក៏បានតាំងនៅក្នុងអរហត្តហើយ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា បុគ្គលទាំងពីរបាន ចេញអំពីផ្ទះបួសជាបព្វជិត បានធ្វើអរហត្តឲ្យជាក់ច្បាស់ហើយ ។ បព្វជ្ជា របស់មាតា និងបុត្រ មានផលហើយ ដោយប្រការដូច្នេះ ។

## សុទិន្នភិក្ខុក្តៅក្រហាយចិត្ត ព្រោះប្រព្រឹត្តអាក្រក់

[ ១៨ ] ចំណែកបិតារបស់ពីជកកុមារនោះ ត្រូវវិប្បដិសារៈគ្របសង្កត់ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលពាក្យថា **អថខោ អាយស្មតោ សុទិន្នស្ស អហុទេវ កុក្កុច្ចំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អហុទេវ** ប្រែថា កើតមានដល់នោះឯង ឥ អក្ខរៈ ធ្វើការភ្ជាប់បទប៉ុណ្ណោះ ។ សេចក្តីថា មានហើយនោះឯង ។

ការតាមក្តៅក្រហាយក្នុងកាលខាងក្រោយ ដែលមានអជ្ឈាចារជាហេតុ ឈ្មោះថា ការក្តៅក្រហាយ ។ សូម្បីពាក្យថា **វិប្បដិសារោ** ក៏ជាឈ្មោះនៃ ការតាមក្តៅក្រហាយក្នុងកាលខាងក្រោយនោះឯង ។

ពិតហើយ ការតាមក្តៅក្រហាយក្នុងកាលខាងក្រោយនោះ លោកហៅថា **កុក្កុច្ច** ( ការស្តាយក្រោយ ) ដោយភាពជាកិរិយា ដែលបណ្ឌិតគប្បីខ្ពើម ព្រោះភាពជាកម្មដែលបណ្ឌិតទាំងឡាយ មិនគប្បីធ្វើ លោកហៅថា **វិប្បដិសារ** ( ការក្តៅក្រហាយ ) ដោយជាការរឭកខុសប្រក្រតីទៅ ព្រោះអាស្រ័យអជ្ឈាចារនោះ ព្រោះមិនអាចនឹងហាមឃាត់អជ្ឈាចារដែលខ្លួនធ្វើហើយបាន ។

ព្រើនបទថា **អលាភា វត មេ** សេចក្តីថា មិនមែនជាលាភរបស់អញហ្ន៎ ។ អធិប្បាយថា ដែលឈ្មោះថា ការមិនបាននូវគុណទាំងឡាយមានឈានជាដើមនោះ មិនមែនជាលាភរបស់អញផង ទាំងមិនមែនជាលាភរបស់អ្នកដទៃផង ។

ព្រើនបទថា **ន វត មេ លាភា** សេចក្តីថា គុណ គឺបព្វជ្ជា សរណគមន៍ និងសមាទានសិក្ខាពួកណា ដែលអញបានចំពោះហើយ គុណ គឺបព្វជ្ជាជាដើមនោះ ឈ្មោះថា មិនមែនលាភរបស់អញឡើយ ព្រោះមានអជ្ឈាចារសៅហ្មង ។

ព្រើនបទថា **ទុល្លទ្ធំ វត មេ** សេចក្តីថា ព្រះសាសនានេះ សូម្បីអញបានហើយ ក៏ឈ្មោះថា អញបានដោយអាក្រក់ ។

ព្រើនបទថា **ន វត មេ សុលទ្ធំ** សេចក្តីថា ព្រះសាសនានេះ អញបានមិនល្អដូចកុលបុត្រដទៃគេបានហ្ន៎ ។ ព្រោះហេតុអ្វី ព្រោះអញបួសក្នុងធម្មវិន័យដែលព្រះដ៏មានព្រះភាគ ត្រាស់ទុកល្អហើយយ៉ាងនេះ នៅមិនអាច

ប្រព្រឹត្តព្រហ្មចរិយៈឲ្យបរិបូណ៌បរិសុទ្ធបាន រហូតអស់ជីវិតដូច្នេះ ។

បទថា **ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈដែលលោកសង្គ្រោះដោយត្រៃសិក្ខា ។

ពីរបទថា **កិសោ អហោសិ** សេចក្ដីថា សុទិន្នភិក្ខុនោះ កាលមិនអាចនឹងទំពាស៊ី ឬធាន់អាហារ ទើបបានជាបុគ្គលស្គមស្គាំង គឺមានសាច់ និងឈាមតិច ។

បទថា **ឧប្បណ្ឌុប្បណ្ឌុកជាតោ** បានដល់ ភាពជាបុគ្គលមានសម្បុរលឿងកើតឡើង គឺជាអ្នកមានចំណែកប្រៀបដូចស្លឹកឈើពណ៌លឿង ។

បទថា **ធមនិសន្ថតគត្តោ** បានដល់ អ្នកមានខ្លួនរវាមដោយសរសៃនោះឯង ព្រោះជាបុគ្គលមានសាច់ និងឈាមអស់ទៅ ។

បទថា **អន្តោមនោ** បានដល់ អ្នកមានគំនិតតាំងនៅខាងក្នុងនោះឯង ( បុគ្គលមានរឿងក្នុងចិត្ត ) ដោយអំណាចសេចក្ដីទុក្ខព្រួយដល់រឿងនោះ ។ម្យ៉ាងទៀត សត្វលោកទាំងអស់ ឈ្មោះថាជាអ្នកមានចិត្តនៅខាងក្នុងនោះឯង ( គិតនៅតែក្នុងចិត្ត ) ដោយអំណាចការប្រព្រឹត្តទៅអាស្រ័យហទយវត្ថុ ។

បទថា **លីនមនោ** បានដល់ អ្នកដាក់ចុះនូវធុរៈ គឺអ្នកមិនមានការខ្នះ-ខ្នែងក្នុងឧទ្ទេស បរិបុច្ឆា កម្មដ្ឋាន អធិសីល អធិចិត្ត អធិប្បញ្ញា និងការបំពេញវត្ត និងកិច្ចវត្ត ។ ឈ្មោះថា ជាអ្នកមានចិត្តរួញរា ព្រោះអត្ថថា ចិត្តរបស់បុគ្គលនោះរួញរា គឺរួញថយក្រោយដោយអំណាចកោសជ្ជៈដោយពិតនោះឯង ។

បទថា **ទុក្ខី** បានដល់ ជាអ្នកមានទុក្ខ ព្រោះទុក្ខផ្លូវចិត្ត ។

បទថា **ទុម្មនោ** បានដល់ អ្នកមានចិត្តដែលទោសប្រទូស្តហើយ ឬអ្នកមានចិត្តខុសប្រក្រតី ព្រោះភាពជាបុគ្គលត្រូវទោមនស្សគ្របសង្កត់ ។

បទថា **បជ្ឈាយិ** សេចក្តីថា សុទិន្នភិក្ខុគិតដល់កម្មអាក្រក់ដែលខ្លួនធ្វើហើយនោះ ដោយអំណាចការក្តៅក្រហាយ ( សោកសៅ ) ដូចសត្វលាដែលគេកាត់ចេញអំពីការៈហើយ សោកសៅ ។

ពីរបទថា **សហាយកា ភិក្ខូ** សេចក្តីថា ភិក្ខុទាំងឡាយ ដែលសួរដល់ផាសុក ដែលជាអ្នកស្និទ្ធស្នាលរបស់សុទិន្នភិក្ខុ ឃើញសុទិន្នភិក្ខុនោះជាអ្នកកើតហើយ មានសភាពយ៉ាងនោះ ដែលបណ្តោយឲ្យថ្ងៃ និងយប់កន្លងទៅ ដោយធម៌ជាគ្រឿងយឺតយូរ គឺការប្រឡូកប្រឡំដោយពួកគណៈ ទើបពោលពាក្យនេះនឹងសុទិន្នភិក្ខុនោះ ។

បទថា **បីណិន្ទ្រិយោ** សេចក្តីថា អ្នកមានចក្ខុន្ទ្រិយជាដើមពោរពេញព្រោះឱកាសដែលជាទីតាំងនៃបសាទបរិបូណ៌ ។

សព្ទថា **ធានិ** ដែលមាននៅក្នុងពាក្យថា **សោធានិ ត្វំ** នេះ ជានិបាត លោកពោលអធិប្បាយទុកថា **សោ បន ត្វំ** ដែលប្រែថា ឯអ្នកឯង ( ស្តាំងស្តម ) ។

ច្រើនបទថា **កច្ចិ នោ ត្វំ** គឺ **កច្ចិ នុ ត្វំ** ដែលប្រែថា អ្នកមិនត្រេកអរប្រព្រឹត្តព្រហ្មចរិយៈ ទេឬ ។

បទថា **អនភិរតោ** ប្រែថា ជាអ្នកមិនត្រេកអរ អធិប្បាយថា ជាអ្នក

ប្រាថ្នាភាពជាគ្រហស្ថ ។

ព្រោះហេតុនោះ សុទិន្នភិក្ខុ កាលនឹងបដិសេធការមិនត្រេកអរនោះឯង ទើបពោលថា អាវុសោទាំងឡាយ តាមពិត មិនមែនខ្ញុំមិនត្រេកអរ (ប្រព្រឹត្តព្រហ្មចរិយៈ) ។ អធិប្បាយថា ខ្ញុំត្រេកអរនោះឯងក្នុងការចម្រើនកុសលធម៌ដ៏ក្រៃលែង ។

ត្រង់បទថា **អត្ថិ មេ បាបកម្មំ កតំ** សេចក្តីថា បាបកម្មឯណាមួយដែលខ្ញុំធ្វើមានហើយ គឺខ្ញុំបានទទួល បានដល់ មានប្រាកដដល់ខ្ញុំជានិច្ច ដូចមានចំពោះមុខដូច្នោះ ។

បន្ទាប់អំពីនោះ សុទិន្នភិក្ខុ កាលនឹងប្រកាសបាបកម្ម ដែលខ្លួនធ្វើហើយនោះ ( ដល់ភិក្ខុជាសម្លាញ់ ) ទើបបានពោលពាក្យជាដើមថា **បុរាណទុតិយិកាយ** ដូច្នេះ ។

ត្រង់បទថា **អលំ ហិ តេ អាវុសោ សុទិន្ន កុក្កុច្ចាយ** សេចក្តីថា អាវុសោសុទិន្ន បាបកម្មនោះរបស់លោក ល្មម គឺអាចឲ្យលោកក្តៅក្រហាយបាន អធិប្បាយថា ជារបស់អាចឲ្យកើតការសោកស្តាយ ។

ក្នុងពាក្យថា **យំ ត្វំ** ជាដើម គប្បីជ្រាបការភ្ជាប់សេចក្តីដូច្នេះថា លោកនឹងមិនអាចប្រព្រឹត្តព្រហ្មចរិយៈ ព្រោះកម្មអាក្រក់ណា កម្មអាក្រក់នោះរបស់លោក ល្មមឲ្យលោកក្តៅក្រហាយបាន ។

បន្ទាប់អំពីនោះ ពួកភិក្ខុជាសម្លាញ់ កាលនឹងជាស់តឿនសុទិន្នភិក្ខុនោះ ទើបពោលពាក្យជាដើមថា **ននុ អាវុសោ ភគវតា** ដូច្នេះ ។

បណ្ដាបទទាំងនោះ សព្ទថា **ឧទ** ជានិបាត ចុះក្នុងអត្ថ អនុមតិ និងតិះដៀល ។

បទថា **អនេកបរិយាយេន** ប្រែថា ដោយហេតុមិនមែនតែមួយ ។

បទថា **វិរាគាយ** ប្រែថា ដើម្បីប្រាសចាកតម្រេក ។

ពីរបទថា **នោ សរាគាយ** សេចក្ដីថា មិនមែនដើម្បីឲ្យប្រកបដោយរាគៈឡើយ អធិប្បាយថា ពិតហើយ ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្ដែងហើយ ដើម្បីប្រយោជន៍នៃការប្រាសចាកតម្រេកនោះថា សត្វទាំងឡាយបានស្ដាប់ធម៌របស់តថាគតនេះហើយ នឹងបន្ទោបង់នូវតម្រេក គឺនឹងមិនត្រេកអរក្នុងភព និងភោគសម្បត្តិទាំងពួង ។ ក្នុងបទទាំងពួងក៏មានន័យដូច្នោះ ។

ឯពាក្យថា **វិសំយោគាតិ កិលេសេហិ វិសំយុជ្ជនត្ថាយ** នេះ ដែលមានក្នុងបទថា **វិសំយោគាយ** ជាដើមនេះ ត្រឹមតែជាការពោលដោយន័យអមប៉ុណ្ណោះ ។

បទថា **វិសំយោគាយ** សេចក្ដីថា ដើម្បីប្រាសចាកការប្រកបដោយកិលេសទាំងឡាយ ។

ពីរបទថា **នោ សំយោគាយ** សេចក្ដីថា មិនមែនដើម្បីប្រកប ( ដោយកិលេសទាំងឡាយ ) ។

បទថា **អនុបាទានាយ** សេចក្ដីថា ដើម្បីការមិនប្រកាន់មាំ ។

ពីរបទថា **នោ សឧបាទានាយ** សេចក្ដីថា មិនមែនដើម្បីការប្រកាន់មាំ ។

ច្រើនបទថា **តត្ថ នាម ត្វំ** សេចក្ដីថា កាលធម៌ឈ្មោះនោះ ( ដែល

ព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដើម្បីខ្ជាក់ចោលនូវតម្រេក ) លោកនៅគិតដើម្បីរាគៈទៀតឬ ។

ពីរបទថា **សរាគាយ ចេតេស្សសិ** សេចក្តីថា លោកនៅគិត គឺនៅត្រិះរិះដើម្បីមេថុនធម្មដែលប្រព្រឹត្តទៅហើយ ព្រមដោយតម្រេកឬ អធិប្បាយថា លោកគង់នឹងនៅព្យាយាមដើម្បីមេថុនធម្មនោះឬ ក្នុងបទទាំងពួងមានន័យដូច្នេះ ។

## អធិប្បាយ ឈ្មោះព្រះនិព្វាន ៩ បទ

បទទាំង ៩ មាន **រាគវិរាគ** ជាដើម ព្រះដ៏មានព្រះភាគទ្រង់សំដៅយកព្រះនិព្វានជាលោកុត្តរធម៌ ដែលប្រាសចាកវដ្តៈនោះឯង ត្រាស់ទុកដដែលទៀត ។ ព្រោះហេតុនោះ កាលទ្រង់ត្រាស់ថា **រាគវិរាគាយ** ក្តី **មទនិម្មទ្ទនាយ** ក្តី បណ្ឌិតគប្បីឃើញអត្ថយ៉ាងនេះប៉ុណ្ណោះថា ដើម្បីប្រយោជន៍ដល់ព្រះនិព្វាន ។

ពិតហើយ ព្រះនិព្វាន ព្រះដ៏មានព្រះភាគត្រាស់ហៅថា ធម៌ជាទីខ្ជាក់ចោលនូវរាគៈ ព្រោះថា រាគៈមកដល់ គឺអាស្រ័យព្រះនិព្វាននោះហើយ រមែងប្រាសទៅ គឺមិនមាន ។

មួយវិញទៀត ព្រះនិព្វាន ទ្រង់ត្រាស់ថា ជាធម៌ស្វាងស្រវឹង ព្រោះថា ការស្រវឹងទាំងឡាយ មានការស្រវឹងដោយអំណាចមានះ និងបុរិសមានះជាដើម មកដល់ព្រះនិព្វាននោះហើយ រមែងស្វាងទៅ មិនស្រវឹង គឺសាបសូន្យទៅ ។

មួយវិញទៀត ព្រះនិព្វាន ទ្រង់ត្រាស់ថា ជាធម៌ដែលប្រាសចាកការស្រេក

ព្រោះថា ការស្រេកក្នុងកាមទាំងពួង មកដល់ព្រះនិព្វាននោះហើយ រមែងអស់ទៅ គឺវិនាសទៅ ។

ម្យ៉ាងទៀត ព្រះនិព្វាន ទ្រង់ត្រាស់ថា ជាធម៌ដកនូវអាល័យ ព្រោះថា អាល័យ គឺបញ្ចកាមគុណ កាលមកដល់ព្រះនិព្វានហើយ រមែងដល់នូវការដកទៅ ។

ម្យ៉ាងទៀត ព្រះនិព្វាន ទ្រង់ត្រាស់ថា ជាធម៌ដែលកាត់ផ្តាច់វដ្តៈ ព្រោះថា វដ្តៈមាន ៣ ភូមិ កាលមកដល់ព្រះនិព្វាននោះហើយ រមែងដាច់ទៅ ។

ម្យ៉ាងទៀត ព្រះនិព្វាន ទ្រង់ត្រាស់ថា ជាធម៌អស់តណ្ហា ធម៌ជាទីប្រាសចាករាគៈ ធម៌ជាទីរលត់ ព្រោះថា តណ្ហាកាលមកដល់ព្រះនិព្វាននោះហើយ រមែងដល់នូវការអស់ទៅ រមែងប្រាសទៅ និងរមែងរលត់ទៅ ដោយប្រការទាំងពួង ។

ម្យ៉ាងទៀត ព្រះនិព្វាននោះ ទ្រង់ត្រាស់ថា **និព្វាន** ព្រោះថា ចេញទៅ គឺផុតទៅ ប្រាសទៅចាកតណ្ហា ដែលបានវោហារថា **វាន** ព្រោះដោតក្រង គឺចងភ្ជាប់កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ដើម្បីការបន្តទៅរឿយៗ ដូច្នេះឯង ។

ប្រើនបទថា **កាមានំ បហានំ អក្ខាតំ** សេចក្តីថា ការលះវត្ថុកាម និងកិលេសកាមទាំងឡាយ ព្រះដ៏មានព្រះភាគត្រាស់ទុកហើយមិនមែនឬ ។

ពីរបទថា **កាមសញ្ញានំ បរិញ្ញា** សេចក្តីថា ការកំណត់ដឹងអត្ថក្នុងកាមទាំងអស់ មាន ៣ យ៉ាង ដោយអំណាចញាតបរិញ្ញា ( កំណត់ដឹងដោយ

ការដឹង ) តីរណបរិញ្ញា ( កំណត់ដឹងដោយការពិចារណា ) និងបហានបរិញ្ញា( កំណត់ដឹងដោយការលះបង់ ) ព្រះដ៏មានព្រះភាគត្រាស់ហើយមិនមែនឬ ។

បទថា **កាមបិបាសានំ** សេចក្តីថា ការកម្ចាត់ភាពជាបុគ្គលប្រាថ្នាផឹកកាមទាំងឡាយ ឬការចង់ផឹកកាមទាំងឡាយ ព្រះដ៏មានព្រះភាគត្រាស់ហើយ មិនមែនឬ ។

បទថា **កាមវិតក្កានំ** សេចក្តីថា ការដកឡើងនូវវិតក្កៈទាំងឡាយដែលស្និទ្ធស្នាលក្នុងកាម ព្រះដ៏មានព្រះភាគត្រាស់ហើយមិនមែនឬ ។

បទថា **កាមបរិឡាហានំ** សេចក្តីថា ការស្ងប់នៃការក្តៅក្រហាយដែលកើតឡើងដោយអំណាចតម្រេក ដែលប្រកបដោយបញ្ចកាមគុណ បានដល់ ការរួបរឹតខាងក្នុង ព្រះដ៏មានព្រះភាគត្រាស់ហើយមិនមែនឬ ។

លោកុត្តរមគ្គ ដែលជាគ្រឿងធ្វើការអស់ទៅនៃកិលេស ព្រះដ៏មានព្រះភាគត្រាស់ទុកហើយក្នុងស្ថាន ៥ នេះ ។ តែមគ្គដែលលាយឡំគ្នាដោយលោកិយផង លោកុត្តរផង បណ្ឌិតគប្បីជ្រាបថា ព្រះដ៏មានព្រះភាគត្រាស់ទុកហើយក្នុងស្ថាន ៣ ដំបូង នៃស្ថានទាំងអស់នោះ ។

ពាក្យថា **នេតំ អាវុសោ** ជាដើម សេចក្តីថា អ្នកមានអាយុ កម្មលាមកនោះរបស់លោក រមែងមិនប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លានៃជនទាំងឡាយ ដែលនៅមិនទាន់ជ្រះថ្លា គឺដើម្បីប្រយោជន៍ដល់ការជ្រះថ្លារបស់ជនទាំងឡាយ ដែលមានសភាពបែបនោះឬ ។

បទថា **អជទេ្វឝំ** កាត់បទជា **អជទេ្វ ឝំ** ។ បាលីថា **អជទេ្វឝំ** ក៏មាន ។ បទថា **អញ្ញថត្តាយ** សេចក្តីថា ( កម្មអាក្រក់នោះរបស់លោក ) រមែងប្រព្រឹត្តទៅដើម្បីដោយប្រការដទៃអំពីការជ្រះថ្លា គឺដើម្បីការក្តៅក្រហាយ

អធិប្បាយថា រមែងធ្វើការក្តៅក្រហាយដល់ជនទាំងឡាយ ដែលមិនទាន់មានសទ្ធា មកក្នុងមគ្គថា យើងទាំងឡាយជ្រះថ្លាហើយក្នុងព្រះធម្មវិន័យឈ្មោះនេះ ដែលមានពួកភិក្ខុបដិបត្តិថោកថយ ។

ចំណែកការជ្រះថ្លារបស់ជនទាំងឡាយ ដែលមានសទ្ធាមកហើយដោយមគ្គ ជារបស់មិនញាប់ញ័រ ដោយរឿងដូច្នេះ ឬដោយរឿងអាក្រក់ក្រៃលែងជាងនេះ ដូចភ្នំសិនេរុមិនញាប់ញ័រដោយខ្យល់ ដូច្នោះ ។ ព្រោះហេតុនោះទើបភិក្ខុសម្លាញ់ទាំងនោះពោលថា ដើម្បីប្រព្រឹត្តទៅដោយប្រការដទៃនៃជនពួកខ្លះ ។

ពាក្យថា **ភគវតោ ឯតមត្ថំ អារោចេសុំ** សេចក្តីថា ភិក្ខុសម្លាញ់ទាំងនោះបានក្រាបទូល គឺបានប្រាប់សេចក្តីនោះដល់ព្រះដ៏មានព្រះភាគ កាលក្រាបទូល មិនមែនក្រាបទូលដើម្បីប្រាថ្នាឲ្យខ្លួនជាទីប្រោសប្រាណឡើយ មិនបានក្រាបទូលដើម្បីប្រាថ្នា នឹងធ្វើការញុះញង់ឡើយ មិនបានក្រាបទូលដើម្បីផ្ចាញ់ទោស របស់លោកអ្នកមានអាយុនោះឡើយ មិនបានទូលដើម្បីប្រាប់ទោសដែលគួរតិះដៀលឡើយ ក្រាបទូលដោយគិតថា ព្រះដ៏មានព្រះភាគកាលទ្រង់ស្តាប់សេចក្តីនេះហើយ នឹងមិនឲ្យសុទិន្ននេះគង់នៅក្នុងព្រះសាសនានឹងឲ្យអូសទាញលោកចេញទៅ ទើបបានក្រាបទូលក៏ទេ សេចក្តីពិត បានទូល

ដោយធ្វើទុកក្នុងចិត្តថា ព្រះដ៏មានព្រះភាគកាលទ្រង់ជ្រាបសេចក្តីវិនាសនេះ ដែលកើតឡើងក្នុងព្រះសាសនាហើយ ទ្រង់នឹងបញ្ញត្តសិក្ខាបទ ទ្រង់នឹងតាំងព្រំដែន គឺអាជ្ញាទុក ។

## ព្រះដ៏មានព្រះភាគ តិះដៀលសុទិន្ន

[ ២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ឯតស្មឹ និទានេ ឯតស្មឹ បករណេ** នេះដូច្នេះថា ការល្មើសអជ្ឈាចាររបស់សុទិន្ន គប្បីជ្រាបថា លោកពោលថាជានិទាន និងជា បករណ៍ ព្រោះជាហេតុនៃការបញ្ញត្តសិក្ខាបទ ។ ពិតហើយ ហេតុ លោកហៅថា និទាន និងបករណ៍ ព្រោះជាទីប្រគល់ឲ្យនូវផលរបស់ខ្លួន គឺញុំាងផលឲ្យប្រព្រឹត្តទៅ ហាក់ដូចជាបង្ហាញថា អញ្ជើញកាន់យកផលនោះចុះ និងព្រោះហេតុដែលផ្តើមធ្វើ គឺប្រារព្ធដើម្បីនឹងធ្វើផលនោះ ឬថា តាក់តែងផលនោះឯង ។

ត្រើនបទថា **វិគរហិ ពុទ្ធោ ភគវា** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ត្មះ គឺទ្រង់តិះដៀល ( សុទិន្ន ) នោះ ដូចជាបុគ្គលដ៏លើស កាលនឹងសម្តែងគុណ និងទោសរបស់ជនទាំងឡាយ ដែលសមគួរដល់គុណ និងទោស ក៏តិះដៀល និងសរសើរ ដូច្នោះ ។

ពិតហើយ ព្រោះទ្រង់ឃើញបុគ្គលដែលធ្វើការកន្លងល្មើសសីល ការគិតរមែងមិនកើតឡើងដល់ព្រះដ៏មានព្រះភាគថា បុគ្គលនេះ ជាមនុស្សមានឈ្មោះល្បី មានយសដោយជាតិ ឬដោយគោត្រ ឬដោយភាពជាកូន របស់បុគ្គលមានត្រកូល ឬដោយគន្ថៈ ( បរិយត្តិធម៌ ) ឬដោយធុតង្គវត្ត តថាគត

សមគួរនឹងរក្សាបុគ្គលដូច្នោះទុក ព្រោះទ្រង់ឃើញបុគ្គលដែលមានគុណ គឺសីលជាទីស្រឡាញ់ ព្រះទ័យដែលគិតនឹងបិទបាំងគុណ របស់បុគ្គលនោះមិនបានកើតឡើងឡើយ សេចក្តីពិត ទ្រង់រមែងតិះដៀលបុគ្គលដែលគួរតិះដៀលប៉ុណ្ណោះ ទ្រង់រមែងសរសើរបុគ្គលដែលគួរសរសើរប៉ុណ្ណោះ ឯសុទិន្ននេះ ជាបុគ្គលសមគួរនិន្ទា ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់តាំងនៅក្នុងលក្ខណៈនៃបុគ្គលមិនញាប់ញ័រ មានព្រះទ័យមិនលំអៀង ទ្រង់បានតិះ-ដៀលសុទិន្ននោះ ដោយព្រះតម្រាស់ថា **អននុច្ឆវិយំ** ជាដើម ។

ក្នុងពាក្យថា **អននុច្ឆវិយំ** ជាដើមនោះ មានការពណ៌នាអត្ថដូច្នេះថា ម្នាលមោឃបុរស អ្នកជាមនុស្សទទេ កម្មដែលអ្នកធ្វើហើយ មិនសមគួរដោយធម៌ ដែលធ្វើភាពជាសមណៈ ឬដល់មគ្គ ផល និព្វាន និងសាសនា គឺមិនប្រព្រឹត្តទៅតាម គឺមិនអនុលោមទៅតាមសម្បុរ គឺស្រមោល បានដល់ភាពជាធម៌ល្អ នៃធម៌ទាំងនោះ ដោយពិតនោះ ជាកម្មដែលឆ្ងាយអំពីធម៌ទាំងនោះឯង ព្រោះការប្រព្រឹត្តទៅរបស់ធម៌មិនសមគួរនោះឯង ទើបកម្មនោះឈ្មោះថា ជារបស់មិនសមគួរ គឺមិនអនុលោមដល់ធម៌ទាំងនោះ ដោយពិតនោះ ជារបស់បញ្ច្រាសគ្នា គឺតាំងនៅក្នុងភាពជាសត្រូវគ្នា ព្រោះភាពជារបស់មិនគួរគប្បីនោះឯង ទើបកម្មនោះរាប់ថា ជាកម្មមិនសមប្រក្រតី គឺជាកម្មមិនចូលគ្នា មិនដូចគ្នា មិនត្រូវចំណែកគ្នាឡើយ ដោយពិត ជារបស់មិនដូចគ្នា មិនត្រូវចំណែកគ្នានោះឯង ព្រោះភាពជារបស់មិនសមនឹងគ្នានោះឯង ទើបកម្មនោះមិនរាប់ថា ជារបស់សមណៈ គឺមិនជាកម្មរបស់ពួកសមណៈ ព្រោះ

គោលបដិបត្តិ មិនមែនជារបស់សម្រាប់សមណៈ ទើបកម្មនោះ ចាត់ជាអកប្បិយៈ ពិតហើយ កម្មណា មិនមែនជាកម្មរបស់សមណៈ កម្មនោះរមែងមិនសមគួរដល់សមណៈទាំងនោះ ព្រោះកម្មនោះជាអកប្បិយៈ ទើបកម្មនោះរាប់ថាមិនគួរធ្វើពិតហើយកម្មណាមិនសមគួរដល់ពួកសមណៈ សមណៈទាំងឡាយ រមែងមិនធ្វើកម្មនោះ ។ តែកម្មនោះអ្នកបានធ្វើហើយ ម្នាលមោឃបុរស ព្រោះហេតុនោះ កម្មដែលមិនសមគួរ មិនសមសួន មិនសមប្រក្រតី មិនមែនកិច្ចរបស់សមណៈ ជាអកប្បិយៈ មិនគួរធ្វើ ឈ្មោះថា អ្នកធ្វើហើយ ។

ពាក្យថា **កថំ ហិ នាម** សេចក្តីថា ព្រោះហេតុអ្វី អធិប្បាយថា អ្នកឯងសម្លឹងឃើញហេតុដូចម្តេច ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងការមិនមានហេតុ ទើបត្រាស់ថា **ឆន្នុ មយា មោឃបុរិស** ជាដើមខាងមុខ ។ ពាក្យទាំងអស់មានអត្ថដូចពោលហើយនោះឯង ។ កម្មណាមក ដែលសុទិន្ននោះធ្វើហើយ កាលឲ្យផល រមែងជាកម្មមានវិបាកជាទុក្ខយ៉ាងក្រៃលែង ព្រោះហេតុនោះ ឥឡូវនេះ កាលទ្រង់នឹងពោលទោសសុទិន្ន ដោយព្រះទ័យប្រកបដោយករុណា ដូចមាតាបិតា ដែលមានការអាណិតអាសូរ ស្តីថាបុត្រដែលធ្វើខុសហើយ ដូច្នោះ ទើបត្រាស់ពាក្យថា **វរន្តេ មោឃបុរិស** ជាដើម ដើម្បីសម្តែង វិបាកនោះដល់សុទិន្ននោះ ។

ក្នុងពាក្យថា **វរន្តេ មោឃបុរិស** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា

ពិសរបស់ពស់នោះ រមែងជ្រាបរហ័ស គឺឆាប់ ហេតុនោះ ទើបពស់នោះ ឈ្មោះថា **អាសីវិស** ( មានពិសជ្រាបរហ័ស ) ពិសរបស់ពស់នោះខ្លាំងក្លា គឺមានកម្លាំងខ្លាំង ហេតុនោះ ទើបពស់នោះ ឈ្មោះថា **ឃោរវិស** ( មានពិសដ៏ពន្លឹក ) ។ នៃអាសិរពិសដែលមានពិសជ្រាបរហ័ស មានពិសខ្លាំងក្លានោះ ។ គប្បីភ្ជាប់បទនេះថា **បក្ខិត្តំ** ដោយបទថា **វរំ** នេះ ។ អង្គជាតដែលអ្នកដាក់ចូលទៅក្នុងមាត់នៃពស់មានពិសជ្រាបរហ័សដូច្នេះ ប្រសើរជាង ។ អធិប្បាយថា បើអង្គជាតគប្បីជារបស់ដែលអ្នកឯងដាក់ចូលទៅសោត គប្បីជារបស់ប្រសើរជាង គឺជាការល្អ ការប្រសើរ ការប្រពៃ នឹងគប្បីមាន ។

បទថា **ន ត្វេវ** សេចក្តីថា មិនប្រសើរឡើយ គឺមិនជាការល្អឡើយ មិនស្អាតឡើយ បានដល់ មិនជាការប្រពៃនោះឯង ។ បទដទៃក៏មានន័យដូច្នេះ ។

បទថា **កណ្ហសប្បស្ស** ប្រែថា ពស់វែក បានដល់ ពស់ពណ៌ខ្មៅ ។

បទថា **អង្គារកាសុយា** ប្រែថា ក្នុងរណ្តៅដែលពេញដោយរងើកភ្លើង ឬក្នុងគំនររងើកភ្លើង ។

បទថា **អាទិត្តាយ** ប្រែថា ដែលភ្លើងឆេះសន្ធោសន្ធៅហើយ គឺមានពន្លឺរន្ទាលប្រាលភ្លៅហើយ ។

បទថា **សម្បជ្ជលិតាយ** ប្រែថា រុងរឿង គឺអណ្តាតភ្លើងឆេះឡើងដោយជុំវិញ ។

បទថា **សញ្ជោតិភូតាយ** ប្រែថា មានពន្លឺភ្លឺប្រាលភ្លៅ អធិប្បាយថា

មានការកើតឡើងនៃពន្លឺ ដែលដូចគ្នានឹងអណ្ដាតភ្លើង ដែលឆេះសន្ធោសន្ធៅដោយជុំវិញ ។

ក្នុងពាក្យថា **តំ កិស្ស ហេតុ** នេះ បើមានអ្នកសួរ សួរថា ពាក្យដែលតថាគតពោលថា គង់ប្រសើរជាង ជាហេតុនៃអ្វី គឺព្រោះហេតុអ្វី ឆ្លើយថា ព្រោះគប្បីដល់នូវការស្លាប់ អធិប្បាយថា បុគ្គលណាគប្បីដាក់អង្គជាតចូលទៅក្នុងមាត់ពស់ជាដើមនោះ បុគ្គលនោះគប្បីដល់នូវការស្លាប់ ។

ប្រើនបទថា **ឥតោនិទានញ្ច ខោ ។បេ។ ឧប្បជ្ជេយ្យ** សេចក្ដីថា បុគ្គលធ្វើការដាក់អង្គជាតចូលក្នុងអង្គជាតរបស់មាតុគ្រាមនោះ គប្បីចូលដល់នរក ដែលមានការធ្វើនេះជាហេតុ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងដល់កម្មជារបស់មានទោសច្រើនយ៉ាងនោះហើយ ទើបទ្រង់តិះដៀលសុទិន្ននោះ ទ្រង់មិនបានតិះដៀលក្នុងបំណងឲ្យសុទិន្ននោះដល់នូវសេចក្ដីទុក្ខឡើយ ។

ប្រើនបទថា **តត្ថ ឆាម ត្វំ** សេចក្ដីថា កាលកម្មនោះ គឺបែបនោះជារបស់មានទោសច្រើនយ៉ាងនេះ អ្នកគង់បានឈ្មោះថា ត្រូវអសទ្ធម្ម ដែលជាធម៌របស់អ្នកស្រុក ជាមារយាទរបស់មនុស្សថោកទាប ។

សព្ទថា **យំ** ដែលមាននៅក្នុងពាក្យថា **យំ ត្វំ** នេះ ជានិបាត ចុះក្នុងអត្ថនៃការមើលងាយ ។ បទថា **ត្វំ** ជាវេវចនៈនៃ **តំ** សព្ទ ។ លោកពោលអធិប្បាយទុកក្នុងបទទាំងពីរថា បានដល់ ការមាក់ងាយ គឺការមើលងាយ ឯណានីមួយ ។

បទថា **អសទ្ធម្មំ** បានដល់ ធម៌របស់អសប្បុរស គឺបុគ្គលជាន់ទាប អធិប្បាយថា ដែលបុគ្គលថោកទាបទាំងនោះគប្បីសេព ។

បទថា **គាមធម្មំ** បានដល់ ធម៌របស់អ្នកស្រុក អធិប្បាយថា ជាធម៌របស់ពួកជនជាអ្នកស្រុក ។

បទថា **វសលធម្មំ** សេចក្ដីថា ជាមារយាទរបស់ពួកជនដែលជាបុគ្គលថោកទាប ព្រោះអត្ថថា ហូរចេញ គឺហូរចេញមកនូវបាបធម៌ បានដល់ ជារបស់ពួកបុរសថោកទាប ។ ម្យ៉ាងទៀត ធម៌ជាហេតុហូរចេញនៃកិលេសឈ្មោះថា វសលធម៌ ។

បទថា **ទុដ្ឋុល្លំ** បានដល់ ជារបស់អាក្រក់ ជារបស់គ្រោតគ្រាតដែលត្រូវកិលេសប្រទូស្ត អធិប្បាយថា ជារបស់មិនសុខុម គឺមិនល្អិត ។

បទថា **ឱទកន្តិកំ** សេចក្ដីថា មេថុនធម្ម ឈ្មោះថា មានទឹកជាទីបំផុត ព្រោះអត្ថថា កិច្ចទាក់ទងដោយទឹកជាទីបំផុត គឺជាអវសាននៃមេថុនធម្មនោះដែលមេថុនធម្មតែងមានទឹកជាទីបំផុតនោះ ។

បទថា **រហស្សំ** បានដល់ កម្មកំបាំង គឺកើតឡើងក្នុងឱកាសដែលបិទបាំង ។ ពិតហើយ ធម៌នេះ បុគ្គលណាមួយ មិនអាចនឹងធ្វើឲ្យបើកផ្សារ គឺមិនអាចធ្វើក្នុងវិស័យដែលបុគ្គលដទៃទឹងឃើញបាន ព្រោះជាកម្មគួរខ្ពើម ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ជាកម្មក្នុងទីកំបាំង ។

បទថា **ទ្វយទ្វយសមាបត្តី** ប្រែថា ដែលជនពីរនាក់ៗ គប្បីប្រព្រឹត្តរួមគ្នា បាលីថា **ទ្វយំ ទ្វយំ សមាបត្តី** ក៏មាន ។ អាចារ្យពួកខ្លះសូធ្យថា

**ឧយឧយសមាបត្តី** ដូច្នេះក៏មាន តែពាក្យនោះមិនសមគួរ ។ គប្បីប្រកបបទថា **សមាបជ្ជិស្សសិ** នោះ ចូលដោយនាមសព្ទ ដែលលោកពោលទុកក្នុងបទថា **តត្ថ នាម តុំ** នេះថា **សមាបជ្ជិស្សសិ នាម** ( អ្នកនៅមានឈ្មោះថា បានត្រូវអសទ្ធម្ម ) ។

ព្រះដ៏មានព្រះភាគទ្រង់សំដៅយកព្រះសាសនា ត្រាស់ថា ម្នាលមោឃបុរស អ្នកឯងជាគំរូ ជាប្រធាននៃអកុសលធម៌ទាំងឡាយច្រើនដូច្នេះ ។ អធិប្បាយថា អ្នកឯងរាប់ថា ជាគំរូនៃបុគ្គលទាំងឡាយ ឬអកុសលធម៌ទាំងឡាយដ៏ច្រើនក្នុងសាសនានេះ ព្រោះធ្វើមុនបុគ្គលទាំងពួង រាប់ថា ជាប្រធាន គឺជាបុគ្គលឲ្យទ្វារ បានដល់ ចន្លុលឧបាយ ព្រោះជាអ្នកដើរផ្លូវនេះមុនបុគ្គលទាំងពួង ។

ពិតហើយ ក្នុងពាក្យថា **ពហុន្នំ ខោ** ជាដើមនេះ មានបំណងដូច្នេះថា បុគ្គលជាច្រើនបានលេសនេះហើយ យកលំអានតាមកិរិយារបស់អ្នកឯង នឹងធ្វើអកុសលធម៌ មានប្រការផ្សេងៗ មានសេពមេថុនធម្មទីងស្វាញ៉ីជាដើម ។

បទថា **អនេកបរិយាយេន** គឺដោយហេតុជាច្រើន ដែលត្រាស់ហើយដោយន័យជាដើមថា **អននុច្ឆវិកំ** នេះ ។

ច្រើនបទថា **ទុព្ភរតាយ ។បេ។ កោសជ្ជស្ស អវណ្ណំ ភាសិត្វា** សេចក្ដីថា ទ្រង់ត្រាស់ទោស គឺប្រការដែលគួរតិះដៀល បានដល់ ប្រការដែលគួរតិះដៀលនៃអសំវរៈ ដែលជាទីតាំងនៃសេចក្ដីវិនាស មានភាពជាបុគ្គលចិញ្ចឹមក្រជាដើម ។

ពិតហើយ ខ្លួនរបស់បុគ្គលដែលតាំងនៅក្នុងការមិនសង្រួម រមែងដល់នូវភាពជាសភាវៈដែលចិញ្ចឹមក្រ និងទំនុកបម្រុងលំបាក ព្រោះហេតុនោះ អសំវរៈ ទើបលោកហៅថា ភាពជាបុគ្គលចិញ្ចឹមក្រ និងភាពជាបុគ្គលទំនុក-បម្រុងលំបាក ។

ម្យ៉ាងទៀត ខ្លួនរបស់បុគ្គល ដែលតាំងនៅក្នុងការមិនសង្រួម រមែងដល់នូវភាពជាអ្នកប្រាថ្នាច្រើនក្នុងបច្ច័យ ៤ សូម្បីបានបច្ច័យទាំងឡាយ មានប្រមាណប៉ុនភ្នំសិនេរុហើយ ក៏គង់ដល់នូវភាពជាអ្នកមិនសន្តោស ព្រោះហេតុនោះ ទើបអសំវរៈ លោកហៅថា ភាពជាអ្នកប្រាថ្នាច្រើន និងភាពជាបុគ្គលមិនសន្តោស ។

ម្យ៉ាងទៀត ខ្លួនរបស់បុគ្គល ដែលតាំងនៅក្នុងការមិនសង្រួម រមែងប្រព្រឹត្តទៅដើម្បីការប្រឡូកប្រឡំដោយពួកគណៈ និងដើម្បីការប្រឡាក់ប្រឡូសដោយកិលេស ទាំងរមែងជាសភាវៈប្រព្រឹត្តទៅតាមសេចក្តីខ្ជិលច្រអូស គឺប្រព្រឹត្តទៅដើម្បីញ៉ាំងវត្ថុជាទីតាំងនៃកោសជ្ជៈ ៨ យ៉ាងឲ្យបរិបូណ៌ ព្រោះហេតុនោះទើបអសំវរៈ លោកហៅថា ការប្រឡូកប្រឡំ និងការខ្ជិលច្រអូស។

ច្រើនបទថា **សុភរតាយ ។បេ។ វីរិយារម្ភស្ស វណ្ណំ ភាសិត្វា** សេចក្តីថា ទ្រង់សរសើរគុណនៃសំវរៈ ដែលជាទីតាំងនៃគុណទាំងឡាយ មានភាពជាបុគ្គលប្រដៅងាយជាដើម ។

ពិតហើយ ខ្លួនរបស់បុគ្គលដែលលះអសំវរៈ ហើយតាំងនៅក្នុងសំវរៈ រមែងជាសភាវៈដែលចិញ្ចឹមងាយ ទំនុកបម្រុងងាយ រមែងដល់នូវភាពជា

បុគ្គលប្រាថ្នាតិច គឺអស់ការចង់បានក្នុងបច្ច័យ ៤ និងរមែងប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស ៣ យ៉ាង ដោយអំណាចនៃយថាលាភសន្តោស យថាពលសន្តោស យថាសារុប្បសន្តោស ក្នុងបច្ច័យឯណានីមួយ ព្រោះហេតុនោះ ទើបសំវរៈ លោកហៅថា ភាពជាបុគ្គលចិញ្ចឹមងាយ ភាពជាបុគ្គលទំនុកបម្រុងងាយ ភាពជាអ្នកប្រាថ្នាតិច និងភាពជាអ្នកសន្តោស ។

ម្យ៉ាងទៀត ខ្លួនរបស់បុគ្គលដែលលះអសំវរៈ តាំងនៅក្នុងសំវរៈ រមែងប្រព្រឹត្តទៅដើម្បីជាអ្នកជុសខាត់កិលេស និងភាពជាអ្នកកម្ចាត់កិលេសចេញ ព្រោះហេតុនោះ ទើបសំវរៈ លោកហៅថា ការជុសខាត់ និងការលះបង់ ។

ម្យ៉ាងទៀត ខ្លួនរបស់បុគ្គលដែលលះអសំវរៈ ហើយតាំងនៅក្នុងសំវរៈ មិនចូលទៅជិតកាយទុច្ចរិត និងវចីទុច្ចរិត ដែលមិននាំឲ្យកើតការជ្រះថ្លា គឺមិនជាទីតាំងនៃសេចក្តីជ្រះថ្លា មិនស្ងប់ មិនរៀបរយនៃកាយ និងវាចា និងមិនចូលទៅជិតអកុសលវិតក្កៈ ៣ ដែលមិននាំចិត្តឲ្យបរិសុទ្ធ គឺមិនជាទីតាំងនៃការផូរផង់របស់ចិត្ត មិនស្ងប់ មិនរៀបរយ រមែងប្រព្រឹត្តទៅដើម្បីការបរិបូណ៌ នៃកាយសុចរិត វចីសុចរិត និងកុសលវិតក្កៈ ៣ ដែលខុសប្លែកអំពីនោះឯង គឺនាំឲ្យកើតសេចក្តីជ្រះថ្លា ជាទីតាំងនៃសេចក្តីជ្រះថ្លា ស្ងប់មានរបៀប ព្រោះហេតុនោះ ទើបសំវរៈ លោកហៅថា នាំឲ្យកើតសេចក្តីជ្រះថ្លា ។

ម្យ៉ាងទៀត ខ្លួនរបស់បុគ្គលដែលលះអសំវរៈ តាំងនៅក្នុងសំវរៈ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកវដ្តៈ ដែលកើតអំពីការមិនសន្សំកិលេសទាំងពួង

និងដើម្បីភាពបរិបូណ៌ក្នុងវត្ថុជាទីតាំងនៃវីរិយារម្ភៈ ៨ យ៉ាង ព្រោះហេតុនោះ ទើបសំវរៈលោកហៅថា ការមិនសន្សំ និងការប្រារព្ធព្យាយាម ដូច្នេះ ។

ពាក្យថា **ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ** សេចក្ដីថា ទ្រង់ធ្វើធម្មទេសនាក្រៅរឿងដែលផុតអំពីបាលី មិនទាក់ទងដោយសុត្តន្តដែលបដិសំយុត្តដោយសំវរប្បហាន ដែលសមគួរ និងគួរដល់សិក្ខាបទ ដែលទ្រង់នឹងបញ្ញត្តក្នុងឥឡូវនេះ ទាំងសមគួរ និងគួរដល់សំវរៈ ដែលត្រាស់ដោយធម៌ទាំងឡាយ មានភាពជាបុគ្គលចិញ្ចឹមងាយជាដើម ដល់ភិក្ខុទាំងឡាយដែលប្រជុំគ្នាហើយ ក្នុងទីនោះ ។

បានឮថា ព្រះដ៏មានព្រះភាគ ប្រៀបដូចអ្នករចនាកម្រងផ្កា ដែលមានពណ៌ ៥ ប្រៀបដូចជាអ្នករចនាកម្រងផ្កាកែវ កាលទ្រង់ព្រមានបុគ្គលទាំងឡាយ ដែលពេញចិត្ត គឺជូន់ក្នុងអសំវរៈ ក្នុងបំណងនឹងជំទាស់ដោយវដ្តភ័យដែលមានក្នុងសម្បរាយភព ទ្រង់សម្ដែងទោស មានប្រការជាច្រើន ទ្រង់ញ៉ាំងបុគ្គលអ្នកស្រឡាញ់ចំពោះការសិក្សា តាំងនៅក្នុងសំវរៈ ពួកខ្លះឲ្យប្រតិស្ឋាននៅក្នុងអរហត្ត ពួកខ្លះឲ្យតាំងនៅក្នុងអនាគាមិផល សកទាគាមិផល និងសោតាបត្តិផល ទ្រង់ញ៉ាំងបុគ្គលទាំងឡាយ ដែលប្រាសចាកឧបនិស្ស័យឲ្យប្រតិស្ឋានក្នុងផ្លូវសួគ៌ ទើបទ្រង់ធ្វើធម្មទេសនា មានខ្នាតនៃទីឃនិកាយខ្លះ មានខ្នាតនៃមជ្ឈិមនិកាយខ្លះ ក្នុងស្ថានទាំងឡាយដូច្នេះ ។ ព្រះឧបាលិត្ថេរសំដៅយកធម្មទេសនានោះ ទើបពោលពាក្យនេះថា ទ្រង់ធ្វើធម្មីកថា សមគួរដល់សិក្ខាបទ និងសំវរៈនោះ ដែលសមគួរដល់សិក្ខាបទ និងសំវរៈនោះដល់

ភិក្ខុទាំងឡាយ ។

បទថា **តេន ហិ** សេចក្តីថា ព្រោះអជ្ឈាចារនោះរបស់សុទិន្នភិក្ខុដែលជាដើមហេតុ ។

ក្នុងបទថា **សិក្ខាបទំ** នេះ មានវិនិច្ឆ័យដូចតទៅនេះថា ដែលឈ្មោះថា សិក្ខា ព្រោះអត្ថថា ជាគុណជាតិដែលបុគ្គលគប្បីសិក្សា ។ ដែលឈ្មោះថា **បទ** ព្រោះអត្ថថា ជាផ្លូវ ជាគ្រឿងដែលបុគ្គលគប្បីដល់ ។ ផ្លូវជាគ្រឿងដែលបុគ្គលគប្បីដល់នូវសិក្ខា ឈ្មោះថា **សិក្ខាបទ** សេចក្តីថា ឧបាយនៃការបានសិក្ខា ។

ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ជាមូល គឺជាទីអាស្រ័យ ជាទីពំនាក់នៃសិក្ខា ។ ពាក្យថា **សិក្ខាបទ** នោះ ជាឈ្មោះនៃការសង្រួមចាកមេថុន ដោយវៀរចាកមេថុន ។ ពិតហើយ មេថុនសំវរៈ លោកសំដៅយកជា **សិក្ខាបទ** ក្នុងទីនេះ ព្រោះភាពជាផ្លូវនៃធម៌ គឺសីល វិបស្សនា ឈាន និងមគ្គ ពោល គឺសិក្ខាដទៃក្រៅអំពីមេថុនសំវរៈនោះ ដោយអំណាចនៃអត្ថដូចពោលហើយ ឯអត្ថនេះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសិក្ខាបទវិភង្គ ។ ម្យ៉ាងទៀត សូម្បីពាក្យដែលសម្តែងអត្ថនោះ គប្បីជ្រាបថា ជាសិក្ខាបទ ពិតហើយ សូម្បីព្រះដ៏មានព្រះភាគក៏បានត្រាស់ពាក្យនេះថា បណ្តាពួកទាំងនោះ ពួកនាម ពួកបទ ពួកភាសា ពួកព្យញ្ជនៈឯណា ពួកធម៌ទាំងនោះ ឈ្មោះថា សិក្ខាបទ ។ ប្រការមួយទៀត កាលលោកពោលថា **អនភិជ្ឈា** ជាធម្មបទ អត្ថរមែងមានថា **អនភិជ្ឈា** ជាចំណែកធម៌មួយ សេចក្តី

នេះ យ៉ាងណា សូម្បីក្នុងទីនេះ ក៏យ៉ាងនោះ កាលលោកពោលថា សិក្ខាបទ គប្បីជ្រាបអត្ថថា ចំណែកនៃសិក្ខា គឺបទេសឯណាមួយនៃសិក្ខា ដូច្នេះក៏បាន ។

## ប្រយោជន៍ ១០ យ៉ាងនៃការបញ្ញត្តសិក្ខាបទ

ប្រើនបទថា **ទស អត្ថវសេ បដិច្ច** មានអត្ថថា នឹងអាស្រ័យ គឺ សំដៅប្រារព្ធអំណាចនៃហេតុ គឺប្រយោជន៍ពិសេស ១០ យ៉ាង ដែលគប្បីបាន ព្រោះហេតុ បញ្ញត្តសិក្ខាបទ ។ មានពាក្យអធិប្បាយថា សម្លឹងឃើញការសម្រេចប្រយោជន៍ពិសេស ១០ យ៉ាង ។ ឥឡូវនេះ ព្រះដ៏មានព្រះភាគ នឹងសម្តែងប្រយោជន៍ ១០ យ៉ាងនោះ ទើបត្រាស់ពាក្យថា **សង្ឃសុដ្ឋុតាយ** ជាដើម ។

បណ្តាប្រយោជន៍ ១០ យ៉ាងនោះ ដែលឈ្មោះថា ការឃើញប្រពៃនៃសង្ឃ បានដល់ សង្ឃព្រមទទួលថា ប្រពៃ គឺសង្ឃទទួលព្រះតម្រាស់ថា **សុដ្ឋុ ភន្តេ** ប្រពៃហើយ ព្រះអង្គ ដូចក្នុងអាគតដ្ឋានថា **សុដ្ឋុ ទេវា** ប្រពៃហើយ ព្រះសម្មតិទេព ពិតហើយ ភិក្ខុណា ព្រមទទួលព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ការព្រមទទួលព្រះតម្រាស់របស់ភិក្ខុនោះ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏យូរ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់បើកផ្សាយអត្ថនេះថា តថាគតនឹងសម្តែងទោសក្នុងការមិនព្រមទទួល និងអានិសង្ស ក្នុងការព្រមទទួល គឺមិនញាំញីដោយពលក្ការនឹងបញ្ញត្ត ( សិក្ខាបទ ) ដើម្បីឲ្យសង្ឃព្រមទទួលពាក្យរបស់តថាគតថា សាធុ ព្រះអង្គ ដូច្នេះ ទើបត្រាស់ពាក្យថា **សង្ឃសុដ្ឋុតាយ** ។

បទថា **សង្ឃផាសុតាយ** គឺដើម្បីនៅសប្បាយដល់សង្ឃ អធិប្បាយថា ដើម្បីប្រយោជន៍ដល់ការនៅជាផាសុក ដោយភាពជាអ្នកនៅរួមគ្នា ។

ត្រើនបទថា **ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ** សេចក្ដីថា បុគ្គលអ្នកទ្រុស្តសីល ឈ្មោះថា បុគ្គលដែលប្រដៅក្រ ភិក្ខុពួកណា ដែលភិក្ខុទាំងឡាយ នឹងឲ្យដល់នូវភាពជាអ្នកប្រដៅក្រ រមែងដល់បានដោយលំបាក កំពុងធ្វើការល្មើស ឬធ្វើហើយ រមែងមិនខ្មាស ដើម្បីប្រយោជន៍ដល់ការសង្កត់សង្កិនភិក្ខុទាំងនោះ ។

ពិតហើយ ភិក្ខុទាំងនោះ កាលសិក្ខាបទមិនមាន នឹងបៀតបៀនសង្ឃដោយពាក្យថា រឿងដូចម្ដេចដែលពួកលោកឃើញមកហើយ រឿងដូចម្ដេចដែលពួកលោកបានស្ដាប់មកហើយ វត្ថុដូចម្ដេចដែលពួកខ្ញុំធ្វើហើយ ពួកលោកលើកអាបត្តិណា ព្រោះវត្ថុអ្វីមកសង្កត់សង្កិនពួកខ្ញុំ កាលបើសិក្ខាបទមានសង្ឃនឹងអាងសិក្ខាបទ ហើយសង្កត់សង្កិនភិក្ខុពួកនោះដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនា ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ដើម្បីសង្កត់សង្កិនពួកបុគ្គលដែលប្រដៅក្រ ។

ត្រើនបទថា **បេសលានំ ភិក្ខូនំ ផាសុវិហារាយ** គឺ ដើម្បីប្រយោជន៍ដល់ការនៅជាសុខសប្បាយរបស់ភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ។ ពិតហើយ ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ មិនដឹងវត្ថុដែលគួរធ្វើ និងមិនគួរធ្វើ វត្ថុដែលមានទោស និងមិនមានទោស កំណត់ព្រំដែន កំពុងព្យាយាម ដើម្បីការបរិបូរនៃត្រៃសិក្ខា កាលមានសេចក្ដី

សង្ស័យ រមែងលំបាក រមែងក្តៅក្រហាយ តែកាលដឹងរបស់ដែលគួរធ្វើ និង មិនគួរធ្វើរបស់ដែលមានទោស និងមិនមានទោស កំណត់ព្រំដែនបានហើយ ព្យាយាមដើម្បីការសម្បូរនៃសិក្ខា ៣ រមែងមិនលំបាក រមែងមិនក្តៅ ក្រហាយ ព្រោះហេតុនោះ ទើបការបញ្ញត្តសិក្ខាបទ ប្រព្រឹត្តទៅដើម្បីការនៅ ជាផាសុករបស់ពួកភិក្ខុនោះ ។

ម្យ៉ាងទៀត ការសង្កត់សង្កិនបុគ្គលដែលប្រដៅក្រទាំងឡាយនោះឯង ជាការនៅផាសុកនៃភិក្ខុទាំងនោះ ។ ព្រោះថា ឧបោសថ រមែងតាំងនៅមិន បាន បវារណា រមែងតាំងនៅមិនបាន សង្ឃកម្មទាំងឡាយ រមែងប្រព្រឹត្តទៅ មិនបាន សាមគ្គី រមែងមានមិនមាន ព្រោះអាស្រ័យពួកបុគ្គលអ្នកទ្រុស្តសីល ។ ភិក្ខុទាំងឡាយ មានអារម្មណ៍តែមួយមិនបាន រមែងមិនអាចប្រកបតាមនូវ ឧទ្ទេស បរិបុច្ឆា និងកម្មដ្ឋានជាដើម ។ កាលពួកបុគ្គលអ្នកទ្រុស្តសីល ត្រូវ សង្កត់សង្កិនហើយ ឧបទ្រវទាំងអស់នេះក៏មិនមាន កាលនោះ ពួកភិក្ខុអ្នក មានសីលជាទីស្រឡាញ់ រមែងនៅជាផាសុក ។

ក្នុងពាក្យថា ដើម្បីការនៅជាផាសុករបស់ភិក្ខុទាំងឡាយ ដែលមាន សីលជាទីស្រឡាញ់នេះ បណ្ឌិតគប្បីជ្រាបអធិប្បាយដោយន័យ ២ ដោយ ប្រការដូច្នេះ ។

ពាក្យថា ដើម្បីរាំងអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន អធិប្បាយថា ទុក្ខពិសេស មានការប្រហារដោយបាតដៃ ប្រហារដោយដំបង កាត់ដៃ កាត់ជើង ការខូចកេរ្តិ៍ឈ្មោះ ការវិនាសយស និងការក្តៅក្រហាយ

ជាដើម ដែលបុគ្គលតាំងនៅក្នុងការមិនសង្រួម គប្បីដល់ក្នុងអត្តភាពនេះឯង ឈ្មោះថា អាសវៈដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ។ ដើម្បីរារាំង គឺហាមផ្លូវមកនៃអាសវៈដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នទាំងនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដើម្បីកម្ចាត់អាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងសម្បរាយកព សេចក្តីថា ទុក្ខពិសេស មានបាបកម្មដែលខ្លួនធ្វើហើយជាមូល ដែលបុគ្គលតាំងនៅក្នុងការមិនសង្រួម នឹងគប្បីដល់ក្នុងនរកជាដើម ក្នុងសម្បរាយកព ឈ្មោះថា អាសវៈដែលប្រព្រឹត្តទៅក្នុងសម្បរាយកព ដើម្បីប្រយោជន៍ការកម្ចាត់ មានពាក្យអធិប្បាយថា ដើម្បីប្រយោជន៍ដល់ការរម្ងាប់ គឺដើម្បីប្រយោជន៍ដល់ការចូលទៅស្ងប់អាសវៈ ដែលប្រព្រឹត្តទៅក្នុងសម្បរាយកពទាំងនេះ ។

ពាក្យថា **អប្បសន្នានំ បសាទាយ** សេចក្តីថា កាលមានសិក្ខាបទប្បញ្ញត្តិ មនុស្សដែលជាបណ្ឌិតទាំងឡាយ សូម្បីមិនជ្រះថ្លា បានជ្រាបសិក្ខាបទប្បញ្ញត្តិ ឬបានឃើញភិក្ខុទាំងឡាយបដិបត្តិសិក្ខាបទ តាមដែលទ្រង់បញ្ញត្តរមែងដល់នូវការជ្រះថ្លាថា ធម៌ពួកណាហ្ន៎ ជាទីតាំងនៃតម្រេក ការអាក់អន់និងការវង្វេងរបស់មហាជនក្នុងលោក សមណសក្យបុត្រទាំងនេះ រមែងនៅឆ្ងាយអំពីធម៌ទាំងនោះ ពួកលោកធ្វើកម្មដែលគេធ្វើបានដោយកម្រហ្ន៎ ធ្វើកិច្ចដែលធ្ងន់ហ្ន៎ ដូច្នេះ ដូចព្រាហ្មណ៍ដែលជាមិច្ឆាទិដ្ឋិចេះត្រៃវេទ បានឃើញគម្ពីរព្រះវិនយបិដកហើយ ជ្រះថ្លា ដូច្នោះ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **អប្បសន្នានំ បសាទាយ**។

ពាក្យថា **បសន្នានំ ភិយ្យោភាវាយ** សេចក្តីថា កុលបុត្រទាំងឡាយ សូម្បីជ្រះថ្លាក្នុងព្រះសាសនា បានជ្រាបសិក្ខាបទប្បញ្ញត្តិ ឬបានឃើញភិក្ខុទាំងឡាយបដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្តទុក រមែងជ្រះថ្លាជាភិយ្យោភាពថា ឱ ភិក្ខុពួកណា ឃុំរក្សាវិនយសំវរៈដែលមានអាហារតែមួយពេលអស់មួយជីវិត ជាការប្រព្រឹត្តប្រសើរ ភិក្ខុទាំងនោះ ជាអ្នកមានប្រក្រតីធ្វើកម្មដែលធ្វើបានលំបាក ។ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **បសន្នានំ ភិយ្យោភាវាយ ។**

ពាក្យថា **សទ្ធម្មដ្ឋិតិយា** សេចក្តីថា សទ្ធម្មមាន ៣ យ៉ាង គឺបរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ អធិគមសទ្ធម្ម ១ បណ្តាសទ្ធម្ម ៣ យ៉ាងនេះ ដែលឈ្មោះថា បរិយត្តិសទ្ធម្ម បានដល់ ពុទ្ធវចនៈទាំងអស់ រួមដោយព្រះត្រៃបិដក ។ ដែលឈ្មោះថា បដិបត្តិសទ្ធម្ម បានដល់ ធម៌ គឺធុតង្គគុណ ១៣ ខន្ធកវត្ត ១៤ មហាវត្ត ៨២ សីល សមាធិ និងវិបស្សនា ។ ដែលឈ្មោះថា អធិគមសទ្ធម្ម បានដល់ ធម៌ គឺអរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ ។ កាលមានសិក្ខាបទប្បញ្ញត្តិ ភិក្ខុទាំងឡាយ រមែងរៀនសិក្ខាបទ និងវិភង្គនៃសិក្ខាបទនោះ និងព្រះពុទ្ធវចនៈដទៃ ដើម្បីធ្វើឱ្យបញ្ជាក់អត្ថនៃសិក្ខាបទ និងវិភង្គនោះ ហើយកាលបដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្តទុក រមែងសម្រេចលោកុត្តរធម៌ ដែលខ្ជួននឹងគប្បីបំពេញបដិបទា ហើយសម្រេចបានដោយការបដិបត្តិ ព្រោះហេតុនោះ ទើបសទ្ធម្មទាំងអស់នោះ ជាសភាវៈមានការតាំងនៅ ស្ថិតស្ថេរ ដោយសិក្ខាបទប្បញ្ញត្តិ ។ ដោយហេតុនោះ ទើបព្រះដ៏មាន

ព្រះភាគត្រាស់ថា **សទ្ធម្មដ្ឋិតិយា**។

បទថា **វិនយានុគ្គហាយ** សេចក្តីថា ពិតហើយ កាលមានសិក្ខាបទ-ប្បញ្ញត្តិ វិន័យទាំង ៤ យ៉ាង គឺសំវរវិន័យ ១ បហានវិន័យ ១ សមថវិន័យ ១ បញ្ញត្តិវិន័យ ១ ទ្រង់រមែងអនុគ្រោះ គឺឧបត្ថម្ភទុកដោយល្អ ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **វិនយានុគ្គហាយ** ។ ឯបទទាំងអស់នោះ គប្បីប្រកបនឹងពាក្យនេះថា តថាគតនឹងបញ្ញត្តសិក្ខាបទ ។ ប្រកបបទដើម និងបទចុង ក្នុងបណ្តាបទទាំងនោះ ដូច្នេះថា តថាគតនឹងបញ្ញត្តសិក្ខាបទដើម្បីការឃើញប្រពៃរបស់សង្ឃ ។បេ។ តថាគតនឹងបញ្ញត្តសិក្ខាបទដើម្បីសេចក្តីអនុគ្រោះព្រះវិន័យ ។ ប្រការមួយទៀត ព្រះដ៏មានព្រះភាគទ្រង់ធ្វើសង្ខលិកបទ្ទិចបទ្ទួចយ៉ាងនេះថា ការឃើញប្រពៃនៃសង្ឃឯណា នុ៎ះជាការសុខសាន្តនៃសង្ឃ ការសុខសាន្តនៃសង្ឃឯណា នុ៎ះដើម្បីសង្កត់សង្កិនបុគ្គលទាំងឡាយដែលប្រដៅក្រ ហើយយោជនាទាំង ១០ មានបទនីមួយៗ ជាគោលយ៉ាងនេះថា ការឃើញប្រពៃនៃសង្ឃឯណា នុ៎ះគឺការសុខសាន្តនៃសង្ឃ ការឃើញប្រពៃនៃសង្ឃឯណា នុ៎ះដើម្បីសង្កត់សង្កិនបុគ្គលប្រដៅក្រទាំងឡាយ ដូច្នេះហើយ ទ្រង់ត្រាស់ពាក្យណាទុកក្នុងគម្ពីរបរិវារថា

ក្នុងបករណៈសម្តែង អំណាចប្រយោជន៍ ( នេះ ) បណ្ឌិតត្រូវដឹង
ថា មានអត្ថ ១០០ មានធម៌ ១០០ និរុត្តិ ២០០ និងញាណ ៤០០ ។

ពាក្យទាំងអស់នោះ គប្បីជ្រាបក្នុងបទថា **សង្ឃសុដ្ឋុតាយ** ជាដើមនេះ ។ តែពាក្យនោះឯង នឹងមានច្បាស់ក្នុងគម្ពីរបរិវារនោះឯង ព្រោះដូច្នោះ

ទើបខ្ញុំមិនពណ៌នាក្នុងទីនេះ ។

# ទ្រង់បញ្ញត្តបឋមបារាជិក

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងអានិសង្សនៃការបញ្ញត្តសិក្ខាបទទុកយ៉ាងនោះហើយ កាលទ្រង់បង្ហាញកិច្ចដែលភិក្ខុទាំងឡាយគួរធ្វើក្នុងសិក្ខា-បទនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឯពួកអ្នកគប្បីសម្តែងឡើងនូវសិក្ខាបទយ៉ាងនេះ ។ ព្រះអង្គទ្រង់ត្រាស់អធិប្បាយទុកដូចម្តេច ទ្រង់ត្រាស់អធិប្បាយទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែង ត្រូវរៀនសូត្រ ត្រូវចងចាំ និងគប្បីប្រាប់ដល់បុគ្គលដទៃនូវសិក្ខាបទនេះ គឺមានអានិសង្សដែលតថាគតសម្តែងហើយយ៉ាងនេះ ក្នុងបាតិមោក្ខុទ្ទេសយ៉ាងនេះ ។ ពិតហើយ ច សព្ទ ក្នុងពាក្យថា **ឯវញ្ច បន** នេះ មានការនាំអត្ថជាច្រើនមកជាអត្ថ ព្រោះដូច្នោះ អត្ថនេះ គឺលោកនាំមកហើយ ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងពាក្យដែលព្រះអង្គត្រាស់ទុកថា សិក្ខាបទនេះ ទើបត្រាស់ថា ម្យ៉ាងទៀត ភិក្ខុណាមួយ សេពមេថុនធម្ម ( ភិក្ខុនោះ ) ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។ កាលព្រះអង្គទ្រង់បញ្ញត្តបឋមបារាជិកឲ្យរឹងមាំ ដោយអំណាចមូលច្ឆេទយ៉ាងនោះហើយ សូម្បីរឿងស្វាញីដទៃទៀត ក៏កើតឡើងដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ ដើម្បីសម្តែងរឿងស្វាញីដែលកើតឡើងនោះ ទើបព្រះធម្មសង្គាហកត្ថេរទាំង-ឡាយបានពោលពាក្យនេះទុកថា សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយ ចំពោះភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។ អធិប្បាយសេចក្តីនៃ

ពាក្យនោះថា សិក្ខាបទនេះ គឺព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយយ៉ាងនេះ ដល់ភិក្ខុទាំងឡាយ ឯរឿងដទៃនេះ ក៏បានកើតឡើងហើយ ។

## បឋមប្បញ្ញត្តិកថា ចប់

# អនុប្បញ្ញត្តិទី ១ នៃបឋមបារាជិក
## រឿងស្វាញី

[ ២១ ] ឥឡូវនេះ ដើម្បីសម្តែងរឿងដែលកើតឡើង ទើបព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានពោលពាក្យជាដើមថា **តេន ខោ បន សមយេន។** ក្នុងពាក្យថា **តេន ខោ បន សមយេន** ជាដើមនោះ មានការពណ៌នាបទដែលមិនទាន់ច្បាស់ដូច្នេះថា ពីរបទថា **មក្កដឹ អាមិសេន** សេចក្តីថា ជំពូកសត្វតិរច្ឆានជាច្រើន មានម្រឹគ ក្ងោក មាន់ និងស្វាជាដើម មិនមានការគិតភ័យ ខ្លាច រន្ធត់ ព្រោះអានុភាពនៃគុណ មានខន្តី និងមេត្តាជាដើមរបស់ភិក្ខុទាំងឡាយ ក្នុងព្រៃមហាវ័ន រមែងត្រាច់ទៅក្នុងផ្ទះស្វាត់ដែលបំពេញព្យាយាម ។ មានពាក្យអធិប្បាយថា ភិក្ខុអង្គណាមួយ យកអាមិស មានបបរ បាយ និងរបស់ទំពាជាដើម បញ្ឆោត គឺសង្គ្រោះស្វាញីមួយ ក្នុងបណ្តាសត្តតិរច្ឆានជាដើមទាំងនោះ ។

បទថា **តស្សា** ជាសត្តមីវិភត្តិ ។

បទថា **បដិសេវតិ** សេចក្តីថា រមែងជាអ្នកសេពដោយច្រើន ។ វត្តមានាវិភត្តិ រមែងចុះក្នុងអត្ថថា **បចុរ** គឺច្រើន ។

ពីរបទថា **សោ ភិក្ខុ** បានដល់ ភិក្ខុអ្នកសេពមេថុនធម្មនោះ ។

ពីរបទថា **សេនាសនចារិកំ អាហិណ្ឌន្តា** សេចក្តីថា ភិក្ខុអាគន្តុកៈទាំងនោះ មកគាល់ព្រះដ៏មានព្រះភាគ បានអាគន្តុកកត្តអំពីព្រលឹម ធ្វើភត្តកិច្ចរួចហើយ បបួលគ្នាថា ពួកយើងនឹងមើលទីកន្លែងលំនៅរបស់ភិក្ខុទាំងឡាយ

ហើយសឹមត្រាច់ទៅ ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកត្ថេរទាំងឡាយពោលថា **សេនាសនចារិកំ អាហិណ្ឌន្តា** ដូច្នេះ ។

## ស្វាញីបង្ហាញរបស់កំចាំងដល់អាគន្តុកភិក្ខុ

ប្រើនបទថា **យេន តេ ភិក្ខូ តេនុបសង្កមិ** សេចក្តីថា ធម្មតាតិរច្ឆានទាំងឡាយ កាលបានធ្វើសេចក្តីស្និទ្ធស្នាលជាមួយភិក្ខុអង្គណាមួយហើយ ក៏ញុំាងការគិតដូច្នោះនោះឯងឲ្យកើតឡើង សូម្បីក្នុងភិក្ខុដទៃផងដែរ ។ ព្រោះដូច្នោះ ទើបស្វាញីនោះ បានចូលទៅរកភិក្ខុទាំងនោះរហូតដល់លំនៅ គ្រានោះក៏សម្តែងវិការនោះដល់ភិក្ខុទាំងនោះ ដូចសម្តែងដល់ភិក្ខុដែលខ្លួនស្និទ្ធស្នាលដូច្នោះ ។

បទថា **ជេប្បំ** ប្រែថា កន្ទុយ ។

បទថា **ឱឌ្ឌិសិ**(១) ប្រែថា ពើងចង្កេះ ។

ពីរបទថា **និមិត្តម្បិ អកាសិ** សេចក្តីថា ភិក្ខុអាគន្តុកៈទាំងនោះ រមែងដឹងសេចក្តីត្រូវការមេថុន ដោយការកំណត់យ៉ាងណា ដោយកិរិយាយ៉ាងណា ស្វាញីនោះ ក៏បានធ្វើនិមិត្តនោះ ដោយការកំណត់ និងកិរិយានោះៗ ។

ពីរបទថា **សោ ភិក្ខុ** សេចក្តីថា នេះជាវិហារ ( លំនៅ ) របស់ភិក្ខុណា ( ភិក្ខុនោះ រមែងសេពមេថុនធម្ម ក្នុងស្វាញីនេះ មិនចាំបាច់សង្ស័យដូច្នេះ ) ។

ពីរបទថា **ឯកមន្តំ និលីយឹសុ** សេចក្តីថា អាគន្តុកភិក្ខុទាំងនោះ បាន

---

១- បិដកថា ឱឌ្ឌិ ។ យកតាមអដ្ឋកថា ។

ពួននៅត្រង់ឱកាសមួយកន្លែង ។ ពីរបទថា **សច្ចំ អាវុសោ** សេចក្តីថា ភិក្ខុអង្គនោះ រមែងត្រូវពួកអាគន្តុកភិក្ខុឃើញកម្ម ដែលលោកធ្វើនោះច្បាស់នឹងភ្នែក ដូចចាប់ចោរបាន ព្រមទាំងកស្តុតាង ដូច្នោះ កាលមិនអាចនឹងពោលពាក្យជាដើមថា ខ្ញុំធ្វើកម្មអាក្រក់ដូចម្តេច ទើបពោលទទួលថា ពិតហើយលោកម្ចាស់ ។

ប្រើនបទថា **ននុ អាវុសោ តថេវ តំ ហោតិ** សេចក្តីថា លោកម្ចាស់ សូម្បីក្នុងសត្វតិរច្ឆានញី សិក្ខាបទនោះ រមែងដូចក្នុងស្រីមនុស្សមិនមែនឬ ( លោកម្ចាស់ កាលសុទិន្នភិក្ខុសេពមេថុនធម្មក្នុងស្រីមនុស្ស សិក្ខា-បទរមែងមានយ៉ាងណា កាលលោកសេពមេថុនធម្ម សូម្បីក្នុងសត្វតិរច្ឆានញី សិក្ខាបទនោះ ក៏រមែងដូចគ្នាដូច្នោះ មិនមែនឬ ) ។ ពិតហើយ ការសម្លឹងមើលក្តី ចាប់ពាល់ក្តី ស្ទាបអង្អែលក្តី និងពាល់ត្រូវក្តី ប៉ះខ្ទប់ក្តី នូវស្រីមនុស្ស ជាកម្មអាក្រក់ទាំងអស់ កិរិយា មានការសម្លឹងមើលជាដើម ទាំងអស់នេះ សូម្បីនូវសត្វតិរច្ឆានញីជាកម្មអាក្រក់ដូចគ្នា ក្នុងស្រីមនុស្សនិងសត្វតិរច្ឆានញីនេះ មិនមានអ្វីប្លែកគ្នាទេ លោកអាងលេសក្នុងឋានៈដែលមិនមែនជាលេស ដូច្នេះ ។

[ ២២ ] ប្រើនបទថា **អន្តមសោ តិរច្ឆានគតាយបិ ចារាជិកោ ហោតិ អសំវាសោ** សេចក្តីថា ព្រះដ៏មានព្រះភាគ ទ្រង់បានធ្វើសិក្ខាបទឲ្យមាំទាំឡើងទៀតថា ភិក្ខុសេពមេថុនធម្ម សូម្បីក្នុងសត្វតិរច្ឆានញី ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។

# សិក្ខាបទទាំងអស់មានទោស ២ យ៉ាង

ពិតហើយ សិក្ខាបទមាន ២ យ៉ាង គឺលោកវជ្ជៈ ( មានទោសផ្លូវលោក ) ១ បណ្ណត្តិវជ្ជៈ ( មានទោសផ្លូវពុទ្ធប្បញ្ញត្តិ ) ១ ។ បណ្តាទោស ២ យ៉ាងនោះ សិក្ខាបទណាដែលជាសចិត្តកៈ មានចិត្តអកុសលសុទ្ធៗ សិក្ខាបទនោះ ឈ្មោះថា ជាលោកវជ្ជៈ សិក្ខាបទដ៏សេស ជាបណ្ណត្តិវជ្ជៈ ។

បណ្តាទោស ២ យ៉ាងនោះ អនុប្បញ្ញត្តិក្នុងសិក្ខាបទដែលជាលោកវជ្ជៈ កាលកើតឡើង រាំង បិទទ្វារ កាត់ក្រសែ ធ្វើឲ្យតឹងឡើងជាងមុន រមែងកើតឡើង ។ ចំណែកអនុប្បញ្ញត្តិនេះថា វៀរតែសម្គាល់ថា បានសម្រេច វៀរតែយល់សប្តិ ព្រះដ៏មានព្រះភាគត្រាស់ទុក ព្រោះមិនមានការកន្លងល្មើស និងព្រោះជាអព្វោហារិក ( មិនមែនជាវោហារ ) ។ ក្នុងសិក្ខាបទ ដែលជាបណ្ណត្តិវជ្ជៈ កាលភិក្ខុមិនទាន់បានធ្វើការកន្លងល្មើសអនុប្បញ្ញត្តិ កាលកើតឡើង ធ្វើឲ្យធូរថយចុះ ធ្វើឲ្យស្រាលចុះ បើកទ្វារឲ្យ ធ្វើមិនឲ្យជាអាបត្តិ តៗទៅ រមែងកើតឡើង ដូចអនុប្បញ្ញត្តិក្នុងគណភោជនសិក្ខាបទ និងបរម្បរភោជនសិក្ខាបទ ដូច្នោះ ។ ចំណែកអនុប្បញ្ញត្តិមានយ៉ាងនេះថា ( ប្រាប់ ) សូម្បីដល់ស្រីពេស្យាដែលគប្បីនៅរួមមួយផ្លូវខណៈ ឈ្មោះថា មានគតិដូចបញ្ញត្តិនោះឯង ព្រោះកើតឡើងក្នុងកាលភិក្ខុធ្វើការកន្លងល្មើសហើយ ។ ក៏ព្រោះបឋមសិក្ខាបទនេះជាលោកវជ្ជៈ មិនមែនជាបណ្ណត្តិវជ្ជៈ ព្រោះដូច្នោះ អនុប្បញ្ញត្តិនេះក៏រាំង បិទទ្វារ កាត់ក្រសែ បានដល់ ធ្វើឲ្យតឹងឡើងជាងមុនទៀត រមែងកើតឡើង ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ប្រមូលរឿងទាំងពីរមក ហើយបញ្ញត្ត

បឋមបារាជិក ធ្វើឲ្យតាំងឡើងជាងមុន ដោយអំណាចមូលច្ចេទយ៉ាងនោះ រឿងភិក្ខុអ្នកវជ្ជីបុត្រដទៃទៀតក៏កើតឡើង ដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ ដើម្បីសម្តែងការកើតឡើងនៃរឿងវជ្ជីបុត្តភិក្ខុនោះ ទើបព្រះធម្មសង្គាហកត្ថេរ ទាំងឡាយបានពោលពាក្យនេះថា ឯសិក្ខាបទនេះ គឺព្រះដ៏មានព្រះភាគ ទ្រង់ បញ្ញត្តហើយដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។ អធិប្បាយសេចក្តីនៃ ពាក្យនោះថា សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយយ៉ាងនេះ ដល់ភិក្ខុទាំងឡាយ ឯរឿងដទៃនេះ ក៏បានកើតឡើង ។

មក្កដីវត្ថុកថា ចប់

# អនុប្បញ្ញត្តិទី២នៃបឋមបារាជិក
# រឿង ភិក្ខុវជ្ជីបុត្រ

[ ២៣ ] ឥឡូវនេះ ដើម្បីសម្តែងរឿងដទៃ ដែលកើតឡើងហើយ ទើបព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានពោលពាក្យជាដើមថា **តេន ខោ បន សមយេន**។ ក្នុងពាក្យថា **តេន ខោ បន សមយេន** ជាដើមនោះ មានការពណ៌នាបទដែលមិនទាន់ភ្លឺច្បាស់យ៉ាងនេះថា បទថា **វេសាលិកា** បានដល់អ្នកមានប្រក្រតីនៅក្នុងក្រុងវេសាលី ។

បទថា **វជ្ជិបុត្តកា** បានដល់ ជាកូនរបស់ត្រកូលក្នុងក្រុងវេសាលី នាដែនវជ្ជី ។

បានឮថា ឧបទ្រវទោស ការវឹកវរបានកើតឡើងក្នុងព្រះសាសនា ទាំងអស់នោះ បានកើតឡើងហើយ ព្រោះអាស្រ័យពួកភិក្ខុវជ្ជីបុត្រ ។ ពិតហើយ សូម្បីទេវទត្តភិក្ខុបានពួកភិក្ខុវជ្ជីបុត្រជាបក្ខពួកហើយ ទើបបំបែកសង្ឃ ។ ឯពួកវជ្ជីបុត្តភិក្ខុនោះឯង បានសម្តែងសត្ថុសាសនាក្រៅធម៌ ក្រៅវិន័យ ក្នុងកាលព្រះដ៏មានព្រះភាគបរិនិព្វានបាន ១០០ ឆ្នាំ បណ្តាវជ្ជីបុត្តភិក្ខុទាំងនោះ សូម្បីភិក្ខុទាំងនេះ ពួកខ្លះកាលទ្រង់បញ្ញត្តសិក្ខាបទហើយយ៉ាងនេះ ក៏បានងូតទឹកតាមសេចក្តីត្រូវការ ។បេ។ បានសេពមេថុនធម្មតាមសេចក្តីត្រូវការដោយប្រការដូច្នេះ ។

ក្នុងបទថា **ញាតិព្យសនេនបិ** នេះ មានវិនិច្ឆ័យដូច្នេះថា ពាក្យថា ការវិនាស ការទិភាស ការបែកបាក់ ការព្រាត់ប្រាស ការអន្តរាយ ទាំងអស់នេះ

មានអត្ថតែមួយ ។ ការវិនាសនៃពួកញាតិ ឈ្មោះថា ញាតិព្យសនៈ ។ ឯការវិនាសនៃញាតិនោះ ( ពាល់ត្រូវហើយ ) អធិប្បាយថា ឯការវិនាសនៃញាតិ មានការដាក់ចុះនូវរាជអាជ្ញា ត្រូវរោគបៀតបៀន ការស្លាប់ និងការព្រាត់ប្រាស ជានិមិត្ត( ពាល់ត្រូវហើយ ) ។ សូម្បីក្នុងបទទី ២ ក៏មានន័យដូច្នេះ ។ ចំណែកក្នុងបទទី ៣ រោគដែលធ្វើការមិនមានរោគឲ្យវិនាសទៅនោះឯង ឈ្មោះថា រោគព្យសនៈ ។ ពិតហើយ រោគនោះ រមែងធ្វើការមិនមានរោគឲ្យវិនាសទៅ គឺកម្ចាយទៅ បានដល់ ឲ្យវិនាសទៅ ព្រោះហេតុនោះទើបឈ្មោះថា ព្យសនៈ ការវិនាស គឺរោគ ឈ្មោះថា រោគព្យសនៈ ។ ឯការវិនាស គឺរោគនោះ ( ពាល់ត្រូវហើយ ) ។

បទថា **ផុដ្ឋា** គឺពាល់ត្រូវ បានដល់ គ្របសង្កត់ អធិប្បាយថា ដែលប្រកបព្រមហើយ ។

ប្រើនបទថា **ន មយំ ភន្តេ អានន្ទ ពុទ្ធគរហិនោ** សេចក្ដីថា លោកម្ចាស់អានន្ទ ពួកខ្ញុំមិនបានតិះដៀលព្រះពុទ្ធ គឺមិនបានពោលទោសព្រះពុទ្ធ មិនបានតិះដៀលព្រះធម៌ មិនបានតិះដៀលព្រះសង្ឃ ។

ពីរបទថា **អត្តគរហិនោ មយំ** សេចក្ដីថា ពួកខ្ញុំតិះដៀលខ្លួនឯងប៉ុណ្ណោះ គឺពោលទោសរបស់ខ្លួន ។

បទថា **អលក្ខិកា** ប្រែថា អ្នកអស់សិរី ។

បទថា **អប្បបុញ្ញា** ប្រែថា អ្នកមានបុណ្យតិច ។

ប្រើនបទថា **វិបស្សកា កុសលានំ ធម្មានំ** សេចក្ដីថា ពួកខ្ញុំនឹងគប្បី

ជាអ្នកឃើញច្បាស់នូវកុសលធម៌ទាំងឡាយ ដែលព្រះដ៏មានព្រះភាគទ្រង់ចែកទុកហើយ ក្នុងអារម្មណ៍ ៣៨ ប្រការ ។ អធិប្បាយថា ចេញអំពីអារម្មណ៍នោះហើយ នឹងឃើញច្បាស់នូវធម៌ទាំងនោះឯង ។

បទថា **បុព្វរត្តាបររត្តំ** សេចក្តីថា ខាងដើមនៃរាត្រី ឈ្មោះថា បុព្វរាត្រី ខាងចុងនៃរាត្រី ឈ្មោះថា អបររាត្រី មានពាក្យអធិប្បាយថា បឋមយាម និងបច្ឆិមយាម ។

បទថា **ពោធិបក្ខិកានំ** គឺមានក្នុងចំណែកនៃបញ្ញាជាគ្រឿងត្រាស់ដឹង អធិប្បាយថា ជាឧបការៈដល់អរហត្តមគ្គញ្ញាណ ។

បទថា **ភាវនានុយោគំ** ប្រែថា ការប្រកបរឿយៗ ក្នុងការចម្រើន ( ពោធិបក្ខិយធម៌ ) ។

ពីរបទថា **អនុយុត្តា វិហារេយ្យាម** សេចក្តីថា ពួកខ្ញុំលះបង់គហិបលិពោធ និងអាវាសបលិពោធហើយ នឹងគប្បីជាអ្នកប្រកបសេចក្តីខ្វល់ខ្វាយ មិនមានកិច្ចដទៃ នៅក្នុងសេនាសនៈដ៏ស្ងាត់ ។

បទថា **ឯវមាវុសោ** សេចក្តីថា ព្រះថេរៈ កាលមិនជ្រាបអជ្ឈាស្រ័យរបស់ជនទាំងនោះ បានស្តាប់ការគំរាមយ៉ាងច្រើន ( ពាក្យអង្វរ ) នេះ របស់ភិក្ខុទាំងនោះហើយ ទើបសម្គាល់ថា បើជនទាំងនេះ ជាបុគ្គលដូច្នេះសោត ក៏ជាការប្រពៃ ហើយទទួលពាក្យថា បាន អាវុសោទាំងឡាយ ។

## រឿង ទ្រង់ហាមមិនឱ្យវជ្ជីបុត្តភិក្ខុបព្វជ្ជាឧបសម្បទា

ពីរបទថា **អដ្ឋានំ អនវកាសោ** នេះ ជាការត្រាស់ហាមហេតុ ។ ពិត

ហើយ ហេតុ លោកហៅថា ឋានៈ និងឱកាស ព្រោះជាទីតាំងនៃផល ដោយកាពដែលផលនោះប្រព្រឹត្តទៅ ទាក់ទងដោយហេតុនោះ និងព្រោះហេតុ នោះក៏ជាឱកាសនៃផលនោះ ដោយភាពដែលហេតុនោះ ប្រព្រឹត្តទៅទាក់ទងដោយផលនោះ ។ ព្រះដ៏មានព្រះភាគ កាលទ្រង់ហាមហេតុនោះ ទើបត្រាស់ថា **អដ្ឋានមេតំ អានន្ទ អនវកាសោ** ជាដើម សេចក្ដីថា ឋានៈ ឬឱកាសនេះមិនមាន ។

ពីរបទថា **យំ តថាគតោ** សេចក្ដីថា ព្រះតថាគតគប្បីដកបារាជិកសិក្ខាបទដែលបញ្ញត្តហើយដល់សាវកទាំងឡាយ ព្រោះហេតុនៃពួកវជ្ជី ឬពួកវជ្ជីបុត្ត ដោយហេតុណា ហេតុនោះ មិនមាន សេចក្ដីពិត បើព្រះដ៏មានព្រះភាគនឹងគប្បីប្រទានឧបសម្បទាដល់វជ្ជីបុត្រទាំងនេះ ដែលទូលសូមថា ខ្ញុំព្រះអង្គទាំងឡាយគប្បីបានឧបសម្បទាដូច្នេះសោត កាលបើដូច្នោះ ព្រះដ៏មានព្រះភាគក៏នឹងគប្បីដកបារាជិកសិក្ខាបទ ដែលទ្រង់បញ្ញត្តទុកថា រមែងត្រូវអាបត្តិបារាជិកមិនមានសំវាស ។ តែព្រោះហេតុដែលទ្រង់មិនដកសិក្ខាបទដែលទ្រង់បញ្ញត្តទុកហើយនោះ ដូច្នោះ ទើបត្រាស់ថា នុ៎ះមិនមែនជាឋានៈដូច្នេះជាដើម ។

[ ២៤ ] ប្រើនបទថា **សោ អាគតោ ន ឧបសម្បាទេតព្វោ** សេចក្ដីថា ព្រះដ៏មានព្រះភាគ ទ្រង់មានសេចក្ដីអនុគ្រោះ ទ្រង់ជ្រាបថា បើជនទាំងនោះមកហើយយ៉ាងនេះ គប្បីបានទទួលឧបសម្បទាសោត ជនទាំងនោះគប្បីជាបុគ្គលមិនមានសេចក្ដីគោរពក្នុងសាសនា តែបើជនទាំងនោះតាំងនៅក្នុង

សាមណេរភូមិហើយ នឹងជាអ្នកមានសេចក្តីគោរព និងធ្វើប្រយោជន៍ខ្លួនបាន ទើបត្រាស់ថា បើជនទាំងនោះមកហើយ សង្ឃមិនគួរឲ្យឧបសម្បទា ។

ត្រើនបទថា **សោ អាគតោ ឧបសម្បាទេតព្វោ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់ជ្រាបហើយថា ភិក្ខុនោះមកហើយយ៉ាងនេះ គង់តាំងនៅក្នុងភាវៈជាភិក្ខុ និងជាអ្នកមានសេចក្តីគោរពក្នុងសាសនា ព្រោះភាពដែលលោកមិនមានសីលវិបត្តិ លោកកាលនៅមានឧបនិស្ស័យ នឹងសម្រេចប្រយោជន៍ដ៏ឧត្តមក្នុងកាលមិនយូរឡើយ ទើបត្រាស់ថា បើជនទាំងនោះមកហើយ គួរឲ្យឧបសម្បទា ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់វជ្ជីបុត្តអ្នកមិនគួរឲ្យឧបសម្បទា និងអ្នកគួរឲ្យឧបសម្បទា ក្នុងបណ្តាពួកវជ្ជីបុត្រអ្នកសេពមេថុនធម្ម មកហើយយ៉ាងនេះ មានព្រះបំណងនឹងប្រមូលរឿងទាំងបីមក ហើយទ្រង់បញ្ញត្តសិក្ខាបទឲ្យបរិបូណ៌ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះ ហើយទ្រង់បានបញ្ញត្តសិក្ខាបទឲ្យបរិបូណ៌យ៉ាងនេះថា **យោ បន ភិក្ខុ ។បេ។ អសំវាសោ** ប្រែថា ភិក្ខុណាមួយ ដល់ព្រមដោយសិក្ខា និងសាជីវៈ ( ដែលព្រះតថាគតបញ្ញត្តហើយ ) សម្រាប់ភិក្ខុទាំងឡាយ ហើយមិនពោលលាសិក្ខា មិនធ្វើឲ្យជាក់ច្បាស់នូវភាវៈ ជាអ្នកមានកម្លាំងថយ ហើយសេពមេថុនធម្ម ដោយហោចទៅ សូម្បីតែនឹងសត្វតិរច្ឆានញី ភិក្ខុនោះ ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។

# អធិប្បាយ
# សិក្ខាបទវិភង្គនៃបឋមបារាជិក
# វិន័យ ៤ យ៉ាង

[ ២៥ ] ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់ចែកអត្ថនៃសិក្ខាបទនោះ ទើបត្រាស់ពាក្យជាដើមថា **យោ បនាតិ យោ យាទិសោ** ដូច្នេះ ។

ព្រះវិនយធរ ដែលប្រាថ្នាភាពជាអ្នកឈ្លាសក្នុងសិក្ខាបទវិភង្គនៃសិក្ខាបទនោះ និងវិនយវិនិច្ឆ័យទាំងអស់ គួរជ្រាបវិន័យ ៤ យ៉ាងថា ពិតហើយ ព្រះធម្មសង្គាហកមហាថេរៈទាំងឡាយ ដែលមានឫទ្ធិច្រើនក្នុងកាលមុន បាននាំវិន័យ ៤ យ៉ាង មកបើកផ្សាយហើយ ។

វិន័យ ៤ យ៉ាងដូចម្ដេច វិន័យ ៤ យ៉ាង គឺសុត្តៈ សុត្តានុលោម អាចរិយវាទ អត្តនោមតិ ដែលព្រះនាគសេនត្ថេរពោលទុក ( ក្នុងមិលិន្ទបញ្ហា ) ថា មហាបពិត្រ សេចក្ដីដែលកុលបុត្រគប្បីទទួលដោយបទខាងដើមនោះឯង ដោយរស ដោយភាពជាវង្សនៃអាចារ្យ ដោយសេចក្ដីអធិប្បាយ ... ។

ពិតហើយ បណ្ដាពាក្យទាំងនេះ ពាក្យថា **អាហច្ចបទ** លោកសំដៅយកសុត្តៈ ។ ពាក្យថា **រស** លោកបំណងយកសុត្តានុលោម ។ ពាក្យថា **អាចរិយវង្ស** លោកសំដៅយកអាចរិយវាទ ។ ពាក្យថា **អធិប្បាយ** លោកសំដៅយកអត្តនោមតិ ។

បណ្ដាវិន័យ ៤ យ៉ាងនេះ ដែលឈ្មោះថា សុត្តៈ បានដល់ បាលីក្នុង

វិនយបិដកទាំងមូល ដែលឈ្មោះថា សុត្តានុលោម បានដល់ មហាបទេស ៤ ដែលព្រះដ៏មានព្រះភាគត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំង-ឡាយឡើយ ១ ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរ បើរបស់នោះ អនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលតថាគតមិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំងឡាយឡើយ ១ ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលតថាគតមិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ១ ។

ដែលឈ្មោះថា អាចរិយវាទ បានដល់ អដ្ឋកថា ដែលញុំាងការវិនិច្ឆ័យសាច់រឿងឲ្យប្រព្រឹត្តទៅក្រៅអំពីបាលី ដែលព្រះអរហន្ត ៥០០ អង្គ ជាធម្ម-សង្គាហកៈរចនាទុក ។

ដែលឈ្មោះថា អត្តនោមតិ បានដល់ ពាក្យដែលផុតចាកសុត្តៈ សុត្តានុលោម និងអាចរិយវាទ ពោលតាមអាការដែលប្រាកដដោយការដៅយក គឺដោយចំណេះរបស់ខ្លួន ដោយការកាន់យកន័យ ដោយការកាន់យកអត្ថ ។ ន័យម្យ៉ាងទៀត ថេរវាទទាំងអស់ដែលមកក្នុងអដ្ឋកថានៃព្រះសូត្រ

ព្រះអភិធម្ម និងព្រះវិន័យឈ្មោះថា អត្តនោមតិ ។

## វិធីសង្កេតពិនិត្យសុត្តៈ និងសុត្តានុលោមជាដើម

កុលបុត្រ ដែលអាងអត្តនោមតិនោះពោល មិនគួរនឹងកាន់យកជាពិតប្រាកដ គួរកំណត់ហេតុ ប្រៀបធៀបបាលីនឹងអត្ថ ឬអត្ថនឹងបាលី ហើយទើបពោល ។ អត្តនោមតិ គួរប្រៀបធៀបមើលក្នុងអាចរិយវាទ បើចូលគ្នា ឬសមគ្នាក្នុងអាចរិយវាទនោះ ទើបគួរកាន់យក បើមិនស៊ីគ្នា មិនសមគ្នា មិនគួរកាន់យក ។ ពិតហើយ ឈ្មោះថា អត្តនោមតិនេះ នៅជារបស់ខ្សោយកម្លាំងជាងគេ ។ អាចរិយវាទមានកម្លាំងជាងអត្តនោមតិ ។ សូម្បីអាចរិយ-វាទក៏គួរប្រៀបធៀបមើលក្នុងសុត្តានុលោម កាលស៊ីសេចក្តីគ្នា សមគ្នាពិតក្នុងសុត្តានុលោមនោះ ទើបគួរកាន់យក បើមិនចូលគ្នា មិនសមគ្នា មិនគួរកាន់យក ។ ព្រោះថា សុត្តានុលោមជារបស់មានកម្លាំងជាងអាចរិយវាទ ។ សូម្បីសុត្តានុលោម ក៏គួរផ្ទៀងផ្ទាត់មើលក្នុងសុត្តៈ បើចូលគ្នា សមគ្នាពិតក្នុងសុត្តៈនោះ ទើបគួរកាន់យក ចំណែកដែលមិនចូលគ្នា មិនសមគ្នា មិនគួរកាន់យក ព្រោះថា សុត្តៈប៉ុណ្ណោះជារបស់មានកម្លាំងជាងសុត្តានុលោម ។ ពិតហើយ សុត្តៈជារបស់ដែលបុគ្គលណាមួយ មិនអាចរចនាគម្ពីរយកមកប្រៀបធៀបបាន ដូចសង្ឃដែលធ្វើ ដូចកាលដែលព្រះពុទ្ធទាំងឡាយគង់ធរមាននៅ ។ ព្រោះដូច្នោះ កាលភិក្ខុពីរអង្គសាកច្ឆាគ្នា សកវាទីអាងសុត្តៈហើយពោល បរវាទីអាងសុត្តានុលោម ហើយពោល កាលនោះ ភិក្ខុពីរអង្គនោះ មិនគួរធ្វើការប្រទាញ ឬ តិះដៀលដល់គ្នានឹងគ្នា គួរផ្ទៀងផ្ទាត់

សុត្តានុលោមក្នុងសុត្តៈ បើស៊ីសេចក្តីគ្នា សមគ្នា គួរកាន់យក បើមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តៈប៉ុណ្ណោះ ។

បើសកវាទីអាងសុត្តៈ ហើយពោល បរវាទីអាងអាចរិយវាទ ហើយពោលសោត ទាំងពីរអង្គនោះ មិនគួរធ្វើការសង្កត់សង្កិន ឬតិះដៀលដល់គ្នានឹងគ្នា គួរផ្ទៀងផ្ទាត់អាចរិយវាទក្នុងសុត្តៈ បើត្រូវគ្នា សមគ្នា គួរកាន់យក ។ បើអាចរិយវាទមិនត្រូវគ្នា និងមិនសមគ្នា ទាំងជារបស់ដែលគួរតិះដៀល ក៏មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តៈប៉ុណ្ណោះ ។

បើសកវាទីនោះ អាងសុត្តៈហើយពោល បរវាទីអាងអត្តនោមតិពោលសោត ភិក្ខុទាំងពីរអង្គនោះមិនគួរធ្វើការប្រទាញ ឬតិះដៀលដល់គ្នានឹងគ្នា គួរផ្ទៀងផ្ទាត់អត្តនោមតិក្នុងសុត្តៈ បើចូលគ្នា សមគ្នា គួរកាន់យក បើមិនស៊ីសេចក្តីគ្នា មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តៈប៉ុណ្ណោះ ។ បើសកវាទីអាងសុត្តានុលោម ហើយពោល បរវាទីអាងសុត្តៈ ហើយពោលសោត គួរផ្ទៀងផ្ទាត់សុត្តៈក្នុងសុត្តានុលោម បើចូលគ្នា សមគ្នា ប្រាកដមកក្នុងបាលី ដែលឡើងកាន់សង្គីតិទាំង ៣ ដង ទើបគួរកាន់យក បើមិនប្រាកដដូចគ្នាយ៉ាងនោះ មិនត្រូវគ្នា មិនសមគ្នា ជាពាហិរកសូត្រ សិលោកសោឡកឬសូត្រដែលគួរតិះដៀលដទៃៗ ដែលមកអំពីបណ្តាសូត្រទាំងឡាយ មានគុឡ្ហវេស្សន្តរ គុឡ្ហវិន័យ និងគុឡ្ហវេទល្លៈជាដើម ឯណានីមួយ មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តានុលោមប៉ុណ្ណោះ ។

បើសកវាទីអាងសុត្តានុលោមពោល បរវាទីអាងអាចរិយវាទពោល

សោត គួរផ្ទៀងផ្ទាត់អាចរិយវាទក្នុងសុត្តានុលោម បើស៊ីគ្នា សមគ្នា គួរកាន់យក បើមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តានុលោមប៉ុណ្ណោះ ។

បើសកវាទីអាងសុត្តានុលោមពោល បរវាទីអាងអត្តនោមតិពោលសោត គួរផ្ទៀងផ្ទាត់អត្តនោមតិក្នុងសុត្តានុលោម បើចូលគ្នា សមគ្នា គួរកាន់យក បើមិនចូលគ្នា មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងសុត្តា-នុលោមប៉ុណ្ណោះ ។

បើសកវាទីអាងអាចរិយវាទពោល បរវាទីអាងសុត្តៈពោលសោត គួរផ្ទៀងផ្ទាត់សុត្តៈក្នុងអាចរិយវាទ បើត្រូវគ្នា សមគ្នា គួរកាន់យក ។ សូត្រដែលគួរតិះដៀលក្រៅពីនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអាចរិយវាទប៉ុណ្ណោះ ។

បើសកវាទីអាងអាចរិយវាទពោល បរវាទីអាងសុត្តានុលោម ហើយពោលសោត គួរផ្ទៀងផ្ទាត់សុត្តានុលោមក្នុងអាចរិយវាទ បើស៊ីគ្នា សមគ្នាពិត ទើបគួរកាន់យក ។ ក្រៅអំពីនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអាចរិយវាទប៉ុណ្ណោះ ។

បើសកវាទីអាងអាចរិយវាទពោល បរវាទីអាងអត្តនោមតិពោលសោត គួរផ្ទៀងផ្ទាត់អត្តនោមតិក្នុងអាចរិយវាទ បើស៊ីសេចក្តីគ្នា សមគ្នា គួរកាន់យក បើចូលគ្នាមិនបាន មិនសមគ្នា មិនគួរកាន់យក គួរតាំងនៅក្នុងអាចរិយ-វាទប៉ុណ្ណោះ។ ការកាន់យក ( មតិ ) របស់ខ្លួននោះឯង គួរធ្វើឲ្យមានកម្លាំង

( មានគោលដ្ឋាន ) ។

ម្យ៉ាងទៀត បើសកវាទីអាងអត្តនោមតិពោល បរវាទីអាងសុត្តៈពោលសោត គួរផ្ទៀងផ្ទាត់ក្នុងអត្តនោមតិ បើចូលគ្នា សមគ្នា គួរកាន់យក ។ សូត្រដែលគួរតិះដៀលក្រៅអំពីនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ ។

បើសកវាទីនេះអាងអត្តនោមតិពោល បរវាទីអាងសុត្តានុលោមពោលសោត គួរផ្ទៀងផ្ទាត់សុត្តានុលោមក្នុងអត្តនោមតិ បើចូលគ្នា សមគ្នាពិត គួរកាន់យក។ ក្រៅអំពីនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ។

បើសកវាទីអាងអត្តនោមតិពោល បរវាទីអាងអាចរិយវាទពោលសោត គួរផ្ទៀងផ្ទាត់អាចរិយវាទក្នុងអត្តនោមតិ បើចូលគ្នា សមគ្នា គួរកាន់យក ។ អាចរិយវាទដែលគួរតិះដៀលក្រៅអំពីនេះ មិនគួរកាន់យក គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ ។ ការកាន់យក ( មតិ ) របស់ខ្លួននោះឯង គួរធ្វើឲ្យមានកម្លាំង ( ឲ្យមានគោលអាង ) ។ ម្យ៉ាងទៀត មិនគួរធ្វើការជៀមជាមឬតិះដៀលក្នុងទីទាំងពួង ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត បើសកវាទីពោលអាងថា ជាកប្បិយៈ បរវាទីពោលអាងថា ជាអកប្បិយៈ គួរផ្ទៀងផ្ទាត់របស់នោះៗ ក្នុងសុត្តៈ និងសុត្តានុលោម បើរបស់នោះជាកប្បិយៈ គួរតាំងនៅក្នុងវត្ថុជាកប្បិយៈ បើរបស់នោះជាអកប្បិយៈ ក៏គួរតាំងនៅក្នុងរបស់ដែលជាអកប្បិយៈ ។

បើសកវាទីចង្អុលប្រាប់ហេតុ និងពាក្យវិនិច្ឆ័យជាច្រើនអំពីសូត្រ ជា

គ្រឿងសាធកៈ វត្ថុជាកប្បិយៈដល់បរវាទីនោះសោត បរវាទីមិនជួបហេតុ ក៏គួរតាំងនៅក្នុងរបស់ដែលជាកប្បិយៈ ។

បើបរវាទីចង្អុលហេតុ និងពាក្យវិនិច្ឆ័យជាច្រើនអំពីសូត្រ ជាគ្រឿងសាធកៈ នូវវត្ថុជាអកប្បិយៈដល់សកវាទីនោះសោត សកវាទីនោះមិនគួរប្រកាន់មាំថា ការកាន់យកមតិរបស់ខ្លួន ( ត្រូវតែមួយចំណែក ) គួរព្រមទទួលថា សាធុ ហើយតាំងនៅក្នុងរបស់ដែលជាអកប្បិយៈប៉ុណ្ណោះ ។ បើស្រមោលនៃហេតុរបស់ទាំងពីរចំណែក រមែងប្រាកដច្បាស់សោត សេចក្តីទាំងពីរចំណែកផ្ទុយគ្នានោះឯង ជាការល្អ តែគួរតាំងនៅក្នុងរបស់ដែលជាអកប្បិយៈ ។ សេចក្តីពិត កាលមកដល់វិន័យហើយ ឯភិក្ខុបរិស័ទគួរអាស្រ័យការពិចារណាដល់របស់ដែលគួរ និងមិនគួរការពារទុក គួរធ្វើការកាន់យកឲ្យមាំទាំ គួរកាត់ក្រសែចេញ គួរតាំងនៅក្នុងភាពជាបុគ្គលធ្ងន់ធ្ងរនោះឯង ។

ម្យ៉ាងទៀត បើសកវាទីពោលអាងថា ជាអកប្បិយៈ បរវាទីអះអាងថា ជាកប្បិយៈ គួរផ្ទៀងផ្ទាត់វត្ថុនោះៗ ក្នុងសុត្តៈ និងសុត្តានុលោម បើវត្ថុនោះជាកប្បិយៈ គួរតាំងនៅក្នុងវត្ថុដែលជាកប្បិយៈ បើរបស់នោះជាអកប្បិយៈ គួរតាំងនៅក្នុងរបស់ដែលជាអកប្បិយៈ ។

បើសកវាទីចង្អុលដល់របស់ ដែលជាអកប្បិយៈ ដោយសូត្រ ពាក្យវិនិច្ឆ័យ និងហេតុជាច្រើនសោត បរវាទីមិនជួបហេតុ គួរតាំងនៅក្នុងរបស់ដែលជាអកប្បិយៈ ។

បើបរវាទីចង្អុលដល់របស់ដែលជាកប្បិយៈ ដោយសូត្រ ពាក្យវិនិច្ឆ័យ

និងហេតុជាច្រើនសោត សកវាទីមិនបានជួបហេតុ គួរតាំងនៅក្នុងរបស់ដែលជាកប្បិយៈ បើស្រមោលនៃហេតុក្នុងរបស់ទាំងពីរចំណែក រមែងប្រាកដច្បាស់សោត មិនគួរលះបង់ការកាន់យក ( មតិ ) របស់ខ្លួន ។ ដូចក្នុងវត្ថុដែលជាកប្បិយៈ និងអកប្បិយៈ និងក្នុងវត្ថុដែលជាអកប្បិយៈ និងកប្បិយៈ លោកពោលវិនិច្ឆ័យនេះទុកហើយ យ៉ាងណា ក្នុងវាទៈថា ជាអនាបត្តិ និងអាបត្តិក្តី ក្នុងវាទៈថា ជាអាបត្តិ និងអនាបត្តិក្តី ក្នុងវាទៈថា ជាលហុកាបត្តិ និងគរុកាបត្តិក្តី ក្នុងវាទៈថា ជាគរុកាបត្តិ និងលហុកាបត្តិក្តី ក៏គួរជ្រាបវិនិច្ឆ័យ ដូច្នោះ។

ពិតហើយ ក្នុងវាទៈដែលពោលថា ជាអនាបត្តិ និងអាបត្តិជាដើមនេះ មានការផ្សេងគ្នា ព្រោះហេតុត្រឹមឈ្មោះប៉ុណ្ណោះ ក្នុងន័យនៃការប្រកបសេចក្តី មិនមានការផ្សេងគ្នាឡើយ ព្រោះដូច្នោះ ការប្រកបសេចក្តី ទើបលោកមិនធ្វើឲ្យពិស្តារ បើកើតពាក្យវិនិច្ឆ័យដល់របស់ដែលជាកប្បិយៈ និងអកប្បិយៈជាដើមយ៉ាងនេះហើយ ចំណែកណាបានជួបហេតុច្រើន ក្នុងសុត្តៈ សុត្តានុលោម អាចរិយវាទ និងអត្តនោមតិ គួរតាំងនៅក្នុងវាទៈរបស់ចំណែកនោះ ។ ម្យ៉ាងទៀត ទាំងពីរចំណែក កាលមិនបានជួបហេតុ និងពាក្យវិនិច្ឆ័យដោយប្រការទាំងពួង មិនគួរលះបោលនូវសុត្តៈ គួរតាំងនៅក្នុងសុត្តៈប៉ុណ្ណោះដូច្នេះឯង ។ អ្នកទ្រទ្រង់វិន័យ ដែលប្រាថ្នាភាពជាអ្នកឈ្លាសក្នុងសិក្ខាបទក្តី សិក្ខាបទវិភង្គក្តី វិន័យវិនិច្ឆ័យទាំងអស់ក្តី គួរជ្រាបវិន័យ ៤ យ៉ាងនេះ ដូចពណ៌នាមកដូច្នេះ ។

## វិនយធរប្រកបដោយលក្ខណៈ ៣ យ៉ាង

*វិនយធរ កាលប្រាបមហាបទេស ៤ នេះហើយ ក៏គួរជាអ្នកប្រកបដោយលក្ខណៈ ៣ ។ ពិតហើយ លក្ខណៈនៃវិនយធរ ៣ យ៉ាងគួរប្រាថ្នា ។ លក្ខណៈ ៣ យ៉ាងដូចម្តេច លក្ខណៈ ៣ យ៉ាង គឺពាក្យថា សូត្ររបស់ព្រះវិនយធរនោះ ជាពុទ្ធវចនៈដែលលោកបានទ្រទ្រង់ ចាំស្ទាត់រត់មាត់ ស្ទាត់ជំនាញល្អ វិនិច្ឆ័យ បានស្រួលតាមសុត្តៈ និងព្យញ្ជនៈ នេះជាលក្ខណៈ ១ ។ ពាក្យថា វិនយធរនោះ ជាអ្នកមាំទាំ មិនរំកើបក្នុងវិន័យ នេះជាលក្ខណៈ ទី ២ ។ ពាក្យថា លំដាប់អាចារ្យ ជាលំដាប់ដែលវិនយធរនោះ ចាំស្ទាត់ជំនាញធ្វើឲ្យជាក់ច្បាស់ក្នុងចិត្តដោយល្អ ពិចារណាបានត្រឹមត្រូវហើយ នេះជាលក្ខណៈទី ៣ ។*

*ក្នុងពាក្យថា* **សុត្តញ្ច** *ជាដើមនោះ មានវិនិច្ឆ័យថា វិនយបិដកទាំងអស់ ឈ្មោះថា សុត្តៈ សុត្តៈរបស់វិនយធរនោះ ជាពុទ្ធវចនៈដែលមកត្រឹមត្រូវ គឺមកដោយល្អ ។*

*បទថា* **សុប្បវត្តិតំ** *បានដល់ ប្រព្រឹត្តទៅដោយល្អ គឺជំនាញ រត់មាត់ ។*

*ប្រើនបទថា* **សុវិនិច្ឆិតំ សុត្តសោ អនុព្យញ្ជនសោ** *បានដល់ ដែលវិនិច្ឆ័យបានល្អ គឺដែលខ្លួនកាត់សេចក្តីសង្ស័យ រៀនយកដោយបាលី បរិបុច្ឆា និងអដ្ឋកថា ។*

*ប្រើនបទថា* **វិនយេ ខោ បន ឋិតោ ហោតិ** *សេចក្តីថា វិន័យធរនោះ ជាអ្នកតាំងមាំក្នុងវិន័យ ដោយភាពជាលជ្ជីភិក្ខុ ។ ពិតហើយ អលជ្ជីភិក្ខុ សូម្បីជាពហុសូត ព្រោះតម្លៃដែលខ្លួនជាអ្នកជូនក្នុងលាភ ក៏ក្លែងពោលឲ្យ*

ខុសបែបផែន សម្តែងសត្ថុសាសនាក្រៅធម៌ ក្រៅវិន័យ រមែងធ្វើឧបទ្រពជាច្រើនក្នុងសាសនា គឺញុំាងឲ្យកើតសង្ឃភេទខ្វះ សង្ឃរាជិខ្វះ ។ ចំណែកលជ្ជីភិក្ខុ ជាអ្នកច្រើនដោយសេចក្តីរង្កៀស ស្រឡាញ់ការសិក្សា សូម្បីព្រោះហេតុនៃជីវិត ក៏មិនក្លែងពោលឲ្យខុសទំនងបែបបទ រមែងសម្តែងចំពោះធម៌ ចំពោះវិន័យប៉ុណ្ណោះ គឺធ្វើសត្ថុសាសនាឲ្យជាទីគោរព ។ ពិតហើយ ព្រះមហាថេរៈទាំងឡាយក្នុងកាលមុន បន្ទឹវាចា ៣ ដងថា ក្នុងអនាគតកាល លជ្ជីភិក្ខុនឹងរក្សាទុក លជ្ជីភិក្ខុនឹងរក្សាទុក ដូច្នេះជាដើម ។ ឯភិក្ខុអង្គណាជាលជ្ជីដូចពោលមកហើយនោះ ភិក្ខុអង្គនោះ កាលមិនលះបង់ មិនប្រព្រឹត្តកន្លងវិន័យជាអ្នកតាំងមាំ គឺមាំទាំនៅក្នុងព្រះវិន័យ ដោយភាពជាលជ្ជីភិក្ខុដូច្នេះឯង ។

បទថា **អសំហិរោ** សេចក្តីថា បុគ្គលណាត្រូវអ្នកដទៃសួរដោយបាលីដោយទីទាប ឬទីខ្ពស់ ដោយលំដាប់បទ ឬអដ្ឋកថា រមែងញាប់ញ័រ រសាប់-រសល់ មិនអាចតាំងមាំនៅបាន រមែងបណ្តោយតាមពាក្យដែលអ្នកដទៃពោលបោលវាទៈរបស់ខ្លួន កាន់យកវាទៈរបស់អ្នកដទៃ បុគ្គលនោះ ឈ្មោះថា ជាអ្នកញាប់ញ័រ ។ ចំណែកបុគ្គលណាត្រូវអ្នកដទៃសួរដោយបទខាងក្រោម និងខាងលើ ឬដោយលំដាប់បទក្នុងបាលីក្តី ក្នុងអដ្ឋកថាក្តី រមែងមិនញាប់ញ័រមិនរសាប់រសល់ ប្រៀបដូចយកចន្ទាសចាប់រោមមួយសរសៃៗ ដូច្នោះ ចង្អុលប្រាប់គេថា ខ្ញុំពោលយ៉ាងនេះ អាចារ្យទាំងឡាយរបស់ខ្ញុំក៏ពោលយ៉ាងនេះ ។

ម្យ៉ាងទៀត បាលី និងវិនិច្ឆយបាលី តាំងនៅក្នុងបុគ្គលណា មិនដល់នូវការអស់ទៅ សូន្យទៅ ដូចខ្លាញ់រាជសីហ៍ ដែលដាក់ក្នុងភាជនៈមាស មិន

*ដល់នូវការអស់ទៅដូច្នោះ បុគ្គលនេះ លោកហៅថា បុគ្គលមិនញាប់ញ័រ ។*

*ច្រើនបទថា* **អាចរិយបរម្បរា ខោ បនស្ស សុគ្គហិតា ហោតិ** *សេចក្ដីថា លំដាប់នៃព្រះថេរៈ គឺលំដាប់វង្ស ជាលំដាប់ដែលព្រះវិនយធរនោះ ចាំបានយ៉ាងច្បាស់លាស់ ។*

*បទថា* **សុមនសិកតា** *បានដល់ ធ្វើឲ្យចាំយ៉ាងល្អ គ្រាន់តែនឹកក៏ ប្រាកដបាន ដូចគ្នានឹងប្រទីបដែលឆេះសន្ធោសន្ធៅ ដូច្នោះ ។*

*បទថា* **សូបធារិតា** *បានដល់ ពិចារណាដោយល្អ គឺពិចារណាដោយ ការបន្តគ្នានៃខាងដើម និងខាងចុង ដោយផល និងដោយហេតុ ។*

## លំដាប់អាចារ្យ រាប់អំពីឧបាលិត្ថេរមក

*បុគ្គលលះមតិរបស់ខ្លួនហើយ ជាអ្នកពោលកាពបរិសុទ្ធនៃអាចារ្យ គឺ នាំលំដាប់អាចារ្យ បានដល់ លំដាប់នៃព្រះថេរៈទាំងអស់យ៉ាងនេះ គឺអាចារ្យ របស់ខ្ញុំរៀនយកក្នុងសម្នាក់របស់អាចារ្យឈ្មោះនោះ អាចារ្យឈ្មោះនោះរៀន យកក្នុងសម្នាក់អាចារ្យឈ្មោះនោះ ទៅតាំងទុករហូតដល់ពាក្យថា ព្រះឧបាលី រៀនយកក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ។*

*អាចារ្យអង្គតៗ មក បានអំពីព្រះឧបាលិត្ថេរនោះមក គឺបានលំដាប់នៃ អាចារ្យ បានដល់ ជួរនៃព្រះថេរៈទាំងអស់ រហូតឲ្យដល់អាចារ្យរបស់ខ្លួន ហើយតាំងទុកយ៉ាងនេះថា ព្រះឧបាលិត្ថេររៀនមកក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ព្រះទាសកត្ថេររៀនមកក្នុងសម្នាក់របស់ព្រះឧបាលិត្ថេរ ដែលជាឧបជ្ឈាយ៍នៃ ខ្លួន ព្រះសោណកត្ថេររៀនមកក្នុងសម្នាក់របស់ព្រះទាសកត្ថេរ ដែលជា*

ឧបជ្ឈាយ៍របស់ខ្លួន ព្រះសិគ្គវត្ថេររៀនមកក្នុងសម្នាក់របស់ព្រះសោណកត្ថេរ ដែលជាឧបជ្ឈាយ៍របស់ខ្លួន ព្រះមោគ្គលីបុត្តតិស្សត្ថេររៀនមកក្នុងសម្នាក់ព្រះសិគ្គវត្ថេរ និងព្រះចណ្ឌវជ្ជិត្ថេរ ដែលជាឧបជ្ឈាយ៍របស់ខ្លួន ។ ពិតហើយ លំដាប់នៃអាចារ្យដែលអ្នកទ្រទ្រង់វិន័យ រៀនយកហើយយ៉ាងនេះ លោកក៏បានចាំដោយល្អហើយ តែកាលមិនអាចនឹងរៀនយកយ៉ាងនោះ ក៏គួររៀនយកត្រឹមតែ ២-៣ លំដាប់ក៏ល្មម ។ ពិតហើយ ដោយន័យចុងក្រោយ គួរជ្រាបដូចអាចារ្យ និងអាចារ្យរបស់អាចារ្យ ពោលបាលី និងបរិបុច្ឆា ដូច្នោះ ។

## ឋានៈ ៦ សម្រាប់វិនិច្ឆ័យអធិករណ៍

ឯវិនយធរដែលប្រកបព្រមដោយលក្ខណៈ ៣ យ៉ាងនេះហើយ កាលសង្ឃប្រជុំគ្នាដើម្បីវិនិច្ឆ័យក្តី ហើយរឿងក៏ឈោងចុះហើយ ទាំងអ្នកចោទ និងអ្នកត្រូវចោទក៏ឲ្យការណ៍ហើយ កាលនឹងនិយាយ មិនគួរប្រញាប់កាត់សេចក្តីភ្លាមទេ គួរពិនិត្យមើលឋានៈទាំង ៦ ជាមុនសិន ។

ឋានៈ ៦ យ៉ាងដូចម្តេច ឋានៈ ៦ យ៉ាងនោះ គឺគួរពិនិត្យមើលសំណុំរឿង ១ ពិនិត្យមើលមាតិកា ១ ពិនិត្យមើលបទភាជនីយ ១ ពិនិត្យមើលតិកបរិច្ឆេទ ១ ពិនិត្យមើលអន្តរាបត្តិ ១ ពិនិត្យមើលអនាបត្តិ ១ ។

ពិតហើយ ព្រះវិនយធរ កាលនឹងពិនិត្យអធិករណ៍ រមែងឃើញអាបត្តិខ្លះ យ៉ាងនេះ គឺភិក្ខុដែលមានចីវរបាត់ គួរយកស្មៅ ឬស្លឹកឈើបិទបាំងកាយ សឹមមក តែមិនគួរមកទាំងអាក្រាតឡើយ ភិក្ខុណាអាក្រាតកាយដើរមក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ព្រះវិនយធរនោះ កាលនាំសូត្រនោះ

មកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

កាលពិនិត្យមើលមាតិកា លោករមែងឃើញអាបត្តិ ៥ កង កងណានីមួយ ដោយន័យជាដើមថា ភិក្ខុពោលកុហកដោយដឹងខ្លួន ត្រូវអាបត្តិបាចិត្តិយ លោកកាលនាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

លោកកាលពិនិត្យមើលបទភាជនីយ រមែងឃើញអាបត្តិ ៧ កង កងណានីមួយ ដោយន័យជាដើមថា ភិក្ខុសេពមេថុនធម្មក្នុងសរីរៈដែលសត្វមិនទាន់បានកកេរស៊ី ត្រូវអាបត្តិបារាជិក សេពមេថុនធម្មក្នុងសរីរៈដែលសត្វកកេរស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ ។ កាលលោកនាំសូត្រអំពីបទភាជនៈមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

លោកកាលពិនិត្យមើលតិកបរិច្ឆេទ រមែងឃើញការកំណត់តិកសង្ឃាទិសេសខ្លះ តិកបាចិត្តិយខ្លះ តិកទុក្កដខ្លះ អាបត្តិឯណានីមួយខ្លះ ។ លោកកាលនាំសូត្រមកអំពីបាលីតិកបរិច្ឆេទនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

លោកកាលពិនិត្យមើលអន្តរាបត្តិ នឹងឃើញអន្តរាបត្តិ ដែលមានក្នុងចន្លោះនៃសិក្ខាបទយ៉ាងនេះ គឺភិក្ខុលើកឡើងនូវគប់ភ្លើង ( ធ្លាក់ទៅត្រង់ទីនោះវិញ ) ត្រូវអាបត្តិទុក្កដ លោកកាលនាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

លោកកាលពិនិត្យមើលអនាបត្តិ នឹងឃើញអនាបត្តិដែលលោកសម្តែងទុកហើយ ក្នុងសិក្ខាបទនោះៗ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អាបត្តិ

មិនមានដល់ភិក្ខុដែលមិនត្រេកអរ មិនមានថេយ្យចិត្ត មិនមានបំណងនឹងឲ្យស្លាប់ មិនមានបំណងនឹងអួត មិនមានបំណងនឹងបញ្ចេញ ( នូវទឹកសុក្កៈ ) មិនក្លែង មិនដឹង មិនមានសតិ ។ លោកកាលនាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

ពិតហើយ ភិក្ខុណាជាអ្នកឈ្លាសក្នុងវិន័យ ៤ យ៉ាង សម្បូរដោយលក្ខណៈ ៣ បានពិនិត្យមើលឋានៈ ៦ យ៉ាងនេះហើយ នឹងរម្ងាប់អធិករណ៍បាន ។ ការវិនិច្ឆ័យ ( អធិករណ៍ ) របស់ភិក្ខុនោះ បុគ្គលណាមួយឲ្យប្រព្រឹត្តទៅប្រៀបធៀបមិនបាន ហាក់ដូចជាការវិនិច្ឆ័យដែលព្រះសម្មាសម្ពុទ្ធទ្រង់វិនិច្ឆ័យឯង ដូច្នោះ ។

## វិធីវិនិច្ឆ័យអធិករណ៍

បើភិក្ខុអង្គខ្លះ ដែលធ្វើការកន្លងល្មើសសិក្ខាបទហើយ ចូលទៅរកភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះ យ៉ាងនោះហើយ គប្បីសួរដល់ការរង្កៀសសង្ស័យរបស់ខ្លួនសោត ភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះ គួរធ្វើកំណត់ឲ្យល្អ បើជាអនាបត្តិ ក៏គួរប្រាប់ថា ជាអនាបត្តិ តែបើជាអាបត្តិ ក៏គួរប្រាប់ថាជាអាបត្តិ បើអាបត្តិនោះជាទេសនាគាមិនី ក៏គួរប្រាប់ថា ជាទេសនាគាមិនី បើវុដ្ឋានគាមិនី ក៏គួរប្រាប់ថា ជាវុដ្ឋានគាមិនី បើធាយាបារាជិកប្រាកដដល់ភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះសោត មិនគួរប្រាប់ថា ជាអាបត្តិបារាជិក ។ ព្រោះហេតុអ្វី ព្រោះថា ការកន្លងល្មើសមេថុនធម្ម និងការកន្លងល្មើសឧត្តរិមនុស្សធម្ម ជារបស់គ្រោតគ្រាត ។ ចំណែកការកន្លងល្មើសក្នុងអទិន្នាទាន

និងមនុស្សវិគ្គហៈ ជារបស់សុខុម ដែលមានចិត្តផ្លាស់ប្តូរបរហ័ស ភិក្ខុត្រូវវិតិក្កមទាំងពីរនោះ ដោយអាការសុខុមនោះឯង ( និង ) រមែងរក្សាទុកដោយអាការសុខុម ( ដូចគ្នា ) ។ ព្រោះហេតុនោះ ភិក្ខុដែលត្រូវសួរការវេៀសសង្ស័យ ដែលមានការល្មើសនោះ ជាទីតាំងដោយពិសេស មិនគួរពោលថា ត្រូវអាបត្តិ បើអាចារ្យរបស់លោកនៅមានជីវិតសោត បន្ទាប់អំពីនោះ ភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះ គួរបញ្ជូនភិក្ខុនោះទៅថា លោកចូរសួរអាចារ្យរបស់ខ្ញុំមើលចុះ ។ បើលោកត្រឡប់មកវិញប្រាប់ថា អាចារ្យរបស់លោកផ្ទៀងផ្ទាត់អំពីព្រះសូត្រ ព្រះវិន័យហើយ ប្រាប់ខ្ញុំថា ជាសតេកិច្ឆា( ល្មមកែកុនបាន ) ក្នុងកាលនោះ ភិក្ខុអ្នកឈ្លាសក្នុងការវិនិច្ឆ័យនោះ គួរពោលនឹងលោកថា សាធុ សាធុ លោកចូរធ្វើដូចអាចារ្យប្រាប់ចុះ ។ បើអាចារ្យលោកមិនមានទេ តែព្រះថេរៈដែលរៀនរួមជាមួយខ្លួននៅមាន គប្បីបញ្ជូនលោកទៅកាន់សម្នាក់របស់ព្រះថេរៈនោះ ដោយប្រាប់ថា ព្រះថេរៈដែលរៀនជាមួយខ្ញុំ ជាគណៈបាមោក្ខមាន លោកចូរទៅសួរលោកមើលចុះ ។ កាលព្រះថេរៈនោះវិនិច្ឆ័យថា ជាសតេកិច្ឆា ក៏គួរប្រាប់នឹងលោកថា សាធុ លោកចូរធ្វើតាមពាក្យរបស់ព្រះថេរៈនោះឲ្យល្អនោះឯង ។ បើព្រះថេរៈដែលជាអ្នករៀនជាមួយគ្នានឹងលោកមិនមានសោត តែមានភិក្ខុដែលជាអន្តេវាសិកដែលជាបណ្ឌិត គប្បីបញ្ជូនលោកទៅកាន់សម្នាក់របស់ភិក្ខុដែលជា អន្តេវាសិកនោះ ដោយប្រាប់ថា ចូរលោកទៅសួរភិក្ខុកំលោះអង្គនោះមើលចុះ ។ កាលភិក្ខុដែលជាអន្តេវាសិកនោះវិនិច្ឆ័យថា ជាសតេកិច្ឆា ក៏គួរពោលជាមួយលោកថា

សាធុ ចូរលោកធ្វើតាមពាក្យរបស់ភិក្ខុនោះឲ្យល្អ ។ បើធាយាបារាជិកនោះឯង ប្រាកដដល់ភិក្ខុកំលោះដែរសោត ភិក្ខុកំលោះនោះក៏មិនគួរប្រាប់ភិក្ខុដែលត្រូវអាបត្តិថា លោកត្រូវអាបត្តិបារាជិកហើយ ។

# ភិក្ខុទុស្សីលប្រព្រឹត្តកម្មដ្ឋានមិនចម្រើន

ពិតហើយ ការកើតឡើងនៃព្រះពុទ្ធ ជារបស់រកបានដោយលំបាក បព្វជ្ជា និងឧបសម្បទា ជារបស់បានដោយកម្រជាងនោះ ។ តែវិនយធរ-ភិក្ខុពោលយ៉ាងនេះថា អ្នកចូរបោសសម្អាតឱកាសដែលស្ងប់ស្ងាត់ ហើយអង្គុយសម្រាកពេលថ្ងៃ ជម្រះសីលឲ្យបរិសុទ្ធ ចូរធ្វើមនសិការ អាការៈ ៣២ មើលសិន ។ បើសីលរបស់ភិក្ខុនោះ មិនពព្រុសពពាលសោត កម្មដ្ឋានរមែងបន្ត ។ សង្ខារទាំងឡាយ ជារបស់ប្រាកដច្បាស់ឡើង ចិត្តក៏ជាឯកគ្គតាដូចបានសម្រេចឧបចារៈ និងអប្បនាសមាធិ ដូច្នោះ សូម្បីថ្ងៃខាងមុខទៅក៏ដោយ លោកក៏មិនជ្រាប ។ តែក្នុងថ្ងៃកន្លងទៅ លោកមកកាន់ទីឧបដ្ឋាកហើយ គួរពោលយ៉ាងនេះថា ការប្រព្រឹត្តទៅនៃចិត្តរបស់លោកដូចម្តេច កាលលោកប្រាប់ការប្រព្រឹត្តទៅនៃចិត្តហើយ គួរពោលនឹងលោកថា ដែលបានឈ្មោះថា បព្វជ្ជាមានភាពបរិសុទ្ធនៃចិត្តជាប្រយោជន៍ អ្នកកុំប្រមាទចូរបំពេញសមណធម៌ចុះ ។ ចំណែកភិក្ខុណាមានសីលដាច់ កម្មដ្ឋានរបស់ភិក្ខុនោះរមែងមិនបន្ត ចិត្តរមែងរំជើបរំជួល ត្រូវភ្លើង គឺការក្តៅក្រហាយដុតរោលដូចត្រូវចាក់ទម្លុះដោយជន្លួញ ដូច្នោះ ភិក្ខុនោះរមែងក្រោកឡើងក្នុងខណៈនោះឯង ដូចអង្គុយនៅលើដុំថ្មដែលក្តៅ ដូច្នោះ ។ កាលលោកមកហើយ

គប្បីសួរថា ការប្រព្រឹត្តទៅនៃចិត្តរបស់លោកដូចម្តេច កាលលោកប្រាប់ការប្រព្រឹត្តទៅនៃចិត្តហើយ គួរពោលថា ឈ្មោះថា ការកំបាំងរបស់អ្នកធ្វើបាប-កម្ម រមែងមិនមានក្នុងលោក ពិតហើយ បុគ្គលធ្វើកម្មអាក្រក់ រមែងដឹងដោយខ្លួនឯងមុនអ្នកដទៃទាំងអស់ បន្ទាប់អំពីនោះ អារក្ខទេវតាទាំងឡាយ សមណព្រាហ្មណ៍ និងទេវតាដទៃៗ ដែលដឹងចិត្តរបស់បុគ្គលដទៃ រមែងដឹង ( កម្មអាក្រក់ ) របស់ខ្លួន ឥឡូវនេះ អ្នកឯងចូរស្វែងរកភាពសួស្តីដល់ខ្លួនឯងចុះ ។

ឥឡូវនេះ ខ្ញុំនឹងពណ៌នាអត្ថ គឺការចែកន័យសិក្ខាបទតទៅ ។ ក្នុងពាក្យថា **យោ បនាតិ យោ យាទិសោ** ព្រះដ៏មានព្រះភាគត្រាស់ទុក មានវិនិច្ឆ័យយ៉ាងនេះថា ពីរបទថា **យោ បន** ជាបទដែលគួរចែក ។ បទជាដើមថា **យោ យាទិសោ** ជាដើមចែកនៃបទថា **យោ បន** នោះ ។ ក្នុងពីរបទថា **យោ បន** នេះ សព្ទថា **បន** ជានិបាត បទថា **យោ** ជាបទប្រាប់អត្ថ បទថា **យោ** នោះ សម្តែងបុគ្គលដោយមិនចំពោះខ្លួន ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគកាលទ្រង់សម្តែងអត្ថនៃបទថា **យោ** នោះ ទើបត្រាស់ចំពោះ **យោ** សព្ទ ដែលសម្តែងបុគ្គលដោយមិនចំពោះ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបន័យក្នុងបទថា **យោ បន** នេះ យ៉ាងនេះ ។

បទថា **យោ បន** អធិប្បាយថា **យោកោចិ** ប្រែថា បុគ្គលឯណាមួយ ។ ឯបុគ្គលដែលឈ្មោះថា បុគ្គលឯណានីមួយនោះ រមែងប្រាកដដោយអាការឯណាមួយ ក្នុងភេទ ការប្រកប ជាតិ ឈ្មោះ គោត្រ សីល វិហារធម៌

គោចរ និងវិន័យ ដោយពិត ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ប្រកាសប្រភេទនោះ ដើម្បីឲ្យស្គាល់បុគ្គលនោះ ដោយអាការយ៉ាងនោះ ទើបត្រាស់ពាក្យថា **យាទិសោ** ជាដើម ។ ក្នុងពាក្យថា **យាទិសោ** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា បទថា **យាទិសោ** សេចក្ដីថា ពោលដោយអំណាចភេទ ទោះជាបុគ្គលប្រភេទណាក៏ដោយ ជាមនុស្សខ្ពស់ ឬ ទាប ខ្មៅ ឬ ស មានសម្បុរលឿង ស្គម ឬធាត់ក៏ដោយ ។

បទថា **យថាយុត្តោ** សេចក្ដីថា ពោលដោយអំណាចការប្រកប ទោះជាមនុស្សប្រកបដោយការងារណាមួយក៏ដោយ ទោះជាបុគ្គលប្រកបដោយនវកម្មក្ដី ប្រកបដោយឧទ្ទេសក្ដី ប្រកបដោយធុរៈ គឺការអប់រំ ( គឺវិបស្សនាធុរៈ ) ក្ដី ។

បទថា **យថាជច្ចោ** សេចក្ដីថា ពោលដោយអំណាចជាតិ ទោះជាបុគ្គលមានជាតិយ៉ាងណាក្ដី គឺជាក្សត្រ ជាព្រាហ្មណ៍ ជាវេស្សៈ ឬជាសូទ្រៈក្ដី ។

បទថា **យថានាមោ** សេចក្ដីថា ពោលដោយអំណាចឈ្មោះ ទោះជាបុគ្គលមានឈ្មោះយ៉ាងណា គឺឈ្មោះថា ពុទ្ធរក្ខិតៈក្ដី ធម្មរក្ខិតៈក្ដី សង្ឃរក្ខិតៈក្ដី ។

បទថា **យថាគោត្តោ** សេចក្ដីថា ពោលដោយអំណាចគោត្រ ទោះជាអ្នកមានគោត្រយ៉ាងណាក៏ដោយ គឺកច្ចានគោត្រក្ដី វាសេដ្ឋគោត្រក្ដី កោសិយគោត្រក្ដី ។

បទថា **យថាសីលោ** សេចក្តីថា មានប្រក្រតីទាំងឡាយ ទោះជាមានប្រក្រតីយ៉ាងណាក៏ដោយ គឺជាអ្នកមាននវកម្មជាប្រក្រតីក្តី មានឧទ្ទេសជាប្រក្រតីក្តី មានធុរៈ គឺការអប់រំ ( វិបស្សនាធុរៈ ) ក្តី ។

បទថា **វិហារី** សេចក្តីថា ក្នុងវិហារធម៌ទាំងឡាយ ទោះជាវិហារធម៌ណាក៏ដោយ គឺជាអ្នកមាននវកម្មជាវិហារធម៌ក្តី មានឧទ្ទេសជាវិហារធម៌ក្តី មានធុរៈជាវិហារធម៌ក្តី ។

បទថា **យថាគោចរោ** សេចក្តីថា ក្នុងគោចរទាំងឡាយ ទោះជាគោចរឯណាទីមួយក៏ដោយ គឺជាបុគ្គលមាននវកម្មជាគោចរក្តី មានឧទ្ទេសជាគោចរក្តី មានធុរៈជាគោចរក្តី ។

ចំណែកបទថា **ថេរោ វា** ជាដើម មាននិទ្ទេសដូច្នេះថា ទោះជាបុគ្គលណា ក្នុងបណ្តាបុគ្គលចម្រើនដោយវ័យជាដើម អធិប្បាយថា ជាព្រះថេរៈព្រោះមានវស្សាគម្រប់ ១០ ក្តី ជានវៈ ព្រោះមានវស្សាតិចជាង ៥ ក្តី ជាមជ្ឈិមបុគ្គល ព្រោះមានវស្សាច្រើនជាង ៥ ក្តី ។ ដោយពិត បុគ្គលទាំងអស់ ព្រះដ៏មានព្រះភាគត្រាស់ក្នុងអត្ថនេះថា **យោ បន**។

# អធិប្បាយ អត្ថនៃភិក្ខុសព្ទ

[ ២៦ ] ក្នុងភិក្ខុនិទ្ទេស មាននិទ្ទេសដូច្នេះថា បុគ្គលណារមែងសូម ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា អ្នកសូម ។ អធិប្បាយថា ទោះបានក៏ដោយ មិនបានក៏ដោយ រមែងសូមដោយវិធីសូមដ៏ប្រសើរ ។ ឈ្មោះថា បុគ្គល អាស្រ័យការដើរសូម ព្រោះជាអ្នកអាស្រ័យការដើរសូម

ដែលព្រះពុទ្ធជាដើម ទ្រង់អាស្រ័យហើយ ។ ពិតហើយ បុគ្គលណាមួយ លះគំនរភោគៈតិច ឬច្រើន ចេញចាកផ្ទះ បួសមិនមានផ្ទះ បុគ្គលនោះ ឈ្មោះថា អាស្រ័យការដើរសូម ព្រោះលះការចិញ្ចឹមជីវិតដោយកសិកម្ម និង គោរក្ខកម្មជាដើមចោល រមែងទទួលយកភេទនោះឯង ព្រោះដូច្នោះ ទើប ឈ្មោះថា ភិក្ខុ ។

ម្យ៉ាងទៀត សូម្បីចាន់កត្តដែលគេនាំមកដោយអម្រែក ក្នុងកណ្ដាលវិហារ ក៏ឈ្មោះថា អាស្រ័យការដើរសូម ព្រោះមានការរស់នៅអាស្រ័យដោយអ្នក ដទៃ ព្រោះដូច្នោះ ទើបឈ្មោះថា ភិក្ខុ ។

ម្យ៉ាងទៀត ឈ្មោះថា អាស្រ័យការដើរសូម ព្រោះជាអ្នកកើតឧស្សាហៈ ក្នុងបព្វជ្ជា អាស្រ័យភោជន គឺពំនូតបាយដែលរកបានដោយកម្លាំងស្នង ព្រោះដូច្នោះ ទើបឈ្មោះថា ភិក្ខុ ។

បុគ្គលណា រមែងទ្រទ្រង់ផ្ទាំងសំពត់ដែលកាត់ហើយ ព្រោះធ្វើតម្លៃ សម្ផស្ស និងពណ៌ឲ្យខូចទៅ ហេតុនោះ បុគ្គលនោះ ឈ្មោះថា អ្នកទ្រទ្រង់ ផ្ទាំងសំពត់ដែលកាត់ហើយ ។ បណ្ដា ការធ្វើតម្លៃឲ្យខូចទៅជាដើមនោះ គប្បី ជ្រាបការធ្វើតម្លៃឲ្យវិនាស ព្រោះកាត់ដោយសស្ត្រា ។ ពិតហើយ ផ្ទាំងសំពត់ សូម្បីមានតម្លៃមួយពាន់ ដែលគេយកកាំបិតកាត់ឲ្យជាចម្រៀកតូចធំ ហើយ រមែងអស់តម្លៃ គឺមានតម្លៃមិនដល់សូម្បីពាក់កណ្ដាលតម្លៃដើម ។ ភិក្ខុ គប្បីជ្រាបការធ្វើសម្ផស្សឲ្យវិនាសទៅ ព្រោះដេរដោយអំបោះ ។ ពិតហើយ ផ្ទាំងសំពត់ដែលមានសម្ផស្សជាសុខ ដែលត្រូវដេរដោយអំបោះ ហើយរមែង

មានសម្ពស្សបាត់បង់ទៅ គឺដល់នូវភាពជាសំពត់ដែលមានសម្ពស្សគ្រោត-គ្រាត ។ គប្បីជ្រាបការធ្វើពណ៌ឲ្យវិនាសទៅ ព្រោះសៅហ្មងដោយប្រេះមូលជាដើម ។ ពិតហើយ ផ្ទាំងសំពត់ សូម្បីបរិសុទ្ធល្អ តាំងអំពីធ្វើការដោយមូលហើយ រមែងមានពណ៌វិនាសទៅ គឺរមែងលះបង់ពណ៌ដើមទៅ ព្រោះប្រេះមូល និងព្រោះទឹកដែលជាមន្ទិលកើតអំពីក្អែលដៃ និងព្រោះការជ្រលក់ និងធ្វើកប្បក្នុងទីបំផុត ។ បុគ្គលណា ឈ្មោះថា ជាអ្នកទ្រទ្រង់សំពត់ដែលត្រូវកាត់ដាច់ហើយ ព្រោះទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវកាត់ ដោយអាការ ៣ យ៉ាង ដូចអធិប្បាយមកហើយនោះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា ភិក្ខុ ។

ម្យ៉ាងទៀត បុគ្គលណា ឈ្មោះថា ជាអ្នកទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវកាត់ហើយ ព្រោះត្រឹមតែទ្រទ្រង់សំពត់កាសាវៈទាំងឡាយ ដែលមិនដូចនឹងសំពត់របស់គ្រហស្ថ ហេតុនោះ បុគ្គលនោះ ឈ្មោះថា ភិក្ខុ ។

បទថា **សមញ្ញាយ**[១] សេចក្តីថា ដោយបញ្ញត្តិ គឺដោយវោហារ ។ ពិតហើយ បុគ្គលខ្លះរមែងប្រាកដថា ជាភិក្ខុ ដោយវោហារប៉ុណ្ណោះ ។ ពិតហើយ ក្នុងកិច្ចនិមន្តជាដើម មនុស្សទាំងឡាយ កាលរាប់ចំនួនភិក្ខុ រាប់យកទាំងពួកសាមណេរចូលផង ហើយពោលថា ភិក្ខុចំនួនមួយរយអង្គ ភិក្ខុចំនួនមួយពាន់អង្គ ។

បទថា **បដិញ្ញាយ** គឺដោយការប្តេជ្ញារបស់ខ្លួនឯង ពិតហើយ បុគ្គលពួកខ្លះ រមែងប្រាកដថា ជាភិក្ខុ សូម្បីដោយការប្តេជ្ញា ។ គប្បីជ្រាបការប្តេជ្ញា

ថា ជាភិក្ខុនោះ កើតមានក្នុងបយោគជាដើមយ៉ាងនេះថា សួរថា ក្នុងទីនេះ ជានរណា ឆ្លើយថា លោកម្ចាស់ ខ្ញុំជាភិក្ខុ ។ ឯការប្តេជ្ញានេះ ជាការប្តេជ្ញា ដែលត្រូវតាមធម៌ គឺព្រះអានន្ទត្ថេរបានពោលទុកហើយ ។ ម្យ៉ាងទៀត ដោយ ចំណែកនៃរាត្រី សូម្បីពួកភិក្ខុទ្រុស្តសីលដើរបញ្ច្រាសផ្លូវមក កាលត្រូវសួរថា ក្នុងទីនេះ ជានរណា ក៏ឆ្លើយថា ពួកខ្ញុំជាភិក្ខុ ដូច្នេះ ដើម្បីប្រយោជន៍ដល់ ការប្តេជ្ញាដែលមិនប្រពៃតាមធម៌ មិនត្រូវតាមសេចក្តីពិត ។

បទថា **ឯហិភិក្ខុ** សេចក្តីថា អ្នកដល់នូវភាពជាភិក្ខុ គឺ ឧបសម្បទា ដោយឯហិភិក្ខុ ដោយត្រឹមព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ យ៉ាងនេះថា **ឯហិ ភិក្ខុ** អ្នកចូរមកជាភិក្ខុចុះ ឈ្មោះថា ភិក្ខុ ។ ពិតហើយ ព្រះដ៏មាន-ព្រះភាគទត ឃើញបុគ្គលដែលដល់ព្រមដោយឧបនិស្ស័យ ដើម្បីជាឯហិភិក្ខុ ទើបទ្រង់លា ព្រះហស្តខាងស្តាំ ដែលមានពណ៌ដូចមាសចេញអំពីស្រទាប់ បង្សុកូលចីវរ ដែលមានពណ៌ក្រហម បន្លឺព្រះសូរសៀងក្រអួនដូចសំឡេង ព្រហ្ម ត្រាស់ថា **ឯហិ ភិក្ខុ ចរ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយ** អ្នកចូរមកជាភិក្ខុចុះ ចូរប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃ ចុះ ដំណាលគ្នានឹងព្រះវាចារបស់ព្រះដ៏មានព្រះភាគនោះឯង ភេទគ្រហស្ថ ក៏អន្តរធានទៅ បព្វជ្ជា និងឧបសម្បទាក៏សម្រេច បុគ្គលនោះ ជាអ្នកដាក់ចុះ នូវសក់ ស្លៀកដណ្តប់នូវសំពត់កាសាវៈ គឺ ស្លៀកស្បង់ មួយផ្ទាំង ដណ្តប់ ចីវរមួយផ្ទាំង ពាក់សង្ឃាដីលើចង្កេះមួយផ្ទាំង ស្ពាយបាត្រដីដែលមាន

១ បិដកថា សាមញ្ញាយ ។ យកតាមអដ្ឋកថា ។

ពណ៌ដូចផ្កាឧប្បលខៀវ ត្រង់ស្មាខាងឆ្វេង ។ ភិក្ខុនោះ លោកកំណត់ដោយបរិក្ខារ ៨ ប្រដាប់ត្រង់កាយ ដូចបុរាណាចារ្យពោលទុក យ៉ាងនេះថា

បរិក្ខារទាំងនេះ គឺត្រៃចីវរ បាត្រ កាំបិតតូច ម្ជុល និងវត្ថពន្ធចង្កេះ មានធម្មក្រកជាគម្រប់ ៨ រមែងគួរដល់ភិក្ខុដែលប្រកបសេចក្តីព្យាយាម ។

ជាអ្នកសម្បូរដោយឥរិយាបថ ដូចព្រះថេរៈមានវស្សា ៦០ មានព្រះពុទ្ធជាអាចារ្យ មានព្រះពុទ្ធជាឧបជ្ឈាយ៍ ឈរវន្ទាព្រះសម្មាសម្ពុទ្ធនោះឯង ។

ពិតហើយ ក្នុងបឋមពោធិកាល ព្រះដ៏មានព្រះភាគទ្រង់ឲ្យកុលបុត្រឧបសម្បទាដោយឯហិភិក្ខុឧបសម្បទានោះឯង ក្នុងមួយរយៈកាល ហើយភិក្ខុដែលឧបសម្បទាដោយវិធីយ៉ាងនេះ មានចំនួន ១៣៤១ អង្គ ។ បុគ្គលទាំងនោះ គឺនរណា គឺមានចំនួនដូច្នេះ បញ្ចវគ្គិយភិក្ខុ ៥ យសកុលបុត្រ ១ សម្លាញ់ជាបរិវាររបស់លោក ៥៤ ភទ្ទវគ្គិយភិក្ខុ ៣០ បុរាណជដិល ១០០០ បរិព្វាជកបរិវារអគ្គសាវកទាំងពីរ ២៥០ អង្គុលិមាលត្ថេរ ១ ( រួមជា ១៣៤១ អង្គ ) សមដូចពាក្យព្រះអដ្ឋកថាចារ្យពោលទុកថា

ភិក្ខុ ១៣០០ អង្គ និងភិក្ខុដទៃទៀត ៤០ អង្គ និងព្រះថេរៈមានបញ្ញា ១ អង្គទៀត ភិក្ខុទាំងអស់នោះ លោកពោលថាជាឯហិភិក្ខុ ។

ភិក្ខុទាំងនោះ ជាឯហិភិក្ខុមួយពួកក៏ទេ សូម្បីពួកដទៃក៏នៅមានច្រើនទៀត ភិក្ខុទាំងនោះ គឺនរណា គឺមានចំនួនជាដើមយ៉ាងនេះថា សេលព្រាហ្មណ៍ និង

បរិវារ ៣០០ ព្រះមហាកប្បិន និងបរិវារ ១០០០ កុលបុត្រ អ្នកស្រុកកបិលពស្តុ មានចំនួន ១០០០០ ពួកបារាយនិកព្រាហ្មណ៍ ( សិស្សរបស់អាចារ្យពាវរី ) មានចំនួន ១៦០០០ ( រួមជា ២៧៣០០ អង្គ ) ។ តែភិក្ខុទាំងនោះ ព្រះអដ្ឋកថាចារ្យមិនបានពោលទុក ព្រោះព្រះឧបាលិត្ថេរមិនបានសម្តែងទុកក្នុងបាលីព្រះវិនយបិដក ។ ភិក្ខុទាំងនេះព្រះអដ្ឋកថាចារ្យពោលទុក ព្រោះព្រះឧបាលិត្ថេរសម្តែងទុកក្នុងបាលីព្រះវិនយបិដកនោះហើយ ។ ព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថា ដូច្នេះថា

> ភិក្ខុទាំងអស់នេះ គឺ ២៧០០០ និង ៣០០ អង្គ ភិក្ខុទាំងអស់នោះ លោកពោលថា ជាឯហិភិក្ខុ ។

## ឧបសម្បទា ៨ យ៉ាង

ប្រើនបទថា **តីហិ សរណគមនេហិ ឧបសម្បន្នោ** សេចក្តីថា អ្នកឧបសម្បទាដោយត្រៃសរណគមន៍ ដែលបន្លឺវាចាពោល ៣ ដង ដោយន័យជាដើមថា **ពុទ្ធំ សរណំ គច្ឆាមិ ។** ពិតហើយ ដែលបានឈ្មោះថា ឧបសម្បទានេះ មាន ៨ យ៉ាង គឺឯហិភិក្ខុឧបសម្បទា ១ សរណគមនឧបសម្បទា ១ ឱវាទប្បដិគ្គហណឧបសម្បទា ១ បញ្ហាព្យាករណឧបសម្បទា ១ គរុធម្មប្បដិគ្គហណឧបសម្បទា ១ ទូតេនឧបសម្បទា ១ អដ្ឋវាចិកាឧបសម្បទា ១ ញត្តិចតុត្ថកម្មឧបសម្បទា ១ ។

ក្នុងឧបសម្បទា ៨ យ៉ាងនោះ ឯហិភិក្ខុឧបសម្បទា និងសរណគមនឧបសម្បទា ខ្ញុំបានពោលរួចហើយ ។

ដែលឈ្មោះថា ឱវាទប្បដិគ្គហណឧបសម្បទា បានដល់ ឧបសម្បទាដែលទ្រង់អនុញ្ញាតដល់ព្រះមហាកស្សបត្ថេរ ដោយការទទួលឱវាទនេះថា ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ហិរិនិងឱត្តប្បៈដ៏ក្លៀវក្លា អាត្មាអញបានតម្កល់ទុក ក្នុងភិក្ខុចាស់ទាំងឡាយ ក្នុងភិក្ខុថ្មីទាំងឡាយ ក្នុងភិក្ខុកណ្ដាលទាំងឡាយ ម្នាលកស្សប អ្នកគួរសិក្សាយ៉ាងនេះឯង ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងស្ដាប់នូវធម៌ ដែលប្រកបដោយកុសលណានីមួយ ហើយធ្វើនូវធម៌ទាំងអស់នោះឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចង់ចិត្តទាំងពួងផ្ទៀងត្រចៀកចាំស្ដាប់ធម៌ ម្នាលកស្សប អ្នកគប្បីសិក្សាយ៉ាងនេះចុះ ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះអ្នកគប្បីសិក្សាយ៉ាងនេះថា កាយគតា-សតិរបស់អាត្មាអញ ប្រកបដោយសេចក្ដីសុខ មិនទាន់សាបសូន្យនៅឡើយ ម្នាលកស្សប អ្នកគប្បីសិក្សាយ៉ាងនេះឯង ។

បញ្ហាព្យាករណឧបសម្បទា បានដល់ ឧបសម្បទាដែលទ្រង់អនុញ្ញាតដល់សោបាកសាមណេរ បានឮថា ព្រះដ៏មានព្រះភាគត្រាស់សួរបញ្ហា ទាក់-ទងដោយអសុភ ១០ នឹងសោបាកសាមណេរ ដែលចង្ក្រមតាមទ្រង់នៅក្នុងបុព្វារាមថា សោបាកៈ ធម៌ទាំងនេះ គឺឧទ្ធុមាតកសញ្ញាក្ដី រូបសញ្ញាក្ដី មានអត្ថផ្សេងគ្នា មានព្យញ្ជនៈផ្សេងគ្នា ឬមានអត្ថតែមួយ ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ សោបាកសាមណេរនោះ ឆ្លើយដោះបញ្ហាទាំងនោះបាន ។ ព្រះដ៏មានព្រះភាគ

ទ្រង់ប្រទានសាធុការដល់លោក ហើយសួរថា ម្នាលសោបាកៈ អ្នកមានវស្សាប៉ុន្មាន សាមណេរទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមានវស្សា ៧ ។

ព្រះដ៏មានព្រះភាគ មានព្រះទ័យដែលសោបាកសាមណេរឲ្យត្រេកអរ ហើយថា សោបាកៈ អ្នកឆ្លើយបញ្ហាហាក់ដូចសព្វញ្ញុតញ្ញាណរបស់តថាគត ហើយទើបទ្រង់អនុញ្ញាតឲ្យឧបសម្បទា ។ នេះឈ្មោះថា បញ្ហាព្យាករណ-ឧបសម្បទា ។

ដែលឈ្មោះថា គរុធម្មប្បដិគ្គហណឧបសម្បទា បានដល់ ឧបសម្បទាដែលទ្រង់អនុញ្ញាតដល់ព្រះនាងមហាបជាបតី ដោយការទទួលគរុធម៌ ៨ ។

ដែលឈ្មោះថា ទូតេនឧបសម្បទា បានដល់ ឧបសម្បទាដែលទ្រង់អនុញ្ញាតដល់នាងអឌ្ឍកាសីគណិកា ។

ដែលឈ្មោះថា អដ្ឋវាចិកាឧបសម្បទា បានដល់ ឧបសម្បទារបស់ភិក្ខុនី ដោយកម្មពីរពួក គឺញត្តិចតុត្ថកម្មភិក្ខុនីសង្ឃ ញត្តិចតុត្ថកម្មខាងភិក្ខុ-សង្ឃ ។

ដែលឈ្មោះថា ញត្តិចតុត្ថកម្មឧបសម្បទា បានដល់ ឧបសម្បទារបស់ភិក្ខុទាំងឡាយក្នុងបច្ចុប្បន្ននេះ ។

មានពាក្យពោលអធិប្បាយថា បុគ្គលដែលឧបសម្បទាហើយ ក្នុងបណ្ដាឧបសម្បទា ៨ យ៉ាងនេះ ដោយឧបសម្បទានេះ ដែលទ្រង់អនុញ្ញាតហើយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវបព្វជ្ជាឧប-សម្បទា ដោយត្រៃសរណគមន៍នេះ ។

បទថា **ភទ្រោ** បានដល់ មិនថោកថយ ។ ពិតហើយ សេក្ខបុគ្គលទាំងឡាយ មានកល្យាណបុថុជ្ជនជាដើម រហូតដល់ព្រះអរហន្ត រមែងមិនរាប់ថា ភិក្ខុអ្នកចម្រើន ព្រោះប្រកបដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈដ៏ចម្រើន ។

បទថា **សារោ** សេចក្ដីថា សេក្ខកល្យាណបុថុជ្ជននោះ គប្បីជ្រាបថាភិក្ខុអ្នកមានសារៈ ព្រោះប្រកបដោយសារៈទាំងឡាយ មានសីលសារៈជាដើមនោះឯង ប្រៀបដូចសំពត់ពណ៌ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ដូច្នោះ ។ ម្យ៉ាងទៀត ព្រះខីណាស្រពប៉ុណ្ណោះ គប្បីជ្រាបថា ជាអ្នកមានសារៈ ព្រោះជាអ្នកប្រាសចាកធូលី គឺកិលេស ។

បទថា **សេក្ខោ** សេចក្ដីថា ព្រះអរិយបុគ្គល ៧ ពួក និងកល្យាណ-បុថុជ្ជន រមែងសិក្សាសិក្ខា ៣ ព្រោះហេតុនោះ ទើបចាត់ជាសេក្ខបុគ្គល ។ ក្នុងសេក្ខបុគ្គលទាំងនោះ បុគ្គលណាមួយ គប្បីជ្រាបថា ជាភិក្ខុសេក្ខៈ ។ ដែលឈ្មោះថា អសេក្ខបុគ្គល ព្រោះមិនមានការសិក្សា ។ ព្រះខីណាស្រពលោកហៅថា អសេក្ខបុគ្គល ព្រោះកន្លងសេក្ខធម៌ហើយ តាំងនៅក្នុងអគ្គផលមិនមានសិក្ខាដែលត្រូវសិក្សាឲ្យក្រៃលែងជាងនោះ ។

ពីរបទថា **សមគ្គេន សង្ឃេន** សេចក្ដីថា ដោយសង្ឃ ឈ្មោះថាចូលដល់ភាពជាអ្នកព្រមព្រៀងគ្នាក្នុងកម្មណាមួយ ព្រោះភិក្ខុដែលចូលធ្វើកម្មក្នុងកម្មដែលនឹងគប្បីធ្វើ ដោយសង្ឃបញ្ចវគ្គ ដោយបរិយាយយ៉ាងទាបបំផុតបានមកគ្រប់ចំនួន ព្រោះបាននាំឆន្ទៈរបស់ពួកភិក្ខុដែលគួរដល់ឆន្ទៈមកហើយ

និងព្រោះពួកភិក្ខុដែលនៅចំពោះមុខមិនជំទាស់ ។

បទថា **ញត្តិចតុត្ថេន** សេចក្តីថា ដែលគប្បីធ្វើដោយអនុស្សាវនា ៣ ដង ញត្តិ ១ ដង ។ បទថា **កម្មេន** គឺវិនយកម្មដែលត្រូវតាមធម៌ ។

បទថា **អកុប្បេន** សេចក្តីថា ចូលដល់ភាពជាកម្មដែលបុគ្គលណាមួយឲ្យកម្រើកមិនបាន គឺដែលបុគ្គលណាមួយ ជំទាស់មិនបាន ព្រោះដល់ព្រមដោយវត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុស្សាវនាសម្បត្តិ សីមាសម្បត្តិ និងបរិស-សម្បត្តិ ។ បទថា **ឋានារហេន** គឺគួរដល់ហេតុ បានដល់ គួរដល់សត្ថុ-សាសនា ។ ឈ្មោះថា **ឧបសម្បន្នោ** គឺមកដល់ អធិប្បាយថា សម្រេចការៈដ៏ឧត្តម គឺភាពជាភិក្ខុ ដែលជាការៈដ៏ឧត្តម ។ ពិតហើយ បុគ្គលនោះលោកហៅថា ឧបសម្បន្ន ព្រោះមកដល់ភាពជាភិក្ខុនោះ ដោយកម្មតាមដែលពោលហើយ ។

ក្នុងអធិការនេះ មកអំពីញត្តិចតុត្ថកម្មតែម្យ៉ាងប៉ុណ្ណោះ ។ តែក្នុងទីនេះ គួរនាំសង្ឃកម្មទាំង ៤ មកពោលទុកដោយពិស្តារ ។ ពាក្យទាំងអស់នោះ លោកពោលហើយក្នុងអដ្ឋកថាទាំងឡាយ ។ ឯសង្ឃកម្មទាំងនោះ គឺអប-លោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម បណ្ឌិតគប្បីរៀបរៀងទុកតាមលំដាប់ ហើយលើកបាលីមកពោលដោយពិស្តារ អំពីគម្ពីរខន្ធកៈ និងកម្មវិភង្គក្នុងទីបំផុតនៃគម្ពីរបរិវារ ។

ខ្ញុំនឹងពណ៌នាសង្ឃកម្មទាំងនោះ ក្នុងកម្មវិភង្គក្នុងទីបំផុតនៃគម្ពីរបរិវារនោះឯង ។ ព្រោះថា បើមានការពណ៌នាយ៉ាងនោះ បឋមបារាជិកវណ្ណនានឹង

មិនជាការធ្ងន់ពេក ហើយការពណ៌នាព្រះបាលី តាមដែលតាំងទុក ក៏នឹងជាវណ្ណនាដែលដឹងបានងាយ ទាំងឋានៈទាំងនោះ នឹងជារបស់មិនសូន្យបង់ ព្រោះដូច្នោះ ខ្ញុំនឹងធ្វើការពណ៌នាទៅតាមលំដាប់បទប៉ុណ្ណោះ ។

បទថា **តត្រ** សេចក្ដីថា បណ្ដាភិក្ខុទាំងឡាយ ដែលពោលដោយន័យមានពាក្យថា អ្នកសូមជាដើមប៉ុណ្ណោះ ។ ពីរបទថា **យ្វាយំ ភិក្ខុ** កាត់បទជា **យោ អយំ ភិក្ខុ** ប្រែថា ភិក្ខុនេះ។ បទថា **សមគ្គេន សង្ឃេន ។បេ។ ឧប-សម្បន្នោ** សេចក្ដីថា បណ្ដាឧបសម្បទា ៨ ដែលឧបសម្បទាហើយ ដោយញត្តិចតុត្ថកម្មប៉ុណ្ណោះ ។

បទថា **អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខុ** សេចក្ដីថា ភិក្ខុនេះសំដៅយកថា ភិក្ខុ ក្នុងអត្ថថា សេពមេថុនធម្មហើយ រមែងជាអ្នកចាលចាញ់នេះ ។ ចំណែក **ភិក្ខុ** សព្ទក្រៅអំពីនេះ មានពាក្យថា **ភិក្ខកោ** ជាដើម ទ្រង់ត្រាស់ដោយអំណាចការពង្រីកសេចក្ដី ហើយក្នុងពាក្យថា **ភិក្ខកោ** ជាដើមនោះ សព្ទជាដើមថា **អ្នកសូម** ទ្រង់ត្រាស់ដោយអំណាចភាសា ។ ពីរបទថា **សមញ្ញាយ ភិក្ខុ បដិញ្ញាយ ភិក្ខុ** ជាភិក្ខុដោយការប្ដេជ្ញា ទ្រង់ត្រាស់ដោយអំណាចការហៅ ។ បទថា **ឯហិភិក្ខុ** ត្រាស់ដោយអំណាចវិធីឧបសម្បទា ដែលកុលបុត្របានហើយ ដោយមានព្រះពុទ្ធជាឧបជ្ឈាយ៍ ។ **សរណគមនភិក្ខុ** ទ្រង់ត្រាស់ ដោយអំណាចបុគ្គលដែលឧបសម្បទាហើយ ក្នុងកាលកម្មវាចាមិនទាន់កើតឡើង ។ សព្ទជាដើមថា **ភទ្រ** គប្បីជ្រាបថា ទ្រង់ត្រាស់ដោយអំណាចគុណ ។

# អធិប្បាយ អធិសីល អធិចិត្ត អធិប្បញ្ញា

[ ២៧ ] ព្រះដ៏មានព្រះភាគ ទ្រង់មិនបានចែកបទនេះថា **ភិក្ខូនំ** ទុកក្នុងឥឡូវនេះឡើយ ព្រោះមិនមានអត្ថដែលប្លែក កាលទ្រង់សម្តែងសិក្ខា និងសាជីវៈ ព្រោះជាហេតុឲ្យភិក្ខុដល់ព្រមហើយ ទើបជាបុគ្គលដែលឈ្មោះថា ដល់ព្រមដោយសិក្ខា និងសាជីវៈរបស់ភិក្ខុទាំងឡាយ ទើបត្រាស់ថា **សិក្ខា** ជាដើម ក្នុងពាក្យថា **សិក្ខា** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ឈ្មោះថា **សិក្ខា** ព្រោះអត្ថថា ដែលកុលបុត្រគប្បីសិក្សា ។

បទថា **តិស្សោ** ជាសង្ខ្យាកំណត់ការគណនា ។

បទថា **អធិសីលសិក្ខា** មានអត្ថវិគ្គហៈថា សីលដ៏ក្រៃលែង គឺឧត្តម ហេតុនោះ ទើបឈ្មោះថា អធិសីល ។ អធិសីលផង ជាសិក្ខាផង ហេតុនោះ ទើបឈ្មោះថា អធិសីលសិក្ខា ។ ក្នុងអធិចិត្តសិក្ខា និងអធិប្បញ្ញាសិក្ខាក៏មានន័យដូច្នោះ ។

សួរថា ក្នុងអធិការនេះ សីលដូចម្តេច អធិសីលដូចម្តេច ចិត្តដូចម្តេច អធិចិត្តដូចម្តេច បញ្ញាដូចម្តេច អធិប្បញ្ញាដូចម្តេច ? ខ្ញុំនឹងឆ្លើយថា សីលមានអង្គ ៥ និងអង្គ ១០ ឈ្មោះថា សីលប៉ុណ្ណោះជាបឋម ។ ពិតហើយ សីលនោះ កាលព្រះពុទ្ធកើតឡើងហើយក៏ដោយ មិនទាន់កើតឡើងក៏ដោយ ប្រព្រឹត្តទៅក្នុងលោកជាធម្មតា ។ កាលព្រះពុទ្ធកើតឡើងហើយ ព្រះពុទ្ធទាំងឡាយក្តី សាវកទាំងឡាយក្តី រមែងដឹកនាំមហាជនឲ្យសមាទានក្នុងសីលនោះ ។ បើព្រះពុទ្ធមិនកើតឡើង ព្រះបច្ចេកពុទ្ធ សមណព្រាហ្មណ៍ដែលជាកម្មវាទី ប្រព្រឹត្តត្រូវតាមធម៌ ស្តេចចក្រពត្តិមហារាជ និងមហាពោធិសត្វ រមែងដឹកនាំ

មហាជនឲ្យសមាទាន ( ក្នុងសីលនោះ ) ។ ពួកសមណព្រាហ្មណ៍ដែលជាបណ្ឌិតក៏សមាទាន ( សីលនោះ ) ដោយខ្លួនឯងផងដែរ ។ សមណព្រាហ្មណ៍ជាដើមនោះ កាលបំពេញកុសលធម៌នោះឲ្យបរិបូណ៌ហើយ រមែងសោយសម្បត្តិក្នុងពួកទេវតា និងក្នុងពួកមនុស្ស ។

ចំណែកបាតិមោក្ខសំវរសីល លោកហៅថា អធិសីល ។ ពិតហើយ បាតិមោក្ខសំវរសីលនោះ ជាសីលដ៏ក្រៃលែង និងឧត្តមជាងបណ្ដាលោកិយ-សីលទាំងអស់ ដូចព្រះអាទិត្យក្រៃលែងជាងពន្លឺទាំងឡាយ ដូចភ្នំសិនេរុខ្ពស់ជាងភ្នំទាំងឡាយដូច្នោះ រមែងប្រព្រឹត្តទៅបានតែក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ ក្រៅពីពុទ្ធុប្បាទកាលមិនអាចប្រព្រឹត្តទៅបានឡើយ ។ ព្រោះថា សត្វដទៃមិនអាចលើកបញ្ញត្តិនោះតាំងទុកបាន ។ ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ទ្រង់កាត់ក្រសែនៃអជ្ឈាចារផ្លូវកាយទ្វារ និងវចីទ្វារបានជាសមុច្ឆេទ ដោយប្រការទាំងពួងហើយ ទើបទ្រង់បញ្ញត្តសីលសំវរៈនោះទុក ដែលសមគួរដល់ការកន្លងល្មើសនោះៗ ។

ម្យ៉ាងទៀត សីលដែលសម្បយុត្តដោយមគ្គ និងផលប៉ុណ្ណោះ ឈ្មោះថា សីលដែលក្រៃលែងជាងបាតិមោក្ខសំវរៈ ។ តែសីលដែលសម្បយុត្តដោយមគ្គ និងផលនោះ លោកមិនបានសំដៅយកក្នុងអធិការនេះ ។ ព្រោះភិក្ខុដែលដល់ព្រមដោយសីលនោះ លោកមិនសេពមេថុនធម្មឡើយ ។ កាមាវចរកុសលចិត្ត ៨ និងសមាបត្តិចិត្ត ៨ ដែលជាលោកិយ រួមចូលជាមួយគ្នា គប្បីជ្រាបថា ជាចិត្តប៉ុណ្ណោះ ។ ក្នុងកាលព្រះពុទ្ធកើតឡើង ឬមិន

កើតឡើង ចិត្តនោះក៏ប្រព្រឹត្តទៅបាន ការដឹកនាំ និងសមាទាន ក៏គប្បីជ្រាប ដោយន័យដែលពោលទុកហើយ ក្នុងសីលនោះឯង ។

ចំណែកសមាបត្តិចិត្ត ៨ ដួង ដែលជាបាទនៃវិបស្សនា លោកហៅថា អធិចិត្ត ។ ពិតហើយ អដ្ឋសមាបត្តិចិត្តនោះ ជាចិត្តដែលក្រៃលែង និងឧត្តម ជាងលោកិយចិត្តទាំងអស់ ដូចអធិសីលក្រៃលែងជាងបណ្តាសីលទាំងឡាយ ដូច្នោះ និងមានចំពោះពុទ្ធុប្បាទកាលប៉ុណ្ណោះ ក្រៅពុទ្ធុប្បាទកាល មិនមាន ។ ម្យ៉ាងទៀត ចិត្តដែលសម្បយុត្តដោយមគ្គ និងផលនោះឯង ជាចិត្តដែលក្រៃ-លែងជាងអដ្ឋសមាបត្តិចិត្តនោះ ។ តែចិត្តដែលសម្បយុត្តដោយមគ្គ និងផល នោះ លោកមិនបានសំដៅយកក្នុងអធិការនេះទេ ។ ព្រោះថា ភិក្ខុដែលដល់ព្រមដោយចិត្តនោះ លោកមិនសេពមេថុនធម្មឡើយ ។

ម្យ៉ាងទៀត កម្មស្សកតាញាណ ( ញាណដែលដឹងថា សត្វមានកម្មជារបស់ខ្លួន ) ដែលប្រព្រឹត្តទៅដោយន័យជាដើមថា ទានដែលឲ្យហើយ មានផល ការបូជាមានផល ឈ្មោះថា បញ្ញា ។ ពិតហើយ បញ្ញានោះ កាលព្រះពុទ្ធកើតឡើងហើយក៏ដោយ មិនបានកើតឡើងក៏ដោយ ប្រព្រឹត្តទៅធម្មតាក្នុងលោក ។ កាលព្រះពុទ្ធកើតឡើងហើយ ព្រះពុទ្ធទាំងឡាយក្តី សាវកទាំង-ឡាយក្តី រមែងដឹកនាំមហាជនឲ្យសមាទានក្នុងបញ្ញានោះ ។ កាលព្រះពុទ្ធមិនបានកើតឡើង ព្រះបច្ចេកពុទ្ធ សមណព្រាហ្មណ៍ ពួកកម្មវាទីដែលប្រព្រឹត្តត្រូវតាមធម៌ ស្តេចចក្រពត្តិមហារាជ និងមហាពោធិសត្វ រមែងដឹកនាំមហាជនឲ្យសមាទាន ( ក្នុងបញ្ញានោះ ) ។ សត្វទាំងឡាយដែលជាបណ្ឌិត

ក៏សមាទានដោយខ្លួនឯង ។ ពិតហើយ អង្គុរទេវបុត្របានថ្វាយមហាទាន អស់ម៉ឺននៃឆ្នាំ ។ វេលាមព្រាហ្មណ៍ ព្រះវេស្សន្តរ និងមនុស្សបណ្ឌិតពួកដទៃជាច្រើន បានថ្វាយមហាទានហើយ ។ វេលាមព្រាហ្មណ៍ជាដើមនោះ កាលបំពេញកុសលធម៌នោះ ឲ្យបរិបូណ៌ហើយ ក៏បានសោយសម្បត្តិក្នុងពពួកទេវតា និងក្នុងពពួកមនុស្ស ។

ចំណែកវិបស្សនាញាណ ដែលជាគ្រឿងកំណត់អាការ គឺត្រៃលក្ខណ៍ លោកហៅថា អធិប្បញ្ញា ។ ពិតហើយ អធិប្បញ្ញានោះ ជាបញ្ញាដែលក្រៃលែង និងឧត្តមជាងបណ្តាលោកិយប្បញ្ញាទាំងអស់ ដូចអធិសីលនិងអធិចិត្តក្រៃលែង និងឧត្តមជាងបណ្តាសីល និងចិត្តទាំងឡាយ ដូច្នោះ ក្រៅពុទ្ធុប្បាទកាល មិនប្រព្រឹត្តទៅក្នុងលោកឡើយ ។ ឯបញ្ញាដែលសម្បយុត្តដោយមគ្គ និងផលនោះឯង ជាបញ្ញាដែលក្រៃលែងជាងវិបស្សនាញាណនោះ ។ តែបញ្ញាដែលសម្បយុត្តដោយមគ្គ និងផលនោះ លោកមិនបានសំដៅយកក្នុងអធិការនេះ ព្រោះថា ភិក្ខុដែលដល់ព្រមដោយបញ្ញានោះ មិនសេពមេថុនធម្មឡើយ ។ បទថា **តត្រ** គឺបណ្តាសិក្ខាទាំង ៣ នោះ ។ ច្រើនបទថា **យា អយំ អធិសីលសិក្ខា** បានដល់ អធិសីលសិក្ខានេះ ពោល គឺបាតិមោក្ខសីល ។

## អធិប្បាយ បទថា សិក្ខា និង សាជីវៈ

[ ២៨ ] ពីរបទថា **ឯតំ សាជីវន្នាម** សេចក្តីថា សិក្ខាបទទាំងពួងនោះ ដែលព្រះដ៏មានព្រះភាគទ្រង់តាំងទុកក្នុងព្រះវិន័យ នេះហៅថា **សាជីវ** ព្រោះថា ជាទីនៅរួមគ្នា គឺរស់នៅដូចគ្នា រស់នៅត្រូវចំណែកគ្នា ប្រព្រឹត្តត្រូវចំណែកគ្នា នៃភិក្ខុទាំងឡាយ ដែលផ្សេងគ្នាដោយប្រភេទ មានបទេស ជាតិ

និងគោត្រផ្សេងៗ គ្នាជាដើម ។

ពីរបទថា **តស្មឹ សិក្ខតិ** សេចក្ដីថា ភិក្ខុធ្វើសិក្ខាបទនោះឲ្យជាទីពឹងនៃចិត្តហើយ កំណត់ពិចារណាដោយចិត្តថា អាត្មាអញសិក្សាសមគួរដល់សិក្ខាបទហើយឬនៅហ្ន៎ ភិក្ខុនេះ ឈ្មោះថា កំពុងសិក្សាក្នុងសិក្ខាបទ ពោលគឺសាជីវៈនោះតែម្យ៉ាងប៉ុណ្ណោះក៏ទេ សូម្បីក្នុងសិក្ខា ក៏ឈ្មោះថា សិក្សាដែរ ។

ចំណែកពីរបទថា **តស្មឹ សិក្ខតិ** ព្រះដ៏មានព្រះភាគត្រាស់ដោយអំណាចបទដែលរៀងជាលំដាប់គ្នាថា **ឯតំ សាជីវន្នាម** នេះ ។ បទថា **តស្មឹ សិក្ខតិ** នោះ ព្រះអង្គត្រាស់យ៉ាងនោះពិតហើយ តែអត្ថក្នុងបទថា **តស្មឹ សិក្ខតិ** នេះ គប្បីឃើញយ៉ាងនេះថា កាលញុំាងសិក្ខាឲ្យបរិបូណ៌ ឈ្មោះថា កំពុងសិក្សាក្នុងសិក្ខានោះ ហើយកាលមិនកន្លងល្មើស ឈ្មោះថា កំពុងសិក្សាក្នុងសិក្ខាបទនោះ ។ បទថា **តេន វុច្ចតិ សាជីវសមាបន្នោ** នេះ ក៏ត្រាស់ដោយអំណាចនៃបទថា **សាជីវ** ដែលជាលំដាប់ដូចគ្នា ។ ភិក្ខុនោះសូម្បីដល់ព្រមនូវសិក្ខា ព្រោះហេតុណា ហេតុនោះ បណ្ឌិតគប្បីជ្រាបដោយសំដៅថា ដល់ព្រមដោយសិក្ខាផងដែរ ព្រោះថា កាលមានបំណងយ៉ាងនោះ បទភាជនៈនៃបទថា **សិក្ខាសាជីវសមាបន្នោ** នេះ ឈ្មោះថា បរិបូណ៌ ។

## អធិប្បាយ វិធីលាសិក្ខា

[ ២៩ ] បទច្រើនថា **សិក្ខំ អបច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា** សេចក្ដីថា មិនពោលលាសិក្ខាផង មិនប្រកាសភាពជាបុគ្គលមានកម្លាំងខ្សោយផង ។

ការធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយហើយ សិក្ខាមិនទាន់ជាការពោលលាឡើយ តែកាលពោលលាសិក្ខាហើយ ភាពជាអ្នកមានកម្លាំងខ្សោយ រមែងជាការធ្វើឲ្យជាក់ច្បាស់ផងដែរ ព្រោះហេតុនោះ ដោយបទថា **ទុព្វល្យំ អនាវិកត្វា** នេះ ទើបមិនបានអត្ថវិសេសណាមួយឡើយ ដូចជាពាក្យថា ពោលលា ដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា គប្បីសម្រេចការដេករួម ២-៣ យប់ ដូច្នេះ បណ្ឌិតក៏មិនបានអត្ថពិសេសណាមួយឡើយ ។ ពាក្យថា ២-៣ យប់នេះ ព្រះអង្គត្រាស់ដោយភាពជាពាក្យពីរោះរណ្ដំដោយព្យញ្ជនៈ ដោយភាពជាពាក្យជាប់ព្រះឱស្ឋ ដោយអំណាចលោកវោហារតែម្យ៉ាង សេចក្ដីនេះយ៉ាងណា សូម្បីពាក្យថា មិនបានធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលខ្សោយកម្លាំងនេះ ក៏ដូច្នោះ បណ្ឌិតគប្បីជ្រាបថា ព្រះដ៏មានព្រះភាគត្រាស់ដោយភាពជាពាក្យសម្រួលមាត់ ដោយភាពជាពាក្យពីរោះរណ្ដំដោយព្យញ្ជនៈ ដោយភាពជាពាក្យជាប់ព្រះឱស្ឋ ។

ប្រការមួយទៀត ព្រះដ៏មានព្រះភាគ ទ្រង់រមែងសម្ដែងធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ព្រោះដូច្នោះ ទើបទ្រង់ញ៉ាំងអត្ថឲ្យដល់ព្រម ដោយបទថា មិនពោលលាសិក្ខានេះ ញ៉ាំងព្យញ្ជនៈឲ្យដល់ព្រមដោយបទថា មិនធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយនេះ ។ ពិតហើយ អត្ថដែលពោលចំពោះបទមួយ ប្រាសចាកបទដែលជាបរិវារហើយ រមែងមិនពីរោះ ប្រៀបដូចព្រះរាជាដែលប្រាសចាកបរិវារ និងបុរសដែលប្រាសចាកសំពត់ និងអលង្ការ រមែងមិនស្រស់ស្អាត ដូច្នោះ ។ តែអត្ថក្នុងបទនោះ រមែងពីរោះ

ព្រមដោយបទប្រៀបធៀប ដែលជាបទបរិវារ ល្មមសមគួរដល់អត្ថ ។

ប្រការមួយទៀត ការធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលទុព្វលណានីមួយ រមែងជាអត្ថនៃការពោលលាសិក្ខា ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់សំដៅយកការធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលខ្សោយកម្លាំងណានីមួយដែលជាអត្ថបាននោះ កាលទ្រង់លម្អិតសេចក្ដីក្នុងបទថា មិនពោលលាសិក្ខា ទើបត្រាស់ថា មិនបានធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយ ។

ក្នុងពាក្យថា មិនពោលលាសិក្ខា មិនបានធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយនោះ បើគប្បីមានពាក្យចោទសួរថា ការធ្វើឲ្យជាក់-ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយទាំងអស់ មិនមែនជាការពោលលាសិក្ខា ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគគួរត្រាស់បទថា មិនបានធ្វើឲ្យជាក់-ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយ ដូច្នេះមុន ហើយទើបត្រាស់បទថា មិនពោលលាសិក្ខា ដើម្បីកំណត់អត្ថនៃបទថា មិនបានធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយនោះ ឆ្លើយថា ពាក្យនោះ មិនគួរពោល ព្រោះហេតុអ្វី ព្រោះមិនមានលំដាប់នៃអត្ថ ។ ពិតហើយ ព្រោះព្រះដ៏មានព្រះភាគបានត្រាស់ទុកថា **សិក្ខាសាជីវសមាបន្នោ** ដូច្នេះ អត្ថ ឈ្មោះថាទ្រង់ត្រាស់ហើយតាមលំដាប់ ក្នុងកាលត្រាស់ថា ខ្លួនដល់ព្រមនូវការលាសិក្ខាណា មិនពោលលាសិក្ខានោះ មិនមែនដោយប្រការដទៃឡើយ ព្រោះហេតុនោះ ពាក្យថា **សិក្ខំ អបច្ចក្ខាយ** នេះឯង ទើបព្រះដ៏មានព្រះភាគត្រាស់មុន ។ មួយវិញទៀត គប្បីជ្រាបអត្ថក្នុងបទទាំងពីរថា មិនពោលលា

សិក្ខា មិនធ្វើឲ្យជាក់ច្បាស់នូវភាពជាអ្នកខ្សោយកម្លាំងនេះ តាមសមគួរដល់លំដាប់ខ្លះ ។ គប្បីជ្រាបដូចម្ដេច គប្បីជ្រាបយ៉ាងនេះថា ក្នុងបទថា ដល់ព្រមដោយសិក្ខា និងសាជីវៈនេះ ភិក្ខុដល់ព្រមនូវសិក្ខាណា មិនពោលលាសិក្ខានោះ នឹងដល់ព្រមនូវសាជីវៈណា មិនធ្វើឲ្យជាក់ច្បាស់នូវភាពជាអ្នកមានកម្លាំងខ្សោយក្នុងសាជីវៈនោះ ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងការប្លែកគ្នា និងការមិនប្លែកគ្នានៃការពោលលាសិក្ខា និងការធ្វើឲ្យជាក់ច្បាស់នូវភាពជាអ្នកមានកម្លាំងខ្សោយ និងលក្ខណៈនៃការពោលលាសិក្ខា ទើបត្រាស់ថា **អត្ថិ ភិក្ខវេ** ជាដើម ។ ក្នុងពាក្យទាំងពីរនោះ បទថា **អត្ថិ ភិក្ខវេ** ជាដើម ជាបទមាតិកា ព្រះដ៏មានព្រះភាគកាលទ្រង់ចែកបទមាតិកាទាំងពីរនោះ ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ** ជាដើម ។

[ ៣០ ] ក្នុងពាក្យថា **កថញ្ច** ជាដើមនោះ មានការពណ៌នា បទដែលមិនទាន់ជាក់ច្បាស់យ៉ាងនេះថា បទថា **កថំ** បានដល់ ដោយអាការដូចម្ដេច បទថា **ទុព្វល្យាវិកម្មញ្ច** បានដល់ ការធ្វើឲ្យជាក់ច្បាស់នូវភាពជាអ្នកមានកម្លាំងខ្សោយផង ។ បទថា **ឥធ** គឺក្នុងសាសនានេះ ។

បទថា **ឧក្កណ្ឋិតោ** សេចក្ដីថា ជាអ្នកដល់នូវភាពជាបុគ្គលលំបាកក្នុងសាសនានេះ ព្រោះការធុញទ្រាន់ ។ ប្រការមួយទៀត មានពាក្យអធិប្បាយថា បុគ្គលមានចិត្តរាយមាយ មិនមានឯកគ្គតាក្នុងអារម្មណ៍ អើត-កដោយគិតថា អញនឹងទៅថ្ងៃនេះ អញនឹងទៅស្អែកនេះ អញនឹងទៅអំពីទីនេះ អញនឹងទៅក្នុងទីនេះ ។

បទថា **អនភិរតោ** បានដល់ ដែលប្រាសចាកការត្រេកអរក្នុងសាសនា ។

ពីរបទថា **សាមញ្ញា ចវិតុកាមោ** បានដល់ ដែលចង់ចៀសចេញទៅអំពីភាពជាសមណៈ ។

បទថា **ភិក្ខុភាវំ** គឺដោយភាពជាភិក្ខុ ។ បទថា **ភិក្ខុភាវំ** នេះ ជាទុតិយាវិភត្តិ ប្រព្រឹត្តទៅក្នុងអត្ថនៃតតិយាវិភត្តិ ។ ចំណែកលក្ខណៈដែលសមគួរ ព្រះដ៏មានព្រះភាគត្រាស់ដោយតតិយាវិភត្តិនោះឯង ក្នុងពាក្យថា គប្បីខ្ពើមរអើមដោយសាកសពដែលចងទុកត្រង់ក ដូច្នេះជាដើម ។

បទថា **អដ្ដិយមានោ** សេចក្ដីថា ប្រព្រឹត្តខ្វះដូចខ្វាច គឺត្រូវបៀតបៀនដល់នូវភាពលំបាក ។ ម្យ៉ាងទៀត អធិប្បាយថា ដែលភាវៈជាភិក្ខុនោះកំពុងរុកកួន កំពុងបៀតបៀន ។

បទថា **ហរាយមានោ** ប្រែថា ធុញទ្រាន់ បានដល់ កំពុងខ្មាសអៀន ។

បទថា **ជិគុច្ឆមានោ** បានដល់ ដែលខ្ពើមស្អប់ភាពជាភិក្ខុនោះ ដូចខ្ពើមរបស់ស្មោកគ្រោក ដូច្នោះ ។

បទថា **គិហិភាវំ បដ្ឋយមានោ** ជាដើម មានអត្ថជាក់ច្បាស់ហើយ ។

សព្ទថា **យន្នូន** ក្នុងពាក្យថា **យន្នូនាហំ ពុទ្ធំ បច្ចក្ខេយ្យំ** នេះ ជានិបាតសម្ដែងសេចក្ដីរំពឹង ។ មានពាក្យអធិប្បាយដូច្នេះថា បើអញគប្បីពោលលាព្រះពុទ្ធ ការពោលលាព្រះពុទ្ធនេះ គប្បីជាការល្អរបស់អញហ្ន៎ ។

ពីរបទថា **វទតិ វិញ្ញាបេតិ** សេចក្ដីថា ភិក្ខុមានការអផ្សុកនោះ លាន់វាចាពោលអត្ថនេះ ដោយព្យញ្ជនៈទាំងនោះ ឬព្យញ្ជនៈដទៃ និងញុំាងបុគ្គល

ដែលខ្លួនប្រាប់ឲ្យដឹងច្បាស់ គឺឲ្យយល់បាន ។

**បិ** អក្ខរៈក្នុងបទថា **ឯវម្បិ** នេះ មានការប្រមូលអត្ថខាងលើមកជាអត្ថ ការធ្វើឲ្យជាក់ច្បាស់នូវភាពជាអ្នកមានកម្លាំងខ្សោយ ហើយសិក្ខាមិនជាការពោលលា រមែងមានដោយប្រការយ៉ាងនេះ ការធ្វើឲ្យជាក់ច្បាស់នូវភាពជាអ្នកមានកម្លាំងខ្សោយ និងសិក្ខាមិនជាការពោលលា ដោយប្រការដទៃ ក៏នៅមានទៀត ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងការធ្វើឲ្យជាក់ច្បាស់នូវភាពជាអ្នកខ្សោយកម្លាំង និងការមិនពោលលាសិក្ខា ដោយប្រការដទៃនោះ ទើបត្រាស់ពាក្យថា **អថវា បន** ជាដើម ។ ពាក្យទាំងអស់នោះ ដោយអត្ថគឺជាក់ច្បាស់ហើយ ។ តែដោយពាក្យវិនិច្ឆ័យដោយបទទាំង ១៤ ជាដើមនេះថា **ពុទ្ធំ បច្ចក្ខាមិ** ខ្ញុំគប្បីលាព្រះពុទ្ធ **ធម្មំ បច្ចក្ខាមិ** ខ្ញុំគប្បីលាព្រះធម៌ **សង្ឃំ បច្ចក្ខាមិ** ខ្ញុំគប្បីលាព្រះសង្ឃ **សិក្ខំ បច្ចក្ខាមិ** ខ្ញុំគប្បីលាសិក្ខា **វិនយំ បច្ចក្ខាមិ** ខ្ញុំគប្បីលាវិន័យ **បាតិមោក្ខំ បច្ចក្ខាមិ** ខ្ញុំគប្បីលាបាតិមោក្ខ **ឧទ្ទេសំ បច្ចក្ខាមិ** ខ្ញុំគប្បីលាឧទ្ទេស **ឧបជ្ឈាយំ បច្ចក្ខាមិ** ខ្ញុំគប្បីលាឧបជ្ឈាយ៍ **អាចរិយំ បច្ចក្ខាមិ** ខ្ញុំគប្បីលាអាចារ្យ **សទ្ធិវិហារិកំ បច្ចក្ខាមិ** ខ្ញុំគប្បីលាសទ្ធិវិហារិក **អន្តេវាសិកំ បច្ចក្ខាមិ** ខ្ញុំគប្បីលាអន្តេវាសិក **សមានុបជ្ឈាយកំ បច្ចក្ខាមិ** ខ្ញុំគប្បីលាអ្នករួមឧបជ្ឈាយ៍ **សមានាចរិយកំ បច្ចក្ខាមិ** ខ្ញុំគប្បីលាអ្នករួមអាចារ្យ **សព្រហ្មចារឹ បច្ចក្ខាមិ** ខ្ញុំគប្បីលាសព្រហ្មចារី ព្រះដ៏មានព្រះភាគ ត្រាស់ក្នុងវារៈពោលដោយធ្វើឲ្យ

ជាអ្នកខ្សោយកម្លាំងនេះ ដោយអាការ គឺការពោលលាមាន ៨ បទ គឺ **គិហី អស្សំ** ខ្ញុំគប្បីជាគ្រហស្ថ **ឧបាសកោ អស្សំ** ខ្ញុំគប្បីជាឧបាសក **អារាមិកោ អស្សំ** ខ្ញុំគប្បីជាអារាមិក **សាមណេរោ អស្សំ** ខ្ញុំគប្បីជាសាមណេរ **តិត្ថិយោ អស្សំ** ខ្ញុំគប្បីជាតិរ្ថិយ **តិត្ថិយសាវកោ អស្សំ** ខ្ញុំគប្បីជាសាវកតិរ្ថិយ **អស្សមណោ អស្សំ** ខ្ញុំគប្បីជាបុគ្គលមិនមែនសមណៈ **អសក្យបុត្តិយោ អស្សំ** ខ្ញុំគប្បីជាបុគ្គលមិនមែនពូជពង្សសក្យបុត្រ ព្រះដ៏មានព្រះភាគ ត្រាស់ដោយអាការ គឺកំណត់ការៈ ដោយបទថា **អស្សំ** នេះ នៃបណ្តាបទទាំងឡាយមានបទថា **គិហី អស្សំ** ជាដើម ។

បទ ២២ ទាំងដែលប្រកបដោយបទថា **យន្នូនាហំ** នេះ ទ្រង់ត្រាស់ហើយដូចពណ៌នាមក ដូច្នេះ ។ ក្នុង ២២ បទដែលប្រកបដោយបទថា **យន្នូនាហំ** នេះ ទ្រង់ត្រាស់ហើយយ៉ាងណា បទ ២២ ដែលប្រកបដោយបទ ១ ក្នុងបណ្តាបទទាំងនេះ គឺ **យទិ បនាហំ ពុទ្ធំ បច្ចក្ខេយ្យំ** បើមែន ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ... **បនាហំ ពុទ្ធំ បច្ចក្ខេយ្យំ** កាលបើហេតុយ៉ាងនេះមានពិតមែន ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ... **ហន្ទាហំ ពុទ្ធំ បច្ចក្ខេយ្យំ** ណ្ហើយចុះខ្ញុំត្រូវតែលះបង់ព្រះពុទ្ធ ... **ហោតុ មេ ពុទ្ធំ បច្ចក្ខេយ្យំ** ហេតុរបស់ខ្ញុំលើកទុកសិនចុះ ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ... ( ត្រង់សញ្ញាពងត្រី ត្រូវបន្ថែមឲ្យគ្រប់ទាំង ២២ បទ ) ។

ព្រះដ៏មានព្រះភាគត្រាស់ហើយ ដូច្នោះ រួមទាំងអស់ ទើបជា ១១០ បទ ដោយប្រការដូច្នេះ ។

បន្ទាប់អំពីបទថា **ហោតុ មេ** ជាដើមនោះទៅ មាន ១៧ បទជាដើមថា **មាតរំ សរាមិ** ខ្ញុំនឹករឭកដល់មាតា ដែលប្រព្រឹត្តទៅដោយន័យសម្តែងវត្ថុដែលខ្លួនគួររឭកដល់ ។

បណ្តាបទទាំងនោះ បទថា **ខេត្តំ** បានដល់ ស្រែស្រូវសាលីជាដើម ។

បទថា **វត្ថុ** បានដល់ ទីកន្លែងកើតឡើងនៃស្មៅ ស្លឹកឈើ បន្លែ និងផ្លែឈើតូចធំ ។

បទថា **សិប្បំ** បានដល់ សិប្បៈរបស់ជាងថ្នាំង និងជាងតម្បាញជាដើម ។

បន្ទាប់ពីបទ ១៧ នេះទៅ មានបទ ៩ ទៀតថា **មាតា មេ អត្ថិ សា មយា ពោសេតព្វា** មាតារបស់ខ្ញុំមាន មាតានោះ ខ្ញុំត្រូវចិញ្ចឹម ជាការប្រព្រឹត្តទៅដោយអំណាចការសម្តែងភាពជាអ្នកមានកង្វល់ និងមានការជាប់ជំពាក់ ។

បន្ទាប់ពី ៩ បទនោះទៅ មាន ១៦ បទជាដើមថា **មាតា មេ អត្ថិ សា មំ ពោសេស្សតិ** មាតារបស់ខ្ញុំមាន មាតានោះនឹងត្រូវចិញ្ចឹមខ្ញុំ ដែលប្រព្រឹត្តទៅដោយអំណាចសម្តែងដល់បុគ្គលដែលជាទីអាស្រ័យ និងដែលជាពឹងពំនាក់ ។

បន្ទាប់ពី ១៦ បទនោះទៅ មាន ៨ បទជាដើមថា **ទុក្ករំ** ព្រហ្មចរិយៈជាការៈដែលធ្វើបានលំបាក ដែលប្រព្រឹត្តទៅដោយការសម្តែងដល់ភាពដែលព្រហ្មចរិយៈ មានធាន់មួយពេល និងដេកមួយពេល ជាការៈដែលធ្វើបានលំបាក ។

បណ្តាបទទាំងនោះ បទថា **ទុក្ករំ** ភិក្ខុអផ្សុកនោះ រមែងសម្តែងភាព

ដែលព្រហ្មចរិយៈធ្វើបានលំបាក ព្រោះធ្វើកិច្ចវត្តទាំងឡាយ មានការឆាន់ម្ដង ជាដើម ។

ដោយបទថា **ន សុករំ** រមែងផ្ទុយនឹងភាពដែលព្រហ្មចរិយៈជាការៈ ដែលធ្វើបានងាយ ។ ក្នុងពីរបទថា **ទុច្ចរំ ន សុចរំ** នេះ គប្បីជ្រាបន័យ យ៉ាងនោះ ។

ដោយបទថា **ន ឧស្សហាមិ** រមែងសម្ដែងភាពដែលខ្លួនមិនមានសេចក្ដី ឧស្សាហ៍ គឺភាពដែលខ្លួនមិនមានសមត្ថភាពក្នុងការធ្វើកិច្ចវត្ត មានការឆាន់ មួយពេលជាដើម ។

ដោយបទថា **ន វិសហាមិ** រមែងសម្ដែងដល់ភាពដែលខ្លួនមិនមាន ការអត់ធន់ ( ក្នុងកិច្ចវត្ត មានការឆាន់មួយពេលជាដើមនោះ ) ។

ដោយបទថា **ន រមាមិ** រមែងសម្ដែងដល់ការមិនត្រេកអរ ។

ដោយបទថា **នាភិ រមាមិ** រមែងសម្ដែងដល់ការមិនមានសេចក្ដី ត្រេកអរក្រៃលែងនៃចិត្ត ។

ឯបទទាំង ៥០ នេះ និងបទ ១១០ ខាងដើម ទើបរួមជាបទ ១៦០ គប្បីជ្រាបថា ព្រះដ៏មានព្រះភាគត្រាស់ក្នុងវារៈពោលដោយធ្វើឲ្យជាក់ច្បាស់ នូវភាពជាអ្នកខ្សោយកម្លាំង ដោយន័យដូចពោលមកហើយ ។

[ ៣១ ] ពាក្យថា **កថញ្ច ភិក្ខវេ** ជាដើម ក្នុងវារៈពោលដោយការ លាសិក្ខា ដោយអត្ថជាក់ច្បាស់ហើយនោះឯង តែគួរជ្រាបវិនិច្ឆ័យដោយបទ ដូច្នេះថា បទ ១៤ ដែលប្រព្រឹត្តទៅដោយសម្ពន្ធពាក្យពោលលាសិក្ខាទាំង

នេះ គឺ **ពុទ្ធំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធ **ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ **សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃ **សិក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាសិក្ខា **វិនយំ បច្ចក្ខាមិ** ខ្ញុំសូមលាវិន័យ **ចាតិមោក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាបាតិមោក្ខ **ឧទ្ទេសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេស **ឧបជ្ឈាយំ បច្ចក្ខាមិ** ខ្ញុំសូមលាឧបជ្ឈាយ៍ **អាចរិយំ បច្ចក្ខាមិ** ខ្ញុំសូមលាអាចារ្យ **សទ្ធិវិហារិកំ បច្ចក្ខាមិ** ខ្ញុំសូមលាសទ្ធិវិហារិក **អន្តេវាសិកំ បច្ចក្ខាមិ** ខ្ញុំសូមលាអន្តេវាសិក **សមានុបជ្ឈាយកំ បច្ចក្ខាមិ** ខ្ញុំសូមលាអ្នករួមឧបជ្ឈាយ៍ **សមានាចរិយកំ បច្ចក្ខាមិ** ខ្ញុំសូមលាអ្នករួមអាចារ្យ **សព្រហ្មចារឹ បច្ចក្ខាមិ** ខ្ញុំសូមលាសព្រហ្មចារី ព្រះដ៏មានព្រះភាគត្រាស់ហើយ ក្នុងវារៈពោលដោយការលាសិក្ខានេះ ។

ម្យ៉ាងទៀត ពាក្យថា **វទតិ វិញ្ញាបេតិ** ក្នុងគ្រប់ៗ បទ មានអត្ថយ៉ាងនេះថា ភិក្ខុអ្នកអផ្សុកនោះបញ្ចេញវាចាពោល និងញុំាងបុគ្គលដែលខ្លួនប្រាប់ឲ្យដឹងច្បាស់ គឺប្រកាសឲ្យបានឮ បានដល់ឲ្យយល់ដោយការបន្លឺវាចានោះថា ភិក្ខុនេះ មានបំណងនឹងលះបង់សាសនា នឹងផុតចាកសាសនា នឹងលះបង់ភាពជាភិក្ខុ ទើបបន្លឺវាចានេះ ។

បើភិក្ខុនេះមានបំណងនឹងពោលថា **ពុទ្ធំ បច្ចក្ខាមិ** តែធ្វើបទត្រឡប់គ្នាដោយពោលថា **បច្ចក្ខាមិ ពុទ្ធំ** ឬគប្បីពោលអត្ថនោះ ដោយបណ្ដាភាសារបស់អ្នកមិលក្ខភាសាណានីមួយ ឬមានបំណងនឹងពោលថា **ពុទ្ធំ បច្ចក្ខាមិ** តែពោលដោយឆ្លងលំដាប់ថា **ធម្មំ បច្ចក្ខាមិ** ឬពោលថា **សព្រហ្មចារឹ**

**បច្ចក្ខាមិ** សេចក្តីនេះដូចគ្នាក្នុងវិភង្គនៃឧត្តរិមនុស្សធម្ម គឺភិក្ខុដែលមានបំណងនឹងពោលថា **បឋមំ ឈានំ សមាបជ្ជាមិ** ខ្ញុំចូលបឋមជ្ឈាន តែបែរជាពោលថា **ទុតិយំ ឈានំ សមាបជ្ជាមិ** ខ្ញុំចូលទុតិយជ្ឈាន ដូច្នេះ យ៉ាងណា បើភិក្ខុអ្នកអផ្សុកនឹងប្រាប់ដល់បុគ្គលណា បុគ្គលនោះរមែងដឹងពាក្យពោល មានប្រមាណប៉ុណ្ណេះថា ភិក្ខុនេះមានបំណងនឹងលះបង់ភាពជាភិក្ខុ ទើបបានពោលសេចក្តីនេះ ដែលបានឈ្មោះថា ការពោលខុសភ្លាំងភ្លាត់ រមែងមិនមាន ការពោលដូច្នោះ ក៏គង់ចុះកាន់ខេត្តដូចគ្នា សិក្ខាក៏ត្រូវបានលាហើយ ដូច្នោះ ។ ភិក្ខុនោះ រមែងជាអ្នកឃ្លាតចាកសាសនានោះឯង ដូចសត្វដែលឃ្លាតចាកភាពជាសក្កទេវរាជ ឬឃ្លាតចាកភាពជាព្រហ្ម ដូច្នោះ ។

ម្យ៉ាងទៀត បើភិក្ខុពោលដោយពាក្យកំណត់អតីតកាល និងអនាគតកាលថា **ពុទ្ធំ បច្ចក្ខឹ** ក្តី **ពុទ្ធំ បច្ចក្ខេស្សាមិ** ក្តី **ពុទ្ធំ បច្ចក្ខេយ្យំ** ក្តី បញ្ជូនទូតទៅក្តី បញ្ជូនដំណឹងទៅក្តី ធ្លាក់ (សរសេរ)អក្សរក្តី ប្រាប់អត្ថនោះ ដោយមេដៃក្តី សិក្ខារមែងមិនមែនជាការលា ។ ចំណែកការអួតឧត្តរិមនុស្សធម្ម រមែងដល់ទីបំផុត ដោយហោចសូម្បីដោយមេដៃ ។ ការពោលលាសិក្ខា រមែងដល់ទីបំផុត លុះតែភិក្ខុបន្លឺវាចាដែលសម្បយុត្តដោយចិត្ត ក្នុងសម្នាក់របស់សត្វដែលមានជាតិជាមនុស្សប៉ុណ្ណោះ ។

ម្យ៉ាងទៀត ភិក្ខុ កាលបន្លឺវាចាប្រកាសឲ្យអ្នកដទៃដឹង បើចោះចំពោះប្រាប់ចំពោះបុគ្គលម្នាក់ថា បុគ្គលនេះប៉ុណ្ណោះចូរដឹង ហើយបុគ្គលនោះឯងដឹងបំណងរបស់លោកនោះសោត សិក្ខាបទរមែងជាការពោលលា ។ បើបុគ្គល

នោះមិនដឹង តែបុគ្គលដទៃដែលឈរនៅក្នុងទីជិតដឹង សិក្ខារមែងមិនមែនជាការលា បើភិក្ខុនោះបោះចំពោះបុគ្គលពីរនាក់ក្នុងទីដែលបុគ្គលពីរនាក់ឈរ ថា ខ្ញុំប្រាប់ដល់បុគ្គលពីរនាក់នេះ ដូច្នេះ បណ្ដាជនទាំងពីរនោះ កាលបុគ្គលម្នាក់ដឹងក៏ដោយ ដឹងទាំងពីរក៏ដោយ សិក្ខារមែងជាការលា ។ ការលាសិក្ខាសូម្បីក្នុងបុគ្គលច្រើននាក់ បណ្ឌិតក៏គួរជ្រាបដូចអធិប្បាយមកហើយនោះ ។

ម្យ៉ាងទៀត បើភិក្ខុដែលត្រូវភាពមិនត្រេកអរគ្របសង្កត់ ខ្វាចក្រែងភិក្ខុទាំងឡាយ ដែលធ្លាប់ស្និទ្ធស្នាលគ្នា ( ឃាត់ ) ស្រែកប្រកាសថា **ពុទ្ធំ បច្ចក្ខាមិ** ដោយសំឡេងខ្លាំងក្នុងបំណងថា បុគ្គលណាក៏ដោយចូរដឹង បើមានអ្នកធ្វើការនៅក្នុងព្រៃ ឬបុរសដទៃដែលចេះលទ្ធិសាសនា ឈរនៅក្នុងទីមិនឆ្ងាយ បានឮសំឡេងរបស់ភិក្ខុនោះ ក៏យល់ថា សមណៈអ្នកអផ្សុកអង្គនេះប្រាថ្នាភាពជាគ្រហស្ថ ឃ្លាតចាកសាសនាហើយ ដូច្នេះ សិក្ខាបទរមែងជាការពោលលាពិត ។ តែក្នុងខណៈនោះឯង ការពោលលាសិក្ខា មិនមុន មិនក្រោយ ជាប្រការដែលដឹងបានលំបាក ដូចពួកមនុស្សក្នុងលោក ដោយប្រក្រតីធម្មតា ស្ដាប់ពាក្យពោលហើយ រមែងដឹងបាន យ៉ាងណា បើបុគ្គលដែលធ្វើការងារនៅក្នុងព្រៃជាដើមនោះ រមែងដឹងបានដោយសម័យដែលនឹកគិតសោត សិក្ខាបទ ឈ្មោះថា លាហើយ ដូច្នោះ បើក្នុងកាលខាងក្រោយបុរសដែលនៅក្នុងព្រៃនោះ សង្ស័យថា ភិក្ខុអង្គនេះ និយាយអ្វី គិតយូរៗទើបយល់ សិក្ខាបទ មិនឈ្មោះថា លាឡើយ ។ ពិតហើយ ការពោលលាសិក្ខានេះផង អភូតារោចនសិក្ខាបទ ទុដ្ឋុល្លវាចសិក្ខាបទ អត្តកាមសិក្ខាបទ

ទុដ្ឋទោសសិក្ខាបទ និងកូតាភេចនសិក្ខាបទទាំងឡាយ ដែលនឹងពោលតទៅផង មានកំណត់សេចក្ដីដូចគ្នា រមែងដល់ទីបំផុតក្នុងកាលបុគ្គលស្ដាប់ដឹងអត្ថបាន ដោយសម័យដែលនឹកគិតនោះឯង ។ កាលអ្នកស្ដាប់សង្ស័យថា ភិក្ខុអង្គនេះនិយាយអ្វី គិតយូរៗ ទើបយល់សេចក្ដីបាន សិក្ខាទាំង ៥ នោះ គង់មិនដល់ទីបំផុត ។ ដូចវិនិច្ឆ័យនេះ ដែលលោកពោលទុកក្នុងបទថា **ពុទ្ធំ បច្ចក្ខាមិ** យ៉ាងណា គ្រប់បទទាំងអស់ក៏គួរជ្រាបវិនិច្ឆ័យយ៉ាងនោះ ។ ព្រោះសិក្ខារមែងត្រូវភិក្ខុពោលលាក្នុងកាលណា ក្នុងកាលនោះ សូម្បីភិក្ខុមិនពោលពាក្យជាដើមថា **យន្នូនាហំ ពុទ្ធំ បច្ចក្ខេយ្យំ** ភាពជាអ្នកមានកម្លាំងខ្សោយក៏ឈ្មោះថា ធ្វើឲ្យជាក់ច្បាស់ហើយ ហេតុដូច្នោះ ក្នុងទីបំផុតនៃបទទាំងអស់ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយ និងការពោលលាសិក្ខា រមែងមានដោយអាការយ៉ាងនេះ ។

បន្ទាប់អំពី ១៤ បទនោះទៅ ក្នុងបទថា **គិហីតិ មំ ធារេហិ** នេះ មានវិនិច្ឆ័យដូច្នេះថា បើភិក្ខុអ្នកអផ្សុកនោះពោលថា **គិហី ភវិស្សាមិ** ខ្ញុំនឹងជាគ្រហស្ថដូច្នេះក្ដី **គិហី ហោមិ** ខ្ញុំប្រាកដជាគ្រហស្ថដូច្នេះក្ដី **គិហី តោម្ហិ** ខ្ញុំកើតជាគ្រហស្ថហើយដូច្នេះក្ដី **គិហិម្ហិ** ខ្ញុំរមែងជាគ្រហស្ថដូច្នេះក្ដី សិក្ខាមិនឈ្មោះថា ពោលលាឡើយ ។ តែបើពោលថា **អជ្ជ បដ្ឋាយ គិហីតិ មំ ធារេហិ** តាំងអំពីថ្ងៃនេះទៅ សូមអ្នកចាំនូវខ្ញុំថាជាគ្រហស្ថចុះ ដូច្នេះក្ដី **អជ្ជ បដ្ឋាយ គិហីតិ មំ ជានាហិ** តាំងអំពីថ្ងៃនេះទៅ សូមអ្នកដឹងនូវខ្ញុំថាជា

គ្រហស្ថ ដូច្នេះក្តី **អជ្ជ បដ្ឋាយ គិហីតិ មំ សញ្ជានាហិ** តាំងអំពីថ្ងៃនេះទៅ សូមអ្នកចំណាំ ខ្ញុំថាជាគ្រហស្ថចុះ ដូច្នេះក្តី **អជ្ជ បដ្ឋាយ គិហីតិ មំ មនសិករោហិ** តាំងអំពីថ្ងៃនេះទៅ សូមអ្នកដាក់ចិត្តនូវខ្ញុំថាជាគ្រហស្ថចុះ ដូច្នេះក្តី ឬពោលដោយវោហាររបស់អ្នកអរិយកៈ ឬវោហាររបស់អ្នកមិលក្ខក្តី កាលលោកពោលអត្ថនោះយ៉ាងនេះហើយ បើបុគ្គលដែលខ្លួនប្រាប់យល់បាន សិក្ខាបទឈ្មោះថា លា ។

ក្នុងពាក្យ មានបទថា **ឧចាសកោ** ជាដើមដ៏សេសក៏មានន័យដូច្នោះ ។ ឯ ៨បទនេះ និង១៤ បទជាដើម ទើបរួមជា ២២ បទដូច្នេះឯង ។ បន្ទាប់អំពី ៨ បទនោះទៅ លោកពោលសង្គ្រោះយក ១៤ បទខាងដើមនោះឯងចូលដោយ ៤ បទនេះ គឺ **អលម្មេ កិន្នុមេ ន មមត្ថោ សុមុត្តាហំ** ទើបត្រូវជា ៥៦ បទ ។

បណ្តាបទទាំងនោះ បទថា **អលំ** ប្រែថា ល្មោយចុះ អធិប្បាយថា យ៉ាងណាក៏ដោយចុះ ។

បទថា **កិន្នុមេ** សេចក្តីថា កិច្ចអ្វីរបស់ខ្ញុំ គឺកិច្ចអ្វីដែលខ្ញុំគួរធ្វើ អធិប្បាយថា កិច្ចអ្វីដែលខ្ញុំគប្បីធ្វើឲ្យសម្រេច ។

បទថា **ន មមត្ថោ** សេចក្តីថា ខ្ញុំមិនមានសេចក្តីត្រូវការ ។

បទថា **សុមុត្តាហំ** កាត់បទជា **សុមុត្តោ អហំ** ប្រែថា ខ្ញុំផុតល្អហើយ ( អំពីព្រះពុទ្ធ ) ។

ពាក្យដ៏សេសក្នុង ៥៦ បទនេះ មានន័យដូចពោលមកហើយនោះឯង។

៦ ៥៦ បទនេះ និង ២២ បទខាងដើម ទើបរួមជា ៧៨ បទ លោកពោល ទុកដោយសរុបប៉ុណ្ណោះ ដោយប្រការយ៉ាងនេះ ព្រោះការពោលលាសិក្ខា រមែងមានសម្បីដោយពាក្យដែលជាវេវចនសព្ទ នៃបទដែលជាខេត្តទាំងនោះ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **យានិ វាបនញ្ញានិបិ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យានិ វាបនញ្ញានិបិ** សេចក្តីថា វៀរបទ ដែលមកក្នុងបាលីថា **ពុទ្ធំ** ជាដើមចេញហើយ ពាក្យវេវចនសព្ទដទៃពួកណា នៅមានទៀត ។

បទថា **ពុទ្ធវេវចនានិ វា** បានដល់ ព្រះនាមដោយបរិយាយនៃព្រះពុទ្ធ ។បេ។ ឬនាមដោយបរិយាយនៃបុគ្គលដែលមិនមែនពូជពង្សសក្យបុត្រ ។

បណ្តាព្រះនាមដែលជាវេវចនៈនៃព្រះពុទ្ធជាដើមនោះ ព្រះនាមរាប់ពាន់ មកហើយក្នុងវណ្ណប្បដ្ឋាន ព្រះនាម ១០០ មកហើយក្នុងឧបាលិវាទសូត្រ និង ព្រះនាមដទៃ ដែលបានដោយព្រះគុណ គប្បីជ្រាបថា ជាវេវចនៈនៃព្រះពុទ្ធ ។ ឈ្មោះនៃព្រះសទ្ធម្មទាំងអស់ គប្បីជ្រាបថា ជាវេវចនៈនៃព្រះធម៌ ។ ក្នុង វេវចនៈនៃព្រះសង្ឃទាំងអស់ ក៏មានន័យដូច្នោះ ។

ក្នុងព្រះនាមដែលជាវេវចនៈនៃព្រះពុទ្ធជាដើមនេះ មានយោជនាដូច្នេះថា ការពោលលាដោយពាក្យថា **ពុទ្ធំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយ វេវចនៈតាមដែលពោលឡើយ ការពោលលាជាដើមយ៉ាងនេះថា **សម្មាសម្ពុទ្ធំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង **អនន្តពុទ្ធឹ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធទ្រង់មានការត្រាស់ដឹងមិនមានទីបំផុត **អនោមពុទ្ធឹ**

**បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធទ្រង់មានការត្រាស់ដឹងមិនថោកថយ **ពោធិប្ប-ញ្ញាណំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធទ្រង់មានការត្រាស់ដឹងជាគ្រឿងប្រាកដ **ធីរំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធទ្រង់មានបញ្ញាជាគ្រឿងទ្រទ្រង់ចាំ **វិគតមោហំ បច្ចក្ខាមិ** ខ្ញុំសូមលា ព្រះពុទ្ធទ្រង់ប្រាសចាកមោហៈ **បភិន្នខីលំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធទ្រង់ទម្លាយសសរខឿនក្នុងចិត្តហើយ **វិជិតវិជយំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះពុទ្ធទ្រង់មានជម្នះវិសេស រាប់ជាការពោលលាសិក្ខាដោយពាក្យវេវចនៈនៃព្រះពុទ្ធ ។

ការពោលលាដោយពាក្យថា **ធម្មំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយវេវចនៈតាមដែលពោលឡើយ ។

ឈ្មោះនៃព្រះធម្មក្ខន្ធមួយៗ ក្នុងបណ្តា ៨៤០០០ ធម្មក្ខន្ធ ( នេះ ) គឺ **ស្វាក្ខាតំ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយ **សន្ទិដ្ឋិកំ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលអ្នកបានសម្រេចគប្បីឃើញឯង **អកាលិកំ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលឲ្យផលមិនរង់ចាំកាល **ឯហិបស្សិកំ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលគួរហៅមកមើល **ឱបនយិកំ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលគួរបង្អោនចូលមកទុកក្នុងចិត្ត **បច្ចត្តំ វេទិតព្វំ វិញ្ញូហិ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលវិញ្ញូជនគប្បីដឹងចំពោះខ្លួន **អសង្ខតំ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលបច្ច័យមិនបានតាក់តែង **វិរាគំ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលប្រាសចាករាគៈ **និរោធំ ធម្មំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះធម៌ដែលរំលត់ល្អ

**អមតំ ធម្មំ បច្ចក្ខាមិ** *ខ្ញុំសូមលាព្រះធម៌ដែលជាអមតៈ* **ទីឃនិកាយំ បច្ចក្ខាមិ** *ខ្ញុំសូមលាទីឃនិកាយ* **ព្រហ្មជាលំ បច្ចក្ខាមិ** *ខ្ញុំសូមលាព្រហ្មជាលសូត្រ* **មជ្ឈិមនិកាយំ បច្ចក្ខាមិ** *ខ្ញុំសូមលាមជ្ឈិមនិកាយ* **មូលបរិយាយំ បច្ចក្ខាមិ** *ខ្ញុំសូមលាមូលបរិយាយសូត្រ* **សំយុត្តនិកាយំ បច្ចក្ខាមិ** *ខ្ញុំសូមលាសំយុត្តនិកាយ* **អង្គុត្តរនិកាយំ បច្ចក្ខាមិ** *ខ្ញុំសូមលាអង្គុត្តរនិកាយ* **ជាតកនិកាយំ បច្ចក្ខាមិ** *ខ្ញុំសូមលាជាតកនិកាយ* **អភិធម្មំ បច្ចក្ខាមិ** *ខ្ញុំសូមលាព្រះអភិធម្ម* **កុសលំ ធម្មំ បច្ចក្ខាមិ** *ខ្ញុំសូមលាកុសលធម៌* **អកុសលំ ធម្មំ បច្ចក្ខាមិ** *ខ្ញុំសូមលាអកុសលធម៌* **អព្យាកតំ ធម្មំ បច្ចក្ខាមិ** *ខ្ញុំសូមលាអព្យាកតធម៌* **សតិប្បដ្ឋានំ បច្ចក្ខាមិ** *ខ្ញុំសូមលាសតិប្បដ្ឋាន* **សម្មប្បធានំ បច្ចក្ខាមិ** *ខ្ញុំសូមលាសម្មប្បធាន* **ឥទ្ធិបាទំ បច្ចក្ខាមិ** *ខ្ញុំសូមលាឥទ្ធិបាទ* **ឥន្ទ្រិយំ បច្ចក្ខាមិ** *ខ្ញុំសូមលាឥន្ទ្រិយ* **ពលំ បច្ចក្ខាមិ** *ខ្ញុំសូមលាពលៈ* **ពោជ្ឈង្គំ បច្ចក្ខាមិ** *ខ្ញុំសូមលាពោជ្ឈង្គ* **មគ្គំ បច្ចក្ខាមិ** *ខ្ញុំសូមលាមគ្គ* **ផលំ បច្ចក្ខាមិ** *ខ្ញុំសូមលាផល* **និព្វានំ បច្ចក្ខាមិ** *ខ្ញុំសូមលាព្រះនិព្វាន រាប់ថា ជាវេវចនៈនៃពាក្យថា ព្រះធម៌នោះឯង ។*

*ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃព្រះធម៌ដូចពណ៌នាមក ដូច្នេះ ។*

*ការពោលលាដោយពាក្យថា* **សង្ឃំ បច្ចក្ខាមិ** *មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃព្រះសង្ឃយ៉ាងនេះ គឺ* **សុបដិបន្នំ សង្ឃំ បច្ចក្ខាមិ** *ខ្ញុំសូមលាព្រះសង្ឃ*

អ្នកបដិបត្តិល្អ **ឧជុបដិបន្នំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃអ្នកបដិបត្តិត្រង់ **ញាយបដិបន្នំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃអ្នកបដិបត្តិដើម្បីត្រាស់ដឹងនូវធម៌ **សាមីចិបដិបន្នំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃអ្នកបដិបត្តិសមគួរ **ចតុប្បុរិសយុគំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃដែលជាគូនៃបុរស ៤ គូ **អដ្ឋបុរិសបុគ្គលំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃគឺបុរសបុគ្គល ៨ **អាហុនេយ្យំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃដែលគួរបូជា **ចាហុនេយ្យំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃអ្នកគួរទទួលរបស់សម្រាប់ភ្ញៀវ **ទក្ខិណេយ្យំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃអ្នកគួរដល់ទក្ខិណា **អញ្ជលិករណីយំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃអ្នកគួរធ្វើអញ្ជលី **អនុត្តរំ បុញ្ញក្ខេត្តំ សង្ឃំ បច្ចក្ខាមិ** ខ្ញុំសូមលាព្រះសង្ឃអ្នកជាស្រែបុណ្យ ( ដែលជារបស់សត្វលោក ) មិនមានស្រែបុណ្យដទៃក្រៃលែងជាង ។

# អធិប្បាយ វិធីពោលលាសិក្ខាតទៅ

ការពោលលាដោយពាក្យថា **សិក្ខំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃសិក្ខាយ៉ាងនេះ គឺ **ភិក្ខុ សិក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាសិក្ខារបស់ភិក្ខុ **ភិក្ខុនី សិក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាសិក្ខារបស់ភិក្ខុនី **អធិសីលសិក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាអធិសីលសិក្ខា **អធិចិត្តសិក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាអធិចិត្តសិក្ខា **អធិប្បញ្ញា សិក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាអធិប្បញ្ញាសិក្ខា ។

ការពោលលាដោយពាក្យថា **វិនយំ បច្ចក្ខាមិ** មិនមែនជាការពោល

លាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃវិន័យ មានជាដើមយ៉ាងនេះ គឺ **ភិក្ខុវិនយំ បច្ចក្ខាមិ** ខ្ញុំសូមលាវិន័យរបស់ភិក្ខុ **ភិក្ខុនីវិនយំ បច្ចក្ខាមិ** ខ្ញុំសូមលាវិន័យរបស់ភិក្ខុនី **បឋមំ បារាជិកំ បច្ចក្ខាមិ** ខ្ញុំសូមលាបឋមបារាជិក **ទុតិយំ បារាជិកំ បច្ចក្ខាមិ** ខ្ញុំសូមលាទុតិយបារាជិក **តតិយំ បារាជិកំ បច្ចក្ខាមិ** ខ្ញុំសូមលាតតិយបារាជិក **ចតុត្ថំ បារាជិកំ បច្ចក្ខាមិ** ខ្ញុំសូមលាចតុត្ថបារាជិក **សង្ឃាទិសេសំ បច្ចក្ខាមិ** ខ្ញុំសូមលាសង្ឃាទិសេស **ថុល្លច្ចយំ បច្ចក្ខាមិ** ខ្ញុំសូមលាថុល្លច្ច័យ **បាចិត្តិយំ បច្ចក្ខាមិ** ខ្ញុំសូមលាបាចិត្តិយ **បាដិទេសនីយំ បច្ចក្ខាមិ** ខ្ញុំសូមលាបាដិទេសនីយ **ទុក្កដំ បច្ចក្ខាមិ** ខ្ញុំសូមលាទុក្កដ **ទុព្ភាសិតំ បច្ចក្ខាមិ** ខ្ញុំសូមលាទុព្ភាសិត ។

ការពោលលាដោយពាក្យថា **បាតិមោក្ខំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃបាតិមោក្ខយ៉ាងនេះ គឺ **ភិក្ខុបាតិមោក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាភិក្ខុបាតិមោក្ខ **ភិក្ខុនីបាតិមោក្ខំ បច្ចក្ខាមិ** ខ្ញុំសូមលាភិក្ខុនីបាតិមោក្ខ ។

ការពោលលាដោយពាក្យថា **ឧទ្ទេសំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃឧទ្ទេសមានជាដើមយ៉ាងនេះ គឺ **ភិក្ខុបាតិមោក្ខុទ្ទេសំ បច្ចក្ខាមិ** ខ្ញុំសូមលាភិក្ខុបាតិមោក្ខុទ្ទេស **បឋមំ បាតិមោក្ខុទ្ទេសំ បច្ចក្ខាមិ** ខ្ញុំសូមលាបាតិមោក្ខុទ្ទេសទី ១ **ទុតិយំ បាតិមោក្ខុទ្ទេសំ បច្ចក្ខាមិ** ខ្ញុំសូមលាបាតិមោក្ខុទ្ទេសទី ២ **តតិយំ បាតិមោក្ខុទ្ទេសំ បច្ចក្ខាមិ** ខ្ញុំសូមលាបាតិ-

មោក្ខទោសទី ៣ **ចតុត្ថំ ធាតិមោក្ខទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាបាតិមោក្ខទោសទី ៤ **បញ្ចមំ ធាតិមោក្ខទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាបាតិមោក្ខទោសទី ៥ **សម្មាសម្ពុទ្ធទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេសនៃព្រះសម្មាសម្ពុទ្ធ **អនន្ត-ពុទ្ធិទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេសនៃព្រះអនន្តពុទ្ធិ **អនោមពុទ្ធិទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេសនៃព្រះអនោមពុទ្ធិ **ពោធិបញ្ញាណទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេសនៃព្រះពោធិបញ្ញាណ **ធីរទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេសនៃព្រះធីរៈ **វិគតមោហទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេសនៃព្រះវិគតមោហៈ **បភិន្នខីលទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេសនៃព្រះបភិន្នខីលៈ **វិជិតវិជយទោសំ បច្ចក្ខាមិ** ខ្ញុំសូមលាឧទ្ទេសនៃព្រះវិជិតវិជ័យ ។

ការពោលលាដោយពាក្យថា **ឧបជ្ឈាយំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈឡើយ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃឧបជ្ឈាយ៍យ៉ាងនេះ គឺកិក្ខុណាឲ្យខ្ញុំបព្វជ្ជា កិក្ខុណាឲ្យខ្ញុំឧប-សម្បទា ខ្ញុំបព្វជ្ជាហើយ ព្រោះមានកិក្ខុណាជាប្រធាន ខ្ញុំឧបសម្បទាហើយមានកិក្ខុណាជាប្រធាន បព្វជ្ជារបស់ខ្ញុំ មានកិក្ខុណាជាប្រធាន ឧបសម្បទារបស់ខ្ញុំ មានកិក្ខុណាជាប្រធាន ខ្ញុំសូមលាកិក្ខុនោះ ។

ការពោលលាដោយពាក្យថា **អាចរិយំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយវេវចនៈនៃអាចារ្យយ៉ាងនេះ គឺកិក្ខុឲ្យខ្ញុំបព្វជ្ជា កិក្ខុសូធ្យប្រកាសខ្ញុំ ខ្ញុំនៅអាស្រ័យកិក្ខុណា ខ្ញុំឲ្យកិក្ខុណាសម្តែងឧទ្ទេសឲ្យ ខ្ញុំសាកសួរឧទ្ទេសនឹងកិក្ខុ

ណា ភិក្ខុណាសម្តែងឧទ្ទេសដល់ខ្ញុំ ភិក្ខុណាអនុញ្ញាតឲ្យខ្ញុំសួរឧទ្ទេស ខ្ញុំសូមលាភិក្ខុនោះ ។

ការពោលលាដោយពាក្យថា **សទ្ធិវិហារិកំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃសទ្ធិវិហារិកយ៉ាងនេះ គឺខ្ញុំឲ្យសាមណេរណាបព្វជ្ជា ខ្ញុំឲ្យភិក្ខុណាឧបសម្បទា សាមណេរណាបព្វជ្ជាហើយ ព្រោះមានខ្ញុំជាប្រធាន ភិក្ខុណាឧបសម្បទាហើយ ព្រោះមានខ្ញុំជាប្រធាន បព្វជ្ជារបស់សាមណេរណាមានខ្ញុំជាប្រធាន ឧបសម្បទារបស់ភិក្ខុណាមានខ្ញុំជាប្រធាន ខ្ញុំសូមលាសាមណេរ និងភិក្ខុនោះ ។

ការពោលលាដោយពាក្យថា **អន្តេវាសិកំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃអន្តេវាសិកយ៉ាងនេះ គឺខ្ញុំឲ្យសាមណេរណាបព្វជ្ជា ខ្ញុំសូធ្យប្រកាសឲ្យភិក្ខុណា ភិក្ខុណានៅអាស្រ័យខ្ញុំ ភិក្ខុណាឲ្យខ្ញុំសម្តែងឧទ្ទេសឲ្យភិក្ខុណាសាកសួរឧទ្ទេសនឹងខ្ញុំ ខ្ញុំសម្តែងឧទ្ទេសដល់ភិក្ខុណា ខ្ញុំអនុញ្ញាតឲ្យភិក្ខុណាសាកសួរឧទ្ទេស ខ្ញុំសូមលាភិក្ខុនោះ ។

ការពោលលាដោយពាក្យថា **សមានុបជ្ឈាយកំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃភិក្ខុអ្នករួមឧបជ្ឈាយ៍យ៉ាងនេះ គឺឧបជ្ឈាយ៍របស់ខ្ញុំឲ្យសាមណេរណាបព្វជ្ជាហើយ ឲ្យភិក្ខុណាឧបសម្បទាហើយ សាមណេរណា

បព្វជ្ជាហើយ ក្នុងសម្នាក់របស់ឧបជ្ឈាយ៍នោះ ភិក្ខុណាឧបសម្បទាហើយក្នុងសម្នាក់របស់ឧបជ្ឈាយ៍នោះ បព្វជ្ជារបស់សាមណេរណាមានឧបជ្ឈាយ៍នោះជាប្រធាន ឧបសម្បទារបស់ភិក្ខុណាមានឧបជ្ឈាយ៍នោះជាប្រធាន ខ្ញុំសូមលាភិក្ខុនោះ ។

ការពោលលាដោយពាក្យថា **សមានាចរិយកំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃអ្នករួមអាចារ្យយ៉ាងនេះ គឺអាចារ្យរបស់ខ្ញុំឲ្យសាមណេរណាបព្វជ្ជា សូធ្យប្រកាសឲ្យភិក្ខុណា ភិក្ខុណានៅអាស្រ័យអាចារ្យនោះ ភិក្ខុណាឲ្យអាចារ្យនោះសម្តែងឧទ្ទេស ឲ្យសាកសួរឧទ្ទេស អាចារ្យរបស់ខ្ញុំសម្តែងឧទ្ទេសដល់ភិក្ខុណា អនុញ្ញាតឲ្យភិក្ខុណាសាកសួរឧទ្ទេស ខ្ញុំសូមលាភិក្ខុនោះ ។

ការពោលលាដោយពាក្យថា **សព្រហ្មចារឹ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃសព្រហ្មចារីយ៉ាងនេះ គឺខ្ញុំសិក្សាអធិសីល សិក្សាអធិចិត្ត សិក្សាអធិប្បញ្ញា រួមជាមួយភិក្ខុណា ខ្ញុំសូមលាសព្រហ្មចារីនោះ ។

ការពោលលាដោយពាក្យថា **គិហីតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃគ្រហស្ថយ៉ាងនេះ គឺ **អាគារិកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាអ្នកគ្រប់គ្រងផ្ទះចុះ **កស្សកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថាជាកសិករចុះ **វាណិជោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថាជាអ្នកជំនួញចុះ

**គោរក្ខោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថាជាអ្នករក្សាគោចុះ **ឱគល្វកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថាជាមនុស្សកំព្រាចុះ **មោលិពទ្ធោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថាជាអ្នកទុកផ្នួងសក់ចុះ **កាមគុណិកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថាជាអ្នកបរិភោគកាមគុណចុះ ។

ការពោលលាដោយពាក្យថា **ឧបាសកោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃឧបាសកយ៉ាងនេះ គឺ **ទ្វេវាចិកោ ឧបាសកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាឧបាសកមានវាចាពីរចុះ **តេវាចិកោតិ ឧបាសកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាឧបាសកមានវាចាបីចុះ **ពុទ្ធំ សរណាគមនិកោ ឧបាសកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាឧបាសក អ្នកដល់នូវព្រះពុទ្ធជាទីពឹងចុះ **ធម្មំ សរណាគមនិកោ ឧបាសកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថាជាឧបាសក អ្នកដល់នូវព្រះធម៌ជាទីពឹងចុះ **សង្ឃំ សរណាគមនិកោ ឧបា-សកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាឧបាសក អ្នកដល់នូវព្រះសង្ឃជាទីពឹងចុះ **បញ្ចសិក្ខាបទិកោឧបាសកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាឧបាសកអ្នករក្សាសិក្ខាបទ ៥ ចុះ **ទសសិក្ខាបទិកោឧបាសកោតិ មំ ធារេហិ** អ្នកចូរចាំ ខ្ញុំទុកថា ជាឧបាសកអ្នករក្សាសិក្ខាបទ ១០ ចុះ ។

ការពោលលាដោយពាក្យថា **អារាមិកោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃអារាមិកយ៉ាងនេះ គឺ **កប្បិយការកោតិ មំ ធារេហិ** អ្នក

ចូរចាំខ្ញុំទុកថា ជាកប្បិយការកៈ **វេយ្យាវច្ចករោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាវេយ្យាវច្ចករ **អប្បហារិតការកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាអ្នកចោលរបស់ស្រស់ពណ៌ខៀវ ( អ្នកជម្រះ ឬកាត់ស្មៅ ) ចុះ **យាគុភាជកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុក ថាជាអ្នកចែកបបរចុះ **ផល-ភាជកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុក ថាជាអ្នកចែកផ្លែឈើចុះ **ខជ្ជក-ភាជកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុក ថាជាអ្នកចែករបស់ទំពាចុះ ។

ការពោលលាដោយពាក្យថា **សាមណេរោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃសាមណេរយ៉ាងនេះ គឺ **កុមារកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាសាមណេរក្មេងចុះ **ចេដកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាសាមណេរតូចចុះ **បេដកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាសាមណេរកណ្ដាលចុះ **មោឡិគល្លោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាសាមណេរធំចុះ **សមណុទ្ទេសោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាសមណុទ្ទេស ( សាមណេរដែលមានអាយុច្រើន ឬថេរសាមណេរ ) ចុះ ។

ការពោលលាដោយពាក្យថា **តិត្ថិយោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃតិត្ថិយយ៉ាងនេះ គឺ **និគណ្ឋោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជានិគណ្ឋចុះ **អាជីវកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាអាជីវកចុះ **តាបសោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាតាបសចុះ **បរិព្វាជកោតិ មំ**

**ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាបរិព្វាជកចុះ **បណ្ឌរង្គោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាតាបសស្លៀកសចុះ ។

ការពោលលាដោយពាក្យថា **តិត្ថិយសាវកោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃសាវកតិរ្ថិយយ៉ាងនេះ គឺ **និគណ្ឋសាវកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាសាវករបស់និគណ្ឋចុះ **អាជីវកតាបសបរិព្វាជក-បណ្ឌរង្គសាវកោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាសាវករបស់អាជីវក តាបស បរិព្វាជក និងតាបសស្លៀក-សចុះ ។

ការពោលលាដោយពាក្យថា **អស្សមណោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃបុគ្គលមិនមែនសមណៈយ៉ាងនេះ គឺ **ទុស្សីលោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាបុគ្គលទ្រុស្តសីលចុះ **បាបធម្មោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាបុគ្គលមានធម៌ដ៏លាមកចុះ **អសុចិសង្កស្សរសមាចារោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាបុគ្គលមិនស្អាត និងមានសមាចារ ដែលគាប់រពឹកដោយសេចក្តីរង្កៀសចុះ **បដិច្ឆន្នកម្មន្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាអ្នកមានការងារក្នុងទីកំបាំងចុះ **អស្សមណោសមណបដិញ្ញោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាបុគ្គលមិនមែនសមណៈ តែប្តេជ្ញាថាជាសមណៈចុះ **អព្រហ្មចារីព្រហ្មចារិបដិញ្ញោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាអ្នកប្រព្រឹត្តធម៌មិនប្រសើរ ក៏ប្តេជ្ញាថាជាអ្នកប្រព្រឹត្តប្រសើរចុះ **អន្តោបូតីតិ មំ**

**ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាអ្នកស្មុយក្នុងចុះ **អវស្សុតោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាបុគ្គលដែលរាគៈឲ្យសើមជោកជាំហើយចុះ **កសម្ពុជាតោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាបុគ្គលដូចកាកសំណល់ចុះ **កោណ្ឌោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា ជាបុគ្គលអាក្រក់លាមកចុះ ។

ការពោលលាដោយពាក្យថា **អសក្យបុត្តិយោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងមានដោយពាក្យវេវចនៈនៃបុគ្គលមិនមែនពូជពង្សសក្យបុត្រ មានយ៉ាងនេះជាដើម គឺ **ន សម្មាសម្ពុទ្ធបុត្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា មិនជាបុត្ររបស់ព្រះសម្មាសម្ពុទ្ធ **ន អនន្តពុទ្ធិបុត្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា មិនមែនជាបុត្ររបស់ព្រះអនន្តពុទ្ធិ **ន អនោមពុទ្ធិបុត្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា មិនមែនជាបុត្ររបស់ព្រះអនោមពុទ្ធិ **ន ពោធិប្បញ្ញាណបុត្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា មិនមែនជាបុត្ររបស់ព្រះពោធិប្បញ្ញាណ **ន ធីរ-បុត្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា មិនមែនជាបុត្ររបស់ព្រះធីរៈ **ន វិគតមោហបុត្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា មិនមែនជាបុត្ររបស់ព្រះវិគតមោហៈ **ន បភិន្នខីលបុត្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា មិនមែនជាបុត្ររបស់ព្រះបភិន្នខីលៈ **ន វិជិតវិជយបុត្តោតិ មំ ធារេហិ** អ្នកចូរចាំខ្ញុំទុកថា មិនមែនជាបុត្ររបស់ព្រះវិជិតវិជ័យ ។

ច្រើនបទថា **តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ** សេចក្ដីថា ( ភិក្ខុរមែងពោលឲ្យអ្នកដទៃដឹង ) ដោយពាក្យវេវចនៈនៃព្រះរតន-

ត្រ័យ មានព្រះពុទ្ធជាដើមនោះ ដែលត្រាស់ដោយន័យជាដើមថា វេវចនៈនៃព្រះពុទ្ធក្តី ។ ពិតហើយ ពាក្យវេវចនៈទាំងឡាយ លោកហៅថា អាការ ព្រោះជាហេតុនៃការពោលលាសិក្ខា ហៅថា ភេទ ព្រោះសម្តែងទ្រង់ទ្រាយនៃព្រះពុទ្ធជាដើម ឬព្រោះការសមគួរដល់ការពោលលាសិក្ខានោះឯង ហៅថា និមិត្ត ព្រោះជាហេតុឲ្យដឹងការពោលលាសិក្ខា ដូចចំណុចខ្មៅទាំងឡាយ មានអាចម៍រុយជាដើម ( ប្រជ្រុយ ) របស់ពួកមនុស្សដូច្នោះ ។

ព្រះដ៏មានព្រះភាគត្រាស់កំណត់ពិតប្រាកដយ៉ាងនេះថា **ឯវំ ខោ ភិក្ខវេ** ដូច្នេះជាដើម ព្រោះហេតុនៃការពោលលាសិក្ខាដទៃ ក្រៅពីហេតុដែលពោលហើយនេះមិនមាន ។ ពិតហើយ ក្នុងពាក្យថា **ឯវំ ខោ** នេះ មានអធិប្បាយដូច្នេះថា ការធ្វើឲ្យជាក់ច្បាស់នូវភាពជាបុគ្គលមានកម្លាំងខ្សោយ និងការពោលលាសិក្ខា រមែងមានដោយអាការយ៉ាងនេះឯង ហេតុដទៃ ក្រៅអំពីនេះមិនមាន ។

## ពោលលាសិក្ខានឹងមនុស្សវិកលចរិតជាដើមមិនជាឋានៈ

[ ៣២ ] ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងលក្ខណៈនៃការពោលលាសិក្ខា ដើម្បីការមិនភ័ន្តច្រឡំក្នុងការមិនពោលលា និងដើម្បីសម្តែងវិបត្តិនៃលក្ខណៈការពោលលាសិក្ខានោះឯង ដោយអំណាចនៃបុគ្គលជាដើម ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ អបច្ចក្ខាតា** ដូច្នេះជាដើម ។ ក្នុងពាក្យថា **អបច្ចក្ខាតា** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ពាក្យថា **យេហិ អាការេហិ** ជាដើម មានន័យដូចពោលហើយនោះឯង ។

បទថា **ឧម្មត្តកោ** បានដល់ ភិក្ខុឆ្កួត ព្រោះត្រូវខ្មោចចូល ឬឆ្កួតព្រោះប្រមាត់កម្រើក គឺភិក្ខុមានសញ្ញាវិបរិតអន្តណាទីមួយ ។ ភិក្ខុឆ្កួតនោះ បើពោលលា ( សិក្ខា ) សោត សិក្ខាមិនឈ្មោះថា លាឡើយ ។

បទថា **ឧម្មត្តកស្ស** បានដល់ ភិក្ខុឆ្កួតនោះដូចគ្នា ។ ពិតហើយ បើបកតត្តភិក្ខុ ( ភិក្ខុប្រក្រតី ) ពោលលាសិក្ខាក្នុងសម្នាក់របស់ភិក្ខុឆ្កួត ដូច្នោះសោត ភិក្ខុឆ្កួតមិនយល់ សិក្ខា ឈ្មោះថា មិនពោលលាឡើយ ។

ភិក្ខុឆ្កួត ព្រោះត្រូវខ្មោចចូល លោកហៅថា ភិក្ខុមានចិត្តរវើរវាយ ។ ម្យ៉ាងទៀត ពាក្យថា ភិក្ខុឆ្កួត ព្រោះត្រូវខ្មោចចូលសណ្ឋិត ឬភិក្ខុឆ្កួតព្រោះប្រមាត់កម្រើក លោកពោលទុកហើយក្នុងបទដើម ដោយភាពជាភិក្ខុឆ្កួតស្មើគ្នា ។ ការប្លែកគ្នានៃភិក្ខុឆ្កួតទាំងពីរ នឹងមានច្បាស់ក្នុងអនាបត្តិវារៈ ។ ភិក្ខុមានចិត្តរវើរវាយយ៉ាងនោះ ពោលលា ( សិក្ខា ) សិក្ខា មិនឈ្មោះថា លាឡើយ ។ សិក្ខា សូម្បីបកតត្តភិក្ខុពោលលាហើយក្នុងសម្នាក់របស់ភិក្ខុ ឆ្កួតព្រោះត្រូវខ្មោចចូលនោះ កាលភិក្ខុឆ្កួតនោះមិនយល់ ក៏ឈ្មោះថា មិនជាការពោលលាឡើយ ។

បទថា **វេទនដ្ដោ** បានដល់ ភិក្ខុដែលទុក្ខវេទនាដ៏មានកម្លាំងពាល់ត្រូវហើយ គឺបុគ្គលដែលត្រូវកំរោលគ្របសង្កត់ហើយ ។ សិក្ខាដែលភិក្ខុត្រូវវេទនាបៀតបៀនគ្របសង្កត់នោះ សូម្បីពោលលាហើយ ក៏ឈ្មោះថា មិនពោលលា ។ សិក្ខា ដែលភិក្ខុពោលលាហើយ ក្នុងសម្នាក់របស់ភិក្ខុដែលត្រូវវេទនាគ្របសង្កត់នោះ បើភិក្ខុត្រូវវេទនាគ្របសង្កត់នោះមិនយល់ ក៏មិន

ជាការពោលលាឡើយ ។

ពីរបទថា **ទេវតាយ សន្តិកេ** សេចក្ដីថា សិក្ខាដែលភិក្ខុពោលលាហើយ ក្នុងសម្នាក់របស់ទេវតា តាំងអំពីកុម្មទេវតាទៅ រហូតដល់អនិដ្ឋទេវតា ឈ្មោះថា មិនជាការពោលលាឡើយ ។

បទថា **តិរច្ឆានគតស្ស** សេចក្ដីថា សិក្ខាដែលភិក្ខុពោលលាហើយ ក្នុងសម្នាក់របស់នាគមាណពក្ដី សុបណ្ណកំលោះក្ដី ឬក្នុងសម្នាក់របស់ទេវតាពួកកិន្នរ ដំរី និងស្វាជាដើមពួកណានីមួយក្ដី ឈ្មោះថា មិនជាការពោលលាឡើយ ។

សិក្ខា ដែលភិក្ខុពោលលា ក្នុងសម្នាក់របស់បណ្ដាភិក្ខុឆ្កួតជាដើមនោះ ឈ្មោះថា មិនជាការពោលលាដោយពិត ព្រោះ ( ភិក្ខុឆ្កួតជាដើមនោះ ) មិនយល់ ។ ដែលពោលលាក្នុងសម្នាក់របស់ទេវតា ក៏មិនឈ្មោះថា ពោលលា ព្រោះ ( ទេវតា ) យល់រហ័សពន់ពេក ។ ឈ្មោះថា ទេវតា ដែលមានបដិសន្ធិជាត្រៃហេតុ មានបញ្ញាច្រើន រមែងដឹងអ្វីរហ័សពន់ពេក ។ ដែលឈ្មោះថា ចិត្តនេះ ជាធម្មជាតប្រព្រឹត្តទៅរហ័ស ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគដាក់ព្រះទ័យថា ការវិនាសរបស់បុគ្គល ( ភិក្ខុ ) ដែលមានចិត្តត្រឡប់កុំបីមានរហ័សពេក ព្រោះអំណាចចិត្តនោះឡើយ ទើបទ្រង់ហាមការលាសិក្ខាក្នុងសម្នាក់របស់ទេវតានោះ ។ ចំណែកក្នុងពួកមនុស្សមិនមានកំណត់ទុក សិក្ខាដែលភិក្ខុពោលលាក្នុងសម្នាក់របស់បុគ្គលណាមួយ ដែលជាសភាគៈគ្នា ( គឺបុរស ) ក៏ដោយ ដែលជាវិសភាគៈគ្នា ( គឺមាតុគ្រាម )

ក៏ដោយ ជាគ្រហស្ថក៏ដោយ ជាបព្វជិតក៏ដោយ ដែលយល់សេចក្តី ( បុគ្គលដឹងក្តី ) ឈ្មោះថា ជាការពោលលាដោយពិត ។ បើបុគ្គលនោះ មិនយល់សេចក្តីសោត សិក្ខា ក៏មិនមានឈ្មោះថា ពោលលាឡើយ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់ថា **អរិយកេន** ជាដើម ។ ក្នុងពាក្យថា **អរិយកេន** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា វោហាររបស់អ្នកអរិយៈ ឈ្មោះថា អរិយកៈ បានដល់ ភាសារបស់អ្នកមគធៈ ។ វោហារដែលមិនមែនរបស់អ្នកអរិយៈឯណានីមួយ ឈ្មោះថា មិលក្ខៈ បានដល់ វោហាររបស់អន្ធទមិឡ ( បុគ្គលខ្មៅជាដើម ) ។

ត្រើនបទថា **សោ ចេ ន បដិវិជានាតិ** សេចក្តីថា ( បើជនអ្នកមិលក្ខៈនោះ ) មិនយល់សេចក្តីថា ភិក្ខុនោះ ពោលអត្ថឈ្មោះនេះ ព្រោះភាពដែលខ្លួនមិនដឹងក្នុងភាសាដទៃ ឬព្រោះភាពដែលខ្លួនមិនឈ្លាសក្នុងពុទ្ធសម័យ សិក្ខា ឈ្មោះថា មិនពោលលាឡើយ ។

បទថា **ទវាយ** សេចក្តីថា ភិក្ខុមានបំណងនឹងនិយាយលេងយ៉ាងណាមួយដោយរហ័ស តែពោលទៅដោយរហ័សថា ខ្ញុំលាព្រះពុទ្ធ ដូច្នេះ ( ឈ្មោះថា ភិក្ខុពោលលាសិក្ខាដោយការពោលលេង ឬពោលរហ័ស ) ។

បទថា **រវាយ** ប្រែថា ដោយការពោលភ្លាត់ ។

បើមានអ្នកសួរ សួរថា ភិក្ខុគិតថា អញនឹងពោលយ៉ាងនេះ ដូច្នេះ តែទៅពោលយ៉ាងនោះ គឺពោលថា ខ្ញុំលាព្រះពុទ្ធ ដូច្នេះ ពាក្យសម្តីដែលពោលនេះ និងពាក្យដែលពោលមុន មានសេចក្តីប្លែកគ្នាដូចម្តេច ឆ្លើយថា សូម្បី

បុគ្គលឈ្លាសពោលពាក្យមុន ភ្លាត់ទៅពាក្យដទៃ ក៏ដោយអំណាចការរហ័ស តែបុគ្គលអ្នកពោលភ្លាត់ តាំងចិត្តថា អញនឹងពោលយ៉ាងនេះ តែទៅពោលយ៉ាងនោះ ព្រោះភាពដែលខ្លួនជាបុគ្គលអប្បបញ្ញា ជាបុគ្គលវង្វេង ។

ពីរបទថា **អសញ្ញាវេតុកាមោ សាវេតិ** សេចក្តីថា ភិក្ខុប្រាប់ សាកសួរសិក្សា ធ្វើការស្វាធ្យាយ ពណ៌នាបាលីនៃសិក្ខាបទនេះ ភិក្ខុនេះ ហៅថា បុគ្គលមិនមានបំណងនឹងប្រកាស តែប្រកាសឲ្យបានឮ ។

ច្រើនបទថា **សាវេតុកាមោ ន សាវេតិ** សេចក្តីថា ភិក្ខុដែលធ្វើឲ្យជាក់ច្បាស់នូវភាពជាអ្នកមានកម្លាំងខ្សោយ ហើយពោលលាសិក្ខា តែមិនបន្លឺវាចា ភិក្ខុនេះហៅថា អ្នកមានបំណងនឹងប្រកាស តែមិនប្រកាសឲ្យបានឮ ។

ពីរបទថា **អវិញ្ញុស្ស សាវេតិ** សេចក្តីថា ប្រកាសដល់មនុស្សជរា ដែលដូចជាបុគ្គលដូចគ្នានឹងរូបសិប្បនិមិត្ត ឬបុគ្គលអប្បបញ្ញា ដែលមិនឈ្លាសក្នុងលទ្ធិ ( សាសនា ) ឬពួកក្មេងអ្នកស្រុកដែលមិនទាន់ដឹងក្តី ។

ពីរបទថា **វិញ្ញុស្ស ន សាវេតិ** សេចក្តីថា មិនប្រកាសដល់អ្នកឈ្លាសដែលអាចយល់សេចក្តីបាន ។

ច្រើនបទថា **សព្វសោ វា បន** សេចក្តីថា សិក្ខា គឺពោលលាហើយដោយបរិយាយណា ក្នុងបណ្តាពាក្យថា **ពុទ្ធំ បច្ចក្ខាមិ** ជាដើម តែលោកមិនបានធ្វើបរិយាយណាមួយ អំពីបរិយាយនោះ គឺមិនបន្លឺវាចាប្រកាសឲ្យបានឮ ។ ព្រះដ៏មានព្រះភាគទ្រង់រមែងកំណត់លក្ខណៈនៃការមិនពោលលាទុកដោយពាក្យថា **ឯវំ ខោ** ។ ពិតហើយ ក្នុងពាក្យថា **ឯវំ ខោ** ជាដើមនេះ

អធិប្បាយដូច្នេះថា សិក្ខា ឈ្មោះថា ភិក្ខុមិនពោលលាដោយអាការយ៉ាងនេះឯង មិនមែនដោយអាការដទៃឡើយ ។

[ ៣៣ ] ឥឡូវនេះ ដើម្បីសម្ដែងអត្ថនៃបទថា **មេថុនំ ធម្មំ បដិសេវេយ្យ** ជាដើម ទើបព្រះដ៏មានព្រះភាគត្រាស់ថា **មេថុនធម្មោ នាម** ជាដើម ។ ក្នុងពាក្យថា **មេថុនធម្មោ នាម** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ពាក្យថា **មេថុនធម្មោ នាម** នេះ ជាបទឧទ្ទេសនៃមេថុនធម្ម ដែលគួរអធិប្បាយ ។

ធម៌របស់ពួកអសប្បុរសទាំងឡាយ គឺបុគ្គលថោកទាប ឈ្មោះថា អសទ្ធម្ម ។ ធម៌ជាទីសេពរបស់ពួកអ្នកស្រុក ឈ្មោះថា គាមធម៌ ។ ធម៌របស់បុគ្គលថោកថយ ឈ្មោះថា វសលធម៌ ។ម្យ៉ាងទៀត ធម៌ដែលថោកថយខ្លួនឯងនោះឯង ព្រោះជាទីហូរចេញនៃកិលេស ព្រោះដូច្នោះ ទើបឈ្មោះថា វសលធម៌ ។

បទថា **ទុដ្ឋុល្លំ** សេចក្ដីថា ឈ្មោះថាជាធម៌អាក្រក់ ព្រោះជាធម៌ដែលកិលេសទាំងឡាយប្រទូស្ដហើយ និងឈ្មោះថាជាធម៌គ្រោតគ្រាត ព្រោះជាធម៌មិនសុខុម ដូច្នោះ ទើបឈ្មោះថា ធម៌គ្រោតគ្រាត ។

ម្យ៉ាងទៀត តាំងអំពីនេះទៅ គប្បីផ្ទាស់ពីរបទថា **យោ សោ** នេះ ទៅជា **យន្តំ** ប្រកបក្នុង ៣ បទថា **យន្តំ ទុដ្ឋុល្លំ យន្តំ ឱទកន្តិកំ យន្តំ រហស្សំ**។ ដូច្នេះ គប្បីជ្រាបយោជនាក្នុងបទទាំង ៣ នេះ យ៉ាងនេះថា ការឃើញក្ដី ការចាប់ក្ដី ការស្ទាបអង្អែលក្ដី ការពាល់ត្រូវក្ដី ការត្រដុសក្ដី ដែលជាបរិវារ

របស់កម្មនោះ ចាត់ជាកម្មគ្រោតគ្រាត ព្រោះហេតុនោះ ទើបកម្មនោះ ចាត់ជាកម្មគ្រោតគ្រាត កម្មថោកទាបនោះ ឈ្មោះថា មេថុនធម្ម ទឹកដែលបុគ្គលរមែងកាន់យកដើម្បីសម្អាតក្នុងទីបំផុតនៃកម្មនោះ ហេតុនោះ ទើបកម្មនោះ ឈ្មោះថា មានទឹកជាទីបំផុត កម្មមានទឹកជាទីបំផុតនោះឯង ឈ្មោះថា **ឧទក-កន្តិក** កម្មមានទឹកជាទីបំផុតនោះ ឈ្មោះថា មេថុនធម្ម កម្មនោះ ឈ្មោះថា កម្មកំបាំង ព្រោះភាពជាកម្មដែលត្រូវធ្វើក្នុងទីស្ងាត់ គឺក្នុងឱកាសដែលបិទបាំង កម្មនោះ ឈ្មោះថា មេថុនធម្ម ។

កម្មនោះ ដែលបុគ្គលជាគូៗ គប្បីដល់រួមគ្នា ព្រោះភាពជាកម្មដែលបុគ្គលគប្បីរួមគ្នាជាគូៗ ។ ក្នុងបទថា **ទ្វយទ្វយសមាបត្តិ** នោះ គប្បីជ្រាបយោជនាថា កម្មដែលមនុស្សជាគូៗ គប្បីដល់រួមគ្នា ឈ្មោះថា មេថុនធម្ម ។ ឯក្នុងអធិការនេះ ព្រះដ៏មានព្រះភាគទ្រង់ទាញយកធម៌ទាំងពួង មានអសទ្ធម្មជាដើមនោះ មករួមក្នុងទីតែមួយ ទើបត្រាស់ថា នេះឈ្មោះថា មេថុនធម្ម ។

សួរថា ព្រោះហេតុអ្វី ទើបអសទ្ធម្ម ហៅថា មេថុនធម្ម ឆ្លើយថា អសទ្ធម្មនោះ ជារបស់មនុស្សពីរនាក់ដែលមានតម្រេកហើយ បុគ្គលមានតម្រេកខ្លាំងហើយ បុគ្គលដែលរាគៈជ្រៀមចិត្តហើយ គឺបុគ្គលដែលរាគៈចោមរោមហើយ បានដល់ ជាធម៌របស់មនុស្សគូគ្នា ព្រោះហេតុនោះ ទើបហៅថា មេថុនធម្ម ។

[ ៣៤ ] បទថា **បដិសេវតិ ណាម** នេះ ជាបទមាតិកា ដើម្បីសម្តែងអាការជាហេតុដែលទ្រង់ត្រាស់ហៅបុគ្គលថា គប្បីសេពចំពោះ ក្នុងបទថា

**បដិសេវេយ្យ** *នេះ ។*

*ក្នុងបទថា* **យោ និមិត្តេន និមិត្តំ** *ជាដើម មានវិនិច្ឆ័យដូច្នេះថា ភិក្ខុណាឲ្យនិមិត្តរបស់ខ្លួនចូលទៅក្នុងនិមិត្តរបស់ស្ត្រី គឺឲ្យអង្គជាតខ្លួន ចូលទៅក្នុងអង្គជាតស្រី ក្នុងឱកាសដែលសើម ដែលខ្យល់ពាល់ត្រូវមិនបាន ដោយហោចសូម្បីត្រឹមមួយគ្រាប់ល្ង ភិក្ខុនោះឈ្មោះថា រមែងសេពចំពោះ ដោយអាការត្រឹមប៉ុណ្ណេះ លោករមែងដល់នូវការបែកធ្លាយនៃសីល គឺត្រូវអាបត្តិបារាជិក ។*

## ឥត្ថីនិមិត្តមានឋាន ៥ បុរិសនិមិត្តមានឋាន ៦

*បណ្តានិមិត្តស្ត្រី និងបុរសនេះ ក្នុងនិមិត្តរបស់ស្ត្រីមានស្ថាន ៥ គឺខាងៗ ទាំង ៤ និងត្រង់កណ្តាល ១ ។ ក្នុងនិមិត្តរបស់បុរសមានស្ថាន ៦ គឺខាងៗ ទាំង ៤ កណ្តាល ១ ចុង ១ ។ ព្រោះហេតុនោះ ក្នុងនិមិត្តរបស់ស្ត្រី សូម្បីស៊កអង្គជាតចូលទៅតាមផ្លូវក្រោម រមែងត្រូវអាបត្តិបារាជិក ស៊កទៅផ្នែកខាងលើក្តី ស៊កទៅផ្នែកចំហៀងទាំងពីរក្តី ស៊កទៅត្រង់កណ្តាលផុតស្ថានទាំង ៤ ក្តី រមែងត្រូវអាបត្តិបារាជិក ( ទាំងអស់ ) ចំណែកនិមិត្តនៃបុរស សូម្បីភិក្ខុស៊កចូលទៅឲ្យត្រូវចំណែកខាងក្រោម រមែងត្រូវអាបត្តិបារាជិក ស៊កចូលទៅឲ្យត្រូវផ្នែកខាងលើក្តី ស៊កចូលទៅឲ្យត្រូវផ្នែកទាំងសងខាងក្តី ស៊កចូលទៅឲ្យត្រូវចំពោះត្រង់កណ្តាល ( បត់អង្គជាត ) ដូចឲ្យម្រាមដៃដែលបត់ចូលហើយ រុកចូលដោយខ្នងកណ្តាលក្តី ស៊កចូលទៅឲ្យត្រូវផ្នែកខាងលើក្តី រមែងត្រូវអាបត្តិបារាជិក ( ទាំងអស់ ) ។*

បណ្ដានិមិត្តបុរស និងស្ត្រីនោះ សូម្បីកាលភិក្ខុស៊កអង្គជាតចូលទៅឲ្យដូចនឹងដងជញ្ជីង មានស្ថាន ៥ គឺខាងៗ ទាំង ៤ និងត្រង់កណ្ដាល ១ ។ សូម្បីកាលបត់អង្គជាតស៊កចូលទៅក៏មានស្ថាន ៥ គឺខាងៗ ទាំង ៤ ចំណែកខាង ចុងត្រង់កណ្ដាល ១ ។ ស្ថានទាំងអស់ក្នុងនិមិត្តរបស់បុរសមាន ១០ ដោយប្រការដូច្នេះ ។

ភិក្ខុស៊កសាច់ដែលដុះ ដែលមានកាយបសាទនៅល្អ ដែលកើតនៅក្នុងនិមិត្ត ( របស់ខ្លួន ) ចូលទៅ ( ក្នុងនិមិត្តរបស់ស្ត្រី ) ត្រូវអាបត្តិបារាជិក ស៊កសាច់ដែលដុះ ដែលមិនមានកាយបសាទ ឬសាច់ដែលស្លួត ដែលមានកាយបសាទខូចហើយចូលទៅ ( ក្នុងនិមិត្តរបស់ស្ត្រី ) ត្រូវអាបត្តិទុក្កដ ។ សូម្បីស៊ករោម ឬចុងម្រាមដៃ និងម្រាមមេដៃចូលទៅ ( ក្នុងនិមិត្តរបស់ស្ត្រី ) ដោយសេចក្ដីត្រេកអរក្នុងមេថុន ត្រូវអាបត្តិទុក្កដដូចគ្នា ។

## ភិក្ខុកាលពណ៌នាមេថុនកថា គួររឭកដល់ពុទ្ធគុណ

ដែលបានឈ្មោះថា មេថុនកថានេះ គឺកថាដែលគ្រោតគ្រាត ដែលជាកថារបស់ពួកអសប្បុរស ព្រោះដូច្នោះ ភិក្ខុកាលនឹងពោលដល់ស្ថាននោះក្ដី ស្ថានដទៃក្ដី ឬស្ថានដូច្នេះក្នុងព្រះវិន័យ ក៏គួរឲ្យបដិកូលមនសិការ សមណសញ្ញា និងហិរិឱត្តប្បៈតាំងឡើងចំពោះមុខ ហើយឲ្យការគោរពកើតឡើងក្នុងព្រះសម្មាសម្ពុទ្ធ នឹករំពឹងដល់ព្រះករុណាគុណរបស់ព្រះលោកនាថ ដែលមានព្រះករុណា មិនមានបុគ្គលស្មើ ហើយពោលចុះ ។ គួរនឹករំពឹងដល់ព្រះករុណាគុណរបស់ព្រះលោកនាថយ៉ាងនេះថា ពិតហើយ ព្រះដ៏មានព្រះភាគ

អង្គនោះ មានព្រះទ័យវិលត្រឡប់ហើយចាកកាមទាំងឡាយ ដោយប្រការទាំងពួង ទ្រង់អាស្រ័យសេចក្ដីករុណាក្នុងសត្វទាំងឡាយ ដើម្បីអាណិតអាសូរពួកសត្វ ដើម្បីសេចក្ដីអនុគ្រោះដល់សត្វ បានត្រាស់កថាដូច្នេះទុក ដើម្បីការបញ្ញត្តសិក្ខាបទ ព្រះសាស្ដាមានព្រះករុណាគុណពិតហ្ន៎ ដូច្នេះហើយ គប្បីពោលចុះ ម្យ៉ាងទៀត បើព្រះដ៏មានព្រះភាគមិនគប្បីត្រាស់កថាដូច្នេះ ដោយប្រការទាំងពួងសោត បុគ្គលណាហ្ន៎ គប្បីដឹងបានថា ក្នុងស្ថានប្រមាណប៉ុណ្ណោះត្រូវអាបត្តិបារាជិក ក្នុងស្ថានប្រមាណប៉ុណ្ណោះ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងស្ថានប្រមាណប៉ុណ្ណោះ ត្រូវអាបត្តិទុក្កដ ។ ព្រោះហេតុនោះ ភិក្ខុអ្នកពោលអត្ថ កំពុងស្ដាប់ក្ដី កំពុងពោលក្ដី ( នូវមេថុនកថានោះ ) មិនគួរបើកមាត់អង្គុយសើចលេងឡើយ គួរពិចារណាថា សូម្បីស្ថានដូច្នេះ ព្រះសម្ពុទ្ធក៏បានត្រាស់ហើយ ដូច្នេះ ជាអ្នកមិនខ្មាច ព្រោះហេតុដូច្នោះ ដល់ព្រមដោយហិរិ និងឱត្តប្បៈ មានចំណែកប្រៀបដូចព្រះសាស្ដា ហើយគប្បីពោលដូច្នេះឯង ។

មូលប្បញ្ញត្តិសិក្ខាបទ ចប់

# អនុប្បញ្ញត្តិវារៈ

## កំណាត់សត្វដែលជាវត្ថុនៃបារាជិកជាដើម

[ ៣៩ ] ក្នុងវារៈនៃអនុប្បញ្ញត្តិ មានវិនិច្ឆ័យដូច្នេះថា បទថា **អន្តមសោ** ប្រែថា ដោយហោច គឺដោយកំណត់យ៉ាងទាបបំផុត ។

បទថា **តិរច្ឆានគតាយបិ** សេចក្តីថា ក្នុងប្រជាសត្វដែលទៅហើយ ( គឺដែលកើតហើយ ) ក្នុងពួកសត្វតិរច្ឆាន ដោយអំណាចបដិសន្ធិ ។

ពីរបទថា **បគេវ មនុស្សិត្ថិយា** សេចក្តីថា ( ភិក្ខុសេពមេថុនធម្ម ) ក្នុងស្រីដែលជាជាតិមនុស្សមុនដំបូង ។ ឯតិរច្ឆានញីដែលជាវត្ថុបារាជិកនោះឯង គួរកាន់យកថា សត្វតិរច្ឆានក្នុងបឋមបារាជិកនេះ មិនមែនសត្វតិរច្ឆានញីទាំងអស់ ( សត្វតិរច្ឆានញី មិនមែនសុទ្ធតែវត្ថុនៃបារាជិកទាំងអស់ទេ ) ក្នុងពាក្យថា សត្វតិរច្ឆាននោះ មានកំណត់ ( ប្រភេទសត្វ ) ដូច្នេះថា

បណ្តាពួកសត្វអត់ជើង បានដល់ ពស់ និងត្រី បណ្តាពួកសត្វ
មានជើងពីរ បានដល់ មាន់ញី បណ្តាពួកសត្វមានជើង ៤
បានដល់ ឆ្មាញី សត្វតិរច្ឆានញីទាំងនេះ ជាវត្ថុនៃបារាជិក ។

## អធិប្បាយ ប្រភេទសត្វផ្សេងៗ

បណ្តាសត្វ មានពស់ជាដើមនេះ ទីឃជាតិ រាប់ដោយប្រភេទ មានពស់ថ្លាន់ និងពស់ត្បាល់[១] ជាដើមទាំងអស់ លោកសង្គ្រោះចូលដោយ **អហិ** សពូ ។ ព្រោះដូច្នោះ បណ្តាទីឃជាតិទាំងឡាយ ទីឃជាតិដែលភិក្ខុអាច

---

១- ពាក្យថា គោនសា ទីខ្វះប្រែថា ពស់វែករនាម ។

ស៊កអង្គជាតចូលទៅក្នុងបណ្ដាមគ្គទាំង ៣ មគ្គណាទីមួយ ប្រមាណប៉ុនគ្រាប់ល្ង ជាវត្ថុនៃបារាជិក ពាក្យដ៏សេសគប្បីជ្រាបថា ជាវត្ថុនៃទុក្កដ ។ សត្វដែលកើតក្នុងទឹក រាប់ដោយប្រភេទ មានត្រី អណ្តើក និងកង្កែបទាំងអស់ជាដើម លោកសង្គ្រោះចូលដោយ **មច្ឆ** សព្ទ ។ ក្នុងសត្វដែលកើតក្នុងទឹកនោះ គប្បីជ្រាបថា ជាវត្ថុនៃបារាជិក និងជាវត្ថុនៃទុក្កដ ដោយន័យដូចពោលរួចហើយក្នុងទីឃជាតិនោះឯង ។ ចំណែកសេចក្ដីដែលប្លែកគ្នា មានដូច្នេះថា ដែលឈ្មោះថា កង្កែប ជាសត្វមានមាត់រីង កង្កែបទាំងនោះមានសណ្ឋានមាត់ទូលាយ តែមានប្រហោងមាត់ចង្អៀត ក្នុងសណ្ឋានមាត់នោះ ទើបមិនល្មមដែលនឹងស៊កអង្គជាតចូលទៅបាន តែសណ្ឋានមាត់ រមែងដល់នូវការរាប់ថាជាមុខដំបៅ ព្រោះដូច្នោះ គប្បីជ្រាបមុខសណ្ឋាន ( មាត់ ) នោះថា ជាវត្ថុនៃថុល្លច្ច័យ ។

បក្សីជាតិ រាប់ដោយប្រភេទ មានក្អែក និងសារិកាជាដើមទាំងអស់ លោកសង្គ្រោះចូលដោយ **កុក្កុដី** សព្ទ ។ ក្នុងបក្សីជាតិនោះ គប្បីជ្រាបថា ជាវត្ថុបារាជិក និងវត្ថុនៃទុក្កដ ដោយន័យដូចពោលមកហើយនោះឯង ។

ចតុប្បាទជាតិ រាប់ដោយប្រភេទ មានកង្ហែន ស្ការ និងទន្សងជាដើមទាំងអស់ លោកសង្គ្រោះចូលដោយ **មជ្ជារី** សព្ទ ។ ក្នុងចតុប្បាទជាតិនោះ គប្បីជ្រាបថា ជាវត្ថុនៃបារាជិក និងវត្ថុនៃទុក្កដ ដោយន័យដូចពោលមកហើយនោះឯង ។

# **បារាជិក សព្ទ ក្នុងសិក្ខាបទជាដើម**

[ ៣៦ ] *បទថា* **បារាជិកោ** *ប្រែថា ចាលចាញ់ហើយ គឺដល់ហើយនូវការចាលចាញ់ ។ ពិតហើយ* **បារាជិក** *សព្ទនេះ រមែងប្រព្រឹត្តទៅទាំងក្នុងសិក្ខាបទផង អាបត្តិផង បុគ្គលផង ។ ក្នុង ៣ យ៉ាងនោះ* **បារាជិក** *សព្ទ ដែលប្រព្រឹត្តទៅក្នុងសិក្ខាបទ គប្បីជ្រាប ( ក្នុងទីមក ) យ៉ាងនេះថា* **អដ្ឋានមេតំ អានន្ទ អនវកាសោ យំ តថាគតោ វជ្ជីនំ វា វជ្ជិបុត្តកានំ វា ការណា សាវកានំ បារាជិកំ សិក្ខាបទំ បញ្ញត្តំ សមូហនេយ្យ** *ម្នាលអានន្ទ តថាគតគប្បីដកសិក្ខាបទឈ្មោះបារាជិក ដែលតថាគតបានបញ្ញត្តហើយ ដល់សាវកទាំងឡាយ ព្រោះហេតុនៃជន អ្នកនៅក្នុងដែនវជ្ជីទាំង-ឡាយក្តី ព្រោះហេតុនៃវជ្ជីបុត្តភិក្ខុទាំងឡាយក្តី ដោយអំពើណា អំពើនុ៎ះ មិនមែនជាហេតុ មិនមែនជាឱកាសឡើយ ។*

*ដែលប្រព្រឹត្តទៅក្នុងអាបត្តិ គប្បីជ្រាប ( ក្នុងទីមក ) យ៉ាងនេះថា* **អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកំ** *ម្នាលភិក្ខុទាំងឡាយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ ដែលប្រព្រឹត្តទៅ ក្នុងបុគ្គល គប្បីជ្រាបយ៉ាងនេះថា* **ន មយំ បារាជិកា យោ អវហដោ សោ បារាជិកោ** *ពួកយើងមិនបានត្រូវអាបត្តិបារាជិក បុគ្គលណាលួច បុគ្គលនោះត្រូវអាបត្តិបារាជិក ។ តែអាចារ្យពួកខ្លះពោលថា* **បារាជិក** *សព្ទនេះ គង់ប្រព្រឹត្តទៅក្នុងធម៌បានទៀត ដូចក្នុងទីមក មានពាក្យថា* **បារាជិកេន ធម្មេន អនុទ្ធំសេយ្យ** *( ភិក្ខុ ) ចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិក ដូច្នេះជាដើម ។*

*តែព្រោះក្នុងអាបត្តិ និងសិក្ខាបទទាំង ២ នោះ ក្នុងទីខ្លះ ព្រះដ៏មាន*

ព្រះភាគទ្រង់បំណងយកអាបត្តិ ថាធម៌ កន្លែងខ្លះ ទ្រង់បំណងយកសិក្ខាបទ នោះឯង ព្រោះដូច្នោះ ទើបមិនគួរពោលធម៌នោះទុកមួយផ្នែកទៀតឡើយ ។

បណ្ដាសិក្ខាបទ អាបត្តិ និងបុគ្គលនោះ សិក្ខាបទ ព្រះដ៏មានព្រះភាគ ត្រាស់ថា បារាជិក ព្រោះញុំាងបុគ្គលដែលកន្លងល្មើសឲ្យចាលចាញ់ ចំណែក អាបត្តិ ទ្រង់ត្រាស់ថា បារាជិក ព្រោះញុំាងបុគ្គលដែលត្រូវឲ្យចាលចាញ់ បុគ្គលទ្រង់ត្រាស់ថា ជាបារាជិក ព្រោះជាអ្នកចាលចាញ់ គឺដល់នូវការ ចាញ់ ។ ពិតហើយ សូម្បីក្នុងគម្ពីរបរិវារ ព្រះដ៏មានព្រះភាគក៏សំដៅយក ចំពោះសេចក្ដីនេះ ដោយត្រាស់ថា

> អាបត្តិណា ដែលតថាគតហៅថា បារាជិក ចូរអ្នកប្រុង
> ស្ដាប់សិក្ខាបទនោះ ដូចសម្ដែងតទៅនេះ ។ បុគ្គលដែល
> ឃ្លាតខុសភ្លាត់របូត ចាកព្រះសទ្ធម្មទាំងឡាយហើយ
> សង្វាស មិនមានក្នុងបុគ្គលនោះឡើយ ព្រោះហេតុនោះ
> អាបត្តិនោះ តថាគត ហៅថា បារាជិក ។

ក្នុងបរិវារគាថានេះ មានអត្ថដូច្នេះថា បុគ្គលកន្លងល្មើសសិក្ខាបទនោះ ក្ដី ត្រូវអាបត្តិនោះក្ដី រមែងជាអ្នកឃ្លាត ( ចាកព្រះសទ្ធម្ម ) ពាក្យទាំងពួង បណ្ឌិតគប្បីប្រកបយ៉ាងនេះ ។

ពីរបទថា **តេន វុច្ចតិ** សេចក្ដីថា បុគ្គល រមែងមិនមែនជាសមណៈ មិនមែនជាពូជពង្សនៃសក្យបុត្រ ភ្លាត់ធ្លាក់ទៅ ដាច់ទៅ គឺចាលចាញ់ចាក សាសនា ដោយហេតុណា ហេតុនោះ ទើបបុគ្គលនោះ តថាគតពោល ។

សួរថា ពោលដូចម្តេច ឆ្លើយថា ពោលថា ជាអ្នកចាលចាញ់ ។

[ ៣៧ ] ភិក្ខុទាំងឡាយ រមែងនៅរួមគ្នាក្នុងធម៌នេះ ហេតុនោះ ទើបធម៌នេះ ឈ្មោះថា សង្វាស ។ ព្រះដ៏មានព្រះភាគត្រាស់ថា **សំវាសោ នាម** ដូច្នេះហើយ ទើបត្រាស់ពាក្យជាដើមថា **ឯកកម្មំ** ក៏ដើម្បីសម្តែងសង្វាសនោះ ។

ក្នុងពាក្យថា **ឯកកម្មំ** ជាដើមនោះ មានពាក្យអធិប្បាយ ព្រមទាំងយោជនាដូច្នេះថា សង្ឃកម្ម ៤ យ៉ាង ឈ្មោះថា កម្មដូចគ្នា ព្រោះជាកម្មដែលភិក្ខុទាំងឡាយជាបកតត្ត កំណត់ដោយសីមា នឹងគប្បីធ្វើរួមគ្នា ។ មួយ៉ាងទៀត បាតិមោក្ខុទ្ទេសទាំង ៥ យ៉ាង ឈ្មោះថា ឧទ្ទេសតែ ១ ព្រោះជាឧទ្ទេសដែលគប្បីសូធ្យជាមួយគ្នា ។ ចំណែកសិក្ខាបទដែលទ្រង់បញ្ញត្តហើយ ឈ្មោះថា **សមសិក្ខាតា** ព្រោះជាសិក្ខាដែលលជ្ជីបុគ្គលទាំងពួង គប្បីសិក្សាស្មើគ្នា ។ លជ្ជីបុគ្គលទាំងពួង រមែងនៅរួមគ្នាក្នុងកម្មជាដើមទាំងនេះ បុគ្គលសូម្បីម្នាក់ឯង នឹងប្រាកដខាងក្រៅកម្មជាដើមនោះក៏ទេ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់រួមយកវត្ថុទាំងអស់នោះ ត្រាស់ថា នេះឈ្មោះថា សង្វាស ក្នុងព្រះបាលីនេះ ។ ឯសង្វាស មានប្រការដូចពោលហើយនោះ មិនមានដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបបុគ្គលដែលចាលចាញ់ ទ្រង់ត្រាស់ថា ជាបុគ្គលមិនមានសង្វាស ដូច្នេះឯង ។

សិក្ខាបទវិភង្គនៃបឋមបារាជិក ចប់

# អធិប្បាយ

## បទភាជនីយនៃបឋមបារាជិក

[ ៣៨ ] ព្រះដ៏មានព្រះភាគ កាលទ្រង់ចែកសិក្ខាបទដែលទ្រង់ឧទ្ទេស យ៉ាងនោះ តាមលំដាប់បទហើយ ឥឡូវនេះ ទើបទ្រង់សម្តែងសត្វទាំងឡាយ ដែលមាននិមិត្តជាវត្ថុនៃបារាជិក ដោយន័យ មានពាក្យថា ស្រី ៣ ជំពូកជាដើម ហើយត្រាស់វត្ថុ ៣ ដោយន័យ មានពាក្យថា មគ្គ ៣ នៃស្រីមនុស្សជាដើម ដើម្បីសម្តែងនិមិត្តដែលជាវត្ថុនៃបារាជិក ព្រោះនិមិត្តស្រីតែម្យ៉ាងប៉ុណ្ណោះ ទើបជាវត្ថុនៃបារាជិកក៏មិនមែន និមិត្តស្រីមនុស្សប៉ុណ្ណោះ ទើបជាវត្ថុក៏មិនមែន ទាំងនិមិត្តនៃស្រីទាំងឡាយ ដែលគាក់តែងដោយមាស និងប្រាក់ជាដើម ទើបជាវត្ថុក៏មិនមែន ក្នុងពាក្យថា **និមិត្តេន និមិត្តំ អង្គជាតេន អង្គជាតំ** ដែលព្រះអង្គ ទ្រង់តាំងបទមាតិកានេះថា **បដិសេវតិ នាម** ដើម្បីសម្តែងអាការជាហេតុ ត្រាស់ថា គប្បីសេពចំពោះ ក្នុងបទថា **បដិសេវេយ្យ** នេះ ត្រាស់ទុកហើយ ។

ក្នុងពាក្យថា ស្រី ៣ ជំពូកជាដើមនោះ មានសត្វ ១២ ជំពូក ដែលជាទីអាស្រ័យនៃនិមិត្ត ជាវត្ថុនៃបារាជិក គឺ ស្ត្រី៣ពួក ឧភតោព្យញ្ជនកៈ៣ពួក ខ្ទើយ៣ពួក បុរស៣ពួក ក្នុងសត្វ ១២ ពួកនោះ ស្ត្រី និងបុរសប្រាកដច្បាស់ហើយ ។ ប្រភេទរបស់ខ្ទើយ និងឧភតោព្យញ្ជនកៈ នឹងមានប្រាកដក្នុងវណ្ណនានៃបព្វជ្ជាខន្ធកៈ ។ ចំណែកក្នុងពាក្យថា អ្នកសេពមេថុនធម្មចំពោះមគ្គ ៣ នៃស្រីមនុស្សនេះ គប្បីជ្រាបអត្ថថា ក្នុងមគ្គ ៣ នៃស្រីមនុស្ស ។ គប្បីជ្រាបយ៉ាងនេះគ្រប់ៗ បទចុះ ។

## ទ្វារមគ្គ ៣០

មគ្គទាំងអស់នោះ មានចំនួន ៣០ គឺមគ្គស្រីមនុស្ស ៣ ស្រីអមនុស្ស ៣ តិរច្ឆានញី ៣ រួមជា ៩ មគ្គរបស់មនុស្សឧភតោព្យញ្ជនកៈជាដើមមាន ៩ របស់មនុស្សខ្ទើយជាដើមមាន ៦ ព្រោះមួយពួកៗ មាន ២ មគ្គ របស់មនុស្សប្រុសជាដើមមាន ៦ ដូចគ្នា ។ ភិក្ខុកាលសេពមេថុនធម្ម ស៊កអង្គជាតរបស់ខ្លួនចូលទៅក្នុងបណ្តាមគ្គ ដែលតែងស្គាល់ថា ជានិមិត្តទាំងនោះក្នុងមគ្គឯណានីមួយ សូម្បីត្រឹមមួយគ្រាប់ល្ង រមែងត្រូវអាបត្តិបារាជិក តែកាលនឹងត្រូវ រមែងត្រូវដោយសេវនចិត្តប៉ុណ្ណោះ វៀរចាកសេវនចិត្ត មិនត្រូវឡើយ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងលក្ខណៈនោះ ទើបត្រាស់ថា **ភិក្ខុស្ស សេវនចិត្តំ ឧបដ្ឋិតេ** ដូច្នេះជាដើម ។

## ពណ៌នា បឋមចតុក្កៈ

[ ៣៩ ] បណ្តាបទទាំងនោះ បទថា **ភិក្ខុស្ស** បានដល់ ភិក្ខុអ្នកសេពមេថុនធម្ម ។ ក្នុងពាក្យថា **សេវនចិត្តំ ឧបដ្ឋិតេ** នេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថសត្តមីវិភត្តិ អធិប្បាយថា កាលសេវនចិត្តប្រាកដហើយ ។

ច្រើនបទថា **វច្ចមគ្គំ អង្គជាតំ បវេសេន្តស្ស** សេចក្តីថា កាលភិក្ខុស៊កអង្គជាត គឺបុរិសនិមិត្តរបស់ខ្លួនចូលទៅក្នុងវច្ចមគ្គនោះ សូម្បីត្រឹមមួយគ្រាប់ល្ង ។

ពីរបទថា **អាបត្តិ ធារាជិកស្ស** សេចក្តីថា អាបត្តិបារាជិក រមែងមានដល់ភិក្ខុនោះ ។ម្យ៉ាងទៀត បទថា **អាបត្តិ** ប្រែថា រមែងមានការត្រូវ ។

បទថា **ធារាជិកស្ស** បានដល់ ធម៌ គឺបារាជិក ។ ក្នុងគ្រប់ៗ បទ ក៏

មានន័យដូច្នេះឯង ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងអាបត្តិរបស់ភិក្ខុដែលស៊ក ( អង្គជាតរបស់ខ្លួន ) ចូលទៅដោយសេវនចិត្តតែម្យ៉ាងប៉ុណ្ណោះហើយ ឥឡូវនេះ ដើម្បីទ្រង់រក្សាពួកកុលបុត្រដែលបួសដោយសទ្ធា ជាអ្នកបដិបត្តិប្រពៃ មិនត្រេកអរសូម្បីក្នុងកាល មានការស៊កចូលទៅដោយសេចក្តីព្យាយាមរបស់អ្នកដទៃ ព្រោះឈ្មោះថាការស៊ក ( អង្គជាត ) ចូលទៅនោះ មិនមែនមានដោយការព្យាយាមរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះទេ រមែងមានដោយការព្យាយាមរបស់អ្នកដទៃផងដែរ ហើយកាលភិក្ខុត្រេកអរក្នុងការស៊កចូលទៅ ដោយសេចក្តីព្យាយាមរបស់អ្នកដទៃនោះ ក៏ត្រូវអាបត្តិ គឺកាលភិក្ខុមានការដល់ព្រមដោយបដិសេវនចិត្ត ក៏ត្រូវអាបត្តិ ក្រៅអំពីនេះ មិនត្រូវអាបត្តិ ទើបត្រាស់ថា **ភិក្ខុបច្ចត្ថិកា មនុស្សិត្ថឹ** ជាដើម ។

[ ៤០ ] ក្នុងពាក្យថា **បច្ចត្ថិកា** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ពួកជនដែលឈ្មោះថា ជាសត្រូវ ព្រោះអត្ថថា ត្រូវការ គឺប្រាថ្នាជាបដិបក្ខ ។ សត្រូវទាំងឡាយ គឺពួកភិក្ខុ ឈ្មោះថា **ភិក្ខុបច្ចត្ថិកា** ( ភិក្ខុជាសត្រូវ ) ។ ពាក្យថា **ភិក្ខុបច្ចត្ថិកា** នោះ ជាឈ្មោះរបស់ពួកភិក្ខុ ជាអ្នកចងពៀរ ដែលជាវិសភាគៈគ្នា ។

ច្រើនបទថា **មនុស្សិត្ថឹ ភិក្ខុស្ស សន្តិកេ អានេត្វា** សេចក្តីថា ពួកភិក្ខុមានការប្រណែន ប្រាថ្នានឹងធ្វើឲ្យភិក្ខុនោះវិនាស យកអាមិសលួងលោម ឬនិយាយដោយអំណាចមិត្តសន្ថវៈថា អ្នកចូរធ្វើកិច្ចនេះរបស់ពួកយើងចុះ

ហើយនាំយកស្រីមនុស្សខ្លះ មកកាន់ឱកាសដែលជាលំនៅរបស់ភិក្ខុនោះ ក្នុងពេលរាត្រី ។

ប្រើនបទថា **វច្ចមគ្គេន អង្គជាតំ អភិនិសីទេន្តិ** សេចក្តីថា ចាប់ភិក្ខុនោះត្រង់អវយវៈ មានដៃ ជើង និងក្បាលជាដើមយ៉ាងនោះ គឺមិនឲ្យរើបាន ហើយឲ្យអង្គុយសង្កត់ គឺឲ្យប្រកបអង្គជាតរបស់ភិក្ខុអង្គនោះ ដោយវច្ចមគ្គរបស់ស្ត្រី ។

ពាក្យថា **សោ ចេ** ជាដើម មានវិនិច្ឆ័យដូច្នេះថា បើភិក្ខុអង្គនោះត្រេកអរ គឺព្រមទទួលការសើកអង្គជាតរបស់ខ្លួនចូលទៅក្នុងវច្ចមគ្គ ( របស់ស្រី ) គឺលោកឲ្យសេវនចិត្តប្រាកដឡើងក្នុងខណៈនោះ ត្រេកអរ គឺព្រមទទួលការចូលទៅហើយ ។ ក្នុងវេលាដែលចូលទៅហើយ លោកក៏ឲ្យសេវនចិត្ត ប្រាកដឡើងក្នុងខណៈនោះ ត្រេកអរ គឺព្រមទទួលការចូលទៅស៊ប់ ។ ក្នុងវេលាដែលអង្គជាតដល់ទី លោកក៏ឲ្យសេវនចិត្តប្រាកដឡើងក្នុងខណៈនោះ ក្នុងវេលាដែលហូរទឹកសុក្ក ត្រេកអរ គឺព្រមទទួលការស្ថិតនៅ ។ ក្នុងវេលាដែលទាញចេញ លោកក៏ឲ្យបដិសេវនចិត្ត ប្រាកដឡើងក្នុងខណៈនោះ ត្រេកអរ គឺព្រមទទួលការដកចេញ ។ ភិក្ខុកាលត្រេកអរក្នុងស្ថាន ៤ យ៉ាងដូចអធិប្បាយមកហើយនេះ រមែងមិនបានដើម្បីនឹងពោល ( កែខ្លួន ) ថា សមណៈអ្នកចងពៀរទាំងឡាយ ធ្វើកម្មនេះដល់ខ្ញុំហើយ រមែងត្រូវអាបត្តិបារាជិកនោះឯង ។ ភិក្ខុ កាលត្រេកអរក្នុងស្ថាន ៤ នេះ រមែងត្រូវអាបត្តិយ៉ាងណា ភិក្ខុមិនត្រេកអរ ក្នុងស្ថាន ១ ដំបូង តែត្រេកអរក្នុងស្ថាន ៣ ក្តី

មិនត្រេកអរក្នុងស្ថាន ២ តែត្រេកអរក្នុងស្ថាន ២ ក្តី មិនត្រេកអរក្នុងស្ថាន ៣ តែត្រេកអរក្នុងស្ថាន ១ ក្តី រមែងត្រូវអាបត្តិដូចគ្នា ដូច្នោះ ។

ចំណែកភិក្ខុកាលមិនត្រេកអរដោយប្រការទាំងពួង សម្គាល់អង្គជាត ដូចចូលទៅកាន់មាត់អាសិរពិស ឬចូលទៅត្រង់គំនររងើកភ្លើង មិនត្រូវអាបត្តិឡើយ ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ភិក្ខុមិនត្រេកអរក្នុងការចូលទៅ មិនត្រេកអរក្នុងការចូលស៊ប់ មិនត្រេកអរក្នុងការស្ថិតនៅ មិនត្រេកអរក្នុងការដកចេញ មិនត្រូវអាបត្តិ ។

ពិតហើយ ព្រះដ៏មានព្រះភាគ កាលទ្រង់រក្សាបុគ្គលដែលចម្រើនវិបស្សនា មានសភាពបែបនេះ មិនមានការជាប់ជំពាក់ក្នុងកាយ និងជីវិត សម្លឹងឃើញអាយតនៈទាំងពួង ដូចត្រូវភ្លើង ១១ កង ឲ្យឆេះសន្ធោសន្ធៅហើយ ទាំងសម្លឹងឃើញបញ្ចកាមគុណ ដូចពេជ្ឈឃាតឯដាវឡើងហើយ ដូច្នោះ ។ ហើយកាលទ្រង់ធ្វើការកម្ចាត់មនោរថនៃបុគ្គលដែលជាសត្រូវនៃបុគ្គលមិនត្រេកអរនោះ ទើបទ្រង់នាំចតុក្កៈយ៉ាងនេះថា ភិក្ខុមិនត្រេកអរក្នុងការចូលទៅជាដើមនេះមកតាំងទុក ដូច្នេះឯង ។

បឋមចតុក្កៈ ចប់

# អធិប្បាយ ចតុក្កៈ ២៦៩ ដ៏សេស

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងបឋមចតុក្កៈយ៉ាងនោះហើយ ឥឡូវនេះ កាលទ្រង់សម្តែងចតុក្កៈដទៃ ដោយអំណាចមគ្គទាំង ៣ នោះ ព្រោះ ភិក្ខុដែលជាសត្រូវនាំស្រីមកហើយ ឲ្យអង្គុយសង្កត់ដោយវច្ចមគ្គតែម្យ៉ាងប៉ុណ្ណោះក៏ទេ ដោយពិតនោះ ឲ្យអង្គុយសង្កត់ដោយទ្វារបស្សាវមគ្គខ្លះ ដោយមុខមគ្គខ្លះ ហើយកាលភិក្ខុដែលជាសត្រូវនាំស្រីមក ពួកខ្លះនាំស្រីដែលភ្ញាក់មក ពួកខ្លះនាំស្រីដេកលក់មក ពួកខ្លះនាំស្រីស្រវឹងមក ពួកខ្លះនាំស្រីឆ្កួតមក ពួកខ្លះនាំស្រីប្រមាទមក គឺនាំស្រីដែលបញ្ជូនចិត្តទៅ ក្នុងអារម្មណ៍ដទៃ គឺដែលវាយមាយមក ពួកខ្លះនាំស្រីដែលស្លាប់ហើយ សត្វមិនទាន់កកេរស៊ីមក គឺនាំស្រីដែលស្លាប់មាននិមិត្ត ដែលសត្វទាំងឡាយ មានឆ្កែចចកជាដើមមិនទាន់កកេរស៊ីមក ពួកខ្លះនាំស្រីស្លាប់ហើយ ដែលសត្វមិនទាន់បានកកេរស៊ីដោយច្រើនមក ស្រីស្លាប់ដែលឈ្មោះថា សត្វមិនទាន់បានកកេរស៊ីដោយច្រើន គឺត្រង់វច្ចមគ្គក្តី បស្សាវមគ្គក្តី មុខមគ្គក្តី ដែលជានិមិត្តមានឱកាស គឺសត្វមិនទាន់បានកកេរស៊ីមានចំណែកច្រើន ពួកខ្លះនាំស្រីដែលស្លាប់សត្វកកេរស៊ីហើយដោយច្រើនមក ស្រីស្លាប់ដែលសត្វកកេរស៊ីហើយដោយច្រើន គឺអវយវៈត្រង់និមិត្ត មានវច្ចមគ្គជាដើម ត្រូវសត្វកកេរស៊ីជាចំណែកច្រើន ដែលមិនទាន់បានកកេរស៊ីមានចំណែកតិច មិនមែននាំមកតែស្រីមនុស្សតែម្យ៉ាងប៉ុណ្ណោះឡើយ ដោយពិត នាំស្រីអមនុស្សខ្លះ សត្វតិរច្ឆានញីខ្លះមក មិនមែននាំមកចំពោះតែស្រី មានប្រការដូចពោលហើយប៉ុណ្ណោះមកទេ គឺនាំឧភតោព្យញ្ជនកៈខ្លះ ខ្ទើយខ្លះ មនុស្សប្រុសខ្លះមក ទើបត្រាស់ពាក្យ

ជាដើមថា ភិក្ខុដែលជាសត្រូវនាំស្រីមនុស្សដែលភ្ញាក់មក ។

## មគ្គរបស់មនុស្សស្រីមានមាន ២៧ ចតុក្កៈ

ក្នុងពាក្យថា **ជាគរន្តិំ** ជាដើមនោះ ដើម្បីការមិនវង្វេងក្នុងព្រះបាលី បណ្ឌិតគប្បីជ្រាបចតុក្កៈដូចពោលហើយ ដោយការគណនាដែលនឹងពោលយ៉ាងនេះថា ដោយអំណាចមគ្គទាំង ៣ របស់មនុស្សស្រីមាន ២៧ ចតុក្កៈ គឺសុទ្ធិចតុក្កៈ ( ចតុក្កៈពោលដោយមគ្គសុទ្ធៗ ) ៣ ជាគរន្តិចតុក្កៈ ( ចតុក្កៈពោលដោយស្រីដែលភ្ញាក់ ) ៣ សុត្តចតុក្កៈ ( ចតុក្កៈពោលដោយស្រីដេកលក់ ) ៣ មត្តចតុក្កៈ ( ចតុក្កៈពោលដោយស្រីស្រវឹង ) ៣ ឧម្មត្តកចតុក្កៈ ( ចតុក្កៈពោលដោយស្រីឆ្កួត ) ៣ បមត្តចតុក្កៈ ( ចតុក្កៈពោលដោយស្រីប្រមាទ ) ៣ មតអក្ខយិតចតុក្កៈ ( ចតុក្កៈពោលដោយស្រីស្លាប់ដែលសត្វមិនទាន់កកេរស៊ី ) ៣ យេភុយ្យេនអក្ខយិតចតុក្កៈ ( ចតុក្កៈពោលដោយនិមិត្តដែលសត្វមិនទាន់បានកកេរស៊ីដោយច្រើន ) ៣ យេភុយ្យេនខយិត-ចតុក្កៈ ( ចតុក្កៈពោលដោយនិមិត្តដែលសត្វកកេរស៊ីដោយច្រើន ) ៣ ។

ដោយអំណាចមគ្គទាំង ៣ របស់អមនុស្សស្រីក៏មាន ២៧ ចតុក្កៈដូចគ្នា របស់សត្វតិរច្ឆានញីក៏មាន ២៧ ចតុក្កៈដូចគ្នា ក្នុងឥត្ថីវារៈមាន ៨១ ចតុក្កៈ ដោយប្រការដូច្នេះ ។ ហើយក្នុងឧភតោព្យញ្ជនកវារៈក៏មាន ៨១ ចតុក្កៈដូចក្នុងឥត្ថីវារៈ ។

ចំណែកក្នុងបណ្ឌកបុរិសវារៈ ដោយអំណាចមគ្គទាំង ២ មានចតុក្កៈមួយពួក ៥៤ ចតុក្កៈ រួមទាំងអស់មាន ២៧០ ចតុក្កៈ ដោយប្រការដូច្នេះ ។

ចតុក្កៈទាំងនេះ មានអត្ថជាក់ច្បាស់ហើយ ។

គ្រប់ៗ ពាក្យ បណ្ដាស្ថានទាំងនោះ ក្នុងឋានៈនេះថា ស្រីស្លាប់ដែលសត្វមិនទាន់បានកកេរស៊ីដោយច្រើន និងដែលសត្វកកេរស៊ីហើយដោយច្រើន មានវិនិច្ឆ័យដូច្នេះថា

# រឿងព្រះវិនយធរ ២ អង្គ

បានឮថា ឯកោះតម្ពបណ្ណិទ្វីប មានព្រះវិនយធរ ២ អង្គ ជាព្រះថេរៈរួមអាចារ្យតែមួយ គឺព្រះឧបតិស្សត្ថេរ ១ ព្រះបុស្សទេវត្ថេរ ១ ។ ព្រះថេរៈ ២ អង្គនោះ ក្នុងគ្រាមានមហាភ័យ បានថែរក្សាព្រះវិនយបិដកទុក ។ បណ្ដាព្រះថេរៈទាំង ២ អង្គនោះ ព្រះឧបតិស្សត្ថេរជាអ្នកឈ្លាសជាង ។ ព្រះឧបតិស្សត្ថេរនោះ មានអន្តេវាសិក ២ អង្គ គឺមហាបទុមត្ថេរ ១ មហាសុមត្ថេរ ១ បណ្ដាព្រះថេរៈ ២ អង្គនោះ ព្រះមហាសុមត្ថេរបានស្ដាប់ព្រះវិនយបិដក ៩ ដង ។ ព្រះមហាបទុមត្ថេរបានស្ដាប់ដល់ទៅ ១៨ ដង គឺបានស្ដាប់ជាមួយព្រះមហាសុមត្ថេរនោះ ៩ ដង និងបានស្ដាប់មួយអង្គឯងដទៃទៀត ៩ ដង ។ បណ្ដាលោកទាំង ២ អង្គនោះ ព្រះមហាបទុមត្ថេរនេះឯង ជាអ្នកឈ្លាសជាង ។ បណ្ដាព្រះថេរៈទាំង ២ អង្គនោះ ព្រះមហាសុមត្ថេរ កាលស្ដាប់ព្រះវិនយបិដកដល់ទៅ ៩ ដងហើយ ក៏លះបង់អាចារ្យ បានទៅកាន់ទន្លេគង្គាឯត្រើយនាយ ។

គ្រានោះ ព្រះមហាបទុមត្ថេរពោលថា ព្រះវិនយធរលះបង់អាចារ្យដែលនៅមានជីវិតនោះឯង សម្គាល់កាលដែលខ្លួនគប្បីស្នាក់នៅក្នុងទីដទៃ នេះជា

ភិក្ខុអ្នកក្លាហានពិតប្អូន កាលអាចារ្យនៅមានជីវិត លោករៀនយកព្រះវិនយ-បិដក និងអដ្ឋកថាច្រើនដងហើយក៏ដោយ ក៏មិនគួរលះបង់ចោល គួរស្តាប់ជានិច្ចកាល គួរស្វាធ្យាយ រាល់កន្លះឆ្នាំម្តង ។ ក្នុងកាលនៃភិក្ខុទាំងឡាយដែលធ្ងន់ក្នុងព្រះវិន័យយ៉ាងនោះ ថ្ងៃមួយ ព្រះឧបតិស្សត្ថេរអង្គុយពណ៌នាបាលីបទេសនេះ ក្នុងបឋមបារាជិកសិក្ខាបទដល់ពួកអន្តេវាសិក ៥០០ អង្គដែលមានព្រះមហាបទុមត្ថេរជាប្រធាន ។

ពួកអន្តេវាសិកសួរឧបតិស្សត្ថេរនោះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងសាកសពដែលសត្វមិនទាន់បានកកេរស៊ីដោយច្រើន ត្រូវអាបត្តិបារាជិក ក្នុងសាកសពដែលសត្វកកេរស៊ីដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ ចុះក្នុងសាកសពដែលសត្វកកេរស៊ីពាក់កណ្តាល គប្បីត្រូវអាបត្តិអ្វី ព្រះថេរៈឆ្លើយថា អាវុសោ ធម្មតាព្រះពុទ្ធទាំងឡាយ កាលទ្រង់បញ្ញត្តបារាជិក មិនមែនទ្រង់បញ្ញត្តឲ្យមានចំណែកសេសសល់នោះឡើយ ទ្រង់រួមយកខេត្តបារាជិកទាំងអស់ មិនឲ្យមានចំណែកសល់ឡើយ ទ្រង់កាត់ទ្វារហើយបញ្ញត្តបារាជិកក្នុងវត្ថុនៃបារាជិកនោះឯង ពិតហើយ សិក្ខាបទនេះ ជាលោកវជ្ជៈ មិនមែនជាបណ្ណត្តិវជ្ជៈ ព្រោះហេតុនោះ បើក្នុងសាកសពដែលសត្វកកេរស៊ីពាក់កណ្តាល គប្បីជាអាបត្តិបារាជិកសោត ព្រះសម្មាសម្ពុទ្ធទ្រង់ក៏គប្បីបញ្ញត្ត បារាជិកទុកតែព្រោះក្នុងសាកសព ដែលសត្វកកេរស៊ីពាក់កណ្តាលនេះ ស្រមោលបារាជិកមិនប្រាកដ ប្រាកដត្រឹមតែថុល្លច្ច័យប៉ុណ្ណោះ ។

ម្យ៉ាងទៀត ព្រះដ៏មានព្រះភាគ កាលទ្រង់បញ្ញត្តបារាជិកទុកក្នុងសរីរៈ

ដែលស្លាប់ហើយ ទ្រង់ក៏តាំងបារាជិកទុកក្នុងសាកសពដែលសត្វមិនទាន់បានកកេរស៊ីដោយច្រើន បន្ទាប់អំពីសាកសពដែលសត្វមិនទាន់បានកកេរស៊ីដោយច្រើននោះទៅ ទ្រង់បញ្ញត្តថុល្លច្ច័យ ដើម្បីសម្តែងថា មិនមានបារាជិក ទើបទ្រង់តាំងថុល្លច្ច័យទុកក្នុងសាកសព ដែលសត្វកកេរស៊ីហើយដោយច្រើន បន្ទាប់អំពីសាកសពដែលសត្វបានកកេរស៊ីដោយច្រើននោះទៅ គប្បីជ្រាបថា មិនមានថុល្លច្ច័យ ។

ដែលបានឈ្មោះថា សាកសពដែលសត្វកកេរស៊ី និងមិនទាន់បានកកេរស៊ីនោះ គួរយល់ក្នុងសរីរៈដែលស្លាប់ហើយប៉ុណ្ណោះ មិនគួរយល់ក្នុងសរីរៈដែលកំពុងរស់នៅ ។ ព្រោះថា ក្នុងសរីរៈដែលនៅរស់ កាលសាច់ ឬសរសៃមានប្រមាណប៉ុនខ្នងក្រចកនៅមាន រមែងត្រូវអាបត្តិបារាជិកនោះឯង ។ សូម្បីនិមិត្តត្រូវសត្វកកេរស៊ីហើយដោយប្រការទាំងពួង ស្បែកសាច់មិនមាន តែសណ្ឋាននិមិត្តនៅប្រាកដ សម្រេចការសេពក ( អង្គជាត ) ចូលទៅ ត្រូវអាបត្តិបារាជិកដូចគ្នា ។ កាលអ្នកពុកពនុះត្រង់និមិត្តទាំងអស់ចេញមិនឲ្យមានសណ្ឋាននិមិត្តសេសសល់ ចៀរចេញដោយជុំវិញ រមែងត្រូវអាបត្តិថុល្លច្ច័យដោយអំណាចសន្ទេបថា ជាមុខដំបៅ ។ កាលកិត្តព្យាយាមត្រង់ចម្រៀកសាច់ដែលធ្លាក់ទៅអំពីនិមិត្តនោះ ត្រូវអាបត្តិទុក្កដ ។

ចំណែកក្នុងសរីរៈដែលស្លាប់ហើយ បើសរីរៈទាំងអស់ត្រូវសត្វកកេរស៊ីហើយខ្លះ នៅមិនទាន់បានកកេរស៊ីខ្លះ តែមគ្គទាំង ៣ សត្វមិនទាន់បានកកេរស៊ី កាលកិត្តព្យាយាមក្នុងមគ្គទាំង ៣ នោះ រមែងត្រូវអាបត្តិបារាជិក ។ ក្នុង

សរីរៈដែលសត្វមិនទាន់បានកកេរស៊ីដោយច្រើន ត្រូវអាបត្តិបារាជិកនោះឯង ក្នុងសរីរៈដែលសត្វកកេរស៊ីពាក់កណ្ដាល និងដែលកកេរស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ ។ បើភិក្ខុស៊កអង្គជាតចូលទៅត្រង់ភ្នែក ច្រមុះ ត្រចៀក ប្រហោងពោះវៀន និងស្រោមអង្គជាត ឬត្រង់មុខដំបៅ ដែលធ្លុះដោយមុខសស្ត្រាជាដើម ក្នុងសរីរៈដែលនៅរស់របស់មនុស្សទាំងឡាយ ដោយការត្រេកត្រអាលក្នុងមេថុនធម្ម សូម្បីត្រឹមមួយគ្រាប់ល្ង ក៏ត្រូវអាបត្តិថុល្លច្ច័យដូចគ្នា ។ ស៊កចូលទៅក្នុងអវយវៈទាំងឡាយ មានរន្ធក្លៀកជាដើម ក្នុងសរីរៈដ៏សេស ត្រូវអាបត្តិទុក្កដ ។ កាលស៊កចូលទៅក្នុងសាកសព ដែលសរីរៈនៅស្រស់ ក្នុងខេត្តនៃបារាជិក ត្រូវអាបត្តិបារាជិក ក្នុងខេត្តនៃថុល្លច្ច័យ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងខេត្តនៃទុក្កដ ត្រូវអាបត្តិទុក្កដ ។ តែក្នុងកាលណាសរីរៈជារបស់ហើមរលួយ មានរុយរោម មានពួកដង្កូវចោះ បុគ្គលណាមួយមិនអាចចូលទៅជិតបាន ព្រោះជាសាកសពដែលមានដង្កូវរូងជញ្ជក់ទូទៅក្នុងទ្វារទាំង ៩ ក្នុងកាលនោះ វត្ថុនៃបារាជិក និងវត្ថុនៃថុល្លច្ច័យ រមែងលះបង់ទៅ កាលភិក្ខុព្យាយាមក្នុងសរីរៈដូច្នោះ ក្នុងកន្លែងណាមួយ ត្រូវអាបត្តិទុក្កដតែម្យ៉ាង កាលព្យាយាមក្នុងច្រមុះរបស់សត្វតិរច្ឆានទាំងឡាយ ( ដែលស្លាប់ហើយ ) មានដំរី សេះ គោ ពពែ អូដ្ឋ និងក្របីជាដើម ត្រូវអាបត្តិថុល្លច្ច័យ កាលព្យាយាមក្នុងប្រហោងពោះវៀន និងស្រោមរបស់អង្គជាត ជាថុល្លច្ច័យដូចគ្នា ។ កាលព្យាយាមក្នុងភ្នែក ត្រចៀក និងមុខដំបៅរបស់សត្វតិរច្ឆានទាំងអស់ ( ដែលស្លាប់ហើយ ) ត្រូវអាបត្តិទុក្កដ សូម្បីក្នុងសរីរៈដ៏សេស

ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។ កាលព្យាយាមក្នុងសរីរៈដែលស្រស់របស់សត្វតិរច្ឆានដែលស្លាប់ហើយ ក្នុងខេត្តនៃបារាជិក ត្រូវអាបត្តិបារាជិក ក្នុងខេត្តនៃថុល្លច្ច័យ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងខេត្តនៃទុក្កដ ត្រូវអាបត្តិទុក្កដ ។ កាលព្យាយាមក្នុងសាកសពដែលហើមស្អុយ ត្រូវអាបត្តិទុក្កដ ក្នុងទីគ្រប់អន្ទើដោយន័យដូចពោលហើយខាងដើមនោះឯង ។ ភិក្ខុកាលមិនបានសិកពោះវៀន និងស្រោមអង្គជាតរបស់បុរសដែលនៅរស់ចូលទៅ ដោយតម្រេកក្នុងការស្ទាបអង្អែលកាយ ឬដោយតម្រេកក្នុងមេថុន តែធ្វើនិមិត្តពាល់ត្រូវត្រង់និមិត្ត ត្រូវអាបត្តិទុក្កដ ។ កាលមិនបានសិក ( អង្គជាតរបស់ខ្លួន ) ចូលទៅក្នុងនិមិត្តរបស់ស្រីដោយតម្រេកក្នុងមេថុន តែនិមិត្ត និងនិមិត្តប៉ះគ្នា ត្រូវអាបត្តិថុល្លច្ច័យ ។

ចំណែកក្នុងមហាអដ្ឋកថាលោកពោលថា ភិក្ខុប៉ះនិមិត្តរបស់ស្រីដោយមាត់ ដោយតម្រេកក្នុងមេថុន ត្រូវអាបត្តិថុល្លច្ច័យ ។ ព្រោះការមិនប្លែកគ្នានៃរឿងដែលកើតឡើងថា ឆព្វគ្គិយភិក្ខុចាប់មេគោទាំងឡាយ ដែលកំពុងឆ្លងស្ទឹងអចិរវតីត្រង់ស្នែងខ្លះ ត្រង់ត្រចៀកខ្លះ ត្រង់កខ្លះ ត្រង់កន្ទុយខ្លះ ឡើងជិះលើខ្នងខ្លះ មានចិត្តតម្រេក ពាល់ត្រូវអង្គជាតគោខ្លះ ដូច្នេះ ទើបព្រះដ៏មានព្រះភាគត្រាស់ក្នុងចម្មក្ខន្ធកៈថា ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អង្គជាតដែលភិក្ខុមានចិត្តតម្រេក មិនគប្បីពាល់ត្រូវ ភិក្ខុណាពាល់ត្រូវ ភិក្ខុនោះត្រូវអាបត្តិថុល្លច្ច័យ ។ បណ្ឌិតគួរប្រៀបធៀបពាក្យទាំងអស់នោះមើលហើយកាន់យកដោយអាការដែលមិនខុសចុះ ។

ពាក្យនោះមិនខុសដូចម្ដេច មិនខុសយ៉ាងនេះថា បានឮថា ក្នុងពាក្យដែលលោកពោលទុកក្នុងមហាអដ្ឋកថាថា ពាល់ត្រូវដោយមាត់ដោយតម្រេកក្នុងមេថុន មាត់ គឺនិមិត្ត លោកសំដៅថា មាត់ ។ ឯអត្ថនេះឯង បណ្ឌិតគប្បីជ្រាបថា ជាបំណងក្នុងមហាអដ្ឋកថានោះ សូម្បីលោកពោលថា ដោយតម្រេកក្នុងមេថុន ។ ពិតហើយ សេចក្ដីព្យាយាមក្នុងមេថុន ដោយមាត់ធម្មតាក្នុងនិមិត្តរបស់ស្រីមិនមាន ។ បណ្ឌិតគប្បីជ្រាបសន្និដ្ឋានថា ព្រះដ៏មានព្រះភាគទ្រង់សំដៅយកឧព្វត្តិយភិក្ខុដែលជិះលើខ្នង ( មេគោ ) ហើយពាល់ត្រូវអង្គជាតគោ ដោយអង្គជាត ( របស់ខ្លួន ) ដោយតម្រេកក្នុងមេថុន ទើបត្រាស់ថុល្លច្ច័យទុកក្នុងខន្ធកៈនោះ ឯសេចក្ដីពិត ពាល់ត្រូវដោយបំណងដទៃជាអាបត្តិទុក្កដ ។

ចំណែកអាចារ្យពួកខ្លះពោលថា សូម្បីក្នុងខន្ធកៈ ព្រះដ៏មានព្រះភាគទ្រង់សំដៅយកការពាល់ត្រូវដោយមាត់ធម្មតា ទើបត្រាស់ថា ជាអាបត្តិថុល្លច្ច័យ ព្រោះភាពជាកម្មគ្រោតគ្រាត សូម្បីក្នុងអដ្ឋកថា លោកក៏កាន់យកសូត្រដែលត្រាស់សំដៅដល់កម្មគ្រោតគ្រាតនោះឯង ទើបពោលថា ភិក្ខុប៉ះពាល់ដោយមាត់ធម្មតា ដោយតម្រេកក្នុងមេថុន ជាថុល្លច្ច័យ ដូច្នេះ ព្រោះហេតុនោះ ក្នុងពាក្យវិនិច្ឆ័យទាំងពីរ គួរកំណត់ឲ្យល្អ ហើយកាន់យកអំពីពាក្យវិនិច្ឆ័យដែលត្រឹមត្រូវជាង ។

តែអ្នកប្រាជ្ញទាំងឡាយ អ្នកចេះព្រះវិន័យ រមែងសរសើរពាក្យវិនិច្ឆ័យដំបូង គឺបើភិក្ខុពាល់ត្រូវនិមិត្តរបស់ស្រីដោយមាត់ធម្មតាក្ដី ដោយមាត់ គឺ

និមិត្តក្តី ដោយតម្រេក ក្នុងការស្ទាបអង្អែលកាយ ត្រូវអាបត្តិសង្ឃាទិសេស កាលពាល់ត្រូវបស្សាវមគ្គរបស់សត្វតិរច្ឆានញីដោយមាត់ គឺនិមិត្តជាថុល្លច្ច័យ ដោយន័យដូចពោលហើយនោះឯង កាលពាល់ត្រូវដោយតម្រេកក្នុងការស្ទាប អង្អែលកាយ ត្រូវអាបត្តិទុក្កដ ដូច្នេះ ។

អធិប្បាយ ចតុក្កៈ ២៦៩ ដ៏សេស ចប់

# អធិប្បាយ អង្គជាតមានស្រោម និងមិនមានស្រោម

[ ៤១ ] ព្រះដ៏មានព្រះភាគ កាលទ្រង់នាំចតុក្កៈ ២៧០ មកហើយ ដើម្បីរក្សាភិក្ខុអ្នកបដិបត្តិដោយប្រការយ៉ាងនេះ ឥឡូវនេះ បានទតឃើញថា បាបភិក្ខុពួកណាក្នុងអនាគត នឹងក្លែងអាងលេសថា ឧបាទិន្នកៈ ( គឺកាយិន្ទ្រិយដែលមានជីវិត ) ណាមួយ ដែលអនុបាទិន្នកៈ ( គឺកាយិន្ទ្រិយដែលមិនមានជីវិត ) នឹងពាល់ត្រូវអង្គជាតដែលមានស្រោមហើយនេះ មិនមាន ក្នុងការដែលមិនប៉ះពាល់នេះ នឹងមានទោសដូចម្ដេច បាបភិក្ខុទាំងនោះ នឹងមិនមានទីពឹងក្នុងសាសនាយ៉ាងនេះ ដូច្នេះហើយ កាលទ្រង់សម្ដែងចែកបណ្ដាចតុក្កៈ ២៧០ ចតុក្កៈនោះ ក្នុងចតុក្កៈនីមួយៗ ដោយការផ្សេងគ្នានៃអង្គជាត ដែលពាក់ស្រោមហើយ ជា ៤ យ៉ាង ទើបត្រាស់ថា ពួកភិក្ខុដែលជាសត្រូវនាំមនុស្សស្រីមកក្នុងសម្នាក់ភិក្ខុ ហើយឲ្យអង្គុយសង្កត់អង្គជាត ដោយវច្ចមគ្គ បស្សាវមគ្គ មុខមគ្គ របស់ស្រីដែលមានស្រោម របស់ភិក្ខុមិនមានស្រោម ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ ក្នុងបទជាដើមថា **សន្ថតាយ អសន្ថតស្ស** គប្បីជ្រាបយោជនាដោយន័យនេះថា ឲ្យអង្គុយសង្កត់អង្គជាតរបស់ភិក្ខុដែលមិនមានស្រោម ដោយវច្ចមគ្គ បស្សាវមគ្គ មុខមគ្គរបស់ស្រីដែលមានស្រោម ។ បណ្ដាមគ្គទាំង ៣ ក្នុងមគ្គណាមួយរបស់ស្រី ដែលឈ្មោះថា មានស្រោម ក្នុងបណ្ដាមគ្គដែលមានស្រោម និងមិនមានស្រោមទាំងនោះ បានដល់ មគ្គដែលគេយកសំពត់ ឬស្បឹកឈើ សម្បកផ្ចៃ ឬស្បែក បន្ទះសំណ ឬសង្កសីជាដើមឯណានីមួយ រុំ ឬស៊កចូលទៅពាក់ទុកខាងក្នុង ។ អង្គជាតរបស់បុរស

ដែលឈ្មោះថា មានស្រោមនោះ បានដល់ អង្គជាតគេយកបណ្ដាវត្ថុឯណា នីមួយ មានសំពត់ជាដើមនោះៗ ឯងមកពាក់ ។

ក្នុងមគ្គទាំង ៣ នោះ អនុបាទិន្នកៈ ( គឺកាយិន្ទ្រិយដែលមិនមានចិត្តគ្រប់គ្រង ) និងឧបាទិន្នកៈ ( គឺកាយិន្ទ្រិយដែលមានចិត្តគ្រប់គ្រង ) នឹងប៉ះខ្ទប់គ្នាក៏ដោយ ឧបាទិន្នកៈ និងអនុបាទិន្នកៈប៉ះខ្ទប់គ្នាក៏ដោយ អនុបាទិន្នកៈ និងអនុបាទិន្នកៈប៉ះខ្ទប់គ្នាខ្លួនឯងក៏ដោយ ឧបាទិន្នកៈ និងឧបាទិន្នកៈ នឹងប៉ះខ្ទប់គ្នាខ្លួនឯងក៏ដោយ បើអង្គជាតចូលទៅត្រង់បទេសដែលអាចារ្យទាំងឡាយពោលថា កាលអង្គជាតចូលទៅហើយ ត្រូវអាបត្តិបារាជិក ដូច្នេះសោត បើភិក្ខុត្រេកអរក្នុងគ្រប់ៗ មគ្គ ក្នុងខេត្តនៃបារាជិក ត្រូវអាបត្តិបារាជិក ក្នុងខេត្តថុល្លច្ច័យ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងខេត្តទុក្កដ ត្រូវអាបត្តិទុក្កដនោះឯង ។

បើនិមិត្តស្រីគេពាក់ស្រោមទុក កាលភិក្ខុប៉ះស្រោម ត្រូវអាបត្តិទុក្កដ បើនិមិត្តរបស់បុរសគេពាក់ស្រោម កាលភិក្ខុស៊កស្រោមចូលទៅ ត្រូវអាបត្តិទុក្កដ បើនិមិត្តទាំងពីរពាក់ស្រោម កាលភិក្ខុប៉ះស្រោមនឹងស្រោម ត្រូវអាបត្តិទុក្កដ បើគេយកបណ្ដាវត្ថុ មានថ្នេ ឫស្សី និងដើមបបុស វត្ថុណាមួយ ដាក់ក្នុងនិមិត្តរបស់ស្រី បើភិក្ខុស៊ក ( អង្គជាត ) ចូលទៅត្រូវចំណែកខាងក្រោមនៃវត្ថុដែលដាក់នោះ សូម្បីប៉ុនគ្រាប់ល្ង ត្រូវអាបត្តិបារាជិក បើស៊កចូលទៅត្រូវចំណែកខាងលើក្ដី ត្រូវខាងៗ ក្ដី បណ្ដាខាងទាំងពីរក្ដី ត្រូវអាបត្តិបារាជិក បើស៊កចូលទៅ មិនត្រូវខាងទាំង ៤ សូម្បីត្រូវផ្ទៃខាងក្នុងនៃឫស្សី និងបបុសជាដើមនោះ ក៏ត្រូវអាបត្តិបារាជិក ។ បើស៊កចូលទៅមិនឲ្យត្រូវ

ត្រង់ខាង ឬត្រង់ផ្ទៃ ឲ្យសំយុងទៅក្នុងអាកាសតែម្យ៉ាងហើយ ដកចេញ ត្រូវអាបត្តិទុក្កដ ពាល់ត្រូវស្រោមខាងក្រៅ ត្រូវអាបត្តិទុក្កដដូចគ្នា ។ បណ្ឌិតគប្បីជ្រាបលក្ខណៈសព្វអន្ទើ ក្នុងមគ្គ មានវច្ចមគ្គជាដើម ដូចដែលពោលទុកក្នុងនិមិត្តស្រី ដូច្នោះឯង ។

សន្ថតចតុក្កបភេទកថា ចប់

# អធិប្បាយ ភិក្ខុដែលជាសត្រូវ

[ ៤២-៤៣ ] ព្រះដ៏មានព្រះភាគ កាលត្រាស់ប្រភេទនៃសន្ថតចតុក្កៈយ៉ាងនោះហើយ ឥឡូវនេះ កាលទ្រង់សម្តែងប្រភេទនោះ ( ដដែលទៀត ) ព្រោះពួកភិក្ខុដែលជាសត្រូវ មិនមែននាំជន មានមនុស្សស្រីជាដើមមកក្នុងសម្នាក់នៃភិក្ខុតែម្យ៉ាងឡើយ ដោយពិតគឺ នៅនាំភិក្ខុមកក្នុងសម្នាក់របស់មនុស្សស្រីជាដើមទាំងនោះទើបទ្រង់នាំចតុក្កៈទាំងអស់នោះមកសម្តែងដដែលទៀត ដោយន័យជាដើមថា ពួកភិក្ខុដែលជាសត្រូវ នាំភិក្ខុមកក្នុងសម្នាក់របស់មនុស្សស្រីដូច្នេះ ។ ក្នុងចតុក្កៈទាំងនោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយន័យដូចពោលមកហើយនោះឯង ។

ការពណ៌នាភាពផ្សេងគ្នានៃចតុក្កៈ
ដោយអំណាចភិក្ខុដែលជាសត្រូវ ចប់

## រឿង ព្រះរាជា និងចោរជាសត្រូវចំពោះភិក្ខុជាដើម

[ ៤៤ ] ព្រោះពួកភិក្ខុដែលជាសត្រូវ រមែងធ្វើដូចដែលពោលមកហើយយ៉ាងនោះឯង សូម្បីឥស្សរជន មានព្រះរាជាដែលជាសត្រូវជាដើម ក៏ទ្រង់ធ្វើ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងប្រភេទសត្រូវនោះ ត្រាស់ពាក្យថា **រាជបច្ចត្ថិកា** ជាដើម ។

ក្នុងពាក្យថា **រាជបច្ចត្ថិកា** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា សត្រូវទាំងឡាយ គឺព្រះរាជា ឈ្មោះថា **រាជបច្ចត្ថិកា** ( ព្រះរាជាជាសត្រូវ ) ឯព្រះរាជាទាំងនោះ ទ្រង់នាំមកឯងខ្លះ ឲ្យអ្នកដទៃនាំមកខ្លះ ( នូវមនុស្សស្រីជាដើម ) គប្បីជ្រាបថា ទ្រង់នាំមកទាំងអស់ ។ សត្រូវទាំងឡាយ គឺចោរឈ្មោះថា **ចោរបច្ចត្ថិកា**។

អ្នកស្រុក និងបុរសដែលធ្វើការបោកបញ្ឆោត ដែលខ្វល់ខ្វាយក្នុងការលេង ទាក់ទងដោយមេថុនក្ដី អ្នកលេងស្រី និងអ្នកលេងសុរាជាដើមក្ដី ឈ្មោះថា អ្នកលេង ។ សត្រូវទាំងឡាយ គឺអ្នកលេង ឈ្មោះថា **ធុត្ត-បច្ចត្ថិកា**។

ហទយៈ លោកហៅថា គន្ធៈ ។ ពួកសត្រូវដែលឈ្មោះថា ឧប្បលគន្ធៈ ព្រោះអត្ថថា វះយកហទយៈនោះ ។ សត្រូវទាំងឡាយ គឺអ្នកកាត់បេះដូង ឈ្មោះថា **ឧប្បលគន្ធបច្ចត្ថិកា**។

## សត្រូវសម្លាប់ភិក្ខុបង់ទៅតាដើម្បីសម្រេចការងារ

បានឮថា សត្រូវអ្នកកាត់បេះដូងទាំងនោះ មិនមែនរស់នៅដោយកសិកម្ម និងពាណិជ្ជកម្មជាដើមឡើយ នាំគ្នាធ្វើចោរកម្ម មានការប្លន់អ្នកដើរ

ដូវជាដើមដើម្បីចិញ្ចឹមបុត្រនិងភរិយា។ ចោរទាំងនោះ បើត្រូវការភាពសម្រេចនៃការងារ បានបួងសួងចំពោះពួកទេវតា ទើបបានវះហទយៈរបស់ពួកមនុស្ស ដើម្បីបួងសួងដល់ទេវតាទាំងនោះ ។ ឯពួកមនុស្សជាអ្នករកបានលំបាកគ្រប់កាល ចំណែកពួកភិក្ខុដែលស្នាក់នៅក្នុងព្រៃ រមែងរកបានងាយ ។ ចោរទាំងនោះចាប់យកភិក្ខុអ្នកមានសីលហើយ បានរឭកថា ឈ្មោះថា ការសម្លាប់អ្នកមានសីល រមែងជារបស់ធ្ងន់ ដើម្បីនឹងទម្លាយសីលរបស់ភិក្ខុនោះឲ្យវិនាសទៅ ទើបនាំមនុស្សស្រីជាដើមមក ឬនាំភិក្ខុនោះទៅក្នុងសម្នាក់របស់មនុស្សស្រីជាដើមនោះ ។

ក្នុងរឿងពោលដោយព្រះរាជាដែលជាសត្រូវជាដើមនេះ មានការប្លែកគ្នាប៉ុណ្ណេះ ។ រឿងដ៏សេស គប្បីជ្រាបដោយន័យ ដូចពោលហើយនោះឯង ។ គប្បីជ្រាបចតុក្កៈទាំងឡាយ ក្នុងវារៈទាំង ៤ នេះ ដោយន័យដូចពោលហើយ ក្នុងភិក្ខុបច្ចត្ថិកាវារៈនោះឯង ។ តែក្នុងព្រះបាលី ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកហើយដោយសង្ខេប ។

ពោលអំពីប្រភេទនៃចតុក្កៈ ដោយអាការទាំងពួង ចប់

## រឿង ភិក្ខុសេពមេថុនធម្មតាមទ្វារមគ្គ និងមិនមែនទ្វារមគ្គ

[ ៤៥ ] ឥឡូវនេះ ដើម្បីការមិនវង្វេងក្នុងពាក្យដែលព្រះដ៏មានព្រះភាគ ត្រាស់ថា កាលភិក្ខុសេពមេថុនធម្មក្នុងមគ្គទាំង ៣ របស់ស្រីមនុស្សជាដើម ទើបព្រះឧបាលិត្ថេរពោលពាក្យថា **មគ្គេន មគ្គំ** ជាដើម ។

បណ្តាបទទាំងនោះ ពីរបទថា **មគ្គេន មគ្គំ** សេចក្តីថា ភិក្ខុស៊កអង្គ-ជាតរបស់ខ្លួនចូលទៅក្នុងបណ្តាមគ្គទាំង ៣ របស់ស្រី មគ្គណានីមួយ ម្យ៉ាង ទៀត បណ្តាមគ្គទាំង ២ ដែលលាយគ្នា ភិក្ខុស៊កវច្ចមគ្គចូលទៅផ្លូវបស្សាវ-មគ្គ ឬស៊កបស្សាវមគ្គចូលទៅផ្លូវវច្ចមគ្គ ។

ពីរបទថា **មគ្គេន អមគ្គំ** សេចក្តីថា កាលស៊កចូលទៅក្នុងបស្សាវមគ្គ ជាដើមហើយ ទើបបញ្ចេញមកតាមមុខដំបៅដោយជុំវិញនៃមគ្គនោះ ។

ពីរបទថា **អមគ្គេន មគ្គំ** សេចក្តីថា កាលស៊កចូលទៅតាមមុខដំបៅ ដោយជុំវិញហើយ ទើបបញ្ចេញតាមទ្វារមគ្គ ។

ពីរបទថា **អមគ្គេន អមគ្គំ** សេចក្តីថា បណ្តាមុខដំបៅទាំងពីរដែល លាយគ្នា កាលស៊កចូលទៅតាមមុខដំបៅមួយហើយ ទើបបញ្ចេញតាមមុខ ដំបៅទី ២ ។ ក្នុងការកំណត់មុខដំបៅ គប្បីជ្រាបថា ត្រូវអាបត្តិថុល្លច្ច័យ ក្នុងទីគ្រប់អន្លើ ដោយអំណាចអនុលោមតាមព្រះសូត្រនេះ ។

## ភិក្ខុសេពមេថុនធម្មក្នុងទ្វាររបស់ភិក្ខុដេកលក់

[ ៤៦ ] ឥឡូវនេះ ដើម្បីការមិនវង្វេងក្នុងព្រះតម្រាស់ ដែលត្រាស់ទុក ខាងមុខថា កាលភិក្ខុមិនដឹង មិនត្រេកអរមិនត្រូវអាបត្តិ ទើបព្រះឧបាលិត្ថេរ ពោលពាក្យថា **ភិក្ខុ សុត្តភិក្ខុម្ហិ** ជាដើម ។

ក្នុងពាក្យថា **ភិក្ខុ** ជាដើមនោះ មានអធិប្បាយដូច្នេះថា ភិក្ខុអង្គណាភ្ញាក់ហើយ ហើយត្រេកអរ ភិក្ខុអង្គនោះ ពោលថា លោកអង្គនេះ បដិបត្តិខុសក្នុងខ្ញុំដែលដេកលក់ ខ្ញុំមិនដឹងខ្លួន រមែងមិនផុត ( អំពីអាបត្តិ ) ។ ឯក្នុងពីរបទថា **ឧភោ នាសេតព្វា** នេះ សេចក្តីថា ព្រះវិន័យធរគប្បីឲ្យនាសនៈចេញទាំងពីរអង្គ ដោយលិង្គនាសនៈ ។

បណ្តាអ្នកប្រទូស្ត និងអ្នកត្រូវប្រទូស្ត ទាំងពីរអង្គនោះ អ្នកប្រទូស្តមិនមានការធ្វើប្តេជ្ញា តែអ្នកត្រូវប្រទូស្ត ព្រះវិន័យធរសាកសួរហើយ គប្បីឲ្យនាសនៈចេញ ដោយពាក្យប្តេជ្ញា បើលោកមិនត្រេកអរ មិនគួរឲ្យនាសនៈទេ សូម្បីក្នុងវារៈសាមណេរក៏មាននន័យ ដូច្នេះ ។

## អធិប្បាយ អនាបត្តិវារៈ

[ ៤៧ ] ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងអាបត្តិ និងអនាបត្តិនោះៗ ក្នុងវារៈនោះៗ យ៉ាងនោះហើយ ឥឡូវនេះ កាលទ្រង់សម្តែងអនាបត្តិតែម្យ៉ាង ទើបត្រាស់ថា **អនាបត្តិ អជានន្តស្ស** ជាដើម ។

ក្នុងពាក្យថា **អជានន្តស្ស** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុដែលឈ្មោះថា មិនដឹងខ្លួននោះ បានដល់ ដែលឈោងចុះកាន់ការដេកលក់យ៉ាងស៊ប់ រមែងមិនដឹងសេចក្តីព្យាយាម ដែលអ្នកដទៃធ្វើហើយ ភិក្ខុបែបនោះមិនត្រូវអាបត្តិ ដូចភិក្ខុដែលទៅសម្រាកពេលថ្ងៃ ក្នុងព្រៃមហាវន ជិតក្រុងវេសាលី ដូច្នោះ ។ សមដូចពាក្យដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា ភិក្ខុក្រាបទូលថា ខ្ញុំព្រះអង្គមិនដឹងខ្លួនទេ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាល

ភិក្ខុ បើភិក្ខុមិនដឹងខ្លួន មិនត្រូវអាបត្តិ ។

ភិក្ខុដែលឈ្មោះថា មិនត្រេកអរនោះ បានដល់ បុគ្គលដែលដឹងខ្លួន ហើយក៏មិនត្រេកអរ ភិក្ខុបែបនោះ មិនត្រូវអាបត្តិ ដូចភិក្ខុដែលប្រញាប់ក្រោកឡើងដោយរូតរះក្នុងព្រៃមហាវន ជិតក្រុងវេសាលីដូច្នោះឯង ។ សមដូចពាក្យដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា ភិក្ខុក្រាបទូលថា ខ្ញុំព្រះអង្គមិនត្រេកអរទេ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ បើមិនត្រេកអរ មិនត្រូវអាបត្តិ ។

ភិក្ខុឆ្កួតព្រោះប្រមាត់ ( កម្រើក ) ឈ្មោះថា ឆ្កួត ។ ពិតហើយ ប្រមាត់មាន ២ យ៉ាង គឺប្រមាត់មានស្រោម ១ ប្រមាត់មិនមានស្រោម ១ ។ ប្រមាត់ដែលមិនមានស្រោម ជ្រួតជ្រាបពេញសព៌ាង្គកាយ ដូចឈាមដូច្នោះ។ កាលប្រមាត់ដែលមិនមានស្រោមនោះកម្រើក ពួកសត្វរមែងមានកម រមាស់ដំណួចពិស និងសរីរៈញ័ររន្ធត់ជាដើម ។ កម និងរមាស់ជាដើមនោះ ជាសះស្បើយបាន ព្រោះការលាបថ្នាំ ។ ចំណែកប្រមាត់មានស្រោម តាំងនៅក្នុងស្រោមរបស់ប្រមាត់ ។ កាលប្រមាត់មានស្រោមនោះកម្រើក ពួកសត្វរមែងឆ្កួត ។

ភិក្ខុមានសញ្ញាវិបល្លាស ( បាត់ការចងចាំ ) លះបោលនូវហិរិ និងឱត្តប្បៈចេញហើយ រមែងដើរប្រព្រឹត្តកម្មដែលមិនសមគួរ ។ សូម្បីញាំញីសិក្ខាបទទាំងស្រាល និងធ្ងន់ ក៏មិនដឹងខ្លួន ។ ឈ្មោះថា ជាអ្នកកែខៃមិនបាន សូម្បីព្រោះការព្យាបាល ភិក្ខុមានសភាពបែបនោះ មិនត្រូវអាបត្តិ ។

ភិក្ខុឈ្មោះថា មានចិត្តរវើរវាយ បានដល់ ដែលបណ្ដោយចិត្ត ( ទៅតាមអារម្មណ៍ ) លោកហៅថា ឆ្កួតព្រោះខ្មោចចូល បានឮថា ពួកយក្សសម្ដែងអារម្មណ៍ទាំងឡាយដែលគួរខ្លាច ឬលូកដៃចូលតាមមាត់ ហើយប្របាច់បេះដូង ធ្វើពួកសត្វឲ្យមានការចាំឃ្លៀងឃ្លាត ។ ភិក្ខុអ្នកមានចិត្តរវើរវាយបែបនោះ មិនត្រូវអាបត្តិ ។

ចំណែកការប្លែកគ្នានៃភិក្ខុឆ្កួតទាំងពីរពួកនោះ មានដូច្នេះ គឺភិក្ខុដែលឆ្កួតព្រោះប្រមាត់កម្រើក រាប់ថា ជាឆ្កួតអស់កាលជានិច្ចនោះឯង មិនបានសញ្ញាតាមប្រក្រតី ។ បុគ្គលឆ្កួតព្រោះយក្សចូលសណ្ឋិត អាចត្រឡប់បានសញ្ញាតាមប្រក្រតីក្នុងកាលខ្លះ ។ តែក្នុងបឋមបារាជិកសិក្ខាបទនេះ ឆ្កួតព្រោះប្រមាត់កម្រើកក្ដី ឆ្កួតព្រោះយក្សចូលក្ដី សូមលើកទុក ភិក្ខុអង្គណា វង្វេងមិនមានស្មារតីដោយប្រការទាំងពួង ទោះវត្ថុណាមួយ ជាភ្លើងក៏ដោយ មាសក៏ដោយ លាមកក៏ដោយ ខ្លឹមចន្ទន៍ក៏ដោយ ក៏មិនស្គាល់ រមែងដើរជាន់ដូចគ្នាទាំងអស់ ភិក្ខុឆ្កួតមានសភាពបែបនោះ មិនត្រូវអាបត្តិ តែកាលត្រឡប់បានសញ្ញាឡើងក្នុងគ្រាខ្លះ ហើយធ្វើទាំងដែលដឹង ប្រព្រឹត្តជាអាបត្តិនោះឯង ។

ភិក្ខុឈ្មោះថា រសាប់រសល់ព្រោះវេទនានោះ បានដល់ បុគ្គលដែលគ្រាំគ្រា ព្រោះទុក្ខវេទនាលើសប្រមាណ រមែងមិនដឹងអ្វីៗ ភិក្ខុបែបនោះ មិនត្រូវអាបត្តិ ។

ភិក្ខុឈ្មោះថា អាទិកម្មិកនោះ បានដល់ បុគ្គលជាខាងដើមក្នុងកម្មនោះ ចំណែកក្នុងបឋមបារាជិកសិក្ខាបទនេះ សុទិន្នភិក្ខុ ជាអាទិកម្មិក ព្រះថេរៈ

នោះមិនត្រូវអាបត្តិ ភិក្ខុទាំងឡាយដ៏សេស មានសមណៈដែលសេពមេថុន នឹងស្វាញី និងវជ្ជីបុត្តកភិក្ខុជាដើមប្រព្រឹត្តជាអាបត្តិនោះឯង ដូច្នេះ ។

ពណ៌នាបទភាជនីយ ចប់

## សមុដ្ឋានជាទីកើតនៃអាបត្តិមាន ៦

ម្យ៉ាងទៀត ដើម្បីភាពជាអ្នកឈ្លាសក្នុងសិក្ខាបទនេះ គប្បីជ្រាបបកិណ្ណកៈដូច្នេះថា សមុដ្ឋាន ១ កិរិយា ១ សញ្ញា ១ សចិត្តក ១ លោកវជ្ជៈ ១ កម្ម និងកុសល ព្រមដោយវេទនា ១ ។

ក្នុងបកិណ្ណកៈទាំងនោះ ឈ្មោះថា សមុដ្ឋាននោះ បានដល់ សមុដ្ឋាននៃសិក្ខាបទ មាន ៦ ដោយអំណាចការប្រមូលយកទាំងអស់ ។ សមុដ្ឋានទាំងនោះនឹងមានច្បាស់ក្នុងគម្ពីរបរិវារ ។ តែកាលពោលដោយសង្ខេបហើយ ឈ្មោះថា សិក្ខាបទមានសមុដ្ឋាន ៦ ក៏មាន មានសមុដ្ឋាន ៤ ក៏មាន មានសមុដ្ឋាន ៣ ក៏មាន មានសមុដ្ឋានដូចកឋិនសិក្ខាបទក៏មាន មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទក៏មាន មានសមុដ្ឋានដូចធុរនិក្ខេបសិក្ខាបទក៏មាន ។

ក្នុងសិក្ខាបទទាំងនោះ សិក្ខាបទខ្លះ កើតព្រោះធ្វើ សិក្ខាបទខ្លះ កើតព្រោះមិនធ្វើ សិក្ខាបទខ្លះ កើតព្រោះធ្វើ និងព្រោះមិនធ្វើ សិក្ខាបទខ្លះ កើតព្រោះធ្វើខ្លះ កើតព្រោះមិនធ្វើខ្លះ សិក្ខាបទខ្លះ គ្រាខ្លះកើតព្រោះធ្វើ គ្រាខ្លះ

កើតព្រោះធ្វើ និងមិនធ្វើ ។

## អធិប្បាយ សិក្ខាបទជាសចិត្តកៈ និងអចិត្តកៈ

បណ្ដាសិក្ខាបទទាំងនោះ សិក្ខាបទដែលជាសញ្ញាវិមោក្ខក៏មាន ដែលជានោសញ្ញាវិមោក្ខក៏មាន ។ ក្នុងសិក្ខាបទដែលជាសញ្ញាវិមោក្ខ និងនោសញ្ញាវិមោក្ខនោះ សិក្ខាបទណាបានអង្គ គឺចិត្តផង សិក្ខាបទនោះជាសញ្ញាវិមោក្ខ សិក្ខាបទក្រៅអំពីនេះ ជានោសញ្ញាវិមោក្ខ ។ សិក្ខាបទដែលជាអចិត្តកៈក៏មាន ដែលជាសចិត្តកៈក៏មានទៀត ។ សិក្ខាបទណា ត្រូវព្រោះមានចិត្តប៉ុណ្ណោះ សិក្ខាបទនោះជាសចិត្តកៈ សិក្ខាបទណាសូម្បីវៀរចាកចិត្តក៏ត្រូវ សិក្ខាបទនោះជាអចិត្តកៈ សិក្ខាបទទាំងអស់នោះ ចែកជា ២ យ៉ាង គឺជាលោកវជ្ជៈ ១ ជាបណ្ណត្តិវជ្ជៈ ១ លក្ខណៈនៃសិក្ខាបទដែលជាលោកវជ្ជៈ និងបណ្ណត្តិវជ្ជៈនោះ បានពោលហើយ ។

## អធិប្បាយ សិក្ខាបទជាកាយកម្មជាដើម

ម្យ៉ាងទៀត បើពោលដោយអំណាចកម្ម កុសល និងវេទនាហើយ បណ្ដាសិក្ខាបទទាំងនេះ សិក្ខាបទដែលជាកាយកម្មក៏មាន ជាវចីកម្មក៏មាន ។ ក្នុងកាយកម្ម និងវចីកម្មនោះ សិក្ខាបទណាប្រព្រឹត្តទៅតាមកាយទ្វារ សិក្ខាបទនោះ គប្បីជ្រាបថា ជាកាយកម្ម សិក្ខាបទណាប្រព្រឹត្តទៅតាមវចីទ្វារ សិក្ខាបទនោះ គប្បីជ្រាបថា ជាវចីកម្ម ។

ម្យ៉ាងទៀត សិក្ខាបទដែលជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ពិតហើយ ចិត្តដែលឲ្យកើតអាបត្តិ មាន ៣២ ដួង

ប៉ុណ្ណោះ គឺកាមាវចរកុសលចិត្ត ៨ អកុសលចិត្ត ១២ កាមាវចរកិរិយាចិត្ត ១០ អភិញ្ញាចិត្ត ២ គឺកុសលអភិញ្ញា ១ និងកិរិយាអភិញ្ញា ១ ។ ក្នុងចិត្តទាំងនោះ សិក្ខាបទណាត្រូវដោយកុសលចិត្ត សិក្ខាបទនោះជាកុសល សិក្ខាបទណាត្រូវដោយចិត្តក្រៅអំពីនេះ សិក្ខាបទនោះ ជាចំណែកក្រៅអំពីនេះ ។

ម្យ៉ាងទៀត សិក្ខាបទមានវេទនា ៣ ក៏មាន មានវេទនា ២ ក៏មាន មានវេទនា ១ ក៏មាន ។ ក្នុងសិក្ខាបទទាំងនោះ បើត្រូវសិក្ខាបទណា ជាអ្នកដល់ព្រមដោយបណ្ដាវេទនា ៣ វេទនាណាមួយ ទើបត្រូវ សិក្ខាបទនោះគប្បីជ្រាបថា មានវេទនា ៣ បើភិក្ខុត្រូវសិក្ខាបទណា ជាអ្នកដល់ព្រមដោយសេចក្ដីសុខ ឬជាអ្នកដល់ព្រមដោយឧបេក្ខា ទើបត្រូវ សិក្ខាបទនោះ គប្បីជ្រាបថា មានវេទនា ២ ។ បើភិក្ខុត្រូវសិក្ខាបទណា ជាអ្នកដល់ព្រមដោយទុក្ខវេទនាប៉ុណ្ណោះ ទើបត្រូវ សិក្ខាបទនោះ គប្បីជ្រាបថា មានវេទនា ១ ។ គប្បីជ្រាបបកិណ្ណកៈនេះ គឺសមុដ្ឋាន ១ កិរិយា ១ សញ្ញា ១ សចិត្តកៈ ១ លោកវជ្ជៈ ១ កម្ម និងកុសល ព្រមដោយវេទនា ១ យ៉ាងនេះហើយ គប្បីជ្រាបថា បណ្ដាបកិណ្ណកៈ មានសមុដ្ឋានជាដើមនោះ សិក្ខាបទនេះពោលដោយសមុដ្ឋាន មានសមុដ្ឋាន ១ ពោលដោយអំណាចអង្គ កើតដោយអង្គ ២ គឺកើតព្រោះកាយ និងចិត្ត ហើយសិក្ខាបទនេះកើតព្រោះធ្វើ ពិតហើយកាលធ្វើប៉ុណ្ណោះ ទើបត្រូវអាបត្តិនោះ ជាសញ្ញាវិមោក្ខ ព្រោះរួចផុតដោយមិនមានកាមសញ្ញា ដែលសម្បយុត្តដោយមេថុន ពិតហើយ ព្រះដ៏មានព្រះភាគបានត្រាស់ថា អាបត្តិមិនមានដល់ភិក្ខុដែលមិនដឹង មិនត្រេកអរ ជា

សចិត្តកៈ ព្រោះភិក្ខុត្រូវអាបត្តិនោះ ដោយចិត្តបដិសំយុត្តដោយមេថុនប៉ុណ្ណោះ វៀរចាកចិត្តមិនត្រូវឡើយ ជាលោកវជ្ជៈ ព្រោះគប្បីត្រូវអាបត្តិនោះ ដោយអំណាចរាគៈខ្លាំងក្លាប៉ុណ្ណោះ ជាកាយកម្ម ព្រោះកើតតាមកាយទ្វារប៉ុណ្ណោះ ចំណែកចិត្ត ត្រឹមតែជាអង្គក្នុងសិក្ខាបទនេះ នឹងចាត់ជាកម្មដោយអំណាចចិត្តនោះក៏ទេ ជាអកុសលចិត្ត ព្រោះគប្បីត្រូវដោយលោភចិត្ត មានវេទនា ២ ព្រោះភិក្ខុមានការដល់ព្រមដោយសុខ ឬមានការដល់ព្រមដោយឧបេក្ខា ទើបត្រូវអាបត្តិនោះ ។

ក្នុងបកិណ្ណកៈទាំងពួង មានសមុដ្ឋានជាដើមនោះ រមែងសមក្នុងអាបត្តិតែក្នុងអដ្ឋកថាទាំងពួង លោកលើកឡើងសម្តែងដោយមាតិកាសិក្ខាបទ ព្រោះដូច្នោះ ទើបត្រូវពោលយ៉ាងនោះដូច្នេះឯង ។

បទភាជនីយនៃបឋមបារាជិក ចប់

# វិធីតវត្ថុក្នុងបឋមធារាជិក

## ឧទានគាថា

[៤៨] *សួរថា ពាក្យប្រព័ន្ធជាព្រះគាថាថា*

*រឿងស្វាញ់ ១ រឿងវជ្ជីបុត្តភិក្ខុ ១ រឿងភិក្ខុក្មេងភេទជាគ្រហស្ថ ១ រឿងអាក្រាត ១ រឿងពួកភិក្ខុប្រព្រឹត្តតាមលទ្ធិតិរ្ថិយ ៧ រឿង រឿងទារិកា ១ រឿងឧប្បលវណ្ណាភិក្ខុនី ១ រឿងជនផ្សេងគ្នា ២ រូប គឺភិក្ខុក្លាយភេទជាស្រី ១ និងភិក្ខុនីក្លាយភេទជាប្រុស ១ រឿងមាតា ១ រឿងធីតា ១ រឿងប្អូនស្រី ១ រឿងប្រពន្ធ ១ រឿងភិក្ខុខ្នងទន់ ១ រឿងភិក្ខុមានអង្គជាតវែង ១ រឿងមុខដំបៅ ២ រឿង រឿងរូបគំនូរ ១ រឿងឈើចម្លាក់ជារូបធីតា ១ រឿងភិក្ខុ ៥ រូប និងសុន្ទរភិក្ខុផង ១ រឿងស្ត្រី ៥ រឿង រឿងព្រៃខ្មោច ៥ រឿង រឿងឆ្អឹង ១ រឿងនាគញី ១ រឿងយក្ខិនី ១ រឿងស្រីប្រេត ១ រឿងភិក្ខុខ្ទើយ ១ រឿងភិក្ខុកើតរោគស្ពឹក ១ រឿងចាប់មាតុគ្រាមប្រុងនឹងសេព ១ រឿងព្រះអរហន្តសិងលក់ក្នុងក្រុងភទ្ទិយៈ ១ រឿងភិក្ខុក្រុងសាវត្ថី ៤ រឿង រឿងភិក្ខុអ្នកចំបាប់ ៣ រូប ក្នុងក្រុងវេសាលី ៣ រឿង រឿងភិក្ខុសិងបើកទ្វារ ១ រឿងភិក្ខុក្រុងភារុកច្ឆយល់សប្តិ ១ រឿងឧបាសិកាឈ្មោះសុបញ្ញា ៩ រឿង រឿងឧបាសិកាឈ្មោះសទ្ធា ៩ រឿង រឿងភិក្ខុនី ១ រឿងសិក្ខមានា ១ រឿងសាមណេរី ១ រឿងស្រីផ្កាមាស ១ រឿងមនុស្សខ្ទើយ ១ រឿងស្ត្រីគ្រហស្ថ ១ រឿងភិក្ខុសេពគ្នានឹងគ្នា ១ រឿងភិក្ខុចាស់ ១ រឿងកូនម្រឹគ ១ នេះដូចម្តេច ។*

ធ្វើយថា ព្រះគាថានេះ ឈ្មោះឧទានគាថានៃវិនីតវត្ថុ គឺរឿងនោះៗ ព្រះដ៏មានព្រះភាគទ្រង់វិនិច្ឆ័យដោយព្រះអង្គឯង ដែលព្រះធម្មសង្គាហកត្ថេរទាំងឡាយ បានដាក់ចិត្តថា ព្រះវិនយធរទាំងឡាយ នឹងចងក្រងរឿងទាំងនោះឲ្យបានល្អ ទើបបានរចនាទុក ។ ចំណែកវត្ថុគាថា ព្រះឧបាលិត្ថេរបានធ្វើទុកក្នុងចិត្តថា ព្រះវិនយធរទាំងឡាយនឹងវិនិច្ឆ័យតទៅ ( ក្នុងអនាគត ) ដោយលក្ខណៈនេះ ទើបបានទ្រទ្រង់ក្នុងកាលព្រះដ៏មានព្រះភាគគង់ព្រះជន្មនៅនោះឯង ។ ព្រោះដូច្នោះ ព្រះវិនយធរគួរកំណត់លក្ខណៈដែលត្រាស់ទុកក្នុងវិនីតវត្ថុនេះឲ្យល្អ ហើយទើបវិនិច្ឆ័យបឋមសិក្ខាបទ ។ មួយវិញទៀត ទុតិយបារាជិកជាដើម ក៏គួរវិនិច្ឆ័យដោយលក្ខណៈនៃទុតិយបារាជិកជាដើម ដែលត្រាស់ទុកហើយក្នុងវិនីតវត្ថុទាំងឡាយ ពិតហើយ វិនីតវត្ថុទាំងឡាយរមែងជារឿងសម្រាប់ប្រៀបធៀបរបស់ព្រះវិនយធរទាំងឡាយ ដូចរូបដែលជាគោលប្រៀបធៀបរបស់ពួកអ្នកវិចិត្រកម្ម ដូច្នោះ ។

[ ៤៩-៥០ ] បណ្តារឿងទាំងនោះ រឿង ២ ខាងដើម មានអត្ថដូចត្រាស់ទុកហើយក្នុងអនុប្បញ្ញត្តិនោះឯង ។

[ ៥១ ] ក្នុងរឿងទី ៣ មានវិនិច្ឆ័យដូច្នេះថា បទថា **គិហិលិង្គេន** គឺអ្នកស្លៀកសំពត់សដូចគ្រហស្ថ ។

[ ៥២ ] ក្នុងរឿងទី ៤ មិនមានពាក្យអ្វីដែលគួរពោលទុក ។

[ ៥៣ ] ក្នុងសំពត់ ៧ ប្រភេទ បន្ទាប់អំពីរឿងទី ៤ នោះទៅ មានវិនិច្ឆ័យដូច្នេះថា សំពត់ដែលក្រងដោយស្បូវក្លាំង ឈ្មោះថា សំពត់ក្រងដោយ

ស្បូវ ។ សំពត់សម្បកឈើរបស់ពួកតាបស ឈ្មោះថា សំពត់សម្បកឈើ ។ សំពត់ដែលគេដេរភ្ជាប់គ្នាជាបន្ទះ មានសណ្ឋានដូចបន្ទះក្តារ ឈ្មោះថា សំពត់ត្បាញជាបន្ទះ សំពត់កម្ពលដែលគេយកសរសៃសក់ ( របស់មនុស្ស ) ធ្វើជាអំបោះត្បាញ ឈ្មោះថា សំពត់កម្ពលធ្វើដោយសរសៃសក់ ។ សំពត់កម្ពលដែលគេត្បាញធ្វើដោយរោមកន្ទុយសត្វចាមរី ឈ្មោះថា សំពត់កម្ពលធ្វើដោយរោមកន្ទុយសត្វ ។ សំពត់ដែលគេយករោមស្លាបមៀមធ្វើ ឈ្មោះថា សំពត់ធ្វើដោយស្លាបមៀម ។ ស្បែកខ្លា និងម្រឹគ ទាំងរោម និងក្រចក ឈ្មោះថា សំពត់ស្បែកខ្លា ។

[ ៥៤ ] ក្នុងរឿងទី ១២ មានវិនិច្ឆ័យដូច្នេះថា បទថា **សារត្តោ** បានដល់ អ្នកមានតម្រេកដោយរាគៈក្នុងការស្ទាបអង្អែលកាយ ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបតម្រេកនោះហើយ ទើបត្រាស់ថា ត្រូវអាបត្តិសង្ឃាទិសេស ។

## រឿង ឧប្បលវណ្ណាភិក្ខុនី

[ ៥៥ ] ក្នុងរឿងទី ១៣ មានវិនិច្ឆ័យដូច្នេះថា ព្រះថេរីនោះ ឈ្មោះថា ឧប្បលវណ្ណា ជាធីតារបស់សេដ្ឋី ក្នុងក្រុងសាវត្ថី សម្បូរដោយអភិនីហាររាប់សែនកប្ប ។ ដោយប្រក្រតី ព្រះថេរីនោះ មានពណ៌សម្បុរកាយប្រៀបដោយផ្កាឧប្បលខៀវ គួរពេចពិលពន់ពេក ។ ព្រះថេរីនោះ រុងរឿងក្រៃលែង ព្រោះមិនមានការក្តៅក្រហាយដោយកិលេសខាងក្នុង ។ នាងបានឈ្មោះថា ឧប្បលវណ្ណា ព្រោះនាងមានពណ៌សម្បុរស្រស់ស្អាតនោះឯង ។

បទថា **បដិពទ្ធចិត្តោ** សេចក្តីថា មាណពនោះមានចិត្តស្រឡាញ់តាំង

ពីពេលនាងនៅជាគ្រហស្ថ ។ បានឮថា នន្ទមាណពនោះ ជាបុរសកំលោះ ដែលជាញាតិរបស់ព្រះថេរីនោះ ។

សព្ទថា **អជ្ជាខោ** ជានិបាត ចុះក្នុងអត្ថថា លំដាប់ ។ មានពាក្យអធិប្បាយថា ក្នុងលំដាប់នៃព្រះថេរីអង្គុយលើគ្រែនោះឯង ។ ពិតហើយ នៅពេលថ្ងៃ កាលបុគ្គលមកអំពីខាងក្រៅ បិទទ្វារហើយអង្គុយ ការងងឹតទឹងមានឡើង ។ អធិប្បាយថា មាណពនោះ បានធ្វើយ៉ាងនោះអស់កាលដែលការងងឹតនោះរបស់ព្រះថេរីនោះមិនទាន់បាត់ទៅនោះឯង ។

បទថា **ទូសេសិ** ប្រែថា បានប្រទូស្តហើយ ។ ចំណែកព្រះថេរីជាអ្នកមិនមានទោស ផ្តើមតាំងសមណសញ្ញា មិនត្រេកអរ អង្គុយស្ងៀម ត្រូវសេចក្តីប៉ុនប៉ងអសទ្ធម្មប៉ះពាល់ ដូចគំនរភ្លើង សសរថ្ម និងដង្កត់គគីរ ដូច្នោះ ។ ចំណែកនន្ទមាណពកាលឲ្យតម្រេករបស់ខ្លួនសម្រេចបរិបូណ៌ហើយ ក៏ទៅ ។

កាលនន្ទមាណពចេញផុតកន្ទយភ្នែករបស់ព្រះថេរីប៉ុណ្ណោះ មហាប្រឹថពីសូម្បីអាចទ្រទ្រង់ភ្នំសិនេរុទុកបានក៏ដោយ ក៏មិនអាចទ្របុរសអាក្រក់នោះដែលមានសរីរៈប្រមាណមួយព្យាមបាន ទើបញែកចន្លោះឲ្យហើយ ។ ខណៈនោះឯង នន្ទមាណពបានដល់នូវភាពជាចំណីនៃអណ្តាតភ្លើងក្នុងអវិចីហើយ ។ ព្រះដ៏មានព្រះភាគកាលទ្រង់ស្តាប់រឿងនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលមិនត្រេកអរ មិនត្រូវអាបត្តិ ទ្រង់សំដៅយកព្រះថេរី បានត្រាស់គាថានេះក្នុងធម្មបទថា

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ

ដូចទឹកលើស្លឹកឈូក ឬគ្រាប់ស្ពៃលើចុងដែកស្រួច
តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

[ ៥៦ ] ក្នុងរឿងទី ១៤ មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **ឥត្ថីលិង្គំ បាតុភូតំ** សេចក្តីថា កាលភិក្ខុនោះ ឈានចុះកាន់ការដេកលក់ក្នុងពេលយប់ អវយវៈទាំងពួង មានពុកមាត់ពុកចង្កាជាដើម ដែលជាទ្រង់ទ្រាយរបស់បុរស វិនាសទៅ ទ្រង់ទ្រាយរបស់ស្ត្រីកើតឡើងជំនួសវិញ ។

ប្រើនបទថា **តញ្ញេវ ឧបជ្ឈំ តំ ឧបសម្បទំ** សេចក្តីថា តថាគតអនុញ្ញាតឧបជ្ឈាយ៍ ដែលអ្នកធ្លាប់កាន់យកមកហើយ ក្នុងកាលមុននោះឯង ( និង ) ការឧបសម្បទាមានសង្ឃធ្វើទុកក្នុងកាលមុនដូចគ្នា ។ អធិប្បាយថា មិនចាំបាច់កាន់យកឧបជ្ឈាយ៍ថ្មី មិនចាំបាច់ឲ្យឧបសម្បទាជាថ្មី ។

ពីរបទថា **តានិ វស្សានិ** សេចក្តីថា តថាគតអនុញ្ញាតឲ្យរាប់វស្សា ចាប់តាំងអំពីឧបសម្បទាជាភិក្ខុមកនោះឯង ។ អធិប្បាយថា មិនចាំបាច់រាប់វស្សាតាំងអំពីក្លាយភេទនេះទៅឡើយ ។

ពីរបទថា **ភិក្ខុនីហិ សង្គមិតុំ** សេចក្តីថា ទាំងតថាគតអនុញ្ញាតឲ្យភិក្ខុនីនោះទៅជាមួយគ្នា គឺ សមាគមគ្នា ព្រមព្រៀងគ្នាជាមួយភិក្ខុនីទាំង-ឡាយ ។ មានពាក្យអធិប្បាយត្រាស់ទុកដូច្នេះថា ឥឡូវនេះ ភិក្ខុនីនោះមិនគួរនៅក្នុងចំណោមភិក្ខុទាំងឡាយឡើយ ចូរទៅកាន់សម្នាក់ភិក្ខុនី ហើយនៅរួមជាមួយភិក្ខុនីចុះ ។

ប្រើនបទថា **យា អាបត្តិយោ ភិក្ខូនំ ភិក្ខុនីហិ សាធារណា**

សេចក្តីថា អាបត្តិណាជាទេសនាគាមិនីក្តី ជាវុដ្ឋានគាមិនីក្តី ដែលទូទៅដល់ភិក្ខុ និងភិក្ខុនីទាំងឡាយ ។

ត្រង់បទថា **តា អាបត្តិយោ ភិក្ខុនីនំ សន្តិកេ វុដ្ឋាតុំ** សេចក្តីថា តថាគតអនុញ្ញាតឲ្យធ្វើវិនយកម្មដែលពួកភិក្ខុនីគប្បីធ្វើ ហើយចេញចាកអាបត្តិទាំងអស់នោះ ក្នុងសម្នាក់ភិក្ខុនីទាំងឡាយ ។

ត្រង់បទថា **តាហិ អាបត្តីហិ អនាបត្តិ** សេចក្តីថា ចំណែកអាបត្តិពួកណា មានសុក្កវិសដ្ឋិរបស់ពួកភិក្ខុដែលមិនទូទៅដល់ភិក្ខុនីទាំងឡាយ មិនត្រូវអាបត្តិ ព្រោះអាបត្តិទាំងនោះ គឺ អាបត្តិទាំងនោះត្រូវលោកចេញស្រេចហើយ ព្រោះត្រឡប់ភេទ ។ សូម្បីកាលភេទត្រឡប់កើតឡើងទៀត គង់ត្រូវអាបត្តិដល់លោក ដោយអាបត្តិទាំងនោះដូចគ្នា ។ វិនិច្ឆ័យបាលីក្នុងរឿងទី ១៤ នេះ ប៉ុណ្ណេះសិន ។

ចំណែកវិនិច្ឆ័យក្នុងបាលីមុត្តក មានដូច្នេះថា ដំបូង ក្នុងភេទទាំង ២ នេះ បុរសភេទ ជាឧត្តមភេទ ភេទស្រី ជាហីនភេទ ព្រោះហេតុនោះ ភេទប្រុស ទើបឈ្មោះថា អន្តរធានទៅ ព្រោះអកុសលមានកម្លាំងខ្លាំង ភេទស្រីប្រាកដឡើងជំនួស ព្រោះកុសលមានកម្លាំងខ្សោយ ។ ចំណែកភេទស្រីនឹងអន្តរធានទៅ ឈ្មោះថា អន្តរធានទៅ ព្រោះអកុសលមានកម្លាំងខ្សោយចុះ ភេទប្រុសប្រាកដឡើងជំនួស ព្រោះកុសលមានកម្លាំងខ្លាំងក្លា ។ ភេទទាំងពីរអន្តរធានទៅ ព្រោះអកុសល ត្រឡប់បានឡើងវិញ ព្រោះកុសល ដោយប្រការដូច្នេះ ។

## ត្រូវអាបត្តិព្រោះដេករួមជាមួយភិក្ខុត្រឡប់ភេទ

បណ្ដាភេទស្រី និងភេទប្រុសនោះ បើភិក្ខុពីរអង្គធ្វើការស្វាធ្យាយ ឬសន្ទនាធម៌ជាមួយគ្នា ដេកលក់ទៅក្នុងកុដិជាមួយគ្នា ភេទស្រីប្រាកដដល់ភិក្ខុមួយអង្គ អាបត្តិត្រូវមានដល់លោកទាំងពីរនោះ ព្រោះដេករួមគ្នា ។ បើភិក្ខុក្លាយភេទនោះភ្ញាក់ឡើង ឃើញអាការប្លែកនោះរបស់ខ្លួនហើយ មានសេចក្ដីទុក្ខទោមនស្ស គប្បីប្រាប់ដល់ភិក្ខុមួយអង្គទៀត ក្នុងកណ្ដាលរាត្រីនោះឯង លោកចូរជាអ្នកដែលភិក្ខុនោះគួរលួងលោមថា កុំទោមនស្សឡើយ នេះជាទោសរបស់វដ្តៈទេតើ ព្រះសម្មាសម្ពុទ្ធក៏បានប្រទានឱកាសទុកហើយថា ទោះជាភិក្ខុ ឬភិក្ខុនីក៏ដោយ ធម្មតាធម៌មិនបានកំណត់ ឬហាមផ្លូវសួគ៌ ផ្លូវនិព្វានឡើយ ។

## វិធីបដិបត្តិជាមួយភិក្ខុនីត្រឡប់ភេទ

កាលលួងលោមហើយ គួរពោលយ៉ាងនេះថា សមគួរអ្នកនឹងទៅកាន់សម្នាក់ភិក្ខុនី ភិក្ខុនីអង្គខ្លះដែលជាមិត្តធ្លាប់ឃើញគ្នារបស់អ្នកមានដែរឬ បើលោកមានពួកភិក្ខុនីដូច្នោះ គប្បីប្រាប់ថា មាន បើមិនមានគប្បីប្រាប់ថា មិនមាន ហើយគប្បីប្រាប់ភិក្ខុនោះថា លោកមេត្តាសង្គ្រោះខ្ញុំចុះ សូមនាំខ្ញុំទៅកាន់សម្នាក់ភិក្ខុនីឥឡូវនេះឯង ។ ភិក្ខុនោះ គប្បីនាំលោកទៅកាន់សម្នាក់របស់ភិក្ខុនីទាំងឡាយដែលជាមិត្តធ្លាប់ឃើញគ្នារបស់លោក ឬជាមិត្តធ្លាប់ឃើញគ្នារបស់ខ្លួនក៏បាន កាលបើទៅ មិនគួរទៅមួយអង្គឯង គួរកាន់យកចង្កៀង និងឈើច្រត់ ដោយការបបួលចេញទៅរួមជាមួយភិក្ខុ ៤-៥ អង្គ ដោយពោលថា ពួកយើងនឹងទៅកាន់ទីកន្លែងឈ្មោះនោះ ។

បើខាងក្រៅស្រុក មានវត្តនៅឆ្ងាយ ក៏មិនត្រូវអាបត្តិក្នុងរវាងផ្លូវ ព្រោះគាមន្តរាបត្តិ ( អាបត្តិព្រោះដើរឆ្លងកាត់ស្រុកមួយ ) នទីបារាបត្តិ ( អាបត្តិព្រោះឆ្លងទៅត្រើយ ) រត្តិវិប្បវាសាបត្តិ ( អាបត្តិព្រោះនៅប្រាសចាកត្រៃចីវរអស់រាត្រី ) និងគណាឱហីយនាបត្តិ ( អាបត្តិព្រោះនៅមួយអង្គឯង មិនគ្រប់គណៈ ) ។ កាលទៅដល់សម្នាក់របស់ភិក្ខុនីហើយ គប្បីពោលនឹងភិក្ខុនីទាំងនោះថា នាងទាំងឡាយស្គាល់ភិក្ខុឈ្មោះនោះឬ ភិក្ខុនីទាំងឡាយឆ្លើយថា ខ្ញុំព្រះករុណាស្គាល់ លោកម្ចាស់ ភិក្ខុទាំងនោះគប្បីពោលថា ភិក្ខុអង្គនោះក្លាយភេទជាស្រី សូមមេត្តាសង្គ្រោះលោកផងចុះ ។ បើភិក្ខុនីទាំងនោះពោលថា សាធុ លោកម្ចាស់ ឥឡូវនេះ ពួកខ្ញុំនឹងស្វាធ្យាយ នឹងស្តាប់ធម៌ សូមលោកម្ចាស់ទាំងឡាយទៅចុះ ដូច្នេះហើយ ធ្វើការសង្គ្រោះផង ឲ្យត្រេកអររីករាយផង ជាលជ្ជិនីអ្នកមានការសង្គ្រោះផង នាងមិនគួរលះចោលភិក្ខុនីទាំងនោះ ទៅក្នុងទីដទៃឡើយ បើទៅក៏មិនផុតអំពីគាមន្តរាបត្តិ នទី-បារាបត្តិ រត្តិវិប្បវាសាបត្តិ និងគណាឱហីយនាបត្តិ ។

ម្យ៉ាងទៀត បើភិក្ខុនីនោះ ជាលជ្ជនី តែមិនមានការសង្គ្រោះ រមែងបានដើម្បីនឹងទៅក្នុងទីកន្លែងដទៃ ។ បើជាអលជ្ជនី ( ពេញមួយវគ្គ ) តែធ្វើការសង្គ្រោះ រមែងបានដើម្បីនឹងលះបង់ភិក្ខុនីទាំងនោះ ហើយទៅក្នុងទីដទៃ ។ អាចារ្យពួកខ្លះពោលថា បើលជ្ជនីផង មានការសង្គ្រោះផង តែមិនជាញាតិនិងក្នុងស្រុកជិត ភិក្ខុនីពួកដទៃដែលជាញាតិមាន ទាំងជាអ្នកផ្គត់ផ្គង់ គួរទៅកាន់សម្នាក់របស់ភិក្ខុនីទាំងនោះ កាលទៅហើយ បើខ្លួនបដិបត្តិនិស្ស័យ

( កាន់យកនិស្ស័យ ) ក្នុងគ្រាជាភិក្ខុ ក៏គួរកាន់យកនិស្ស័យក្នុងសម្នាក់របស់ភិក្ខុនីតាមសមគួរ ។ មាតិកាក្ដី វិន័យក្ដី ដែលរៀនមកហើយ គឺជាការរៀនដោយល្អ មិនមានហេតុដែលនឹងត្រូវរៀនជាដែលទៀត ។ បើក្នុងគ្រាជាភិក្ខុ ភិក្ខុអង្គនោះជាអ្នកគ្រប់គ្រងបរិស័ទ កុលបុត្រទាំងឡាយ ដែលឧបសម្បទាហើយក្នុងសម្នាក់របស់ភិក្ខុអង្គនោះឯង ក៏ជាការឧបសម្បទាប្រពៃហើយ តែត្រូវកាន់យកនិស្ស័យក្នុងសម្នាក់របស់អាចារ្យអង្គដទៃ ។ សូម្បីពួកអន្តេវាសិកដែលអាស្រ័យលោកក្នុងកាលមុន ក៏ត្រូវកាន់យកនិស្ស័យក្នុងសម្នាក់របស់អាចារ្យអង្គដទៃ ។ សូម្បីសាមណេរមានអាយុពេញបរិបូណ៌ ក៏ត្រូវកាន់ឧបជ្ឈាយ៍ក្នុងសម្នាក់របស់ភិក្ខុអង្គដទៃ ។

# វិធីបដិបត្តិក្នុងគ្រឿងបរិក្ខារផ្សេងៗ

ម្យ៉ាងទៀត ត្រៃចីវរ និងបាត្រដែលភិក្ខុនោះអធិដ្ឋានទុកហើយ ក្នុងកាលនៅជាភិក្ខុ រមែងដាច់អធិដ្ឋាន ត្រូវអធិដ្ឋានជាថ្មី ។ ភិក្ខុនីគួរឲ្យសំពត់ចោមពុង និងសំពត់ងូតទឹក ។ អតិរេកចីវរក្ដី អតិរេកបាត្រក្ដី ដែលភិក្ខុនោះធ្វើវិនយកម្មរក្សាទុកហើយទាំងអស់ រមែងលះវិនយកម្មទៅ ត្រូវធ្វើជាថ្មី ។ សូម្បីភេសជ្ជៈ មានប្រេង ទឹកឃ្មុំ និងទឹកអំពៅដែលលោកទទួលប្រគេនទុកជាដើម រមែងដាច់ប្រគេនទៅ ។ បើក្លាយភេទក្នុងថ្ងៃទី ៧ អំពីថ្ងៃដែលទទួលប្រគេនទៅ គួរទទួលប្រគេនជាថ្មី គួរឆាន់បាន ៧ ដង ។ ចំណែកវត្ថុរបស់ភិក្ខុដទៃ លោកទទួលប្រគេនទុកក្នុងវេលាជាភិក្ខុ វត្ថុនោះមិនដាច់ប្រគេនឡើយ សូម្បីវត្ថុណាដែលជារបស់ទូទៅដល់ភិក្ខុពីរអង្គ ដែលមិនទាន់បាន

ចែកគ្នា បកតត្តភិក្ខុ រមែងរក្សាវត្ថុនោះទុក ។ ចំណែកវត្ថុណាចែកគ្នាហើយ ជារបស់លោក វត្ថុនោះរមែងដាច់ប្រគេនទៅ មែនពិត ព្រះដ៏មានព្រះភាគ ក៏ត្រាស់ពាក្យនេះ ទុកក្នុងគម្ពីរបរិវារថា

ភិក្ខុទទួលប្រេង ទឹកឃ្មុំ ទឹកអំពៅ និងទឹកដោះថ្លា
ហើយទុកដាក់ដោយខ្លួនឯង ទុកជាមិនទាន់កន្លង ៧ ថ្ងៃ
នៅឡើយ កាលបើមានបច្ច័យ ហើយធាន់ ត្រូវអាបត្តិ
ប្រស្នានេះពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

## ការដាច់ប្រគេនព្រោះហេតុ ៧ យ៉ាង

ពិតហើយ ព្រះពុទ្ធវចនៈនេះ ព្រះដ៏មានព្រះភាគត្រាស់សំដៅយកការត្រឡប់ភេទ ។ ឈ្មោះថា ការទទួលប្រគេនរមែងដាច់ទៅ ព្រោះត្រឡប់ភេទ ១ ព្រោះមរណភាព ១ ព្រោះលាសិក្ខា ១ ព្រោះបែរទៅជាបុគ្គលថោកទាប ១ ព្រោះឲ្យដល់អនុបសម្បន្ន ១ ព្រោះដាច់អាល័យ ១ ព្រោះត្រូវដណ្តើមយកទៅ ១ ព្រោះដូច្នោះ បើមានវត្ថុដែលទទួលប្រគេនទុក ជាចំណិតសម៉ក្តី វត្ថុទាំងអស់របស់លោក រមែងដាច់ប្រគេនទៅ ម្យ៉ាងទៀត វត្ថុណានីមួយ ដែលជារបស់ភិក្ខុនីនោះ លោកទទួលប្រគេន ឬមិនទាន់បានទទួលប្រគេនក៏ដោយ ដែលរក្សាទុកក្នុងវិហាររបស់ភិក្ខុ ភិក្ខុនីអង្គនោះឯង ជាធំលើវត្ថុទាំងនោះ គួរឲ្យលោកជញ្ជូនយកទៅចុះ ។ ចំណែករបស់ណាដែលជាថាវរវត្ថុ ដែលជារបស់ផ្ទាល់ខ្លួនរបស់លោក ក្នុងវិហាររបស់ភិក្ខុនេះ ទោះជាសេនាសនៈក្តី ឬដើមឈើដែលដាំទុកក្តី លោកប្រាថ្នានឹងឲ្យរបស់ទាំងនោះដល់បុគ្គលណា ក៏គប្បី

ឲ្យដល់បុគ្គលនោះ ។

បណ្ដាសម្មុតិ ១៣ យ៉ាង សម្មុតិដែលនាងបានក្នុងវេលាជាភិក្ខុរមែងរម្ងាប់ទៅទាំងអស់ ។ ការកាន់យកសេនាសនៈក្នុងថ្ងៃចូលវស្សាដំបូង រមែងរម្ងាប់ទៅ ។ បើក្លាយភេទក្នុងកាលលោកកាន់យកសេនាសនៈ ក្នុងថ្ងៃចូលវស្សាលើកទី ២ ( បច្ឆិមិកវស្សា ) ហើយ ភិក្ខុសង្ឃប្រាថ្នានឹងឲ្យលាភដែលកើតឡើងដល់លោក គួរអបលោកឲ្យ ។ បើក្លាយភេទកាលកំពុងនៅបរិវាស ដើម្បីអាបត្តិដែលបិទបាំងទុកទូទៅនឹងភិក្ខុនី សង្ឃគប្បីឲ្យបក្ខមានត្តនោះឯង ។ បើក្លាយភេទកំពុងប្រព្រឹត្តមានត្ត គួរឲ្យបក្ខមានត្តដដែលទៀត បើក្លាយភេទកាលប្រព្រឹត្តមានត្តហើយ ពួកភិក្ខុនីគួរធ្វើអព្ភានកម្ម ។ បើអកុសលវិបាកអស់ហើយ ភេទត្រឡប់ថ្មីទៀត ក្នុងកាលនៃបក្ខមានត្ត គប្បីឲ្យមានត្ត ៦ រាត្រីប៉ុណ្ណោះ ។ បើប្រព្រឹត្តបក្ខមានត្តស្រេចហើយ ទើបភេទត្រឡប់ពួកភិក្ខុគប្បីធ្វើអព្ភានកម្មដូច្នេះឯង ។

ក្នុងរឿងត្រឡប់ភេទរបស់ភិក្ខុនីក្នុងលំដាប់តទៅ គប្បីជ្រាបវិនិច្ឆ័យទាំងពួងតាមន័យដែលពោលហើយ ក្នុងរឿងនេះនោះឯង ។ ចំណែកសេចក្ដីដែលប្លែកគ្នា មានដូច្នេះថា បើក្នុងវេលាជាភិក្ខុនី មានសញ្ចរិតអាបត្តិ ដែលត្រូវហើយ និងបាំងទុក មិនមានការឲ្យបរិវាស គប្បីឲ្យមានត្ត ៦ រាត្រីនោះឯង ។ បើក្លាយភេទកំពុងប្រព្រឹត្តបក្ខមានត្ត មិនត្រូវការដោយបក្ខមានត្តនោះ គប្បីឲ្យមានត្ត ៦ រាត្រីដូចគ្នា ។ បើក្លាយភេទ កាលប្រព្រឹត្តស្រេចហើយ មិនត្រូវឲ្យមានត្តដដែលទៀតឡើយ ភិក្ខុទាំងឡាយគប្បីធ្វើអព្ភាន ។ បើភិក្ខុទាំង-

ឡាយមិនទាន់ឲ្យមានត្ត ក្លាយភេទឡើងជាថ្មី ពួកភិក្ខុនីគប្បីឲ្យបក្ខមានត្តនោះឯង ។ បើកំពុងប្រព្រឹត្តមានត្ត ៦ រាត្រី ក្លាយភេទជាថ្មី គប្បីឲ្យបក្ខមានត្តដូចគ្នា ។ តែកាលប្រព្រឹត្តស្រេចហើយ ក្លាយភេទដូចដើម ពួកភិក្ខុនីគប្បីធ្វើអព្ភានឲ្យ ។ ម្យ៉ាងទៀត បើភិក្ខុនីនោះ តាំងនៅក្នុងភាពជាភិក្ខុនី ក្នុងកាលក្លាយភេទ គឺទៅជាសភាពដើមហើយ អាបត្តិពួកណាដែលរម្ងាប់ទៅហើយក្នុងកាលមុន អាបត្តិទាំងនោះ គឺរម្ងាប់ហើយដោយល្អនោះឯង ។

[ ៥៧ ] រឿងទាំង ៤ បន្ទាប់អំពីក្លាយភេទនេះទៅ មានជាដើមថា **មាតុយា មេថុនំ ធម្មំ** នេះ មានអត្ថជាក់ច្បាស់ហើយទាំងអស់ ។

[ ៥៨ ] ក្នុងរឿងភិក្ខុមានខ្នងទន់ មានវិនិច្ឆ័យដូច្នេះថា បានឮថា ភិក្ខុអង្គនោះ ធ្លាប់ជាអ្នករបាំ ខ្នងរបស់លោកបានហ្វឹកហាត់មកហើយ ដើម្បីភាពជាអ្នកឈ្លាសក្នុងសិប្បៈ ទើបមានអវយវៈទន់ ព្រោះដូច្នោះ ទើបលោកអាចធ្វើកម្មយ៉ាងនេះ ។

រឿងភិក្ខុមានអង្គជាតវែង មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអង្គនោះមានអង្គ-ជាតវែង ព្រោះដូច្នោះ ទើបលោកហៅថា **លម្ពី** ប្រែថា អ្នកមានអង្គជាតវែង ។

[ ៥៩ ] រឿងមុខដំបៅ ២ រឿង បន្ទាប់អំពីរឿងភិក្ខុមានអង្គជាតវែងនេះទៅ មានអត្ថជាក់ច្បាស់ហើយ ។

[ ៦០ ] ក្នុងរឿងរូបគំនូរ មានវិនិច្ឆ័យដូច្នេះថា រូបដែលធ្វើដោយចិត្រកម្ម ឈ្មោះថា **លេបចិត្ត** គឺរូបគំនូរ ។

ក្នុងរឿងរូបចម្លាក់ឈើ មានវិនិច្ឆ័យដូច្នេះថា រូបដែលគេធ្វើដោយឈើ

ឈ្មោះថា រូបចម្លាក់ ។ បើព្យាយាមក្នុងរូបចិត្រកម្ម និងរូបចម្លាក់ឈើទាំងពីរនេះ ត្រូវអាបត្តិទុក្កដ យ៉ាងណា បើព្យាយាមដោយតម្រេកក្នុងមេថុនត្រង់និមិត្តក្នុងរូបស្រី ដែលជាអនុបាទិន្នកៈ ( រូបដែលមិនមានចិត្តគ្រប់គ្រង ) មានរូបធ្វើដោយភ្លុកដំរី រូបគំនូរ និងរូបលោហៈជាដើម អសុចិនឹងឃ្លាតចេញ ឬមិនចេញក៏ដោយ ត្រូវអាបត្តិទុក្កដនោះឯង ។ សូម្បីព្យាយាមដោយតម្រេកក្នុងការអង្អែល ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។ តែបើព្យាយាមដោយតម្រេកក្នុងការបញ្ចេញ បើអសុចិឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស បើមិនឃ្លាតចេញ ត្រូវអាបត្តិថុល្លច្ច័យ ដូច្នេះឯង ។

## រឿង ភិក្ខុឈ្មោះសុន្ទរៈ

[ ៦១ ] ក្នុងរឿងសុន្ទរភិក្ខុ មានវិនិច្ឆ័យដូច្នេះថា មានភិក្ខុមួយអង្គឈ្មោះសុន្ទរៈ ជាយុវជនកំលោះរបស់ត្រកូល ក្នុងក្រុងរាជគ្រឹះ បួសដោយសទ្ធា ព្រោះលោកមានរូបស្អាត ទើបបានឈ្មោះថា សុន្ទរៈ ។ ស្រីម្នាក់នោះឃើញលោកកំពុងដើរទៅតាមផ្លូវរថ ក៏កើតឆន្ទរាគៈឡើង ហើយបានធ្វើអាការដែលប្លែកនេះ ។ ចំណែកព្រះថេរៈ ជាព្រះអនាគាមី ព្រោះហេតុនោះ ទើបលោកមិនត្រេកអរ ។ សភាព គឺការមិនត្រេកអរនេះ មិនមែនវិស័យនៃបុថុជ្ជនដទៃៗ ឡើយ ។

[ ៦២ ] ក្នុងរឿង ៤ បន្ទាប់ពីរឿងសុន្ទរភិក្ខុនេះទៅ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុទាំងនោះ ជាមនុស្សល្ងង់ខ្លៅ ស្តាប់ពាក្យរបស់មាតុគ្រាមហើយ ធ្វើតាមយ៉ាងនោះ ក្រោយមក ទើបមានសេចក្តីរង្កៀសឡើង ។ ៣ រឿង មាន

រឿងសាកសព ដែលសត្វមិនទាន់បានកកេរស៊ីជាដើម មានអត្ថជាក់ច្បាស់ហើយ ទាំងអស់ ។

[ ៦៣ ] ក្នុងរឿងសាកសព ដាច់ក្បាល ២ រឿង មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **វិដ្ដករតេ មុខេ** គឺក្នុងមាត់ដែលហា ។ ភិក្ខុកាលស៊កអង្គជាតចូលទៅ ( ក្នុងមាត់ដែលហានោះ ) បើស៊កចូលទៅឲ្យត្រូវខាងក្រោមក្ដី ខាងលើក្ដី ខាងចំហៀងទាំងពីរក្ដី ត្រូវអាបត្តិបារាជិក ។ កាលស៊កចូលទៅមិនត្រូវស្ថានទាំង ៤ តែត្រូវពិតានខាងក្នុង ត្រូវអាបត្តិបារាជិកដូចគ្នា ។ កាលមិនត្រូវស្ថានទាំង ៤ និងពិតាន សំយុងក្នុងអាកាសប៉ុណ្ណោះ ហើយដកចេញ ត្រូវអាបត្តិទុក្កដ ។ ម្យ៉ាងទៀត បើធ្មេញបិទជិតល្អ ខាងក្នុងមាត់មិនមានប្រហោង ហើយធ្មេញត្រូវសាច់បបូរមាត់ខាងក្រៅបិទជិត បើភិក្ខុស៊កចូលទៅទីកាន់ដែលសើម ដែលខ្យល់មិនត្រូវ ក្នុងមាត់ដែលមានបបូរមាត់បិទទុកនោះ សូម្បី ១គ្រាប់ល្ង ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។ តែកាលព្យាយាមចំពោះធ្មេញ ដែលមានសាច់បបូរមាត់ត្រូវគេចៀរចេញទៅហើយ ត្រូវអាបត្តិថុល្លច្ច័យ សូម្បីធ្មេញក្រាសណា ដែលលៀនចេញមកខាងក្រៅ មិនអាចបិទបបូរមាត់បាន កាលភិក្ខុព្យាយាមត្រង់ធ្មេញនោះក្ដី ព្យាយាមត្រង់អណ្ដាតដែលលៀនចេញទៅខាងក្រៅក្ដី ត្រូវអាបត្តិថុល្លច្ច័យដូចគ្នា ។ សូម្បីក្នុងសរីរៈដែលនៅមានជីវិត ការព្យាយាមត្រង់អណ្ដាតដែលលៀនចេញទៅខាងក្រៅ ត្រូវថុល្លច្ច័យដូចគ្នា ។ តែបើអណ្ដាតលៀនចេញមកខាងក្រៅ បាំងធ្មេញជិតហើយ ទើបភិក្ខុស៊កអង្គជាតចូលទៅក្នុងមាត់ ត្រូវអាបត្តិបារាជិកដូចគ្នា ។

កាលសឹកអង្គជាតចូលទៅតាមបំពង់ក អំពីខាងក្រោមនៃក្បាលសាកសពដែលដាច់ប៉ះដល់ពិតាន ត្រូវអាបត្តិបារាជិកដូចគ្នា ។

ក្នុងរឿងឆ្អឹង មានវិនិច្ឆ័យដូច្នេះថា កាលភិក្ខុកំពុងដើរទៅកាន់ស្មសាន ត្រូវអាបត្តិទុក្កដ កាលប្រមូលឆ្អឹងមកទុកក្តី គរទុកក្តី ព្យាយាមត្រង់និមិត្តដោយតម្រេកក្នុងមេថុនក្តី ព្យាយាមដោយតម្រេកក្នុងការស្ទាបអង្អែលកាយក្តី អសុចិឃ្លាតចេញ ឬមិនឃ្លាតក្តី ត្រូវអាបត្តិទុក្កដទាំងអស់ តែបើព្យាយាមដោយតម្រេកក្នុងការបញ្ចេញ កាលអសុចិឃ្លាតចាកទី ត្រូវអាបត្តិសង្ឃាទិសេស កាលមិនឃ្លាតចេញ ត្រូវអាបត្តិថុល្លច្ច័យ ។

[ ៦៤ ] ក្នុងរឿងនាគញី មានវិនិច្ឆ័យដូច្នេះថា កាលភិក្ខុសេពមេថុនធម្មក្នុងជំពូកសត្វទាំងពួង ទោះជានាគមាណវិកា ឬបណ្ឌាកិន្នរីជាដើម ណាមួយក្តី ត្រូវអាបត្តិបារាជិក ។

ក្នុងរឿងយក្ខិនី មានវិនិច្ឆ័យដូច្នេះថា ទេវតាទាំងអស់ គឺយក្ខិនីនោះឯង ។

ក្នុងរឿងស្រីប្រេត មានវិនិច្ឆ័យដូច្នេះថា ប្រេតទាំងឡាយ មាននិជ្ឈាមតណ្ហិកប្រេតជាដើម បុគ្គលណាមួយមិនអាចពាល់ត្រូវបាន ។ តែនាងវេមានិកប្រេតទាំងឡាយមាន អកុសលកម្មរបស់នាងវេមានិកប្រេតពួកណាឲ្យផលក្នុងកាឡបក្ខ នាងវេមានិកប្រេតទាំងនោះ រមែងបានសោយសម្បត្តិ ក្នុងជុណ្ហបក្ខ ដូចទេវតា ដូច្នោះ ។ បើការឃើញ ការចាប់ពាល់ ការស្ទាបអង្អែល ការបបោស ការប៉ះពាល់របស់ស្រីប្រេត ឬរបស់យក្ខិនី ដែលមានសភាពបែបនោះប្រាកដបាន ត្រូវអាបត្តិបារាជិក ។ បើមើលមិនឃើញ តែកិច្ចក្រៅ

ពីនេះប្រាកដ ត្រូវអាបត្តិបារាជិកដូចគ្នា ។

ម្យ៉ាងទៀត ការឃើញ និងការចាប់មិនប្រាកដ តែប្រេតធ្វើបុគ្គលនោះ ( គឺភិក្ខុ ) ឲ្យប្រាសចាកសញ្ញា ( គ្មានសតិ ) ដោយការស្ទាបអង្អែល ពាល់ត្រូវ និងប៉ះពាល់ដែលប្រាកដ ឲ្យសម្រេចមនោរថរបស់ខ្លួន ហើយក៏ទៅ សេចក្ដីព្យាយាមនេះ ឈ្មោះថា មិនមែនវិស័យ ដូច្នោះ ក្នុងសេចក្ដីនេះ ទើបមិនត្រូវអាបត្តិ ព្រោះមិនមែនជាវិស័យ ។

រឿងខ្ទើយប្រាកដច្បាស់ហើយ ។

[ ៦៥ ] ក្នុងរឿងភិក្ខុមានកាយស្ពឹក មានវិនិច្ឆ័យដូច្នេះថា បទថា **ឧប-ហតិន្ទ្រិយោ** សេចក្ដីថា លោកមានកាយបសាទត្រូវរោគបៀតបៀនហើយ មិនដឹងសុខ និងទុក្ខ ដូចជគ្គត់ឈើ និងកំណាត់ឈើ ដូច្នោះ ។ កាលលោកមិនដឹង ក៏ត្រូវអាបត្តិ ព្រោះអំណាចសេវនចិត្ត ។

[ ៦៦ ] ក្នុងរឿងចាប់មាតុគ្រាមប្រុងនឹងសេព មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអង្គណា គិតក្នុងចិត្តថា អញនឹងសេពមេថុនធម្ម ទើបចាប់មាតុគ្រាម កំពុងចាប់នោះឯង ក៏ប្រាសចាកក្នុងតម្រេកក្នុងមេថុន ហើយជាអ្នកមានវិប្បដិសារៈ ភិក្ខុអង្គនោះត្រូវអាបត្តិទុក្កដ ព្រោះថា កិច្ចទាំងឡាយ មានការចាប់ដៃជាដើម ជាបុព្វយោគនៃមេថុន រមែងតាំងនៅក្នុងទុក្កដ ដរាបដែលមិនទាន់ដល់ទីបំផុត បើដល់ទីបំផុតហើយ ទើបជាបារាជិក ។ ពិតហើយ ទុក្កដប៉ុណ្ណោះរងចំពោះបឋមបារាជិក ។ បណ្ដាអាបត្តិទាំង ៣ ក្រៅអំពីនេះ ( ទុក្កដ ថុល្លច្ច័យ សង្ឃាទិសេស ) ថុល្លច្ច័យ ក៏រងចំពោះបឋមបារាជិក ចំណែកភិក្ខុអង្គនេះ

ប្រាសចាកតម្រេកក្នុងមេថុនធម្មហើយ គប្បីជ្រាបថា ត្រេកអរចំពោះការស្ទាប អង្អែលកាយ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ត្រូវអាបត្តិសង្ឃាទិសេស ។

[ ៦៧ ] ក្នុងរឿងភិក្ខុអ្នកក្រុងកទ្ទិយៈ មានវិនិច្ឆ័យដូច្នេះថា នគរឈ្មោះថា កទ្ទិយៈ ។ នគរនោះបានឈ្មោះយ៉ាងនេះ ព្រោះមានគុម្ពផ្កាម្ទិះជាតិ ដែលឈ្មោះថា ជាតិយាវនៃសន្ទឹកសន្ទាប់ ។ ព្រៃនោះនៅជិតឧបចារៈនៃព្រះនគរនោះ ។ ភិក្ខុអង្គនោះ សិងត្រង់ព្រៃនោះ ហើយឈានចុះកាន់និទ្រាស៊ប់ ព្រោះត្រូវខ្យល់បក់រំភើយៗ នោះ ។ កវង្គចិត្ត មានក្រសែមួយប៉ុណ្ណោះប្រព្រឹត្តទៅ ។

ពីរបទថា **កិលិន្នំ បស្សិត្វា** សេចក្តីថា ឃើញអង្គជាតប្រឡាក់ប្រឡូសដោយអសុចិ ។

[ ៦៨ ] ៥ រឿង បន្ទាប់អំពីរឿងភិក្ខុក្រុងកទ្ទិយៈនេះទៅ គឺរឿងដែលបដិសំយុត្តដោយការត្រេកអរមាន ៤ រឿង និងរឿងដែលមិនដឹងខ្លួនមាន ១ រឿង មានអត្ថជាក់ច្បាស់ហើយនោះឯង ។

[ ៦៩ ] ក្នុងរឿងមិនត្រេកអរ ២ រឿងទៀត មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **សហសា វុដ្ឋាសិ** សេចក្តីថា ភិក្ខុអង្គនោះ ប្រញាប់ក្រោកឡើងភ្លាមដូចត្រូវអាសិរពិសខាំ និងដូចត្រូវភ្លើងឆេះ ដូច្នោះ ។

ពីរបទថា **អក្កមិត្វា បវដ្ដេសិ** សេចក្តីថា ភិក្ខុអ្នកមិនប្រមាទ ផ្តើមចម្រើនវិបស្សនា គ្រប់គ្រងសតិទុកចំពោះមុខ ប្រញាប់ក្រោកឡើងមួយរំពេចប្រានឲ្យរមៀលធ្លាក់ទៅលើផែនដី កល្យាណបុថុជ្ជនទាំងឡាយ គួររក្សាចិត្ត

ទុកក្នុងឋានៈបែបនេះ ។ ឯភិក្ខុអង្គនេះ ជាកល្យាណបុថុជ្ជន ក្នុងបណ្តាភិក្ខុអង្គណាមួយ ដែលដូចជាកំពូលនៃអ្នកចម្បាំងក្នុងសង្គ្រាម ។

[៧០] ក្នុងរឿងបើកទ្វារដេក មានវិនិច្ឆ័យដូច្នេះ ពីរបទថា **ទិវា បដិសល្លិយន្តេន** សេចក្តីថា ដែលសម្រាកសិងក្នុងពេលថ្ងៃ ។

ប្រើនបទថា **ទ្វារំ សំវរិត្វា បដិសល្លិយិតុំ** សេចក្តីថា ដើម្បីឲ្យបិទទ្វារមុន ទើបសិងបាន ។ ក្នុងរឿងបើកទ្វារសិងនេះ ក្នុងព្រះបាលី ព្រះដ៏មានព្រះភាគមិនបានដាក់អាបត្តិទុកថា ជាអាបត្តិឈ្មោះនេះក៏ពិត សូម្បីយ៉ាងនោះ ព្រះថេរៈទាំងឡាយ ក៏កាត់អាបត្តិទុក្កដដល់ភិក្ខុមិនបិទទ្វារមុនសម្រាក ព្រោះកាលរឿងកើតឡើង ព្រោះទោសដែលបើកទ្វារសិង ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុសម្រាកពេលថ្ងៃ បិទទ្វារជាមុនសិន ទើបសម្រាកបាន ។

ពិតហើយ ព្រះថេរៈទាំងឡាយ មានព្រះឧបាលិត្ថេរជាដើម ជ្រាបបំណងរបស់ព្រះដ៏មានព្រះភាគហើយ ទើបតាំងអដ្ឋកថាទុក ។ ឯពាក្យថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលមិនបិទទ្វារជាមុន ហើយសម្រាកនេះ សម្រេចហើយដោយពាក្យនេះថា មានអាបត្តិ ដែលភិក្ខុត្រូវពេលថ្ងៃ មិនត្រូវក្នុងពេលយប់ ។

# ទ្វារដូចម្តេចគួរបិទ និងមិនគួរបិទ

សួរថា ឯទ្វារដូចម្តេចគួរបិទ ទ្វារដូចម្តេចមិនគួរបិទ ឆ្លើយថា ទ្វារវិលដែលគេយកបណ្តាវត្ថុប្រភេទណាមួយ មានបន្ទះក្តារ បន្ទះឫស្សី កន្ទេល និង

ស្លឹកឈើជាដើមធ្វើជាបន្ទះទ្វារ ហើយខាងក្រោមនុកមេទ្វារ ទុកក្នុងដំណាប់ ខាងលើនុកមេទ្វារទុកក្នុងក្រវិលលើនោះឯង គួរបិទ ។ ទ្វារប្រភេទដទៃបែប នេះ គឺទ្វារគន្លឹះឈើ និងទ្វារបន្ទាត្រង់ក្រោលគោ ទ្វារមានកង់រំកិលសម្រាប់ ការពារផ្ទះក្នុងស្រុក ទ្វារកង់វិលដែលគេធ្វើប្រកបកូនកង់ ២-៣ ដែលទុកត្រង់ បន្ទះក្តារ ឬត្រង់ប្រជីស ( ត្បាញដោយរនាប ) ទ្វារប្រជីសទល់ឡើងដែល គេធ្វើលើកទល់បាន ដូចក្នុងរានផ្សារ ទ្វារដែលគេខ្ទាស់បន្ទះឫស្សីទុកក្នុងទី ២-៣ កន្លែង ត្រង់បណ្ណកុដិ ( ខ្ទមស្បូវ ) និងទ្វាររាំងនន មិនគួរបិទ ។

ទ្វាររាំងននមួយប៉ុណ្ណោះ មិនធ្វើឲ្យត្រូវអាបត្តិ ក្នុងវេលាដែលភិក្ខុ មាន បាត្រត្រង់ដៃប្រានទ្វារចូលទៅ កាលប្រានទ្វារដទៃ ប្រព្រឹត្តជាអាបត្តិ ។ តែ ទ្វារវិលនោះឯង ធ្វើឲ្យត្រូវអាបត្តិដល់ភិក្ខុដែលសម្រាកក្នុងពេលថ្ងៃ ។ ទ្វារដ៏ សេស ទោះភិក្ខុបិទក្តី មិនបិទក្តី ហើយសិង មិនត្រូវអាបត្តិ តែគួរបិទជាមុន សឹមសិង សេចក្តីនេះ ជាទំនៀម ។ សួរថា ឯទ្វារវិល រមែងជាការបិទល្អ ហើយ ដោយហេតុមានប្រមាណប៉ុន្មាន ឆ្លើយថា កាលដាក់គន្លឹះ និងស្នៀត ហើយ ក៏ជាការបិទដោយល្អនោះឯង ។ ម្យ៉ាងទៀត សូម្បីកាលដាក់ត្រឹមតែ គន្លឹះ ហើយសិងក៏គួរ ។ សូម្បីដាក់ត្រឹមតែនុក ហើយសិងក៏គួរ កាលបិទ ល្មមឲ្យបន្ទះទ្វារទល់គ្នាហើយ សិងក៏គួរ កាលបិទបង្អើបទុកបន្តិចបន្តួច ហើយ សិងក៏គួរ ដោយហោចសូម្បីកាលបិទទ្វារបង្អើបទុក ល្មមក្បាលចូលមិនបាន សិងក៏គួរ ដូច្នេះឯង ។

បើទីកន្លែងនោះមានច្រើនគ្នា សូម្បីពោលនឹងភិក្ខុ ឬសាមណេរថា

អាវុសោ ចូរជួយរក្សាទ្វារផង ហើយសិងក៏គួរ បើធ្វើការចងចិត្តថា ភិក្ខុទាំងឡាយដែលអង្គុយធ្វើចីវរកម្ម ឬកិច្ចអ្វីដទៃ លោកទាំងនោះនឹងជួយរក្សាទ្វារនោះ ដូច្នេះ ហើយសិងក៏គួរ ។

ចំណែកក្នុងអដ្ឋកថាកុរុន្ទី លោកពោលថា នឹងប្រាប់ឧបាសក ឬធ្វើការតាំងចិត្តទុកថា ឧបាសកនេះនឹងជួយរក្សា ហើយសិងក៏គួរ នឹងប្រាប់ភិក្ខុនី ឬមាតុគ្រាម មិនគួរ ។

បើកង់ ឬត្រចៀកទ្វារខូចទៅ ឬគេមិនបានប្រកបទុក ទើបមិនអាចនឹងបិទបាន ម្យ៉ាងទៀត ដើម្បីប្រយោជន៍ដល់នវកម្ម គេធ្វើគំនរឥដ្ឋ ឬគំនរដីស្អិតជាដើមទុកខាងក្នុងទ្វារ ឬចងរន្ទាទុក ដោយមិនអាចនឹងបិទ ( ទ្វារ ) បាន ក្នុងអន្តរាយមានសភាពបែបនោះ សូម្បីមិនបិទទ្វារ សិងក៏គួរ ។ បើមិនមានទ្វារ ជាការបានលេសពិត ។ បើសិងខាងលើ គួរលើករាំងននទ្បើងសឹមសិង ។ បើខាងលើរាំងននមានឈើ សម្រាប់រាំង គួររាំង សឹមសិង ។ កាលសិងក្នុងបន្ទប់ បិទទ្វារ ឬទ្វារយ៉មុខឯណានីមួយ ហើយសិងក៏គួរ ។

បើក្នុងកុដិតែមួយ គេធ្វើទ្វារ ២ សម្រាប់ប្រើប្រាស់ គួររក្សាទ្វារទាំងពីរ ។ បើក្នុងប្រាសាទ ៣ ជាន់ គួររក្សាទ្វារនោះឯង ។ បើភិក្ខុច្រើនអង្គត្រឡប់អំពីត្រាច់បិណ្ឌបាត ចូលទៅកាន់ប្រាសាទ ដូចជា លោហប្រាសាទជាដើម ដើម្បីសម្រាកពេលថ្ងៃ ព្រះសង្ឃត្ថេរគួរប្រាប់អ្នកយាមទ្វារថា ចូរជួយរក្សាទ្វារ ឬធ្វើទុកក្នុងចិត្តថា ការរក្សាទ្វារជាភារៈ របស់នាយទ្វារបាលនោះ ហើយគប្បីចូលទៅសិងចុះ ។ ភិក្ខុទាំងឡាយគួរធ្វើ យ៉ាងនោះដូចគ្នា

រហូតដល់ព្រះសង្ឃនវកៈ ។ បុគ្គលដែលចូលទៅមុន សូម្បីនឹងធ្វើទុកក្នុងចិត្ត យ៉ាងនេះថា ឈ្មោះថា ការរក្សាទ្វារជាភារៈរបស់អ្នកមកខាងក្រោយ ដូច្នេះ ក៏គួរ ។

បើភិក្ខុមិនធ្វើការប្រាប់ ឬការតាំងចិត្តទុក ហើយសិងខាងក្នុងបន្ទប់ដែល មិនបានបិទទ្វារ ឬខាងក្រៅបន្ទប់ ត្រូវអាបត្តិ ។ សូម្បីក្នុងវេលាសិងក្នុង បន្ទប់ ឬខាងក្រៅបន្ទប់ ធ្វើការតាំងចិត្តទុកថា ឈ្មោះថា ការរក្សាទ្វារក្នុង ទ្វារធំ ជាភារៈរបស់នាយទ្វារបាល ដូច្នេះហើយ សិងក៏គួរដូចគ្នា ។

បើភិក្ខុសិងត្រង់ផ្ទៃស្រឡះ ( ផ្ទៃរាបខាងលើ ) ក្នុងលោហប្រាសាទ ជាដើម គួរបិទទ្វារផងដែរ ។

ក្នុងរឿងបិទទ្វារសិងនេះ មានសេចក្ដីសន្និបដូច្នេះថា ការសម្រាកក្នុង ពេលថ្ងៃនេះ លោកពោលទុកក្នុងស្ថានទីមានរបៀង ឬព័ទ្ធដោយកំពែង ឬ របងឯណានីមួយ ។ ព្រោះដូច្នោះ ភិក្ខុអ្នកសិងក្នុងទីវាលក្ដី គល់ឈើក្ដី មណ្ឌបឯណានីមួយក្ដី ដែលមានរបៀង គួរបិទទ្វារជាមុន សឹមសិង ។ បើជា បរិវេណធំដែលជាទីប្រជុំរបស់ភូមិច្រើន ដូចជា លានមហាពោធិ៍ និងលាន លោហប្រាសាទ ក្នុងទីកន្លែងណា ទ្វារសូម្បីដែលគេបិទហើយ ក៏នៅបិទ ដដែល មនុស្សទាំងឡាយ កាលចូលតាមទ្វារមិនបាន ក៏ត្រូវឡើងតាមកំពែង ផ្ទោះទៅក្នុងទីកន្លែងនោះ មិនមានកិច្ចដែលនឹងត្រូវបិទទ្វារ ។

ភិក្ខុបើកទ្វារសិងរហូតទល់ភ្លឺ ក្រោកឡើងហើយក្នុងពេលអរុណរះ មិន ត្រូវអាបត្តិ ។ តែបើភ្ញាក់ហើយ សិងលក់ដដែលទៀត ត្រូវអាបត្តិ ឯភិក្ខុណា

កំណត់ទុកនោះឯងថា កាលអរុណរះហើយ នឹងក្រោកឡើង មិនបានបិទទ្វារ សិងរហូតដល់ភ្លឺ តែក្រោកឡើងមិនទាន់តាមកំណត់នោះឯង ភិក្ខុនោះប្រព្រឹត្ត ជាអាបត្តិនោះឯង ។ ចំណែកក្នុងអដ្ឋកថាមហាបច្ចរី លោកពោលទុកថា កាលសិងដោយអាការយ៉ាងនោះ មិនផុតអំពីអាបត្តិទុក្កដ ព្រោះមិនអើពើ ។

ចំណែកភិក្ខុណា រក្សា ( ព្យាបាល ) ភិក្ខុអាពាធជាដើម ឬដើរផ្លូវឆ្ងាយ មានរាងកាយល្ហិតល្ហៃពេញមួយថ្ងៃ អង្គុយលើគ្រែហើយលើកជើងមិនទាន់ផុតផែនដី ក៏សិងលក់ ព្រោះអំណាចការលក់ ( គ្របសង្កត់ ) ភិក្ខុនោះមិនត្រូវអាបត្តិ ។ បើលោកឈានចុះកាន់និទ្រាទាំងមិនដឹងខ្លួន លើកជើងឡើងលើគ្រែ ត្រូវអាបត្តិនោះឯង ។ បើអង្គុយផ្អែកដេកលក់ទៅ មិនត្រូវអាបត្តិ ។ម្យ៉ាងទៀត ភិក្ខុអង្គណា ដើរចង្រ្កមដោយតាំងចិត្តថា នឹងបន្ទោបង់ងងុយ ហើយដួល ប្រញាប់ក្រោកឡើងភ្លាម ភិក្ខុអង្គនោះ ក៏មិនត្រូវអាបត្តិ ។ ចំណែកភិក្ខុណាដួលហើយ ដេកនៅក្នុងទីនោះឯង មិនព្រមក្រោកឡើង ភិក្ខុនោះត្រូវអាបត្តិ ។

សួរថា បុគ្គលណាត្រូវអាបត្តិ បុគ្គលណាមិនត្រូវអាបត្តិ ឆ្លើយថា មហាបច្ចរីអដ្ឋកថា លោកពោលទុកថា បុគ្គលដែលសិងលក់ដោយផ្ទៀងទៅតែម្ខាងនោះឯង រមែងមិនត្រូវអាបត្តិ ចំណែកអ្នកលើកជើងផុតពីផែនដីហើយសិង ឬអ្នកដែលត្រូវយក្ខចូលសណ្ឋិត ជាអ្នកប្រាសចាកសញ្ញា ( បាត់សតិ ) ក៏ដោយ រមែងត្រូវអាបត្តិ ។

ក្នុងកុរុន្ទីអដ្ឋកថា លោកពោលទុកថា អ្នកដែលត្រូវចងឲ្យដេកប៉ុណ្ណោះ

មិនត្រូវអាបត្តិ ចំណែកក្នុងមហាអដ្ឋកថា ព្រះមហាបទុមត្ថេរពោលថា ភិក្ខុណាដើរចង្រ្កម ដួលសន្ធប់ ហើយដេកលក់ក្នុងទីនោះឯង អាបត្តិរមែងមិនប្រាកដដល់ភិក្ខុនោះ ព្រោះលោកមិនមានអំណាច តែអាចារ្យទាំងឡាយមិនបានពោលទុក ព្រោះដូច្នោះ ទើបត្រូវអាបត្តិនោះឯង ។ ចំណែកភិក្ខុពីរអង្គ គឺ ភិក្ខុយក្ខចូលសណ្ឋិត ១ ដែលត្រូវចងឲ្យដេក ១ រមែងមិនត្រូវអាបត្តិដោយពិត ។

# រឿង ភិក្ខុយល់សប្តិសេពមេថុនធម្ម

[ ៧១ ] ក្នុងរឿងភិក្ខុអ្នកស្រុកភារុកច្ឆៈ មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **អនាបត្តិ សុបិនន្តេន** សេចក្តីថា ឈ្មោះថា មិនត្រូវអាបត្តិ ព្រោះការយល់សប្តិដោយអាការយ៉ាងនេះ ព្រោះមិនមែនវិស័យ ហេតុដូច្នោះ ទើបព្រះឧបាលិត្ថេរវិនិច្ឆ័យរឿងនេះ សូម្បីព្រះដ៏មានព្រះភាគ ទ្រង់មិនជាប់វិនិច្ឆ័យដោយការកាន់យកតាមន័យ ។ សូម្បីព្រះដ៏មានព្រះភាគ កាលទ្រង់ស្តាប់ ( ព្រះឧបាលិត្ថេរវិនិច្ឆ័យនោះហើយ ) ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាលីពោលប្រពៃហើយ ឧបាលីពោលដោះស្រាយបញ្ហានេះ ដូចធ្វើស្ពានជើងទុកក្នុងទីមិនមានស្ពានជើង ដូចសម្តែងស្ពានជើងទុកក្នុងអាកាសដូច្នោះ ដូច្នេះហើយ ទើបទ្រង់តាំងព្រះថេរៈទុកក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុជាសាវ័ករបស់តថាគត ឧបាលីនេះឯង ជាកំពូលលើនៃអ្នកទ្រទ្រង់វិន័យ ។

[ ៧២-៧៤ ] រឿងទាំងឡាយ មានរឿងនាងសុបព្វា ( សុប្បវាសា ) ជាដើម បន្ទាប់ពីរឿងភិក្ខុអ្នកស្រុកភារុកច្ឆៈនេះទៅ មានអត្ថជាក់ច្បាស់ហើយ

នោះឯង ។

[ ៧៥-៧៦ ] ក្នុងរឿងទាំងឡាយ មានរឿងបង្ខំឲ្យភិក្ខុសេពមេថុនធម្ម ក្នុងភិក្ខុនីជាដើម មានវិនិច្ឆ័យដូច្នេះថា ព្រះបាទលិច្ឆវីកុមារទាំងនោះ ជាអ្នក ខ្វល់ខ្វាយក្នុងការលេង បានធ្វើយ៉ាងនោះ ព្រោះអនាចាររបស់ខ្លួន ។ តាំង អំពីកាលនោះមក ទើបការវិនាសបានកើតឡើងដល់ស្តេចលិច្ឆវីទាំងឡាយ ព្រោះទ្រង់ធ្វើហេតុយ៉ាងនោះ ។

[ ៧៧ ] ក្នុងរឿងភិក្ខុបួសវ័យចាស់ មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **ឧស្សុក្កំ អកាសិ** សេចក្តីថា ភិក្ខុចាស់នោះគិតថា នឹងសួរសុខទុក្ខកិរិយា ចាស់ ទើបទៅកាន់ផ្ទះ ព្រោះការអនុគ្រោះ ។ ខណៈនោះ នាងបានរៀប រាប់ដល់ប្រការដែលខ្លួន និងកូនៗ មិនមានទីពឹងឲ្យលោកស្តាប់ ដោយប្រការ ផ្សេងៗ កាលជ្រាបថា ភិក្ខុចាស់នោះ មិនមានការជាប់ជំពាក់ ទើបក្រោធ ពោលថា សូមលោកសឹកមក ទើបបានចាប់លោកដោយកម្លាំងរបស់ខ្លួន ។ ភិក្ខុចាស់បានថយក្រោយដើម្បីដោះខ្លួន ទើបបានដួលផ្ងារ ព្រោះជរាទុព្វលភាព ខណៈនោះ នាងបានធ្វើតាមចិត្តរបស់ខ្លួនហើយ ។ តែភិក្ខុអង្គនោះលោកជា ព្រះអនាគា លះកាមរាគៈដាច់ជាសមុច្ឆេទហើយ ព្រោះដូច្នោះ ទើបលោកមិន ត្រេកអរ ដូច្នេះឯង ។

[ ៧៨ ] រឿងកូនម្រឹគមានអត្ថជាក់ច្បាស់ហើយដូច្នេះឯង ។

បឋមបារាជិកវណ្ណនា

នៃវិនយវណ្ណនា ឈ្មោះ សមន្តបាសាទិកា ចប់

ក្នុងសេចក្ដីដែលអដ្ឋកថាឈ្មោះសមន្តបាសាទិកា ក្នុងពាក្យថា ក្នុងវិនយសំវណ្ណនា ឈ្មោះសមន្តបាសាទិកានោះ ញ៉ាំងឲ្យកើតសេចក្ដីជ្រះថ្លាដោយជុំវិញ មានពាក្យអធិប្បាយដូចតទៅនេះថា បើវិញ្ញូជនទាំងឡាយសាកសួរហើយ តាមលំដាប់នៃអាចារ្យ ដោយការសម្ដែងប្រភេទនៃនិទាន និងវត្ថុ ព្រោះការវៀរលទ្ធិដទៃ ដោយសេចក្ដីបរិសុទ្ធនៃលទ្ធិរបស់ខ្លួន ដោយការជម្រះព្យញ្ជនៈឲ្យរៀបរយ ដោយអត្ថចំពោះបទ ដោយលំដាប់នៃបាលី និងយោជនារបស់បាលី ដោយការវិនិច្ឆ័យសិក្ខាបទ និងដោយការបង្ហាញសេចក្ដីផ្សេងគ្នានៃវិន័យក្នុងវិភង្គ ពាក្យណាមួយដែលមិននាំឲ្យកើតសេចក្ដីជ្រះថ្លារមែងមិនប្រាកដក្នុងសមន្តបាសាទិកានេះ ព្រោះហេតុនោះ វិនយ-វណ្ណនាដែលព្រះលោកនាថ ទ្រង់អនុគ្រោះលោក ឈ្លាសក្នុងការទូន្មានវេនេយ្យសត្វ បានត្រាស់ទុកនេះ ទើបប្រព្រឹត្តទៅ ដោយឈ្មោះថា សមន្តបាសាទិកា ដូច្នេះ ។

# ក្បាលទី ១
# វិនយបិដក បាលីប្រែ - ១
## សន្ទឹកចន្ទុលប្រាប់មាតិកា


មាតិកា លេខទំព័រ

### វិនយបិដក

វេរញ្ជកណ្ឌវណ្ណនា ...... ...... ...... ...... ...... ...... ...... ...... .... ៣

### អដ្ឋកថា

អារម្ភកថា ...... ...... ...... ...... ...... ...... ...... ...... .... ២៩
ពាហិរនិទាន ...... ...... ...... ...... ...... ...... ...... ...... ..... ៣៣
ទុតិយសង្គាយនា ...... ...... ...... ...... ...... ...... ...... ...... ...... ៨១
តតិយសង្គាយនា ...... ...... ...... ...... ...... ...... ...... ...... ...... ៨៩
រឿងអសោកមហារាជ ...... ...... ...... ...... ...... ...... ...... ...... ...... ៩៥
ចតុត្ថសង្គាយនា ...... ...... ...... ...... ...... ...... ...... ...... ...... ១៩១
វេរញ្ជកណ្ឌវណ្ណនា ...... ...... ...... ...... ...... ...... ...... ...... ...... ១៩៧
ពុទ្ធគុណកថា ...... ...... ...... ...... ...... ...... ...... ...... ...... ២១១
បឋមជ្ឈានកថា ...... ...... ...... ...... ...... ...... ...... ...... ...... ២៨៣
ទុតិយជ្ឈានកថា ...... ...... ...... ...... ...... ...... ...... ...... ...... ២៩៨
តតិយជ្ឈានកថា ...... ...... ...... ...... ...... ...... ...... ...... ...... ៣០៥
ចតុត្ថជ្ឈានកថា ...... ...... ...... ...... ...... ...... ...... ...... ...... ៣១៣
បុព្វេនិវាសញ្ញាណកថា ... ...... ...... ...... ...... ...... ...... ...... ៣២១
អធិប្បាយអំពីកប្ប ...... ...... ...... ...... ...... ...... ...... ...... ...... ៣២៨
ទិព្វចក្ខុកថា ...... ...... ...... ...... ...... ...... ...... ...... ...... ៣៣៨
អាសវក្ខយញ្ញាណកថា ... ...... ...... ...... ...... ...... ...... ...... ៣៥២

មហាគោបាលសីហនាទកថា ...... ...... ...... ...... ...... ...... ...... ៣៨៨
ប្រស្នារបស់ព្រះសារីបុត្រ ........ ...... ...... ...... ...... ...... ៣៩៤

## វិនយបិដក

បារាជិកកណ្ឌសិក្ខាបទទី ១ .. ...... ...... ...... ...... ...... ...... ៤៣៣

## អដ្ឋកថា

មេថុនធម្មសិក្ខាបទវណ្ណនា ...... ...... ..... ...... ...... ...... ...... .... ៥១៤
ហេតុដែលឲ្យស្ត្រីតាំងគភ៌មាន ៧ យ៉ាង ...... ...... ...... ...... ....... ៥៤៥
ប្រយោជន៍ ១០ យ៉ាង នៃការបញ្ញត្តសិក្ខាបទ ...... ...... ...... .... ៥៧១
អនុប្បញ្ញត្តិទី ១ នៃបឋមបារាជិក ...... ...... ...... ...... ...... ៥៧៩
អនុប្បញ្ញត្តិទី ២ នៃបឋមបារាជិក ...... ...... ...... ...... ...... ៥៨៤
សិក្ខាបទវិភង្គនៃបឋមបារាជិក ...... ........ ...... ...... ...... ....... ៥៨៩
វិនយធរប្រកបដោយលក្ខណៈ ៣ យ៉ាង ...... ...... ...... ...... ...... ៥៩៧
វិធីវិនិច្ឆ័យអធិករណ៍ ...... ...... ...... ...... ...... ...... ...... ...... ...... ៦០២
ឧបសម្បទា ៨ យ៉ាង ..... ...... ...... ...... ...... ...... ...... ...... ៦១២
អធិប្បាយ វិធីលាសិក្ខា ...... ...... ...... ...... ...... ...... ...... ...... ៦២២
អនុប្បញ្ញត្តិវារៈ កំណត់សត្វដែលជាវត្ថុនៃបារាជិកជាដើម ...... ......... ៦៥៨
បទភាជនីយនៃបឋមបារាជិក ...... ...... ...... ...... ...... ......... ......... ៦៦៣
ទ្វារមគ្គ ៣០ ...... ...... ...... ...... ...... ...... ...... ...... ...... ៦៦៤
អធិប្បាយ ចតុក្កៈ ២៦៩ ដ៏សេស ...... ...... ...... ...... ...... ......... ៦៦៨
វិនីតវត្ថុក្នុងបឋមបារាជិក ...... ...... ...... ...... ...... ...... .. ៦៩០
ដាច់ប្រគេនដោយហេតុ ៧ យ៉ាង ... ...... ...... ...... ...... ...... .... ៦៩៩